# ប្រជុំនិទានជាតក

## លំនាំរឿងទេសនា



ឧបត្ថម្ភការសិក្សាធម្មវិន័យជាដើម

ផ្សាយចេញពីបណ្ណាគារត្រៃរតន៍

ព.ស ២៥៤៦-គ.ស ២០០២

រក្សាសិទ្ធិគ្រប់យ៉ាង

# ប្រជុំនិទានជាតក

សិទ្ធត្ថបណ្ឌិត ស្វង ស៊ីង

រៀបរៀងជាមួយ

ព្រះមហា សំ សុខ សាស្ត្រាចារ្យសាលាបាលីវត្តលង្កា

( បោះពុម្ពលើកទី២ )

ព.ស ២៥០៥

គ.ស ១៩៦២

**ចម្លងដោយ**

លេខ ១៣៦Eo វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥៤៦-គ.ស ២០០២

អំណោយអ្នករបស់ខ្ញុំ

រ៉ាប៊ី ឃ្លូន ឧបសម្ព បុត្រីតា.

11/21/2010.

+ ស្រី !

Digital Conversion by Sokha Hy

# អានក្យារម្ភបទ

********

ការរៀបរៀងសៀវភៅនេះ មានបំណងពីរយ៉ាងគឺ :

១. ចង់បើកបញ្ចេញរឿងរ៉ាវ ដែលកប់នៅក្នុងគម្ពីរផ្សេងៗ ក្រៅពីគម្ពីរធម្មបទ ព្រោះរឿងរ៉ាវទាំងនោះចេះតែកប់លិចបាត់ទៅៗ មិនលេចចេញទៅបង្ហាញមុខដល់ពុទ្ធបរិស័ទភាគច្រើនឡើយ ។

២. ដើម្បីឱ្យងាយស្រួលដល់ពុទ្ធបរិស័ទ អ្នកត្រូវការនិយាយថ្លែងសំដែងនូវបុគ្គលាធិដ្ឋានធម៌នឹងជាឧត្តមគតិក្នុងផ្លូវលោកនឹងផ្លូវធម៌ ។

សៀវភៅនេះមិនកំណត់ថាចប់ត្រឹមភាគណានោះទេ កំណត់ចប់ត្រឹមអស់រឿងដែលខ្ញុំបានប្រទះឃើញ. ខ្ញុំរៀបរៀងកំណត់៥១រឿង ក្នុង១ភាគឬក៏លើសខ្វះខ្លះតាមរឿងវែងខ្លី ។

ឯរឿងដែលត្រូវយកមករៀបរៀងនោះ ជានិទានខ្លះជាតកខ្លះ សុទ្ធតែជារឿងដែលមានពិតប្រាកដក្នុងគម្ពីរ. ទើបសន្មតសៀវភៅនេះថា "ប្រជុំនិទានជាតក" ។

លុះរៀបរៀងចប់ហើយ ជូនថៅកែ **ឆោ-ឃ្លួត** ឱ្យចាត់ការបោះពុម្ពផ្សាយតាមសេចក្ដីត្រូវការ ។

សិទ្ធត្ថបណ្ឌិត **សុខ-ស៊ុម**

# បញ្ជីរឿង

**ឈ្មោះរឿង** **ទំព័រ**


១- ពក្កបណ្ឌិត ..................................... ១

២- ព្រះបាទមន្ធាតុ ..................................... ៤

៣- នាងថូនទាសី ..................................... ៩

៤- សត្វបាង្សក្បាលពីរ ..................................... ១៤

៥- ទុគ្គតធីតា ..................................... ១៨

៦- នាងពុទ្ធេណី ..................................... ២០

៧- គុត្តិលមាណព ..................................... ២៣

៨- មាតុឃាតក ..................................... ២៩

៩- មហាល្ហកចណ្ឌាលី..................................... ៣៣

១០- សុជាតកុមារ ..................................... ៣៥

១១- នាងកេសការី ..................................... ៣៩

១២- កែវមរកត ..................................... ៤១

១៣- បល្ល័ង្កអណ្តែត ..................................... ៤៥

១៤- សសបណ្ឌិត ..................................... ៤៨

១៥- នាងគព្ភិនី ..................................... ៥២

១៦- បញ្ចបក្ខី ..................................... ៥៤

១៧- គវម្បតិមាណព ..................................... ៥៨

១៨- យក្ខិនីមុខសេះ ..................................... ៦១

១៩- រុក្ខទេវតា ........................................................ ៦៤
២០- នាងសេសវតី ........................................................ ៦៧
២១- ទិសាបាមោក្ខព្រាហ្មណ៍ ........................................................ ៧១
២២- នាងលតា ........................................................ ៧៣
២៣- ឥល្លិសសេដ្ឋី ........................................................ ៧៦
២៤- អញ្ញតរឧបាសិកា ........................................................ ៨០
២៥- យមលោកនិងទេវលោក ........................................................ ៨១
២៦- នាងវជ្ជមាលា ........................................................ ៨៤
២៧- ថ្មើរព្រៃឈ្មោះសុរះ ........................................................ ៨៧
២៨- នាងសុភទ្រា ........................................................ ៩០
២៩- ចណ្ឌាលបណ្ឌិត ........................................................ ៩២
៣០- នន្ទិយឧបាសក ........................................................ ៩៥
៣១- មារុត្តព្រាហ្មណ៍ ........................................................ ៩៩
៣២- នហាបិតបុត្ត ........................................................ ១០១
៣៣- រាជគហទារិកា ........................................................ ១០៣
៣៤- យក្ខឈ្មោះនន្ទិ ........................................................ ១០៥
៣៥- សាវត្ថីធីតា ........................................................ ១១០
៣៦- ចម្មសាដកបរិព្វាជក........................................................ ១១២
៣៧- បុណ្ណសេដ្ឋី ........................................................ ១១៣
៣៨- វនបាលបុត្រ ........................................................ ១១៧

៣៩- នាគទេវបុត្រ ........................................ ១១៩
៤០- ទុដ្ឋកុមារ ........................................ ១២១
៤១- ក្អែកពោធិសត្វ ........................................ ១២២
៤២- ខ្មោចយក្ខ ........................................ ១២៥
៤៣- ប្រេតក្លាយជាទេវតា ........................................ ១២៦
៤៤- កិសវច្ឆតាបស ........................................ ១២៩
៤៥- កដ្ឋហារកៈ ........................................ ១៣២
៤៦- នាងវិសាខា ........................................ ១៣៥
៤៧- នាងបទុមវតី ........................................ ១៤៣
៤៨- ឧបសាឡកព្រាហ្មណ៍ ........................................ ១៤៥
៤៩-ព្រះបាទមឃទេវរាជ ........................................ ១៤៨
៥០- សោតាបន្នឧបាសក ........................................ ១៥៣
៥១- កសកព្រាហ្មណ៍ ........................................ ១៥៤
៥២- អម្ពតាបស ........................................ ១៦០
៥៣- ព្រះឥន្ទនិម្មិតជាយក្ខ ........................................ ១៦២
៥៤- កដាហកមាណព ........................................ ១៦៦
៥៥- សេកសោមបណ្ឌិត ........................................ ១៦៨
៥៦- ឆ្កែខាំពពៃ ........................................ ១៧២
៥៧- ព្រាហ្មណ៍ចាស់ ........................................ ១៧៦
៥៨- អាយលម្អាយចាប់ពស់ ........................................ ១៧៩

៥៩- នាងអសិតាភូ ........................................................ ១៨១
៦០- ខ្មោចយក្ខនិងក្មេងតូច ................................................ ១៨៣
៦១- សិរីលក្ខណព្រាហ្មណ៍ ................................................ ១៨៦
៦២- សីហៈនិងជ្រូក ........................................................ ១៨៨
៦៣- នាងកល្យាណី ........................................................ ១៩០
៦៤- សោមទត្តព្រាហ្មណ៍ ................................................ ២០៥
៦៥- នាងកាញ្ចនទេវី ...................................................... ២០៨
៦៦- នាងបង្គជាទេវី ...................................................... ២១១
៦៧- វិសមលោមរាជកុមារ ................................................ ២១៧
៦៨- ចិត្តគហបតី ........................................................... ២២១
៦៩- ឈើទ្រទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ ........................................ ២២៣
៧០- ឧត្តរសាមណេរ........................................................ ២២៦
៧១- ព្រាហ្មណ៍សម្លាប់កូនធ្វើទាន ........................................ ២៣០
៧២- បុរសលិចសំពៅ ...................................................... ២៣២
៧៣- ខ្លាធំនិងសេក ......................................................... ២៣៤
៧៤- ព្រះបាទអភង្គិរាជ .................................................... ២៣៧
៧៥- បុរសចាញ់បោកចោរ ................................................ ២៤២
៧៦- សរណមាតា ........................................................... ២៤៥
៧៧- នាងវេស្សាមិត្ត........................................................ ២៤៩
៧៨- ព្រានព្រៃ ............................................................... ២៥១

៧៩- សច្ចកនិគ្រិន្ថ ........................................ ៤៥៤
៨០- នាងវេទេហិកា ........................................ ២៥៦
៨១- សេនបណ្ឌិត ........................................ ២៥៨
៨២- ស្តេចចណ្ឌប្បជ្ជោត ........................................ ២៦៣
៨៣- តក្កបណ្ឌិត ........................................ ២៦៥
៨៤- សេដ្ឋីបុត្រ ........................................ ២៦៨
៨៥- ភិក្ខុកូនសេដ្ឋី ........................................ ២៧០
៨៦- សត្ថុទទា ........................................ ២៧៣
៨៧- ព្រាហ្មណ៍សម្លាប់ពពែ ........................................ ២៧៤
៨៨- សីលវិមំសកព្រាហ្មណ៍ ........................................ ២៧៦
៨៩- បាដលិបុត្តព្រាហ្មណ៍ ........................................ ២៧៧
៩០- ព្រះបាទឃតៈ ........................................ ២៧៨
៩១- ទហរភិក្ខុ ........................................ ២៨១
៩២- នន្ទយក្ខ ........................................ ២៨២
៩៣- ពស់ថ្លាន់ ........................................ ២៨៥
៩៤- កិន្នរ ........................................ ២៨៨
៩៥- សេដ្ឋីបុត្ត ........................................ ២៩២
៩៦- មិត្តវិន្ទុក ........................................ ២៩៤
៩៧- សាវត្ថីសេដ្ឋីបុត្ត ........................................ ២៩៧
៩៨- ចចកឈ្មោះបូតិមំសៈ ........................................ ៣០០

៩៩- ស្តេចសេក ........................................ ៣០២
១០០- អតិចារិណិតី ........................................ ៣០៦
១០១- ពាណិជបុរស ........................................ ៣០៨
១០២- ពារាណសីសេដ្ឋិបុត្រ ........................................ ៣១១
១០៣- គហបតីប្រេត ........................................ ៣១៣
១០៤- មណិកណ្ឋនាគរាជ ........................................ ៣១៧
១០៥- ស្វាទេវទត្ត ........................................ ៣២១
១០៦- នាងវិមានប្រេត ........................................ ៣២៤
១០៧- និស្សិតឈ្មោះគំរក់ ........................................ ៣២៩
១០៨- ស្តេចលិច្ឆវី និងភូមទេវតា ........................................ ៣៣៣
១០៩- ជ្រូកឈ្មោះតច្ឆកៈ ........................................ ៣៤១
១១០- ស្រីពេស្យាកើតជាប្រេត ........................................ ៣៤៧
១១១- អឡូមាសករាជ ........................................ ៣៥០
១១២- បុរសកាឡណ្ឌី ........................................ ៣៥៣
១១៣- កុមារកូនស្រីផ្កាមាស ........................................ ៣៥៧
១១៤- រឿងដំរីស្ដរ និងមេចាប ........................................ ៣៦០
១១៥- ប្រេតប្ដីប្រពន្ធ ........................................ ៣៦២
១១៦- នាងឧត្តរា ........................................ ៣៦៦
១១៧- ភិមសេនបុរស ........................................ ៣៧៣
១១៨- មិតលុទ្ទកប្រេត ........................................ ៣៧៩

១១៩- ព្រហ្មទត្តរាជកុមារ .......................................................... ៣៨១

១២០- ប្រេតស៊ីសាច់ឯង .......................................................... ៣៨៧

១២១- ឧទិច្ចតាបស .......................................................... ៣៨៩

១២២- ពារាណសីសេដ្ឋី .......................................................... ៣៩៧

១២៣- មហាល្ហួកឧបាសិកា .......................................................... ៤០០

១២៤- ចូឡកសេដ្ឋី .......................................................... ៤០៦

១២៥- សីលវរាជកុមារ .......................................................... ៤០៩

១២៦- ស្តេចដើរ .......................................................... ៤២១

១២៧- អ្នកប្រមឹក .......................................................... ៤២៤

១២៨- ភិក្ខុហាល់ថ្ងៃ .......................................................... ៤២៧

១២៩- ព្រះបាទបទុមរាជ .......................................................... ៤៣០

១៣០- ភិក្ខុជាញាតិ នឹងប្រេត .......................................................... ៤៣៨

១៣១- ព្រះបាទអជាតសត្រូវ .......................................................... ៤៤២

១៣២- ព្រានសន្ធច .......................................................... ៤៥៧

១៣៣- ជាងកែវមណី .......................................................... ៤៥៩

១៣៤- សត្វមៀម .......................................................... ៤៦១

១៣៥- បុត្តខាទករាជ .......................................................... ៤៦៣

១៣៦- សត្វខ្លែងនិងអ្នកប្រមាញ់ .......................................................... ៤៦៦

១៣៧- តាបសដាច់ឈាន .......................................................... ៤៧០

១៣៨- ស្វាពោធិសាត់ .......................................................... ៤៧៦

១៣៩- យក្ខិនីស៊ីមនុស្ស ........................................ ៤៧៩
១៤០- ប្រេីស និងព្រានព្រៃ ........................................ ៤៨៥
១៤១- ខន្តិវាទិតាបស ........................................ ៤៩០
១៤២- សច្ចវាទិនី ........................................ ៤៩៤
១៤៣- សង្ខព្រាហ្មណ៍ ........................................ ៤៩៦
១៤៤- ឆ្កែខាំប្រេត ........................................ ៤៩៨
១៤៥- សមុទ្ទទេវតា ........................................ ៥០៧
១៤៦- ប្រេតស៊ីខ្ទុះឈាម ........................................ ៥០៩
១៤៧- ប្រេត ៤នាក់ ........................................ ៥១៣
១៤៨- មហាកប្បិន ........................................ ៥១៥
១៤៩- ទុគតបុរស ........................................ ៥២៧
១៥០- ស្រីមានគូកំណាន់ ........................................ ៥៣៩
១៥១- កញ្ញាកុណ្ឌលកេសី ........................................ ៥៤១
១៥២- ព្រះបាទនន្ទរាជ ........................................ ៥៤៧
១៥៣- ឧបាសកតិស្សៈ ........................................ ៥៥១
១៥៤- សញ្ជីវមាណព ........................................ ៥៥៤
១៥៥- ព្រាហ្មណ៍ភារទ្វាជៈ ........................................ ៥៥៧
១៥៦- បុរសខ្វិន ........................................ ៥៥៩
១៥៧- ធម្មបាលកុមារ ........................................ ៥៦២
១៥៨- អសោកមហារាជ ........................................ ៥៦៨

១៥៩- អសោកនិងអគ្គមហេសី ............................................ ៥៧០
១៦០- ពាណិជលង់ទឹកសមុទ្រ ............................................ ៥៧៤
១៦១- បិប្ផលិមាណព ............................................ ៥៧៦
១៦២- ស្តេចចចកឈ្មោះសព្វទាឋៈ ............................................ ៥៨០
១៦៣- ចក្កនឧបាសក ............................................ ៥៨៣
១៦៤- អ្នកកំណាញ់ ............................................ ៥៨៥
១៦៥- កុហកតាបស ............................................ ៥៩៤
១៦៦- មុសាមាទិព្រាហ្មណ៍ ............................................ ៥៩៧
១៦៧- សាធិនរាជ ............................................ ៦០១
១៦៨- គោបាលមាតាទេវី ............................................ ៦០៣
១៦៩- នាងរោហិណី ............................................ ៦០៥
១៧០- អ្នកផឹកសុរា ............................................ ៦១១
១៧១- អយុវឌ្ឍនកុមារ ............................................ ៦១៤
១៧២- នាងបតិបូជិកា ............................................ ៦១៧
១៧៣- ឧបាសកកសាងមេបុណ្យ ............................................ ៦២០
១៧៤- មល្លិកាទេវី ............................................ ៦២២
១៧៥- អង្គុលីមាលចោរ ............................................ ៦២៤
១៧៦- ករម្បិយអចេល ............................................ ៦៣០
១៧៧- ស្រីកំសត់ ............................................ ៦៣៣
១៧៨- ព្រះបាទវិបុលរាជ ............................................ ៦៤១

១៧៩- អភ័យចោរ ........................................ ៦៥០
១៨០- ទមិឡប្អូនរាជ្យ ........................................ ៦៥២
១៨១- ជាងប៉ាក់ផុល ........................................ ៦៥៨
១៨២- មហាកាញ្ចនកុមារ ........................................ ៦៦៣
១៨៣- អរិយព្រានមានសីលជាខ្លឹម ........................................ ៦៧៧
១៨៤- ឥសីមាត់ទិព្វ ........................................ ៦៩១
១៨៥- នង្គលកូដត្លែរ ........................................ ៦៩៩
១៨៦- ប្រេតមាត់ស្អុយ ........................................ ៧០១
១៨៧- ជោតិកសេដ្ឋី ........................................ ៧០៦
១៨៨- ស្រ្តីពីរនាក់ចងពៀរនឹងគ្នា ........................................ ៧២៨
១៨៩- ព្រានប្រេត ........................................ ៧២៩
១៩០- ឧបាសកត្រចៀកខ្ទូរ ........................................ ៧៣៤
១៩១- ដីរនិងទន្សាយ ........................................ ៧៤៣
១៩២- ជដិលសេដ្ឋី ........................................ ៧៤៦
១៩៣- ក្អែកញីឈ្មោលនិងពស់ ........................................ ៧៥៦
១៩៤- បុរសក្លាយភេទជាស្រី ........................................ ៧៥៨
១៩៥- ហង្សនិងក្អែក ........................................ ៧៦១
១៩៦- មេណ្ឌកសេដ្ឋី ........................................ ៧៦២
១៩៧- ប្រេតស៊ីកូនម្តង ៧ ........................................ ៧៧៥
១៩៨- សាមណេរ ៤រូបជាព្រះអរហន្ត ........................................ ៧៧៨

១៩៩- យមកប្បាដិហារិយ៍ .................................... ៧៨៣

២០០- ទីឃាវុកុមារ .................................... ៨០០

២០១- ប្រេតញីស៊ីកូនម្តង ៥ .................................... ៨០១

២០២- អគ្គិទត្តបុរោហិត .................................... ៨០៦

២០៣- វុថកាប្រេត .................................... ៨១៤

២០៤- សុជាតមាណព .................................... ៨១៧

២០៥- ខេមកសេដ្ឋីបុត្ត .................................... ៨២១

២០៦- វង្គីសព្រាហ្មណ៍ .................................... ៨២៤

២០៧- នាងចិញ្ចមាណវិកា .................................... ៨២៧

២០៨- អម្ពដ្ឋមាណព .................................... ៨៣៣

២០៩- នាងចូឡសុភទ្ទា .................................... ៨៤២

២១០- ភរិយាគោបាល និងសាហាយពីរនាក់ .................................... ៨៥០

២១១- នាងអម្ពបាលី .................................... ៨៥១

២១២- សក្កទេវរាជ .................................... ៨៥៥

២១៣- ឧបនន្ទសក្យបុត្តត្ថេរ .................................... ៨៥៩

២១៤- បញ្ចសិខទេវបុត្រ .................................... ៨៦៣

២១៥- អនិត្ថិគន្ធកុមារ .................................... ៨៦៨

២១៦- ព្រាហ្មណ៍កុហក .................................... ៨៧៣

២១៧- ស្ទូនឆ្មាំងឈ្មោះឃដិការ .................................... ៨៧៧

២១៨- ដំបូកហុយផ្សែង .................................... ៨៨៨

២១៩- អហិប្រេត ............................................................ ៨៩២
២២០- រដ្ឋបាលកុលបុត្រ ........................................................ ៨៩៥
២២១- ប្រេតញីឈ្មោះឧត្តរមាតា ................................................ ៩០៤
២២២- ទេវិលតាបស ............................................................ ៩០៦
២២៣- វត្តលិមាណ ............................................................ ៩១២
២២៤- ធម្មទិន្នារាជទេវី ........................................................ ៩១៨
២២៥- ពាកុលកុមារ ............................................................ ៩២៧
២២៦- អបុត្តកសេដ្ឋី ............................................................ ៩៣១
២២៧- អនុរុទ្ធសាក្យរាជកុមារ ................................................ ៩៣៥
២២៨- យក្សឈ្មោះកោធភក្ស .................................................. ៩៤៣
២២៩- ចចកពណ៌ខៀវ ............................................................ ៩៤៦
២៣០- ស្តេចលិច្ឆវីនិងប្រេត .................................................. ៩៤៩
២៣១- អាឡវីរាជកុមារ ........................................................ ៩៦០
២៣២- ព្រះនាងអសន្ធមិត្តា .................................................... ៩៨៣
២៣៣- តួឯករបាំឈ្មោះតាលបុត្ត .............................................. ៩៨៩
២៣៤- រាធព្រាហ្មណ៍ ............................................................ ៩៩៣
២៣៥- ចុល្លបន្ថកភិក្ខុ .......................................................... ៩៩៦
២៣៦- នកុលបិតា ................................................................ ១០០៧
២៣៧- អញ្ញតរភិក្ខុ .............................................................. ១០០៩
២៣៨- កណ្ឌកទេវបុត្រ .......................................................... ១០១៤

២៣៩- សានុវាសិប្រេត ........................................ ១០១៨
២៤០- ព្រះអង្គម្ចាស់រីតសោក ........................................ ១០២១
២៤១- សុភមាណព ........................................ ១០៣៨
២៤២- ព្រះអង្គម្ចាស់ក្សត្រីសុប្បវាសា ........................................ ១០៤២
២៤៣- ទេពធីតា ២៥ រូប ........................................ ១០៤៩
២៤៤- ចៅអធិការវត្តឈ្មោះ ធម្មិកៈ ........................................ ១០៥៣
២៤៥- ព្រះកុមារកស្សប ........................................ ១០៦០
២៤៦- ព្រះបាទមធុររាជ ........................................ ១០៦៣
២៤៧- បុក្កសាតិកុលបុត្រ ........................................ ១០៦៨
២៤៨- កសិករឈ្មោះចុល្លកាឡ ........................................ ១០៧៣
២៤៩- មល្លិកាបញ្ហា ........................................ ១០៧៩
២៥០- ព្រះអនុរុទ្ធនិងសុមនសាមណេរ ........................................ ១០៨៤
២៥១- ធម្មកថិកឈ្មោះកបិលភិក្ខុ ........................................ ១០៩៣
២៥២- ក្អែកប្រពន្ធនាយសំពៅនិងក្មេងឃ្វាលគោ ........................................ ១០៩៧
២៥៣- ឯកបុត្តគហបតី ........................................ ១១០២
២៥៤- កុនាលរាជកុមារ ........................................ ១១១០
២៥៥- កុទ្ទាលកបណ្ឌិត ........................................ ១១២៨
២៥៦- ចចកល្មោភ ........................................ ១១៣២
២៥៧- ព្រះបាទបិង្គលកៈនិងប្រេត ........................................ ១១៣៤
២៥៨- ភិក្ខុធុតង្គ ៧ អង្គ ........................................ ១១៤០

២៥៩- ព្រះសមុទ្ទត្ថេរ ........................................................... ១១៤៣

២៦០- ត្មាតខ្វាក់ និងឆ្មា ........................................................... ១១៥៣

២៦១- ព្រះបាទអស្សកៈ ........................................................... ១១៥៧

២៦២- វិភាគបទ ........................................................... ១១៦៥

# ប្រជុំនិទានជាតក

- ដើម្បីឱ្យងាយស្រួល ដល់សេចក្តីត្រូវការរបស់លោកអ្នកអានទាំងឡាយ ខ្ញុំសូមនាំយកឈ្មោះរឿងទាំងអស់ ដែលមាននៅក្នុងសៀវភៅប្រជុំនិទានជាតក ទាំង៧ភាគ ចំនួន ២៦១ រឿង មករៀបរៀងតាមលំដាប់ភាគដូចតទៅនេះ ។

| | | | |
|---|---|---|---|
| ភាគ ទី ១ | មាន ៥១ រឿង | ទំព័រ ទី ១ | ដល់ ១៥៤ |
| ភាគី ទី ២ | មាន ៥១ រឿង | ទំព័រ ទី ១៦០ | ដល់ ៣១១ |
| ភាគី ទី ៣ | មាន ៤៤ រឿង | ទំព័រ ទី ៣១៣ | ដល់ ៥០៩ |
| ភាគី ទី ៤ | មាន ៣៦ រឿង | ទំព័រ ទី ៥១៣ | ដល់ ៦៦៣ |
| ភាគី ទី ៥ | មាន ២៥ រឿង | ទំព័រ ទី ៦៧៧ | ដល់ ៨២៧ |
| ភាគី ទី ៦ | មាន ២៩ រឿង | ទំព័ ទី ៨៣៣ | ដល់ ១០០៧ |
| ភាគី ទី ៧ | មាន ២៥ រឿង | ទំព័ ទី ១០០៩ | ដល់ ១១៥៧ |

ឈឈឈ

# ១~ រឿងពត្តបណ្ឌិត

( ចាក ឈោ ផា )

( អ្នកប្រាជ្ញគួរធ្វើល្ងង់ក្នុងកាលខ្លះ ដើម្បីសន្តិភាព )

ក្នុងអវសរដែលកន្លងទៅហើយ មានកូនបក្សីបីគឺ កូនក្អែក, កូនសាលិកា, កូនកុក នៅអាស្រ័យក្នុងសំបុកលើមែកព្រឹក្សាជិត ៗ គ្នា ។ សម័យនោះមានថ្មើរព្រៃបីនាក់, នៅក្នុងដែនកម្ពោជៈ បាននាំគ្នាចរចូលទៅក្នុងព្រៃដើម្បីចាប់ម្រឹគ ។ ថ្មើរព្រៃទាំងបីនាក់ ខំស្វែងរកម្រឹគអស់មួយថ្ងៃ ពុំបានជួបប្រទះសោះ ដល់ពេលល្ងាចជិតត្រឡប់មកផ្ទះវិញ បានឃើញកូនបក្សីបីដែលនៅក្នុងសំបុកជិតៗ គ្នានោះ ក៏ចាប់យកមួយ ៗ ម្នាក់មកចិញ្ចឹម ។

ឯថ្មើរព្រៃទាំងបីរូបនោះ មានសេចក្ដីស្រឡាញ់ចំពោះកូនបក្សីទាំងបីហាក់ដូចជាកូនបង្កើត, បានគិតគ្នាថា យើងខំចិញ្ចឹមរក្សាបង្រៀនឱ្យមានបែបបទល្អហើយ យកទៅថ្វាយស្ដេចជាគ្រឿងបណ្ណាការ ។ ថ្មើរព្រៃម្នាក់ដែលចិញ្ចឹមកូនក្អែកខំបង្ហាត់ឱ្យចេះពង់ចេះរាំ ចេះក្រាបសំពះ, ឯក្អែកជាសត្វមានគំនិតខ្ចី ក៏ចេះតែខំធ្វើតាមដរាបដល់ចេះពង់ ចេះរាំ ចេះក្រាបសំពះដូចបំណងរបស់ម្ចាស់ ។ ថ្មើរព្រៃម្នាក់ទៀតដែលចិញ្ចឹមកូនសាលិកា ក៏ខំបង្ហាត់បង្ហាញឱ្យរៀននិយាយភាសាមនុស្ស, សាលិកាជាសត្វមានគំនិតខ្ចី

ខំប្រឹងនិយាយតាមដរាបដល់ចេះនិយាយជាមួយនឹងមនុស្សបាន ។ ឯចៅ្ររព្រៃម្នាក់ទៀតដែលចិញ្ចឹមកូនកុក ក៏ខំបង្ហាត់បង្រៀនកុកនោះតាមបំណងរបស់ខ្លួន ប៉ុន្តែកុកជាបណ្ឌិតមានគំនិតវែង បានគិតថាអញមិនគួរធ្វើជាអ្នកចេះរាំ ចេះនិយាយ ចេះក្រាបសំពះ តាមឱវាទរបស់ចៅ្ររព្រៃទុច្ចរិតនេះទេ បើអញធ្វើជាអ្នកចេះដឹងមុខតែចៅ្ររព្រៃនេះដាក់ក្នុងទ្រុងដរាបដល់អស់ជីវិត, លុះគិតដូច្នេះហើយ ក៏មិនអើពើនឹងឱវាទរបស់ចៅ្ររព្រៃជាម្ចាស់ឡើយ បើគេបង្ខំខ្លាំងគ្រាន់តែស្រែកក្រក ១ ប៉ុណ្ណោះ ។

ថ្ងៃមួយចៅ្ររព្រៃទាំងនោះ បានយកកូនបក្សីទាំងពីរទៅថ្វាយស្តេច, ព្រះរាជាបានទតឃើញកូនបក្សីនោះហើយ ទ្រង់មានព្រះតម្រាស់ថា ម្នាលព្រានកូនក្អែកនេះមានគុណវិសេសដូចម្តេចខ្លះ ? អ្នកម្ចាស់ក្អែកក្រាបទូលថា បពិត្រព្រះសម្មតិទេព ក្អែកនេះចេះរាំចេះពង់ ចេះក្រាបថ្វាយបង្គំ ក៏ប្រើក្អែកនោះថ្វាយបង្គំព្រះរាជា, លុះក្អែកនោះថ្វាយបង្គំហើយ អ្នកម្ចាស់ក្អែកធ្វើភ្លេងដោយមាត់របស់ខ្លួន ក្អែកក៏ពន់ពេនរេរាំតាមភ្លេងនោះ ។ ព្រះរាជាបានទតឃើញដូច្នោះទ្រង់សព្វព្រះហឫទ័យណាស់ ក៏ត្រាស់បង្គាប់ឱ្យអាមាត្យចងទុកក្បែរទីនោះទៅ ។ ទ្រង់ត្រាស់សួរទៅអ្នកចិញ្ចឹមសាលិកាទៀត, អ្នកចិញ្ចឹមសាលិកាក្រាបទូលថា បពិត្រមហារាជសាលិកានេះចេះនិយាយភាសាមនុស្សបាន ក៏នាំសាលិកានោះ

និយាយថ្វាយព្រះរាជាជាព្រះសណ្ដាប់, ព្រះរាជាទ្រង់ព្រះសណ្ដាប់ភាសាកូនសាលិកានោះហើយ ទ្រង់សព្វព្រះហឫទ័យ ក៏បង្គាប់អាមាត្យឱ្យចងទុកក្បែរសត្វក្អែក ។ ទើបត្រាស់សួរទៅអ្នកចិញ្ចឹមកុកទៀត, អ្នកចិញ្ចឹមកុកក្រាបទូលថា បពិត្រព្រះសម្មតិទេព កុកនេះជាសត្វល្ងង់បំផុត ទោះបីទូលព្រះបង្គំខំបង្ហាត់បង្ហាញយ៉ាងណា ក៏ពុំចេះដឹងអ្វីសោះ ចេះត្រឹមតែស្រែកក្រកៗ ប៉ុណ្ណោះ ។ កុកបណ្ឌិតកាលបើម្ចាស់របស់ខ្លួនទូលព្រះរាជាដូច្នោះហើយ ក៏ស្រែកក្រកៗឡើង ។ លំដាប់នោះព្រះរាជាទ្រង់ព្រះសំរួលយ៉ាងខ្លាំង ទើបបង្គាប់អាមាត្យថា ឯងយកកុកនេះទៅលែងទៅកុំទុក ព្រោះវាល្ងង់ណាស់មិនចេះនិយាយស្ដីនឹងគេទេ ។ កុកបណ្ឌិតកាលបើអាមាត្យលែងហើយ ក៏ហើរទៅទំលើកំពូលប្រាសាទ សូត្របទគាថាជាភាសាមនុស្សថា :

**ពន្ធោ បណ្ឌិតោ រាជ ភាសកញ្ចេវមាទិច**

**មយ្ហំ សាលិកាចេវ ពហូ ញាតា ពហូ ពន្ធា**

បពិត្រមហារាជ ខ្ញុំជាកុកបណ្ឌិតមានប្រាជ្ញា ម្ចាស់ខ្ញុំព្រះអង្គឱ្យនិយាយ ខ្ញុំមិននិយាយឡើយ ដើម្បីដោះខ្លួនឱ្យរួចពីចំណង, ឯក្អែកនិងសាលិកា ជាអ្នកចេះដឹងច្រើនជាប់ចំណងក៏ច្រើន ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់គាថារបស់កុកបណ្ឌិតហើយ ក៏ទ្រង់បន្លឺនូវព្រះសូរសីហនាទថាសាធុ ៗ អ្នកជាបណ្ឌិតមានប្រាជ្ញា

មែន ។ កុកបណ្ឌិត ក៏ហើរទៅតាមវត្តុប៉ងរបស់ខ្លួនដោយសួស្តី ។ លំដាប់នោះព្រះរាជាទ្រង់ទតឃើញក្អែកនិងសាលិកា ដែលជាប់ចំណង មានមុខក្រៀមក្រមស្រងូតស្រងាត់ ក៏ត្រាស់បង្គាប់អាមាត្យឱ្យដោះលែងទៅ ។

## ២. រឿងព្រះបាទមន្ធាតុ

( ចាក ម. តិ. )

( សេចក្តីប្រាថ្នារបស់សត្វលោក ឥតមានទីបំផុត )

ក្នុងខាងដើមនៃភទ្ទកប្បនេះ មានព្រះបរមចក្រពត្រាធិរាជមួយព្រះអង្គ ព្រះនាមមន្ធាតុ មានមហិទ្ធិឫទ្ធិធំអស្ចារ្យ សោយរាជ្យក្នុងទ្វីបទាំង ៤ មានមហាក្សត្រិយ៍ ៨ ម៉ឺន ៤ ពាន់ព្រះអង្គជាបរិវារ។ មនុស្សក្នុងជំនាន់នោះ មានអាយុកំណត់ ១ អសង្ខេយ្យឆ្នាំ ។ ឯព្រះបាទមន្ធាតុនោះ មានឥទ្ធិពលសំបើមអស្ចារ្យណាស់ គ្រាន់តែទះដៃវេលាណា មានភ្លៀងកែវ ៧ ប្រការ ធ្លាក់ចុះមកវេលានោះ, ទ្រង់នៅជាកុមាររត់លេងសប្បាយដោយល្បែងក្មេងជាង ៨ ម៉ឺនឆ្នាំ ដល់ព្រះជន្មគំរប់ ៨ ម៉ឺន ៤ ពាន់ព្រះរាជបិតាទ្រង់ប្រទានកិត្តិយសឱ្យធ្វើជាឧបរាជ ១ បាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ បានទទួលរាជាភិសេកជាស្តេចបរមចក្រពត្រាធិរាជ, សោយរាជ្យបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ ទ្រង់មិនស្កប់ស្កល់ដោយរាជសម្បត្តិ បានត្រាស់សួរមហាមាត្យថា ទី

ដែលបរិបូណ៌ដោយរាជ្យសម្បត្តិវិសេសជាងនេះទៅទៀត មានឬទេ ? ។ មហាមាត្យទូលថា បពិត្រព្រះសម្មតិទេព ក្នុងមនុស្សលោកនេះពុំមានទេ មានតែស្ថានចាតុមហារាជិកា ទើបបរិបូណ៌ដោយសេចក្ដីសុខប្រសើរជាងស្ថានមនុស្ស ។ ព្រះបាទមន្ធាតុបានជ្រាបហើយ ក៏កាន់ចក្ករតន៍គ្រវី អណ្ដែកទៅឰដ៏អាកាសព្រមទាំងចតុរង្គសេនា ទៅចុះនៅស្ថានចាតុមហារាជិកា។ ពួកទេវតាក្នុងស្ថាននោះបានឃើញព្រះបាទមន្ធាតុហើយ ក៏នាំគ្នាកាន់ភ្ញីផ្កាចូលទៅបូជាថ្វាយរាជសម្បត្តិទិព្វដល់ព្រះបាទមន្ធាតុ ។ បានសោយរាជ្យសម្បត្តិនៅស្ថានចាតុមហារាជិកានោះ បានចំនួន ៨ ម៉ឺន ៤ ពាន់ឆ្នាំមនុស្សទ្រង់មិនបានស្កប់ស្កល់ក្នុងរាជសម្បត្តិនោះទៀត. ទើបត្រាស់សួរទៅស្ដេចចតុលោកបាលទាំង ៤ ថា ទីស្ថានដែលបរិបូណ៌ដោយសេចក្ដីសុខជាងនេះ មានដែរឬ ? ។ ស្ដេចចតុលោកបាលទាំង ៤ ក្រាបទូលថា រាជសម្បត្តិក្នុងស្ថាននេះ មិនវិសេសជាងស្ថានមនុស្សប៉ុន្មានទេ មានតែរាជសម្បត្តិក្នុងស្ថានត្រៃត្រឹង្ស ទើបប្រសើរជាងនេះជា ១ រយគុណ ។ ព្រះបាទមន្ធាតុបានជ្រាបហើយ ក៏ចាប់ចក្ករតន៍គ្រវីហោះទៅស្ថានត្រៃត្រឹង្សទៀត ។ ព្រះឥន្ទ្រាធិរាជ បានទតឃើញព្រះបាទមន្ធាតុហើយ ក៏មានព្រះទ័យសោមនស្សរីករាយ កាន់ផ្កាភ្ញីចូលទៅបូជាថ្វាយរាជសម្បត្តិពាក់កណ្ដាល ។ ព្រះបាទមន្ធាតុ បានសោយរាជ្យសម្បត្តិពាក់កណ្ដាលនៅស្ថានត្រៃត្រឹង្សនោះ ជាសុខ

ក្សេមក្សាន្តអស់កាលជាយូរអង្វែងណាស់ចំនួន៣៦ ដំណាព្រះឥន្ទ្រ ។ ឯសេចក្តីប្រាថ្នារបស់ព្រះអង្គ មិនចេះពេញសោះ នៅតែខ្វះកន្លះជានិច្ច សូម្បីសោយរាជសម្បត្តិទិព្វ ជាយូរអង្វែងដល់ម៉្លោះ ក៏មិនចេះស្កប់ស្កល់ ទើបទ្រង់ព្រះចិន្តាថា បើអញសម្លាប់ព្រះឥន្ទ្រចោលហើយសោយរាជ្យតែម្នាក់ឯង ទើបល្មមសមនឹងបុណ្យស័ក្តិរបស់អញ ។ គ្រាន់តែគិតយ៉ាងនេះ ការទ្រុឌទ្រោមនៃសរីរៈ ក៏កើតឡើងប្រាកដ ពុំអាចនៅលាយឡំជាមួយនឹងពួកទេវតាបាន ស្រាប់តែច្យុតមកស្ថិតនៅក្នុងឱទ្យានរបស់ព្រះអង្គ នាស្ថានមនុស្សដូចកាលមុនវិញ ។ នាយឱទ្យានបាល បានឃើញព្រះបាទមន្ធាតុចុះពីស្ថានសួគ៌មកស្ថិតនៅក្នុងឱទ្យានវិញហើយ ក៏ចូលទៅក្រាបទូលដល់ព្រះរាជត្រកូល ។ ព្រះរាជាដែលជាធំក្នុងព្រះរាជត្រកូល បានជ្រាបដំណឹងនោះហើយ មានសេចក្តីត្រេកអរណាស់ ទ្រង់ម្ចីម្នាយាងទៅឱទ្យានជាមួយនឹងស្តេចទាំង ៨ ម៉ឺន ៤ ពាន់ព្រះអង្គ ចាត់ចែងក្រាលរៀបចំរាជសេយ្យាសនៈដ៏ប្រសើរក្នុងឱទ្យាននោះ ។ ព្រះបាទមន្ធាតុ ទ្រង់ឡើងផ្ទំលើសិរីរាជសេយ្យាសនៈនោះហើយ បានប្រកាសប្រាប់ដល់ព្រះរាជវង្សានុវង្សទាំងឡាយថា យើងលែងក្រោកចាកអាសនៈនេះហើយ អ្នកទាំងឡាយចូលចាំគ្រប់គ្នាថា សេចក្តីប្រាថ្នារបស់សត្វលោកធំទូលាយវែងឆ្ងាយឥតមានទីបំផុត. ទ្រង់មានព្រះបន្ទូលដូច្នេះជាដើមហើយ ក៏ទ្រង់សោយទិវង្គតទៅ បានទៅកើតក្នុងសុគតិភព

តាមសមគួរដល់បុញ្ញកម្មរបស់ព្រះអង្គ ។

ឯបុព្វកម្មរបស់ព្រះបាទមន្ធាតុ ដែលមានឥទ្ធិពលធំអស្ចារ្យ គ្រាន់តែទះដៃមានភ្លៀងកែវ ៧ ប្រការធ្លាក់ចុះមកពីអាកាស និងមានព្រះជន្មវែង ហើយបានសោយរាជ្យសម្បត្តិទិព្វទៀតនោះគឺ កាលសាសនាព្រះសម្ពុទ្ធព្រះនាម វិបស្សី រាប់ពីភទ្ទកប្បនេះទៅក្រោយវិញចំនួន ៩១ កប្ប, កាលនោះព្រះបាទមន្ធាតុកើតជាបុរសកំសត់ម្នាក់នៅក្នុងនគរពន្ធុមតី ជាអ្នកស៊ីឈ្នួលជួលប៉ះជុលសំលៀកបំពាក់ ចាស់ដាច់ដាចរបស់អ្នកនគរនោះ ។ ថ្ងៃមួយពួកពុទ្ធបរិស័ទបានរៀបចាត់ចែងថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន, ឯបុរសកំសត់បានដឹងថា គេរៀបចាត់ចែងនឹងថ្វាយមហាទានដូច្នោះហើយ ក៏នឹកសង្វេគចំពោះខ្លួនថា ឱ! អាត្មាអញ ជាមនុស្សសេសសល់ថោកទាបជាទីបំផុត ពុំបានចាត់ចែងមហាទាននឹងគេសោះ ពីព្រោះជាអ្នកទ័លក្រ, ពេលនេះបើអញមិនឆ្លៀតធ្វើទានទេពុំដឹងជាជាតិណានឹងបានរួចផុតពីសេចក្ដីទុក្ខលំបាក គិតឃើញដូច្នេះហើយសទ្ធាក៏កើតឡើងមាំ ចំពោះគុណព្រះសម្ពុទ្ធ ។ ពេលនោះខំជួសប៉ះជុលសំពត់ឱ្យបុគ្គលម្នាក់ បានលុយមួយមាសក ដឹងថាពេលថ្វាយមហាទានជិតដល់ហើយ ក៏ម្នីម្នាទៅផ្សារទិញបានគ្រាប់សណ្ដែកស្ងោរមួយកំបង់ យកទៅដាក់បាត្រ, ទៅដល់រោងទាន ពុំបានឱកាសនឹងចូលទៅដាក់បាត្រឡើយ ព្រោះខ្លួនជាអ្នក

ទ័លក្រថោកទាប ពួកមហាជនមិនបើកឱកាសឱ្យចូល, ទើបគិតថា អញអស់បានចូលទៅជិតព្រះសម្ពុទ្ធនឹងព្រះសង្ឃហើយ បើដូច្នេះ អញគួរបោះគ្រាប់សណ្តែក សំដៅទៅត្រង់បាត្រព្រះសម្ពុទ្ធនឹងព្រះសង្ឃចុះ បើបានចូលទៅក្នុងបាត្រតែមួយគ្រាប់គង់មានផលច្រើន ។ បុរសកំសត់ ក៏ចាប់គ្រាប់សណ្តែកស្ងោរបោះទៅ, ដោយអំណាចឫទ្ធិព្រះសម្ពុទ្ធ គ្រាប់សណ្តែកក៏អណ្តែកទៅធ្លាក់ចុះក្នុងបាត្រជាលំដាប់ តាំងពីបាត្រព្រះសម្ពុទ្ធជាម្ចាស់ដរាបទៅដល់បាត្រព្រះសង្ឃឥតមានជ្រុះទៅទីដទៃមួយគ្រាប់ឡើយ ។ បុរសកំសត់ឃើញអស្ចារ្យដូច្នោះហើយ សេចក្តីជ្រះថ្លាក៏រីងរឹតតែកើតឡើងយ៉ាងក្រៃលែង ទើបតាំងសេចក្តីប្រាថ្នាថា ដោយអំណាចការបូជារបស់ខ្ញុំនេះ ក្នុងអនាគតកាល សូមឱ្យបានជាធំជាងជនអ្នកត្រូវការដោយកាមទាំងឡាយ បើខ្ញុំលើកដៃទះឡើងវេលាណា សូមឱ្យភ្លៀងកែវ ៧ ប្រការធ្លាក់ចុះពីផ្ទៃអាកាសវេលានោះកុំខាន ។ បុរសកំសត់ លុះអស់អាយុបានទៅសោយសុខក្នុងទេវលោក និងមនុស្សលោកអស់កាលជាអង្វែង លុះដល់មកខាងដើមនៃភទ្ទកប្បនេះ បានមកកើតជាព្រះរាជបុត្ររបស់ព្រះបាទកល្យាណរាជ មាននាមបញ្ញត្តិថា ព្រះបាទមន្ធាតុនេះឯង ។

# ៣~ រឿងនាងថូនទាសី

( ចាក វិ. ខុ. )

( ទឹកមួយក្អមរបស់ស្ត្រីមានសទ្ធា ជូនយកសិរីក្នុងស្ថានសួគ៌បាន )

ក្នុងពុទ្ធកាល, ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ស្តេចយាងទៅដែនកោសល ជាមួយនឹងភិក្ខុសង្ឃ ៥ រយអង្គ ទ្រង់យាងចូលទៅសម្រាកព្រះកាយក្នុងថូនគ្រាម ដើម្បីកំចាត់បង់នូវមិច្ឆាទិដ្ឋិរបស់ពួកព្រាហ្មណ៍ក្នុងថូនគ្រាមនោះ ។ ពួកព្រាហ្មណ៍ទាំងឡាយ បានឮដំណឹងថា ព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ស្តេចយាងនិមន្តមកដល់ត្រើយស្ទឹងខាងនាយ បម្រុងនឹងឆ្លងចូលទៅក្នុងថូនគ្រាមហើយ, ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យទាំងឡាយ បានប្រកាសប្រាប់ដល់ព្រាហ្មណ៍ជាបរិស័ទថា យើងទាំងអស់គ្នាមិនគប្បីគួរសមរាប់រកឱ្យវត្ថុអ្វី ដល់សមណគោតមឡើយ ។ ម្យ៉ាងទៀតយើងទាំងអស់គ្នា ត្រូវអូសទូកឡើងពីកំពង់ឱ្យអស់ ហើយរុះស្ពានចោលចេញ ទាំងសាលាសំណាក់ក៏ត្រូវរុះស្បូវរើរនាបឱ្យអស់, បើអ្នកណាមួយទៅគួរសមឱ្យវត្ថុអ្វីដល់សមណគោតមនិងភិក្ខុសង្ឃ ត្រូវធ្វើទោសអ្នកនោះដល់ជីវិត ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបវិប្បការៈរបស់ព្រាហ្មណ៍ដូច្នោះហើយក៏នាំភិក្ខុសង្ឃទាំង ៥ រយ ហោះពួយអាកាស ឆ្លងស្ទឹងទៅចុះត្រង់កណ្តាលស្រុកនោះ ទ្រង់និមន្តទៅគង់ក្រោមម្លប់ឈើមួយដើមក្បែរអណ្តូងទឹក ។

សម័យនោះ មាននាងទាសីម្នាក់ ជាខ្ញុំបំរើត្រកូលព្រាហ្មណ៍មួយក្នុងថូនគ្រាមនោះ កំពុងកណ្ដៀតក្អមទៅដងទឹកអណ្ដូង បានឃើញព្រះមានព្រះភាគ ក៏មានចិត្តជ្រះថ្លាកើតឡើង, នាងគិតថា សម័យនេះក្ដៅណាស់ ព្រះសម្ពុទ្ធ និងព្រះសង្ឃទាំងអស់អង្គប្រហែលជាស្រេកទឹកខ្លាំងបានជាមកគង់ក្នុងទីនេះ, អញត្រូវតែដងទឹកមួយក្អមយកទៅប្រគេនទើបគួរ, ប៉ុន្តែព្រាហ្មណ៍ព្រឹទ្ធាចារ្យបានដាក់អាជ្ញាថា បើអ្នកណាទៅគួរសម យកវត្ថុអ្វីៗ ទៅប្រគេនដល់សមណគោតមនិងព្រះសង្ឃនេះ ត្រូវមានទោសដល់ជីវិត ។ នាងគិតដូច្នេះហើយ ក៏ដើរហួសទៅដងទឹក, លុះត្រឡប់មកវិញសទ្ធាក៏កាន់តែកើតខ្លាំងឡើងៗ ទើបគិតថា ណ្ហើយចុះអញបានជួបនឹងស្រែបុណ្យដ៏ប្រសើរយ៉ាងនេះហើយ គួរតែធ្វើទានកុំខាន ទោះបីគេសម្លាប់ ឬដាក់អាជ្ញាយ៉ាងណាតាមការចុះ, នាងក៏កណ្ដៀតក្អមចូលទៅកណ្ដាលហ្វូងភិក្ខុសង្ឃ យកទឹកមួយក្អមទៅប្រគេនព្រះសម្ពុទ្ធ ។ ទ្រង់ទទួលដោយព្រះហស្តទាំងពីរ ថ្លែងអាការៈឱ្យនាងដឹងថា ព្រះអង្គត្រូវការទឹកនោះណាស់, ទ្រង់ចាក់ទឹកនោះលប់ព្រះភ័ក្ត្រ ហើយឆាន់ក្នុងទីចំពោះមុខរបស់នាង, ដោយអំណាចឫទ្ធិរបស់ព្រះអង្គ ទឹកក្នុងក្អមនៅពេញដដែល ទើបឱ្យក្អមទឹកនោះទៅភិក្ខុសង្ឃទាំង ៥ រយឆាន់ទៀត ទឹកក្អមក៏នៅតែពេញដដែល ។ នាងថូនទាសីបានឃើញចំឡែកអស្ចារ្យដូច្នេះហើយ សេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ក៏

កាន់តែចំរើនស្ថាពរឡើងជារយគុណ ។ កាលភិក្ខុសង្ឃទាំង ៥ រយ ធាន់ឆ្អែតស្កប់ស្កល់ហើយ, ព្រះសម្ពុទ្ធទ្រង់ប្រទានក្អមទឹកនោះដល់នាងថូនទាសីវិញ, នាងបានទទួលក្អមហើយ ថ្វាយបង្គំលាព្រះមានព្រះភាគទៅគេហដ្ឋានរបស់នាងវិញ។ ជាលំដាប់នោះពួកព្រាហ្មណ៍ទាំងឡាយ ក៏ចាប់នាងវាយតប់ បណ្ដើរយកទៅឱ្យព្រាហ្មណ៍ជាចៅហ្វាយទាំងឡាយនាយៗ បានវាយថែមទៀតទាល់តែស្លាប់ក្នុងពេលនោះទៅ ។ ចំណែកខាងព្រះមានព្រះភាគ កាលបើនាងថូនទាសីចេញទៅផុតហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទ ប្រើឱ្យយកបាត្រព្រះអង្គទៅដងទឹកអណ្ដូង, ព្រះអានន្ទមិនហ៊ានទៅដង ព្រោះខ្លាចព្រាហ្មណ៍វាយសម្លាប់, ទ្រង់ប្រើជាគំរប់បីដង ព្រះអានន្ទមិនហ៊ានប្រកែក ទើបកាន់យកបាត្រនិមន្តទៅអណ្ដូងទឹក គ្រាន់តែទៅដល់មាត់អណ្ដូង ទឹកក៏បាញ់ចេញពីក្នុងអណ្ដូង ជោរជនរាចទៅលើមហាប្រថពី លិចភូមិស្រុកថូនគ្រាមនោះមួយរំពេច ប៉ុន្តែត្រង់កន្លែងដែលព្រះសម្ពុទ្ធ និងព្រះសង្ឃគង់នោះឥតមានទឹកលិចឡើយ ។ ពួកព្រាហ្មណ៍ទាំងឡាយ ឃើញហេតុអស្ចារ្យដូច្នោះហើយភិតភ័យខ្លាំងណាស់ ក៏នាំគ្នារត់ចូលទៅសុំទោសព្រះសម្ពុទ្ធថ្វាយខ្លួនជាឧបាសកឧបាសិកា យកព្រះរតនត្រ័យជាទីពឹងទីរលឹកស្មើដោយជីវិត, ទឹកក៏បាត់អស់រលីងក្នុងខណៈនោះទៅ ។

ឯនាងថូនទាសី ដែលព្រាហ្មណ៍វាយសម្លាប់នោះ បានទៅ

កើតក្នុងស្ថានត្រៃត្រឹង្ស មានរូបល្អឥតឧបមា មានរស្មីចែងចាំង ចេញអំពីកាយផ្សាយទៅក្នុងទិសទាំងពួង មានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានមាស មានសណ្ឋានដូចជាទូកកឹង ប្រតិស្ឋានទៅលើទឹកទិព្វ ក្នុងមហាស្រះបោក្ខរណីមួយ ។ លើមាត់ស្រះមានដើមកប្បព្រឹក្សដុះព័ទ្ធជុំវិញ, ក្នុងស្រះនោះមានដើមឈូកដុះព្រោងព្រាត បញ្ចេញផ្កាផ្លែផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប ឈូកនោះមានផ្កា ៥ ពណ៌ ខ្លះដើមជាមាស ស្លឹកជាកែវមណី ផ្កាជាប្រាក់ ផ្លែជាត្បូងទទឹម, ខ្លះដើមជាត្បូងទទឹម ស្លឹកជាប្រាក់ ផ្កាជាកែវមណី ផ្លែជាមាស ដុះព័ទ្ធព័ន្ធវិមានប្រាសាទ ។ ក្នុងពេលនោះ នាងគិតពិចារណាមើលអតីតជាតិរបស់នាង ក៏បានដឹងសព្វគ្រប់ថា ឱ ! អញដែលបានមកកើតជាទេវធីតាបរិបូណ៌ ដោយទិព្វសម្បត្តិដូច្នេះ ដោយសារតែទឹកមួយក្អម ដែលអញបានប្រគេនព្រះសម្ពុទ្ធក្នុងស្រុកថ្ងួនគ្រាម, ឥឡូវនេះព្រះសម្ពុទ្ធគង់នៅក្នុងទីនោះ ពុំទាន់និមន្តទៅណាឡើយ ដូច្នេះគួរតែទៅបំពេញសម្បត្តិរបស់អញ ឱ្យវិសេសជាងនេះទៅទៀត, គិតដូច្នេះហើយចុះមកភ្លាម វិមានប្រាសាទក៏អណ្តែកដោយមកប្រតិស្ឋានលើផែនដី ក្នុងទីចំពោះព្រះភ័ក្ត្រព្រះសម្ពុទ្ធ ។ នាងទេពធីតា បាននាំបរិវារទាំងមួយពាន់ ចេញពីវិមានប្រាសាទចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូ ។ ពេលនោះពួកព្រាហ្មណ៍ទាំងឡាយ ដែលកំពុងអង្គុយគាល់ព្រះមានព្រះភាគ ក៏ធ្មើលឈ្ងូឆរ

ទឹកស្ងើចក្នុងចិត្តឥតឧបមា ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរនាងទេពធីតា ដើម្បីឱ្យព្រាហ្មណ៍ទាំងអស់បានដឹងក្នុងពេលនោះថា ម្នាលទេពធីតា អ្នកបរិបូណ៌ដោយទិព្វសិរី មានពន្លឺចែងចាំងជានិច្ច តើនាងមកអំពីទីណា ? បានធ្វើបុណ្យអ្វីក្នុងជាតិមុន ? ។ នាងទេពធីតាក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមកពីស្ថានត្រៃត្រឹង្ស, កាលពីម្សិលមិញខ្ញុំព្រះអង្គនៅក្នុងស្រុកថូនគ្រាមនេះ បានដងទឹកមួយក្អមប្រគេនព្រះអង្គ, លុះត្រឡប់ទៅផ្ទះ ពួកព្រាហ្មណ៍ទាំងឡាយដែលអង្គុយជុំវិញនេះ នាំគ្នាចាប់វាយខ្ញុំព្រះអង្គបណ្ដើរទៅឱ្យព្រាហ្មណ៍ជាចៅហ្វាយរបស់ខ្ញុំព្រះអង្គ ។ បានវាយថែមទៀតដរាបដល់ស្លាប់ ។ បន្ទាប់មកនាងក៏បានថ្លែងរៀបរាប់អំពីទិព្វសម្បត្តិរបស់នាងក្នុងស្ថានសួគ៌ដោយសព្វគ្រប់ លុះចប់ហើយព្រះសម្ពុទ្ធបរមគ្រូ ទ្រង់សំដែងនូវធម្មកថា ពន្យល់អំពីអរិយសច្ចធម៌ ៤ ប្រការ នាងទេពធីតាក៏បានសម្រេចដល់សោតាបត្តិផលក្នុងពេលនោះ ទើបថ្វាយបង្គំលាព្រះមានព្រះភាគ ទៅស្ថានត្រៃត្រឹង្សវិញ ។ ពួកព្រាហ្មណ៍ក្នុងថូនគ្រាម ក៏បានយល់ជាក់ច្បាស់នូវលទ្ធិពុទ្ធសា-សនាក្នុងពេលនោះ ។

# ៤. រឿងសត្វមានក្បាលពីរ

( ចាក ពា. ប. )

( ការញុះញង់ ជាអាវុធក្លាហានបំផុតក្នុងលោក )

ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានស្ត្រីម្នាក់ មានចិត្តស្មោះត្រង់ស្នេហាចំពោះស្វាមីរបស់ខ្លួន តែងគោរពប្រតិបត្តិចំពោះស្វាមី ដូចជាស្រីទេពអប្សរគោរពបំរើព្រះឥន្ទ្រាធិរាជ ពុំដែលឱ្យហ្មងឆ្គងត្រង់កិច្ចណាមួយឡើយ ។ ថ្ងៃមួយស្ត្រីនោះបាននាំស្វាមីចាត់ចែងទាន ថ្វាយដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយតាំងសេចក្តីប្រាថ្នាថា ក្នុងជាតិខាងមុខ ៗ បន្ទាប់អំពីជាតិនេះទៅសូមឱ្យបានកើតជាបុរសរាល់ៗជាតិ ហើយសូមឱ្យកើតជាប្អូនរួមផ្ទៃនឹងស្វាមីរបស់ខ្ញុំ, ម្យ៉ាងទៀត បើយើងខ្ញុំទាំងពីរនាក់ភ្លាត់គតិទៅកើតជាតិរច្ឆាន សូមឱ្យមានខ្លួនជាប់គ្នាមានក្បាលពីរកុំខាន ។ ព្រះសម្ពុទ្ធទ្រង់ធ្វើភត្តានុមោទនាហើយ ស្តេចត្រឡប់ទៅអារាមជាមួយនឹងព្រះសង្ឃជាបរិវារវិញ ។

ឯជនទាំងពីរនាក់ស្វាមីភរិយា លុះដល់ក្ស័យជីវិតបានទៅកើតជាកុមារក្នុងត្រកូលមហាសេដ្ឋីមួយជាតិ, ព្រាហ្មណ៍មហាសាលមួយជាតិ, ខត្តិយមហាសាលមួយជាតិ កើតរួមផ្ទៃជាមួយគ្នា ជាកូនភ្លោះ នាងភរិយាកើតជាប្អូនប្រុស ស្វាមីជាបងប្រុស, កុមារទាំងពីរមានសេចក្តីរាប់អានស្រឡាញ់គ្នាជាទីបំផុត ។ បន្ទាប់ពីជាតិនោះ

មក ភ្លាត់គតិទៅកើតជាសត្វហង្សមាស មានខ្លួនព្រែកជាប់គ្នា មានក្បាលពីរស្វាប ៤ ជើង ៤ នៅអាស្រ័យក្នុងព្រៃហេមពាន្ត ក្បែរស្រះបោក្ខរណីមួយ តែងទៅរកចំណីអាហារជាមួយគ្នាពុំដែលទាស់ទែងខ្វែងគំនិតគ្នាឡើយ ។ ថ្ងៃមួយមានថ្មើរព្រៃម្នាក់ បានឃើញហង្សមាសក្បាលពីរនោះ ក៏កើតសេចក្ដីអស្ចារ្យពន់ពេក ទើបត្រឡប់ទៅក្រាបទូលដល់ព្រះបាទពារាណសី ។ គ្រានោះព្រះពោធិសត្វទ្រង់សោយព្រះជាតិ ជាព្រះបាទពារាណសី ទ្រង់បានព្រះសណ្ដាប់ពាក្យនោះហើយ ក៏ប្រើថ្មើរព្រៃឱ្យទៅចាប់ហង្សក្បាលពីរនោះយកមកថ្វាយ ។ ថ្មើរព្រៃក៏ទៅចាប់បានយកមកថ្វាយ ដូចព្រះរាជបំណងស្ដេចទ្រង់សព្វព្រះរាជហឫទ័យណាស់ បានប្រទានរង្វាន់ដល់ថ្មើរព្រៃនោះជាច្រើន ទើបប្រគល់ហង្សមាសក្បាលពីរនោះឱ្យព្រះអគ្គ-មហេសីយកទៅចិញ្ចឹម ។ ព្រះអគ្គមហេសី បានឱ្យជាងធ្វើទ្រុងមាសដាក់ហង្សនោះ ហើយទ្រង់ប្រទានលាជនិងទឹកឃ្មុំដាក់លើថាសមាស ឱ្យស៊ីតែរាល់ ៗ ថ្ងៃ ។ ក្នុងកាលជាខាងក្រោយមក ព្រះនាងទេវី បានចូលទៅក្រាបទូលព្រះបាទពារាណសីថា ហង្សមាសក្បាលពីរនោះ ប្រសិនបើបំបែកឱ្យដាច់ពីគ្នាបាន ហង្សមួយទុកចិញ្ចឹមក្នុងព្រះរាជវាំង ហង្សមួយទុកក្នុងសួនសត្វសម្រាប់ឱ្យមហាជនមើល ជាការប្រពៃណាស់ ។ ព្រះបាទពារាណសី ទ្រង់យល់តាមមតិរបស់ព្រះនាងទេវី ទើបបង្គាប់ឱ្យអាមាត្យទាំងឡាយមកប្រជុំគ្នា

ហើយត្រាស់សួរថា អ្នកណាអាចបំបែកហង្សនេះឱ្យបែកចេញពីគ្នាបានដោយឥតមានគ្រោះថ្នាក់ យើងនឹងឱ្យរង្វាន់ជាច្រើនដល់អ្នកនោះ ។ ពេលនោះមានអាមាត្យម្នាក់ ជាអ្នកឈ្លាសវៃក្នុងឧបាយកលបានថ្វាយដំណឹងដល់ព្រះរាជាថា ខ្ញុំព្រះអង្គអាចបំបែកបាន. ព្រះរាជាក៏ប្រគល់ហង្សនោះឱ្យទៅ ។ ថ្ងៃមួយអាមាត្យនោះ រៀបតាក់តែងខ្លួនចូលទៅក្នុងវាំង មុននឹងទៅបានបង្ហាញខ្លួនឱ្យហង្សទាំងពីរដឹងថាទៅគាល់ព្រះរាជា. លុះត្រឡប់មកវិញ ទៅឱនខ្សិបជិតក្បាលហង្សម្ខាង និយាយខ្សាវៗ តិចៗ ធ្វើហាក់ដូចជាប្រាប់រឿងកំបាំងអ្វីមួយ ហើយចៀសចេញទៅ ។ ឯហង្សម្ខាងឃើញដូច្នោះហើយមានសេចក្ដីសង្ស័យណាស់ ទើបសួរទៅហង្សជាសំឡាញ់ថាអម្បាញ់មិញនេះ អាមាត្យខ្សិបប្រាប់រឿងកំបាំងអ្វីដល់អ្នក ? ចូរប្រាប់គ្នាផង. ហង្សម្ខាងប្រាប់ថា ឥតមានប្រាប់ការអ្វីទេ គ្រាន់តែឮខ្សាវ ៗ មិនដឹងជាគេថាដូចម្ដេច ។ ហង្សម្ខាងតូចចិត្តណាស់ទើបនិយាយថា ឱ! សំឡាញ់ឯងមិនគួរលាក់នឹងគ្នាសោះ គ្នាពិតជាឃើញអាមាត្យនិយាយប្រាប់ឯងនឹងភ្នែក. ទោះបីហង្សម្ខាងនិយាយប្រាប់យ៉ាងណាក៏មិនជឿ ចេះតែទទូចសួរជាញឹកញយ ។ ថ្ងៃក្រោយអាមាត្យទៅខ្សិបក្បែរត្រចៀកហង្សនោះទៀត. ហង្សម្ខាងសង្ស័យក៏សួរដូចមុន ហង្សម្ខាងប្រាប់ថាខ្ញុំមិនឮអ្វីទេ ហេតុដូចម្ដេចបានចេះតែសួរខ្ញុំ ។ ចាប់តាំងពីពេលនោះមក ហង្សទាំងពីរក៏ឈ្មោះ

ប្រកែកគ្នាកាន់តែខ្លាំងឡើង ៗ ដរាបដល់ជេរប្រទេច ហើយទទះស្លាបចឹកគ្នាជាខ្លាំង, ដោយអំណាចសេចក្ដីក្រោធ សរីរៈកាយនៃហង្សក៏របែកចេញពីគ្នាជាពីរចំណែក ។ អាមាត្យឃើញដូច្នោះហើយ ក៏នាំយកហង្សទាំងពីរទៅថ្វាយព្រះបាទពារាណសី, ព្រះអង្គបានទតឃើញមានសេចក្ដីសោមនស្សពន់ពេក ទើបព្រះរាជទានស្រុកសួយមួយឱ្យជារង្វាន់ ហើយទ្រង់ត្រាស់សួរថា អ្នកធ្វើដូចម្ដេចបានជាហង្សបែកចេញពីគ្នា ? សូម្បីតែយកមកដាក់ជិតគ្នាក៏មិនបាន អាមាត្យក្រាបទូលតាមការដែលខ្លួនបានធ្វើ ទ្រង់បានព្រះសណ្ដាប់ពាក្យនោះហើយ ក៏មានព្រះទ័យសង្វេគតក់ស្លុតពន់ពេក ទើបមានព្រះរាជឱង្ការថា ឱហ្ន ! អាវុធគឺពាក្យញុះញង់ក្លាហានណាស់តើ ! អាចពុះបំបែករូបធម៌នឹងអរូបធម៌ ឱ្យបែកចេញពីគ្នាបាន, ក្នុងលោកនេះឥតមានអាវុធណា ដែលក្លៀវក្លាស្មើនឹងពាក្យញុះញង់នេះឡើយ

ប្រជុំជាតក, ច្មើរព្រៃក្នុងកាលនោះគឺឆន្នត្ថេរ, ហង្សមាសទាំងពីរគឺ គឺរមានន្ទត្ថេរនឹងកាឡុទាយិត្ថេរ, អាមាត្យអ្នកឈ្លាសវៃក្នុងឧបាយកល់ គឺសារីបុត្តត្ថេរ, ព្រះបាទពារាណសី គឺព្រះសម្មា-សម្ពុទ្ធ ។

# ៥. រឿងទុគ្គតធីតា

( ចាកវិ. ខុ. )

( បាយក្តាំងមួយដុំរបស់ស្ត្រីមានភ័ព្វ មានតម្លៃកាត់មិនបាន )

កាលព្រះសម្ពុទ្ធទ្រង់គង់នៅវត្តវេឡុវ័ន មានត្រកូលមួយនៅក្នុងក្រុងរាជគ្រឹះ កើតអហិវាតរោគស្លាប់អស់ នៅសល់តែកូនស្រីមួយ ។ នាងធីតានោះ កាលបើមាតាបិតាបងប្រុសស្រីស្លាប់អស់ហើយ ក៏រត់ចុះពីផ្ទះទៅជ្រកកោននៅក្រោមសំយាបផ្ទះរបស់ជនដទៃ. មនុស្សទាំងឡាយបានឃើញធីតាកំសត់នោះ ក៏មានចិត្តមេត្តាករុណាឱ្យបាយកកបាយក្តាំងដែលសល់ពីខ្លួនបរិភោគ ឱ្យដល់នាងតែរាល់ៗ ថ្ងៃ ។ ថ្ងៃមួយព្រះមហាកស្សបត្ថេរ លោកចេញពីនិរោធសមាបត្តិ បានរំពឹងពិចារណារកបុគ្គលដែលគួរទៅជួយសង្គ្រោះ ក៏បាននាងទុគ្គតធីតានោះ ហើយបានជ្រាបដោយសព្វគ្រប់ថា បើអាត្មាអញទៅដល់ នាងទុគ្គតធីតានឹងឱ្យបាយក្តាំងដល់អាត្មាអញពុំខាន កាលបើឱ្យដូច្នោះហើយ នាងនឹងបានទៅកើតក្នុងស្ថានសួគ៌ពិតប្រាកដ ។ម្យ៉ាងទៀតនាងនេះ ត្រូវជាមាតារបស់អាត្មាអញក្នុងជាតិជាគំរប់បី រាប់អំពីជាតិនេះទៅ ។ ព្រះមហាកស្សបត្ថេរ បានជ្រាបដូច្នេះហើយ ក៏យកបាត្រនិមន្តសំដៅទៅទីដែលនាងទុគ្គតធីតានោះនៅអាស្រ័យ ។ លំដាប់នោះ សក្កទេវរាជព្រះចៅស្ថានត្រៃត្រឹង្សបានជ្រាបហេតុនោះហើយ ក៏និម្មិតខ្លួនជាមាណពកាន់អាហារ

ទិព្វដើរទៅស្កាត់មុខព្រះមហាកស្សបត្ថេរ ។ បានជ្រាបថាព្រះឥន្ទ្រមកក្លែងដូច្នោះ ក៏មានថេរដីកាហាមឃាត់ថា មហារាជកុំប្លន់យកសម្បត្តិរបស់នាងទុគ្គតធីតាឡើយ សូមព្រះអង្គចៀសចេញទៅ ។ សក្កទេវរាជក៏វិលត្រឡប់ទៅទេវលោកវិញ, ព្រះមហាកស្សបត្ថេរ, បាននិមន្តទៅឈរក្នុងទីចំពោះមុខនាងគុគ្គតធីតា។ គិតថា ព្រះថេរៈនេះលោកមកប្រោសអញហើយតើ! អញចំជាស្ត្រីមានលាភប្រសើរណាស់ ។ សេចក្តីជ្រះថ្លារបស់នាងក្នុងពេលនោះ ក៏កើតឡើងពេញបរិបូណ៌ ផរាបផល់ព្រឺរោមព្រឺស្បែក នាងបានយកបាយក្តាំងមួយដុំដែលនៅក្នុងអំបែង ទៅដាក់បាត្រព្រះមហាកស្សបត្ថេរ ។ កាលបើបានបាយក្តាំងហើយ ក៏ងាកមើលនាយអាយ បំរុងនឹងរកកន្លែងឆាន់ពួកមហាជនបានឃើញអាការៈនោះហើយ នាំគ្នាក្រាលអាសនៈប្រគេន, លុះឆាន់ហើយ ក៏ធ្វើភត្តានុមោទនាសរសើរអានិសង្សទានដោយពិស្តារ ទើបមានថេរដីកាទៅរកនាងទុគ្គតធីតាថា ម្នាលនាងកំសត់ កាលពីជាតិមុន នាងត្រូវជាមាតាបង្កើតរបស់អាត្មា ក្នុងជាតិទីបីរាប់ពីជាតិនេះទៅ ។ នាងទុគ្គតធីតា បានឮដូច្នោះហើយក៏រីករីតតែជ្រះថ្លារីករាយជាភិយ្យោភាព, បន្ទាប់មកនាងក៏ធ្វើមរណកាលទៅកើតក្នុងស្ថាននិម្មានរតីទេវលោក បរិបូណ៌ដោយទិព្វសិរីខ្ពាត់ផុតសេចក្តីទ័លក្រគ្រប់យ៉ាង ។

# ៦. រឿងនាងពុទ្ធេណី

( ចាក ម. វា. )

( តិរច្ឆាន ជាសត្វមានចិត្តស្មោះត្រង់ មិនសាំញ៉ាំងដូចមនុស្ស )

កាលព្រះសម្ពុទ្ធបរមគ្រូរបស់យើងបរិនិព្វានហើយ, ក្នុងកាលជាខាងក្រោយមក មានសេដ្ឋីម្នាក់មានទ្រព្យ ៨៧ កោដិ នៅក្នុងក្រុងបាតលីបុត្ត ។ សេដ្ឋីនោះមានធីតាមួយរូបឈ្មោះពុទ្ធេណី នាងមានអាយុ ៧ ឆ្នាំ មាតាបិតាស្លាប់ចោលអស់ទៅ នៅតែម្នាក់ឯងជាមួយនឹងក្រុមញាតិ, សម្បត្តិទាំងប៉ុន្មានធ្លាក់នៅលើដៃនាងទាំងអស់ ។ ឯនាងពុទ្ធេណីនោះ ជាស្ត្រីមានរូបល្អដូចជារូបស្រីទេពអប្សរ, ដល់អាយុគំរប់ ១៦ ឆ្នាំ ពួកឥស្សរជនទាំងឡាយ មានក្សត្រិយ៍និងមន្ត្រីជាដើម តែងចោមរោមដណ្ដឹងនាង តែនាងពុំព្រមយកស្វាមីឡើយ ព្រោះជាស្ត្រីមាននិស្ស័យខ្ពស់, នាងខំតែធ្វើទានរក្សាសីលប្រព្រឹត្តសុចរិតតែម្យ៉ាង ។

ថ្ងៃមួយ មានឈ្មួញសេះម្នាក់នៅក្នុងឧត្តរទិស បាននាំសេះជាច្រើនចូលទៅលក់ក្នុងក្រុងបាតលីបុត្ត ទៅសំណាក់ក្នុងរោងទានរបស់នាងបានឃើញចរិយាសម្បត្តិ នឹងគុណសម្បត្តិរបស់នាងហើយក៏មានចិត្តបដិព័ទ្ធស្រឡាញ់ហាក់បីដូចជាធីតាបង្កើត ទើបសុំនាងធ្វើជាកូនចិញ្ចឹម នាងក៏ព្រមតាមពាក្យសុំ ។ ឈ្មួញសេះនោះបានឱ្យកូនសេះសិន្ធវៈមួយដល់នាង ។ ក៏មានចិត្តស្រឡាញ់សេះនោះដូចជាកូន

បង្កើត ខំថែរក្សាដោយថ្មិតថ្មង់, ឯសេះក៏បានស្រឡាញ់នាងវិញដូចជាម្ដាយបង្កើត ។ ថ្ងៃក្រោយនាងបានដឹងថា សេះនោះមានបឫទ្ធិប្ញទ្ធិច្រើន អាចហោះហើរឰដ៏អាកាសបាន ក៏គិតថា អញបានចិញ្ចឹមសេះនេះប្រពៃណាស់ ព្រោះមានបំណងចង់ទៅថ្វាយបង្គំមហាពោធិព្រឹក្សជាយូរហើយ លុះគិតដូច្នេះហើយក៏ចាត់ចែងធ្វើភួងផ្កាមាសព្រមទាំងគ្រឿងក្រអូបផ្សេង ៗ មានខ្លឹមចន្ទន៍ជាដើម, ធ្វើហើយវេចខ្ចប់ស្រួលបួលកាន់ដើរទៅរោងសេះ និយាយប្រាប់សេះថា ម្នាលកូនសំឡាញ់ អ្នកជូនម្ដាយទៅថ្វាយបង្គំមហាពោធិព្រឹក្ស ។ សេះឮដូច្នោះក៏ដើរចេញពីក្រោលមក ឱ្យនាងឡើងជិះលើខ្នងហើយហោះសំដៅទៅពោធិមណ្ឌល ទៅចុះក្បែរគល់មហាពោធិព្រឹក្សដោយសន្ទុះយ៉ាងរហ័សក្រៃលែង ដូចជាបុរសមានកំឡាំងបត់ជុំដៃហើយលាចេញ ។ ពេលនោះមានព្រះសង្ឃមួយអង្គ ព្រះនាមធម្មរក្ខិតព្រមទាំងព្រះសង្ឃដទៃទៀតជាបរិវារ នៅថែរក្សាមហាពោធិព្រឹក្សនោះ ។ នាងពុទ្ធេណីយកភួងផ្កាមាសនិងគ្រឿងក្រអូបផ្សេងៗទៅបូជាមហាពោធិព្រឹក្សហើយ បានប្រកាសប្រាប់ដល់ព្រះសង្ឃថាគ្រឿងសក្ការៈនេះ សូមព្រះសង្ឃចាត់ចែងទុកដាក់ថែរក្សាចុះ ។ តាំងពីកាលនោះមក នាងតែងជិះសេះទៅបូជានិងបោសសំអាតគល់មហាពោធិព្រឹក្សតែរាល់ៗពេល ។ ថ្ងៃមួយព្រះរាជាក្រុងបាតលីបុត្តបានជ្រាបថា នាងពុទ្ធេណីជិះសេះទៅថ្វាយបង្គំមហាពោធិព្រឹក្ស

តែរាល់ថ្ងៃដូច្នោះ ក៏ចាត់អាមាត្យឱ្យនាំគ្នាទៅចាំស្កាត់ចាប់នាង យកមកអភិសេកជាអគ្គមហេសី ។ ពេលនោះនាងពុទ្ធេណី បូជាមហាពោធិព្រឹក្សហើយ រៀបដំណើរនឹងត្រឡប់មកវិញ, ព្រះធម្មរក្ខិតជាព្រះអរហន្ត បានជ្រាបហេតុដែលអាមាត្យពួនចាំចាប់នោះ ទើបប្រាប់ដល់នាងពុទ្ធេណីថា ម្នាលនាងដល់ត្រឡប់ទៅវិញចូរប្រយ័ត្នខ្លួនកុំប្រមាទ ។ នាងពុទ្ធេណីបានទៅដល់ពាក់កណ្តាលផ្លូវ ពួកអាមាត្យដែលពួនចាំចាប់នោះ នាំគ្នាស្រែកសន្ធាប់ឡើង សេះក៏ភ្ញាក់ហោះឡើងទៅលើអាកាស ធ្លាក់នាងពុទ្ធេណីពីខ្នង នាងភ័យខ្លាំងណាស់ខំស្រែកហៅសេះថា នែ ! កូនសំឡាញ់ម្តាយជួយម្តាយផង, សេះនោះដឹងថានាងធ្លាក់ពីខ្នងហើយ ក៏ហក់ចុះដោយសន្ទុះយ៉ាងឆាប់រហ័ស យកខ្នងទៅរងទទួលនាងឱ្យជិះដូចដើមវិញ ឥតឱ្យធ្លាក់ដល់ដីឡើយ ទើបហោះទៅគេហស្ថានរបស់ខ្លួនដោយសួស្តី ។ តាំងពីពេលនោះមកនាងពុទ្ធេណី បានចំណាយទ្រព្យចាត់ចែងទានដរាបដល់អស់ ៨៧ កោដិ លុះអស់អាយុ ក៏បានទៅកើតក្នុងស្ថានសួគ៌សោយទិព្វសម្បត្តិ បរិបូណ៌ដោយសុខភាពអស់កាលជាអង្វែង ។

# ៧. រឿងគុត្តិលមាណព

( ចាក វិ. ខុ. )

( ចំណេះវិជ្ជាពិតប្រាកដ ជាឃ្លាំងនៃសិរីក្នុងលោក )

ក្នុងកាលកន្លងទៅហើយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះព្រះបរមគ្រូទ្រង់សោយព្រះជាតិក្នុងត្រកូលអ្នករបាំ មានព្រះនាមប្រាកដថា គុត្តិលមាណព, ព្រះអង្គខំសិក្សាសិល្បសាស្ត្ររបស់អ្នករបាំបានចេះដឹងស្ទាត់ពិតប្រាកដ កិត្តិស័ព្ទរបស់ព្រះអង្គក៏ល្បីទូទៅពេញសាកលលោក ។ ព្រះបាទព្រហ្មទត្តបានជ្រាបដំណឹងថា គុត្តិលមាណពចេះដឹងនូវចម្រៀងតូរ្យតន្ត្រីល្បីល្បាញដូច្នេះហើយ ក៏ហៅមកឱ្យដេញពិណថ្វាយ, ឯពិណរបស់គុត្តិលមាណពនោះ មានខ្សែ ៧ បើដេញកាលណា សំឡេងពិណនឹងចម្រៀង វេញចូលគ្នាតែមួយ ពិរោះក្រៃពេកហាក់ដូចជាតូរ្យតន្ត្រីទិព្វ ។ ព្រះបាទព្រហ្មទត្តទ្រង់ព្រះសណ្ដាប់ហើយ មានព្រះទ័យត្រេកអរណាស់ បានតាំងគុត្តិលមាណពនោះ ជាអាចារ្យធំបំផុតក្នុងក្រុងពារាណសី ឱ្យឈ្មោះថាគុត្តិលាចារ្យ ទ្រង់ព្រះរាជទានរង្វាន់បៀវត្សឱ្យជានិច្ចរាល់ខែដរាបដល់អស់ជីវិត ។ គុត្តិលាចារ្យកាលបើបានប្រាក់រង្វាន់បៀវត្សនោះហើយ ក៏យកទៅទំនុកបម្រុងចិញ្ចឹមមាតាបិតារបស់ខ្លួនដោយគោរព។ ក្នុងកាលជាខាងក្រោយមក មានបុរសម្នាក់ឈ្មោះមុសិលៈ

នៅក្នុងនគរឧជ្ជេនី បានឮដំណឹងថា គុត្តិលាចារ្យចេះសិល្បសាស្ត្រខាងវាយពិណក្បួនកន្ត្រៃយ៉ាងឯកដូច្នោះហើយ ក៏ចូលទៅសូមរៀន ។ ឯគុត្តិលាចារ្យបានឃើញលក្ខណៈរបស់មូសិលមាណពនោះ ក៏ដឹងច្បាស់ថា មាណពនេះជាមនុស្សមិនល្អ អញមិនគួរឱ្យរៀនឡើយ ទើបប្រាប់ទៅមូសិលមាណពថា ខ្ញុំគ្មានឱកាសបង្រៀនទេ ចូរអ្នកទៅរកអាចារ្យរៀនទៀតចុះ ។ ពេលនោះមូសិលមាណពមិនព្រមទៅណាសោះ ក្រាញនៅបម្រើមាតាបិតារបស់គុត្តិលាចារ្យ បាននិយាយអង្វរឱ្យមាតាបិតានោះ ជួយសុំឱ្យបានរៀន ។ គុត្តិលាចារ្យកាលបើមាតាបិតារបស់ខ្លួន និយាយសុំឱ្យមូសិលមាណពរៀនដូច្នោះហើយ ក៏ព្រមឱ្យរៀន ។ ឯមូសិលមាណព ជាមនុស្សមានបញ្ញាអាចរៀននូវសិល្បសាស្ត្រនោះ ចេះស្ទាត់ជំនាញដូចជាអាចារ្យរបស់ខ្លួន ។ ថ្ងៃមួយមូសិលមាណពគិតថា ក្នុងលោកទាំងមូលមានតែព្រះបាទព្រហ្មទត្ត ដែលសោយរាជ្យក្នុងក្រុងពារាណសីនេះ ជាមហារាជាធិរាជ ធំចម្បងជាងស្តេចទាំងពួង គួរតែអញទៅសម្តែងសិល្បសាស្ត្រថ្វាយដល់ស្តេច ដើម្បីឱ្យមានកេរ្តិ៍ឈ្មោះល្បីទូទៅក្នុងលោក ដូចជាអាចារ្យរបស់អញ លុះគិតដូច្នេះហើយ ក៏និយាយអង្វរសុំឱ្យគុត្តិលាចារ្យជូនទៅនៅបំរើព្រះបាទព្រហ្មទត្ត ដើម្បីចិញ្ចឹមជីវិតទៅ ។ ឯគុត្តិលាចារ្យជាអ្នកមានសេចក្តីសង្គ្រោះ បានឮដូច្នោះហើយ ក៏នាំមូសិលមាណពទៅថ្វាយព្រះបាទព្រហ្មទត្ត ហើយក្រាប

ទូលថា បពិត្រព្រះសម្មតិទេព សូមព្រះករុណាជាម្ចាស់ជីវិតលើត្បូង ជួយសង្គ្រោះដល់មុសិលមាណពនេះឱ្យទាន ព្រោះជាកូនសិស្ស របស់ទូលព្រះបង្គំ, មួយទៀតមាណពនេះ ចេះដេញពិណវិសេស ណាស់ ។ ព្រះបាទព្រហ្មទត្ត ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ទ្រង់ ប្រើមុសិលមាណពនោះឱ្យដេញពិណថ្វាយ, ទ្រង់សព្វព្រះរាជ ហឫទ័យនឹងសំឡេងពិណនោះ ក៏ទទួលឱ្យនៅ ។ ក្នុងកាលជាខាង ក្រោយមក មុសិលមាណពបានចូលទៅសូមលាព្រះបាទព្រហ្មទត្ត ទៅកាន់ជាតិភូមិរបស់ខ្លួន។ ព្រះបាទព្រហ្មទត្តទ្រង់ឃាត់ថាអ្នកកុំទៅ ណា ចាំអញឱ្យយសស័ក្តិនឹងបៀវត្ស ពាក់កណ្ដាលបន្ទាប់ពីអាចារ្យ របស់អ្នក។ ឯមុសិលមាណពជាមនុស្សអកតញ្ញូ លុះទៅក្នុងអំណាច នៃសេចក្ដីលោភ បានឮដូច្នោះហើយ ក៏ទូលតបវិញថា គុត្តិលាចារ្យ គាត់ចេះស្មើនឹងទូលព្រះបង្គំដែរ បើព្រះមហារាជពុំជឿហៅគាត់ឱ្យ មកដេញពិណប្រឡងល្បងមើល ។ ព្រះរាជាត្រាស់ថា អើបើដូច្នោះ ចាំអញឱ្យដំណឹងទៅគុត្តិលាចារ្យ កំណត់ ៧ ថ្ងៃទៀត ឱ្យមកដេញ ប្រឡងនៅមុខព្រះរាជវាំង ។ ដំណឹងប្រឡងពិណនោះ ក៏ល្បីទូទៅ ពេញសាកលលោក, ឯគុត្តិលាចារ្យ កាលបើបានទទួលព្រះរាជសារ ហើយ ក៏កើតសង្វេគក្នុងចិត្តបានគិតថា មុសិលមាណពនេះ ជា មនុស្សនៅក្មេងកំពុងមានកំឡាំងច្រើន បើអញទៅដេញពិណភ្ជាប់ នឹងវា មុខតែចាញ់វាមិនខាន, ព្រោះចំណេះទាំងប៉ុន្មានបានបង្រៀន

វាអស់ឥតសល់ អញពុំគួរទៅភ្នាល់នឹងវាឡើយ ហើយចុះស៊ូស្លាប់ទៅកើតទៀតល្អជាង កុំទៅឱ្យឃើញមុខអកត្តញ្ញូ. គិតដូច្នេះហើយ ក៏ដើរទៅចងកក្នុងព្រៃ រៀបនឹងចងកបាននឹកឃើញដល់មាតាបិតាចាស់ជរា ក៏ត្រឡប់មកវិញ. មកដល់ផ្ទះហើយ នឹកឃើញសព្វគ្រប់ទៅចងកទៀត. គ្រាន់តែទៅមក។ យ៉ាងនេះអស់ ៦ ថ្ងៃ ដោយសេចក្ដីអាល័យចំពោះមាតាបិតា. ដល់ថ្ងៃជាគំរប់ ៧ ទៅចងកទៀតដោយអំណាចកតញ្ញូតាចិត្ត ក៏ក្ដៅក្រហាយដល់ពិភពសក្កទេវរាជ ១ បានជ្រាបថា ឱ ! គុត្តិលាចារ្យនេះ មានទុក្ខធ្ងន់ណាស់តើ ! ថ្ងៃនេះត្រូវទៅដេញពិណភ្នាល់នឹងមុសិលមាណព. ម្យ៉ាងទៀតគាត់ត្រូវជាអាចារ្យរបស់អញក្នុងជាតិមុន អញគួរតែទៅជួយគាត់ខានពុំបាន ក៏ហោះចុះមកបង្ហាញខ្លួនដល់គុត្តិលាចារ្យហើយសួរថា លោកអាចារ្យមានទុក្ខដូចម្ដេច ? ចាំខ្ញុំជួយ ។ គុត្តិលាចារ្យដំណាលរឿងរ៉ាវប្រាប់សព្វគ្រប់ សក្កទេវរាជបានជ្រាបហើយនិយាយថា សូមលោកអាចារ្យទៅដេញពិណភ្នាល់នឹងមុសិលមាណពចុះ ឥឡូវជិតដល់ពេលហើយ. លោកអាចារ្យកុំព្រួយឱ្យសោះ ខ្ញុំនេះជាព្រះឥន្ទ្រ ត្រូវជាកូនសិស្សលោកអាចារ្យក្នុងជាតិមុន អ្នកដែលមានកូនសិស្សប្រហែលនឹងខ្ញុំនេះហើយ កុំព្រួយសោះឡើយទៀងតែឈ្នះពុំខាន ។ ឯគុត្តិលាចារ្យ កាលបើដល់ពេលហើយ ក៏ស្លៀកពាក់សំពត់សអាវសល្អស្អាត លីពិណមានខ្សែ ៧ ចូលទៅកាន់ទីប្រជុំ ថ្វាយបង្គំព្រះបាទ

ព្រហ្មទត្តហើយ ឡើងទៅលើតាំងខ្ពស់ជាមួយនឹងសិលមាណព ។ ក្នុងពេលនោះមនុស្សទាំងឡាយជាច្រើនលាននាក់ បានមកប្រជុំគ្នានៅមុខព្រះបរមរាជវាំង ដើម្បីមើលពិធីភ្នាល់ពិណ ។ គុត្តិលាចារ្យមុននឹងលើកពិណឡើងដេញ បានអើតមើលទៅអាកាស ឃើញព្រះឥន្ទ្រកាន់ពិណមាសមានពណ៌ដូចព្នៅទុំ ស្ថិតនៅពីលើ ក៏នឹកសង្ឃឹមថា ជ័យជំនះនឹងមានដល់អញពុំខាន, ឯមនុស្សទាំងឡាយមើលព្រះឥន្ទ្រនោះមិនឃើញឡើយ ។ គុត្តិលាចារ្យនិងមុសិលមាណព ចាប់ដេញពិណមួយបទដំបូងស្មើគ្នា ដល់បទទីពីរព្រះឥន្ទ្រឱ្យសញ្ញាដល់គុត្តិលាចារ្យ ឱ្យបណ្តាច់ខ្សែពិណរបស់ខ្លួនមួយចេញ សំឡេងពិណរបស់គុត្តិលាចារ្យ ក៏កាន់តែពិរោះឡើង ៗ, ព្រះឥន្ទ្រចេះតែឱ្យបណ្តាច់ខ្សែម្តងមួយ ៗ ដរាបដល់អស់នៅសល់តែខ្សែមួយ, សំឡេងពិណ ក៏រឹងរឹតតែពិរោះឡើងជាអស្ចារ្យឮសូរគ្រលួចទៅឮដល់អាកាស, គ្របសង្កត់សំឡេងពិណរបស់មុសិលមាណព ដោយអំណាចឫទ្ធិរបស់ព្រះឥន្ទ្រ ។ ចំណែកឯមុសិលមាណព កាលបើបានឃើញគុត្តិ-លាចារ្យបណ្តាច់ខ្សែពិណនៅសល់តែមួយ ហើយមានសំឡេងពិរោះដូច្នោះ ក៏បណ្តាច់តាម, បណ្តាច់ខ្សែមួយអន់បន្តិច ពីរអន់បន្តិចដរាបដល់នៅតែខ្សែមួយ ក៏លែងឮជាបែបបទអ្វីសោះ ពួកមហាជនទាំងឡាយ ក៏ស្រែកហ៊ោឱ្យពរស័ព្ទសាធុការដល់គុត្តិលាចារ្យ មានសំឡេងគឹកកងហាក់ដូចជាទ្រុឌផែនដី ។ ពេលនោះព្រះបាទ

ព្រហ្មទត្តបានប្រើរាជអាមាត្យ ឱ្យយកច្រវាក់ទាក់កមុសិលមាណព អូសបញ្ចេញទៅខាងក្រៅទីប្រជុំ, ពួកមហាជនទាំងឡាយ ក៏ទាត់ធាក់វាយមុសិលមាណព ដរាបដល់ស្លាប់ក្នុងពេលនោះទៅ ។ ឯគុត្តិលាចារ្យក៏បាននូវរង្វាន់ក្នុងពេលនោះជាច្រើន, កាលបើព្រះបាទព្រហ្មទត្តបានបូជារង្វាន់ដល់គុត្តិលាចារ្យហើយ សក្កទេវរាជក៏ត្រឡប់ទៅស្ថានទេវលោកវិញ ។ ពួកទេវតាទាំងឡាយ នាំគ្នាចូលទៅសួរសក្កទេវរាជថា បពិត្រមហារាជអម្បាញ់មិញនេះ ស្ដេចយាងទៅទីណា ? ។ សក្កទេវរាជប្រាប់ថា ទៅមើលលោកអាចារ្យរបស់ខ្ញុំដេញពិណភ្នាល់នឹងមុសិលមាណពឯក្រុងពារាណសី ។ ពួកទេវតាទាំងឡាយបានដឹងថា ព្រះរាជារបស់ខ្លួន មានគ្រូអាចារ្យចេះដេញពិណដូច្នោះ ចង់ស្ដាប់ណាស់ ទើបនាំគ្នាអង្វរសក្កទេវរាជ សុំឱ្យអញ្ជើញគុត្តិលាចារ្យទៅដេញពិណឱ្យស្ដាប់ ។ ព្រះឥន្ទ្រ ក៏ប្រើមាតលិទេវបុត្រឱ្យយកវេជយន្តរតន៍ ចុះមកអញ្ជើញគុត្តិលាចារ្យទៅស្ថានត្រៃត្រឹង្ស ទៅដល់ពួកទេវបុត្រទេវធីតា ក៏នាំគ្នាមកចោមរោមជុំជិត ហើយអញ្ជើញឱ្យដេញពិណឱ្យស្ដាប់ ។ គុត្តិលាចារ្យនិយាយថា ខ្ញុំតាំងពីចេះពិណមក ពុំដែលដេញអត់ឈ្នួលទេ ព្រោះខ្ញុំតែងចិញ្ចឹមជីវិត ដោយសារតែថ្លៃឈ្នួលដេញពិណប៉ុណ្ណោះ ។ ព្រះឥន្ទ្របានឮហើយសួរថា លោកអាចារ្យត្រូវការរបស់អ្វី ? ខ្ញុំបូជា ។ គុត្តិលាចារ្យឆ្លើយថា ខ្ញុំមិនត្រូវការដោយទ្រព្យសម្បត្តិទេ ខ្ញុំសុំឱ្យ

ទេវបុត្រទេវធីតាទាំងនេះ ប្រាប់បុព្វកម្មរបស់ខ្លួនដល់ខ្ញុំសិន ចាំខ្ញុំដេញពិណឱ្យស្ដាប់ជាខាងក្រោយ ។ ពេលនោះទេវបុត្រទេវធីតាទាំងឡាយ ក៏ថ្លែងបុព្វកម្មរបស់ខ្លួន ប្រាប់ដល់គុត្តិលាចារ្យគ្រប់ៗគ្នា ទើបគុត្តិលាចារ្យដេញពិណឱ្យស្ដាប់ លុះចប់ហើយមាតលិទេវបុត្រក៏ជូនគុត្តិលាចារ្យមកមនុស្សលោកវិញ ។

## ៨. រឿងមាតុឃាតក

( ចាក ប. ធ. )

( បុរសក្នុងលោក មិនគួរជឿពាក្យភរិយាគ្រប់មាត់ )

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់នៅក្នុងដែនកាសី, កាលបើបិតាធ្វើមរណកាលហើយ ក៏ទំនុកបំរុងបំរើមាតាដោយគោរព, ឯមាតាបានឃើញកូនមានវត្តប្រតិបត្តិល្អ ក៏នាំស្ត្រីមានរូបស្រស់ប្រិមប្រិយម្នាក់ មករៀបចំឱ្យកូននោះ ។ ចំណែកខាងនាងនោះ បិតាស្លាប់ចោលតាំងពីក្មេង នៅសល់តែមាតា ទើបនាំមកនៅរួមក្នុងត្រកូលស្វាមី ហើយទំនុកបំរុងដល់មាតាទាំងពីរដោយគោរព ។ តមកខាងក្រោយ នាងក៏មានចិត្តនឿយណាយធុញទ្រាន់ចំពោះមាតាទាំងពីរ មានគំនិតអាក្រក់កើតឡើង គិតសម្លាប់ម្ដាយក្មេកចោល. បាននិយាយញុះញង់ស្វាមីថា ឥឡូវនេះយើងគិតសម្លាប់ម្ដាយយើងចេញ ព្រោះចាស់ចង្រៃនេះខុសអស់នឹងចាស់

ទាំងពួង តែងបន្ទោរបង់មូត្រលាមកដាក់ពេញផ្ទះសម្បែង ហើយ ប្រចាំលេងដូចកូនក្មេងទើបនឹងកើត. បើឯងមិនទៅពេលណា ហើយ គាត់ធ្វើបាបតែអញឱ្យវេទនារាប់មិនឈ្នះ, បើដូច្នេះយើងគិតសម្លាប់គាត់ទៅឬ ? ។ បុរសជាស្វាមី បានឮភរិយានិយាយរ៉ាយរ៉ាប់ប្រាប់ជាញយៗ ហើយក៏និយាយថា ការសម្លាប់មនុស្សនីមួយៗ មិនងាយទេក្រណាស់ ។ ភរិយានោះនិយាយតបវិញថា បពិត្រស្វាមី ការសម្លាប់នោះងាយទេ មើលតែគាត់ដេកលក់ យើងចងគ្រែសែងទៅទំលាក់ក្នុងស្ទឹងខាងក្រោយផ្ទះ ឱ្យឆ្លាមមករទំពារស៊ី ។ បុរសជាស្វាមីសួរថា ម្ដាយអញគាត់ដេកកន្លែងណា ? ម្ដាយឯងដេកកន្លែងណា ? ។ ភរិយាប្រាប់ថា ម្ដាយអ្នកសម្រាន្តខាងនេះ ម្ដាយខ្ញុំសម្រាន្តខាងនុះ ។ ស្វាមីប្រាប់ថាបើដូច្នោះ ចូរនាងចងគ្រែម្ដាយអញទុកឱ្យស្រេចទៅ ដល់យប់ជ្រៅយើងនឹងសែងទៅទំលាក់ក្នុងស្ទឹង ។ ភរិយាត្រេកអរណាស់ ក៏ធ្វើតាមបង្គាប់ស្វាមីហើយដេកលក់ទៅ ។ បុរសជាស្វាមី បានដឹងថាភរិយារបស់ខ្លួនដេកលក់ហើយ ក៏ចូលទៅស្រាយចំណងពីគ្រែម្ដាយខ្លួនចេញ យកខ្សែទៅចងគ្រែម្ដាយក្មេកវិញ លុះចងសព្វគ្រប់ហើយ ដើរចូលទៅដាស់ភរិយាថា នែ ! ក្រោកឡើងយើងលួមសែងជូនចាស់ទៅទំលាក់ចោលហើយ។ ជនទាំងពីរនាក់ ក៏ម៉ីម្នាសែងគ្រែយកទៅទំលាក់ក្នុងស្ទឹងខាងក្រោយផ្ទះ ដោយប្រញាប់ប្រញាល់ខ្លាចក្រែងជនទាំងឡាយមើលឃើញ ។

ពួកសត្វសាហាវទាំងឡាយមានធ្លាមមករជាដើម ក៏ផណ្ដើមប្រជែងគ្នាស៊ីយាយចាស់នោះអស់ទៅ ។ លុះព្រឹកឡើង នាងភរិយាបានដឹងច្បាស់ថា ម្ដាយខ្លួនស្លាប់ហើយ ក៏នឹកតូចចិត្តក្ដៅក្រហាយអន្ទះសាពន់ពេក ទើបប្រាប់ស្វាមីថា យើងគិតសម្លាប់ជូនចាស់មួយទៀត ។ បុរសជាស្វាមី ក៏ទទួលព្រមថាល្អហើយ ទើបនាំគ្នាទៅធ្វើថ្ករក្នុងព្រៃស្មសាន, ដល់យប់ជ្រៅម្ដាយដេកលក់ ក៏នាំគ្នាសែងទាំងគ្រែ យកទៅដាក់លើជើងថ្ករប្រារព្ធនឹងដុតភ្លើង, ជួនជាពេលនោះភ្លេចដាក់ភ្លើងទៅ ក៏នាំគ្នាត្រឡប់មកយកភ្លើងវិញ ។

កាលជនទាំងពីរនាក់ត្រឡប់មកផ្ទះវិញហើយ យាយចាស់នោះក៏ភ្ញាក់ឡើងក្រោកអង្គុយ ដោយត្រូវសន្សើមត្រជាក់ខ្លាំង, លុះមើលសព្វគ្រប់ដឹងខ្លួនថា គេយកមកសម្លាប់ ក៏ចុះចេញទៅបានយកសាកសពខ្មោចពពែមួយ ទៅដាក់លើគ្រែគ្របសំពត់ពីលើ ហើយគៀសខ្លួនចេញពីទីនោះ ដើរចូលទៅក្នុងគុហាមួយ, បានរំពឹងគិតថា ឱ ! អាត្មាអញ នឹកស្មានថាបានកូនប្រសាជាទីពឹង ឥឡូវនេះវាធ្វើអញឱ្យភ័យយ៉ាងក្រៃលែង ។ ចំណែកខាងបុរសប្ដីប្រពន្ធ យកភ្លើងបានមក ក៏ដុតសាកសពពពែនោះទៅ ដោយសំគាល់ថាជាម្ដាយរបស់ខ្លួនពិត ។ ឯគុហាដែលយាយចាស់ចូលទៅអង្គុយនោះ មានចោរម្នាក់យកបង្វិលមាសប្រាក់ ទៅលាក់ទុកក្នុងទីនោះជាច្រើន ។ យាយចាស់បានឃើញមាសប្រាក់នោះហើយ ក៏នឹកដល់កូនថា ឱ !

កូនសំឡាញ់អញ ប្រសិនបើបានមាសប្រាក់ច្រើនយ៉ាងនេះ ប្រហែលជាត្រេកអរីករាយណាស់. កំពុងតែគិតដូច្នេះស្រាប់តែចោរទៅដល់ ចោរនោះបានឃើញយាយចាស់ហើយ ក៏ភ្ញាក់ភិតភ័យញ័ររន្ធត់ មិនហ៊ានចូលទៅជិតឡើយ ដោយនឹកស្មានថាយក្ស ក៏ត្រឡប់មកវិញ បានហៅពេទ្យខ្មោចម្នាក់ឱ្យចូលទៅសង្កេតមើល. ពេទ្យខ្មោចនោះក៏រាយមន្តវិជ្ជាហើយដើរចូលទៅកាន់គុហា ។ ចំណែកខាងយាយចាស់បានឃើញពេទ្យខ្មោចនោះ ក៏និយាយថាយើងមិនមែនជាយក្សទេ អ្នកចូរចូលមក យើងទាំងពីរនាក់នឹងចែកទ្រព្យគ្នា ។ ពេទ្យខ្មោចនោះនិយាយថា យើងមិនជឿទេ ។ យាយចាស់ថាបើអ្នកឯងមិនជឿយើង ចូរអ្នកលៀនអណ្ដាតមកដាក់លើអណ្ដាតយើងចុះ នឹងដឹងច្បាស់ថាយើងជាមនុស្សពិត ។ ពេទ្យខ្មោច ក៏ធ្វើតាមពាក្យយាយចាស់នោះទៅ. យាយចាស់ក៏ខាំអណ្ដាតពេទ្យខ្មោចជាប់ដោយចង្កូមមួយយ៉ាងចំណាប់ ពេទ្យខ្មោចខំបម្រះរើរួចហើយ ក៏ស្រែកប្រាប់គ្នាថា យក្សទេវ៉ឺយ ! យក្សទេ ! ទើបនាំគ្នារត់ចេញទៅ ។ លុះដល់ភ្លឺច្បាស់ឡើងយាយចាស់ ក៏ប្រមូលមាសប្រាក់វេចស្ពាយយកទៅឱ្យកូន ។

ចំណែកខាងកូនប្រសារ ក្រឡេកឃើញម្ដាយស្ពាយបង្វិចទ្រព្យមកដូច្នោះ ក៏ចុះទៅទទួលរាក់ទាក់បដិសណ្ឋារៈគួរសមយ៉ាងអស្ចារ្យ ហើយនិយាយថា ឱ ! លោកម្ដាយគេយកទៅដុតក្នុងព្រៃ

ខ្មោចត្រឡប់ជាបានមាសប្រាក់មកឱ្យកូន. បើដូច្នោះខ្ញុំសូមឱ្យលោកម្ដាយ យកខ្ញុំទៅដុតម្ដងវិញ ខ្ញុំនឹងកើបវេចយកមាសប្រាក់ឱ្យច្រើនជាងនេះទៅទៀត ។ ស្ត្រីនោះ ជាស្ត្រីពាលកាឡកណ្ណីល្មោភចង់បានទ្រព្យមិនគិតវែងខ្លី បានឱ្យស្វាមីយកទៅដុតក្នុងព្រៃស្មសាន. ស្វាមីក៏នាំយកទៅដុតឆេះខ្មោចខ្លីស្លាប់ទៅកើតក្នុងនរកទៅ ។ ឯស្វាមីដល់អស់អាយុ ក៏ទៅកើតក្នុងនរកជាមួយគ្នា ។

## ៩. រឿងមហាល្លកចណ្ឌាលី

( ចាក វិ. ខុ. )

( ការចំរើនទន្ទូវពុទ្ធគុណ មានតម្លៃកាត់មិនបាន )

ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ស្ថិតនៅជាសុខក្នុងនិរោធសមាបត្តិ នាក្រុងរាជគ្រឹះ ។ ក្នុងពេលជិតភ្លឺ ព្រះអង្គទ្រង់ប្រមើលមើលនិស្ស័យរបស់សត្វដោយពុទ្ធចក្ខុ ទ្រង់បានឃើញស្រីចណ្ឌាលចាស់ម្នាក់ នៅក្នុងចណ្ឌាលគ្រាម នាក្រុងរាជគ្រឹះនោះ ជាស្ត្រីល្ងង់អាប់ឥតប្រាជ្ញា តាំងតែពីកើតមកដរាបដល់ចាស់ជរា ពុំដែលបានធ្វើកុសលណាមួយឡើយ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិតម្យ៉ាង, កាលបើស្លាប់ហើយ នឹងធ្លាក់ទៅកើតក្នុងមហានរកពុំខាន. លុះទ្រង់ជ្រាបដូច្នេះហើយ ក៏មានព្រះទ័យករុណាចំពោះយាយចណ្ឌាលនោះពន់ពេក. ដល់ភ្លឺច្បាស់ឡើង ក៏ទ្រង់ចាត្រចីវរនាំភិក្ខុសង្ឃជាច្រើនអង្គ

មានព្រះមោគ្គល្លានជាដើម ចរចូលទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាម នោះ ។ យាយចណ្ឌាល កំពុងតែដើរទប់ខ្លួននឹងឈើច្រត់តាមមាគ៌ា, ព្រះភគវាទ្រង់ឈរវាំងផ្លូវ ពុំឱ្យយាយចណ្ឌាលនោះដើរទៅទីដទៃបានឡើយ ។ ព្រះមោគ្គល្លានបានជ្រាបហេតុនោះហើយ ក៏ប្រាប់យាយចណ្ឌាលថា នែ ! យាយព្រឹទ្ធា យាយអញ្ជើញទៅណា ? ចូរថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូសិន, ការដែលបានជួបនឹងព្រះបរមគ្រូនេះ ប្រសើរពេកណាស់ ព្រោះព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងសព្វដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅដាស់តឿនព្រះអង្គឡើយ, ព្រះអង្គមានព្រះទ័យករុណាអាណិតដល់យាយ ទើបទ្រង់និមន្តមក ដើម្បីឱ្យយាយបានសេចក្ដីសុខចំរើន ទៅកើតក្នុងស្ថានសួគ៌, ចូរយាយគ្រេកអរចំពោះព្រះសម្ពុទ្ធបរមគ្រូចុះ ។ យាយចណ្ឌាលលើកដៃឡើងបាំងថ្ងាស អើតមើលព្រះភក្ត្រព្រះសម្ពុទ្ធ សេចក្ដីជ្រះថ្លាកើតឡើង ក៏អង្គុយដាក់ឈើច្រត់ក្បែរខ្លួនហើយថ្វាយបង្គំដោយសេចក្ដីជ្រះថ្លា មានពុទ្ធានុស្សតិជាអារម្មណ៍។ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា យាយចណ្ឌាលនេះអស់អាយុហើយ ត្រូវស្លាប់ក្នុងពេលឥឡូវនេះ កាលបើស្លាប់ហើយនឹងបានទៅកើតក្នុងស្ថានតាវតឹង្សពុំខាន, លុះជ្រាបដូច្នេះហើយ ក៏និមន្តហួសទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាមនោះទៅ ។ ឯយាយចណ្ឌាល ក៏ក្រោកដើរទៅផ្ទះ មានចិត្តស្ថិតនៅក្នុងពុទ្ធគុណជាឯកគ្គតារម្មណ៍ ។ ក្នុងពេល

នោះ មានមេគោមួយមានកូនខ្ចី បានឃើញព្រះសម្ពុទ្ធនិងព្រះសង្ឃ ក៏ផ្អើលស្ទុះទៅជាន់យាយចណ្ឌាលនោះស្លាប់ទៅ ។ យាយចណ្ឌាល ក៏បានទៅកើតក្នុងវិមានមាសកំពស់ ១២ យោជន៍ នាស្ថានតាវតឹង្ស ទេវលោក សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្ត ។

## ១០. រឿងសុជាតកុមារ

( ចាក សុ. ប. )

( អ្នកតូចគួរទូន្មានអ្នកធំ ដោយឧបាយកល )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី, កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិក្នុងត្រកូលកុដុម្ពីក៏ មាននាមបញ្ញត្តិថា សុជាតៈ បានសិក្សាសិល្បសាស្ត្រចេះសព្វគ្រប់ហើយ ក៏ទំនុកបំរុងបំរើមាតាបិតាដោយគោរព ។

ថ្ងៃមួយជីតារបស់សុជាតកុមារ អនិច្ចកម្មទៅ, កុដុម្ពីក៏ជាបិតារបស់សុជាតកុមារ មានសេចក្តីសោកស្តាយ វិយោគយំរៀបរាប់ អាល័យចំពោះបិតានោះក្រៃពេក, លុះធ្វើឈាបនកិច្ចបូជាសពរួចហើយ រើសប្រមូលឆ្អឹងខ្ចប់នឹងកំណាត់សំពត់ យកទៅបញ្ចុះទុកក្នុងស្តូប ដែលសាងទុកក្នុងសួនដំណាំខាងក្រោយផ្ទះរបស់ខ្លួន ។ រាល់តែថ្ងៃ បិតារបស់សុជាតកុមារ តែងទៅធ្វើកិច្ចគោរពបូជាស្តូប

នោះដោយមែកឈើ ផ្កាឈើផ្សេងៗ ហើយដើរប្រទក្សិណយំរៀបរាប់សោកស្តាយជាអនេកប្បការ រូបកាយរបស់គាត់ ក៏ក្រៀមក្រមសៅហ្មងដោយទឹកភ្នែក ដេកមិនលក់បក់មិនល្ហើយ ភ្លេចបាយភ្លេចទឹក ការងារទាំងពួង ក៏អាក់ខានឈប់ធ្វើអស់ ។ សុជាតកុមារ បានឃើញវិប្បការៈរបស់បិតាខុសប្រក្រតីដូច្នោះហើយ ក៏គិតថា បិតាអញតាំងពីលោកតាអនិច្ចកម្មទៅ មានតែសេចក្តីទុក្ខសោកសៅតែម្យ៉ាង, មនុស្សដទៃក្រៅពីអាត្មាអញមិនមាននរណាមួយ អាចជួយដោះទុក្ខគាត់បាន តើអញនឹងរកឧបាយកលដូចម្តេច នឹងរំលត់សេចក្តីទុក្ខរបស់គាត់ ។ សុជាតកុមារ ខំគិតរកឧបាយជាច្រើនថ្ងៃ, ថ្ងៃមួយចេញអំពីផ្ទះទៅក្រៅភូមិ បានឃើញគោស្លាប់មួយ ដែលគេអូសយកទៅចោល, ឧបាយដែលគិតទុកយូរហើយ ក៏លេចប្រាកដឡើង ទើបទៅយកស្មៅនិងទឹក មកដាក់ក្បែរមាត់ខ្មោចគោនោះ, កាលបើឃើញជនណាមួយដើរទៅជិត ក៏តាំងយំសោកនិយាយអង្វរខ្មោចគោនោះថា នែសំឡាញ់ ! ចូរក្រោកឡើង ! ស៊ីស្មៅផឹកទឹកទៅ កុំដេកយូរពេក ។ មនុស្សទាំងឡាយឃើញដូច្នោះហើយសង្ស័យណាស់ ទើបសួរថា លោកសុជាត ! ពីពេលមុន ខ្ញុំស្គាល់លោកច្បាស់ថា ជាអ្នកប្រាជ្ញ ជាមនុស្សល្អត្រឹមត្រូវ ថ្ងៃនេះខ្ញុំមើលទៅលោក ហាក់ដូចជាមនុស្សវិកលចរិត ។ សុជាតកុមារ មិនអើពើនឹងពាក្យសំដីរបស់មហាជនឡើយ នៅតែធ្វើអាការៈដូច្នោះយ៉ាង

ព្រងើយកន្តើយ ហាក់ដូចជាមិនដឹងមិនឮ ។ កិច្ចការដែលសុជាតកុមារប្រព្រឹត្តធ្វើទាំងប៉ុន្មាន ក៏ឮរន្ទឺសុះសាយពេញពាសទីក្រុងទាំងមូល ។ ជនជាញាតិមិត្របងប្អូន បានឮដំណឹងនោះហើយ ក៏ទៅប្រាប់ដល់កុដុម្ពីក៏ជាបិតាថា លោកកុដុម្ពីក៏ ! កូនរបស់លោកវិកលចរិតហើយ បានយកទឹកនិងស្មៅទៅដាក់ក្បែរមាត់គោស្លាប់មួយខាងក្រៅភូមិ ហើយយំសោករៀបរាប់ ហៅខ្មោចគោនោះឱ្យក្រោកស៊ីស្មៅផឹកទឹក, លោកមិនដឹងទេឬ ? ។ កុដុម្ពីក៏បានឮដូច្នោះហើយ ទើបហៅកូនមកសួរថា កូនសំឡាញ់បិតា ! បិតាឮថាកូនឯងយំសោកអាឡោះអាល័យចំពោះគោស្លាប់ ដែលគេអូសទៅចោលខាងក្រៅភូមិមែនឬ ?, បាទ ! ខ្ញុំធ្វើយ៉ាងហ្នឹងមែនលោកឪពុក, ឱកូនសំឡាញ់ ! ហេតុអ្វីក៏ឆោតម្ល៉េះ បិតាសូមសួរកូនបន្តិច កូនទឹកឃើញដូចម្តេច ? បានជាយកស្មៅនិងទឹកទៅដាក់ក្បែរមាត់គោស្លាប់ ហើយយំសោករៀបរាប់អង្វរគោឱ្យស៊ីស្មៅផឹកទឹក ? ធ្វើដូច្នេះមិនមែនជាលក្ខណៈរបស់បណ្ឌិតទេ ជាអំពើប្រាសចាកប្រយោជន៍ទាំងពួង ។ សុជាតកុមារបានស្តាប់បិតានិយាយដូច្នេះហើយ មានសេចក្តីត្រេកអរណាស់ដោយនឹកឃើញថា ឱកាសនេះសមគួរហើយ, ទើបនិយាយដោយវាចារទន់ភ្លន់តបពាក្យបិតាថា បាទលោកឪពុក ! ការដែលខ្ញុំធ្វើនោះ ខ្ញុំសូមទទួលកំហុសទាំងអស់ ព្រោះជាអំពើរបស់មនុស្សអន់ទន់ខ្សោយ គ្មានវិចារណញ្ញាណ,

ធម្មតាគោស្លាប់ហើយ អវយវៈគ្រប់ចំណែក ក៏ស្លាប់ទៅព្រមគ្នាមិន
អាចកំរើកបានឡើយ, ប៉ុន្តែគោដែលស្លាប់នោះ នៅមានរូបប្រាកដ
មើលឃើញច្បាស់ គួរឱ្យអាឡោះអាល័យបាន ។ ខ្ញុំសូមសួរលោក
ឱពុកបន្តិចថា ការដែលលោកឪពុកយំសោកអាឡោះអាល័យលោក
តា ដែលអនិច្ចកម្មទៅនៅសល់តែឆ្អឹង បញ្ចុះក្នុងចេតិយ ឥតឃើញ
រូបប្រាកដដល់ភ្នែក សូម្បីត្រឹមតែអវយវៈណាមួយ ក៏មើលមិនឃើញ
នោះ, តើលោកតានឹងត្រឡប់រស់ឡើងវិញដោយការយំសោករបស់
លោកឪពុកនោះឬ ? សូមលោកឪពុកពិនិត្យមើល តើអំពើរបស់ខ្ញុំ
និងលោកឪពុកខាងណាគ្រាន់បើជាង ? ។ កុដុម្ពីក៏ បានស្តាប់ពាក្យ
សំដីដែលសមហេតុសមផល របស់បុត្រហើយក៏គិតថា កូនរបស់
អញជាបណ្ឌិត មានប្រាជ្ញាអាចជួយដោះទុក្ខរបស់អញបានដោយ
ឧបាយដ៏ប្រសើរ, ទើបនិយាយនឹងកូនថា ម្នាលសុជាត ! ឪពុកត្រេក
អរណាស់ អ្នកបានគិតរកឧបាយបង្ហាញឪពុកឱ្យដឹងច្បាស់ នូវការ
មិនទៀងរបស់សង្ខារបានដោយជាក់ច្បាស់, ចាប់តាំងពីពេលនេះ
ទៅ ឪពុកអស់សេចក្តីទុក្ខសោកអាឡោះអាល័យទៀតហើយ ។
បិតារបស់សុជាតកុមារ ក៏អស់សេចក្តីសោកចំពោះបិតាតាំងពីថ្ងៃ
នោះទៅ ។

# ១១. រឿងនាងកេសការី

( ចាក វិ. ឧ. )

( គុណនៃការរក្សាសីល ៥ នឹងចំរើនអាការៈ ៣២ )

កាលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវន នាក្រុងពារាណសី ជាមួយនឹងភិក្ខុសង្ឃច្រើនរយអង្គ ។ កាលនោះក្នុងក្រុងពារាណសី មានធីតាមួយរូបឈ្មោះកេសការី កំពុងអង្គុយរកចៃឱ្យមាតាក្នុងផ្ទះ បានឃើញភិក្ខុសង្ឃ ចូលទៅបិណ្ឌបាតក៏និយាយប្រាប់មាតាថា បពិត្រអ្នកម្តាយ ភិក្ខុសង្ឃដែលគង់នៅក្នុងព្រៃឥសិបតនមិគទាយវន បានចូលមកបិណ្ឌបាត្រក្នុងភូមិរបស់យើង ភិក្ខុទាំងនោះនៅក្មេងៗ កំពុងពេញកំឡោះមានរូបស្អាតផូរផង់ល្អ ហេតុដូចម្តេចបានជានាំគ្នាបួស ដើរសុំគេយ៉ាងនេះ ? លោកមានប្រាថ្នាដូចម្តេច ? ។ មាតានិយាយប្រាប់ថា លោកបួសយកបុណ្យ កុំសួរអ្វីគិតតែរកចៃទៅ ។ ក្នុងពេលនោះមានឧបាសកម្នាក់ សម្រេចដល់សោតាបត្តិផល កំពុងដើរនៅមុខផ្ទះ បានឮនាងព្រាហ្មណីនិយាយនឹងកូនក្រមុំដូច្នោះ ក៏ឡើងទៅលើផ្ទះនោះ។ នាងព្រាហ្មណីនិងកូនក្រមុំ បានឃើញឧបាសកឡើងលើផ្ទះខ្លួនដូច្នោះហើយ ក៏រៀបចំអាសនៈឱ្យអង្គុយ, ទើបនាងកេសការីជាកូន សួរទៅឧបាសកនោះថា បពិត្រលោកអ៊ុំ ភិក្ខុសង្ឃដែលនិមន្តបិណ្ឌបាត្រអម្បាញ់មិញនេះ នៅក្មេងៗ កំពុងពេញកំឡោះ មានរូបស្អាតបាត អង្គខ្លះ

ប្រហែលជាកូនគហបតី សេដ្ឋីឬក៏ព្រះរាជបុត្ររបស់ក្សត្រិយ៍អង្គណាមួយក៏មិនដឹង, លោកគិតឃើញដូចម្ដេចបានជាទៅបួស ៗ ប្រាថ្នាអ្វី ? ខ្ញុំសង្ស័យណាស់ ។ ឧបាសកប្រាប់ថា ម្នាលនាងក្រមុំ ភិក្ខុសង្ឃទាំងអស់នេះ លោកប្រាថ្នាឱ្យរួចចាកទុក្ខក្នុងវដ្ដសង្សារ ព្រោះលោកពិចារណាឃើញច្បាស់នូវទោសរបស់វត្ថុកាម និង កិលេសកាម និងឃើញច្បាស់នូវអានិសង្សរបស់បព្វជ្ជា ព្រោះបព្វជ្ជានេះ មានគុណខ្ពង់ខ្ពស់បំផុត អាចធ្វើសត្វឱ្យឆាប់រួចពីការកើតចាស់ឈឺស្លាប់បាន, សំដែងដូច្នេះហើយ ក៏សរសើរអំពីអានិសង្សត្រៃសរណគមន៍ និងសីល៥ តទៅទៀត លុះចប់ហើយនាងកេសការី សួរឧបាសកនោះទៀតថា លោកអុំ ! បើខ្ញុំដល់នូវត្រៃសរណគមន៍ ហើយរក្សាសីល ៥ តើបានអានិសង្សដូចលោកអុំមានប្រសាសន៍ដែរឬ ? ឧបាសកឆ្លើយថា ប្រសើរវិសេសណាស់នាង ! ព្រោះធម៌របស់ព្រះសម្ពុទ្ធមិនរើសថាក្មេងចាស់ទេ ។ នាងក៏សូមសមាទានសីល ៥ អំពីឧបាសកនោះ ហើយសួរថា កិច្ចដែលខ្ញុំត្រូវធ្វើមានដូចម្ដេចទៀត ? ។ ឧបាសកប្រាប់ថា កិច្ចដទៃក្រៅពីនេះមានច្រើនណាស់ ប៉ុន្តែនាងចូរពិចារណានូវទ្វត្តឹសាការកម្មដ្ឋានជានិច្ចរាល់ថ្ងៃចុះ ដើម្បីឱ្យបានអានិសង្សច្រើន ។ ឧបាសកបានពន្យល់អាការៈ ៣២ ប្រការ និងវិធីពិចារណាដោយពិស្ដារហើយ ក៏លានាងទាំងពីររូបទៅគេហដ្ឋានរបស់ខ្លួនទៅ ។ ឯនាងកេសការី

កូនក្រមុំរបស់នាងព្រាហ្មណីនោះ ជាស្ត្រីមានឧប្បនិស្ស័យចាស់ក្លា គ្រាន់តែបានពិចារណានូវអាការៈ ៣២ ក្នុងថ្ងៃនោះ ក៏បានសំរេចដល់សោតាបត្តិផល ។ ក្នុងកាលជាខាងក្រោយមក នាងអស់អាយុក៏បានទៅកើតក្នុងវិមានកែវពិទូរ្យកំពស់ ៣០ យោជន៍ នាស្ថានត្រៃត្រឹង្ស បានជាអគ្គមហេសីរបស់ព្រះឥន្ទ្រាធិរាជ, នាងមានស្រីទេពអប្សរមួយសែន ចោមរោមជាបរិវារ មានពន្លឺផ្សាយចេញអំពីកាយដ៏រុងរឿង ដូចជាពន្លឺព្រះចន្ទ្រ បរិបូណ៌ដោយទិព្វសិរី ស្ថិតនៅក្នុងទេវលោកជាសុខក្សេមក្សាន្ត ។

## ១២. រឿងកែវមរកត

( ចាក រ. វ. )

( ព្រះកែវមរកត ជាមរកតរបស់ប្រទេសកម្ពុជា )

ព្រះកែវមរកត កើតឡើងក្នុងព.ស.៥០០ កើតដោយអានុភាពរបស់ព្រះនាគសេនត្ថេរជាព្រះអរហន្ត ដែលគង់នៅក្នុងអសោការាម នាក្រុងបាតលីបុត្ត ដែនមគធៈ ។ ព្រះអរហន្តអង្គនេះ មានបំណងចង់កសាងព្រះពុទ្ធបដិមាករ, បំណងនោះក៏បានជ្រាបដល់ព្រះឥន្ទ្រ ១ ទ្រង់ជ្រះថ្លាក្នុងការកសាងនោះដែរ ទើបត្រាស់ប្រើវិស្សកម្មទេវបុត្រ ឱ្យទៅយកកែវមណីជោតិ នៅភ្នំវេបុល្ល ដែលពួកកុម្ភណ្ឌថែរក្សា ។ ពួកកុម្ភណ្ឌ មិនហ៊ានថ្វាយកែវមណីជោតិនោះ

ឡើយ ដោយខ្វាចក្រែងមានស្ដេចចក្កពត្រាធិរាជកើតឡើង មិនបាន យកកែវមណីជោតិទៅថ្វាយនឹងបែកក្បាលជា ៧ ភាគ ។ វិស្សកម្ម ទេវបុត្រ ក៏ត្រឡប់ទៅក្រាបទូលព្រះឥន្ទ្រវិញតាមដំណើរ ។ ព្រះឥន្ទ្រ កាលបើមិនបាននូវកែវមណីជោតិនោះហើយ ទើបស្ដេច យាងទៅកាន់ភ្នំវេបុល្លជាមួយនឹងវិស្សកម្មទេវបុត្រ ។ ពួកកុម្ភណ្ឌ ទាំងឡាយ ក៏ក្រាបទូលតាមហេតុដែលថ្វាយមិនបាន ។ ព្រះឥន្ទ្រ បានសួររកកែវដទៃទៀត ដែលល្អបន្ទាប់នឹងកែវមណីជោតិ ។ កុម្ភណ្ឌក្រាបទូលថា មានកែវមរកតមួយដុំ ពណ៌ដូចត្រួយចេក នៅ បាទភ្នំវេបុល្ល ជាកែវឥម្ចាស់ ។ ព្រះឥន្ទ្រ ក៏ប្រើពួកកុម្ភណ្ឌឱ្យទៅយក កែវមរកតនោះមកថ្វាយ លុះបានហើយ ទើបយកទៅប្រគេនព្រះ នាគសេនត្ថេរ ។ មិនអាចរកជាងឆ្លាក់បានឡើយ ព្រោះកែវនោះរឹង ពេក ។ ព្រះឥន្ទ្របានជ្រាបដំណឹងនោះ ក៏ប្រើវិស្សកម្មទេវបុត្រឱ្យទៅ ឆ្លាក់ប្រគេន ដោយហេតុវិស្សកម្មទេវបុត្រ ធ្លាប់ឃើញព្រះសម្ពុទ្ធ កាលគង់ព្រះជន្មនៅ អាចឆ្លាក់ព្រះពុទ្ធរូប មានលក្ខណៈប្រហែល នឹងតួអង្គព្រះសម្ពុទ្ធដោយច្រើន ។ ព្រះពុទ្ធរូបព្រះកែវមរកតនោះ មានកំពស់មួយហត្ថ ៧ ធ្នាប់ ព្រះភ្នែន ២៣ ធ្នាប់ ។ ព្រះនាគសេន ត្ថេរ បានបញ្ចុះព្រះបរមធាតុ ៧ អង្គ ទៅក្នុងព្រះកែវមរកតនោះគឺ បញ្ចុះនៅព្រះសិរ ១ អង្គ, ព្រះនលាដ ១ អង្គ, ព្រះឧរា ១ អង្គ, ព្រះ អង្សាស្មាស្ដាំ ១ អង្គ, ឆ្វេង ១ អង្គ, ព្រះជង្ឃស្មងស្ដាំ ១ អង្គ, ឆ្វេង

១ អង្គ. លុះកសាងហើយស្រេច ពុទ្ធបរិស័ទទាំងឡាយមានព្រះនាគសេនត្ថេរជាប្រធាន បានចាត់ចែងធ្វើមណ្ឌប ប្រតិស្ឋានព្រះកែវ-មរកតនោះ នៅក្រុងបាតលីបុត្រ ហើយមានការសម្ពោធ អភិសេកជាឱឡារិក ។ តមក ក្នុងរជ្ជកាលព្រះបាទសិរិកិត្តិរាជរវាង ព.ស. ១០០០, ប្រទេសមគធៈកើតចលាចលបះបោរជណ្ដើមរាជសម្បត្តិ, ឯព្រះពុទ្ធសាសនា ក៏រៀវរោយថយចុះជាច្រើន ទើបមានពុទ្ធបរិស័ទមួយក្រុម និមន្តព្រះកែវមរកតចុះសំពៅបើកសំដៅទៅកោះលង្កា ដោយបំណងយកព្រះកែវមរកតទៅទុកនៅទីនោះ ឱ្យផុតពីកណ្ដាប់ដៃពួកជនមិច្ឆាទិដ្ឋិ, ទៅដល់កោះលង្កា ពុទ្ធបរិស័ទទាំងឡាយមានព្រះមហាក្សត្រិយ៍ និងព្រះសង្ឃបរិនាយកជាដើម បានទទួលព្រះកែវមរកត ហែរទៅប្រតិស្ឋាននៅវត្តមេឃគីរីមហាវិហារ ដែលជាវត្តសំខាន់បំផុតក្នុងទីក្រុង ។ ពេលនោះព្រះពុទ្ធសាសនានៅកោះលង្កា រុងរឿងជាងនានាប្រទេស មានគម្ពីរព្រះត្រៃបិតកគ្រប់គ្រាន់បរិបូណ៌ទាំងបែបភាសាបាលីទាំងភាសាលង្កា ។ តមកក្នុងព.ស. ១៥៦០ ប្រទេសភូមាមានព្រះមហាក្សត្រិយ៍មួយអង្គព្រះនាមអនុរុទ្ធជាអគ្គពុទ្ធសាសនូបត្ថម្ភ ក៏ទ្រង់បានជ្រាបថា នៅកោះលង្កា មានព្រះត្រៃបិតកចប់បរិបូណ៌ ទើបទ្រង់ឱ្យតាក់តែងសំពៅពីរ ហើយស្ដេចយាងចុះសំពៅទៅលង្កាទ្វីប ជាមួយនឹងអ្នកប្រាជ្ញច្រើនរូបមានទាំងបព្វជិតទាំងគ្រហស្ថ ដើម្បីចម្លងព្រះត្រៃបិតក, លុះទៅ

ដល់កោះលង្កាហើយ ស្តេចយាងចូលទៅគាល់ព្រះចៅកោះលង្កា, ព្រះនាមលង្កិស្សររាជ ។ ព្រះចៅកោះលង្កា ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងខ្ពង់ខ្ពស់ លុះទទួលបដិសណ្ឋារកិច្ចរួចហើយ ស្តេចយាងទៅថ្វាយបង្គំព្រះសង្ឃបរិនាយក នៅវត្តមេឃគីរីមហាវិហារ សុំចម្លងព្រះត្រៃបិដក ជាភាសាបាលីមួយចប់, ភាសាលង្កាមួយចប់, ចម្លងស្រេចហើយព្រះបាទអនុរុទ្ធ ទ្រង់សុំព្រះកែវមរកតយកទៅប្រតិស្ឋានទុកនៅប្រទេសភូមាជាទីរលឹក ។ ព្រះបាទលង្កិស្សររាជ បានថ្វាយព្រះកែវមរកតដល់ព្រះបាទអនុរុទ្ធតាមសេចក្តីសុំ ទើបព្រះបាទអនុរុទ្ធត្រាស់បង្គាប់ឱ្យជញ្ជូនព្រះត្រៃបិតកភាសាបាលីដាក់សំពៅមួយ, ព្រះត្រៃបិដកភាសាលង្កានិងព្រះកែវមរកតដាក់សំពៅមួយ, ចំណែកព្រះអង្គគង់សំពៅដែលដាក់ព្រះត្រៃបិដកភាសាបាលី ។ សំពៅទាំងពីរបានបើកចេញពីកោះលង្កា សំដៅទៅប្រទេសភូមា ដល់ពាក់កណ្តាលមហាសាគរ សំពៅដែលដឹកលព្រះត្រៃបិដកភាសាលង្កានឹងព្រះកែវមរកត ត្រូវខ្យល់ព្យុះបោកបក់រសាត់មកជាប់នៅត្រើយសមុទ្រត្រង់ជាយខែត្របន្ទាយមាស នៃប្រទេសកម្ពុជាភាគខាងត្បូងរាជការខែត្របន្ទាយមាស ចាប់សំពៅនោះបាន ទើបនាំយកគម្ពីរព្រះត្រៃបិដក និងព្រះកែវមរកតទៅថ្វាយព្រះបាទសូរ្យវង្សទី១ នៅក្រុងស្រីសោធរបុរៈ, ទ្រង់ស្តេចទតឃើញព្រះកែវមរកតនោះទ្រង់សោមនស្សណាស់ បានឱ្យសាងវិហារមួយដំកល់ទុក ខាងក្នុងព្រះ

បរមរាជវាំង ។ ថ្ងៃក្រោយព្រះបាទអនុរុទ្ធបានជ្រាបដំណឹង ទើបប្រើរាជបំរើឱ្យនាំសារមកសុំយករបស់ទាំងនោះទៅវិញ ។ ព្រះបាទសូរ្យវង្សទី១ បានប្រគល់តែព្រះត្រៃបិដកឱ្យវិញ ទ្រង់ទុកព្រះកែវមរកត ពុំបានថ្វាយដល់ព្រះបាទអនុរុទ្ធព្រះចៅភូមាឡើយ ព្រោះទ្រង់សព្វព្រះរាជហឫទ័យសោមនស្សជ្រះថ្លា ចំពោះព្រះកែវមរកតនោះក្រៃពេក ។

ព្រះកែវមរកត ក៏បានមកជាមតកប្រទេសកម្ពុជាក្នុងវេលានោះដោយសិរី ឥតបានដឹងបានប្រាថ្នា ឬសូមអំពីសំណាក់បុគ្គលណាឡើយ ។

## ១៣~ រឿងបល្ល័ង្កអណ្តែត

( ចាក វិ. ខុ. )

( សទ្ធាជាពូជ នៃសិរីក្នុងលោក )

ក្នុងពុទ្ធកាល, ព្រះមហាមោគ្គល្លានត្ថេរ បាននិមន្តទៅស្ថានត្រៃត្រឹង្សទេវលោក បានឃើញពួកទេវតាទាំងឡាយ កំពុងនាំគ្នាលេងមហោស្រពក្នុងនន្ទវនឧទ្យាន, មួយស្របក់ស្រាប់តែឃើញបល្ល័ង្កមាសកំពស់ ១ យោជន៍ អណ្តែតក្នុងអាកាស មានល្បឿនលឿនក្រៀវក្រៃ សំដៅចុះមកក្នុងនន្ទវនឧទ្យាន ។ បល្ល័ង្កនោះសណ្ឋានជាបុស្បុក មានស្រីទេពអប្សរមួយពាន់ អង្គុយចោមរោម

នាងទេពធីតាម្នាក់លើបល្ល័ង្កនោះ ។ នាងទេពធីតាជាម្ចាស់បល្ល័ង្កអណ្តែកនោះ មានរូបឆោមល្អស្រស់ប្រិមប្រិយ មានពន្លឺភ្លឺចេញអំពីកាយដូចជាព្រះចន្ទ្រពេញវង់ នាងទ្រទ្រង់នូវគ្រឿងអលង្ការទម្ងន់ ៦០ រទេះ បានឃើញព្រះមោគ្គល្លានហើយ នាងមានសេចក្តីជ្រះថ្លារីករាយឥតឧបមា បាននាំស្រីទេពអប្សរជាបរិវារទាំងមួយពាន់ ចុះពីបល្ល័ង្កទៅថ្វាយបង្គំនមស្សការព្រះមហាមោគ្គល្លានត្ថេរ ។ មានថេរដីកាសួរថា ម្នាលនាងទេពធីតា អ្នកមានកាយរុងរឿងដូចជាព្រះចន្ទ្រពេញវង់ ទ្រទ្រង់នូវគ្រឿងអលង្ការទិព្វទម្ងន់ ៦០ រទេះ មានកេសាព័ទ្ធព័ន្ធប្រទាក់ផ្ទាក់ដោយភួងផ្កា កាលពីជាតិមុន នាងបានធ្វើបុណ្យដូចម្តេចខ្លះ ? ។ នាងទេពធីតា ថ្លែងរៀបរាប់ប្រវត្តិរបស់នាង ប្រាប់ដល់មហាមោគ្គល្លានត្ថេរថា បពិត្រលោកម្ចាស់ដ៏ចំរើន កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅក្នុងវត្តជេតពន, សម័យនោះមានភិក្ខុមួយរូប ជាអ្នករក្សាធុតង្គ បាននិមន្តចូលទៅបិណ្ឌបាត្រក្នុងក្រុងសាវត្ថី ។ កាលនោះខ្ញុំព្រះករុណាកើតជាធីតាក្នុងត្រកូលមួយ នៅក្នុងក្រុងសាវត្ថីនោះដែរ, បានឃើញភិក្ខុនោះកំពុងនិមន្តបិណ្ឌបាតក៏មានចិត្តត្រេកអររីករាយឥតឧបមា បាននិមន្តលោកចូលទៅក្នុងគេហដ្ឋាន ហើយចាត់ចែងរៀបគ្រែតូចមួយជាអាសនៈ បានយកសំពត់កម្ពលពណ៌លឿង ទៅក្រាលលើគ្រែនោះជាគ្រឿងលំអ លុះក្រាលហើយ និមន្តភិក្ខុនោះឱ្យគង់, ខ្ញុំព្រះករុណាក៏ម្នីម្នាទៅចាត់

ចែងភោជនាហារ យកទៅប្រគេនលោកឆាន់ ហើយបានកាន់ផ្តិត ចូលទៅអង្គុយបក់ប្រគេនលោកទៀត លុះភិក្ខុនោះឆាន់ហើយ សំដែងនូវភត្តានុមោទនាចប់ ក៏និមន្តទៅវត្តជេតពនទៅ ។ ខ្ញុំព្រះករុណា បានរំពឹងពិចារណានូវទានដែលបានធ្វើហើយ សទ្ធាគឺសេចក្តីជ្រះថ្លា ក៏កាន់តែកើតឡើងជាភិយ្យោភាព, ខ្ញុំព្រះករុណាជ្រះថ្លាខ្លាំងពេក បានយកគ្រែដែលរៀបតាក់តែងដោយសំពត់កម្ពលនោះ ទៅតាមប្រគេនលោកដល់វត្តទៀត ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំព្រះករុណាអស់អាយុ ក៏បានមកកើតក្នុងវិមានមាសកំពស់ ១២ យោជន៍ មានស្រីទេពអប្សរមួយពាន់ជាបរិវារ មានបល្លង្កមាសមួយកំពស់ ១ យោជន៍ កើតឡើងក្នុងវិមាននោះ សំរាប់ជាយានរបស់ខ្ញុំព្រះករុណា, បល្លង្កនោះមានសន្ទុះលឿនស្មើនឹងចិត្ត បើចិត្តរបស់ខ្ញុំព្រះករុណានឹកចង់ទៅទីណា ក៏អណ្តែកទៅដល់ទីនោះមួយរំពេច ។ ព្រះមោគ្គល្លានបានស្តាប់ប្រវត្តិរបស់នាងទេពធីតានោះចប់ហើយ ក៏និមន្តហួសទៅកាន់ទីដទៃទៀតទៅ ។

## ១៤. រឿងសសបណ្ឌិត

( ចាក ស. ច. )

( បើមានបំណងធំ គួរកុំស្តាយជីវិតនិងទ្រព្យសម្បត្តិ )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូ ទ្រង់សោយព្រះជាតិជាសត្វទន្សាយ នៅអាស្រ័យក្នុងដងព្រៃមួយ. ក្នុងព្រៃនោះមានស្វា១. ចចក១. ភេ១. ជាសំឡាញ់នឹងគ្នា បាននៅរួមជាមួយនឹងទន្សាយ សុទ្ធតែជាបណ្ឌិតគឺជាសត្វចេះដឹង តែងនាំគ្នាស្វែងរកអាហារតាមគោចរស្ថានរៀងៗ ខ្លួន ដល់ពេលល្ងាចទើបមកជួបជុំគ្នា ។ ចំណែកសសបណ្ឌិតគឺទន្សាយ តែងពន្យល់ធម៌ដល់សត្វទាំងបីថា អ្នករាល់គ្នាត្រូវធ្វើទាន រក្សាសីលធ្វើឧបោសថកម្មកុំខាន ។ សត្វទាំងបី ក៏ព្រមទទួលប្រតិបត្តិតាមឱវាទរបស់ទន្សាយគ្រប់ៗគ្នា ។ ថ្ងៃមួយទន្សាយក្រឡេកមើលទៅឰដ៏អាកាស បានឃើញព្រះចន្ទ្រះពេញវង់ ភ្លឺស្វាងចែងក្នុងនភាល័យ ក៏ដឹងច្បាស់ថា ស្អែកនេះជាថ្ងៃឧបោសថ ទើបហៅសត្វទាំងបីមកប្រាប់ថា នែ ! សំឡាញ់ស្អែកនេះជាថ្ងៃឧបោសថ អ្នកទាំងអស់គ្នាត្រូវរក្សាឧបោសថហើយឱ្យទានផងព្រោះការរក្សាសីលហើយឱ្យទាន តែងបានផលច្រើន ។ សត្វទាំងបីនោះព្រមទទួលធ្វើតាម. លុះព្រឹកឡើងភេបានកំណត់សីលក្នុងចិត្តហើយ ក៏ត្រាច់ទៅរកចំណីក្បែរឆ្នេរគង្គានទីបានឃើញត្រីថ្កិន ៧

ដែលព្រានសន្ទូចដោតជាចង្កោមកប់ទុកក្នុងគំនរខ្សាច់ ក៏បន្លឺនូវសំឡេងបីដងថា ត្រីនេះមានម្ចាស់ឬទេ ? កាលបើមិនឃើញម្ចាស់ហើយ ក៏ពាំត្រីនោះទៅទុកក្នុងលំនៅរបស់ខ្លួន រង់ចាំកាលគួរនឹងបរិភោគ, ក៏ដេកពិចារណាសីលរបស់ខ្លួនទៅ ។ ឯចចកចេញទៅរកអាហារ បានប្រទះឃើញសាច់ទន្សងឆ្អើរមួយចង្កាក់នឹងទធិមួយផបដែលអ្នកស្រែម្នាក់ដាក់ក្នុងខ្ទម ក៏ស្រែកបន្លឺបីដងថា របស់នេះមានម្ចាស់ឬទេ ? កាលបើមិនឃើញម្ចាស់ហើយ ក៏ពាំយកទៅទុកក្នុងលំនៅរបស់ខ្លួន រង់ចាំកាលគួរនឹងបរិភោគ, ក៏ដេកពិចារណាសីលរបស់ខ្លួនទៅ ។ ឯស្វា ក៏បានចូលទៅក្នុងព្រៃ រកបេះបានផ្លែស្វាយទុំមួយ យកទៅទុកក្នុងលំនៅរបស់ខ្លួន រង់ចាំកាលគួរនឹងបរិភោគ, ក៏ដេកពិចារណាមើលសីលរបស់ខ្លួនទៅ ។ ឯទន្សាយបណ្ឌិត បានគិតថា ចាំដល់ពេលស្រួលអញចេញទៅស៊ីស្មៅ ប៉ុន្តែបើមានស្មូមយាចក មកកាន់សំណាក់អញ ៗ គ្មានអ្វីឱ្យទេ សូម្បីតែអង្ករ និងល្ងក៏គ្មានដែរ, បើប្រសិនជាមានស្មូមយាចកមកសុំមែន អញឱ្យសរីរៈរបស់អញទាំងមូលនេះជាទាន ។ ដោយតេជៈសីលនិងទានចេតនារបស់ទន្សាយបណ្ឌិត ដែលកើតមានពិតក្នុងចិត្ត ក៏ក្តៅដល់អាសនៈរបស់សក្កទេវរាជ ។ លំដាប់នោះសក្កទេវរាជ បានពិចារណាជ្រាបហេតុសព្វគ្រប់ហើយ ទើបចង់ល្បងមើលសីលនិងទានរបស់ទន្សាយបណ្ឌិត ក៏និម្មិតខ្លួនជាព្រាហ្មណ៍ចាស់ ដើរចូលទៅកន្លែងភេ

ជាមុន, ភេបានឃើញឥន្ទព្រាហ្មណ៍នោះហើយ ក៏សួរថា តាអញ្ជើញមកមានការអ្វី ? ។ ឥន្ទព្រាហ្មណ៍ប្រាប់ថា ខ្ញុំមកនេះប្រាថ្នារកអាហារ បើប្រសិនជាបានបន្តិចបន្តួច ខ្ញុំបរិភោគហើយនិងរក្សាសីលនៅក្នុងទីនេះ ។ ភេឆ្លើយថា ប្រពៃហើយលោកតា. ថ្ងៃនេះខ្ញុំបានត្រីថ្កិន ៧ ដែរ សូមលោកតាពិសាចុះ ។ ឥន្ទព្រាហ្មណ៍ទទួលផ្ញើទុកហើយ ក៏ហួសទៅលំនៅចចកទៀត ។ ចចកបានឃើញហើយ ក៏និយាយរាក់ទាក់នឹងឥន្ទព្រាហ្មណ៍ថា លោកតាថ្ងៃនេះ ខ្ញុំបានសាច់ទន្សងឆ្អើរមួយចង្កាក់ និងទធិមួយដប សូមលោកតាពិសាហើយនៅធ្វើសមណធម៌ក្នុងទីនេះចុះ ។ ឥន្ទព្រាហ្មណ៍គ្រាន់តែនិយាយទទួលអំណរហើយ ហួសទៅលំនៅរបស់ស្វាទៀត ។ ស្វាបានឃើញហើយ ក៏និយាយរាក់ទាក់គួរសមនឹងឥន្ទព្រាហ្មណ៍ថា ថ្ងៃនេះខ្ញុំមានតែស្វាយទុំមួយ និងទឹកត្រជាក់ទេ សូមអញ្ជើញលោកតាពិសាហើយ នៅធ្វើសមណធម៌ក្រោមម្លប់ឈើជាទីរីករាយនេះចុះ។ ឥន្ទព្រាហ្មណ៍ គ្រាន់តែរាក់ទាក់ទទួលអំណរហើយ ហួសទៅលំនៅរបស់ទន្សាយបណ្ឌិតទៀត ។ លុះទៅដល់ហើយ ក៏និយាយរៀបរាប់អំពីសេចក្តីត្រូវការចង់បរិភោគអាហារ និងនៅរក្សាឧបោសថសីលប្រាប់ដល់ទន្សាយបណ្ឌិត ។ ឯទន្សាយបណ្ឌិតបានឮដូច្នោះហើយ ក៏និយាយថា តាព្រាហ្មណ៍អើយ តាអញ្ជើញមកកាន់សំណាក់ខ្ញុំប្រពៃណាស់ហើយ ខ្ញុំនឹងបានឱ្យទានដែលខ្ញុំមិនធ្លាប់បានឱ្យ ប៉ុន្តែបើ

លោកតាជាអ្នករក្សាសីល គមមិនធ្វើបាណាតិបាត ចូរតាទៅរកឧស បង្កាត់ភ្លើងហើយមកប្រាប់ដល់ខ្ញុំ ៗ នឹងលោតទុំលាក់ខ្លួនត្រង់ កណ្ដាលរងើកភ្លើងនោះ បើសាច់របស់ខ្ញុំឆ្អិនល្មមហើយ សូមលោក តាពិសាហើយធ្វើសមណធម៌ចុះ ។ វេលានោះឥន្ទព្រាហ្មណ៍បាន បង្កាត់ភ្លើងដោយឫទ្ធិរបស់ខ្លួនឆេះសន្ធោរសន្ធៅហើយ មកប្រាប់ ដល់ទន្សាយបណ្ឌិត ៗ ក៏ដើរទៅឈរជិតគំនរភ្លើងនោះនិយាយថា ប្រសិនបើមានសត្វល្អិតជ្រកនៅត្រង់ចន្លោះរោមរបស់យើង សុំកុំឱ្យ ស្លាប់, រលាស់ខ្លួនបីដងហើយ ក៏លោតទៅក្នុងគំនរភ្លើងដោយចិត្ត រីករាយដូចជារាជហង្ស ចុះទំលើគំនរផ្កាឈូកក្រហម គួរអស្ចារ្យ ពេកណាស់ សូម្បីតែរោមមួយ ក៏មិនឆេះឡើយ ត្រជាក់ដូចជាលោត ចូលទៅក្នុងគំនរទឹកសន្សើម ។ លំដាប់នោះទន្សាយបណ្ឌិតសួរឥន្ទ ព្រាហ្មណ៍ថា តាអើយភ្លើងនេះក៏ត្រជាក់ម្ល៉េះ ? ។ ឥន្ទព្រាហ្មណ៍ ឆ្លើយថា ចៅអើយ តាមិនមែនជាព្រាហ្មណ៍ទេ គឺជាព្រះឥន្ទ្រ. ខ្ញុំមក នេះដោយចង់ល្បងមើលសីល និងទានរបស់អ្នកទេតើ ! ។ ទន្សាយ បណ្ឌិត បានបន្លឺសីហនាទតបថា បពិត្រទេវរាជ កុំថាឡើយព្រះអង្គ ម្នាក់ឯង បើទុកជាលោកសន្និវាសទាំងមូល មកចង់ល្បងមើលទាន របស់ខ្ញុំក៏ដោយ ត្រង់របស់អ្វីដែលខ្ញុំមិនចង់ឱ្យនោះគ្មានទេ ។ លំដាប់នោះសក្កទេវរាជពោលថា ម្នាលទន្សាយបណ្ឌិត គុណរបស់ អ្នកចូរតាំងនៅអស់មួយកប្ប កុំឱ្យរលុបបាត់ឡើយ ទើបចាប់ថ្មភ្នំ

ដោយទេវានុភាព ប្រចាំពួកយកជ័រទៅគួរជារូបទន្សាយភ្ជាប់នឹងមណ្ឌលព្រះចន្ទ្រ ហើយត្រឡប់ទៅកាន់ទេវលោកវិញ ។

ឯសត្វទាំង ៤ ក៏នាំគ្នារក្សាសុចរិតធម៌ ដរាបដល់អស់អាយុបានទៅកើតក្នុងទេវលោកទាំងអស់គ្នា ។

ជាតកនេះព្រះសាស្តាទ្រង់ត្រាស់ថា ភេក្នុងកាលនោះគឺអានន្ទ ចចកគឺមោគ្គល្លាន, ស្វាគឺសារីបុត្រ, ព្រះឥន្ទ្រគឺអនុរុទ្ធ, ទន្សាយបណ្ឌិតគឺអង្គព្រះតថាគត ។

## ១៥. រឿងនាងគព្ភិនី

( បាក វិ. ខុ. )

( គ្រាប់ល្ងបន្តិច ដូរយកសម្បត្តិក្នុងស្ថានសួគ៌បាន )

ក្នុងពុទ្ធកាល មានស្ត្រីម្នាក់មានគភ៌ នៅក្នុងក្រុងរាជគ្រឹះ, ថ្ងៃមួយនាងមានចំណង់ ចង់ផឹកប្រេងល្ង បានយកគ្រាប់ល្ងទៅលាងទឹក ហើយហាលថ្ងៃ ដើម្បីបុកចម្រាញ់យកប្រេង ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងវត្តជេតពននាងក្រុងសាវត្ថី បានប្រមើលមើលឧបនិស្ស័យរបស់សត្វទ្រង់ជ្រាបថា នាងគព្ភិនីនឹងធ្វើមរណកាលក្នុងថ្ងៃស្អែកនេះ ហើយធ្លាក់ទៅកើតក្នុងនរកធំឈ្មោះអវិចី, ប៉ុន្តែបើបានឃើញតថាគតនឹងត្រឡប់ទៅកើតក្នុងស្ថានសួគ៌

វិញ. លុះទ្រង់ជ្រាបដូច្នេះហើយ ក៏យកបាត្រហោះឰដ៏អាកាស សំដៅទៅក្រុងរាជគ្រឹះ យាងទៅដល់ហើយ ទ្រង់និមន្តបិណ្ឌបាត្រក្នុងទីក្រុង រៀងតាមមាគ៌ាដរាបទៅដល់ផ្ទះនាងគព្ភិនី ។ ពេលនោះនាងកំពុងហាលគ្រាប់ល្ង លុះបានឃើញព្រះមានព្រះភាគហើយ ក៏មានចិត្តសោមនស្សជ្រះថ្លា ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ទើបគិតថា អាត្មាអញបានវត្ថុអ្វីគួរសមនឹងថ្វាយព្រះសម្ពុទ្ធ មានតែគ្រាប់ល្ងប៉ុណ្ណោះ ក្រៅពីគ្រាប់ល្ងនេះចេញគ្មានឡើយ. គិតដូច្នេះហើយ ក៏កើបគ្រាប់ល្ងពីរកំបង់ យកទៅដាក់ក្នុងបាត្រព្រះសម្ពុទ្ធ ៗ ទ្រង់ទទួល ធ្វើអនុមោទនាហើយ និមន្តហួសទៅ ។ លុះដល់ថ្ងៃស្អែកឡើង នាងធ្វើមរណកាលទៅ បានទៅកើតក្នុងវិមានមាសកំពស់ ១២ យោជន៍ នាងស្ថានត្រៃត្រឹង្សបរិបូណ៌ដោយទិព្វសម្បត្តិ មានពន្លឺភ្លឺថ្លាផ្សាយចេញអំពីកាយ មានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ។ ថ្ងៃមួយព្រះមោគ្គល្លានត្ថេរ លោកនិមន្តទៅស្ថានត្រៃត្រឹង ដើម្បីពិនិត្យមើលស្ថានភាព និងលក្ខណៈសម្បត្តិរបស់ទេវតា បានឃើញនាងទេវធីតានោះហើយ ក៏សួរប្រវត្តិរបស់នាង ៗ បានថ្លែងប្រាប់ដោយសព្វគ្រប់ ។ ព្រះមោគ្គល្លាន បានជ្រាបថានាងជាស្ត្រីមានឧបនិស្ស័យខ្ពស់ ទើបសំដែងអំពីអរិយសច្ចធម៌ឱ្យនាងស្ដាប់ លុះសំដែងចប់ នាងទេវធីតាព្រមទាំងបរិវារមួយពាន់ ក៏បានសម្រេចដល់សោតាបត្តិផល ។ ព្រះមោគ្គល្លាន ក៏និមន្តត្រឡប់មកមនុស្ស

លោកវិញ ទៅថ្វាយបង្គំព្រះសម្ពុទ្ធដំណាលរឿងរ៉ាវរបស់នាងទេព ធីតានោះ ថ្វាយជាព្រះសណ្ដាប់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាល មោគ្គល្លានអ្នកមានឫទ្ធិ រឿងនេះពិតណាស់ តថាគតបានដឹងយូរ ហើយ ប៉ុន្តែគ្មានអ្នកណាជាសាក្សី បានជាតថាគតមិនសំដែងប្រាប់ ដល់អ្នកទាំងឡាយ លុះមានព្រះពុទ្ធដីកាដូច្នេះហើយ ទ្រង់សំដែង សរសើរអំពីអានិសង្សរបស់ទាន, ជាភិយ្យោភាពតទៅ ។

## ១៦- រឿងបញ្ចបក្សី

( ចាក លោ. ជា. )

( ការច្រណែន ជាពូជរបស់ពៀរក្នុងលោក )

កាលពីបឋមកប្បនេះ មានសត្វបក្សី ៥ គឺ : ហង្ស, ត្រុឌ, សេក, ក្អែក, មៀម ។ សត្វទាំង ៥ នេះ ជាប្រមុខរបស់បក្សីទាំង ឡាយក្នុងពេលនោះ, ឯសត្វទាំង ៥ នេះ មានសមត្ថភាពស្មើៗគ្នា ពុំ មានសត្វណាគោរពស្ដាប់បង្គាប់សត្វណាឡើយ ទោះបីមានសត្វ សាហាវ មកបៀតបៀនបក្សីណាមួយ ក៏គ្មានសត្វណាការពារមើល ថ្នីគ្នាឡើយ, កោលាហល ក៏កើតឡើងដល់បក្សីទាំងឡាយនោះ រាល់ពេលវេលា ។ ថ្ងៃមួយពួកបក្សីចាស់ៗ បានហើរទៅប្រជុំគ្នាលើ ដុំមនោសិលាមួយខ្ពស់ បានប្រឹក្សាគ្នាថា យើងគួររើសបក្សីណាមួយ

ដែលអង់អាច ឱ្យធ្វើជាស្ដេច គ្រាន់បានជាទីគោរព និងមើលការខុសត្រូវ ដើម្បីឱ្យមានសន្តិសុខក្នុងពួកបក្សីយើង ។ បក្សីចាស់ៗដទៃទៀត និយាយឡើងថា បើដូច្នោះគួរយើងទៅប្រមូលពួកបក្សីទាំងអស់គ្រប់ប្រភេទ ឱ្យមកកាន់ទីនេះ ហើយយើងត្រូវរើសបក្សី ៥ រូប ដែលមានសមត្ថភាពល្អ ឱ្យធ្វើជាបេក្ខបក្សី ទើបយើងរើសយកតែមួយរូប ឱ្យធ្វើជាស្ដេចទើបគួរ. និយាយហើយ ក៏ទៅហៅពួកបក្សីទាំងអស់ឱ្យមកប្រជុំគ្នានៅលើជុំមនោសិលានោះ. ដល់មកជួបជុំបក្សីចាស់មួយរូបនិយាយប្រកាសថា បណ្ដាបក្សីទាំងអស់នេះ យើងរើសយកបក្សី ៥ រូបគឺ : ហង្ស១. គ្រុឌ១. សេក១. ក្អែក១. មៀម១ ឱ្យធ្វើជាបេក្ខបក្សី តើអ្នកទាំងអស់គ្នា គួរយកបក្សីណាឱ្យធ្វើជាស្ដេច ? ។ ពេលនោះមានសត្វខ្លែងស្រាកចាស់មួយឆ្លើយឡើងថា គួរតែតាំងសត្វមៀមឱ្យធ្វើជាស្ដេចរបស់បក្សីទាំងឡាយ. ព្រោះមៀមជាសត្វអង់អាច មានភ្នែកក៏ធំល្អ អាចមើលការខុសត្រូវបានច្រើនជំពូក មានសំឡេងក៏ពិរោះ ហើយជាអ្នកក្លៀវក្លាផង ។ ពួកបក្សីទាំងឡាយ ក៏ព្រមអនុម័តតាម បានបន្លឺសំឡេងគឹកកងឡើងថា ស្រួលហើយ ៗ ។ កាលនោះមានសត្វក្អែកចាស់មួយ. ប្រាថ្នាចង់សោយរាជ្យ ក៏ស្រែកបញ្ចេញមតិជំទាស់ឡើងថា សត្វមៀមនេះ ជាកោសិយគោត្រ មានជាតិថោកទាបទាសអប្រិយ. តែថា បើញាតិទាំងឡាយស្ដាប់ពាក្យរបស់ខ្ញុំ ៗ នឹងនិយាយឱ្យស្ដាប់ ។ បក្សីទាំង

អស់ ក៏បើកឱកាសឱ្យក្អែក ១ និយាយថា តាមមតិរបស់ខ្ញុំ មិនគួរឱ្យមៀមធ្វើជាស្ដេច ត្រួតត្រារក្សាសុខទុក្ខរបស់យើងទាំងឡាយទេ ព្រោះមៀមនេះ មានមុខក្រញូវអាក្រក់ពេកណាស់ បើតាមលក្ខណៈក្បួនចាស់ទំនាយថា មុខមិនទទួលភ្ញៀវ មិនទាន់ខឹងផងមុខដូចជាខឹងទៅហើយ. បើយ៉ាងនេះតើបក្សីណានឹងហ៊ានចូលទៅប្រាស្រ័យការផងបាន. មិនគួរតាំងឱ្យធ្វើជាស្ដេចឡើយ ។ បក្សីទាំងឡាយ ក៏ទទួលព្រមតាមក្អែក បានបន្លឺសំឡេងគឹកកងថា មែនហើយៗ ឱ្យធ្វើជាស្ដេចមិនកើតទេ ព្រោះភ្នែកអាក្រក់ណាស់ ។ បន្ទាប់នោះមានសត្វត្មាតចាស់មួយ ស្រែកបញ្ចេញមតិឡើងថា តាមទំនៀមបុរាណបើបុគ្គលណាឈ្លាសវៃ អាចចាប់ពិរុទ្ធរបស់ជនជាធំបាន ដោយសមហេតុផលតាមគន្លងច្បាប់ ត្រូវតាំងអ្នកនោះឱ្យធ្វើជាធំវិញ ហេតុនេះត្រូវតែយើងតាំងក្អែកឱ្យធ្វើជាស្ដេច ព្រោះជាសត្វភ្លៀវភ្លាហើយរៀងវៃល្មមជាប្រមុខរបស់យើងបាន ។ បក្សីទាំងឡាយក៏បន្លឺសំឡេងគឹកកងឡើងថា ពាក្យរបស់ត្មាតនេះត្រឹមត្រូវណាស់គួរយើងតាំងក្អែកឱ្យធ្វើជាស្ដេចចុះ ។ ពេលនោះមៀមពុំសុខចិត្តបានសុំឱកាសនិយាយ បក្សីទាំងឡាយ ក៏ព្រមបើកឱកាសឱ្យ ទើបមៀមស្រែកនិយាយឡើងថា ពាក្យដែលត្មាតនិយាយនោះ ត្រូវតាមច្បាប់បុរាណហើយ ប៉ុន្តែក្អែកនេះ មិនគួរសមតាមច្បាប់នោះទេ ព្រោះមានអតីតនិទានដំណាលថា សត្វក្អែកជាចណ្ឌាលគោត្រ

អាក្រក់ថោកទាបបំផុត ជាអ្នកមានទោសកំហុសក្បត់ផែនដី ត្រូវរាជការកាត់ទោសយកទៅដុតទាំងរស់ ប៉ុន្តែវារត់រួចមក បានជាខ្មៅក្រខ្វក់យ៉ាងនេះ. បើអ្នកមានទោសកំហុសដល់ម្ល៉ឹង តើឱ្យធ្វើជាធំដូចម្ដេចកើត ។ បក្សីទាំងឡាយ បានបន្លឺសំឡេងគឹកកងឡើងថា ពាក្យរបស់មៀមនេះត្រូវណាស់ ព្រោះអ្នកមានទោសកំហុសបុរាណមិនដែលឱ្យធ្វើជាធំទេ បើដូច្នេះយើងត្រូវរើសបក្សីដទៃទៀត ។ ក្អែកបានស្ដាប់ពាក្យនោះ ក៏ខឹងច្រឡោតមហិមា ទើបស្រែកឡើងថា ម្នាលក្អែកគ្នាយើងទាំងឡាយ អញវិនាសហើយ ព្រោះតែអាមៀមមុខខ្មោច មុខដូចគេខមនេះឯង ។ ឯសត្វមៀមបានឮថាមុខខ្មោច មុខដូចខមដូច្នោះ ក៏ខឹងច្រឡោតស្រែកឡើងថា ម្នាលមៀមគ្នាយើងទាំងឡាយ អញវិនាសហើយ ព្រោះតែអាក្អែកចណ្ឌាលមានទោសឧក្រិដ្ឋ គេដុតទាំងរស់នេះឯង ។ សត្វទាំងពីរក្រុមនេះ ក៏ឈ្លោះទាស់ទែងប្រចឹកគ្នាជាខ្លាំង, ពួកបក្សីទាំងឡាយនាំគ្នាបណ្ដេញចេញពីទីប្រជុំ សត្វទាំងពីរក្រុម ក៏ហើយចេញទៅប្រចឹកគ្នាខាងក្រៅទៀត ហើយចងគំនុំគ្នាអស់មួយកប្ប. សត្វទាំងពីរក្រុមក៏មានពៀរនឹងគ្នា រហូតដល់មកក្នុងកាលឥឡូវនេះ ។ កាលបើសត្វទាំងពីរក្រុមចេញផុតហើយ បក្សីទាំងឡាយ ក៏បើកពេលប្រជុំម្ដងទៀត. ពេលនោះមានបក្សីចាស់មួយរូបនិយាយឡើងថា យើងគួរយកសត្វត្រុឌឱ្យធ្វើជាស្ដេចចុះ ព្រោះជាសត្វមានកំឡាំង

ខ្លាំងជាងសត្វនានា លុះនិយាយចប់ហើយ មានសេកចាស់មួយជាបណ្ឌិតបាននិយាយប្រកាសថា សត្វគ្រុឌមានកំឡាំងខ្លាំងជាងសត្វនានាមែនហើយ ប៉ុន្តែខ្វះបញ្ញាសម្បត្តិនិងចរិយាសម្បត្តិ, បើសត្វហង្សទើបគួរជាង ព្រោះជាសត្វបរិបូណ៌ដោយរូបសម្បត្តិ បញ្ញាសម្បត្តិ ចរិយាសម្បត្តិ និងគុណសម្បត្តិ ជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ល្មមធ្វើជាស្ដេចបាន ។

ពួកបក្សីទាំងឡាយមានគ្រុឌជាដើម បានទទួលព្រមតាមមតិរបស់សេក ក៏បន្លឺសំឡេងគឹកគងឡើងថាសាធុៗ សមរម្យហើយ ទើបសន្មតិតាំងសត្វហង្សឱ្យធ្វើជាស្ដេចបក្សីតាំងពីកាលនោះមក ។

## ១៧_ រឿងគវម្បតិមាណព

( ចាក វិ. ខុ. )

( គុណនៃការសាងសេនាសនៈ សម្រាប់អ្នកដំណើរ )

ក្នុងសាសនាព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ មានគង្វាលគោម្នាក់ ជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា បានឃើញភិក្ខុមួយអង្គជាព្រះខីណាស្រព និមន្តទៅបិណ្ឌបាត្រក្នុងភូមិរបស់ខ្លួន, ដល់លោកត្រឡប់ចេញពីភូមិមកវិញ ទៅគង់ឆាន់ចង្ហាន់កណ្ដាលទីវាលឆ្ងាយពីភូមិនោះបន្តិច ។ ឯភូមិនោះគ្មានដើមឈើជាម្លប់ទេ ព្រោះតាំងនៅកណ្ដាលទីវាលស្រឡះ ។ នាយគោបាល បានឃើញយ៉ាង

នេះហើយ ក៏គិតថា បើអញធ្វើខ្ទមត្រង់ទីនេះមួយសម្រាប់អ្នកដំណើរ ប្រហែលជាព្រះថេរៈលោកចូលទៅជ្រកក្នុងខ្ទមអញមិនខាន ។ លុះគិតយ៉ាងនេះហើយ ក៏ទៅកាប់កូនច្រេស ៤ ដើម យកមកបោះធ្វើជាសសរ យកមែកនិងស្លឹកបាំងពីលើ ហើយទៅបវារណាប្រគេនខ្ទមនោះដល់ព្រះថេរៈ : ក៏តែងចូលទៅឆាន់ចង្ហាន់ក្នុងខ្ទមនោះរាល់ៗថ្ងៃ ។ ថ្ងៃក្រោយមកបានយកកូនច្រេសមួយដើម ទៅដាំមុខខ្ទមនោះទៀត ដើម្បីធ្វើជាម្លប់ ។ នាយគោបាលដល់អស់អាយុ បានទៅកើតក្នុងស្ថានចាតុមហារាជិកា មានស្រីទេពអប្សរចោមរោមមីរដេរដាសពេញវិមានប្រាសាទ, នៅមុខវិមានប្រាសាទនោះ មានដើមច្រេសមួយដើមធំ មានផ្កានិងស្លឹករីកស្គុះស្គាយផុះឡើងជាគ្រឿងលំអរ, ដោយអំណាចផលដែលបានសាងខ្ទមនិងដាំដើមច្រេសនោះ គោបាលទេវបុត្របានសោយសេចក្ដីសុខ ក្នុងមនុស្សលោកនិងទេវលោក ជាអនុលោមបដិលោមអស់មួយពុទ្ធន្តរដល់មកសាសនាព្រះសម្ពុទ្ធបរមគ្រូយើងនេះ បានមកកើតក្នុងត្រកូលមួយ នាមជ្ឈិមប្រទេស មានឈ្មោះថា គវម្បតិមាណព ជាមិត្រសំឡាញ់របស់ព្រះយសត្ថេរ ។ ថ្ងៃមួយគវម្បតិមាណពទៅស្ដាប់ធម៌ព្រះសម្ពុទ្ធ បានសម្រេចព្រះអរហត្ត ក៏បួសក្នុងពេលនោះទៅ ។ ឯដើមច្រេសនៅស្ថានចាតុមហារាជិកា ដែលផុះមុខវិមានរបស់លោកកាលកើតជាទេវបុត្រនោះ មិនវិនាសបាត់បង់ទៅណាឡើយ

លោកតែងនិមន្តទៅសម្រាកកាយ ចំរើនឈានសមាបត្តិក្រោមម្លប់ច្រេសនោះតែរាល់ៗ ពេល ។

ឯស្តេចបាយាសិ ដែលមិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាអ្នកធ្វើទានខ្ជីខ្ជា លុះទីវង្គតទៅ បានទៅកើតក្នុងស្ថានចាតុមហារាជិកា ជាទេវបុត្រកំសត់ទុគ៌តឥតវិមានប្រាសាទឥតបរិវារ, បានឃើញដើមច្រេសនោះទំនេរ ក៏ចូលទៅអាស្រ័យនៅ ។ ថ្ងៃមួយព្រះគវម្បតិថេរ និមន្តទៅសម្រាកកាយនាដើមច្រេសនោះ ស្រាប់តែឃើញបាយាសិទេវបុត្រនៅក្នុងទីនោះម្នាក់ឯង ទើបសួរថា ម្នាលទេវបុត្រ អ្នកទើបនឹងមកពីទីណា ? ។ បាយាសិទេវបុត្រ បានថ្លែងប្រវត្តិរបស់ខ្លួនតាំងពីដើមដរាបដល់ចប់ លោកបានជ្រាបប្រវត្តិនោះហើយ និមន្តចុះមកស្ថានមនុស្សវិញ ។ ឯបាយាសិទេវបុត្រ ក៏នៅអាស្រ័យនឹងដើមច្រេសនោះដរាបមក ។ ថ្ងៃមួយព្រះបាទវេស្សវ័ណ បានហៅបាយាសិទេវបុត្រ ប្រើឱ្យទៅរក្សាសមុទ្រខ្សាច់មួយ ដែលមានពួកអមនុស្សចេះតែបៀតបៀនពួកឈ្មួញរទេះ អ្នកត្រាច់ចរទៅមកធ្វើពាណិជ្ជកម្ម។ បាយាសិទេវបុត្រ កាលបើបានពរអំពីស្តេចវេស្សវ័ណហើយ ក៏ទៅនៅកណ្តាលវាលខ្សាច់នោះ, ឯដើមច្រេស ក៏ទៅប្រតិស្ឋានជាវិមាន នៅនាវាលខ្សាច់នោះដែរ ។

# ១៨~ រឿងយក្ខិនីមុខសេះ

( ចាក ម. អ. )

( ទោសផឹកសុរា និយាយកុហក និងក្បត់ចិត្តស្វាមី )

ក្នុងកាលកន្លងទៅហើយ មានអគ្គមហេសីនៃព្រះរាជាមួយព្រះអង្គ សោយរាជ្យក្នុងក្រុងពារាណសី ជាអ្នកផឹកសុរា និយាយកុហក និងប្រព្រឹត្តក្បត់ចិត្តស្វាមី ។ អគ្គមហេសីនោះ លុះធ្វើមរណកាលទៅ បានកើតជាយក្ខិនីប្លែកអំពីត្រកូលយក្សធម្មតា គឺមានខ្លួនជាយក្សមុខជាសេះ ហៅថា អស្សមុខិយក្ខិនី, ស្ថិតនៅក្នុងលេណគុហា នាបាទភ្នំមួយ បានចូលទៅបំរើស្តេចវេស្សវ័ណអស់វារៈ ៣ឆ្នាំ ស្តេចទ្រង់ប្រទានគោចរភក្សមួយមានបណ្តោយ ៣០ យោជន៍ ទទឹង ៥ យោជន៍ដើម្បីចាប់សត្វម្រឹគ និងមនុស្សទាំងឡាយបរិភោគជាអាហារ ។ ថ្ងៃមួយយក្ខិនីមុខសេះនោះ ចាប់បានព្រាហ្មណ៍កំឡោះម្នាក់ មានរូបឆោមសមរម្យល្អ លើកដាក់ឱ្យដេកលើខ្នង នាំយកទៅទុកក្នុងគុហា ដើម្បីធ្វើជាស្វាមី ។ ចាប់ដើមតាំងពីថ្ងៃនោះមក យក្ខិនីតែងស្វះស្វែងរកចាប់មនុស្ស ដើម្បីយកវត្ថុផ្សេងៗ មានសំពត់អាវនិងអង្ករ ស្លឹកគ្រៃ ម្ហូបចំណី ដែលមានរសឆ្ងាញ់ពិសាទៅចិញ្ចឹមព្រាហ្មណ៍ជាស្វាមីនោះតែរាល់ៗ ថ្ងៃ ។ ក្នុងពេលដែលយក្ខិនីចេញទៅរកអាហារ បានយកដុំថ្មមួយដុំធំខ្ទប់មាត់ទ្វារ ព្រោះខ្លាចព្រាហ្មណ៍នោះរត់ចោល ។ ក្នុងគ្រានោះ ព្រះពោធិសត្វបានសោយ

ព្រះជាតិក្នុងគភ៌ នៃនាងយក្ខិនីមុខសេះនោះ លុះគ្រប់ទសមាស ក៏ប្រសូត្រមកមានរូបល្អស្រស់ប្រិមប្រិយ. នាងមានសេចក្ដីស្នេហាចំពោះកូននិងបិតាយ៉ាងក្រៃលែង តែងទំនុកបម្រុងដោយភោជនាហារមានរសឆ្ងាញ់ផ្សេងៗ ។ លុះព្រះពោធិសត្វមានវ័យចំរើនធំឡើង ក៏ប្រមៀលដុំថ្មដែលមាតាបិទទ្វារគុហានោះចេញ ហើយនាំបិតាមកអង្គុយលេងកំសាន្តខាងក្រៅ ដល់យក្ខិនីជាមាតាត្រឡប់មកវិញ ព្រះពោធិសត្វ ក៏ប្រាប់ភ្លាមថា ខ្ញុំបានប្រមៀលដុំថ្មនេះចេញហើយ ព្រោះងងឹតអផ្សុកណាស់. យក្ខិនីហេតុតែស្រឡាញ់កូន ក៏នៅស្ងៀមគ្មានថាអ្វីឡើយ ។ ថ្ងៃក្រោយព្រះពោធិសត្វមានសេចក្ដីឆ្ងល់នឹងមាតារបស់ខ្លួនថា ហេតុអ្វីបានជាមាតាគាត់មានមុខដូចជាសេះ ទើបសួរទៅបិតា ៗ ប្រាប់ថា ម្ដាយឯងជាយក្សទេ យើងទាំងពីរនាក់ជាមនុស្ស ។

ព្រះពោធិសត្វបានដឹងហេតុនោះសព្វគ្រប់ហើយ ក៏នាំបិតារត់ចេញពីទីនោះទៅ ។ យក្ខិនីជាមាតាដល់ត្រឡប់មកវិញ មិនឃើញកូននិងស្វាមី ក៏ហោះទៅតាម មានសន្ទុះលឿនដូចជាខ្យល់ទៅទាន់ពាក់កណ្ដាលផ្លូវនាំយកមកវិញ. ថ្ងៃក្រោយបាននាំបិតារត់ទៅទៀត យក្ខិនីតាមទាន់ទៀត ។ ថ្ងៃមួយព្រះពោធិសត្វបានគិតថា មាតារបស់អញ មានឱកាសទីស្ថានបរិច្ឆេទ កំណត់ពីត្រឹមណាដល់ត្រឹមណា ? លុះគិតដូច្នេះហើយ ក៏សួរទៅមាតាៗ បានប្រាប់ទីស្ថាន

ខែត្រដែនរបស់ខ្លួនសព្វគ្រប់ដល់ព្រះពោធិសត្វ ។ ថ្ងៃមួយព្រះពោធិសត្វបានឱកាសស្ទាត់ល្អ ក៏បញ្ជិះបិតាលើក នាំរត់ទៅដោយសន្ទុះយ៉ាងលឿនដូចជាខ្យល់ បានទៅដល់ឆ្នេរស្ទឹងជាទីបំផុតនៃព្រំដែនរបស់យក្ខិនីជាមាតាហើយ នាំបិតាឆ្លងស្ទឹងនោះទៅ, លុះដល់ពាក់កណ្តាលស្ទឹង មាតាទៅតាមទាន់ ប៉ុន្តែពុំអាចហ៊ានចាប់យកមកវិញឡើយ ព្រោះហួសព្រំដែនរបស់ខ្លួន, ក៏ខំនិយាយអង្វរកូននិងស្វាមីនោះឱ្យត្រឡប់វិលមកវិញ ដោយអាការៈផ្សេងៗ, ដឹងថាជនទាំងពីរមិនត្រឡប់មកវិញហើយ ក៏មានសេចក្តីខ្សឹកខ្សួលយំសោកបោកខ្លួនព្រោះស្រឡាញ់កូនយ៉ាងក្រៃលែង, ទើបស្រែកហៅព្រះពោធិសត្វថា នែកូនសំឡាញ់មាសម្តាយ បើអ្នកមិនត្រឡប់វិញទេ ចូរកូនរៀនយកមន្តវិជ្ជាឈ្មោះចិន្តាមណីពីម្តាយទៅចុះ ព្រោះមនុស្សលោក បើគ្មានសិប្បៈហើយ រស់នៅបានដោយកម្រពេកណាស់, ឯមន្តវិជ្ជាឈ្មោះចិន្តាមណីនេះ មានតម្លៃកាត់មិនបាន ព្រោះមានអានុភាពយ៉ាងវិសេស បើទុកជាចោរនាំយកនូវភណ្ឌៈទៅលាក់ទុកអស់ ១២ ឆ្នាំ ក៏អាចតាមដានដើងចាប់ចោរនោះបានភ្លាម, ចូរកូនយកទៅរក្សាទុកឱ្យល្អចុះ ។ ព្រះពោធិសត្វ ឈរនៅពាក់កណ្តាលស្ទឹង បានស្តាប់មាតាថ្លែងគុណវិសេស នៃមន្តវិជ្ជាឈ្មោះចិន្តាមណីនោះរួចហើយ ក៏ថ្វាយបង្គំព្រះមាតា រៀនយកនូវមន្តនោះដោយសព្វគ្រប់ហើយលាមាតាថា សូមលោកម្តាយអញ្ជើញត្រឡប់ទៅវិញចុះ ខ្ញុំ

សូមថ្វាយបង្គំលាហើយ ។ ចំណែកខាងនាងយក្ខិនី កប្រហារដើមទ្រូងបែកហឫទ័យស្លាប់ក្នុងទីនោះទៅ ។ ព្រះពោធិសត្វឃើញមាតាស្លាប់ហើយ ក៏នាំបិតាចាត់ចែងធ្វើជើងថ្ករបូជាសព លុះបូជាហើយបានបេះផ្ការុក្ខជាតិផ្សេងៗ យកទៅបូជាធាតុ ថ្វាយបង្គំលានាំបិតាទៅកាន់ក្រុងពារាណសីទៅ ។

៙ ✵ ៚

## ១៩~ រឿងរុក្ខទេវតា

( ចាក ព្យ. តិ. )

( អ្នកមានទ្រព្យ មានយសស័ក្តិ គួររក្សាអ្នកក្រឥតយសស័ក្តិ )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី, កាលនោះព្រះពោធិសត្វទ្រង់សោយព្រះជាតិជារុក្ខទេវតា គង់នៅនាដើមឈើមួយក្បែរព្រៃធំ ។ មានរុក្ខទេវតាមួយអង្គទៀត អាស្រ័យនៅនឹងដើមឈើធំបំផុត ក្នុងព្រៃជិតលំនៅរបស់ព្រះពោធិសត្វ ។

ក្នុងព្រៃនោះមានរាជសីហ៍ និងខ្លាធំអាស្រ័យនៅផង, ដោយហេតុតែរាជសីហ៍និងខ្លាអាស្រ័យនៅ មនុស្សទាំងឡាយ មិនហ៊ានទៅធ្វើស្រែចំការក្នុងទីជិតព្រៃនោះ ឬកាប់ដើមឈើក្នុងព្រៃនោះឡើយ ព្រោះខ្លាចសត្វទាំងពីរបៀតបៀន ។ សីហៈនិងខ្លាតែងចាប់ម្រឹគផ្សេងៗស៊ីជាអាហារ ចោលសាច់និងឆ្អឹងគរពាសពេញព្រៃនោះ

សាច់និងឆ្អឹងសំណល់ទាំងឡាយនោះ ក៏រលួយរលិចមានក្លិនស្អុយផ្សាយទៅពេញព្រៃទាំងមូល ។ ឯរុក្ខទេវតាដែលនៅនឹងដើមឈើធំ ជាអ្នកល្ងង់ខ្លៅមិនយល់ហេតុផលជ្រៅឆ្ងាយ, បាននិយាយនឹងព្រះពោធិសត្វថា នែ ! សំឡាញ់ ព្រៃនេះមានក្លិនស្អុយអសោចិ៍ពេកណាស់ ព្រោះតែសត្វសីហៈនិងខ្លា ដែលជាសត្វចង្រៃ យើងត្រូវដេញវាឱ្យរត់ចេញទៅ កុំឱ្យនៅតទៅទៀត ។ ព្រះពោធិសត្វនិយាយឃាត់ថា នែ ! សំឡាញ់ អ្នកមិនដឹងទេឬ ? វិមានរបស់យើងដែលតាំងនៅបាន ព្រោះអាស្រ័យសត្វទាំងពីរនោះឯង បើយើងដេញវាទៅ មនុស្សទាំងឡាយ កាលមិនឃើញដានជើងសីហៈនិងខ្លាធំហើយ ក៏នឹងនាំគ្នាមកកាប់ឈើរីព្រៃជីកគាស់ឱ្យស្រឡះយកទីព្រៃទាំងមូលនេះធ្វើជាស្រែចំការ វិមានរបស់យើងមុខជាវិនាសមិនខាន, ព្រោះហេតុនោះ អ្នកកុំចូលចិត្តចង់ដេញសត្វទាំងពីរនោះឡើយ ។ ទេវតាឆោតល្ងង់នោះ ទោះបីព្រះពោធិសត្វនិយាយប្រាប់យ៉ាងណា ក៏មិនធ្វើតាមឡើយ ។ ថ្ងៃមួយបាននិម្មិតខ្លួនធំសំបើមអស្ចារ្យ លងបន្លាចគ្រហឹមគម្រាម ដេញរាជសីហ៍និងខ្លាធំឱ្យរត់បាត់អស់ទៅ ។

មនុស្សទាំងឡាយកាលបើមិនឃើញដានជើង របស់សត្វទាំងពីរនោះហើយ ក៏សំគាល់ថារាជសីហ៍និងខ្លាមិននៅក្នុងទីនោះទេ ទើបនាំគ្នាកាប់គាស់ដើមឈើក្នុងព្រៃអស់ជាច្រើន ។ រុក្ខទេវតា

នោះ លុះឃើញដូច្នោះក៏ចូលទៅរកព្រះពោធិសត្វ ហើយនិយាយថាសំឡាញ់ ខ្ញុំមិនបានធ្វើតាមពាក្យរបស់អ្នក ខ្ញុំដេញសត្វទាំងពីរនោះឱ្យរត់អស់ទៅ ឥឡូវពួកមនុស្សដឹងថា សត្វទាំងពីរនោះមិននៅ ទើបនាំគ្នាចូលទៅកាប់គាស់ឈើក្នុងព្រៃអស់ជាច្រើន បើយ៉ាងនេះតើយើងគិតដូចម្ដេចទើបស្រួល ។ ព្រះពោធិសត្វ បានពន្យល់ដឹកនាំប្រាប់ឧបាយថា ឥឡូវសត្វទាំងពីរនោះទៅនៅក្នុងព្រៃឯណោះ អ្នកត្រូវទៅបបួលវាឱ្យត្រឡប់មកវិញ ។ រុក្ខទេវតាឆោតល្ងង់ ក៏ចូលទៅក្នុងព្រៃនោះតាមពាក្យពោធិសត្វ អង្គុយផ្គងអញ្ជលីខាងមុខសត្វទាំងពីរហើយ អង្វរឱ្យត្រឡប់ទៅនៅព្រៃដដែលវិញ ។ សត្វទាំងពីរនោះ ទោះបីទេវតាអង្វរយ៉ាងណា ក៏បដិសេធយ៉ាងដាច់ខាតថា អ្នកចូរទៅចុះ យើងមិនទៅទេ ។ រុក្ខទេវតាទាល់គំនិត ក៏ត្រឡប់ទៅលំនៅរបស់ខ្លួនវិញ ។ មនុស្សទាំងឡាយ បាននាំគ្នាជីកគាស់កាប់រំលើងរំលុំដើមឈើ រហូតអស់ព្រៃធំនោះទៅ ។ ឯទេវតាឆោតល្ងង់ក៏ខានបាននៅក្នុងទីនោះតទៅទៀត ។

## ២០. រឿងនាងសេសវតី

( ចាក វិ. ខុ. )

( លទ្ធផលនៃការបូជាព្រះសារីរិកធាតុ )

ក្នុងសាសនាព្រះសម្ពុទ្ធកស្សបៈ ព្រះអង្គបរិនិព្វានទៅហើយ, ពួកមហាជនទាំងឡាយ បាននាំគ្នាយកមាសទៅកសាងចេតិយកំពស់មួយយោជន៍ ដើម្បីបញ្ចុះព្រះសារីរិកធាតុ ។ កាលនោះមានឧបាសិកាម្នាក់ បាននាំនាងទារិកាជាកូនរបស់ខ្លួនទៅមើលជាងទងដែលកំពុងរំលាយមាសធ្វើឥដ្ឋ ។ នាងទារិកា ឃើញជាងកំពុងរំលាយមាស ក៏សួរទៅមាតាថា បពិត្រអ្នកម្តាយ គេរំលាយមាសធ្វើអ្វី ? ។ មាតាប្រាប់ថា គេធ្វើចេតិយបញ្ចុះព្រះសារីរិកធាតុព្រះសម្ពុទ្ធ នាងទារិកាបានឮដូច្នោះ ក៏មានចិត្តជ្រះថ្លាចំពោះព្រះសម្ពុទ្ធទើបប្រាប់ម្តាយថា ខ្សែមាសពាក់នៅករបស់ខ្ញុំនេះ ខ្ញុំយកទៅចូលធ្វើចេតិយនឹងគេ, មាតាឆ្លើយថាល្អហើយកូនស្រីម្តាយ ក៏យកខ្សែមាសនោះ ទៅចូលធ្វើចេតិយនឹងគេទៅ ។ សង្ខេបសេចក្តីតែប៉ុណ្ណេះ លុះដល់នាងក្ស័យជីវិតទៅ បានទៅកើតក្នុងសុគតិភព ជាអនុលោមបដិលោម អស់មួយពុទ្ធន្តរ ដល់មកសាសនាព្រះសម្ពុទ្ធបរមគ្រូរបស់យើងនេះ បានមកកើតក្នុងស្រុកនាឡន្ទគ្រាម មានឈ្មោះថាសេសវតី, កាលនាងមានអាយុ ១៥ ឆ្នាំ មាតាបានប្រើឱ្យទៅទិញប្រេងឯផ្សារ ។ ក្នុងស្រុកនាឡន្ទគ្រាមនោះ មានគហបតី

ម្នាក់ធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះទ្រព្យសម្បត្តិមាសប្រាក់កែវទាំង ៧ ប្រការ ដែលមាតាបិតាចែកឱ្យទាំងប៉ុន្មាន ដល់មាតាបិតាស្លាប់ទៅ របស់ទាំងនោះ ក៏ក្លាយទៅជាថ្មនោសិលាអស់ឥតសល់ ។ អតីតគហបតី បានយកថ្មនោសិលានោះ ទៅដាក់លក់ក្នុងរានផ្សារ ផ្សងរកអ្នកមានបុណ្យដោយមានគំនិតថា បើអ្នកមានបុណ្យដើរមកឃើញ របស់ទាំងនេះនឹងក្លាយទៅជាមាសប្រាក់ជាកែវ ៧ ប្រការដូចដើមវិញពុំខាន ។ កាលនោះនាងសេសវតី កាន់ដបប្រេងដើរចូលទៅផ្សារ បានឃើញរានមួយ ចាក់គរសុទ្ធតែមាសប្រាក់និងកែវទាំង ៧ ប្រការ, នាងក៏ចូលទៅមើល ហើយសួរទៅម្ចាស់រានថា បពិត្រអ្នកដង្ហៅ ហេតុអ្វីក៏យកមាសប្រាក់កែវមកចាក់គរលើរានដូច្នេះ របស់ទាំងនេះគេតែងទុកដាក់លាក់បំពួនក្នុងហឹបក្នុងឃ្លាំង ។ អ្នកម្ចាស់រានឮដូច្នោះហើយ ត្រេកអរណាស់ ទើបសួរទៅនាងសេសវតីថា នាងនៅទីណា ? ជាកូនចៅអ្នកណា ? នាងប្រាប់ថា ខ្ញុំជាកូនអ្នកស្រែ នៅក្នុងស្រុកនេះឯង, អ្នកម្ចាស់រាន ក៏កើបមាសប្រាក់ច្រកក្នុងចាវ ហើយនាំនាងសេសវតីទៅផ្ទះរបស់ខ្លួន បាននិយាយប្រាប់នាងថា កាលពីដើម ខ្ញុំជាគហបតីមួយ នៅក្នុងស្រុកនេះ ឥឡូវធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះមាសប្រាក់កែវទាំងប៉ុន្មានក្លាយទៅជាថ្មនោសិលាអស់ បានជាខ្ញុំយកថ្មនោះ ទៅដាក់នៅរានផ្សារ ដើម្បីផ្សងរកអ្នកមានបុណ្យ, ឥឡូវទ្រព្យទាំងអស់នេះ ជាទ្រព្យ

របស់នាងហើយ ព្រោះនាងជាអ្នកមានបុណ្យ ។ គហបតីបាននាំនាងសេសវតីទៅចាក់ឃ្លាំងមើលទៀត គ្រាន់តែនាងចូលទៅដល់ របស់ក្នុងឃ្លាំងទាំងប៉ុន្មាន ក៏ក្លាយទៅជាមាសប្រាក់កែវដូចដើមវិញទាំងអស់ ។ គហបតីនោះ ក៏ជូននាងសេសវតីទៅផ្ទះ និយាយប្រាប់ឪពុកម្ដាយនាងដោយសព្វគ្រប់ ទើបដណ្ដឹងនាងឱ្យជាភរិយាកូនកំឡោះរបស់ខ្លួន. លុះរៀបអាពាហ៍ពិពាហ៍ហើយ មាតាបិតាក្មេកបាននាំនាងសេសវតី ទៅនៅក្នុងសំណាក់របស់ខ្លួន ។ ក្នុងកាលជាខាងក្រោយមក ព្រះសារីបុត្តត្ថេរ ជាធម្មសេនាបតី បានរំពឹងមើលអាយុសង្ខាររបស់លោក ឃើញថាអស់ហើយ ក៏ចូលទៅថ្វាយបង្គំលាព្រះសម្ពុទ្ធ សុំទៅបរិនិព្វានឯស្រុកនាឡន្ទគ្រាម ដើម្បីប្រោសមាតាបិតាដែលជាជនមិច្ឆាទិដ្ឋិ. លុះទូន្មានមាតាបិតាហើយ ក៏បរិនិ-ព្វានក្នុងបន្ទប់ ដែលលោកប្រសូត្រនោះទៅ ។ កន្លងមកបាន ៧ ថ្ងៃ ពួកពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើជើងថ្ករកំពស់ ១ រយហត្ថ ដើម្បីបូជាសពរបស់លោក ។ កាលនោះនាងសេសវតី មានគភ៌ជិតគ្រប់ខែហើយ បានឮថាពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើបុណ្យរំលាយសពព្រះសារីបុត្ត ក៏សុំលាមាតាបិតាក្មេក យកមាសប្រាក់កែវភ្ញីផ្កាទៅបូជាសពព្រះសារីបុត្រ ។ មាតាបិតាឃាត់ថា នាងទៅពុំកើតទេ ព្រោះគភ៌ចាស់គ្រប់ខែហើយ ។ នាងសេសវតី ជាស្ត្រីមានសេចក្ដីជ្រះថ្លាខ្លាំងទ្រាំមិនបាន ក៏លាមាតាបិតា នាំបរិវារកាន់មាសប្រាក់

កែវភ្ជីផ្កាដើរសំដៅទៅកន្លែងដំកល់សពព្រះសារីបុត្ត ។ ក្នុងពេលនោះមានមនុស្សច្រើនណែនណាន់ ចង្អៀតជាទីបំផុត ប៉ុន្តែនាងសេសវតីជាស្ត្រីស្គុកស្គម្ភដោយភោគសម្បត្តិ, ពួកមហាជនបានឃើញហើយ ក៏បើកឱកាសឱ្យចូលទៅជិតសព, នាងយកមាសប្រាក់កែវភ្ជីផ្កា ទៅចាក់គរក្បែរក្តាររមឈូស ហើយថយមកអង្គុយប្រណម្យអាញ្ជលីនមស្សការ ។ ក្នុងពេលនោះ ចំហាយរបស់មនុស្ស ដែលកកកុញនោះ ក៏បណ្តាលឱ្យនាងសេសវតី ទៅជាខ្យល់ចាប់ សន្លប់នៅទីនោះ ។ ឯដំរីរបស់ពួកឥស្សរជនទាំងឡាយ ដែលជិះទៅក្នុងទីនោះ ក៏ផ្អើលស្ទុះស្រែកជាខ្លាំង, ពួកមហាជនភ័យនឹងដំរី ស្ទុះរត់ច្រូលច្របល់ទៅជាន់នាងសេសវតីនោះស្លាប់ទៅ, នាងបានទៅកើតក្នុងស្ថានត្រៃត្រឹង្សទេវលោក ស្ថិតនៅក្នុងវិមានប្រាសាទមាសរំលេចដោយកែវ ៧ ប្រការ មានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ។ ថ្ងៃមួយនាងសេសវតីទេពធីតា បានរំលឹកឃើញបុញ្ញកម្មរបស់នាង ក៏ចុះមកទាំងវិមាន មកថ្វាយបង្គំព្រះសម្ពុទ្ធក្នុងវត្តជេតពន ។ កាលនោះព្រះវង្គីសត្ថេរ លោកកំពុងអង្គុយគាល់ព្រះមានព្រះភាគ បានឃើញនាងទេពធីតានោះ ក៏សួរបុញ្ញកម្មរបស់នាង ៗ បានប្រាប់ដោយសព្វគ្រប់ ។ ព្រះសម្ពុទ្ធទ្រង់ប្រារព្ធហេតុនោះហើយ ក៏សំដែងនូវធម្មទេសនា សរសើរអានិសង្សនៃការបូជាព្រះសារីរិកធាតុ ជាភិយ្យោភាពតទៅ ។

# ២១. រឿងទិសាបាមោក្ខព្រាហ្មណ៍

( ចាក អ. ឯ. )

( ការមិនប្រាកដ មិនស្គាល់កាល ជាថ្នាំពិសក្នុងលោក )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូរបស់យើង ទ្រង់សោយព្រះជាតិក្នុងត្រកូលព្រាហ្មណ៍ឈ្មោះឧទិច្ចៈ លុះមានវ័យចំរើនឡើង ទ្រង់បរិបូណ៌ដោយរូបកាយនិងសតិបញ្ញាប្រសើរវិសេសជាងព្រាហ្មណ៍ទាំងអស់ក្នុងជាតិភូមិ ។ ព្រាហ្មណ៍ជាមាតាបិតា បានបញ្ជូនឱ្យទៅរៀនសិល្បសាស្ត្រក្នុងមហាវិទ្យាល័យក្រុងពារាណសី មិនយូរប៉ុន្មាន ព្រាហ្មណ៍បុត្រ ក៏បានចេះចប់ត្រៃវេទ ហើយយល់នូវអត្ថនិងធម៌ដ៏ជ្រាលជ្រៅ ។ ព្រះបាទព្រហ្មទត្តបានជ្រាបថា ព្រាហ្មណ៍បុត្រជាអ្នកប្រាជ្ញវិសេសដូច្នោះ ក៏តាំងឱ្យធ្វើជាអាចារ្យទិសាបាមោក្ខ ក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គ ។ ទិសាបាមោក្ខព្រាហ្មណ៍ ក៏បានបង្រៀនសិល្បសាស្ត្រដល់មាណព ៥០០ នាក់. ក្នុងវិជ្ជាស្ថានដែលបង្រៀននោះ មានមាន់មួយរងាវត្រូវកាល. មាណពទាំងឡាយ តែងក្រោកឡើងស្វាធ្យាយសិល្បសាស្ត្រដោយសំឡេងមាន់រងាវនោះគ្រប់ ៗ គ្នា ។ មាណពទាំងឡាយតែងនាំគ្នារក្សាមាន់នោះដោយប្រពៃ ។ ក្នុងកាលជាខាងក្រោយមកមាន់នោះក៏ស្លាប់ទៅ បាននាំគ្នារកមាន់មួយទៀត ។ គ្រានោះមាន

មាណពម្នាក់ ចូលទៅកាប់ឧសក្នុងព្រៃខ្មោច បានឃើញមាន់ឈ្មោលមួយ ក៏ចាប់យកមកចិញ្ចឹមទុកក្នុងទ្រុង ដើម្បីឱ្យរងាវ ។ មាន់នោះជាសត្វមិនមានប្រក្រតី មិនស្គាល់កាល ចេះតែរងាវមិនប្រាកដ ព្រោះជាសត្វកើតក្នុងព្រៃខ្មោចតែម្នាក់ឯង មិនដែលឮសូររងាវរបស់មាន់ចាស់ ៗ ឡើយ ជាសត្វប្រាសចាកដំបូន្មាន ជួនកាលរងាវក្នុងវេលាអាធ្រាត្រ ជួនកាលរងាវក្នុងពេលអរុណរះ ជួនកាលរងាវក្នុងវេលាថ្ងៃត្រង់។ មាណពទាំងនោះ ជួនកាលក្រោកកណ្ដាលអាធ្រាត្រសិក្សាសិល្បសាស្ត្រក៏មាន ជួនកាលដេកលក់ដល់អរុណរះក៏មាន ជាអ្នកមានការសិក្សាមិនប្រាកដ. សិល្បសាស្ត្រទាំងឡាយកាលបើខ្វះការស្វាធ្យាយហើយ ក៏ភ្លេចបាត់បង់អស់ជាច្រើន ទើបមាណពទាំងនោះប្រឹក្សាគ្នាថា មាន់នេះគ្មានប្រក្រតីទេ ជាសត្វមិនស្គាល់កាល រងាវមិនប្រាកដ បើយើងយកមាន់នេះជាប្រមាណ មុខតែវិនាសសិល្បសាស្ត្រអស់មិនខាន. និយាយប្រឹក្សាគ្នាដូច្នេះហើយក៏ចាប់មូលកមាន់នោះស្ងោរស៊ីទៅ (នេះហើយហៅថាមាន់សម្ល បើជាមនុស្សវិញហៅថាមនុស្សសម្ល) ។ មាណពទាំងនោះ ក៏នាំគ្នាទៅជំរាបអាចារ្យទិសាបាមោក្ខថា មាន់ដែលចាប់ពីព្រៃខ្មោចមក ចេះតែរងាវខុសវេលា យើងខ្ញុំទាំងឡាយមូលកសម្លាប់ទៅហើយ ។ អាចារ្យទិសាបាមោក្ខ ក៏និយាយប្រាប់សិស្សទាំងនោះថា មាន់នេះជាសត្វមិនចំរើនឡើងក្នុងសំណាក់មាតាបិតា មិនដែលនៅក្នុង

សំណាក់អាចារ្យទេ បានជាមិនដឹងនូវកាលគួរនឹងមិនគួរ ការមិនដឹងនេះហើយ ជាទោសរបស់មាន់នោះ ។

## ២២. រឿងនាងលតា

( ចាក វិ. ខុ. )

( គុណនៃការរក្សាឧបោសថសីល តាំងពីក្មេងដរាបដល់ចាស់ )

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅក្នុងជេតវនមហាវិហារ ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី នាក្រុងសាវត្ថី ។ កាលនោះមានធីតាម្នាក់ឈ្មោះនាងលតា ជាកូនរបស់សាវត្ថីឧបាសក ។ នាងលតាធីតានោះ ជាស្ត្រីមានប្រាជ្ញាឈ្លាសវៃ ចេះដឹងនូវច្បាប់ព្រះពុទ្ធសាសនាជាច្រើន មាតាបិតាបានរៀបឱ្យមានគូស្វាមីភរិយា, ក្នុងពេលដែលរៀបអាវាហមង្គលនោះ បាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានទៅថ្វាយភត្ត លុះរៀបមង្គលការហើយ ក៏បញ្ជូនឱ្យទៅនៅក្នុងសំណាក់មាតាបិតាក្មេក ។ នាងលតា ជាស្ត្រីមានមាយាទល្អត្រឹមត្រូវ ខំប្រតិបត្តិបំរើស្វាមីនិងមាតាបិតាក្មេកដោយគោរព ទាំងមានចិត្តអាណិតអាសូរដល់ទាសកម្មកររបស់នាង តែងចែកចាយសំពត់សាវអាវស្បៀងម្ហូបចំណី ដល់ទាសកម្មករជារឿយៗ, វេលាថ្ងៃឧបោសថ នាងបានរក្សាឧបោសថសីលជានិច្ចពុំដែលខានឡើយ ។

ឯមាតាបិតាក្មេក ឃើញកូនប្រសារមានចរិយាល្អដូច្នោះ ក៏មានសេចក្តីស្រឡាញ់ពេញចិត្តជាទីបំផុត ព្រោះជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដូចគ្នា។ ក្នុងកាលជាខាងក្រោយមក នាងលតានោះ ក៏ធ្វើមរណកាលទៅ បានទៅកើតជាធីតារបស់ស្តេចវេស្សវ័ណ នាស្ថានចាតុមហារាជិកាទេវលោក មានឈ្មោះថាលតាដូចជាឈ្មោះក្នុងស្ថានមនុស្ស ។ ឯព្រះបាទវេស្សវ័ណនោះ មានព្រះរាជធីតា ៥ អង្គគឺ : នាងលតា១, សជ្ជា១, បវរា១, អច្ចិមុតី១, សុត្រា១ កាលបើនាងធីតាទាំង ៥ នេះកើតហើយ សក្កទេវរាជ ក៏នាំយកទៅស្ថានត្រៃត្រឹង្ស ឱ្យធ្វើជាបាទបរិចារិការបស់ព្រះអង្គ តែងឱ្យនាងទាំង ៥ លេងរបាំថ្វាយទតរាល់ ៧ ថ្ងៃ ។ ថ្ងៃមួយធីតាទាំង ៥ បានជជែកគ្នាថា យើងទាំងអស់គ្នានេះអ្នកណារាំច្រៀងពិរោះល្អជាងគេ នាងមួយថាខ្លួនគ្រាន់បើ, នាងមួយទៀតថាខ្លួនគ្រាន់បើជាង, ជជែកមិនដាច់ស្រេច ក៏នាំគ្នាទៅថ្វាយបង្គំព្រះបាទវេស្សវ័ណជាបិតា ហើយទូលសួរថា បពិត្រព្រះបិតា នាងខ្ញុំទាំង ៥ រូបនេះ នាងណារាំច្រៀងល្អពិរោះជាងគេ ? ។ ព្រះបាទវេស្សវ័ណ បានឮព្រះរាជបុត្រីសួរដូច្នោះហើយក៏ប្រាប់ថា ម្នាលកូនសំឡាញ់ឪពុក បើនាងចង់ដឹង ចូរនាំគ្នាទៅរាំច្រៀងក្នុងទីប្រជុំនៃទេវតាក្បែរមាត់ស្រះអនោតត្ត នាព្រៃហេមពាន្តឯណោះទើបដឹងប្រាកដបាន ។ ព្រះរាជបុត្រីទាំង ៥ អង្គ ក៏នាំគ្នាទៅរាំច្រៀងក្បែរមាត់ស្រះអនោតត្ត តាម

ព្រះរាជបញ្ញារបស់បិតា ។ ក្នុងពេលនោះទេវតាទាំងឡាយបានដឹងដំណឹងនោះហើយ ក៏នាំគ្នាឈូចរទៅប្រជុំនៅព្រៃហេមពាន្ត ច្រើនមីរដេរដាសពេញព្រៃទាំងមូល ។ ពេលនោះព្រះរាជបុត្រី ក៏ឡើងរាំច្រៀងម្តងម្នាក់ ៗ ដរាបដល់អស់ ៤ នាក់នៅសល់តែនាងលតាមួយពុំទាន់ច្រៀង. កាលបើធីតាទាំង ៤ នោះច្រៀងចប់ហើយ ពួកទេវតាទាំងឡាយ ក៏នៅស្ងាត់ឈឹងឥតឮសូរស័ព្ទសាធុការឡើយ ។ បន្ទាប់ពីនោះមកនាងលតា ក៏ក្រោកឡើងរាំ ស្រែកច្រៀងមានសំឡេងពិរោះ ឮណែនពេញព្រៃហេមពាន្តទាំងមូល លុះរាំច្រៀងចប់ហើយពួកទេវតាទាំងឡាយ ក៏ស្រែកឱ្យពរស័ព្ទសាធុការឮលាន់កក្រើកញាប់ញ័រព្រៃហេមពាន្ត ។ លំដាប់នោះនាងសុត្រាជាព្រះរាជបុត្រីពៅបង្អស់ នឹកស្ងើចអស្ចារ្យក្នុងចិត្ត ទើបសួរទៅនាងលតាជាបងថា បងបានធ្វើបុណ្យដូចម្តេចពីជាតិមុន បានជាមានរូបល្អមានសំឡេងពិរោះ មានប្រាជ្ញាច្រើន ? ។ នាងលតាប្រាប់ថា បានជាបងមានរូបល្អ មានសំឡេងពិរោះ មានប្រាជ្ញាច្រើនដូច្នេះ កាលពីជាតិមុន បងបានរក្សាឧបោសថសីលតាំងពីក្មេងដរាបដល់ចាស់ ពុំដែលឱ្យដាច់ធ្លុះធ្លាយម្តងឡើយ ។

## ២៣. រឿងឥល្លិសសេដ្ឋី

( ចាក ឥ. តិ. )

( មាតាបិតាតែងប្រាថ្នាឱ្យប្រយោជន៍ ដល់បុត្រធីតា )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះមានមហាសេដ្ឋីម្នាក់ មានសទ្ធាមាំក្នុងព្រះពុទ្ធសាសនា បានបំពេញសត្តបទទាំង ៧ ប្រការដោយបរិបូណ៌ ជាអ្នកពេញចិត្តក្នុងការឱ្យទាន បានសង់សាលាឆទានជាច្រើនខ្នង ។ មហាសេដ្ឋីនោះ មានកូនប្រុសមួយឈ្មោះឥល្លិស ជាទីស្រឡាញ់ពេញចិត្តក្រៃពេក ដល់ពេលជិតស្លាប់ បានហៅឥល្លិសជាកូនមកប្រគល់ទ្រព្យសម្បត្តិឱ្យ ហើយប្រាប់ឱ្យខំធ្វើទានតាមដំណើរដែលខ្លួនបានធ្វើ លុះស្លាប់ទៅ បានទៅកើតជាព្រះឥន្ទ្រ ។ ព្រះបាទព្រហ្មទត្ត កាលបើមហាសេដ្ឋីស្លាប់ហើយ ក៏តាំងឥល្លិសសេដ្ឋីបុត្រនោះជាមហាសេដ្ឋី ។ ឯឥល្លិសសេដ្ឋីនោះ ជាមនុស្សពិការមានជើងខ្វក ដៃក្ញែង ភ្នែកស្រលៀង ក្បាលពក ហើយជាមនុស្សកំណាញ់ស្វិតជាទីបំផុត ។ ថ្ងៃមួយឥល្លិសសេដ្ឋី ចង់ផឹកសុរា ក៏គិតថានឹងបិទសុរាក្នុងផ្ទះ ក្រែងជនដទៃដណ្ដើមផឹក ទើបកាន់យកសម្ភារៈសំរាប់បិទសុរា មួយមុខបន្តិចៗ ចូលទៅបិទក្នុងព្រៃឆ្ងាយអំពីភូមិ ។ ចំណែកខាងមហាសេដ្ឋីជាបិតា ដែលបានទៅកើតជាព្រះឥន្ទ្រ បានដឹងថា ឥល្លិសសេដ្ឋីជាកូនកំណាញ់ស្វិតស្វាញ បាន

ចូលទៅទៅបិទស្រាក្នុងព្រៃដូច្នោះហើយ ក៏ចុះមកនិម្មិតជាឥល្លិសសេដ្ឋី ដើរចេញពីដងព្រៃមកវិញ ។ ពួកមហាជនបានឃើញហើយក៏គិតថា ឥល្លិសសេដ្ឋីប្រហែលជាស្រវឹងស្រា បានជាមានអាការៈខុសប្រក្រតី ។ ឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិតនោះ ក៏ចូលទៅក្នុងព្រះបរមរាជវាំង លើកទ្រព្យសម្បត្តិទាំងអស់ថ្វាយដល់ព្រះបាទព្រហ្មទត្ត ។ ពុំព្រមទទួល ទើបក្រាបទូលថា បើមហារាជពុំទទួលទេខ្ញុំព្រះអង្គនឹងចំណាយទាន សូមថ្វាយព្រះរាជកុសលដល់ព្រះអង្គ ។ ព្រះបាទព្រហ្មទត្តទ្រង់ទទួលហើយនឹកស្ងើចក្នុងព្រះទ័យថា ឥល្លិសសេដ្ឋី កាលពីដើមជាមនុស្សកំណាញ់ណាស់ ឥឡូវនេះក៏មានសទ្ធាមាំម្ល៉េះ ! ។ ឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិតនោះ ត្រឡប់ពីព្រះបរមរាជវាំងទៅផ្ទះវិញ បានប្រកាសប្រាប់មហាជនឱ្យចូលទៅទទួលយកទាន ។ ពេលនោះមានបុរសម្នាក់ទទួលយកទានបានគោនិងរទេះផ្ទុកទ្រព្យពេញបរចេញទៅក្បែរដងព្រៃ ដែលឥល្លិសសេដ្ឋីបិទស្រាហើយស្រែកឱ្យពរដល់ឥល្លិសសេដ្ឋីដោយសំឡេងយ៉ាងខ្លាំង ។ ឥល្លិសសេដ្ឋី ឮសំឡេងឱ្យពរដល់ខ្លួនហើយ ក្រឡេកមើលទៅស្គាល់ជាគោរទេះរបស់ខ្លួន ក៏រត់ទៅចាប់មុខរទេះ ហើយចោទប្រកាន់អ្នកបររទេះនោះថា លួចគោលួចរទេះរបស់ខ្លួន ។ អ្នកបររទេះប្រាប់ថារទេះនិងគោនេះ ឥល្លិសសេដ្ឋីដាក់ទានឱ្យខ្ញុំ។ មិនមែនលួចយកទ្រព្យរបស់អ្នកទេ, ឥល្លិសសេដ្ឋីនិងអ្នកបររទេះ បានជជែកគ្នាខ្លាំងឡើង ។

ដរាបដល់ចាប់ចំបាប់គ្នា ឯអ្នកបររទេះ បានចាប់ប្រានឥល្លិសសេដ្ឋី ដួលទៅលើផែនដី ហើយបររទេះដឹកឥវ៉ាន់យកទៅផ្ទះទៅ ។ ឥល្លិសសេដ្ឋីខឹងណាស់, ឈប់បិទស្រាដើរត្រឡប់មកផ្ទះវិញ លុះមកដល់ខ្លោងទ្វារអ្នកចាំទ្វារ មិនឱ្យចូលដោយអាងថាសេដ្ឋីរបស់ខ្លួនកំពុងចែកទានទៅខាងក្នុង ។ ឥល្លិសសេដ្ឋី កាលបើមិនបានចូលទៅក្នុងផ្ទះរបស់ខ្លួនហើយ សេចក្ដីក្រោធក៏កាន់តែកើតឡើងជាខ្លាំង ទើបចូលទៅក្រាបទូលដល់ព្រះបាទព្រហ្មទត្តថា បពិត្រមហារាជ ថ្ងៃនេះមានមនុស្សអាក្រក់ ចូលទៅលួចទ្រព្យរបស់ទូលព្រះបង្គំដាក់ទានឱ្យមហាជន ។ ព្រះរាជាទ្រង់ត្រាស់ថា អម្បាញ់មិញនេះអ្នកមកប្រាប់ថា លើកសម្បត្តិទាំងអស់ឱ្យយើង ៗ មិនព្រមទទួល អ្នកប្រាប់ម្ដងទៀតថានឹងបរិច្ចាគទាន ថែមទាំងបានថ្វាយកុសលដល់យើងទៀត ចុះពេលនេះហេតុអ្វីបានជាអ្នកមកនិយាយដូច្នេះវិញ ។ ឥល្លិសសេដ្ឋីក្រាបទូលដាច់អហង្ការថា មិនដឹងសោះ ហើយទូលសូមឱ្យហៅខ្លួនអ្នកទូលមុនមកពិចារណា ។ ព្រះបាទព្រហ្មទត្តទ្រង់ចាត់ឱ្យរាជអាមាត្យ កោះយកខ្លួនអ្នកចុងចម្លើយ ៗ មកដល់ស្រាប់តែមានរូបដូចគ្នា ឥតប្លែកត្រង់ណាឡើយ, អ្នកដើមចោទថាខ្លួនជាឥល្លិសសេដ្ឋី អ្នកចុងចោទក៏ថាខ្លួនជាឥល្លិសសេដ្ឋីដែរ, ជជែកតវ៉ាគ្នាមិនដាច់ស្រេច ទើបអ្នកដើមចោទអាងយកមនុស្សក្នុងផ្ទះជាបន្ទាល់សាក្សី, ឯបន្ទាល់សាក្សីនោះបានចង្អុលយកអ្នកចុងចម្លើយ

ថាជាសេដ្ឋីរបស់ខ្លួន. អ្នកដើមចោទគឺឥល្លិសសេដ្ឋីមែនទែននោះមិនព្រម និយាយអាងថា ខ្លួនមានពកត្រង់ក្បាលមានតែជាងកាត់សក់ទើបដឹង ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូ ទ្រង់សោយព្រះជាតិជាជាងកាត់សក់ ។ ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់បង្គាប់ឱ្យហៅជាងកាត់សក់នោះមក ជាងកាត់សក់មកដល់ បានសង្កេតមើលសព្វគ្រប់ហើយក្រាបទូលថា មនុស្សពីរនាក់នេះមានជើងខ្វក ដៃក្ញែង ភ្នែកស្រលៀង ក្បាលពកដូចគ្នា ខ្ញុំព្រះអង្គមិនដឹងថាអ្នកណាជាឥល្លិសសេដ្ឋីឡើយ ។ ឥល្លិសសេដ្ឋីមែនទែន ឮដូច្នោះហើយ នឹកតូចចិត្តណាស់ទាល់តែខ្យល់ចាប់ដួលទៅ ។ ពេលនោះឥល្លិសសេដ្ឋីគឺព្រះឥន្ទ្រនិម្មិត ក៏ក្លាយខ្លួនជាព្រះឥន្ទ្រវិញ ហោះឰដ៍អាកាស. លុះឥល្លិសសេដ្ឋីដឹងខ្លួនឡើង ទើបប្រាប់ថា ខ្ញុំជាបិតារបស់ឥល្លិសសេដ្ឋី បានសង់រោងទានបំពេញការកុសលជរាបដល់អស់អាយុ បានមកកើតជាព្រះឥន្ទ្រ ។ ឯឥល្លិសសេដ្ឋីកូនខ្ញុំនេះ ជាមនុស្សកំណាញ់ស្វិតស្វាញអាក្រក់ បានជាខ្ញុំមកទូន្មានប្រដៅឱ្យលះបង់គំនិតអាក្រក់នោះចេញ ។ ទីបំផុតព្រះឥន្ទ្របានបង្គាប់ឱ្យឥល្លិសសេដ្ឋី ប្ដេជ្ញាខ្លួនជាអ្នកបរិច្ចាគទាន បំពេញការកុសល. ឥល្លិសក៏ព្រមប្រតិបត្តិតាម ទើបព្រះឥន្ទ្រហោះទៅស្ថានត្រៃត្រឹង្សវិញ ។

## ២៤. រឿងអញ្ញតរឧបាសិកា

( ចាក វិ. ខុ. )

( គុណនៃការអុជប្រទីប បូជាធម្មទេសនា )

កាលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងវត្តជេតពន, ថ្ងៃមួយ ព្រះមោគ្គល្លានត្ថេរ បាននិមន្តទៅស្ថានត្រៃត្រឹង្ស ឃើញវិមានប្រាសាទរបស់នាងទេពធីតាម្នាក់ ជាវិការៈនៃកែវមណីជោតិ មានពន្លឺរស្មីថែងចាំងផ្សាយទៅពេញទេវលោកទាំងមូល គ្របសង្កត់ពន្លឺនៃទេវតាទាំងពួង ។ នាងទេពធីតាជាម្ចាស់ប្រាសាទ បានឃើញព្រះមោគ្គល្លានត្ថេរហើយ ក៏ប្រញាប់ប្រញាល់នាំបរិវារទាំងមួយពាន់ចុះអំពីប្រាសាទមកថ្វាយបង្គំ ។ ព្រះមោគ្គល្លានត្ថេរបានសួរថា ម្នាលនាងទេពធីតា អ្នកបរិបូណ៌ដោយទិព្វសិរី នាងបានធ្វើបុណ្យអ្វីពីជាតិមុនមក បានជាមានពន្លឺចាំងថែងចិញ្ចាចដូច្នេះ ? ។ នាងទេពធីតាបានថ្លែងរៀបរាប់ប្រវត្តិរបស់ខ្លួន ប្រាប់ដល់ព្រះមហាមោគ្គល្លានថា បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាទើបនឹងមកពីស្ថានមនុស្សក្នុងពេលព្រឹកមិញនេះ. កាលពីថ្ងៃឧបោសថម្សិលមិញ ខ្ញុំព្រះករុណា បានទៅស្តាប់ធម៌ទេសនា ក្នុងវត្តជេតពន ជាមួយនឹងពុទ្ធបរិស័ទទាំងឡាយ កំពុងតែស្តាប់ធម៌ព្រះអាទិត្យក៏អស្តង្គតទៅ ខ្ញុំព្រះករុណាបានគិតថា ព្រះធម៌ទេសនាមិនទាន់ចប់ ងងឹតក៏កាន់តែចំរើនឡើង ៗ គួរតែអញទៅយកប្រទីបមកអុជ. លុះគិតដូច្នេះហើយ

សេចក្តីជ្រះថ្លាក៏កាន់តែកើតឡើង ទើបក្រោកដើរទៅគេហស្ថាន របស់ខ្ញុំព្រះករុណា យកទៀនមួយគូនិងជើងទៀនកែវមួយគូមកអុជ ហើយយកទៅដំកល់លើតាំងមុខគ្រែទេសនា បានអង្គុយស្តាប់ធម៌ ផរាបដល់ចប់. លុះត្រឡប់ពីស្តាប់ធម៌ទៅផ្ទះវិញ ខ្ញុំព្រះករុណាកើត រោគខ្យល់ក៏ធ្វើមរណកាលក្នុងពេលនោះ ស្រាប់តែបានមកកើតក្នុង វិមានកែវមណីជោតិ នាស្ថានត្រៃត្រឹង្សនេះឯង ។ ព្រះមោគ្គល្លាន បានជ្រាបដំណឹងនោះហើយ ក៏និមន្តហួសទៅទីដទៃទៀតទៅ ។

## ២៥~ រឿងយមលោកនិងទេវលោក

( ចាក អ. ម. )

( អានិសង្សនិងទោស របស់កុសលាកុសលកម្ម )

កាលព្រះបរមគ្រូសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តជេតពន នាក្រុង សាវត្ថី ។ កាលនោះព្រះមហាមោគ្គល្លានដ៏មានអាយុ ជាអ្នកមាន ឫទ្ធិច្រើន មានបំណងចង់ទៅមើលស្ថាននរក បានចូលទៅថ្វាយបង្គំ លាព្រះសម្ពុទ្ធជាបរមគ្រូហើយ ក៏និមន្តទៅយមលោកពិនិត្យមើល ស្ថានភាពទីកន្លែងនរក តាំងពីនរកតូចៗ រហូតដល់នរកធំឈ្មោះ អវិចី, លោកនិមន្តទៅដល់ទីណា សត្វនរកក៏បានស្បើយទុក្ខក្នុងទី នោះ ដោយអំណាចឫទ្ធិរបស់លោក ។ មហានរកឈ្មោះអវិចី កាល បើព្រះមហាមោគ្គល្លាននិមន្តទៅដល់ហើយ គំនរភ្លើងក៏វិនាសបាត់

ទៅ មានផ្កាឈូកប៉ុនកង់រទេះផុះឡើង លោកក៏ឡើងគង់លើផ្កាឈូកនោះ ។ ពួកសត្វនរកទាំងឡាយ បានចូលទៅចោមរោមថ្វាយបង្គំសួរថា លោកម្ចាស់និមន្តមកអំពីទីណា ? ។ ព្រះមោគ្គល្លានប្រាប់ថា អាត្មាមកពីមនុស្សលោក ។ សត្វនរកទាំងឡាយ បានឮដូច្នោះហើយ ក៏ផ្តាំងទៅញាតិមិត្ររបស់ខ្លួនថា សូមលោកម្ចាស់ប្រាប់ដល់មាតាបិតាបុត្រភរិយា ញាតិមិត្ររបស់ខ្ញុំព្រះករុណាផង ខ្ញុំព្រះករុណាជាកូន ជាឪពុកម្តាយ ជាមីងមា ធ្លាក់ទៅកើតក្នុងនរកសោយទុក្ខវេទនាជាយូរយាណាស់ហើយ មានសេចក្តីនឹករលឹកមកជាខ្លាំងណាស់ អាណិតធ្វើបុណ្យទានឧទ្ទិសផលបញ្ជូនឱ្យផង ។ ព្រះមោគ្គល្លានបានទទួលដំណឹងនោះហើយ ក៏ត្រឡប់មកមនុស្សលោកវិញ. មុននឹងត្រឡប់មក លោកបានយកភ្លើងអវិចីប៉ុនគ្រាប់ស្ពៃ ខ្ចប់នឹងជាយចីវររបស់លោកដោយឫទ្ធិ. មកដល់មនុស្សលោក បានប្រកាសប្រាប់ញាតិមិត្រ មាតាបិតារបស់សត្វនរកទាំងនោះតាមបណ្តាំ ។ ពួកមហាជនទាំងឡាយ ដែលត្រូវជាញាតិមិត្ររបស់សត្វនរក បានដឹងដូច្នោះហើយ ក៏យំសោកបោកខ្លួនប្រាណតែសព្វខ្លួន លុះបន្ទោរបង់នូវសេចក្តីសោកនោះហើយ បាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន មកថ្វាយទក្ខិណាទាន ឧទ្ទិសបញ្ជូនផលទៅសត្វនរកទាំងនោះ. ដោយអំណោយរបស់ព្រះមោគ្គល្លាន និងដោយសត្វនរកទាំងនោះមានចិត្តទន្ទឹងចាំតែទទួលផលផង ក៏បានទទួល

ដូចបំណង ។ ពេលនោះសត្វនរកទាំងឡាយ បានរួចចាកទុក្ខទៅកើតក្នុងស្ថានសួគ៌ជាច្រើន ដូចមានបាលីក្នុងគម្ពីរនោះថា **តេ និរយកសត្តា ឧក្ខតោ មុញ្ចន្តិ តតោ ចវិត្វា សគ្គបទំ បូរយឹសុ** សត្វនរកទាំងនោះបានរួចចាកទុក្ខ ទៅកើតក្នុងស្ថានសួគ៌មីរដេរដាសត្រៀបត្រា ។ ក្នុងពេលនោះព្រះមោគ្គល្លាន បាននិមន្តទៅស្ថានសួគ៌ទៀត ទៅពិនិត្យមើលភូមិភាគ និងសុខភាពរបស់ពួកទេពតាក្នុងស្ថានសួគ៌ទាំង ៦ ជាន់, បាននិមន្តទៅឈរវេរានៅស្ថានត្រៃត្រឹង្ស ។ ពេលនោះពួកទេវតាក្នុងសួគ៌ទាំង ៦ ជាន់ក្តៅក្រហល់ក្រហាយនឹងចំហាយភ្លើងអវិចី ដែលខ្ចប់នឹងជាយចីវរនោះគ្រប់ ៗ គ្នា ។ សក្កទេវរាជ បានជ្រាបហេតុហើយ ទៅប្រគេនសញ្ញាដល់ព្រះមោគ្គល្លាន ៗ យល់ថា ទេវតាទាំងអស់ ក្តៅក្រហាយដោយកំទេចភ្លើងដែលជាប់នឹងជាយចីវររបស់អញទេតើ ! បានជាផ្ទៃផ្ទាយ៉ាងនេះ, លោកគិតថាភ្លើងប៉ុនគ្រាប់ស្ពៃនេះ មានកំឡាំងក្តៅខ្លាំងណាស់ បើអាត្មាអញចោលទៅលើផែនដី នឹងឆេះខ្ទេចខ្ទីអស់, ចោលទៅក្នុងសមុទ្រនឹងរីងខះទឹកអស់ឥតសល់, ចោលទៅឰដ៏អាកាសនឹងរាំងភ្លៀងអស់ ១២ ឆ្នាំ បើដូច្នោះមានតែអាត្មាអញយកទៅចោលនៅកន្លែងអវិចីវិញ ក៏យកទៅចោលក្នុងអវិចីនោះទៅហើយនិមន្តទៅថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូ ក្រាបទូលដំណើងអំពីយមលោក និងទេវលោកដោយសព្វគ្រប់ ។ ព្រះសម្ពុទ្ធទ្រង់ប្រារព្ធ

នូវហេតុនោះហើយ ក៏ប្រទាននូវធម្មទេសនាដល់ពុទ្ធបរិស័ទទាំងឡាយថា :

**នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ**
**អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ**

សភាវៈពីរប្រការគឺ : កុសលធម៌ ១. អកុសលធម៌ ១ ឱ្យផលមិនស្មើគ្នា អកុសលធម៌តែងនាំសត្វទៅនរក. កុសលធម៌តែងនាំសត្វទៅស្ថានសួគ៌ ។

លុះចប់នៅធម្មទេសនានេះហើយ ពួកពុទ្ធបរិស័ទទាំងឡាយបានលុះនូវមគ្គាភិសម័យ ចំនួន ៣ ម៉ឺន ៤ ពាន់នាក់ក្នុងវេលានោះឯង ។

## ២៦. រឿងនាងរជ្ជុមាលា

( ចាក វិ. ខុ. )

( ការមិនប្រទូស្ត ជាសិរីក្នុងលោក )

កាលព្រះសម្ពុទ្ធគង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ កាលនោះ មានកុមារីម្នាក់ជាកូនរបស់ទាសី អ្នកបំរើព្រាហ្មណ៍ម្នាក់ក្នុងស្រុកគយា ។ ឯនាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះតាំងតែពីនាងកុមារីកូនទាសីរបស់ខ្លួនកើតឡើង មិនដែលបានសប្បាយចិត្តសោះ. តែឃើញកុមារីនោះកាលណា សេចក្ដីក្រោធ

កើតឡើងក្នុងកាលនោះ ។ ចំណែកនាងកុមារីដល់ធំឡើង ក៏បំរើនាងព្រាហ្មណីជាមួយនឹងម្ដាយ ប៉ុន្តែនាងពុំដែលបានសប្បាយចិត្តសោះ ព្រោះនាងព្រាហ្មណី ចេះតែវាយតប់ជេរប្រទេចជានិច្ចរាល់ថ្ងៃ ។ ថ្ងៃមួយនាងកុមារីនោះ ទៅរកទាសីនាយសំពៅគោរសក់ឱ្យលុះគោរហើយប្រញាប់ប្រញាល់ត្រឡប់មកវិញ. នាងព្រាហ្មណីក្រឡេកឃើញក្បាលត្រងោលខឹងណាស់ ទើបយកខ្សែគោមួយចង្វាយ ស្ទុះទៅសំពងនាងកុមារីនោះ ហើយចងកនាងដឹកយកទៅផ្ទះ ខ្សែដែលចងនោះមិនស្រាយឡើយ ទើបមនុស្សទាំងឡាយហៅនាងកុមារីនោះថារជ្ជុមាលា ។ នាងរជ្ជុមាលានេះ បានជាចៅហ្វាយចេះតែស្អប់ឃើញមុខមិនបាន ព្រោះកាលជាតិមុនក្នុងសាសនាព្រះពុទ្ធកស្សប នាងជាចៅហ្វាយរបស់នាងព្រាហ្មណី បានវាយទះតប់ទាសីរបស់ខ្លួនឥតត្រាប្រណីឡើយ បានជាពៀរនោះតាមជាប់មកបណ្ដាលឱ្យនាងព្រាហ្មណីជេរប្រទេច វាយទះតប់ខ្លួនវិញ ។ ឯនាងរជ្ជុមាលានេះ ជាស្ត្រីមានចិត្តធ្ងន់បំផុត មិនដែលខឹងតបត ដោយពាក្យសំដី ឬដោយអាការណាមួយ ចំពោះនាងព្រាហ្មណីជាចៅហ្វាយឡើយ ។ ថ្ងៃមួយព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ប្រមើលមើលនិស្ស័យសត្វ បានជ្រាបថានាងរជ្ជុមាលា ជាស្ត្រីមាននិស្ស័យខ្ពស់ត្រូវបានសម្រេចដល់សោតា ។ លុះទ្រង់ជ្រាបដូច្នេះហើយ ពេលថ្ងៃរសៀល ក៏និមន្តទៅគង់ក្នុងព្រៃក្រោមឈើមួយដើមក្បែរភូមិនាង

ព្រាហ្មណីនោះ ។ ឯនាងវដ្ឋមាលា កាលបើចៅហ្វាយចេះតែធ្វើបាបខ្លាំងដូច្នោះ នាងព្រួយចិត្តខ្លាំងណាស់ ក៏កាន់ក្អមធ្វើជាទៅដងទឹក ហើយលួចរត់ចូលទៅក្នុងព្រៃដើម្បីចងក. ទៅដល់ឃើញឈើធំមួយក៏ឡើងទៅខាងលើ យកខ្សែម្ខាងចងក ខ្សែម្ខាងចងភ្ជាប់ទៅមែកឈើបំរុងនឹងលោតសម្លាប់ខ្លួន. ស្រាប់តែឃើញព្រះសម្ពុទ្ធគង់ក្រោមម្លប់ឈើមួយដើម ក្បែរឈើដែលខ្លួនឡើងនោះ. សេចក្ដីជ្រះថ្លាក៏កើតឡើង ទើបស្រាយខ្សែអំពីក ហើយចុះទៅថ្វាយបង្គំព្រះសម្ពុទ្ធ ៗ ទ្រង់ត្រាស់សួរថា នាងមកមានការអ្វី ? ។ នាងវដ្ឋមាលាបានថ្លែងប្រវត្តិរបស់ខ្លួនថ្វាយព្រះសម្ពុទ្ធជាម្ចាស់ តាំងពីដើមដរាបដល់ចប់. លុះចប់ហើយព្រះសម្ពុទ្ធទ្រង់សំដែងអនុបុព្វិកថាឱ្យនាងស្ដាប់. នាងខំផ្ចង់ស្មារតីស្ដាប់ដរាបដល់ចប់ ក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយបង្គំលាព្រះសម្ពុទ្ធ កណ្ដៀតក្អមដងទឹកទៅផ្ទះវិញ ។ កាលនោះ ព្រាហ្មណ៍ជាស្វាមីរបស់នាងព្រាហ្មណី កំពុងអង្គុយនៅមាត់ទ្វារ បានឃើញនាងវដ្ឋមាលាមានទឹកមុខស្រស់បស់ជាងសព្វដងក៏សួរថា នាងទៅណាយូរម្ល៉េះ ? មកវិញស្រាប់តែញញឹមញញែម ។ នាងប្រាប់ចៅហ្វាយថា ខ្ញុំបានជួបនឹងព្រះសម្ពុទ្ធព្រះអង្គនៅក្នុងដងព្រៃក្បែរភូមិ ខ្ញុំស្ដាប់ធម៌របស់ព្រះអង្គបានជាយូរក្រមក ។ មនុស្សទាំងឡាយក្នុងស្រុកគយា បានឮថា ព្រះមានព្រះភាគនិមន្តមក ក៏នាំគ្នាទៅបបួលនាងព្រាហ្មណី ទៅថ្វាយបង្គំព្រះ

សម្តុទ្ទ ។ កាលបើមហាជនទៅជួបជុំហើយ ព្រះសម្តុទ្ទទ្រង់សំដែង អតីតនិទានរបស់នាងព្រាហ្មណីនិងនាងវដ្ឋមាលា ឱ្យមហាជនបាន ដឹង, លុះចប់ហើយនាងព្រាហ្មណីនិងស្វាមីរបស់នាង ព្រមទាំង មហាជនដែលទៅស្តាប់ធម៌ទាំងប៉ុន្មាន ក៏បានដល់នូវត្រៃសរណ-គមន៍ខ្លះ បានរក្សាសីលប្រាំខ្លះ ។ ចាប់តាំងពីថ្ងៃនោះមក នាង ព្រាហ្មណីនិងនាងវដ្ឋមាលា បានរាប់អានគ្នាដូចជាបងប្អូនបង្កើត ដរាបដល់អស់ជីវិត ។ ឯនាងវដ្ឋមាលាលុះធ្វើមរណកាលទៅ បាន ទៅកើតក្នុងស្ថានតាវតឹង្ស សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្ត ។

## ២៧. រឿងព្រានព្រៃឈ្មោះសុរៈ

( ចាក កុ. គឺ. )

( ការកើតឡើងនៃសុរាក្នុងលោក )

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងក្រុងពារាណសី ។ សម័យនោះមានព្រានព្រៃម្នាក់ឈ្មោះសុរៈ នៅក្នុងកាសិករដ្ឋ គាត់បានទៅព្រៃហេមពាន្តដើម្បីប្រកបកិច្ច ផ្សេងៗ ។ នៅព្រៃហេមពាន្តនោះ មានឈើមួយដើមកំពស់មួយ ជំហរ បែកមែកជាបី ក្នុងប្រឡោះប្រគាបនោះមានរណ្តៅធំប៉ុន ពាង, លុះដល់ធ្លាក់ភ្លៀងមក ទឹកដក់នៅក្នុងរណ្តៅនោះ ហើយមាន ដើមស្រមរកន្ទួតព្រៃនិងម្រេចជាដើម ដុះក្បែរដើមឈើនោះ តែង

ជ្រុះផ្លែទៅក្នុងរណ្ដៅនោះ, មិនតែប៉ុណ្ណោះសត្វបក្សីទាំងឡាយ តែងពាំស្រូវសាលីទៅទំស៊ីហើយជ្រុះទៅក្នុងរណ្ដៅទៀត ។ ទឹកក្នុងរណ្ដៅនោះ ក៏មានពណ៌ក្រហមមានរសជាតិខ្លាំង ។ ដល់រដូវក្ដៅ សត្វបក្សីទាំងឡាយមានសេចក្ដីស្រេកឃ្លានបានផឹកទឹកនោះ ក៏ស្រវឹងបំរះនទៀលជួលជ្រប់នៅទៀបគល់ឈើ បន្តិចក៏ស្រែកកញ្ច្រៀវខ្ញៀវខ្ញាហើរចេញទៅ, សូម្បីសត្វកំប្រុកស្វាកង្កែនជាដើម ដែលបានផឹកទឹកនោះ ក៏មានទំនងដូចគ្នាដែរ ។ ថ្មើរព្រៃបានឃើញហើយក៏គិតថា ទឹកនេះមិនមែនពុលទេ បើជាទឹកពុលសត្វដែលផឹកទាំងប៉ុន្មាន មុខជាស្លាប់អស់ឥតសល់ ក៏ផងទឹកនោះផឹកដរាបដល់ស្រវឹង ហើយបង្កាត់ភ្លើងចាប់សត្វដែលដួលជ្រប់ក្រាបក្បែរគល់ឈើសម្លាប់ចោច អាំងស៊ីផឹកទឹកនោះអស់ពីរបីថ្ងៃ ។

សម័យនោះ មានតាបសមួយរូបឈ្មោះវរុណៈ នៅក្នុងទីជិតនោះ ។ ថ្មើរព្រៃផងយកទឹកនោះមួយបំពង់ឫស្សី និងដុំសាច់ដែលចំអិនស្រេចមួយចំកាក់ ដើរទៅកាន់សំណាក់វរុណតាបស ហើយនិយាយថា សូមលោកម្ចាស់ឆាន់ទឹកនិងសាច់នេះលេងលមើល ។ តាបសនិងថ្មើរព្រៃ ក៏នាំគ្នាទំពាស៊ីដុំសាច់ផឹកទឹកនោះអស់កាលជាយូរថ្ងៃ, ទើបទឹកនោះមានឈ្មោះថាសុរាផងវរុណីផង ព្រោះថ្មើរព្រៃឈ្មោះសុរ និងតាបសឈ្មោះវរុណ បានឃើញបានផឹកមុនគេ ។ អ្នកទាំងពីរ គិតគ្នាថាទឹកនេះសំខាន់ណាស់ ក៏ផងចាក់ពេញបំពង់

ឫស្សីជាច្រើន វែកទៅស្រុកបច្ចន្តគ្រាម ឱ្យអ្នកស្រុកក្រាបបង្គំទូល ព្រះមហាក្សត្រថា មានអ្នកចេះធ្វើទឹកស្រវឹងយ៉ាងវិសេសទើបនឹងមកដល់ ។ ព្រះមហាក្សត្រ ទ្រង់ត្រាស់បង្គាប់ឱ្យអ្នកទាំងពីរចូលទៅគាល់ អ្នកទាំងពីរនាក់ក៏ចូលយកទឹកនោះទៅថ្វាយព្រះរាជា១ ទ្រង់សោយ ក៏ស្រវឹងស្រួលមែន លុះអស់ទឹកនោះទៅបានត្រាស់បង្គាប់ឱ្យដងយកទៅថ្វាយទៀត។ ជនទាំងពីរនាក់ទៅនាំទឹកសុរានោះបានពីរបីថ្ងៃ ទើបគិតគ្នាថាយើងមិនអាចទៅយកជានិច្ចបានទេ ហើយក៏កំណត់យកនូវគ្រឿងផ្សំគ្រប់មុខមកផ្សំធ្វើសុរាក្នុងនគរនោះ ។ អ្នកនគរនាំគ្នាផឹកសុរាតែរាល់១ គ្នា ក៏ទៅជាអ្នកមានសេចក្ដីប្រមាទក្នុងការងារ ធ្លាក់ខ្លួនទៅជាកំសត់ទុគ៌ត. នគរនោះក៏សាបសូន្យចាកសេចក្ដីចំរើនគ្រប់យ៉ាង ។ អ្នកធ្វើសុរាក៏នាំគ្នារត់ទៅនៅក្នុងនគរពារាណសី ឱ្យអ្នកនគរក្រាបទូលព្រះបាទពារាណសី ១ ទ្រង់បង្គាប់ឱ្យហៅមក ហើយទ្រង់ព្រះរាជទានស្បៀងអាហារឱ្យធ្វើសុរាថ្វាយ។ នគរនោះក៏វិនាសដូចមុនទៀត ។ អ្នកធ្វើសុរាចេញពីទីនោះទៅនៅនគរសាកេត ចេញពីនគរសាកេតទៅនៅក្នុងនគរសាវត្ថី។ គ្រានោះព្រះចៅក្រុងសាវត្ថីទ្រង់ព្រះនាមព្រះបាទសព្វមិត្រ ព្រះអង្គបានធ្វើសេចក្ដីសង្គ្រោះដល់អ្នកធ្វើសុរាទាំងពីរនាក់នោះ ទ្រង់ព្រះរាជទានទេយ្យវត្ថុផ្សេង១ ដល់អ្នកទាំងពីរ១ ក៏បានធ្វើសុរានៅក្នុងនគរសាវត្ថីនោះអស់កាលជាយូរ. ការធ្វើសុរាក៏ចេះតែកើតត១ពីត្រឹមនោះមក។

# ២៨. រឿងនាងសុភទ្រា

( ចាក វិ. ខុ. )

( គុណនៃការធ្វើសង្ឃគតទក្ខិណាទាន )

កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ កាលនោះមានកុដុម្ពិកម្នាក់ ជាញោមឧបដ្ឋាកព្រះរេវតត្ថេរ នៅក្នុងនាឡន្ទគ្រាម ។ កុដុម្ពិកនោះមានកូនស្រីពីរនាក់ឈ្មោះភទ្រា ១, សុភទ្រា១, នាងភទ្រាមានស្វាមីទៅនៅក្នុងត្រកូលមាតាបិតាក្មេក ប៉ុន្តែនាងជាស្ត្រីអាឥតកូន នាងបាននិយាយនឹងស្វាមីថា ខ្ញុំមានប្អូនស្រីមួយឈ្មោះសុភទ្រា ខ្ញុំនឹងនាំមកជាភរិយារបស់អ្នក ដើម្បីឱ្យបានបុត្រ ។ បុរសជាស្វាមីព្រមទទួលតាមពាក្យរបស់នាង។ ឯនាងភទ្រានោះ ជាស្ត្រីមានសទ្ធាមាំក្នុងព្រះពុទ្ធសាសនា បានរំឭកដាស់តឿននាងសុភទ្រាជាប្អូន ឱ្យខំធ្វើទានរក្សាសីលបំពេញការកុសលគ្រប់យ៉ាង ។ នាងសុភទ្រាក៏ខំប្រតិបត្តិតាមឱវាទរបស់បង, ថ្ងៃមួយបាននិមន្តព្រះរេវតត្ថេរ ព្រមទាំងភិក្ខុដទៃទៀតជាគំរប់ ៨ អង្គ មកថ្វាយសង្ឃទានក្នុងគេហដ្ឋានរបស់នាង ។ ព្រះរេវតត្ថេរលោកមានព្រះទ័យករុណា ចង់ឱ្យនាងសុភទ្រាបានផលច្រើន លោកក៏នាំភិក្ខុសង្ឃទាំង ៧ អង្គឡើងទៅគង់លើអាសនៈ ហើយប្រាប់ថា នាងចូរថ្វាយទានដល់សង្ឃចុះ, នាងសុភទ្រាក៏លើកភោជនាហារទៅប្រគេនព្រះសង្ឃទាំង ៨ អង្គបានតាំងចិត្តចំពោះសង្ឃ

តែម្យ៉ាង លុះឆាន់ហើយព្រះរេវតត្ថេរ បានធ្វើភត្តានុមោទនារួច ក៏និមន្តទៅអារាមវិញទៅ ។ ចំណែកខាងនាងសុភទ្រា ដល់អស់អាយុ បានទៅកើតក្នុងស្ថាននិម្មានរតី ឯនាងភទ្រាជាបង ដែលជាអ្នកពេញចិត្តក្នុងការធ្វើទាន ដល់អស់អាយុ បានទៅកើតជាបាទបរិចា-រិការបស់ព្រះឥន្ទ្រ នាស្ថានត្រៃត្រឹង្ស ។ ក្នុងពេលនោះ នាងសុភទ្រាទេវធីតា បានរំពឹងមើលបុព្វកម្មរបស់ខ្លួនឃើញថា ដែលបានមកកើតក្នុងស្ថាននិម្មានរតីនេះ ដោយសារឱវាទរបស់នាងភទ្រាជាបង, ទើបនាងនឹករកនាងភទ្រា ក៏បានឃើញក្នុងស្ថានត្រៃត្រឹង្សមានយសស័ក្តិទាបជាងនាង ៗ មានចិត្តអាណិតបងខ្លាំងណាស់ ទើបហោះចុះទៅស្ថានត្រៃត្រឹង្ស ចូលទៅប្រាសាទនាងភទ្រាទេវធីតា ។ នាងភទ្រាទេវធីតានោះមិនស្គាល់ជាប្អូនរបស់ខ្លួនឡើយ ទើបសួរថា ម្នាលនាងមានតេជៈច្រើន ភ្លឺងរុងរឿងដោយពន្លឺរស្មី គ្របដណ្តប់នូវពួកទេវតាក្នុងជាន់តាវតឹង្ស, នាងមកពីស្ថានណា? បានធ្វើបុណ្យដូចម្តេចពីជាតិមុន ? ។ នាងសុភទ្រាទេវធីតាប្រាប់ថា បពិត្រអ្នកបង ខ្ញុំមកពីស្ថាននិម្មានរតី កាលពីជាតិមុន ខ្ញុំត្រូវជាប្អូនបង្កើតរបស់អ្នកបងដែលខ្ញុំមានតេជៈរុងរឿងយ៉ាងនេះ ដោយសារឱវាទរបស់អ្នកបង ។ នាងភទ្រាសួរទៀតថា ម្នាលនាងទេពធីតា នាងបានធ្វើបុណ្យអ្វី បានជាមានស័ក្តិធំជាងយើង ៗ កាលពីនៅស្ថានមនុស្ស បានធ្វើបុណ្យច្រើនណាស់ ហេតុអ្វីក៏មានស័ក្តិតូច

ដូច្នេះ ? ។ នាងសុភទ្រ្ទាប្រាប់ថា អ្នកបងធ្វើទានច្រើនមែន ប៉ុន្តែបានធ្វើតែបុគ្គលិកទាន ឯខ្ញុំបានធ្វើទានតែចំពោះព្រះសង្ឃ ៨ អង្គ ទាននោះឈ្មោះសង្ឃទាន ព្រោះខ្ញុំតាំងចិត្តចំពោះសង្ឃតែម្យ៉ាង បានជាខ្ញុំមានស័ក្តិធំជាងអ្នកបង, និយាយដូច្នេះហើយ ក៏លានាងភទ្ទ្រាត្រឡប់ទៅស្ថានរបស់ខ្លួនវិញ ។ ថ្ងៃមួយព្រះមោគ្គល្លាននិមន្តទៅស្ថានត្រៃត្រឹង្ស បានជ្រាបប្រវត្តិរបស់នាងទាំងពីរអំពីសំណាក់ព្រះឥន្ទ្រហើយ ក៏ចុះមកស្ថានមនុស្សវិញ នាំដំណឹងនោះទៅក្រាបទូលដល់ព្រះមានព្រះភាគ ។ ទ្រង់ប្រារព្ធនូវរឿងនោះឱ្យជាហេតុហើយ ទើបសំដែងនូវអានិសង្សគតាទក្ខិណាទាន ជាភិយ្យោភាពតទៅ ។

## ២៩. រឿងចណ្ឌាលបណ្ឌិត

( បាក អ. តេ. )

( ការលុបគុណ ជាថ្នាំបន្សាបលទ្ធផលក្នុងលោក )

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិក្នុងត្រកូលចណ្ឌាល នាចណ្ឌាលគ្រាម, មានប្រាជ្ញាឈ្លាសវាងវៃចេះនូវមន្តវិសេស, អាចធ្វើដើមឈើឱ្យផ្លែខុសរដូវបាន ។ ពួកមហាជនទាំងឡាយ ហៅព្រះពោធិសត្វថា ចណ្ឌាលបណ្ឌិត ។

សម័យនោះ មានបុត្ររបស់បុរោហិតម្នាក់នៅក្នុងក្រុងពារាណសី ឈ្មោះទេវបុត្តកុមារ ជាមនុស្សទុច្ចរិតអកតញ្ញូ. បានដឹងថាចណ្ឌាលបណ្ឌិតចេះមន្តវិសេសដូច្នោះ ក៏ចូលទៅសុំរៀន. ទៅដល់ឃើញចណ្ឌាលបណ្ឌិត កំពុងរែកផ្លែស្វាយមកពីព្រៃ ក៏ស្ទុះទៅទទួលយកអំរែកពីស្មា រែកឡើងទៅលើផ្ទះដាក់អំរែកហើយ ថ្វាយបង្គំសុំរៀនមន្តអំពីចណ្ឌាលបណ្ឌិត ។ បានក្រឡេកឃើញស្គាល់លក្ខណៈជាមនុស្សមិនល្អ ក៏និយាយថា មន្តរបស់ខ្ញុំពិបាករៀនណាស់ មនុស្សមិនល្អរៀនមិនបានទេ ។ តាំងពីថ្ងៃនោះមកចណ្ឌាលបណ្ឌិត មិនអើពើនឹងការបង្រៀនមន្តនោះឡើយ ទោះបីទេវបុត្តកុមារខំគោរពប្រតិបត្តិយ៉ាងណាក៏មិនបង្រៀន ព្រោះយល់ច្បាស់ថា បើរៀនចេះទៅក៏មិនបានការ ។ ចំណែកខាងទេវបុត្តកុមារដឹងថា ចណ្ឌាលបណ្ឌិតមិនព្រមបង្រៀនហើយ ក៏ទៅនិយាយអង្វរភរិយារបស់ចណ្ឌាលបណ្ឌិតឱ្យជួយសុំ ។ នាងជាភរិយាទើសទាល់ពេក ព្រោះទេវបុត្តកុមារនៅបំរើយូរហើយមិនព្រមទៅណាសោះ ក៏និយាយសុំស្វាមីឱ្យបង្រៀនមន្តដល់ទេវបុត្តកុមារ ។ ចណ្ឌាលបណ្ឌិតទើសទាល់ពេក ក៏ព្រមបង្រៀន ។ ទេវបុត្តកុមារកាលបើបានរៀនចេះដឹងសព្វគ្រប់ហើយ សុំលាទៅផ្ទះវិញ. មុននឹងទៅចណ្ឌាលបណ្ឌិតបានឱ្យឱវាទថា មន្តនេះវិសេសណាស់ យើងបានបង្រៀនអ្នកសព្វគ្រប់អស់ហើយ ចូររក្សាទុកឱ្យល្អ បើទៅក្នុងទីណាៗ មានគេសួរថាដូចម្ដេច

អ្នកត្រូវឆ្លើយតាមពិតកុំកុហកឡើយ ។ ទេវបុត្តកុមារទទួលថា សាធុៗ ហើយលាអាចារ្យចេញទៅ សំដៅទៅក្រុងពារាណសី, ដល់ពាក់កណ្ដាលផ្លូវបានឃើញស្វាយមួយដើម ក៏រាយមន្តតាមក្បួនដែលបានរៀន ។ ដើមស្វាយនោះបញ្ចេញផ្កាផ្លែចាស់ទុំមួយរំពេច ក៏បេះផ្លែស្វាយនោះរែកចូលទៅលក់ក្នុងក្រុងពារាណសី ។ ថ្ងៃមួយអ្នករក្សាឧទ្យានរបស់ព្រះបាទព្រហ្មទត្ត បានឃើញផ្លែស្វាយទុំខុសកាលក៏សួរហេតុផលសព្វគ្រប់ ហើយទិញផ្លែស្វាយនោះ យកទៅថ្វាយព្រះបាទព្រហ្មទត្ត ។ បានជ្រាបថាទេវបុត្តកុមារចេះមន្តដូច្នោះ ទើបឱ្យរាជអាមាត្យហៅចូលគាល់ ។ ព្រះរាជាបានសាកសួរសព្វគ្រប់ហើយ ទ្រង់បង្គាប់ឱ្យធ្វើថ្វាយទតក៏ឃើញមានផ្កាផ្លែប្រាកដមែន ទ្រង់ស្ងើចអស្ចារ្យពន់ពេក ទើបត្រាស់សួរថា : មន្តនេះអ្នកចេះមកពីគ្រូណា ? ។ ទេវបុត្តកុមារមនុស្សលុបគុណគ្រូ បានគិតថា គ្រូរបស់អញជាតិចណ្ឌាល បើអញទូលព្រះរាជាតាមត្រង់ថោកទាបណាស់ មិនសមនឹងខ្លួនអញដែលចេះមន្តវិជ្ជានេះឡើយ លុះគិតដូច្នេះហើយក៏ក្រាបទូលព្រះរាជាថា មន្តនេះខ្ញុំរៀនចេះអំពីសំណាក់អាចារ្យទិសាបាមោក្ខ នៅក្រុងតក្កសិលា ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយសព្វព្រះរាជហឫទ័យណាស់ ទ្រង់ឱ្យនៅក្នុងព្រះបរមរាជវាំងជាមួយនឹងព្រះអង្គ, ព្រឹកឡើងបាននាំទៅឧទ្យាន មានសេនាយោធាហែរហមទៅជាច្រើន ទៅដល់ ទ្រង់ប្រើទេវបុត្តកុមារឱ្យធ្វើស្វាយមួយ

ដើមឱ្យមហាជនមើល ។ ទេវបុត្តកុមារដើរទៅឈរជិតហើយ រាយមន្តប្រស់ទឹកដើមស្វាយនោះអស់វារៈបីដង ស្វាយមិនផ្កាផ្លែឡើយ ក៏ឈរនៅស្ងៀម. ទើបព្រះរាជាត្រាស់សួរថា ម្នាលទេវបុត្តកុមារហេតុអ្វីក៏អ្នកឈរស្ងៀមដូចជាកំណាត់ឈើ ដែលគេបញ្ឈរចោលយ៉ាងនេះ. ទោះបីព្រះរាជាត្រាស់សួរយ៉ាងណា ក៏រកពាក្យឆ្លើយមិនរួចព្រោះដឹងថាមន្តរបស់ខ្លួនវិនាសអស់ហើយ ។ ក្នុងពេលនោះព្រះរាជាទ្រង់ព្រះពិរោធជាខ្លាំង បានប្រើឱ្យអាមាត្យទាក់គរួសចោលទៅខាងក្រៅឧទ្យាន ។ តាំងពីថ្ងៃនោះមកទេវបុត្តកុមារ ក៏សាបសូន្យចាកលាភសក្ការៈដរាបដល់អស់ជីវិត ។

## ៣០. រឿងនន្ទិយឧបាសក

( ចាក វិ. ខុ. )

( គុណនៃការសាងសេនាសនៈសម្រាប់សង្ឃ )

កាលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន នាក្រុងពារាណសី ។ កាលនោះមានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជាបុត្ររបស់ត្រកូលអ្នកមានសទ្ធាជឿកាន់លទ្ធិពុទ្ធសាសនា នន្ទិយកុមារកាលបើមាតាបិតាជាសប្បុរសដូច្នោះហើយ ក៏ខំប្រតិបត្តិតាមលំនាំរបស់មាតាបិតា បានថ្វាយខ្លួនជាឧបាសកតាំងពីតូចមក ។ មហាជនទាំងឡាយហៅនន្ទិយកុមារនោះថា នន្ទិយឧបាសក

តាំងពីកាលនោះមក ។ ថ្ងៃមួយមាតាបិតាទៅដណ្តឹងនាងរេវតី ជាធីតារបស់បងស្រីនៃមាតាឱ្យនន្ទិយឧបាសក ។ នាងរេវតីនោះត្រូវជាម្តាយមីងរបស់នន្ទិយឧបាសក ជាស្ត្រីមិច្ឆាទិដ្ឋិ មិនមានសទ្ធាកំណាញ់ស្វិតស្វាញស្អប់ខ្ពើមទានសីលភាវនា ។ ឯនន្ទិយឧបាក មិនត្រូវការនឹងនាងរេវតីនោះឡើយ ប៉ុន្តែមាតាបិតាទាំងពីរខាងចេះតែបង្ខំ ក៏ព្រមទទួលយក ។ តាំងពីថ្ងៃរៀបអាវាហមង្គលហើយ នន្ទិយឧបាសកចេះតែនិយាយទូន្មាននាងរេវតី ឱ្យខំធ្វើទានរក្សាសីលគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តែរាល់ៗថ្ងៃ. ទោះបីនន្ទិយឧបាសកទូន្មានយ៉ាងណា នាងរេវតីឥតមានសេចក្តីជ្រះថ្លាឡើយ ។ កាលជាខាងក្រោយមក មាតាបិតាទាំងពីរខាងធ្វើមរណកាលអស់ទៅ នន្ទិយឧបាសកបានជាធំក្នុងការគ្រប់គ្រងផ្ទះ ក៏ប្រគល់កិច្ចការក្នុងផ្ទះទាំងប៉ុន្មានឱ្យដល់នាងរេវតីថែរក្សា ។ តាំងពីថ្ងៃនោះមក នន្ទិយឧបាសក បានចាត់ចែងធ្វើមហាទានថ្វាយដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន និងចែកចាយបាយទឹកនំចំណីដល់ស្មូមយាចកតែរាល់ៗថ្ងៃ ហើយបានសាងសាលាមុខ ៤ មួយខ្នងក្នុងព្រៃឥសិបតនមិគទាយវន វេរប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ក្នុងទីបំផុតនៃកិច្ចវេរនោះ គាត់យកទឹកមានក្លិនក្រអូបទៅជ្រួតលើបាតព្រះហស្តព្រះសម្ពុទ្ធ ដើម្បីសំដែងបរិច្ចាគចេតនារបស់គាត់ឱ្យច្បាស់លាស់ ។ ក្នុងពេលនោះ មានសេចក្តីចំឡែកអស្ចារ្យ

ណាស់ គ្រាន់តែដំណក់ទឹកស្រក់ដល់បាតព្រះហស្ថព្រះសម្ពុទ្ធវេលាណា មានប្រាសាទមាសរំលេចដោយកែវ ៧ ប្រការទំហំ ១២ យោជន៍ កំពស់ ១៧ យោជន៍ ពេញប្រៀបដោយគ្រឿងបរិក្ខារនិងស្រីទេពអប្សររាប់ពាន់ ផុះឡើងក្នុងស្ថានតាវតឹង្ស ទុកបំរុងខ្លួនគាត់ក្នុងវេលានោះ ។ ថ្ងៃមួយព្រះមោគ្គល្លានទិមន្តទៅស្ថានតាវតឹង្ស បានឃើញវិមានប្រាសាទមានពន្លឺព្រោងព្រាត ពេញប្រៀបដោយស្រីទេពកញ្ញា ប៉ុន្តែមិនឃើញទេវតាជាម្ចាស់ប្រាសាទនោះឡើយ ទើបសួរស្រីទេពកញ្ញាទាំងនោះថា ចៅហ្វាយរបស់នាងនៅក្នុងទីណា ? ឈ្មោះអ្វី ? ។ ពួកស្រីទេពកញ្ញាប្រាប់ថា ចៅហ្វាយរបស់ខ្ញុំព្រះករុណា ឈ្មោះ នន្ទិយៈ សព្វថ្ងៃលោកនៅក្នុងស្ថានមនុស្ស ។ ព្រះមោគ្គល្លានចុះមកវិញ ក៏នាំរឿងនោះទៅទូលព្រះមានព្រះភាគ ។ ត្រាស់ថាតថាគត ដឹងតាំងពីនន្ទិយៈយកទឹកមកជ្រួចលើដៃតថាគតម្ល៉េះ ប៉ុន្តែពេលនោះគ្មាននរណាដឹង បានជាតថាគតមិនសំដែងប្រាប់ ។ វេលានោះ នន្ទិយឧបាសកនៅក្នុងទីនោះដែរ បានឮដូច្នោះហើយក៏រីងរិតតែ មានសេចក្តីជ្រះថ្លាជាភិយ្យោភាពឡើងទៀត ។ ក្នុងកាលខាងក្រោយមក នន្ទិយឧបាសកមានដំណើរទៅជួញនូវប្រទេសក្រៅ បានប្រាប់ដល់នាងរេវតី ឱ្យខំរៀបចាត់ចែងភោជនាហារប្រគេនដល់ព្រះសង្ឃ ដែលតែងនិមន្តទៅឆាន់នៅផ្ទះរាល់ៗថ្ងៃ ។ ឯនាងរេវតី កាលបើស្វាមីទៅផុត

ហើយ ក៏បញ្ឈប់ព្រះសង្ឃលែងឱ្យឆាន់ បានជេរស្តីតិះដៀលព្រះសង្ឃជាអនេកបរិយាយ ។ លុះដល់នន្ទិយឧបាសកត្រឡប់មកវិញ ដឹងដំណឹងដូច្នោះហើយ ក៏បណ្តេញនាងរេវតីឱ្យចុះចេញពីផ្ទះ ទើបគាត់ឡើងទៅលើផ្ទះជាខាងក្រោយ រៀបចំចាត់ចែងទានដោយខ្លួនឯង ប្រគេនដល់ព្រះសង្ឃដូចពេលមុន ១ ទៀត ។ ថ្ងៃមួយពួកក្រុមញាតិបាននាំនាងរេវតី ទៅសុំទោសនន្ទិយឧបាសក ឱ្យចូលទៅនៅក្នុងផ្ទះវិញ គាត់ក៏ព្រមឱ្យនៅ តែមិនប្រគល់ឱ្យជាធំក្នុងផ្ទះដូចមុនឡើយ ។ ក្នុងកាលខាងក្រោយមក នន្ទិយឧបាសកក៏ធ្វើមរណកាលទៅ បានទៅកើតក្នុងវិមាននាស្ថានត្រៃត្រឹង្ស ។ ឯនាងរេវតីតាំងពីពេលនោះមក ក៏រុះរើរោងទាននៅមុខផ្ទះចោលអស់ឥតសល់ តាំងខ្លួនជាសត្រូវនឹងសាសនា បានជេរស្តីតិះដៀលដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន. ដោយអំណាចកម្មអាក្រក់នោះ ក៏ក្តៅក្រហាយដល់ព្រះបាទវេស្សវ័ណ ដែលជាអ្នកត្រួតត្រាពួកយក្ខ ។ ព្រះបាទវេស្សវ័ណបានជ្រាបដំណឹងនោះហើយ ក៏ប្រើយក្ខជាសេនាបតីពីរនាក់ ឱ្យមកស្រែកប្រាប់ដល់អ្នកក្រុងពារាណសីថា នៅ ៧ ថ្ងៃទៀត យើងនឹងចាប់យកនាងរេវតី ទៅទម្លាក់ក្នុងនរកទាំងរស់ ។ នាងរេវតីឮដូច្នោះហើយ ភិតភ័យខ្លាំងណាស់រត់ចូលទៅក្នុងផ្ទះបិទទ្វារចាក់សោ មិនចេញទៅទីណាឡើយ ដល់ថ្ងៃជាគំរប់ ៧ យក្ខទាំងពីរក៏មកនិម្មិតកាយធំសំបើមគួរខ្លាច លូកដៃទៅហែកទ្វារផ្ទះ ហើយ

ចាប់ទាញអូសយកនាងរេវតីចេញអំពីផ្ទះ,

ចាប់ដៃម្ខាងម្នាក់ហោះព័ទ្ធក្រុងពារាណសី ៧ជុំ ទើបនាំទៅបង្ហាញនន្ទិយទេវបុត្រនាស្ថានត្រៃត្រឹង្ស ។ ឯនាងរេវតីបាន ឃើញនន្ទិយទេវបុត្រស្គាល់ជាក់ជាស្វាមីរបស់ខ្លួនហើយ ក៏និយាយអង្វរឱ្យជួយ។ នន្ទិយទេវបុត្រប្រាប់ថា យើងជួយនាងយូរណាស់ហើយ ពេលនេះជួយទៀតមិនបានទេ ព្រោះហួសវិស័យរបស់យើង យក្ខទាំងពីរក៏អូសនាងរេវតីទៅបោះចោលក្នុងឧស្សទនរកវេលានោះទៅ ។

## ៣១ - រឿងមារុត្តព្រាហ្មណ៍

( ចាក ម. វា. )

( ចិញ្ចឹមតិរច្ឆាន ប្រសើរជាងចិញ្ចឹមភរិយាក្បត់ )

កាលកន្លងទៅហើយ មានព្រាហ្មណ៍ម្នាក់ឈ្មោះមារុត្ត នៅក្នុងស្រុកមួយក្បែរឆ្នេរស្ទឹងចន្ទភាគា ។ ថ្ងៃមួយមារុត្តព្រាហ្មណ៍បានចេញទៅជួញឯនគរតក្កសិលា. លុះត្រឡប់មកវិញដល់ពាក់កណ្ដាលផ្លូវ បានឃើញឆ្កែមួយស្គមនៅតែឆ្អឹង អង្គែស៊ីជ្រុះរោមអស់ ដេកក្រោមសាលាសំណាក់មួយ ក៏មានសេចក្ដីករុណាអាណិតអាសូរដល់ឆ្កែនោះពន់ពេក បានផ្សំថ្នាំឱ្យផឹកជាមួយរំពេច ។ ឆ្កែក៏មានសេចក្ដីស្រឡាញ់ បានដើរតាមព្រាហ្មណ៍នោះទៅ. ព្រាហ្មណ៍បានចិញ្ចឹមឆ្កែនោះដោយសេចក្ដីសង្គ្រោះ ។ ក្នុងកាលជាខាងក្រោយមក

ភរិយារបស់ព្រាហ្មណ៍សម្រាលកូនមិនរួច ពេទ្យក៏យកកាំបិតកាត់កូននោះជាកំណាត់តូចធំយកចេញមកក្រៅផ្ទៃ ។ ឯមារុត្តព្រាហ្មណ៍ជាស្វាមី បានឃើញដូច្នោះ ក៏កើតសេចក្ដីសង្វេគនឿយណាយក្នុងការគ្រប់គ្រងផ្ទះ បានលាភរិយាទៅបួសជាតាបសនៅក្នុងព្រៃតែម្នាក់ឯង ។ ឯភរិយារបស់មារុត្តព្រាហ្មណ៍ មិនយូរប៉ុន្មានក៏បែកចិត្តទៅនៅរួមជាមួយនឹងបុរសដទៃទៀត បានចងគំនុំប្រទុស្តនឹងព្រាហ្មណ៍ជាប្ដីដើមដោយគិតថា មារុត្តព្រាហ្មណ៍នេះមានចិត្តអាក្រក់ណាស់ លះបង់ចោលអញរត់ទៅបួសយកសុខតែម្នាក់ឯងឥតគិតគូរដល់អញបន្តិចបន្តួចឡើយ ។ គិតដូច្នេះហើយ ក៏និយាយប្រាប់ប្ដីចុងថា បពិត្រអ្នកស្វាមី អ្នកត្រូវសម្លាប់មារុត្តព្រាហ្មណ៍កំណាចចោលចេញ ក្រែងថ្ងៃក្រោយវាត្រឡប់មកវិញ ។ ឯសត្វឆ្កែបានស្ដាប់ពាក្យរបស់នាងនោះហើយ ក៏រត់ទៅនៅក្នុងព្រៃជាមួយនឹងមារុត្តតាបស ។ ថ្ងៃមួយបុរសជាប្ដីចុង កាន់ធ្នូនឹងបំពង់ព្រួញចូលទៅក្នុងអាស្រមរបស់តាបស ។ គ្រានោះតាបសចេញទៅរកផ្លែឈើនិងមើមឈើជាអាហារបាត់ទៅ នៅតែឆ្កែដេកចាំអាស្រម ។ ឯបុរសនោះកាលមិនឃើញតាបសក្នុងអាស្រមនោះហើយ ក៏អង្គុយពួនចាំក្បែរគុម្ពឈើមួយ. ឆ្កែក៏លបចូលទៅខាំបន្ទោះធ្នូបុរសនោះដាច់អស់ទៅ ។ បុរសបានឃើញបន្ទោះធ្នូដាច់ក៏ធ្វើឱ្យជាប់វិញ. ឆ្កែលបទៅខាំបណ្ដាច់ទៀត អស់វារៈជាច្រើនផង ។ លុះដល់តាបស

ត្រឡប់មកអាស្រមវិញ បុរសនោះក៏ចងខ្សែធ្នូផ្ទាប់ព្រួញបំរុងនឹងបាញ់ ឆ្កែក៏ស្ទុះទៅខាំកន្ត្រាក់ឱ្យដួលដេកលើ ផែនដីដរាបដល់ដើរពុំរួច ។ លំដាប់នោះតាបសបានឮសំឡេងឆ្កែ ក៏ ដើរចូលទៅដោយរួសរាន់ បានឃើញវិប្បការៈដូច្នោះហើយ មានសេចក្តីករុណាអាណិតអាសូរ បានថែទាំដំពៅបុរសនោះដរាបដល់ជាសះស្បើយ ហើយបញ្ជូនបុរសនោះឱ្យត្រឡប់ទៅផ្ទះវិញ ។ ឯតាបស បាននៅក្នុងព្រៃនោះជាសុខក្សេមក្សាន្ត ខំចំរើនឈានទឹងអភិញ្ញាឱ្យកើតឡើង ដល់អស់អាយុក៏បានទៅកើតក្នុងព្រហ្មលោក ។

## ៣២. រឿងនហាបិតបុត្ត

( ចាក សិ. ទុ. )

( សេចក្តីស្រឡាញ់ តែងសម្លាប់សត្វលោក )

កាលកន្លងទៅហើយ មានខ្ទាន់ព្រះកេសម្នាក់នៅក្នុងក្រុងវេសាលី ជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ប្រកបកិច្ចការចិញ្ចឹមជីវិតដោយការកាត់ព្រះកេសាព្រះមស្សុ របស់ព្រះរាជា និងពួកស្រីស្នំរបស់ព្រះអង្គ ។ ថ្ងៃមួយខ្ទាន់ព្រះកេសនោះទៅក្រុបកិច្ចការក្នុងព្រះរាជនិវេសន៍ បាននាំបុត្រទៅផង, ឯបុត្រនោះបានឃើញនាងលិច្ឆវីរាជកុមារិកា ដែលប្រដាប់តាក់តែងដោយគ្រឿងអលង្ការមានរូបឆោមល្អស្រស់ប្រិមប្រិយ ដូចជារូបស្រីទេពអប្សរ ក៏មានចិត្ត

ប្រតិព័ទ្ធស្នេហា ចំពោះរាជកុមារិកានោះពន់ពេក ដោយអំណាចនៃកិលេសគ្របសង្កត់. លុះត្រឡប់ទៅផ្ទះវិញ ក៏ដេកអត់បាយអត់ទឹកនឹករំពឹងចំពោះតែរូបនាងកុមារិកា ទើបប្រាប់ដល់បិតាថា បពិត្របិតាខ្ញុំបើមិនបាននាងលិច្ឆវីរាជកុមារិកានោះធ្វើជាភរិយាទេ មុខតែស្លាប់ក្នុងទីនេះពុំខាន ។ បិតាក៏និយាយអង្វរថា ម្នាលកូនសម្លាញ់ឪពុក អ្នកជាមនុស្សថោកទាបដោយជាតិនិងគោត្រ ជាកូនរបស់ខ្មាន់ព្រះកេស មិនគួរនឹងធ្វើនូវឆន្ទាគចំពោះហេតុដែលមិនមែនជាវត្ថុបំណងទេ ព្រោះព្រះរាជធីតានោះជាធីតារបស់ស្តេចលិច្ឆវី មានជាតិដ៏ខ្ពង់ខ្ពស់ មិនសមរម្យនឹងកូនឯងទេ. ចាំបិតាទៅរកនាងកុមារិកា ដែលមានជាតិនិងគោត្រស្មើគ្នាឱ្យ ។ ឯកូនរបស់នហាបិតនោះ មិនតាមពាក្យសំដីរបស់បិតាឡើយ នៅតែមានចិត្តប្រតិព័ទ្ធស្រឡាញ់ ចំពោះរូបនាងលិច្ឆវីរាជកុមារិកានោះជាខ្លាំងឡើង ៗ ដរាបដល់មានរូបកាយស្គមស្គាំង ស្លាប់ក្នុងពេលនោះទៅ ។

( មហាសំ. សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៣_ រឿងរាជគហទារិកា

( ចាក វិ. ខុ. )

( គុណនៃការប្រគេននំ ដល់ព្រះមោគ្គល្លាន )

កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅក្នុងវត្តវេឡុវន នាក្រុងរាជគ្រឹះ ។ កាលនោះមាននាងទារិកាម្នាក់ នៅក្នុងក្រុងរាជគ្រឹះជាកូនរបស់ឧបដ្ឋាកព្រះមហាមោគ្គល្លាន ។ នាងនោះជាស្ត្រីមានសទ្ធាមាំក្នុងព្រះពុទ្ធសាសនា ដល់អាយុ ១៦ ឆ្នាំ មាតាបិតាបានរៀបឱ្យមានស្វាមី ហើយបញ្ជូនឱ្យទៅនៅខាងសំណាក់មាតាបិតាក្មេក ។ ឯមាតាបិតាក្មេកនោះ ជាមនុស្សមិច្ឆាទិដ្ឋិ មានចិត្តរឹងរឹងរូសមិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅបិណ្ឌបាត្រក្នុងភូមិនោះ, នាងកូនប្រសារបានឃើញហើយ ក៏ចុះទៅនិមន្តឱ្យឈប់នៅមុខផ្ទះរបស់ខ្លួន ទើបនាងទៅប្រាប់ដល់ម្តាយក្មេក ៗ នោះធ្វើជាមិនឮ គេចចុះពីផ្ទះបាត់ទៅ ។ នាងដឹងហេតុនោះហើយ គិតពិចារណាថាក្នុងផ្ទះនេះមានវត្ថុអ្វីល្អប្រគេនលោកមានតែនំមួយដែលអ្នកម្តាយគាត់ទុកពិសា ក៏យកនំនោះទៅកាត់ជាពីរចំណែក មួយចំណែកទុកជូនម្តាយ មួយចំណែកយកទៅប្រគេនព្រះមហាមោគ្គល្លាន ៗ ធ្វើភត្តានុមោទនាហើយ ក៏និមន្តបាត់ទៅ ។ ម្តាយក្មេកបានឃើញព្រះមោគ្គល្លាននិមន្តចេញទៅផុតហើយ ក៏ឡើងទៅលើផ្ទះ ។ នាងទារិកាក៏ចូលទៅអង្គុយបត់ជើងលើកដៃ

ប្រណម្យ ជូនបុណ្យដែលបានប្រគេននំនោះដល់ម្ដាយក្មេក ។ ខឹង ខ្លាំងណាស់ ក្រឡេកមើលទៅគៀនជញ្ជាំងឃើញអង្រែមួយ ក៏ចាប់ អង្រែនោះសំពងកូនប្រសា ត្រូវត្រង់ចង្កួយស្មា ស្លាប់ក្នុងពេលនោះ ទៅ ។ កូនប្រសានោះបានទៅកើតក្នុងស្ថានតាវតឹង្ស ។ ថ្ងៃមួយព្រះ មហាមោគ្គល្លាននិមន្តទៅស្ថានតាវតឹង្ស បានឃើញនាងទេពធីតា ស្ថិតនៅក្នុងវិមានមាស មានស្រីទេពអប្សរកំពុងចោមរោមបំរើ, លោកក៏និមន្តទៅក្បែរវិមាននោះ ។ នាងទេពធីតាបានឃើញហើយ មានសេចក្ដីត្រេកអរណាស់នឹកថា ព្រះថេរនេះហើយ ដែលបាន សង្គ្រោះដល់អញក្នុងជាតិមុន ក៏នាំបរិវារចុះទៅថ្វាយបង្គំ ។ ព្រះ មហាមោគ្គល្លាន មានថេរដីកាសួរប្រវត្តិរបស់នាង ។ បានរៀបរាប់ ប្រគេនដោយសព្វគ្រប់, លោកក៏និមន្តមកស្ថានមនុស្សវិញ នាំ ដំណឹងនោះទៅក្រាបទូលដល់ព្រះមានព្រះភាគ ។ ទ្រង់ប្រារព្ធរឿង នោះឱ្យជាហេតុហើយ ក៏សំដែងនូវអានិសង្សរបស់ទានជាភិយ្យោ- ភាពក្នុងពេលនោះ ។

## ៣៤. រឿងយក្សឈ្មោះនន្ទិ

( ចាក លោ. ជា. )

( ធ្វើគុណចំពោះសប្បុរស គុណមិនសាបសូន្យ )

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ សោយរាជសម្បត្តិក្នុងនគរឥន្ទបត្ត ។ ថ្ងៃមួយព្រះរាជាបាននាំរាជសេវកាមាត្យទៅព័ទ្ធព្រៃមួយកន្លែង ដើម្បីចាប់ម្រឹគបានដាក់អាជ្ញាថា បើម្រឹគរត់ចេញរួចចំមុខអ្នកណា ត្រូវយកទោសអ្នកនោះដល់ជីវិត ។ ពេលនោះម្រឹគរត់ចេញរួចចំព្រះភ័ក្ត្រព្រះរាជា ។ ក៏ស្ដេចដេញតាមម្រឹគនោះ ចូលទៅក្នុងព្រៃជ្រៅឆ្ងាយដាច់ស្រយាលតែមួយព្រះអង្គឯងម្រឹគគេចបាត់ទៅពុំអាចចាប់បានឡើយ ។ ព្រះរាជាអស់សង្ឃឹមហើយ ស្ដេចយាងត្រឡប់មកវិញ ដល់ពាក់កណ្ដាលផ្លូវ បានឃើញដើមជ្រៃធំមួយមានម្លប់ល្អ ក៏ចូលទៅសម្រាកព្រះកាយក្នុងទីនោះ ។ ឯដើមជ្រៃនោះ ជាលំនៅរបស់នន្ទិយក្ខ ដែលកាចរបឹងរឹងរូសជាទីបំផុត ។ នន្ទិយក្ខបានឃើញហើយ ក៏ស្ទុះចូលទៅចាប់ព្រះរាជាប៉ងនឹងហែកស៊ី ប៉ុន្តែព្រះជន្មរបស់ព្រះអង្គថ្លៃ យក្ខបែរជាសួរថាអ្នកជាអ្វី ? មកពីណា ? ។ ព្រះរាជាប្រាប់ថា យើងជាស្ដេចសោយរាជ្យក្នុងនគរឥន្ទបត្ត , យើងដេញតាមម្រឹគមកអស់កម្លាំងពេក បានជាចូលមកសម្រាកក្រោមដើមជ្រៃនេះ ។ នន្ទិយក្ខនិយាយថា ឥឡូវនេះស្ដេចយាងចូលមកក្នុងអាណាខេត្តរបស់យើង ។ ត្រូវចាប់មហា

រាជបរិភោគជាអាហារ ប៉ុន្តែបើមហារាជចេះនូវមលតរ[១] ធម៌ ចូរសំដែងឱ្យយើងស្តាប់ យើងនឹងលែងឱ្យត្រឡប់ទៅនគរវិញ បើមិនចេះទេ នឹងបរិភោគមិនខាន ។ ព្រះរាជាទ្រង់មានព្រះតម្រាស់ថា មលតរធម៌នោះខ្ញុំមិនចេះទេ ប៉ុន្តែមានអ្នកប្រាជ្ញនៅក្នុងនគររបស់ខ្ញុំចេះ ។ នន្ទិយក្ខ ក៏អនុញ្ញាតឱ្យហៅអ្នកប្រាជ្ញមកសំដែងធម៌នោះឱ្យស្តាប់ ទើបដាក់អាជ្ញាចំពោះព្រះរាជាថា បើហួសអំពី ៧ ថ្ងៃមិនឃើញបញ្ជូនអ្នកប្រាជ្ញមកទេ យើងនឹងស៊ីមនុស្សក្នុងនគររបស់ព្រះអង្គទាំងអស់ ។ ព្រះរាជាព្រមតាមហើយ ស្តេចយាងចូលទៅព្រះរាជធានី ។ កាលនោះព្រះសម្ពុទ្ធបរមគ្រូទ្រង់សោយព្រះជាតិក្នុងត្រកូលមហាសេដ្ឋី នានគរឥន្ទបត្តនោះ ព្រះនាមធនញ្ជយបណ្ឌិត មានព្រះជន្ម ៧ ឆ្នាំ ជាអ្នកប្រាជ្ញចម្បងក្នុងលោក កិត្តិសព្ទរបស់ព្រះអង្គ ក៏ផ្សាយទូទៅពេញនគរទាំងមូល ។ ចំណែកខាងព្រះរាជា បានចូលទៅដល់ព្រះរាជនិវេសន៍ហើយ ក៏ប្រជុំពួកអ្នកប្រាជ្ញច្រើនរូប មានឧដុកសេនាបតីជាដើម ឱ្យសំដែងមលតរធម៌ថ្វាយព្រះអង្គ ។ អ្នកប្រាជ្ញទាំងនោះគ្មានអ្នកណាចេះមួយឡើយ ទើបព្រះរាជាមានព្រះតម្រាស់ថា បើអ្នកទាំងអស់គ្នាមិនចេះយ៉ាងនេះ ជីវិតរបស់យើង និងអ្នកនគរទាំងមូលនឹងវិនាសអស់ឥតសល់ ព្រោះយើងបាន

---

១. ទិដ្ឋិ. ឯជា. ឧទ្ធច្ច. ទោសោ. អន្ទោ. កង្ខា. ថីនំ. ឧទតិ. អហិរិកំ. អនោត្តប្បំ ទាំង ១០ នេះហៅថា មលតរធម៌ ។

សន្យានឹងនន្ទិយក្តថា បើដល់ថ្ងៃជាគំរប់ ៧ ហើយមិនឃើញមានអ្នកប្រាជ្ញចូលទៅសំដែងធម៌ឱ្យស្តាប់ទេ នឹងប្រគល់អ្នកនគរទាំងអស់ឱ្យជាចំណីដល់វា ។ ពេលនោះមានអ្នកប្រាជ្ញម្នាក់ក្រាបទូលព្រះរាជាថា មលតរធម៌នោះក្រែងតែធនញ្ជយកុមារទើបចេះ ។ ឧជុកសេនាបតី ជាមនុស្សឥច្ឆាក្រែងធនញ្ជយកុមារប្រសើរជាងខ្លួន ក៏ទូលថាវាគ្មានចេះដឹងអ្វីទេ កូនក្មេងទើបនឹងកើតនៅធំក្លិនទឹកដោះពីមាត់នៅឡើយ ចាំខ្ញុំព្រះអង្គទៅរំពឹងគិតរកមលតរធម៌នោះថ្វាយ កុំព្រួយព្រះទ័យឡើយ ។ ឧជុកសេនាបតីដេកគិតអស់ ៦ ថ្ងៃ រកមលតរធម៌មិនឃើញឡើយ ពេលថ្ងៃរសៀល បានឡើងទៅគាល់ព្រះរាជាទូលថា បពិត្រមហារាជ មលតរធម៌នោះ ខ្ញុំព្រះអង្គរកមិនឃើញទេ ។ ព្រះរាជាទ្រង់ពិរោធជាខ្លាំង ក៏ដាក់ទណ្ឌកម្មប្រើឱ្យទៅអញ្ជើញធនញ្ជយកុមារ ៗ បានចូលគាល់តាមព្រះរាជបញ្ជា ។ ព្រះរាជាបានឃើញធនញ្ជយកុមារហើយ ក៏ត្រាស់ហៅថា មហាបណ្ឌិតអ្នកជួយដោះទុក្ខយើងផង អ្នកចេះសំដែងមលតរធម៌ឬទេ ? ព្បិតស្នែកនេះដល់កំណត់ ៧ ថ្ងៃហើយ បើរកអ្នកប្រាជ្ញទៅសំដែងមលតរធម៌ឱ្យនន្ទិយក្តស្តាប់មិនបានទេ នគរយើងនឹងវិនាសអស់ឥតសល់ ។ ធនញ្ជយកុមារបានជ្រាបហើយទូលថា ខ្ញុំព្រះអង្គចេះមលតរធម៌សព្វគ្រប់ទាំងបាលីនិងសេចក្តីអធិប្បាយ សូមព្រះអង្គកុំព្រួយព្រះទ័យឱ្យសោះ សេចក្តីសុខសួស្តីនឹងមានដល់ព្រះអង្គដោយពិត ។

ព្រះពោធិសត្វក៏ចាត់ចែងរៀបដំណើរ ចេញទៅសំដែងមលតរធម៌ឱ្យនន្ទិយក្លស្តាប់ ។ នន្ទិយក្លស្តាប់ហើយមានសេចក្តីជ្រះថ្លា បានថ្វាយខ្លួនជាកូនសិស្សរបស់ធនញ្ជយកុមារ ហើយបានប្តេជ្ញានឹងធនញ្ជយកុមារថា បើលោកអាចារ្យមានទុក្ខយ៉ាងណាគ្រាន់តែនឹកដល់ខ្ញុំ ៗ នឹងទៅជួយដើម្បីតបឧបការគុណ ។ ចំណែកខាងព្រះរាជាព្រមទាំងមហាជន បានឃើញនន្ទិយគោរពកោតខ្លាចធនញ្ជយកុមារដូច្នោះហើយ ក៏ឱ្យពរសព្ទសាធុការបូជាដោយទ្រព្យសម្បត្តិជាច្រើន ព្រះរាជាបានលើកធនញ្ជយកុមារ ហើយសូមធ្វើជាព្រះរាជបុត្រ បានចាត់ចែងសាងប្រាសាទឱ្យនៅជាសុខក្សេមក្សាន្ត ។ តមកឧជកសេនាបតីនឹកឃើញថា បើទុកធនញ្ជយកុមារនេះឱ្យរស់នៅ មុខតែបានឡើងទីជាឧបរាជក្នុងវេលាឆាប់ៗ នេះពុំខាន បើដូច្នេះគួរអញទូលញុះស្តេចឱ្យសម្លាប់ចោលចេញ ។ ថ្ងៃមួយឧជុកសេនាបតី ចូលទៅទូលញុះញង់ព្រះរាជាឱ្យសម្លាប់ មិនយូរប៉ុន្មានព្រះរាជាក៏ដោយតាមពាក្យឧជុកសេនាបតី បានហៅធនញ្ជយកុមារឱ្យទៅប្រណាំងសេះជាមួយនឹងអ្នកប្រាជ្ញក្មេង ១ ៣នាក់ មានអភបណ្ឌិតជាដើម បានកំណត់ទីប្រណាំងចម្ងាយ ៣ យោជន៍ សេះដែលលឿន ១ មានតែ ៣ ប្រគល់ឱ្យទៅអ្នកប្រាជ្ញ ៣ នាក់ ឯធនញ្ជយកុមារឱ្យរកសេះជិះខ្លួនឯង ហើយទ្រង់ដាក់អាជ្ញាថា បើអ្នកណាឈ្នះគេ ៤ ដង ត្រូវបានកែវមណី ៤ ដុំ. ឈ្នះ ៣ ដងបាន ៣ ដុំ. ឈ្នះ ២ ដងបាន២ដុំ.

ឈ្នះម្តងបាន១ជុំ, បើចាញ់នៅក្រោយគេបំផុត ត្រូវសម្លាប់ចោល ។ ធនញ្ជយកុមារបានជ្រាបហេតុនោះសព្វគ្រប់ហើយ ក្រាបទូលថា ខ្ញុំព្រះអង្គរកសេះមិនបានទេ ទូលព្រះបង្គំនឹងរត់ប្រណាំងដោយកម្លាំងស្មង ជាមួយនឹងបណ្ឌិត ៣ នាក់ដែលជិះសេះលឿន ។ ព្រះរាជានិងឧដុកសេនាបតី ឮដូច្នោះហើយ នឹកសង្ឃឹមថា នឹងបានសម្លាប់ធនញ្ជយកុមារដោយពិត, ហើយមានព្រះរាជឱង្ការថា ស្រួលហើយបណ្ឌិតអ្នកទៅប្រណាំងចុះ ។ ព្រះពោធិសត្វចុះពីដំណាក់ចូលទៅកាន់ទីប្រណាំង គិតក្នុងព្រះទ័យថា អញមានឧបការគុណលើស្តេចឥឡូវស្តេចបែរជាប្រទុស្តអញវិញ, ទើបនឹកដល់នន្ទិយក្ខជាសិស្សនន្ទិយក្ខក៏មកដល់ភ្លាម តែមិនឱ្យអ្នកណាមើលឃើញឡើយ ។ ធនញ្ជយកុមារនិយាយប្រាប់យក្ខថា ឥឡូវព្រះរាជាប្រាថ្នានឹងសម្លាប់យើង ហេតុនេះអ្នកជួយយើងក្នុងការប្រណាំងសេះនេះផង ។ នន្ទិយក្ខប្រាប់ថា សូមលោកអាចារ្យកុំព្រួយ ខ្ញុំជួយឱ្យមានជ័យជំនះដោយពិត, និយាយយ៉ាងនេះហើយ ក៏និម្មិតខ្លួនធំខ្ពស់ក្រៃលែង យកដៃទ្រធនញ្ជយកុមារឱ្យអង្គុយពែនលើបាតដៃ ហើយបំបាំងខ្លួនមិនឱ្យអ្នកដទៃមើលឃើញ ឱ្យឃើញតែរូបធនញ្ជយកុមារ, ដល់ពេលបើកសម័យប្រណាំងគេវាយគងឡើង មហាជនទាំងអស់ស្រាប់តែឃើញធនញ្ជយកុមារពែនភ្នែនឮដ៏អាកាស អណ្តែកលឿនជ្រៀវប្រែចឥតឧបមា អ្នកជិះសេះទាំង៣ ទើបតែទៅដល់ពាក់កណ្តាលទី ធនញ្ជយ

កុមារទៅមកបាន ៤ បក យកកែវមណីអស់ទាំង ៤ ដុំ ។ អ្នកជិះសេះ ៣ នាក់ក៏ចាញ់ធនញ្ជយកុមារ មហាជនបានស្រែកឱ្យពរសព្ទសាធុការជាខ្លាំងស្ទើរស្រុតផែនដី. ព្រះរាជាក៏ខានសម្លាប់ទៅ ។ ថ្ងៃក្រោយព្រះរាជាបានប្រគល់រាជសម្បត្តិដល់ធនញ្ជយកុមារ ឱ្យសោយរាជ្យក្នុងនគរឥន្ទបត្តនោះ ។

## ៣៥~ រឿងសាវត្ថីធីតា

( ចាក វិ. ខុ. )

( គុណនៃការគោរពបំរើស្វាមីរបស់ខ្លួន )

ក្នុងពុទ្ធសម័យ. កាលព្រះសម្ពុទ្ធបរមគ្រូទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ។ កាលនោះមានស្ត្រីម្នាក់នៅក្នុងក្រុងសាវត្ថី ជាស្ត្រីគ្រប់លក្ខណ៍ មានគំនិតមារយាទត្រឹមត្រូវមិនផ្តេសផ្តាស ជាស្ត្រីមានចិត្តត្រង់នឹងស្វាមីរបស់ខ្លួន. តាំងតែពីកាលដែលមាតាបិតាបានផ្សំផ្គុំឱ្យមានគូស្រករមក ពុំដែលមានសេចក្តីច្រណែនរិះគន់ដល់ស្វាមីម្តងឡើយ ខំផ្គត់ផ្គង់បំរើស្វាមីដូចជាមាតារក្សាបុត្រ ទោះបីស្វាមីនោះទៅប្រព្រឹត្តមិនគប្បីនឹងស្ត្រីដទៃ ក៏នាងពុំដែលតូចចិត្តអាក់អន់ចិត្តចំពោះស្វាមីឡើយ ជាស្ត្រីមានប្រាជ្ញាជ្រៅ មានគំនិតត្រង់ជានិច្ច ។ ក្នុងកាលបច្ឆិមវ័យនាងធ្វើមរណកាលទៅ បានទៅកើតក្នុងពិភពតាវតឹង្ស ស្ថិតនៅក្នុងវិមានមាសកំពស់ ១២ យោជន៍ មាន

ទេវបុត្រទេវធីតារាប់ពាន់ចោមរោមជាបរិវារ, មានអានុភាពភ្លៀវក្លាហោះហើរឰដ៏អាកាសលឿនជ្រៀវជ្រែ មានសំឡេងស្រួចពិរោះប្លែកគួរចង់ស្តាប់ ។ ពួកទេវបុត្រទេវធីតាទាំងឡាយក្នុងឆកាមាសួគ៌ទាំងអស់ ស្រឡាញ់រាប់អានចូលចិត្តទៅលេងពេញៗ វិមានប្រាសាទរបស់នាង ឧបមាដូចជាបក្សីពេញចិត្តនឹងដើមជ្រៃ ដែលបរិបូណ៌ដោយផ្កានិងស្លឹក ។ ថ្ងៃមួយព្រះមោគ្គល្លានទិមន្តទៅស្ថានត្រៃត្រឹង្ស បានឃើញហ្វូងទេវតា កំពុងចោមរោមវិមានប្រាសាទនោះដូច្នោះហើយ ក៏និមន្តទៅជិត ។ ពួកទេវតាផ្អើលឈូឆរ, នាងទេពធីតា ក៏ចុះទៅថ្វាយបង្គំ ទើបព្រះមោគ្គល្លានមានថេរដីកាសួរថា ម្នាលនាងទេពធីតាអ្នកបរិបូណ៌ដោយទិព្វសិរី នាងបានធ្វើបុណ្យដូចម្ដេចពីជាតិមុនបានជាមកកើតក្នុងនេះ មានទេវបុត្រទេវធីតារាប់អានច្រើនម្ល៉េះ ? ។ នាងប្រាប់ថា ខ្ញុំព្រះករុណាមិនបានធ្វើបុណ្យអ្វីទេគ្រាន់តែគោរពបំរើស្វាមីប៉ុណ្ណោះ, ក៏ថ្លែងប្រវត្តិរបស់ខ្លួនប្រាប់ដល់ព្រះមោគ្គល្លានដោយសព្វគ្រប់, លុះចប់ហើយព្រះមោគ្គល្លានក៏និមន្តចៀសចេញទៅ ។

# ៣៦. រឿងចម្មសាដកបរិព្វាជក

( ចាក ច. ច. )

( មិនគួរគោរពបុគ្គល ដែលគេមិនគោរព )

កាលកន្លងទៅហើយ មានបរិព្វាជកម្នាក់ឈ្មោះចម្មសាដក នៅក្នុងក្រុងពារាណសី ។ បរិព្វាជកនោះចូលចិត្តស្លៀកពាក់តែស្បែកសត្វ គឺយកស្បែកចៀមពពែជាដើមមកធ្វើជាសំលៀកបំពាក់។ ថ្ងៃមួយគាត់ដើរទៅរកភិក្ខាហារ បានដើរទៅដល់កន្លែងសម្រាប់បញ្ចល់ពពែ, ក្នុងកាលនោះមានពពែ ១ បានឃើញបរិព្វាជកនោះហើយ ក៏ថយក្រោយបំរុងនឹងជល់ គាត់ឃើញពពែមានអាការដូច្នោះ នឹកស្មានថា វាធ្វើសេចក្ដីគោរពចំពោះខ្លួន ក៏អង្គុយថ្វាយបង្គំគួរសមចំពោះពពែនោះវិញ ។ គ្រានោះមានឈ្មួញបណ្ឌិតម្នាក់កំពុងអង្គុយលើរានផ្សារ ឃើញហេតុដូច្នោះហើយ ក៏និយាយឃាត់ថា នែព្រាហ្មណ៍ អ្នកឯងស្និទ្ធស្នាលនឹងសត្វជើង ៤ ធ្វើអ្វី ? មិនដឹងទេ ! វាបំរុងនឹងជល់អ្នកហើយ ។ ឈ្មួញបណ្ឌិតទើបតែនិយាយផុតពីមាត់ ពពែក៏បុះត្រង់ដើមទ្រូងដួលប្រួសក្នុងទីនោះទៅ ដល់នូវសេចក្ដីវេទនាជាទម្ងន់, ទើបភ្ញាក់ខ្លួនហើយពោលគាថាថា :

ឯវំ សោ និហតោ សេតិ យោ អបូជំ បសំសតិ
យថាហមជ្ជ បហដោ ហតោ មេណ្ឌេន ទុម្មតិ

ជនណាសរសើរបុគ្គលដែលគេមិនគួរបូជា ជននោះត្រូវ

បុគ្គលដែលគេមិនគួបួជាសម្លាប់, ដូចជាខ្ញុំដែលពពែកំណាច ដល់ស្លាប់ក្នុងថ្ងៃនេះ ។ និយាយដូច្នេះហើយ ក៏យំខ្សឹកខ្សួលប្រកាច់ស្លាប់ក្នុងពេលនោះទៅ ។

( មហា ប៉ុល_សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៧_ រឿងបុណ្ណសេដ្ឋី

( ចាក វិ. ខុ. )

( មានសទ្ធាប្រសើរជាងមានទ្រព្យ )

កាលព្រះសម្ពុទ្ធបរមគ្រូទ្រង់គង់នៅក្នុងវត្តវេឡុវន នាក្រុងរាជគ្រឹះ ។ ក្នុងកាលនោះមានបុរសកំសត់ម្នាក់ឈ្មោះបុណ្ណ បាននាំភរិយានិងកូនស្រីម្នាក់ឈ្មោះនាងឧត្តរា ទៅជួលធ្វើការឱ្យសុមនៈសេដ្ឋី ។ ថ្ងៃមួយអ្នកក្រុងរាជគ្រឹះ បាននាំគ្នាលេងមហោស្រពកំណត់ ៧ ថ្ងៃ ។ ឯសុមនសេដ្ឋី បានឮដំណឹងនោះហើយ ក៏បើកឱ្យទាសៈកម្មករទាំងឡាយ ទៅលេងមហោស្រពទាំងអស់គ្នា ។ ឯបុណ្ណៈមាណពពុំបានទៅលេងមហោស្រពនឹងគេឡើយ ទើបសេដ្ឋីសួរថា បុណ្ណ ! ហេតុអ្វីក៏មិនទៅលេងមហោស្រពនឹងគេ? ។ បុណ្ណមាណព ឆ្លើយថា បពិត្រលោកសេដ្ឋី ការទៅលេងមហោស្រព ជាភារៈរបស់ជនអ្នកមានទ្រព្យសម្បត្តិ ឯខ្ញុំនេះក្រណាស់រកតែអង្ករមួយនាឡិនៅលើផ្ទះមិនមាន, ព្រោះហេតុនោះបានជាខ្ញុំបាទមិនទៅលេងនឹង

គេ ។ សុមនសេដ្ឋីនិយាយថា ពាក្យដែលអ្នកនិយាយនេះត្រូវណាស់ យើងមិនដែលឮបុគ្គលណាមួយនិយាយដូចអ្នកឡើយ បើដូច្នោះអ្នកយកគោនិងនង្គ័លទៅភ្ជួរស្រែចុះ, បុណ្ណមាណព ក៏យកគោនង្គ័លទៅភ្ជួរស្រែទៅ ។ ពេលនោះព្រះសារីបុត្តចេញពីនិរោធសមាបត្តិហើយ ពិចារណារកបុគ្គលដែលគួរទៅសង្គ្រោះ ក៏បានឃើញបុណ្ណមាណពនោះ ចូលក្នុងសំណាញ់ញាណ ទើបលោកយកបាត្រ និមន្តសំដៅទៅស្រែដែលបុណ្ណមាណពកំពុងភ្ជួរ, ទៅដល់ហើយឈរងើយមើលឈើមួយដើម ។ បុណ្ណមាណពឃើញអាការដូច្នោះ ក៏ដាក់នង្គ័លចូលទៅថ្វាយបង្គំដោយសេចក្តីជ្រះថ្លា បានដឹងអធ្យាស្រ័យរបស់ព្រះសារីបុត្ត ដែលត្រូវការដោយឈើស្ទន់និងទឹកហើយ ក៏ឡើងកាច់ឈើស្ទន់ផងទឹកយកទៅប្រគេន, លោកក៏ទទួលយកទៅលុបព្រះភ័ក្ត្រខ្ពុរព្រះឱស្ឋ លុះធ្វើកិច្ចនោះស្រេចហើយ បានជ្រាបថាបន្តិចទៀត ភរិយារបស់បុណ្ណមាណពនេះ នឹងយកបាយមកឱ្យស្វាមីរបស់នាង ទើបលាបុណ្ណមាណព និមន្តទៅចាំស្ទាក់ផ្លូវនាងជាភរិយា ។ ឯនាងជាភរិយារបស់បុណ្ណមាណព កាលបើដល់ពេលហើយ ក៏ទូលបាយមួយចំអែតទៅឱ្យស្វាមី ទៅដល់ពាក់កណ្តាលផ្លូវបានឃើញព្រះសារីបុត្តឈរស្ពាយបាត្រក៏គិតថា អញមានលាភធំណាស់តើ បានជួបនឹងស្រែបុណ្យដ៏ប្រសើរយ៉ាងនេះ គិតដូច្នេះហើយ យកបាយទាំងអស់ដាក់ក្នុងបាត្រទៅ ទើបនាងតាំងសេចក្តី

ប្រាថ្នាថា ដោយផលនៃទាននេះ ខ្ញុំព្រះករុណាសូមឱ្យបានសម្រេចនូវគុណវិសេស ដូចជាលោកម្ចាស់ ។ ព្រះសារីបុត្តបានធ្វើភត្តានុ-មោទនាហើយ ក៏និមន្តហួសទៅ ។ ឯនាងជាភរិយារបស់បុណ្ណ-មាណពនោះ ក៏ម្នីម្នាត្រឡប់ទៅផ្ទះវិញ ខំចាត់ចែងចំអិនអាហារម្តងទៀត លុះចំអិនហើយ ក៏ដួសដោះដាក់ភាជន៍ យកទៅឱ្យស្វាមី ។ ឯបុណ្ណមាណពកាលបើមិនឃើញភរិយា យកបាយទៅឱ្យតាមទម្លាប់ពេលហើយ ក៏ចេះតែខំភ្ជួរដេររាបដល់បានដីចំនួន ៣២ សិន ដល់ថ្ងៃរសៀលបន្តិចមិនឃើញភរិយាយកបាយទៅឱ្យ ក៏ឈប់ភ្ជួរលែងគោឱ្យស៊ីស្មៅចូលទៅអង្គុយចាំភរិយាក្រោមម្លប់ឈើមួយដើម ។ ឯនាងជាភរិយាដើរទៅជិតដល់ហើយ បានឃើញស្វាមីអង្គុយចាំដូច្នោះ ភ័យខ្លាំងណាស់ទើបគិតថា បើអញយកបាយទៅជូនដូចធម្មតាក្រែងគាត់វាយ ដូច្នេះអញត្រូវស្រែកប្រាប់ពីចម្ងាយ នាងក៏ស្រែកប្រាប់ថា ខ្ញុំប្រគេនបាយលោកកណ្តាលផ្លូវអស់មួយដងទៅហើយ បានជាយូរក្រយកមកជូនអ្នក សូមអ្នកទទួលយកបុណ្យឱ្យបានច្រើនជាងខ្ញុំចុះ ។ បុណ្ណមាណពឮដូច្នោះហើយត្រេកអរណាស់ស្រែកថាសាធុ ៗ ក៏ជូនបុណ្យដែលខ្លួនបានប្រគេនឈើស្ទន់និងទឹកដល់ភរិយាវិញ ។ បុណ្ណមាណពបរិភោគអាហារហើយ ញ៉រខ្លួនខ្លាំងណាស់ ព្រោះហួសពេល ក៏ដេកកើយភ្លៅភរិយាលក់ទៅ ដល់ភ្ញាក់ឡើងក្រឡេកមើលទៅកន្លែងដែលភ្ជួរ ស្រាប់តែឃើញក្រហមច្រាល

ក៏នាំភរិយាដើរទៅមើល ឃើញដីដែលភ្ជួរបាន ៣២ សិននោះសុទ្ធតែជាមាសទាំងអស់. ទើបនិយាយថា បុណ្យយើងឱ្យផលហើយតើ បើដូច្នេះយើងត្រូវទៅក្រាបទូលដល់ព្រះរាជារបស់យើង ក៏នាំគ្នាទៅក្រាបទូលដល់ព្រះបាទពិម្ពិសារ ៗ ត្រេកអរណាស់បានចាត់ចែងឱ្យរាជអាមាត្យយករទេះដឹកជញ្ជូនទៅចាក់គរក្នុងព្រះរាជវាំង បានគំនរកំពស់ ៨០ ហត្ថ ទើបតាំងបុណ្ណមាណពនោះជាមហាសេដ្ឋីក្នុងនគររាជគ្រឹះ បានឈ្មោះថាបុណ្ណសេដ្ឋី ។ ក្នុងកាលជាខាងក្រោយមក ព្រះបាទពិម្ពិសារ បានព្រះរាជទានដីភូមិ ១ កន្លែងដល់បុណ្ណសេដ្ឋី ៗ ក៏ចាត់ចែងសង់ផ្ទះធ្វើឃ្លាំងធ្វើកំពែងព័ទ្ធភូមិនោះ ហើយជញ្ជូនយកមាសទៅដាក់ក្នុងឃ្លាំងរបស់ខ្លួនទៅ ទើបនិមន្តព្រះសម្ពុទ្ធ ព្រមទាំងព្រះសង្ឃទៅថ្វាយមហាទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃជាគំរប់ ៧ ព្រះសម្ពុទ្ធទ្រង់សំដែងអនុបុព្វិកថា លុះចប់កាលណា ជនទាំង ៣ រូបគឺ បុណ្ណសេដ្ឋី ភរិយារបស់បុណ្ណសេដ្ឋី និងនាងឧត្តរាជាកូន ក៏បានសម្រេចដល់សោតបត្តិផលក្នុងពេលនោះ ។

# ៣៨_ រឿងវនបាលបុត្រ

( ចាក ខុ. តិ. )

( ការក្លាហានរបស់នាយកជន អាចផ្ចាញ់សត្រូវបានងាយ )

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះព្រះបរមពោធិសត្វទ្រង់សោយព្រះជាតិក្នុងត្រកូលនៃបុគ្គលអ្នករក្សាព្រៃម្នាក់ ដល់ចំរើនវ័យឡើង មានបុរស ៥០០ នាក់ជាបរិវារ បានជាធំជាងត្រកូលទាំងឡាយ ដែលអាស្រ័យនៅក្បែរដងព្រៃមួយ ជាអ្នកស៊ីឈ្នួលជូនពួកអ្នកដំណើរដែលឆ្លងកាត់ដងព្រៃនោះ ។

ថ្ងៃមួយសត្ថវាហបុត្រ នៅក្នុងនគរពារាណសី បររទេះ ៥០០ ទៅដល់ស្រុកនោះហើយ បានហៅវនបាលបុត្រពោធិសត្វមកនិយាយថា ម្នាលសម្លាញ់ អ្នកចូរយកប្រាក់មួយពាន់រៀល ហើយសូមជូនចម្លងខ្ញុំឆ្លងកាត់ឱ្យផុតពីដងព្រៃនេះ ។ ព្រះពោធិសត្វកាលបើបានទទួលរង្វាន់នោះហើយ ក៏តាំងចិត្តលែងភិតភ័យ លះកាត់សេចក្តីអាល័យក្នុងជីវិតរបស់ខ្លួន ក្នុងដំណើរដែលប្រកបដោយភ័យដ៏ពន្លឹក ទើបជូនសត្ថវាហបុត្រឆ្លងកាត់ព្រៃនោះទៅ ។ ខណៈនោះមានចោរ ៥០០ នាក់ធ្វើជម្រុំពួនសម្ងំនៅកណ្តាលព្រៃ ដើម្បីស្ទាត់ប្លន់ពួករទេះ ។ ចោរទាំងនោះបានឃើញរទេះ ៥០០ បរទៅដល់ហើយ ក៏នាំគ្នាស្ទុះចូលទៅប្លន់ ។ ឯអ្នករទេះបានឃើញពួក

ចោរនោះ ក៏ភិតភ័យលោតរត់ចោលរទេះទៅពួនអស់ទៅ នៅសល់តែព្រះពោធិសត្វម្នាក់ឯង ឥតតក់ស្លុតរន្ធត់ឡើយ ក៏ក្លែងសេចក្តីក្លាហាន ស្រែកសន្ធាប់បន្លឺសំឡេងស្នូរសីហនាទ ធ្វើហាក់ដូចជាមានគ្នាច្រើនណាស់ បានវាយគុម្ពឈើធ្វើឱ្យ ចោរភិតភ័យរត់បាត់បង់អស់ទៅ ទើបជូនសត្ថវាហបុត្រឆ្លងកាត់ព្រៃ នោះបានដោយសួស្តី ។ ចំណែកខាងសត្ថវាហបុត្រ កាលបើបានរួចអំពីភ័យទៅដល់ទីក្សេមហើយ ក៏ដាក់រទេះក្នុងតំបន់មួយ អញ្ជើញព្រះពោធិសត្វឱ្យបរិភោគភោជនាហារ លុះបរិភោគហើយ ក៏សួរព្រះពោធិសត្វថា ម្នាលសម្លាញ់ក្នុងពេលដែលចោរ ៥០០ នាក់សុទ្ធតែកាចឃោរឃៅកាន់អាវុធគ្រប់ដៃ ស្ទុះចូលមកគម្រាមប្ញទ់ ហេតុអ្វីបានជាសំឡាញ់នៅតែក្លាហានឥតមានភ័យតក់ស្លុតសោះ ? ។ ព្រះពោធិសត្វប្រាប់ថា មនុស្សដែលធ្វើជានាយកលើគេ ត្រូវតែមានចិត្តក្លាហាន មានអំណត់តស៊ូនឹងឧបសគ្គទាំងពួង មិនត្រូវស្តាយជីវិតមិនត្រូវគិតប្រយោជន៍ផ្ទាល់ខ្លួន ទាំងមិនត្រូវមើលបំណាំគ្នាឡើយត្រូវជួយការពារផ្តល់ប្រយោជន៍ឱ្យគ្នីគ្នាជាដរាប ។ ព្រះពោធិសត្វសំដែងសេចក្តីក្លាហានរបស់នាយកជនដូច្នេះហើយ ក៏វិលទៅលំនៅរបស់ខ្លួនវិញ ។

# ៣៩. រឿងនាគទេវបុត្រ

( ចាក វិ. នុ. )

( គុណនៃការបូជាផ្កាឈើ ដល់ព្រះចេតិយ )

កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅវត្តជេតពន, កាលនោះព្រះមោគ្គល្លាន ចូលទៅថ្វាយបង្គំលាព្រះសម្ពុទ្ធនិមន្តទៅទេវលោក ដើម្បីពិនិត្យមើលទិព្វសម្បត្តិរបស់ពួកទេវតាក្នុងឆកាមាសួគ៌ . ព្រះសម្ពុទ្ធក៏ទ្រង់អនុញ្ញាតឱ្យទៅ ។ ដល់ស្ថានតាវត្តិង្សបានឃើញទេវបុត្រមួយរូប ជិះវិមានធំសំបើមអស្ចារ្យ មានអវយវៈទាំងអស់សសុទ្ធ. វិមាននោះមានភ្លុកពីរធំវែង ក្នុងភ្លុកមួយៗ មានស្រះបោក្ខរណីមួយៗ. ក្នុងស្រះមួយៗ មានផ្កាឈូក ៧. ក្នុងផ្កាឈូកមួយៗ មានស្រីទេពអប្សរមួយ ៗ ច្រៀងរាំប្រគំដេញដំតូរ្យតន្ត្រីថ្វាយដល់ទេវបុត្រនោះ ។ ព្រះមោគ្គល្លានបាននិមន្តទៅឈរពីមុខវិមាននោះ, ទេវបុត្របានឃើញហើយ ក៏ចុះទៅថ្វាយបង្គំដោយគោរព លុះថ្វាយបង្គំរួច ព្រះមោគ្គល្លានមានថេរដីកាសួរអំពីឈ្មោះ និងប្រវត្តិរបស់ទេវបុត្រនោះ ។ បានទូលតបថេរដីកាថា ខ្ញុំព្រះករុណាឈ្មោះនាគទេវបុត្រ, កាលសាសនាព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបព្រះអង្គបរិនិព្វានហើយ, កាលនោះពួកមហាជន នាំគ្នាដង្ហែព្រះសារីរិកធាតុទៅបញ្ចុះក្នុងចេតិយមាសកំពស់មួយយោជន៍ ហើយនាំគ្នាយកផ្កាភ្ញីទៅបូជាព្រះចេតិយ ។ ក្នុងសម័យនោះខ្ញុំព្រះករុណា កើតជាឧបាសក

មួយរូប មានសទ្ធាជឿជាក់ក្នុងគុណព្រះរតនត្រ័យ បានយកលុយ ៨ កហាបណៈ ទៅទិញផ្កាអំពីនាយមាលាការម្នាក់ ។ ពេលនោះផ្កាក្រ ជាទីបំផុត ក្នុងសួនរបស់នាយមាលាការនោះ រកផ្កាមួយទងគ្មាន ឡើយ ព្រោះមហាជននាំគ្នាទិញយកទៅបូជាព្រះចេតិយគ្រប់ៗគ្នា។ នាយមាលាការបានប្រាប់ខ្ញុំព្រះករុណាថា ផ្កាគ្មានទេ បើអ្នកត្រូវការ ខានមិនបាន អញ្ជើញរកមើលបេះខ្លួនឯងចុះ ។ ខ្ញុំព្រះករុណាក៏បាន ចូលទៅក្នុងសួន ខំរកមើលតាំងពីដើមសួនរហូតដល់ចុងសួន, ឃើញផ្កា ៨ ទងជ្រុះនៅក្បែរគល់ ក៏រើសយកទៅបង្ហាញនាយ មាលាការ បានឱ្យថ្លៃ ៨ កហាបណៈ នាយមាលាការមិនព្រមយក បែរជានិយាយថា ផ្កានេះជាលាភរបស់អ្នកហើយ អ្នកអញ្ជើញយក ចុះ, ខ្ញុំព្រះករុណា ក៏យកទៅបូជាព្រះចេតិយនោះទៅ ។ ក្នុងកាល ជាខាងក្រោយមក ខ្ញុំព្រះករុណាធ្វើមរណកាល ក៏បានមកកើតក្នុងទី នេះតែម្តង ។ ព្រះមោគ្គល្លានបានជ្រាបដំណឹងនោះហើយ និមន្ត ហួសទៅទីដទៃទៀតទៅ ។

# ៤០~ រឿងទុដ្ឋកុមារ

( ចាក ធ. ទុ. )

( ការឥច្ឆាប្រណែន តែងផុតសត្វលោក )

ក្នុងកាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមកិត្តិវាសៈ សោយរាជសម្បត្តិក្នុងក្រុងពារាណសី. មានព្រះរាជបុត្រមួយព្រះអង្គទ្រង់ព្រះនាមទុដ្ឋកុមារ បានធ្វើជាឧបរាជ ។ ថ្ងៃដែលកុមារនោះប្រសូត្រ ហោរបានទាយថា ព្រះរាជបុត្រនេះ បើមិនបានទឹកសោយវេលាណា នឹងទីវង្គតក្នុងវេលានោះ ។ ព្រះរាជាបានជ្រាបហេតុដូច្នោះហើយ ទ្រង់ចាត់ចែងឱ្យជីកស្រះបោក្ខរណីទាំងខាងក្នុងខាងក្រៅនគរ ហើយឱ្យធ្វើមណ្ឌបសម្រាប់ដាក់ទឹកត្រង់ផ្លូវបែកជា ៤ ទៀត ។ ថ្ងៃមួយទុដ្ឋកុមារឧបរាជ ស្ដេចយាងទៅឧទ្យានអំពីព្រលឹម លុះយាងទៅដល់ពាក់កណ្ដាលផ្លូវ បានជួបនឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គ កំពុងនិមន្តទៅបិណ្ឌបាត្រ ។ ពួកមហាជនទាំងឡាយ បានឃើញព្រះបច្ចេកពុទ្ធនោះ ក៏នាំគ្នានិយាយសរសើរហើយថ្វាយបង្គំគ្រប់ៗ គ្នា ។ ឧបរាជឃើញដូច្នោះសេចក្ដីប្រណែនក៏កើតឡើង ទ្រង់ព្រះពិរោធជាខ្លាំងដោយទ្រង់ព្រះចិន្តាថា ពួកមហាជនទាំងនេះ ដើរជាមួយនឹងអញដែលជាឥស្សរជនលើវាបែរជានាំគ្នានិយាយសរសើរថ្វាយបង្គំមនុស្សត្រងោលវិញ ។ ទ្រង់ព្រះចិន្តាដូច្នេះហើយក៏យាងចុះពីដំរី ស្ទុះទៅកញ្ឆក់យកបាត្រពីព្រះ

ហស្តព្រះបច្ចេកពុទ្ធ បោកចោលទៅលើផែនដី ហើយយកព្រះបាទ ជាន់ឈ្លួចឈ្លីបំបែកខ្ទេចខ្ទីអស់ទៅ ។ ព្រះបច្ចេកពុទ្ធឃើញបាត្រ បែកខ្ទេចខ្ទីអស់ហើយ គ្រាន់តែមើលព្រះភ័ក្ត្រគិតថា ឱហ្ន ! សត្វ នេះវិនាសហើយតើ ក៏ហោះទៅកាន់ញកភ្នំនន្ទមូលទៅ។ ក្នុងខណៈ នោះកម្មអាក្រក់ឱ្យផលដល់ឧបរាជ ធ្វើឱ្យក្តៅអន្ទះអន្ទែងក្រហល់ ក្រហាយដូលជ្រប់ក្នុងទីនោះ ។ ទឹកទាំងឡាយក៏រីងស្ងួតអស់ សូម្បី តែទឹកក្នុងប្រឡាយ ក៏រីងអស់ឥតសល់ ។ ឧបរាជកាលបើរកទឹក សោយមិនបានហើយក៏ទិវង្គតទៅ ធ្លាក់ទៅកើតក្នុងនរកធំឈ្មោះ អវីចិ ។

( មហា ប៊ុល - សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៤១- រឿងស្វេ្វាពោធិសត្វ

( ចាក កា. ឯ. )

( អ្នកសង្គ្រោះជាតិ គួរកុំស្តាយជីវិត )

ក្នុងកាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិ ជាក្អែក មានក្អែក ៨០ ពាន់ចោមរោមជាបរិវារ នៅក្នុងមហាស្ម សាន ។ ថ្ងៃមួយមានបុរោហិតរបស់ព្រះបាទពារាណសីម្នាក់ ទៅ មុជទឹកស្ទឹងក្រៅនគរ លុះមុជហើយក៏ត្រឡប់ចូលមកនគរវិញ ។ សម័យនោះមានក្អែកពីរ ទំលើចុងកំពូលខ្លោងទ្វារនគរ ក្អែកមួយ

និយាយថា ម្នាលសម្លាញ់ ខ្ញុំគិតជុះដាក់ក្បាលបុរោហិតនេះ ។ ក្អែកមួយឃាត់ថា អ្នកកុំធ្វើយ៉ាងនេះឡើយ. បុរោហិតនេះជាអ្នកធំ ការមានពៀរជាមួយនឹងអ្នកធំពិបាកណាស់ ព្រោះអ្នកធំតែខឹងហើយ គេធ្វើពួកក្អែកទាំងអស់ឱ្យវិនាសបាន ។ ក្អែកមួយមិនស្ដាប់ ក៏ជុះដាក់ក្បាលបុរោហិតនោះទៅ ។ បុរោហិតដឹងថាក្អែកជុះដាក់ខ្លួនហើយខឹងណាស់ បានចងពៀរចំពោះពួកក្អែកទាំងឡាយ តាំងពីពេលនោះមក ។ គ្រានោះមានស្ត្រីម្នាក់កំពុងហាលស្រូវ ស្រាប់តែមានពពែមួយទៅស៊ីស្រូវ ស្ត្រីនោះក៏ចោលពពែនឹងអង្កត់ឧស ឆេះរោមសន្ធោសន្ធៅ, ពពែក្ដៅខ្លាំងណាស់រត់ទៅត្រដុសខ្លួននឹងខ្ទមស្លឹកមួយក្បែររោងដំរីព្រះរាជា ភ្លើងក៏ឆេះខ្ទមរាលឆេះដល់រោងដំរីរលាកដំរីក្នុងរោងនោះជាច្រើន ។ អ្នករក្សាដំរីមិនអាចមើលដំបៅដំរីនោះបានឡើយ ក៏ចូលទៅក្រាបទូលដល់ព្រះរាជា ។ កាលនោះព្រះរាជាទ្រង់ត្រាស់សួរបុរោហិតថា អ្នកដឹងថ្នាំលាបដំបៅដំរីឬទេ ? បុរោហិតក្រាបទូលថា បពិត្រមហារាជខ្លាញ់សត្វក្អែក ពូកែបំផុតខាងលាបដំបៅដំរី ។ ព្រះរាជាទ្រង់ត្រាស់ថា បើដូច្នោះអ្នកនាំគ្នាសម្លាប់ក្អែកយកខ្លាញ់ទៅឱ្យហ្មដំរីឱ្យឆាប់ ៗ ។ តាំងពីពេលនោះមក បុរោហិតក៏បង្គាប់ឱ្យមនុស្សទាំងឡាយសម្លាប់ក្អែកគ្រប់ៗ គ្នា ដើម្បីយកខ្លាញ់ ។ អសន្តិសុខ ក៏កើតឡើងដល់ពួកក្អែកក្នុងពេលនោះជាខ្លាំង ។ ក្អែកព្រះពោធិសត្វបានដឹងហេតុនោះហើយ មានប្រាថ្នា

ដើម្បីសង្គ្រោះជាតិ ក៏នឹករំពឹងដល់បារមីធម៌ញាំងមេត្តាបារមីឱ្យកើតឡើង លះបង់ជីវិត ហើរសំដៅចូលតាមបង្អួចមហាប្រាសាទ ទៅក្រាបក្រោមអាសនៈព្រះរាជា ។ ក្នុងពេលនោះមានមនុស្សម្នាក់ប្រុងស្ទុះទៅចាប់ ព្រះរាជាទ្រង់ឃាត់មិនឱ្យចាប់ ។ ព្រះពោធិសត្វសម្រាកបន្តិចហើយ ដើរចេញពីក្រោមអាសនៈមកថ្លែងការណ៍ទូលព្រះរាជាដោយបណ្ឌិតវ៉ាទ ហើយទូលថែមទៀតថា បុរោហិតជាអ្នកមានពៀរក្នុងពួកក្អែក បាននិយាយទូលព្រះអង្គថា ក្អែកមានខ្លាញ់, ធម្មតាសត្វក្អែកតាំងពីកាលណាមក មិនដែលមានខ្លាញ់ឡើយ. ទើបពោលគាថាថា :

**និច្ចំ ឧព្វិគ្គហទយា សព្វលោកវិហេសកា**
**តស្មា នេសំ វសា នត្ថិ កាកានស្មាកញាតីនំ**

បពិត្រមហារាជ ធម្មតាក្អែកជាសត្វមានចិត្តភ័យញ័របំផុតជានិច្ច ព្រោះមនុស្សលោកទាំងពួងចោមរោមបៀតបៀនហើយហេតុនោះ បានជាខ្លាញ់របស់ក្អែកទាំងឡាយ ដែលជាញាតិរបស់ទូលបង្គំនោះមិនមាន ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយសោមនស្សរីករាយ បានយកប្រេងក្រអូបលាបស្រលាប ហើយលើករាជសម្បត្តិបូជាដល់ក្អែកពោធិសត្វ ។ ព្រះពោធិសត្វទ្រង់ថ្វាយរាជសម្បត្តិដល់ព្រះរាជាវិញ បានទូន្មានព្រះរាជាឱ្យស្ថិតនៅក្នុងសីល ៥ ទើបសូមអភ័យដល់

សត្វក្អែកទាំងពួង ។ ព្រះរាជាក៏ទ្រង់ឱ្យអភ័យដល់សត្វក្អែកទាំងអស់ ហើយទ្រង់ព្រះរាជទានចំណីដល់ពួកក្អែកទាំងឡាយក្នុងពេលនោះ។ ចំណែកខាងព្រះពោធិសត្វ ទ្រង់ព្រះរាជទានភោជនដែលព្រះអង្គតែងសោយឱ្យជានិច្ចរាល់ថ្ងៃ ។

## ៤២_ រឿងខ្មោចយក្ស

( ចាក ម. វា. )

( គុណនៃការដល់នូវត្រៃសរណគមន៍ )

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ឈ្មោះពុទ្ធទាសៈ នៅក្នុងគុណកគ្រាម ក្នុងអាណាចក្ររបស់ព្រះបាទកោសល ជាអ្នកដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិត ។ កាលនោះ មានបុរសម្នាក់នៅក្នុងបរជនបទ បានចូលទៅសំណាក់ក្នុងផ្ទះនៃឧបាសកឈ្មោះពុទ្ធទាសៈនោះ ។

វេលានោះ មានខ្មោចយក្សមួយ ចូលទៅបៀតបៀនអ្នកស្រុកក្នុងគុណកគ្រាមនោះ ដើម្បីយកចំណីអាហារបរិភោគ ។ ឯខ្មោចយក្សនោះ បានឃើញបុរសម្នាក់ដែលចូលទៅសំណាក់ក្នុងផ្ទះពុទ្ធទាសឧបាសកនោះហើយ ចង់ចាប់បរិភោគជាអាហារ ប៉ុន្តែមិនអាចចូលទៅជិតផ្ទះនោះបានឡើយ ព្រោះខ្លាចតេជៈនៃពុទ្ធទាសឧបាសកដែលដល់នូវត្រៃសរណគមន៍ ក៏រង់ចាំបុរសនោះខាងក្រៅភូមិអស់៦

ថ្ងៃ ។ លុះដល់ថ្ងៃជាគំរប់ ៧ បុរសដែលចូលទៅសំណាក់ ក៏លាពុទ្ធ-ទាសឧបាសកត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ គ្រាន់តែចេញផុតពីផ្ទះទៅដល់ក្រៅភូមិ ខ្មោចយក្ខស្ទុះទៅចាប់បុរសនោះជាប់. បុរសនោះភិតភ័យខ្លាំងណាស់ ភ្ញាក់មាត់សួរខ្មោចយក្ខនោះថា អ្នកទៅណាមកចាប់ខ្ញុំធ្វើអ្វី ? ។ ខ្មោចយក្ខនិយាយតបថា អញមកចាំចាប់អ្នកឯងបរិភោគអស់ ៦ ថ្ងៃហើយ ព្រោះអញមិនហ៊ានចូលទៅចាប់ឯងក្នុងផ្ទះពុទ្ធទាសឧបាសក ដោយខ្លាចគុណនៃព្រះរតនត្រ័យ។ បុរសនោះឮខ្មោចយក្ខថាដូច្នោះហើយ ក៏និយាយបញ្ឆោតថា ពុទ្ធទាសឧបា-សក គាត់ដល់នូវត្រៃសរណគមន៍យ៉ាងណា ខ្ញុំក៏ដល់នូវត្រៃសរណ-គមន៍យ៉ាងនោះដែរ និយាយដូច្នេះហើយក៏សូត្រថា ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ គច្ឆាមិ, យក្ខគ្រាន់តែឮដូច្នោះ ក៏ភ័យតក់ស្លុតរន្ធត់ញ័រសព្វសព៌ាង្គកាយ ស្ទុះរត់បាត់ទៅ ។

## ៤៣_ រឿងប្រេតក្លាយជាទេវតា

( ចាក លោ. ទី. )

( គុណនៃការផ្សាយកុសលដល់ប្រេត )

ក្នុងកាលកន្លងទៅហើយ មានប្រេតមួយរូប អត់ឃ្លានអាហារច្រើនលានឆ្នាំ តែងនឹករឭករកញាតិមិត្របងប្អូនជានិច្ច. ប៉ុន្តែពុំដែលបងប្អូនញាតិមិត្រណា ឧទ្ទិសកុសលផ្សាយឱ្យម្ដងសោះ ។ ថ្ងៃមួយ

មានឧបាសកម្នាក់ឈ្មោះវិទេហៈ ដេកនៅក្នុងខ្ទមស្រែ ចាំស្រូវក្នុងលង្កាទ្វីប ស្រាប់តែប្រេតនោះទៅសុំអាហារបរិភោគ ដោយទឹកវព្វកឃើញថា វិទេហឧបាសកនេះ ត្រូវជាសម្លាញ់របស់អញក្នុងជាតិមុនយូរអង្វែងណាស់ហើយ។ វិទេហឧបាសកឮសំឡេងប្រេតស្រែកសុំអាហារបរិភោគដូច្នោះ ក៏សួរថាអ្នកជាអ្វី ? មកពីណា ? ។ ប្រេតប្រាប់ថា ខ្ញុំត្រូវជាសម្លាញ់របស់អ្នកក្នុងជាតិដែលកន្លងទៅយូរអង្វែងណាស់ហើយ ខ្ញុំស្លាប់ពីជាតិនោះបានមកកើតជាប្រេតនៅក្នុងលង្កាទ្វីបនេះ ពុំដែលបានអាហារបរិភោគឡើយ ញាតិមិត្របងប្អូនទាំងឡាយ គេមិនដែលឧទ្ទិសផលដល់ខ្ញុំម្តងសោះ បានជាខ្ញុំមកសុំអាហាររបស់សម្លាញ់បរិភោគ ។ វិទេហឧបាសកឮដូច្នោះ មានចិត្តអាណិតពន់ពេក ទើបហៅប្រេតឱ្យឡើងទៅលើខ្ទម យកបាយមកឱ្យប្រេតស៊ី ។ ប្រេតឃើញឧបាសកឱ្យបាយដូច្នេះហើយ ក៏និយាយថា ម្នាលសម្លាញ់បើអាណិតខ្ញុំ អ្នកចូរយកភត្តទៅថ្វាយដល់ព្រះសង្ឃ ហើយឧទ្ទិសផលឱ្យដល់ខ្ញុំ ទើបខ្ញុំទទួលបរិភោគបាន ។ លុះព្រឹកឡើងវិទេហឧបាសក បានចាត់ចែងថ្វាយភត្តដល់ព្រះសង្ឃឧទ្ទិសបញ្ជូនផលទៅប្រេតនោះៗ កាលបើបានទទួលផលហើយ ក៏មានរូបកាយស្អាតបាត បរិភោគអាហារទិព្វឆ្អែតស្កប់ស្កល់ ប៉ុន្តែនៅខ្វះសំពត់ស្លៀកទៀត ក៏ដើរទៅឈរបង្ហាញខ្លួនដល់វិទេហឧបាសកនិយាយសុំសំពត់អាវស្លៀកពាក់ ។ វិទេហឧបាសកប្រាប់ថា បើអ្នក

ខ្ទះសំពត់ខ្ញុំមានសំពត់កម្ពល ៣ អ្នកមកយកទៅស្លៀកចុះ ។ ប្រេត និយាយថា ឱ្យខ្ញុំយ៉ាងហ្នឹងមិនបានទេ ចូរសម្លាញ់យកទៅប្រគេន ព្រះសង្ឃដូចមុន ទើបខ្ញុំទទួលបាន ។ វិទេហឧបាសក ក៏ចាត់ចែង យកសំពត់ទៅប្រគេនដល់ព្រះសង្ឃ. សំពត់នោះក៏ក្លាយទៅជា សំពត់ទិព្វ កើតដល់ប្រេតនោះ ។ ក្នុងវេលានោះប្រេតក៏ក្លាយខ្លួន ទៅជាទេវបុត្រ ដោយអំណាចកុសលដែលវិទេហឧបាសកឧទ្ទិស ផ្សាយឱ្យ ។ ប្រេតកាលបើបានក្លាយខ្លួនទៅជាទេវតាហើយ ក៏រឭក ដល់គុណរបស់វិទេហឧបាសក ទើបដើរទៅបង្ហាញខ្លួនហើយ និយាយថា ម្នាលសម្លាញ់ អ្នកមានគុណលើរូបខ្ញុំច្រើនណាស់ ខ្ញុំគ្មាន អ្វីតបគុណសម្លាញ់ទេ ចូរសម្លាញ់ទៅគាស់យកកំណប់ទ្រព្យ ៣ ក្អម នៅក្រោមដើមជ្រៃក្បែរភ្លឺស្រែអ្នកចុះ ព្រោះកំណប់នោះខ្ញុំឃើញយូរ ហើយ គ្មានម្ចាស់ថែរក្សាទេ ។ វិទេហឧបាសកយកចបទៅកាប់ មើល ឃើញជាកំណប់ពិតមែន ក៏ទៅក្រាបទូលដល់ព្រះរាជារបស់ ខ្លួន ។ ព្រះរាជាបានចាត់ចែងឱ្យយករទេះទៅដឹកមកចាក់គរនៅមុខ ព្រះបរមរាជវាំង ហើយទ្រង់តាំងឧបាសកនោះឱ្យធ្វើមហាសេដ្ឋី គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទៅ ។ ឯប្រេតនោះមានប្រាសាទ មាសផុសនៅស្ថានត្រៃត្រឹង្ស ក៏ឡើងទៅនៅក្នុងស្ថានទេវលោក បរិបូណ៌ដោយទិព្វសិរីខ្ពង់ខ្ពស់ផុតពីសេចក្តីទាល់ក្រគ្រប់យ៉ាង ។

## ៤៤. រឿងកិសវច្ឆតាបស

( ចាក ស. ម. )

( មើលងាយមនុស្សសុចរិត ដូចមើលងាយទេវតា )

កាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាកូនបុរោហិតរបស់ស្តេចក្រុងពារាណសី មានព្រះនាមថាជោតិបាល ។ ក្នុងកាលជាខាងក្រោមមក កុមារនោះបានសំដែងសិល្បសាស្ត្រធ្នូថ្វាយព្រះរាជា ក៏ប្រែរជាមានព្រះនាមថាសរភង្គវិញ ។ ថ្ងៃមួយសរភង្គមិនបានប្រាប់បុគ្គលណាសោះ ចូលទៅក្នុងព្រៃខិតបួសជាឥសីតែម្នាក់ឯង អាស្រ័យនៅក្នុងអាស្រមដែលសក្កប្រទានឱ្យ. ព្រៃនោះចម្ងាយ៣០ យោជន៍ពីក្រុងពារាណសី ក្បែរឆ្នេរស្ទឹងឈ្មោះគោធាវរី នៅក្នុងទីនោះបាន ៧ ថ្ងៃ ក៏ញុំាងឈានឱ្យកើតឡើង ។ ថ្ងៃមួយព្រះរាជាជាច្រើនអង្គ មានព្រះរាជាក្រុងពារាណសី និងអ្នកក្រុងនោះជាដើម នាំគ្នាចូលទៅបួសក្នុងសំណាក់សរភង្គតាបសចង្អៀតពាសពេញអាស្រម ។ ឯសរភង្គតាបសនោះមានសិស្សច្បងមួយរូប ឈ្មោះកិសវច្ឆៈ ជាអ្នកពេញចិត្តក្នុងទីស្ងាត់ បានគេចចេញអំពីអាស្រមនោះ ទៅនៅក្នុងឱទ្យានរបស់ព្រះរាជាទ្រង់ព្រះនាមទណ្ឌកី នានគរកុម្ភវតី ដោយមានសេនាបតីម្នាក់ ជាអ្នកទំនុកបំរុង។ កាលនោះព្រះបាទទណ្ឌកី ទ្រង់មិនសព្វព្រះទ័យនឹងស្ត្រីផ្កាមាសម្នាក់ បានបង្គាប់ឱ្យរដ្ឋមន្ត្រីដកឋានន្តរពីស្ត្រីនោះចេញ ។ តាំងពីថ្ងៃនោះ

មក ស្ត្រីនោះចេះតែដើរសម្លុតដើម្បីឱ្យបានឋានន្តរវិញ. សម័យមួយ បានចូលទៅក្នុងឱទ្យាន ជួបនឹងកិសវច្ឆតាបសទើបគិតថា អញ ឃើញតាបសនេះចង្រៃណាស់ ក៏ស្តោះទឹកមាត់ចោលឈើស្ទន់ចាក់ ទឹកលុបមុខទៅលើព្រះកេសតាបស ហើយចៀសចេញទៅ ។ ក្នុង ថ្ងៃនោះព្រះរាជា បានប្រទានឋានន្តរឱ្យវិញ. កន្លងពីរបីថ្ងៃមក ព្រះ រាជាទ្រង់ហូតឋានន្តរពីបុរោហិតម្នាក់ទៀត ។ បុរោហិតក៏ចូលទៅ សួរស្ត្រីនោះថា នាងធ្វើឧបាយដូចម្តេច ទើបបានឋានន្តរវិញ ? ស្ត្រី នោះក៏ប្រាប់ហេតុសព្វគ្រប់ ។ បុរោហិតធ្វើតាមក៏បានឋានន្តរវិញ ជនទាំងពីរនាក់នឹកស្មានថា ដែលព្រះរាជាប្រទានឋានន្តរវិញ ព្រោះ ខ្លួនបានទៅស្តោះទឹកមាត់ដាក់ព្រះកេសឥសី មិនមែនបានដោយ កុសលពីជាតិមុន ។ កន្លងពីរបីថ្ងៃមក មានការបះបោរកើតអសន្តិ- សុខ ក្នុងបច្ចន្តប្រទេស ព្រះរាជាបានប្រជុំពួកយោធាបំរុងនឹងចេញ ទៅបង្ក្រាបសត្រូវ ទ្រង់បានជ្រាបថាការស្តោះទឹកមាត់ដាក់ព្រះ កេសកិសវច្ឆតាបសមានជោគជ័យល្អ ក៏នាំទ័ពចូលទៅក្នុងឱទ្យាន ខាកស្តោះទឹកមាត់ដាក់ព្រះកេសតាបសគ្រប់ៗគ្នា គ្រាន់តែកំហាក នឹងទឹកមាត់ ប្រឡាក់ជោរជោគគ្របលេចសរីរៈតាបស ។ ចំណែក ខាងសេនាបតីជាឧបដ្ឋាកតាបស ដឹងហេតុនោះហើយក៏មីម្នាទៅ ឱទ្យាន ដងទឹកទៅដុសលាងជំរះមន្ទិលកំហាកនិងទឹកមាត់ស្អាតបាត ហើយ ក៏លាន់មាត់ថាមនុស្សទាំងអស់នេះ មិនគួរធ្វើយ៉ាងហ្នឹង

សោះ ទើបសួរតាបសថា លោកម្ចាស់ខឹងឬទេ ? ។ តាបសប្រាប់ថា អាត្មាឥតអាក់អន់ចិត្តខឹងបន្តិចបន្តួចទេ ប៉ុន្តែទេវតាគេខឹងខ្លាំងណាស់ នៅតែ ៧ ថ្ងៃទៀត នគរកុម្ភវតីនេះនឹងវិនាសសាបសូន្យអស់ឥតសល់ ។ សេនាបតីក៏បានរៀបដំណើរដឹកនាំទ្រព្យសម្បត្តិចេញផុតពីនគរនោះទៅ ។ ឯសរភង្គតាបសបានប្រើតាបសពីររូបឱ្យមកនិមន្តកិសវច្ឆតាបសទៅអាស្រមវិញ ។ ឯព្រះរាជាដែលលើកទ័ពទៅបង្ក្រាបបច្ចន្តគ្រាម ក៏មានជ័យជំនះដូចបំណង លុះត្រឡប់ចូលមកនគរវិញទេវតាក៏បង្អុរភ្លៀងផ្កាម្លិះ ភ្លៀងមាសប្រាក់ ភ្លៀងកែវទាំង ៧ ប្រការធ្លាក់ចុះមកគរពាសពេញនគរទាំងមូល ។ ព្រះរាជាព្រមទាំងជនអ្នកប្រព្រឹត្តទុច្ចរិតទាំងប៉ុន្មាន មានសេចក្ដីត្រេកអរណាស់បាននិយាយគ្នាថា យើងតាំងពីខាកស្ដោះដាក់ព្រះកេសឥសីចេះតែមានជោគជ័យជាប់ជានិច្ច ។ ក្នុងពេលនោះ មានបុរសម្នាក់ឈ្មោះរាម នៅក្នុងនគរពារាណសីជាអ្នកចិញ្ចឹមមាតាបិតា បានមកធ្វើជំនួញទៅក្នុងនគរកុម្ភវតី ចំនួន ៩ ឆ្នាំហើយ ទេវតាបានជ្រាបថា បុរសនោះ ជាអ្នកចិញ្ចឹមមាតាបិតា ក៏នាំចេញពីនគរនោះទៅ ។ ឯពួកមនុស្សដែលមិនប្រទូស្តដល់តាបស និងសត្វតិរច្ឆានទាំងឡាយទេវតាក៏បណ្ដាលឱ្យចេញផុតអស់ទៅ ។ លំដាប់នោះ ស្រាប់តែមានភ្លៀងអាវុធ ភ្លៀងរងើកភ្លើង ភ្លៀងដុំថ្មប៉ុនៗ ផ្ទះ ភ្លៀងដីខ្សាច់ធ្លាក់ចុះមកមានកំពស់ ៨០ ហត្ថ សម្លាប់មនុស្សទុច្ចរិត និងបំផ្លាញបំបែក

វិមានប្រាសាទ ផ្ទះសំបែង ធ្វើនគរកុម្ភវតីនោះ ឱ្យសាបសូន្យវិនាស អស់ទៅ ។

( មហាប៉ុល សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

៧៛៩

## ៤៥. រឿងភដ្ដហារកៈ

( ចាក ម. អ. )

( អ្នកមានលាភ មិនស្មើអ្នកមានបុណ្យ )

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់រកស៊ីលក់ឧស នៅក្នុងក្រុងពារាណសី ។ ថ្ងៃមួយបុរសនោះចេញទៅនាំឧសអំពីព្រៃដើម្បីយកទៅលក់ឯក្រុងវេសាលី ស្ដុនដំណើរទៅមិនដល់ទីក្រុង ក៏ដាក់រទេះដេកក្បែរខ្ទមអ្នកតាមួយ នៅលើដើមឈើក្បែរខ្ទមអ្នកតានោះ មានមាន់ដេកជាច្រើន ។ ពួកមាន់ទាំងនោះ មានមាន់មួយដេកខ្ពស់ជាងគេ បានជុះដាក់មាន់ដែលដេកខាងក្រោម ។ មាន់ដេកខាងក្រោមសួរថា អ្នកណាជុះដាក់យើង. មាន់ខាងលើប្រាប់ថាខ្ញុំជុះមិនបានជាគិត ហើយជុះដាក់ម្ដងទៀត ។ មាន់ទាំងពីរក៏កើតវិវាទទាស់ទែង សួរគ្នាទៅវិញទៅមកថា កម្លាំងសាច់របស់អ្នកមានអានុភាពយ៉ាងណា ពូកែដូចម្ដេចខ្លះ ? ។ លំដាប់នោះមាន់ដេកខាងក្រោមនិយាយឡើងថា សាច់ខ្ញុំមានអានុភាពណាស់ អ្នកណាបានបរិភោគ អ្នកនោះត្រូវបានប្រាក់១ពាន់រៀលពីព្រលឹម ។ ចំណែក

ខាងមាន់ដែលដេកខាងលើនិយាយថា សាច់អ្នកឯងមិនដល់សាច់ខ្ញុំទេ បើអ្នកណាស៊ីសាច់ចំឡករបស់ខ្ញុំ អ្នកនោះនឹងបានជាស្ដេច. បើអ្នកណាស៊ីសាច់ខាងក្រៅ អ្នកនោះបើជាបុរសនឹងបានជាសេនាបតី បើជាស្ត្រីនឹងបានជាអគ្គមហេសី. បើអ្នកណាស៊ីសាច់បន្ទាប់ឆ្អឹង អ្នកនោះបើជាគ្រហស្ថនឹងបានជានាយឃ្លាំង បើជាបព្វជិតនឹងបានជាជីតុនរបស់ព្រះរាជា ។ កដ្ឋហារបុរស លុះឮពាក្យរបស់មាន់ទាំងពីរហើយ ក៏ឡើងទៅចាប់យកមាន់ខាងលើដោយបំណងថានឹងបានជាស្ដេច ហើយយកមាន់នោះទៅឱ្យភរិយាចំអិនជាអាហារ ។ លុះភរិយាចំអិនហើយ ដាក់ក្នុងភាជន៍យកទៅជូនស្វាមី ៗ ប្រាប់ថាសាច់មាន់នេះមានអានុភាពធំណាស់ យើងទាំងពីរនាក់បរិភោគនឹងបានជាស្ដេច ជាអគ្គមហេសី ចូរនាងយកភាជន៍ទៅក្បែរស្ទឹងគង្គា យើងនាំគ្នាមុជទឹកហើយសឹមបរិភោគ ។ ជនទាំងពីរនាក់ស្វាមីភរិយា នាំគ្នាយកភាជន៍ដែលដាក់មាន់នោះ ទុកក្បែរមាត់ច្រាំងហើយចុះមុជទឹកទាំងពីរនាក់ទៅ ។ ពេលនោះមានខ្យល់ព្យុះបក់ទឹកឱ្យរលកឡើងលើមាត់ច្រាំង បន្សាត់យកភាជន៍ដាក់មាន់នោះទៅ ។ ពេលនោះមានហ្មដំរីម្នាក់ កំពុងលាងដំរីខាងក្រោមខ្សែទឹក បានឃើញភាជន៍អណ្ដែតនោះ ចាប់បើកមើលឃើញមាន់ស្ងោរនិងបាយក៏យកទៅឱ្យភរិយា ។ ឯបុរសពីនាក់ប្ដីប្រពន្ធដែលមុជទឹកនោះជាបុគ្គលឥតបុណ្យ គ្រាន់តែមានលាភចាប់បានមាន់យកមកបោចស្ងោរ

ប៉ុណ្ណោះ កាលបើភាជន៍ដាក់មាន់អណ្ដែកបាត់ហើយ ក៏ដល់នូវសេចក្ដីទុក្ខព្រួយជាខ្លាំង ហើយត្រឡប់ទៅផ្ទះទៅ ។ លំដាប់នោះមានតាបសម្នាក់ភ្នែកទិព្វ ជាជីតុនរបស់ហ្មដំរីនោះ បានគិតថាឧបដ្ឋាករបស់អញពេលណានឹងលះបង់ចោលឋានៈជាហ្មដំរី បានជាអ្នកមានទ្រព្យសម្បត្តិយសស័ក្តិនឹងគេ. លុះពិចារណាដឹងថានឹងបានសោយរាជ្យជាស្ដេច ក៏ម្នីម្នាទៅផ្ទះហ្មដំរីនោះ ។ ឯហ្មដំរីបានឃើញតាបសទៅដល់ផ្ទះខ្លួនហើយ ក៏លើកភាជន៍មាន់ស្ងោរនោះទៅប្រគេន. តាបសក៏ហែកសាច់មាន់នោះយកសាច់ចំឡកឱ្យហ្មដំរី សាច់ខាងក្រោឱ្យដល់ភរិយារបស់ហ្មដំរី ខ្លួនឯងក៏ឆាន់សាច់បន្ទាប់ឆ្អឹង. លុះឆាន់ហើយប្រាប់ដល់ហ្មដំរីថា អ្នកកុំប្រមាទនៅបីថ្ងៃទៀតអ្នកនឹងបានជាស្ដេច. ប្រាប់ហើយក៏ចៀសចេញទៅ ។ លុះដល់ថ្ងៃទីបី មានស្ដេចសាមន្តរាជមួយអង្គ មកលោមព័ទ្ធក្រុងពារាណសី កាលនោះព្រះរាជាទ្រង់បង្គាប់ឱ្យហ្មដំរីក្លែងភេទជាស្ដេច ហើយទ្រង់មានព្រះតម្រាស់ថា អ្នកចូរឡើងជិះដំរីទៅច្បាំង. ឯព្រះរាជាក៏ក្លែងភេទត្រួតត្រាសេនាដោយព្រះអង្គឯង ។ ក្នុងពេលនោះស្រាប់តែមានសរមួយដ៏ក្លៀវក្លាត្រូវព្រះរាជាសោយទិវង្គតទៅ ។ ហ្មដំរីដឹងថាព្រះរាជាសោយទិវង្គតហើយ ក៏ចាត់ចែងទ័ព ចូលទៅសម្លាប់ស្ដេចសាមន្តរាជក្នុងពេលនោះ ។ ពួករាជ្យអាមាត្យទាំងឡាយបានធ្វើសរីរកិច្ចព្រះរាជារបស់ខ្លួនស្រេចហើយ បានប្រឹក្សាគ្នាថា ព្រះរាជាកាលទ្រង់

ព្រះជន្មទៅ បានព្រះរាជទានភេទរបស់ទ្រង់ដល់ហ្មជីវិរនេះ ទើបនាំគ្នាអភិសេកហ្មជីវិឱ្យសោយរាជ្យក្នុងក្រុងពារាណសីនោះទៅ ។ ឯភរិយាបានជាអគ្គមហេសី, តាបសបានជាជីតុនរបស់ព្រះរាជានោះឯង ។

( មហាសំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៤៦- រឿងនាងវិសាខា

( ចាក ធ. ខុ. )

( ស្ត្រីល្អ កម្រមានក្នុងលោក )

កាលព្រះសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តបុព្វារាម នាងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវមហាឧបាសិកាឈ្មោះវិសាខា បានសំដែងធម្មទេសនាមានបទថា យថាបិ បុប្ផរាសិម្ហា ដូច្នេះជាដើម ។ សេចក្ដីថា នាងវិសាខា ជាធីតារបស់ធនញ្ជយសេដ្ឋី មាតាឈ្មោះសុមនាទេវី ជីតារបស់នាងឈ្មោះមេណ្ឌកៈ ជីដូនឈ្មោះចន្ទបទុមា ។ នាងវិសាខាជាស្ត្រីមានឧបនិស្ស័យខ្ពស់ បានសម្រេចសោតាបត្តិផលតាំងពីអាយុ ៧ ឆ្នាំ ជាមួយនឹងនាងទារិកា ៥០០ នាក់ជាបរិវាររបស់នាង, នាងជាស្ត្រីប្រកបដោយបញ្ចពិធកល្យាណី មានលំអ ៥ យ៉ាងគឺ :

**១- កេសកល្យាណ** លំអសក់

**២- មំសកល្យាណ** លំអសាច់

៣. អដ្ឋិកល្យាណ លំអឆ្អឹង

៤. ឆវិកល្យាណ លំអសម្បុរថ្ងៃ

៥. វយកល្យាណ លំអវ័យ

## អធិប្បាយ

១. កេសកល្យាណ លំអសក់, សក់នៃស្ត្រីមានលំអមានសរសៃល្អិត មានពណ៌ដូចស្លាបកំភេម កាលរំសាយចុះទៅមានចុងងឡើងលើ ដូចសណ្ឋានកន្ទុយក្ងោកពង់ មិនចេះស្កូវឡើយ សូម្បីមានអាយុមួយរយឆ្នាំហើយ ក៏នៅតែមានពណ៌រលង់រលើបល្អដូចកាលនៅពីក្មេង ។ យ៉ាងនេះហៅថាលំអសក់ ។

២. មំសកល្យាណ លំអសាច់, សំដៅយកសាច់បបូរមាត់, ស្ត្រីមានលំអសាច់បបូរមាត់ឡើងពណ៌ក្រហមរលោង ដូចផ្លែបាសទុំឬផ្លែទន្លាប់ទុំ ជាសាច់ស្អាតឥតមន្ទិលសៅហ្មង ទោះបីមានអាយុមួយរយឆ្នាំហើយ ក៏នៅតែក្រហមរលោងស្រស់ដូចដើម ។ យ៉ាងនេះហៅថាលំអសាច់ ។

៣. អដ្ឋិកល្យាណ លំអឆ្អឹង, សំដៅយកឆ្អឹងធ្មេញ ស្ត្រីប្រកបដោយលំអ មានធ្មេញជិតស្និទ្ធរាបស្មើ មិនចំពើស មានពណ៌សរលោងដូចជាត្បូងពេជ្រ ដែលជាងច្នៃយ៉ាងស្អាតហើយដាក់តំរៀបគ្នា ឬដូចជាស័ង្ខដែលបុគ្គលច្នៃយ៉ាងល្អ បើហានិយាយឡើងកាលណា មានពន្លឺទឹកដមព្រាត១ សូម្បីមានអាយុមួយរយឆ្នាំហើយ ក៏

ធ្មេញនៅតែជិតស្និទ្ធល្អដូចកាលអាយុ ១៦ ឆ្នាំ ។ យ៉ាងនេះ ហៅថា លំអឆ្អឹង ។

៤. ឆវិកល្យាណ លំអសម្បុរថ្ងៃ, បានដល់លំអពណ៌ស្បែក, ស្ត្រីប្រកបដោយលំអ មានពណ៌ពីរយ៉ាងគឺ ស១ ខ្មៅ១, ស មានពណ៌ដូចជាកណ្ណិការ រលីងរលោងស្អាតឥតមានអាចម៍រុយ ឬសម្លាកមន្ទិលសៅហ្មងឡើយ សូម្បីតែសម្លាកកមរមាស់មួយក៏គ្មាន, លំអខាងពណ៌ខ្មៅ មានពណ៌ខៀវស្រស់ដូចផ្កាឧប្បល ជាសម្បុរមានទឹកដមរលើបរលោង ។ យ៉ាងនេះហៅថាលំអសម្បុរថ្ងៃ ។

៥. វយកល្យាណ លំអវ័យ, ស្ត្រីបរិបូណ៌ដោយលំអ ទោះបីប្រសូត្របុត្រមួយរយដង ក៏នៅស្អាតល្អដូចជាវ័យក្មេងកាលដែលមានអាយុ ១៦ ឆ្នាំ ទោះបីមានអាយុមួយរយឆ្នាំហើយ ក៏នៅតែល្អស្រស់គ្រប់អវយវៈដូចជាស្ត្រីពេញក្រមុំ ។ យ៉ាងនេះហៅថា លំអវ័យ ។

ក្នុងកាលដែលនាងវិសាខាមានអាយុ ១៦ ឆ្នាំ, ថ្ងៃមួយជាថ្ងៃបុណ្យនក្ខត្តឫក្ស នាងបាននាំបរិវារទាំង ៥០០ ព្រមទាំងធីតារបស់សេដ្ឋីគហបតីទៅលេងទឹកក្នុងស្ទឹង ។ ពេលនោះមហាមេឃបង្អុរភ្លៀងចុះមក ពួកធីតាទាំងឡាយក៏នាំគ្នារត់ព្រោងព្រាតចូលទៅក្នុងសាលា ឯនាងវិសាខានាងដើរសន្សឹមៗ ហាក់ដូចជាមិនខ្លាចទទឹក។ គ្រានោះមានព្រាហ្មណ៍ ៨ នាក់ជាបំរើរបស់មិគារសេដ្ឋី ដែលប្រើ

ឱ្យដើររកស្ត្រីប្រកបដោយលំអ ៥ យ៉ាង ដើម្បីផ្សំផ្គុំជាភរិយាឱ្យបុណ្ណវឌ្ឍនកុមារជាកូន ។ ព្រាហ្មណ៍ទាំង៨ នាក់បានឃើញចរិយាសម្បត្តិរបស់នាងវិសាខាដូច្នោះហើយ នាំគ្នាសង្កេតពិនិត្យមើលបានដឹងជាក់ថា ជាស្ត្រីប្រកបដោយលំអ ៥ យ៉ាង ប៉ុន្តែមិនទាន់ឃើញធ្មេញរបស់នាង, លុះនាងវិសាខាឡើងដល់លើសាលា មានសរីរៈទទឹកជោកដោយទឹកភ្លៀង, ព្រាហ្មណ៍ក៏បានឱកាសនឹងឃើញធ្មេញរបស់នាង ទើបនាំគ្នានិយាយថា ស្ត្រីនេះប្រហែលជាកូនអ្នកក្រីក្រ បានជាខ្ជិលយ៉ាងនេះ ស៊ូដើរឱ្យភ្លៀងទទឹកអស់ ។ នាងវិសាខាឮដូច្នោះហើយ ក៏សួរព្រាហ្មណ៍ថា អ្នកនិយាយពីអ្នកណា ? ។ ព្រាហ្មណ៍ថា យើងនិយាយពីនាង ។ ក្នុងពេលនោះនាងវិសាខាបាននិយាយប្រាប់ដល់ព្រាហ្មណ៍ដោយសំឡេងពិរោះ ហាក់ដូចជាសំឡេងនៃរគាំងសំរិទ្ធថា បានជាខ្ញុំមិនរត់ស៊ូដើរឱ្យទទឹកគ្រឿងអលង្ការយ៉ាងនេះ ព្រោះពួកជនដែលគ្រប់លក្ខណ៍មាន ៤ ពួកគឺ បព្វជិត, ស្តេច, ស្ត្រី, ដំរី, ជនទាំង ៤ ពួកនេះ មិនគួររត់ឡើយព្រោះថា :

១. បព្វជិត ទោះបីមានហេតុយ៉ាងណា មានភ្លៀងនិងខ្យល់ព្យុះជាដើម មិនត្រូវរត់ឡើយ ត្រូវតែដើរសន្សឹមៗ តាមធម្មតាទើបហៅថា បព្វជិតមានលក្ខណ៍ ។

២. ស្តេចដែលបានអភិសេកហើយ កំពុងទ្រទ្រង់នូវគ្រឿងបញ្ចកុក្កុដភណ្ឌ ទោះបីមានហេតុយ៉ាងណា មានភ្លៀងនិងខ្យល់ព្យុះ

ជាដើម មិនគួររត់ដូចជាគហបតីឡើយ ត្រូវតែយាងសន្សឹមៗ ទើបហៅថាស្តេចមានលក្ខណ៍ ។

៣. ស្ត្រីដែលពេញក្រមុំ ទោះបីមានហេតុយ៉ាងណាមានភ្លៀងនិងខ្យល់ព្យុះជាដើម មិនត្រូវរត់ដូចជាបុរសឡើយ ត្រូវតែដើរសន្សឹមៗ ទើបហៅថាស្ត្រីមានលក្ខណ៍ ។

៤. ដំរីមង្គលដែលគេប្រដាប់តាក់តែងដោយគ្រឿងអលង្ការហើយ ទោះបីមានហេតុយ៉ាងណាមិនត្រូវរត់ឡើយ ត្រូវដើរដោយដំណើរធម្មតា ទើបហៅថាដំរីមានលក្ខណ៍ ។

ព្រាហ្មណ៍ទាំង ៨ នាក់ស្តាប់ហើយ បានឱ្យពរសព្វសាធុការដល់នាងវិសាខា, ការចង់ឃើញនូវធ្មេញរបស់នាងក៏បានឃើញដូចបំណង ។ ព្រាហ្មណ៍ទាំង ៨ នាក់និយាយប្រាប់ដល់នាងវិសាខាថា យើងទាំងអស់គ្នា មានសេចក្តីប្រាថ្នាចំពោះនាង ហើយលើកភួងផ្កាមាសដែលមានតម្លៃ ១ សែនជូនជាគ្រឿងបញ្ចាំចិត្តដល់នាង ១ ក៏ព្រមទទួលយកមកពាក់នូវក ដើម្បីបញ្ជាក់ឱ្យព្រាហ្មណ៍ដឹងថា នាងព្រមទទួល, ទើបនាងសួរទៅព្រាហ្មណ៍ថា អ្នកមកអំពីនគរណា ?។ ព្រាហ្មណ៍ថា ខ្ញុំមកពីនគរសាវត្ថី ត្បិតមិគារសេដ្ឋីមានកូនប្រុស ១ ឈ្មោះបុណ្ណវឌ្ឍនកុមារ បានបញ្ជូនខ្ញុំមកដណ្តឹងនាង ។ នាងវិសាខាព្រមទទួល ទើបនាំព្រាហ្មណ៍ទាំង ៨ នាក់ទៅប្រាប់ដល់ធនញ្ជយសេដ្ឋីជាបិតា ។ ធនញ្ជយសេដ្ឋី ក៏ព្រមឱ្យ បានសួរអំពីសម្បត្តិរបស់

មិគារសេដ្ឋី, ព្រាហ្មណ៍ប្រាប់ថាមិគារសេដ្ឋីមានប្រាក់ ៤០ កោដិ ។ ធនញ្ជយសេដ្ឋីលាន់មាត់ថាប្រាក់៤០ កោដិនោះតិចពេកណាស់ មិនបានប្រហែលនឹងតម្លៃថែរក្សា មានតម្លៃម្សៅនិងប្រេងជាដើមរបស់កូនខ្ញុំទេ ។ តមកធនញ្ជយសេដ្ឋីនិងមិគារសេដ្ឋី ក៏ចាត់ចែងរៀបមង្គលការបុត្រធីតា បានអញ្ជើញស្តេចពីរនគរព្រមទាំងគហបតីសេដ្ឋី មន្ត្រីតូចធំប្រជារាស្ត្រទាំងអស់ មកជាកិត្តិយសក្នុងមង្គលការក្នុងថ្ងៃទី ១ ជាដំបូង ធនញ្ជយសេដ្ឋីបានហៅជាងមាស ៥០០ នាក់មកធ្វើគ្រឿងមហាលតាបសាធន៍អាវសម្រាប់ពាក់ការ ។ អាវនោះមានតម្លៃ៩ កោដិ ថ្លៃឈ្នួលជាង១ សែនរៀល, អាវនោះធ្វើអំពីមាសនិងពេជ្រសុទ្ធគឺ : ត្បូងពេជ្រចំនួន ៤ នាឡិ កែវមុក្តា ១១ នាឡិ កែវបវាឡ២២ នាឡិ កែវមណី៣៣ នាឡិ ព្រមទាំងមាសនិងប្រាក់ជាច្រើនយកទៅហូតធ្វើជាអំបោះ ។ អាវនោះរាងជាសត្វក្ងោក ស្លាបម្ខាង១ចំនួន៥០០ ស្លាប រចនាអំពីមាសនិងប្រាក់ ចំពុះរចនាដោយកែវបវាឡ, ភ្នែករចនាដោយកែវមណី, កន្ទុយមានស្លាប ៥០០ រចនាដោយមាសនិងប្រាក់ ។ អាវនោះលើកពាក់ឡើងកាលណា ឃើញហាក់ដូចជាក្ងោកមាសពង់រាំឮដ៏កំពូលភ្នំ, ឮសូរសំឡេងលាន់ចេញអំពីស្លាបដូចជាដូរ្យដន្ត្រីទិព្វ ។ សេដ្ឋីរៀបមង្គលការបានចំនួន ៣ ខែ ពួកអ្នកចំអិនអាហារប្រាប់ថា អស់ឧសដុតហើយ ។ សេដ្ឋីប្រាប់ឱ្យទៅរុះផ្ទះចាស់ៗ និងរោងដំរីយកមកដុត, ដល់ដុតបាន

កន្លះខែ ក៏អស់ឧសនោះទៅទៀត ទើបសេដ្ឋីបង្គាប់ឱ្យចាក់ឃ្លាំងយកសំពត់សាច់ក្រាស់ ៗ ជ្រលក់ប្រេងដុតចំអិនអាហារតទៅទៀត ដុតបានកន្លះខែទៀតជាគំរប់៤ខែ ។ ជាងទាំង៥០០ នាក់ ដែលធ្វើគ្រឿងមហាលតាបសាធន៍ តាំងពីថ្ងៃចូលរោងមកក៏គ្រប់ ៤ ខែគត់ ទើបហើយអាវមហាតាបសាធន៍នោះ ។ ធនញ្ជយសេដ្ឋី និង មិគារសេដ្ឋីបានផ្សំផ្គុំនាងវិសាខានិងបុណ្ណវឌ្ឍនកុមារ ឱ្យជាគូរស្វាមីភរិយាក្នុងថ្ងៃជាគំរប់៤ ខែនោះ។ លុះរៀបអាពាហ៍ពិពាហ៍ហើយធនញ្ជយសេដ្ឋី បញ្ជូននាងឱ្យទៅនៅខាងសំណាក់ម្ដាយក្មេកឪពុកក្មេក បានចែកទ្រព្យសម្បត្តិឱ្យជាច្រើនគឺ ឱ្យភាជនៈមាស៥០០ រទេះ, ភាជនៈប្រាក់៥០០ រទេះ, ភាជនៈទង់ដែង៥០០ រទេះ ភាជនៈសំរិទ្ធ ៥០០ រទេះ, សំពត់អំបោះនិងសំពត់សូត្រ ៥០០ រទេះ, សប្បិ ៥០០ រទេះ, ប្រេង៥០០រទេះ, ស្ករអំពៅ៥០០ រទេះ អង្ករស្រូវសាលី៥០០ រទេះ, គ្រឿងឧបករណ៍ផ្សេងៗ មាននង្គ័ល និងផាលជាដើម ៥០០ រទេះ, និងខ្ញុំប្រុសខ្ញុំស្រីជាច្រើន ។ ក្នុងថ្ងៃដែលនាងចេញទៅ បានបង្គាប់ឱ្យបុរសបើកទ្វារក្រោលគោ ហើយឱ្យដេញគោចេញទៅវាល់បណ្ដោយបីល្បើស្ករទទឹង៣ឧសភ បុរសក៏ធ្វើតាមបង្គាប់របស់សេដ្ឋី, លុះគ្រប់ចំនួនហើយ បុរសបិទទ្វារក្រោលគោក៏ស្ទុះទម្លាយ ក្រោលទៅតាមនាងទៀត ដោយផលបុណ្យដែលនាងបានធ្វើទានដោយចិត្តទូលាយពីជាតិមុនមក ។ ថ្ងៃមួយនាងវិសាខាទៅស្ដាប់ធម៌នៅវត្ត

ជេតពន បាននាំកូននិងចៅជាច្រើនពាន់ទៅជាមួយផង. កាលនោះមានភិក្ខុមួយរូបចង់ឃើញនាងវិសាខា បានសួរភិក្ខុមួយរូបដែលអង្គុយជិតភិក្ខុនោះប្រាប់ថា មើតែស្ត្រីណាក្រោកឡើងយកដៃច្រត់ក្បាលជង្គង់ ស្ត្រីនោះហើយគឺនាងវិសាខា។ កាលនោះនាងវិសាខាមានអាយុជាង៧០ ឆ្នាំហើយ នាងនៅតែក្មេងដូចជាចៅរបស់នាងដែលមានអាយុ១៦ឆ្នាំ ។ នាងវិសាខាមានកូន២០ ក្នុងកូនមួយៗមានចៅ២០ ក្នុងចៅមួយៗ មានកូន ២០ រួមទាំងកូនទាំងចៅទាំងចៅទួតចំនួន៨៤២០ នាក់ឥតមានឈឺស្លាប់មួយឡើយ។ នាងវិសាខាមានកម្លាំងស្មើកម្លាំងដំរី៥. ថ្ងៃមួយនាងត្រឡប់មកពីស្តាប់ធម៌. ព្រះរាជាចង់ល្បងកម្លាំងរបស់នាងបានលែងដំរីចុះប្រេង១. ឱ្យទៅព្រេចនាង ។ បានយកម្រាមដៃពីរទប់ដំរី។ ក៏ដួលក្រាបលើផែនដីមិនអាចក្រោកបានឡើយ ។ ថ្ងៃមួយនាងវិសាខាទៅស្តាប់ធម៌ ដោះគ្រឿងមហាលតាបសាធន៍ទុកខាងក្រៅវិហារ ដល់ស្តាប់ហើយភ្លេចចោលនៅទីនោះ ទើបប្រើនាងទាសីដែលមានកម្លាំងស្មើនឹងនាងឱ្យទៅយកអាវបានប្រាប់ថា បើភិក្ខុអង្គណាមួយលោករើសទុកនាងប្រគេនលោកចុះកុំយកមកវិញ ។ ពេលនោះព្រះអានន្ទបានរើសទុក, ព្រោះលោកមានកម្លាំងលើកអាវនោះរួច ។ តម្លៃអាវនេះហើយដែលកសាងបានវត្តបុព្វារាមមួយ ។ នាងវិសាខាមានអាយុ ១២០ ឆ្នាំ, នាងធ្វើមរណកាលទៅបានទៅកើតក្នុងស្ថាន និម្មានរតី ជាអគ្គមហេ-

សិរបស់ព្រះបាទនិម្មាតទេវបុត្រ[១] ។

## ៤៧. រឿងនាងបទុមវតី

( ចាក អ. វ. )

( សេចក្តីប្រាថ្នារបស់ស្ត្រីមានសទ្ធា មិនសាបសូន្យ )

ក្នុងអតីតកាល មានស្ត្រីម្នាក់ដើរទៅធ្វើការងស្រែពីព្រលឹម បានឃើញផ្កាឈូកដែលរីកស្គុះស្គាយក្នុងស្រះមួយក្បែរផ្លូវ ក៏ចុះទៅបេះផ្កាឈូក ហើយកាច់នូវស្លឹកឈូកខ្ចប់ផ្កានោះ លុះទៅដល់ខ្ទមបានរាប់លាជចំនួន ៥០០ គ្រាប់ ខ្ចប់នឹងស្លឹកឈូក ។ ខណៈនោះ មានព្រះបច្ចេកពុទ្ធមួយអង្គ និមន្តពីភ្នំគន្ធមាទន៍ មកឈរត្រង់ទីចំពោះមុខរបស់នាង ។ ឃើញព្រះបច្ចេកពុទ្ធនោះហើយ ក៏កាន់លាជនិងផ្កាឈូកចុះទៅដាក់បាត្រ បានយកផ្កាឈូកដាក់ពីលើគ្របបាត្ររបស់លោក, លុះលោកនិមន្តផុតបន្តិចទៅ នាងទៅតាមពីក្រោយនិយាយសុំទោសថា លោកម្ចាស់ជាបព្វជិតខ្ញុំព្រះករុណាមិនគួរប្រគេនផ្កាឡើយ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំព្រះករុណា ទើបតាំងសេចក្តីប្រាថ្នាថា ក្នុងអនាគតកាលខ្ញុំសូមឱ្យមានកូន ៥០០ នាក់ប្រហែលនឹងគ្រាប់លាជដែលប្រគេនលោកម្ចាស់, ម្យ៉ាងទៀត

---

១. មានក្នុងគម្ពីរវិមានវត្ថុ

សូមឱ្យផ្កាឈូកផុះឡើងរាល់ៗ ជំហានក្នុងទីដែលខ្ញុំកើតហើយៗ ។ ដោយអានិសង្សនៃការប្រគេនផ្កាឈូកដល់ព្រះបច្ចេកពុទ្ធនោះ នាងបានទៅកើតក្នុងទេវលោក មានផ្កាឈូកផុះឡើងរាល់ៗ ជំហានក្នុងវេលាដែលនាងដើរ. លុះច្យុតពីទេវលោក បានមកកើតជាឧបបាតិកកំណើត ក្នុងត្របកឈូក នាស្រះមួយក្បែរជើងភ្នំ ។ កាលនោះមានតាបសមួយរូបទៅខ្ពុរមាត់លុបមុខក្នុងស្រះនោះពីព្រលឹមស្រាង ៗ បានឃើញផ្កាឈូកមួយនៅក្រពុំធំជាងគេក្នុងស្រះនោះ លោកពិចារណាថា ឱផ្កាឈូកនេះនៅក្រពុំទេ ម្ដេចក៏ធំជាងផ្កាដែលរីកស្គុះស្គាយ ច្បាស់ជាមានអ្វីនៅក្នុងផ្កាឈូកនោះពុំខាន ក៏ចុះទៅកាច់យកផ្កាឈូកនោះមក ។ ឯផ្កាឈូកនោះក៏រីកឡើងភ្លាម ក្នុងពេលដែលតាបសទៅពាល់ត្រូវ ។ តាបសបានឃើញនាងទារិកាដេកនៅក្នុងត្របកឈូកនោះហើយ មានសេចក្ដីត្រេកអរណាស់បានកាច់យកទាំងផ្កាទៅទុកក្នុងអាស្រម ។ លំដាប់នោះទឹកដោះតាបស ក៏កើតឡើងដោយអំណាចបុណ្យរបស់នាង ។ តាបសនោះ កាលបើផ្កាឈូកស្រពោនហើយ ទៅកាច់ផ្កាថ្មីមកដាក់ឱ្យដេកទៀត ដរាបដល់នាងទារិកានោះធំចេះដើរចេះរត់ នាងដើរទៅក្នុងទីណាមានផ្កាឈូកដុះទ្ររាល់ៗ ជំហាន ។ តាបសក៏កំណត់ទាមនាងទារិកានោះថាបទុមវតី ។ ថ្ងៃមួយមានព្រានព្រៃម្នាក់ បានឃើញនាងមានសម្បុរដូចជាទេវតា ល្អប្លែកអស្ចារ្យជាងមនុស្សសាមញ្ញ ក៏ក្រាបទូល

ដល់ព្រះបាទពារាណសី, ព្រះរាជាក៏ទៅថ្វាយបង្គំសុំតាបស យកនាងបទុមវតីមកអភិសេកលើគំនរកែវ ដំកល់នាងជាអគ្គមហេសីធំបំផុត ។ ថ្ងៃក្រោយមក នាងមានគភ៌ដល់គ្រប់ខែក៏ប្រសូត្រព្រះរាជបុត្រមួយអង្គមក ឱ្យនាមថាបទុមរាជកុមារ ។ ក្នុងពេលដែលប្រសូត្រនោះ មានទារក ៤៩៩ រូបកើតជាសំសេទជ: កើតតាមរន្ធញើសរបស់នាងដែលបែកញើសក្នុងវេលាប្រសូត្រ. រួមកូនរបស់នាងទាំងអស់ ៥០០ នាក់ កើតក្នុងថ្ងៃជាមួយគ្នា ។ ដល់ទារកនោះមានអាយុ ១៥ ឆ្នាំ បានទាំគ្នាទៅលេងទឹកក្នុងស្រះបោក្ខរណីដែលមានផ្កាឈូករីកព្រោងព្រាត ។ កុមារទាំង ៥០០ បានពិចារណានូវរូបកាយប្រៀបធៀបទៅនឹងផ្កាឈូក ដែលរុះរាយត្របកកេសរ ក៏បានត្រាស់ជាព្រះបច្ចេកពុទ្ធទាំងអស់គ្នា ។ ឯនាងបទុមវតី ដល់មកក្នុងពុទ្ធកាលនេះបានមកកើតជានាងឧប្បលវណ្ណាថេរី ។

( មហា សំ. សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៤៨- រឿងឧបសាឡ្ហកព្រាហ្មណ៍

( ចាក ខុ. ធុ. )

( សត្វលោក មានការកើតស្លាប់ញឹកញាប់រាប់មិនអស់ )

ក្នុងកាលកន្លងទៅហើយ មានព្រាហ្មណ៍ម្នាក់ឈ្មោះឧបសាឡ្ហក នៅក្នុងនគររាជគ្រឹះ ជាអ្នកប្រកាន់ខ្លួន ។ ថ្ងៃមួយគាត់បាន

ប្រាប់ដល់កូនប្រុសរបស់គាត់ថា បើអញស្លាប់ទៅកូនឯងចូរចាត់ចែងបូជាសពអញ ត្រង់កន្លែងណាដែលមនុស្សទាំងឡាយមិនដែលបូជា មិនធ្លាប់ចោលសាកសព មិនធ្លាប់កប់សាកសពរបស់មនុស្សដទៃៗ ។ កូនឮដូច្នោះហើយបាននិយាយប្រាប់បិតាថា ខ្ញុំមិនអាចដឹងទីកន្លែងដែលបរិសុទ្ធស្អាត មិនដែលមានបុគ្គលណា យកសាកសពទៅបូជាទៅកប់ទៅចោលទេ ហេតុនេះសូមបិតាចង្អុលប្រាប់ទីដែលបរិសុទ្ធនោះដល់កូន ។ ឧបសាឡ្ហកព្រាហ្មណ៍បានចង្អុលទីលើកំពូលភ្នំគិជ្ឈកូដត្រង់ចន្លោះភ្នំ ៣ ហើយបាននាំកូនឡើងទៅលើកំពូលភ្នំចង្អុលប្រាប់ទីនោះដោយសព្វគ្រប់ ទើបនាំគ្នាចុះមកវិញ ដល់មកជើងភ្នំបានជួបនឹងឥសីមួយរូប ជាអ្នកបានសម្រេចអភិញ្ញា និងសមាបត្តិ ។ ឥសីឃើញជនទាំងពីរនាក់នោះហើយ ក៏សួរថា ម្នាលព្រាហ្មណ៍អ្នកនាំគ្នាមកពីទីណា ? ។ ព្រាហ្មណ៍ជាកូនប្រាប់ឥសីថា ខ្ញុំមកពីមើលទីដែលបរិសុទ្ធ មិនដែលបុគ្គលណាយកសាកសពទៅកប់ទៅបូជាទៅចោលក្នុងទីនោះ ព្រោះបិតាខ្ញុំប្រាប់ថា ដល់គាត់ធ្វើមរណកាលទៅ ឱ្យខ្ញុំយកទៅបូជាក្នុងទីដែលបរិសុទ្ធ មិនដែលបុគ្គលណា គេយកសាកសពទៅបូជាទៅកប់ទៅចោលក្នុងទីនោះ ។ ឥសីលោករឭកជាតិបាន ក៏បបួលព្រាហ្មណ៍ទាំងពីរនាក់ ត្រឡប់ទៅលើកំពូលភ្នំនោះម្ដងទៀត ទៅដល់ហើយឱ្យព្រាហ្មណ៍ជាកូនចង្អុលបង្ហាញទីនោះ ។ ឥសីឃើញហើយ ក៏រឭកជាតិរបស់ព្រាហ្មណ៍ដឹង

ដោយសព្វគ្រប់ ទើបនិយាយថា ម្នាលព្រាហ្មណ៍បិតារបស់អ្នកធ្លាប់កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងរាជគ្រឹះនេះ មានឈ្មោះថាឧបសាឡ្ហកដូចកាលឥឡូវនេះជាច្រើនជាតិមកហើយ លុះស្លាប់ទៅ បាននាំសពមកបូជាក្នុងទីនេះចំនួន ១ ហ្មឺន ៤ ពាន់ជាតិហើយ. ទើបលោកសំដែងគាថាប្រាប់ដល់ព្រាហ្មណ៍នោះថា :

**ឧបសាឡ្ហកនាមានំ សហស្សានិ ចតុទ្ទស**
**អស្មឹបទេសេ ទឌ្ឍានិ នត្ថិលោកេ អនាមតំ ។**
**យម្ហិ សច្ចញ្ច ធម្មោច អហឹសា សញ្ញមោ ទមោ**
**ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ ។**

ព្រាហ្មណ៍ឈ្មោះឱបសាឡ្ហកៈ ត្រូវគេបូជាក្នុងទីនេះ ១៤ ពាន់ជាតិហើយ ទីស្ថានដែលសត្វមិនស្លាប់ត១ គ្មាឥតមានក្នុងលោកទេ ។ សច្ចៈ ធម្មៈអហឹសាសញ្ញមៈ និងទមៈទាំង ៥ នេះមានក្នុងទីណា ព្រះអរិយទាំងឡាយតែងសេពនូវទីនោះ, ទីនោះឯងឈ្មោះថាអនាមតៈ ឥតមានសត្វស្លាប់ត១ គ្នាឡើយ ។ ព្រាហ្មណ៍ទាំងពីរនាក់ពូជូច្នោះហើយលែងខ្វល់ខ្វាយក្នុងទីបូជាសព ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ។

# ៤៩. រឿងព្រះបាទមឃទេវរាជ

( ចាក នេ. ម. )

( គុណនៃសេចក្ដីមិនប្រមាទ ចំពោះរូបកាយ )

កាលព្រះសម្ពុទ្ធបរមគ្រូ ស្ដេចយាងទៅសម្រាកព្រះកាយក្នុងឱទ្យានឈ្មោះអម្ពវន នាក្រុងមិថិលា ជាមួយនឹងពួកភិក្ខុសង្ឃជាច្រើនអង្គ ។ ពេលនោះព្រះសាស្ដាទតមើលអម្ពវននោះហើយទ្រង់ញញឹម, ទើបព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះមានហេតុដូចម្ដេច បានជាទ្រង់ញញឹម? ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ ឱទ្យានឈ្មោះអម្ពវននេះ កាលពីដើម តថាគតធ្លាប់មកក្រសាលលេងសប្បាយមកចំរើនឈានក្នុងទីនេះដែរ ។ ព្រះអានន្ទទូលសូមព្រះសម្ពុទ្ធឱ្យសំដែងនូវហេតុនោះពិស្ដារតទៅទៀត ។ ព្រះសម្ពុទ្ធទ្រង់ប្រទាននូវធម្មទេសនាដល់ភិក្ខុសង្ឃទាំងឡាយ នាឱទ្យានឈ្មោះអម្ពវននោះថា ម្នាលភិក្ខុទាំងឡាយ កាលកន្លងទៅយូរយារណាស់ហើយ តថាគតបានកើតជាមហាក្សត្រមួយព្រះអង្គព្រះនាមមឃទេវរាជ សោយរាជសម្បត្តិក្នុងនគរមិថិលានេះ តថាគតបានបំពេញនូវសុចរិតធម៌ពេញបរិបូណ៌ដល់កំរិតធម៌ ។ ព្រះបាទមឃទេវរាជនោះ មានព្រះជន្ម ១ ហ្មឺន ៨ពាន់ឆ្នាំ តែងនាំបរិវារមកក្រសាលលេងក្នុងឱទ្យាននេះ, ជាអ្នកមិនមានសេចក្ដីប្រមាទចំពោះរូបកាយ បានប្រាប់ដល់ខ្មាន់ព្រះកេសឱ្យចាំគយគន់មើលព្រះកេសា

បើឃើញមានស្កូវតែមួយសរសៃ ឱ្យចាប់ថ្វាយដំណឹង ។ កាលជាខាងក្រោយមក ខ្នាន់ព្រះកេសបានឃើញព្រះកេសាស្កូវមួយសរសៃហើយ ក៏យកសណ្ដាសមាសដកថ្វាយ ។ ព្រះបាទមឃទេវរាជ បានទតឃើញហើយ ក៏កើតសង្វេគចំពោះរូបកាយរបស់ព្រះអង្គ បានប្រគល់ស្រុកសួយមួយដល់ខ្នាន់ព្រះកេស នោះហើយហៅព្រះរាជបុត្រច្បងមកប្រគល់រាជសម្បត្តិឱ្យ ក៏ចេញទៅបព្វជ្ជាជាឥសីខំចំរើនឈានទៅក្នុងអម្ពវនឧទ្យាននេះ ដរាបដល់អស់ព្រះជន្ម បានទៅកើតក្នុងព្រហ្មលោក ។ ព្រះរាជបុត្រព្រះរាជនត្តាក្រោយៗមក ក៏ខំប្រតិបត្តិតាមតែយ៉ាងនេះ ដរាបដល់អស់ ៨ ហ្មឺន ៤ពាន់ដំណវង្សសុទ្ធតែបានទៅកើតក្នុងព្រហ្មលោកទាំងអស់ ។ ក្នុងកាលជាខាងក្រោយមកក្សត្រជាទីបំផុតវង្ស មិនបានប្រាប់ឱ្យខ្នាន់ព្រះកេសគយគន់មើលព្រះកេសាស្កូវ ជាអ្នកប្រមាទមិនប្រតិបត្តិតាមដំណែលវត្តរបស់ក្សត្រមុន ៗ ។ ពេលនោះព្រះបាទមឃទេវរាជ ដែលទៅកើតក្នុងព្រហ្មលោកមុនក្សត្រទាំងអស់ បានជ្រាបដំណឹងនោះហើយ ក៏ច្យុតមកចាប់បដិសន្ធិក្នុងផ្ទៃ នៃព្រះអគ្គមហេសីរបស់ក្សត្របង្អស់នោះ ដើម្បីរក្សាព្រះញាតិវង្សកុំឱ្យសាបសូន្យចាកសុចរិតធម៌ ។ លុះប្រសូត្រមក ព្រះរាជបិតាទតឃើញរូបកាយមានពណ៌រស្មីស្រស់បស់ល្អ ក៏អញ្ជើញព្រាហ្មណ៍ព្រឹទ្ធាចារ្យអ្នកចេះដឹងជំនាញក្នុងលក្ខណ-សាស្ត្រ ឱ្យមកទាយលក្ខណៈព្រះរាជបុត្រថ្វាយ. ទ្រង់បានជ្រាបថា

ព្រះរាជបុត្រថ្វាយ, ទ្រង់បានជ្រាបថា ព្រះរាជបុត្រនោះជាញាតិសន្តានដើមព្រះរាជវង្ស បានមកកើតក្នុងវង្សដដែលវិញ ក៏សន្មតិព្រះនាមថា "នេមិរាជកុមារ" ព្រោះមានព្រះជាតិវិលមកជួបព្រះរាជវង្សដដែលវិញដូចជាកង់រទេះ ។ នេមិរាជកុមារកាលបើដឹងក្តីច្បាស់ហើយ តែងរឭកទូន្មានដល់ព្រះរាជវង្សពួកសេវកាមាត្យ និងពលរដ្ឋទាំងអស់ ឱ្យយល់ជាក់ច្បាស់នូវគុណនៃសុចរិតធម៌ ។ ចំណែកព្រះរាជបិតាកាលបើមានព្រះកេសាស្កូវមួយសរសៃហើយ ក៏ប្រគល់រាជសម្បត្តិដល់នេមិរាជកុមារ ជាព្រះរាជបុត្រ ហើយចេញទៅបួសជាឥសី ខំចំរើនឈានទៅក្នុងឧទ្យានឈ្មោះអម្ពវន, ដល់អស់ព្រះជន្មក៏បានទៅកើតក្នុងព្រហ្មលោក ។ ឯព្រះបាទនេមិរាជ ជាធម្មិកមហារាជាធិរាជ តែងតែរឭកដាស់តឿនពួកសេកាមាត្យ នឹងពលរដ្ឋរបស់ព្រះអង្គ ឱ្យខំបំពេញសុចរិតធម៌ពួកជនទាំងឡាយ មានសេវកាមាត្យជាដើមនោះ ក៏ខំប្រតិបត្តិតាមព្រះរាជឱវាទ លុះស្លាប់ទៅ បានទៅកើតក្នុងទេវលោកឥតសល់ម្នាក់ ។ ថ្ងៃមួយព្រះបាទនេមិរាជ ទ្រង់រក្សាឧបោសថសីល ហើយមានបរិវិតក្កថា បុណ្យដែលអញបានធ្វើហើយ ច្រើនមុខណាស់ តើបុណ្យណាប្រសើរជាងគេ គិតទៅគិតមកដាច់ស្រេចក្នុងព្រះទ័យ ។ ក្នុងពេលនោះក្តៅក្រហាយដល់អាសន៍របស់ព្រះឥន្ទ្រាធិរាជ ១ ក៏ហោះចុះមកជួយវិនិច្ឆ័យថា កុសលកម្មទាំងអស់ មានតែបព្វជ្ជាមួយទេ ដែលមានផលធំបរិសុទ្ធ

ប្រសើរជាងកុសលកម្មទាំងពួង, គ្រាន់តែជួយវិនិច្ឆ័យប៉ុណ្ណោះ ក៏បាត់អំពីទីនោះទៅ ។ ឯពួកទេវតាក្នុងស្ថានតាវតឹង្សបានឃើញព្រះឥន្ទ្រាធិរាជត្រឡប់ទៅវិញ ក៏សួរថាបពិត្រមហារាជ ស្ដេចយាងទៅទីណាអម្បាញ់មិញនេះ ? ។ ព្រះឥន្ទ្រប្រាប់ថា ទៅជួយវិនិច្ឆ័យសេចក្ដីសង្ស័យរបស់ព្រះបាទនេមិរាជ នៅស្ថានមនុស្សលោក ។ ពួកទេវតាបានឮថានេមិរាជដូច្នេះ ក៏មានចិត្តនឹករឭកចង់ឃើញគ្រប់ ៗ គ្នា ព្រោះដឹងថាខ្លួនដែលបានមកកើតជាទេវតា ដោយសារព្រះបាទនេមិរាជ, ទើបនិយាយអង្វរព្រះឥន្ទសុំឱ្យអញ្ជើញព្រះបាទនេមិរាជទៅស្ថានសួគ៌ ដើម្បីបានស្ដាប់ធម៌ ។ ព្រះឥន្ទក៏ប្រើមាតលិទេបុត្រឱ្យទឹមវេជយន្តរថ ទៅអញ្ជើញព្រះបាទនេមិរាជ ។ មាតលិទេវបុត្រ ក៏យកសេះអាជានេយ្យទឹមវេជយន្តរថបរទៅស្ថានមនុស្ស, ទៅដល់មនុស្សក្នុងនគរមិថិលាទាំងមូលផ្អើលជ្រួលជ្រើមគ្រប់ ៗ គ្នា ព្រោះឃើញពន្លឺរស្មីរបស់វេជយន្តរថ បញ្ចេញពន្លឺអស់ទិសទាំងពួង ហាក់ដូចជាពន្លឺព្រះអាទិត្យ។ មាតលិទេវបុត្រ បររថទៅឈប់មុខប្រាសាទហើយឡើងទៅអញ្ជើញព្រះបាទនេមិរាជ តាមពាក្យដែលព្រះឥន្ទបង្គាប់ ។ ព្រះបាទនេមិរាជ កាលបើបានទទួលការអញ្ជើញរបស់ព្រះឥន្ទហើយ ក៏ប្រជុំពួកព្រះរាជវង្សានុវង្ស ពួកសេវកាមាត្យមកផ្ដាំឱ្យខំធ្វើទានរក្សាសីល និងរក្សាសន្តិសុខក្នុងព្រះនគរហើយ ទើបឡើងគង់លើវេជយន្តរថ ។ មាតលិទេបុត្រ ក៏បរចេញពីក្រុងមិថិលា

ទៅ ៗ ដល់ពាក់កណ្ដាលផ្លូវ បានទូលព្រះបាទនេមិរាជថា ស្ដេចយាងទៅស្ថានសួគ៌តែម្ដង ឬចង់យាងទៅមើលស្ថាននរកផង ។ ព្រះបាទនេមិរាជ មានព្រះរាជឱង្ការថា បើអ្នកអាចទៅក្នុងយមលោកបាន ប្រសើរពេកណាស់ ដើម្បីបានឃើញទីកន្លែងរបស់បុគ្គលអ្នកធ្វើអំពើទុច្ចរិត ។ មាតលិទេវបុត្រ ក៏ទាញញាក់ខ្សែរថ បរទៅយមលោកដោយអំណាចឫទ្ធិរបស់ខ្លួន ទៅដល់ហើយ ក៏អធិប្បាយថ្វាយដំណឹងអំពីហេតុផល និងភូមិភាគរបស់សត្វនរកទាំងនោះ តាំងពីនរកតូចៗ ដរាបដល់អវិចិ ទើបហួសទៅស្ថានត្រៃត្រឹង្ស ទៅដល់អាណាខេត្តរបស់ទេវតាហើយ ក៏ថ្វាយដំណឹងអំពីហេតុផលរបស់ទេវតាទាំងនោះ ដល់ព្រះបាទនេមិរាជទៀត ទើបទៅឈប់នៅមុខទេវសភា នាស្ថានត្រៃត្រឹង្ស ។ ព្រះឥន្ទ្រព្រមទាំងទេវតាទាំងឡាយ ក៏ចោមរោមគួរសមនឹងព្រះបាទនេមិរាជ បានអញ្ជើញឱ្យសំដែងធម៌ក្នុងទេវសភានោះ លុះចប់ហើយ មាតលិទេវបុត្រ ក៏ជូនមកស្ថានមនុស្សលោកវិញ ។

## ៥០. រឿងសោតាបន្នឧបាសក

( ចាក សី. ទុ. )

( គុណនៃការអនុមោទនាបុណ្យ )

ក្នុងកាលនៃព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សប មានឧបាសកម្នាក់ ជាអ្នកដល់នូវសោតា បានឡើងជិះសំពៅជាមួយនឹងជាងកាត់សក់ម្នាក់ឆ្លងមហាសមុទ្រទៅប្រកបកិច្ចការផ្សេងៗ. ឆ្លងទៅបាន ៧ ថ្ងៃ សំពៅក៏ធ្លាយលិចកណ្ដាលមហាសមុទ្រ ។ ជនទាំងពីរនាក់នោះនាំគ្នាតោងផែនក្ដារមួយសន្ទឹក ហែលឡើងលើកោះតូចមួយ ក្នុងកោះនោះមានសត្វបក្សីជាច្រើន ជាងកាត់សក់ ក៏សម្លាប់បក្សីនោះចំអិនបរិភោគ លុះចំអិនហើយ បានចែកឱ្យសោតាបន្នឧបាសក ៗ មិនព្រមទទួលយកសាច់នោះបរិភោគឡើយ បាននិយាយប្រាប់ជាងកាត់សក់ថា ទីពឹងដទៃរបស់ខ្ញុំមិនមានទេ មានតែព្រះរតនត្រ័យទាំង ៣ ជាទីពឹងរបស់ខ្ញុំ និយាយដូច្នេះហើយក៏នឹករឭកដល់គុណព្រះរតនត្រ័យ ។ ក្នុងកោះនោះមាននាគរាជមួយ បានដឹងថាឧបាសកមានគុណខ្ពង់ខ្ពស់ដូច្នោះហើយ ក៏និម្មិតខ្លួនជាសំពៅមួយយ៉ាងធំ ពេញព្រៀបដោយកែវទាំង ៧ ប្រការ. ឯទេវតាអ្នករក្សាសមុទ្រជាអ្នកកាន់ចង្កូតសំពៅនោះបានស្រែកឃោសនាថា អ្នកណាចង់ទៅជម្ពូ-ទ្វីបឡើងជិះសំពៅនេះមក ។ ឧបាសកនិយាយថា យើងទៅជម្ពូទ្វីប ទេវតាអ្នករក្សាសមុទ្រក៏អែបសំពៅឱ្យឧបាសកនោះឡើង លុះឡើង

ហើយឧបាសកបានហៅជាងកាត់សក់ឱ្យជិះជាមួយ ។ ទេវតារក្សាសមុទ្រស្រែកឃាត់មិនឱ្យជិះ ។ ឧបាសកឮដូច្នោះហើយ ក៏និយាយនឹងជាងកាត់សក់ថា ទានដែលខ្ញុំបានឱ្យហើយ សីលដែលខ្ញុំបានរក្សាហើយ ភាវនាដែលខ្ញុំបានចំរើនហើយ អ្នកចូរទទួលយកចំណែកបុណ្យនោះចុះ ។ ជាងកាត់សក់ញុំាងសេចក្ដីត្រេកអរឱ្យកើតឡើង ក៏ទទួលយកបុណ្យអំពីឧបាសកនោះ ។ ក្នុងពេលនោះទេវតាព្រមឱ្យជាងកាត់សក់ឡើងជិះសំពៅ ទើបនាំជនទាំងពីរនាក់នោះទៅក្រុងពារាណសី ទៅដល់ហើយ បានឱ្យកែវ ៧ ប្រការមួយសំពៅនោះដល់ជនទាំងពីរនាក់ ក៏ត្រឡប់ទៅលំនៅរបស់ខ្លួនវិញ ។

## ៥១. រឿងកសកព្រាហ្មណ៍

( ចាក ឧ. ប. )

( គុណនៃការមិនយំសោក មិនអាឡោះអាល័យ )

ក្នុងកាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាព្រាហ្មណ៍អ្នកធ្វើស្រែ នៅក្នុងក្រុងពារាណសី ។ ក្នុងត្រកូលនោះមានជន ៦ នាក់គឺ ព្រះពោធិសត្វ១, នាងព្រាហ្មណី១, កូនប្រុស១, ភរិយារបស់កូនប្រុស១, កូនស្រី១, ខ្ញុំស្រី១ ។ ព្រះពោធិ-សត្វតែងរំលឹកទូន្មានដល់ជនទាំង ៥ នាក់ ឱ្យខំចំរើននូវមរណស្សតិថា សេចក្ដីស្លាប់របស់សត្វទាំងឡាយទៀង ជីវិតរបស់សត្វទាំង

ឡាយមិនទៀង សង្ខារធម៌ទាំងឡាយមិនទៀង មានកិរិយាអស់ទៅនឹងសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរកុំប្រមាទក្នុងវេលាយប់និងថ្ងៃ ។ ជនទាំង ៥ នាក់នោះស្ថិតនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ខំចំរើនមរណសតិរាល់វេលារាត្រី មិនដែលធ្វេសប្រហែសឡើយ ។ ថ្ងៃមួយព្រះពោធិសត្វនាំកូនប្រុសទៅភ្ជួរស្រែ។ កូនប្រុសបានប្រមូលសំរាមដុតក្បែរដំបូកមួយ ក្នុងដំបូកនោះមានពស់មួយ កាចសាហាវជាទីបំផុត ផ្សែងភ្លើងចូលភ្នែកក៏ស្ទុះមកចឹកកូននោះទៅ ។ ព្រះពោធិសត្វដឹងថាកូនស្លាប់ហើយ បានលើកយកទៅផ្តេកក្រោមដើមឈើមួយដើម ឥតមានយំសោកអាឡោះអាល័យឡើយ គ្រាន់តែកំណត់ទុកក្នុងចិត្តថា សង្ខារទាំងឡាយមិនទៀង ក៏ទៅភ្ជួរស្រែវិញទៅ. មួយស្របក់បានឃើញបុរសស្និទ្ធស្នាលម្នាក់ ដើរទៅជិត ក៏សួរថា អ្នកឯងទៅផ្ទះឬ ? ។ បុរសអ្នកស្និទ្ធស្នាលប្រាប់ថា ខ្ញុំទៅឥឡូវនេះ ។ ព្រះពោធិសត្វនិយាយថា បើដូច្នោះអ្នកទៅផ្ទះខ្ញុំផង ទៅប្រាប់ដល់ភរិយារបស់ខ្ញុំ ឱ្យយកបាយតែមួយចំអែតមក ហើយនាំគ្នាទាំង ៤ នាក់មកផង ។ ជនទាំង ៤ នាក់ ក៏មកតាមបង្គាប់របស់ព្រះពោធិសត្វ មកដល់ឃើញកូនស្លាប់. ជនទាំង ៤ នាក់នោះឥតមានយំសោកអាឡោះអាល័យឡើយ លុះព្រះពោធិសត្វបរិភោគហើយក៏នាំគ្នាកាច់ផ្កាបូជា ហើយដុតរំលាយសពនោះទៅ ។ ក្នុងពេលនោះក្តៅក្រហាយដល់អាសនៈរបស់ព្រះឥន្ទ្រ ដោយអំណាចគុណនៃ

មរណសតិ ដែលជនទាំងនោះចំរើនហើយដោយល្អ ។ ព្រះឥន្ទ្រ ជ្រាបហេតុនោះហើយ មានចិត្តត្រេកអរីករាយ ចុះមកសួរនូវហេតុ ដែលមិនយំសោករបស់ជនទាំងនោះថា ម្នាលអ្នកដ៏ចំរើន ហេតុអ្វី បានជាមិនយំសោក ។ ព្រះពោធិសត្វនិយាយប្រាប់ព្រះឥន្ទ្រថា :

ឧរគោវ តចំ ជិណ្ណំ ហិត្វា គច្ឆតិ សន្តនុំ
ឯវំ សរីរេ និព្ភោគេ បេតេ កាលកតេ សតិ
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ ។
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

កូនខ្ញុំលះបង់រូបកាយរបស់ខ្លួនទៅហើយ ដូចជាពស់ដែលសកនូវសំណាកចាស់ដូច្នោះដែរ, សរីរកាយរបស់កូនខ្ញុំដែលទៅកាន់បរលោកហើយ ជារបស់ប្រើការមិនកើត, ខ្ញុំដុតក៏កូនខ្ញុំមិនដឹង ការយំសោករបស់ញាតិទាំងឡាយ ក៏កូនខ្ញុំមិនដឹង, គតិរស់កូនខ្ញុំទៅទីណា កូនខ្ញុំទៅកើតក្នុងទីនោះហើយ ព្រោះហេតុនោះបានជាខ្ញុំមិនយំសោក ។

ភរិយារបស់ព្រះពោធិសត្វនិយាយប្រាប់ព្រះឥន្ទ្រថា :

អនព្ភិតោ តតោ អាគា អននុញ្ញាតោ ឥតោ គតោ
យថាគតោ តថា គតោ តត្ថ កា បរិទេវនា
ឌយ្ហមាណា ន ជានាតិ ញាតីនំ បរិទេវិតំ ។
តស្មា ឯតំ ន សោចាមិ គតោ សោតស្ស យា គតិ ។

កូនខ្ញុំដែលធ្វើដំណើរពីលោកដទៃមកនៅក្នុងផ្ទះរបស់ខ្ញុំ ក៏ខ្ញុំមិនបានហៅរកមក លះបង់ពីលោកនេះទៅកាន់លោកដទៃវិញ ក៏ខ្ញុំមិនបានអនុញ្ញាតឱ្យទៅ ស្រេចតែនឹងទៅមក, ការយំសោកក្នុងដំណើរទៅមកនោះដូចម្ដេចកើត, កូនរបស់ខ្ញុំគេដុតក៏មិនដឹង ការយំសោករបស់ញាតិទាំងឡាយក៏មិនដឹង, គតិរបស់កូនខ្ញុំទៅទីណា កូនខ្ញុំទៅកើតក្នុងទីនោះហើយ ព្រោះហេតុនោះបានជាខ្ញុំមិនយំសោក ។

កូនស្រីរបស់ព្រះពោធិសត្វ និយាយប្រាប់ព្រះឥន្ទ្រថា :

**សចេ រោទេ កិសា អស្សំ តស្សា មេ កឹ ផលំ សិយា**

**ញាតិមិត្តសុហជ្ជានំ ភិយ្យោ នោ អរតី សិយា**

**ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ ។**

**តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។**

បើខ្ញុំយំសោកនឹងជាស្ត្រីស្គមស្រកស្រុតសាច់ ផលនៃការយំសោកឥតមានដល់ខ្ញុំទេ មានតែសេចក្ដីថ្នាំងថ្នាក់ចិត្តដ៏ក្រៃលែងដល់ញាតិមិត្រសម្លាញ់របស់យើងខ្ញុំទាំងឡាយ, បងរបស់ខ្ញុំគេដុតក៏គាត់មិនដឹង ការយំសោករបស់ញាតិទាំងឡាយ ក៏គាត់មិនដឹង, គតិរបស់បងខ្ញុំទៅទីណា គាត់ទៅកើតក្នុងទីនោះហើយ ព្រោះហេតុនោះបានជាខ្ញុំមិនយំសោក ។

កូនប្រសាររបស់ព្រះពោធិសត្វនិយាយប្រាប់ព្រះឥន្ទ្រថា :

យថាបិ ទារកោ ចន្ទំ គច្ឆន្តំ អនុរោទតិ
ឯវំ សម្បទមេវេតំ យោ បេតមនុសោចតិ
ឧយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ ។
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

បុគ្គលណា សោកស្តាយនូវជនដែលទៅកាន់បរលោកហើយ បុគ្គលនោះ ដូចជាក្មេងតូចដែលយំចង់បានព្រះចន្ទកំពុងចរឰដ៍អាកាសដូច្នោះឯង, នេះជាពាក្យឧបមានៃការមិនសោកស្តាយរបស់ខ្ញុំ, ស្វាមីខ្ញុំគេដុតក៏លោកមិនដឹង ការយំសោករបស់ញាតិទាំងឡាយក៏លោកមិនដឹង គតិរបស់ស្វាមីខ្ញុំទៅទីណា លោកទៅកើតក្នុងទីនោះហើយ ព្រោះហេតុនោះបានជាខ្ញុំមិនយំសោក ។

ខ្ញុំស្រីនិយាយប្រាប់ព្រះឥន្ទ្រថា :

យថា ព្រហ្មេ ឧទកុម្ភោ ភិន្នោ អប្បដិសន្ធិយោ
ឯវំ សម្បទមេវេតំ យោ បេតមនុសោចតិ
ឧយ្ហមានោ ន ជានាតិ ញាតី បរិទេវតំ ។
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

បពិត្រអ្នកប្រសើរ ក្អមទឹកដែលបែកហើយ មិនអាចបុគ្គលណាតភ្ជាប់បានឡើយ មានឧបមាយ៉ាងណា បុគ្គលដែលសោកស្តាយនូវជនអ្នកទៅកាន់បរលោកហើយក៏ដូច្នោះដែរ, នេះជាពាក្យឧបមានៃការមិនសោកស្តាយរបស់ខ្ញុំ, ចៅហ្វាយខ្ញុំគេដុតក៏លោក

មិនដឹង, ការយំសោករបស់ញាតិទាំងឡាយក៏លោកមិនដឹង, គតិរបស់ចៅហ្វាយខ្ញុំទៅទីណា លោកទៅកើតក្នុងទីនោះហើយ ព្រោះហេតុនោះបានជាខ្ញុំមិនយំសោក ។

ព្រះឥន្ទ្របានស្តាប់នូវធម្មកថា របស់ជនទាំង ៥ នាក់នោះហើយ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង ទើបនិយាយប្រាប់ជនទាំងនោះថា ចាប់តាំងពីថ្ងៃនេះទៅ អ្នកទាំងឡាយកុំធ្វើការដោយដៃខ្លួនឯងឡើយ, ខ្ញុំជាស្តេចនៃទេវតា នឹងញាំងផ្ទះរបស់អ្នកឱ្យពេញព្រៀបដោយកែវទាំង ៧ ប្រការ, អ្នកទាំងឡាយចូរឱ្យទាន រក្សាសីល ចំរើនមេត្តាភាវនាចុះ ។ ព្រះឥន្ទ្រយកកែវទៅចាក់គរក្នុងផ្ទះជនទាំង ៥ នាក់នោះហើយ ក៏ត្រឡប់ទៅស្ថានទេវលោកវិញ ។

ចប់ភាគ ១

ភាគ២ - ភាគ៣ ផ្សាយចេញហើយ

មានរឿងប្លែកៗជាងភាគ១

ភាគ ២

## ១~ រឿងអម្ពតាបស

( ចាក អ. ជា )

( សេចក្ដីសង្គ្រោះ ជាមហាស្នេហ៍ពូកែផុតក្នុងលោក )

ក្នុងអវសានដែលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី, កាលនោះ ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់សោយព្រះជាតិជាព្រាហ្មណ៍ នៅក្បែរផ្លូវ ឧត្តរទិសនៃក្រុងនោះ លុះចំរើនវ័យធំឡើងចេញចាកគេហដ្ឋានចូល បួសជាតាបស មានពួកតាបស៥០០ រូបជាបរិវារស្នាក់នៅក្បែរជើង ភ្នំហិមាល័យ ។ គ្រានោះទឹកក្នុងជ្រោះភ្នំក្នុងស្ទឹង ត្រពាំង បឹងបួរ អូរ ព្រែក រីងស្ងួតអស់ឥតសល់ សត្វម្រឹគបក្សាបក្សីដែលអាស្រ័យ នៅក្នុងព្រៃហិមាល័យទាំងប៉ុន្មាន កើតសេចក្ដីក្ដៅក្រហាយដោយ ស្រេកទឹកជាខ្លាំង ។ តាបសបានឃើញសត្វទាំងនោះមានទុក្ខវេទនា ដូច្នោះហើយ មានតាបស ១ រូបបានកាប់រំលំឈើ១ ដើមចោះលុង ធ្វើជាស្នូក ហើយទៅដងទឹកដែលលោកអាចទៅដងបាន យកមក ដាក់ក្នុងស្នូកនោះទុកបំរុងឱ្យសត្វទាំឡាយផឹក ។ ពួកសត្វទាំងឡាយ ក៏នាំគ្នាផឹកទឹកទាំងហ្វូង១ ឥតឈប់ឈរ ទាល់តែតាបសអស់ឱកាស នឹងចេញទៅស្វែងរកផ្លែឈើមកឆាន់ខ្លួនឯង ។ តាបសនោះលោក

មិនអើពើនឹងសេចក្តីស្រេកឃ្លានរបស់ខ្លួនឡើយ លោកខំតែដងទឹកមកចាក់ក្នុងស្នូកឱ្យសត្វទាំងនោះផឹកទាល់តែបាត់ស្រេក ព្រោះលោកជាអ្នកមានសេចក្តីសង្គ្រោះ ចំពោះសត្វទាំងឡាយឥតរើសមុខ ។

ពួកសត្វទាំងនោះ កាលបើបានឃើញតាបសមានសេចក្តីសង្គ្រោះដល់ខ្លួនហើយ ក៏គិតគ្នាថាយើងរាល់គ្នាត្រូវតបស្នងគុណតាបសនេះគ្រប់ៗគ្នាកុំខាន យើងត្រូវព្រមព្រៀងគ្នាយ៉ាងនេះ គឺត្រូវយកផ្លែឈើ មើមឈើមកគ្រប់ៗ គ្នាក្នុងវេលាដែលមកផឹកទឹកនៅទីនោះ ដើម្បីប្រគេនតាបស ។

សត្វទាំងអស់ក៏ព្រមព្រៀងគ្នា ក្នុងវេលាដែលមកផឹកទឹកបាននាំផ្លែស្វាយ និងផ្លែឈើមើមឈើផ្សេងៗ មកប្រគេនតាបសរាល់ថ្ងៃទាល់តែផ្លែឈើមើមឈើនោះសម្បូណ៌ពោរពាស ក្នុងគម្ពីរប្រាប់ថាបើផ្ទុកជាររទេះបាន ២៥០០ ររទេះក្នុងមួយថ្ងៃៗ ពួកតាបសទាំង ៥០០ រូបឆាន់ឆ្អែតស្កប់ស្កប់នៅសល់ពោរពាសពេញអាស្រម ។

ព្រះពោធិសត្វដែលជាប្រធាននៃតាបសទាំង ៥០០ រូបបានឃើញអស្ចារ្យដូច្នោះហើយ ក៏បន្លឺនូវវាចាប្រកាសថា : គុណគឺសេចក្តីល្អរបស់បុគ្គលតែម្នាក់ ដែលមានសេចក្តីសង្គ្រោះ អាចបណ្តាលឱ្យកើតចំណីអាហារដល់ពួកគណៈបរិភោគឆ្អែតស្កប់ស្កល់បាន. ព្រោះហេតុនោះអ្នកទាំងឡាយ ត្រូវតាំងព្យាយាមមាំមួនក្នុងការបំពេញ

សង្គហធម៌ ស្វែងរកប្រយោជន៍ ចំពោះសាធារណជន កុំខ្ជិលគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនយកចិត្តទុកដាក់អើពើនឹងប្រយោជន៍របស់សាធារណជនឡើយ ។

## ២. រឿងព្រះឥន្ទនិម្មិតជាយក្ស

( ចាក ម. វាំ )

( ការលះបង់ជីវិតចំពោះបំណងល្អ មិនដែលសាបសូន្យ )

កាលពីព្រេងនាយមានព្រះរាជាមួយព្រះអង្គ ព្រះនាមធម្ម-សោកណ្ឌកៈ តាំងពីបានទទួលរាជាភិសេកមកទ្រង់មានបំណងតែមួយ គឺចង់ស្តាប់ព្រះសទ្ធម្មទេសនា បានចាត់ព្រះរាជបំរើឱ្យយកប្រាក់តាំងពី ១ ពាន់កហាបណៈដរាបដល់ ១ កោដិ ទៅរកជួលអ្នកចេះសំដែងធម៌មកសំដែងឱ្យស្តាប់មិនបានសោះ ក៏លះបង់រាជសម្បត្តិត្រេចទៅស្វែងរកស្តាប់ធម៌ដោយព្រះអង្គឯង ។

ក្នុងពេលនោះព្រះឥន្ទ្របានជ្រាបហើយ ក៏និម្មិតជាយក្សធំអស្ចារ្យ មានអាការៈសំបើមគួរស្ញប់ស្ញែង គឺមានសម្បុរដូចជាកំពូលភ្នំអញ្ជន, មាត់ធំមានចង្កូមលៀនចេញមកក្រៅ, ភ្នែកធំក្រហមច្រាលដូចគំនរភ្លើងដែលកំពុងឆេះ, ទ្រូងខ្វង, ច្រមុះមានចុងក្រហមសក់និងពុកមាត់ពុកចង្កាពណ៌ទង់ដែងរួញក្រញាញ់, ពោះធំពណ៌ខៀវ, សំឡេងគ្រហឹមឮដូចផ្គរលាន់, ដៃមានក្រចកវែងៗ ប្រឡាក់

សុទ្ធតែឈាម មានដំបងគ្រឿងសស្ត្រាវុធជាប់នៅដៃមានឧធំខ្ពស់ស្មើត្នោតលៃ ចូលទៅឈរកៀកជិតព្រះធម្មសោកណ្ឌករាជ ។ បានឃើញយក្ខនោះហើយ ឥតមានខ្លាចញាប់ញ័រឡើយ បែរជាមានព្រះតម្រិះថា យក្ខដែលមានអានុភាពបែបនេះ ប្រហែលជាចេះសំដែងធម៌ ក៏ទ្រង់មានព្រះតម្រាស់ត្រាស់សួរទៅយក្ខថា : បពិត្រមហាយក្ខជាសំឡាញ់ អ្នកមានអានុភាពច្រើន មានអាការៈក្លាហាន បានមកជួបនឹងយើងប្រសើរណាស់ ព្រោះយើងបានលះបង់រាជសម្បត្តិនិងព្រះរាជវង្ស ចូលមកក្នុងព្រៃនេះដើម្បីរកអ្នកចេះធម៌ទេសនាឱ្យស្តាប់ ឥឡូវនេះបើអ្នកចេះធម៌ សូមសំដែងឱ្យយើងស្តាប់ ។

ឥន្ទយក្ខនិយាយតបវិញថា : បពិត្រមហារាជយើងបានចេះធម៌ដែលព្រះពុទ្ធពីបុរាណទ្រង់សំដែងទុកមក ប៉ុន្តែបើយើងសំដែងថ្វាយព្រះអង្គស្តាប់ តើព្រះអង្គបូជាអ្វីដល់យើង។ ព្រះបាទធម្មសោកករាជ ទ្រង់មានព្រះបន្ទូលថាយើងគ្មានអ្វីទេ មានតែសេរីកាយរបស់យើងនេះឯង សូមបូជាធម៌របស់អ្នក បើអ្នកសំដែងធម៌ឱ្យយើងស្តាប់ហើយអ្នកបរិភោគយើងចុះ ។ ឥន្ទយក្ខនិយាយថាស្រួលហើយ ប៉ុន្តែយើងអស់កំឡាំងណាស់ ព្រោះអត់អាហារយូរថ្ងៃហើយ បើបានបរិភោគឱ្យមានកំឡាំងសិន ទើបសំដែងធម៌ថ្វាយមហារាជបាន។ លំដាប់នោះព្រះរាជា ទ្រង់មានព្រះបន្ទូលថា បើអ្នកបរិភោគយើងហើយ ធ្វើម្តេចយើងនឹងបានស្តាប់ធម៌អ្នក ដែលយើងស៊ូលះ

បង់ជីវិត និងរាជសម្បត្តិចូលមកក្នុងព្រៃនេះ ក៏ព្រោះតែចង់ស្តាប់ធម៌ប៉ុណ្ណោះឯង ។ ឥន្ទយក្ខនិយាយថា បើដូច្នោះសូមមហារាជឡើងទៅលើកំពូលភ្នំដែលខ្ពស់នេះចុះ កាលបើឡើងទៅដល់កំពូលភ្នំហើយ លោតចុះមកឱ្យចំមាត់យើង ៗ នឹងសំដែងធម៌ថ្វាយឱ្យបានប្រយោជន៍ទាំងអស់គ្នា គឺមហារាជក៏បានស្តាប់ធម៌ យើងក៏បានបរិភោគមហារាជ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យឥន្ទយក្ខហើយទ្រង់ព្រះចិន្តាថា ពាក្យដែលយក្ខនិយាយនេះគួរហើយ ថ្ងៃនេះបំណងរបស់អញសម្រេចហើយ អញត្រូវតែលះបង់ជីវិតដើម្បីស្តាប់ធម៌ចុះ. ទើបទ្រង់មានព្រះបន្ទូលទៅកាន់ឥន្ទយក្ខថា ម្នាលសំឡាញ់ពាក្យអ្នកនិយាយអម្បាញមិញនេះប្រពៃណាស់ អ្នកជាបុគ្គលមានឧបការគុណច្រើនដល់យើងពិត ព្រោះហេតុនោះយើងនឹងធ្វើតាមពាក្យរបស់អ្នក សូមអ្នកកុំរង្កៀសចិត្តឡើយ ចាំសំដែងធម៌ឱ្យយើងស្តាប់ចុះ. លុះមានព្រះបន្ទូលដូច្នេះហើយ ក៏ឡើងទៅឈរលើកំពូលភ្នំ ហើយបន្លឺនូវព្រះសូរសីហនាទថា "ថ្ងៃនេះអញបានបូជាជីវិតផងរាជសម្បត្តិផង ចំពោះព្រះធម៌ទេសនា" បពិត្រមហាយក្ខ យើងមានសេចក្តីត្រេកអរយ៉ាងក្រៃលែង ចំពោះធម៌ទេសនារបស់អ្នកសូមអ្នកសំដែងធម៌ចុះ ទ្រង់មានព្រះបន្ទូលហើយ ក៏លោតសំដៅទៅក្នុងមាត់យក្ខដែលហាចាំពីក្រោម ។ ខណៈនោះឥន្ទយក្ខក៏ក្លាយខ្លួនជាព្រះឥន្ទវិញភ្លាម ហើយបីពព្រះរាជាហោះយកទៅស្ថានត្រៃ

ត្រឹងឲ្យគង់លើថ្មបណ្ឌុកម្ពល បូជាដោយគ្រឿងសក្ការទិព្វច្រើនជាអនេក ហើយថ្វាយដំណឹងដល់ព្រះរាជាថា សូមមហារាជប្រុងស្ដាប់ធម៌ចុះ ខ្ញុំនឹងសំដែងធម៌ដែលខ្ញុំបានស្ដាប់ពីសំណាក់ព្រះសម្ពុទ្ធអំពីបុរាណមកថា :

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**

**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។**

ព្រះបាទធម្មសោណ្ឌករាជ កាលបើបានស្ដាប់នូវធម្មទេសនារបស់ព្រះឥន្ទហើយ មានសេចក្ដីរីករាយយ៉ាងក្រៃលែង ហាក់ដូចជាបានស្ដាប់អំពីសំណាក់នៃព្រះសម្ពុទ្ធ ។ បន្ទាប់អំពីធម្មទេសនានោះមក ព្រះឥន្ទ្របានសំដែងប្រាប់នូវសេចក្ដីសុខក្នុងទេវលោកសព្វគ្រប់ហើយ ក៏នាំព្រះរាជាត្រឡប់មកស្ថានមនុស្សឱ្យសោយរាជសម្បត្តិដូចដើមវិញ។ ព្រះបាទធម្មសោណ្ឌករាជក្នុងកាលនោះ គឺព្រះសម្ពុទ្ធបរមគ្រូយើងនេះឯង ។

## ៣. រឿងកដាហកមាណព

( ចាក ក. ឯ. )

( ផ្ចាញ់មនុស្សអំនួត ដោយពាក្យសច្ចៈ )

ក្នុងកាលកន្លងទៅហើយ មានខ្ញុំបំរើម្នាក់របស់ពារាណសីសេដ្ឋី មានកូនប្រុសមួយឈ្មោះកដាហក ជាមនុស្សប៉ិនប្រសប់និយាយណាស់ ។ កូននោះអាយុដំណាលនឹងកូនប្រុសរបស់សេដ្ឋី តែងកាន់សៀវភៅតាមកូនសេដ្ឋីទៅរៀនអក្សរសាស្ត្ររាល់ថ្ងៃ ។ សេដ្ឋីបានបង្គាប់ឱ្យមើលថែរក្សាសេដ្ឋីបុត្រជាកូន ។ កដាហក គិតថាអញធ្វើជាខ្ញុំបំរើយ៉ាងនេះ បើធ្វើខុសបន្តិចបន្តួច សេដ្ឋីនឹងយកទោសធ្វើទណ្ឌកម្មមិនខាន ។ ថ្ងៃមួយ កដាហកសរសេរសំបុត្រក្លែងធ្វើជាចុតហ្មាយរបស់មហាសេដ្ឋី បង្គាប់ទៅសេដ្ឋីក្នុងជនបទថា : កដាហកដែលកាន់សំបុត្រមកនេះជាកូនបង្កើតរបស់ខ្ញុំជាមហាសេដ្ឋី បើឃើញមកដល់ឱ្យរៀបផ្សំផ្គុំជាមួយនឹងបុត្រីចុះ. លុះសរសេរហើយលួចត្រារបស់មហាសេដ្ឋីបោះហើយ យកទ្រព្យរបស់ជាច្រើន រេចស្ពាយរត់សំដៅទៅផ្ទះសេដ្ឋីក្នុងជនបទ ។ សេដ្ឋីនោះបានទទួលសំបុត្រមើលសព្វគ្រប់ហើយ សំគាល់ថាជាកូនរបស់មហាសេដ្ឋីមែន មានសេចក្តីត្រេកអរណាស់ បានរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំកដាហកនឹងបុត្រីរបស់ខ្លួនយ៉ាងឆាប់រហ័សឥតបង្អង់ឡើយ ។ ចំណែកមហាសេដ្ឋីដឹងថា កដាហករត់បាត់ ក៏ប្រើមនុស្សឱ្យដើរស៊ើបដំណឹងរក

បានដឹងដំណឹងសព្វគ្រប់ហើយ ទៅតាមដោយខ្លួនឯងបំណងនឹងចាប់ខ្លួនយកមក ។ ឯកដាហកជាមនុស្សប៉ិនប្រសប់ បានដឹងថាមហាសេដ្ឋីមកតាមហើយ ក៏ប្រញាប់ប្រញាល់ចេញទៅទទួលនៅទីពាក់កណ្តាលផ្លូវ ទៅថ្លែងអាការៈគោរពប្រណិបតន៍ដោយផ្ងិតផ្ងង់លុះបានឱកាស ក៏អង្វរសេដ្ឋី សូមឱ្យអត់ទោសហើយឱ្យទទួលថាជាកូនបង្កើតមែន មហាសេដ្ឋីក៏ព្រមអត់ទោសឱ្យតាមសុំ ។ មហាសេដ្ឋីទៅដល់ផ្ទះហើយ ក៏និយាយទៅរកសេដ្ឋីក្នុងជនបទថា កដាហកជាកូនរបស់ខ្លួនមែន ។

ថ្ងៃមួយមហាសេដ្ឋីសួរភរិយារបស់សេដ្ឋីក្នុងជនបទថា : ដូចម្តេចបុត្រប្រសាររបស់នាង ល្អឬអាក្រក់? នាងប្រាប់ថាគេល្អហើយទាស់តែរញ៉ាំរញ៉ូវច្រើននិយាយអួតពីរបស់ស៊ីនិងអ្វីៗ គ្រប់យ៉ាង ។ មហាសេដ្ឋីក៏បង្រៀនមន្ត ឱ្យនាងសូត្រក្នុងវេលាដែលកដាហកកំពុងនិយាយអួតថា :

**ពហុំបិ សោ វិកត្ថេយ្យ អញ្ញំ ជនបទំ គតោ**
**អន្វាគន្ត្វាន ទូសេយ្យ ភុញ្ជ ភោគេ កដាហក ។**

មានមនុស្សទៅកាន់ជនបទដទៃ ហើយនិយាយអួតច្រើនបន្តិច ម្ចាស់គេនឹងមកតាមចាប់ខ្លួនយកទៅ ម្នាលកដាហកអ្នកអញ្ជើញបរិភោគអាហារចុះ ។

មហាសេដ្ឋីនៅលេងបន្តិចក៏ត្រឡប់ទៅវិញ. ក្រោយមក

កដាហកនិយាយរញ៉ាំរញ៉ូវតិះដៀលអ្នកអាងទៀត ភរិយានោះក៏រាយមន្តដែលមហាសេដ្ឋីបានបង្រៀន ។ កដាហក បានឮហើយសំគាល់ថានាងដឹងរឿងដើមរបស់ខ្លួន ក៏ស្ងាត់ស្ងៀមលែងរញ៉ាំរញ៉ូវអ្នកអាងទៀតឡើយ ។

## ៤. រឿងសេកសោមបណ្ឌិត

( ចាក ម. វ៉ា. )

( អកតញ្ញូជន អន់ជាងសត្វតិរច្ឆាន )

ក្នុងកាលកន្លងយូរហើយ មានសេកសោមមួយព្រួយចិត្តអន្ទះសាព្រោះស្រេកទឹក ត្បិតក្នុងសម័យនោះគ្មានភ្លៀងសោះរាំងអស់ពីរបីឆ្នាំ ទឹកក្នុងទន្លេស្ទឹងត្រពាំងបឹងបួរីងស្ងួតឥតសល់ ។ ថ្ងៃមួយសេកសោមហើរចូលទៅក្នុងព្រៃធំ បានជុំខ្លិនទឹកក៏ខំរកមើលឃើញអណ្ដូងមួយមានជម្រៅប្រហែល ៦០ ហត្ថទើបហើរចុះទៅក្នុងអណ្ដូងនោះបានឃើញទឹក ហើយមានសេចក្ដីត្រេកអរក្រៃពេកខំផឹកមុជងរាបដល់ឆ្អែតស្កប់ស្កល់ ធាតុទឹកជ្រួតជ្រាបត្រជាក់សព្វសកលកាយ បណ្ដាលឱ្យកើតអន្តរាយហើរឡើងមកវិញពុំរួចឡើយ។

មួយស្របក់ស្រាប់តែមានមនុស្សម្នាក់ និងនាគរាជមួយកំពុងតែដើរស្វែងរកទឹកផឹក ក៏ធ្លាក់ចុះទៅក្នុងអណ្ដូងនោះដែរ ។ ជនទាំងបីគឺ សេកសោម១. មនុស្សម្នាក់. និងនាគរាជ១ ខំឡើងពី

ក្នុងអណ្តូងមកវិញពុំរួចឡើយ ក៏ព្រួយចិត្តកើតទុក្ខតែរៀងខ្លួន ។ កាលនោះជួនជាមានបុរសម្នាក់នៅក្នុងក្រុងពារាណសី ដើរទៅផងទឹក បានឃើញជនទាំងបីនៅក្នុងអណ្តូង ក៏មានចិត្តមេត្តាករុណាជួយសង្គ្រោះជីវិត យកវល្លិចងជាសង្រែកយោងយកជនទាំងនោះចេញពីក្នុងអណ្តូងមក ។ ជនទាំងបីមានសេចក្តីត្រេកអរណាស់បានប្រគល់ខ្លួនដល់បុរសនោះ ហើយប្រាប់ទីកន្លែងរៀងៗ ខ្លួនប្តេជ្ញាថាបើមានការយ៉ាងណាឱ្យប្រាប់នឹងតបគុណវិញ ។

កាលជាខាងក្រោយមកបុរសនោះគិតថា អញនឹងល្បងមើលចិត្តរបស់ជនទាំងបី តើនរណាដឹងគុណអញជាងគេ ក៏ទៅកាន់សំណាក់សេកសោមជាមុន ។ សេកសោមឃើញហើយមានសេចក្តីត្រេកអររាក់ទាក់គួរសមថា លោកអញ្ជើញមកមានការអ្វី ។ បុរសនោះប្រាប់ថា ណាក់ចាំងអ្វី ខ្ញុំសព្វថ្ងៃទ័លក្រណាស់ សំឡាញ់ឯងមានឧបាយដូចម្តេចធ្វើឱ្យខ្ញុំបានផុតអំពីសេចក្តីទ័លក្របាន ? ។ សេកសោមនិយាយថា លោកមានគុណនឹងខ្ញុំធំណាស់បានឱ្យជីវិតដល់ខ្ញុំសូមលោកនៅចាំខ្ញុំក្នុងទីនេះសិន ខ្ញុំនឹងទៅរកទ្រព្យមកបូជាតបគុណលោក ក៏ហើរចេញទៅ ។

សម័យនោះព្រះរាជាក្នុងក្រុងពារាណសី ស្តេចយាងទៅក្រសាលសប្បាយក្នុងឧទ្យាន ដល់ពេលថ្ងៃក្តៅដោះគ្រឿងអលង្ការទុកក្បែរមាត់ស្រះបោក្ខរណីចុះស្រង់ទឹក ។ សេកសោមហើរទៅ

ដល់ទីនោះឃើញពន្លឺរស្មីនៃគ្រឿងអលង្ការ ក៏ទៅទំលើមែកឈើ សំឡឹងមើលទៅឃើញកែវមុក្តាមួយដុំតូចល្មមពាំរួច ក៏លួចពាំយក មកឱ្យបុរសដែលមានឧបការគុណលើខ្លួន ហើយប្រាប់បុរសនោះថា កែវនេះវិសេសណាស់គ្មាននរណាមានទេ មានតែស្តេចជាម្ចាស់ផែនដី សូមលោកលាក់ទុកសិនកុំអាលលក់ដូរ ។ បុរសនោះគិតថា អញមិនដឹងជាយកទៅលាក់ក្នុងទីណាឱ្យកំបាំង ក៏យកកែវនោះទៅផ្ញើនឹងជនម្នាក់ដែលខ្លួនបានជួយសង្គ្រោះ ស្រង់ពីក្នុងអណ្តូងជាមួយនឹងសេក, ទៅដល់ប្រគល់កែវនោះឱ្យ ប្រាប់ថាសូមសំឡាញ់ទុកឱ្យខ្ញុំស្រួលបួល កុំនិយាយឱ្យគេដឹង, ជននោះក៏ទទួលទុកទៅ ។ កន្លងមកពីរបីថ្ងៃ ជននោះបានឮដំណឹងថា ព្រះរាជាក្រុងពារាណសីបាត់កែវមុក្តា១ ដុំ បើអ្នកណារកឃើញនឹងប្រទានឱ្យស្មើនឹងតម្លៃកែវ ។ ជនដែលទទួលកែវទុកឱ្យបុរសនោះ ជាមនុស្សអកតញ្ញូ គិតតែប្រយោជន៍ផ្ទាល់ខ្លួន ក៏យកកែវនោះទៅថ្វាយព្រះរាជាទូលថា មានបុរសម្នាក់យកកែវនេះទៅផ្ញើនឹងទូលព្រះបង្គំ ។ ព្រះរាជាក៏ចាត់រាជបុរសឱ្យទៅចាប់បុរសនោះទៅសម្លាប់ ដោយចោទថាទៅលួចយកកែវរបស់ព្រះអង្គ ។ រាជបុរសក៏ចងបុរសនោះ បណ្តើរចេញពីនគរទៅកាន់ទីសម្លាប់ ទៅដល់ក្បែរដំបូកបុរសនោះ ក៏នឹកដល់នាគរាជទើបស្រែកហៅថាម្នាលសំឡាញ់មកជួយខ្ញុំផង ។ នាគរាជឮហើយស្ទុះចេញពីរូងមកដោយស្គាល់ច្បាស់ជាសំឡេងបុរសដែលមានគុណ

លើខ្លួន បានឃើញគេចងយកទៅសម្លាប់ដូច្នោះមានចិត្តអាណិតក្រៃពេក ក៏និម្មិតខ្លួនជារាជបុរសមួយរំពេច ឥតជនណាដឹងបានឡើយ ចូលទៅឃាត់រាជបុរសដែលកំពុងនាំទៅសម្លាប់ថា ម្នាលគ្នាយើង ឈប់សិនកុំអាលសម្លាប់បុរសនេះចាំខ្ញុំទៅផ្ទះសិន. រាជបុរសទាំងឡាយក៏ត្រៀមចាំ នាគរាជខំរត់ទៅក្នុងនគរចូលទៅប្រាសាទព្រះអគ្គមហេសីរបស់ព្រះរាជា និម្មិតខ្លួនជាពស់មួយតូច ចឹកព្រះអគ្គ-មហេសីនោះ ស្រែកឡើលដឹងពួដល់ព្រះរាជាមួយរំពេច ក៏និម្មិតខ្លួនជារាជបុរសវិញប្រាប់ថា ថ្នាំបន្សាបពិសពស់មានតែបុរស ដែលយកទៅសម្លាប់ទេ ដែលចេះពូកែជាងគេក្នុងនគរនេះ ។ ព្រះរាជាក៏ប្រើឱ្យទៅនាំយកបុរសនោះមកវិញ នាគរាជបានប្រាប់បុរសនោះសព្វគ្រប់ គ្រាន់តែបុរសនោះមកដល់យកទឹកទៅលាប ក៏ជាភ្លាមមួយរំពេច ។ ព្រះរាជាទ្រង់មានព្រះទ័យសោមនស្សរីករាយលែងសម្លាប់ ហើយបានព្រះរាជទានរង្វាន់ជាច្រើនដល់បុរសនោះ ។ បុរសនោះបានក្រាបបង្គំទូលអំពីដំណើរដែលខ្លួនបានកែវ និងដំណើររឿងជនទាំង ៣ គឺ : សេកសោម១, មនុស្សម្នាក់ ដែលខ្លួនបានផ្ញើកែវ និងនាគរាជ១ តាំងពីដើមដរាបដល់ចប់ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ ហើយរឹងរិតតែមានព្រះទ័យសោមនស្សជាខ្លាំង បានចំណាយព្រះរាជទ្រព្យឱ្យជាងចាត់ចែងសង់ផ្ទះឱ្យនៅជាមួយសេកសោម និងនាគរាជជាសុខក្សេមក្សាន្តដរាបដល់ទីបំផុតនៃអាយុ លុះស្លាប់ទៅ

បានទៅកើតក្នុងស្ថានសួគ៌ទៀត. ឯជនអកតញ្ញូត្រូវមានទោសក្នុងបច្ចុប្បន្នយ៉ាងអស្ចារ្យ លុះស្លាប់ទៅកើតក្នុងនរកទៀត ។

## ៥. រឿងផ្អែខាំពពែ

( ចាក លោក. ជា )

( ការវិនិច្ឆ័យក្ដីពិនិត្យហេតុផល ជាគតិរបស់បណ្ឌិត )

កាលពីព្រេងនាយ មានអ្នកគង្វាលពពែម្នាក់គៀងពពែទៅឱ្យស៊ីស្មៅក្បែរព្រៃមួយ ។ កាលនោះមានថ្មើរព្រៃម្នាក់ បាននាំឆ្កែជាច្រើនចូលទៅក្នុងព្រៃនោះដើម្បីរកឧសនិងបន្លែ ។ ថ្មើរព្រៃបានឃើញហ្វូងពពែនៅក្នុងទីនោះ ក៏នាំឆ្កែចេញឆ្ងាយប្រហែល៦០ព្យាមព្រោះខ្លាចឆ្កែខាំពពែ ។ លុះនាំឆ្កែទៅឆ្ងាយហើយចូលទៅសម្រាកក្រោមម្លប់ឈើមួយ ត្រូវខ្យល់រំភើយៗ ត្រជាក់ទន់ត្របកភ្នែកក៏ដេកលក់ទៅ ។ ពេលនោះមានកូនពពែមួយដើរចេញពីហ្វូងទៅឆ្ងាយប្រហែលជាង ៦០ ព្យាមទៅជួបនឹងឆ្កែរបស់ថ្មើរព្រៃ ពួកឆ្កែទាំងឡាយក៏ចោមរោមខាំកូនពពែនោះស្លាប់ទៅ ។ អ្នកគង្វាលពពែស្ទុះរត់ស្រែកដេញឆ្កែយ៉ាងខ្លាំង សំដៅទៅកន្លែងដែលឆ្កែកំពុងខាំពពែ។ ថ្មើរព្រៃក៏ភ្ញាក់ឡើងភ័យឆោឡោ ទើបនិយាយអង្វរគង្វាលពពែថា ម្នាលសំឡាញ់កុំខឹងនឹងខ្ញុំ ឥតដឹងជាពពែអ្នលមកក្នុងទីនេះទេ ខ្ញុំខ្លាចក្រែងឆ្កែខាំពពែសំឡាញ់ដូច្នេះ បានជាខ្ញុំនាំឆ្កែឱ្យឆ្ងាយពីហ្វូងពពែ

ប្រហែល ៦០ ព្យាម ។ គង្វាលពពែមិនសុខចិត្តក៏ទៅប្រាប់ដល់សេដ្ឋីជាចៅហ្វាយរបស់ខ្លួន ។ សេដ្ឋីហៅថ្មើរព្រៃទៅស្តីបន្ទោសដាក់កំហុសឱ្យសងថ្លៃពពែ, ថ្មើរព្រៃមិនព្រមសងព្រោះអាងថាខ្លួនឥតមានកំហុស ។ សេដ្ឋីក្តៅចិត្តខ្លាំងណាស់ ព្រោះអាងខ្លួនមានទ្រព្យ ក៏និយាយប្រាប់ថ្មើរព្រៃថាស្អែកអញទៅប្តឹង ឱ្យចៅក្រមកាត់ទោសអ្នកឯងហើយ ។ ថ្មើរព្រៃនិយាយបណ្តោយថា ស្រួលហើយលោកសេដ្ឋីដើម្បីរកខុសត្រូវឱ្យឃើញដោយសុចរិត ។ ល្ងាចនោះសេដ្ឋីយកសំណូកទៅសូកឧជុកសេនាបតីជាចៅក្រម, ឧជកសេនាបតីចៅក្រមទុច្ចរិត ទទួលសំណូកហើយប្រាប់សេដ្ឋីថាកុំព្រួយឡើយ ចាំខ្ញុំគម្រាមឱ្យវាសងពពែមួយជាពពែបួនទើបឱ្យវារួចខ្លួន បើវាមិនសងទេ នឹងដាក់ទោសវាជាទម្ងន់ ។ ព្រឹកឡើងឧជុកសេនាបតីទៅកាន់សាលាកាត់ក្តីឃើញសេដ្ឋី និងថ្មើរព្រៃនៅក្នុងទីនោះក៏ធ្វើជាសួរពើរថា : លោកសេដ្ឋី និងថ្មើរព្រៃអញ្ជើញមកមានការអ្វី ចៅក្រមទីពីរជំរាបថាសេដ្ឋីនិងថ្មើរព្រៃនេះមានវិវាទនឹងគ្នា ត្រូវកាត់ក្តីក្នុងថ្ងៃនេះឧជុកសេនាបតីសួរទៅសេដ្ឋីថា : លោកមានរឿងមិនសុខចិត្តដូចម្តេច ? សេដ្ឋីឆ្លើយថា ថ្មើរព្រៃនេះឱ្យឆ្កែខាំពពែខ្ញុំស្លាប់ ហើយមិនព្រមសងថ្លៃពពែខ្ញុំ ជាមនុស្សប្រព្រឹត្តបំពានលើច្បាប់ ព្រោះហេតុនោះ បានជាខ្ញុំមិនសុខចិត្តចូលមកឱ្យលោកជាទេវតាកាត់សេចក្តីឱ្យបានសុចរិត ។ ឧជុកសេនាបតី ក៏និយាយទៅថ្មើរព្រៃថា

អ្នកឯងក៏អាក្រក់ម្ល៉េះឱ្យផ្តែខាំពពែគេស្លាប់ ហើយមិនសងពពែគេ អ្នកឯងជាមនុស្សទុច្ចរិតអាក្រក់ណាស់ ត្រូវតែសងពពែលោកសេដ្ឋី ១ជា៤ មិនសងមិនបាននឹងមានទោសជាទម្ងន់ ។ ថ្មើរព្រៃក៏និយាយតវ៉ាតាមសេចក្តីពិត ទើបតែនិយាយបានពីរបីម៉ាត់ ឧជុកសេនាបតីស្រែកគម្រាម ឱ្យឆាប់ចេញទៅយកលុយថ្លៃពពែមកសងសេដ្ឋី ។ ថ្មើរព្រៃទាល់គំនិតអស់សង្ឃឹម ក៏លើកដៃខ្ទប់មុខស្រែកទ្រហោយំដើរចេញទៅផ្ទះ ។

ក្នុងកាលនោះធនញ្ជយបណ្ឌិតពោធិសត្វ ដើរចេញមកអំពីបំរើស្តេច ថ្មើរព្រៃឃើញហើយក៏ដើរសំដៅទៅរក ក្រាបថ្វាយបង្គំប្រាប់តាមដំណើររឿង ។ ព្រះពោធិសត្វក៏នាំថ្មើរព្រៃចូលទៅកាន់សាលាកាត់ក្តីវិញ ទៅដល់ឧជុកសេនាបតីឃើញក៏សួរព្រះពោធិសត្វថា លោកបណ្ឌិតនាំថ្មើរព្រៃកំណាចមកធ្វើអ្វី មកឱ្យកំហុសខ្ញុំឬ ? ។ ព្រះពោធិសត្វនិយាយថាមិនដូច្នោះទេ ខ្ញុំចង់ដឹងថាថ្មើរព្រៃនេះមានរឿងដូចម្តេច បានជាលោកកាត់ឱ្យថ្មើរព្រៃនេះសងថ្លៃពពែសេដ្ឋី ១ ជា ៤ បើតាមខ្ញុំដឹងលោកកាត់ក្តីនេះមិនសមរម្យទេ ។ ឧជុកសេនា-បតីឮធនញ្ជយបណ្ឌិតពោធិសត្វថាដូច្នោះ ក៏មានចិត្តតក់ស្លុតភ័យញ័រខ្លួនដោយខ្លាចបញ្ញាបារមីរបស់ព្រះពោធិសត្វ ។ ពេលនោះព្រះពោធិសត្វសួរទៅថ្មើរព្រៃនិងអ្នកគង្វាលពពែ ចំពោះមុខសេដ្ឋីនិងចៅក្រមទាំងអស់ម្តងទៀត ។ ថ្មើរព្រៃឆ្លើយតាមពិតថា ឆ្កែខ្ញុំនៅ

ឆ្ងាយពីពពែប្រហែល ៦០ ព្យាម ខ្ញុំនាំឆ្កែចូលទៅសម្រាកក្រោមម្លប់ឈើត្រូវខ្យល់ត្រជាក់ ខ្ញុំទទួលទានដំណេកលក់ទៅ ស្រាប់តែឮមាត់គង្វាលពពែស្រែកថាឆ្កែខាំពពែស្លាប់ មកចាប់ពិរុធខ្ញុំម្ចាស់ឱ្យសង ។ ព្រះពោធិសត្វសួរបញ្ជាក់ទៀតថា ពពែនោះឆ្កែខាំក្នុងទីណា ខាំក្នុងហ្វូងពពែឬអ្វី? ។ គង្វាលពពែឆ្លើយថា ខាំក្នុងទីជិតដើមឈើដែលច្មើរព្រៃដេកចម្ងាយប្រហែល៦០ ព្យាមពីហ្វូងពពែមក ។ ពេលនោះព្រះពោធិសត្វសួរបញ្ជាក់ទៅឧជុកសេនាបតី និងចៅក្រមទាំងអស់ថា ត្រូវកាត់ឱ្យកំហុសទៅខាងណា ? ។ ចៅក្រមទាំងអស់នៅស្ងៀម ឧជុកសេនាបតីឆ្លើយថា សូមលោកជាបណ្ឌិតកាត់ឱ្យបានសុចរិតចុះ ។ ព្រះពោធិសត្វកាត់សេចក្ដីថា រឿងនេះមិនត្រូវឱ្យច្មើរព្រៃសងថ្លៃពពែសេដ្ឋីទេ ត្រូវឱ្យគង្វាលពពែសងវិញទើបត្រូវ ព្រោះខ្លួនជាអ្នកឃ្វាលពពែ ហេតុអ្វីក៏បណ្ដោយឱ្យពពែដើរចេញពីហ្វូងចម្ងាយ ៦០ ព្យាម មិនប្រមូលឱ្យជួបជុំគ្នា បើតាមច្បាប់ច្មើរព្រៃត្រូវមានអំណាចស្ដីបន្ទោសធ្វើទណ្ឌកម្មដល់គង្វាលពពែទៀត ព្រោះខ្លួនឥតគំនិត ។

# ៦. រឿងព្រាហ្មណ៍ចាស់

( ចាក ធ. ឧ. )

( កូនមិនដឹងគុណមាតាបិតា អន់ជាងឈើច្រត់ )

ក្នុងពុទ្ធសម័យ មានព្រាហ្មណ៍មហាសាលម្នាក់នៅក្នុងក្រុងសាវត្ថីមានទ្រព្យ ៨ សែនកហាបណៈ មានកូនប្រុស ៤ នាក់ ។ កាលកូននោះមានវ័យធំឡើង បានរៀបអាវាហមង្គលហើយចែកទ្រព្យសម្បត្តិឱ្យកូនម្នាក់ៗ ១ សែនកហាបណៈ ។ ខាងក្រោយមកនាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះស្លាប់ទៅ គាត់នៅពោះម៉ាយតែម្នាក់ឯង ។ កូនទាំង៤ នាក់ប្រឹក្សាគ្នាថា បើឪពុកយើងមានប្រពន្ធទៀត មុខជាមានកូនមិនខាន ទ្រព្យ៤ សែននឹងកើតអាករផ្សេងៗ ដែលនៅសល់ក្នុងកណ្ដាប់ដៃគាត់ គាត់មុខជាចែកឱ្យកូនចុងទាំងអស់ បើដូច្នេះគួរតែយើងទៅនាំយកគាត់មកចិញ្ចឹមជប់លៀងគាត់ ។ ថ្ងៃមួយព្រាហ្មណ៍ក្រោកពីដេកក្នុងវេលាថ្ងៃ កូនទៅជួបជុំគ្នាហើយ និយាយអំពីទោសនៅគ្រប់គ្រងផ្ទះ ដោយឡែកៗពីគ្នា រួចនិយាយអង្វរថា : លោកឪពុកយើងខ្ញុំជាកូនទាំងអស់គ្នានឹងបំរើទំនុកបំរុងលោកឪពុកដោយគោរពដរាបដល់អស់ជីវិត សូមលោកឪពុកប្រគល់ទ្រព្យសម្បត្តិដែលនៅសល់ទាំងប៉ុន្មាន មកយើងខ្ញុំទាំងអស់គ្នាឱ្យអស់មក កុំរវល់នឹងទុកដាក់ថែរក្សាព្រោះចាស់ហើយ ។ ព្រាហ្មណ៍ក៏ប្រគល់ទ្រព្យឱ្យដល់កូនទាំង ៤ នាក់ ម្នាក់ត្រូវ

បាន ១ សែនកហាបណៈទៀត ខ្លួននៅសល់តែសំពត់ ១ ចង្កេះប៉ុណ្ណោះ ទៅនៅជាមួយនឹងកូនច្បងបង្អស់មិនយូរប៉ុន្មានកូនប្រសារកើតសេចក្តីធុញទ្រាន់ ក៏និយាយដៀមដាមថា : លោកឪពុកប្រហែលជាមិនស្គាល់ផ្លូវទៅផ្ទះកូនដទៃទៀតទេដឹង បានជាក្រាញនៅតែផ្ទះខ្ញុំ ។ ព្រាហ្មណ៍ឮដូច្នោះតូចចិត្តណាស់ ក៏បានដើរទៅនៅគ្រប់ផ្ទះកូនទាំង ៤ នាក់ គេចេះតែបណ្តេញដូចៗគ្នា គាត់ទ្រាំនៅមិនបាន ក៏ចេញទៅដើរសូមទានគេតាមច្រកល្ហកផ្ទះបុគ្គលដទៃទៅជាស្គមស្គាំង ព្រោះបរិភោគអាហារនិងដេកមិនស្រួលនឹកអាណិតអាសូរខ្លួនថា : ឱ ! អាត្មាអញចាស់ឡើងកាន់តែលំបាកខ្លាំងឡើងមិនសមបើកូនអញវាមិននឹកអាណិតអញបន្តិចបន្តួចសោះ វាលះបង់ចោលអញដូចជាគោចាស់ បើដូច្នេះអញចូលទៅរកព្រះសមណគោតមចុះក្រែងលោបានសុខស្រួលបន្តិច. លុះគិតដូច្នេះហើយក៏ទៅកាន់សំណាក់ព្រះសម្ពុទ្ធ ៗ ត្រាស់សួរថា : នែព្រាហ្មណ៍ហេតុអ្វីបានជាអ្នកស្គមស្លេកស្លាំងម្ល៉េះ? ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានកូនប្រុស៤ នាក់ ឥឡូវនេះវាត្រូវគំនិតនឹងប្រពន្ធវាបណ្តេញខ្ញុំព្រះអង្គចោល ។ ម្នាលព្រាហ្មណ៍បើដូច្នោះ អ្នកចូររៀនមន្តពីតថាគត ហើយសូត្រក្នុងទីប្រជុំជនដែលមានកូនរបស់អ្នកទាំងនោះអង្គុយនៅជាមួយផង. មន្តនោះថា :

"ខ្ញុំត្រេកអរដោយកូនឯណាដែលកើតហើយផង ប្រាថ្នានូវ

សេចក្តីចំរើនដល់កូនឯណាផង. កូននោះសមគំនិតជាមួយប្រពន្ធវា ហើយបណ្តេញខ្ញុំចោលដូចជាឆ្កែបណ្តេញជ្រូក. កូនជាអសប្បុរស លាមកគ្រាន់តែហៅឪ ៗ ប៉ុណ្ណោះ វាលះបង់ខ្ញុំដែលមានវ័យចាស់ជ្រុលហើយ. កូនខ្ញុំនោះប្រៀបដូចអារក្សទឹកមកក្លែងធ្វើជាកូន. ឪពុកចាស់របស់កូនពាល តែងដើរសូមទានប្របផ្ទះអ្នកដទៃ ដូចជាសេះចាស់ប្រើមិនកើត គេនាំចេញចាកចំណី. ឈើច្រត់របស់ខ្ញុំនេះប្រសើរ ឯកូនដែលមិនស្តាប់បង្គាប់មិនប្រសើរឡើយ. ត្បិតឈើច្រត់នេះអាចការពារគោកាច ឆ្កែកាចក៏បាន ច្រត់ទៅខាងមុខក្នុងទីងងឹតក៏បាន ស្ទង់ចុះទៅក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិលគង់ទប់ខ្លួនបានដោយអនុភាពនៃឈើច្រត់" ។ លុះព្រាហ្មណ៍ចាស់រៀនមន្តនេះអំពីសំណាក់ព្រះមានព្រះភាគចប់ហើយ ក៏ចូលទៅកាន់ទីប្រជុំដែលមានកូន ៤ នាក់អង្គុយនៅទីនោះផង ហើយសូត្ររាយមន្តនោះ ។

សម័យនោះទំនៀមរបស់អ្នកស្រុកប្រកាន់ថា : "បើកូនណាបានទទួលមតិកពីមាតាបិតាហើយ មិនចិញ្ចឹមវិញត្រូវអ្នកស្រុកប្រហារជីវិត" ។

គ្រាន់តែព្រាហ្មណ៍ចាស់សូត្រមន្តចប់ មហាជនផ្អើលឆោឡោរកដំបងព្រនង់ប្រុងវាយកូនទាំង ៤ នោះសម្លាប់ចោល ។ កូនព្រាហ្មណ៍ទាំង ៤ នាក់ភ័យខ្លាំងស្ទុះទៅក្រាបទៀបបាទាបិតា សូមខមាទោសរ៉ាប់រងទំនុកបំរុងដោយគោរពតទៅ កូនម្នាក់ៗ បានជូន

សំពត់ ១ គូនិងនិច្ចភត្តទៀត ។ ព្រាហ្មណ៍ចាស់កាលបើបានសុខហើយ នឹកឃើញគុណរបស់ព្រះសាស្តា ។ ទើបនាំយកសំពត់ ៣ គូនិងនិច្ចភត្តជាច្រើនទៅថ្វាយព្រះសាស្តា ៗ ទ្រង់ទទួលដោយសេចក្តីអនុគ្រោះ ។

## ៧. រឿងអាយលម្ពាយចាប់ពស់

( ចាក ម. វា. )

( គុណនៃព្រះរតនត្រ័យ ជាឱសថវិសេសផុតក្នុងលោក )

កាលសាសនាព្រះសម្ពុទ្ធព្រះនាមកស្សប ព្រះអង្គបរិនិព្វានហើយ, កាលនោះពួកពុទ្ធបរិស័ទនាំគ្នាសាងព្រះចេតិយមាសវិចិត្រដោយកែវ ៧ ប្រការកំពស់ ១ យោជន៍, មនុស្សទាំងឡាយក្នុងសម័យនោះច្រើនជាសម្មាទិដ្ឋិ តែងសូត្រធម៌រំឭកគុណព្រះរតនត្រ័យថា : នមោ ពុទ្ធាយ នមោ ធម្មាយ នមោ សង្ឃាយ ដូច្នេះគ្រប់ៗ គ្នា

កាលនោះមានព្រានម្នាក់ធ្វើអាយលម្ពាយចាប់ពស់ ជាមនុស្សមិច្ឆាទិដ្ឋិ ជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ ត្រេកអរតែក្នុងការចាប់ពស់ លុះចាប់បានហើយយកមកបង្រៀនឱ្យលេងល្បែងផ្សេងៗជូលឱ្យអ្នកនគរមើលយកថ្លៃឈ្នួលចិញ្ចឹមជីវិត ។ ថ្ងៃមួយអាយល-ម្ពាយឮពួកពុទ្ធបរិស័ទនាំគ្នាសូត្រថា : នមោ ពុទ្ធាយ ដូច្នេះ ក៏សើចចំអកធ្វើត្រាប់តាម ហើយដើរទៅរកចាប់ពស់ក្បែរជំបូកមួយ ។

គ្រានោះមាននាគរាជមួយ មានឫទ្ធិច្រើនជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ បានទៅបូជាគោរពព្រះចេតិយដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្ពុទ្ធព្រះនាមកស្សប, គោរពបូជាព្រះចេតិយហើយលូនត្រឡប់មកវិញ ក៏ជួបនឹងអាយលម្ពាយ ៗ ឃើញនាគរាជនោះស្ទុះចូលទៅជិតហើយរាយមន្តដើម្បីនឹងចាប់ ។ នាគរាជឮមន្តនោះហើយក៏កើតទោសៈក្រេវក្រោធ ស្ទុះដេញអាយលម្ពាយនោះវិញបំណងនឹងចឹកសម្លាប់ ។ អាយលម្ពាយដឹងថាជានាគរាជមិនស្តាប់មន្តខ្លួនហើយ ក៏ភិតភ័យជាខ្លាំងប្រឹងស្ទុះរត់គេចដោយរហ័ស មិនបានស្ញោកមើលក្រោម ក៏ទង្គិចជើងនឹងដុំថ្មដួលភ្លាត់មាត់ថា : នមោ ពុទ្ធាយ ៗ ព្រោះធ្លាប់មាត់កាលធ្វើត្រាប់អ្នកនគរ ។ ឯនាគរាជគ្រាន់តែឮថា នមោ ពុទ្ធាយ ដូច្នេះ ក៏រលត់បាត់នូវសេចក្តីក្រោធមួយរំពេចហាក់ដូចជាដុំភ្លើងធ្លាក់ចុះទៅក្នុងទឹក ទើបនិយាយទៅរកអាយលម្ពាយថា ម្នាលសំឡាញ់អ្នកកុំភិតភ័យអ្វីឡើយ យើងមានសេចក្តីជ្រះថ្លាចំពោះអ្នកក្រៃពេក សូមអ្នកទទួលយកគ្រឿងបណ្ណាការនេះចុះ ។ នាគរាជក៏ខ្ជាក់ផ្កាមាស ៣ ដុំពីក្នុងមាត់ឱ្យដល់អាយលម្ពាយ ហើយប្រាប់ថា ផ្កាមាសនេះ ១ ដុំតម្លៃ ១ ពាន់កហាបណៈ អ្នកយក ១ ដុំទៅបូជាព្រះចេតិយយកបុណ្យរបស់អ្នកចុះ ១ ដុំយកទៅបូជាព្រះចេតិយឱ្យខ្ញុំ ១ ដុំទៀតអ្នកយកទៅលក់យកលុយចិញ្ចឹមជីវិតចុះ។ អាយលម្ពាយក៏មានសេចក្តីជ្រះថ្លាចំពោះ

គុណព្រះរតនត្រ័យយ៉ាងមុតមាំ បានថ្វាយខ្លួនជាឧបាសកតាំងពីពេលនោះមក លុះស្លាប់ទៅបានទៅកើតក្នុងស្ថានសួគ៌ បរិបូណ៌ដោយទិព្វសម្បត្តិជាសុខក្សេមក្សាន្តអស់កាលជាយូរអង្វែង ។

## ៨. រឿងនាងអសិតាភូ

( ចាក អ. ទុ. )

( ប្រាថ្នាហួសហេតុ នាំឱ្យអន្តរាយ )

កាលកន្លងទៅហើយ មានព្រះរាជបុត្រព្រះចៅពារាណសីមួយព្រះអង្គ ព្រះរាជបិតាមិនគាប់ព្រះរាជហឫទ័យ ទ្រង់បំបរបង់ចាកព្រះរាជនិវេសន៍ បាននាំព្រះរាជទេពីរបស់ទ្រង់ព្រះនាមអសិតាភូ ចូលទៅនៅក្នុងព្រៃហេមពាន្ត សោយត្រីសាច់និងផ្លែឈើមើមឈើជាអាហារ ។ ព្រះនាងអសិតាភូ ជាព្រះទេពីខំគោរពប្រតិបត្តិបំរើដោយឥតមានធ្វេសប្រហែសឡើយ ។ ថ្ងៃមួយព្រះរាជបុត្រជាព្រះភស្តានាងបានឃើញកិន្នរីមានរូបឆោមល្អ ក៏លះបង់ចោលព្រះនាងខំស្វះស្វែងទៅតាមកិន្នរីនោះ ។ ព្រះនាងគិតថាឥឡូវនេះព្រះរាជបុត្រមិនអើពើនឹងអញ ស៊ូទៅតាមនាងកិន្នរីវិញ, លុះគិតហើយក៏ចូលទៅរកតាបសម្នាក់សុំរៀនចំរើនកសិណ មិនយូរប៉ុន្មានក៏ញ៉ាំងឈាននឹងអភិញ្ញាឱ្យកើតឡើង ទើបមកនៅក្នុងបណ្ណសាលារបស់ខ្លួនវិញ ។ ព្រះរាជបុត្រនោះ កាលបើរកផ្លូវទៅតាមនាងកិន្នរី

មិនឃើញហើយអស់សង្ឃឹមក៏ត្រឡប់មករកព្រះនាងវិញ។ ព្រះនាងអសិតាភូឃើញព្រះរាជបុត្រយាងមកវិញហើយ ក៏ហោះទៅឰដ៏អាកាសទៅនៅក្នុងទីដទៃទៀត ។ ព្រះរាជបុត្រកាលបើព្រះទេពីលះបង់លែងត្រូវការហើយក៏ខ្សឹកខ្សួលទូញយំសង្រេងសង្រៃថា :

អត្រិច្ឆំ អតិលោភេន អតិលោភមទេន ច
ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ។

សេចក្ដីថា : បុគ្គលដែលប្រាថ្នាហួសកំរិត ចង់បានខ្លាំងពេកព្រោះស្រវឹងងប់ដោយចំណង់ រមែងសាបសូន្យចាកប្រយោជន៍យ៉ាងណា ខ្ញុំឯងកាលប្រាថ្នា ក៏ទៅជាអ្នកសាបសូន្យចាកព្រះទេពីឈ្មោះអសិតាភូយ៉ាងនោះដែរ ។

ព្រះរាជបុត្រតាំងពីថ្ងៃនោះមក នៅក្នុងព្រៃតែម្នាក់ឯង លុះអំណើះឥតអំពីព្រះរាជបិតាទៅ បានសោយរាជ្យជាស្ដេចស្នងអង្គព្រះរាជបិតា ។ គ្រានោះមានទេវតាមួយអង្គ បានសូត្រគាថាថ្វាយជាព្រះសណ្ដាប់ថា :

អត្រិច្ឆំ អតិលោភេន អតិលោភមទេន ច
ឯវំ សោ ហាយតត្ថានំ ចន្ទំវ អសិតាភុយា ។

សេចក្ដីថា : បុគ្គលដែលប្រាថ្នាហួសកំរិត ចង់បានខ្លាំងពេកព្រោះស្រវឹងងប់ដោយចំណង់ បុគ្គលនោះរមែងញ៉ាំងប្រយោជន៍របស់ខ្លួនឱ្យសាបសូន្យយ៉ាងនេះ ដូចជាព្រះរាជបុត្រកាលប្រាថ្នានូវ

នាងកិន្នរីឈ្មោះចន្ទាហើយ ជាអ្នកសាបសូន្យចាកព្រះទេពីឈ្មោះអសិតាភូ ។

ព្រះរាជាទ្រង់អៀនខ្មាស ហើយតាំងព្រះទ័យលែងប្រព្រឹត្តយ៉ាងនោះតទៅទៀត ទ្រង់គ្រងរាជសម្បត្តិជាសុខក្សេមក្សាន្តដរាបទៅ ។

## ៩. រឿងខ្មោចយក្ខនិងក្មេងតូច

( ចាក ម. វា. )

( អានិសង្សនៃការរលឹកនូវពុទ្ធគុណ )

ក្នុងពុទ្ធសម័យ មានបុរសសម្មាទិដ្ឋិម្នាក់រកស៊ីកាប់ឧសលក់។ ថ្ងៃមួយបាននាំកូនតូចទៅកាប់ឧសជាមួយផង, ដល់ពេលល្ងាចបានឧសពេញរទេះហើយនាំកូនបរមកផ្ទះ ដល់ជិតនគរបានដោះគោលែងឱ្យស៊ីស្មៅ ហើយនាំកូនដេកលេងលើជីខ្ពស់ក្បែររទេះ។ ឯគោទាំងពីរដឹងថា ពេលល្ងាចហើយក៏នាំគ្នាដើរចូលទៅក្នុងនគរ ។ បុរសនោះដល់ពេលមកផ្ទះរកគោមិនឃើញ ក៏ឱ្យកូននៅចាំរទេះហើយដើរចូលទៅរកគោក្នុងនគរ, ពួកទ្វារបាលកាលបើដល់ពេលហើយក៏បិទទ្វារនគរទៅ, បុរសនោះពុំអាចចេញមកជួបនឹងកូនបានឡើយ ។ វេលាយប់នោះមានខ្មោចយក្ខពីររូបមួយសម្មាទិដ្ឋិ មួយមិច្ឆាទិដ្ឋិជាសំឡាញ់នឹងគ្នា នាំគ្នាទៅរកចំណីអាហារ ក៏បានឃើញ

ក្មេងតូចដេកនៅក្រោមរនេះ ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិនិយាយថាអញចាប់កុមារនេះស៊ីឥឡូវនេះ, ខ្មោចយក្ខសម្មាទិដ្ឋិនិយាយឃាត់ថា កុំអ្នកមិនត្រូវធ្វើយ៉ាងនេះទេ ព្រោះកុមារនេះតែងរលឹកដល់គុណព្រះពុទ្ធថា នមោ ពុទ្ធស្ស ដូច្នេះរាល់ពេលវេលាពុំដែលដាច់ ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិមិនស្តាប់ស្ទុះទៅចាប់បំរុងបរិភោគ, កុមារភ្ញាក់ឡើងភ្ញាត់មាត់ស្រែកថា "នមោពុទ្ធស្សៗ" ញាប់មាត់ដោយបុព្វចរិតដែលខ្លួនធ្លាប់សន្សំមកយូរហើយ ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិគ្រាន់តែឮនមោពុទ្ធស្សដូច្នោះ ក៏ភ័យតក់ស្លុតលែងកុមារនោះទៅវិញ ហើយថយមកឈរក្នុងទីឆ្ងាយ ។

កាលនោះខ្មោចយក្ខសម្មាទិដ្ឋិនិយាយបំភ័យថា អំពើដែលអ្នកធ្វើនេះមានទោសធំណាស់ ហាក់ដូចជាប្រមាទមើលងាយព្រះពុទ្ធ, អ្នកឯងត្រូវទទួលទណ្ឌកម្មទើបរួចទោស គឺអ្នកឯងត្រូវទៅរកអាហារមកឱ្យកុមារនេះបរិភោគឱ្យបានឆ្អែតស្កប់ស្កល់ទើបបាន ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិទទួលព្រមធ្វើតាម ទើបនិយាយផ្តាំនឹងសំឡាញ់ថា បើខ្ញុំទៅរកអាហារមិនទាន់ត្រឡប់មកដរាបណា អ្នកត្រូវរង់ចាំខ្ញុំដរាបនោះ ផ្តាំហើយក៏ចូលទៅក្នុងនគរ ដើររកអាហារទៅដល់ព្រះរាជដំណាក់ បានប្រទះឃើញភាជន៍មាសធំមួយ ដែលពេញដោយអាហារមានរសឆ្ងាញ់ អាហារនោះជាព្រះស្ងោយសំរាប់ព្រះបាទអជាតសត្រូវ ក៏យកទាំងភាជន៍មកឱ្យកុមារបរិភោគ មកជិតដល់បាន

បាននិម្មិតខ្លួនដូចជាបិតារបស់កុមារចាត់ចែងឱ្យកុមារបរិភោគដរាបដល់ឆ្អែត ហើយសរសេរអក្សរភ្ជាប់នឹងភាជន៍មាសថា "ពាក្យថាពុទ្ធំគឺកុមារកូនបុរសអ្នកលក់ឧសបានពោលហើយ សេចក្ដីព្យាយាមនេះគឺខ្ញុំបានធ្វើឱ្យជាទណ្ឌកម្ម " ហើយអធិដ្ឋានអក្សរនោះឱ្យបានស្ដេចទតកុំខាន ធ្វើដូច្នេះហើយខ្មោចយក្ខទាំងពីរក៏បបួលគ្នាចៀសចេញពីទីនោះទៅ ។ វេលាព្រឹកឡើងដល់ពេលព្រះមហាក្សត្រ នឹងសោយព្រះស្ងោយពួកព្រះរាជបំរើរកភាជន៍នោះពុំឃើញឡើយ កោលាហលក៏កើតឡើងក្នុងព្រះរាជដំណាក់ ទើបព្រះមហាក្សត្រចាត់រាជបុរសឱ្យស៊ើបដំណឹងរក, រាជបុរសបានទៅរកឃើញនៅក្នុងរទេះរបស់បុរសអ្នកលក់ឧសនោះ ក៏ចាប់កុមារដែលនៅចាំរទេះយកទៅថ្វាយស្ដេច ។ ពេលនោះព្រះមហាក្សត្របានទតឃើញអក្សរដែលខ្មោចយក្ខសរសេរភ្ជាប់នឹងភាជន៍មាសនោះហើយ ក៏មានព្រះទ័យសោមនស្សជ្រះថ្លាចំពោះកុមារ បានព្រះរាជទានទីជាសេដ្ឋីដល់កុមារនោះ ។

## ១០. រឿងសិរីលក្ខណព្រាហ្មណ៍

( ចាក ម. អ. )

( សិរីស្ថិតនៅបានតែលើមនុស្សមានបុណ្យ )

មានរឿងដំណាលថា ក្នុងក្រុងសាវត្ថីមានព្រាហ្មណ៍ម្នាក់ ឈ្មោះសិរីលក្ខណៈ ចេះក្បួនមើលសិរី ។ ថ្ងៃមួយព្រាហ្មណ៍នោះគិតថា អនាថបិណ្ឌិកសេដ្ឋី កាលពីដើមជាអ្នកទ័លក្រលំបាកណាស់ ឥឡូវនេះបានឡើងឋានៈជាមហាសេដ្ឋី មានទ្រព្យច្រើនព្រោះគាត់មានសិរី បើដូច្នោះអញទៅលួចយកសិរីគាត់ គិតដូច្នោះហើយក៏ទៅផ្ទះសេដ្ឋីមួយរំពេច សេដ្ឋីទទួលដោយរាក់ទាក់ ហើយសួរថា "អ្នកអញ្ជើញមកមានការអ្វី ព្រាហ្មណ៍នៅស្ងៀមខំរំពឹងរកមើលសិរីឋិតនៅទីណា លុះដឹងថានៅលើសិរ៍មាន់គក ក៏ឆ្លើយថា "បពិត្រសេដ្ឋីខ្ញុំមានការបន្តិច ព្រោះខ្ញុំជាអ្នកបង្រៀនមន្តមាណព ៥០០ នាក់ ត្រូវការរកមាន់រងាវត្រូវកាល ឮថាមាន់របស់លោករងាវត្រូវកាល ហេតុនេះសូមលោកឱ្យមាន់នេះដល់ខ្ញុំ សេដ្ឋីនិយាយថា ម្នាលព្រាហ្មណ៍អ្នកចូរយកចុះ, គួរអស្ចារ្យណាស់ សេដ្ឋីគ្រាន់តែហាមាត់ថាឱ្យយកចុះប៉ុណ្ណេះ សិរីក៏ឃ្លាតចេញអំពីសិរ៍មាន់មួយរំពេចទៅស្ថិតនៅលើកែវមណី ដែលសេដ្ឋីដាក់លើក្បាលដំណេក ព្រាហ្មណ៍ដឹងហេតុនោះភ្លាម ក៏សុំកែវមណីទៀត, ក្នុងខណៈដែលសេដ្ឋីថាយកចុះដូច្នេះ សិរីក៏ឃ្លាតចេញអំពីកែវមណីទៅនៅលើឈើច្រត់

ដែលសេដ្ឋីដាក់ក្បែរដំណេក. ព្រាហ្មណ៍ដឹងហេតុនោះភ្លាម ក៏សុំឈើច្រត់ទៀត សេដ្ឋីឱ្យទៀត. សិរីក៏ឃ្លាតចេញអំពីឈើច្រត់ទៅនៅលើក្បាលរបស់នាងបុញ្ញលក្ខណទេពី ជាជាយារបស់សេដ្ឋី ។ លុះព្រាហ្មណ៍ឃើញហេតុអស្ចារ្យយ៉ាងនេះហើយ ក៏គិតថា របស់នេះមិនអាចលះបង់ពីសេដ្ឋីបានទេ អញមិនអាចសុំបានឡើយ ទើបនិយាយប្រាប់សេដ្ឋីតាមត្រង់ថា ខ្ញុំមិនអាចលួចសិរីរបស់លោកបានទេ ។

ព្រោះហេតុនោះ សិរីអាចស្ថិតនៅបានតែលើមនុស្សមានបុណ្យ. តាមពិត សិរីគឺសម្បត្តិរបស់បុណ្យ ឬថាកំលាំងរបស់បុណ្យ បើបុគ្គលឥតបុណ្យហើយសិរីក៏គ្មានដែរ ។

បានជាព្រះសម្ពុទ្ធទ្រង់សំដែងមានក្នុងសិរីចោរជាតក តិកនិបាតថា :

> យំ ឧស្សុក្កា សង្ឃរន្តិ ពហុំ ធនំ
> សិប្បវន្តោ អសិប្បា វា លក្ខិវ តានិ ភុញ្ជតិ
> សព្វត្ថ កតបុញ្ញស្ស អតិច្ចញ្ញេវ បាណិនោ
> ឧប្បជ្ជន្តិ ពហូ ភោគា អប្បនាយតនេសុបិ ។

សេចក្ដីថា : ពួកជនអ្នកឥតបុណ្យ ទោះមានសិប្បៈក្ដី គ្មានក្ដីខ្វល់ខ្វាយប្រមូលនូវទ្រព្យច្រើនឯណា. អ្នកមានបុណ្យហ្នឹងតែងបរិភោគ ប្រើប្រាស់នូវទ្រព្យច្រើននោះ. ភោគៈទាំងឡាយច្រើន

តែងរំលងនូវពួកសត្វដទៃ កើតចំពោះតែបុគ្គលមានបុណ្យធ្វើហើយ កើតក្នុងទីគ្រប់អន្លើ ទោះបីក្នុងទីដែលមិនគួរក៏កើតមានដែរ ។

## ១១. រឿងសីហៈនិងជ្រូក

( ចាក សុ. ទុ. )

( ឃើញគេស្លូត កុំថាគេខ្លាចអន់ជាងខ្លួន )

កាលពីព្រេងនាយមានសីហៈមួយចាប់សត្វស៊ីឆ្អែតហើយ ចុះទៅផឹកទឹកក្នុងត្រពាំង ត្រឡប់ឡើងមកវិញឃើញជ្រូកមួយរកស៊ីនៅមាត់ត្រពាំង ។ សីហៈនោះនឹកថាថ្ងៃនេះអញស៊ីឆ្អែតហើយ ជ្រូកនេះទុកស៊ីទៅថ្ងៃស្អែត ទើបគេចទៅផ្លូវម្ខាង ជ្រូកឃើញដូច្នោះសំគាល់ថាសីហៈនោះខ្លាចខ្លួន ក៏ស្រែកសួរថា :

**ចតុប្បទោ អហំ សម្ម តុម្ហេ សម្ម ចតុប្បទោ**
**ឯហិ សីហ និវត្តស្សុ កិន្នុ ភីតោ បលាយសិ ។**

នែ! សំឡាញ់ យើងជាសត្វជើង ៤ សំឡាញ់ឯងក៏ជាសត្វជើង ៤ ដែរ. ម្នាលសីហៈ អ្នកចូរត្រឡប់មកវិញអ្នកខ្លាចខ្ញុំឬ? បានជារត់ទៅ ។

សីហៈឮហើយនិយាយសន្យាថា ចាំថ្ងៃក្រោយចុះសឹមយើងជួបគ្នា ជ្រូកមានគំនិតខ្លីសំគាល់ថាគេខ្លាចខ្លួន ក៏មានសេចក្ដីត្រេកអរត្រឡប់មកទីលំនៅវិញ ដំណាលប្រាប់ជ្រូកដទៃ ៗ ដែលជាមិត្ត

សំឡាញ់របស់ខ្លួន ។ ជ្រូកទាំងនោះបានស្តាប់ហើយភ័យស្លុតចិត្ត ទើបនាំគ្នាតិះដៀលជ្រូកនោះថា សំឡាញ់ឯងល្ងង់ណាស់ជាអ្នកនាំសេចក្តីវិនាសមកដល់មិត្តសំឡាញ់ ព្រោះគ្មានគំនិតមិនដឹងឧបាយរបស់សត្វសីហៈ ។ ជ្រូកនោះស្រាប់តែភ័យញ័រស្លុតស្មារតីស្រៀវខ្នង ទើបខំនិយាយប្រឹក្សានឹងមិត្តសំឡាញ់ថា : នឹងគិតធ្វើយ៉ាងណាឱ្យបានរួចខ្លួនពីសីហៈ ។ ពួកជ្រូកជាមិត្តសំឡាញ់ទាំងឡាយប្រាប់ឧបាយថា ធម្មតាសីហៈជាសត្វស្អាតមិនចូលចិត្តនឹងវត្ថុស្មោគគ្រោកទេ អ្នកឯងចូរដើរទៅដេកននៀលក្នុងរណ្តៅលាមក ឱ្យប្រឡាក់ពេញខ្លួនទៅ ទើបមិនធ្វើអន្តរាយដល់អ្នក ។ ជ្រូកនោះក៏ធ្វើតាមពាក្យគេពន្យល់ ដល់ថ្ងៃណាត់គ្នាក៏ទៅចាំសីហៈ មួយស្របក់សីហៈមកដល់ធុំខ្លិនស្អុយធន់មិនបានទើបនិយាយទៅរកជ្រូកថា :

អសុចិ បូតិលោមោសិ ទុគ្គន្ធោ វាយសិ សូករ
សចេ យុជ្ឈិតុកាមោសិ ជយំ សម្ម ទទាមិ តេ ។

ម្នាលសូករៈ អ្នកឯងក្រខ្វក់ មានរោមប្រឡាក់ដោយសំអុយធុំក្លិនខ្ទួរភាយៗ, ម្នាលសំឡាញ់បើអ្នកចង់ច្បាំងនឹងយើង ៗ ចាញ់អ្នកហើយ ឱ្យអ្នកឯងឈ្នះចុះខ្ពើមណាស់ សីហៈថាហើយក៏ទៅកាន់ទីដទៃទៀត ។

# ១២. រឿងនាងកល្យាណី

( ចាក លោ. ជា )

( បុរសថោកទាបច្រើនចាញ់បោកប្រាជ្ញាស្រី )

កាលព្រះសម្ពុទ្ធបរមគ្រូកំពុងសាងបារមីនៅឡើយ ទ្រង់សោយព្រះជាតិជាកូនសេដ្ឋីមានឈ្មោះថា ធនញ្ជយបណ្ឌិត ភរិយាឈ្មោះនាងកល្យាណី ជាស្ត្រីឆ្លាតមានប្រាជ្ញាច្រើន មានចរិយាមារ-យាទត្រឹមត្រូវល្អជាទីបំផុត ឯធនញ្ជយបណ្ឌិតនេះព្រះរាជាសព្វព្រះទ័យណាស់ សុំសេដ្ឋីយកធ្វើជាព្រះរាជបុត្រតាំងតែពីអាយុ ៧ ឆ្នាំ ។ ថ្ងៃមួយព្រះរាជាចាត់ប្រើឱ្យធនញ្ជយបណ្ឌិតទៅបង្ក្រាបសត្រូវក្នុងបច្ចន្តជនបទ ព្រះពោធិសត្វក៏ថ្វាយបង្គំលាមាតាបិតាហើយផ្តាំនាងកល្យាណីជាភរិយាឱ្យមើលទំនុកបំរុងមាតាបិតា និងថែរក្សាខ្លួនកុំឱ្យសត្រូវមើលងាយ ផ្តាំងស្រេចហើយក៏នាំសេនាទា-ហានចេញទៅ។ មានសេចក្តីដំណាលថា ក្នុងនគរនោះមានសេនា-បតីម្នាក់ ឈ្មោះឧជុកសេនាបតីជាសត្រូវនឹងព្រះពោធិសត្វ ។ កាលបើដឹងថាព្រះពោធិសត្វ ព្រះរាជាចាត់ឱ្យចេញទៅបង្ក្រាបសត្រូវបាត់ហើយនៅតែនាងកល្យាណី ក៏ហៅអ្នកប្រាជ្ញ៣ នាក់ជាសំឡាញ់របស់ខ្លួនមកប្រាប់ឱ្យទៅប្រលោមស្រឡាញ់នាងកល្យាណី ។ អ្នកប្រាជ្ញ ៣ នាក់នោះគឺឈ្មោះ សុទ្ធភលេយ្យបណ្ឌិត១, ឥន្ទារម្មណបណ្ឌិត១, អភយបណ្ឌិត១ ។

ឧជុកសេនាបតីនិយាយពន្យល់អ្នកប្រាជ្ញទាំង ៣ នាក់នោះថា ម្នាលបណ្ឌិត នាងកល្យាណីជាស្ត្រីក្មេងព្រាត់ប្តី ធម្មតាស្ត្រីក្មេងតែងបរិបូណ៌ដោយកាមតណ្ហាគៀវក្លា យើងត្រូវលួងលោមដោយកាមតណ្ហា ដើម្បីប្រកបមេថុន មុខជាបានសម្រេចដោយងាយ ។ អ្នកប្រាជ្ញទាំង ៣ នាក់និយាយថា : បពិត្រលោកម្ចាស់ ការណ៍នេះមិនងាយទេ ត្បិតនាងកល្យាណីមានបរិវារច្រើន មានគ្រឿងរក្សាការពារមាំមួន យើងខ្ញុំមិនអាចលួងលោមបានឡើយ ។ ឧជុកសេនាបតីថា មិនក្រទេងាយណាស់ ឯស្រីជាបរិវារ វាចង់បានទ្រព្យ បើយើងឱ្យទ្រព្យវាហើយ វានឹងជួយគិតការយើងបានសម្រេចដោយងាយ ។ អ្នកប្រាជ្ញ ៣ នាក់ស្តាប់សេចក្តីពន្យល់នេះហើយជឿថាងាយមែន ដល់វេលាថ្ងៃរសៀលស្លៀកខោអាវស្អាតបាត ដើរក្បែរកំពែងវាំងដើរទៅមកៗ ដើម្បីបង្ហាញខ្លួនឱ្យនាងកល្យាណីឃើញ ។ គ្រានោះនាងកល្យាណីអគ្គនារីរ័ត្នស្ថិតនៅលើប្រាសាទ បានឃើញអាការៈរបស់អ្នកប្រាជ្ញទាំង ៣ នាក់នោះប្លែកដូច្នោះ ក៏ប្រើស្ត្រីបំរើម្នាក់ដែលមានគំនិតត្រឹមត្រូវជិតដិតនឹងនាង ឱ្យចុះទៅស៊ើបការ តើអ្នកប្រាជ្ញទាំង៣ នាក់នោះមានការដូចម្តេច?។ ស្ត្រីបំរើចុះទៅឈរក្បែរកំពែងវាំងធ្វើអាការៈតាមសេចក្តីបង្គាប់របស់នាង ។ ឯអ្នកប្រាជ្ញទាំង៣ នាក់ឃើញស្ត្រីបំរើនោះហើយ ក៏ចូលទៅជិតនិយាយរាក់ទាក់ថាម្នាលប្អូនស្រី ម្ចាស់នាងប្រហែលជាអផ្សុកស្ងាត់ណាស់

ព្រោះធនេញ្ជយ្យបណ្ឌិតមិននៅ ចូរនាងប្រាប់បណ្ដាំបងដល់នាងកល្យាណីផង ថាបណ្ឌិតនៅមានទៀតមិនទាន់អស់ទេ កុំភ័យភិតអ្វីឡើយ និយាយដូច្នេះហើយក៏ដើរចៀសចេញទៅ ។ ស្ត្រីបំរើនាំពាក្យនោះទៅក្រាបទូលដល់នាងកល្យាណី ។ គិតថាអញនឹងបញ្ឆោតចាប់អ្នកប្រាជ្ញទាំង ៣ នេះឱ្យបាន ហើយក៏ហៅទាសកម្មកររបស់នាងទៅប្រាប់រឿងសម្ងាត់សព្វគ្រប់ ហើយបង្គាប់ឱ្យជីកអណ្ដូងជិតកំពែងវាំង ដាក់ផងថ្នឹងលៃឱ្យល្មមផងថ្នឹងរំលងផុតទៅខាងក្រៅកំពែងវាំងបាន និងឱ្យធ្វើរានលក់ទំនិញក្បែរអណ្ដូងនោះ ហើយឱ្យធ្វើសាលាពីរ សាលាមួយឱ្យលក់ថ្នាំឱសថ មួយទៀតឱ្យលក់គ្រឿងប្រដាប់ក្ដារមឈូស និងតុទូជាដើម ឱ្យធ្វើសាលាមួយទៀតខ្ពស់ផុតកំពែងវាំងសម្រាប់នាងអង្គុយលេងលំហើយ ។ ចាប់តាំងពីថ្ងៃនោះមក នាងកល្យាណីអត្តនារីរ័ត្ន កាលបើថ្ងៃរសៀលត្រជាក់ហើយ នាងស្អិតស្អាងកាយយ៉ាងល្អស្រស់ទៅអង្គុយលើសាលាខ្ពស់នោះ និយាយលេងសើចក្អាកក្អាយជាមួយស្ត្រីបរិវាររបស់នាង ។ ឯបណ្ឌិតទាំង ៣ នាក់កាលបើត្រឡប់ពីគាល់ព្រះមហាក្សត្រហើយក៏ដើរទៅក្បែរកំពែងវាំងជិតសាលាដែលនាងកល្យាណីអង្គុយ ។

បណ្ដាបណ្ឌិតទាំង ៣ នាក់នោះសុទ្ធាភលេយ្យបណ្ឌិតអត់ទ្រាំពុំបានដោយកាមតណ្ហាគ្របសង្កត់ខ្លាំង ក៏លួចដើរត្រឡប់មកវិញមិនឱ្យបណ្ឌិត ២ នាក់ដឹងឡើយ ។ កាលបើមកដល់ហើយក៏ចូលទៅជិត

កំពែងវាំងក្បែរអណ្តូងទឹក ឃើញនាងពលត្តីស្រីបំរើរបស់នាងកល្យាណីម្នាក់កំពុងដងទឹកក៏និយាយខ្សឹប ៗ និងស្ត្រីនោះថាម្នាលប្អូនស្រីនាងមកដងក្នុងវេលាយប់ដូច្នេះព្រោះអ្វី? ។ ស្ត្រីនោះប្រាប់តាមឧបាយរបស់នាងកល្យាណីថា បពិត្របណ្ឌិត ខ្ញុំនេះនាងកល្យាណីចាត់ឱ្យមកចាំលោក ដើម្បីជំរាបការស្ងាត់កំបាំង ។ សុន្ទរាលេយ្យបណ្ឌិត បានស្តាប់ពាក្យនោះហើយមានសេចក្តីរីករាយព្រឺព្រួចក្នុងចិត្តឥតឧបមា ព្រោះត្រូវចំណុចចិត្តរបស់ខ្លួន ទើបនិយាយទៅកាន់ស្ត្រីនោះថា ម្នាលប្អូនស្រីនាងអាចនាំបងចូលទៅក្នុងវាំង ដើម្បីប្រឹក្សាការសម្ងាត់ជាមួយនឹងនាងកល្យាណីបានឬ? ។ ស្ត្រីនោះនិយាយថា ឱ! លោកអើយការនេះពិបាកណាស់មិនងាយទេ ព្រោះមានអ្នកចាំទ្វារច្រើនសង្កាត់ណាស់ លុះត្រាតែខ្ញុំទៅនិយាយឱ្យត្រូវនឹងអ្នកទាំងនោះសិនទើបបាន ។ សុន្ទរាលេយ្យបណ្ឌិតស្តាប់ហើយនិយាយលួងលោមស្ត្រីនោះថា សូមប្អូនទៅគិតនឹងមនុស្សទាំងនោះឱ្យបងបានឬទេ? ។ ស្ត្រីនោះថាមិនងាយទេ ប៉ុន្តែខ្ញុំមានឧបាយមួយបើលោកព្រមតាមខ្ញុំប្រហែលចូលទៅបានងាយ គ្មានអ្នកណាដឹងឡើយ គឺខ្ញុំសង្កត់ដងថ្លឹងបង្វិលចេញទៅខាងក្រៅកំពែងវាំងវិញ បើលោកព្រមធ្វើតាមខ្ញុំ ចាំស្អែកពេលយប់សូមលោកអញ្ជើញមក ។ សុន្ទរាលេយ្យបណ្ឌិតថា បងត្រូវការតែយប់នេះឯង ចាំស្អែកមិនបានទេយូរណាស់ ។ ស្ត្រីនោះថា បើដូច្នេះឱ្យខ្ញុំធ្វើដូចម្តេចបានបើដង

ថ្នឹងនេះធ្ងន់ពេកខ្ញុំនឹងសង្កត់ម្នាក់ឯងពុំបានឡើយ បើលោកឱ្យប្រាក់មួយរយកហាបណៈមកខ្ញុំ ១ ទៅជូលបុរសស្និតស្នាលនឹងខ្ញុំឱ្យមកជួយសង្កត់។ សុន្ទរាលេយ្យបណ្ឌិតស្ដាប់ហើយត្រេកអរណាស់ ទើបយកឈ្នួតក្បាលខ្ចប់ប្រាក់មួយរយកហាបណៈបោះទៅស្ត្រីនោះ ១ និយាយថាសូមលោករង់ចាំខ្ញុំមួយស្របក់សិន កុំអញ្ជើញទៅណាឆ្ងាយ និយាយដូច្នេះហើយ ក៏ទៅកាន់សំណាក់នាងកល្យាណីជំរាបកិច្ចការសព្វគ្រប់ នាងកល្យាណីស្ដាប់បានសព្វអស់សេចក្ដីហើយប្រើទាសីនោះឱ្យទៅហៅបុរសមានកំឡាំងម្នាក់ មកបង្គាប់ថាអ្នកឯងត្រូវយកខ្សែចងដងថ្នឹងនោះឱ្យមាំហើយ យឹតលោតរំលងទៅខាងក្រៅកំពែងវាំងទាញខ្សែឱ្យដងថ្នឹងនោះទាប មកឱ្យអាពាលនោះវាតោងដងថ្នឹង ហើយអ្នកឯងល្បួងចងវាឱ្យជាប់មាំនឹងដងថ្នឹងស្រេចហើយ សង្កត់លើកឱ្យត្រឡប់ចូលមកក្នុងកំពែងវាំងវិញ កុំស្រាយវាឡើយ អ្នកឯងរត់មកប្រាប់អញឱ្យឆាប់ ។ បុរសនោះទៅធ្វើការជាមួយនាងទាសី តាមបង្គាប់របស់នាងកល្យាណីស្រេចហើយ ក៏រត់មកក្រាបទូលដល់នាង ។ ឯសុន្ទរាលេយ្យបណ្ឌិតកាលបើជាប់ចំណងនឹងដងថ្នឹងហើយ ក៏មានសេចក្ដីភិតភ័យញ័រញាក់សព្វខ្លួនប្រាណ សម្ងំនៅស្ងៀមឥតមាត់កឡើយ ។ ឯនាងកល្យាណីអគ្គនារីរ័ត្ន កាលបើបុរសនិងទាសីក្រាបទូលហើយក៏បង្គាប់ថា ទុកវាចោលនៅទីនោះ ហើយកុំអាលស្រាយវា ចាំព្រឹកឡើងអ្នកទៅប្ដឹង

មហាមាត្យថា ល្ងាចមិញចោរទៅលួចដងទឹកអណ្តូងចាប់បានចង ភ្ជាប់នឹងដងថ្លឹង សូមលោកទៅពិនិត្យមើលធ្វើទោសឱ្យតាមច្បាប់ ។ លុះដល់ព្រឹកឡើងមនុស្សទាំងឡាយនាំគ្នាមកគឹកកង ឯបណ្ឌិតពីរ នាក់ទៀតគឺ ឥដ្ឋារម្មណបណ្ឌិត និងអភយបណ្ឌិតបានទៅមើល ឃើញសុទ្ធាភលេយ្យបណ្ឌិតជាប់ចំណងដូច្នោះ មានសេចក្តីអៀន ខ្មាសគេចចេញទៅ ចំណែកខាងបុរសបំរើនាងកល្យាណីបានទៅ ប្តឹងមហាមាត្យ ។ ចាត់អ្នករាជការទៅឃើញសុទ្ធាភលេយ្យបណ្ឌិត ក៏មកជំរាបមហាមាត្យវិញ មហាមាត្យដឹងថាសុទ្ធាភលេយ្យបណ្ឌិត ដូច្នោះ ក៏យកសេះជិះយ៉ាងលឿនទៅដល់ទីនោះមួយរំពេច សួរថា នែលោកបណ្ឌិតចុះហេតុអ្វីបានជាមកធ្វើយ៉ាងនេះមិនគួរសោះ ។ សុទ្ធាភលេយ្យបណ្ឌិតនៅស្ងៀម រកឆ្លើយថាដូចម្តេចមិនកើត ចេះតែ ឈ្ងោកធ្មេចភ្នែក ទើបមហាមាត្យប្រាប់បុរសបំរើឱ្យទៅទូលដល់ព្រះ នាងកល្យាណីថា សុំដោះលែងសុទ្ធាភលេយ្យបណ្ឌិត នាងកល្យាណី ស្តាប់ហើយនាងចេញពីប្រាសាទ ទៅកាន់សាលាក្បែរអណ្តូងមាន ព្រះសុវណ្ណីយថា បពិត្រមហាមាត្យតាមតែលោកពិចារណាតាម ច្បាប់ចុះ ហើនាងស្តីបន្ទោសតិះដៀលដល់សុទ្ធាភលេយ្យបណ្ឌិត យ៉ាងធ្ងន់អស្ចារ្យក្នុងកណ្តាលទីប្រជុំ ។ មហាមាត្យដោះលែងសុទ្ធាភ លេយ្យបណ្ឌិតពីដងថ្លឹងនាំទៅថ្វាយព្រះមហាក្សត្រ ។ ទតឃើញ ហើយត្រាសសួរថា ម្នាលសុទ្ធាភលេយ្យបណ្ឌិត អញសំគាល់ថាឯង

គ្រាន់បើ ចុះហេតុអ្វីបានជាឯងធ្វើយ៉ាងនេះ ឯងចង់ចូលទៅប្រលោមនាងកល្យាណីឬ? ។ សុន្ទរាលេយ្យបណ្ឌិតទូលត្រង់ថាពិតមែន សូមមហារាជទ្រង់ព្រះមេត្តាព្រះរាជទានអភ័យទោស ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយទ្រង់ខ្វាល់ជាខ្លាំង មានព្រះរាជឱង្ការថា អាចង្រៃព្រហើន អាឯងហ៊ានទៅប្រលោមស្រឡាញ់កូនប្រសារអញ ។ សុន្ទរាលេយ្យបណ្ឌិតក៏ភ័យញ័រខ្លួនថ្វាយបង្គំលាយកកន្សែងទទូជិតក្បាលរត់ទៅ ។

ដល់ព្រឹកឡើងឥន្ទារម្មណបណ្ឌិតគិតថា សុន្ទរាលេយ្យបណ្ឌិតល្ងង់មិនឆ្លាតបានជាឱ្យគេចាប់បាន ចាំអញទៅម្ដងប្រលោមនាងកល្យាណីឱ្យបានដូចប្រាថ្នា ។ លុះដល់ថ្ងៃរសៀលក៏ដើរទៅក្បែរសាលានាងកល្យាណី ធ្វើអាការៈទៅមក ៗ នាងកល្យាណីឃើញហើយគិតថា អញចាប់ចងបណ្ឌិតនេះមួយទៀត ក៏ដើរចូលទៅក្នុងប្រាសាទប្រាប់នាងពលក្ដីស្រីបំរើដូចពេលមុន នាងពលក្ដីក៏ចុះទៅជួបនឹងឥន្ទារម្មណបណ្ឌិត និយាយការឱ្យពាក្យសំដីល្មមបណ្ឌិតនោះទុកចិត្ត ឯបណ្ឌិតនោះកាលបើទុកចិត្តជឿនាងពលក្ដីហើយក៏សួរថា នាងជួយរកឧបាយធ្វើដូចម្ដេចឱ្យបងចូលទៅស្រួល នាងថាបើលោកតាមខ្ញុំ ៗ ជួយឱ្យកើតការ ប៉ុន្តែលោកត្រូវឱ្យលុយខ្ញុំមួយរយកហាបណៈ យកទៅជួលគេជីករណ្ដៅទម្លុះកំពែងវាំង លុះជីកហើយ លោកចូលចេញតាមប្រហោងរណ្ដៅនោះបានស្រួល ឥត

មានអ្នកណាដឹងឡើយ ម្យ៉ាងទៀតសូមលោកកុំប្រញាប់ ចាំស្ដែក ល្ងាចសុំអញ្ជើញមក ។ ឥន្ទារម្មណបណ្ឌិតយល់ថាស្រួលមែន ក៏ឱ្យលុយមួយរយកហាបណៈទៅនាងពលត្ថិ ។ ក៏ចូលទៅក្រាបទូលដល់នាងកល្យាណី ។ ចាត់ឱ្យមនុស្សជីករូងទម្លុះកំពែងវាំង ឱ្យយកកន្ទេលគ្របជិតហើយ ឱ្យបុរសពីរនាក់នៅក្នុងរណ្ដៅពីរនាក់ទៀតពួនចាំខាងក្រៅ ឱ្យចាំចាប់ឥន្ទារម្មណបណ្ឌិត ចងស្លាបសេករុំកន្ទេលយកទៅចងនឹងសរសរខឿនកណ្ដាលព្រះនគរ ត្រង់ផ្លូវបំបែកជាបួន ។ មនុស្សទាំងនោះក៏ចាត់ចែងរៀបចំតាមបង្គាប់នាង ។ លុះដល់ពេលព្រលប់ឥន្ទារម្មណបណ្ឌិតមកដល់ នាងពលត្ថិឈរចាំក្បែរមាត់រូងប្រាប់ថា រូងផ្លូវគេធ្វើស្រេចហើយ សូមលោកអញ្ជើញចូលប្រញាប់ចុះ ។ ឥន្ទារម្មណបណ្ឌិតត្រេកអរណាស់ នឹកថាអញដើរតាមឧបាយនាងពលត្ថិនេះស្រួលហើយ មិនដូចសុទ្ធាភោជ្យបណ្ឌិត ឱ្យគេចាប់ចងភ្ជាប់នឹងដងថ្នឹងនោះទេ, កំពុងតែដើរចូលទៅក្នុងរូងបានពាកកណ្ដាល បុរសពីរនាក់នៅក្នុងរូងចាប់ជាប់យកខ្សែចងស្លាបសេក បុរសពីរនាក់ទៀតយកកន្ទេលរុំហើយទៅទូលដល់នាងកល្យាណី ។ ចុះពីប្រាសាទឱ្យទាសីអុជប្រទីបភ្លឺព្រោងព្រាតមើលមុខឥន្ទារម្មណបណ្ឌិត ហើយស្ដីបន្ទុះបង្អាប់អស់ចិត្ត ដល់យប់ស្ងាត់ឱ្យបុរស ៤ នាក់នាំយកទៅចងភ្ជាប់នឹងសរសរខឿនកណ្ដាលព្រះនគរត្រង់ផ្លូវបំបែកជា ៤ ដល់ព្រឹកឡើងមហាជនបានឃើញ

ហើយផ្ទើលឆោឡោទៅប្ដីងមហាមាត្យ ៗ មកពិនិត្យស្រាយកន្ទេល មើលឃើញឥដ្ឋារម្មណបណ្ឌិត សួរដឹងហេតុសព្វគ្រប់នាំទៅថ្វាយព្រះមហាក្សត្រ ៗ ត្រាស់សួរថា ហេតុអ្វីបានជាអ្នកឯងជាប់ចំណងបណ្ឌិតនោះក្រាបទូលតាមត្រង់ថា ទោសដែលជាប់ចំណងនេះមកពីនាងកល្យាណី ។ ព្រះមហាក្សត្រត្រាស់សួរបញ្ជាក់ថា អ្នកឯងទៅប្រលោមស្រឡាញ់នាងកល្យាណីឬ? បណ្ឌិតនោះក្រាបទូលថាពិតមែន ។ ព្រះមហាក្សត្រទ្រង់ខ្ញាល់ដេញឱ្យចេញពីទីនេះឱ្យឆាប់ ។ ឥដ្ឋារម្មណបណ្ឌិតមានសេចក្ដីខ្មាសអៀនខ្លាំង យកសំពត់ទទូក្បាលរត់ចេញទៅ ។

ដល់ថ្ងៃក្រោយទៀតអភយបណ្ឌិតគិតថា បណ្ឌិតពីរមិនឆ្លាតចង់ស្រីប៉ុណ្ណេះមិនបាន ចាំអញម្ដង គិតដូច្នេះហើយដល់ពេលរសៀល ស្លៀកពាក់ខោអាវស្អាតបាតទៅក្បែរសាលានាងកល្យាណីនាវីវត្តធ្វើអាការៈទៅមក ៗ ។ នាងកល្យាណីឃើញហើយ ក៏ប្រើបំរើឱ្យទៅហៅពាណិជអ្នកលក់ក្ដារមឈូសទាំង៤ នាក់ឱ្យចូលគាល់ហើយនាងបង្គាប់ពាណិជថា អ្នកទាំងឡាយដ៏ចំរើន អ្នកអាចឱ្យអភយបណ្ឌិតចូលទៅក្នុងក្ដារមឈូស បានដោយឧបាយបែបណាអ្នកត្រូវធ្វើដោយឧបាយនោះចុះ កាលបើបានចូលទៅក្នុងក្ដារមឈូសហើយ ត្រូវបិទឱ្យជិតសែងយកមកក្នុងវាំង ហើយមកប្រាប់យើង ។ អ្នកលក់ក្ដារមឈូសទាំង ៤ នាក់ទូលថាអាចធ្វើបានដោយ

ងាយ ក៏ថ្វាយបង្គំលានាងចេញទៅគួរសមរាក់ទាក់នឹងអភយ-
បណ្ឌិត ។ ឃើញជនទាំង៤ ស្និទ្ធស្នាលនឹងខ្លួនល្មមទុកចិត្តបានហើយ
ក៏និយាយការសម្ងាត់ជាមួយថា ម្នាលអ្នកដ៏ចំរើនអ្នកអាចនាំខ្ញុំទៅ
ជួបជាមួយនាងកល្យាណីបានឬ? ជនទាំង ៤ នាក់ថាការចូលទៅ
ពិបាកណាស់ ព្រោះមានអ្នកយាមទ្វារច្រើនកន្លែង ប៉ុន្តែខ្ញុំតែងយក
ក្តារមឈូសទៅទុកក្នុងវាំង បើលោកព្រមធ្វើតាមខ្ញុំអាចចូលទៅ
ងាយ លោកឱ្យខ្ញុំតែមួយរយកហាបណៈម្នាក់បានហើយ ខ្ញុំយកទៅ
គិតគូរនឹងអ្នកដែលស្និទ្ធស្នាលនឹងនាងកល្យាណី ។ អភយបណ្ឌិតឮ
ជនទាំង ៤ នាក់និយាយឱ្យន័យដូច្នោះមានសេចក្តីត្រេកអរណាស់
យកលុយ ៤ រយកហាបណៈឱ្យភ្លាម ។ ជនទាំង ៤ នាក់ប្រាប់តាម
ឧបាយនាងកល្យាណីថា លោកត្រូវចូលទៅដេកក្នុងមឈូសសម្ងំឱ្យ
ស្ងៀម ខ្ញុំទាំង ៤ នាក់គ្របឱ្យជិត ហើយនាំគ្នាសែងចូលទៅក្នុងវាំង
លុះចូលទៅដល់ហើយ ខ្ញុំទៅជំរាបនាងកល្យាណីឱ្យចុះមកជួបនឹង
លោក ។ អភយបណ្ឌិតទទួលព្រមថាឧបាយនេះស្រួលហើយ ខ្ញុំតាម
ទាំងអស់ ។ ជនទាំង ៤ នាក់ ក៏នាំទៅក្នុងផ្ទះឱ្យចូលទៅដេកក្នុង
ក្តារមឈូស លុះដេកហើយយកក្តារគម្របគ្របចងយ៉ាងជិត សែង
ចូលទៅក្នុងវាំង យកទៅដាក់ក្បែរប្រាសាទ ទើបទៅទូលដល់នាង
កល្យាណី ។ ចុះមកឱ្យបុរសយកដែកគោលវាយយ៉ាងជិត ហើយតិះ
ដៀលស្តីបណ្តុះបង្អាប់យ៉ាងអស្ចារ្យ ដល់វេលាជិតភ្លឺឱ្យបុរស ៤ នាក់

សែងយកទៅដាក់ក្បែរសួនមុខវាំង ដល់ភ្លឺច្បាស់មហាជនប្រុសស្រី ដើរទៅមកឃើញក្ដារមឈូស ក៏នាំគ្នាផ្អើលស្រែកឆោឡោឡាន់ឮទ្រហឹងថា អ្នកណាយកខ្មោចមកចោលនៅមុខវាំងនេះ យើងទាំងឡាយត្រូវនាំគ្នាសែងយកទៅដុត អភយបណ្ឌិតឮថាគេយកទៅដុតដូច្នោះ ភ័យណាស់ខំរើបំរាស់យ៉ាងខ្លាំង ប៉ុន្តែមិនអាចធ្វើក្ដារមឈូសនោះឱ្យរបើកឡើយ ។ មហាជនឮសូររើបំរាស់ដូច្នោះដឹងច្បាស់ថាខ្មោចនេះនៅរស់ទេ ក៏នាំគ្នាគាស់ក្ដារមើលឃើញអភយបណ្ឌិតដេកផ្កាធ្វើមុខក្រៀមស្ងួរមិននិយាយ រាជបុរសក៏នាំទៅថ្វាយស្ដេច ។ ព្រះរាជាត្រាស់សួរថាហេតុអ្វីអ្នកឯងធ្វើយ៉ាងនេះ, អភយបណ្ឌិតឆ្លើយទូលតាមពិតថាមកពីនាងកល្យាណី ។ ព្រះរាជាត្រាស់សួរបញ្ជាក់ទៀតថា អ្នកឯងទៅប្រលោមស្រឡាញ់នាងកល្យាណីឬ? ក្រាបទូលពិតមែន ។ ព្រះរាជាទ្រង់ខ្ញាល់ដេញឱ្យចេញពីទីនោះឆាប់ ។ អភយបណ្ឌិតយកសំពត់ទទូក្បាលរត់ទៅ លែងហ៊ានដើរចេញវាលមិនឱ្យអ្នកណាឃើញឡើយ ។ ចាប់ដើមពីថ្ងៃនោះមកឧជុកសេនាបតីដែលជាសត្រូវនឹងព្រះពោធិសត្វ គិតពិចារណាថាបណ្ឌិត ៣ នាក់អប្បឥតប្រាជ្ញាឱ្យស្រីបោកបាន បើដូច្នោះអញទៅចែចង់យកនាងកល្យាណីឱ្យបាន គិតដូច្នេះហើយដល់វេលាថ្ងៃរសៀល ក៏ជិះដំរីទៅចុះក្បែរសាលានាងកល្យាណី ដើរមើលផ្សារដែលនាងកល្យាណីឱ្យឈ្នួញលក់ឥវ៉ាន់ ។ ពេលនោះនាងកល្យាណី

កំពុងអង្គុយលើសាលា នាងឃើញអាការៈរបស់សេនាបតីប្លែក ទើបនាងធ្វើជាសើចក្អាកក្អាយជាមួយពួកឈ្នួញថ្លែងអាការៈ ហាក់ដូចជាត្រូវការនឹងសេនាបតី មួយស្របក់នាងចូលទៅក្នុងប្រាសាទបាត់ទៅ ។ ឯឧដុកសេនាបតីបានឃើញរូបនាង និងអាការៈរបស់នាង ក៏មានសេចក្តីស្នេហាយ៉ាងក្រៃលែង សួរពួកឈ្នួញថាមានលក់ខ្លឹមចន្ទន៍ក្រហមទេ? ឈ្នួញថាមាន. បើមានស្អែកយកទៅឱ្យខ្ញុំឯផ្ទះទាំងអស់ ។ ឧដុកសេនាបតីដែលឱ្យឈ្នួញយកខ្លឹមចន្ទន៍ទៅឱ្យឯផ្ទះខ្លួននោះ ដើម្បីនិយាយឱ្យជួយគិតការប្រលោមនាងកល្យាណី ។

ដល់ព្រឹកឡើងនាងកល្យាណីហៅឈ្នួញទៅសួរដឹងរឿងសព្វគ្រប់ នាងប្រាប់ឧបាយថា : ថ្ងៃបន្តិចអ្នកឯងយកខ្លឹមចន្ទន៍ទៅលក់ឱ្យសេនាបតី ហើយប្រាប់ថានាងកល្យាណីប្រហែលជាត្រូវការនឹងលោកបានជាក្នុងពេលដែលលោកអញ្ជើញទៅរកខ្លឹមចន្ទន៍ នាងមានសេចក្តីរីករាយសើចក្អាកក្អាយក្នុងទីចំពោះមុខលោក បើអ្នកនិយាយដូច្នេះ សេនាបតីមុខតែពឹងឱ្យអ្នកជួយគិតការដើម្បីអញ្ញពុំខាន អ្នកត្រូវប្រាប់ថាអ្នកប្រាជ្ញ ៣ នាក់មុនបានជាមានទោសគេចាប់ទៅថ្វាយស្តេច ព្រោះទៅគិតការនឹងបរិវាររបស់នាងកល្យាណី បើសិនជាគិតនឹងខ្ញុំបានសម្រេចដោយងាយ អ្នកត្រូវប្រាប់ថាបើលោកឱ្យខ្ញុំជួយគិតលោកត្រូវតាមខ្ញុំទាំងអស់ ព្រោះនាងកល្យាណីតែង
១ យាងមកលេងក្នុងបន្ទប់ខ្ញុំ ចំណែកលោកត្រូវទៅផ្ទះខ្ញុំពីព្រលឹម កុំឱ្យ

អ្នកណាឃើញ ទៅដល់ខ្ញុំឱ្យលោកចូលទៅនៅក្នុងហិបខាងក្នុងបន្ទប់ ដល់នាងកល្យាណីចូលទៅក្នុងបន្ទប់លោកបើកហិបចេញមកជួបគ្នាហើយ ធម្មតាស្ត្រីក្មេងឥតប្តីយូរថ្ងៃបានជួបនឹងបុរសក្នុងទីស្ងាត់តែពីរនាក់ឥតប្រកែកអ្វីឡើយ ។ ឧជុកសេនាបតីជាមនុស្សមានរាសីទន់ កាលបើឈ្មួញយកខ្លឹមចន្ទន៍ទៅឱ្យនិយាយតាមឧបាយនាងកល្យាណីបង្គាប់ហើយ មានសេចក្ដីត្រេកអរក្រៃលែងយកលុយឱ្យឈ្មួញមួយរយកហាបណៈថែមលើថ្លៃខ្លឹមចន្ទន៍ទៀត។ ឈ្មួញត្រឡប់មកផ្ទះទៅទូលនាងកល្យាណីថាបានការហើយ នាងប្រាប់ថែមទៀតថា បើវាចូលទៅក្នុងហិបហើយបិទចាក់សោឱ្យជាប់មកប្រាប់ខ្ញុំ ៗនឹងឱ្យបុរសសែងដើរតាមក្រោយខ្ញុំយកទៅថ្វាយស្ដេច ។ ចំណែកឧជុកសេនាបតីកាលបើដល់ព្រឹកហើយ ក៏រៀបចំខ្លួនប្រាណដើរចូលទៅក្នុងផ្ទះឈ្មួញឥតឱ្យអ្នកណាដឹងឡើយ ទៅដល់ឈ្មួញថ្លែងអាការៈគួរសមនាំចូលទៅក្នុងបន្ទប់ បើកហិបឱ្យចូលទៅអង្គុយស្រួលបួលបិទគ្របសង្កត់ជាប់ចាក់សោហើយ រត់ទៅអញ្ជើញនាងកល្យាណី ៗយាងមកឥតឮមាត់ឡើយ ឱ្យបុរស ៤ នាក់សែងដើរតាមក្រោយនាងចូលទៅកាន់ព្រះរាជមន្ទីរ ។ ពេលនោះព្រះរាជាកំពុងប្រឹក្សាការជាមួយនាហ្មឺនមុខមន្ត្រីគ្រប់ក្រសួង បាត់តែឧជុកសេនាបតីមួយស្រាប់តែនាងកល្យាណី និងបុរស ៤ នាក់សែងហិបចូលទៅ ដាក់ហិបកណ្ដាលទីប្រជុំ។ ព្រះរាជាទតឃើញហើយត្រាស់សួរថា ម្នាល

នាងដ៏ចំរើនមានការអ្វី ? ហិបនេះដាក់អ្វី? នាងកល្យាណីទូលថា ហិបនេះដាក់ចោរ ។ ព្រះរាជាត្រាស់សួរថានាងបានឃើញចោរឈ្មោះអ្វី? ក្រាបទូលមិនឃើញទេ ។ ព្រះរាជាឱ្យរាជបុរសចាក់សោបើកឡើង ឃើញឧដុកសេនាបតីអង្គុយឈ្ងោកធ្មេចភ្នែក ព្រះរាជាទ្រង់ក្រោធពិរោធស្តីតិះដៀលថា នែអាពាលចង្រៃអាឯងខូចណាស់ប្រាកដជាទៅមើលងាយកូនប្រសារអញហើយ ។ ឧដុក-សេនាបតីទាល់ប្រាជ្ញនៅស្ងៀម ទើបនាងកល្យាណីអគ្គនារីរ័ត្ន ទូលតាមដំណើររឿងសព្វគ្រប់តាំងពីរឿងបណ្ឌិត ៣ នាក់មក ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ ហើយត្រាស់បង្គាប់ឱ្យរាជបុរសទៅហៅបណ្ឌិត៣នាក់មកសួរ. បណ្ឌិតទាំង ៣ ឆ្លើយថាដែលទូលព្រះបង្គំភ្លាត់គំនិតធ្លាក់ខ្លួនទៅមានទោស ក៏មកតែអំពីឧដុកសេនាបតីនេះឯងជាអ្នកពន្យល់ដឹកនាំ ។ ព្រះរាជាទ្រង់ក្រោធពិរោធជាខ្លាំងបន្លឺព្រះសូរសីហនាទកណ្ដាលទីប្រជុំថា ឧដុកៈនេះលាមកអាក្រក់បំផុតក្នុងលោកអញលែងត្រូវការសេពគប់ជាមួយហើយ នាយពេជ្ឈឃាតចូរយកច្រវាក់មកទាក់កអាពាលទាំង ៤ នេះយកទៅចងទុកក្នុងគុកចាំធនេញ្ឈយ្យបណ្ឌិតកូនអញមក អញនឹងធ្វើទោសជាទម្ងន់ ។

ឯនាងកល្យាណីអគ្គនារីរ័ត្ន ស្ដាប់ព្រះរាជឱង្ការហើយត្រាស់តបវិញថា : បពិត្រព្រះភូមិន្ទ្រ ទោសរបស់ជនទាំង ៤ នាក់នេះគួរណាស់តែខ្ញុំព្រះអង្គសូមទោស ប៉ុន្តែបើខ្ញុំព្រះអង្គសូមទៅ ព្រះអង្គក្តី

ស្វាមីខ្ញុំព្រះអង្គក្តីនឹងរង្កៀសចិត្តចំពោះខ្ញុំព្រះអង្គថា ប្រហែលជាប្រព្រឹត្តអនាចារជាមួយជនទាំង ៤ នាក់នេះ បានជាមានចិត្តមេត្តាសូមទោសឱ្យ ព្រោះហេតុនេះខ្ញុំម្ចាស់មិនសូមទោសដល់ជនទាំង ៤ នាក់នេះទេ ។ ព្រះនាងកល្យាណីថ្វាយបង្គំលាព្រះរាជបិតា ត្រឡប់ទៅលំនៅរបស់ព្រះនាងវិញ ។

ចំណែកខាងជនទាំង ៤ នាក់គឺ ឧជុកសេនាបតី១, សុទ្ធរាលេយ្យបណ្ឌិត១, ឥន្ទារម្មណបណ្ឌិត១, អភយបណ្ឌិត១, ពិជ្ឈឃាតបាននាំយកទៅដាក់ក្នុងគុក ដល់នូវសេចក្តីទុក្ខវេទនាក្នុងកាលនោះឯង ។

រឿងនេះសង្ខេបតែប៉ុណ្ណោះ ដើម្បីជាទិដ្ឋានុគតិបំភ្លឺឱ្យឃើញច្បាស់ថា ភ្លើងរាគៈតែងដុតកំឡោចសត្វ ដែលល្ងង់ឥតអប្បបញ្ញា, ដែលស្រវឹងងប់ក្នុងកាមរាគ, ដែលប្រព្រឹត្តអបាយមុខ, ដែលលង់កំនិតទៅក្នុងស្ត្រីភាព, ដែលមានចំណង់គ្របសង្កត់ស៊ប់ ឱ្យវិនាសអន្តរាយចាកយសស័ក្តិ, ទ្រព្យសម្បត្តិ និងប្រយោជន៍ក្នុងលោកទាំងពីរដោយពិតដូចរឿងរ៉ាវដែលបាននាំមកសំដែងនេះឯង ។

# ១៣. រឿងសោមទត្តព្រាហ្មណ៍

( ចាក ម. វា. )

( គុណនៃការបូជាប្រយោជន៍ ចំពោះមិត្តសំឡាញ់ )

កាលព្រះសម្ពុទ្ធបរមគ្រូ ព្រះអង្គបរិនិព្វានទៅយូរហើយ ក្នុងក្រុងសាវត្ថីមានព្រាហ្មណ៍ពីររូបឈ្មោះសោមព្រាហ្មណ៍១, សោម-ទត្តព្រាហ្មណ៍១ ជាសំឡាញ់នឹងគ្នា ។ ព្រាហ្មណ៍ទាំងពីររូបនេះជាអ្នកចូលចិត្តលេងបាស្កាភ្នាល់គ្នាដាក់គ្រឿងអលង្ការ និងសំលៀកបំពាក់ ។ ថ្ងៃមួយសោមព្រាហ្មណ៍លេងចាញ់ ត្រូវបានសំលៀកបំពាក់ និងចិញ្ចៀនទៅសោមទត្តព្រាហ្មណ៍ទាំងអស់ នៅសល់តែខោខ្លីមួយ ក៏មិនហ៊ានទៅផ្ទះខ្លាចប្រពន្ធរករឿងឈ្លោះប្រកែក ។ ឯសោមទត្តព្រាហ្មណ៍ កាលបើដល់ពេលទៅផ្ទះ ក៏បបួលសោម-ព្រាហ្មណ៍ទៅផ្ទះ សោមព្រាហ្មណ៍ប្រកែកមិនព្រមទៅដាច់អហង្ការ ទើបសោមទត្តព្រាហ្មណ៍សួរថា ម្នាលសំឡាញ់ហេតុអ្វីបានជាអ្នកមិនទៅផ្ទះ អ្នកឈឺចិត្តនឹងលេងចាញ់ខ្ញុំឬ? សោមព្រាហ្មណ៍ថាមិនមែនឈឺចិត្តដូចសំឡាញ់ទេ ប៉ុន្តែប្រពន្ធខ្ញុំបើមិនឃើញចិញ្ចៀនពាក់នៅដៃខ្ញុំទេមុខជានឹងរករឿងឈ្លោះនឹងខ្ញុំជាប្រាកដ ខ្ញុំមិនចង់ឱ្យមានការឈ្លោះប្រកែក បានជាខ្ញុំមិនព្រមទៅផ្ទះ ។ សោមទត្ត-ព្រាហ្មណ៍ឮដូច្នោះហើយ ក៏ឱ្យសំលៀកបំពាក់ និងចិញ្ចៀនទៅសោមព្រាហ្មណ៍វិញ ហើយនាំគ្នាទៅផ្ទះរៀងខ្លួនទៅ ។

ចំណែកសោមទត្តព្រាហ្មណ៍ជាមនុស្សខិលខូច ប្រព្រឹត្តកាមេសុមិច្ឆាចារនឹងកូនប្រពន្ធអ្នកដទៃ ព្រះរាជាបានទទួលបណ្ដឹងអំពីអ្នកប្ដឹង ហើយចាត់ឱ្យរាជបុរសទៅចាប់ខ្លួនសោមទត្តព្រាហ្មណ៍មកធ្វើទោស លុះសោមទត្តព្រាហ្មណ៍មកដល់ ព្រះរាជាទតឃើញរូបភាពជាមនុស្សខ្ពង់ខ្ពស់ ហើយទ្រង់រំលឹកប្រដៅឱ្យឈប់ធ្វើអំពើនោះទៀត ទ្រង់លែងឱ្យរួចខ្លួនត្រឡប់ទៅផ្ទះវិញ ។ សោមទត្តព្រាហ្មណ៍មិនព្រមលះបង់អំពើនោះ នៅតែប្រព្រឹត្តធ្វើដដែល ព្រះរាជាហៅមកហាមឃាត់អស់វារៈ៣ ដងមិនព្រមតាមសោះ ដល់គ្រប់៤ ដងទ្រង់ក្រោធពិរោធជាខ្លាំងឱ្យរាជបុរសយកទៅសម្លាប់ ។ ពួករាជបុរសចាប់ចងស្លាបសេកបណ្ដើរអាក្រោសគ្រប់ច្រកល្ហកក្នុងទីក្រុងក៏បានឮដល់សោមព្រាហ្មណ៍ ៗ រត់មកមើលឃើញស្គាល់ជាសម្លាញ់អ្នកឱ្យប្រយោជន៍ដល់ខ្លួនក្នុងពេលដែលលេងពាស្កាចាញ់ ក៏និយាយអង្វររាជបុរសឱ្យឈប់ចាំនៅទីនោះសិន កុំអាលយកទៅសម្លាប់ចាំទៅសូមទោសព្រះរាជាសិន រាជបុរសព្រមចាំ។ សោមព្រាហ្មណ៍ទៅទូលសូមទោសព្រះរាជា ៗ ទ្រង់តុណ្ហីភាពស្ងៀមពុំមានព្រះរាជឱង្ការថាដូចម្ដេចឡើយ ។ សោមព្រាហ្មណ៍ថ្វាយបង្គំលាត្រឡប់មកវិញឱ្យរាជបុរសដោះលែងសោមទត្តព្រាហ្មណ៍ ហើយឱ្យចងខ្លួនយកទៅសម្លាប់វិញ(ឱ! គួរឱ្យស្ញើចណាស់ មិត្តសំឡាញ់មានសភាពបែបនេះមានតិចពេកក្នុងលោក ស្ទើរតែគ្មានសោះ។ អ្នកមានមិត្តសម្លាញ់

ទាំងឡាយក្នុងលោក គួរតែយកតម្រាប់តាមសោមព្រាហ្មណ៍នេះ គ្រប់គ្នា កុំសម្លាប់មិត្តក្នុងវេលាមានអាសន្នឡើយ) ។

ពួករាជបុរសទាំងឡាយ ដោះលែងសោមទត្តព្រាហ្មណ៍ ហើយ ចងសោមព្រាហ្មណ៍យកទៅសម្លាប់ចោលទៅ។ ដួងវិញ្ញាណ ដ៏បរិសុទ្ធរបស់សោមព្រាហ្មណ៍ ក៏អណ្តែកទៅប្រតិស្ឋានក្នុងវិមាន មាសកណ្តាលហ្វូងនៃពួកនារីទាំងឡាយ នាស្ថានទេវលោកសោយ ទិព្វសម្បត្តិជាសុខក្សេមក្សាន្ត ។ ចំណែកសោមទត្តព្រាហ្មណ៍កាល បើរាជបុរសសម្លាប់សម្លាញ់ហើយ ក៏យំសោកបោកខ្លួនប្រាណ អាណិតអាសូរក្រៃពេក លុះបន្ទោបង់នូវការយំសោកហើយ រៀប ធ្វើជើងថ្កប្ដូជាសពរើសឆ្អឹងសំឡាញ់យកទៅទុកនៅផ្ទះរបស់ខ្លួន ធ្វើ ទក្ខិណានុប្បទានផ្សាយកុសលទៅឱ្យអស់វារៈបីថ្ងៃ ។ ឯសោមទេវ-បុត្ត បានរលឹកឃើញសោមទត្តព្រាហ្មណ៍ជាសំឡាញ់ បានធ្វើទាន ឧទ្ទិសកុសលចំពោះខ្លួនហើយ ក៏ចុះពីទេវលោកមកនិម្មិតជាមាណព ដើរចូលទៅផ្ទះសោមទត្តព្រាហ្មណ៍ និយាយប្រាប់សព្វគ្រប់តាម ដំណើររឿងរបស់ខ្លួន ទើបនាំសោមទត្តព្រាហ្មណ៍ទៅស្ថានទេវ លោកដោយឫទ្ធិរបស់ខ្លួន ប្រគល់ទិព្វសម្បត្តិឱ្យ ៧ ថ្ងៃ ហើយនាំមក មនុស្សលោកវិញ ។ សោមទត្តព្រាហ្មណ៍ខំធ្វើបុណ្យទានគ្រប់យ៉ាង ដោយចង់បានទិព្វសម្បត្តិដូចសោមទេវបុត្ត តែងគិតដល់កំហុស របស់ខ្លួនថា កាលពីដើមអញមានសម្បត្តិច្រើនមិនគិតធ្វើបុណ្យទាន

គិតតែស៊ីចាយសប្បាយវិនាសសម្បត្តិអស់ ធ្លាក់ខ្លួនជាអ្នកក្រ ពេលនេះធ្វើម្ដេចហ្ន ! នឹងបានទ្រព្យធ្វើបុណ្យទានឱ្យអស់ចិត្តនឹងគេ ការគិតយ៉ាងនេះយូរៗ ទៅក៏បណ្ដាលទៅជារោគស្គមល្មើងដេកនៅលើកន្ទេលដើរទៅណាមិនរួច ។ សោមទេវបុត្រដឹងដូច្នោះហើយមានប្រាថ្នាចង់ឱ្យទិព្វសម្បត្តិ ប៉ុន្តែយល់ថាមនុស្សលោកប្រើប្រាស់ទិព្វសម្បត្តិមិនបានឡើយ ទើបយកកែវមណីជោតិមួយដុំមកឱ្យ កែវនោះអាចសម្រេចសេចក្ដីប្រាថ្នាបានគ្រប់យ៉ាង ។ សោមទត្ត-ព្រាហ្មណ៍បានកែវមានអានុភាពនោះហើយ សប្បាយចិត្ត ជារោគទាំងពួង គិតជាចំណាយធ្វើបុណ្យទានតែម្យ៉ាងដរាបដល់អស់អាយុបានទៅកើតស្ថានទេវលោក សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្តជាមួយសោមទេវបុត្តជាសំឡាញ់អស់កាលជាយូរអង្វែង ។

## ១៤. រឿងនាងភាគ្យានទេវី

( ចាក ម. វ៉ា. )

( គុណនៃការបូជាបាត្រ ព្រះសម្ពុទ្ធនិងអានិសង្សស្ដាប់ទេសនា )

កាលព្រះសម្ពុទ្ធបរមគ្រូបរិនិព្វានហើយ ពួកពុទ្ធបរិស័ទទាំងឡាយក្នុងទេវបុត្តនគរនាំគ្នាយកបាត្រព្រះសម្ពុទ្ធទៅបញ្ចុះក្នុងចេតិយកែវ មុនបញ្ចុះក្នុងចេតិយនោះ ព្រះរាជាបានចាត់ចែងធ្វើក្បួនហែយ៉ាងអស្ចារ្យ គឺឱ្យរាជបុរសហៅជាងទងជាច្រើនរូបមក ឱ្យយក

ដើមឫស្សី១ ដើមយ៉ាងធំមករចនាស្រោបមាសរំលេចដោយកែវ ៧ ប្រការ យកបាត្រដាក់ភ្ជាប់លើចុងឫស្សី ហើយលើកឡើងដម្កល់លើរាជរថមាស ហែប្រទក្សិណទីក្រុងបីជុំ ទើបនាំចូលទៅបញ្ចុះក្នុងចេតិយកែវ ប្រជុំគ្នាធ្វើបុណ្យសម្ពោធឆ្លងអស់វារៈ ៧ ថ្ងៃ មានធម្មកថិកសំដែងធម៌ទេសនារាល់រាត្រី ។ ពួកមនុស្សនិងទេវតា នាគគ្រុឌជាច្រើនបាននាំគ្នាមកស្តាប់ធម្មទេសនា ។ កាលនោះមាននាគរាជមួយមានឫទ្ធិអស្ចារ្យបានមកស្តាប់ធម៌ដែរ បានឃើញនារីម្នាក់មានរូបល្អស្រស់ប្រិមប្រិយ ជាស្រីមានសទ្ធាមាំក្នុងព្រះពុទ្ធសាសនា ។ នាគរាជមានសេចក្តីស្នេហា និម្មិតជាមាណពទៅនិយាយលួងលោមនាង យកនាងជាភរិយា នាងមិនព្រម ក៏មានសេចក្តីក្រោធខឹង និម្មិតខ្លួនជាពស់នាគយ៉ាងធំ រុំព័ទ្ធនាងនោះជិតតាំងពីបាតជើងឡើងទៅ ហើយបើកពពារគ្របបិទពីលើ បំណងឱ្យនាងស្លាប់ ប៉ុន្តែនាងតាំងចិត្តមាំក្នុងការគោរពព្រះចេតិយ និងព្រះធម៌ទេសនាតែម្យ៉ាងឥតរំភើបញាប់ញ័រអ្វីឡើយ មិនយូរប៉ុន្មាននាគរាជក្តៅក្រហាយរលាភ្នែនស្ទុះចេញឆ្ងាយអំពីនាង នឹកស្ញើចអស្ចារ្យ កើតសេចក្តីជ្រះថ្លាចំពោះនាង ទើបនិម្មិតខ្លួនមានពពា១ រយឱ្យនាងអង្គុយពីលើក្នុងទីកណ្តាលហ្វូងពុទ្ធបរិស័ទ ហើយបូជាដោយកហាបណៈជាច្រើនពាន់ ។ ចំណែកពុទ្ធបរិស័ទទាំងឡាយឃើញហេតុអស្ចារ្យដូច្នោះហើយ កើតសេចក្តីជ្រះថ្លានាំគ្នាយកកហាបណៈទៅបូជានាង រួម

ទាំងអស់ ១៨ កោដិ ។ នាងបានសម្បត្តិច្រើនដូច្នេះហើយខំធ្វើទាន សីលដរាបដល់អស់អាយុ ក៏ទៅចាប់កំណើតកើតក្នុងផ្ទៃអគ្គមហេសី នៃព្រះមហាក្សត្រក្នុងទេវបុត្តនគរនោះឯង ដល់ពេលដែលប្រសូត្រ មានហេតុអស្ចារ្យ ភ្លៀងកែវ ៧ ប្រការធ្លាក់ចុះមកពេញទេវបុត្តនគរ ទាំងមូលទើបព្រះបរមរាជវង្សានុវង្សថ្វាយព្រះនាមថា កាញ្ចនទេវី។

ឯនាងកញ្ចនទេវីនេះ មានរូបល្អស្រស់ដូចជារូបស្រីទេព អប្សរ មានពន្លឺផ្សាយចេញពីកាយប្រវែងមួយហត្ថ ជានិច្ចដោយ អានិសង្សដែលនាងបូជាបាត្រព្រះសម្ពុទ្ធ និងអានិសង្សស្តាប់ធម៌ ទេសនា ។ ស្តេចក្នុងជម្ពូទ្វីបទាំងមូលនាំគ្នាបញ្ជូនគ្រឿងបណ្ណាការ មកថ្វាយព្រះរាជបិតា ដើម្បីដណ្តឹងនាង ។ មិនព្រមយក ព្រោះជា ស្ត្រីមាននិស្ស័យខ្ពស់ នាងសូមអង្វរព្រះរាជបិតា សូមចេញចាកព្រះ រាជនិវេសន៍ទៅបួសក្នុងសំណាក់ភិក្ខុនី ព្រះរាជបិតាក៏ទ្រង់ព្រះរាជា អនុញ្ញាតតាមសូម ទើបដង្ហែនាងចេញពីព្រះរាជនិវេសន៍យ៉ាង មហោឡារិកអស្ចារ្យទៅបួសជាភិក្ខុនី មិនយូរប៉ុន្មាន នាងបាន សម្រេចអរហត្តផល ព្រមទាំងបដិសម្ភិទា មាននាមប្រាកដថា កាញ្ចនថេរី ដល់អស់អាយុក៏បរិនិព្វានទៅ ។

# ១៥~ រឿងនាងបង្កជាទេវី

( ចាក លោ. ជា )

( កំឡាំងនៃពាក្យឃោសនាពូកែស័ក្តិសិទ្ធិ )

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមកាសិករាជ សោយរាជសម្បត្តិក្នុងនគរពារាណសី មានអគ្គមហេសីពីរព្រះអង្គ មួយព្រះនាមចន្ទាទេវី ជាព្រះអគ្គមហេសីដើម, មួយទៀតព្រះនាមបង្កជាទេវី ។ ហេតុដែលបានព្រះនាងបង្កជានោះដូច្នេះ ថ្ងៃមួយព្រះរាជាចេញពីព្រះនគរទៅទស្សនាការនូវបច្ចន្តជនបទ ដល់ពាក់កណ្ដាលផ្លូវក្បែរបឹងឈូកមួយ បានឃើញស្ត្រីអ្នករកស៊ីលក់ស្លឹកឈូក ផ្កាឈូក និងផ្លែឈូកជាដើម កំពុងតែនាំម្ដាយនិងកូនបេះឈូកនៅក្នុងបឹង ឯកូនរបស់ស្ត្រីកំសត់នោះឈ្មោះនាងបង្កជាមានអាយុ ១៦ ឆ្នាំ ។ ម្ដាយរបស់នាងបានឃើញព្រះរាជាឈប់ទតបឹងឈូកនោះ ក៏បេះផ្កាឈូកឱ្យនាងបង្កជាយកទៅថ្វាយ ហេតុតែវាសនាឆើតរបស់នាងបង្កជា ក៏បណ្ដាលទឹកព្រះទ័យព្រះរាជា ឱ្យជោរជោគទៅដោយសេចក្ដីស្នេហាចំពោះនាងយ៉ាងក្រៃលែង ទប់ទល់ពុំបាន ក៏ចាប់នាងដាក់លើខ្នងដំរីមង្គលវិលត្រឡប់មកឯព្រះរាជធានីវិញ រៀបពិធីរាជាភិសេកជាអគ្គមហេសីទី ១ ។

ស្លេះសេចក្ដីត្រឹមនេះសិន នឹងដំណាលអំពីឈ្មោះរបស់ព្រះនាងទាំងពីរ, ដែលឈ្មោះថា ចន្ទា ព្រោះនាងនោះមានរូបល្អស្រស់

មានមុខមូលដូចជាព្រះចន្ទ្រ ដែលឈ្មោះថា បង្គជា ព្រោះនាងនោះ កាលគ្រប់ខែ ១០ ហើយ មាតាចុះទៅបេះឈូកក្នុងបឹង ក៏សម្រាល នាងដេកនៅលើភក់ ។ នាងបង្គជានេះពិតតែជាកូនអ្នកស្រែមែន ប៉ុន្តែដូចមាសទឹកដប់ ល្អសព្វអន្លើឥតខ្ចោះ ទឹកមុខស្រស់ញញឹមដូច បុប្ផាតិរីកក្នុងរាត្រីត្រជាក់ ដែលមានដំណក់ទឹកសន្សើមសម្រក់ចុះ មកប្រស់ព្រំ ។

ដំណាលពីនាងចន្ទាទេវី ដែលធ្លាក់បុណ្យថយមកជាមហេសី ទី ២ ទឹកបេះដូងរបស់ព្រះនាងពុះកញ្ច្រោលស្មើរធ្លាយព្រះឱរា បញ្ចេញផ្សែងជាអណ្តាតភ្លើងឆេះព្រះនាងរាល់ទិវារាត្រី ដើមភ្លើង នេះបណ្តាលមកពីសេចក្តីស្នេហា ព្រះនាងខំផ្ទៀតរកឧបាយលត់មិន បានបណ្តាលឱ្យកើតសេចក្តីព្យាបាទយ៉ាងធំ ។ ថ្ងៃមួយព្រះរាជាស្តេច យាងទៅក្រសាលឧទ្យាន ទុកមហេសីទាំងពីរឱ្យនៅចាំព្រះរាជ ដំណាក់ ពេលនេះហើយជាសម័យល្អបើកឱកាសឱ្យសេចក្តីព្យាបាទ របស់នាងចន្ទាទេវីសំដែងឫទ្ធិ ។ គឺបានជូលអ្នកលេង ៤ នាក់ឱ្យបួស ជាលោកធុតង្គ ទៅនៅក្នុងព្រៃស្មសាន ហើយនាងទូលសុំពរព្រះ រាជានិមន្តលោក ៤ អង្គដែលធុតង្គនៅព្រៃស្មសាននោះមកដាក់ បាត្រក្នុងវាំងជាយូរខែហើយ ទាំងព្រះរាជាក៏គោរពរាប់អានលោក ធុតង្គនោះ ដម្កល់ទុកជាជីតុនយ៉ាងខ្ពស់របស់ព្រះអង្គ ។ ក្នុងពេល យប់ដែលព្រះរាជាចេញទៅផ្ទំយកខ្យល់អាកាសនៅឱទ្យាន នាង

ចន្ទាទេវីបានជូលស្ត្រីចេះសណ្ដំម្នាក់ ឱ្យចូលទៅរាយមន្តសណ្ដំនាងបង្គជាដែលផ្ទំក្នុងបន្ទប់ដ៏មានសិរី កាលបើត្រូវសណ្ដំហើយ នាងចន្ទាចូលទៅដោះយកចិញ្ចៀនព្រះទម្រង់ និងកោសក់របស់នាងបង្គជា មួយចំហៀងក្បាល ហើយបិទទ្វារទៅវិញ យកសក់និងចិញ្ចៀនទៅឱ្យលោកធុតង្គ ៤ អង្គដែលនាងបានជូលឱ្យបួសនៅព្រៃស្មសាន ហើយប្រាប់ឧបាយដល់លោកនោះថា បើព្រះរាជាយាងមកដល់ព្រះរាជដំណាក់ហើយ លោកត្រូវយកសក់និងចិញ្ចៀនថ្វាយរួចទូលថា ល្ងាចមិញមានយក្ខិនីម្នាក់ទៅស៊ីសាច់សពខ្មោចក្នុងព្រៃស្មសាន អាត្មាភាពដើរចង្ក្រមប្រទះឃើញ គិតធ្វើបាបអាត្មាភាព ៗ រាយមន្តចាប់បានដោះយកចិញ្ចៀនកោសក់យកមកថ្វាយ សូមព្រះករុណាចាត់ឱ្យរាជអាមាត្យរកមើលក្រែងមាននៅក្នុងនគរ ។

ថ្ងៃងពីព្រះរាជា កាលបើព្រះអាទិត្យបើកទិសខាងកើតបញ្ចេញរស្មីក្រហមហើយ ទ្រង់នឹកភ្នកដល់ព្រះនាងបង្គជាទេវីជាទីសំណាប់ ក៏ស្ដេចយាងត្រឡប់មកព្រះរាជនិវេសន៍វិញ. ស្ដេចយាងដល់ព្រះរាជដំណាក់ឃើញលោកធុតង្គជាជីតុន ៤ អង្គគង់ចាំខាងក្រៅ ។ លោកធុតង្គនោះ ក៏យកសក់ក្បាលនិងចិញ្ចៀនថ្វាយព្រះរាជា ហើយទូលតាមពាក្យដែលនាងចន្ទាទេវីបង្គាប់ ព្រះរាជាទតឃើញចិញ្ចៀនស្គាល់ច្បាស់ជាចិញ្ចៀន ដែលព្រះរាជទានដល់នាងបង្គជា ពិនិត្យមើលសក់ក្បាលទៀត ក៏ហាក់ដូចជាសក់នាងបង្គជា

ទ្រង់នឹកឆ្ងល់ពេកហើយពិចារណាថា នាងបង្កជាប្រហែលជាយក្ខិនី មែន ព្រោះកាលអញយកមកធ្វើជាមហេសី មិនមែនយកពីផ្ទះបុគ្គលណាទេ គឺយកពីបឹងឈូក ប្រហែលជាយក្ខិនីទៅលេងបឹងឈូកឃើញអញ ក៏និម្មិតជាស្ត្រីក្រមុំឱ្យអញស្រឡាញ់ ។ ទ្រង់ពិចារណាដូច្នេះហើយ ក៏ចូលទៅគោះទ្វារបន្ទប់នាងបង្កជា ៗ មិនបើកទ្វារមិនឆ្លើយ ព្រោះនាងនឹកអៀនខ្មាសពេកដេកឱ្យគេលួចគោរសក់អស់មួយចំហៀងក្បាលមិនដឹងខ្លួន ស៊ូដេកអត់បាយឱ្យស្លាប់ក្នុងបន្ទប់ប្រសើរជាង ។ ឯព្រះរាជាកាលបើហៅមិនឆ្លើយហើយ ក៏គាស់ទ្វារបើកស្ទុះចូលទៅ ឃើញបាត់ចិញ្ចៀនពីដៃ ក្បាលគោរមួយចំហៀង ហើយសំគាល់នាងថាពិតជាយក្ខិនី ក៏បញ្ចេញព្រះសូរសីហនាទថាយក្ខិនី ៗ ស្ទុះចេញមកក្រៅវិញ ពួកនាងចន្ទាទេវីក៏នាំគ្នាស្រែកឃោសនាថា នាងបង្កជាគឺយក្ខិនីទេ១ ឮសន្ធឹកកងរំពងពេញព្រះរាជធានីមួយរំពេច ។ ព្រះរាជាក៏ប្រើរាជអាមាត្យឱ្យដេញនាងចេញពីដំណាក់, នាងយកកន្សែងគ្របក្បាលក៏រត់ចុះទៅ ពួកនាងចន្ទាទេវីនិងអ្នកនគរ ក៏នាំគ្នាដេញនាងបង្កជាដរាបដល់ចេញផុតពីនគរនោះទៅ ( ឱ! គួរសំវេគនាងបង្កជាខ្លួនជាមនុស្សសុទ្ធ អ្នកនគរសំគាល់ថាយក្ខិនីពិត ដោយសារតែពាក្យឃោសនារបស់នាងចន្ទាទេវី ) ។

នាងបង្កជាទេវី កាលបើគេដេញចេញផុតពីព្រំដែននគរ

ហើយ ក៏លែងស្តាយជីវិតគិតតែដើរចូលទៅក្នុងព្រៃឱ្យស្លាប់ ទៅដល់ពាក់កណ្តាលព្រៃ ឃើញផ្ទះយាយតាកំសត់ម្នាក់ ក៏សុំបាយទឹកទទួលទាន យាយតាមានធម៌សប្បុរស បានឱ្យបាយទឹកដល់នាង ហើយសួរដឹងរឿងរ៉ាវសព្វគ្រប់ ឃាត់នាងឱ្យនៅជាមួយមិនឱ្យទៅណាទៀត នាងក៏ព្រមនៅ ។ ចំណែកខាងព្រះរាជាតាំងតែពីថ្ងៃដែលនាងបង្គជាចេញផុតពីនគរហើយ ចេះតែរំពឹងពិចារណារឿងនោះមិនភ្លេច ព្រោះឃើញអាការប្លែករបស់នាងចន្ទាទេវីនឹងបាត់ពុំដែលឃើញលោកធុតង្គ ៤ អង្គ ។ ថ្ងៃមួយមានព្រះទ័យនឹកភ្នកដល់នាងបង្គជាទេវីថា នាងពុំមែនយក្ខិនីទេ គឺប្រាកដជាឧបាយព្យាបាទរបស់នាងចន្ទាទេវី ទ្រង់សង្ស័យដូច្នេះហើយ ដល់វេលាយប់ទ្រង់ក្លែងភេទ មិនឱ្យអ្នកណាស្គាល់ ចេញពីព្រះរាជដំណាក់យាងទៅក្បែរទៀមស្រា ទាំងប៉ុន្មានដែលមាននៅក្នុងនគរ ក៏បានជួបនឹងអ្នកលេង ៤ នាក់ដែលនាងចន្ទាជួលឱ្យបួសធ្វើនយោបាយ ស្គាល់បានដោយសក់ក្បាលខ្លី ព្រោះទើបនឹងសឹកក្នុងវេលាដែលធ្វើនយោបាយសម្រេចហើយ ។ អ្នកលេងទាំង ៤ នាក់នោះស្រវឹងជជែកដណ្តើមលុយគ្នា ។ អាមួយថា អញទើបត្រូវចាយច្រើនជាង ព្រោះអញជាអ្នកទទួលការសម្ងាត់ផ្ទាល់ពីនាងចន្ទាទេវី ។ អាមួយទៀតថាមិនដល់អញទេ អញខំទៅយកសក់ក្បាលនិងចិញ្ចៀនរបស់នាងបង្គជាពីដៃនាងចន្ទាទេវីមក។ ព្រះរាជាកាលបើយកការណ៍បានសព្វគ្រប់ហើយ

ស្ដេចត្រឡប់មកផ្ទុំវិញ ទ្រង់សង្កេតការណ៍នេះអស់ពីរបីរាត្រី ទើបឱ្យរាជអមាត្យចាប់អ្នកលេងទាំង ៤ នាក់ និងចាប់នាងចន្ទាទេវីព្រមទាំងញាតិមិត្តរបស់នាងមកឃុំទុកមួយកន្លែង ហើយចាត់ចែងឱ្យរាជបុរសទៅស៊ើបដំណឹងរកនាងបង្គជាទេវី ទៅរកឃើញនៅផ្ទះយាយតាកំសត់ ហើយប្រាប់នាងថាស្ដេចឱ្យអញ្ជើញទៅវិញ នាងបង្គជាមិនព្រមទៅបានផ្ដាំមកព្រះរាជាវិញថា នាងជាយក្ខិនីទេ សូមលាព្រះអង្គឈប់ឱ្យជួបព្រះភ័ក្ត្រព្រះអង្គហើយ ។ រាជអមាត្យមកទូលតាមបណ្ដាំ. ព្រះរាជាទ្រង់ព្រះសណ្ដាប់ ហើយអួលចុកក្នុងព្រះឱរាអាណិតព្រះនាងផរាបផល់ស្រក់ទឹកព្រះនេត្រ ទ្រង់ប្រើឱ្យទៅអញ្ជើញព្រះនាងអស់វារៈ ២ ដង ព្រះនាងមិនព្រមមក ទើបព្រះរាជាស្ដេចត្រាស់បង្គាប់នាហ្មឺនមុខមន្ត្រីគ្រប់ក្រសួង ឱ្យរៀបចំដំរីមង្គលទៅអញ្ជើញព្រះនាងជាមួយនឹងព្រះអង្គ អភិសេកជាថ្មីម្ដងទៀត ។ ព្រះនាងបង្គជាទេវី កាលបើឃើញព្រះរាជាទៅដល់ហើយក៏យំសោកបោកខ្លួនប្រាណមិនព្រមត្រឡប់មកវិញ ព្រះរាជាលួងលោមឱ្យព្រះនាងស្បើយចាកសេចក្ដីទុក្ខ ទើបលើកដាក់លើខ្នងដំរីយកមកអភិសេកម្ដងទៀត លុះរៀបអភិសេកហើយ បង្គាប់រាជអមាត្យឱ្យនាំខ្លួនអ្នកលេង ៤ នាក់ និងពួកក្រុមនាងចន្ទាមកកាត់ទោសក្នុងទីចំពោះមុខនាងបង្គជាទេវី ។ ព្រះរាជាកាត់ទោសឱ្យជីកជីកប់ត្រឹមក ហើយយកភ្លើងដុតរាស់ដោយរនាស់ដែក អ្នកទោសយំ

រំពង ។ ព្រះនាងបង្គជាទេវីក៏ឃាត់ព្រះរាជាមិនឱ្យផាក់ទោសដូច្នោះ សុំឱ្យរួចខ្លួនទាំងអស់គ្នា ហើយក្រាបទូលព្រះរាជាដោយមេត្តាចិត្ត ថា ទោសនេះកើតមកអំពីខ្លួនទូលព្រះបង្គំទេ បើព្រះអង្គកុំយកខ្ញុំព្រះអង្គមក នាងចន្ទាទេវី ក៏មិនបានធ្វើអំពើនេះឡើយ បើព្រះអង្គយកទោសអ្នកទាំងអស់នេះ គួរតែយកទោសខ្ញុំព្រះអង្គផង ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ក៏ប្រគល់អ្នកទោសទាំងអស់ដល់ព្រះនាង ៗ ក៏លើកលែងឱ្យរួចខ្លួនដូចដើមវិញ. ឯនាងចន្ទាក៏ស្ទុះលូនទៅលើកបាទារបស់នាងបង្គជាផាក់លើក្បាល សុំធ្វើជាខ្ញុំបំរើនាងដរាបដល់អស់អាយុ ។

## ១៦. រឿងវិសមលោមរាជកុមារ

( ចាក ម. វ៉ា. )

( ផលនៃការធ្វើទានដោយសេចក្ដីជ្រះថ្លា )

កាលសាសនាព្រះសម្ពុទ្ធព្រះនាមកស្សប មានបុរសម្នាក់បានស្ដាប់ធម៌ទេសនាព្រះសម្ពុទ្ធ មានសេចក្ដីជ្រះថ្លាបានធ្វើទានប្រគេនចង្ហាន់ចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន លុះស្លាប់ទៅបានទៅកើតក្នុងសុគតិភពអស់កាលជាយូរអង្វែង ដល់មកសាសនាព្រះសម្ពុទ្ធគោតមបរមគ្រូរបស់យើងនេះ ព្រះអង្គបរិនិព្វានផុតទៅហើយ បានមកកើតជាព្រះរាជបុត្រព្រះបាទធម្មាសោករាជស្ដេច

ចុល្លចក្រ មានរូបកាយល្អអស្ចារ្យ មានរោមក្រញាញ់ប្រទាក់គ្នា បាន ជាព្រះរាជបិតាព្រះរាជទាននាមថា វិសមលោមរាជកុមារ ដល់ ចំរើនវ័យឡើងមានព្រះជន្ម ១៦ ឆ្នាំ រូបរាងកាយក៏រឹតតែល្អមាន កំលាំងខ្លាំងអស្ចារ្យ អាចហក់លោតទៅឰដ៏អាកាសបានកំពស់ ១៨ ហត្ថ ។ ថ្ងៃមួយព្រះបាទធម្មាសោករាជបានប្រជុំព្រះរាជាចំនួន ៨ ហ្មឺន ៤ ពាន់ព្រះអង្គដែលជាស្តេចចំណុះ លុះមកជួបជុំហើយក៏នាំ ទៅលេងព្រៃហេមពាន្ត ដើម្បីកំសាន្តសប្បាយ ឯវិសមលោមរាជ កុមារ បានយាងទៅជាមួយដែរ ។ ព្រះបាទធម្មាសោកដែលមាន ស្តេច ៨ ហ្មឺន ៤ ពាន់អង្គចោមរោមជាបរិវារ ស្តេចយាងទៅដល់ ស្ទឹងចន្ទភាគា ទ្រង់ឈប់សម្រាកនៅទីនោះ ។ ឯស្ទឹងចន្ទភាគានោះ ជាស្ទឹងធំ មានទទឹង ១ យោជន៍ ជម្រៅ ៣ គាវុត មានទឹកហូរខ្លាំង បែកពពុះធំៗ ជាស្ទឹងសម្បូណ៌ទៅដោយសត្វសាហាវគ្រប់មុខ ។ ព្រះបាទធម្មាសោក ទតឃើញស្ទឹងនោះគួរឱ្យខ្លាច ហើយទ្រង់មាន ព្រះតម្រាស់ត្រាស់សួរពួកបរិវារទាំងអស់ថា អ្នកណាហ៊ានហែល កាត់ស្ទឹងនេះទេ? ព្រះរាជាទាំង ៨ ហ្មឺន ៤ ពាន់ព្រះអង្គដែលពូកែៗ ទាំងប៉ុន្មានមិនហ៊ានហែលឆ្លងឡើយ មានតែវិសមលោមរាជកុមារ មួយចូលទៅថ្វាយបង្គំទូលថាហ៊ានហែលឆ្លង ។ ព្រះរាជបិតាត្រាស់ ថា បើបាឯងហ៊ានមែន ហែលឆ្លងទៅ ! ហើយហែលមកវិញយើង នៅចាំក្នុងទីនេះ ។

វិសមលោមរាជកុមារ កាលបើព្រះរាជបិតាអនុញ្ញាតហើយ ក៏ផ្លាស់គ្រឿងអម្ពរទុកនៅសល់តែខោទ្រនាប់ខ្លី (ស្លីប) ថ្វាយបង្គំបិតាហើយហក់ពីមាត់ច្រាំងទៅលើអាកាសបាន ១៨ ហត្ថ ទើបលោតចុះទៅក្នុងស្ទឹងហែលឆ្លងទៅត្រើយនាយ ហើយហែលត្រឡប់មកវិញ មានសន្ទុះរហ័សដូចព្រួញ ពួកសត្វសាហាវទាំងឡាយមានក្រពើ ឆ្លាមម្ករជាដើមស្ទុះដេញខាំ វិសមលោមកុមារយកដៃទះបែកបាក់ខ្លួនប្រាណខ្ទេចខ្ទីស្លាប់ជាច្រើន លុះមកដល់ហើយឡើងទៅថ្វាយបង្គំព្រះរាជបិតា ៗ នឹកស្ញើចអស្ចារ្យក្រៃពេក ថាព្រះរាជបុត្រនេះមានឫទ្ធិច្រើនណាស់ គ្មានបុគ្គលណាស្មើឡើយ ឯស្ដេចទាំង ៨ ហ្មឺន ៤ ពាន់ព្រះអង្គ ក៏អស្ចារ្យស្លុតព្រះទ័យ ។

គ្រាក្រោយមកព្រះរាជបិតានឹកខ្លាចថា ព្រះរាជបុត្រនេះនឹងសម្លាប់អញយករាជសម្បត្តិបានដោយងាយ បើដូច្នេះអញត្រូវតែសម្លាប់ចោល លុះដល់ត្រឡប់មកនគរវិញ ក៏ប្រើរាជអមាត្យឱ្យចាប់វិសមលោមកុមារ ជាព្រះរាជបុត្រដាក់គុកបង្ខត់បាយឱ្យតែបន្តិច ៗ កុំឱ្យតែឆាប់ស្លាប់ ដល់គ្រប់ ៤ ខែ ព្រះរាជាឱ្យរាជអមាត្យចងឫស្សី ៦០ បាច់បង្កប់ដែកនៅខាងក្នុង ហើយតម្រៀបបញ្ឈរទុកក្នុងទីមួយ ទើបឱ្យទៅយកព្រះរាជកុមារពីគុកមកប្រាប់ថា ព្រះរាជបិតាឱ្យយកព្រះខ័នកាប់ឫស្សីទាំង ៦០ បាច់ឱ្យដាច់ជាកំណាត់ប្រវែងបួនៗ ធ្នាប់ បើកាត់មិនដាច់ទេនឹងសម្លាប់ចោល ។ វិសមលោមកុមារប្រាប់រាជ

អមាត្យថា រកអាហារមកឱ្យខ្ញុំបរិភោគសិន ព្រោះ ៤ ខែហើយមិនដែលបានអាហារបរិភោគឱ្យឆ្អែតម្តងទេ ។ រាជអមាត្យថាមិនបានទេ ។ វិសមលោមកុមារនឹកក្នុងចិត្តថា បើបានអាហារបរិភោគឱ្យឆ្អែតអញនឹងកាប់ឫស្សីឱ្យដាច់ជាកំណាត់បួន១ ធ្នាប់កុំឱ្យសល់ កំពុងតែគិតបណ្តើរដើរបណ្តើរ ក៏ឃើញស្រះមួយមានទឹកថ្លាល្អហើយសុំអមាត្យផឹក អមាត្យព្រមឱ្យផឹក ក៏ចុះទៅក្នុងស្រះមុជទៅកាយភក់ស៊ីដរាបដល់ឆ្អែត ទើបឡើងមកវិញទៅថ្វាយបង្គំព្រះរាជបិតា ១ ថាបើបាឯងកាត់ឫស្សី ៦០ បាច់នេះដាច់ដូចបង្គាប់មែន នឹងលើកលែងឱ្យរួចទោស បើកាត់មិនដាច់ទេយកទោសដល់ជីវិត ។ វិសមលោមកុមារទូលថាកាត់ដាច់ ទើបកាន់ព្រះខ័នហក់ស្ទុះទៅឰដ៏អាកាសកំពស់ ៨០ ហត្ថចុះមកវិញកាត់ឫស្សីទាំង ៦០ បាច់ដាច់ជាកំណាត់ ៤ ១ ធ្នាប់ ហើយបានឮសូរកិណិ១ ដឹងថាគេបង្កប់ដែកនៅក្នុង ក៏បោះព្រះខ័នចោលស្រែកទ្រហោយំ. វិសមលោមកុមារប្រាប់ថា ខ្ញុំគ្មានអ្នកណាមួយស្រឡាញ់រាប់អានខ្ញុំទេ បើមានខ្លះមុខជាប្រាប់ខ្ញុំថាឫស្សីនេះមានដែកនៅខាងក្នុងផង ខ្ញុំនឹងកាប់ដាច់ជាងនេះទៅទៀត ។

រាជបិតាឮដូច្នោះហើយទ្រង់មានព្រះទ័យមេត្តា សោមនស្សចំពោះឥទ្ធិពលរបស់ព្រះរាជបុត្រ ក៏ព្រះរាជទានសម្បត្តិជាច្រើនអភិសេកឱ្យឡើងឋានៈជាឧបរាជ ។ វិសមលោមកុមារកាលបើបាន

សុខស្រួលហើយ ក៏មានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា បាន បរិច្ចាគទានរក្សាសីលទំនុកបំរុងព្រះសង្ឃ មានព្រះមោគ្គល្លីបុត្រតិស្សត្ថេរជាដើមដរាបដល់ទីបំផុតព្រះជន្មហោង ។

## ១៧. រឿងចិត្តគហបតី

( ចាក ធ. ខុ. )

( អ្នកបរិបូណ៌ដោយសទ្ធានិងសីលមានគេបូជាគ្រប់ទីកន្លែង )

កាលព្រះសម្ពុទ្ធបរមគ្រូទ្រង់ព្រះជន្មនៅ, ថ្ងៃមួយព្រះអានន្ទទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន ចិត្តគហបតីមកកាន់សំណាក់ព្រះអង្គអស់ ១ ខែ ទេវតានិងមនុស្សទាំងឡាយតែងបូជាគ្រឿងសក្ការៈដល់គាត់រាល់ៗ ថ្ងៃ គាត់ឱ្យទានតែគ្រឿងសក្ការៈនោះមិនអស់ ឥឡូវគាត់បររទេះ ៥០០ ត្រឡប់ទៅវិញ ពួកទេវតានាំគ្នាយកកែវ៧ ប្រការដាក់ពេញរទេះទាំងអស់ ។ បពិត្រព្រះអង្គដ៏ចំរើន គ្រឿងសក្ការៈកើតឡើងដល់ចិត្តគហបតីនេះ តែក្នុងកាលដែលមកកាន់សំណាក់ព្រះអង្គទេឬ? ឬថាកើតឡើងដល់គាត់ក្នុងទីដទៃដែរ? ព្រះមានព្រះភាគត្រាស់ថា : ម្នាលអានន្ទក្នុងទីណាៗ ក៏ដោយគ្រឿងសក្ការៈតែងកើតដល់ចិត្តគហបតីជានិច្ច ព្រោះគាត់មានសទ្ធានិងសីល បានកសាងទុកមកតាំងពីសាសនាព្រះពុទ្ធព្រះនាមបទុមមុត្តរៈលុះដល់មកសាសនាព្រះពុទ្ធព្រះនាមកស្សប គាត់ច្យុតពីទេវលោក

មកកើតក្នុងត្រកូលព្រានម្រឹគ ។ ថ្ងៃមួយជាពេលមានភ្លៀងជោគជាំ គាត់កាន់លំពែងដើរចូលទៅក្នុងព្រៃដើម្បីចាប់ម្រឹគ ស្រាប់តែឃើញភិក្ខុ ១ រូបទូរចីពរឈររនៅក្បែរញកភ្នំ គាត់គិតថាលោកអង្គនេះប្រហែលជាធ្វើសមណធម៌ អញនឹងប្រគេនចង្ហាន់លោកបានម្តង ក៏ទៅប្រាប់ភរិយាឱ្យចំអិនអាហារ ស្រាប់តែឃើញភិក្ខុ ១ រូបទៀតកំពុងដើរបិណ្ឌបាត ក៏និមន្តឱ្យគង់លើផ្ទះប្រគេនចង្ហាន់ស្រួលបួលទើបយកទៅប្រគេនលោកដែលនៅក្បែរញកភ្នំ លុះដល់កណ្តាលផ្លូវបានបេះផ្កាយកទៅផង ទៅដល់ទូលលោកថា សូមព្រះគុណម្ចាស់សង្គ្រោះដល់ខ្ញុំព្រះករុណាផង រួចយកចង្ហាន់ដាក់បាត្រលោកហើយ បូជាផ្កានោះទៀតទើបធ្វើសេចក្តីប្រាថ្នាថា ផ្កានេះដែលញ៉ាំងចិត្តព្រះករុណាឱ្យរីករាយយ៉ាងណា គ្រឿងបណ្ណាការទាំងពាន់ៗ ចូរកើតដល់ខ្ញុំព្រះករុណារាល់ៗ ជាតិ ទាំងផ្កាក៏សូមបង្អុរចុះមករាល់ៗ ជាតិត្រង់ទីដែលខ្ញុំព្រះករុណាកើតហើយ ៗ កុំបីឃ្លាត ។ ព្រាននេះបានធ្វើកុសលតាំងពីពេលនោះដរាបដល់អស់ជីវិត ក៏បានទៅកើតក្នុងទេវលោក ឯភ្លៀងផ្កាទិព្វក៏បង្អុរចុះជាជួរ ត្រឹមជង្គង់ត្រង់ទីដែលគាត់កើតនោះឯង ដល់មកសាសនាគតថាគតនេះ បានមកកើតជាចិត្តគហបតីនេះឯង មានគ្រឿងបណ្ណាការនិងភ្លៀងផ្កាម្ធិះ កើតឡើងដល់គាត់ជានិច្ចកាលគ្រប់ទីកន្លែង ។ នេះជាអានិសង្សរបស់អ្នកបរិបូណ៌ដោយសទ្ធានិងសីល. ទ្រង់មានព្រះពុទ្ធដីកាដូច្នេះ

ហើយសំដែងថា :

**សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធាបរិបូណ៌ដោយសីល ជាអ្នកឆ្អែតស្កប់ដោយយសនិងភោគៈ គប់រកនូវប្រទេសណា ៗ មានគេបូជាក្នុងប្រទេសនោះ ៗ ។

## ១៨_ រឿងឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ

( ចាក ម. វា. )

( គុណព្រះសម្ពុទ្ធតែងញុំាងបំណងអ្នកមានសទ្ធាមាំឱ្យសម្រេច )

កាលព្រះសម្ពុទ្ធបរិនិព្វានហើយ មានព្រះខីណាស្រព១ ព្រះអង្គបានយកឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ ដាក់ក្នុងយាមទិមន្តទៅកាន់ជនបទមួយស្ថិតនៅខាងត្បូងនៃមហាពោធិព្រឹក្ស ។ ក្នុងជនបទនោះមានជនជាសម្មាទិដ្ឋិខ្លះ មិច្ឆាទិដ្ឋិខ្លះស្មើភាគគ្នា ។ ចំណែកជនជាសម្មាទិដ្ឋិទាំងឡាយ បានឃើញព្រះខីណាស្រពយកឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធទៅក្នុងស្រុករបស់ខ្លួនហើយ មានសទ្ធាជ្រះថ្លាចំពោះគុណព្រះសម្ពុទ្ធដ៏ក្រៃលែង បាននាំគ្នាជញ្ជូនដីខ្សាច់យ៉ាងស្អាតល្អម មកធ្វើជាស្តូបចេតិយបញ្ចុះឈើទ្រនាប់ព្រះបាទនោះហើយនាំគ្នាគោរពបូជាធ្វើសក្ការៈរាល់ៗថ្ងៃ ។ ឯជនមិច្ឆាទិដ្ឋិទាំង

ឡាយនាំគ្នាគោរពបូជា ធ្វើសក្ការៈចំពោះឥស្សរទេវតាគឺ (អារ័ក្ស, អ្នកតា, ខ្មោច, បិសាច) មិនបានជ្រះថ្លាចំពោះគុណព្រះសម្ពុទ្ធឡើយ ។

ថ្ងៃមួយពួកជនទាំងពីរពួកនេះ បណ្តាលឱ្យកើតចលាចលយ៉ាងអស្ចារ្យ គឺជជែកភ្នាល់គ្នាអួតគុណរៀង១ខ្លួន, ពួកជនសម្មាទិដ្ឋិអួតថាគុណព្រះសម្ពុទ្ធពូកែវិសេសអស្ចារ្យផុតក្នុងលោក ឥតមានគុណអ្វីប្រៀបស្មើបាន, ឯជនមិច្ឆាទិដ្ឋិអួតថា គុណឥស្សរទេវតាគឺអារ័ក្ស, អ្នកតា, ខ្មោច, បិសាច ពូកែផុតផ្តាច់ក្នុងលោក ។ រឿងជជែកនេះកាន់តែធំឡើង ១ ក៏នាំគ្នាភ្នាល់ថាបើគុណខាងណាពូកែផុតក្នុងលោក សូមឱ្យគុណនោះធ្វើបាដិហារ្យឱ្យប្រាកដដល់ភ្នែកមហាជនទាំងអស់ លុះព្រមភ្នាល់គ្នាយ៉ាងនេះហើយ ក៏នាំគ្នាចូលទៅក្រាបទូលព្រះមហាក្សត្ររបស់ខ្លួន, ព្រះមហាក្សត្រ ក៏កំណត់ថ្ងៃឱ្យភ្នាល់គ្នា ហើយឱ្យរាជអមាត្យនាំគ្នាវាយស្គរដើរទៅក្នុងព្រះរាជអាណាចក្រទាំងមូលថា នៅ ៧ ថ្ងៃទៀតនឹងមានភ្នាល់គុណព្រះសម្ពុទ្ធ និងគុណឥស្សរទេវតា ក្នុងព្រះរាជអាណាចក្រយ៉ាងអស្ចារ្យឱ្យមហាជនមកជួបជុំដើម្បីធ្វើសាក្សី ។

ឯពួកជនសម្មាទិដ្ឋិ នាំគ្នាជំរះស្មៅធ្វើមណ្ឌបតុបតែងព្រះស្តូបចេតិយ ដែលបញ្ចុះឈើទ្រទនាប់ព្រះបាទព្រះសម្ពុទ្ធ ។ ពួកជនមិច្ឆាទិដ្ឋិ នាំគ្នាធ្វើខ្ទមអ្នកតា, រានទេវតា, ធ្វើស្វាធមី បាយសីគ្រប់ទី

កន្លែងដែលខ្លួនតែងទៅបន់ស្រន់ ។

កាលបើថ្ងៃទី ៧ មកដល់ហើយ ពួកមហាជនក្នុងព្រះរាជអាណាចក្រទាំងមូល និងពួកជនបរទេសជាច្រើន បានមកជួបជុំគ្នាក្នុងទីភ្លាល់រាប់រយលាននាក់ ។ ពួកជនមិច្ឆាទិដ្ឋិ ក៏រៀបតុបតែងរានទេព្តា ខ្ទមអ្នកតា បូជាដោយស្វាធមីបាយសីខ្លះ ក៏បញ្ឆាន់អារក្សបញ្ចូលបង់បត់ឮស្ទូរស្គរ និងសំលេងហោកញ្ច្រៀវលាន់រំពង ។ ឯពួកជនសម្មាទិដ្ឋិទាំងឡាយ នាំគ្នាទៅនមស្សការព្រះស្តូបចេតិយដែលបញ្ចុះឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ ហើយមានបណ្ឌិតជនម្នាក់ក្រោកឈរឡើងថ្លែងសច្ចវាចាសរសើរគុណព្រះសម្ពុទ្ធ រៀបរាប់តាមពុទ្ធជ័យមង្គល ដែលព្រះអង្គទ្រង់ឈ្នះសត្រូវទាំងឡាយមានឈ្នះមារាធិរាជជាដើម ហើយនាំគ្នាអធិដ្ឋានថា "សូមឱ្យឈើទ្រនាប់ព្រះបាទដែលបញ្ចុះក្នុងចេតិយ ធ្វើបដិហារ្យឱ្យអស្ចារ្យក្នុងពេលឥឡូវនេះ ដើម្បីប្រកាសគុណព្រះសម្ពុទ្ធឱ្យប្រាកដដល់មហាជន និងជួយសង្គ្រោះកំចាត់បង់នូវមិច្ឆាទិដ្ឋិ របស់ជនទាំងឡាយផង ។ កាលបើបណ្ឌិតជនធ្វើសច្ចកិរិយាបួងសួងចប់ហើយ ឈើទ្រនាប់ព្រះបាទដែលបញ្ចុះក្នុងពាលុកចេតិយ ក៏បញ្ចេញសំលេងលាន់រំពងក្នុងចេតិយ កំរើកញ័រមហាប្រិថពី មួយស្របក់ក៏បែកព្រះចេតិយជាពីរ ហើយអណ្តែកឡើងទៅប្រតិស្ឋានឰដ៏នភាល័យ បញ្ចេញពន្លឺរស្មី ៦ ពណ៌ភ្លឺឆើតអស្ចារ្យ ។ ពួកមហាជនទាំងសម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ

សម្បើមព្រឺព្រួចក្នុងចិត្តដរាបដល់ទន់ជង្គង់ ក្រាបចុះនៅលើផែនដី ថ្វាយបង្គំនមស្សការ ស្រែកប្រកាសឮលាន់រំពងថា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកដរាបដល់អស់អាយុ ទាំងព្រះមហាក្សត្រ ក៏បានថ្វាយព្រះអង្គជាឧបាសក យកព្រះពុទ្ធជាទីពឹងទីរលឹកដរាបដល់ទីបំផុតព្រះជន្ម ។ ឯឈើទ្រទាប់ព្រះបាទកាលបើធ្វើបដិហារ្យហើយ ក៏បន្ទាបចុះទៅប្រតិស្ឋានក្នុងពាលុកចេតិយដូចដើមវិញ ។ តាំងពីនោះមក ពួកមិច្ឆាទិដ្ឋិជនគោរពរាប់អានជឿគុណព្រះសម្ពុទ្ធ ជាមួយនឹងពួកជនសម្មាទិដ្ឋិទាំងឡាយ ដរាបដល់អស់អាយុគ្រប់ៗ គ្នា ។

ពួកជនទាំងឡាយក្នុងកាលនោះ លុះអស់អាយុហើយឥតមានជនណាមួយទៅអបាយភូមិឡើយ ខ្លះបានទៅកើតក្នុងស្ថានសួគ៌ ៦ ជាន់ ខ្លះបានកើតក្នុងមនុស្សលោកនេះ បរិបូណ៌ដោយសេចក្តីសុខចំរើន ។

## ១៩~ រឿងឧត្តរសាមណេរ

( ចាក ម. វា. )

( បុណ្យនិងបាបជាញាតិមិត្ររបស់សត្វទាំងឡាយ )

កាលសាសនាព្រះសម្ពុទ្ធព្រះនាមសុមេធៈ មានវិជ្ជាធរ១ រូបនៅក្នុងព្រៃហេមពាន្ត ជាអ្នកមានសេចក្តីជ្រះថ្លាមុតមាំក្នុងព្រះពុទ្ធសាសនា ។ ថ្ងៃមួយព្រះអរហន្តសម្ពុទ្ធព្រះនាមសុមេធៈ ស្តេចយាង

ទៅព្រៃហេមពាន្ត វិជ្ជាធរបានចូលទៅនមស្សការថ្វាយបង្គំបូជាផ្កាកណ្ណិកាបីទង ដោយអំណាចសេចក្តីជ្រះថ្លានិងពុទ្ធតេជៈ ផ្កាបីទងនោះ ក៏ប្រតិស្ឋានលើអាកាសបាំងព្រះសម្ពុទ្ធ ហាក់ដូចជាពាំទិព្វ។ វិជ្ជាធរនោះ មានបីតិសោមនស្សដ៏ក្រៃពេកចំពោះពុទ្ធបូជារបស់ខ្លួន លុះអស់អាយុបានទៅកើតក្នុងទេវលោក និងមនុស្សលោកសោយសេចក្តីសុខអស់កាលជាយូរអង្វែង មិនដែលធ្លាក់ទៅក្នុងអបាយភូមិម្តងឡើយ. លុះដល់មកសាសនាព្រះសម្ពុទ្ធបរមគ្រូរបស់យើងនេះ បានមកកើតក្នុងត្រកូលព្រាហ្មណ៍មហាសាលនាក្រុងរាជគ្រិះ មានឈ្មោះថា ឧត្តរកុមារ ជាអ្នកមានបញ្ញាឈ្លាសវៃ និងបរិបូណ៌ដោយរូបសម្ប័ទល្អឆើតជាងអ្នកនគរទាំងអស់ ។ ឧត្តរកុមារនេះមានអាយុ ១៦ ឆ្នាំមានព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការជាមហាមាត្យ បានឃើញឧត្តរកុមារមានរូបល្អ ចង់បានធ្វើជាកូនប្រសារ បានប្រើអ្នកបំរើឱ្យទៅប្រាប់ដល់មាតាបិតារបស់ឧត្តរកុមារ ឱ្យចូលមកដណ្តឹងកូនក្រមុំរបស់ខ្លួន ។ ចំណែកខាងឧត្តរកុមារឮដំណឹងនោះហើយ ក៏ហាមឃាត់មាតាបិតាមិនឱ្យចូលទៅដណ្តឹង ព្រោះចង់ចេញទៅបួស. មាតាបិតាក៏ព្រមតាម ។ មិនយូរប៉ុន្មានឧត្តរកុមារលាមាតាបិតាចូលទៅបួសក្នុងសំណាក់ព្រះសារីបុត្រ ខំប្រតិបត្តិតាមសមណប្បវេណីដោយផ្ចិតផ្ចង់ ។ ថ្ងៃមួយព្រះសារីបុត្រជាឧបជ្ឈាយ៍មានអាពាធ ។ ឧត្តរសាមណេរ ក៏លាឧបជ្ឈាយ៍ទៅរកថ្នាំ ទៅដល់ស្រះមួយដាក់

បាត្រក្រោមដើមឈើ ចុះទៅស្រង់ទឹកក្នុងវេលាព្រឹកព្រហាម. ពេលនោះជួនជាមានចោរលួចយកបង្វិចទ្រព្យអ្នកនគរ ពួករាជអមាត្យដេញតាម. ចោរបានយកបង្វិចទ្រព្យទៅដាក់ក្នុងបាត្ររបស់សាម-ណេរ ហើយរត់ហួសទៅ ។ ពួករាជអមាត្យទៅដល់ឃើញបង្វិចទ្រព្យនៅក្នុងបាត្រ ក៏ចាប់សាមណេរនោះយកមកឱ្យវស្សការព្រាហ្មណ៍ ជាមហាមាត្យ ដោយសំគាល់ថាសាមណេរនោះជាចោរពិត ។ វស្សការមហាមាត្យស្គាល់ជាក់ជាឧត្តរសាមណេរហើយ ក៏កើតសេចក្តីក្រោធឡើង ព្រោះចងគំនុំនឹងឧត្តរសាមណេរដែលមិនព្រមទទួលយកកូនក្រមុំរបស់ខ្លួន បានប្រើឱ្យពេជ្ឈឃាតចាប់សាមណេរចងស្លាបសេក យកទៅដោតលើចុងឈើអណ្តោត ចាក់ទម្លុះទម្លាយមានឈាមហូរពាសពេញខ្លួន ។ សាមណេរខំអត់ធន់មិនអើពើនឹងការចាក់ដោតនោះឡើយ ខំបញ្ជូនចិត្តទៅរកឧបជ្ឈាយ៍នឹកថាបាននរណាយកថ្នាំទៅប្រគេនឧបជ្ឈាយ៍របស់អញ ម៉្លេះលោកចាំមើលផ្លូវអញយ៉ាងណាទៅហ្ន ! កំពុងតែគិតដូច្នេះព្រះសារីបុត្រជាឧបជ្ឈាយ៍ លោកជ្រាបថាឧត្តរសាមណេរកំពុងត្រូវទោសជាទម្ងន់. ក៏ទៅក្រាបទូលដល់ព្រះសម្ពុទ្ធ ។ ទ្រង់ជ្រាបថាសាមណេរនេះមានឧបនិស្ស័យខ្ពស់ល្មមព្រះអង្គទៅជួយសង្គ្រោះបាន ក៏ស្តេចយាងទៅដល់ទីនោះមួយរំពេច ជាមួយនឹងភិក្ខុសង្ឃជាច្រើនពាន់អង្គ ។ ឯឧត្តរសាមណេរកាលបើឃើញព្រះសម្ពុទ្ធស្តេចយាងទៅ

ដល់ហើយ ក៏ថ្លែងសេចក្តីទុក្ខរបស់ខ្លួនថ្វាយព្រះសម្ពុទ្ធ ។ ទ្រង់យកព្រះហស្តស្ទាបសិរិសាឧត្តរសាមណេរ ដោយថ្នាក់ថ្នមមានពន្លឺរស្មីផ្សាយចេញពីព្រះហស្តភ្លឺរន្ទោល ទើបមានព្រះពុទ្ធដីកាថា "ម្នាលសាមណេរ អ្នកកុំតូចចិត្តអំពើនេះជាអំពើរអ្នកបានសន្សំទុកមកជាយូរហើយ អ្នកទទួលទុក្ខលំបាកម្តងនេះ ជាទីបំផុតហើយលែងមានតទៅទៀត. ទ្រង់រំលឹកយ៉ាងនេះហើយទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា "កាលកន្លងយូរយារណាស់ហើយ នេនឯងកើតជាកូនអ្នកស្រែ បានចាប់រុយយកបន្លាស្រួចដោតក្តិត ហើយយកទៅដោតភ្ជាប់នឹងសំបកស្តៅសើចលេងសប្បាយ មាតាបិតាស្តីបន្ទោសបាននិយាយចំអកឱ្យវិញថា បើមិនឱ្យដោតរុយលេងមានតែដោតម៉ែនឹងឯងលេង ។ ដោយអំពើអាក្រក់នេះឯង បានជានេនឯងទទួលនូវសេចក្តីលំបាក ដោយគេដោតឱ្យដេកលើឈើអណ្តោតរាប់រយរាប់ពាន់ជាតិ ។ ម្យ៉ាងទៀតដែលតថាគតមកជួយសង្គ្រោះនេះដោយផលដែលនេនឯងកើតជាវិជ្ជាធរ បានបូជាផ្កាកណ្ណិកាបីទងដល់ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ។ កាលបើព្រះសម្ពុទ្ធមានព្រះពុទ្ធដីកាចប់ហើយ ឧត្តរសាមណេរក៏បានសម្រេចព្រះអរហត្តផលព្រមទាំងបដិសម្ភិទា ហើយទៅឰដ៏អាកាសធ្វើបដិហារ្យថ្វាយព្រះសាស្តាយ៉ាងអស្ចារ្យ ដល់ទីបំផុតព្រះជន្មក៏បរិនិព្វានទៅ ។

## ២០. រឿងព្រាហ្មណ៍សម្លាប់កូនធ្វើទាន

( ចាក គ. ទា. )

( សម្បត្តិរបស់ជនមានសទ្ធាមិនវិនាសសាបសូន្យ )

កាលពីព្រេងនាយ មានព្រាហ្មណ៍ម្នាក់មានសទ្ធាជឿស៊ប់ក្នុងព្រះពុទ្ធសាសនា ជាអ្នកពេញចិត្តក្នុងការធ្វើទាន ។ ព្រាហ្មណ៍នេះកាលមាតាបិតារៀបឱ្យមានគូស្រករ បានចែកទ្រព្យសម្បត្តិជាច្រើនស្មើភាគនឹងបងប្អូនរបស់គាត់ ដល់ពេលក្រោយមកព្រាហ្មណ៍នេះទៅជាអ្នកក្រដើរសុំទានគេ ឯបងប្អូនទាំងប៉ុន្មានសុទ្ធតែជាអ្នកមានទ្រព្យ ប៉ុន្តែគេមិនដែលឱ្យវត្ថុអ្វីបន្តិចបន្តួចដល់ព្រាហ្មណ៍នោះឡើយ. ពួកជនទាំងឡាយតែងហៅព្រាហ្មណ៍នោះថាទុគ្គតព្រាហ្មណ៍ ។ ឯទុគ្គតព្រាហ្មណ៍នោះមានកូនប្រុសមួយរូប ជាទីស្រឡាញ់ពេញចិត្តនៃឪពុកមានិងម្ដាយមីងក្រៃពេក ។ ថ្ងៃមួយមានព្រះអរហន្តមួយព្រះអង្គនិមន្តទៅបិណ្ឌបាត ទុគ្គតព្រាហ្មណ៍ឃើញហើយមានសេចក្ដីជ្រះថ្លា និមន្តចូលទៅផ្ទះដើម្បីទទួលភត្ត លុះលោកចូលទៅគង់ហើយទូលលោកឱ្យរងចាំភត្តបន្តិច ទើបគិតគ្នាប្ដីប្រពន្ធថា យើងបានអ្វីធ្វើចង្ហាន់លោក បើក្នុងផ្ទះយើងសូម្បីតែអង្ករ ១ គ្រាប់ក៏គ្មានផង ទុគ្គតព្រាហ្មណ៍នឹកឃើញថា បងប្អូនយើងស្រឡាញ់កូនយើងណាស់ បើយើងយកកូនទៅដាក់នៅមាត់រូងនាគរាជ ក្រោយផ្ទះយើង នាគនឹងខាំស៊ីមួយរំពេច ហើយយើងទៅប្រាប់បងប្អូនថា កូនស្លាប់ឥឡូវបាន

និមន្តលោក ១ អង្គមកធ្វើបុណ្យឱ្យវា ។ បងប្អូនយើងគេមុខតែយក អង្គរត្រីជាដើមមកឱ្យយើងធ្វើចង្ហាន់លោកមិនខាន, លុះគិតហើយ ក៏យកកូនទៅដាក់នៅមាត់រន្ធនាគរាជ ពួនចាំមើល ។ នាគរាជកាល បើធុំខ្លិនមនុស្សហើយ ក៏ស្ទុះចេញមក ។ ដោយគុណនៃសទ្ធាពិត ប្រាកដរបស់ព្រាហ្មណ៍ និងអានុភាពនៃអាយុរបស់កុមារនោះមិន អស់ផង ក៏បណ្តាលឱ្យនាគរាជនោះភ្ញាក់ផ្អើលនឹងកុមារ ស្ទុះរត់ ចេញទៅ ជ្រុះកែវពីក្នុងមាត់ក្បែរមាត់រន្ធ ។ កុមារឃើញកែវភ្លឺ ១ រើសយកមកកាន់លេង ។ ឯមាតាបិតាឃើញកូនកាន់កែវដូច្នោះ ក៏ ស្ទុះទៅយកកូននិងកែវ. កែវនោះល្អក្រៃលែងរកថ្លៃកាត់មិនបាន យកទៅលក់ឱ្យសេដ្ឋីក្នុងនគរនោះ គេមិនហ៊ានទិញព្រោះគ្មានលុយ ឱ្យ ។ ទុគ្គតព្រាហ្មណ៍ ក៏បញ្ចាំកែវទុកនឹងសេដ្ឋីសិន សុំយកម្ហូបចំណី ចាយសម្លមកប្រគេនលោក ។ ដល់ពេលក្រោយបានយកកែវទៅ ថ្វាយព្រះរាជា ១ ទ្រង់តាំងឱ្យធ្វើជាសេដ្ឋីក្នុងនគរនោះ ដល់អស់ អាយុបានទៅកើតក្នុងស្ថានសួគ៌ទៀត ។

រឿងនេះបំភ្លឺឱ្យឃើញថា សទ្ធាបើមានពិតប្រាកដមាំមួន ចំពោះបុគ្គលណាហើយ អាចរក្សានូវសម្បត្តិ ដែលបំរុងនឹងវិនាស មិនឱ្យវិនាស ហើយញ៉ាំងប្រយោជន៍ដែលជននោះប្រាថ្នាឱ្យសំរេច បានដូចបំណងសមដូចពុទ្ធភាសិតថា "សទ្ធាសាធុបតិដ្ឋិតា សទ្ធាដែល បុគ្គលបានដម្កល់ស៊ប់ហើយ អាចញ៉ាំងប្រយោជន៍ឱ្យសម្រេចបាន"។

## ២១. រឿងបុរសលិចសំពៅ

( ចាក ម. វា. )

( អ្នកមានកតញ្ញូកតវេទិតាធម៌ តែងមានទេវតាជួយ )

កាលពីព្រេងនាយ មានបុរសម្នាក់ឈ្មោះតម្កុលៈ នៅក្នុងក្រុងសាវត្ថី បានធ្វើដំណើរទៅកាន់ឧត្តរាបថជនបទ ក្នុងតិម្ករផ្លូវក្តៅខ្លាំងពេកចូលទៅជ្រកក្រោមម្លប់ឈើមួយ បានជួបនឹងបុរសម្នាក់ដែលចូលទៅជ្រកមុន ។ បុរសចូលទៅជ្រកមុនបាននិយាយសុំស្វាម្ចូថា ម្នាលសំឡាញ់អ្នកមានស្វាម្ចូឬទេ? បើមានខ្ញុំសូមទាន១មាត់ទទួលទានគ្រាន់មានទឹកមាត់ ព្រោះស្រេកទឹកខះកណាស់ ។ តម្កុលបុរសឮសូមដូច្នោះហើយ មានចិត្តមេត្តាករុណា បានឱ្យម្ចូស្វាមួយមាត់ទៅបុរសនោះបរិភោគ ។

កាលខាងក្រោយមក បុរសទាំងពីរនាក់បានឡើងជិះសំពៅឆ្លងមហាសាគរ ទៅជួញជាមួយនឹងពួកឈ្មួញទាំងឡាយ ទៅបាន ៧ ថ្ងៃមានខ្យល់ព្យុះជាខ្លាំងធ្លាយសំពៅកណ្តាលមហាសាគរ ពួកឈ្មួញទាំងឡាយត្រូវរលកទឹកបោកលិចស្លាប់អស់ នៅសល់តែតម្កុលបុរសនិងបុរសដែលបានសុំស្វាស៊ីក្នុងពេលដែលជ្រកក្រោមម្លប់ឈើឯបុរសដែលសុំម្ចូស្វា បានក្តារមួយបន្ទះតោងហែលទៅដោយឡែកតម្កុលបុរសឥតបានក្តារតោងទេ ខំហែលទៅដោយឡែកមានសេចក្តីទុក្ខលំបាកយ៉ាងខ្លាំង ស្ទើរតែនឹងស្លាប់ជួនជាអាយុមិនអស់ ក៏

អណ្តែកទៅជួបនឹងបុរសដែលសុំស្លាម្ហូ ១ នោះឃើញហើយចាប់លើកឡើងស្គាល់ច្បាស់ជាតម្កុលបុរស ដែលខ្លួនបានសុំម្ហូស្លាក៏ឱ្យតោងបន្ទាស់ក្តារ ហែលឆ្ពងទៅខ្លួនស្ងួហែលដៃទទេព្រោះនឹកឃើញគុណដែលឱ្យស្លាម្ហូ ១ មាត់ដល់ខ្លួនក្នុងពេលដែលខ្លួនស្រេកទឹកខ្លាំង

ឯតម្កុលបុរសកាលបើបានផែនក្តារហើយ ក៏ខំហែលសំដៅទៅរកត្រើយ ចំណែកខាងបុរសអ្នកហែលដៃទទេ ក៏ចេះតែខំហែលយូរទៅៗ អស់កំឡាំង ក៏បណ្តែកខ្លួននៅលើទឹក គិតថាអាយុអញអស់ក្នុងកណ្តាលមហាសាគរនេះហើយ ប៉ុន្តែស្លាប់ក៏ស្លាប់ចុះឱ្យតែតម្កុលបុរសអ្នកមានឧបការៈបានរស់ជីវិត កំពុងតែគិតយ៉ាងនេះ ក៏ក្តៅក្រហាយដល់ទេវតារក្សាសមុទ្រ ទេវតារំពឹងមើលឃើញបុរសនោះមានគុណធម៌ល្អ ក៏ស្ទុះទៅស្រង់យកទៅដាក់នៅត្រើយនាយមុនតម្កុលបុរស លុះតម្កុលបុរសទៅដល់ស្រាប់តែឃើញបុរសនោះនៅលើច្រាំងទើបសួរថា សំឡាញ់ឯងបានអ្វីជិះមកបានជាឆាប់ដល់ម្ល៉េះ ។ បុរសនោះប្រាប់តាមត្រង់ថា ខ្ញុំឥតដឹងខ្លួនទេអស់កំឡាំងពេក បណ្តែកខ្លួនលើទឹកចាំតែពេលនឹងស្លាប់ ស្រាប់តែដល់មកទីនេះតែម្តង ។ កំពុងតែនិយាយដូច្នោះទេវតាក៏បង្ហាញខ្លួនឱ្យបុរសទាំងពីរនាក់ឃើញហើយនិយាយប្រាប់ថា ខ្ញុំយកអ្នកមកព្រោះអ្នកមានកតញ្ញូកតវេទិតាធម៌ប្រាកដក្នុងខ្លួន បុគ្គលដែលមានភាពដូចអ្នកនឹងបណ្តោយឱ្យវិនាសមិនបានឡើយ តាំងពីព្រេងនាយមកទេវតា

ទាំងឡាយ មិនដែលមើលបំណាំបុគ្គលដែលប្រាកដស្មើដូចជាអ្នកនេះឡើយ។ ទេវតាប្រាប់ដូច្នេះហើយ ក៏ឱ្យបុរសទាំងពីររូបបរិភោគអាហារទិព្វ ស្លៀកពាក់គ្រឿងអលង្ការទិព្វ ហើយនាំទៅដាក់ក្នុងនគរសាវត្ថីក្នុងខណៈនោះឯង ។

## ២២. រឿងខ្លាធំនិងសេក

( ចាក ម. វា. )

( សេពនឹងជនអសប្បុរសអន់ជាងសេពនឹងសត្វតិរច្ឆាន )

កាលពីព្រេងនាយ មានភ្នំមួយឈ្មោះបំសុបព៌ត ស្ថិតនៅក្បែរព្រំអាណាចក្រពារាណសី ។ នៅញកភ្នំនោះមានខ្លាធំមួយ មេស្លាប់ចោលទៅ នៅជាមួយបាចាស់ជរា ។ ខ្លានេះជាសត្វសប្បុរសមានធម៌កតញ្ញូប្រចាំនៅជានិច្ច តែងនាំយកចំណីអាហារមកចិញ្ចឹមឪពុករបស់ខ្លួនដែលចាស់ជរា ។ កាលនោះមានសេកមួយក៏ជាសត្វសប្បុរសដែរ អាស្រ័យនៅនាភ្នំនោះ បានយកខ្លាធ្វើជាមិត្តសំឡាញ់យ៉ាងជិតស្និទ្ធ ។ សម័យខាងក្រោយមក មានបុរសម្នាក់នៅក្នុងបច្ចន្តជនបទ ជាមនុស្សអសប្បុរសឈ្មោះទាស់ប្តីប្រពន្ធលែងលះគ្នា ឯមនុស្សអសប្បុរសនោះ ក៏ដើរស្តាយបង្វិចកាត់ភ្នំបំសុបព៌តនោះសំដៅទៅក្រុងពារាណសី ទៅដល់ជើងភ្នំជួបនឹងសេក ១ ធ្វើបដិ-សណ្ឋារៈសួរដំណឹងសព្វគ្រប់ បានដឹងថានឹងឆ្លងកាត់ភ្នំទៅក្រុង

ពារាណសី ក៏ប្រាប់ថាភ្នំនេះមានខ្លាសាហាវច្រើនណាស់អញ្ជើញទៅពុំបានទេ ក្រែងមានគ្រោះថ្នាក់អញ្ជើញវាងតាមជើងភ្នំនេះទៅវិញ ។ បុរសនោះមិនព្រម ឆ្លើយប្រាប់ថាខ្ញុំចង់ប្រញាប់ស៊ូដើរកាត់ទៅចុះ ។ សេកយល់អធ្យាស្រ័យហើយ ក៏និយាយប្រាប់ថាបើដូច្នោះអញ្ជើញត្រង់ញកភ្នំនេះទៅ ខ្ញុំមានពួកម៉ាកសំឡាញ់ខ្លាធំមួយ បើទៅជួបប្រាប់ថា អ្នកជាមិត្រភក្ត្រនឹងខ្ញុំ ។ ឱ្យជូនដំណើរទៅក្រុងពារាណសី មើលសុខទុក្ខតាមផ្លូវឱ្យផងក្រែងសត្រូវមើលងាយ ។ មនុស្សអសប្បុរសឮដូច្នោះ មានសង្ឃឹមថានឹងធ្វើដំណើរកាត់ភ្នំនេះបានស្រួលហើយ ក៏រកអាហារស៊ីឱ្យមានកំឡាំង, សេកក៏បានរកផ្លែឈើឱ្យបរិភោគ មិនបរិភោគតែផ្លែឈើប៉ុណ្ណោះ ក៏យកដំបងវាយសំលាប់សេកនោះបោចអាំងស៊ីថែមទៀត លុះស៊ីហើយក៏ដើរសំដៅទៅរកកន្លែងខ្លាធំដែលសេកបានប្រាប់ ខ្លាឃើញបានដឹងថាជាមិត្តសំឡាញ់នឹងសេក ក៏រាក់ទាក់ឱ្យសំណាក់នៅមួយយប់សិន ខ្លាធំក៏ចេញទៅរកចំណីអាហារមកជប់លៀង ។ ក្នុងពេលដែលខ្លាធំចេញទៅ បុរសនោះនៅជាមួយខ្លាចាស់ជាឪពុក ក៏និយាយប្រាប់ខ្លាចាស់នោះថា អម្បាញ់មិញខ្ញុំសម្លាប់សេកមួយអាំងស៊ីឆ្ងាញ់ជាងសេកធម្មតា ដែលនិយាយយ៉ាងនេះ ដោយគិតថាខ្លាចាស់មិនដឹងជាសេកមិត្តសំឡាញ់នឹងខ្លាធំជាកូនទេ ។ ឯខ្លាធំរកចំណីបានហើយឱ្យបុរសនោះបរិភោគឆ្អែតដេកលក់ ។ ខ្លាចាស់ប្រាប់ថា បុរសនេះសម្លាប់

សេកមិត្រភក្ត្រកូនឯងស្លាប់ហើយ ។ ខ្លាធំឮហើយយំសោកស្ទុះរត់ទៅមើលកន្លែងដែលសេកនៅ ឃើញតែរោមនៅលើដីនឹកខឹងថានឹងស៊ីបុរសនេះវិញ ។ ឯបុរសនោះភ្ញាក់ឡើងបាត់ខ្លាធំ ក៏សួរខ្លាចាស់បានដឹងថាទៅមើលសេកដែលខ្លួនស៊ី ក៏កើតទោសៈចំពោះខ្លាចាស់យកដុំថ្មគប់ខ្លាចាស់នោះស្លាប់ទៅ ហើយយកដំបងមួយយ៉ាងធំឈរក្បែរគល់ឈើចាំវាយសំឡាប់ខ្លាធំទៀត ប៉ុន្តែដោយខ្លាធំមានធម៌សប្បុរសមិនអាចសម្លាប់បានឡើយ ឃើញខ្លាធំមកដល់ បុរសនោះក៏ភ័យញាប់ញ័រក្រាបថ្វាយបង្គំសុំទោស ។ ខ្លាធំក្រឡេកមើលទៅឃើញឪពុកត្រូវដំបងបែកក្បាលស្លាប់ ដឹងថាបុរសនោះសម្លាប់នឹកតូចចិត្តគិតខាំបុរសនោះម្តង ។ ប៉ុន្តែធម្មតាអ្នកមានធម៌សប្បុរសតែងមានគំនិតគិតវែងឆ្ងាយ ជឿបុណ្យជឿបាបយល់ហេតុផលច្បាស់លាស់ ទើបមានគំនិតថាមនុស្សនេះអសប្បុរស អញមិនគួរប្រទូស្តតបឱ្យជាប់ពៀរនឹងវាទេ សំឡាញ់អញក្តី ឪពុកអញក្តី ដែលស្លាប់ទៅគឺជាផលកម្មរបស់គាត់បានសាងពីបុព្វជាតិមក យល់ច្បាស់ដូច្នេះហើយ ក៏និយាយរាក់ទាក់ទៅរកបុរសនោះ ហើយជូនដំណើរទៅទៀតដរាបដល់ផុតទីមានគ្រោះថ្នាក់ ។

ឯសេកដែលស្លាប់ទៅ បានទៅកើតនៅស្ថានសួគ៌បរិបូណ៌ដោយទិព្វសម្បត្តិ ដោយអំណាចនៃសប្បុរសធម៌ ។ ចំណែកខាងខ្លាធំដល់អស់អាយុ ក៏បានទៅកើតនៅស្ថានទេវលោកដូចសេកដែរ ។

សេចក្ដីពិសេស គួរសង្ស័យថាខ្លាចាប់តែសត្វស៊ីជាអាហារ ធ្វើបាណាតិបាតរាល់ពេល ហេតុអ្វីក៏បានទៅកើតស្ថានសួគ៌ដែរ? ដែលទៅកើតស្ថានសួគ៌នោះ មិនមែនអំពើបាណាតិបាតនាំទៅកើតទេ គឺសប្បុរសធម៌ដែលមានក្នុងសម័យដែលមិនគួរមាននោះទេ នាំទៅកើត មិនចាំបាច់និយាយឡើយដល់ទៅខ្លាធំ ដែលមានសប្បុរសដល់ម្លោះ សូម្បីគ្មានសោះក៏ដោយ បើប្រសិនជាពេលជិតស្លាប់ ជនចិត្តចាប់បានកុសលធម៌ណាមួយហើយ ទៀងតែទៅសួគ៌សិនមិនខាន ដូចពុទ្ធភាសិតថា ចិត្តេ បរិសុទ្ធេ សុគតិ បាដិកង្ខា ចិត្តបរិសុទ្ធ ទៅសុគតិ ។

## ២៣ រឿងព្រះបាទអាភត្ថិរាជ

( ចាក លោ. ជា. )

( ជ័យជំនះរបស់បុថុជ្ជន មិនដែលមានតែម្នាក់ឯង )

កាលពីព្រេងនាយ មានព្រះរាជាមួយព្រះអង្គព្រះនាមអាភត្ថិរាជ មានឫទ្ធិអំណាចច្រើន អាចរិបជាន់យកនគររបស់ស្ដេចដទៃៗ មកធ្វើជានគរចំណុះរបស់ខ្លួនបាន ១០០ នគរ យកអគ្គមហេសីរបស់ស្ដេចទាំង ១០០ នោះមកធ្វើជាមហេសីរបស់ខ្លួន ។

កាលខាងក្រោយមក មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រះបាទកោរព្យរាជ សោយរាជសម្បត្តិនៅនគរឥន្ទបត្ត ទ្រង់វង្វៀស

ព្រះទ័យថា ព្រះបាទអាភង្គិរាជនឹងមកដណ្តើមយករាជសម្បត្តិក្នុងថ្ងៃណាមួយជាពុំខាន ទើបអញ្ជើញធនញ្ជយបណ្ឌិតបរមពោធិសត្វជាអ្នកប្រាជ្ញរបស់ព្រះអង្គមកពិគ្រោះការណ៍ ព្រះពោធិសត្វក្រាបទូលថារឿងនេះពិតណាស់ ព្រោះព្រះបាទអាភង្គិរាជជាមនុស្សពាលលុះលង់ទៅក្នុងសេចក្តីលោភ មិនគិតដល់សេចក្តីសុខទុក្ខរបស់ជនដទៃឡើយ។ ព្រះបាទកោរព្យរាជទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ព្រួយព្រះទ័យ ព្រោះមិនអាចទប់ទល់នឹងកំឡាំងទ័ពរបស់ព្រះបាទអាភង្គិរាជបានឡើយ ឯកំឡាំងទ័ពរបស់ព្រះបាទអាភង្គិរាជនោះមានដល់ទៅមួយអក្ខោភិនី ព្រោះរួមសេនាទាហានទាំង ១០០ នគរ មកបញ្ជាការតែមួយព្រះអង្គឯង ។ ព្រះពោធិសត្វជាអ្នកប្រាជ្ញឆ្នើមក្នុងលោក មានព្រះយោបល់ច្បាស់ក្នុងការធ្វើសឹកជាមួយនឹងព្រះបាទអាភង្គិរាជឱ្យមានជ័យជំនះ ដោយប្រើនយោបាយត្រជាក់ ទើបក្រាបទូលដល់ព្រះបាទកោរព្យរាជថា សូមព្រះករុណាកុំព្រួយព្រះទ័យឡើយ ទូលព្រះបង្គំនឹងយកព្រះបាទអាភង្គិរាជធ្វើជាកូនសិស្សហើយនាំមកថ្វាយបង្គំព្រះអង្គបាន ។ ព្រះបាទកោរព្យរាជទ្រង់ព្រះសណ្តាប់ហើយស្បើយចាកទុក្ខទើបត្រាស់សួរថា ការធ្វើសឹកនឹងព្រះបាទអាភង្គិរាជនោះ អ្នកត្រូវការទាហានប៉ុន្មាន? គ្រឿងសស្ត្រាវុធប៉ុន្មាន? ព្រះពោធិសត្វក្រាបទូលថា ធ្វើសឹកនេះមិនធ្វើដោយគ្រឿងសស្ត្រាវុធទេ ទូលព្រះបង្គំសុំតែមេទាហានអ្នកស្ទាត់ការ ៥០០ នាក់

ដែលកើតថ្ងៃជាមួយនឹងខ្ញុំព្រះអង្គ ហើយនឹងរទេះគោ ៥០០ប៉ុណ្ណោះទេ ។ ព្រះបាទកោរព្យរាជទ្រង់ព្រះរាជានុញ្ញាតតាមសូម ហើយទ្រង់ជប់លៀងដោយភោជនាហារដ៏មានឱជារស និងឱ្យពរសព្ទសាធុការដល់ព្រះពោធិសត្វ និងបរិវារទាំង ៥០០ ហើយបញ្ជូនទៅ ។ ព្រះពោធិសត្វចាត់ចែងរៀបផ្ទុកឥវ៉ាន់ពេញរទេះទាំង ៥ រយស្រេច ចូលទៅថ្វាយបង្គំលាមាតាបិតា ហើយចេញទៅកាន់នគរព្រះបាទអាភង្គិរាជ ក្លែងភេទជាឈ្មួញរទេះ បរិវារម្នាក់មានគូលី ៤ នាក់ បររទេះមួយៗ ចូលទៅកាន់នគរ ប៉ុន្តែមិនចូលទៅទាំងអស់គ្នាតែម្តងទេ គឺចូលទៅមួយថ្ងៃម្នាក់តាមទ្វារផ្សេងៗ គ្នា ទៅលក់ដូរឥវ៉ាន់ដូចឈ្មួញធម្មតា ទៅ ៣ ខែទើបដល់ លក់ឥវ៉ាន់អស់ឱ្យគូលីនាំរទេះមកវិញ ឯព្រះពោធិសត្វនិងបរិវារ ៥០០ នាក់សុំគេចូលធ្វើទាហានទាំងអស់គ្នា ហើយធ្វើជាមិនស្គាល់គ្នាឡើយមិនយូរប៉ុន្មាន ព្រះបាទអាភង្គិរាជក៏តាំងឱ្យធ្វើជាមេទ័ពធំទាំង ៥០០. ឯព្រះពោធិសត្វជាមេទ័ពធំបន្ទាប់ព្រះមហាក្សត្រ ១ តែងពិគ្រោះការណ៍ជាមួយ ព្រោះជាអ្នកមានសេចក្តីក្លាហាន អង់អាចឈ្លាសវៃក្នុងកិច្ចការទាំងពួង នៅធ្វើការជាមួយអស់រយៈ ១២ ខែ. ព្រះបាទអាភង្គិរាជឥតមានរង្កៀសសង្ស័យអ្វីឡើយ ព្រោះសំគាល់ថាជាពលរដ្ឋរបស់ព្រះអង្គ ។ ថ្ងៃមួយព្រះបាទអាភង្គិរាជប្រាប់ឱ្យព្រះពោធិសត្វ ធ្វើព្រះពន្លានៅទីឧទ្យាន ដើម្បីជប់លៀងពួកទ័ពទាំងអស់ ព្រោះតាំងពីច្បាំងដណ្តើម

យកនគរបាន ១០០ មកហើយមិនទាន់បានធ្វើបុណ្យសំរើបទឹកចិត្តទាហាននៅឡើយ ។ ព្រះពោធិសត្វក៏ចាត់មេទ័ពនិងកូនទាហានឱ្យរៀបធ្វើព្រះពន្លា និងកន្លែងស៊ីលៀងនៅទីឱទ្យាន តាមផែនទីដែលបានគូរឱ្យ លុះធ្វើហើយព្រះបាទអាភទ្ធិរាជយាងទៅទតមើលឃើញទីនោះគួរសប្បាយអស្ចារ្យ ទើបចាត់ការចែកឱ្យរៀបចំជប់លៀង ។ ក្នុងពេលដែលទៅស៊ីលៀងនោះ ព្រះពោធិសត្វបានឱ្យសញ្ញាដល់បរិវារ៥០០ នាក់របស់ព្រះអង្គថា អ្នកទាំងអស់គ្នាកុំផឹកស្រាឱ្យសោះ ហើយត្រូវចាក់ស្រាឱ្យពួកមេទាហាន និងកូនទាហានទាំងប៉ុន្មានផឹកឱ្យស្រវឹងពេញបន្ទុក ហើយយើងត្រូវធ្វើជាស្រវឹងបង្ករឿងឈ្លោះគ្នាស្រែកអឺរអរឡើង ព្រោះថ្ងៃនេះយើងត្រូវចាប់ព្រះបាទអាភទ្ធិរាជ បើអញចាប់ព្រះបាទអាភទ្ធិរាជហើយ ឯងម្នាក់ៗ ត្រូវចាប់មេទ័ពដែលចំណាន១ ចងស្លាបសេកឱ្យអស់ ។ ព្រះពោធិសត្វឱ្យការដល់បរិវាររួចហើយ ដល់ពេលស៊ីផឹកក៏ធ្វើតាមពាក្យព្រះពោធិសត្វ ឯព្រះពោធិសត្វចាំតែមើល កាលបើពួកមេទាហានផឹកស្រវឹងពេញបន្ទុកហើយ ពួកបរិវារបង្ករឿងជម្លោះស្រែកអឺរអរឡើង ព្រះបាទអាភទ្ធិរាជភ័យញ័រស្រែកឱ្យព្រះពោធិសត្វជួយ ក្រែងលោមានអន្តរាយដល់ព្រះអង្គ ។ ព្រះពោធិសត្វក៏ស្ទុះទៅចាប់ព្រះបាទអាភទ្ធិរាជ ហក់ស្ទុះទៅលើបានកំពស់៧ ត្នោតលៃទៅចុះនៅទីឆ្ងាយដែលបានសន្យានឹងបរិវារឱ្យទៅជួបជុំគ្នា។ ព្រះបាទអាភទ្ធិរាជឃើញឫទ្ធិអស្ចារ្យដូច្នោះ

ក៏ភ័យញ័រសព្វសាច់អង្វរសុំព្រះពោធិសត្វទុកអាយុឱ្យ ព្រះពោធិសត្វនិយាយគម្រាមថា ព្រះអង្គស្គាល់ទេនេះហើយធនញ្ជយបណ្ឌិតជាតិពោធិសត្វ ព្រះអង្គនេះអាក្រក់ណាស់ ជាស្តេចទុច្ចរិត រឹបជាន់យកនគរគេសម្លាប់គេចោល យកមហេសីគេមកធ្វើជាមហេសីខ្លួនឥតមានចិត្តអាណិតអាសូរដល់គេឯងឡើយ. កំពុងតែនិយាយដូច្នេះពួកបរិវារព្រះពោធិសត្វ៥០០ នាក់ចាប់ចងមេទ័ពទាំងអស់នាំយកមក. មេទ័ពដែលជាប់ចំណងនោះ ឃើញព្រះរាជារបស់ខ្លួនគោរពព្រះពោធិសត្វ ក៏អង្វរសុំអាយុជីវិតរៀង១ ខ្លួន ព្រះពោធិសត្វសួរទៅមេទ័ពទាំងនោះថា ព្រះរាជារបស់អ្នកល្អឬអាក្រក់ មេទ័ពទាំងនោះឆ្លើយថាអាក្រក់ណាស់ រឹបជាន់យកនគរគេ សម្លាប់គេចោលយកប្រពន្ធគេទៀត ជាស្តេចទុច្ចរិតអាក្រក់ផុតក្នុងលោក. ព្រះពោធិសត្វឃើញថា ពួកទ័ពនិងព្រះបាទអាភង្គិរាជឃើញទោសលាមករបស់ខ្លួនហើយ ក៏និយាយទូន្មានតាមគតិបណ្ឌិតលែងឱ្យរួចជីវិតរៀង១ខ្លួន ពួកទ័ពទាំងអស់មានព្រះបាទអាភង្គិរាជជាដើម ក៏សូមព្រះពោធិសត្វធ្វើជាគ្រូអាចារ្យ បានសមាទានសីល៥ អំពីព្រះពោធិសត្វ ប្រគល់រាជសម្បត្តិទាំង១០០ នគរឱ្យព្រះពោធិសត្វ១ បានចាត់ចែងឱ្យទៅម្ចាស់នគរវិញរៀង១ខ្លួន ឯព្រះបាទអាភង្គិរាជមានសេចក្តីត្រេកអរចំពោះព្រះពោធិសត្វយ៉ាងក្រៃលែង បានចាត់ចែងរៀបដំរីមង្គលអញ្ជើញព្រះពោធិសត្វឱ្យគង់មុខ ហែហមជូនទៅនគរឥន្ទប័ត្តវិញ ។

# ២៤. រឿងបុរសចាញ់បោកចោរ

( ចាក ម. វា. )

( កុំជឿពាក្យមិត្តសំឡាញ់ ដូចជឿពាក្យឪពុកម្ដាយ )

កាលពីព្រេងនាយ មានបុរសពីរនាក់ជាសំឡាញ់នឹងគ្នា ដល់ពេលខាងក្រោយមក បុរសម្នាក់ទាល់ក្រករកអ្វីចិញ្ចឹមជីវិតមិនបាន ក៏រត់ចូលទៅក្នុងព្រៃប្រព្រឹត្តធ្វើចោរកម្ម ពួករាជបុរសចាប់បានយកទៅដាក់គុកអស់ ១២ ឆ្នាំ ។ ថ្ងៃមួយបុរសជាសំឡាញ់ដើរទៅក្បែរគុក ឃើញបុរសនោះមានរូបស្គមជាប់ច្រវាក់នៅក្នុងគុក ក៏សុំអ្នករក្សាគុកចូលទៅសួរ ។ បុរសជាប់គុកប្រាប់ថាខ្ញុំមកនៅក្នុងទីនេះចំនួន ១២ ឆ្នាំហើយ មិនដែលបានអាហារឆ្អែតម្ដងទេ ខ្ញុំស្រេកឃ្លានណាស់ សូមសំឡាញ់ឯងជួយសុំអ្នករក្សាគុកឱ្យខ្ញុំចេញទៅរកទទួលទានអាហារឱ្យបានឆ្អែតហើយ ខ្ញុំត្រឡប់មកវិញភ្លាម ។ បុរសជាសំឡាញ់ឮដូច្នោះហើយ មានចិត្តមេត្តាករុណាអាណិតដរាបដល់ស្រក់ទឹកភ្នែកហូររហាម ក៏ដើរទៅថ្វាយបង្គំអ្នករក្សាគុកសុំប្ដូរឱ្យបុរសនោះចេញទៅរកអាហារបរិភោគ ។ អ្នករក្សាគុកនិយាយថា បើដូច្នោះ យើងត្រូវដាក់ច្រវាក់អ្នកឯងនៅក្នុងគុកនេះ ទំរាំសំឡាញ់អ្នកឯងត្រឡប់មកវិញទើបយើងលែង ។ បុរសនោះក៏ព្រមចូលទៅក្នុងគុកឱ្យអ្នករក្សាគុកដោះលែងសំឡាញ់ចេញពីច្រវាក់ ហើយឱ្យគេយកច្រវាក់មកដាក់ខ្លួន ។ បុរសចោរកាលបើបានរួចពីគុកច្រវាក់

ហើយ ក៏ដើរទៅស៊ីផឹកសប្បាយតាមអំពើរចិត្តខ្លួន ឥតនឹកដល់សំឡាញ់ដែលទៅធានាខ្លួននៅក្នុងគុកឡើយ ។

បុរសអ្នកធានា កាលបើមិនឃើញសំឡាញ់មកវិញហើយ ក៏នៅជាប់គុកច្រវាក់អស់ ១២ ឆ្នាំមិនដែលបរិភោគអាហារឆ្អែតម្តងឡើយ មានរូបកាយស្គាំងស្គម ដេកកើតទុក្ខខ្លោចផ្សានៅក្នុងគុកនោះឯង ។

សម័យមួយព្រះរាជាក្នុងនគរនោះ មានព្រះរាជបុត្រមួយព្រះអង្គទើបប្រសូត្រថ្មីៗ មានព្រះទ័យសោមនស្សចំពោះព្រះរាជបុត្រ ក៏ត្រាស់បង្គាប់ឱ្យរាជបុរសឱ្យអភ័យដល់សត្វជើងពីរជើងបួនទាំងឡាយ ឱ្យរួចពីចំណងទ្រុងគុកច្រវាក់ទាំងអស់ ។ អ្នករក្សាគុកក៏លែងចោរទាំងអស់ក្នុងគុកឱ្យរួចខ្លួនត្រឡប់ទៅផ្ទះរៀងៗខ្លួន។ ចោរទាំងឡាយសប្បាយចិត្តចេញទៅផ្ទះអស់ទៅ នៅសល់តែបុរសចាញ់បោកចោរជាសំឡាញ់មិនព្រមចេញឡើយ ។ អ្នករក្សាគុកឃើញហើយសួរថា ហេតុអ្វីបានជាអ្នកមិនចេញទៅផ្ទះនឹងគេ ។ បុរសនោះថាខ្ញុំមិនហ៊ានចេញទៅក្នុងវេលាថ្ងៃទេខ្មាសគេណាស់ ចាំយប់ស្ងាត់បានខ្ញុំចេញ ។ ដល់វេលាយប់ស្ងាត់បុរសនោះចេញពីគុកហើយមិនដឹងជាដើរទៅទីណា ព្រោះឃ្លានអាហារខ្លាំងពេក ទើបនឹកឃើញថានៅទីនេះមានព្រៃស្មសាននៅជិត ក៏ដើរចូលទៅក្នុងព្រៃស្មសាននោះ ឃើញសពខ្មោចមនុស្សនៅស្រស់ៗ ក៏រើសកាំបិតនៅក្បែរ

ជើងថ្ករអោយកសាច់ខ្មោច ហើយរើសដាក់ក្នុងអំបែងលលាដ៍ក្បាល យកលលាដ៍ក្បាលខ្មោចបីមកដម្កល់ធ្វើចង្ក្រាន ស្ងោសាច់ខ្មោចនោះធ្វើជាអាហារ ពេលដែលកំពុងស្ងោនោះបានយកស្នឹកឈើមកស្លៀកស្រាតយកខោទៅចាំងខ្យល់ ។ កាលនោះមានទេវតាមួយរូបនៅលើដើមឈើក្បែរទីនោះ ឃើញប្លែកដូច្នោះក៏សួរថា អ្នកជាអ្វីមានមុខក្រៀមក្រមមកចំអិនសាច់ខ្មោចស៊ីដូច្នេះ អ្នកយកខោចាំងធ្វើអ្វី? បុរសនោះឆ្លើយប្រាប់តាមដំណើររឿងរបស់ខ្លួនសព្វគ្រប់ ហើយប្រាប់ទៀតថា ដែលខ្ញុំយកខោចាំងនេះជាកិច្ចរបស់ខ្ញុំ ព្រោះថាខ្យល់ជាសភាវៈឥតវិញ្ញាណ ឥតខ្លួនប្រាណចេះតែបក់ផាត់តាមធម្មតា ប៉ុន្តែខ្យល់នេះមិនចេះឱ្យទោសដល់បុគ្គលណាឡើយ. ដែលខ្ញុំចាំងនេះគឺចាំងខ្យល់ពាក្យសំដីរបស់បុគ្គលពាល កុំឱ្យបក់ផាត់ដល់ខ្លួនខ្ញុំទៀត ដែលខ្ញុំលំបាកមកស៊ីសាច់ខ្មោចដូច្នេះ ក៏ព្រោះតែជឿខ្យល់ដែលផ្សាយចេញពីមាត់បុគ្គលពាលនោះឯង ។

ទេវតាស្ដាប់សព្វគ្រប់ហើយ មានសេចក្ដីអាណិតអាសូរដោយយល់ឃើញថា បុរសនេះជាបណ្ឌិតប្រាកដក្នុងលោក ទើបហៅបុរសនោះឱ្យស្លៀកសំពត់ទិព្វ បរិភោគអាហារទិព្វ ហើយនាំបុរសនោះទៅស្រែកឃោសនាសរសើរគុណធម៌ ឱ្យលាន់ឮពេញទេវទហនគរ ដោយឫទ្ធិរបស់ខ្លួន ។ ព្រះរាជាក្នុងនគរនោះឮហើយទ្រង់មានព្រះទ័យរំភើបញាប់ញ័រជាខ្លាំង ទើបឱ្យរាជអមាត្យនាំបុរស

នោះចូលគាល់ ទ្រង់ត្រាស់សួរបានជ្រាបដំណើររឿងសព្វគ្រប់ ក៏បន្ទូលព្រះសូរសីហនាទថា បុរសមានគុណធម៌ល្អបែបនេះមិនងាយរកបានក្នុងលោក យើងមិនដែលបានជួបប្រទះសោះឡើយ បុរសនេះគួរជាទីគោរពបូជារបស់ទេវតានិងមនុស្សទាំងឡាយ ឥឡូវនេះយើងសូមបូជារាជសម្បត្តិចំពោះបុរសនេះ អ្នកទាំងឡាយចូលរៀបចាត់ចែងរាជាភិសេកដល់បុរសនេះចុះ ។

ពួកមហាមាត្យទាំងឡាយ ក៏ចាត់ចែងរៀបពិធីរាជាភិសេកបុរសនោះឱ្យជាស្ដេចសោយរាជ្យក្នុងនគរនោះទៅ ។

## ២៥. រឿងសរណមាតា

( ចាក ម. វា. )

( ជាតិបុរសថោកទាបច្រើនលុះទៅក្នុងអំណាចស្ត្រី )

ក្នុងក្រុងសាវត្ថី មានគហបតីម្នាក់ឈ្មោះសុមនៈ ភរិយាឈ្មោះនាងសុជម្បកា មានកូនពីរនាក់ ប្រុស១ ស្រី១ ។ កាលកូនប្រុសមានអាយុ ១៦ ឆ្នាំ មាតាបិតាមានរោគាពាធជាទម្ងន់ បានហៅកូនទាំងពីរមកប្រគល់ទ្រព្យសម្បត្តិឱ្យ ហើយប្រគល់នាងជាប្អូនឱ្យបងរៀបចំឱ្យមានស្វាមីផង ផ្ដាំស្រេចហើយក៏ធ្វើមរណកាលទាំងពីររូបទៅ ។ បុត្តធីតានាំគ្នាធ្វើបុណ្យឈាបនកិច្ចតបស្នងសងគុណតាមទំនៀម ។ ខាងក្រោយមកបុរសជាបងមានភរិយា ដល់នាងជា

ប្អូនពេញរូបរាងហើយ មានបុរសដទៃមកដណ្តឹង ក៏រៀបឱ្យមានស្វាមី ហើយបញ្ជូនឱ្យទៅនៅក្នុងសំណាក់ម្តាយក្មេកឪពុកក្មេក. ដល់នាងមានគភ៌ចាស់ជិតគ្រប់ខែ សុំលាស្វាមីនិងមាតាបិតាក្មេកទៅប្រសូត្របុត្រក្នុងសំណាក់បង ស្វាមីក៏ជូននាងទៅ ទៅដល់ពាក់កណ្តាលផ្លូវជួបនឹងព្រះសម្ពុទ្ធ មានសេចក្តីជ្រះថ្លា បានថ្វាយខ្លួនជាឧបាសក-សិកាទាំងពីរនាក់ ក៏ហួសទៅ. ទៅដល់ស្វាមីប្រគល់ឱ្យបងហើយត្រឡប់មកផ្ទះវិញ ។ បងឃើញប្អូនទៅរកហើយ មានសេចក្តីត្រេកអរជាទីបំផុត បានហៅភរិយារបស់ខ្លួនឱ្យមើលថែរក្សានាង ។ នាងជាបងថ្លៃ ក៏ទំនុកបំរុងនាងដោយទឹកក្តៅនិងទឹកត្រជាក់ផ្សេងៗពីរបីថ្ងៃមក នាងបងថ្លៃឃើញខ្សែកពេជ្រដែលប្អូនថ្លៃពាក់នៅកចង់បានមកជារបស់ខ្លួន ប៉ុន្តែមិនដឹងគិតធ្វើដូចម្តេចឱ្យបាន ។ ថ្ងៃមួយនាងគិតឃើញឧបាយថា អញគិតដេកធ្វើពុតជាឈឺ បើស្វាមីអញសួរ ថាចង់ស៊ីសាច់បេះដូងនាងប្អូនថ្លៃ បើមិនបានស៊ីទេនឹងស្លាប់ គិតហើយក៏ដេកធ្វើពុតជាឈឺអត់បាយអត់ទឹក ស្វាមីសួរប្រាប់ថាចង់ស៊ីសាច់នាងប្អូនថ្លៃ ។ បុរសស្វាមីចេះតែឃាត់ នាងភរិយាចេះតែឃំស្រែកតួនត្អែររៀបរាប់រំលើកពីការកំសត់កម្រ និងការស្រឡាញ់គ្នា. បុរសថោកទាបគ្រាន់តែឮខ្យល់ដែលមានពីសកំណាចប៉ុណ្ណោះ ក៏ទៅលួងលោមប្រពន្ធថា ចាំបងសម្លាប់យកសាច់បេះដូងមកឱ្យអូនញ៉ាំ ។ នាងជាភរិយាគ្រាន់តែដឹងថា ស្វាមីដោយតាមខ្លួន

ហើយ ក៏ធ្វើជាគ្រាន់ចាត់ឈើចាប់មានមុខស្រស់ប៉ប្រឹម និយាយទៅរកស្វាមីថា បងឆាប់សម្លាប់វាទៅ ហើយយកខ្សែកពេជ្រមកឱ្យខ្ញុំផង ។ ចំណែកបុរសជាស្វាមីកាលបើលុះទៅក្នុងអំណាចប្រពន្ធហើយ ក៏ភ្លេចប្អូនបង្កើតរបស់ខ្លួនដែលកំព្រាឥតម៉ែឪ ទៅនិយាយបោកប្អូនរបស់ខ្លួនយកទៅសម្លាប់ថា ម្នាលប្អូនមានមនុស្សម្នាក់ជំពាក់បំណុលឪពុកម្ដាយយើង បើប្អូនទៅទារជាមួយបងគេនឹងឱ្យមួយរំពេច នាងព្រមទៅ បុរសជាបងទឹមរទេះហើយលើកនាងដាក់លើរទេះបរទៅៗ ដល់ពាក់កណ្ដាលព្រៃស្ងាត់បញ្ឈប់បរទេះចាប់នាងអូសទំលាក់ពីលើរទេះ នាងភ័យខ្លាំងស្រែកអង្វរថា សូមបងអាណិតខ្ញុំកុំធ្វើបាបខ្ញុំ ព្រោះខ្ញុំមានគភ៌ចាស់គ្រប់ខែហើយ ។ បុរសជាបងមិនព្រម ចាប់អូសនាងយកទៅសម្លាប់ នាងក៏ប្រសូត្របុត្រក្នុងពេលនោះសន្ធប់បាត់ស្មារតី លុះដឹងខ្លួនឡើងនាងនឹកឃើញដល់គុណព្រះសម្ពុទ្ធ នាងនឹកសូត្រភាវនាក្នុងមនោទ្វារថា នមោពុទ្ធស្សៗ ដូច្នេះពុំដែលដាច់ ។

មានសេចក្ដីអស្ចារ្យថា នៅលើដើមឈើនោះមានរុក្ខទេវតាមួយអង្គជាអ្នកមានឫទ្ធិ ឃើញនាងជាស្ត្រីសប្បុរសមានពុទ្ធានុស្សតិជាអារម្មណ៍ដូច្នោះហើយ ក៏ដឹងច្បាស់ថាស្ត្រីនេះជាអ្នកមានគុណធម៌ខ្ពស់ បើអញមិនជួយឱ្យមានជីវិតរស់នៅទេ ក្បាលអញនឹងបែកជា ៧ ចំណែកពុំខាន ។ ដឹងច្បាស់ដូច្នេះហើយ ក៏និម្មិតខ្លួនដូចជាប្ដី

របស់នាងកាន់ដំបងដេញបុរសជាបងរត់បាត់ទៅ ទើបនាំនាងនិងកូនតូចទៅដាក់ក្បែរផ្ទះ ព្រឹកឡើងស្វាមីបើកទ្វារផ្ទះឃើញប្រពន្ធរបស់ខ្លួនអង្គុយបីកូន ក៏ស្ទុះចុះទៅទទួលកូនសួរថា នាងមកជាមួយអ្នកណា បងយើងជូនមកឬ? នាងថា បងម៉េចក៏សួរខ្ញុំដូច្នោះ បើអម្បាញ់មិញបងនាំខ្ញុំមក ។ បុរសស្វាមីចេះតែប្រកែកថាមិនដឹង ទើបនាងនិយាយប្រាប់តាមរឿងរបស់នាងសព្វគ្រប់ ដរាបដល់មកអង្គុយក្បែរផ្ទះ បុរសជាស្វាមីដឹងដូច្នោះហើយ អាណិតប្រពន្ធណាស់ យំសោកបោកខ្លួនប្រាណ ប៉ុន្តែមិនបានចងគំនុំដល់បងថ្លៃឡើយ លុះបន្ទោបង់នូវសេចក្តីសោកហើយ ក៏និមន្តព្រះសម្ពុទ្ធព្រមទាំងព្រះសង្ឃជាច្រើនពាន់អង្គមកថ្វាយភត្ត ហើយកំណត់ដាក់ឈ្មោះឱ្យកូនថា "សរណៈ" ព្រោះកូននោះដែលបានរស់ឡើងដោយសារមាតានឹករឭកដល់ពុទ្ធគុណយកជាទីពឹង ទើបពោរាណាចារ្យទាំងឡាយឱ្យឈ្មោះមាតារបស់កុមារនោះថា "សរណៈមាតា" លុះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ធ្វើភត្តកិច្ចរួចស្រេចហើយ ព្រះសម្ពុទ្ធទ្រង់សំដែងធម៌ទេសនា ជនទាំងពីរនាក់ស្វាមីភរិយាបានសំរេចដល់សោតាបត្តិផល ។ ឯសរណកុមារដល់ធំដឹងក្តីឡើង ក៏ទៅបួសជាសាមណេរក្នុងសំណាក់ព្រះសារីបុត្ត ទើបមានឈ្មោះថា "សរណសាមណេរ" តាំងពីកាលនោះតមក ។

# ២៦. រឿងនាងវេស្សាមិត្តា

( ចាក ម. វា. )

( ទីពឹងទាំងពួងក្នុងលោកមិនស្មើទីពឹងព្រះរតនត្រ័យឡើយ )

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាម កោសម្ពិករាជ ព្រះអគ្គមហេសីព្រះនាមវេស្សាមិត្តា សោយរាជសម្បត្តិក្នុងក្រុងសម្ពិយ ។ ថ្ងៃមួយព្រះនាងវេស្សាមិត្តាបានស្ដាប់ធម៌ព្រះសម្ពុទ្ធកើតសេចក្ដីជ្រះថ្លា ថ្វាយខ្លួនជាឧបាសិកាយកព្រះរតន-ត្រ័យជាទីពឹងទីរលឹកស្មើដោយជីវិត តែងទំនុកបំរុងភិក្ខុសង្ឃដោយបច្ច័យទាំងបួនពុំដែលដាច់ ។ ចំណោរកាលខាងក្រោយមក មានស្ដេចបច្ចន្តរាជមួយអង្គប្រាថ្នាចង់បានរាជសម្បត្តិ លើកទ័ពមកបំរុងឡោមចាប់ព្រះបាទកោសម្ពិករាជ ៗ ទ្រង់ជ្រាបហើយ ក៏លើកទ័ពទៅច្បាំងយកព្រះអគ្គមហេសីទៅជាមួយផង រៀបចំព្រះពន្លាស្នាក់ទ័ពនៅឆ្ងាយពីសមរភូមិ ទុកព្រះអគ្គមហេសីឱ្យនៅក្នុងទីនោះ ហើយទ្រង់មានព្រះរាជឱង្ការប្រាប់ព្រះនាងជាអគ្គមហេសីថា បើឃើញលើកទង់ក្រហម ឱ្យនាងរត់ទៅពួនក្នុងទីណាឱ្យបានសុខចុះ គឺបង់ចាញ់ពួកបច្ចាមិត្រហើយ ទ្រង់មានព្រះរាជឱង្ការដូច្នេះហើយ ស្ដេចយាងទៅកាន់ទីសមរភូមិច្បាំងជាមួយស្ដេចបច្ចន្តរាជ ក៏បរា-ជ័យចាញ់ស្ដេចបច្ចន្តរាជ ទើបប្រាប់ឱ្យសេនាលើកទង់ក្រហម ស្ដេចបច្ចន្តរាជក៏ចាប់ព្រះអង្គធ្វើគត់ទៅ ។ ឯនាងវេស្សាមិត្តាជាព្រះអគ្គ-

មហេសី ត្រូវពួកទាហានខាងស្តេចបច្ចន្តរាជចាប់បាននាំយកទៅថ្វាយស្តេចបច្ចន្តរាជ ៗ ទតឃើញព្រះរូបឆោមល្អស្រស់ ក៏និយាយលួងលោមនាងដើម្បីមហេសី ព្រះនាងមិនព្រមទ្រង់មានព្រះសុវណ្ណិយថា ខ្ញុំជាស្ត្រីមានយសស័ក្តធំដោយសារព្រះស្វាមីខ្ញុំព្រះរាជទានឱ្យ ឥឡូវព្រះអង្គសម្លាប់ស្វាមីខ្ញុំ ហើយឱ្យខ្ញុំរីករាយជាមួយព្រះអង្គដូចម្តេចកើត ខ្ញុំមានតែសេចក្តីក្រោធចំពោះព្រះអង្គតែម្យ៉ាង ។ ព្រះបាទបច្ចន្តរាជទ្រង់ព្រះសណ្តាប់ហើយ ក្រោធពិរោធជាខ្លាំង បង្គាប់ឱ្យអមាត្យដុតភ្លើងឆេះសន្ធោសន្ធៅ ហើយបង្គាប់ឱ្យនាងចូលទៅក្នុងភ្លើង ព្រះនាងមិនព្រមចូល ទ្រង់មានព្រះសុវណ្ណិយតបថា ព្រះអង្គមានព្រះទ័យអាក្រក់ផុតជាងជនទាំងពួងក្នុងលោក សម្លាប់ស្វាមីគេហើយ ដុតសម្លាប់មហេសីគេទៀត ខ្ញុំគ្មានសត្រូវនឹងព្រះអង្គទេ មិនគួរអ្នកណាធ្វើទោសបានឡើយ ។ ព្រះបាទបច្ចន្តរាជឱ្យអមាត្យចងបោះទៅក្នុងភ្លើង ។ ក្នុងពេលដែលគេចាប់ចងព្រះនាងវេស្សាមិត្តា ទ្រង់រំពឹងថាអាត្មាអញគ្មានអ្វីជាទីពឹងទេ មានតែព្រះរតនត្រ័យទាំងបីជាទីពឹងដ៏ប្រសើររបស់អញ គិតដូច្នេះហើយនាងរំពឹងក្នុងព្រះទ័យថា ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ដូច្នេះពុំដែលដាច់ ។ ដោយគុណានុភាពព្រះរតន-ត្រ័យភ្លើងឥតមានក្តៅដល់ព្រះនាងឡើយ ទោះបីនៅក្នុងគំនរដើកភ្លើងធំដល់ម្ល៉ោះ ក៏ហាក់ដូចជានៅក្នុងត្របកឈូក ។ ព្រះបាទបច្ចន្ត

រាជទតឃើញអស្ចារ្យដូច្នោះហើយ ក៏ស្ទុះទៅយកនាងពីគំនរភ្លើង ហើយថ្វាយបង្គំនាងសុំធ្វើជាមាតាបង្កើត ទំនុកបំរុងនាងសព្វគ្រប់ឥតមានខ្វះ ។ ព្រះនាងវេស្សាមិត្តាទ្រង់រំលឹកទូន្មានព្រះបាទបច្ចន្តរាជនិងមហាជនឱ្យធ្វើទានរក្សាសីលគ្រប់ៗ គ្នា ដល់ព្រះនាងអស់អាយុ បានទៅកើតក្នុងទេវលោកបរិបូណ៌ដោយសម្បត្តិយ៉ាងអស្ចារ្យ ឯពួកមហាជនដែលប្រតិបត្តិតាមនាង ដល់អស់អាយុក៏បានទៅកើតទេវលោកដែរ ។

## ២៧~ រឿងព្រានព្រៃ

( ចាក សី. ឯ. )

( ទោសអកតញ្ញូជន ធ្ងន់ជាងភ្នំសិនេរុ )

កាលពីព្រេងនាយ មានព្រានព្រៃម្នាក់នៅក្នុងក្រុងពារាណសីធ្វើដំណើរទៅស្វែងរកទ្រព្យ ទុកបំរុងផ្គត់ផ្គង់ជីវិតរបស់ខ្លួនក្នុងព្រៃហេមពាន្ត ដើរវិលវល់ ៗ ក៏វង្វេងរកផ្លូវរកច្រកចេញមិនឃើញតាំងទ្រហោយំខ្ទរពេញព្រៃនោះ ។ កាលគ្រានោះព្រះពោធិសត្វទ្រង់យោនយកកំណើតជាដំរី មានសរីរកាយសសុទ្ធកំណត់នាមថាសីលវនាគរាជ បានឮនូវសំរែកទ្រហោយំនោះ ក៏មានសេចក្ដីករុណាអាណិតអាសូរបុរសនោះក្រៃពេក ទើបបញ្ជិះលើខ្នងនាំចេញពីព្រៃទៅដាក់ក្នុងផ្លូវមនុស្ស ហើយពោលប្រាប់ថា នែបុរសដ៏ចំរើន! អ្នក

អញ្ជើញទៅតាមផ្លូវនេះ ហើយបើមានគេសួរកន្លែងរបស់ខ្ញុំ អ្នកកុំប្រាប់ឱ្យសោះ ។ ឯព្រានព្រៃនោះជាមនុស្សទ្រុស្តមិត្តអកតញ្ញូ កាលជិះលើខ្នងដំរីពោធិសត្វ ក៏កំណត់នូវឈើព្រៃភ្នំតូចធំតាមលំដាប់ដរាបដល់ផ្លូវមនុស្ស លុះដល់ក្រុងពារាណសី បានឃើញជាងអ្នករចនាភ្លុកច្រើននាក់ក៏ពោលសួរថា នែជាងដ៏ចំរើនទាំងឡាយ អ្នកចង់បានភ្លុកដំរីទាំងរស់ដែរឬទេ? គាត់ស្តាប់ពាក្យជាងពោលតបថា អើភ្លុកដំរីរស់មានតម្លៃលើសលប់ ជាងភ្លុកស្លាប់ទៅទៀត ទើបគាត់រៀបចំស្បៀងអាហារពន្លាក និងរណារសព្វគ្រប់ ក៏ចូលទៅរកដំរីពោធិសត្វដើម្បីសុំភ្លុកទាំងពីរ ។ ដំរីពោធិសត្វកាលបើបុរសនោះកំពុងអារកាត់ភ្លុកដ៏ប្រសើរទាំងពីរ ក៏ច្បាមជាប់ដោយប្រមោយបំរុងនឹងបោកកំទេចទទួលគិតឃើញថា អញមិនឱ្យដោយបំណងថាភ្លុកទាំងឡាយនេះជាទីស្រឡាញ់របស់អញ. ណ្ហើយចុះ ភ្លុកទាំងនេះមិនមែនថ្លៃជាងសព្វញ្ញុតញ្ញាណទេ. អាត្មាអញនឹងឱ្យភ្លុកទាំងនេះទៅ ជាទានដល់ព្រាននោះ. ដើម្បីនឹងបានត្រាស់នូវសព្វញ្ញុតញ្ញាណ ព្រានព្រៃនោះ កាន់យកភ្លុកត្រឡប់ទៅនគរវិញ ក៏លក់ចាយវាយចិញ្ចឹមអាជីពអស់ទៅទើបទៅសុំម្តងទៀត ។ ឯដំរីក៏ឱ្យ ។ លុះព្រានត្រឡប់មកវិញ ក៏លក់ចាយវាយអស់ទៅទៀត ហើយសុំជាគំរប់ ៣ ដង ។ ឯដំរីពោលថា ប្រពៃហើយអញ្ជើញតាមត្រូវការ ទើបទ្រោមចុះឱ្យរាបប្រយោជន៍ឱ្យព្រានស្រួលអារកាត់។ រីព្រាននោះជាមនុស្ស

អកតញ្ញូមិនដឹងដប់ ក៏ឡើងជិះលើពោងដំរី ហើយកាត់ភ្លុកទាំងពីរ ទាំងបណ្តូល ឱ្យហូរឈាមសស្រាក់ពេញកន្រ្តាឥតមានករុណាបន្តិចឡើយ ធ្វើប៉ុណ្ណោះហើយមិនអស់ចិត្តអស់ចង់ ក៏ពន្លះសាច់និងគាស់ថ្គាមទៀតទើបចៀសចេញទៅ ។ គ្រាន់តែព្រានដើរផុតពីមុខដំរីភ្លាម មហាផែនដីដែលមានសមត្ថភាព អាចទ្រទ្រង់នូវភារៈដ៏ធ្ងន់ដូចយ៉ាងភ្នំសិនេរុ និងយុគន្ធរជាដើមបាន ក៏មិនអាចទ្រទ្រង់នូវគំនរទោសរបស់ព្រានចង្រៃនោះបានឡើយ ទើបបើកនូវចន្លោះឱ្យព្រាននោះចូលទៅ ។ អណ្តាតភ្លើងអវិចីក៏ចេញមកស្រោបព្រានអកតញ្ញូទ្រុស្តមិត្តនោះយ៉ាងទាន់ហាន់ ។ ពពួកទេវតាដែលអាស្រ័យនៅនាដើមព្រៃនោះ ក៏ស្រែកបន្ទឺពោលព្រមគ្នាថា :

អកតញ្ញុស្ស បោសស្ស　　និច្ចំ វិវរទស្សិនោ
សព្វញ្ចេ បថវឹ ទជ្ជា　　នេវ នំ អភិរាធយេ ។

សត្វអកតញ្ញូទោះបី　　រាជ្យយ៉ាងចំណានលើពសុធា
មិនអាញ៉ាំងខ្លួនឱ្យរមនា　　ព្រោះស្វែងទោសាគេជានិច្ច ។
ដំរីឋិតនៅដរាបដល់អស់អាយុ ក៏ទៅកើតតាមយថាកម្ម ។

( មហា សំ-សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ២៨- រឿងសច្ចកនិគ្រន្ថ

( ចាក ម. មូ. )

( បុណ្យព្រេងដែលបានសាងហើយ ដល់កំណត់កាលទើបឱ្យផល )

បានឮថា ក្នុងក្រុងវេសាលី មានគ្រិន្ថម្នាក់ឈ្មោះសច្ចកៈ ឬ អគ្គិវេស្សនៈ ជាអ្នកបង្រៀនសិល្បសាស្ត្រដល់ព្រះរាជកុមារ ពេលនោះគាត់ភ័យជាខ្លាំង ដោយគាត់យល់ឃើញថា ផ្ទៃពោះរបស់គាត់មុខជាធ្លាយ ព្រោះពេញប្រៀបទៅដោយបញ្ញាដ៏លើសលប់ ក៏យកបន្ទះដែកមករុំជិតទើបដើរទៅ ។ ថ្ងៃមួយគាត់ចូលទៅក្រាបបង្គំគាល់ព្រះសាស្ដា ក៏បានស្ដាប់ចូឡសច្ចកសូត្រទើបត្រឡប់ទៅផ្ទះទៅ ថ្ងៃក្រោយមកបានស្ដាប់មហាសច្ចកសូត្រពីសំណាក់ព្រះអង្គទៀត ។ និគ្រិន្ថនោះ សូម្បីបានស្ដាប់សូត្រទាំងពីរនោះចប់ដោយសព្វគ្រប់ ក៏នៅតែមិនបានត្រាស់ដឹង មិនបានបួស មិនបានតាំងខ្លួនឱ្យនៅស៊ប់សួនក្នុងសរណៈសោះ ។ អើគួរឆ្ងល់ណាស់ ព្រះមានព្រះភាគទ្រង់សំដែងប្រោសនិគ្រន្ថនោះធ្វើអ្វី? បើស្ដាប់ហើយមិនបានសម្រេចគុណវិសេសបន្តិចបន្តួចសោះ មានតែការនឿយលំបាកប៉ុណ្ណោះ ។ បានជាទ្រង់សំដែងប្រោសនិគ្រិន្ថនោះ ព្រោះឃើញច្បាស់នូវវាសនារបស់គាត់ក្នុងអនាគតកាល ដោយវិចារណញ្ញាណរបស់ព្រះអង្គថា ពិតតែឧបនិស្ស័យរបស់គាត់គ្មានក្នុងកាលឥឡូវនេះមែន ប៉ុន្តែតថាគតបរិនិព្វានទៅបាន ២១៨ ឆ្នាំ សាសនានឹងប្រតិស្ឋានទៅក្នុង

តម្ពបណ្ណិទ្វីប(កោះលង្កា) ហើយគាត់បានកើតក្នុងត្រកូលមួយនាតម្ពបណ្ណិទ្វីបនោះ, លុះកាលដ៏សមគួរដល់គាត់ ៗ នឹងចេញទៅបួសខំស្វាធ្យាយរៀនសូត្រព្រះត្រៃបិដក ហើយចំរើនវិបស្សនានឹងបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំង ៤ ជាមហាខីណាស្រពឈ្មោះ កាឡពុទ្ធរក្ខិត ជាពិត ។ ទើបសំដែងសូត្រទាំងពីរនោះប្រោស ។ ពិតដូច្នោះមែន, លុះសាសនាមកប្រតិស្ឋានក្នុងតម្ពបណ្ណិបទ្វីប គាត់ច្យុតចាកទេវលោកមកកើតក្នុងត្រកូលអមាត្យម្នាក់ នាភិក្ខាចារគ្រាមនៃវត្តឈ្មោះ ទក្ខិណាគីរី ពេលមានកាលដ៏សមគួរគាត់ក៏ចេញទៅបួសរៀនសូត្រព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកចេះចាំសព្វគ្រប់ ក៏បង្រៀនភិក្ខុសង្ឃជាច្រើន ។ ថ្ងៃមួយភិក្ខុនោះ ព្រមដោយមហាភិក្ខុសង្ឃជាបរិវារទៅគាល់ព្រះឧបជ្ឈាយ៍ ៗ ចង់ចោទភិក្ខុនោះ ហើយមិនស្ដីនិយាយអ្វីបន្តិចបន្តួចឡើយ ។ ភិក្ខុនោះថ្វាយបង្គំទៅវិញ លុះភ្លឺស្រាងៗ ក៏ចូលទៅគាល់សួរថា បពិត្រព្រះឧបជ្ឈាយ៍ដ៏ចំរើន លោកម្ចាស់មិនស្ដីនិយាយរកខ្ញុំព្រះករុណាដែលធ្វើនូវការរៀនសូត្រហើយមក តើខ្ញុំព្រះករុណាមានទោសដូចម្ដេច? ។ ព្រះថេរៈប្រាប់ថា នែអាវុសោពុទ្ធរក្ខិត អ្នកកុំសំគាល់ថា បព្វជិតកិច្ចរបស់អញដល់នូវទីបំផុតដោយហេតុប៉ុណ្ណោះឱ្យសោះ ។ បពិត្រព្រះឧបជ្ឈាយ៍ដ៏ចំរើន តើខ្ញុំព្រះករុណាធ្វើដូចម្ដេចទៀត ។ អ្នកលះបង់នូវគណៈ ហើយរំលាយចោលនូវកិលេស ជាគ្រឿងញាំងសត្វឱ្យយឺត

យូរចេញ ហើយធ្វើសមណធម៌ទៅ ។ ភិក្ខុនោះឋិតនៅក្នុងឱវាទរបស់ព្រះឧបជ្ឈាយ៍នោះហើយ ធ្វើតាមដោយសព្វគ្រប់ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាក្នុងពេលនោះឯង ។

( ព្រះមហា សំ-សុខ )

## ២៩- រឿងនាងវេទេហិកា

( ចាក ក. មូ. )

( កិត្តិសព្ទល្អច្រើនយ៉ាងណាក៏ដោយមានអាក្រក់តែបន្តិចរលត់បាត់អស់ )

បានឮថា កាលកន្លងទៅហើយ ក្នុងក្រុងសាវត្ថីមានគហបតានីម្នាក់ឈ្មោះវេទេហិកា ជាអ្នកស្លូតបូត ចេះលំអុតលំឱន និងមានចរិយាស្រគត់ស្រគំសមរម្យល្អ ។ កិត្តិសព្ទដ៏ពិរោះរបស់នាងនោះក៏រន្ទឺលាន់ឮសុសសាយថា នាងវេទេហិកា ជាស្ត្រីស្លូតបូត ចេះលំអុតលំឱន និងមានចរិយាស្រគត់ស្រគំល្អ ។ ឯនាងវេទេហិកានោះ មានទាសីម្នាក់ឈ្មោះនាងកាឡី ជាស្ត្រីវាងវៃមិនខ្ជិលច្រអូសប្រកបការងារសព្វយ៉ាងដោយត្រឹមត្រូវ ។ ថ្ងៃមួយ នាងចង់ល្បងមើលស្ត្រីជាម្ចាស់របស់ខ្លួន ដោយឧបាយដ៏ប្រសើរថា ស្ត្រីម្ចាស់អញមានសេចក្តីក្រោធខាងក្នុងស្ងប់រម្ងាប់មែនឬ ៗ គ្រាន់តែបញ្ចេញអាការៈខាងក្រៅឱ្យគេឃើញប៉ុណ្ណោះទេដឹង ទើបនាងដេកឱ្យយូរក្រោកឡើងថ្ងៃរះច្បាស់តែម្តង ។ នែនាងកាឡីថ្ងៃនេះម្តេចនាងដេក

យូរម្ល៉េះ ឬមួយមិនស្រួលខ្លួន។ បពិត្រស្ត្រីជាម្ចាស់ ខ្ញុំគ្មានកើតអីទេ។ នាងវេទេហិកាគ្រាន់តែឮពាក្យនោះ ក៏ខឹងច្រឡោតគោតត្បូងធ្វើមុខក្រញូវចងចិញ្ចើមក្រួចសើចដាក់ភ្លាម ហើយជេរផ្តាសាថា នែមីទាសីលាមកចង្រៃអប្រិយហួសប្រៀប បើហាងមិនឈឺទេ ម្តេចក៏ហាងដេកយូរម្ល៉េះ ។ ទាសីដឹងថា នាងជាម្ចាស់ខឹងដូច្នោះហើយស្អែកឡើងដេករឹតតែថ្ងៃរះជាងនោះទៅទៀត ដោយបំណងថា កំឡាំងសេចក្តីក្រោធមានសន្ទុះប៉ុនណាទៅទៀត បើល្បងមើលហួសប្រមាណយ៉ាងនេះ ។ នាងវេទេហិកាឃើញដូច្នោះ រឹងរិតតែខឹងលើសដើម ២-៣ ភាគទៀត ហើយក៏ស្ទុះទៅយកចន្ទាស់ទ្វារសំពងក្បាលនាងទាសីផ្ទូង ។ ក្បាលទ្រាំនឹងចន្ទាស់ទ្វារមិនបានក៏បែកឈាមហូររហាម ។ នាងកាឡីដឹងថាក្បាលបែកឈាមហូរដល់បំពង់កដូច្នោះហើយ ក៏ប្រាប់ស្ត្រីជាសំឡាញ់របស់ខ្លួនឱ្យរត់អស់ហើយស្រែកឃោសនាដោយសំឡេងគឹកកងថា អស់លោកទាំងឡាយ សូមលោកជួយពិនិត្យមើលកម្មរបស់ស្ត្រីអ្នកស្លូតបូត អ្នកចេះសំអុតលំឱន អ្នកមានចរិយាមារយាទសមរម្យស្រគត់ស្រគំល្អចុះ ។ កិត្តិស័ព្ទអាក្រក់ឮល្បីហួស កិត្តិសព្ទល្អទៅទៀតថា នាងវេទេហិកាជាស្ត្រីកាចអាក្រក់ នាងវេទេហិកាជាស្ត្រីមិនចេះលំអុតលំឱន នាងវេទេហិកាជាស្ត្រីមិនមានចរិយាមារយាទស្រគត់ស្រគំសោះឡើយ។

( ព្រះមហា សំ-សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣០. រឿងសេនកបណ្ឌិត

( ចាក ម. អ. )

( បុរសចាស់មានប្រពន្ធក្រមុំ ដូចបានដុំភ្លើង )

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមជនកៈ សោយរាជ្យក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វរបស់យើងសោយព្រះជាតិជាព្រាហ្មណ៍ ទ្រង់ព្រះនាមសេនកៈ នៅក្នុងក្រុងពារាណសីនោះដែរ. បានទៅសិក្សាសិល្បសាស្ត្រនានាក្នុងនគរតក្កសិលា ។ លុះត្រឡប់មកកាន់ស្រុកកំណើតព្រះអង្គវិញ ព្រះចៅក្នុងក្រុងនោះទ្រង់ព្រះរាជទានដំណែងជាអមាត្យ និងយសដ៏ធំដល់ព្រះពោធិសត្វ ៗ តែងឡើងគង់លើអាសនៈ ដែលឥស្សរជនទាំងឡាយមានព្រះរាជាជាដើម ប្រជាប់គាត់តែងសំដែងអត្ថនិងធម៌រៀងរាល់ថ្ងៃពេញបូណ៌មី តាមលំអានព្រះពុទ្ធ។ គ្រាក្រោយមកមានព្រាហ្មណ៍ចាស់ម្នាក់ ដើរសុំទានគេបានប្រាក់មួយពាន់កហាបណៈ យកទៅផ្ញើនឹងត្រកូលព្រាហ្មណ៍មួយ ហើយដើរទៅសុំទៀតតាមលំដាប់ហូរហែរ ។ ឯត្រកូលព្រាហ្មណ៍នោះយកប្រាក់ទៅចាយវាយទាល់តែអស់ ។ ដល់ព្រាហ្មណ៍ចាស់ត្រឡប់មកវិញរកប្រាក់សងមិនបាន ក៏ឱ្យកូនក្រមុំរបស់ខ្លួនធ្វើជាភរិយាព្រាហ្មណ៍ចាស់ ៗ ឥតមានប្រកែកបន្តិចបន្តួចព្រមយកទៅនៅក្បែរក្រុងពារាណសី ។ ឯប្រពន្ធនៅក្មេងមិនឆ្អែតស្កប់ស្កល់មេថុនធម្មសោះ ទៅធ្វើមិច្ឆាចារ (សាហាយ

ស្ងួន) ជាមួយនឹងព្រាហ្មណ៍កំឡោះម្នាក់ដែលមានវ័យស្មើគ្នា ។ ថ្ងៃមួយនាងព្រាហ្មណីនិយាយទៅព្រាហ្មណ៍ថា បពិត្រព្រាហ្មណ៍ ខ្ញុំមិនអាចធ្វើការងារក្នុងផ្ទះអ្នកឈ្នះទេ អ្នកត្រូវទៅសុំប្រាក់គេយកជួលខ្ញុំប្រុស ឬស្រីម្នាក់ឱ្យខ្ញុំ. ព្រាហ្មណ៍ចាស់ដោយហេតុតែស្រឡាញ់ប្រពន្ធក្មេងក្រៃពេកទុកជាយ៉ាងដូចម្តេចក៏ដោយ ឥតមានការយល់ទាស់ឡើយ ទើបនិយាយថាល្អហើយនាង ត្រូវហើយនាង ញាប់មាត់ ហើយស្ពាយការុងស្បែកសម្រាប់ដាក់សតូវ ត្រាច់ម្នីម្នាតាមច្រកល្ហកស្រុក និគមសុំទានគេបានប្រាក់ ៧ រយកហាបណៈ ដល់ត្រឡប់មកវិញ អង្គុយបរិភោគសតូវមាត់ផ្លូវ ក្បែរដើមឈើមានប្រហោងមួយដើម លុះបរិភោគរួចហើយ មិនបានចងមាត់ការុងដែលទុកត្រង់កន្លែងនោះ ដើរចុះទៅផឹកទឹកក្នុងស្ទឹង ។

កាលនោះ មានពស់វែកក្របីមួយនៅក្នុងប្រហោងឈើនោះធុំក្លិនសតូវ លូនចូលទៅក្នុងការុងស៊ីសតូវទាល់តែឆ្អែត ហើយពែនដេកសម្ងំស្ងៀមក្នុងទីនោះ ដល់ព្រាហ្មណ៍ត្រឡប់មកវិញ មិនបានជាចាប់ភ្លឹកគិតមើលនាយអាយ ក៏ចងមាត់ការុងស្ពាយដើរតយង៉យបានបន្តិចឮពាក្យរុក្ខទេវតាពោលថា ព្រាហ្មណ៍ក្នុងថ្ងៃនេះ បើអ្នកឈប់សម្រាកត្រង់ពាក់កណ្តាលផ្លូវអ្នកឯងស្លាប់. បើដើរទៅដល់ផ្ទះប្រពន្ធអ្នកស្លាប់ ។ ព្រាហ្មណ៍ឮដូច្នោះ ភិតភ័យអំពីសេចក្តីស្លាប់ជាខ្លាំង យំបណ្តើរដើរបណ្តើរ បានមកដល់ក្រុងពារាណសី ឃើញពួក

មហាជនជាច្រើននាក់កាន់គ្រឿងក្រអូប និងផ្កាកម្រងដើរទៅស្តាប់ធម៌ព្រះពោធិសត្វ ព្រាហ្មណ៍ឃើញដូច្នោះ ទើបសួរដឹងហេតុសព្វគ្រប់ប្រការហើយ គិតថា សេនកបណ្ឌិតជាធម្មកថិក មុខជាសំដែងធម៌ត្រង់ណាមួយ ដើម្បីកំចាត់បង់សេចក្តីសោករបស់អញបាន ដូច្នេះគួរតែអញទៅស្តាប់ធម៌. លុះគិតហើយ គាត់ដើរទៅជាមួយជនទាំងនោះ ដល់ហើយគាត់អង្គុយក្រោយពួកបរិស័ទទាំងអស់ ។ ព្រះពោធិសត្វឃើញដូច្នោះ គិតថាហេតុអ្វីហ្ន ! ទើបសួរដំណើរដែលសោកនោះ ។ ព្រាហ្មណ៍បានប្រាប់តាមពាក្យទេវតាពោលហើយសួរថា បពិត្របណ្ឌិត ហេតុដូចម្តេចបានជាខ្ញុំស្លាប់. ប្រពន្ធរបស់ខ្ញុំស្លាប់ ។ ព្រះពោធិសត្វទឹករំពឹងឃើញដោយប្រាជ្ញាឈ្លាសវៃក្នុងឧបាយ ដឹងហេតុសព្វគ្រប់ហើយ ទើបសួរទៅព្រាហ្មណ៍ថា សត្វក្នុងការុងអ្នកមានទេ? ព្រាហ្មណ៍ឆ្លើយថា បពិត្របណ្ឌិតមាន។ ចុះពីព្រឹកមិញអ្នកបរិភោគក្នុងទីណា? បរិភោគទៀបគល់ឈើត្រង់ពាក់កណ្តាលផ្លូវ ។ អ្នកបរិភោគរួចហើយចុះទៅផឹកទឹកបានចងមាត់ការុងឬទេ? មិនបានចងទេ ។ ព្រះពោធិសត្វពោលថា បើដូច្នោះមានពស់វែកក្របីមួយធំក្លិនសត្វចូលទៅក្នុងការុង. បើល្ងាចនេះអ្នកបរិភោគត្រង់ពាក់កណ្តាលផ្លូវ លូកយកសត្វមុខជាពស់ចឹកអ្នកស្លាប់. បើហួសទៅដល់ផ្ទះប្រពន្ធអ្នកលូកយកនំក្នុងការុងពស់នឹងចឹកស្លាប់. ពាក្យដែលទេវតាពោលព្រោះសំដៅហេតុហ្នឹង

ឯង, ដូច្នេះអ្នកត្រូវដាក់ការុងត្រង់កណ្ដាលបរិស័ទ ស្រាយមាត់រួច យកឈើគោះ មុខជាពស់លូនចេញ។ ព្រាហ្មណ៍ធ្វើតាម ពស់ក៏លូន ចេញមែនដកពពារធ្វើសំឡេងសុស ។ កាលនោះមានហ្មពស់ម្នាក់ យកពស់ទៅលែងចោលក្នុងព្រៃ ។ ពួកមនុស្សទាំងឡាយបានឃើញ ហេតុអស្ចារ្យដូច្នោះ និយាយគ្នាថា ព្រះពោធិសត្វនេះទាយដូចព្រះ សព្វញ្ញុពុទ្ធ ទើបនាំគ្នាលើកឡើងនូវសែននៃទង់ជ័យផង ទះដៃផង ស្រែកឱ្យសាធុការពរផង ។

គ្រានោះភ្ញៀវរតនៈ ៧ ប្រការបង្ហូរបូជាព្រះពោធិសត្វ ។ ឯ ព្រាហ្មណ៍ ក៏យកកហាបណៈដែលខ្លួនបានបូជាព្រះពោធិសត្វ ៗ មិន ព្រមទទួលយកសោះ បែរជាបង្គាប់ឱ្យជនឱ្យ ៣០០ កហាបណៈទៅ ព្រាហ្មណ៍ទៀត ដើម្បីបង្គ្រប់ ១០០០ កហាបណៈហើយសួរថា នែ ព្រាហ្មណ៍អ្នកណាប្រើឱ្យដើរសុំគេយ៉ាងនេះ? ព្រាហ្មណ៍ឆ្លើយថា បពិត្របណ្ឌិតប្រពន្ធប្រើ ។ ប្រពន្ធចាស់ឬក្មេង? បពិត្របណ្ឌិតនៅ ក្មេង ។ ព្រះពោធិសត្វពោលទៀតថា បើដូច្នោះប្រពន្ធរបស់អ្នកធ្វើ មិច្ឆាចារជាមួយនឹងព្រាហ្មណ៍ដទៃហើយ បានជាវាប្រើអ្នកឱ្យដើរសុំ គេ បើអ្នកយកកហាបណៈទាំងនេះទៅដល់ផ្ទះ មុខជាវាយកទៅ ឱ្យសាហាយ អ្នកត្រូវលាក់ទុកត្រង់ទីណាមួយសិន សឹមចូលទៅតែ ខ្លួនទទេចុះ ព្រាហ្មណ៍បានទៅដល់ស្រុករបស់ខ្លួនហើយ ក៏លាក់ទុក កហាបណៈទាំងនោះត្រង់មាត់ទ្វារស្រុក ទើបស្រែកហៅប្រពន្ធថា

នៃប្អូន នៃប្អូន ។ ពេលនោះនាងព្រាហ្មណីកំពុងចរចាលេងជាមួយសាហាយ បានឮពាក្យព្រាហ្មណ៍ស្រែកហៅក្តែង១ ក៏ពន្លត់ចង្កៀងបើទ្វារបន្តិចម្តង១ កាលបើឃើញព្រាហ្មណ៍ចូលផុតហើយ វាដឹកដៃសាហាយឱ្យទៅពួនត្រង់សន្ទះទ្វារ ទើបសួរទៅព្រាហ្មណ៍ថា អ្នកបានប្រាក់ប៉ុន្មាន? ព្រាហ្មណ៍ប្រាប់ថាបាន ១០០០ កហាបណៈ តែអញដំកល់ទុកត្រង់ទ្វារស្រុក មិនបានយកមកទេ ។ នាងព្រាហ្មណីទៅប្រាប់សាហាយ ១ ទៅយកទាល់តែអស់ ។ លុះព្រឹកឡើងព្រាហ្មណ៍ទៅយកកហាបណៈមិនឃើញសោះ ទើបទៅប្រាប់ដល់ព្រះពោធិសត្វម្តងទៀត ព្រះពោធិសត្វជ្រាបហេតុនោះសព្វគ្រប់ ក៏ឱ្យស្បៀងគ្រប់គ្រាន់ ៧ ថ្ងៃដល់ព្រាហ្មណ៍ ហើយប្រាប់ឧបាយថា អ្នកត្រូវអញ្ជើញព្រាហ្មណ៍ ១៤ នាក់គឺ ៧ នាក់ជាជិតុខាងអ្នក ៧ នាក់ទៀតជាជិតុនខាងប្រពន្ធ ឱ្យបរិភោគតាំងពីរថ្ងៃស្អែកទៅ ក្នុងមួយថ្ងៃ១ អ្នកត្រូវបន្ថយម្នាក់ ១ រៀងរាល់ថ្ងៃ លុះដល់ថ្ងៃទី ៧ អញ្ជើញតែពីរនាក់ គឺម្នាក់ខាងអ្នក ម្នាក់ទៀតខាងប្រពន្ធ. បណ្តាព្រាហ្មណ៍ទាំងអស់នោះ ព្រាហ្មណ៍ណាត្រូវជាជិតុនប្រពន្ធអ្នក មកគ្រប់ទាំង៧ថ្ងៃពុំដែលលោះខាន អ្នកត្រូវប្រាប់ដល់ខ្ញុំ ។ ព្រាហ្មណ៍ធ្វើដូច្នោះឃើញមែន ទើបទៅប្រាប់ដល់ព្រះពោធិសត្វ ១ ឱ្យបុរសទាំងឡាយទៅចាប់ព្រាហ្មណ៍ចោរនោះមក ហៅសួរថា អ្នកយកប្រាក់ ១០០០ កហាបណៈរបស់ព្រាហ្មណ៍នេះអំពីគល់ឈើនោះឬទេ? ព្រាហ្មណ៍

ចោរឆ្លើយថា បពិត្របណ្ឌិតខ្ញុំឥតយកទេ ។ ព្រះពោធិសត្វប្រាប់ថា ខ្ញុំហ្នឹងហើយឈ្មោះសេនកបណ្ឌិត អ្នកស្គាល់ទេឬ? ព្រាហ្មណ៍ចោរឮឈ្មោះភ្លាម ភិតភ័យជាខ្លាំង ទើបឆ្លើយប្រាប់ត្រង់ថាខ្ញុំយកមែន ឥឡូវនេះទុកត្រង់កន្លែងនោះ ។ ព្រះពោធិសត្វ ប្រើបុរសទាំងឡាយនាំព្រាហ្មណ៍ចោរទៅធ្វើអជ្ជារបស់ស្តេច ហើយឱ្យនិរទេសចេញពីនគរទៀត. ទើបឱ្យប្រាក់ ១០០០ កហាបណៈជាមួយនឹងយសយ៉ាងធំដល់ព្រាហ្មណ៍ចាស់ ហើយឱ្យនៅក្នុងសំណាក់របស់ព្រះអង្គទាំងពីរនាក់ប្ដីប្រពន្ធជាសុខរហូតដល់អស់អាយុ ។

( ព្រះមហា ប៉ុល_សៅ )

## ៣១_ រឿងស្តេចចណ្ឌប្បជ្ជោត

( ចាក ម. អ. )

( កម្លាំងនៃសេចក្ដីប្រាថ្នារបស់ជនមានសទ្ធា )

កាលកន្លងទៅហើយ មានឥស្សរជនម្នាក់ ធ្វើដំណើរទៅងូតទឹកខាងក្រៅនគរ លុះត្រឡប់មកវិញបានប្រទះព្រះបច្ចេកពុទ្ធមួយអង្គត្រាច់បិណ្ឌបាតត្រង់ពាក់កណ្ដាលផ្លូវ មិនបានចង្ហាន់សោះ គឺមានបាត្រទទេស្អាត ព្រោះពួកអ្នកនគរនោះ លុះដោយអំណាចមារចូលជ្រែកទាំងអស់គ្នា. ទើបគាត់ថ្វាយបង្គំនិមន្តឱ្យឈប់ ហើយសួរថា បពិត្រលោកម្ចាស់ដ៏ចំរើនបានចង្ហាន់ខ្លះដែរឬ? ព្រះបច្ចេកពុទ្ធ

ឆ្លើយតបថា ម្នាលអាវុសោ អាត្មាគ្រាន់តែចូលទៅភ្លាម ហើយចេញមកវិញ ។ ជនជាឥស្សរគិតថាលោកម្ចាស់នេះ មិនឆ្លើយតាមពាក្យអញសួរសោះ បែរជាពោលពាក្យដទៃវិញ ប្រហែលជាមិនបានចង្ហាន់ទេមើលទៅ ទើបឱនឈ្ងោកមើលក្នុងបាត្រ មិនឃើញមានចង្ហាន់មួយគ្រាប់សោះ គាត់គ្រាន់តែននះននាទប៉ុណ្ណោះ មិនបានយកបាត្រទៅទេ ព្រោះគាត់មិនដឹងភត្តឯផ្ទះមានឬគ្មាន ទើបទូលថាបពិត្រលោកម្ចាស់បង្អង់ចាំកាលបន្តិច. គាត់ក៏ស្ទុះរត់ទៅផ្ទះដោយសន្ទុះយ៉ាងលឿន ដឹងថាមានភត្ត ក៏បញ្ជូនអ្នកបំរើម្នាក់ថា នែអ្នកអ្នកឯងត្រូវរត់ទៅយកបាត្រលោកម្ចាស់ឱ្យលឿនមក ។ អ្នកបំរើក៏រត់ទៅយកមកបាន ។ ជនជាឥស្សរដាក់ភត្តក្នុងបាត្រទាល់តែពេញហើយពោលម្តងទៀតថា អ្នកយកបាត្រទៅប្រគេនលោកម្ចាស់យ៉ាងឆាប់ អញចែកបុណ្យឱ្យអ្នកខ្លះ ។ បុរសនោះ ស្ទុះរត់ទៅយ៉ាងលឿនប្រគេនបាត្រទៅព្រះបច្ចេកពុទ្ធ រួចថ្វាយបង្គំតាំងសេចក្តីប្រាថ្នាថាបពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា ទៅផង មកផង ដោយរបៀនយ៉ាងរហ័សនេះ សូមឱ្យខ្ញុំព្រះករុណាកើតជាតិណា ៗ មានវាហនៈទាំងឡាយទៅបានចម្ងាយ៥០ យោជន៍, ៦០ យោជន៍, ១០០ យោជន៍ និង ២០០ យោជន៍, ដែលខ្ញុំព្រះករុណារត់ទៅមកក្តៅដោយកំដៅព្រះអាទិត្យ សូមឱ្យមានអំណាចដូចជាកំដៅព្រះអាទិត្យ, ទាំងចំណែកបុណ្យដែលម្ចាស់ខ្ញុំព្រះករុណាឱ្យនោះសូមឱ្យបាន

សម្រេចដូចសេចក្ដីប្រាថ្នា ។ ព្រះបច្ចេកពុទ្ធពោលថា សេចក្ដីប្រាថ្នា ដែលអ្នកប្រាថ្នាហើយឱ្យបានសម្រេចឆាប់រួសរាន់ទាន់ចិត្ត ។ បុរស នោះ អន្ទោលទៅមកក្នុងសំសារវដ្ដជាយូរអង្វែង ដល់ពុទ្ធកាល ព្រះសម្មាសម្ពុទ្ធយើងនេះ បានមកកើតជាស្ដេចទ្រង់ព្រះនាម ចណ្ឌប្បជ្ជោត នានគរឧជ្ជេនី. ដោយអានិសង្សនោះ ព្រះអង្គមាន វាហនៈ៥ គឺ មេដំរីមួយ ទៅមួយថ្ងៃបាន ៥០ យោជន៍, ខ្ញុំប្រុសម្នាក់ រត់មួយថ្ងៃបាន៦០ យោជន៍, សេះពីរឈ្មោះវេលកំសិ និងមុញ្ជកេសិ រត់មួយថ្ងៃបាន១០០ យោជន៍. ដំរីឈ្មោលឈ្មោះនាឡាគីរី រត់មួយ ថ្ងៃបាន២០០ យោជន៍សម្រេចដូចសេចក្ដីប្រាថ្នាមែន ។

( ព្រះមហា ប៉ុល_សៅ )

## ៣២_ រឿងតក្កបណ្ឌិត

( ចាក ម. អ. )

( ទោសកាមេសុមិច្ឆាចារ )

ពួដ៍អតីតកាល ព្រះបរមពោធិសត្វរបស់យើងជាតាបសនៅ ជាសុខក្នុងឈាននាបណ្ណសាលាទៀបឆ្នេរគង្គារ ។ មានសេដ្ឋីធីតា នៅក្នុងក្រុងពារាណសីម្នាក់ឈ្មោះទុដ្ឋកុមារី ជាស្រីធ្លាស់និងកាច ឃោរឃៅក្រៃពេក បានជេរប្រទេចវាយពួកកម្មករទាំងឡាយគ្មាន សំចៃដៃ ។ ថ្ងៃមួយពួកកម្មករទាំងនោះបានចាប់យកនាងទៅទំលាក់

ក្នុងស្ទឹងគង្គា។ ទុដ្ឋកុមារីនោះអណ្តែកទៅតាមខ្សែទឹកស្រែកយំហ៊ូៗ ដល់ទៅកន្លែងក្បែរសាលាបរមពោធិសត្វតាបស ក្នុងពេលអធ្រាត្រ សន្លប់បាត់ស្មារតី ។ តាបសក៏ស្រង់នាងពីទឹកដោយសេចក្តីអាណិតអាសូរ ហើយធ្វើរដរាបដល់នាងមានស្មារតីឡើង ទើបឱ្យផ្លែឈើទុំខ្ទិបរិភោគក៏សួរថា នាងនៅក្នុងទីណា? ចា ! នៅក្នុងក្រុងពារាណសីលោកតា ។ នាងចូរទៅឥឡូវទៅ (តាបសពោលយ៉ាងនេះ ដោយខ្លាចនាងធ្វើទុក្ខបុកម្នេញ ម្ងិកម្ងក់ឱ្យធ្លុះធ្លាយសីលរបស់ខ្លួន) ។ ស្រីនោះគិតថា អញត្រូវប្រលោមតាបសនេះ ដោយធ្វើអាការៈញ៉េះញ៉ោះលុះត្រាតែមានតម្រេកស្នេហ៍ស្និទ្ធទប់អាត្មាមិនបាន ដោយកាមតណ្ហាបានជាគូសង្សាសិន សិមទៅទាំងពីរនាក់ ។ តាបសទប់អាត្មាមិននឹង ដោយមេអសុភស្រស់លងបន្ទាចបង្ហាញអាការគួរស្ញើមក្រៃពេក ក៏រលំខ្លួនទៅផ្តេកផ្តិតស្និទ្ធស្នេហាលុះត្រាតែធ្លាយធ្លុះសីល មានឈានសាបសូន្យ ក៏ទៅកាន់ស្រុកប្រទល់ដែនជាមួយស្រីនោះ ហើយលក់ដូរខ្លាញ់បានប្រាក់បន្តិចបន្តួចគ្រាន់នឹងទិញស្បៀងអាហារចិញ្ចឹមអាជីព នៃគូសង្សាកំសត់របស់ខ្លួនតែរាល់ថ្ងៃ ។ ព្រោះហេតុនោះ ជនទាំងឡាយក៏កំណត់នាមធេយ្យតាបសតាមហេតុនោះថា តក្កបណ្ឌិត ។ មនុស្សទាំងឡាយក៏ឱ្យបរិព្វយវត្ថុដល់តក្កបណ្ឌិតនោះ ហើយឱ្យកូនខ្ទមមួយគ្រាន់ជាទីជ្រកកោនទៀបទ្វារស្រុក ។

ថ្ងៃមួយ ពួកចោរចូលទៅប្លន់ស្រុកនោះ ហើយចាប់យកប្រពន្ធតក្កបណ្ឌិតទៅឱ្យមេរបស់ខ្លួន ។ មេចោរក៏ទទួលយកស្រីនោះធ្វើជាស្រីកំណាន់ ។ នាងនោះចង់សម្លាប់តក្កបណ្ឌិតណាស់ ក៏ធ្វើលិខិតមួយច្បាប់ផ្ញើទៅប្រាប់ដូចសេចក្ដីតទៅនេះ :

"បពិត្រស្វាមីប្ដីកំសត់! ឥឡូវនេះខ្លួនប្អូនមានទុក្ខយ៉ាងធ្ងន់ដោយចោរទាំងឡាយចាប់យកធ្វើជាស្រីកំណាន់របស់វា ប្រព្រឹត្តធ្វើកាមេសុមិច្ឆាចារ ឥតមានកោតស្ញែងសោះ ហេតុនោះសូមយកប្អូនទៅវិញឆាប់ៗ កុំខាន ។

តក្កបណ្ឌិតក៏ទៅយ៉ាងរួសរាន់ ។ ឯនាងនោះឃើញតក្កបណ្ឌិតមកដល់ខ្សឹបប្រាប់ថា ប្រសិនបើយើងទៅឥឡូវនេះ សមចោរតាមចាប់ហើយសម្លាប់យើងមិនខាន ចាំរាត្រីកាលសឹមទៅ. ហើយឱ្យអង្គុយក្នុងបន្ទប់មួយ ទើបទៅប្រាប់មេចោរដែលកំពុងស្រវឹងស្រាក្នុងពេលល្ងាចថា ប្ដីខ្លួនមកនៅក្នុងបន្ទប់ឯណោះ ប្រុងប៉ុនប៉ងប្រមាថពាធជន្ទលោក ។ ចោរស្ទុះទៅចាប់តក្កបណ្ឌិតចងផ្ដេកចុះ ហើយវាយតាមចិត្តក្ដៅ ។ តក្កបណ្ឌិត ចោរវាយយ៉ាងណាក៏មិនស្រែកយំឡើយ គ្រាន់តែពោលថា ស្រីទ្រុស្តមិត្តមានសេចក្ដីក្រោធផង មិនដឹងគុណគេផង ជាអ្នកញុះញង់ផង ។ ឯចោរ បើស្រាស្វាងហើយក៏ប្រារព្ធវាយទៀត ។ តក្កបណ្ឌិត ក៏ពោលតែពាក្យនោះ ។ ចោរគិតថា យី ! គាត់នេះ ពោលពាក្យដដែលៗ ប្រហែល

ជាមានហេតុយ៉ាងណាហើយដឹង? ក៏សួរតាបស ។ ប្រាប់ដំណឹងទាំងអស់ហើយគិតម្តងទៀត អើ! ស្រីនេះកាឡកណ្ណីអីម្លេះ អញសម្លាប់ចោលហើយមិនទុកទេមើលទៅ. ក៏ដាស់ថា មកនាង អញនឹងសម្លាប់បុរសនេះ. ហើយចេញទៅខាងក្រៅស្រុកបែរជាសម្លាប់ស្រីនោះវិញ ទើបនាំតក្កបណ្ឌិតទៅផ្ទះសួរថា ឥឡូវអ្នកនឹងនៅក្នុងទីណា? ខ្ញុំនឹងបួសនៅក្នុងព្រៃ ។ បើអ្នកបួស ខ្ញុំក៏បួសដែរ ។ តក្កបណ្ឌិត និងមេចោរក៏បួសទាំងពីរនាក់ខំចំរើនឈាន និងអភិញ្ញាឱ្យកើត លុះស្លាប់បានទៅកើតឯព្រហ្មលោកនាយ ។

## ៣៣. រឿងសេដ្ឋីបុត្រ

( ចាក ម. អ. )

( គុណនៃការពោលពាក្យទៀងត្រង់ )

កាលយូរលង់ណាស់ហើយ មានសេដ្ឋីបុត្រ ៣ នាក់នៅក្នុងក្រុងពារាណសី ។ ជួនជាក្នុងនគរនោះមានស្រះមួយដ៏ពោរពេញទៅដោយផ្កាឈូកក្រហមស រីកស្គុះស្គាយគួរជាទីមនោរម្យក្រៃពេក តែមានបុរសកំបុតច្រមុះម្នាក់ជាអ្នកថែរក្សា ។ ថ្ងៃមួយសេដ្ឋីបុត្រទាំង ៣ នាក់នោះចង់ប្រដាប់កាយដោយកម្រងផ្កាហើយនឹងលេងមហោស្រព ក៏ចូលទៅរកបុរសកំបុតច្រមុះហើយគិតថា យើងនឹងពោលនូវគុណ របស់បុរសកំបុតច្រមុះនោះដោយពាក្យមិនពិត

ហើយនិយាយសុំផ្ការៀងៗ ខ្លួន ។ សេដ្ឋីបុត្រទី ១ ពោលសុំដោយបទជាគាថា ថា :

**យថា កេសា ច មស្សុ ច ឆិន្នំ ឆិន្នំ វិរូហតិ**
**ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ ៕**

សក់និងពុកមាត់ ដែលគេកាត់កោរហើយរមែងដុះវិញ យ៉ាងណាច្រមុះអ្នកក៏ដុះវិញយ៉ាងនោះ ចូរឱ្យផ្កាឈូកដល់ខ្ញុំ ។

សេដ្ឋីបុត្រទី ២ ពោលថា

**យថា សារទិកំ ពីជំ ខេត្តេ វុត្តំ វិរូហតិ**
**ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ ៕**

ពូជដុះក្នុងសរទកាល ដែលគេព្រោះក្នុងស្រែយ៉ាងណាច្រមុះអ្នកក៏ដុះយ៉ាងនោះ ចូរឱ្យផ្កាឈូកដល់ខ្ញុំ ។

ឯសេដ្ឋីបុត្រទី ៣ ពោលសុំថា

**ឧភោបិ បលបន្តេតេ អបិ បទ្មានិ ទស្សតិ**
**វជ្ជុំ វា តេ ន វា វជ្ជុំ នត្ថិ នាសាយ រូហនា**
**ទេហិ សម្ម បទុមានិ ត្វំបិ មេ តស្ស យាចិតោ ៕**

សេដ្ឋីបុត្រ ២ នាក់នោះពោលបញ្ឆោះដើម្បីឱ្យអ្នកឱ្យផ្កាឈូក. តាមការពិតសេដ្ឋីបុត្រនោះពោលក្តី មិនពោលក្តី ធម្មតាច្រមុះមិនល្បីថាដុះវិញឡើយ ម្នាលសំឡាញ់ខ្ញុំសុំផ្កាអ្នក ចូរអ្នកឱ្យផ្កាដល់ខ្ញុំ ។

បុរសកំបុត្រច្រមុះឮពាក្យនោះពោលតបថា សេដ្ឋីបុត្រពីរនាក់នេះពោលមុសាវាទ រកការពិតគ្មាន ឯសេដ្ឋីបុត្រទី ៣ ពោលតាមពិត ខ្ញុំនឹងឱ្យផ្កាដល់សេដ្ឋីបុត្រទី ៣. ហើយហុចឱ្យនូវបាច់នៃផ្កាឈូកដ៏ធំដល់សេដ្ឋីបុត្រទី ៣ នោះ ។

( ព្រះមហា សំ_សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៤_ រឿងភិក្ខុកូនសេដ្ឋី

( ចាក បុ. សា. )

( គូព្រេងធ្លាប់សាងជាមួយគ្នាពីដើមមកមិនដែលព្រាត់ )

កាលពីព្រេងនាយ បោរាណបណ្ឌិតបានដំណាលទុកមកថា មានភិក្ខុ ១ រូបជាកូនសេដ្ឋីមានទ្រព្យសម្បត្តិច្រើន ។ ថ្ងៃមួយសេដ្ឋីជាបិតា របស់ភិក្ខុមកធ្វើបុណ្យក្នុងវត្តនោះ មានខ្ញុំស្រីម្នាក់មានកូនតូច ទើបនឹងចេះដើរបន្តិច ។ ជាប់តាមមកបំរើសេដ្ឋីនោះ នាងខ្ញុំស្រីក៏ទៅចងអង្រឹងឱ្យកូនដេកក្រោមកុដិភិក្ខុនោះ ។ ជួនជាពេលនោះ មានតាចាស់ម្នាក់ចេះទាយមើលគូព្រេង ក៏ឡើងមកលេងសប្បាយនឹងភិក្ខុនោះ និយាយពីនេះពីនោះយូរបន្តិច ក៏ភិក្ខុនោះរកតានោះមើលគូព្រេងឱ្យ ។ តានោះក៏ពិនិត្យមើលតាមដំណើរក្បួនឃើញច្បាស់ ហើយក៏និយាយថា លោកចៅកុំអន់ចិត្តនឹងតា ទើបតាហ៊ានទាយឱ្យបាន ។ លោកនោះថា កុំព្រួយ អាត្មាមិនអន់ចិត្តទេ

អាណិតតែទាយឱ្យត្រឹមត្រូវឱ្យចុះ ។ ទើបតានោះទាយថា លោកចៅសិកទៅវិញ មុខជានឹងបានប្រពន្ធកូនខ្ញុំគេជាប្រាកដ ។ លោកនោះឮដូច្នោះក៏ធ្លាក់ទឹកមុខមិនសប្បាយចិត្តសោះ ទើបសួរដេញដោលទៅទៀតថា កូនហ្នឹងតើកើតហើយឬនៅ? តានោះប្រាប់ថាកើតហើយ គេបានទាំងនាំយកមកក្នុងកំឡុងបុណ្យនេះផង ។ តាគ្រូទាយនោះទាយរួចហើយក៏លាចុះទៅវិញបាត់ទៅ ។ ក្រោយពីនោះមកភិក្ខុនោះថា មានកូនអ្នកណាជាកូនខ្ញុំគេមកក្នុងឱកាសបុណ្យនេះលុះរំពឹងទៅឃើញ មានតែខ្ញុំស្រីម្នាក់ដែលតាមមកបំរើមាតាបិតាហើយយកទាំងកូនស្រីតូចមកចងអង្រឹង ឱ្យដេកក្រោមកុដិរបស់ខ្លួនក៏សន្និដ្ឋានថាច្បាស់ជាកូនស្រីហ្នឹងដែលតាគ្រូគាត់ទាយថា គូព្រេងរបស់អាត្មាអញ លោកនោះក្តៅចិត្តខ្លាំងពេកទប់ពុំបាន ក៏ស្ទុះទៅយកកាំបិតចុងស្រួចមក ហើយវែកញែករនាបកុដិបោះកាំបិតពួយចុងសំយុងសំដៅទៅកូនក្នុងអង្រឹងនោះ ដើម្បីឱ្យមុតស្លាប់ ចុងកាំបិតនោះមិនបានត្រូវត្រង់កន្លែងដំណាំឡើយ គ្រាន់តែត្រូវធើយធិតរលាត់ស្បែកពោះបន្តិចល្មមមានស្នាម កូននោះក៏ស្រែកយំផ្អើលអស់មនុស្សដែលមកបុណ្យទាំងប៉ុន្មាន រួចហើយភិក្ខុនោះក៏វេះគេចពីវត្តបាត់ទៅ ឯម្តាយកាលបើឮមាត់កូនយំ ក៏ស្ទុះរលះរលាំងមកលើកកូនបីត្រកងឡើង ឃើញឈាមក៏អាណិតកូនយ៉ាងក្រៃលែង នាងនោះអន់ចិត្តពេក ក៏លាសេដ្ឋីនោះលែងទៅបំរើពីថ្ងៃនោះ ហើយដើរទៅ

រកសុំនៅបំរើត្រកូលអ្នកមានទ្រព្យសម្បត្តិ ដែលនៅស្រុកឆ្ងាយឯទៀតនោះវិញ ។ លុះយូរទៅប្រហែលជាជិត២០ ឆ្នាំ សេដ្ឋីជាមាតាបិតារបស់ភិក្ខុនោះក៏ស្លាប់បាត់បង់ទៅ ឯទ្រព្យសម្បត្តិទាំងប៉ុន្មាន ក៏វិនាសអន្តរាយអស់គ្មានសល់ ភិក្ខុនោះក៏សឹកទៅវិញធ្លាក់ខ្លួនជាអ្នកទីទ័លក្រលំបាក ដើរស៊ីឈ្នួលគេចិញ្ចឹមជីវិត ក៏បានទៅជួបប្រទះនាងទាំងពីរនាក់ គឺម្ដាយនិងកូននោះនៅបំរើគេ ។ អ្នកបណ្ឌិតនោះក៏មិនបានស្គាល់សោះ លុះឃើញកាលណា ក៏មានចិត្តប្រតិព័ទ្ធស្នេហាចង់បានធ្វើជាភរិយា ឯត្រកូលទាំងពីរនាក់នឹងម្ដាយនាងនោះ ក៏សុខចិត្តព្រមឱ្យ ទើបរៀបចំផ្សំផ្គុំកូនស្រីនោះជាមួយនឹងអ្នកបណ្ឌិតឱ្យជាស្វាមីភរិយានឹងគ្នា ។

លុះដល់វេលារាត្រីនឹងចូលដេក ប្ដីនោះក្រឡេកឃើញស្នាមត្រង់ពោះប្រពន្ធហើយក៏សួរថា ចុះហេតុអ្វីបានជានាងមានភិនស្លាកស្នាមយ៉ាងនេះ ប្រពន្ធក៏ប្រាប់តាមត្រង់ថា ម្ដាយគាត់បានប្រាប់ខ្ញុំថាកាលខ្ញុំនៅតូចទើបនឹងចេះដើរបន្តិចៗ គាត់នាំយកទៅឱ្យដេកក្រោមកុដិលោកសង្ឃ មានភិក្ខុមួយរូបនៅក្នុងកុដិនោះ ត្រូវព្រគ្រូគេទាយឱ្យថា លោកសឹកទៅវិញមុខជានឹងការប្រពន្ធកូនខ្ញុំគេមិនខានក៏កើតទោមនស្សអន់ចិត្ត ទើបទាញកាំបិតចុងស្រួចបោះពួយទំលាក់លើកុដិសំដៅទៅលើខ្លួនខ្ញុំមិនមុតជំណាំ គ្រាន់តែឆិតរលាត់ស្បែកពោះ ព្រោះហេតុនោះបានជាជាប់មានស្លាកស្នាមមកដល់សព្វថ្ងៃ

នេះ ។ ប្ដីនោះឮហើយក៏ភ្ញាក់ខ្លួនព្រើតគិតថា ឱអាត្មាអញហ្នឹងទេតើ ដែលកាលនៅជាបព្វជិត បានគិតប្រុងនឹងសម្លាប់នាងនេះមែន ឯអ្នកទាំងពីរនាក់នោះលុះរួមគ្នាយូរទៅ ក៏បានឡើងទៅជាអ្នកមានទ្រព្យសម្បត្តិច្រើន ។

( និស្សិត អៀង-ស៊ុនភន )

## ៣៥- រឿងសត្វឧនកា

( ចាក់ ម. វា. )

( គុណនៃសេចក្ដីគោរពកោតក្រែងដល់គ្នានឹងគ្នា )

បានឮថា កាលកន្លងទៅហើយ មានសត្វបីគឺៈ ដំរី១, ស្វា១, ទទា១ ត្រូវជាសំឡាញ់នឹងគ្នា នៅអាស្រ័យនឹងដើមជ្រៃធំមួយនាហេមវន្តប្រទេស ។ សត្វទាំងនោះ មិនមានការគោរពដល់គ្នានឹងគ្នាសោះ ព្រោះមិនទាន់ដឹងអ្នកណាចាស់ជាងគេ, ថ្ងៃមួយគិតគ្នាថា បើយើងទាំងអស់គ្នានៅយ៉ាងនេះមិនស្រួលទេ ដូច្នេះយើងត្រូវតែធ្វើសេចក្ដីគោរពកោតក្រែង និងឋិតនៅក្នុងឱវាទអ្នកណាដែលចាស់ជាងគេ, ទើបសួរគ្នាថា នែសំឡាញ់ អ្នកណាដឹងដើមជ្រៃនេះកើតពីត្រឹមណាមក? លំដាប់នោះ ដំរីឆ្លើយថា ម្នាលសំឡាញ់ កាលឈើនេះនៅតូច ខ្ញុំដើរទៅមកនៅក្រោមចន្លោះភ្លៅខ្ញុំ តែងត្រដុសផ្ចិតជានិច្ច ។ ស្វាពោលថា ម្នាលសំឡាញ់ កាលខ្ញុំនៅពីតូច អង្គុយលើផែន

ដីមិនចាំបាច់ងើយក្រឡេកមើលទេ តែងស៊ីបណ្តូលជ្រៃនេះ ខ្ញុំដឹងតាំងពីជ្រៃនេះនៅតូចម្ល៉េះ ។ តពីនោះមក សត្វទទាពោលថា ម្នាលសំឡាញ់ កាលជ្រៃនេះមិនទាន់កើត ខ្ញុំស៊ីផ្លែជ្រៃធំនៅទីឯណោះ ហើយមកជុះអាចម៍ត្រង់កន្លែងនេះជានិច្ច ដើមជ្រៃនេះប្រាកដជាកើតពីអាចម៍ខ្ញុំ ខ្ញុំដឹងតាំងពីជ្រៃនេះមិនទាន់កើតម្ល៉េះ ព្រោះហេតុនោះខ្ញុំចាស់ជាងអ្នករាល់គ្នា ។ តាំងពីថ្ងៃនោះរៀងមក សត្វទាំងពីរ ក៏នាំគ្នាធ្វើសេចក្តីគោរពមានការបូជា_កោតក្រែង_និងថ្វាយបង្គំជាដើម ដល់សត្វទទា ទាំងស្ថិតនៅក្នុងឱវាទទៀតផង ។ សត្វទទា តែងឱ្យសត្វទាំងពីរនោះស្ថិតនៅក្នុងសីល ៥ ហើយសមាទានដោយខ្លួនឯងផង ។ សត្វទាំងបី ក៏ដំកល់នៅក្នុងសីល ៥ និងធ្វើសេចក្តីគោរពដល់គ្នានឹងគ្នាដរាបដល់អស់អាយុ បានទៅកើតក្នុងទេវលោកទាំងអស់គ្នា ។

( ព្រះមហា ប៉ុល_សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៦_ រឿងព្រាហ្មណ៍សម្លាប់ពពែ

( ចាក ម. អ. )

( ពលភាពរបស់ពៀរវេរាក្នុងលោក )

កាលកន្លងទៅហើយ មានព្រាហ្មណ៍ជាអាចារ្យទិសាបាមោក្ខម្នាក់នៅក្នុងក្រុងពារាណសី បានសម្លាប់ពពែមួយធ្វើមតកភត្ត ។

ដោយកម្មនោះឯង គាត់កើតជាពពែត្រូវដាច់ក្បាលអស់ ៤៩៩ អត្តភាពមកហើយ លុះដល់អត្តភាពជាគំរប់ ៥ រយ បានកើតជាពពែរបស់ព្រាហ្មណ៍ម្នាក់ ។ ថ្ងៃមួយ ព្រាហ្មណ៍ជាម្ចាស់ចង់ធ្វើមតកភត្តប្រារព្ធនឹងសម្លាប់ពពែ ពពែរឭកឃើញជាតិដែលខ្លួនធ្វើមកពីមុនក៏សើច ហើយបែរជាយំ ព្រាហ្មណ៍ឃើញហេតុដូច្នោះទើបសួរទៅពពែ ពពែឆ្លើយប្រាប់ បានជាខ្ញុំសើចនោះ ព្រោះគិតឃើញថា ថ្ងៃនេះច្បាស់ជាខ្ញុំរួចចាកទុក្ខបែបនេះ. ដែលត្រឡប់ជាយំវិញ ព្រោះអាណិតថា បើអ្នកសម្លាប់ខ្ញុំហើយ អ្នកត្រូវដាច់ក្បាលអស់ ៥ រយអត្តភាពដូចជាខ្ញុំយ៉ាងហ្នឹង ។ ព្រាហ្មណ៍ឮដូច្នោះមានសេចក្ដីសង្វេគជាខ្លាំង ទើបពោលថា ម្នាលពពែ អ្នកកុំភ័យអ្វី ខ្ញុំមិនសម្លាប់អ្នកទេ. ពពែនិយាយថា បើអ្នកសម្លាប់ក្ដី មិនសម្លាប់ក្ដី ខ្ញុំត្រូវតែស្លាប់ក្នុងពេលនេះមិនខាន ។ ព្រាហ្មណ៍ក៏លែងពពែឱ្យទៅតាមសេចក្ដីសប្បាយ ហើយតាំងចិត្តលែងសម្លាប់សត្វដទៃទៀត ។ ឯពពែបានរួចពីកណ្ដាប់ដៃព្រាហ្មណ៍ភ្លាម ក៏ឈរលើខ្នងថ្មមួយដុំងើយស៊ីស្លឹកឈើមួយគុម្ព ពេលនោះរន្ទះបាញ់ថ្មបែកខ្ទាតទៅត្រូវពពែដែលឈរដាច់កស្លាប់នៅទីនោះមួយរំពេច ។

( ព្រះមហា ប៉ុល_សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

# ៣៧_ រឿងសីលវិមំសកព្រាហ្មណ៍

( ចាក ម. អ. )

( សីលជាប្រធាននៃសេចក្ដីរាប់អានក្នុងលោក )

មានព្រាហ្មណ៍ម្នាក់ឈ្មោះសីលវិមំសកៈ នៅក្រុងពារាណសី រស់នៅដោយសារព្រះរាជា ទ្រង់ព្រះនាមកោសល ជាអ្នកដល់នូវត្រៃសរណគមន៍ និងមានសីល ៥ មិនដែលដាច់សោះ ។ ព្រះរាជាស្រឡាញ់រាប់អានព្រាហ្មណ៍នោះជាងព្រាហ្មណ៍ដទៃៗ ដោយគាត់មានសីល ។ ថ្ងៃមួយព្រាហ្មណ៍នោះគិតថា ព្រះរាជាដែលរាប់អានអញយ៉ាងនេះ ព្រោះអាស្រ័យជាតិ-គោត្ត-ត្រកូល-ប្រទេស-សិប្បសម្បត្តិទេឬ? ឬក៏ព្រោះអាស្រ័យសីលសម្បត្តិ បើដូច្នោះគួរតែអញល្បងមើល, ដល់ពេលគាត់ទៅបំរើព្រះរាជា លុះត្រឡប់មកផ្ទះវិញក៏យកកហាបណៈមួយមិនប្រាប់នាយឃ្លាំងឡើយ នាយឃ្លាំងមិនហ៊ានពោលពាក្យតិចតួចសោះ ព្រោះធ្វើសេចក្ដីគោរពចំពោះព្រាហ្មណ៍ ។ ដល់ថ្ងៃទី ២ យកកហាបណៈពីរ នាយឃ្លាំងមិនថាអ្វីទៀត ។ ដល់ថ្ងៃទី ៣ យកមួយក្ដាប់ នាយឃ្លាំងអត់មិនបានខឹងជាខ្លាំង ក៏ទៅស្រែកបីដងថា ចោរប្លន់កហាបណៈខ្ញុំចាប់បានហើយ ។ មនុស្សទាំងឡាយនាំគ្នាស្ទាក់ខាងណោះ ខាងណោះចាប់បានចង ហើយពោលថាអ្នកឯងនេះ ប្រព្រឹត្តដូចជាអ្នកមានសីលយូរយាមក ហើយ ទើបទះតប់ពីរបីដៃ ក៏បញ្ជូនទៅថ្វាយព្រះរាជា ៗ ទ្រង់ព្រះ

ពិរោធយ៉ាងខ្លាំងមានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ ព្រោះហេតុអី បានជាអ្នកធ្វើអំពើទុច្ចរិតបែបនេះ? ព្រាហ្មណ៍ឆ្លើយថា បពិត្រមហារាជ ខ្ញុំព្រះអង្គមិនមែនចោរទេ ដែលខ្ញុំព្រះអង្គធ្វើយ៉ាងនេះ ដោយល្បងមើលទេតើ ឥឡូវនេះខ្ញុំព្រះអង្គដឹងច្បាស់ថា ព្រះអង្គដែលរាប់អានខ្ញុំព្រះអង្គយ៉ាងនេះព្រោះតែមានសីល មិនមែនព្រោះអ្វីទេ. ម្យ៉ាងទៀតក្នុងលោកទាំងមូល ឥតមានអ្វីឧត្តុង្គឧត្តម ឬជាប្រធានជាងសីលទេ. ហេតុនេះ ខ្ញុំព្រះអង្គលែងនៅផ្ទះទៀតហើយ នឹងទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធក្នុងថ្ងៃនេះឯង សូមព្រះអង្គអនុញ្ញាតឱ្យផង ។ ព្រះរាជាទ្រង់អនុញ្ញាតឱ្យ. គាត់ក៏ទៅសូមផ្នួសព្រះសម្មាសម្ពុទ្ធឯវត្តជេតពនក្នុងថ្ងៃនោះមែន ។ តាំងពីបានឧបសម្បទាកាលណាមក គាត់មិនដែលលះបង់កម្មដ្ឋានសោះ ខំប្រឹងចំរើនវិបស្សនាដរាបដល់បានសម្រេចព្រះអរហត្ត ។

( ព្រះមហា ប៉ុល-សៅ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៨- រឿងបាដលិបុត្តកព្រាហ្មណ៍

( ចាក ធ. ប. )

( អ្នកមានសទ្ធាតែងជ្រះថ្លាប្រាថ្នាចំពោះអ្នកមានសីលគុណ )

បានឮថា មានព្រាហ្មណ៍ម្នាក់អង្គុយលើសាលាទៀបទ្វារក្រុងបាដលិបុត្ត បានឮនូវគុណកថារបស់ព្រះមហានាគត្ថេរ លោកមាន

ប្រក្រតី នៅក្នុងកាឡវល្លិមណ្ឌបរិហារនាជនបទឈ្មោះរោហណៈ ហើយគាត់បំណងចង់ឃើញលោក ក៏ជិះទូកទៅតាមឆ្នេរសមុទ្រលុះដល់ទៅវសេនដ្ឋានរបស់លោកហើយ ក៏ចូលទៅសិចតក្នុងផ្ទះមួយជិតចូឡនគរគ្រាម ហើយចាត់ចែងអាហារប្រគេនលោក, លុះព្រឹកឡើងបានទៅកាន់សំណាក់លោក ហើយឋិតនៅក្នុងទីអាសនៈឃើញលោកពីចម្ងាយ ក៏ឈរថ្វាយបង្គំអស់វារៈម្តងហើយចូលទៅចាប់ឱបជើងក្អែកគោលោកយ៉ាងមាំ ទើបបន្ទឺនូវវាចាថា បពិត្រលោកម្ចាស់ដ៏ចំរើនលោកម្ចាស់ខ្ពស់។ ឯព្រះថេរៈ លោកមានមាឌ មិនខ្ពស់ពេកគឺសមរម្យតាមប្រមាណមែន។ ព្រោះហេតុនោះ ព្រាហ្មណ៍ក៏ពោលម្តងទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើនរាងលោកម្ចាស់មិនខ្ពស់មែន ប៉ុន្តែកិត្តិសព្ទកិត្តិគុណរបស់លោកម្ចាស់ ផ្សាយទៅតាមខ្នងនៃសមុទ្រមានពណ៌ផ្ទៃមេឃគ្របដណ្តប់នូវផ្ទៃជម្ពូទ្វីបទាំងអស់, ខ្ញុំព្រះករុណាកំពុងតែអង្គុយនៅលើសាលាទៀបទ្វារក្រុងបាដលិបុត្ត គ្រាន់តែឮនូវគុណកថារបស់លោកម្ចាស់ ក៏មកអំពីនោះភ្លាម ។ លុះគាត់ពោលរៀបរាប់កិត្តិគុណ កិត្តិសព្ទប្រាប់រួចសព្វគ្រប់ហើយ ក៏ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះថេរ ហើយរៀបចំបាត្រចីវរខ្លួនឯង ចូលកាន់ភេទជាបព្វជិតក្នុងសំណាក់លោក និងឋិតក្នុងឱវាទពាក្យប្រៀនប្រដៅរបស់លោកទៀត មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តទៅ ។

ព្រះមហា សំ_សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៣៩. រឿងព្រះបាទឃតៈ

( ចាក ម. អ. )

( ការមិនសោយសោក ជាឱសថវិសេសក្នុងលោក )

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាម ធង្កៈ ជាព្រះចៅក្រុងសាវត្ថី. ថ្ងៃមួយទ្រង់លើកទ័ពកេណ្ឌបរិវារទៅដណ្ដើមយករាជសម្បត្តិក្នុងក្រុងសាវត្ថី ហើយបរិវារចាប់ព្រះរាជាព្រះនាមឃតៈ ជាម្ចាស់រាជសម្បត្តិក្រុងពារាណសីនោះ ចងដោយច្រវាក់ទាំងខ្សែៗ ហើយឱ្យរុញបញ្ចូលក្នុងគុកទៀត ។ ព្រះបាទឃតៈស្ដេចពុំសោយសោកស្ដាយនូវរាជសម្បត្តិ ដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃបច្ចាមិត្តសោះ ទ្រង់គិតប្រមូលមកនូវកសិណ ហើយញ៉ាំងឈានឱ្យកើតឡើងក៏ហោះទៅអង្គុយពែនភ្នែនព្ធដ៏អាកាសវេហាស៍។ ព្រះរាជាធង្កៈគ្រាន់តែទតឃើញហេតុនោះ ការក្ដៅក្រហាយក៏កើតមានក្នុងសរីរៈមួយរំពេច ទើបក្រោកទៅកាន់សំណាក់ព្រះបាទឃតៈនោះ ហើយមើលព្រះភក្ត្រព្រះបាទឃតៈ ក៏ស្រាប់តែឃើញព្រះភក្ត្រនោះស្រស់បំព្រង ព្រមដោយសិរីដូចជាស្រទាប់ផ្កាឈូកមានសម្បុរដូចមាស ទើបសួរហេតុការណ៍ដែលមិនសោយសោកនោះ ។ ព្រះបាទឃតៈទ្រង់ក៏ពោលនូវគាថា ដែលមានក្នុងធង្ករាជជាតកប្រាប់ស្ដេចធង្កៈថា

**នាព្ភតីតាហរោ សោកោ នានាគតសុខាវហោ**

តស្មា ឆន្ទ ន សោចាមិ នត្ថិសោកេ ទុតីយតា
សោចំ បណ្ឌុកិសោ ហោតិ ភត្តញ្ចស្ស ន រុច្ចតិ
អមិត្តា សុមនា ហោន្តិ សល្លវិទ្ធស្ស រុប្បតោ ។

សេចក្ដីសោក មិនមែននាំមកនូវសម្បត្តិដែលកន្លងទៅហើយ ទាំងមិននាំនូវសេចក្ដីសុខក្នុងអនាគតផង ឯខ្ញុំក៏មិនមែនជាសំឡាញ់នឹងសេចក្ដីសោកដែរ ម្នាលឆន្ទៈព្រោះហេតុនោះ ទើបខ្ញុំមិនសោយសោក. បុគ្គលដែលសោកសោយតែងមានសរីរៈស្គមហើយបរិភោគបាយក៏មិនមានឱជារស. សត្រូវទាំងឡាយរមែងក្ដៅក្រហាយចំពោះសរគឺសេចក្ដីសោកដែលមុតហើយ ទើបជាសត្វមានចិត្តល្អវិញ ។

ព្រះរាជាឆន្ទៈទ្រង់ព្រះសណ្ដាប់គាថានោះចប់ហើយ ក៏ឱ្យព្រះបាទយតៈអត់ទោសឱ្យ ហើយប្រគល់រាជសម្បត្តិឱ្យ ទើបស្ដេចត្រឡប់ទៅកាន់នគរសាវត្ថីវិញ ។ គួរឱ្យសរសើរព្រះទ័យព្រះបាទយតៈណាស់ គ្រាន់តែទ្រង់បានទទួលរាជសម្បត្តិពីស្ដេចបច្ចាមិត្តហើយ ក៏ប្រគល់ឱ្យអមាត្យទាំងឡាយ ទើបទៅបួសក្នុងហេមពាន្តប្រទេស មិនដែលមានឈានសាបសូន្យម្ដងឡើយ លុះអាយុអស់ក៏បានទៅកើតក្នុងព្រហ្មលោកនាយ ។

( ព្រះមហា សំ_សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

## ៤០. រឿងឧបាសកភិក្ខុ

( ចាក ថា. ប. )

( គុណនៃការស្ដាប់នូវមហាវេស្សន្តរជាតក )

បានឮថា មានភិក្ខុកំឡោះមួយរូបនៅក្នុងតិស្សមហាវិហារ នាមហាគ្រាម. ថ្ងៃមួយបានឮដំណឹងថា ព្រះថេរឈ្មោះមហាជាតកភាណកនឹងសំដែងនូវមហាវេស្សន្តរជាតក ក៏ប្រកបដោយពាន់នៃគាថា ក៏ចេញពីតិស្សមហាវិហារនោះទៅអស់ផ្លូវ ៩ យោជន៍តែមួយថ្ងៃ ព្រះថេរក៏ប្រារព្ធសំដែងនូវធម្មកថាក្នុងខណៈនោះមែន ។ ភិក្ខុកំឡោះនោះ ក៏កំណត់ស្មារតីចងចាំបានតែគាថាខាងដើម និងចុងបញ្ចប់ប៉ុណ្ណោះ មិនបានចាំទាំងអស់ ព្រោះលោកមកអស់ផ្លូវដ៏ឆ្ងាយមានកាយរសាប់រសល់ខ្វល់អស់សតិបញ្ញា ក៏ពោលប្រាប់ព្រះថេរថា លោកម្ចាស់បានពោលនូវពាក្យនេះ ក្នុងកាលដែលខ្លួនក្រោកឡើងហើយឈរទ្រហោយំដោយអស់សេចក្ដីសង្ឃឹមថា ការមកអស់ផ្លូវឆ្ងាយរបស់ខ្លួន នឹងសាបសូន្យឥតអំពើ ។ លំដាប់នោះមានមនុស្សម្នាក់បានឮសម្រែកយំនោះ ក៏ទៅទូលព្រះថេរថា បពិត្រលោកម្ចាស់ដ៏ចំរើនអម្បាញមិញនេះ មានភិក្ខុកំឡោះមួយរូបមកអំពីតិស្សមហាវិហារដើម្បីស្ដាប់នូវធម្មកថារបស់លោកម្ចាស់ ហើយឈរស្រែកទ្រហោយំដោយអស់សង្ឃឹមថា ការមករបស់អញឥតអំពើរសោះ ព្រោះលោកមានកាយនឿយលំបាកក្នុងដំណើរ ដែលមកអស់ផ្លូវ

ថ្វាយនេះជាខ្លាំង ។ ព្រះថេរប្រាប់ថា បើដូច្នោះអ្នកទៅលួងលោមលោកថា ស្អែកនេះអាត្មានឹងសំដែងម្តងទៀត ។ ឧបាសកក៏ទៅទូលភិក្ខុកំឡោះនោះតាមថេរដីកា ។ លុះថ្ងៃស្អែកឡើងព្រះថេរក៏សំដែងម្តងទៀត, ភិក្ខុកំឡោះនោះចងចិត្តចាំស្តាប់ដោយគោរព ក៏បានសម្រេចដល់ថ្នាក់ធម៌ឈ្មោះសោតៈ បានជាសោតាបន្នបុគ្គលមួយរូបក្នុងថ្ងៃនោះ ។

( ព្រះមហា សំ-សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

៙ ✵ ៚

## ៤១- រឿងនន្ទយក្ខ

( ចាក ម. អ. )

( គុណនៃសមាបត្តិ ពូកែផុតក្នុងលោក )

ក្នុងកាលខ្លះ ព្រះអគ្គសាវកទាំងពីរអង្គសម្រាកសម្រាន្តព្រះឥរិយាបថក្នុងកបោតកន្ទរវិហារក៏មាន ។ នាកាលរាត្រីខាងខ្នើតព្រះចន្ទបានបញ្ចាំងរស្មីភ្លឺត្រចះឆើតឆាយ ជាទីញាំងទឹកចិត្តរបស់សត្វទាំងឡាយឱ្យរីករាយ សប្បាយទូទៅគ្រប់ភូមិស្រុកទាំងអស់, ឯព្រះសាវកទាំងពីរអង្គនោះ, ព្រះសារីបុត្តដ៏មានអាយុជាព្រះធម្មសេនាបតី ទើបនឹងកោរព្រះកេស(សក់) ថ្មី គង់ចូលសមាបត្តិជាសប្បាយក្នុងឱកាសវាលស្រឡះ ។ លំដាប់នោះ នន្ទយក្សព្រមនឹងយក្សមួយទៀត ហោះហើរលើអាកាសវេហាស៍ បានឃើញព្រះថេរ

គង់ចូលសមាបត្តិក្នុងទីវាលដូច្នោះ ក៏ញុំាងចិត្តសាហាវឃោរឃៅ អាក្រក់ក្រៃឱ្យកើតឡើង ។ តែតាមដំណឹងមកថា យក្សនោះមានគំនុំគំគួននឹងព្រះថេរក្នុងជាតិដែលមានក្នុងកាលមុន ។ នន្ទយក្សមានចិត្តទ្រឹស្នូរកើតឡើងហើយ ចង់វាយព្រះសិរព្រះថេរណាស់ ហើយនិយាយប្រាប់យក្សមួយថា សំឡាញ់អញចង់វាយក្បាលលោកនោះណាស់ ។ នែ! សំឡាញ់កុំ លោកនុងមានអំណាចណាស់វាយមួយផ្ទុងនៅដដែល ។ នន្ទយក្សមិនអើពើនឹងសំដីឃាត់សោះ ទើបញុំាងសេចក្តីឧស្សាហ៍ឱ្យកើតឡើង ហើយឈរជ្រែងលើអាកាសសំពងព្រះសិរព្រះថេរលាន់ឮផ្ទូង ខ្លាំងអស្ចារ្យហួសការប្រហារធម្មតា ។ ការប្រហារនោះ អាចពន្លិចចុះនូវនាគមានពូក ៧ ឬ ៧កន្លះ ពុំនោះសោត កំពូលភ្នំដ៏ធំក៏ស្រុតចុះចូលទៅក្នុងផែនដីបានដែរ ។ ប៉ុន្តែគ្រោះល្អបានកំឡាំងសមាបត្តិជួយគាំទ្រ ព្រះសិររបស់លោកពុំមានស្លាកស្នាមអ្វីឡើយ ដូនជាពេលដែលយក្សប្រហារនោះទៀត លោកមិនទាន់ចេញពីសមាបត្តិ ។ ព្រះមហាមោគ្គល្លានមានឫទ្ធិច្រើន បានឃើញយក្សនោះប្រហារព្រះសារីបុត្រដោយទិព្វចក្ខុ ហើយចូលទៅរកលោក ។

ព្រះមហាមោគ្គល្លានសួរថា ហៃអាវុសោសារីបុត្តលោកឈឺដែរ យក្សវាយមួយផ្ទូងអម្បាញមិញនេះ? ទេ អាវុសោមោគ្គល្លានសរីរយន្តរបស់ខ្ញុំល្មមអត់ទ្រាំបាន ល្មមឱ្យប្រព្រឹត្តទៅបានតែឈឺបន្តិច

ដែរ ។ គួរតែឆ្ងល់ខានពុំបាន បើសរីរៈបានកំឡាំងសមាបត្តិជួយឧបត្ថម្ភហើយ ម្ដេចឡើយបានជាមានសេចក្ដីឈឺចាប់បន្តិចបន្តួចក្នុងព្រះសិរព្រះថេរដែរ? បានជាឈឺចាប់ព្រោះលោកប្រញាប់ចេញពីសមាបត្តិពេក ព្រោះថា សេចក្ដីទុក្ខរមែងមិនប្រាកដខាងក្នុងសមាបត្តិទេ ដូចជាបុគ្គលដេកលក់ហើយសត្វទាំងឡាយមានមុសជាដើមខាំ លុះភ្ញាក់ឡើងលែងអ្វីនឹងមានសេចក្ដីឈឺ ។ ឯនន្ទយក្សគ្រាន់តែវាយព្រះថេរហើយភ្លាម ក៏មានសេចក្ដីក្ដៅអន្ទះអន្ទែងដ៏ខ្លាំងក្លាកើតឡើងក្នុងសរីរៈ ទើបស្រែកថា អញនេះហើយ អញឆេះហើយ ហើយធ្លាក់ដាំតិតដាំតួងមកពីអាកាសកាន់ផែនដី ស្រាប់តែអណ្ដាតភ្លើងអវិចីស្រោបពេញអត្តភាព ហើយអូសទំលាក់ទៅក្នុងនរកទាំងស្រស់ ។ គួរឆ្ងល់ម្ដងទៀត ហេតុអ្វីបានជាអណ្ដាតភ្លើងអវិចីរុញគ្នាទៅនរកទាំងអត្តភាពជាយក្សត្រលាំងដូច្នេះ ម្ដេចក៏មិនចាំស្លាប់សិន ឆ្លើយថា បាបកម្ម ជាទិដ្ឋធម្មវេទនីយ (សត្វគប្បីសោយក្នុងបច្ចុប្បន្ន) ណាមានយក្ស ត្រូវសោយនូវមហាទុក្ខទាំងអត្តភាពជាយក្សដោយកំឡាំងនៃបាបកម្មជាទិដ្ឋធម្មវេទនីយនោះ មិនបាច់ចាំដល់ស្លាប់ឡើយ អាចសោយទាំងរស់បានដោយឥតញញើត ។ ឯនន្ទយក្សនោះក៏ចូលទៅកើតក្នុងអនន្តរិយកម្ម ដែលត្រូវរងក្នុងភពជាលំដាប់តទៅ ។

# ៤២. រឿងពស់ថ្លាន់

( ចាក ដី. ម. )

( គុណនៃការស្តាប់ព្រះអភិធម្ម )

មានសេចក្តីដំណាលថា ក្នុងពុទ្ធកាលព្រះបរមសាស្តាព្រះនាមកស្សបៈ មានពស់ថ្លាន់ ១ បានកាន់យកនូវនិមិត្តក្នុងសំឡេងនៃភិក្ខុទាំងឡាយអ្នករៀននូវអភិធម្ម កាលស្វាធ្យាយនូវអាយតនកថា លុះស្លាប់ទៅ បានទៅកើតក្នុងឋានសួគ៌សោយសម្បត្តិទិព្វដរាបដល់ព្រះសាស្តាជាម្ចាស់នៃយើងបរិនិព្វាន, ពេលព្រះសាស្តាបរិនិព្វាន បានច្យុតមកកើតក្នុងត្រកូលព្រាហ្មណ៍ ។ ទារកនោះមានវ័យវឌ្ឍនាការចំរើនឡើងកាលណា ក៏ចេញទៅបួសក្នុងសំណាក់អាជីវក មាននាមាភិធេយ្យថាជនសោណាជីវក បានជាជិតុននៃព្រះនាងធម្មាជាអាយ៏អគ្គមហេសីព្រះបាទពិន្ទុសារៈ ។ លំដាប់នោះព្រះទេវីធម្មាកាលទ្រទ្រង់នូវអសោកកុមារ មានចំណង់ប្លែកកើតឡើង ហើយទូលព្រះរាជស្វាមីថា ខ្ញុំព្រះអង្គចង់ឈរជ្រែងជាន់ព្រះចន្ទដោយជើងម្ខាង ព្រះអាទិត្យដោយជើងម្ខាង ហើយទំពារស៊ីនូវផ្កាយ, របៀបនៃពពក, ជន្លេនទាំងឡាយនិងព្រៃញាតស្បាតទាំងឡាយណាស់ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ បង្គាប់ឱ្យគេធ្វើនំអម្បែងធំៗពីរ ហើយប្រាប់ថា នេះព្រះចន្ទ នេះព្រះអាទិត្យ ហើយត្រាស់បង្គាប់ឱ្យធ្វើនំផ្លែអាយមូលៗ មានសណ្ឋានដូចផ្កាយ នំគ្រាប

លូមានអាការដូចជារបៀបនៃពពក និងបង្អែមមានសណ្ឋានដូចញាតស្បាត ទើបឱ្យជំរះព្រះរាជលាន ហើយក្រាលកន្ទេលផែងដែលដាចពីលើ ឱ្យយកបង្អែមដែលអណ្តែកឡើងៗ ពីប្រហោងនៃកន្ទេលផែងនោះហើយប្រាប់ថា នេះជន្ទេនទាំងឡាយតាមសេចក្តីប្រាថ្នារបស់ព្រះនាងទេវី ។ ព្រះទេវីធម្មា ក៏ឈរជ្រែងលើនំអម្បែងធំៗដោយជើងទាំងពីរខាងដោយបំណងថា ឈរជ្រែងលើព្រះចន្ទព្រះអាទិត្យហើយទំពារសោយនំផ្លែអាយ. នំគ្រាប់លូនិងបង្អែមដោយបំណងថា ទំពារសោយនូវផ្កាយ. របៀបពពកនឹងញាតស្បាតតាមព្រះរាជចិន្តា ។ ព្រះរាជាចង់ដឹងនូវសេចក្តីសម្រេចនៃចំណង់ប្លែក ក៏សួរអាជីវកឈ្មោះជនសោណ ៗ ថ្វាយដំណឹងតែបន្តិចថាមហារាជ ព្រះទេវី នឹងបានបុត្រដ៏ប្រសើរដ៏បរិបូណ៌ដោយលក្ខណៈជាអ្នកមានបុណ្យ ហើយចូលទៅរកព្រះទេវីថ្វាយដំណឹងតាមមតិរបស់ខ្លួនថា បពិត្រព្រះនាង បុត្ររបស់ព្រះនាងនឹងបានជាស្តេច. ការឈរជាន់ព្រះចន្ទនិងព្រះអាទិត្យ ជាបុព្វនិមិត្តនៃស្តេចទាំងឡាយ ១០១ ក្នុងជម្ពូទ្វីបទាំងអស់ជាអ្នកបំរើព្រះរាជបុត្រនោះ. ការទំពារស៊ីនូវផ្កាយ ជាបុព្វនិមិត្តនៃកិរិយាបានសម្លាប់នូវបងប្អូនមានមាតាផ្សេងគ្នាដែលមានមារយាទមិនគាប់ចិត្ត. ការទំពារស៊ីនូវរបៀបពពកជាបុព្វនិមិត្ត នៃកិរិយាផ្តាច់បង់នូវគំនិតយល់ខុសហើយកាន់តាមរបៀបព្រះពុទ្ធសាសនា. ការទំពារស៊ីនូវជន្ទេន ជាបុព្វនិមិត្តនៃ

កិរិយាបាននូវអំណាចផ្សាយទៅក្នុងផែនដី ១ យោជន៍. ការទំពារស៊ីនូវញាតស្បាតពោលគឺកិរិយាលើកជើងទៅលើ ជាបុព្វនិមិត្តនៃកិរិយាបាននូវអំណាចផ្សាយទៅអាកាសខាងលើ១ យោជន៍ ។ កាលបើទំនាយលក្ខណៈរាជបុត្ររួចហើយ អាជីវកឈ្មោះជនសោណទៅនៅក្នុងទី ១ ឆ្ងាយអំពីព្រះបរមរាជវាំងនោះ ១ យោជន៍ ។ ក្នុងកាលជាចំណោរមកខាងក្រោយ អសោកកុមារបានដំកល់នៅក្នុងរាជសម្បត្តិ ហើយស្តាប់នូវប្រវត្តិទាំងអស់ដែលព្រះវរមាតាប្រាប់ ក៏មានប្រាថ្នាចង់ធ្វើសក្ការបូជាដល់អាជីវកឈ្មោះជនសោណនោះ ហើយត្រាស់បង្គាប់ឱ្យរាជបុរសទាំងឡាយ យកអង្រឹងមាសទៅទទួលជាកិត្តិយស ។ អាជីវកឈ្មោះជនសោណមកជាមួយនឹងរាជបុរសទាំងឡាយនោះ បានឃើញទីសម្រាប់គង់នៅរបស់ព្រះថេរឈ្មោះអស្សគុត្ត ទើបគិតថា នេះជាទីសម្រាប់នៅនៃបព្វជិតទាំងឡាយ ហើយចុះចាកពីអង្រឹងចូលទៅកាន់ទីនោះ ក៏បានឃើញសត្វទាំងឡាយ មានសីហៈនិងខ្លាធំជាដើម ដើរជាពួកជាក្រុម មានមេត្តាចិត្តកើតដល់គ្នានឹងគ្នា មិនបៀតបៀនគ្នា ដោយអានុភាពនៃមេត្តាធម៌របស់ព្រះថេរទើបសួរថា នេះជាអ្វី? ព្រះថេររមិលមើលឧបនិស្ស័យរបស់អាជីវកនោះ គឺឃើញថាកាលពីដើមធ្លាប់បានស្តាប់អាយតនកថា ហើយលោកគិតថាមានតែអាយតនកថាហ្នឹងឯង ទើបជាឧបនិស្ស័យរបស់អាជីវកនោះ ក៏ពោលប្រាប់ថា នៃអាវុសោនោះជា

អាយតនៈ ។ គ្រាន់តែបានឮថា អាយតនៈ ៗ ដូច្នេះ អាជីវកនោះក៏មានសេចក្តីអៀនខ្មាសខ្លាចបាបកើតឡើង ហើយអង្គុយច្រហោងស្រួលបួល ។ ព្រះថេរក៏បោះសំពត់ងូតទឹកទៅឱ្យអាជីវកនោះ ១ បួសក្នុងសំណាក់ព្រះថេរបានសម្រេចព្រះអរហត្តទៅ ។

## ៤៣~ រឿងកិន្នរ

( ចាក ត. តេ. )

( គុណនៃពាក្យសុភាសិត )

តាមដំណឹងថា កាលពីព្រេងនាយ មានព្រានម្នាក់នៅក្នុងក្រុងពារាណសី តែងសញ្ចរទៅក្នុងព្រៃហេមពាន្ត ហើយចាប់បានកិន្នរពីររូបជាប្តីប្រពន្ធ នាំយកទៅថ្វាយព្រះចៅពារាណសី ទ្រង់ក៏ទទួលដោយអំណរដ៏ខ្លាំង ហើយមានព្រះបន្ទូលសួរថា កិន្នរនេះមានគុណបែបណាខ្លះ? ព្រានក្រាបទូលថា បពិត្រព្រះសម្មតិទេពកិន្នរនេះចេះច្រៀងសូរសៀងសំឡេងពិរោះក្រៃលែង និងចេះរាំរេតាមកាលជាទីគាប់ព្រះហឫទ័យ, មនុស្សទាំងឡាយច្រៀងនិងរាំសូម្បីតែជ្រិសបន្តិចក៏គ្មាន ។ ព្រះរាជាក៏ប្រទានបៀវត្សជាច្រើនដល់ព្រាននោះ ហើយត្រាស់ប្រើឱ្យកិន្នរនោះច្រៀងរាំ ដើម្បីកំសាន្តព្រះរាជហឫទ័យ ។ កិន្នរទាំងឡាយនោះទុកជាព្រះរាជាត្រាស់ប្រើបង្ខំដូចម្តេច ក៏មិនព្រមច្រៀងរាំសោះ ខ្លាចឃ្លៀងឃ្លាតចាកការពិត

ហើយក្រាបទូលថា ប្រសិនបើទូលព្រះបង្គំទាំងពីររូបច្រៀងទៅមិនត្រឹមត្រូវតាមព្យញ្ជនៈ សំឡេងច្រៀងនោះនឹងក្លាយទៅជាសោគម្រក់មែនពិត, ទ្រង់នឹងតិះដៀលឬសំឡាប់ទូលព្រះបង្គំពុំខាន ព្រោះហេតុនោះបើទូលបង្គំច្រៀងច្រើន មុសាវាទក៏មានច្រើន ។ ព្រះរាជាទ្រង់ព្រះពិរោធក្រេវក្រោធក្រៃពេក ក៏ត្រាស់បង្គាប់ឱ្យសម្លាប់កិន្នរនោះ ហើយចំអិនយកសាច់មកជាព្រះក្រយាស្ងោយ ។ កិន្នរីឮសំដីនោះហើយគិតថា" អើព្រះរាជាខ្វាល់ហើយហ្ន ! ទៀងតែសម្លាប់អញដោយពិត តើធ្វើបែបណាទៅអេះ ទើបជីវិតអញរួចចាកមច្ចុសង្គ្រាមក្នុងពេលភ្លាមៗនេះ" ក៏ពោលគាថានេះថ្វាយព្រះសណ្ដាប់ថា :

សតំ សហស្សានឧុព្ភាសិតានំ
កលម្បិ នាគ្ឃតិ សុភាសិតស្ស
ទុព្ភាសិតំ សង្កមានោ កិលេសេ
តស្មា តុណ្ហី កិម្បុរិសោ ន ពាល្យា ឌ

រយនៃទុព្ភាសិតទាំងឡាយទាំងពាន់ ក៏មិនដល់នូវចំណិតនៃសុភាសិតសូម្បីមួយ. ឋានៈទូលបង្គំវង្វៀសក្នុងទុព្ភាសិតហើយរមែងសៅហ្មងពិត ព្រោះហេតុនោះកិន្នរឈ្មោលនៅស្ងៀម ក៏មិនមែនដោយហេតុនៃខ្លួនល្ងង់ទេ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់គាថានោះហើយ មានព្រះទ័យ

រីករាយចំពោះកិន្នរីយ៉ាងក្រៃលែង ហើយត្រាស់បង្គាប់ឱ្យរាជបរិពារយកកិន្នរីនោះទៅលែងឯព្រៃហេមពាន្ត ហើយឱ្យចំអិនសាច់កិន្នរជាស្វាមីនោះយកមកឱ្យទាន់ពេលព្រះស្ងោយក្នុងវេលាព្រឹក ។ កិន្នរឮព្រះបន្ទូលនោះហើយគិតថា ព្រះរាជានេះពិតជាសម្លាប់អញដោយហេតុមិនច្រៀងហ្នឹងឯង ធ្វើដូចម្ដេចហ្ន ! ទើបជីវិតអញរួចចាកមរណសង្គ្រាមក្នុងគ្រាឥឡូវនេះបាន, ទើបពោលគាថាដទៃទៀតថា

**បជ្ជុន្ននាថា បសវោ បសុនាថា អយំ បជា**

**តំ នាថោស្មិ មហារាជ មមំ នាថា មម ភរិយា**

**ទ្វិន្នមញ្ញតរំ ញត្វា មុត្តោ គច្ឆេយ្យ បព្វតំ ។**

សត្វចិញ្ចឹមទាំងឡាយ មានទឹកភ្លៀងជាពំនឹង, ពពួកសត្វនេះមានសត្វចិញ្ចឹមជាពំនឹង, បពិត្រមហារាជ ឯទូលបង្គំមានព្រះអង្គជាពំនឹង, កិន្នរីដឹងនូវហេតុណា ហើយរួចទៅកាន់ភ្នំ ។

## អធិប្បាយ

បពិត្រមហារាជ សត្វចិញ្ចឹមទាំងឡាយមានស្មៅជាចំណីឈ្មោះថាមានទឹកភ្លៀងជាទីពឹង, ឯមនុស្សទាំងឡាយ ឈ្មោះថាមានសត្វចិញ្ចឹមជាទីពឹង ព្រោះចូលទៅជិតបរិភោគនូវរសគោ៥ ចំណែកទូលបង្គំមានព្រះអង្គជាទីពឹង ឯព្រះអង្គឈ្មោះថាជាទីពឹងរបស់ទូលព្រះបង្គំ, ម្យ៉ាងទៀត ភរិយារបស់ទូលបង្គំ មានទូលព្រះបង្គំជាទីពឹង ឯទូលបង្គំឈ្មោះថាជាទីពឹងរបស់ភរិយាទូលព្រះបង្គំ, បើយើងខ្ញុំនៅ

រស់នឹងមិនសុខចិត្តលែងលះគ្នាទេ ក៏ប្រសិនជាព្រះអង្គមានប្រាថ្នានឹងបំបែកភរិយាឱ្យទៅនៅឯព្រៃហេមពាន្ត សូវទ្រង់សម្លាប់ទូលបង្គំចោលជាមុន ហើយសន្សឹមព្រះអង្គបញ្ជូនឱ្យបែកគ្នាទៅចុះ សោះនឹងរស់, បើមិនដូច្នោះទេ ទូលបង្គំនឹងបែកទ្រូងស្លាប់ក្នុងពេលដែលរាជបរិពារ យកភរិយាទៅលែងឯព្រៃហេមពាន្តពុំខានឡើយ ។ ព្រះរាជាត្រេកអរចំពោះកិន្នរនោះទៀត ហើយឱ្យកិន្នរទាំងពីរញីឈ្មោលអង្គុយលើសុវណ្ណបញ្ជរ ទើបបង្គាប់ឱ្យព្រានយកទៅលែងត្រង់កន្លែងដែលចាប់យកមក ។ ព្រានក៏យកទៅលែងតាមព្រះឱង្ការ ។ កិន្នរប្ដីប្រពន្ធនៅជាសុខសប្បាយដរាបដល់អស់អាយុក៏ព្រោះតែមិនពោលពាក្យជាទុព្ភាសិត ពោលពាក្យសុភាសិតតែម្យ៉ាង ។

**តស្មា មរណតោ មោក្ខំ បត្ថយន្តេន ជន្តុនា**
**បហាយ អលិកំ សច្ចំ ភាសិតព្វំ សុធីមតា ។**

ហេតុនោះ សត្វដែលមានប្រាជ្ញាល្អ កាលប្រាថ្នាឱ្យរួចពីសេចក្ដីស្លាប់ ត្រូវលះបង់ពាក្យឡេះឡោះចេញ ហើយពោលពាក្យសត្យតែម្យ៉ាង ។

# ៤៤. រឿងសេដ្ឋីបុត្រ

( ចាក មំ. ច. )

( គុណនៃបិយវាចា )

កាលកន្លងទៅហើយ មានសេដ្ឋីបុត្ត ៤ នាក់នៅក្នុងក្រុងពារាណសី. ថ្ងៃមួយមានសេចក្តីអផ្សុកអប្បាន្តយ៉ាងខ្លាំង ក៏បបួលគ្នាចេញពីគេហដ្ឋានរៀងៗ ខ្លួនទៅអង្គុយកំសាន្តចិត្តក្នុងកន្លែងមួយ ស្រាប់តែឃើញព្រានម្រឹគម្នាក់បររទេះចេញមកពីព្រៃផ្ទុកពេញទៅដោយសាច់បក្សាបក្សីគ្រប់បែប ក៏និយាយសុំសាច់របស់ព្រាននោះដោយបញ្ញាផ្សេងៗ ពីគ្នា ។ សេដ្ឋីបុត្រទី១ ផ្តើមនិយាយសុំថា អរេ លុទ្ទក ទេហិ មេ មំសខណ្ឌំ នែ! អាចព្រៃព្រានម្រឹគ ឯងឱ្យសាច់ដុំមកអញ ។ ព្រានម្រឹគពោលថា អ្នកដែលសុំរបស់គេត្រូវប្រើសំដីឱ្យល្អ ទើបសមរម្យ ហើយពោលគាថាថា :

**ផរុសា វត តេ វាចា មំសយាចនកោ អសិ**

**កិលោមសទិសី វាចា កិលោមំ សម្ម ទាមិ តេ ៗ**

អ្នកជាបុគ្គលសុំនូវសាច់ ហើយប្រើសំដីឈ្លើយព្រហើនពេកណាស់សំដីអ្នកបែបស្មុគ្រស្មាញដូចសាច់វាវ. ហ្ន៎ ! សំឡាញ់យកសាច់វាវទៅចុះ ហើយក៏ឱ្យសាច់វាវដែលឥតមានរសជាតិអ្វីដល់សេដ្ឋីបុត្រទី១ នោះ ។ សេដ្ឋីបុត្រទី២ ពោលសុំថា ជេដ្ឋភាតិក មំសខណ្ឌំ មេ ទេហិ បពិត្រអ្នកបង ចូរអ្នកបងឱ្យសាច់ដុំមកខ្ញុំ ។

ព្រានម្រឹគពោលគាថាតបថា :

**អង្គមេតំ មនុស្សានំ ភាតា លោកេ បវុច្ចតិ**

**អង្គស្ស សទិសី វាចា អង្គំ សម្ម ទទាមិ តេ ។**

ពាក្យថាបងនេះ ជាលោកវោហាររបស់សាមញ្ញជនទូទៅទេ តើសំដីអ្នកប្រាកដស្មើដោយអវយវៈ, ហ ! សំឡាញ់យកសាច់អវយវៈទៅចុះ, ហើយឱ្យសាច់អវយវៈដល់សេដ្ឋីបុត្រទី២ នោះ ។ សេដ្ឋីបុត្រទី៣ ពោលសុំថា តាត មំសខណ្ឌំ មេ ទេហិ ពា៎ ១ ពា៎ឱ្យសាច់ដុំមកខ្ញុំ ។ ព្រានក៏ឱ្យសាច់ដ៏សមគួរដល់សំដីនោះ ហើយពោលគាថាជាគំរប់ ៣ ថា :

**តាតាតិ បុត្តោ វទមានោ កម្បេតិ ហទយំ បិតុ**

**ហទយស្ស សទិសី វាចា ហទយំ សម្ម ទទាមិ តេ ។**

កូនហៅឪពុកថា ពា៎ ១ ដូច្នេះ រមែងញាំងបេះដូងឪពុកឱ្យញាប់ញ័រសំដីអ្នកប្រាកដស្មើដោយបេះដូង ហ៎ ! សំឡាញ់យកសាច់បេះដូងទៅចុះ ហើយឱ្យសាច់ឆ្ងាញ់ពិសាព្រមទាំងសាច់បេះដូងដល់សេដ្ឋីបុត្រទី ៣ នោះ ។ សេដ្ឋីបុត្រទី៤ ពោលសុំថា សហាយ មំសខណ្ឌំ មេ ទេហិ សំឡាញ់ អ្នកឱ្យសាច់ដុំមកខ្ញុំ ។ ព្រានក៏ឱ្យសាច់ដ៏សមរម្យដល់សំដីនោះ ហើយពោលគាថាជាគំរប់ ៤ ថា :

**យស្ស គាមេ សខា នត្ថិ យថារញ្ញំ តថេវ តំ**

**សព្វស្ស សទិសី វាចា សព្វំ សម្ម ទទាមិ តេ ។**

អ្នកណាគ្មានសំឡាញ់ក្នុងស្រុក ស្រុកអ្នកនោះដូចជាព្រៃស្ងាត់ជ្រងំ សំដីអ្នកប្រាកដដូចសាច់ទាំងអស់ ហា ! សំឡាញ់យកសាច់ទាំងអស់នេះទៅចុះ ហើយគាត់បររទេះដ៏ពេញដោយសាច់ទាំងអស់ យកទៅឱ្យសេដ្ឋីបុត្រទី៤ នោះដល់ទីលំនៅ ។ សេដ្ឋីបុត្រទី៤ នោះកាលបើបានទទួលអំណោយសាច់ទាំងអស់របស់ព្រានម្រឹគ ហើយក៏យកគ្នាជាភ្ញៀវ ហើយឱ្យទៅហៅប្រពន្ធមកនៅកណ្ដាលសម្បត្តិ ដរាបដល់អស់ជីវិតមិនមានប្រេះឆាអ្វីដល់គ្នានឹងគ្នាឡើយ ។

( ព្រះមហា សំ-សុខ )

## ៤៥- រឿងមិត្តវិន្ទុក

( ចាក ម. អ. )

( ទោសនៃការមិនដឹងគុណ )

មានសេចក្ដីដំណាលថា ក្នុងសាសនកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ មានសេដ្ឋីបុត្រម្នាក់ឈ្មោះមិត្តវិន្ទុក មានសម្បត្តិមានទ្រព្យ ៨០ កោដិក្នុងក្រុងពារាណសី ជាបុគ្គលទ្រុស្តសីល មាតានិងបិតាជាសោតាបន្នបុគ្គល ។ លុះចំណេរជាខាងក្រោយមក បិតារបស់មិត្តវិន្ទុកធ្វើមរណកាល, បុរសឈ្មោះមិត្តវិន្ទុកនិយាយនឹងមាតាថា បពិត្រលោកម៉ែ ខ្ញុំនឹងធ្វើនូវជំនួញដោយសំពៅ ។ មាតានិយាយថា នែកូន អ្នកជាកូនតូចមួយ ទ្រព្យក្នុងផ្ទះនេះមានច្រើន

ណាស់ សមុទ្រមានទូកនិងសំពៅច្រើនណាស់អ្នកកុំទៅឡើយ ។ បុរសឈ្មោះមិត្តវិន្ទុកៈ និយាយថា ខ្ញុំទៅឥឡូវនេះ ម៉ែមិនអាចឃាត់ខ្ញុំទេ ទុកណាជាម្ដាយចាប់ដៃរបស់បុរសឈ្មោះមិត្តវិន្ទុក ៗ ក៏រលាស់ដៃប្រហារម្ដាយឱ្យដួលហើយ លោតកន្លងម្ដាយស្ទុះទៅកាន់សមុទ្រដោយសំពៅ ។ សំពៅលុះដល់ថ្ងៃជាគំរប់ ៧ ក៏នឹងថ្កល់ឥតកំរើកព្រោះអាស្រ័យនូវបុរសឈ្មោះមិត្តវិន្ទុកៈជាអ្នកធ្វើអំពើអាក្រក់។ ពួកអ្នកសំពៅកំពុងចែកស្លាកដោយគិតថា នៅក្នុងសំពៅនេះមុខជានឹងមានមនុស្សកាឡកណ្ណី លុះមនុស្សទាំងអស់គ្នាដែលនៅក្នុងសំពៅនោះចាប់ស្លាកជាគំរប់ ៣ ដង ស្លាកនោះទៅត្រូវដល់បុរសឈ្មោះមិត្តវិន្ទុកៈនោះឯង ។ ក្នុងកាលនោះ មនុស្សទាំងឡាយធ្វើនូវក្បូនចាប់បុរសឈ្មោះមិត្តវិន្ទុកៈបោះចោលទៅលើខ្នងសមុទ្រ ។ បុរសឈ្មោះមិត្តវិន្ទុកអណ្ដែតទៅតាមក្បូន ដល់កោះមួយឃើញនគរមួយមានមុខទ្វារបួនក្នុងកោះនោះ ។ បានឮថា កោះនោះជាឧស្សទនរកជាកន្លែងសម្រាប់នៅរបស់កម្មនៃសត្វនរកច្រើនគ្នា ។ ចំណែកខាងនគរនោះ ហាក់ដូចជានគរដែលគេសម្រាប់តាក់តែងដោយគ្រឿងអលង្ការសព្វយ៉ាងប្រាកដដោយកម្លាំងកម្មគឺកិរិយាប្រហារមាតាដល់បុរសឈ្មោះមិត្តវិន្ទុកៈ, មិត្តវិន្ទុកចូលទៅគិតថា អញនឹងបានជាស្ដេចក្នុងនគរនេះ ហើយឃើញសត្វមួយរូបដែលកងចក្កដ៏មុតវិលនៅលើក្បាលកំពុងខ្សឹកខ្សួល ។ ខណៈនោះកងចក្កដ៏មុតលើក្បាលសត្វនរក

ប្រាកដដូចជាផ្កាឈូក ចំណងប្រកបដោយអង្គប្រាំលើដើមទ្រូង ប្រាកដ ដូចជាគ្រឿងសម្រាប់បិទនូវទ្រូងឈាមដែលហូរចេញអំពីសរីរប្រាកដដូចជាគេលាបស្រឡាបដោយខ្លឹមចន្ទន៍ សំឡេងជាទីយំឱ្យបខ្សួល ដូចជាចំរៀងមួយយ៉ាងឯកកើតឡើងដល់បុរសឈ្មោះមិត្តវិន្ទុកៈហើយក៏ចូលទៅរកសត្វនរកនិយាយថា ម្នាលបុរសដ៏ចំរើនផ្កាឈូកនេះអ្នកឯងពាក់យូរណាស់ហើយ ចូរឱ្យដល់ខ្ញុំ។ សត្វនរកប្រាប់ថា ម្នាលសម្លាញ់នេះមិនមែនផ្កាឈូកទេ នេះជាកងចក្រទេ. បុរសនិយាយថាអ្នកឯងពោលយ៉ាងនេះមិនចង់ឱ្យខ្ញុំសោះ។ សត្វនរកគិតថាកម្មរបស់អញអស់ហើយ បុរសនេះសម្លាប់នូវមាតា ដូចជាអញបានជាមកធ្វើយ៉ាងនេះ បើដូច្នេះអញនឹងឱ្យកងចក្រនេះដល់បុរសនោះចុះហើយហៅមកថា នែអ្នកដ៏ចំរើនអ្នកចូលមកចូរទទួលយកផ្កាឈូកនេះ ទើបបោះកងចក្រនោះទៅលើក្បាលបុរសនោះ ។ កងចក្រនោះវិលហាក់ដូចជាកិននូវអម្បែងក្បាលបុរសនោះ ក្នុងខណៈនោះមិត្តវិន្ទុកបុរសដឹងថា វត្ថុនេះជាកងចក្រដ៏មុតដល់នូវសេចក្តីវេទនាស្រែកទ្រហោយំថា អ្នកចូលយកកងចក្រដ៏មុតរបស់អ្នកវិញទៅ ។ ចំណែកខាងសត្វនរករត់បាត់ក្នុងពេលនោះទៅ។ មិត្តវិន្ទុកសោយនូវសេចក្តីទុក្ខក្នុងឧស្សទនរកនោះអស់កាលដ៏យូរដោយវិបាកជាគ្រឿងហូរមកមិនដាច់នៃអកុសលកម្មគឺកិរិយាសម្លាប់មាតា កាលបើផលនោះអស់ហើយ ក៏ចោលកងចក្រទៅតាមយថាកម្មយ៉ាងហ្នឹងឯង ។

# ៤៦. រឿងសាវត្ថីសេដ្ឋីបុត្ត

( ចាក ម. អ. )

( គុណនៃការបំរើមាតាបិតា )

បានឮថា មានសេដ្ឋីបុត្រម្នាក់ក្នុងក្រុងសាវត្ថី បានស្ដាប់ធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធមានសេចក្ដីជ្រះថ្លា សូមបួសជាឧបសម្បទា, លុះឧបសម្បទារួចហើយ គ្រាន់តែរៀនធម៌អំប្រាំឆ្នាំ, ចំរើនកម្មដ្ឋានក្នុងសំណាក់ឧបជ្ឈាយ៍ ទើបចេញអំពីវត្តជេតពនទៅកាន់ស្រុកជាទីបំផុតដែន នៅក្នុងព្រៃអាស្រ័យនឹងស្រុកទីបំផុតដែននោះ ។ ឯមាតាបិតារបស់ភិក្ខុនោះ, តាំងតែអំពីកាលភិក្ខុនោះបួស ទ្រព្យសម្បត្តិក៏ដល់នូវការអស់រលីងតាមលំដាប់ ដល់នូវភាពនៃខ្លួនដែលជនដទៃអាណិតអាសូរក្រៃពេក ទើបកាន់យកអម្បែងដើរសូមនៅអាស្រ័យនូវជញ្ជាំងផ្ទះរបស់ជនដទៃ ។ លុះចំណេរខាងក្រោយមកភិក្ខុនោះឮថា មាតាបិតារបស់ខ្លួនដល់នូវសេចក្ដីទុគ៌ត ហើយគិតថា អញព្យាយាមនៅក្នុងព្រៃអស់ ១២ ឆ្នាំមិនដល់មគ្គផលសោះ អញជាមនុស្សអភព្វ ប្រយោជន៍អ្វីដោយបព្វជ្ជារបស់អញ បើសិកទៅជាគ្រហស្ថ អញនឹងចិញ្ចឹមមាតាបិតាឱ្យនូវទានមានឋានសួគ៌ប្រព្រឹត្តទៅខាងមុខ ទើបចេញអំពីព្រៃដល់ក្រុងសាវត្ថីចូលទៅកាន់វត្តជេតពនដោយបំណងថា ក្នុងថ្ងៃនេះនឹងបានជួបព្រះសាស្ដាស្ដាប់ធម៌ទេសនាក្នុងថ្ងៃស្អែក នឹងបានឃើញមាតាបិតាអំពីព្រលឹម ។ ក្នុង

ថ្ងៃនោះ ព្រះសាស្ដាទ្រង់ប្រមើលមើលនូវសត្វលោកក្នុងកាលជាទីកំចាត់បង់នូវងងឹត ឃើញឧបនិស្ស័យនៃមគ្គជាដំបូងរបស់ភិក្ខុនោះ ព្រះអង្គទ្រង់ត្រាស់សរសើរគុណ របស់មាតាបិតាដោយមាតាបិតុបោសកសូត្រ ភិក្ខុនោះគិតថា អញនឹងសឹកទៅជាគ្រហស្ថបំរើមាតាបិតា ស្រាប់តែព្រះសាស្ដាត្រាស់ថា បព្វជិតក៏ឈ្មោះថាជាអ្នកធ្វើឧបការៈដល់មាតាបិតាបាន ប្រសិនបើអញមិនជួបព្រះសាស្ដាហើយលាចាកបព្វជ្ជាមានសភាពបែបនេះ, ឥឡូវនេះអញជាបព្វជិតនឹងបំរើមាតាបិតា ។ លុះដល់ព្រឹកឡើងភិក្ខុនោះចាប់ស្លាក ដែលគេធ្វើដោយបបរដល់ខ្លួនផង នូវស្លាកដែលគេធ្វើដោយបាយដល់ខ្លួនផង ចូលទៅក្នុងស្រុកយកបបរនិងបាយទៅជូនមាតាបិតា និមន្តទៅបិណ្ឌបាតដោយខ្លួនឯង, លុះធ្វើភត្តកិច្ចរួចហើយ ធ្វើនូវទីសម្រាប់នៅដល់មាតាបិតាទៀត តាំងអំពីពេលនោះចេះតែបំរើមាតាបិតាមិនដែលដាច់, មិនត្រឹមតែប៉ុណ្ណោះភិក្ខុនោះជូននូវបក្ខិកភត្ត ដែលខ្លួនបានហើយដល់មាតាបិតាទៀត, ហើយនិមន្តទៅបិណ្ឌបាតដោយខ្លួនឯងបានទើបឆាន់ មិនបានមិនឆាន់ ថ្ងៃដែលភិក្ខុនោះបានចង្ហាន់តិចណាស់ ថ្ងៃដែលមិនបានមានច្រើន, ភិក្ខុនោះបានសំពត់សម្រាប់ចាំវស្សាក៏ដោយ វត្ថុតិចតួចដទៃក៏ដោយយកទៅជូនមាតាបិតាទាំងអស់ ហើយដេរកំណាត់សំពត់ចាស់ៗ ដែលមាតាបិតាប្រើប្រាស់ហើយជ្រលក់ប្រើប្រាស់ខ្លួនឯង ភិក្ខុនោះដែលអាពាធកើតអំពីការ

បំរើមាតាបិតាបៀតបៀនហើយយ៉ាងនេះ ទៅជាស្រមណ៍ស្គមមានកំឡាំងខ្សោយ ។ ភិក្ខុទាំងឡាយឃើញភិក្ខុអ្នកបំរើមាតាបិតានោះ ទើបសួរដឹងហេតុសព្វគ្រប់ បែរជាតិះដៀលភិក្ខុនោះវិញ ទៅក្រាបបង្គំទូលព្រះសាស្តា ។ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងឡាយឱ្យហៅភិក្ខុអ្នកបំរើមាតាបិតានោះមកព្រះអង្គ ទ្រង់ជ្រាបហើយ ចង់ញ៉ាំងភិក្ខុអ្នកបំរើមាតាបិតាឱ្យជ្រាបសេចក្តីនោះ ទ្រង់ប្រទានពរសព្ទសាធុការប្រកាសនូវបុព្វាចារ្យរបស់ខ្លួន ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុអ្នកឯងបំរើជនណា ជននោះត្រូវជាអ្វីរបស់អ្នក? ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ជននោះត្រូវជាមាតាបិតារបស់ខ្ញុំព្រះអង្គ ។ ក្នុងពេលនោះព្រះសាស្តាទ្រង់ប្រទានពរសព្ទសាធុការអស់វារៈ ៣ ដងដល់ភិក្ខុនោះ សាធុ សាធុ ទ្រង់ត្រាស់ថា អ្នកឋិតនៅក្នុងផ្លូវដែលតថាគតដើរហើយ តថាគតប្រព្រឹត្តនូវបុព្វាចារ្យចិញ្ចឹមមាតាបិតា ទើបទ្រង់សំដែងសុវណ្ណសាមជាតក ក្នុងមហានិបាតត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាការចិញ្ចឹមមាតាបិតា ជាវង្សនៃអ្នកប្រាជ្ញទាំងឡាយ ទើបប្រកាសនូវសច្ចៈទាំងឡាយ ។ លុះដល់ទីបំផុតនៃសច្ចភិក្ខុនោះ បានសម្រេចសោតា ក្នុងពេលនោះទៅ ។

( ព្រះមហា ង៉ោ_អ៊ុំវស៊ុន )

# ៤៧~ រឿងចចកឈ្មោះបូតិមំសៈ

( ចាក បូ. ន. )

( ការឈ្លាសវៃមិនដែលស្លាប់ដោយឧបាយកលអ្នកដទៃ )

បានដឹងថា កាលកន្លងទៅជាយូរលង់ណាស់ហើយ មានហ្វូងសត្វចៀមជាច្រើន នៅអាស្រ័យក្នុងគុហារក្បែរភ្នំទៀបហេមវន្តប្រទេស។ ក្នុងចំណោមសត្វទាំងឡាយនោះ មានមេចៀម១ ឈ្មោះមេណ្ឌមាតា ជាសត្វវាងវៃប៉ិនប្រសប់ក្នុងឧបាយគ្រប់យ៉ាង ។ ក្នុងទីមិនឆ្ងាយពីគុហា ជាលំនៅនៃចៀមទាំងឡាយនោះ មានសត្វចចក១ ឈ្មោះបូតិមំសៈ និងភរិយាឈ្មោះវេណីយានៅរួមសំវាសគ្នាក្នុងគុហា ១ ដែរ ។ ចចកឈ្មោលចចកញីជាប្ដីប្រពន្ធនោះ បានមានមធ្យោបាយដ៏ប្រពៃខាងការប្រវ័ញ្ចន៍ បោកសម្លាប់សត្វចៀមទាំងឡាយស៊ីអស់ជាច្រើន និងចង់ស៊ីសាច់មេចៀមឈ្មោះ មេណ្ឌមាតាជាសត្វឈ្លាសវៃនោះទៀត ទើបពោលប្រាប់ប្រពន្ធថា ចូរនាងយកមេចៀមឈ្មោះមេណ្ឌមាតានោះ ជាសម្លាញ់ចុះ ! កាលបើសេចក្ដីស្រឡាញ់កើតឡើងរវាងនាង និងមេចៀមនោះហើយ អញនឹងដេកធ្វើពុតជាស្លាប់, នាងចូលទៅជិតមេចៀមពោលប្រាប់ថា "ហ៊ឺ! ប្ដីខ្ញុំស្លាប់ទៅហើយ, ឯខ្ញុំរៀរតែនាងចេញគ្មានញាតិណាមួយសោះ សូមអញ្ជើញនាងទៅជួយធ្វើពិធីសរីរកិច្ចដល់ប្ដីខ្ញុំ តាមសេចក្ដីអង្វរនិងសង្គហកិច្ចរបស់នាងរវាងប្ដីខ្ញុំ" លុះនាងពោលយ៉ាងនេះហើយ

ចូរនាំមេណ្ឌមាតានោះមក. បើមេចៀមនោះលុះក្នុងបវព្ជនកិច្ចរបស់នាងមែន អញនឹងលោកទៅខាំវាត្រង់កឱ្យស្លាប់តែម្តង ។ មេចចកធ្វើតាមពាក្យរបស់ប្តីខ្លួនសព្វគ្រប់ ក៏បាននាងមេណ្ឌមាតានោះធ្វើជាសំឡាញ់មែន ហើយពោលប្រាប់រឿងរ៉ាវតាមលំអានពាក្យស្វាមី ។ មេចៀមពោលថា ប្តីនាងស៊ីញាតិរបស់ខ្ញុំអស់ច្រើនគ្នាហើយ. ឥឡូវចង់ស៊ីខ្ញុំទៀតឬ? ខ្ញុំខ្លាចណាស់មិនហ៊ានទៅទេ ។ មេចចកថា កុំខ្លាចអី មិនដែលល្បីថាសត្វស្លាប់ហើយអាចធ្វើឱ្យគេភ័យទៀតទេហើយនាំនាងមេណ្ឌមាតានោះមក ។ ចចកបូតិមំសៈ ឮសូរជើងសត្វទាំងពីរនោះមក គិតថា យី! អស្ចារ្យណាស់ មីចៀមនេះលុះក្នុងអំណាចបវព្ជនកិច្ចប្រពន្ធអញហើយតើ ហើយអើតក្បាលរមិលមើល ។ មេចៀមឃើញអាការៈចចកធ្វើដូច្នោះ ទើបស្រែកអាគ្រោះយ៉ាងខ្លាំងដោយពាក្យអាស្រូវភាសថា "អើអាចង្រៃនេះមានធម៌លាមកណាស៊ីយ វាពុតធ្វើជាស្លាប់ដេកលក់វាហ៎ី ប្រុងបញ្ឆោតសម្លាប់អញធ្វើអាហារចំណីរបស់វា បើកុំតែអញឃើញទាន់ម៉្លេះសមជាធ្លាញ់វាយ៉ាងណាទៅអេះ" ហើយងាកក្បាលស្ទុះបោលយ៉ាងលឿនទៅ ។ មេចចកវេណិយាអស់សង្ឃឹមហើយ ក៏ចូលទៅស្តីបន្ទោសចចកជាប្តីខ្លួននោះដោយគាថាថា:

**តំ ខោសិ សម្ម ឧម្មត្តោ ឧម្មេធោ អទិចក្ខណោ**

**យោតំ មតាលយំ កត្វា អកាលេនវិបេក្ខសិ ។**

នែ! អ្នកចង្រៃអ្នកណាធ្វើពុតជាស្លាប់ រមិលមើលខុសកាល អ្នកនោះជាសត្វឆ្កួត មានគំនិតអាក្រក់ មិនចេះពិចារណា ។

ចចកឈ្មោះបូតិមំសៈទាល់បុច្ឆ ក៏នៅស្ងៀមបើកតែភ្នែក សំឡឹងប្រពន្ធមីស។ រុយទុំលែងទាំងដេញថែមទៀត ព្រោះប្រពន្ធជាន់កែងជាប់ ។

## ៤៨. រឿងស្ដេចសេក

( ចាក កេ. ប. )

( គុណនៃការចិញ្ចឹមមាតាបិតា )

ក្នុងកាលកន្លងទៅហើយ មានព្រាហ្មណ៍គ្រាមមួយឈ្មោះសាលិន្ទិយៈ តាំងនៅទិសឦសានពីក្រុងរាជគហៈ ។ តពីព្រាហ្មណ៍គ្រាមនោះ មានស្រែនៃជនក្នុងដែនមគធៈមួយ នៅទិសឦសានដូចគ្នា ។ ក្នុងទិសឦសានតពីមគធក្ខេត្តនោះដដែល មានដើមរការ ១ ធំដុះទៀបញកភ្នំ ។ លើដើមរកានោះ មានសេកនៅជាច្រើន ។ ពេលនោះព្រះពោធិសត្វ កើតជាស្ដេចសេកមានសរីរៈធំប៉ុនដុំរទេះ តែងតែហើរទៅពាំយកចំណីពីព្រៃហេមពាន្ត មកចិញ្ចឹមមាតាបិតា។ គ្រានោះមានព្រាហ្មណ៍ម្នាក់ ជាកោសិយគោត្ត នៅអាស្រ័យក្នុងស្រុកសាលិន្ទិយនោះ បានសាបព្រោះស្រូវសាលីក្នុងស្រែមួយ មានពាន់នៃករីសជាប្រមាណ ហើយឱ្យបុរសម្នាក់ជាអ្នកថែទាំមើលការ

ខុសត្រូវ ។ ស្តេចសេកនិងបរិវារតែងហើរទៅចុះក្នុងស្រែនោះជានិច្ចកាល ។ ឯខេត្តបាលបុរសដេញមិនឈ្នះសោះ ព្រោះហ្វូងសេកច្រើនហួស ។ អស់សេកទាំងនោះ ស៊ីត្រឹមតែឆ្អែតក៏ហើរទៅ ។ ប្លែកអស្ចារ្យណាស់ មានតែស្តេចសេកមួយទេ ដែលស៊ីឆ្អែតហើយឆ្លៀតពាំគួរស្រូវនោះជាច្រើនយកទៅទៀត ។ ខេត្តបាលបុរសក៏ទៅជំរាបព្រាហ្មណ៍ ៗ ពោលថា បើដូច្នោះ ចូរយកវេញរោមកន្ទុយសេះធ្វើជាអន្ទាក់ដាក់ត្រង់កន្លែងស្តេចសេកនោះវាចុះ. បើចាប់បានត្រូវនាំយកមកទាំងរស់កុំខានហ្ន ! ។ ខេត្តបាលបុរសធ្វើតាមបង្គាប់ព្រាហ្មណ៍ក៏ចាប់បានស្តេចសេកនោះ ហើយយកទៅឱ្យទាំងរស់ ។ ព្រាហ្មណ៍គ្រាន់តែឃើញស្តេចសេកភ្លាម មានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ហើយឱ្យឈរទុំលើភ្លៅខ្លួនសួរថា នែសេក អ្នកស៊ីស្រូវសាលីដរាបឆ្អែត ហើយនាំទៅដោយចំពុះទៀត. យើងឆ្ងល់ណាស់ជង្រុករបស់អ្នកមានឬទេ ឬអ្នកចងពៀរចំពោះយើង? ស្តេចសេកឮនូវសំនួរនោះ ក៏ពោលគាថាដ៏ផ្អែមល្ហែមជាភាសាមនុស្សថា :

**ន មេ វេរំ តយា សទ្ធឹ កោដ្ឋំ មយ្ហំ ន វិជ្ជតិ**
**ឥណំ មុញ្ចាមិណំ ទម្មិ សម្បត្តោ កោដិសិម្ពលឹ**
**និធិម្បិ តត្ថ និទហាមិ ឯវំ ជានាហិ កោសិយ ។**

ខ្ញុំមិនធ្វើពៀរចំពោះអ្នកទេ ជង្រុករបស់ខ្ញុំក៏គ្មាន ខ្ញុំនាំស្រូវទៅដើមរកាវិញនោះ ព្រោះសងបំណុលចាស់បុលបំណុលថ្មី ទាំង

កំណាប់ក៏ខ្ញុំកប់ទុកក្នុងទីនោះ ម្នាលកោសិយព្រាហ្មណ៍អ្នកចូរដឹងយ៉ាងនេះចុះ ។

ដើម្បីដោះស្រាយចំនួរព្រាហ្មណ៍ នឹងធ្វើសេចក្ដីនោះឱ្យច្បាស់លាស់ ទើបពោលគាថាដទៃទៀតថា :

**អជាតបក្ខា សកុណា បុត្តកា មយ្ហំ កោសិយ**
**តេមំ ភតា ភរិស្សន្តិ តស្មា តេសំ ឥណំ ទទេ ។**

ហៃកោសិយៈ សកុណជាតិកូនខ្ញុំមិនទាន់ដុះស្លាបទេ ខ្ញុំចិញ្ចឹមវា វាមុខជាចិញ្ចឹមខ្ញុំវិញ ហេតុនោះខ្ញុំត្រូវឱ្យបំណុលដល់ពួកវានោះ ។

**មាតាបិតា ច មេ ជិណ្ណា ជិណ្ណកា គតយោព្វនា**
**តេសំ តុណ្ឌេន ហាតូន មុញ្ចេ បុព្វេ កតំ ឥណំ ។**

ឯមាតាបិតាខ្ញុំសោត មានវ័យចំរើនណាស់ទៅហើយ ខ្ញុំនាំស្រូវដោយចំពុះ នឹងយកទៅសងបំណុលចាស់នោះ ។

**អញ្ញេ បិ តត្ថ សកុណា ខីណបក្ខា សុទុព្វលា**
**តេសំ បុញ្ញត្ថិកោ ទម្មិ តំ និធឹ អាហុ បណ្ឌិតា ។**

លើដើមរកានោះ មានពួកសត្វស្លាបដទៃ មានស្លាបរិលនឹងមានកំឡាំងអន់ថយណាស់ ខ្ញុំជាអ្នកចំណូលដោយបុណ្យនឹងឱ្យដល់សត្វទាំងឡាយនោះទៀត ពួកបណ្ឌិតពោលនូវបុញ្ញកម្មនោះថាជាអនុគាមិកនិធិ ។

ព្រាហ្មណ៍ឮគាថានោះជ្រះថ្លាណាស់ បានប្រគល់ស្រែឱ្យ ហើយពោលថា ចាប់ពីថ្ងៃនេះទៅ អញនឹងញាតិចូរទំពារស៊ីស្រូវនេះចុះ ទើបស្រាយចំណងពីជើង ។ សេកពោធិសត្វ ជាសត្វដឹងប្រមាណ ក៏ទទួលយកតែត្រឹម ៨ ករីសប៉ុណ្ណោះ សល់ពីនោះប្រគល់ឱ្យព្រាហ្មណ៍វិញ ទើបឱ្យឱវាទជាដំបូន្មានដ៏ប្រសើរធ្មើមតែមួយមាត់ថា មហាព្រាហ្មណ៍ អ្នកកុំប្រមាទឱ្យសោះ ហើយនាំនូវគួរស្រូវសាលីហើរឆ្ពោះទៅកាន់សំណាក់មាតាបិតាទៅ ។ ព្រាហ្មណ៍បោះនូវគោលក្នុងស្រែ ៨ ករីសនោះហើយ ពោលប្រាប់ខេត្តបាលបុរសថា អ្នកកុំឃាត់ឃាំងពួកសេកទៀតចាប់ពីថ្ងៃនេះទៅ ។ ហ្វូងសេកបានមានសេចក្ដីសុខសប្បាយកាយចិត្ត ដោយសារតែស្ដេចរបស់ខ្លួនមានបញ្ញាយ៉ាងពិទ័ត្ន ហើយតែងហើរទៅពាំនាំយកមកបរិភោគនូវស្រូវក្នុងស្រែ ៨ ករីសនោះជាប់ជានិច្ច ។

( ព្រះមហា សំ-សុខ និស្សិតសាលាបាលីជាន់ខ្ពស់ )

# ៤៩. រឿងអតិចារិណិត្ថី

( ចាក អ. ម. )

( ទោសកាម ក្បត់ចិត្តស្វាមី )

ក្នុងកស្សបពុទ្ធកាល មានភរិយារបស់ឧបាសកជាសោតាបន្ន ម្នាក់ ជាស្រីប្រព្រឹត្តក្បត់ចិត្តស្វាមី ។ ឧបាសកនោះ ឃើញនូវហេតុ ប្រព្រឹត្តិបំពាននោះយ៉ាងប្រក្យ័ក្ស ហើយពោលសួរថា ព្រោះហេតុអ្វី បានជានាងប្រព្រឹត្តមិនគប្បីយ៉ាងនេះ? ស្រីភរិយានោះពោលស្បថ ស្បែថា ប្រសិនបើខ្ញុំធ្វើយ៉ាងហ្នឹងមែន សូមឱ្យឆ្កែនេះខាំជញ្ជែងស៊ីខ្ញុំ កុំបីខាន ព្រោះជាអ្នកប្រព្រឹត្តក្បត់ចិត្តស្វាមីខ្លួន ។ លុះនាងនោះ ស្លាប់ទៅ បានកើតជាប្រេតឈ្មោះវេមានិកា ក្នុងស្រះឈ្មោះកណ្ណ-មុណ្ឌៈ ពេលថ្ងៃសោយសម្បត្តិទិព្វ ពេលយប់រងទុក្ខជាខ្លាំង ។

នឹងស្រដីពីព្រះចៅក្រុងពារាណសី ទ្រង់ស្តេចចេញប្រពាធ ព្រៃដើម្បីបរបាញ់ម្រឹគីម្រឹគា ក៏ដល់ទៅស្រះកណ្ណមុណ្ឌៈនោះតាម លំដាប់ សោយសម្បត្តិជាមួយនាងប្រេតនោះ ។ នាងវេមានិកានោះ មិនឱ្យព្រះរាជាជ្រាបសោះ អំពីរឿងរងទោសទុក្ខក្នុងពេលយប់ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ស្ត្រីនេះទៅណាអេះ លុះជ្រាបហើយ ស្តេចយាងទៅប្រថាប់ជិតពីក្រោយខ្នងនាង ស្រាប់តែឃើញឆ្កែមួយ ចោលចេញពីស្រះឈ្មោះកណ្ណមុណ្ឌនោះ មកទំពារស៊ីនាងវេមានិកា ឮសូរបេដៈ! (ខ: ខ:) ទើបហូតដាវកាប់ឆ្កែមួយរឹបដាច់ជាពីរកំណាត់

កំណាត់នោះ បានក្លាយទៅជាផ្លែពីរ ។ ព្រះរាជាកាប់ផ្លែនោះជាកំណាត់ ២ ទៀត (៤ កំណាត់) កំណាត់ ៤ នោះបានក្លាយទៅជាផ្លែ ៤ ។ ព្រះរាជាកាប់ផ្លែនោះជាកំណាត់ ២ ទៀត (៨ កំណាត់) កំណាត់ ៨ នោះ បានក្លាយទៅជាផ្លែ ៨ ព្រះរាជាទ្រង់កាប់ផ្លែទាំង៨ នោះជាកំណាត់ ២ ទៀត (១៦ កំណាត់) កំណាត់ទាំង១៦ នោះបានក្លាយទៅជាផ្លែ ១៦ ទៀត ។ នាងវេមានិកាពោលថា បពិត្រព្រះរាជស្វាមី ស្ដេចទ្រង់ធ្វើអ្វីនេះ ព្រះរាជាពោលសួរវិញថា នេះជាអ្វី? នាងវេមានិកាពោលប្រាប់ថា ព្រះអង្គកុំទ្រង់ធ្វើយ៉ាងនេះឡើយ សូមស្ដេចស្ដោះដុំទឹកមាត់លើដីវិញ ហើយទ្រង់ឈ្លីដោយព្រះបាទទៅ ។ ព្រះរាជាក៏ទ្រង់ធ្វើតាមដូច្នោះ ។ ផ្លែទាំង ១៦ ក៏បាត់ទៅ ។ កម្មរបស់នាងវេមានិកាក៏អស់ក្នុងថ្ងៃនោះ ។ ព្រះរាជាទ្រង់មានព្រះរាជចិន្ដាវិប្បដិសារីក្រៃពេក ទើបទ្រង់ប្រារព្ធនឹងយាងត្រឡប់ទៅព្រះនគរវិញ ។ នាងវេមានិកាពោលឃាត់ថា បពិត្រព្រះរាជស្វាមី កម្មរបស់ទូលព្រះបង្គំជាខ្ញុំអស់ហើយ សូមព្រះករុណាជាម្ចាស់ស្ដេចកុំយាងទៅ នៅរួមគ្នាក្នុងទីនេះហើយ ។ ព្រះរាជាមិនទ្រង់ព្រះសណ្ដាប់សោះ ក៏ស្ដេចយាងទៅព្រះនគរវិញ ។

## ៥០. រឿងពាណិជបុរស

( ចាក អ. វ. )

( ទោសនៃការជាប់ជំពាក់ក្នុងកាមគុណ )

កាលពីអតីតៈ ក្នុងតម្ពបណ្ណិទ្វីប (ទ្វីបរបស់ជនអ្នកមានបាតដៃក្រហមនៅអាស្រ័យ) មាននគរយក្ខមួយឈ្មោះ សិរីសវត្ថុ ។ យក្ខិនីទាំងឡាយក្នុងនគរនោះ តែងឱ្យនូវវត្ថុមានបបរនិងបាយជាដើមដល់ពួកពាណិជ ដែលមានសំពៅបែកហើយមកក្នុងទីនោះ ទើបសួរថា អ្នកទាំងឡាយមកក្នុងទីនេះ តើដោយកម្មដូចម្តេច? សំពៅយើងបែកកណ្តាលសមុទ្រ ទើបមកក្នុងទីនេះ ។ យក្ខិនីទាំងឡាយនោះពោលថា "ប្រពៃហើយអ្នកទាំងឡាយ ស្វាមីនៃយើងទាំងឡាយទៅជួញអស់រយៈពេល ៣ ឆ្នាំមិនឃើញមកសោះ ប្រហែលជាស្លាប់បាត់ហើយមើលទៅ, អ្នកទាំងឡាយសុទ្ធតែជានាយពាណិជ, យើងទាំងឡាយនឹងបានគ្នាជាគូកំសត់ទៅ, ហើយប្រលោមនាយពាណិជទាំងនោះ ដោយអាការៈផ្សេងៗ ទើបនាំទៅនគរយក្ស ។ ឯមនុស្សទាំងឡាយដែលវាចាប់បានមុនៗ វាចងដោយចំណង ហើយរុញបញ្ចូលទៅក្នុងផ្ទះសម្រាប់ធ្វើការ នឹងយកមនុស្សដែលចាប់បានក្រោយធ្វើជាស្វាមីទៀត" បើចាប់មនុស្សទាំងឡាយមិនបានក្នុងលំនៅវា ៗ ត្រាច់ទៅក្នុងឆ្នេរសមុទ្រគឺ ខាងនាយនគរឈ្មោះកល្យាណី ខាងអាយទ្វីបរបស់នាគ ។ សេចក្តីដែលបាន

បរិយាយមកក្នុងខាងលើទាំងប៉ុន្មាននេះ ជាប្រវេណីរបស់យក្ខិនី ទាំងឡាយនោះទេ ។

ថ្ងៃមួយមានពាណិជ ៥០០ នាក់បែកសំពៅត្រង់ទីជិតនគរ យក្ខិនីទាំងឡាយនោះ ។ យក្ខិនីទាំងឡាយនោះ ក៏ប្រលោមល្បួង លួងលោមនាយពាណិជទាំងឡាយនោះ តាមរបៀបអ្នកលម្បួង ហើយនាំមកនគរខ្លួន ទើបចងមនុស្សដែលចាប់បានមុន ៗ នោះវិញ បញ្ចូលទៅក្នុងផ្ទះសម្រាប់ធ្វើការ ។ យក្ខិនីច្បង យកនាយពាណិជ ជាច្បងធ្វើប្ដី ឯយក្ខិនីដទៃទៀត ក៏យកនាយពាណិជជាលំដាប់ ៗ ធ្វើប្ដីដែរ លុះនាយពាណិជទាំងឡាយនោះ ចុះស៊ុបកាន់និទ្រានារាត្រីកាល វាក៏ក្រោកសន្សឹមៗ ទៅស៊ីមនុស្សក្នុងផ្ទះសម្រាប់ធ្វើការ ហើយត្រឡប់មកវិញ ។ ពាណិជចំបងបានឃ្លាំមើលដឹងថាប្រពន្ធជា យក្ខិនីយ ទើបប្រាប់សេចក្ដីនោះដល់ពាណិជទាំងអស់ហើយបបួលថា មកយើងរត់ទៅ ។ ប ណ្ដាពាណិជ ៥០០ នោះ, ពាណិជ ២៥០ ពោលតបថា ទេយើងមិនអាចរត់ចោលស្រ្តីទាំងនេះ ដែលសម្មស្ស ទន់ភ្លន់ត្រជាក់ដល់ចិត្តថ្លើមយើងបានឡើយ ណ្ហើយអញ្ជើញចុះ យើងមិនបានទៅទេ ។ ពាណិជចំបងក៏នាំពាណិជ ២៥០ នាក់ដែល ធ្វើតាមពាក្យរបស់ខ្លួនរត់ទៅ ។ អើគ្រានោះព្រះពោធិសត្វរបស់ យើងទ្រង់សោយព្រះជាតិជាស្ដេចសេះវលាហកៈ មានសព៌ាង្គកាយ សត្រសុស មានឫទ្ធិអស្ចារ្យ អាចហោះហើយ ដើរដោយអាកាស

វេហាស៍បានតាមចិន្តាចង់ ហោះមកពីព្រៃហេមពាន្តមកកាន់តម្ពប-ណ្ណទ្វីប ទំពារស៊ីស្រូវសាលីដែលដុះឯងកើតឯងហើយហោះត្រឡប់ទៅវិញ បានឃើញពាណិជទាំងនោះ ក៏ស្រែកសួរដោយសេចក្ដីករុណាអស់វារៈបីដងថា មានអ្នកណាចង់ទៅកាន់ជនបទដែរឬទេ? ពាណិជទាំងនោះ ឮនូវសម្រែកស្ដេចសេះ ក៏ផ្គងអញ្ជលីពោលថា យើងទាំងឡាយនឹងទៅ ។ ស្ដេចសេះក៏បន្ទាបខ្នងមកហើយពោលថា បើដូច្នោះចូរឡើងជិះលើខ្នងខ្ញុំមក ។ លំដាប់នោះពាណិជមួយពួកឡើងជិះលើខ្នង មួយពួកទៀតកាន់នូវកន្ទុយ មួយពួកទៀតឈរផ្គងអញ្ជលី ។ ដោយហោចទៅ ស្ដេចសេះអាចនាំនូវពាណិជដែលឈរផ្គងអញ្ជលីដោយអានុភាពរបស់ខ្លួន ទៅកាន់លំនៅរៀង១ខ្លួនបាន ទើបហោះត្រឡប់ទៅឋានខ្លួនវិញ ។ ឯពាណិជ ២៥០ នាក់ដែលជាប់ចិត្តស្រឡាញ់ក្នុងរូប, ក្លិន, រស និងសម្ផស្សដ៏ទន់ភ្លន់ត្រជាក់របស់យក្ខិនីទាំងឡាយនោះ ក៏បានជាចំណីរបស់យក្ខិនីទាំងនោះទៅ ។

( ព្រះមហា សំ_សុខ )

## ៥១. រឿងពារាណសីសេដ្ឋីបុត្រ

( ចាក ខ. ឯ. )

( អានិសង្សទានរបស់បុគ្គលមានសទ្ធាមុតមាំ )

កាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាកូនសេដ្ឋីនៅក្នុងនគរពារាណសី លុះឥតអំពីបិតាធ្វើមរណកាលទៅ ព្រះបាទព្រហ្មទត្តបានតាំងព្រះពោធិសត្វជាសេដ្ឋី ក្នុងនគរពារាណសី គ្រប់គ្រងសម្បត្តិជំនួសបិតា ។ ព្រះពោធិសត្វជាបុគ្គលមានសទ្ធាមុតមាំជឿកម្មផលច្បាស់លាស់ បានចំណាយទ្រព្យធ្វើសាលាទាន ៦ កន្លែង ហើយតែងបរិច្ចាគទាន រក្សាឧបោសថសីលជានិច្ចពុំដែលខាន ។ វេលាថ្ងៃមួយ ព្រះពោធិសត្វរៀបបរិភោគអាហារពេលព្រឹកស្រាប់តែមានព្រះបច្ចេកពុទ្ធមួយព្រះអង្គ ទើបនឹងចេញចាកនិរោធសមាបត្តិ ហោះមកឈរទៀបទ្វារផ្ទះ ។ ព្រះពោធិសត្វក្រឡេកទៅឃើញ ទើបប្រើបុរសម្នាក់ឱ្យទៅយកបាត្រពីលោកមកដាក់ចង្ហាន់ ។ គ្រានោះមារាធិរាជ មកនិម្មិតធ្វើជារណ្តៅរងើកភ្លើងក្រហមរន្ទាលច្រាលឆ្អៅដូចជាអវីចិមហានរក ។ បុរសម្នាក់ទៅយកបាត្រឃើញភ្លើងនោះហើយ ភិតភ័យណាស់ត្រឡប់មកជំរាបព្រះពោធិសត្វវិញ ព្រះពោធិសត្វ បានយល់ច្បាស់ថា មារនៅស្ថានវសវត្តីមកធ្វើឱ្យអន្តរាយព្រះជន្មព្រះបច្ចេកពុទ្ធផង ទើបយកភាជន៍ដាក់ចង្ហាន់ពេញចេញអំពីផ្ទះទៅឈរក្បែររណ្តៅភ្លើង ហើយទូលព្រះបច្ចេកពុទ្ធថា

ភាមំ បតាមិ និរយំ ឧទ្ធំបាទោ អវំសិរោ
នានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហ ។

ប្រែជាសេចក្ដីថា : បពិត្រលោកម្ចាស់ដ៏ចំរើន បើទុកណាជាខ្ញុំធ្លាក់ដាំក្បាលចុះក្នុងរណ្ដៅភ្លើងដូចជានរកនេះ ក៏ខ្ញុំមិនថយក្រោយវិញដែរ សូមព្រះករុណាម្ចាស់ទទួលយកនូវចង្ហាន់នេះចុះ ។

ព្រះពោធិសត្វនិយាយទូលព្រះពោធិសត្វដូច្នេះហើយ ក៏លោតចុះទៅក្នុងរណ្ដៅភ្លើង ស្រាប់តែមានឈូកផុះទ្រជើងយ៉ាងអស្ចារ្យ ព្រះពោធិសត្វបានយកចង្ហាន់ទៅដាក់ក្នុងបាត្រប្រគេនព្រះបច្ចេកពុទ្ធដោយសួស្ដី ។

ឯមារឃើញប្លែកអស្ចារ្យដូច្នោះហើយ ភ័យតក់ស្លុតវិនាសបាត់អំពីទីនោះទៅ ។

ចប់ភាគទី ២

( សូមមើលភាគ ៣ ទៀតមានរឿងប្លែក )

# ប្រជុំនិទានជាតក

## ១- រឿងគហបតីប្រេត

(ចាក បេ. ខុ.)

(ទោសនៃការមើលងាយព្រះសារីរិកធាតុ)

កាលព្រះសម្ពុទ្ធបរមគ្រូបរិនិព្វានហើយ ពួកពុទ្ធបរិ. ស័ទទាំងឡាយ មានព្រះបាទមល្លរាជជាប្រធាន បានរៀបបូជាព្រះបរមសពព្រះសម្ពុទ្ធ លុះបូជាហើយ ព្រះមហាក្សត្រទាំងឡាយក្នុងជម្ពូទ្វីប លើកទ័ពមកច្បាំងដណ្តើមព្រះបរមធាតុ, កាលនោះទោណអាចារ្យបានសម្រុះសម្រួលចែកព្រះបរមធាតុ ដល់ព្រះរាជាទាំងឡាយនោះ ដោយសន្តិវិធី ។ ព្រះរាជាទាំងឡាយនោះ ក៏នាំយកព្រះបរមធាតុ ទៅនគររៀងរាល់ព្រះអង្គ ។ ឯព្រះបាទអជាតសត្រូវ ព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង បានរៀបចាត់ចែងធ្វើពិធីដង្ហែយ៉ាងឱឡារិកសន្និកមហិមា ចាប់តាំងតែពីចេញដំណើរពីក្រុងកុសិនារា ទៅដរាបដល់ក្រុងរាជគ្រឹះ គឺដម្កល់ព្រះបរមធាតុលើព្រះរាជរថជ័យ ដែលវិចិត្រដោយរតន ៧ ប្រការ, កាលបើចេញហែរបានចម្ងាយប្រវែង ១ រាជរថហើយ ឈប់ធ្វើបុណ្យម្តងចំនួន ៧ យប់ ៧ ថ្ងៃ ចេះតែធ្វើតាមលំដាប់

ដូច្នេះដរាបដល់ក្រុងរាជគ្រឹះ ។ រួបរួមរយៈវេលាដែលហែចេញពីក្រុងកុសិនារាទៅដល់ក្រុងរាជគ្រឹះអស់ ៧ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបដល់ ។ ពួកពុទ្ធបរិស័ទទាំងអស់ ក្នុងក្រុងរាជគ្រឹះមានសេចក្តីជ្រះថ្លា សប្បាយរីករាយយ៉ាងក្រៃលែង ។ ឯពួកជនមិច្ឆាទិដ្ឋិជាង ៨ ម៉ឺននាក់ មិនជ្រះថ្លាបែរជានិយាយត្អូញត្អែរថាធ្វើបុណ្យយូរយ៉ាងនេះ គ្មានអ្នកណារកស៊ីធ្វើអ្វីកើតទេម្ល៉ោងទៀត គ្មានប្រយោជន៍អ្វីអំពីឆ្អឹងដែលគេដុតជាធ្យូងនោះទេ ។ ពួកជនទាំងនោះ ចងសេចក្តីក្រោធចំពោះព្រះធាតុ និងព្រះមហាក្សត្រជាដើមរាល់ពេលវេលា ។ បណ្តាមនុស្សមិច្ឆាទិដ្ឋិជាង ៨ ម៉ឺននោះ មានគហបតីម្នាក់មានទ្រព្យច្រើន ជាអ្នកមិច្ឆាទិដ្ឋិចំណាប់មួយដែរ ឯភរិយា បុត្រីកូនប្រសារគាត់ ជាសម្មាទិដ្ឋិ មានចិត្តជ្រះថ្លា ទៅហែព្រះសារីរិកធាតុ ធ្វើបុណ្យជាមួយគេឯងរាល់ពេលវេលា ទោះបីគហបតីស្តីបន្ទោសយ៉ាងណា ក៏មិនធ្វើជាដឹងឮ ។ លុះធ្វើមរណកាល តាមលំដាប់សង្ខាររបស់ខ្លួនទៅ, គហបតីកើតជាប្រេតជាមួយពួកជនមិច្ឆាទិដ្ឋិជាង ៨ ម៉ឺននាក់នោះនៅចន្លោះភ្នំគិជ្ឈកូដ ។ ឯភរិយាបុត្រី បុត្រប្រសារទៅកើតជាទេវតានៅស្ថានសួគ៌ ។

ថ្ងៃមួយព្រះមហាកស្សបត្ថេរ ចេញពីនិរោធ ហើយពិចារណាឃើញមនុស្សស្លាប់ទៅកើតជាប្រេត នរកច្រើន ទើបលោកនិមន្តទៅឈរត្រង់ទីលាន មុខព្រះចេតិយដែលបញ្ចុះព្រះបរមធាតុ ហើយថ្លែងឫទ្ធិធ្វើឱ្យនរក ប្រេត មនុស្ស ទេវតាមើលគ្នាឃើញទៅវិញទៅមក ។

ឯគហបតីប្រេតនោះ ក្រឡេកមើលទៅឰដ៍អាកាស ឃើញភរិយា បុត្រី បុត្រប្រសារខ្លួនកើតជាទេវតាសោយទិព្វសម្បត្តិដូច្នោះ នឹកក្តៅក្រហាយនឹងវាសនារបស់ខ្លួន ក៏ចូលទៅជិតព្រះមហាកស្សបហើយប្រកាសថា ឱ្យតែបានរួចពីប្រេតវិស័យទៅកើតជាមនុស្សវិញ នឹងខំគោរព បូជាព្រះសារីរិកធាតុគ្រប់ពេលវេលា ។ មួយស្របក់ក្រោយមក ព្រះមហាកស្សបរំសាយឫទ្ធិលែងឱ្យឃើញ នៅដូចធម្មតាវិញ ។ ពួកពុទ្ធបរិស័ទទាំងឡាយ ឃើញហេតុអស្ចារ្យដូច្នោះ ក៏ចូលទៅថ្វាយបង្គំសួរបុព្វកម្មរបស់នរក ប្រេត ដែលខ្លួនបានឃើញផ្សេង ១ គ្នា ។ ព្រះមហាថេរ ក៏ប្រារព្ធយករឿងប្រេតជាង ៨ ម៉ឺននាក់ មានគហបតីប្រេតមកសម្តែង តាមដំណើរបុព្វកម្មរបស់ប្រេតទាំងនោះ ក្នុងកាលនោះឯង ។ ឯពួកប្រេតជាង ៨ ម៉ឺននាក់ មានគហបតីប្រេតជាប្រធាន នៅវង

ទុក្ខវេទនាផងរាបដល់សព្វថ្ងៃ, ព្រោះតែការមើលងាយព្រះសារីរិកធាតុនោះឯង ។

ឲ្យបាល

## ២- រឿងមណិកណ្ឋនាគរាជ

(ចាក ម. តិ.)

(ការសូមគេហួសប្រមាណ ទុកជាអំពើរបជាប់ខ្លួន)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅអគ្គាឡវចេតិយ ទ្រង់ប្រជុំភិក្ខុទាំងឡាយប្រារព្ធបញ្ញត្តិ នូវកុដិការសិក្ខាបទ ដោយហេតុភិក្ខុអ្នកនៅក្នុងដែនអាឡវី ដើរអង្គាសឃោសនាចតុប្បច្ច័យ បង្ខំដាក់កំរិតអ្នកនគរយកទៅធ្វើកុដិនៅ ។ មនុស្សទាំងឡាយ ធុញទ្រាន់ ភ័យតក់ស្លុតនឹងការឃោសនាបង្ខំ មានសេចក្ដីទើសទាល់ ក៏គេចខ្លួនចេញមិនឱ្យជួបនឹងពួកភិក្ខុទាំងនោះ ។ ថ្ងៃមួយ ព្រះមហាកស្សបត្ថេរ លោកនិមន្តទៅបិណ្ឌបាតក្នុងទីក្រុងអាឡវីនោះ ពួកមហាជនឃើញពណ៌លឿង ៗ ក៏នាំគ្នារត់អស់គ្មានអ្នកណាដាក់បាតដូចមុនឡើយ ទើបលោកសួរភិក្ខុទាំងឡាយថា ហេតុអ្វីក៏សាបសូន្យបែបនេះ ភិក្ខុទាំងនោះទូលលោកថា ពួកអាឡវិ-ភិក្ខុដើរសុំបង្ខំយកលុយកាក់ទៅធ្វើកុដិនៅ របស់ខ្លួនហួសកំលាំងសទ្ធា ទើបអ្នកនគរភិតភ័យចេះតែរត់ពួន ។ ព្រះមហាកស្សបត្ថេរ នាំរឿងនោះទៅក្រាបបង្គំទូលព្រះសម្ពុទ្ធព្រះអង្គទ្រង់ប្រជុំសង្ឃ ហើយស្តីបន្ទោសដល់ភិក្ខុអ្នកធ្វើកុដិ

ទាំងនោះ ជាអនេកកបរិយាយ ហើយបញ្ញត្តសិក្ខាបទ ទើប
ប្រារព្ធសំដែងនូវអតីតនិទានថា ការសុំគេហួសហេតុរឿយៗ
ដូច្នេះកុំថាតែមនុស្ស ទោះជាសត្វតិរច្ឆាន ក៏ធុញទ្រាន់មិនឱ្យ
ជួបមុខដែរ. ដូចកាលដែលកន្លងទៅហើយ. កាលនោះព្រះ
បាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី. ព្រះពោធិ-
សត្វកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល មានសម្បត្តិច្រើន
មានប្អូនប្រុសមួយ. លុះឥតអំពីមាតាបិតាអនិច្ចកម្មទៅ នាំ
បងប្អូនទៅបួសជាតាបស នៅក្បែរស្ទឹងគង្គា. បងធ្វើ
អាស្រមនៅខាងលើស្ទឹង ប្អូននៅខាងក្រោម ។

សម័យនោះ មាននាគរាជមួយឈ្មោះ មណិកណ្ឋៈ
មកអំពីភពនាគ ក្លែងភេទជាមាណព ដើរតាមឆ្នេរស្ទឹងមក
បានជួបនឹងតាបសជាប្អូនព្រះពោធិសត្វនោះ ក៏មានសេចក្តី
ស្រឡាញ់រាប់អានគ្នាក្រៃពេក ដល់ពេល លាតាបសទៅ
ពិភពនាគវិញ ក៏ក្លាយខ្លួនជានាគឱបរឹតតាបស ដោយសេច
ក្តីស្រឡាញ់រាប់អានទើបចេញទៅ. ចេះតែមកលេងនឹង
តាបសយ៉ាងនេះជារាល់ថ្ងៃ. តាបសមានសេចក្តីភិតភ័យ
ឡើងស្គាំងស្គមអស់ទាំងខ្លួន ក៏ទៅប្រាប់តាបស គឺព្រះបរម
ពោធិសត្វជាបងថា មាននាគរាជមួយ ចេះតែមកលេងជា

ញីកញាប់ ខ្ញុំមានសេចក្ដីភ័យខ្លាច មិនចង់ឱ្យមកសោះ ប៉ុន្តែពុំដឹងធ្វើដូចម្ដេចកើត ។ ព្រះពោធិសត្វសួរថា នាគរាជនោះកាលដែលមក មានពាក់អ្វីមកផង. តាបសប្អូនថា មានពាក់កែវមណីមកផង ។ ព្រះពោធិសត្វប្រាប់ឧបាយថា បើដូច្នោះប្អូនឯង ត្រូវសុំកែវមណីនោះអំពីនាគរាជ ៗ មិនឱ្យក៏ចេះតែសុំ បើអ្នកបានធ្វើដូច្នេះ នាគរាជនឹងលែងមកកាន់សំណាក់អ្នកទៀតហើយ ។

តាបសប្អូនត្រឡប់ទៅអាស្រមវិញ. ដល់នាគរាជមកក៏សុំកែវមណីភ្លាម. នាគរាជទើសទាល់មិនដឹងធ្វើដូចម្ដេច ក៏ត្រឡប់ទៅវិញ. បន្តិចវិលមកទៀតដោយសេចក្ដីរឭកតាបស ឯតាបសចេះតែសុំ ដល់គំរប់បីដង នាគរាជស្ថិតនៅលើខ្នងទឹកនិយាយប្រាប់តាបសថា ខ្ញុំសព្វថ្ងៃរស់នៅបានដោយអំណាចកែវមណីនេះឯង ខ្ញុំឱ្យអ្នកដូចម្ដេចកើត ពីត្រឹមថ្ងៃនេះទៅខ្ញុំលែងមកឱ្យជួបនឹងអ្នកហើយ ព្រោះការដែលអ្នកសុំកែវមណីខ្ញុំនោះ ដូចជាបុរសមានកំលាំងកាន់ដាវយ៉ាងមុត គម្រាមកាប់កាត់ខ្ញុំឱ្យដាច់ជាកំណាត់តូចធំដូច្នោះឯង. ប្រាប់តាបសដូច្នេះហើយ ក៏បាត់អំពីទីនោះទៅ លែងមកជួបនឹងតាបសទៀត ។

តាបសទាំងពីរក៏ខំចំរើនឈាន ដល់ទីបំផុតអាយុសង្ខារបានទៅកើតព្រហ្មលោកទាំងពីរនាក់ ។

ឲ្យចប់

## ៣- រឿងស្វារធេនធត្ត

(ចាក ត. ឯ.)

(ព្យាបាទចំពោះអ្នកមិនព្យាបាទតប ដូចបាចធូលីច្រាសខ្យល់)

ក្នុងអវសរ ដែលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី, កាលនោះភិក្ខុទេវទត្តកើតជាស្វាគ្រោសនៅក្នុងព្រៃហេមពាន្ត ជាប្រធាននៃស្វាទាំងឡាយក្នុងទីនោះ, កាលបើមានកូនឈ្មោលរបស់ខ្លួនកើតឡើង តែងសម្លាប់ចោល ខ្វាចក្រែងកូននោះដណ្តើមធ្វើជាមេហ្វូង ។ កាលនោះ ព្រះពោធិសត្វ ចាប់បដិសន្ធិក្នុងផ្ទៃស្វាញីជាភរិយាស្វាទេវទត្តនោះ ។

ស្វាញីដឹងថាខ្លួនមានគភ៌ហើយ ក៏រត់ពាត់ទៅពួននៅកន្លែងដទៃ ដល់សម្រាលកូនឈ្មោលមក ខំលាក់មិនឱ្យចេញទៅទីឆ្ងាយ ។ កូនស្វានោះ មានកំលាំងដូចដំរីសារ ក្លាហានអង់អាចដូចរាជសីហ៍ ព្រោះជាតិព្រះពោធិសត្វ ដល់ធំឡើងសួរមាតាថា អ្នកណាជាបិតាខ្ញុំ សូមនាំខ្ញុំទៅជួប, មាតាប្រាប់ថា បិតាចាឯងជាមេហ្វូងនៅក្នុងព្រៃភ្នំឯនោះ កូនឯងទៅជួបមិនបានទេ ព្រោះបិតានោះចិត្តអាក្រក់ណាស់ តែឃើញកូនឈ្មោល ចាប់ប្របាច់សម្លាប់ចោលហើយ ។ ព្រះពោធិសត្វថា មិនស្លាប់ទេ សូមមាតានាំខ្ញុំទៅចុះ, មាតា

ឃាត់មិនបានក៏នាំទៅ ។ បិតាឃើញហើយ កើតព្យាបាទក្នុងចិត្ត ក៏ធ្វើជាស្រឡាញ់ ហៅព្រះពោធិសត្វឱ្យចូលទៅជិត ចាប់ឱបរឹតពេញទំហឹង ព្រះពោធិសត្វប្រឹងចំគោងប្រាន បិតាទ្រាំមិនបាន ចាញ់កំលាំងព្រះពោធិសត្វក៏លែងទៅ, កើតក្តៅក្រហាយគិតថា កូននេះពូកែតែធំពេញរូបឡើង វាសម្លាប់អញដណ្តើមយកឋានៈជាមេហ្វូងហើយ បើដូច្នោះអញប្រើវាទៅឱ្យអារ័ក្សទឹកចាប់ស៊ី, ទើបហៅព្រះពោធិសត្វមកប្រាប់ដោយឧបាយថា នែកូនសម្លាញ់ ! ឥឡូវឪពុកចាស់ហើយនឹងប្រគល់ឋានៈ មេហ្វូងឱ្យឯង គឺតាំងឯងជាស្តេចឱ្យត្រួតត្រាហ្វូងស្វាទាំងអស់ជំនួសបិតា ឯងត្រូវទៅកាច់ផ្កាក្នុងស្រះឯណោះមកឱ្យបិតា ៗ នឹងអភិសេកឱ្យ ។ ព្រះពោធិសត្វទទួលដោយរីករាយ ហើយម្ទីម្ទាទៅកាន់ស្រះនោះ, ទៅដល់ដើរវៀលពិចារណាមើល មិនឃើញមានស្នាមជើងឡើងវិញសោះ ឃើញតែចុះទៅ, ទើបព្រះពោធិសត្វយល់ច្បាស់ថា ក្នុងស្រះនេះមានអារ័ក្សទឹកហើយ អញមិនត្រូវចុះទេ ក៏ដើរបេះជុំវិញស្រះ មិនឱ្យជ្រុលខ្លួនទៅក្នុងអាណាខេត្តរបស់អារ័ក្សទឹក បេះបានផ្កាជាច្រើនដាក់គរក្បែរមាត់ស្រះ។

អារ័ក្សទឹកឃើញហើយ នឹកអស្ចារ្យក្នុងចិត្តថា ស្វា

នេះចំជាបណ្ឌិតអ្នកប្រាជ្ញ បេះយកផ្កាអញបានហើយ មិនឱ្យអញចាប់ស៊ីកើតទៀត ទើបបង្ហាញខ្លួនឱ្យព្រះពោធិសត្វឃើញ ហើយសូត្រពាក្យស្លោកថា :

**យស្សេតេ ច តយោ ធម្មា ទានរិន្ទ យថា តវ**
**ឧក្ខិយំ សូរិយំ បញ្ញា[១] ទិដ្ឋំ សោ អតិវត្តតិ ។**

ប្រែថា បពិត្រស្តេចស្វា ធម៌ទាំងឡាយ ៣ យ៉ាងនេះ គឺ ទក្ខិយ ១, សុរិយ ១, បញ្ញា ១, មានដល់បុគ្គលណាដែលដូចលោក បុគ្គលនោះតែងបង្ក្រាបនូវខ្មាំងបាន ។

សូត្រដូច្នេះហើយ សួរព្រះពោធិសត្វថា អ្នកយកផ្កាទៅធ្វើអ្វី ? ព្រះពោធិសត្វថា បិតាខ្ញុំឱ្យយកទៅដើម្បីអភិ-សេកខ្ញុំជាស្តេច ។ អារក្សទឹកគិតថា អ្នកមានសេចក្តីអង់អាចយ៉ាងនេះ គួរតែអញយកផ្កាទៅឱ្យ ក៏កាន់ផ្កាដើរតាមក្រោយព្រះពោធិសត្វទៅ ។ បិតាឃើញកូនទៅវិញ មានអារក្សទឹកជាអ្នកកាន់ផ្កាឱ្យដូច្នោះ ក៏កើតក្តៅក្រហាយអន្ទះអន្ទែងបែកទ្រូងស្លាប់ទៅ ។ ពួកស្វាទាំងឡាយ ក៏នាំគ្នាអភិសេកព្រះពោធិសត្វជាស្តេចរបស់ខ្លួនតទៅ ។ ប្រជុំជាតក ស្វាជាបិតាគឺភិក្ខុទេវទត្ត, កូនស្វាព្រះតថាគត ។

---

១- ទក្ខិយ ប្រែថា សេចក្តីប្រសប់ វាងវៃ. ២- សូរិយ ប្រែថា សេចក្តីក្លាហានអង់អាច . ៣- បញ្ញា ប្រែថា សេចក្តីប្រាជ្ញ មិនតាំងគំនិត ។

# ៤- រឿងនាងវិមានប្រេត

(ចាក បេ. ខុ.)

(ទោសលួចទ្រព្យគេ និងទោសលក់សុរា)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានស្ត្រីក្រមុំម្នាក់ឈ្មោះ កល្យាណី មានរូបល្អជាទីស្រឡាញ់ពេញចិត្តចំពោះមហាជន ដែលបានឃើញរូបនាង ។ ថ្ងៃមួយមានបុរសម្នាក់ ចាប់ចិត្តស្រឡាញ់ បានចូលទៅនិយាយជាច្រើនផង នាងមិនព្រមយក ក៏កើតទោសៈ ព្យាបាទនាង យកថ្នាំជម្រុះសក់ទៅផ្លូលនាងទាសី ឱ្យដាក់ក្នុងប្រអប់រមៀត ដល់នាងទៅមុជទឹកនាកំពង់ក្បែរផ្ទះ យករមៀតនោះកក់ក្បាល សក់ក៏ជ្រុះអស់គ្មានសល់មួយសរៃ នៅតែរលោដក្បាលទទេ នាងកើតសេចក្តីអៀនខ្មាស ក៏យកក្រមាទទូក្បាលរត់ភៀសខ្លួន ទៅនៅស្រុកចុងកាត់មាត់ញក ឆ្ងាយពីស្រុកកំណើត ។ រឿងដទៃស្លេះតែប៉ុណ្ណេះ នឹងនិយាយតែអំពីនាងកល្យាណី, ដល់នាងនៅស្រុកចុងកាត់មាត់ញក យូរទៅសក់ក៏ឥតមានដុះឡើងវិញ ប្តីក៏នាងមិនយក ទៅជាអ្នកទំលក្រទើបប្រកបរបរបិទស្រាលក់, ពួកប្រមឹកទាំងឡាយ តែងចោមរោមរាននាងជានិច្ចរាល់ថ្ងៃ ។ កាលនោះ មានប្រមឹក

ពីរនាក់ដេកលក់ នាងលួចសំរាតយកសំពត់អាវអស់ នៅអាក្រាតកាយទទេ, ពួកប្រមឹកដឹងខ្លួនឡើង មានសេចក្តីអៀនខ្មាស ក៏នាំគ្នារត់ទៅផ្ទះអស់ទៅ ។ ថ្ងៃក្រោយមកនាងកល្យាណី បានឃើញព្រះខីណាស្រព ១ អង្គនិមន្តទៅបិណ្ឌបាត មានសេចក្តីជ្រះថ្លា ក៏និមន្តចូលគង់លើអាសនៈក្នុងផ្ទះរបស់ខ្លួន ហើយចាត់ចែងប្រគេនប្រអូលលាយដោយប្រេងល្ង, កាលបើព្រះខីណាស្រពឆាន់ហើយ នាងតាំងសេចក្តីប្រាថ្នាថា សូមឱ្យមានរូបល្អ មានសក់ល្អសសៃល្អិតដូចរោមទ្រាយ, ព្រះខីណាស្រព ធ្វើអនុមោទនាហើយនិមន្តទៅទីដទៃទៀត ។ ដល់នាងអស់អាយុ បានកើតជាប្រេតញី មានរូបល្អ សក់ដុះល្អដូចប្រាថ្នា ស្ថិតនៅក្នុងវិមានមាសតែម្នាក់ឯង កណ្តាលមហាសមុទ្រ ប៉ុន្តែគ្មានសំពត់អាវស្លៀកពាក់ អាក្រាតកាយទទេ យកសក់ក្បាលគ្របខ្លួន មានសេចក្តីអៀនខ្មាសយ៉ាងខ្លាំងតែម្នាក់ឯង មិនដែលចេញទៅណា នៅតែក្នុងវិមានស្នាក់ជ្រងំ កណ្តាលមហាសមុទ្រនោះឯង ។

សម័យនោះមានឈ្មួញសំពៅ ៧០០ នាក់ឆ្លងកាត់មហាសមុទ្រ ទៅប្រកបការងារឯត្រើយម្ខាង ត្រូវខ្យល់ព្យុះបក់បោករសាត់ចុះឡើងនៅកណ្តាលមហាសមុទ្រនោះ ក៏

ទៅជួបនឹងវិមានរបស់នាងប្រេតនោះ ។

អ្នកសំពៅទាំងឡាយ ឃើញរូបនាងស្អាតល្អស្រស់នៅតែម្នាក់ឯង ក៏សំគាល់ថាទេពធីតា បានអញ្ជើញនាងឱ្យចេញមកក្រៅ ដើម្បីចរចាគ្នាឱ្យដឹងដំណើររឿង. នាងមិនព្រមចេញមកសោះ ដោយសេចក្ដីអៀនខ្មាសគ្របសង្កត់ខ្លាំង ពួកអ្នកសំពៅចេះតែទទូចសួរថា នាងមានរូបល្អយ៉ាងនេះ ពួកយើងមិនដែលឃើញសោះ តើនាងជាទេពធីតាឬ ? សួរញយៗ ពេក នាងក៏ប្រាប់ថា ខ្ញុំនេះជាប្រេតទេ ឈ្មោះវិមានប្រេត តាំងពីកើតមក ខ្ញុំមិនដែលបានសំពត់ស្លៀកសោះ ព្រោះផលអាក្រក់ដែលខ្ញុំលួចសំពត់អ្នកប្រមឹកពីជាតិមុន. ដែលខ្ញុំមានរូបល្អ មានចំណីអាហារទិព្វ វិមានមាសប្រតិស្ឋាននៅកណ្ដាលមហាសមុទ្រនេះ កើតឡើងដោយផលបុណ្យ ដែលខ្ញុំបានប្រគេនប្រអូលដល់ព្រះខីណាស្រព ។ ពួកអ្នកសំពៅសួរទៀតថា នាងមកកើតនៅទីនេះ ប៉ុន្មានឆ្នាំហើយ. នាងប្រាប់ថា រាប់ឆ្នាំមិនបានទេ ចំនួន ១ កប្បមកហើយ ។ នាយសំពៅមានសេចក្ដីអាណិតដល់នាងប្រេតនោះពន់ពេក បានយកសំពត់ ១ គូហុចឱ្យទៅស្លៀក. នាងលើកដៃសំពះអង្វរថា ខ្ញុំទទួលយកមកស្លៀកពុំបានទេ ព្រោះ

ខ្ញុំជាប្រេត បើលោកមេត្តាឱ្យទានខ្ញុំ សូមឱ្យទៅព្រះសង្ឃ ឬ អ្នកមានសីលបរិសុទ្ធ ហើយឧទ្ទិសផលឱ្យខ្ញុំ ទើបខ្ញុំទទួលបាន ។ គួរអស្ចារ្យណាស់ ក្នុងសំពៅគ្មានព្រះសង្ឃមួយអង្គសោះ មានតែឧបាសកម្នាក់ មានសីលបរិសុទ្ធ. នាយសំពៅក៏ជូនសំពត់ទៅឧបាសកនោះ ហើយឧទ្ទិសផលចំពោះដល់ប្រេតនោះ ស្រាប់តែប្រេតបានសំពត់ទិព្វស្លៀកដណ្តប់ភ្លាម (នេះរឿងចំឡែក តាមដឹងរឿងមកថា ទាល់តែឱ្យដល់សង្ឃ ទើបឧទ្ទិសផលដល់ប្រេតបាន. សូមអ្នកអានទាំងឡាយពិចារណាមើល តើសមហេតុផលដែរឬទេ ?) ។ នាងវិមានប្រេតកាលបើបានសំពត់ស្លៀកពាក់ហើយ ក៏និម្មិតយកអាហារទិព្វជប់លៀងអ្នកសំពៅនោះ ឱ្យឆ្អែតស្កប់ស្កល់គ្រប់គ្នា ទើបយំសោកប្រាប់ដល់អ្នកសំពៅថា អស់លោកអើយ ! ខ្ញុំជាស្ត្រីកម្មក្រាស់ណាស់នៅតែ ៤ ខែទៀតទេ ខ្ញុំត្រូវអស់អាយុធ្លាក់ទៅកើតក្នុងនរកហើយ ព្រោះទោសដែលខ្ញុំបិទស្រាលក់ពីជាតិមុន ។ នាយសំពៅ និងឧបាសក មានសេចក្តីមេត្តាករុណាប្រាប់ថា បើនាងចង់បានសុខ នាងត្រូវយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឮកស្មើដោយជីវិត. នាងលើកដៃសំពះទទួលថា សាធុ ៗ ក៏នឹកភាវនាគុណព្រះរតនត្រ័យ

ក្នុងចិត្តជាប់ជានិច្ច ។ ដល់ពេលស្ងប់ខ្យល់ នាយសំពៅលា នាងប្រេតត្រឡប់មកនគរវិញ. នាងបានផ្ញើសម្បត្តិទិព្វ មានមាសប្រាក់ជាដើម មកបូជាព្រះសម្ពុទ្ធបរមគ្រូ កាលនោះព្រះអង្គគង់នៅវត្តជេតពន ។ នាយសំពៅ និងឧបាសកទទួលបញ្ញើ ក៏ចេញសំពៅមក លុះសំពៅមកដល់នគរហើយក៏យកគ្រឿងសក្ការដែលនាងប្រេតផ្ញើ ទៅបូជាព្រះមានព្រះភាគ ៗ ទ្រង់ទទួលហើយ ប្រជុំពុទ្ធបរិស័ទ សំដែងធម្មទេសនាប្រារព្ធយករឿងនោះជាហេតុ. ទីបំផុតព្រះអង្គទ្រង់ត្រាស់ថា នាងវិមានប្រេតនោះនៅ ៤ ខែទៀតអស់អាយុហើយ ត្រូវទៅកើតក្នុងនរក ដោយអំណាចបិទស្រាលក់ប៉ុន្តែដោយអំណាចសទ្ធា ដែលនាងជឿចំពោះគុណព្រះរតនត្រ័យ ហើយបានបូជាចំពោះតថាគត ដល់គំរប់ ៤ ខែនាងអស់អាយុទៅ បានទៅកើតជាទេពធីតា នៅស្ថានត្រៃត្រឹង្សសួគ៌ សោយសម្បត្តិទិព្វយ៉ាងធំ ។

ឯនាងវិមានប្រេតកាលបើដល់កំណត់គ្រប់ ៤ ខែហើយ ក៏អស់អាយុលាកំណើតពីប្រេត ទៅកើតជាទេពធីតានៅស្ថានត្រៃត្រឹង្សសួគ៌ សោយទិព្វសម្បត្តិជាក្សេមក្សាន្តហោង ។

## ៥- រឿងនិស្សិតឈ្មោះគំរក់

(ចាក នា. ឯ.)

(អាក្រក់ចុះឱ្យតែល្អ ក្រចុះឱ្យតែមាន)

កាលកន្លងទៅយូរហើយ ព្រះពោធិសត្វ ទ្រង់សោយព្រះជាតិជាអាចារ្យទិសាបាមោក្ខ មាននាមល្បីល្បាញក្នុងក្រុងតក្កសិលា តែងបង្រៀនកូនសិស្ស ៥០០ នាក់ជានិច្ចរាល់ថ្ងៃ ។ កាលនោះ មាននិស្សិតម្នាក់ឈ្មោះ គំរក់ ជាឈ្មោះកំណើត ដែលមាតាបិតាដាក់ឱ្យ(បាលីថា បាបកៈ) នៅរៀនក្នុងសំណាក់ព្រះពោធិសត្វនោះ ។ រាល់តែថ្ងៃនិស្សិតទាំងឡាយជាគ្នូកន នាំគ្នាហៅលេងសើចថា អាគំរក់ៗ ដូច្នេះ ទាំងព្រះពោធិសត្វ ក៏លោកហៅថាគំរក់ដូច្នោះដែរ ព្រោះជាឈ្មោះស្រេចទៅហើយ ។

និស្សិតគំរក់នោះ នឹកអន់ចិត្តនឹងឈ្មោះខ្លួនមិនល្អ ក៏ចូលទៅសុំព្រះពោធិសត្វជាអាចារ្យផ្លាស់ឈ្មោះឱ្យ ។ ព្រះពោធិសត្វថា បើដូច្នោះ ឯងចូរដើរទៅក្នុងនិគមជនបទរាជធានីស្វែងរកឈ្មោះដែលល្អ ប្រកបដោយសិរីសួស្តីជ័យមង្គលរបស់បុគ្គលណាមួយ ដែលជាទីពេញចិត្តរបស់ឯងឱ្យបានមក ចាំអញផ្លាស់ឈ្មោះឱ្យ ។

និស្សិតតំរក់ធ្វើតាមពាក្យអាចារ្យ រៀបចំដំណើរថ្វាយបង្គំ លាត្រេចចរទៅក្នុងនិគមជនបទ រាជធានីផ្សេងៗ ដើម្បីស្វែងរកឈ្មោះឱ្យបានល្អ. ក៏បានទៅដល់នគរមួយ ជួបនឹងអ្នកនគរកំពុងហែសពទៅព្រៃស្មសាន. ទើបនិស្សិតតំរក់សួរគេថា :

សូមទោស ! អ្នកស្លាប់នេះឈ្មោះអ្វី ? គេប្រាប់ថាឈ្មោះរស់ (បាលីថា ជីវកៈ) ។ និស្សិតតំរក់លាន់មាត់ថាអើ! បើឈ្មោះរស់ ហើយម្តេចក៏ស្លាប់ ? គេថានែ ! នាង ធម្មតារបស់មនុស្សសត្វ បើទុកជាឈ្មោះរស់ ក៏ដោយឈ្មោះ កើតក៏ដោយ ឈ្មោះជាក៏ដោយ មិនអាចជៀសវាងរួចអំពី ចាស់ឈឺ ស្លាប់នោះទេ ។ និស្សិតតំរក់ស្តាប់ពាក្យគេហើយ អស់សង្ស័យរវើយតំនិត ក៏ដើរឈៀងចូលទៅក្នុងភូមិមួយ ឃើញនាយចៅហ្វាយម្នាក់កំពុងវាយសំពងទាសី ដែលខ្ជះខ្ជាយ ធ្វើឱ្យបាត់ទ្រព្យរបស់គេ ។ និស្សិតតំរក់ឃើញហើយ សួរថានាងនេះមានទោសដូចម្តេច បានជាលោកវាយដល់ម្លឹង ? គេប្រាប់ថា បានជាវាយព្រោះវាខ្ជះខ្ជាយ មិនចេះរក្សាថែទាំទ្រព្យសម្បត្តិ ។ និស្សិតតំរក់សួរទៀតថា ចុះនាងនេះឈ្មោះអ្វី ? គេប្រាប់ថាឈ្មោះនាងរក្សាទ្រព្យ (បាលីថាធនបាលី) ។

ចុះបើឈ្មោះល្អម៉្លឹង ៗ ក៏មិនចេះថែរក្សាទ្រព្យ ? ។ គេប្រាប់ថា នាងឯងកុំសង្ស័យឈ្មោះនោះ គេគ្រាន់តែកំណត់ឱ្យងាយស្គាល់ ងាយចំណាំគ្នាទៅវិញទៅមកប៉ុណ្ណោះទេ មិនមែនឈ្មោះឱ្យសុខទុក្ខបានឡើយ ។ និស្សិតគំរក់ឮហើយ រឹតតែស្ងើយគំនិតក្នុងការស្វែងរកឈ្មោះល្អ ក៏ត្រឡប់ទៅផ្ទះវិញ ដល់ពាក់កណ្ដាលផ្លូវ ឃើញបុរសម្នាក់ដើរវិលចុះវិលឡើង ក៏សួរថា អ្នកដើរវិលវល់មានការអ្វី ? គេប្រាប់ថា ខ្ញុំវង្វេងផ្លូវ ។ និស្សិតគំរក់ ក៏សួរចង់ដឹងឈ្មោះអ្នកនោះទៀត, គេប្រាប់ថា ខ្ញុំឈ្មោះអ្នកស្គាល់ផ្លូវ (បាលីថា បន្ថក:) ចុះឈ្មោះចំណាប់ម៉្លឹង ម្ដេចក៏រកផ្លូវមិនឃើញ ។ គេឆ្លើយតបវិញថា សំខាន់អ្វីត្រង់ឈ្មោះនោះ ស្រេចតែនឹងខ្ញុំវង្វេង អ្នកឯងក៏ឆោតម្ល៉េះ ។

និស្សិតគំរក់ ត្រូវគេស្ដីឱ្យថាឆោត ក៏លែងស្វែងរកឈ្មោះទៀត ត្រឡប់ទៅកាន់សំណាក់លោកអាចារ្យវិញ ។

ព្រះពោធិសត្វជាអាចារ្យសួរថា ម៉េចឯងទៅរកឈ្មោះល្អបានហើយឬនៅ ? និស្សិតគំរក់ថាឥតអំពើទេ ដើរទៅឱ្យតែខាតរៀន, អាឈ្មោះរស់ បែរជាងាប់, មីឈ្មោះរក្សាទ្រព្យ ទៅជាធ្វើឱ្យបាត់ទ្រព្យគេ ត្រូវដំបង, អាឈ្មោះ

ស្គាល់ផ្លូវ ទៅជាវង្វេងរកតែផ្លូវទៅផ្ទះមិនឃើញ ។ ខ្ញុំបាន ឈប់ផ្លាស់ឈ្មោះហើយ ម៉ែឪខ្ញុំឱ្យមកយ៉ាងណានៅយ៉ាង នោះចុះ ។

ព្រះពោធិសត្វឮដូច្នោះហើយ ក៏សូត្រពាក្យស្លោកថា

**ជីវកញ្ច មតំ ទិស្វា ធនបាលិញ្ច ទុគ្គតំ**
**បន្ថកញ្ច វនេ មុឡ្ហំ បាបកោ បុន រា គតោ ។**

សេចក្តីថា និស្សិតឈ្មោះគំរក់ បានឃើញអារស់វា ស្លាប់, មីរក្សាទ្រព្យវាខ្ចះខ្ចាយ, អាស្គាល់ផ្លូវ វាវង្វេងក្នុងព្រៃ ក៏ត្រឡប់មកវិញបានឈ្មោះថាគំរក់ ១ ដដែល ។

តាំងពីពេលនោះដរាបទៅ និស្សិតគំរក់លែងគិតគួ ត្រង់ឈ្មោះ គិតតែខំរៀនសូត្រ ដរាបដល់បានសំរេចវិជ្ជា តាមបំណងរបស់ខ្លួនហោង ។

## ៦- រឿងស្តេចលិច្ឆវី និងកូមនេទគា

(ចាក បេ. ខុ.)

(អានិសង្សធ្វើផ្លូវថ្នល់ ដោយសេចក្តីជ្រះថ្លា)

សម័យពុទ្ធកាល មានស្តេចលិច្ឆវីមួយព្រះអង្គ ព្រះនាម អម្ពសក្ខរ នៅនគរវេសាលី ជាស្តេចមិច្ឆាទិដ្ឋិ យល់ថាលោកខាងមុខមិនមាន មនុស្សសត្វទាំងអស់តែស្លាប់ទៅសូន្យគ្មានកើតទៀត ។ ព្រះរាជាអង្គនេះ តែងបៀតបៀនពួកពុទ្ធបរិស័ទ មានភិក្ខុសាមណេរជាដើម រាល់ពេលវេលាដែលបានជួបប្រទះ ។

ក្នុងក្រុងវេសាលី មានឈ្មួញលក់ដូរនៅច្រើន, កាលនោះមានឈ្មួញលក់រាន ១ រូបជាបណ្ឌិតអ្នកប្រាជ្ញ បរិបូណ៌ដោយសីល និងទាន មានចិត្តសប្បុរសបានឃើញទឹកភក់ដក់នៅកណ្តាលផ្លូវ ជាហេតុឱ្យលំបាកដល់មហាជនទៅមក ក៏យកឆ្អឹងគោទៅដាក់រៀបលើភក់ ហើយយកដីចាក់ ធ្វើផ្លូវនោះឱ្យស្អាតល្អឡើង ។ ពេលថ្ងៃក្តៅទៅងូតទឹកជាមួយសំឡាញ់ម្នាក់ ប្រឡែងគ្នាយកសំពត់សំឡាញ់នោះលាក់លេងជាល្បែងឱ្យសំឡាញ់នោះអាក្រាតនៅខ្លួនទទេ ។ ដល់ត្រឡប់មករានផ្សារវិញ ជួនជាពេលនោះ ក្មួយប្រុសរបស់គាត់ទៅ

លួចទ្រព្យគេមកទុកនៅវាននោះ ។ ពួករាជបុរសចាប់យកទាំងពីរនាក់ទៅថ្វាយស្តេចលិច្ឆវី ព្រះរាជាឱ្យយកឈ្មួញនោះទៅសំឡាប់ចោល ឯក្មួយឱ្យដោតទុកលើឈើអណ្តោតក្បែរកំពែងវាំង ។

ឈ្មួញនោះស្លាប់ ទៅកើតជាភូមទេវតាអាក្រាតកាយទទេ មានសេះសមួយជាយានជំនិះ សេះនោះឈ្មោះមនោ-ជព មានឫទ្ធិពូកែអស្ចារ្យ កើតឡើងដោយអំណាចបុណ្យដែលបានធ្វើផ្លូវភក់ឱ្យស្អាតពីជាតិមុននោះឯង. ដែលអាក្រាតខ្លួនទទេនោះ ដោយទោសដែលយកសំពត់លាក់ ធ្វើឱ្យសំឡាញ់អាក្រាតកាយកាលពីជាតិមុនដែរ ។

មានសេចក្តីប្លែកថា ភូមទេវតានោះ តែងតែជិះសេះទៅប្រាប់ក្មួយដែលជាប់ឈើអណ្តោតថា កាលដែលគេធ្វើទោសនោះ គួរជាទីពេញចិត្តណាស់ ព្រោះជាទោសតូចស្រាល តែដល់ស្លាប់ទៅ ធ្លាក់ទៅនរកទទួលទោសធំជាងនេះឆ្ងាយណាស់ ដូច្នេះចូរអ្នកខំអត់កុំថ្ងូរ ។ ភូមទេវតា ចេះតែជិះសេះមកប្រាប់ក្មួយដូច្នេះរាល់ពេលពុំដែលខាន ។ សង្ខេបសេចក្តីនេះសិន នឹងនិយាយអំពីស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរនោះ ស្តេចចេញទៅទតទីក្រុង បានឃើញស្ត្រីមាន

រូបល្អម្នាក់ ជាប្រពន្ធរបស់កសិកបុរសដែលកំពុងរើសមើលព្រះអង្គ គឺជូនជាព្រះរាជាទតព្រះនេត្រទៅចំ នាងក៏លិបចូលក្បាលទៅក្នុងផ្ទះ ហាក់ដូចព្រះចន្ទចូលទៅក្នុងដុំពពក ។ ព្រះរាជាកើតសេចក្តីស្នេហាចំពោះរូបស្ត្រីនោះ លុះត្រឡប់មកព្រះរាជដំណាក់វិញ ប្រើរាជបុរសឱ្យទៅសួរ តើនាងនៅក្រមុំ ឬមានប្តីហើយ ។ រាជបុរសសួរដឹងថា ជាភរិយារបស់កសិកបុរស ក៏ចូលទៅក្រាបទូលព្រះរាជាតាមដំណើរ ។ ព្រះរាជាកើតព្យាបាទវិតក្ក រិះរកឧបាយនិងសម្លាប់បុរសនោះយកប្រពន្ធ ក៏បានឃើញឧបាយមួយ. ទើបប្រើរាជបំរើឱ្យទៅហៅបុរសនោះមកបង្គាប់ ឱ្យទៅបេះផ្កាឈូក និងយកដីក្រហមពីស្រះបោក្ខរណីចម្ងាយ ៣ យោជន៍ពីក្រុងវេសាលី ហើយឱ្យយកបានមកទាន់ក្នុងពេលថ្ងៃ បើមកមិនទាន់ទេ ដល់យប់ទើបមកដល់ ត្រូវសម្លាប់ចោល ។

បុរសនោះទទួលព្រះរាជបញ្ជាហើយ ម៉ឺម្នារត់សំដៅទៅស្រះបោក្ខរណីនោះ ។ ឯស្តេចលិច្ឆវី លុះបុរសចេញផុតទៅ បានប្រាប់ដល់អ្នកចាំទ្វារថា បើឃើញបុរសនោះ យកផ្កាឈូក និងដីក្រហមមក ត្រូវបិទទ្វារកុំឱ្យចូល ដល់យប់ចាំបើកឱ្យចូល ។

កសិកបុរសខំរត់ទៅដល់ស្រះបោក្ខរណី ឃើញពួកបិសាចអារក្សទឹកនិម្មិតខ្លួនគួរខ្លាចនៅជុំវិញស្រះនោះ ក៏បួងសួងប្រកាសសេចក្ដីទុក្ខរបស់ខ្លួន ពួកបិសាចឮ ហើយមានចិត្តអាណិត ឱ្យបេះផ្កាឈូកយកដីក្រឡប់មកវិញ មកដល់មាត់ទ្វារវាំងថ្ងៃរសៀល ស្រាប់តែឃើញទ្វារបិទ ខំស្រែកហៅក៏គ្មានអ្នកណាបើកឱ្យ ។ កសិកបុរសក្រឡេកមើលទៅខាងត្បូងវាំង ឃើញបុរសកំពុងស្រែកថ្ងូរនៅលើឈើអណ្ដោត ក៏និយាយប្រាប់ឱ្យបុរសនោះធ្វើជាសាក្សីជួយដឹងឮថាខ្លួនយកផ្កាឈូក និងដីក្រហមមកដល់ទាន់ពេលវេលា ។

បុរសជាប់ឈើអណ្ដោតនិយាយប្រាប់ថា ខ្ញុំអ្នកយកធ្វើជាសាក្សីមិនបានទេ ព្រោះខ្ញុំជាអ្នកមានទោស សូមអ្នកយកភូមទេវតាធ្វើជាសាក្សីវិញបន្តិចមកដល់ហើយ ។

ដល់ពេលព្រលប់ភូមទេវតាមកដល់ បុរសនោះដំណាលប្រាប់តាមដំណើររឿង ភូមទេវតាព្រមទទួលធ្វើសាក្សី ហើយជិះសេះត្រឡប់ទៅវិញ ។

ព្រះរាជា កាលបើព្រះអាទិត្យលិចបាត់ហើយ ក៏ឱ្យរាជបុរសធ្វើជារកមើល តើឃើញកសិកបុរសមកពីរកផ្កាហើយឬនៅ ? រាជបុរសចេញទៅក្រៅកំពែងវាំងឃើញ

បុរសនោះ កំពុងអង្គុយកើតទុក្ខ ក៏នាំទៅថ្វាយព្រះរាជា ដោយចោទប្រកាន់ថា មកហួសពេលកំណត់ ត្រូវព្រះរាជាយកទោសដល់ជីវិត ។ ព្រះរាជាគ្រាន់តែទតឃើញបុរសនោះ ក៏ដាក់ទោសឱ្យថា ត្រូវរាជបុរសយកទៅសម្លាប់ ។ កសកបុរសទូលអង្វរតាមសេចក្តីពិតរបស់ខ្លួន ហើយអាងដល់សាក្សីរបស់ខ្លួនថា បើព្រះរាជាពុំជឿទេចាំសួរភូមទេវតា ដែលតែងជិះសេះមកឱ្យឱវាទដល់បុរសជាប់ឈើអណ្តោតនោះចុះ ។ ព្រះរាជាទាល់ប្រាជ្ញ ដោយចង់ឃើញភូមទេវតា ក៏ឱ្យបុរសនោះនាំទៅជួប, ដល់ពេលព្រលប់ភូមិទេវតាជិះសេះមក, ព្រះរាជាទតឃើញហើយ ត្រាស់សួរថា អ្នកជាសាក្សីកសកបុរសនេះឬ ? បុរសនេះបាននាំយកផ្កា និងជីមកដល់មុនថ្ងៃលិចឬ ? ភូមទេវតាទូលថា ជាសាក្សីមែន, បានឃើញបុរសនេះនាំយកជី និងផ្កាមកដល់មុនថ្ងៃលិចមែន ។ កសកបុរសក៏បានរួចខ្លួនទៅ ។

ដំណាលអំពីភូមទេវតា មានប្រាថ្នាយូរហើយ ចង់ទូន្មានស្តេចលិច្ឆវី ឱ្យលះបង់មិច្ឆាទិដ្ឋិចេញ និងដោះក្លួយរបស់ខ្លួនឱ្យបានរួចពីឈើអណ្តោត ។ ជួនជាឱកាសនោះស្តេចលិច្ឆវី ចង់ដឹងបុព្វកម្មរបស់ភូមទេវតា ក៏ត្រាស់សួរថា

អ្នកនៅទីណា ? យើងមិនដែលឃើញ ? ។ ភូមទេវតាក្រាបទូលថា ពីដើមជាអ្នកលក់រានផ្សារ បានរក្សាសីលធ្វើទានសន្សំបុណ្យកុសលផ្សេងៗ ជាច្រើន ជាអ្នកវៀរអំពើទុច្ចរិតមិនរំលោភខុសច្បាប់ មិនធ្វើតាមអំពើចិត្តពាលរបស់ខ្លួន ។ ថ្ងៃមួយ ត្រូវគេចោទទូលព្រះបង្គំថាលួចទ្រព្យគេ. មហារាជបានឱ្យរាជបុរសសម្លាប់ទូលព្រះបង្គំហើយ យកក្បាលទូលព្រះបង្គំទៅដោតឈើអណ្ដោត. ដោយបុណ្យដែលទូលបង្គំបានធ្វើនោះឯង នាំមកកើតជាទេវតា. ឯសេះនេះកើតដោយបុណ្យដែលទូលព្រះបង្គំ បានយកឆ្អឹងគោទៅដាក់លប់ភក់ធ្វើផ្លូវឱ្យមនុស្សដើរបានស្រួល ។ ព្រះរាជាត្រាស់សួរទៀតថាចុះហេតុអ្វីបានជាអ្នកគ្មានសំពត់ស្លៀក ? ភូមទេវតាទូលថានេះគឺទោសដែលទូលព្រះបង្គំ យកសំពត់សំឡាញ់លាក់លេងជាល្បែង ធ្វើឱ្យសំឡាញ់នោះអាក្រាតនៅខ្លួនទទេ. សូមមហារាជជ្រាប មិនមែនដូចមហារាជធ្លាប់យល់ថា ស្លាប់ទៅសូន្យ ធ្វើបុណ្យបាបមិនមានផលនោះទេ ។

ក្នុងពេលនោះ ព្រះរាជាហាក់ដូចជាភ្ញាក់ព្រះអង្គថាអញប្រហែលយល់ខុសទេដឹង ? ។ ភូមទេវតាក៏ទូលបញ្ជាក់សេចក្ដីទៀតថា បុណ្យក្ដី បាបក្ដីដែលបុគ្គលធ្វើហើយមិន

សាបសូន្យទៅតែងឱ្យផលជានិច្ច. ពេលនេះបើមហារាជទ្រង់មេត្តាដល់ទូលបង្គំដែលគ្មានសំពត់ស្លៀក សូមមហារាជយកសំពត់ទៅប្រគេនសង្ឃ ឧទ្ទិសផលចំពោះទូលបង្គំ ៗ នឹងបានស្លៀកដណ្តប់ មហារាជក៏នឹងបានទតឃើញផលទានជាក់ច្បាស់ចំពោះព្រះនេត្រ ។

ព្រះរាជាទ្រង់ព្រះតម្រាស់ថា ម្នាលទេវតា ឱ្យយើងយកសំពត់ទៅប្រគេនសង្ឃអង្គឯណា. ទេវតាទូលថា សូមមហារាជប្រគេនចំពោះព្រះកប្បិតត្ថេរ ជាព្រះអរហន្ត ដែលលោកតែងនិមន្តបិណ្ឌបាតក្នុងក្រុងវេសាលី ។ ព្រះរាជាយកសំពត់ព្រះរាជទ្រព្យ មានសាច់ម៉ត់ល្អទៅប្រគេនព្រះកប្បិត-ត្ថេរ ហើយឧទ្ទិសផលចំពោះទេវតា ក្នុងពេលនោះ ទេវតាបានស្លៀកដណ្តប់សំពត់ទិព្វ ហើយទៅកាន់សំណាក់ព្រះកប្បិតត្ថេរនោះភ្លាម ព្រះរាជាបានទតឃើញជាក់នឹងព្រះនេត្រ សេចក្តីយល់ខុសមិច្ឆាទិដ្ឋិ ក៏រលត់បាត់អស់ក្នុងពេលនោះឯង ហើយត្រាស់បង្គាប់ឱ្យរាជបុរស ដោះលែងបុរសដែលជាប់ឈើអណ្តោត ។ បុរសនោះបានរួចពីឈើអណ្តោតហើយ ខំមើលមុខជំពោបានសះជា ក៏ចូលទៅបួសបានសម្រេចជាព្រះអរហន្ត ។ ឯព្រះរាជា បានថ្វាយខ្លួនជា

ឧបាសករក្សាសីល ៥ សីលឧបោសថថ្ងៃមួយបានស្ដាប់ធម្ម
ទេសនារបស់ព្រះកប្បិតភ្ថេរ ក៏បានសម្រេចដល់សោតាបត្តិ
ផលហោង ។

៙ចប៙

## ៧- រឿងជ្រូកឈ្មោះតច្ឆកៈ

(ចាក ត. ប.)

(ចេះស្ដាប់បង្គាប់នាយជន អាចញុំាងប្រយោជន៍ឱ្យសំរេចបាន)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានជាងឈើម្នាក់ ចូលទៅកាប់ឈើក្នុងព្រៃ បានឃើញជ្រូកព្រៃតូចមួយធ្លាក់អណ្ដូង ក៏រើសយកមកចិញ្ចឹមឱ្យឈ្មោះថា តច្ឆកៈ ដល់ជ្រូកនោះធំឡើង ចេះជួយធ្វើការជាងឈើនោះតាមសមត្ថភាពរបស់ខ្លួន មានឈ្នុសុត្រឡប់ឈើជាដើម ។ ជាងឈើនោះស្រឡាញ់ដូចកូនបង្កើត ទើបគិតថា ទុកជ្រូកឱ្យនៅជាមួយ ថ្ងៃក្រោយក្រែងគេសម្លាប់ ក៏យកទៅលែងក្នុងព្រៃ។ ជ្រូកតច្ឆកៈគិតថា នៅម្នាក់ឯងមិនកើត ត្រូវរកគ្នីគ្នាច្រើនទើបស្រួល. គិតហើយក៏ដើរចូលទៅក្នុងព្រៃ បានឃើញហ្វូងជ្រូកជាច្រើនទើបនិយាយថា យើងកំពុងដើររកញាតិតាមព្រៃភ្នំគ្រាន់បានពឹងពាក់គ្នា ឥឡូវបានជួបដូចបំណងហើយ យើងនាំគ្នានៅក្នុងទីនេះសប្បាយណាស់ ព្រោះមានផ្លែឈើមើមឈើទឹកព្រៃភ្នំ គួរជាទីរីករាយក្រៃពេក ។ ជ្រូកទាំងឡាយឆ្លើយតបវិញថា : ម្នាលតច្ឆកៈ ចូរស្វែងរកទីលំនៅដទៃវិញ ព្រោះទីនេះមានសត្រូវបៀតបៀន សម្លាប់

ជ្រូកតូចធំជារឿយៗ ។ ជ្រូកតច្នកៈសួរថា :

អ្នកណាជាសត្រូវ ហ៊ានមើលងាយពួកយើង ដែលស្រុះស្រួលគ្នា ! មើលងាយញាំញីមិនបានទេ ! ចូរអ្នកប្រាប់ខ្ញុំ ។

ជ្រូកទាំងឡាយប្រាប់ថា :

បពិត្រលោកតច្នកៈ មានស្តេចខ្លាមួយ ខ្លាំងពូកែមានចង្កូម និងក្រចកជាអាវុធ តែងខាំស៊ីជ្រូកតូច ៗ ជារឿយៗ ។

ជ្រូកតច្នកៈនិយាយថា :

ពួកយើងគ្មានចង្កូមទេ ប៉ុន្តែមានកំលាំងកាយ ឱ្យតែយើងស្រុះស្រួល ចេះស្តាប់បង្គាប់គ្នាសាមគ្គីគ្នា យើងនឹងចាប់សម្លាប់វាបានងាយ ។

ជ្រូកទាំងឡាយស្តាប់ហើយ ត្រេកអរីករាយគ្រប់គ្នានិយាយប្រាប់ជ្រូកតច្នកៈថា :

ពាក្យដែលលោកនិយាយហើយនោះ ចំជាពិរោះចាប់ត្រចៀកត្រូវចិត្តយើងខ្ញុំ. យើងត្រូវតែតស៊ូប្រយុទ្ធសម្លាប់វាឱ្យបាន ។ ជ្រូកតច្នកៈថា បើដូច្នោះឯងត្រូវព្រមព្រៀងគ្នាតាមបង្គាប់អញ. ជ្រូកទាំងអស់ព្រមតាម ទើបជ្រូក

តច្នកៈសួរថា ខ្លាតែងមកចាំស៊ីត្រង់ទីណា ? ជ្រូកទាំងឡាយប្រាប់ឱ្យបានដឹងទីកន្លែងសព្វគ្រប់ហើយ ទើបបង្គាប់ឱ្យជ្រូកធំ ៗ ឈ្មុសរណ្ដៅយ៉ាងជ្រៅសំរាប់បញ្ឆោតខ្លា ហើយឱ្យនាំគ្នាបរិភោគអាហារពីយប់ឱ្យឆ្អែតស្រេច ឱ្យជ្រូកចាស់ ៗ ជរា និងកូនជ្រូកតូចៗ នៅកណ្ដាល រីសជ្រូកធំ ៗ មានខ្នាយស្រួចវែង ៗ ព័ទ្ធជុំកង់ជុំវិញជាជួរ ៗ ហើយប្រាប់ថា បើខ្លាវាមក ធ្វើដូចម្ដេចយើងធ្វើតាមវាកុំភ័យខ្លាច. ឯជ្រូកតច្នកៈក៏ឈរនៅមុខជាមួយពួកជ្រូកព្រៃ ៗ ធ្វើជាមេទ័ពឱ្យជ្រូកទាំងនោះចាំធ្វើតាម ។

ដល់ថ្ងៃរះឡើង ខ្លាក៏ចេញពីលំនៅជដិលកោងម្នាក់ដែលវាតែងចែកសាច់ជ្រូកឱ្យស៊ី. មកដល់ឃើញជ្រូកឈរជុំកង់មីរដេរដាស មានជួរស្រទាប់ដូច្នោះ ក៏ធ្វើជាក្រាបឃើបបំរុងលោតចាប់ល្បងមើល ស្រាប់តែឃើញពួកជ្រូកធ្វើដូច្នោះដែរ ក៏ភិតភ័យរត់ទៅកាន់សំណាក់ជដិលកោងវិញទៅ. ជដិលកោងឃើញខ្លាមិនពាំជ្រូកទៅដូចថ្ងៃមុន ក៏និយាយដៀមដាមឱ្យថា :

នែអ្នកក្លាហាន ថ្ងៃនេះប្រហែលជាអ្នកវៀរចាកបាណាតិបាត ឱ្យអភ័យដល់សត្វទាំងឡាយហើយ ឬក៏ចង្កូម

អ្នកចាក់អស់មិនមានសល់ទេ បានជាទៅដល់ហ្វូងជ្រូកហើយ ត្រឡប់មកធ្វើមុខក្រៀមដូច្នេះ ។ ខ្លាឆ្លើយតបវិញថា :

មិនមែនដូច្នោះទេ កម្លាំងចង្កូមខ្ញុំមានព្រម ប៉ុន្តែខ្ញុំ ឃើញពួកជ្រូកសាមគ្គីរួបរួមគ្នា នៅជុំមួយកន្លែង ឃើញខ្ញុំ ទៅមិនភ្ញាក់ផ្អើលរត់ដូចពេលមុន ៗ សោះគឺវាប្រុងបៀត បៀនខ្ញុំវិញ តើខ្ញុំម្នាក់ឯងគ្មានគ្នាពឹងឱ្យចូលទៅខាំស៊ីគេម្តេច បាន ! ។ ជដិលកោងបានស្តាប់ នឹកអស់សង្ឃឹមនឹងបានស៊ី សាច់ជ្រូកទៀត ទើបខំនិយាយបញ្ឆោរខ្លាថា :

ម្នាលស្តេចខ្លា អ្នកមិនដឹងអំណាចឫទ្ធិរបស់អ្នកទេឬ? អ្នកកុំញញើតឡើយ គ្រាន់តែស្រែកគម្រាមហើយរត់ទៅ តម្រង់ទៅ ជ្រូកទាំងនោះនៅរួបរួមគ្នាមិនបានឡើយ ។

ខ្លាឡើងជោរតាមជដិលកោង ក៏ទៅម្តងទៀត, ជ្រូក បានឃើញហើយនាំគ្នាប្រុង, ខ្លាបោលតម្រង់ចំជ្រូកតច្ឆកៈ ដែលឈរមុខគេ ក្បែររណ្តៅបញ្ឆោត, ជ្រូកតច្ឆកៈគេចភ្លែត ចេញ ខ្លាក៏ធ្លាក់សំយុងកទៅរណ្តៅយ៉ាងជ្រៅនោះ ជ្រូក តច្ឆកៈលោតទៅបុសនឹងខ្នាយចំឆ្អឹងជំនី ធ្លុះដល់ថ្លើមប្រកាច់ ស្លាប់ក្នុងរណ្តៅនោះមួយរំពេច ទើបខាំទាញអូសមកលើ រណ្តៅ ចែកជ្រូកទាំងឡាយស៊ី ១ មាត់ម្នាក់អស់ទៅ ។ ឯ

ជ្រូកដែលមិនបានស៊ី ប្រាប់ជ្រូកតច្ឆកៈថា នៅនាយខ្លា គឺជជិលកោងមួយទៀត ។ ជ្រូកតច្ឆកៈថាបើដូច្នោះ យើងនាំគ្នាទៅសម្លាប់ចោលចេញ ក៏នាំគ្នារត់យ៉ាងលឿនទៅ ។ ចំណែកជជិលកោងកំពុងតែឈរលេបទឹកមាត់ ចាំខ្លាត្រង់ដើមផ្លូវ ស្រាប់តែឃើញជ្រូកទាំងឡាយរត់តាមផ្លូវមក ក៏ភ័យជាខ្លាំង នឹកថាខ្លាស្លាប់ហើយ ឥឡូវវាមកសម្លាប់អញទៀត ក៏រត់ឡើងដើមឈើមួយធំអាក្រាតសំពត់អស់ ។ ជ្រូកទាំងឡាយប្រាប់ តច្ឆកៈជានាយខ្លួនថា នេះឯងជជិលកោង ក៏នាំគ្នាឈ្មុសគល់ឈើនោះ យកខ្នាយចាក់គាស់បណ្ដាច់ឫសរលំធ្លាក់ជជិលកោងដល់ជីវិតក្សាម ជ្រូកទាំងឡាយក៏ខាំក្រញ៉ីស៊ីអស់ទៅ ។ រុក្ខទេវតាបានឃើញអស្ចារ្យដូច្នោះ ស្រែកបន្លឺថា :

សាធុ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញជា
សូករេហិ សមគ្គេហិ ព្យគ្ឃោ ឯកាយនេ ហតោ ៗ

សេចក្ដីថា ញាតិទាំងឡាយច្រើន អាចញ៉ាំងប្រយោជន៍ឱ្យសម្រេចដូចជាឈើដែលដុះច្រើន នៅក្នុងព្រៃ. ខ្លានិងជជិល គឺជ្រូកដែលស្រុះគ្នាសម្លាប់តែមួយភ្លែតហើយស្រេច ។

ជ្រូកទាំងឡាយ កាលបើសម្លាប់សត្រូវបានអស់ហើយ ក៏សប្បាយរីករាយ ។ អភិសេកជ្រូកតច្ឆកៈធ្វើជានាយខ្លួនតទៅ ។

៚ៜ៚

# ៨- រឿងស្រីពេស្យាកើតជាប្រេត

(ចាក បេ. ខុ.)

(ការមើលងាយអ្នកដទៃជាពូជនៃពៀរមួយ)

កាលកន្លងទៅហើយ មានស្ត្រីពេស្យាផ្កាមាសម្នាក់ ឈ្មោះសិរិនី នៅក្នុងហត្ថិនីជនបទនាដែនកុរុ ជាស្ត្រីគ្មានសីលធម៌ប្រចាំខ្លួន ។

ថ្ងៃមួយជាថ្ងៃឧបោសថ ពួកភិក្ខុសង្ឃប្រជុំគ្នាធ្វើឧបោសថកម្ម, ឧបាសកឧបាសិកាទាំងឡាយ មានសេចក្ដីជ្រះថ្លា ក៏នាំគ្នាយកភេសជ្ជផ្សេង ៗ មានស្ករទឹកឃ្មុំទឹកអំពៅជាដើម រៀបចាត់ចែងក្នុងសាលាភត្ត បម្រុងចាំប្រគេនសង្ឃដែលចេញពីរោងឧបោសថមក ។ ពេលនោះពួកឧបាសកឧបាសិកាទាំងឡាយ ជួនជាបានឃើញនាងសិរិនីស្រីផ្កាមាសដើរទៅក្បែរទីនោះ ក៏ហៅឱ្យចូលទៅអនុមោទនាយកចំណែកបុណ្យ, ស្រីផ្កាមាសនោះ មានចិត្តក្រោធខឹង ឆ្លើយតបទៅវិញថា យើងមិនចង់បានទេ គ្មានបុណ្យអ្វីកើតអំពីពួកស្រមណ៍ត្រងោល អ្នកតិះដៀលមាតុគ្រាមនេះទេ ពួកអ្នករាល់គ្នា សុទ្ធតែចាញ់បោកស្រមណ៍ត្រងោលទាំងនេះ និយាយហើយ ក៏ដើរហួសទៅ ។ សម័យខាងក្រោយមក

ឈ្លួញត្រឡប់ទៅស្រុកវិញ ប្រាប់ដល់មាតារបស់ប្រេតនោះតាមបណ្ដាំ មាតាក៏ចាត់ចែងគាស់យកប្រាក់ ធ្វើបុណ្យទានឧទ្ទិសផលឱ្យប្រេតនោះ ក៏បានរួចកម្មពៀរ ក្លាយខ្លួនជារុក្ខទេវធីតា សោយសម្បត្តិទិព្វ មានរូបកាយល្អប្រិមប្រិយ ។ យប់មួយទៅបង្ហាញខ្លួនឱ្យមាតាឃើញ ហើយរៀបរាប់សេចក្ដីទុក្ខរបស់ខ្លួន កាលកើតជាប្រេតជម្រាបមាតា ទើបរំលឹកអង្វរមាតាឱ្យធ្វើទានរក្សាសីល កុំឱ្យធ្វេសប្រហែស ហើយលាមាតាទៅលំនៅអាត្មាវិញ ។

មាតាក៏ធ្វើទានរក្សាសីល ដរាបដល់អស់អាយុបានទៅកើតក្នុងសុគតិភពហោង ។

៚៛៚

នាងធ្វើមរណកាលទៅកើតជាប្រេតញី នៅលើកំពែង ដែលគេជីកគូព័ទ្ធជុំវិញនគរ, មានរូបកាយអាក្រក់ ធុំក្លិនស្អុយចេញពីមាត់ ដូចសពស្អុយរលួយ មិនដែលបានបាយទឹកបរិភោគឡើយ ។ ថ្ងៃមួយមានឈ្មួញម្នាក់បររទេះទៅលក់ដូរឥវ៉ាន់ ដល់ពេលយប់ ក៏ដាក់រទេះដេកក្បែរកំពែងនគរនោះ។ ប្រេតញីឃើញបុរសនោះ ស្គាល់ជាអ្នកមកពីស្រុកកំណើតខ្លួន ក៏ទៅបង្ហាញខ្លួនឱ្យឃើញ ។

ឈ្មួញបានឃើញហើយភិតភ័យ ព្រោះរូបនោះអាក្រក់គួរខ្លាច ទើបសួរប្រញាប់ប្រញាល់ថា នាងជាអ្វីយើងមិនដែលឃើញមនុស្សបែបនេះសោះ នាងប្រេតប្រាប់តាមដំណើរបុព្វកម្មរបស់នាង ហើយផ្តាំងនឹងបុរសឈ្មួញនោះទៅមាតារបស់នាងថា នាងសិរិនីជាកូន ដែលស្លាប់នោះ មកកើតជាប្រេតនៅកំពែងនគរ មានសេចក្តីលំបាកស្រេកឃ្លានណាស់ សុំឱ្យមាតាយកប្រាក់ ៤ សែននៅកប់ក្រោមគ្រែដែលនាងដេក ហើយបែងប្រាក់នោះជាពីរចំណែក, មួយចំណែកឱ្យមាតាទុកចិញ្ចឹមជីវិត មួយចំណែកទៀតយកទៅធ្វើបុណ្យទានឧទ្ទិសផលឱ្យខ្ញុំ, ព្រោះប្រាក់នោះខ្ញុំសន្សំទុកមកយូរហើយ ។

# ៩- រឿងអញ្ញមាសករាជ

(ចាក អ. ភ.)

(ការមិនខ្ជះខ្ជាយទ្រព្យសម្បត្តិ ជាលក្ខណៈអ្នកមាន)

ក្នុងកាលកន្លងទៅហើយ មានអ្នកស៊ីឈ្នួលម្នាក់ នៅអាស្រ័យត្រង់ទ្វារខាងជើងក្រុងពារាណសី គាត់ស៊ីឈ្នួលរែកទឹកបានកន្ទះមាសក ( ៦សេន ) ហើយទុកក្នុងចន្លោះឥដ្ឋ ។ ថ្ងៃមួយធ្វើការដល់ទ្វារខាងត្បូងក្រុង ជួបជាមួយនឹងស្រីអ្នកស៊ីឈ្នួលរែកទឹកម្នាក់, ស្រីនោះមានលុយកន្ទះមាសកដែរ ។ ក្នុងថ្ងៃមួយ មានគេលេងមហោស្រព នាងបាននិយាយនឹងបុរសនោះថា បពិត្រស្វាមី យើងគួរទៅលេងមហោស្រពនឹងគេ ។ បុរសស្វាមីថាស្រួលហើយ អញមានលុយកន្ទះមាសកដែរ ទុកក្នុងចន្លោះឥដ្ឋត្រង់ទ្វារខាងជើងក្រុង ចម្ងាយ ១២ យោជន៍អំពីទីនេះ ។ នាងថាស្រួលហើយ ខ្ញុំក៏មានកន្ទះមាសកដែរ អ្នកទៅយកមករួមគ្នាឱ្យបាន ១ មាសកយើងទិញផ្កាកម្រងផង ទិញទឹកអប់ផង ទិញស្រាផង ។ បុរសកំសត់មានសេចក្តីត្រេកអរីករាយ ព្រោះស្រឡាញ់ពាក្យប្រពន្ធ ។ ពេលនោះកំពុងថ្ងៃក្តៅខ្លាំង គាត់ដើរយ៉ាងលឿនហើយច្រៀងបណ្តើរផង, ដើរបាន ៦ យោជន៍ជាន់លើខ្សាច់

ក្ដៅដូចរងើកភ្លើង ក៏បានដល់ទៅក្បែរព្រះលានស្ដេច ។ ក្នុងកាលនោះ ព្រះឧទយរាជ ជាស្ដេចក្នុងក្រុងពារាណសី កំពុងគង់ត្រង់សីហបញ្ជរ (បង្អួច) បានទតឃើញគាត់ កំពុងដើរដូច្នោះ ទ្រង់ព្រះចិន្ដាថា ថ្ងៃអេះក៏បុរសនេះមិនអើនឹងកំដៅសោះ បែរជាសើចផង ច្រៀងផងដើរផងដូច្នេះ អញនឹងសួរវាមើល ! ក៏ទ្រង់ត្រាស់បំរើឱ្យទៅហៅមកសួរ ។ គាត់ដំណាលរឿងនោះសព្វគ្រប់ថ្វាយព្រះរាជា ទីបំផុតទូលថា បពិត្រព្រះសម្មតិទេព កំដៅព្រះអាទិត្យ មិនដុតរោលទូលបង្គំទេ ឯកំដៅកាមទើបដុតទូលព្រះបង្គំ ដូចក្នុងពេលនេះបានជាមិនក្ដៅ ហើយរីករាយ មកពីទូលព្រះបង្គំគិតថាអញទៅយកលុយមកសប្បាយជាមួយភរិយា ។ ព្រះរាជាត្រាស់សួរបញ្ជាក់ថា លុយរបស់អ្នកមានប៉ុន្មាន មាន ១ សែនកហាបណៈឬ ? គាត់ទូលថាទេ ! ព្រះរាជាទ្រង់សួរបន្ថយចំនួនជាលំដាប់ ដរាបដល់ ១ មាសក. គាត់ទូលថា ទេទៀត ព្រះរាជាត្រាស់ថា អ្នកមានកន្លះមាសកឬ ? គាត់ទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាទ្រង់សង្វេគក្នុងព្រះទ័យ បានត្រាស់ថា : ហៃបុរសអើយ អ្នកកុំទៅ នៅឆ្ងាយចំនួន ៦ យោជន៍ទៀត

ហើយកំពុងក្ដៅដូចភ្លើងផង យើងឱ្យអ្នកកន្ទះមាសក. គាត់ទូលព្រះរាជាថា បើទុកជាទូលព្រះបង្គំទទួលព្រះរាជទានកន្ទះមាសកហើយ ក៏ទូលព្រះបង្គំមិនចោលកន្ទះមាសកនោះឡើយ នៅតែទៅយកក្នុងពេលឥឡូវនេះដែរ. ព្រះរាជាចេះតែទ្រង់បង្កើនព្រះរាជទានរបស់ព្រះអង្គដរាបដល់ ១ រយកោដិ និងទ្រព្យដទៃទៀតរាប់មិនអស់. គាត់នៅតែក្រាបទូលតាមពាក្យដើមដដែល ។ ព្រះរាជាចេះតែល្បួងដោយបុណ្យស័ក្តផ្សេង ៗ ដរាបដល់ឱ្យរាជ្យពាក់កណ្ដាល ទើបគាត់ព្រមលះបង់ចោលកន្ទះមាសក ហើយឈប់ធ្វើដំណើរកណ្ដាលថ្ងៃកំពុងក្ដៅ ។

លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់បង្គាប់ពួករាជការគ្រប់ដំណែង និងរាជបំរើឱ្យនាំបុរសកំសត់ទៅងូតទឹក កោរពុកមាត់ពុកចង្ការ ហើយទ្រង់ឡាយព្រះហស្តលេខាលើរាជក្រិត្យ ប្រគល់រាជ្យពាក់កណ្ដាលឱ្យ ក៏បានសោយរាជ្យជាស្ដេច ព្រះនាមអឌ្ឍមាសកៈនោះហោង ។

ಌಌ

# ១០- រឿងបុរសកាឡកណ្ណី

(ចាក កា. ឯ.)

(ការមិនឆ្មើងឆ្មៃជាលក្ខណៈរបស់បណ្ឌិត)

មានសេចក្តីដំណាលថា អនាថបិណ្ឌិកសេដ្ឋី មានសម្លាញ់ម្នាក់ឈ្មោះកាឡកណ្ណី ធ្លាប់លេងល្បែងក្មេងជាមួយគ្នាកាលនៅពីកុមារតូចៗ និងធ្លាប់រៀនសូត្រក្នុងសាលាជាមួយគ្នា ។ ដល់ធំមានបុត្រភរិយារៀងខ្លួនឡើង បុរសឈ្មោះកាឡកណ្ណីនោះធ្លាក់ខ្លួនជាអ្នកក្រ, ឯអនាថបណ្ឌិកឡើងជាមហាសេដ្ឋី ។ បុរសកាឡកណ្ណីឃើញសំឡាញ់មានទ្រព្យ ទៅសុំនៅពឹងពាក់ប្រាស្រ័យជាមួយ ។

អនាថបណ្ឌិកសេដ្ឋី មានសេចក្តីត្រេកអរីករាយទទួលឱ្យនៅ ឱ្យជួយមើលការខុសត្រូវរបស់ខ្លួន បានទំនុកបំរុងចំណីអាហារ គ្រឿងស្លៀកពាក់មិនឱ្យមានខ្វះកន្លះឡើយ ។ បុរសកាឡកណ្ណី ក៏ជួយធ្វើការផង មើលការខុសត្រូវផង ដោយស្មោះស្ម័គ្រដូចការងាររបស់ខ្លួន ។

ថ្ងៃមួយមិត្រនឹងទាសកម្មរបស់សេដ្ឋី នាំគ្នាទៅនិយាយប្រាប់សេដ្ឋីថា "បពិត្រសំឡាញ់ - លោកសេដ្ឋី សូមកុំឱ្យបុរសកាឡកណ្ណីនៅក្នុងសំណាក់លោកឡើយ ព្រោះ

ពាក្យថាកាឡកណ្ណីនេះចង្រៃណាស់ ក្រែងលោកមានគ្រោះថ្នាក់វិនាសអន្តរាយ. ម្យ៉ាងទៀតបុរសកាឡកណ្ណីនេះ ជាមនុស្សក្រីក្រអនាថា មិនមែនជាមនុស្សសមឋានៈជាមិត្រសំឡាញ់ជាទីរាប់អានរបស់លោកឡើយ ។

មហាសេដ្ឋីត្រិះរិះក្នុងចិត្តថា បុរាណបណ្ឌិតទាំងឡាយ លោកមិនកំណត់យកនាមឈ្មោះជាមង្គល ឬអព្វមង្គលនោះទេ ស្រេចតែអំពើដែលធ្វើ ទើបកំណត់ថាអំពើនេះជាមង្គល ឬជាអព្វមង្គលបាន. ឯខ្លួនអញក៏មិនគួរលះបង់ចោលសំឡាញ់ចាស់របស់អញ ព្រោះតែខ្លាចមានគ្រោះថ្នាក់ ខ្លាចថោកទាបខ្លួននោះទេ. ត្រិះរិះដូច្នេះហើយក៏ស្ងៀមពុំនិយាយអ្វីឡើយ ។

ថ្ងៃមួយមហាសេដ្ឋី មានកិច្ចទៅត្រួតត្រាមើលសុខទុក្ខរបស់ប្រជារាស្ត្រ ដែលនៅក្នុងស្រុកសួយរបស់លោក. មុននឹងចេញទៅ បានហៅបុរសកាឡកណ្ណីជាសំឡាញ់មកផ្តាំផ្ញើ ឱ្យមើលថែរក្សាផ្ទះសម្បែងទ្រព្យសម្បត្តិឱ្យ ។

ក្នុងពេលយប់ដែលសេដ្ឋីមិននៅនោះ ពួកចោរហារយ ដឹងថាសេដ្ឋីមិននៅដូច្នោះ ក៏នាំគ្នាកាន់គ្រឿងសាស្ត្រាវុធគ្រប់ដៃ ចូលមកឡោមព័ទ្ធជុំផ្ទះសេដ្ឋី ។

ចំណែកខាងបុរសកាឡកណ្ណី តាំងចិត្តមិនដេកក្នុងវេលាយប់ ខ្លាចសត្រូវចូលបៀតបៀន. កំពុងតែអង្គុយចាំយាម ស្រាប់តែឃើញពួកចោរព័ទ្ធជុំផ្ទះ ក៏ដាស់មនុស្សក្នុងផ្ទះ ឱ្យភ្ញាក់ឡើង លេងភ្លេងតូរ្យតន្ត្រីដូចកាលសេដ្ឋីនៅ ។ ពួកចោរខំពិនិត្យស្ដាប់ឮសូរភ្លេងរងំ ក៏សំគាល់ថាសេដ្ឋីនៅក្នុងផ្ទះទេតើ ! បើដូច្នេះយើងឆាប់រត់ចេញ. ក៏នាំគ្នារត់ចេញអស់ទៅចោលគ្រឿងសស្ត្រាវុធនៅត្រៀបត្រាជុំវិញផ្ទះ ។

មនុស្សអ្នកស្រុកទាំងឡាយ ដឹងថាចោរចេញទៅអស់ហើយ ក៏នាំគ្នាមកមើលជុំវិញផ្ទះសេដ្ឋី ឃើញសុទ្ធតែគ្រឿងសស្ត្រាវុធ បានដឹងថាចោររត់ទៅ ដោយឧបាយរបស់បុរសកាឡកណ្ណី ក៏នាំគ្នាសរសើរគ្រប់ ៗ គ្នា ។

ដល់សេដ្ឋីត្រឡប់មកវិញ នាំគ្នាទៅជំរាបសេដ្ឋីសរសើរអំពីគុណភាពរបស់បុរសកាឡកណ្ណីគ្រប់ ៗ គ្នា ទើបសេដ្ឋីនិយាយតបវិញថា ពេលមុនអ្នករាល់គ្នា ប្រាប់ឱ្យខ្ញុំដេញបុរសកាឡកណ្ណីនោះចេញ ព្រោះខ្លាចចង្រៃ ឥឡូវត្រឡប់ជាសរសើរថា ជាសុភមង្គលប្រាប់ខ្ញុំវិញ បើយើងដេញចេញឈប់ឱ្យនៅ ទ្រព្យយើងក្នុងថ្ងៃនេះអស់រលីងហើយ ព្រោះហេតុនោះ សូមអ្នករាល់គ្នាជ្រាបថា បុរសកាឡកណ្ណីនេះ

ជាសំឡាញ់ចាស់របស់ខ្ញុំ ធ្លាប់លេងសើច រៀនសូត្រជាមួយគ្នាតាំងពីនៅតូចៗ ម្ល៉េះ ខ្ញុំកាន់យកត្រង់សេចក្ដីរាប់អានស្មោះត្រង់នឹងគ្នានោះជាប្រមាណ មិនមែនយកត្រង់ឈ្មោះល្អអាក្រក់ជាប្រមាណនោះទេ ។ និយាយដូច្នេះហើយ បានឱ្យរង្វាន់ដល់បុរសកាឡកណ្ណីនោះជាការតបគុណ ។

ಣ೯೧ೞ

# ១១- រឿងកុមារកូនស្រីផ្កាមាស

(ចាក បេ. ខុ.)

(ពៀរវេរារបស់សត្វលោកមិនដែលសាបសូន្យ)

កាលព្រះសម្ពុទ្ធគង់នៅវត្តព្រះជេតពន នាក្រុងសាវត្ថី, កាលនោះមានឧបាសក ឧបាសិកា មានសទ្ធាជ្រះថ្លា នាំគ្នាធ្វើរោងបារាំក្នុងព្រះនគរ ហើយចាត់ចែងប្រគេនចង្ហាន់សង្ឃ ។ កាលនោះមានកុមារមួយរូប ជាអ្នកវីងរូសអន្ធពាល ឃើញឧបាសកឧបាសិកា ដឹកជញ្ជូនយកបង្អែមចំអាបទៅប្រគេនសង្ឃ ក៏និយាយចំអកឱ្យគេថា យកទៅចាក់ចោលលើគំនរសំរាម គ្រាន់បើជាងយកទៅឱ្យស្រមណ៍ត្រងោលស៊ី ។ ពុទ្ធបរិស័ទទាំងឡាយ ឮសំដីកុមារជាអសុរសជូចេ្នះ ក៏ទៅប្រាប់មាតាបិតាកុមារនោះ ។ មាតាបិតាកុមារមានសេចក្តីភិតភ័យជាខ្លាំង នាំកុមារនោះ ទៅកាន់សំណាក់ព្រះមានព្រះភាគ ឱ្យកុមារជាកូនរបស់ខ្លួន ស្មាលាទោសចំពោះសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសង្ឃក៏អត់ទោសឱ្យ ។ កុមារក៏មានសទ្ធាជ្រះថ្លាជាមួយមាតាបិតា រៀបចាត់ ចែងភត្តថ្វាយសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ទើបត្រឡប់ទៅគេហស្ថានរបស់ខ្លួនវិញ ។

ថ្ងៃក្រោយកុមារនោះស្លាប់ទៅ ទៅចាប់កំណើតក្នុងផ្ទៃស្រីផ្កាមាស នាក្រុងសាវត្ថីនោះ ។ ធម្មតាស្រីផ្កាមាស តែមានកូនប្រុស គេមិនដែលចិញ្ចឹមទេ បើមិនឱ្យទៅអ្នកដទៃគេយកទៅបោះចោល ។ ឯកុមារនោះ លុះគ្រប់ខែ ១០ សម្រាលមក នាងផ្កាមាសជាមាតាដឹងថា កូនប្រុស ក៏ឱ្យស្រីបំរើយកទៅចោលលើគំនរសម្រាម ក្នុងព្រៃស្មសាន ពួកក្អែកត្មាតរអាត ប្រេតបិសាច អារក្ខ រុក្ខទេវតាទាំងឡាយជួយបីបាច់ថែរក្សា មិនឱ្យមានក្តៅរងាឈឺចាប់អ្វីឡើយ បានសុខដូចជានៅក្នុងផ្ទៃនៃមាតា វេលាឃ្លានយកដៃដាក់ក្នុងមាត់ជញ្ជក់ មានឱជារសដូចទឹកដោះនៃមាតា ដោយអំណាចផលដែលបានថ្វាយទាន គោរពបំរើសង្ឃ និងព្រះសម្ពុទ្ធ អស់ ៧ ថ្ងៃក្នុងជាតិមុន ។ នៅក្នុងព្រៃស្មសានតែយ៉ាងនេះអស់ ៣ យប់ ៣ ថ្ងៃ ជួនជាព្រះសម្ពុទ្ធប្រទមើលមើលឧបនិស្ស័យសត្វ ក៏បានជ្រាបថា កុមារនោះមានវាសនាគួរតថាគតទៅជួយសង្គ្រោះ ។ ព្រឹកឡើងព្រះសម្ពុទ្ធ ទ្រង់ទទួលភត្តហើយ ស្តេចយាងទៅព្រៃស្មសាន ពួកឧបាសកឧបាសិកា នាំគ្នាតាមហែព្រះអង្គទៅ ដល់ទៅទីដែលកុមារដេក ទ្រង់ឈប់នៅទីនោះ បង្ហាញដល់ពុទ្ធបរិស័ទទាំងឡាយ

ថា កុមារនេះបានធ្វើទានចំពោះសង្ឃ មានគថាគតជាប្រធានកាលពីជាតិមុន ឥឡូវមកកើតក្នុងផ្ទៃស្រីផ្កាមាស គេយកមកចោលនៅទីនេះ ៣ ថ្ងៃហើយដោយពៀរវេរា មើលងាយទានដែលគេបំរុងយកទៅប្រគេនសង្ឃថា ឱ្យគេចាក់ចោលលើគំនរសម្រាម បានជាត្រូវគេយកមកចោលដូច្នេះ។ កុមារនេះ ត្រូវបានទទួលសម្បត្តិក្នុងលោកនេះ និងលោកខាងមុខទៀតយ៉ាងធំ ពេលនោះមានគហបតីឧបាសកម្នាក់មានប្រាក់ ៨០ កោដិ បានតាមទៅជាមួយដែរ ឮព្រះមានព្រះភាគត្រាស់សរសើរដូច្នោះ ក៏ចូលទៅបីលើកពីគំនរសម្រាមមក ប្រកាសចំពោះព្រះភក្ត្រព្រះសម្ពុទ្ធថា កុមារនេះជាកូនខ្ញុំព្រះករុណា ក៏យកទៅចិញ្ចឹម ។ សង្ខេបតែប៉ុណ្ណេះ ដល់គហបតីនោះស្លាប់ទៅ ទ្រព្យទាំងអស់ ត្រូវបានដល់កុមារនោះ កុមារនោះមានអាយុ ១០០ ឆ្នាំក៏ស្លាប់ ទៅកើតក្នុងទេវលោកទៀត ។

# ១២- រឿងដំរីស្គរ និងមេចាប

(ចាក ល. ប.)

(អ្នកធំ កុំមើលងាយអ្នកតូច នាំឱ្យខូចយស)

កាលកន្លងទៅហើយ មានដំរីស្គរធំ ១ ដើររកស៊ីក្នុងព្រៃរបោះតែម្នាក់ឯង ។ ថ្ងៃមួយបានប្រទះនឹងមេចាបកំពុងក្រុងកូនលើដុមស្មៅចំមុខផ្លូវដែលខ្លួនដើរ. មេចាបនិយាយអង្វរថា "សូមលោកធំអាណិតកុំដើរមកត្រង់នេះ ជាន់កូនខ្ញុំហើយ. ដំរីអាងខ្លួនធំ មិនខ្វីស្តាប់ដើរជ្រែង ស្តីឱ្យចាបវិញថា អញមិនស្តាប់អាចាបណាទេ ស្រេចតែអញដើរ អាឯងខ្លួនតូចមួយ ចេះធ្វើតម្រូតត្រូតត្រា ឃាត់ឃាំងផ្លូវអញ ១ មិនសមឿមអាឯងទេ បើទុកណាជាអាឯងមានគ្នាដល់ទៅមួយម៉ឺននាក់ក៏មិនខ្លាច អញជាន់តែជើងឆ្វេង ឯងស្លាប់ខ្ទេចខ្ទីរកឆ្អឹងប៉ុនសក់ក៏គ្មានដែរ. ថាដូច្នេះហើយ ក៏ជាន់កូនចាបស្លាប់ខ្ទេចខ្ទីអស់ទៅ ។ មេចាបកើតទុក្ខក្តៅក្រហាយ ហើរទៅទំមែកឈើខ្ពស់និយាយប្រាប់ដំរីថា "ឯងហ៊ានមើលងាយអញដល់ម្ល៉េះ ឃើញខ្លួនអញតូចកំឡាំងតិច ប៉ុន្តែអ្នកឯងមិនទាន់ដឹងកំឡាំងបញ្ញាទេ ចាំមើលអញសម្លាប់អាឯងវិញឱ្យបាន"។ មេចាបនិយាយហើយ ទៅពឹងក្អែកឱ្យចឹកភ្នែកដំរីនោះ ក្អែក

ក៏ជួយយកអាសា. ទើបមេចាបទៅពឹងរុយ ឱ្យពងដាក់ភ្នែកដំរីនោះទៀត រុយក៏ជួយយកអាសាទៅពងដាក់ កើតដង្កូវចុះរកភ្នែកដំរីស្អុរនោះទាល់តែខ្វាក់ទាំងពីរ។ មេចាបឃើញខ្វាក់ដើរពឹមពើមដូច្នោះ ហើយទៅផ្ដន្ទាស្ដីឱ្យថា "អើអ្នកដំរីស្អុរខ្លួនធំល្អពេក ទាស់តែភ្នែកខ្វាក់ អ្នកឯងស្គាល់ទេ នេះហើយជាការសងសឹករបស់មេចាប" ដំរីទាល់គំនិត កើតក្ដៅក្រហាយ ដូចគេយកភ្លើងទៅដុត តែមិនដឹងធ្វើដូចម្ដេច ។ មេចាបគិតថា អញសម្លាប់វាឱ្យបាន ក៏ទៅពឹងកង្កែបនៅជ្រោះភ្នំ ឱ្យឡើងទៅយំលើកំពូលភ្នំ កង្កែបជួយយកអាសាទៅយំលើកំពូលភ្នំ ដំរីស្អុរឮសូរ នឹកថាទីនោះមានបឹងព្រោះខ្លួនស្រេកទឹកយូរថ្ងៃហើយ ក៏ខំដើរឡើងទៅលើភ្នំ. កាលដំរីទៅដល់ កង្កែបលោតចុះទៅយំក្នុងជ្រោះវិញ ដំរីដើរតាមសំឡេងនោះទៅទៀត ក៏ធ្លាក់ទៅក្នុងជ្រោះបាក់កស្លាប់ ។

ឯមេចាបឃើញដំរីស្លាប់ហើយ ក៏សប្បាយចិត្ត លែងទុក្ខសោក ហើរទៅរកចំណីតាមធម្មតារបស់ខ្លួន ។

៙

# ១៣- រឿងព្រេតប្ដីប្រពន្ធ

(ចាក បេ. ខុ.)

(ទោសនៃសេចក្ដីកំណាញ់ មិនមានសទ្ធា)

ក្នុងសម័យពុទ្ធកាល មានត្រកូលព្រាហ្មណ៍មួយ ក្នុងក្រុងពារាណសី ។ ត្រកូលនោះមានកូន៣នាក់ ប្រុស ២ ស្រីមួយពៅបង្អស់. កូនទាំងបីនេះ ជាពួកម៉ាកមិត្រភ័ក្តរាប់អានគ្នាជាមួយឧបាសកម្នាក់ ជាឧបដ្ឋាកព្រះសង្ឃិចភិក្ខុ បានថ្វាយខ្លួនជាឧបាសកឧបាសិកា ចំណាយទ្រព្យធ្វើបុណ្យទាន ក្នុងព្រះពុទ្ធសាសនា ។ ចំណែកខាងព្រាហ្មណ៍ប្ដីប្រពន្ធ ដែលជាមាតាបិតាកូនទាំង ៣ នោះជាបុគ្គលកំណាញ់គ្មាន សទ្ធា មិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ព្រាហ្មណ៍នេះ មានក្មួយប្រុសម្នាក់ ទៅបួសជាសាមណេរក្នុងសំណាក់សង្ឃិចភិក្ខុនោះ ជាអ្នកឃើញទោសរបស់កាម តាំងពីបានបួសហើយ ចេះតែចូលទៅសុំឧបសម្បទាជាភិក្ខុក្នុងសំណាក់ឧបជ្ឈាយ៍. សង្ឃិចភិក្ខុជាឧបជ្ឈាយ៍ចេះតែឃាត់ឱ្យបង្អង់ចាំ ១ ខែទៀត ៗ ជាច្រើនដង ព្រោះលោកជ្រាបថា មានឧបនិស្ស័យជាព្រះអរហន្ត ប៉ុន្តែមិនទាន់ដល់កំណត់កាល ឯអាយុក៏មិនទាន់គ្រប់ ២០ ឆ្នាំផង ។

ថ្ងៃមួយមានខ្យល់ព្យុះធំ បក់បោករលំផ្ទះព្រាហ្មណ៍ស្លាប់អស់មនុស្សក្នុងផ្ទះ គឺព្រាហ្មណ៍ប្ដីប្រពន្ធក៏ស្លាប់ កូន ៣ នាក់ក៏ស្លាប់ ។ ព្រាហ្មណ៍ប្ដីប្រពន្ធ ស្លាប់ទៅកើតជាប្រេតទាំងពីរនាក់ ឯកូនប្រុស ២ នាក់ស្លាប់ទៅកើតជាភូមទេវតា កូនស្រីកើតជាភូមទេវធីតា បរិបូណ៌ដោយទិព្វសម្បត្តិ នៅអាស្រ័យក្នុងព្រៃធំ ក្បែរក្រុងរាជគ្រឹះ ។

ប្រេតប្ដីប្រពន្ធ មានរូបកាយអាក្រក់គួរខ្លាច កំពស់ប៉ុនត្នោតលៃ ខ្លួនប្រឡាក់សុទ្ធតែឈាម និងខ្ទុះ ដៃកាន់ដំបងដែកប៉ុនដើមត្នោត សំពងក្បាលគ្នាទៅវិញទៅមក បែកជាំដំពេញខ្លួន ហើយខាំហែកសាច់គ្នាស៊ីរាល់ពេលវេលា ព្រោះស្រេកឃ្លានខ្លាំងណាស់ ។ ប្រេតទាំងពីរនេះ ចេះតែដើរតាមភូមទេវតាជាកូនទាំងបី ប៉ុន្តែមិនអាចទទួលយកអំណោយពីកូនបានឡើយ ព្រោះកាលជាតិមុន កូនបបួលដឹកនាំឱ្យធ្វើទានសីលមិនព្រមស្ដាប់តាមសោះ ។

ចំណែកខាងសាមណេរ បានដឹងថាព្រាហ្មណ៍ជាឪពុកមាម្ដាយមីង ព្រមទាំងបងប្អូន ៣ នាក់ រលំផ្ទះស្លាប់អស់ ហើយក៏ចូលទៅសុំលាឧបជ្ឈាយ៍សឹកទៅផ្ទះវិញ ។ ឧបជ្ឈាយ៍ឃាត់ឱ្យបង្អង់សិន ទើបលោកនាំសាមណេរនោះ

ទៅគង់ក្នុងព្រៃធំ ស្រាប់តែសាមណេរនោះបានឃើញទេវតា ៣ រូប ហោះចុះឡើងសប្បាយរីករាយក្នុងដងព្រៃ ក៏សួរឧបជ្ឈាយ៍ៗ ឱ្យសួរចំពោះទេវតាផ្ទាល់ខ្លួនឯង ។ សាមណេរក៏សួរទេវតាដែលហោះមុនគេថា អ្នកជាអ្វី បានធ្វើកម្មអ្វីខ្លះពីជាតិមុន ? សួរដូច្នេះគ្រប់ទេវតាទាំងបីរ ។ ទេវតាទាំងនោះ មិនប្រាប់ដោយខ្លួនឯងទេ គ្រាន់តែប្រាប់ថា ចាំសួរប្រេតពីរនាក់នៅខាងក្រោយ ។ មួយស្របក់ស្រាប់តែប្រេតមកដល់ សាមណេរឃើញ នឹកអស្ចារ្យក្នុងចិត្តពន់ពេក ទើបសួរទៅប្រេតនោះថា អ្នកបានធ្វើអំពើដូចម្តេចខ្លះ កាលពីជាតិមុន ? អ្នកស្គាល់ទេវតា ៣ រូបដែលហោះមុនអ្នកឬទេ? កាលពីដើមទេវតានោះធ្វើកម្មអ្វីខ្លះ ? អាត្មាចង់ដឹងណាស់ព្រោះមិនដែលឃើញ ។ ប្រេតនិយាយប្រាប់សាមណេរនោះថា ខ្ញុំព្រះករុណាកាលពីជាតិមុន នៅក្រុងពារាណសី ជាមនុស្សកំណាញ់ គ្មានសទ្ធាជឿក្នុងព្រះពុទ្ធសាសនា ឯទេវតា ៣ រូបនោះជាកូនបង្កើតរបស់ខ្ញុំព្រះករុណា កាលពីជាតិមុនបានធ្វើបុណ្យទានក្នុងសំណាក់ព្រះសង្ឃភិក្ខុ ដល់ពេលមានខ្យល់ព្យុះធំ រលំផ្ទះស្លាប់ បានមកកើតជាទេវតានេះឯង ឯខ្ញុំព្រះករុណា ជាមាតាបិតាស្លាប់ក្នុងពេលរលំផ្ទះនោះដែរបាន

មកកើតជាប្រេតនេះ ។ ចំណែកលោកម្ចាស់ ក៏មិនមែនអ្នកដទៃ គឺជាក្មួយបង្កើតរបស់ខ្ញុំព្រះករុណា ។

គ្រាន់តែថាដូច្នេះហើយ ប្រេតនិងទេវតា ក៏បាត់រូបលែងឃើញតាំងពីពេលនោះមក ។ សង្ខេបតែប៉ុណ្ណេះ ឯសាមណេរ ក៏និមន្តទៅវត្តជាមួយឧបជ្ឈាយ៍ នាំទៅថ្វាយបង្គំព្រះសម្ពុទ្ធ ដំណាលទូលតាមដំណើររឿង ព្រះសម្ពុទ្ធទ្រង់ប្រារព្ធយករឿងប្រេតនោះមកជាហេតុ ហើយទ្រង់សម្តែងធម្មទេសនាប្រកាសអរិយសច្ច ៤ ប្រការ មហាជនបានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ឯសាមណេរដែលទើបបានឧបសម្បទាថ្មីនោះ ខំចំរើនសមណធម៌ មិនយូរប៉ុន្មាន ក៏បានសម្រេចមគ្គផលជាព្រះអរហន្ត ១ អង្គក្នុងលោក ។

## ១៨- រឿងនាងឧត្តរី

(ចាក បេ. ខុ.)

(មិនគួរយំសោកស្តាយចំពោះជនដែលស្លាប់បាត់ទៅហើយ)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅវត្តជេតពន មាន ឧបាសិកាមួយរូប យំសោកស្តាយស្វាមីដែលធ្វើមរណកាល ទៅហើយ ។ រាល់តែព្រឹក នាងទៅយំសោកបោកខ្លួនលើផ្នូរ ខ្មោចស្វាមីក្នុងព្រៃស្មសាន អត់បាយអត់ទឹក ស្គមរីងអស់ ទាំងខ្លួន ទោះបីញាតិមិត្រហាមឃាត់អង្វរយ៉ាងណា ក៏លះ បង់សេចក្តីសោកនោះមិនបាន ។

ថ្ងៃមួយ ព្រះសម្ពុទ្ធបរមគ្រូទ្រង់ជ្រាប បានប្រមើល មើលឧបនិស្ស័យឃើញថា នាងត្រូវបានសម្រេចដល់សោតា បត្តិផល ទើបស្តេចយាងទៅកាន់ផ្ទះនាង ដើម្បីរំលឹកទូន្មាន។ នាងបានឃើញព្រះសាស្តា ហើយនិមន្តគង់លើពុទ្ធាសនៈ ថ្វាយចង្ហាន់. ក្នុងទីបំផុតនៃភត្តកិច្ច ព្រះសម្ពុទ្ធត្រាស់សួរថា នាងកើតទុក្ខយំសោកពីរឿងអ្វី ? នាងក្រាបទូលតាមដំណើរ ព្រះសម្ពុទ្ធទ្រង់ព្រះមេត្តា ត្រាស់រំលឹកថា ការយំសោកឥត អំពើទេ ស្វាមីនាងទៅកើតទៀតហើយ ឥតដឹងថានាងយំ សោកឡើយ ព្រោះហេតុនោះចូរនាងបន្ទោរបង់សេចក្តី

សោកចេញ ចាំតថាគត នាំអតីតនិទានមកសំដែងឱ្យនាងស្តាប់ ។ នាងក៏ខំប្រឹងអត់សង្កត់ចិត្តប្រុងស្តាប់ ព្រះសម្តុទ្ធសម្តែងថា : កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិនាក្រុងពារាណសី ទ្រង់កាន់ទសពិធរាជធម៌ ១០ ប្រការ មហាជនប្រុសស្រីក្នុងព្រះនគរ មានសេចក្តីគោរពរាប់អាន ពោលសរសើរព្រះអង្គគ្រប់ពេលវេលាពុំដែលដាច់ ដោយអំណាចព្រះអង្គចេះគ្រប់គ្រងប្រជារាស្ត្រ ឱ្យបានសន្តិសុខចំរើនគ្រប់ៗ គ្នា មិនលំអៀងខាងរាជការឱ្យទុក្ខរាស្ត្រ មិនលំអៀងខាងរាស្ត្រឱ្យទុក្ខអ្នករាជការ ។ កាលព្រះអង្គស្តេចយាងទៅកាន់និគមជនបទណា ៗ ពួកប្រជារាស្ត្រគ្រប់ប្រភេទ ស្រែកឱ្យពរសព្ទសាធុការ សរសើរព្រះរាជចេស្តាបារមីក្នុងទីនោះៗ ។

ថ្ងៃមួយព្រះអង្គ ទ្រង់ក្លែងភេទជាអ្នកកំសត់ ស៊ីឈ្នួលជួលដេរប៉ះសំពត់អាវ បានហៅមហាមាត្យមកប្រាប់ថា បើអ្នកណាមករកព្រះអង្គ ថាគង់នៅក្នុងព្រះបរមរាជវាំង កុំឱ្យប្រាប់ថា ព្រះអង្គស្តេចទៅកាន់ទីណាៗ ឡើយ ។ ប្រាប់មហាមាត្យដូច្នេះហើយ ពេលរាត្រីស្ងាត់ ព្រះអង្គទ្រង់ព្រះពស្ត្រចាស់រហែករយ៉ៃ តាមភាពអ្នកទ័លក្រកំសត់ស្តាយសំពាយ

មួយមានកំណាត់ចាស់ៗ និងម្ហូលចេសដាក់នៅក្នុង ព្រម ទាំងប្រាក់ ១ ពាន់កហាបណៈផង យាងចូលទៅក្នុងនិគម ជនបទតូចធំ ដើម្បីស្ដាប់មហាជនឱ្យដឹងថា សកម្មភាពរបស់ ព្រះអង្គ នៅមានទាស់ចិត្តមហាជនត្រង់កន្លែងណាខ្លះ ពួក អ្នករាជការ ទទួលប្រតិបត្តិសុចរិតតាមព្រះរាជបញ្ជា ឬ ទុច្ចរិតសង្កត់សង្កិនរាស្ត្ររបស់ព្រះអង្គ ។ ព្រះរាជាទ្រង់ ស្ដេចទៅទីកន្លែងណា គ្មានឮសំដីអាក្រក់ចំពោះព្រះអង្គ និង រាជការរបស់ព្រះអង្គសោះ មានតែសរសើរគ្រប់ៗ គ្នា ។ ចំណែកព្រះអង្គ ក៏គ្មានជនណាស្គាល់ថាជាមហាក្សត្ររបស់ ខ្លួនឡើយ ខ្លះហៅពូ ខ្លះហៅអ៊ំ ខ្លះហៅតា ប្រើឱ្យដេរប៉ះ សំពត់ឱ្យ. ខ្លះឱ្យឈ្នួលជាលុយកាក់ ខ្លះឱ្យចំណីអាហារ ។ ព្រះរាជាក្លែងភេទ នៅក្នុងនគរបែបនេះអស់រយៈវេលាជា យូរខែ ពុំដែលឮពាក្យតិះដៀល មិនពេញចិត្តចំពោះព្រះអង្គ និងអ្នករាជការព្រះអង្គសោះ ។ ជួនជាថ្ងៃមួយនោះ ស្ដេច យាងទៅដល់ផ្ទះស្រីមេម៉ាយស្វាប់ប្ដីម្នាក់ មានកូនក្រមុំមួយ អាយុ ១៦ ឆ្នាំ ជាស្រីគ្រប់ល័ក្ខណ៍ ប្រកបដោយលំអរ ៥ យ៉ាង ប៉ុន្តែជាស្ត្រីទ័លក្រ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះ ព្រឹក ។ ស្ត្រីមេម៉ាយឃើញព្រះអង្គចូលទៅដល់ផ្ទះ ក៏សួរថា

លោកពូអញ្ជើញមកមានការអ្វី ? ព្រះរាជាត្រាស់ថា ខ្ញុំជាអ្នកទ័លក្រ គ្មានស្រូវអង្ករ ស្រែចម្ការទេ មករកស៊ីឈ្នួលប៉ះសំពត់អាវ គ្រាន់នឹងចិញ្ចឹមជីវិត ។ ស្ត្រីមេម៉ាយឃើញបែបភាពជាអ្នកក្រ ស្លៀកពាក់ខោអាវរហែកផុតមុខផុតក្រោយក៏មានចិត្តអាណិត ហៅឱ្យនៅចាំបរិភោគអាហារជាមួយ ទើបហៅកូនស្រីឱ្យមកជំរាបសួរ ហើយប្រាប់ឱ្យរៀបដាំស្លយកមកជូនពិសា ។ ព្រះរាជា កាលបើកូនស្រីអ្នកមេម៉ាយនោះចេញមកសំពះសួរ, ដោយជាតិព្រះអង្គជាក្សត្រ មានព្រះនេត្រមុតដូចព្រះខ័នពេជ្រ អាចស្គាល់បានភ្លាមថាជាស្ត្រីគ្រប់លក្ខណ៍ ប្រកបដោយបញ្ចពិធកល្យាណី[១] (លំអរ ៥ យ៉ាង) ទើបត្រាស់សួរថា នាងនេះឈ្មោះអ្វី ? មានគេដណ្ដឹងហើយឬនៅ ? អ្នកមេម៉ាយប្រាប់ថា ឈ្មោះឧត្ដរី គ្មានអ្នកណាគេត្រូវការមកសួរនាំទេ ព្រោះឯងអ្នកកំសត់ទ័លក្រ ។ ព្រះរាជាត្រាស់ថា បើធ្វើដូច្នោះខ្ញុំសុំស្ដីដណ្ដឹងធ្វើជាភរិយា តើអ្នកមីងព្រមឬទេ ? អ្នកមេម៉ាយព្រមថ្វាយតាមសូមប៉ុន្តែមិនដឹងជាព្រះមហាក្សត្ររបស់ខ្លួនឡើយ ។

---

១- លំអ ៥ យ៉ាង បើចង់ជ្រាបសូមមើលក្នុងសៀវភៅប្រជុំនិទានជាតកភាគ ១ ត្រង់រឿងនាងវិសាខា ។

ដល់នៅជាមួយគ្នាពីរបីថ្ងៃ ទើបព្រះរាជាប្រាប់តាមដំណើរ ហើយដកយកលុយពីក្នុងសំពាយ ១ ពាន់កហាបណៈឱ្យដល់នាងឧព្វិរី លាត្រឡប់ទៅព្រះរាជវាំងវិញ. ស្ដេចយាងទៅដល់ត្រាស់បង្គាប់រាជអាមាត្យ ឱ្យចាត់ចែងរៀបផ្លូវដរាបដល់ផ្ទះមេម៉ាយ ហើយរៀបក្បួនយកជ័រជ័យ មកយកនាង និងអ្នកមេម៉ាយទៅក្នុងព្រះរាជវាំង រៀបអភិសេកជាឯកអគ្គមហេសីក្នុងពេលនោះឯង ។

កាលជាខាងក្រោយមក ព្រះរាជាអស់ព្រះជន្មាយុសង្ខារទីវង្គតទៅ នាងឧព្វិរីឯកអគ្គមហេសី ទ្រង់ព្រះកន្សែងសោកា បោកខ្លួនប្រាណអត់ព្រះស្ងោយពុំសោយឡើយ មានព្រះអង្គាវយវៈស្គាំងស្គម គ្មានបុគ្គលណាអង្វរឃាត់ជួយដោះទុក្ខបានឡើយ ។

ក្នុងកាលនោះជួនជាព្រះពោធិសត្វនៃយើង សោយព្រះជាតិជាព្រាហ្មណ៍ ចេញទៅបួសជាតាបសបានឈានសមាបត្តិ ហោះហើរនាអាកាសបាន លោកគង់នៅព្រៃហេមពាន្ត មានទិព្វចក្ខុពិចារណាយល់ថា នាងឧព្វិរីឯកអគ្គមហេសីព្រះបាទព្រហ្មទត្ត កំពុងទ្រង់ព្រះកន្សែងជាទុក្ខក្រៀមក្រំក្នុងព្រះឱរា ក៏ហោះទៅស្ថិតនាអាកាសបង្ហាញ

កាយឱ្យអ្នកនគរឃើញគ្រប់គ្នា ទើបសួរទៅព្រះនាងឧព្វិរីថា បពិត្រព្រះនាងទ្រង់ព្រះកន្សែងដើម្បីអ្វី ? ព្រោះហេតុអ្វី ? ព្រះនាងឧព្វិរីទូលតាមដំណើរថា ទ្រង់ព្រះកន្សែងអាឡោះអាល័យចំពោះព្រះរាជស្វាមី ដែលមានគុណធ្ងន់ បានជួយទំនុកបំរុងចិញ្ចឹមរក្សាព្រះនាង. តាបសសួរបញ្ជាក់ថា ព្រះរាជស្វាមីព្រះនាមអ្វី ? ព្រះនាមព្រហ្មទត្ត - ចុះព្រះបាទព្រហ្មទត្តអង្គណា ? បើព្រះនាងជាអគ្គមហេសីព្រះបាទព្រហ្មទត្តជាច្រើនព្រះអង្គ ច្រើនជាតិណាស់មកហើយ. ព្រះនាងទូលតាបសថាព្រហ្មទត្ត ជាព្រះរាជបុត្រព្រះបាទចុល្លណីជាព្រះរាជស្វាមីខ្ញុំម្ចាស់ តាបសថា ព្រហ្មទត្តជាបុត្រព្រះបាទចុល្លណី ជាព្រះរាជស្វាមីរបស់ព្រះនាងពីមុនៗ មកសោយរាជ្យសម្បត្តិក្នុងនគរពារាណសីនេះ ទីវង្គតត្រង់កន្លែងនេះជាច្រើនព្រះអង្គណាស់ដែរ ក៏ព្រះនាងមិនទ្រង់ព្រះកន្សែងសោយសោកផង តើព្រះនាងទ្រង់ព្រះកន្សែងនេះសមរម្យហើយឬ ? ព្រះនាងឧព្វិរីទ្រង់សណ្ដាប់ពាក្យតាបសអ្វីប្បោះ ក៏ភ្ញាក់ស្មារតីដឹង ច្បាស់ក្នុងព្រះអង្គថា យោគមិនគួរទ្រង់ព្រះកន្សែងសោយសោកសោះ ។ តាបសប្រដៅទូន្មានព្រះនាងឱ្យយល់ច្បាស់នូវត្រៃលក្ខណ៍ តាមដំណើរទេសនារបស់ព្រះ

ពុទ្ធពីបុរាណ ហើយត្រឡប់ទៅព្រៃហោមពាន្តវិញ ។

ឯព្រះនាងឧព្វិរី ក៏នឿយណាយក្នុងរាជសម្បត្តិ លះកាត់កង្វល់ ចូលទៅបួសជាតបសិនី ខំចំរើនឈានដល់ទីបំផុតព្រះជន្ម បានទៅកើតព្រហ្មលោកហោង ។

ព្រះសម្ពុទ្ធទ្រង់នាំអតីតនិទាននេះ មកសម្តែងប្រាប់នាងឧបាសិកាដូច្នេះហើយ សេចក្តីសោករបស់នាង ក៏រលត់បាត់អស់ដូចជាដុំភ្លើងធំធ្លាក់ចុះទៅក្នុងទឹកសមុទ្រ ។ ព្រះសម្ពុទ្ធយល់ច្បាស់ថា សេចក្តីសោករបស់ឧបាសិការលត់អស់ហើយ ក៏សម្តែងប្រកាសអំពីអរិយសច្ច ៤ ប្រការ, ដល់ចប់នាងឧបាសិកា បានសម្រេចដល់សោតាបត្តិផល ក្នុងពេលនោះហោង ។

ចំណែកពុទ្ធបរិស័ទទាំងឡាយ ដែលបានប្រជុំស្តាប់ព្រះធម៌ទេសនា ក្នុងពេលនោះទាំងប៉ុន្មាន ក៏បានសម្រេចមគ្គផល តាមកំលាំងនិស្ស័យដែលខ្លួនបានអប់រំសន្សំរៀងៗខ្លួន ។

៚ៜ៚

# ១៥- រឿងភិមសេនបុរស

(ចាក ភិ. ឯ.)

(ចិត្តរបស់បុថុជ្ជនតែងតែប៉ោងផតដោយលោកធម៌)

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី កាលនោះព្រះពោធិសត្វទ្រង់សោយព្រះជាតិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ បានរៀនសិល្បសាស្ត្រចេះយ៉ាងចំណានសព្វគ្រប់ ហើយពូកែឆើតខាងវិជ្ជាបាញ់ធ្នូ ទើបអ្នកនគរហៅថា "ចុឡ្លធនុគ្គហបណ្ឌិត" ។

ដំណើរតាមដើមគម្ពីរថា ចុឡ្លធនុគ្គហបណ្ឌិតពោធិ-សត្វនោះមានរូបកាយតូចទាប មិនមាំទាំសមជានាយខ្មាន់ធ្នូទេ ។ ថ្ងៃមួយមានសេក្តីត្រិះរិះថា ខ្លួនអញមិនសមជានាយខ្មាន់ធ្នូ គួរតែអញប្រាស្រ័យទាក់ទងនឹងបុរសណាមួយ ដែលមានរូបមាំទាំសមជាខ្មាន់ធ្នូ ហើយនាំទៅគាល់ព្រះរាជាអង្គណាមួយ ដើម្បីចិញ្ចឹមជីវិតដោយសាររូបបុរសនោះ ។ គិតដូច្នេះហើយ ក៏ដើរស្វែងរកបានជួបនឹងជាងតម្បាញម្នាក់មានរូបធំថ្លោះមាំទាំ ទើបព្រះពោធិសត្វសួរថា សំឡាញ់ឯងឈ្មោះអ្វី ? ជាងតម្បាញប្រាប់ថា ខ្ញុំឈ្មោះភិមសេន ។ ព្រះពោធិសត្វនិយាយថា អ្នកមានរូបកាយល្អធាត់ធំ តែគ្មាន

ចំណេះឱ្យសមតាមមាឌ ចំណែកខ្ញុំមានវិជ្ជាខាងបាញ់ធ្នូពូកែអស្ចារ្យក្នុងជម្ពូទ្វីបមានតែមួយប៉ុន្តែមាឌខ្ញុំមិនបានហេតុនេះចូរអ្នកធ្វើជាមិត្រនឹងខ្ញុំ អ្នកចូលទៅក្រាបទូលព្រះរាជាថា អ្នកជានាយខ្មាន់ធ្នូ ព្រះរាជានឹងសព្វព្រះរាជហឫទ័យចំពោះអ្នក បើមានធ្វើការអ្វីចាំខ្ញុំធ្វើជំនួស យើងនឹងរស់នៅក្នុងឋានៈខ្ពង់ខ្ពស់ ដោយឧបាយនេះទាំងពីរនាក់ ។

ភិមសេនបុរសមានសេចក្ដីត្រេកអរ នាំគ្នាទៅគាល់ព្រះបាទព្រហ្មទត្ត ព្រះពោធិសត្វក៏ដាក់ខ្លួនធ្វើជាអ្នកបំរើភិមសេនបុរស ។

ព្រះបាទព្រហ្មទត្ត ឃើញអ្នកទាំងពីរចូលគាល់ហើយត្រាស់សួរថា អ្នកមកមានការអ្វី ?

ភិមសេនបុរសទូលថា មកសូមជ្រកកោនក្រោមម្លប់ព្រះរាជសម្ភារបារមី ព្រះករុណាថ្លៃវិសេស ព្រោះទូលព្រះបង្គំចេះពូកែយ៉ាងចំណានខាងវិជ្ជាបាញ់ធ្នូ ។

ព្រះរាជាត្រាស់សួរភិមសេនទៀតថា ចុះបុរសតូចទាបដែលអង្គុយក្រោយខ្នងអ្នកនោះជាអ្វីនឹងអ្នក ?

ភិមសេនទូលថា ជាអ្នកបំរើទូលព្រះបង្គំ ។

ព្រះរាជាមានព្រះរាជហឫទ័យ សោមនស្សចំពោះ

នាយភិមសេន ក៏ទ្រង់ទទួលឱ្យនៅ ហើយព្រះរាជទានប្រាក់បៀវត្សន៍ឱ្យក្នុង ១ ខែ ១ ពាន់កហាបណៈ ។

ចាប់ដើមពីថ្ងៃនោះមក កិច្ចការរាជការទាំងប៉ុន្មានដែលជាមុខក្រសួងរបស់នាយភិមសេន គឺចុឡធនុគ្គហបណ្ឌិត ពោធិសត្វធ្វើជំនួសទាំងអស់ ។

ថ្ងៃមួយមានខ្លាធំចូលស្រុក ពួននៅព្រៃគុម្ពោតមួយចាំចាប់អ្នកស្រុកស៊ីជាអាហារ, អ្នកផងដើរទៅមកមិនដឹងវាចាប់ស៊ីអស់ជាច្រើន ។ ព្រះរាជាទ្រង់ជ្រាបដំណឹងនោះ ក៏ចាត់នាយភិមសេនឱ្យទៅចាប់ខ្លា ។ នាយភិមសេនទទួលធានាថា អាចចាប់យកខ្លាមកថ្វាយបាន ហើយថ្វាយបង្គំលាព្រះរាជា ចូលទៅប្រាប់ព្រះពោធិសត្វ ៗ ប្រាប់ឧបាយថា "អ្នកចូលទៅប្រកាសប្រាប់អ្នកស្រុកថា ឱ្យនាំគ្នាកាន់កាំបិទ, ពូថៅ, ដាវ,លំពែង, ស្នា, ធ្នូ ទៅតាមអ្នក ដើម្បីចាប់ខ្លាកាលបើទៅដល់ព្រៃនោះ ឱ្យអ្នកស្រុកព័ទ្ធជុំវិញហើយ អ្នកឯងចូលទៅពួនក្បែរឈើណាមួយ, អ្នកស្រុកនឹងសម្លាប់ខ្លានោះបានជាពុំខាន, បើដឹងថាគេសម្លាប់ខ្លាបានហើយ អ្នកបោចវល្លិ៍កាន់ដើរតម្រង់ទៅកន្លែងនោះ ហើយនិយាយបំភ័យអ្នកស្រុកថា អ្នកណាវាយខ្លានេះស្លាប់ យើងទៅបោច

វល្លិ៍ បំរុងចាប់ខ្លានេះចងទាំងរស់យកទៅថ្វាយព្រះរាជា, អ្នកទាំងឡាយមិនគួរធ្វើដូច្នេះសោះ កាលបើនិយាយដូច្នេះហើយ អ្នកស្រុកនឹងភិតភ័យនិយាយអង្វរអ្នកថា "សូមលោកអត់ទោសពួកយើងខ្ញុំ បានជាសម្លាប់ជ្រុលទៅហើយ យើងខ្ញុំនឹងជូនទ្រព្យជាទីគាប់ចិត្តដល់លោក .. អ្នកនឹងមានល្បីថាអាចសម្លាប់ខ្លាបានតែម្នាក់ឯងផង បានទ្រព្យអំពីអ្នកស្រុកផង បានទទួលព្រះរាជរង្វាន់យ៉ាងច្រើនអំពីព្រះរាជាផង ។

នាយភិមសេន ធ្វើតាមឧបាយព្រះពោធិសត្វ ក៏បានសម្រេចលទ្ធផលដូចឧបាយនោះមែន ។

សម័យក្រោយមក មានក្របីព្រៃកំណាចធ្វើបាបសម្លាប់អ្នកស្រុក, ព្រះរាជាចាត់ប្រើនាយភិមសេនទៀត, នាយភិមសេន ធ្វើតាមឧបាយព្រះពោធិសត្វ បានសម្រេចលទ្ធផលដូចមុនទៀត ។ បុណ្យស័ក្តក៏ចេះតែបានឡើងជាលំដាប់ ។ នាយភិមសេន ស្រវឹងដោយលោកធម៌ ក៏ភ្លេចព្រះពោធិសត្វ ត្រឡប់ជាតិះដៀលព្រះពោធិសត្វថា មិនបានការហើយលើកខ្លួនឯងថា ជាអ្នកគ្រាន់បើឆ្លាតប្រសព្វវាងវៃវិញ ឯព្រះពោធិសត្វ ឮដូច្នោះហើយក៏នៅតែស្ងៀម មានអាការៈជាប្រក្រតីដូចពេលមុន ៗ មក ។

កន្ទងកាលបន្តិចមកមានស្តេចសាមល្ង លើកទ័ពមកព័ទ្ធក្រុងពារាណសី. ព្រះបាទព្រហ្មទត្ត ក៏ចាត់នាយភិមសេនឱ្យចេញទៅបង្ក្រាប នាយភិមសេនក៏តាំងខ្លួនជាមេទ័ពធំឡើងជិះលើខ្នងដំរីជ័យ នាំពលសេនាទៅតតាំងជាមួយស្តេចសាមល្ង ឥតពិគ្រោះសាកសួរព្រះពោធិសត្វដូចមុនឡើយ ទុកព្រះពោធិសត្វដូចជាចាវព្រាវសុទ្ធ ៗ ឱ្យជិះតោងដំរីពីក្រោយខ្លួនទៅ ។ ទៅជិតដល់ទីសមរភូមិឮស្នូរសន្ធឹកសម្រែកហោកព្រៀវ ក៏ភ័យញាប់ញ័រចង់របូតធ្លាក់ពីលើខ្នងដំរី. ព្រះពោធិសត្វ ខំចាប់ទប់កុំឱ្យធ្លាក់. នាយភិមសេនចេះតែភ័យញ័រខ្លាំងឡើង ៗ ដរាបដល់ភគអាចម៍ភគនោមដាក់លើខ្នងដំរី. ព្រះពោធិសត្វបានឱកាសដូច្នោះក៏ស្តីបង្អន់ដោយអាការៈគម្រាម ជាអនេកប្បការដរាបដល់ទន់អស្មិមានៈ ហើយទើបនិយាយលួងលោមថា សំឡាញ់កុំអៀនខ្មាស់ ភិតភ័យអ្វី ចូរចុះទៅមុជទឹកលាងខ្លួនឱ្យស្អាត ចាំខ្ញុំចាប់យកស្តេចសាមល្ងទៅថ្វាយព្រះរាជាឱ្យបានដូចបំណង។ កាលភិមសេនចុះផុតពីខ្នងដំរីហើយ ព្រះពោធិសត្វ បានឱ្យលាងខ្នងដំរីស្អាត ក៏កាន់ធ្នូឡើងជិះលើខ្នងដំរីបញ្ជាការទ័ពចូលចាប់យកស្តេចសាមល្ង បានដូចប្រាថ្នាហើយនាំយក

ស្ដេចសាមល្អនោះទាំងសេនា ទៅថ្វាយព្រះបាទព្រហ្មទត្ត ៗ ទ្រង់មានព្រះហឫទ័យសោមនស្សរីករាយ ព្រះរាជទានរង្វាន់ និងឋានន្តរស័ក្តយ៉ាងធំជាឧត្តមសេនីយ៍ ដល់ព្រះពោធិសត្វ។ កិត្តិស័ព្ទកោតសរសើរឥទ្ធានុភាព របស់ព្រះពោធិសត្វ ក៏ល្បីរន្ទឺសុះសាយពេញជម្ពូទ្វីប. ឯនាយភិមសេន ក៏អន់អស់រាសី នៅអាស្រ័យដោយបុណ្យព្រះពោធិសត្វ លែងមានកេរ្តិ៍ឈ្មោះដរាបដល់អស់ជីវិត ។

## ១៦- រឿងមិគលុទ្ធករប្រេត

(ចាក បេ. ខុ.)

(ទោសបាណាតិបាត និងគុណរបស់មិត្រ)

កាលកន្លងទៅហើយ ក្នុងក្រុងរាជគ្រឹះ មានព្រានម្រិគម្នាក់ ជាមិត្រនឹងធម្មឧបាសក ។ ព្រាននោះសម្លាប់ម្រិគទាំងយប់ទាំងថ្ងៃ ឥតមានបង្អង់ពេលវេលាណាមួយឡើយ ។ ឧបាសកជាមិត្រ ចេះតែនិយាយលួងលោមអង្វរឱ្យឈប់សម្លាប់ ព្រានមិនព្រមតាម ។ ឧបាសកចេះតែឧស្សាហ៍និយាយមិនឈប់ មិនធុញទ្រាន់ដល់យូរៗ ទៅព្រាននោះក៏និយាយប្រាប់ឧបាសកថា ម្នាលសំឡាញ់ ខ្ញុំមានសេចក្ដីរាប់អានសំឡាញ់ក្រៃពេក ខ្ញុំឈប់សម្លាប់សត្វក្នុងវេលាយប់ជូនអ្នកចុះ ឧបាសកឮហើយ ទទួលថា សាធុ ! ៗ ខ្ញុំត្រេកអរណាស់ ក្នុងវេលាយប់ដែលអ្នកឈប់នោះ អ្នកត្រូវតាំងចិត្តរលឹកចំពោះគុណព្រះរតនត្រ័យ កុំរលឹកដល់ការនេសាទរបស់អ្នក ។ ព្រានធ្វើតាមបានទាំងអស់ តែដល់វេលាយប់ទៅដេកអន្ទាក់ ដកលប់ជាដើមទុកក្នុងទីមួយហើយ ដម្កល់ចិត្តក្នុងគុណព្រះរតនត្រ័យ ដល់វេលាថ្ងៃ ទើបទៅនេសាទតាមធម្មតា ។

សម័យក្រោយមក ព្រាននោះស្លាប់ទៅ កើតជាវេមានិកប្រេត នៅក្បែរភ្នំគិជ្ឈកូដ ពេលថ្ងៃរងទុក្ខវេទនា មានឆ្កែទាំងហ្វូងដេញខាំស៊ីអស់សាច់នៅសល់តែឆ្អឹង ដល់វេលាយប់ក្លាយខ្លួនជាទេវបុត្រ សោយសម្បត្តិទិព្វ នៅក្នុងវិមានមាស មានអ្នកបំរើរាប់រយនាក់ ។ ផ្លាស់ប្តូរសោយផលសុខទុក្ខ ៗ តែយ៉ាងនេះជាដរាបរាល់ពេលវេលា ។

ជួនជាថ្ងៃមួយនោះព្រះនារទត្ថេរ លោកនិមន្តទៅក្បែរភ្នំនោះ បានឃើញហើយ សួរដំណើងសព្វគ្រប់ ទើបនាំដំណើងនោះទៅកាន់សំណាក់ព្រះសម្ពុទ្ធ ក្រាបទូលតាមដំណើរ ។ ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ប្រារព្ធរឿងប្រេតនោះ ជាហេតុ ហើយសំដែងធម៌ទេសនា ដើម្បីជាប្រយោជន៍មគ្គផលសុខចំរើន ដល់ពុទ្ធបរិស័ទទាំងឡាយ ។

៚

# ១៧- រឿងព្រហ្មទត្តរាជកុមារ

(ចាក តិ. តិ.)

(គួរក្រែកអរចំពោះទណ្ឌកម្ម[១] ដែលអ្នកមានគុណដាក់ឱ្យ)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅព្រះជេតពនសុគន្ធកុដិស្រីមហាវិហារ. កាលថ្ងៃមួយ ព្រះអង្គទ្រង់សំដែងធម៌ប្រារព្ធនឹងភិក្ខុមួយអង្គ ជាអ្នកខឹងច្រើនឈ្មោះទុព្វចភិក្ខុ ដែលភិក្ខុជាថេរៈស្តីប្រដៅមិនបាន ទ្រង់លើកយកតិលមុដ្ឋិជាតកមកសំដែងប្រាប់ភិក្ខុនោះថា : អតីតេ កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រហ្មទត្ត សោយរាជ្យក្នុងនគរពារាណសី មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមព្រហ្មទត្តរាជកុមារ ។

កាលព្រះរាជបុត្រនោះចំរើនព្រះជន្មបាន ១៦ វស្សា ទំនៀមខត្តិយត្រកូលសម័យនោះ ត្រូវតែបញ្ជូនឱ្យទៅរៀនសិល្បសាស្ត្រនៅនគរដទៃ ដើម្បីឱ្យដឹងសុខទុក្ខសព្វគ្រប់ ។ ព្រះបាទព្រហ្មទត្ត ត្រាស់ហៅព្រះរាជកុមារឱ្យចូលគាល់ទ្រង់រំលឹកដាស់តឿន សព្វគ្រប់ឱ្យយល់ច្បាប់មនុស្សធម៌ ហើយទ្រង់ព្រះរាជទានប្រាក់ ១ សែនកហាបណៈ និងបច្ច័យចំណីអាហារមួយ បញ្ជូនទៅក្រុងតក្កសិលាតែមួយព្រះអង្គឯង ។

---

១. ពាក្យថាទណ្ឌកម្មបានដល់ ការជេរស្តីវាយប្រហារជាដើម របស់អ្នកមានគុណ គឺមាតាបិតា គ្រូអាចារ្យ ញាតិមិត្ត

ព្រះរាជកុមារថ្វាយបង្គំលាព្រះរាជបិតា-មាតា យាងចេញទៅ មិនយូរប៉ុន្មានបានដល់ក្រុងតក្កសិលា ស៊ើបសួររកផ្ទះអាចារ្យទិសាបាមោក្ខ បានឃើញចូលទៅថ្វាយបង្គំ សុំរៀនសិល្បសាស្ត្រ ។ អាចារ្យទិសាបាមោក្ខសួរថា មករៀននេះមានឈ្នួលឬឥតឈ្នួល បើមានឈ្នួលរៀនទាំងយប់ទាំងថ្ងៃឥតធ្វើការអ្វីទេ បើឥតឈ្នួលរៀនបានតែយប់ ថ្ងៃធ្វើការនេះជាទំនៀមអ្នកមកនៅរៀនក្នុងសំណាក់ខ្ញុំ។ ព្រះរាជកុមារទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ លើកយកថង់ប្រាក់១ សែន ទៅបូជាអាចារ្យប្រាប់ថានេះជាថ្លៃឈ្នួល ។ អាចារ្យទិសាបាមោក្ខ កាលបើបានទទួលរង្វាន់ហើយ ក៏ខំបង្រៀនដរាបដល់ចេះសិល្បសាស្ត្រសព្វគ្រប់ ។ ថ្ងៃមួយនាំព្រះរាជកុមារ ទៅស្រង់ទឹកក្នុងស្ទឹងទៅដល់ពាក់កណ្ដាលផ្លូវ ព្រះរាជកុមារទតឃើញយាយចាស់ម្នាក់ កំពុងហាលល្ង ក៏ទ្រង់កើបយក១ ក្ដាប់ធំ សោយហើយយាងហួសទៅដល់ត្រឡប់មកវិញយក១ ក្ដាប់ធំទៀត ទ្រង់យាងកើបល្ងយាយចាស់យ៉ាងនេះជារាល់ពេល យាយចាស់ខឹង ក៏ស្រែកជេរឿលដល់អាចារ្យទិ-សាបាមោក្ខថា មិនចេះប្រដៅសិស្ស ។ លោកអាចារ្យរំលឹក ប្រដៅព្រះរាជកុមារអស់វារៈបីដង ព្រះរាជកុមារនៅតែប្រព្រឹត្តដូច្នេះ ។ លោកអាចារ្យក៏ឱ្យសិស្ស ដទៃចាប់ ព្រះរាជកុមារចង ហើយ

វាយប្រដៅបីរំពាត់ ប្រដៅទូន្មាន អំពីទោសការលួចទ្រព្យគេសព្វគ្រប់ ។ ព្រះរាជកុមារ ទ្រង់ក្រោធពិរោធ ស្រក់ទឹកព្រះនេត្រចងគំនុំ ក្នុងព្រះទ័យថា បើបានសោយរាជ្យពេលណានឹងឱ្យរាជ បុរសហៅលោកអាចារ្យនេះ ទៅវាយធ្វើទោសដល់ជីវិតវិញ។ សម័យក្រោយមក ព្រះរាជកុមារលាអាចារ្យត្រឡប់ទៅព្រះនគរវិញ បានផ្តាំនឹងលោកអាចារ្យនោះថាបើខ្ញុំបានសោយរាជ្យ ខ្ញុំឱ្យរាជបុរសមកអញ្ជើញលោកអាចារ្យទៅជប់លៀង តបស្នងសងគុណ សូមលោកអាចារ្យអញ្ជើញកុំខាន ។ លោកអាចារ្យ ដឹងឧបាយកល ជាចង់ចងពៀរនឹងខ្លួនហើយ ទទួលថាចាំទៅលេង ។ ព្រះរាជកុមារ ក៏យាងត្រឡប់ទៅ នគរពារាណសីទៅ ទៅសំដែងសិល្បសាស្ត្រថ្វាយព្រះបិតាសព្វគ្រប់ ព្រះរាជបិតាទ្រង់សព្វព្រះរាជហឫទ័យចង់ទតឃើញរាជសម្បត្តិរបស់ព្រះរាជបុត្រ ទាន់ព្រះអង្គទ្រង់ព្រះជន្មនៅ ក៏លើករាជសម្បត្តិថ្វាយព្រះរាជបុត្រអភិសេកជាក្សត្រក្នុងក្រុងពារាណសីនោះឯង, ថ្វាយព្រះនាមថា ព្រះបាទព្រហ្មទត្តរាជកុមារ ។

ព្រះបាទព្រហ្មទត្តរាជកុមារនោះ កាលបើបានសោយរាជ្យហើយ ទ្រង់រលឹកឃើញគំនុំចំពោះអាចារ្យទិសាបាមោក្ខ

ក៏ត្រាស់បង្គាប់រាជបុរស ឱ្យទៅអញ្ជើញលោកអាចារ្យនោះមក ។ លោកអាចារ្យបានទទួលសេចក្ដីអញ្ជើញហើយ គិតពិចារណាថា ព្រះរាជាវ័យនៅក្មេងណាស់ អាត្មាអញទៅទូន្មានមិនទាន់បានទេ ចាំដល់ពាក់កណ្ដាលវ័យចាំទៅ. គិតដូច្នេះហើយ ក៏ផ្ដាំនឹងរាជបុរសឱ្យទៅក្រាបទូលព្រះរាជាវិញថាមានកិច្ចរវល់ចាំហើយកិច្ច នឹងមកក្រាបបង្គំគាល់ជាពុំខាន ព្រោះនឹករលឹកព្រះរាជាណាស់ ។ ដល់ព្រះរាជាស្ថិតនៅក្នុងមជ្ឈិមវ័យហើយ អាចារ្យទិសាបាមោក្ខ ក៏ចូលទៅក្រាបបង្គំគាល់ ។ ព្រះរាជាទតឃើញ ទ្រង់ធ្វើបដិសណ្ឋារកិច្ចហើយ ហៅរាជបុរសមកប្រាប់ថា នែរាជបុរសខ្លួនអញឈឺពើកខ្លាំងណាស់ ព្រោះលោកអាចារ្យវាយអញបីរំពាត់ជាយូរហើយ កាលអញនៅរៀនឹងគាត់ ឥឡូវត្រូវឯងរៀបប្រគល់មកុរាជដល់គាត់វិញ ជាការតបស្នងសងគុណរបស់អញ ។

អាចារ្យទិសាបាមោក្ខ ទូលសុំព្រះរាជវរោកាស សំដែងធម៌ថ្វាយថា "បើបុគ្គលណាមួយ ឃើញកូនប្រុសស្រីក្ដី កូនសិស្សក្ដី ធ្វើនូវអំពើអាក្រក់ មានសម្លាប់សត្វ, លួចទ្រព្យគេ, ផឹកស្រាជាដើម ហើយជេរស្ដីវាយប្រដៅឱ្យលះ

បង់អំពើអាក្រក់នោះចេញ បុគ្គលនោះឈ្មោះថាប្រសើរ ព្រោះអាចញ៉ាំងកូនប្រុសស្រី កូនសិស្សនោះ ឱ្យដល់នូវសេចក្ដីប្រសើរទាំង ៤ យ៉ាងគឺ ប្រសើរដោយមារយាទ ១. ដោយលំអរ ១. ដោយភេទ១. ដោយត្រាស់ដឹង១. ។ ដូចជាព្រះរាជា បើកុំបានទូលព្រះបង្គំបង្រៀន រំលឹកទូន្មានវាយប្រដៅ ធ្វើម្ដេចនឹងបានសោយរាជ្យ ដោយឆាប់រហ័សដូច្នេះ" ។ ក្នុងពេលនោះពួកអាមាត្យ នាម៉ឺនសព្វមុខមន្ត្រីដែលអង្គុយគាល់ទាំងប៉ុន្មាន ក៏លាន់មាត់ក្រាបទូលថា បពិត្រព្រះសម្មតិទេព ពាក្យលោកអាចារ្យសំដែងនោះពិតណាស់ ៗ រាជសម្បត្តិដែលព្រះករុណាគ្រប់គ្រងនេះគឺពិតជាកើតមកអំពីអាចារ្យទិសាបាមោក្ខនេះឯង ។

ព្រះរាជាក៏ភ្ញាក់ព្រះហឫទ័យរលឹកឃើញគុណ គ្រូអាចារ្យច្បាស់ក្នុងពេលនោះ ទើបលើករាជសម្បត្តិជូនលោកអាចារ្យ ៗ ថ្វាយទៅវិញ សូមតែសេចក្ដីសុខ ។ ព្រះរាជាក៏ឱ្យរាជបុរស ទៅនាំយកគ្រួសារលោកអាចារ្យទាំងអស់មកចិញ្ចឹម ទំនុកបំរុងឱ្យនៅក្នុងព្រះរាជវាំងដូចជាព្រះជនក ព្រះជននីរបស់ព្រះអង្គដរាបដល់ព្រះជន្មាវសាន ។

ប្រជុំជាតក ព្រះបាទព្រហ្មទត្តរាជកុមារក្នុងកាល

នោះគឺ   ទុព្ចភិក្ខុអ្នកខឹងប្រើននេះឯង.   ឯអាចារ្យទិសាបា
មោក្ខគឺ ព្រះតថាគតជាបរមគ្រូ ។

## ១៨- រឿងប្រេតស៊ីសាច់ឯង

(ចាក បេ. ខុ.)

(ទោសទុច្ចរិតផ្សេងៗ មានស៊ីសំណូកជាដើម)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ ។ កាលនោះ ព្រះបាទពិម្ពិសារ ទ្រង់ជាធម្មិកមហារាជ បាននាំអ្នករាជការ និងបណ្តារាស្ត្រ សមាទានរក្សាឧបោសថសីល ១ ខែ ៦ ដងជានិច្ចរាល់ឆ្នាំ ពួកអ្នករាជការទាំងអស់ គ្រប់ក្រសួងរាប់តាំងពីសេនាបតី រហូតដល់បុគ្គលិកតូចតាច សុទ្ធតែរក្សាសីលទាំងអស់ ឯបណ្តារាស្ត្រ ក៏នាំគ្នារក្សាសីលស្ទើរតែអស់ប្រទេស ។ ចំឡែកតែស្នាក្តីម្នាក់ (អារ៉ូកា) ជាមនុស្សអន្ធពាល ប្រព្រឹត្តទុច្ចរិត និយាយកុហកបំភាន់ត្រូវជាខុស ខុសជាត្រូវ គិតតែប្រយោជន៍ផ្ទាល់ខ្លួនស៊ីសំណូកសព្វយ៉ាង រាល់វេលាថ្ងៃសីល គាត់ទៅអង្គុយសុំសីលជាមួយគេ ដើម្បីឱ្យព្រះរាជាទតឃើញថា គាត់ជាឧបាសកចំណាប់មួយដែរ ។

ថ្ងៃមួយ គាត់និយាយប្រាប់ឧបាសកម្នាក់ ដែលស្និទ្ធស្នាលនឹងគាត់ថា ខ្ញុំគ្រាន់តែទៅសុំសីលកុំឱ្យតែព្រះរាជាទ្រង់សំគាល់ថា ជាមនុស្សគ្មានសីលប៉ុណ្ណោះ ខ្ញុំមិនកាន់តមសិក្ខា

បទអ្វីទេ ។ ឧបាសកនិយាយរំលឹកថា កុំធ្វើដូច្នោះ បើអ្នកមិនរក្សាអស់ ១ យប់ ១ ថ្ងៃដូចគេឯង ក៏រក្សាតែមួយកំណាត់ថ្ងៃពាក់កណ្ដាលឧបោសថ ក៏បានបុណ្យដែរ ។ បុរសស្មាគ្គីនោះ ក៏រក្សាបាន ១ យប់ពាក់កណ្ដាលឧបោសថ ជួនជាខ្យល់ចាប់ស្លាប់យប់នោះទៅ បានទៅកើតជាវិមានប្រេតនៅក្បែរភ្នំគិជ្ឈកូដ ពេលថ្ងៃសោយទិព្វសម្បត្តិ វេលាយប់កើតជាប្រេត មានក្រចកវែង ៗ ធំ ៗ ដូចកាំបិទចាប់ហែកសាច់ខ្លួនឯងស៊ីវារអស់នៅសល់តែឆ្អឹង ពេលថ្ងៃសោយទិព្វសម្បត្តិវិញផ្លាស់ប្ដូរយ៉ាងនេះរាល់ថ្ងៃ ។

សម័យមួយព្រះនារទត្ថេរ និមន្តទៅភ្នំគិជ្ឈកូដ បានឃើញប្រេតនោះ ក៏សួរបុព្វកម្មសព្វគ្រប់បានដឹងហើយនិមន្តនាំដំណឹងនោះ ទៅក្រាបទូលព្រះសម្ពុទ្ធបរមគ្រូ ព្រះអង្គទ្រង់ប្រារព្ធរឿងនោះជាហេតុ ហើយសំដែងធម្មទេសនាទូន្មានពុទ្ធបរិស័ទឱ្យលះទុច្ចរិត ប្រព្រឹត្តសុចរិត ។ ទីបំផុតនៃធម្មទេសនា ព្រះអង្គទ្រង់ប្រទានអរិយសច្ច ៤ ប្រការ ពុទ្ធបរិស័ទទាំងឡាយ ក៏បានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ។

## ១៩- រឿងខុនិច្ចគាបស

(ជាតក ស. ៦.)

(ទោសនៃការទ្រុស្តមិត្រនិងគុណនៃសង្គហធម៌)

ក្នុងអវសរដែលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងនគរពារាណសី មានព្រះរាជបុត្រ ១ ព្រះអង្គ ការឃោរឃៅ ជេរស្តីទាត់ធាក់គេឯងឥតហេតុផល, ពួកព្រះរាជវង្សានុវង្ស និងប្រជាជនទាំងប្រទេស ស្អប់ខ្ពើមព្រះរាជកុមារនោះពន់ពេក នាំគ្នាហៅថាទុដ្ឋកុមារ ប្រែថាកុមារអ្នកប្រទុស្ត ។

ថ្ងៃមួយព្រះរាជកុមារ យាងទៅក្រសាលក្នុងស្ទឹងធំ ជាមួយរាជបរិពារ លុះទៅដល់បង្គាប់មហាត្លឹក ឱ្យនាំទៅស្រង់ទឹកកណ្តាលស្ទឹង ។

សម័យនោះ មហាមេឃងងឹតទោរទឹមគ្រប់ទិស បំរុងបង្អោរភ្លៀងធំ ពួករាជបរិពារនាំព្រះរាជកុមារចុះទៅកណ្តាលស្ទឹង ហើយខ្សិបគ្នាឱ្យដឹងការសម្ងាត់ហើយ លែងព្រះរាជកុមារ ឱ្យអណ្តែកទៅតាមខ្សែទឹកស្ទឹងនោះទៅ ទើបនាំគ្នាមកកាន់ព្រះរាជនិវេសន៍វិញ ។

ព្រះរាជា កាលបើមិនឃើញព្រះរាជបុត្រហើយ

ត្រាស់សួរពួករាជបរិពារ រកព្រះរាជបុត្រនោះ ។ ពួករាជបរិពារក្រាបទូលថា បពិត្រព្រះប្រិយមហាក្សត្រ ពួកខ្ញុំព្រះអង្គមិនបានឃើញទេ. កាលមេឃខ្មៅ ផ្គរ រន្ទះមុនភ្លៀង ទូលព្រះបង្គំស្មានថា ទ្រង់យាងត្រឡប់មកព្រះរាជដំណាក់ហើយ ទើបទូលព្រះបង្គំតាមមករកនេះ ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ព្រួយព្រះរាជហឫទ័យ អាល័យព្រះរាជកុមារនោះជាខ្លាំង ទើបយាងទៅកាន់ស្ទឹង ចាត់រាជបុរសឱ្យដើរស្វែងរកគ្រប់ច្រកល្ហក តែមិនជួបឃើញព្រះរាជកុមារនោះឡើយ ។

ឯព្រះរាជកុមារ កាលអណ្ដែកទៅតាមស្ទឹងនោះ បានឃើញឈើអណ្ដែកទឹក ១ កំណាត់ក៏ចាប់តោងទៅ ។ នៅតាមមាត់ស្ទឹងនោះ មានកំណប់ទ្រព្យជាច្រើន គឺសេដ្ឋីបុត្រម្នាក់នៅក្នុងក្រុងពារាណសី បានយកទ្រព្យ ៤០ កោដិទៅកប់ជិតមាត់ស្ទឹងនោះ ដល់អាយុស្លាប់ ទៅកើតជាពស់ព្រៃនៅរក្សាទ្រព្យនោះ. សេដ្ឋីម្នាក់ទៀត នៅនគរពារាណសីនោះដែរ បានយកទ្រព្យ ៣០ កោដិទៅកប់ក្នុងទីជិតគ្នា ដល់ស្លាប់ទៅកើតជាកណ្ដុរ នៅរក្សាទ្រព្យនោះ ។ ដោយអំណាចភ្លៀងធំ ទឹកស្ទឹងជោរជន់លិចរន្ធពស់ រន្ធកណ្ដុរអស់

សត្វទាំងពីរហែលតាមខ្សែទឹក មកប៉ះនឹងកំណាត់ឈើ ដែលព្រះរាជកុមារកំពុងតោង ក៏ឡើងទំលើកំណាត់ឈើនោះម្នាងម្នាក់ ឯព្រះរាជកុមារនៅតោងកណ្ដាល ឥតបៀតបៀនសត្វនោះឡើយ ចេះតែនាំគ្នាបណ្ដែកខ្លួនតាមខ្សែទឹកនោះទៅ ដល់មាត់ស្ទឹងមួយ មានដើមរកាមួយដើម រលំក្បែរមាត់ស្ទឹងនោះ កូនសេកដែលនៅក្នុងសំបុកលើដើមរកាក៏ធ្លាក់ទៅក្នុងទឹក អណ្ដែតវិលវល់តាមខ្សែទឹក ក៏ទៅតោងនឹងកំណាត់ឈើរបស់ព្រះរាជកុមារនោះដែរ. រួមអ្នកអណ្ដែតទឹកទាំងអស់ ៤ នាក់ គឺ ព្រះរាជកុមារ ១, ពស់ ១, កណ្ដុរ ១, សេក ១ ។

តស្មី សមយេក្នុងសម័យនោះ ព្រះពោធិសត្វ ទ្រង់សោយព្រះជាតិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ នាដែនកាសី បានចេញចាកផ្ទះទៅបួសជាតាបស តាំងអាស្រមនៅក្បែរមាត់ស្ទឹងនោះមានឈ្មោះហៅថា ឧទិច្ចតាបស, លោកកំពុងតែដើរចង្ក្រមក្នុងពេលយប់ ស្រាប់តែឮសំឡេងព្រះរាជកុមារស្រែកយំខ្លែង ៗ ដោយសេក្ដីស្រេកឃ្លាន និងធាតុត្រជាក់បៀតបៀន លោកក៏មានព្រះទ័យមេត្តា ជួយស្រោចស្រង់ឱ្យរួចអំពីសេចក្ដីស្លាប់ ទើបលោកស្រែកប្រាប់ពីចម្ងាយ

ថា កុំភ័យចាំយើងជួយ ក៏លាត់ស្បង់ចងក្បិត ហើយលោក ហែលទៅទាញយកទាំងកំណាត់ឈើនោះ មកដល់ច្រាំង នាំយកព្រះរាជកុមារ និងសត្វទាំងបីទៅអាស្រមរបស់លោក ដុតភ្លើងហើយគិតថា សត្វទាំងបីនេះ មានកំលាំងតិចហេវ ជាង ទើបឱ្យអាំងភ្លើងមុន ឯព្រះរាជកុមារឱ្យអាំងក្រោយ បន្ទាប់គ្នា ដើម្បីឱ្យស្រួលធាតុដល់ព្រះរាជកុមារនោះផង. ដល់ពេលឱ្យអាហារ ក៏ឱ្យសត្វទាំងបីមុនដែរ ។ ព្រះរាជ កុមារឃើញដូច្នោះ មានសេចក្តីអាក់អន់ព្រះទ័យ នឹកថា តាបសនេះកោង មិនស្គាល់ព្រះរាជបុត្រព្រះបាទព្រហ្មទត្ត ក៏ ចងគំនុំនឹងតាបសនោះ ។ នៅបានពីរបីថ្ងៃ មានកំលាំង ស្រួលបួលគ្រប់គ្នា ទឹកស្ទឹងក៏ស្រក់អស់ដូចធម្មតា ។ ទើប ពស់លាតាបស ហើយនិយាយបវារណាចំពោះតាបសថា "លោកម្ចាស់មានព្រះគុណធ្ងន់លើរូបខ្ញុំព្រះករុណា ឥតអ្វី ប្រៀបផ្ទឹមស្មើបាន ខ្ញុំសូមតបគុណលោកដោយកំណប់ទ្រព្យ ៤០ កោដិ បើមានសេចក្តីត្រូវការពេលណា សូមនិមន្តទៅ រកខ្ញុំព្រះករុណា នៅក្បែរស្ទឹងឯនុះ ហើយហៅខ្ញុំព្រះករុណា ថា ពស់ៗ ដូច្នោះ ខ្ញុំព្រះករុណានឹងបង្ហាញកំណប់ទ្រព្យនោះ ដល់លោកម្ចាស់. បវារណាដូច្នេះហើយលាចេញទៅ ។

ឯកណ្ដុរក៏បវារណាដោយ កំណប់ទ្រព្យ ៣០ កោដិរបស់ខ្លួន ដូចពស់ដែរ បានផ្ដាំថាបើទៅរកខ្ញុំព្រះករុណាឱ្យហៅថា កណ្ដុរៗ ដូច្នេះ ហើយលាចេញទៅ ។

ឯសេកបវារណាថា ខ្ញុំគ្មានកំណប់ទ្រព្យទេ បើព្រះគុណត្រូវការដោយស្រូវសាលី សូមនិមន្តទៅកន្លែងខ្ញុំព្រះករុណាឯនោះ ហៅខ្ញុំព្រះករុណាថា សេកៗដូច្នេះ ខ្ញុំព្រះករុណានឹងនាំពួកសេកជាញាតិមិត្រ ទៅនាំស្រូវសាលីមកប្រគេន បវារណាដូច្នេះហើយក៏លាចេញទៅ ។

ចំណែកព្រះរាជកុមារ ដែលចងគំនុំនឹងតាបសគិតថា ត្រូវលានឹងគេដែរ អញបវារណាបញ្ឆោតតាបសឱ្យទៅកាន់ដំណាក់អញៗនឹងសម្លាប់ចោល គិតដូច្នោះហើយបវារណាថាបពិត្រលោកម្ចាស់ បើឮថាខ្ញុំព្រះករុណាបានសោយរាជ្យហើយ សូមទាននិមន្តទៅ ខ្ញុំព្រះករុណានឹងទំនុកបំរុងដោយបច្ច័យទាំងបួន លុះបវារណាហើយ ក៏លាចេញទៅ មិនយូរប៉ុន្មាន បានសោយរាជ្យដូចព្រះរាជបំណងមែន ។

តាបសគិតថា អញនឹងល្បងមើលសត្វទាំងបីជាមុន តើវាដឹងគុណដូចវាថាមែនឬទេ ? ទើបនិមន្តទៅសំណាក់ពស់ជាមុន ពស់ឮតាបសហៅឈ្មោះខ្លួន ក៏ចេញពីរន្ធមកគួរ

សមគោរពតាបស ហើយជូនកំណាប់ទ្រព្យទាំង ៤០ កោដិ តាបសទទួលហើយ ឱ្យពរសរសើរសព្វគ្រប់ ផ្ញើទុកសិន និមន្តទៅសំណាក់កណ្ដុរទៀត កណ្ដុរក៏ធ្វើបដិសណ្ឋារៈ ជូនកំណាប់ទ្រព្យ ៣០ កោដិមានទំនងដូចពស់ដែរ ។ តាបសទៅកាន់សំណាក់សេកទៀត សេកក៏ធ្វើបដិសណ្ឋារៈ សួរតាបសថា បើត្រូវការស្រូវសាលីក្នុងពេលនេះ ខ្ញុំនាំគ្នាទៅពាំពីព្រៃហេមពាន្តមកជូន តាបសថាកុំអាល ចាំត្រូវការយើងប្រាប់ ទើបនិមន្តទៅកាន់សំណាក់ព្រះរាជកុមារ ដែលទើបបានរាជាភិសេកហើយនោះ ទើបតែនិមន្តចូលទៅបិណ្ឌបាតក្នុងទីក្រុង ជួនជាខណៈនោះ ព្រះរាជាទ្រង់គង់លើដំរី ដើម្បីប្រទក្សិណព្រះនគរ ក៏បានទតឃើញតាបសពីចម្ងាយ ស្គាល់ជាក់ហើយគំនុំក៏កើតឡើង ទើបប្រាប់រាជបុរសថា អ្នកទាំងឡាយ ចូរចាប់តាបសនោះ ចងសេកឱ្យធាប់ កុំឱ្យមកជួបនឹងអញ ហើយវាយបណ្ដើរអាក្រោសក្នុងផ្លូវធំទាំង៤ ក្នុងព្រះនគរ យកទៅកាន់ទីសម្លាប់កាត់ក្បាល យកដែកដោតឆ្កាងទុក ។ ពួករាជបុរស ក៏ចាប់តាបសចងស្លាបសេក វាយបណ្ដើរតាមផ្លូវក្នុងព្រះនគរ បំរុងយកទៅសម្លាប់ ឯតាបសលោកមិនយំសោកអង្វរអ្នកណាឡើយ ព្រោះលោកដឹងថា

ជាភាពចងពៀររបស់ព្រះរាជា ទើបលោកនិយាយប្រកាសថា "តាមដំណើងពិត បណ្ឌិតទាំងឡាយក្នុងលោកនេះ លោកពោលថា ស្រង់កំណាត់ឈើអណ្ដែតទឹក ប្រសើរជាងស្រង់មនុស្សទ្រុស្តមិត្តកំណាចដែលលង់ទឹក " ។

ពួកបណ្ឌិតបុរសទាំងឡាយ នៅក្បែរនោះបានឮដូច្នោះហើយ សួរតាបសថា លោកម្ចាស់បានធ្វើគុណចំពោះព្រះរាជារបស់យើងខ្ញុំឬ ? តាបសប្រាប់ហូរហែរតាមដំណើររឿង ។ ពួកអ្នកនគរទាំងឡាយ បានស្តាប់ហើយកើតសេចក្ដីអាណិតអាសូរចំពោះតាបស ខឹងចំពោះព្រះរាជា ទើបស្រែកប្រកាសថា "ព្រះរាជាអង្គនេះជាមនុស្សអកត្តញ្ញូ ទ្រុស្តមិត្ត យើងរាប់អានព្រះរាជាបែបនេះ សេចក្ដីទុក្ខ អន្តរាយនឹងកើតដល់ពួកយើងមិនខាន យើងត្រូវចាប់សម្លាប់ចោលចេញ ក៏នាំគ្នាឡោមព័ទ្ធចាប់សម្លាប់បោះចោលក្នុងជ្រោះហើយ អញ្ជើញតាបសឱ្យសោយរាជ្យអភិសេកជាក្សត្រក្នុងនគរនោះទៅ ។

តាបសគឺព្រះបរមពោធិសត្វ ទ្រង់គ្រប់គ្រងរាជ្យប្រកបដោយទសពិធរាជធម៌ដ៏បរិបូណ៌ ញុំាងប្រជាជនឱ្យបានសុខសាន្តគ្រប់និគមជនបទទាំងអស់ ។ ថ្ងៃមួយ បាន

នាំពួករាជបរិពារទៅនាំយកពស់ កណ្ដុរ សេក និងជីក កំណប់ទ្រព្យ ៧០ កោដិមកទុកក្នុងព្រះនគរ. ចំណាយទ្រព្យ ធ្វើទ្រុងមាស រន្ធកែវផលិកឱ្យពស់ កណ្ដុរ សេក នៅ ហើយ ជប់លៀងឱ្យចំណីដល់សត្វទាំងនោះ ដោយវត្ថុមានតម្លៃ ច្រើន ។

ព្រះរាជា និងសត្វទាំងបី មានសេចក្ដីរាប់អានគ្នា ដរាបដល់អស់អាយុរៀង១ខ្លួន ។

ចប

## ២០- រឿងពារាណសីសេដ្ឋី

(ចាក បុ. ឯ.)

(អ្នកមានស្មារតីពិនិត្យហេតុផលមិនដែលសាបសូន្យ)

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី, កាលនោះព្រះពោធិសត្វ ទ្រង់សោយព្រះជាតិជាសេដ្ឋី មាននាមថា ពារាណសីសេដ្ឋី ជាទីទំនុកទុកព្រទ័យស្និទ្ធិស្នាលនឹងព្រះបាទព្រហ្មទត្ត តែងទៅគាល់បំរើជាញឹកញាប់រាល់វេលា ។

សម័យនោះ មានអ្នកប្រមឹកមួយក្រុម អស់លុយចាយបានជំនុំគ្នារកលុយ. ប្រមឹកម្នាក់ឱ្យយោបល់ថា "ខ្ញុំឃើញលោកពារាណសីសេដ្ឋី តែងអញ្ជើញតាមផ្លូវមុខខ្ទមយើងនេះ ទៅគាល់ព្រះបាទព្រហ្មទត្តជាញឹកញាប់ ទៅម្តងណាក៏ឃើញស្លៀកពាក់តុបតែងកាយដោយសំលៀកបំពាក់ និងគ្រឿងអលង្ការមានតម្លៃច្រើន យើងគិតចាប់សេដ្ឋីនោះយកសំលៀកបំពាក់ និងគ្រឿងអលង្ការ ដោយប្រើថ្នាំសន្លប់ដាក់លាយនឹងសុរាឱ្យគាត់ផឹក គឺបើគាត់មកដល់មុខខ្ទមយើង ។ ចេញទៅសំពះសួរសុខទុក្ខ អញ្ជើញចូលលេងនៅខ្ទមយើង ហើយយើងជូនស្រាគាត់ផឹក ដល់គាត់សន្លប់

យើងដោះយកគ្រឿងប្រដាប់គាត់លក់ស៊ីចាយទាំងអស់គ្នា ។

អ្នកប្រមឹកព្រមមូលមតិគ្នា ក៏ធ្វើតាមឧបាយនោះ ឃើញសេដ្ឋីមកដល់ ក៏នាំគ្នាចូលទៅសំពះសួរ អញ្ជើញឱ្យសំរាកនៅខ្ទមរបស់ខ្លួន ហើយអួតប្រាប់ថា មានសុរាល្អ មានរសជ្ញាញ់ សូមលោកអញ្ជើញពិសាសិនសឹមអញ្ជើញទៅ ។ ពាភណសីសេដ្ឋី ជាមនុស្សមានសតិពិចារណាគ្រប់កិច្ចការទាំងពួង ទើបត្រិះរិះថា "រញមិនត្រូវការ នឹងសុរាទេ តែថាអញចង់ដឹងឧបាយកលអាអស់នេះ តើវាគិតធ្វើអ្វីដល់អញ " ត្រិះរិះដូច្នេះហើយ និយាយទៅរកអ្នកប្រមឹកទាំងនោះថា "អ្នកនាងទាំងអស់គ្នា ខ្ញុំអរគុណហើយ ប៉ុន្តែខ្ញុំមិនគួរផឹកសុរាហើយទៅគាល់ស្តេចទេ ចាំខ្ញុំត្រឡប់មកវិញ អ្នកនាងចូរចាំខ្ញុំក្នុងទីនេះ ។ សេដ្ឋីក៏ទៅគាល់ព្រះរាជាទៅ លុះត្រឡប់មកវិញ ទើបចូលទៅក្នុងខ្ទម ពិចារណាមើលសុរា ឃើញលាយដោយថ្នាំពុល ក៏ស្តីតិះដៀលឱ្យថា " យើ ! អ្នកប្រមឹក យើងស្គាល់ពុតអ្នកហើយ ។ ឧទិនស្រារបស់អ្នក នៅតែពេញប្រៀបដដែល ហើយអ្នកអួតប្រាប់យើងថា ស្រានេះល្អ មានរសជ្ញាញ់ បើល្អមែនពួកអ្នកមុខជាផឹកខ្លះមិនខាន ឥឡូវមិនមែនស្រាល្អទេ គឺអ្នកលាយថ្នាំ

ពិសពុល ដើម្បីឱ្យខ្ញុំផឹកសន្លប់ទៅ នឹងដោះយកគ្រឿងសំលៀកបំពាក់ និងគ្រឿងអលង្ការរបស់ខ្ញុំ នេះជាពុតអាក្រក់របស់អ្នករាល់គ្នា ។ ពួកអ្នកប្រមឹកកាលសេដ្ឋីនិយាយគាស់កកាយពីគំនិតអាក្រក់របស់ខ្លួនហើយ ក៏សុំឱ្យសេដ្ឋីអត់ទោសឱ្យ ហើយចាក់ស្រាមួយឧទិននោះចោលទៅ ។

ឯពារាណសីសេដ្ឋី ក៏ទៅកាន់ទីលំនៅរបស់ខ្លួនហោង ។

៚ ៚

## ២១- រឿងមហាល្លកឧបាសិកា

(ចាក កុ. តិ.)

(សង្គហធម៌ជាពូជនៃសេចក្ដីរាប់អានក្នុងលោក)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់ចាំព្រះវស្សានៅវត្តជេតពន នាក្រុងសាវត្ថី, ដល់ពេលចេញវស្សាហើយថ្មីៗ មហាពុទ្ធបរិស័ទ នាំគ្នាថ្វាយទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន គឺចែកព្រះភិក្ខុសង្ឃដល់គ្នានឹងគ្នា មួយអង្គ ២ អង្គ ម្នាក់យកទៅប្រគេនចង្ហាន់ឯផ្ទះរៀង១ខ្លួន. នៅសល់មហាល្លកឧបាសិកា (យាយឧបាសិកា) ម្នាក់ទៅក្រោយគេរកនិមន្តលោកមិនបាន ព្រោះឥតសល់ នៅតែព្រះសារីបុត្រ ១ ព្រះអង្គកំពុងមានកិច្ចរវល់, ការរកសង្ឃមិនហើនទៅនិមន្តឱ្យ ក៏បង្គាប់មហាល្លឧបាសិកានោះ ឱ្យទៅនិមន្តខ្លួនឯង គ្រាន់តែយាយនោះទៅដល់ ព្រះសារីបុត្រ លោកហុចបាត្រឱ្យ ទើបនិមន្តលោកទៅខ្ទមរបស់គាត់ ស្ពាយបាត្រដើរពីក្រោយលោកទៅ គួរឱ្យអស្ចារ្យព្រឺរោមពន់ពេក ស្បិតយាយនោះជាមនុស្សក្រ កំព្រឺកំព្រាឥតកូនចៅ រស់នៅដោយសារអ្នកផងគេឱ្យ ។

មហាពុទ្ធបរិស័ទ ផ្អើលជ្រួលច្របល់ តាមមើល

យាយ ដែលស្គាល់បាត្រតាមព្រះសារីបុត្រ, ដំណឹងនោះ ក៏ជ្រាបដល់ព្រះបាទបសេនទិកោសល ព្រះអង្គមានសេចក្ដីជ្រះថ្លា បានប្រើរាជបុរសយកភោជនដ៏មានឱជារស និងសំពត់សាដក ១ ប្រាក់ ១ ពាន់កហាបណៈ ព្រះរាជទានឱ្យយាយឧបាសិកានោះ ហើយបង្គាប់ឱ្យរាជបុរស ប្រាប់យាយនោះថា គ្រឿងបណ្ណាការនេះ ជាព្រះរាជទ្រព្យព្រះបាទបសេនទិកោសលជូនដល់យាយ ឱ្យយាយផ្លាស់សំពត់ចាស់រហែកនោះចេញ ស្លៀកសំពត់សាដកថ្មីនេះ ហើយចូរចាត់ចែងទានចុះ ។

ចំណែកខាងមហាអនាថបិណ្ឌិកសេដ្ឋី, ចុឡអនាថ-បិណ្ឌិក, នាងវិសាខាមហាឧបាសិកា បានឱ្យសំពត់សាដកនិងប្រាក់ ១ ពាន់ៗ កហាបណៈម្នាក់ ដល់យាយនោះ, ពុទ្ធបរិស័ទដទៃទៀត បានឱ្យប្រាក់ ១ រយកហាបណៈក៏មាន ២ រយក៏មាន តាមសទ្ធារៀងៗខ្លួន ក្នុងពេលពីព្រឹកទល់នឹងថ្ងៃត្រង់ ពេលប្រគេនចង្ហាន់ លោកយាយឧបាសិកាគាត់បានទទួលប្រាក់ចំនួន ១ សែនកហាបណៈ ។

យាយឧបាសិកា បានរៀបចាត់ចែងដាំស្ល ប្រគេនព្រះសារីបុត្រឆាន់យ៉ាងឆ្ងាញ់ពិសារ ឆ្អែតបរិបូណ៌, លុះធ្វើភត្ត

ហើយ ទើបព្រះសារីបុត្រ លោកសំដែងនូវភត្តានុមោទនា សរសើរអំពីផលទាន តាមលំនាំព្រះពុទ្ធសាសនា យាយឧបាសិកា ក៏បានសម្រេចដល់សោតាបត្តិផលក្នុងពេលនោះ ព្រះសារីបុត្រ លោកនិមន្តទៅលំនៅរបស់លោកវិញ ។ ពេលថ្ងៃរសៀល ភិក្ខុសង្ឃប្រជុំក្នុងធម្មសភា សរសើរគុណព្រះសារីបុត្រ និងសំណាងរបស់យាយឧបាសិកាគ្រប់ៗអង្គ ភិក្ខុខ្លះថា គោតតែព្រះសារីបុត្រត្លេរ លោកមិនខ្ពើមយាយនោះសោះ ។ ដំណឹងនេះជ្រាបដល់ព្រះសម្ពុទ្ធ ព្រះអង្គនិមន្តមកកាន់ធម្មសភាត្រាស់ថា យាយឧបាសិកា និងសារីបុត្រជាធម្មសេនាបតីរបស់តថាគតនេះ ធ្លាប់ជួយសង្គ្រោះគ្នាជាយូរយាររច្រើនជាតិណាស់ហើយ លោកមិនខ្ពើមរអើមទេ ។ ភិក្ខុទាំងនោះ អារាធនាឱ្យព្រះអង្គនាំអតីតនិទានមកសំដែង ទើបព្រះសម្ពុទ្ធសំដែងថា :

កាលកន្លងយូរណាស់ហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី កាលនោះព្រះពោធិសត្វកើតជាឈ្មួញសេះនៅឧត្តរាបថជនបទ បាននាំសេះ ៥០០ ទៅលក់ក្នុងក្រុងពារាណសី មានឈ្មួញ ៥០០ នាក់ ទៀតនាំសេះទៅលក់មុន ទៅដល់ពាក់កណ្ដាលផ្លូវ ឃើញភូមិចាស់

មួយស្នាក់ជ្រកំ មានតែយាយចាស់ម្នាក់ នៅអាស្រ័យនឹងភូមិនោះ ក៏សុំជួលផ្ទះយាយចាស់នោះសំណាក់ ដល់យប់ជ្រៅ មេសេះមួយសម្រាលកូនឈ្មោល ជាសេះសិន្ធវៈ, តែឈ្មួញទាំងនោះមិនស្គាល់ ។ ដល់ពេលនាំសេះធំៗចេញពីផ្ទះយាយនោះទៅ កូនសេះនោះមិនព្រមទៅ ទើបយាយគាត់សុំថា កូនសេះនេះឱ្យជាឈ្នួលផ្ទះខ្ញុំចុះ នាយឈ្មួញព្រមឱ្យ. យាយចាស់ក៏ខំចិញ្ចឹមហៅថា កូន ៗ សេះនោះ ក៏ស្រឡាញ់យាយនោះវិញដូចម្តាយ គាត់ឱ្យកន្ទក់ស៊ី កូនសេះក៏ចេះតែស៊ីយ៉ាងឆ្ងាញ់ពិសា ។

ថ្ងៃក្រោយមក ព្រះពោធិសត្វនាំសេះ ៥០០ រយទៅឈប់សំណាក់នឹងផ្ទះយាយនោះ ឯសេះធំៗ ទាំង ៥០០ រយមិនហ៊ានចូលទៅជិតកូនសេះនោះសោះ ចេះតែខ្លាចរត់ចេញ ព្រះពោធិសត្វរកមើលឃើញកូនសេះ នៅក្រោមផ្ទះយាយ ក៏បានស្គាល់ច្បាស់ថា កូនសេះនេះជាសេះសិន្ធវៈ មានឫទ្ធិខ្លាំងពូកែ មានតម្លៃកាត់មិនបាន ទើបសួរទិញយាយចាស់នោះ ។ និយាយថា មិនដែលមានអ្នកណាលក់កូនឯងដូច្នេះ ទោះបីខ្ញុំក្រយ៉ាងណា ក៏រកកន្ទក់ក្បាលអង្ករម និងស្មៅឱ្យកូនខ្ញុំស៊ីបានដែរ ទឹកខ្មែងដេក ក៏ខ្ញុំបោសរៀបចំឱ្យ

ស្អាតដូចជាដំណេកខ្ញុំដែរ ។ ព្រះពោធិសត្វ និយាយលួងលោមយាយនោះថា កូនសេះនេះបើបានមកខ្ញុំ ឱ្យបរិភោគសុទ្ធតែចំណីមានឱជារសដ៏ថ្លៃថ្លា ទឹកខ្មែងដេកចងសុទ្ធតែពិដានព័ទ្ធព័ន្ធជាគ្រឿងលំអរ យាយឮដូច្នោះក៏ព្រមឱ្យ ។ លំដាប់នោះ ព្រះពោធិសត្វ យកប្រាក់ ៦ ពាន់កហាបណៈ ឱ្យដល់យាយគឺ ៤ ពាន់ជាតម្លៃជើង ៤ ឯ ២ ពាន់ទៀតជាតម្លៃក្បាល ១ កន្ទុយ ១ ។ កូនសេះក្រឡេកមើលមុខយាយក៏ស្រក់ទឹកភ្នែក ទើបយាយស្ទាបខ្នងប្រាប់ថា កូនទៅនៅនឹងឈ្មួញនេះចុះ ម្តាយបាន ៦ ពាន់កហាបណៈ ល្មមចិញ្ចឹមពោះរស់ហើយ កូនសេះក៏ទៅជាមួយឈ្មួញព្រះពោធិសត្វនោះទៅ ។

ពេលព្រឹកឡើង ព្រះពោធិសត្វឱ្យរៀបចំភោជនាហារពេលព្រឹកហើយ យកកូនសេះនោះជិះល្បងមើលកំឡាំងបានដឹងថា ពូកែអស្ចារ្យ រកគូប្រដូចគ្មាន ទើបយកកន្ទក់ទៅដាក់ឱ្យស៊ី កូនសេះនោះមិនស៊ី ។ ព្រះពោធិសត្វសួរថាហេតុអ្វីបានជាអ្នកមិនស៊ី កាលនៅជាមួយយាយចាស់ចូលចិត្តស៊ីម្ល៉េះ ? កូនសេះប្រាប់ថា កាលនោះគេមិនទាន់ស្គាល់ថាខ្ញុំជាសេះមានឫទ្ធិ ឥឡូវគេស្គាល់អស់ហើយ

ទើបខ្ញុំមិនស៊ី តាំងពីថ្ងៃនេះទៅខ្ញុំស៊ី តែរបស់មានឱជារសថ្លៃថ្លា ។ ព្រះពោធិសត្វ និយាយលួងលោម ហើយយកអាហារមានឱជារសមកឱ្យស៊ី រៀបកម្រាលពូកចងពិដានតុបតែងកន្លែងឱ្យសេះនោះដេក ។ ថ្ងៃមួយព្រះបាទព្រហ្មទត្តស្ដេចយាងទៅក្បែរទីនោះ ទតឃើញគេរៀបតុបតែងឱ្យសេះដេកដូច្នោះ ទើបត្រាស់សួរព្រះពោធិសត្វ ៗ ទូលសព្វគ្រប់បានដឹងថា សេះពូកែអស្ចារ្យដូច្នោះ ទើបព្រះរាជទានងារ មហាឧបរាជដល់ព្រះពោធិសត្វ យកសេះនោះទៅអភិសេកមង្គលអស្សតរ សម្រាប់ជាព្រះទីនាំង របស់ព្រះអង្គទៅហោង ។

កាលព្រះសម្ពុទ្ធ សំដែងអតីតនិទាននេះចប់ហើយទ្រង់ប្រជុំជាតកថា យាយចាស់ក្នុងកាលនោះ គឺយាយឧបាសិកានេះឯង, សេះសិន្ធវៈ គឺព្រះសារីបុត្រ, ព្រះបាទពារាណសីគឺ ព្រះអានន្ទ, ឯឈ្មួញសេះពោធិសត្វគឺ ព្រះតថាគតនេះឯង ។

# ២២- រឿងចូឡកសេដ្ឋី

(ចាក អ. ចូ.)

(អ្នកមានប្រាជ្ញានឹងមានវាសនា អាចរកទ្រព្យបានងាយ)

ក្នុងកាលកន្លងទៅហើយ ព្រះពោធិសត្វបានកើតជាសេដ្ឋីឈ្មោះចូឡកៈ នៅក្នុងក្រុងពារាណសី ជាអ្នកចេះពូកែខាងការទាយ ។ ថ្ងៃមួយសេដ្ឋីបានទៅគាល់ព្រះរាជា ឃើញកណ្ដុរស្លាប់កណ្ដាលថ្នល់ ក៏ចាប់យាមទាយឃើញថា បើអ្នកណាអាចយកកណ្ដុរនោះទៅធ្វើជំនួញ នឹងមានទ្រព្យច្រើន ។

មានបុរសកំសត់ម្នាក់ ជាសិស្សរបស់សេដ្ឋីនោះ បានឮហើយ រើសកណ្ដុរស្លាប់នោះទៅលក់ឱ្យអ្នកចិញ្ចឹមឆ្មានៅផ្សារបាន ១ កាកណិក (១ សេន) ហើយទិញស្ករអំពៅផងទឹក១ ក្អមទៅឱ្យដល់ពួកមាលាការ ដែលទើបមកអំពីព្រៃ ។ ពួកមាលាការ បានឱ្យកម្រងផ្កាម្នាក់មួយៗ ដល់គាត់ ។ លក់ហើយទិញស្ករអំពៅផងទឹក ១ ក្អម យកទៅឱ្យពួកមាលាការក្នុងថ្ងៃព្រឹកឡើងទៀត ។ ពួកមាលាការ បានឱ្យឈើតូចៗដែលមានផ្កា ដល់គាត់ពាក់កណ្ដាល មិនយូរប៉ុន្មាន គាត់ក៏បានប្រាក់ចំនួន ៨ កហាបណៈ ។

ក្នុងថ្ងៃមួយទៀត មានភ្លៀងខ្យល់ព្យុះខ្លាំង ឈើក្នុងសួនរបស់ស្ដេចបាក់ជ្រុះគរជាគំនរ ឧទ្យានបាលរើសចោលមិនអស់ បុរសកំសត់ ទៅសុំស៊ីឈ្នួលរើសយកកំទេចឈើនេះ ។ ឧទ្យានបាលព្រមឱ្យ គាត់ក៏យកលុយ ទៅទិញស្ករអំពៅ ជូលក្មេងដែលកំពុងលេងល្បែងផ្សេងៗ ក្មេងក៏មកជួយជញ្ជូនដាក់គរក្បែរសួនអស់ ១ រំពេច ។

ក្នុងកាលនោះសួនច្បាំងរបស់ស្ដេច បានទិញម៉ៅគំនរឈើនោះចំនួន ១៦ កហាបណៈ និងឱ្យភាជនៈ មានពាងជាដើមយ៉ាងច្រើន ព្រោះគំនរកំទេចឈើនោះគួរដល់ការដុតឆ្នាំង ។ រួមទឹកលុយតាំងពីលក់កណ្ដុរមួយ មកទល់ត្រឹមនេះបាន ២៤ កហាបណៈហើយ ។ គាត់ក៏បានប្រកបមុខរបរតទៅទៀត គឺយកពាងទៅដាក់ជិតទ្វារនគរ ដងទឹកដាក់ពេញសំរាប់ឱ្យពួកអ្នកនាំស្មៅ ៥០០ នាក់. មិនតែប៉ុណ្ណោះគាត់បានទៅជួយយកអាសារផ្សេងៗ ជាមួយនឹងឈ្មួញខាងផ្លូវទឹក និងផ្លូវគោកទៀត ។ ថ្ងៃមួយមានឈ្មួញម្នាក់ប្រាប់គាត់ថា ស្អែកមានឈ្មួញសេះម្នាក់ នឹងនាំសេះ ៥០០ មកក្នុងទីនេះ ។ គាត់បានដឹងហើយ ទៅនិយាយនឹងអ្នកនាំស្មៅសុំស្មៅគេ ១ បាច់ ។ ម្នាក់បាន ៥០០ បាច់ហើយប្រាប់គេ

តាមដំណើរ គេក៏ជួយសង្គ្រោះគាត់ ទុកឱ្យគាត់លក់ស្មៅឱ្យឈ្មួញសេះអស់ ទើបគេលក់ស្មៅគេជាខាងក្រោយ ព្រោះគាត់មានគុណបានដងទឹកទុកឱ្យគេផឹក ។ ដល់ឈ្មួញសេះមកដល់ គាត់លក់ស្មៅ ៥០០ បាច់បាន១ ពាន់កហាបណៈ ។

ថ្ងៃក្រោយមក ឈ្មួញដើងទឹក ប្រាប់ដល់គាត់ថា ពីរបីថ្ងៃទៀតមានសំពៅចូលមក គាត់ទៅរកជួលរទេះ សំរាប់ជិះ មកទុកចាំនៅកំពង់សំពៅអស់ថ្លៃឈ្នួល ៨ កហាបណៈហើយគាត់បានជាម្ចាស់កំពង់ចំណត លុះសំពៅមកដល់ គាត់ម៉ៅឥវ៉ាន់ក្នុងសំពៅទាំងអស់ ឱ្យចិញ្ចៀន ១វង់ទៅម្ចាស់សំពៅដើម្បីបញ្ចាំចិត្ត ។ ក្នុងពេលនោះមានឈ្មួញ ១ រយនាក់ មកដណ្ដើមគ្នាទិញឥវ៉ាន់ក្នុងសំពៅនោះ បានឱ្យគាត់ ១ សែនកហាបណៈគឺ ម្នាក់ឱ្យ ១ ពាន់ៗ សុំអង្វរគាត់ឱ្យលក់ឱ្យគាត់ក៏លក់ចែកឱ្យទាំង ១ រយនាក់ គាត់បានចំណេញពីតម្លៃឥវ៉ាន់ ១ សែនកហាបណៈទៀត រួមជា ២ សែន ។

បុរសកំសត់កាលបើបានប្រាក់ ២ សែនកហាបណៈហើយ ក៏រឭកដល់គុណសេដ្ឋីដែលចេះទាយ ក៏យក ១ សែនកហាបណៈទៅជូនសេដ្ឋី សេដ្ឋីត្រេកអរណាស់បានរៀបផ្សំផ្គុំជាមួយបុត្រីរបស់ខ្លួន លុះផុតអំពីសេដ្ឋីទៅ គាត់ក៏បានទទួលងារជាសេដ្ឋីតទៅ ។

## ២៣- រឿងសីលវរាជកុមារ

(ចាក ម. ឯ.)

(ការមិនប្រទុស្តតប តែងមានជ័យជំនះជាផល)

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងនគរពារាណសី កាលនោះព្រះពោធិសត្វ ទ្រង់សោយព្រះជាតិជាព្រះរាជបុត្រ ព្រះនាមសីលវកុមារ កាលទ្រង់មានព្រះជន្មវស្សា ១៦ ឆ្នាំ ទ្រង់បានដល់នៅទីបំផុតនៃការសិក្សាវិជ្ជាទាំងពួង លុះអំណើះអំពីព្រះរាជបិតាទីវង្គតទៅ ព្រះសីលវកុមារពោធិសត្វ គឺបានសោយរាជ្យសម្បត្តិជួសព្រះរាជបិតា ទ្រង់ព្រះនាមថា ព្រះបាទមហាសីលវរាជ ទ្រង់តាំងនៅក្នុងទសពិធរាជធម៌ គ្រប់គ្រងព្រះរាជអាណាចក្រប្រកបដោយគតិបណ្ឌិត ព្រះអង្គទ្រង់ត្រាស់ឱ្យសាងសាលាឲទាន បរិច្ចាគទ្រព្យ សង្គ្រោះមនុស្សកំព្រាអនាថាទាំងពួង ទ្រង់រក្សាសីល និងសមាទានឧបោសថ មានព្រះទ័យប្រកបដោយខន្តី មេត្តា ករុណា ទ្រង់ញុំាងប្រជាជនឱ្យបានសុខសន្តិភាពទាំងប្រទេស ។

គ្រានោះមានអាមាត្យម្នាក់ ប្រព្រឹត្តខុសនឹងស្រីស្នំក្នុងវាំង អាមាត្យទាំងឡាយដទៃនាំសេចក្តីនោះ ក្រាបទូលព្រះ

ពោធិសត្វ ៗ ស៊ើបសួរឃើញថា ធ្វើខុសពិតមែន ទើបត្រាស់បង្គាប់ឱ្យអាមាត្យនោះមកគាល់ ហើយត្រាស់ថា ឯងជាមនុស្សអន្ធពាល ធ្វើអំពើមិនសមគួរ មិនគួរនៅក្នុងនគររបស់យើង ឯងចូរប្រមូលទ្រព្យសម្បត្តិ និងនាំបុត្រភរិយាឯងទៅនៅទីដទៃចុះ ហើយទ្រង់ឱ្យនិរទេសអាមាត្យនោះចេញអំពីនគររបស់ព្រះអង្គ ។ អាមាត្យនោះចេញចាកដែនកាសីទៅដល់ដែនកោសល ក៏ចូលទៅទទួលធ្វើការរាជការក្នុងដែនកោសលនោះ រហូតបានដំណែង ជាអ្នកបំរើផ្ទាល់ព្រះមហាក្សត្រយ៉ាងជិតស្និទ្ធ ។

ថ្ងៃមួយអាមាត្យនោះបានឱកាស ទើបក្រាបទូលព្រះចៅកោសលថា "បពិត្រព្រះសម្មតិទេព រាជសម្បត្តិនគរពារាណសីសព្វថ្ងៃនេះ ប្រៀបដូចសំបុកឃ្មុំ ដែលគ្រាសចាកមេ ព្រោះព្រះរាជទន់ខ្សោយ គ្មានសមត្ថភាព សូម្បីព្រះអង្គលើកយោធាទៅត្រឹមតែបន្តិចបន្តួច ក៏អាចនឹងយករាជសម្បត្តិនោះបាន" ។

ព្រះរាជកាលទ្រង់ព្រះសវនាពាក្យ របស់អាមាត្យនោះហើយ ក៏ទ្រង់ព្រះកង្ខាថា នគរពារាណសីជារដ្ឋធំណាស់ ហេតុអ្វីអមាត្យនេះថាដូច្នោះ បុរសនេះជាមនុស្សដែលព្រះបាទ

មហាសីវរាជ ឱ្យមកស៊ើបហេតុការណ៍ក្នុង ប្រទេសរបស់អញទេដឹង ? ទើបត្រាស់សួរថា ឯងជាបុរសរបស់ព្រះបាទមហាសីលវរាជឬ ? ឯងនិយាយឧបាយកលទេដឹង ? ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនមែនជាចារបុរសទេ ពាក្យដែលទូលព្រះបង្គំក្រាបទូលនោះ ជាសេចក្តីពិត បើព្រះអង្គមិនទ្រង់ជឿទូលព្រះបង្គំ សូមព្រះអង្គចាត់មនុស្ស ឱ្យធ្វើជាចោរទៅប្លន់បច្ចន្តគ្រាមល្បងមើល ព្រះបាទមហាសីលវរាជ នឹងបញ្ជូនទាហានឱ្យចាប់យកទៅ ហើយត្រឡប់ជាព្រះរាជទានព្រះរាជទ្រព្យ ដល់មនុស្សទាំងនោះមិនខាន ហើយនិងលែងឱ្យត្រឡប់វិញ ព្រះបាទកោសល ទ្រង់ចង់ជ្រាប ទើបទ្រង់ចាត់រាជបុរស ឱ្យធ្វើជាចោរទៅប្លន់បច្ចន្តគ្រាម របស់ព្រះបាទពារាណសី. ពលយោធាចាប់ចោរនោះបាន នាំទៅថ្វាយព្រះបាទមហាសីលវរាជ ព្រះអង្គត្រាស់សួរថា ពួកឯងមកប្លន់បច្ចន្តគ្រាមព្រោះហេតុអ្វី ? ។ ចោរទាំងនោះក្រាបទូលថា ទូលព្រះបង្គំទាំងឡាយ មិនអាចរករបរចិញ្ចឹមជីវិតដោយផ្លូវដទៃបាន ទើបប្រព្រឹត្តិចោរកម្មយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា បើដូច្នេះ ហេតុអ្វីក៏ពួកឯងមិនមករកយើង ចាប់ដើមអំពីនោះតទៅ ពួកឯងកុំនាំគ្នាប្រព្រឹត្តិ

ដូច្នេះទៀត ក្រោយដូច្នេះហើយ ក៏ទ្រង់ព្រះរាជទានទ្រព្យដល់ចោរទាំងនោះ ហើយឱ្យលែងខ្លួនទៅ រាជបុរសទាំងនោះក៏ត្រឡប់ទៅក្រាបទូលព្រះចៅកោសល តាមហេតុសព្វគ្រប់ ព្រះអង្គទ្រង់ត្រិះរិះថា ការពិសោធន៍ត្រឹមតែប៉ុណ្ណេះ មិនអាចដឹងពិតបាន ទើបទ្រង់បញ្ជូនទៅឱ្យប្លន់ដល់កណ្ដាលដែនពលយោធា ក៏ចាប់ចោរទាំងនោះ នាំទៅថ្វាយព្រះបាទពារាណសីទៀត ព្រះអង្គ ក៏ទ្រង់ព្រះរាជទានទ្រព្យ ហើយបង្គាប់ឱ្យលែងដូចមុន ។

ព្រះបាទកោសល ក៏នៅមិនទាន់លើកទ័ពទៅវាយយកនគរពារាណសី ទ្រង់បានបញ្ជូនចោរឱ្យទៅប្លន់ទីក្រុងទៀត ព្រះបាទពារាណសី ក៏ព្រះរាជទានទ្រព្យ បង្គាប់ឱ្យលែងដូចមុនទៀត ។ ក្នុងពេលនោះ ព្រះបាទកោសល ទ្រង់ជ្រាបច្បាស់ថា ព្រះបាទពារាណសី ទ្រង់តាំងនៅក្នុងធម៌យ៉ាងក្រៃលែង ទើបត្រិះរិះថា យើងនឹងទៅដណ្ដើមយករាជសម្បត្តិក្រុងពារាណសី ហើយក៏ទ្រង់លើកទ័ពចេញទៅ ។

ក្នុងកាលនោះ កងទ័ពរបស់ព្រះបាទពារាណសី មានគ្រប់គ្រាន់បរិបូណ៌ ពលយោធាប្រកបដោយសេចក្ដីក្លាហានមិនខ្លាចស្លាប់ ស្ទាត់ជំនាញក្នុងយុទ្ធវិធី បើប្រសិនជាព្រះបាទ

មហាសីលវរាជ ពេញព្រះហឫទ័យឱ្យទៅច្បាំង យករាជសម្បត្តិក្នុងសកលជម្ពូទ្វីប ក៏អាចច្បាំងយកជ័យជំនះមកថ្វាយព្រះអង្គបាន ។ កាលមហាយោធាទាំងនោះ ដឹងថាព្រះចៅកោសលលើកទ័ពមក ទើបនាំគ្នាចូលគាល់ព្រះពោធិសត្វ ក្រាបទូលថា បពិត្រមហារាជ ព្រះបាទកោសលស្តេចលើកទ័ពមក ប៉ងនឹងដណ្តើមរាជរបស់ព្រះអង្គហើយ ទូលព្រះបង្គំទាំងឡាយ នឹងលើកទ័ពទៅតតាំង មិនឱ្យចូលមកបាន នឹងចាប់ព្រះចៅកោសល មកថ្វាយមហារាជទាំងរស់ព្រះបាទមហាសីលវរាជបរមពោធិសត្វត្រាស់ថា ការធ្វើសេចក្តីលំបាកដល់មនុស្សដទៃ ព្រោះតែយើងម្នាក់ មិនគួរទេ, បើព្រះចៅកោសលចង់បានរាជសម្បត្តិរបស់យើង ឱ្យចូលមកយកតាមព្រះហឫទ័យចុះ អ្នកទាំងឡាយកុំលើកទ័ពទៅតឡើយ ។

កាលព្រះចៅកោសល យាត្រាទ័ពឆ្លងរាជសេមាមកដល់ជនបទ បណ្តាអាមាត្យទាំងឡាយ ក៏នាំគ្នាចូលទៅក្រាបទូលដូចមុនទៀត ព្រះអង្គទ្រង់ហាមដូចមុន ។ លុះលើកទ័ពចូលមកដល់ក្រៅនគរហើយ បញ្ជូនព្រះរាជសាសន៍ទៅថ្វាយថា "ព្រះបាទមហាសីលវរាជ នឹងព្រមឱ្យរាជសម្បត្តិ ឬ

ឱ្យច្បាំង" ព្រះពោធិសត្វតបព្រះរាជសាសន៍ទៅវិញថា "យើងមិនប្រាថ្នាច្បាំងនឹងព្រះអង្គទេ ចូរព្រះអង្គយាងមកយករាជសម្បត្តិតាមរាជបំណងចុះ" ។ ចំណែកអាមាត្យទាំងឡាយ ក៏នាំគ្នាចូលទៅក្រាបទូលថា "ទូលព្រះបង្គំ យើងខ្ញុំទាំងឡាយ មិនព្រមឱ្យព្រះចៅកោសល ស្តេចចូលមកក្នុងព្រះនគរបានទេ នឹងនាំគ្នាលើកទ័ពចេញទៅតយុទ្ធចាប់យកព្រះចៅកោសល នាំមកថ្វាយព្រះអង្គឱ្យបាន" ព្រះបរមពោធិសត្វ ក៏ត្រាស់ហាមដោយន័យដូចមុន ហើយបង្គាប់ឱ្យបើកទ្វារព្រះនគរ ទុកព្រះអង្គ ក៏ទ្រង់គង់លើរាជបល្ល័ង្កកណ្តាលចំណោមយ៉ាងណែនណាន់តាន់តាប់ នៃពលយោធារាប់ពាន់ ។

ឯព្រះចៅកោសល ស្តេចលើកពលយោធា ចូលទៅក្នុងព្រះនគរ ពុំឃើញមានសត្រូវសូម្បីតែម្នាក់ ទើបស្តេចចូលដល់ទ្វារព្រះរាជនិវេសន៍ដែលបើស្រាប់ ហើយត្រាស់ឱ្យចាប់ព្រះបាទមហាសីលវរាជ ដែលទ្រង់គ្មានកំហុស ព្រមទាំងយោធា ១ ពាន់នាក់ ឱ្យចងស្លាបសេកនាំទៅកាន់ព្រៃខ្មោច ហើយឱ្យជីកជីកប់ទុក ត្រឹមក ឱ្យលុបដីណែនកុំឱ្យរើខ្លួនរួច ដើម្បីឱ្យចចកខាំស៊ីជាអាហារក្នុងវេលាយប់ ។

ចំណែកអ្នកនគរ កាលបានឃើញអាថ្វារបស់ព្រះចៅកោសលធ្វើបាបព្រះរាជារបស់ខ្លួន ព្រមដោយយោធាទាំងឡាយដូច្នេះ ក៏តក់ស្លុតភ័យខ្លាចនាំគ្នា រត់ទៅក្រៅព្រះនគរសម្ងំក្នុងព្រៃភ្នំក្រំថ្ម ។

ឯព្រះមហាសីលវរាជ កាលព្រះអង្គត្រូវចុះព្រះរាជអាជ្ញាដូច្នោះ ក៏ទ្រង់មិនបានចងអាឃាតនឹងព្រះចៅកោសលឯយោធាទាំងឡាយ ក៏មិនបានទម្លាយព្រះរាជអាណត្តិ ដែលព្រះមហាក្សត្ររបស់ខ្លួនបានត្រាស់ទុក ។ រាជបុរសទាំងឡាយ ក៏នាំព្រះពោធិសត្វ ព្រមទាំងអាមាត្យ ១ ពាន់នាក់ទៅកាន់ព្រៃខ្មោច ជីកកប់ត្រឹមក កប់ព្រះពោធិសត្វ ត្រង់កណ្ដាលហើយ នាំគ្នាត្រឡប់មក ។ ព្រះពោធិសត្វ ត្រាស់ឱ្យឱវាទដល់អាមាត្យទាំងឡាយថា អ្នកទាំងឡាយ កុំចងចិត្តខឹងនឹងព្រះបាទកោសលជាចោរឡើយ ចូរផ្សាយមេត្តាចិត្តក្នុងព្រះបាទកោសលចុះ ។ ដល់ពេលយប់ ចចកទាំងឡាយ ក៏នាំគ្នាមក ដោយបំណងថានឹងស៊ីសាច់មនុស្ស. ព្រះរាជា និងអាមាត្យទាំងឡាយ ក៏ស្រែកឡើងព្រមគ្នា ហ្វូងចចកភ័យខ្លាច នាំគ្នារត់ទៅ. ចចកមិនឃើញមនុស្សដេញតាមមក ក៏នាំគ្នាត្រឡប់មកវិញ. ព្រះរាជា និងអាមាត្យ នាំគ្នាស្រែកដូច

មុនទៀត. ហ្វុងចចកក៏រត់ទៅដោយទំនងនេះដល់បីដង ទើបគិតថា មនុស្សទាំងនេះ ជាអ្នកទោសដែលជាប់ចំណង ក៏មានចិត្តក្លាហានត្រឡប់មកទៀត. សូម្បីព្រះរាជា និង អាមាត្យស្រែកកំឡាចយ៉ាងណា ក៏មិនព្រមរត់ទៅ ចចក ដែលជានាយហ្វូង ក៏លោតចូលទៅខាំព្រះរាជា ចចកជាបរិវារ ក៏នាំគ្នារត់ចូលទៅខាំពួកអាមាត្យ ។ ព្រះបាទសីលវមហា រាជបរមពោធិសត្វ ទ្រង់ឆ្លាតក្នុងកលឧបាយ បានទតព្រះ នេត្រឃើញចចកជានាយហ្វូងរត់ចូលមក ក៏ងើយព្រះស្វរ៉ង ឡើងដូចជាធ្វើឱ្យចចកខាំ ហើយក៏សង្កត់ចចក ដែលប្រុង ប្រៀបនឹងខាំដោយព្រះហនុ (ចង្កា) យ៉ាងនេះជាប់ដូចជា អង្គុយដូច្នេះ ចចកមិនបានរើរួចបាន ក៏ស្រែកឡើងដោយ ភ័យខ្លាចស្លាប់ ចចកជាបរិវារបានឮសំឡេងរបស់នាយហ្វូង ស្រែកដូច្នោះ ទើបគិតថា គេចាប់នាយហ្វូងបានហើយ ក៏នាំ គ្នារត់បោលអស់ទៅ ឯចចកនាយហ្វូងដែលព្រះពោធិសត្វ សង្កត់យ៉ាងខ្លាំងនោះ ក៏ខំកកាយដីដោយជើងទាំងបួន ទាល់ តែខ្វងដីជាច្រើន ព្រះរាជា ទ្រង់ជ្រាបថា ដីធ្លូរល្មមនឹង អង្រៀតព្រះអង្គបាន ហើយទ្រង់ឈប់សង្កត់ ចចកក៏រត់ទៅ ព្រះអង្គ ទ្រង់យោកព្រះកាយទៅវិញទៅមក ហើយលើក

ព្រះហស្តទាំងពីរកាន់មាត់រណ្តៅ យោងព្រះអង្គឡើងមក ក្រាស់ល្ងងលោមចិត្តអាមាត្យទាំងឡាយហើយ ក៏ទ្រង់កាយ ដីយកអាមាត្យពីរណ្តៅឡើងមកទាំងអស់. ព្រះអង្គព្រម ដោយពួកអាមាត្យ ក៏ស្ថិតនៅក្នុងព្រៃខ្មោចនោះ ។

សម័យមួយ មនុស្សទាំងឡាយ បាននាំយកសាកសព ទៅចោលក្នុងព្រៃខ្មោចមួយកន្លែងទៀត ជិតលំនៅរបស់ យក្ខពីរនាក់ យក្ខទាំងពីរនោះកើតវិវាទគ្នាពីរឿងដណ្តើម ខ្មោចស៊ី មិនដឹងចែកគ្នាយ៉ាងណា ក៏នាំគ្នាទៅគាល់ព្រះបាទ មហាសីលវរាជបរមពោធិសត្វ យកទាំងសាកសពនោះទៅ ក្រាបទូលព្រះពោធិសត្វថា បពិត្រធម្មរាជ សូមព្រះអង្គទ្រង់ បែងចែកសាកសពនេះដល់យើងខ្ញុំ ។ ព្រះពោធិសត្វត្រាស់ ថា ម្នាលអ្នកទាំងពីរ យើងនឹងបែងសាកសពនេះឱ្យដល់អ្នក បាន ប៉ុន្តែរូបកាយរបស់យើងមិនស្អាត យើងចង់ងូតទឹកជំរះ កាយឱ្យស្អាតជាមុនសិនសឹមចែកឱ្យ យក្ខក៏នាំគ្នាទៅយកទឹក ដែលគេដងទុកសំរាប់ព្រះចៅកោសល ដោយអានុភាព របស់ខ្លួនមកថ្វាយព្រះអង្គស្រង់ លុះស្រង់ស្រេចហើយ ទៅ នាំយកសំពត់សាដក ដែលគេទុកសំរាប់ព្រះចៅកោសល, នាំយកគ្រឿងក្រអូបសំរាប់ប្រស់ព្រំព្រះកាយ និងនាំយកផ្កា

ឈើផ្សេងៗ ដែលគេបេះទុកក្នុងប្រអប់កែវ និងប្រអប់មាស យកមកថ្វាយ ព្រះអង្គទ្រង់គុបតែងព្រះកាយដោយគ្រឿងប្រដាប់ទាំងនោះហើយ យក្ខទាំងពីរទើបក្រាបទូលសួរថា ព្រះអង្គឱ្យទូលព្រះបង្គំធ្វើអ្វីតទៅទៀត ព្រះបរមពោធិសត្វទ្រង់សំដែងអាការៈឱ្យដឹងថា ព្រះអង្គប្រាថ្នានឹងសោយព្រះក្រយាស្ងោយ យក្ខទាំងពីរ ក៏ទៅនាំព្រះស្ងោយដ៏មានរសផ្សេងៗ មកថ្វាយ និងយកទឹកក្នុងកន្ធីមាស ដែលគេចាក់ទុកសំរាប់ព្រះចៅកោសលមកថ្វាយ ។ ព្រះបរមពោធិសត្វសោយហើយ យក្ខក៏ទៅនាំយកព្រះខ័នមង្គលមកថ្វាយ ព្រះអង្គកាន់ព្រះខ័នយាងទៅកាន់ទីសាកសព ហើយកាត់ពីរកំណាត់ឱ្យផល់យក្ខស្មើគ្នា ទ្រង់លាងព្រះខ័ន ហើយច្រកទៅក្នុងស្រោមវិញ ។

យក្ខទាំងពីរនោះ បានស៊ីសាកសពស្រេចហើយ ក៏មានចិត្តរីករាយ ទូលសួរព្រះពោធិសត្វថា ព្រះអង្គនឹងទ្រង់ឱ្យទូលព្រះបង្គំធ្វើអ្វីតទៅទៀត ព្រះអង្គត្រាស់ថា បើដូច្នេះអ្នកចូរនាំយើង ទៅកាន់បន្ទីព្រះចៅកោសល ដែលជាចោរហើយនាំអាមាត្យយើងទាំងឡាយនេះ ទៅទុកតាមផ្ទះរៀងៗខ្លួន ។ យក្ខទាំងពីរ ក៏នាំព្រះអង្គ និងអាមាត្យទាំងពួងទៅ

ទុកតាមផ្ទះតាមពាក្យបង្គាប់គ្រប់ប្រការ. ព្រះចៅកោសល ទ្រង់ផ្ទំលក់ ព្រះពោធិសត្វ ទ្រង់យកដងព្រះខ័នប្រហារ លើព្រះឧទរព្រះចៅកោសល ដែលទ្រង់ផ្ទំលក់ស៊ប់ ព្រះចៅកោសលស្ទុតព្រះហឫទ័យ តើនឡើងទតព្រះនេត្រឃើញ ក៏ទ្រង់ចាំព្រះពោធិសត្វបាន ដោយពន្លឺប្រទីប ហើយស្តេចក្រោកចាកព្រះបន្ទំទូលសួរថា បពិត្រមហារាជ ក្នុងវេលារាត្រីព្រះរាជនិវេសន៍នេះ បិទទ្វារជិតយ៉ាងមាំ មានពលយោធាចាំយាមយ៉ាងម៉ឺងម៉ាត់ ហេតុអ្វីទើបព្រះអង្គ ទ្រង់យាងមកបាន ? ។ ព្រះបរមពោធិសត្វ ត្រាស់សំដែងហេតុដែលព្រះអង្គស្តេចយាងចូលមក ថ្វាយព្រះចៅកោសលឱ្យបានជ្រាបសព្វគ្រប់ ។ ព្រះចៅកោសលទ្រង់សវនា ហើយនឹកអស្ចារ្យក្នុងព្រះទ័យ ទើបត្រាស់ថា បពិត្រមហារាជ ខ្ញុំជាមនុស្សពាលខ្លៅ មិនដឹងព្រះគុណរបស់ព្រះអង្គ ឯយក្ខជាសត្វថោកទាបស៊ីខ្មោចមនុស្សសត្វជាអាហារ នៅដឹងស្គាល់ព្រះគុណរបស់ព្រះអង្គ គ្រាន់បើជាងខ្ញុំ បពិត្រមហារាជ តាំងពីថ្ងៃនេះតទៅ ទូលព្រះបង្គំ នឹងមិនគិតប្រទុស្តរ៉ាយចំពោះព្រះអង្គទៀតទេ ហើយទ្រង់ចាប់ព្រះខ័នធ្វើសច្ចាប្រណិធាន ញ៉ាំងព្រះពោធិសត្វឱ្យទ្រង់អត់ទោស ហើយ

អញ្ជើញព្រះអង្គឱ្យផ្ទំលើសិរិសេយ្យាសនៈដ៏ខ្ពស់ ចំណែកព្រះអង្គឯង ក៏ទ្រង់ផ្ទំលើព្រះបន្ទំទាបធម្មតា ។ ព្រឹកឡើងទ្រង់បង្គាប់ឱ្យវាយគងទូងភេរី ប្រកាសដល់សេនាមាត្យ និងព្រាហ្មណ៍គហបតីទាំងពួង ឱ្យប្រជុំព្រមគ្នា ហើយត្រាស់ចំពោះប្រជាជនរាប់ពាន់ម៉ឺននាក់ ទ្រង់សូមទោសព្រះពោធិសត្វក្នុងកណ្ដាលបរិស័ទម្ដងទៀត ហើយទទួលយកអាសារថា "ចាប់ដើមអំពីថ្ងៃនេះតទៅ បើអសន្តិសុខផ្សេងៗ កើតឡើងដល់ព្រះអង្គ សូមទ្រង់ទុកភារៈដល់ទូលព្រះបង្គំ ។ នឹងការពាររក្សាថ្វាយដោយខ្លួនឯង សូមព្រះអង្គទ្រង់គ្រងរាជសម្បត្តិដោយសុវត្ថិភាព ព្រះចៅកោសល ស្ដេចទ្រង់ឱ្យដាក់ព្រះរាជអជ្ញាអាមាត្យអន្ធពាល ដែលញុះញង់នោះ ហើយស្ដេចនាំសកលយោធាទៅនគរព្រះអង្គវិញ ។

ចំណែកព្រះមហាសីលវរាជបរមពោធិសត្វ កាលបានទទួលរាជសម្បត្តិវិញយ៉ាងនេះវិញហើយ ទ្រង់សាងកុសលទាំងឡាយ មានទានជាដើមដរាបដល់អស់ព្រះជន្ម ។

## ២៨- រឿងស្តេចដំរី

(ចាត ម. អ.)

(អានិសង្ស នៃការចិញ្ចឹមមាតាដោយគោរព)

កាលពីព្រេងនាយ ព្រះបរមពោធិសត្វរបស់យើង ទ្រង់សោយព្រះជាតិ ជាស្តេចដំរី មានព្រះសរីរកាយសសុទ្ធ មានដំរី ៨០០០ ជាបរិវារ បានចិញ្ចឹមមាតា ដែលចាស់ជរា មានចក្ខុងងឹតទាំងគូរ សម្រេចសម្រាន្តឥរិយាបថក្នុងហេមពាន្តប្រទេស ។ ក្នុងកាលជាខាងក្រោយ ទ្រង់ចេញចោលបរិវារទាំងអស់ ហើយនាំមាតាទៅនៅអាស្រ័យទៀបស្រះមានផ្កាឈូក នាជើងភ្នំឈ្មោះចណ្ឌោរ័ណ ឱ្យមាតាឋិតនៅក្នុងញកភ្នំនោះ ខ្លួនបំរើដោយគោរព ។ សម័យមួយ ព្រានព្រៃម្នាក់នៅក្នុងក្រុងពារាណសី ដើរចូលក្នុងព្រៃ ដើម្បីបរបាញ់សព្វសត្វបក្សា ស្រាប់តែវង្វេងផ្លូវអស់មួយសត្តាហ ក៏យំរៀបរាប់បួរបាច់ហើយដល់ទៅទីនោះ ។ ស្តេចដំរីអាណិតព្រានព្រៃ ក៏ឱ្យឡើងជិះលើខ្នង ទើបនាំត្រឡប់ទៅកាន់ផ្លូវមនុស្សវិញ ។ ឯព្រានព្រៃនោះ ជាមនុស្សអប្រិយជូរជាតិ អបលក្ខណ៍ ទ្រឹស្តីស្នូរទុរយស បានត្រឡប់ទៅដល់ក្រុងពារាណសីវិញ ក៏នាំរឿងនោះទៅថ្វាយព្រះចៅម្ចាស់ផែនដី

ឱ្យទ្រង់ជ្រាប ព្រោះដំរីមង្គលរបស់ព្រះអង្គទើបនឹងស្លាប់ថ្មីៗ ។ ទ្រង់ក៏កើតព្រះហឫទ័យរីករាយត្រេកអរយ៉ាងពន្លឹក ទើបចាត់ហ្មដំរីម្នាក់ឱ្យទៅចាប់ដំរីពោធិសត្វ ហើយនាំយកមកឱ្យនៅក្នុងរោងមង្គលនៅបរមរាជវាំង មិនតែប៉ុណ្ណោះ ទ្រង់បានប្រទានអាហារភោជន មានរសឆ្ងាញ់ពិសារច្រើនមុខដល់ដំរី ។ ឯដំរីមិនព្រមទទួលព្រះរាជអំណោយនោះសោះ ព្រោះខ្លួនមិនបានស្វែងរកចំណីមកចិញ្ចឹមមាតា ដែលនៅក្នុងញកភ្នំ ហើយថ្លែងសេចក្ដីថ្វាយជាព្រះសណ្ដាប់ថា បពិត្រព្រះចៅអធិរាជ ទូលព្រះបង្គំជាអ្នកចិញ្ចឹមមាតា ដែលមានចក្ខុអន្ធការ មាតាទូលព្រះបង្គំ បើរៀរចាកខ្ញុំព្រះអង្គហើយ មុខជាស្លាប់ដោយពិត. ខ្ញុំព្រះអង្គមិនត្រូវការដោយឥស្សរិយយស ដែលកើតក្នុងទីកំបាំងមុខមាតាដូច្នេះទេ. មាតាទូលព្រះបង្គំ អត់អាហារគំរប់ ៧ ថ្ងៃនឹងថ្ងៃនេះហើយ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ក៏ថ្លែងគាថាថា :

**មុញ្ចេថេតំ មហានាគំ យោយំ ភរតិ មាតរំ**
**សមេតុ មាតរា នាគោ សហ សព្វេហិ ញាតិភិ ។**

រីអ្នកចូរលែងដំរីធំនេះ ព្រោះជាសត្វបេះចិញ្ចឹមមាតា មហានាគអើយនៅឱ្យសុខា រួបរួមមាតា និងញាតិសន្ដាន ។

កាលព្រះពោធិសត្វ រួចចាកចំណងនោះហើយ បាន សំដែងគាថាទសរាជធម៌ថ្វាយព្រះរាជាបន្តិច ហើយចេញពីទីនោះ ទៅកាន់សំណាក់មាតាក្នុងថ្ងៃនោះឯង ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងគុណ នៃព្រះពោធិសត្វយ៉ាងក្រៃលែង ទើបចាត់ឱ្យគេធ្វើស្រុកមួយ ក្បែរបទុមស្រះនោះ ហើយតាំងវត្តបដិបត្តិជាប់ជានិច្ច, ពេលជាខាងក្រោយ មាតាព្រះពោធិសត្វធ្វើមរណកាល ទ្រង់ក៏ចាត់ធ្វើឈាបនកិច្ចសរីរៈនោះ ហើយកសាងអាស្រមបទមួយឈ្មោះករណ្ឌកៈ ទើបស្ដេចត្រឡប់ទៅនគរវិញ ។ កាលនោះ ឥសី ៥០០ បរចុះពីភ្នំហេមពាន្តមកនៅក្នុងទីនោះ ។ ព្រះរាជាក៏សុំដំរីឱ្យ ២ នូវវត្តបដិបត្តិដល់ពួកឥសី, កាលដំរីពោធិសត្វស្លាប់ហើយ ទ្រង់ធ្វើរូបប្រៀបដោយថ្ម ប៉ុនរូបពោធិសត្វ ហើយធ្វើសក្ការបូជាជានិរន្ត ។ អ្នកជម្ពូទ្វីបទាំងឡាយ កំណត់កាលមួយឆ្នាំ តែងធ្វើបុណ្យរំលឹកដល់វិញ្ញាណក្ខន្ធដំរីពោធិសត្វម្ដង ។ បុណ្យនោះឈ្មោះថា "**បុណ្យឆ្លងដំរី** " ។

(មហាសំ_សុខនិស្សិតសាលាបាលីជាន់ខ្ពស់)

## ២៥- រឿងអ្នកប្រមឹក

(ចាក ម. អ.)

(ទោសនៃការសេពគប់ជនពាល និងផឹកសុរា)

ពីអតីតសម័យ ក្នុងក្រុងពារាណសី មានមាណពម្នាក់ ជាកូនអ្នករក្សានិច្ចសីល ។ មាណពនោះចូលចិត្តដើរជាមួយនឹងអ្នកលេងទាំងឡាយ ដែលមានវ័យស្រករគ្នា ។ អ្នកលេងទាំងឡាយ តែងបបួលមាណព ឱ្យផឹកស្រា តែមិនព្រមសោះ ថ្ងៃមួយគិតគ្នាថា បើមាណពនោះមិនផឹកស្រា មុខជាមិនចេញថ្លៃឱ្យពួកយើងទេ ហើយក៏រិះរកមធ្យោបាយ ដើម្បីឱ្យមាណពនោះផឹក ទើបបបួលទៅលេងឧទ្យានក្នុងថ្ងៃមហោស្រព ខ្ចប់ទឹកស្រាដែលមានរសជីភ្លៀវក្លា (មេស្រា) ដោយស្លឹកត្របកឈូកទៅផង ហើយធ្វើកិច្ចឱ្យបុរសដទៃ នាំមកឱ្យពោលថា អ្នកទាំងឡាយ ចូរឱ្យផឹកទឹកដោះ ដល់មាណពក្នុងកាលជាទីផឹកទឹក ហើយនាំមកនូវទឹកមានរសផ្អែម ។ អ្នកលេងទាំងនោះ ក៏ចោះទំលាយកញ្ចប់ត្របកឈូកខាងក្រោម ហើយលើកយកមកផឹក ធ្វើអាការៈហាក់ដូចជាផឹកទឹកផ្អែម។ (នេះឧបាយអ្នកលេងបញ្ឆោតមាណព ឱ្យលុះក្នុងតម្រាមនុស្សពាល) ។ មាណពមានចំណង់ជាខ្លាំង ដាច់ចិត្តសូម

ទឹកនោះ ស្មានជាមានរសផ្អែមយកមកផឹក នាំស៊ីសាច់ផង ក៏ស្រវឹងមួយរំពេច ។ កាលស្រវឹងស៊ប់ហើយ មានភ្នែកពីរបើកប្រិម ៗ ទ្រេតចុះទ្រេតឡើង ផ្លូវមួយដើរជ្រែងតែម្នាក់ឯង មិនកោតក្រែងដល់ជនដទៃ ស្មានថាខ្លួនជាមនុស្សគាប់ប្រសើរគ្រាន់បើជាងគេ ស្រែកបន្ទរថា នែភៀនទាំងឡាយខ្ញុំមិនដឹងថាទឹកនោះឆ្ងាញ់ដល់ម្ល៉ឹងសោះ ចុះហេតុអីបានជាអ្នកទាំងឡាយមិនប្រាប់ខ្ញុំផង ហៃអ្នកដ៏ចំរើនទាំងឡាយអើយ ចូរនាំយកទឹកនោះមកទៀត ។ ពួកអ្នកលេងក៏ឱ្យតាមពាក្យសុំ ។ សេចក្តីស្រេកក្នុងស្រា រឹតតែមានខ្លាំងឡើង ៗ ដល់មាណពនោះ (ត្រង់នេះឯង បុរាណពោលថាផុះមេ) ។ មាណពចេះតែសសោះអន្ទងទទូចសុំជារឿយ ៗ ដរាបដល់ពួកអ្នកលេងពោលថា ស្រារស់រលីងហើយ ។ មាណពដោះបំពៀនឱ្យអ្នកលេងទាំងនោះ យកទៅលក់ទិញស្រាមកផឹកស្រវឹងតែជាមួយគ្នា វិលទៅដេកឯផ្ទះវិញ ។ បិតានិយាយប្រដៅអស់ចំណោះ ក៏មិនព្រមស្តាប់សោះ ហើយលាមាណពទៅកាន់សាលវិនិច្ឆ័យ ប្តឹងក្រសួងតុលាការថាអាប្រមឹកនេះ មិនមែនកូនខ្ញុំទេ សូមលោកជាចៅក្រមបណ្តេញវាចេញចុះ ។ បុរសនោះ ត្រូវឪពុក និងក្រសួង

តុលាការបណ្តេញចោលហើយ ដោយស្រវឹងជោគជាំមិន អាចធ្វើការអ្វីកើត ក៏កាន់អំបែងកំបែកដើរតាមច្រកល្ហកផ្ទះ សុំទាយ ជរាបផល់ដេកដួលស្លាប់ នាសំយាបផ្ទះអ្នកដទៃ ។ នេះទោសផឹកស្រា វិនាសទាំងទ្រព្យទាំងជីវិត និងប្រយោជន៍ បរលោក អសោចអស់ទាំងកេរ្តិ៍ឈ្មោះវង្សត្រកូល ខូចពូជ អំបូរអស់ ។

(មហាសំ.សុខនិស្សិតសាលាបាលីជាន់ខ្ពស់)

# ២៦- រឿងភិក្ខុហាល់ថ្ងៃ

(ចាក សុ. តិ.)

(ស្រឡាញ់ខ្លួនឱ្យស្គាល់ធំណឹ ស្គាល់គុណទោសពៃរ៍ទើបបានសុខា)

កាលព្រះសម្ពុទ្ធបរមគ្រូ គង់នៅវត្តជេតពន នាក្រុងសាវត្ថី មានភិក្ខុមួយអង្គល្មោភចង្ហាន់ បានទទួលភត្តក្នុងថ្ងៃមង្គលមួយ ក៏ឆាន់ទាល់តែហាល់ថ្ងៃ ស្ទះខ្យល់ដកដង្ហើមមិនរួច មកពីឆាន់ច្រើនពេក, ភិក្ខុទាំងឡាយ ជ្រួលជ្រើមពេញវត្ត ជួយរកថ្នាំដាក់ឱ្យ ប៉ុន្តែមិនបានជា មួយស្របក់ ក៏សុគតទៅ ។

ព្រះសម្ពុទ្ធទ្រង់ជ្រាបរឿងឆាន់ឥតរបបនេះ ទើបប្រជុំសង្ឃក្នុងធម្មសភា ហើយលើកអតីតនិទានភិក្ខុនោះមកសំដែងថា :

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វ ទ្រង់សោយព្រះជាតិជាសេកបក្សា នៅនាព្រៃហេមពាន្ត ជាស្តេចនៃសេកទាំងឡាយ មានសេកមួយពាន់ជាបរិវារ ហើយមានកូនឈ្មោលមួយ ។ លុះខាងក្រោយមក សេកពោធិសត្វជាបិតានៃកូនសេកនោះងងឹតភ្នែកទាំងពីរ ឯសេកជាមាតាក៏ងងឹតដែរ ។

ការងឹតភ្នែកនេះ ជាទំនៀមរបស់សត្វសេក ព្រោះហើរមានសន្ទុះខ្លាំង តែដល់ចាស់ ត្រូវងឹតភ្នែកជាមុន ។ ឯសេកជាកូន កាលបើមាតាបិតាងឹតភ្នែកហើយ ក៏តែងទៅរកចំណីមកចិញ្ចឹម ។ ថ្ងៃមួយហើរទៅទំលើកំពូលភ្នំខ្ពស់ជិតមាត់សមុទ្រ បានឃើញកោះមួយនៅកណ្ដាលសមុទ្រ ក្នុងកោះនោះមានសុទ្ធតែដើមស្វាយ ដុះទ្រុបទ្រុលមានផ្លែធំៗពណ៌ក្រហមដូចមាស ផ្លែគ្រប់មែកគ្រប់ទង ។ កូនសេកក៏ហើរទៅស៊ីផ្លែស្វាយនោះឆ្អែតហើយ ពាំយកផ្លែទុំល្អពីរបីយកទៅជូនមាតាបិតា ។ ស្ដេចសេកពោធិសត្វ បានស៊ីស្វាយនោះហើយ ស្គាល់ជាក់ជាស្វាយដុះនៅកណ្ដាលកោះ ក៏ហាមប្រាមកូនថា ពាកុំទៅកោះនោះទៀត ព្រោះមានអន្តរាយច្រើនយ៉ាងណាស់ ត្បិតផ្លែស្វាយនោះ មានឱជារសទិព្វស៊ីមិនចេះឆ្អែតទេ ក្រែងបាស៊ីជ្រុលហល់ ហើរមិនបានយូរ, ម្យ៉ាងទៀត ខ្យល់ក្នុងសមុទ្រខ្លាំងៗ ណាស់ ។ ចំណែកសេកជាកូននោះ មិនព្រមស្ដាប់ ដល់ព្រឹកឡើងហើរទៅកោះនោះទៀត ព្រោះញៀនស្វាយ, ទៅដល់ស៊ីស្វាយអស់ជាច្រើនទាល់តែណែនពោះហើយ ពាំពីរបីហើរឆ្លងសមុទ្រមក, ហេតុតែសេកនោះស៊ីឆ្អែតពេក កំពុងតែហើរ ក៏ងុយដេកជា

ខ្លាំង ទប់ពុំបានក៏ដេកលក់ទាំងហើរ ក៏ជ្រុះស្វាយពីមាត់អស់ ដល់ស្វាងឡើងវង្វេងផ្លូវ ចេះតែហើរស្មាន១ ដល់តាំងស្លាប ធ្លាក់ស្លាប់ក្នុងមហាសមុទ្រនោះទៅ ។ ដល់ពេលល្ងាចសេក ជាមាតាបិតាចាំមើលផ្លូវមិនឃើញ ក៏យំសោក ដោយដឹងថា កូនស្លាប់ព្រោះតែទៅស៊ីផ្លែស្វាយនោះឯង ។ កន្លងមកប្អូន ដប់ថ្ងៃ សេកទាំងពីរនោះ ក៏ដាច់ចំណីដាច់ទឹក ស្លាប់ទាំងពីរ ទៅហោង ។

កាលព្រះសម្ពុទ្ធបរមគ្រូ សំដែងនូវអតីតនិទាននេះ ចប់ហើយ ទ្រង់ប្រជុំជាតិថា កូនសេកក្នុងកាលនោះ គឺភិក្ខុ មិនដឹងប្រមាណទាល់តែហាល់ផ្ទៃស្លាប់នេះឯង ឯស្តេចសេក ពោធិសត្វក្នុងកាលនោះគឺតថាគតហ្នឹងឯង ។

## ២៧- រឿងព្រះបាទបទុមរាជ

(ចាក ចូ. ធា.)

(ស្ត្រីក្បត់បើទុកជាស្វាមីបង្ហូរឈាមខ្លួន ឱ្យផឹកក៏នៅតែក្បត់)

កាលកន្លងទៅហើយ ព្រះរាជាក្រុងពារាណសី មានរាជបុត្រា ៧ ព្រះអង្គ ។ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាព្រះរាជបុត្រច្បងព្រះនាមបទុមរាជកុមារ ។ ព្រះចៅក្រុងពារាណសីជាព្រះរាជបិតា ទ្រង់ព្រះចិន្តាថា ព្រះរាជកុមារទាំងនោះមុខជានាំគ្នាសម្លាប់អញ ដណ្ដើមយករាជសម្បត្តិតែសព្វខ្លួនពុំខាន ទើបទ្រង់ព្រះចិន្តាដូច្នេះហើយ មានព្រះបន្ទូលថា ហៃបុត្រសំឡាញ់មាសឪពុកទាំងឡាយ ចាកុំនៅក្នុងទីនេះ ចូរនាំគ្នាចេញទៅនៅក្នុងទីដទៃសិនទៅ ទំរាំតែអំណោះឥតអំពីបិតាទៅ សឹមបានាំគ្នាមកទទួលយករាជសម្បត្តិជាខាងក្រោយចុះ ។ ព្រះរាជកុមារទាំងនោះ ព្រមទាំងភរិយា ក៏នាំគ្នាថ្វាយបង្គំលាព្រះវរមាតាបិតា ហើយចេញអំពីនគរទៅ ។ ទៅដល់ផ្លូវដាច់ស្រយាល ដាច់បាយដាច់ទឹក រកស្បៀងអាហារបរិភោគពុំបាន, ក៏បបួលគ្នាកាប់ភរិយានៃព្រះរាជកុមារពៅជាមុន ចែកសាច់ជា១៣ ចំណែកហើយចែកគ្នាបរិភោគរៀង១ ខ្លួន ។ ឯព្រះពោធិសត្វ ត្រូវ

បានពីរចំណែក គឺព្រះអង្គ ១ ចំណែក ភរិយារបស់ព្រះអង្គ ១ ចំណែក ព្រះអង្គលាក់ទុក ១ ចំណែករៀងរាល់ថ្ងៃ មិនបរិភោគឡើយ បរិភោគតែមួយចំណែកជាមួយភរិយា ។ ឯព្រះរាជកុមារដទៃ ក៏សម្លាប់ភរិយាទាំង ៦ នាក់យកសាច់ចែកគ្នាបរិភោគ តាមលំដាប់រហូតមកដល់ថ្ងៃជាគំរប់ ៦ ។

ចំណែកព្រះពោធិសត្វ ហេតុតែមានព្រះបញ្ញាឈ្លាសវៃ បានទុកចំណែកដែលត្រូវបានខ្លួនតែរាល់ៗ ថ្ងៃ លុះដល់មកថ្ងៃទី ៧ ដែលត្រូវវេនសម្លាប់ភរិយារបស់ខ្លួននោះ ព្រះអង្គនៅសល់ចំណែកទាំង ៦ ដែលបានលាក់ទុកពីថ្ងៃមុន យកមកចែកដល់ព្រះរាជកុមារទាំងឡាយ ហើយទ្រង់ពោលថា ម្នាលអ្នកទាំងឡាយក្នុងថ្ងៃនេះ អ្នកចូរបរិភោគចំណែកទាំងនេះសិនចុះ ចាំដល់ថ្ងៃស្អែកសឹមយកគិតតទៅទៀត ។ លុះដល់វេលារាត្រី ព្រះរាជកុមារទាំងនោះកំពុងដេកលក់ស៊ប់ ក៏នាំភរិយារបស់ព្រះអង្គរត់គេចបាត់ទៅ ។ លុះដើរឆ្ងាយបន្តិចទៅ ភរិយាអស់កំឡាំងមិនអាចដើរទៅទៀតបាន ព្រះពោធិសត្វ លើកភរិយាបញ្ជិះលើស្មា ហើយខំប្រឹងដើរទៅ ដរាបដល់បានផ្លូវដាច់ស្រយាលនោះផុត ។ ឯភរិយាបាននិយាយថា បពិត្រស្វាមី ! ខ្ញុំស្រេកទឹកខ្លាំងណាស់ ។

ព្រះពោធិសត្វ រកទឹកឱ្យភរិយាផឹកពុំបាន ក៏យកព្រះខ័នចោះជង្គង់បង្ហូរឈាមឱ្យភរិយាផឹក ។ ជនទាំងពីរនាក់នោះ ដើរជាលំដាប់ទៅ បានដល់ទី ១ ក៏ធ្វើបណ្ណសាលានៅក្បែរមាត់ស្ទឹងគង្គា ។ កាលនោះ ពួកមនុស្សជាច្រើនចាប់បានចោរម្នាក់ ដែលមានទោសចំពោះព្រះរាជា ហើយនាំយកទៅកាត់ដៃ-ជើង-ត្រចៀក និងច្រមុះឱ្យកំបុតអស់ដាក់ក្នុងពោងពាយបណ្តែតចោលទៅក្នុងស្ទឹងគង្គានោះ បុរសកំបុតនោះចេះតែស្រែកថ្ងូរហៅ ។ ព្រះបរមពោធិសត្វ បានឮសំឡេងនោះហើយ មានមេត្តាអាណិតអាសូរ ចុះទៅក្នុងស្ទឹងរើសយកទៅបណ្ណសាលា រកថ្នាំលាបបិទរុំដំបៅឱ្យ ។

ឯភរិយារបស់ព្រះពោធិសត្វ ខ្ពើមរអើមបុរសកំបុតនោះ មិនដែលក្រឡេកមើលចំឡើយ ព្រះពោធិសត្វ ទ្រង់ថែរក្សាបុរសកំបុតនោះ ទាល់តែបានសះជាដោយស្រួលបួល ។ ដល់ជាស្រួលបួលហើយ, ភរិយារបស់ព្រះពោធិសត្វនោះ ជាស្រីអប្រិយមានគំនិតអាក្រក់ ក្បត់ចិត្តស្វាមី កាលបានឱកាសស្ងាត់ហើយ ក៏នៅជាមួយអាកំបុតនោះទៅ ឥតកោតក្រែងដល់ស្វាមីឡើយ, មិនតែប៉ុណ្ណោះសោត គិតរកកលឧបាយនឹងសម្លាប់ព្រះពោធិសត្វ ជាស្វាមីរបស់ខ្លួនទៀត

ហើយក៏ថ្លែងនិយាយថា បពិត្រអ្នកជាស្វាមី កាលដែលខ្ញុំជិះលើស្វាអ្នក ចេញផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះមកបានឃើញភ្នំ ១ ធំ ខ្ញុំបានបួងសួងបន់ស្រន់ទេវតាថា បើសិនជាខ្ញុំ និងស្វាមីរបស់ខ្ញុំបានរួចរស់ជីវិតកាលណា ខ្ញុំនឹងត្រឡប់មកធ្វើពលិកម្មដល់លោកក្នុងកាលនោះពុំខាន. ឥឡូវនេះដល់ពេលដែលខ្ញុំ នឹងត្រូវធ្វើពលិកម្មបូជាដល់ទេវតាហើយ ។ នាងថាតែប៉ុណ្ណោះ ក៏នាំព្រះពោធិសត្វទៅឯភ្នំនោះ លុះដល់ហើយ ទើបនិយាយថា បពិត្រអ្នកជាស្វាមីខ្លួនអ្នកជាទេវតាដ៏ឧត្តមបំផុត ខ្ញុំនឹងដើរប្រទក្សិណអ្នក ៣ ជុំថ្វាយបង្គំអ្នកជាមុនសិន រួចហើយសឹមធ្វើពលិកម្មបូជាដល់ទេវតាជាខាងក្រោយ ។

ស្រីចង្រៃពោលពាក្យយ៉ាងនេះហើយ ក៏ឱ្យព្រះពោធិសត្វឈរបែរមុខទៅរកជ្រោះភ្នំ ហើយធ្វើអាការៈហាក់ដូចជាមានប្រាថ្នា ដើម្បីថ្វាយបង្គំបូជាដោយផ្កាភ្ញី. ដើរចូលទៅក្រោយខ្នង ច្រានព្រះពោធិសត្វទម្លាក់ទៅក្នុងជ្រោះភ្នំនោះទៅ ។ ក៏មិម្មាត្រឡប់ទៅកាន់សំណាក់អាកំបុតនោះវិញដោយប្រញាប់ប្រញាល់ ។ ឯព្រះបរមពោធិសត្វ ដែលធ្លាក់ទៅក្នុងជ្រោះនោះ ហេតុតែបុណ្យបារមី ដែលព្រះអង្គបាន

សាងទុកពីបុព្វជាតិ ក៏ធ្លាក់ទៅលើស្បាតស៊ុមទ្រុំ លើចុងល្វា ១ ដើមជាឈើឥតបន្ទា តែទ្រង់មិនអាចដើរចុះទៅក្នុងទីដទៃបានឡើយ ក៏បេះផ្លែល្វាបរិភោគ នៅលើប្រគាបឈើនោះឯង ។ ជួនជាពេលនោះ មានស្ដេចទន្សោង ១ ជាសត្វធ្លាប់ឡើងអំពីជើងភ្នំទៅរកស៊ីផ្លែល្វា ។ សត្វទន្សោងនោះ កាលឡើងមកស៊ីផ្លែល្វា ស្រាប់តែឃើញព្រះបរមពោធិសត្វ ក៏មានសេចក្ដីស្និទ្ធស្នាលនឹងព្រះអង្គ ទើបសួរហេតុដែលពោធិសត្វធ្លាក់ទៅក្នុងទីនោះ កាលបានស្ដាប់ដឹងសព្វគ្រប់ហើយ ក៏ឱ្យព្រះបរមពោធិសត្វ អង្គុយនៅលើខ្នងរបស់ខ្លួន ហើយវារឡើងអំពីជ្រោះភ្នំ នាំចេញទៅដាក់ដល់ផ្លូវ ហើយត្រឡប់ចូលទៅកាន់ព្រៃវិញ ។ ឯព្រះបរមពោធិសត្វ ទ្រង់ទៅកាន់បច្ចន្តគ្រាម ហើយនៅក្នុងស្រុកនោះ លុះអំណើះឥអំពីព្រះរាជបិតាទៅ ក៏បានសោយរាជ្យ ទ្រង់ព្រះនាមថា ព្រះបាទបទុមរាជ គ្រប់គ្រងរាជ្យសម្បត្តិជាដំណតព្រះវង្សមក ព្រះអង្គបានសាងសាលាសំរាប់ឱ្យទាន ៦ ខ្នង ហើយចំណាយទ្រព្យក្នុង ១ ថ្ងៃ ៦ សែនកហាបណៈឱ្យទានតែរាល់ៗ ថ្ងៃឥតមានលោះថ្ងៃណាមួយឡើយ ។

កាលនោះ ស្ត្រីកាឡកណ្ណីខាតលក្ខណ៍ បានបញ្ជិះ

អាកំបុតលើស្មា ដើរចេញមកអំពីព្រៃ ទៅរកសូមទានបាយ ចំណីគេសព្វច្រកល្ហក ដើម្បីចិញ្ចឹមរក្សាអាកំបុត កាលបើ មានគេសួរថា បុរសនេះត្រូវជាអ្វីនឹងនាង វាក៏តាំងរៀបរាប់ ប្រាប់ថា យើងទាំងពីរនាក់ជាបងប្អូនជីដូនមួយនឹងគ្នា ពួក ចាស់ទុំបានផ្សំផ្គុំឱ្យ ខ្ញុំក៏ស៊ូតែទ្រាំខំប្រឹងរក្សាស្វាមីរបស់ខ្លួន ទៅ ។ អ្នកនគរបានឮសំឡីសាវស័ព្ទរៀបរាប់កុហកប្រាប់ ដូច្នោះហើយក៏គិតថា នាងនេះជាស្រីល្អ មានសេចក្ដីគោរព ប្ដីណាស់តើ ក៏នាំគ្នាឱ្យបាយបបរជាច្រើន បានឱ្យទាំង កញ្ច្រែងធំមួយ ហើយប្រាប់ថា នាងចូរដាក់ប្ដីរបស់នាងឱ្យ អង្គុយនៅក្នុងកញ្ច្រែងនេះ ហើយទូលដើរទៅ ដើម្បីកុំឱ្យ លំបាកពេក ។ នាងនោះក៏ធ្វើតាមបង្គាប់ដែលគេប្រាប់ ហើយទូលអាកំបុតដើររៀង ៗ ទៅដល់ក្រុងពារាណសី ដាក់អាកំបុតចុះអំពីក្បាល ឈប់សំរាកបរិភោគអាហារចំណី ក្នុងសាលាសម្រាប់ឱ្យទាន របស់ព្រះពោធិសត្វនោះ រួច ហើយលើកអាកំបុតទូលទៅទៀត ។ គាប់ជួនជាពេលនោះ ព្រះបរមពោធិសត្វ ស្ដេចយាងទៅក្នុងរោងទាន ដើម្បីព្រះ រាជទានម្ហូបចំណី ដល់ពួកមហាជនទាំងឡាយផ្ទាល់ព្រះ ហស្ដព្រះអង្គ រួចហើយ ត្រឡប់ចូលទៅកាន់ព្រះរាជនិវេសន៍

វិញ ស្រាប់តែទតឃើញស្រីនោះត្រង់ផ្លូវហើយ ត្រាស់សួរមហាជនទាំងឡាយថា គេទូលអ្វី មនុស្សទាំងនោះក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ស្រីនេះទូលស្វាមីរបស់ខ្លួនដែលកំបុតអវៈយវៈ ជាស្រីមានសេចក្ដីគោរពកោតក្រែងដល់ប្ដីរបស់ខ្លួន ។ ព្រះបរមពោធិសត្វ ក៏ទ្រង់ប្រើរាជបំរើឱ្យទៅហៅនាងនោះមកហើយ ទ្រង់ជ្រាបច្បាស់ថាជាភរិយារបស់ព្រះអង្គពីដើម ទើបទ្រង់ឱ្យគេលើកអាកំបុតនោះចេញអំពីកញ្ជ្រោង ហើយត្រាស់សួរសព្វគ្រប់ ។ នាងនោះ ក៏បានថ្លែងសារស័ព្ទសេចក្ដីក្រាបទូលសព្វគ្រប់តាមន័យ ដែលបានថ្លែងរួចមកហើយក្នុងខាងដើម ព្រះរាជាទ្រង់ត្រាស់សួរបញ្ជាក់ថា នាងឯងក្រែងជាភរិយារបស់បទុមកុមារ ជាធីតារបស់ស្ដេចឯណោះមែនឬ ហើយជាស្រីមានឈ្មោះយ៉ាងនេះ ផឹកឈាមដែលហូរចេញពីខ្លួនអញ ហើយនាងឯងក្បត់ចិត្តអញទៅស្រឡាញ់អាកំបុតនេះ បានប្រានអញទម្លាក់ទៅក្នុងជ្រោះភ្នំមែនឬ ? ឥឡូវនេះនាងឯងស្គាល់អញឬទេ ឬក៏ស្មានថាអញស្លាប់ក្នុងជ្រោះនោះបាត់ទៅហើយ ត្រាស់ដូច្នេះហើយបង្គាប់ពួកអមាត្យថា នែអ្នកទាំងឡាយរាល់គ្នាចូរយកអង្រែមកសំពងសម្លាប់អាកំបុតចង្រៃអប្រិយនេះ ឱ្យ

ឆាប់ៗទៅ ហើយចូរនាំគ្នាកាត់ត្រចៀកច្រមុះ នៃស្ត្រីបាបកាឡកណ្ណីនេះ ឱ្យឆាប់កុំទុកវា ។ ព្រះពោធិសត្វ ដែលទ្រង់ធ្វើអាការៈកំហែងគំរាមយ៉ាងនេះ ដើម្បីគ្រាន់តែបង្អួនសេចក្តីក្រោធប៉ុណ្ណោះទេ ព្រះអង្គមិនបានឱ្យគេធ្វើយ៉ាងដូច្នេះឡើយ ។ រួចហើយព្រះអង្គ ទ្រង់ប្រើរាជអមាត្យ ឱ្យបងកញ្ជ្រែងលើក្បាលនាងនោះដូចដើមវិញហើយ ឱ្យដាក់អាកំបុតទៅក្នុងកញ្ជ្រែងនោះ ទ្រង់និរទេសឱ្យចេញផុតពីព្រំដែនរបស់ព្រះអង្គ ។

## ២៨- រឿងភិក្ខុជាញាតិ និងប្រេត

(ចាក បេ. ខុ.)

(ទោសបាណាតិបាត និងទោសនៃសេចក្ដីកំណាញ់)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានព្រះរាជាមួយព្រះអង្គ ព្រះនាមកិត្តវាស សោយរាជ្យក្នុងនគរនោះ មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមបទុដ្ឋកុមារ ។ ព្រះរាជបុត្រអង្គនេះ បានមើលងាយព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយប្រកាន់មានះឱ្យព្រះបច្ចេកពុទ្ធថ្វាយបង្គំខ្លួន ក៏លោតចុះពីខ្នងដំរីទៅគញ្ឆក់យកបាត្រពីព្រះបច្ចេកពុទ្ធ ដែលកំពុងនិមន្តបិណ្ឌបាត បោកបំបែកជាន់កំទេចចោល ធ្វើឱ្យលោកអត់ចង្ហាន់ ។ ព្រះបច្ចេកពុទ្ធ ក៏និមន្តទៅកាន់ញកភ្នំនន្ទមូលវិញ ។ រឿងនេះសង្ខេបតែប៉ុណ្ណេះ ដល់ព្រះរាជកុមារនោះទីវង្គតទៅ ទៅកើតក្នុងអវចីមហានរកអស់ ៨៤០០០ ឆ្នាំ ដល់អស់ផលកម្ម មកកើតជាប្រេតអត់ឃ្លាន ។ ដល់មកពុទ្ធកាលនេះ បានមកកើតនាត្រកូលអ្នកនេសាទម្នាក់ នៅក្នុងអាណាខេត្តក្រុងសាវត្ថី ឈ្មោះហរិកកុមារ ជាបុគ្គលរលឹកជាតិបាន ។ កុមារនេះ តាំងពីធំដឹងក្ដីឡើងកាលណារលឹកឃើញសេចក្ដីទុក្ខ ដែលខ្លួនទៅកើតក្នុងនរកប្រេត ក៏

កើតសេចក្តីខ្លាចបាបជាទីបំផុត ។ ក្នុងគ្រួសារហើរិកកុមារ មានមុខរបរតែមួយគឺ របរនេសាទត្រី. រាល់តែថ្ងៃមាតាបិតា និងបងៗ នាំកុមារទៅដាក់លបដាក់លាយ ចងសន្ទូចបង់សំណាញ់ជាដើម ។ កុមារចេះតែហែកលបលាយ ចាប់ត្រីរស់ៗ បោះបោលទៅក្នុងទឹក ហើយចេះតែនិយាយថាបាបៗ ទោះបីមាតាបិតាបងៗ ជេស្តីវាយដូចម្តេចក៏នៅតែធ្វើដូច្នោះទៀត ។ បើទុកឱ្យនៅផ្ទះ លួចដុតលបលាយបោលអស់ ។ មាតាបិតាខឹងខ្លាំង ក៏បណ្តេញចេញពីផ្ទះឈប់ឱ្យនៅជាមួយ ។ កុមារក៏ចុះពីផ្ទះដើរតាមផ្លូវទៅ បងប្រុសមានសេចក្តីអាណិត យំសោកអង្វរមាតាបិតាឱ្យហៅមកវិញ តែមាតាបិតាមិនព្រម ។ លុះកុមារដើរឆ្ងាយផុតពីភូមិទៅ បានជួបនឹងព្រះអានន្ទកំពុងនិមន្តបិណ្ឌបាត ក៏ចេះតែដើរតាមដរាបដល់វត្ត ។ លោកសួរដឹងថា មាតាបិតាលះបង់បោលហើយ ក៏បំបួសជាសាមណេរ តាមសេចក្តីសុំរបស់កុមារនោះ ។ ដល់បួសហើយទៅបិណ្ឌបាតមិនបានសោះ ដោយផលបាបកាលកើតជាទុដ្ឋកុមារ វាយបំបែកបាត្រព្រះបច្ចេកពុទ្ធនោះឯង ។ ថ្ងៃមួយព្រះអានន្ទនាំទៅថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបកម្មពៀរមួយឱ្យ ដោយប្រាប់ឱ្យផង

ទឹកប្រគេនភិក្ខុសង្ឃឆាន់ស្រង់រាល់ៗ ថ្ងៃ ពួកភិក្ខុមានសេចក្តីអាណិត ក៏ឱ្យបាយចំណីតាំងពីពេលនោះមក. ដល់អាយុបាន ២០ ឆ្នាំ ព្រះអានន្ទឱ្យឧបសម្បទាជាភិក្ខុ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ជាព្រះអរហន្តមួយក្នុងលោក ។

កាលជាខាងក្រោយមក លោកបាននាំភិក្ខុ ១២ រូប ទៅធ្វើសមណធម៌លើកំពូលភ្នំសានុវាសី ។ ឯមាតាបិតាបងប្អូនគ្រួសារលោក ដល់អស់អាយុទៅកើតជាប្រេត អត់ឃ្លាន នៅចន្លោះភ្នំនោះ មានមាត់តូចប៉ុនក្តិតម្ជុល កើតដំបៅស្អុយរលួយពេញខ្លួន មានសេចក្តីស្រេកឃ្លានខ្លាំង ផឹកទឹកស៊ីបាយមិនកើត ដោយអំណាចទោសបាណាតិបាត និងសេចក្តីកំណាញ់មិនដែលធ្វើបុណ្យទាន ។ ពួកប្រេតទាំងនោះដឹងថា ហិរិកភិក្ខុនៅលើកំពូលភ្នំសានុវាសីនោះត្រូវជាកូន ជាប្អូន ជាបងរបស់ខ្លួនពីជាតិមុន ដល់វេលាលោកនិមន្តចុះទៅ បិណ្ឌបាត ក៏ទៅឈរបង្ហាញខ្លួនដល់លោក ប៉ុន្តែផលកម្ម ដែលបណ្តេញលោកមិនឱ្យនៅជាមួយ កាលលោកនៅជា កុមារនោះ បណ្តាលបិទបាំងមិនឱ្យលោកឃើញ ឬគិតនឹកដល់ឡើយ ។

ថ្ងៃមួយ ប្រេតជាបងប្រុស ដែលឃំសោកសុំអង្វរ

មាតាបិតាកាលដែលមាតាបិតាបណ្តេញលោក ត្រូវបានជួប នឹងលោក ហើយយំសោករៀបរាប់ប្រាប់ថា មាតាបិតា គ្រួសារទាំងអស់ ស្លាប់ទៅកើតជាប្រេតអត់ឃ្លានវេទនា ណាស់ មានមាត់តូចប៉ុក្តិតម្ជុល ។ លោកឮដូច្នេះហើយ មានសេចក្តីសង្វេគ អាណិតអាសូរពន់ពេក ទើបលោកធ្វើ ទានចំពោះសង្ឃ ឧទ្ទិសផលឱ្យដល់ប្រេតទាំងនោះ ផល នោះ ក៏បានតែប្រេតជាបងប្រុសមួយប៉ុណ្ណោះ ដល់ពេល ខាងក្រោយមក ទើបបានដល់ប្រេតជាមាតាបិតា និងប្រេត ជាញាតិដទៃទៀត ។ ប្រេតទាំងនោះ ក៏បានក្លាយខ្លួនជារុក្ខ ទេវតាក្នុងពេលនោះហោង ដោយអំណាចទានដែលហិរិក ភិក្ខុជាព្រះអរហន្តលោកឧទ្ទិសឱ្យ ។

ហិរិកភិក្ខុ និងភិក្ខុទាំង ១២ អង្គនាំគ្នាទៅក្រាបទូល ព្រះមានព្រះភាគ អំពីរឿងប្រេតនោះ, ព្រះមានព្រះភាគ ទ្រង់ប្រជុំបរិស័ទ ហើយសំដែងធម៌ទេសនា ប្រារព្ធរឿង ប្រេតនោះ ដល់ទីបំផុតទ្រង់ប្រកាសអរិយសច្ចធម៌ ៤ ប្រការ មនុស្ស និងទេវតាទាំងឡាយ ដែលបានស្តាប់ ក៏បានសម្រេច មគ្គផលតាមនិស្ស័យរៀងខ្លួន ។

## ២៩- រឿងព្រះបាទអជាតសត្រូវសម្លាប់បិតា

( ចាក អ. សា. )

( សេពគប់ពាល អាចហ៊ានសម្លាប់ឪពុកបង្កើត )

ព្រះបាទអជាតសត្រូវ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ ព្រះចៅម្ចាស់រដ្ឋមគធៈ មានឧបនិស្ស័យវាសនាក្នុងបច្ចុប្បន្ននេះ គួរបានលុះធម្មាភិសម័យ ជាអរិយបុគ្គលថ្នាក់សោតាបត្តិផល តែដោយទតឃើញមហិទ្ធិរិទ្ធិដ៏អស្ចារ្យ ដែលភិក្ខុទេវទត្តប្លែងយកអាសិរ្ពិសឃោរឃៅ មកស្ពាយពាក់ធៀងជាព្រះមកុដសង្វារ ហោះឡើងទៅអាកាសវេហាស៍ ហើយចុះចូលទៅក្នុងព្រះរាជដំណាក់ ទ្រង់អង្គុយលើភ្លៅសួរថា ព្រះរាជកុមារទ្រង់ជ្រះថ្លាចំពោះអាត្មាភាពឬទេ ? ព្រះរាជឱរសមានព្រះទ័យតក់ស្លុតរន្ធត់ក្រៃពេក ញ័រអស់សព៌ាង្គកាយ ឆ្លើយតបទេវទត្តថា លោកម្ចាស់ ខ្ញុំជ្រះថ្លានឹងគុណលោកម្ចាស់ណាស់ ។ ចាប់តាំងពីពេលនោះ ព្រះអង្គម្ចាស់អជាតសត្រូវជារជ្ជទាយាទ ទ្រង់តែងនៅបំរើភិក្ខុទេវទត្តរាល់ព្រឹកល្ងាច ។ ថ្ងៃមួយ ភិក្ខុទេវទត្តចូលទៅរកព្រះអង្គ ហើយនិយាយរ៉ាយរ៉ាប់ពន្យល់ពីអាយុក្ស័យ ថ្វាយជាព្រះសណ្ដាប់ថា បពិត្រកុមារ ពីដើមមនុស្សយើងមានអាយុវែង

ណាស់ តែឥឡូវនេះរាយខ្ញីទៅវិញ ព្រោះហេតុនោះព្រះអង្គ ធ្វើគត់ព្រះវរបិតាទៅ នឹងបានជាស្តេច អាត្មាភាពនឹងធ្វើគត់ ព្រះភគវន្តមុនី ហើយនិងបានជាព្រះពុទ្ធ ។ អំណាចនៃពាក្យ ញុះញង់ មានកម្លាំងអានុភាពជាពន្លឹក អាចឱ្យព្រះរាជកុមារ ជឿតាម ហ៊ានកាន់ព្រះទម្រង់ផុរិកា ចូលទៅក្នុងរាជបុរីទាំង ថ្ងៃត្រង់ បំរុងធ្វើគត់ព្រះវររាជបិតា តែគាប់ជួនជាព្រះជន្ម ព្រះបិតាថ្លៃ បានពួកអមាត្យឃាត់ឃាំងទុក ហើយយក ដំណឹងនោះ ទៅក្រាបបង្គំទូលព្រះរាជាឱ្យស្តេចទ្រង់ជ្រាប។ ព្រះរាជាបានបញ្ជាឱ្យអជាតសត្រូវ ជាព្រះរាជបុត្រចូលមក គាល់ ហើយសួរថា នែកុមារ ! អ្នកចង់សម្លាប់បិតា តើប្រា ថ្នាអ្វី ? បពិត្រព្រះបរមបិតា ទូលព្រះបង្គំប្រាថ្នារាជសម្បត្តិ។ នែកូន ! បើដូច្នោះ អ្នកចូរទទួលយករាជសម្បត្តិពីបិតាចុះ បិតាបំរុងនឹងប្រទានឱ្យកូនយូរយារណាស់មកហើយ តែរក ឱកាសនឹងប្រទានមិនបាន ព្រោះកូនមានវ័យនៅក្មេងណាស់ ទើបតែពេលនេះ កូនកាន់ព្រះទម្រង់ផុរិកាមកប៉ងធ្វើគត់ បិតា ៗ ល្មមបិតាសន្និដ្ឋានបានថា កូនគួរទទួលរាជសម្បត្តិ តំណវង្សបាន ណ្ហើយកូន ! ចូរទទួលយកដោយសេចក្តីរីក រាយចុះ ។ ព្រះរាជឱរសទ្រង់ព្រះចិន្តាថា សេចក្តីត្រេក

ព្រះរាជបិត្ត កើតឡើងដល់រាជ្ញាអញហើយ ទើបនាំដំណឹងនោះទៅប្រាប់ភិក្ខុទេវទត្តដោយសព្វគ្រប់ ។ ទេវទត្តអកុសលពោលថា អើព្រះរាជកុមារ ! ព្រះអង្គសំគាល់ថា អាត្មាអញមានករណីយកិច្ចបប់សព្វគ្រប់ហើយ ដូចជាបុរសពាសស្គរដាក់ចចកខាងក្នុង តាមធម្មតាចចកមុខជារំលាយស្បែកពាសនោះ ចេញរួចជាកំណត់តែពីរបីថ្ងៃទៀត ព្រះបិតាព្រះអង្គទ្រង់ឃើញអាការមិនសមគួរ នឹងពោលលើកទោសព្រះអង្គថា នែកូន ! ឯងគ្រប់គ្រងអាណាប្រជារាស្ត្រមិនវាងវៃទេ ដូច្នេះត្រូវឱ្យរាជសម្បត្តិមកអញវិញ ទំរាំកូនស្ទាត់ជំនាញក្នុងការសោយរាជ្យជាមិនខាន ។ ព្រះរាជកុមារជឿពាក្យទេវទត្តញុះញង់ក្រៃពេកទើបសួរថា បពិត្រលោកម្ចាស់ តើធ្វើដូចម្តេចទើបបានស្រួល ? ព្រះអង្គធ្វើគត់ព្រះបិតាឱ្យស្រេចតែម្តង កុំទទឹមទទាមដល់ថ្ងៃក្រោយ ។ ចេះតែជឿមិនស្គាល់ប្រមាណ ក៏ពោលថា បពិត្រលោកម្ចាស់ បើដូច្នោះមិនគួរខ្ញុំព្រះករុណាធ្វើគត់ដោយសស្ត្រាវុធទេមែនឬ ? ថ្វាយព្រះពរ ត្រូវធ្វើគត់ដោយបង្អត់ព្រះក្រយាសោយ ។ សាធុ ប្រពៃណាស់លោកម្ចាស់ឧបាយនេះ ទើបឡាយព្រះហស្តលេខាបង្គាប់ឱ្យរាជបុរសចាប់បិតាដាក់គុកងងឹត[១] គឺ

---

១- កន្លែងខ្លះជាដាក់ទ្រុងដែរ

ផ្ទះដែលរបំដោយផ្សែងងងឹតទ្រុបទ្រុល ស្មើរតែដកដង្ហើម ចេញចូលមិនកើត ហើយពោលប្រាប់រាជបុរសជារាជអង្គ-រក្សថា អ្នកទាំងឡាយ កុំឱ្យអ្នកណាឃើញឱ្យសោះ ឱ្យតែព្រះវររាជមាតាអញតែមួយព្រះអង្គប៉ុណ្ណោះឃើញបានហើយ ។ ព្រះទេវីជាអាយ៌អគ្គមហេសី ទតយល់ព្រះស្វាមីជាប់ព្រះពន្ធនាគារងងឹតដូច្នោះ មានព្រះទ័យសោកសង្រេងជាពន្លឹក មិនដឹងរិះរកមធ្យោបាយបែបណា ដើម្បីនឹងដោះព្រះភស្តាឱ្យរួចពីពន្ធនាគារនោះ លុះពេលព្រះក្រយាស្ងោយ ទ្រង់ដាក់ភត្តក្នុងផ្តិលមាសធ្វើជាថ្នក់ ចូលយកទៅថ្វាយព្រះរាជា ១ ទ្រង់សោយព្រះក្រយាសោយនោះ ក៏មានព្រះជន្មតទៅទៀត ។ ស្តេចអសប្បុរសងប់ក្នុងពាក្យញុះញង់ បណ្តោយឱ្យមោហ៍ចាំង លែងស្គាល់បិតាខ្លួន សួររាជបុរសថា បិតាអញមានព្រះជន្មរស់នៅដោយហេតុដូចម្តេច ? លុះឮពាក្យទូលតបដូច្នោះហើយត្រាស់បង្គាប់ថា នែប្រស្នែង បើមាតាខ្ញុំដាក់ភត្តក្នុងថ្នក់ហើយចូលទៅ កុំឱ្យចូលឱ្យសោះ ។ ព្រះទេវីដាក់ភត្តក្នុងព្រះមោលី យកចូលទៅថ្វាយដូចលើកមុន ។ ដំណឹងនោះ ក៏ជ្រាបដល់ព្រះបាទអជាតិសត្រូវ ទ្រង់បង្គាប់ថា បើព្រះមាតាចងព្រះមោលីចូលទៅ អ្នកទាំងឡាយកុំឱ្យ

ចូល ។ ព្រះទេពីទ្រង់ដាក់ភត្តក្នុងព្រះសុពណ៌ពាតទុក ហើយ បិទមកវិញ ទើបពាក់យកចូលទៅថ្វាយព្រះភស្តាដូចលើក មុនទៀត ។ ព្រះបាទអជាតសត្រូវ ទ្រង់ជ្រាបដំណឹងនោះ ហើយ ហាមឃាត់មិនឱ្យព្រះមាតាពាក់ស្បែកជើងចូលទៅ គាល់ឡើយ ។ គួរអាណោចអធ័មពន់ពេក ! ព្រះនាងទេវី ធ្វើឧបាយបែបណាៗ គេចេះតែដឹង ម្ល៉ោះហើយ ក៏គ្មានតឹង ផ្លូកផ្ញើសស្នើរនឹងថ្វាយព្រះឱរា ព្រោះអាណិតព្រះភស្តា យ៉ាងក្រៃលែង ជាលើកទី ៤ ទ្រង់ស្រង់ជម្រះព្រះកាយ ដោយទឹកក្រអូបស្អាតបាតហើយ យកអាហារមានរស ៤ មុខមកលាបលនស្រឡាបពេញព្រះសរីរកាយ ទើបទ្រង់ គ្រឿងអាភរណៈ យាងដោយព្រះបាទទទេចូលទៅគាល់ព្រះ ភស្តា ។ គួរអាណិតព្រះរាជាជាខ្លាំង ទ្រង់ជាក្សត្រសុខុមាល ជាតិ ធ្លាប់សោយព្រះក្រយាស្ងោយដ៏វិចិត្រ ធ្លាប់ផ្ទំលើព្រះ ទែនក្រឡាបន្ទំជាសុខសាន្ត សម្រាន្តសម្រួលព្រះកាយដោយ ស្រីស្នំស្រីង្គារ គាល់ហៅបំរើត្រៀបត្រាពេញព្រះរាជ ដំណាក់ ឥឡូវទ្រង់ធ្លាក់ព្រះអង្គទៅនៅក្នុងគុកងងឹត ផ្ទំលើ ក្រឡាប្រថពី សោយអាហារមិនគប្បី កាលឃើញព្រះទេវី ចូលទៅ ទ្រង់មានព្រះទ័យសោមនស្សជាពន្លឹក ឱបព្រះសិរ

សាលិទ្ធព្រះសរីរកាយព្រះនាង យករសជាតិអាហារមកផ្សព្វផ្សាយក្នុងព្រះអង្គកាយទ្រង់ ដើម្បីឱ្យសរីរបន្តប្រព្រឹត្តទៅបានស្រួលតាមភាពជាអរិយបុគ្គល ហើយលាន់ព្រះឱស្ឋថា សេចក្ដីស្លាប់ដោយព្យាយាមរបស់ខ្លួនមិនគួរទេ ព្រោះថាព្រះអរិយសាវៈទាំងឡាយ មិនដែលសម្លាប់ខ្លួនដោយខ្លួនឯងឡើយ ។ ព្រះរាជាមានព្រះជន្មតទៅទៀត ព្រោះបានលិទ្ធយកឱជារសពីព្រះកាយព្រះនាងទេវី ជាព្រះអគ្គមហេសី ។ ព្រះបាទអជាតសត្រូវ ទ្រង់សួរដំណឹងនោះជ្រាបសព្វគ្រប់ហើយ ក៏ប្រាប់រាជសេវកថាចាប់ពីពេលនេះទៅ អ្នកទាំងឡាយកុំឱ្យមាតាខ្ញុំចូលទៅគាល់ព្រះបិតាឱ្យសោះ, បើអ្នកណាឱ្យចូល អ្នកនោះត្រូវទទួលទោសជាទម្ងន់ដោយពិត ។ ព្រះទេវីត្រូវពួកអាមាត្យឃាត់មិនឱ្យចូលទៅ ទ្រង់មិនដឹងលៃបែបណា ឃើញថាអស់ផ្លូវសង្ឃឹមក្នុងការជួយស្រោចស្រង់ព្រះជន្មព្រះភស្ដា នឹងពោលអង្វរករយ៉ាងណា ក៏ព្រះបាទអជាតសត្រូវមិនយល់ព្រម ម្ល៉ោះហើយទ្រង់យាងព្រះបាទាទៅប្រថាប់ក្បែរទ្វារគុក ទ្រង់ព្រះកន្សែងរៀបរាប់ថា :

បពិត្រព្រះភស្ដា ពិម្ពិសារម្ចាស់ប្ដូនអើយ
កម្មតាមមកផ្ដល់ហើយ អម្ចាស់អើយរងវេទនា ។

លំបាកចិត្តស្ទើធ្លាយ ឈឺសព្វកាយម៉ាយចិន្តា
ឃើញអង្គព្រះភស្តា ជាប់ពន្ធនាប្អូនសឹងក្ស័យ ។
ធ្វើម្ដេចកម្មព្រះអង្គ ដែលទ្រង់សាងណាក្សត្រថ្លៃ
វេទនាក្លាន់ពេកក្រៃ អ្នកផងទៃជួយមិនបាន ។
ឱះឱព្រះភស្តា ខ្ញុំទស្សនាព្រះរូបប្រាណ
ឃើញអង្គម្ចាស់ក្សត្រក្សាន្ត ធ្វើម្ដេចបានចូលទៅជិត ។
ប្អូនឃើញព្រះរូបទ្រង់ ជាពូជពង្សវង្សវីជិត
ជាប់ក្នុងគុកងងឹត ជាបំផុតពេលនេះហើយ ។
សូមក្រាបទៀបបាទា លើកហត្ថាមិនព្រងើយ
ផ្គុំប្រាមទាំងដប់ហើយ អម្ចាស់អើយប្អូនសូមទោស
សូមអង្គព្រះចមពល ស្រស់និមលអត់កំហុស
ដែលប្អូនប្រព្រឹត្តខុស នឹងព្រះអង្គព្រះភស្តា ។
ព្រះនាងសូមអភ័យ នឹងក្សត្រថ្លៃម្ចាស់សិរសា
ស្រេចថ្វាយបង្គំលា ទៅដំណាក់ព្រះនាងវិញ ។
ជេងជោងអស់កាយា ចុកឈឺផ្សាទុក្ខទោម្និញ
យាងទៅប្រាសាទវិញ ស្ទើរនឹងក្ស័យក្នុងថ្ងៃនោះ ។

ចាប់ពីពេលនោះ ព្រះបាទពិម្ពិសារទ្រង់ឥតមានព្រះក្រយាស្ងោយទេ តែអាចញ៉ាំងព្រះជន្មទ្រង់ឱ្យប្រព្រឹត្តទៅបាន

ដោយការចង្ក្រមណ៍ ។ អត្តភាពរបស់ទ្រង់ នឹងរិតតែរុងរឿង ឡើង ។ ព្រះបាទអជាតសត្រូវសួររាជបុរសថា បិតាអញរស់ នៅដោយអាការយ៉ាងណា ? ក្រាបទូលដំកល់លើត្បូង រស់ នៅដោយការចង្ក្រមណ៍, ទើបទ្រង់បញ្ជូនខ្មាន់ព្រះកេសទៅ បង្គាប់ថា អ្នកទាំងឡាយ ចូរយកកាំបិទដ៏មុតទៅវះ អង្គុន់ ព្រះបាទបិតាអញ ហើយយកអំបិល និងប្រេងលាបឱ្យសព្វ យកអុសគគីធំៗ មកគរដុតជារងើក ហើយយកជើងបិតាអញ ទាំងសងខាងទៅឆ្អើលើរងើកភ្លើងនោះ ។ ខ្មាន់ព្រះកេសទាំង ឡាយ យកដំណឹងនោះទៅក្រាបទូលព្រះបាទពិម្ពិសារ ទ្រង់ ក៏ពោលថា អ្នកទាំងឡាយ ចូរធ្វើផ្តាប់ព្រះទ័យព្រះរាជាអ្នក ចុះ កុំញញើតឱ្យសោះ ។ ពួកខ្មាន់ព្រះកេសពោលម្តងទៀត ថា បពិត្រព្រះសម្មតិទេព សូមស្តេចប្រថាប់ចុះ, ទូលព្រះ បង្គំទាំងឡាយនឹងធ្វើអាជ្ញាដល់ព្រះអង្គ, សូមទ្រង់កុំខ្ញាល់នឹង ទូលព្រះបង្គំ ព្រោះសុទ្ធតែជាអ្នកទទួលព្រះរាជអជ្ញាផ្ទាល់ ទាំងកម្មដ៏លាមកនេះសោត ក៏មានសភាពមិនសមគួរដល់ ព្រះអង្គដែលជាស្តេច ប្រកបដោយធម៌សោះ លុះពោលរួច ហើយ ក៏ចាប់ព្រះបាទាព្រះរាជាវះអង្គុន់ ហើយប្រឡាក់ ដោយអំបិល និងប្រេង ទើបយកអុសគគីរមកគរដុតរោល

កំដៅ ។ ព្រះបាទពិម្ពិសារ មានព្រះកាយពលឈឺផ្សាដោយកម្មនោះណាស់ ព្រោះស្បែកព្រះបាទទាំងគូរដែលគេវះចេញឈាមថ្មីៗ ហើយត្រូវគេយកអំបិល និងប្រេងមកប្រឡាក់ ទាំងដុតរោលដោយរងើកភ្លើងទៀត រឹតតែឈឺផ្សាក្រៃលែង គួរអាសូរព្រះអង្គណាស់ ! បើអត់អាហារក៏អត់ទៅចុះមិនថាទេ ថែមទាំងគេវះអង្គន់ព្រះបាទមិនឱ្យដើរចង្រ្កមរួចទៀត រងទុក្ខវេទនាជាមហិមា តែព្រះអង្គជាអរិយបុគ្គល មិនអើពើនឹងកម្មនោះឡើយ ។ សេចក្ដីថា កាលពីបុរេជាតិ ព្រះរាជាស្ដេចពាក់ទ្រនាប់ព្រះបាទជាន់ប្រាង្គចេតិយ ជាបូជនដ្ឋានដែលគេរោយរាយ ដោយផ្កាមានក្លិនក្រអូបជាដើម. អាចារ្យពួកខ្លះពោលថា ទ្រង់ជាន់កន្ទេលផែង ដែលគេក្រាលសម្រាប់ឱ្យភិក្ខុសង្ឃគង់ នេះជាបុព្វកម្មដែលទ្រង់រងក្នុងបច្ចុប្បន្ន ។ ព្រះរាជារងវេទនាជាខ្លាំង ក៏លាន់ព្រះឱស្ឋថា ឱព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ! ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ ! ទើបសោយព្រះទីវង្គតទៅ កើតជាយក្សឈ្មោះជនវសភជារាជបំរើព្រះបាទវេស្សវ័ណ នាឋានចាតុម្មហារាជិកា ដោយអំណាចនៃសេចក្ដីត្រេកអរ ដែលទ្រង់សន្សំហើយអស់កាលដ៏យូរ ព្រោះទ្រង់ធ្លាប់កើតក្នុងឋានចាតុម្ម

ហារាជិកានោះច្រើនជាតិមកហើយ ។ ក្នុងខណៈនោះ មានរាជបុរសពីរនាក់រត់មកក្រាបបង្គំទូលព្រះបាទអជាតសត្រូវដំណាលគ្នាថា បពិត្រព្រះសម្មតិទេព ព្រះរាជបុត្រព្រះអង្គប្រសូត្រហើយ, បពិត្រព្រះសម្មតិទេព ! ព្រះបរមរាជបិតាព្រះអង្គសោយទីវង្គតហើយ ។ គ្រាន់តែសណ្ដាប់ពាក្យទាំងពីរម៉ាត់នេះហើយ ព្រះអង្គក៏សន្ធប់ស្ងួន្យឈឹងព្រះស្មារតី លុះភ្ញាក់ព្រះអង្គកាលណាក៏លាន់ព្រះឱស្ឋស្ងួរទាំងព្រះជលនេត្រហូរស្រោក់ថា ឱ ! ព្រះបិតាអាត្មាអញ ទ្រង់ផ្សាយព្រហ្មវិហារធម៌មកលើខ្លួនអញជាច្រើន ទ្រង់ស្រឡាញ់អញដូចដូចជា ស្រឡាញ់ព្រះរាជឱរសផ្សាយព្រហ្មវិហារទៅលើឱរសដូច្នោះដែរ លុះបន្ទោរបង់សេចក្ដីសោកហើយ ទ្រង់ក៏ចាត់ចែងធ្វើពិធីព្រះសពសំស្ការថ្វាយព្រះភ្លើង ធ្វើឈាបនកិច្ចតាមទំនៀមព្រះរាជវង្សក្នុងពេលនោះឯង ។

ក្នុងកាលជាខាងនាយ ភិក្ខុទេវទត្តប្រឹក្សាជាមួយនឹងព្រះអង្គតាមន័យ ដែលយើងពោលរួចមកហើយ ធ្វើកម្មដ៏លាមកចាប់តាំងពីឱ្យខ្មាន់ធ្នូទៅសម្លាប់ព្រះសាស្ដា ដរាបដល់បំបែកសង្ឃ គ្រាតែផែនដីស្រូបឱ្យទៅកើតក្នុងមហានរកឈ្មោះអវចី ។ ព្រះរាជា ទ្រង់ជ្រាបដំណឹងនោះហើយ មាន

ព្រះទ័យតក់ស្លុតរំជួលក្រៃពេក ដោយព្រះតម្រិះថា ផែនដីមុខជាស្រួបអាត្មាអញទៀតជាមិនខាន ព្រោះអញចូលដៃនឹងទេវទត្ត. ព្រះតម្រិះប៉ុណ្ណេះ ធ្វើឱ្យព្រះអង្គសោយរាជ្យមិនសប្បាយ ផ្ទំលើព្រះទែនក្រឡាបន្ទំមិនស្រួល ចេះតែក្តៅអន្ទះសាញ់រអស់ព្រះកាយ ហាក់ដូចប្រេតដែលកម្មតាមឱ្យផល ។ មែនពិត ព្រះរាជាអង្គនេះ ទ្រង់ពិចារណាបិតុឃាតកម្មដែលព្រះអង្គបានធ្វើ ក៏ចេះតែភិតភ័យភាំងព្រះស្មារតី ដូចជាត្រូវផែនដីស្រូបទាំងរស់ផង ដូចជាត្រូវអណ្តាតភ្លើងអវចីឆាបឆេះទាំងរស់ផង ដូចជាផ្ទំផ្ងាលើផែនដី ហើយត្រូវបុគ្គលយកដែកស្រួចដ៏រន្ទាលច្រាលឆ្អៅ មកចាក់ទំលាយព្រះកាយទាំងរស់ ។ សូម្បីការស្ងប់ស្ងាត់មួយស្របក់ ក៏មិនមានចេះតែញាប់ញ័រដូចជាមាន់ដែលគេវាយហើយ ។ ថ្ងៃពេញបូណ៌មីខែកត្តិក ព្រះចន្ទមានរស្មីដ៏រុងរឿងភ្លឺចិញ្ចាចចាំងមកពីទិសបូណ៌ ដូចជាកំទេចពេជ្រ ជះពន្លឺពាសមកលើវត្ថុ ដែលមានប្រចាំលោកសន្និវាស, ព្រះបាទអជាតសត្រូវ ប្រថាប់ក្នុងព្រះរាជដំណាក់មិនសុខសោះ ចេះតែអន្ទះងន្ទែងស្ទះចុះឡើង ប្រហែលជាម៉ោង ៩ យប់ ពេលព្រះចន្ទរះផុតចុងព្រឹក្សានានា ទ្រង់ក៏មីម្នាឱ្យប្រជុំអស់អ្នកប្រាជ្ញរាជបណ្ឌិត នៅមុខ

ព្រះបរមរាជវាំង ហើយស្ដេចឡើងទៅឈរប្រថាប់លើប៉ម ប្រកាសសួរអាណាប្រជានុរាស្ត្រថា អ្នកណាអាចដកសរមាន ពិសដ៏ក្លៀវក្លាពីទ្រូងខ្ញុំបាន ? ឬក៏មានសាស្ដាអង្គណាមាន សមត្ថភាពជួយខ្ញុំបាន សូមអ្នកទាំងឡាយ នាំខ្ញុំទៅជួបនឹង សាស្ដាអង្គនោះមួយភ្លែត ។ ពួកអមាត្យខ្លះក្រាបទូលថា មានតែគ្រូឈ្មោះបូរណកស្សបៈ ខ្លះថាគ្រូឈ្មោះនិគ្គណ្ឋនាដ បុត្រ, ខ្លះថាគ្រូឈ្មោះសញ្ជយវេលដ្ឋបុត្រ, ខ្លះថាគ្រូឈ្មោះ បកុធកច្ចាយនៈ ខ្លះថាគ្រូឈ្មោះអជិតកេសកម្ពលៈ, ខ្លះថាគ្រូ ឈ្មោះមក្ខលិគោសាល ទើបអាចដកសរនេះបាន ។ ព្រះរាជា ក៏យាងទៅតាមជជីកសួររកគល់នៃសេចក្ដីទុក្ខមិន ឃើញសោះ ទ្រង់សន្និដ្ឋានថា មិនមានសារៈអ្វីដោយគ្រូទាំង ៦ រូបនេះ ទើបត្រឡប់មកវិញ ជាលើកក្រោយជីវកកោមារ ភច្ច ក្រាបទូលថា មានតែព្រះសម្មាសម្ពុទ្ធបរមគ្រូមួយអង្គ គត់ប៉ុណ្ណោះ ទើបអាចដកសរនេះរួច ។ និមិត្តតែឮពាក្យថា ព្រះសម្មាសម្ពុទ្ធ ព្រះបាទអជាតសត្រូវ ព្រឺព្រះសម្បុរខ្លាក ១ អស់វារៈ ៣ ដង ទើបសួរថា ឥឡូវនេះព្រះសម្មាសម្ពុទ្ធដ៏ ទ្រង់ព្រះភាគ ស្ដេចប្រថាប់ក្នុងទីណា ? ក្រាបទូលក្នុងអម្ពវ នារាមឱទ្យាន ជាព្រះកេរ្តិ៍ ដែលព្រះរាជបិតាព្រះអង្គទ្រង់

ប្រទានដល់ល្អងធូលីព្រះបាទ ។ ព្រះរាជាបង្គាប់ឱ្យហួយកដំរីមង្គលមក ទ្រង់ឡើងប្រថាប់លើខ្នង ឱ្យកុមារពេត្យឡើងជិះជាមួយព្រះអង្គ ហើយទៅកាន់អម្ពវនារាមនោះ លុះទៅដល់កំពែងវត្ត ព្រឹសម្បុរខ្វាក១ បីផងទៀត ទាំងដំរីទុកជាហួបង្ខំយ៉ាងណា ក៏មិនព្រមចូលសោះ ។ ឃើញហេតុជាអស្ចារ្យដូច្នោះ ព្រះរាជាសួរកុមារពេត្យថា ម្តេចក៏ដំរីមិនព្រមចូល ? ក្រាបទូលអំណាចព្រះបារមីនៃព្រះសម្ពុទ្ធជាម្ចាស់ទើបដំរីមិនហ៊ានចូល ។ ធ្វើដូចម្តេចទើបយើងចូលទៅគាល់ព្រះអង្គបាន ? ក្រាបទូល សូមទ្រង់ចុះពីខ្នងដំរី ហើយដោះព្រះសុពណ៌បាទ ទុកចេញទើបចូលទៅគាល់បាន ។ ព្រះរាជាលាន់ព្រះឱស្ឋថា ឱ ! ព្រះអរហន្តសម្មាសម្ពុទ្ធ សូមព្រះអង្គជួយខ្ញុំផង ទើបចុះពីខ្នងដំរីដោះស្បែកជើង ហើយលើកដៃប្រណម្យ យាងចូលទៅថ្វាយបង្គំព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃដោយស្រួលបួល ក៏ប្រថាប់ក្នុងទីសមគួរ ត្រាស់សួរបញ្ហាដែលមានក្នុងសាមញ្ញផលសូត្រ នឹងព្រះសាស្តា ។ ព្រះភគវា ទ្រង់ជ្រាបថា ព្រះបាទអជាតសត្រូវ ស្តាប់ធម៌ព្រះអង្គហើយ និងបានអានិសង្សច្រើន ទើបទ្រង់ឆ្លើយដោះប្រស្នានោះថា ។

ព្រះរាជាអង្គនេះ តាំងពីធ្វើគត់ព្រះវរបិតាមក ផ្ទុំមិនលក់សព្វអហោរាត្រី ព្រោះកាលបើធ្មេចព្រះនេត្រ ដោយបំណងចាក់អាត្មាអញនឹងដេក ក៏ភ្ញាក់ឡើងញាប់ញ័រ តែថ្ងៃនេះព្រះអង្គមក តថាគតនឹងផ្ទុំលក់ចាប់តទៅ បានស្តាប់ធម៌ទេសនានេះហើយ តាំងធ្វើសក្ការៈដល់ព្រះរតនត្រ័យទៀត ឈ្មោះថាបានសម្រេចសទ្ធាជាលោកិយ បុគ្គលដទៃស្មើដោយព្រះរាជា (ដែលធ្វើគត់ព្រះបិតា) អង្គនេះ នឹងមិនដល់ (សទ្ធាជាលោកិយឡើយ) លុះចប់ធម៌ទេសនានឹងដំកល់ក្នុងព្រះត្រ័យសរណៈ, ហេតុតែព្រះរាជាអង្គនេះ ដល់ព្រះត្រៃសរណៈ ហេតុនោះ សាសនាតថាគត ជាសាសនាធំ. ព្រះរាជាអង្គនេះកើតក្នុងខ្ទះល្ហិន ធ្លាក់ចុះទៅក្រោមដល់បាតខ្ទះបីម៉ឺនឆ្នាំ អណ្តែកមកមាត់ខ្ទះវិញបីម៉ឺនឆ្នាំដូចគ្នា ទើបរួច ដូចជាអ្នកដែលដួលធ្លាក់ចុះ. ទើបរួចចាក់អាផ្សដោយត្រឹមតែផ្កាមួយក្តាប់ដូច្នេះ, ឯក្នុងព្រះរាជាអង្គនេះ នឹងបានជាព្រះបច្ចេកពុទ្ធនាមជីវិតវិសេស ទើបបរិនិព្វាន ។

ចប់ធម៌ទេសនា ព្រះរាជាសាបសូន្យចាកសោតាបត្តិផល ព្រោះឧបនិស្ស័យមគ្គ គឺអនន្តរិយកម្មផ្តាច់បង់ហើយ បានសម្រេចត្រឹមតែអត្តសន្និយ្យាតនត្រៃសរណៈ ។ ប្រសិន

បើទ្រង់មិនសម្លាប់ព្រះបិតាទេ នឹងបានសម្រេចសោតាបត្តិផលក្នុងជាតិនេះ តែទ្រង់ចូលដៃនឹងបាបមិត្ត ក៏អន្តរាយចាកមគ្គទៅ ។ ព្រះរាជាដល់សរណៈហើយ ប្រកាសទោសដែលខ្លួនធ្វើចំពោះព្រះភគ្គព្រះសាស្តា ទើបសូមខមាទោសនឹងព្រះសាស្តា ហើយក្រោកចាកអាសនៈធ្វើប្រទក្សិណ ៣ ជុំផ្គងអញ្ជលីឭដ៏ព្រះសិរ យាងថយក្រោយដរាបមើលព្រះសាស្តាលែងឃើញ ក៏ក្រាបចុះផែនដី ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានជៀសចេញទៅ ។ សង្ខេបរឿងនេះប៉ុណ្ណេះចុះគ្រាន់តែលើកមកនិយាយបញ្ជាក់ឱ្យឃើញ ទោសសេពគប់មនុស្សពាលមានទម្ងន់ណាស់ អាចហ៊ានសម្លាប់បិតារបស់ខ្លួន នាំឱ្យឧបនិស្ស័យវាសនា ដែលខ្លួនសាងសន្សំពីបុព្វជាតិក៏ហិនហោចដែរ ដូចនិទស្សន៍ន័យខាងលើនេះស្រាប់ ។

(មហាសំ-សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៣០- រឿងព្រានសន្ទូច

(ចាក ធ. ខុ.)

(មិនល្អដោយឈ្មោះទេ លុះតែត្រាស់ដឹងធម៌ទើបល្អ)

សេចក្ដីដំណាលថា ក្នុងក្រុងសាវត្ថី មានព្រានសន្ទូចម្នាក់ឈ្មោះអរិយៈ ។ ថ្ងៃមួយព្រាននោះយកសន្ទូចទៅស្ទូចត្រី ក៏បានជួបព្រះសាស្ដា មានភិក្ខុសង្ឃចោមរោមជាបរិវារត្រាច់បិណ្ឌបាតនាស្រុកខាងជើងក្រុងសាវត្ថី ហើយដាក់ផងសន្ទូចចុះឈរទ្រើងក្នុងទីនោះ ។ ព្រះសាស្ដាស្ដេចប្រថាប់ក្បែរព្រាននោះ ត្រាស់សួរព្រះថេរទាំងឡាយ មានព្រះសារីបុត្រជាដើមថា អ្នកឈ្មោះអ្វី ? ព្រះថេរក៏ក្រាបទូលព្រះនាមរៀងខ្លួនថា ខ្ញុំព្រះអង្គឈ្មោះសារីបុត្រ ខ្ញុំព្រះអង្គឈ្មោះមោគ្គល្លាន ។ ព្រានសន្ទូចគិតថា ព្រះសាស្ដាសួរឈ្មោះសាវកទាំងឡាយហើយ នឹងសួរឈ្មោះអញទៀតមិនខាន ។ ព្រះសាស្ដាដឹងចិត្តព្រាននោះហើយត្រាស់សួរថា នែឧបាសកអ្នកឯងឈ្មោះអ្វី ? បពិត្រព្រះអង្គដ៏ចំរើនខ្ញុំឈ្មោះអរិយៈ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាសក ជនអ្នកសម្លាប់សត្វទាំងឡាយមិនឈ្មោះថា អរិយៈទេ ឯព្រះអរិយៈទាំងឡាយ លោកមិនដែលបៀតបៀនសត្វឡើយ

ទើបត្រាស់សំដែងគាថានេះថា :

**នតេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**

**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ**

អ្នកបៀតបៀនពួកសត្វដោយហេតុណា មិនឈ្មោះថា អរិយៈ ដោយហេតុនោះ បណ្ឌិតហៅអរិយៈដោយចំពោះបុគ្គលដែលអត់បៀតបៀនសត្វ ។

ចប់ធម៌ទេសនាហើយ ព្រានសន្ទូច ក៏បានសម្រេចធម៌ជាន់ខ្ពស់ឈ្មោះសោតៈ ក្នុងពេលនោះ ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៣១- រឿងជាងកែវមណី និងកណ្ដុរ

(ចាក អ. ព.)

(ទោសនៃការជាប់ចិត្តចំពោះទ្រព្យសម្បត្តិ)

កាលកន្លងទៅហើយ មានសេដ្ឋីម្នាក់ មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ នៅក្នុងស្រុកមួយក្នុងក្រុងពារាណសី ដែនកាសី ។ គាត់កប់ប្រាក់ ៤០ កោដិក្នុងផែនដី ។ ភរិយាសេដ្ឋីធ្វើមរណកាលទៅកើតជាកណ្ដុរនៅថែរក្សាប្រាក់នោះ ។ ត្រកូលទាំងអស់ ក៏វិនាសទៅតាមលំដាប់ ។ ស្រុកនោះកាលម្ចាស់លះបង់ចោលហើយ រកតែចំណាំផងមិនបាន ។ កាលនោះ មានជាងកែវមណីម្នាក់ គាស់ដុំថ្មបើករកកែវមណីហើយគាស់ថ្មក្នុងស្រុកចាស់នោះយកមកដំ ។ មេកណ្ដុរត្រាច់ចុះឡើងទៅរកចំណី បានប្រទះនឹងជាងនោះ មានសេចក្ដីស្រឡាញ់កើតឡើងដោយគំនិតថា ទ្រព្យរបស់អញច្រើន គង់តែវិនាសដោយមិនសមហេតុផល អាត្មាអញចូលដៃជាមួយជាងនេះ នឹងចាយវាយទ្រព្យបានស្រួល ហើយពាំមួយកហាបណៈទៅកាន់សំណាក់ជាងនោះ ។ ជាងឃើញក៏និយាយលួងលោមថា ម្នាលនាងព្រោះហេតុអ្វីបានជានាងពាំកហាបណៈមកក្នុងទីនេះ ? ម្នាលអ្នក ចូរអ្នកយក

កហាបណៈនេះទៅចាយវាយ ហើយនាំយកសាច់មកឱ្យខ្ញុំផង ។ ជាងយកកហាបណៈនោះទៅផ្ទះ ហើយទិញសាច់យកមកឱ្យមេកណ្ដុរនោះ ៗ ទទួលសាច់យកទៅស៊ីឯលំនៅខ្លួន ។ មេកណ្ដុរតែងឱ្យទ្រព្យរាល់ៗ ថ្ងៃដល់ជាងនោះហើយទទួលយកសាច់មកបរិភោគ ។ ថ្ងៃក្រោយបានប្រគល់ទ្រព្យទាំងអស់ឱ្យជាងកែវមណី ៗ ក៏ទិញសាច់យកមកឱ្យកណ្ដុរជារាល់ថ្ងៃដែរ ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៣២- រឿងសត្វមៀម

(ចាក អ. ចូ.)

(ជ្រះថ្លាចំពោះព្រះពុទ្ធ តែងរួចចាកទុក្ខសព្វយ៉ាង)

សេចក្ដីថា ព្រះមានព្រះភាគទ្រង់នៅអាស្រ័យក្នុងឥន្ទសាលគុហានាវេទិយកបព៌ត ។ គ្រានោះមានសត្វមៀមមួយ ពេលព្រះសាស្ដាស្ដេចយាងទៅបិណ្ឌបាត តែងហើរតាមពាក់កណ្ដាលផ្លូវ លុះព្រះអង្គត្រឡប់វិញ ក៏នៅទទួលពាក់កណ្ដាលផ្លូវជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយ សត្វមៀមចុះពីភ្នំមកថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ដែលប្រថាប់កណ្ដាលប្រជុំព្រះភិក្ខុសង្ឃក្នុងសាយណ្ហសម័យ ហើយសំរូលស្លាប ផ្គងអញ្ជលីបន្ទាបក្បាលឈរនមស្សការព្រះទសពល ។ ព្រះអង្គឃើញហើយ ក៏ទ្រង់ញញឹម ។ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ញញឹម តើមានហេតុអ្វី? ម្នាលអានន្ទ អ្នកចូរមើលសត្វមៀមនេះ ញុំាងចិត្តឱ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកអស់មួយសែនកប្ប នឹងបានជាព្រះបច្ចេកពុទ្ធមួយអង្គនាម សោមនស្ស ។ ពួករុក្ខទេវតាបានពោលគាថាឱ្យសព្វសាធុការព្រមៗ គ្នាថា :

ឱលុក មណ្ឌលក្ខិក
ទេនិយកេ មំនិយទាសិក
សុខិតោសិ ត្វំ អយ្យេ កោសិយ
កាលុដ្ឋិតំ បស្សសិ ពុទ្ធចរំ ឱ

ហៃមៀមកោសីភ្នែកមូលម្ចាស់អើយ អ្នកនៅយូរហើយលើបព្វតា នាមវេទិយកៈដល់នូវសុខា ឃើញពុទ្ធវរាក្រោកក្នុងកាលគួរ ។

បន្ទាប់មក ព្រះសាស្តាពោលព្យាករណ៍ថា

មយិ ចិត្តំ បសាទេត្វា តិក្ខសង្ឃេ អនុត្តរេ
កប្បានំ សតសហស្សានិ ទុគ្គតេសោ ន គច្ឆតិ ។

មៀមនេះច្យុតចាកទេវលោក គឺកុសលមូលដាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធមានវិស្សុតនាមថា សោមនស្ស មានញាណគ្មានទីបំផុត ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៣៣- រឿងបុត្តខាធកជាតក

(ចា. ម. អ.)

(អ្នកប្រមឹកស្រវឹងស៊ប់ មើលមិនស្គាល់កូនខ្លួនទេ)

កាលកន្លងទៅហើយ ព្រះចៅក្រុងពារាណសី ទ្រង់ជាអ្នកប្រមឹកសុរាបើរៀចាកសាច់ មិនសោយព្រះក្រយាស្ងោយឡើយ ។ សូម្បីពួកអ្នកនគរឃោត់ថាកុំសម្លាប់ ក៏មានរៀងរាល់ថ្ងៃឧបោសថដែរ ។ ថ្ងៃ ១៣ កើត អ្នកគ្រួរកាន់សាច់យកមកព្យួរទុកមិនស្រួល ឆ្កែក៏ពាំស៊ីអស់ ។ ក្នុងថ្ងៃឧបោសថ អ្នកគ្រួរកសាច់មិនបាន មិនហ៊ានលើកព្រះក្រយាស្ងោយទៅថ្វាយព្រះរាជាឡើយ ទើបយកដំណឹងនោះទៅក្រាបទូលព្រះទេពី ។ ត្រាស់ថា នែអ្នក ព្រះរាជបុត្រខ្ញុំជាទីស្រឡាញ់ពេញចិត្តព្រះរាជា ។ ទតយល់ព្រះរាជបុត្រនោះហើយ នឹងស្ទុះមកឱបរឹតថើបជាមិនខាន មុខជាភ្លេចទាររកសាច់ហើយ. អ្នកបំពៅព្រះរាជបុត្រហើយ នឹងយកទៅឱ្យអង្គុយលើភ្លៅព្រះរាជា ហើយអ្នកត្រូវលើកព្រះក្រយាស្ងោយទៅថ្វាយ ក្នុងពេលដែលព្រះអង្គកំពុងប្រឡែងលេងជាមួយរាជបុត្រ. លុះត្រាស់ដូច្នេះហើយ ព្រះនាងក៏ធ្វើឧបាយបែបនោះ ។ លំដាប់នោះឯង អ្នកគួរបង្អោនភត្តទៅ

ថ្វាយ ព្រះរាជាកំពុងស្រវឹងស្រា ទតមិនឃើញសាច់ក្នុងភាជន៍ ត្រាស់សួរថាសាច់ទៅឯណា ? បពិត្រព្រះសម្មតិទេព ថ្ងៃនេះជាថ្ងៃឧបោសថ មិនគួរព្រះអង្គសោយសាច់ទេ ។ ព្រះរាជាត្រាស់ថា អញរកសាច់បានដោយកម្រណាស់ ហើយទ្រង់ចាប់ព្រះរាជបុត្រមូល ផ្តាច់ព្រះសុរងបោះទៅខាងមុខអ្នកគ្រួត្រាស់ថា ចំអិនឱ្យឆាប់មក ។ អ្នកគ្រួក៏ធ្វើតាមព្រះរាជបញ្ជា សូម្បីជនម្នាក់ មិនហ៊ានឃាំ ឬនិយាយថាម្តេចឡើយ ព្រោះខ្លាចព្រះរាជា លុះអ្នកគ្រួបង្អោនភត្តមកទ្រង់ក៏សោយជាមួយនឹងសាច់ព្រះរាជបុត្រ ហើយផ្ទំលក់ទៅពេលភ្លឺល្ងះ១ ទ្រង់តើនឡើងបាត់ស្រវឹងពោលប្រាប់ស្រីស្នំថា នាងចូរនាំព្រះរាជបុត្រមកឱ្យអញ ខណៈនោះ ព្រះទេពីទ្រង់ព្រះកន្សែងសោយសោក បោកព្រះកាយដួលដេកលើផែនដី លុះមានព្រះស្មារតីវិញ ក៏ត្រាស់ថា បពិត្រព្រះស្វាមី ម្សិលមិញ ព្រះអង្គសម្លាប់ព្រះរាជបុត្រយកសាច់សោយ ជាមួយនឹងភត្តទៅហើយ ម្តេចឡើយទ្រង់រកព្រះរាជបុត្រទៀត ។ ព្រះរាជាទ្រង់សណ្តាប់ពាក្យនោះចប់ហើយ ក៏យំសោកស្រណោះអាឡោះអាល័យ ស្តាយព្រះរាជបុត្រស្មើរនឹងក្ស័យព្រះជន្ម ទ្រង់យល់ឃើញទោសក្នុងកាលផឹកស្រាថា អញ

កើតទុក្ខព្រោះតែផឹកសុរានេះ ទើបយកកន្សែងមកជូតព្រះភក្ត្រអធិដ្ឋានថា ចាប់ពីពេលនេះទៅ បើអញមិនទាន់បានសម្រេចព្រះអរហត្តដរាបណា ដរាបនោះអញលែងផឹក ហើយទឹកស្រានេះ ព្រោះជាមេបង្កើតសេចក្ដីទុក្ខ បង្កើតវិនាសសព្វបែបយ៉ាង កាលឃើញទោសជាប្រត្យក្សយ៉ាងនេះ ទ្រង់ក៏លែងសោយស្រាតាំងពីថ្ងៃនោះមក ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៣៤- រឿងសត្វខ្លែង និងអ្នកប្រមាញ់

(ចាក ម. ប.)

(ចេះជួយយកអាសាគ្នាក្នុងគ្រាក្រ ទើបជាមិត្រល្អ)

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី កាលនោះអ្នកស្រុកបច្ចន្តគ្រាម ចូលចិត្តរកស៊ីបរបាញ់សត្វយកសាច់ចិញ្ចឹមគ្រួសារ ។ នៅជិតស្រុកនោះ មានស្រះធំមួយមានសត្វ ៥ ពួកនៅអាស្រ័យគឺ ខ្លែងឈ្មោលនៅខាងត្បូងស្រះ, ខ្លែងញីនៅខាងលិច, រាជសីហ៍នៅខាងជើង, អកនៅខាងកើត អណ្តើកនៅត្រង់ដីទួលកណ្តាលស្រះ ។ ខ្លែងឈ្មោលនិយាយសុំខ្លែងញីធ្វើជាប្រពន្ធ ខ្លែងញីសួរថា អ្នកចង់បានខ្ញុំជាប្រពន្ធនេះ តើអ្នកមានមិត្តសំឡាញ់ឬទេ ? ខ្លែងឈ្មោលថា ខ្ញុំមិនមានមិត្តសំឡាញ់ទេ។ ខ្លែងញីក៏ប្រាប់ទៅវិញថា ត្រូវអ្នករកចងមិត្តឱ្យបានគ្នាច្រើនសិន ទើបខ្ញុំព្រមទទួលយក ហើយពន្យល់ខ្លែងឈ្មោលឱ្យទៅចងមេត្រីនឹងសត្វទាំងបីគឺ អក អណ្តើក និងរាជសីហ៍ ។ ខ្លែងឈ្មោលបានស្តាប់ហើយ ក៏ទៅចងមិត្តនឹងសត្វទាំងនោះបានសំរេចដូចបំណង ។ គ្រានោះ ខ្លែងទាំងពីរបានព្រមព្រៀងគ្នាជាប្តីប្រពន្ធ ធ្វើសំបុកពងលើដើមក្តម្ពដែលដុះ

ត្រង់ដីទួលកណ្ដាលស្រះនោះឯង ក្រោយមកខ្លែងញីឈ្មោលក៏បានកូនពីរ ។

ថ្ងៃមួយពួកអ្នកស្រុកបច្ចន្តគ្រាម ដើរបរបាញ់សត្វក្នុងព្រៃមិនបាន ដល់ពេលយប់ ក៏នាំគ្នាទៅដេកក្រោមដើមគ្លម្ពកណ្ដាលស្រះនោះឯង ដល់ពេលមូសខាំអត់ទ្រាំមិនបាន ក៏ដុតភ្លើងបង្ហុយផ្សែងបណ្ដើលមូស ។ ផ្សែងភ្លើងហុយឡើងទៅដល់សំបុកខ្លែងលើចុងគ្លម្ព កូនខ្លែងតូចៗ ដែលនៅក្នុងសំបុកក៏យំស្រែករំពង ។ អ្នកប្រមាញ់ឮសំលេងកូនសត្វមានសេចក្ដីត្រេកអរណាស់ ផាស់គ្នាឱ្យក្រោកឡើង កាន់គប់ភ្លើងបំភ្លឺទៅយកកូនសត្វមកដុតស៊ី ។ ខ្លែងញីឮមាត់ជនទាំងនោះហើយ ក៏និយាយនឹងខ្លែងឈ្មោលថា អ្នកប្រមាញ់ប្រាថ្នានឹងឡើងមកយកកូនយើងទៅស៊ីហើយ ដូច្នេះសូមអ្នកទៅឱ្យដំណឹងដល់មិត្តសំឡាញ់យើង ត្បិតយើងមានភ័យអាសន្នដល់ហើយ ។ ខ្លែងឈ្មោល ក៏ស្ទុះម្នីម្នាទៅប្រាប់អកតាមដំណើរ អកមកជួយយកអាសា ហើយបញ្ជូនខ្លែងឈ្មោលឱ្យប្រញាប់ប្រញាល់ទៅមុន អកទៅដល់ទំលើចុងឈើមួយក្បែរដើមគ្លម្ពនោះ ឃើញអ្នកប្រមាញ់កំពុងកាន់គប់ភ្លើងឡើងទៅរកសំបុកអក ក៏មុជទៅក្នុងស្រះឱ្យទទឹកស្លាប

ជោក ហើយបៀមទឹកពេញមាត់ ហើរទៅទទះស្វាបព្រួស ទឹកលត់គប់ភ្លើងនោះ ប្រមាញ់ម្នាក់កាន់គប់ឡើងទៅទៀត អកខំលត់ដោយឧបាយនោះទៀត ដរាបដល់ពាក់កណ្ដាល អធ្រាតុរងារញ័រអស់ទាំងខ្លួន, ខ្លែងញីឃើញដូច្នោះ ក៏និយាយនឹងខ្លែងឈ្មោលឱ្យទៅប្រាប់អណ្ដើកជាប្រញាប់ ។ ខ្លែងឈ្មោលប្រាប់អណ្ដើកឱ្យមកជួយ អណ្ដើកទទួលយកអាសាដោយសេចក្ដីស្ម័គ្រ ។ គ្រានោះកូនអណ្ដើក បានឮឪពុកនិយាយឆ្លើយឆ្លងជាមួយខ្លែងដូច្នោះ ក៏និយាយនឹងឪពុក សុំធានាទៅជួយការពាកូនខ្លែងនោះ ។ អណ្ដើកជាឪពុកឃាត់កូនមិនឱ្យទៅ ទើបទៅយ៉ាងប្រញាប់ដោយខ្លួនឯង ចុះទៅក្នុងស្រះបាភក់ និងសារាយនាំទៅបាចលើគំនរភ្លើងរលត់អស់ ។ ឯពួកប្រមាញ់បានឃើញអណ្ដើកធំសំបើមដូច្នោះ ក៏និយាយគ្នាដោយត្រេកអរថា យើងកុំរវល់នឹងកូនខ្លែងល្អិតនោះ នាំគ្នាចាប់អណ្ដើកធំឯណោះវិញ · បើយើងបានតែមួយនេះ ល្មមឆ្អែតទាំងអស់គ្នា ។ អ្នកប្រមាញ់មិនដឹងដូចម្ដេចចាប់អណ្ដើកធំនោះឱ្យបានជាប់ ក៏ស្រាតសំពត់ចុះទៅវេចខ្ចប់អណ្ដើកនោះហើយ នាំគ្នាទាញចុងសំពត់ម្ខាង, ប៉ុន្តែទាញមិនឈ្នះសោះ ព្រោះអណ្ដើកធំពេក ក៏ត្រូវ

អណ្តើកអួសរហូតដល់ទឹកជ្រៅ ហេតុតែសេចក្តីលោភ អ្នកទាំងនោះ ស្ទូមុជទៅតាមទាល់តែឈ្លក់ទឹកផឹកចោងពោះទើបឡើងមកវិញរងាររញ៉ូវខ្លួនងាកទៅរកភ្នក់ភ្លើងរលត់អស់សំលៀកក៏គ្មាន បានទៅអណ្តើកអស់ទៅ, ក៏នាំគ្នាឱបដៃអស់សង្ឃឹម ហើយនិយាយថា ណ្ហើយចុះចាំថ្ងៃរះ យើងយកកូនខ្លែងស៊ីឱ្យបាន ។ ខ្លែងញីឮដូច្នេះ ប្រើខ្លែងឈ្មោលឱ្យទៅពឹងរាជសីហ៍ទៀត ។ រាជសីហ៍ ក៏តម្រង់ទៅរកដើមក្តុម្ពនោះ ។ ពួកអ្នកប្រមាញ់ បានឃើញរាជសីហ៍ ហើយក៏ភ័យរកច្រករត់គ្រប់ៗ គ្នា ។ រាជសីហ៍ទៅដល់គល់ក្តុម្ព ឥតឃើញមនុស្សម្នាក់សោះ ។ ខណៈនោះអក, អណ្តើក និងខ្លែងចូលទៅរករាជសីហ៍ ។ សំដែងនូវអានិសង្ស មិត្តដល់សត្វទាំងនោះ ហើយរំលឹកគ្នាតទៅទៀតថា ពីថ្ងៃនេះតទៅយើងទាំងអស់គ្នា ត្រូវរក្សាមិត្តឱ្យថិតថេរមាំមួន កុំប្រហែសធ្វេសឡើយ ក៏លាគ្នាទៅកាន់លំនៅរៀងៗ ខ្លួន ។

## ៣៥- រឿងតាបសជាច់ឈាន

(ចាក មុ. ឯ.)

(អាវុធកាមគុណធ្ងន់ខ្លាំងជាអាវុធបរមាណូ)

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងនគរពារាណសី កាលនោះព្រះពោធិសត្វ សោយព្រះជាតិនាត្រកូលព្រាហ្មណ៍មហាសាលក្នុងដែនកាសី កាលចំរើនវ័យហើយ បានសិក្សាដល់ទីបំផុតនៃវិជ្ជា ក្រោយមកលះកាមគុណចេញបួសជាតាបស បានសម្រេចឈាននឹងអភិញ្ញាណស្ថិតនៅក្នុងព្រៃហេមពាន្ត ។

សម័យមួយ ជារដូវមានទឹកសន្សើមជោគជាំ តាបសចង់សេពអាហារជូរប្រៃ ទើបចេញអំពីព្រៃទៅនគរពារាណសី ចូលទៅអាស្រ័យក្នុងព្រះរាជឧទ្យាន នៃព្រះបាទព្រហ្មទត្តក៏ឡើងស្លៀកសំពត់សំបកឈើ ដណ្តប់ស្បែកខ្លាធៀងស្មាម្ខាង កាន់ភាជន៍ចូលទៅបិណ្ឌបាតក្នុងនគរពារាណសី រហូតដល់ទ្វារព្រះរាជវាំង ។

ព្រះមហាក្សត្រទតឃើញតាបសនោះ ទ្រង់មានសេចក្តីជ្រះថ្លា ទើបត្រាស់ឱ្យព្រះរាជបុត្រទៅនិមន្ត ហើយអារាធនាឱ្យគង់លើរាជាសនៈ ទ្រង់ថ្វាយខាទនិយភោជនា-

ហារ ។ តាបសឆាន់បរិបូណ៌ហើយ ទ្រង់អារាធនាឱ្យទៅគង់ក្នុងឧទ្យាន បវារណាឱ្យមកឆាន់ក្នុងព្រះរាជវាំងអស់ ១៦ វស្សា ។

ថ្ងៃមួយ ព្រះរាជាស្ដេចយាងទៅបង្ក្រាបបច្ចន្តប្ប-ទេស ដែលកើតចលាចល ទ្រង់មានព្រះតម្រាសផ្ដាំនឹងព្រះនាងមុទុលក្ខណទេវី ជាព្រះអគ្គមហេសី ឱ្យបំរើតាបសដូចកាលព្រះអង្គគង់នៅ ។

ឯព្រះពោធិសត្វ តាំងអំពីព្រះរាជាស្ដេចយាងចាត់ទៅ ក៏ទៅកាន់ព្រះរាជវាំងដូចធម្មតា ។ មានថ្ងៃមួយ ព្រះនាងមុទុលក្ខណទេវី តាក់តែងចង្ហាន់ហើយ ទៅស្រង់ព្រះសុគន្ធវារី ហើយប្រដាប់ព្រះកាយដោយគ្រឿងអលង្ការ ផ្ទំលើព្រះបន្ទំតូច ១ ទតព្រះនេត្ររង់ចាំមើលផ្លូវតាបស ។

មួយស្របក់តាបសចុះចាកអាកាស ចូលទៅក្នុងព្រះរាជវាំង ឯនាងមុទុលក្ខណទេវី ទ្រង់ឮសូរសំពត់សំបកឈើ ក៏ភ្ញាក់ស្ទុះប្រញាប់ប្រញាល់ឡើងរបូតព្រះភូសាអស់. តាបសឃើញវិសភាគារម្មណ៍ដូច្នោះ កិលេសក៏ផាលឡើង សាបសូន្យចាកឈាន មិនអាចហោះហើរបានឡើយ លោកឈរទទួលអាហារ ចុះចាកប្រាសាទ និមន្តដើរទៅកាន់ព្រះរាជ

ឧទ្យានចូលទៅក្នុងបណ្ណសាលា ទុកភាជន៍អាហារក្រោមគ្រែ សំណឹង ទើបសឹងសន្ទឹងសន្ធៃ ក្ដៅអន្ទះអន្ទែងអស់ ៧ ថ្ងៃ មានសរីរកាយស្គាំងស្គម ចង្អាន់ក្នុងភាជន៍ ក៏ផ្អូមផ្អូរអស់ ។

ក្នុងថ្ងៃគម្រប់ ៧ នោះព្រះបាទពារាណសី ទ្រង់បង្ក្រាបបច្ចន្តគ្រាមហើយ ស្ដេចនាំយោធាត្រឡប់មកវិញ ទ្រង់តាំងព្រះទ័យថា នឹងទៅថ្វាយបង្គំតាបសជាមុន ទើបស្ដេចយាងទៅកាន់ព្រះរាជឧទ្យាន ទតព្រះនេត្រឃើញតាបសសឹងស្លឹកក្នុងបណ្ណសាលា ក៏ទ្រង់ព្រះរាជតម្រិះថា តាបសប្រហែលជាអាពាធ ទើបស្ដេចយាងចូលទៅច្របាច់ព្រះបាទត្រាស់សួរថា ព្រះករុណាម្ចាស់មិនសប្បាយឬ ? បពិត្រមហារាជ អាត្មាមិនសប្បាយខាងក្នុង ព្រោះត្រូវសរគឺ កាមខ្មៅខ្មីឈានសមាបត្តិអស់រលីងទៅហើយ សូមអភ័យទោសសរគឺ កាមដូចម្ដេច ? បពិត្រមហារាជ ! សរគឺកាមនោះបានដល់ចិត្តរបស់អាត្មាភាព ដែលជាប់ស្រឡាញ់ព្រះនាងមុទុលក្ខណាទេវី ។ ព្រោះកាលមហារាជស្ដេចយាងទៅបច្ចន្តគ្រាម អាត្មាកើតវិសភាគារម្មណ៍ដោយហេតុយ៉ាងនេះ ៗ .... ។

ព្រះរាជាត្រាស់ថា ស្រួលហើយ ខ្ញុំព្រះករុណានឹង

ថ្វាយនាងមុទុលក្ខណទេវីដល់ព្រះគុណម្ចាស់ សូមកុំព្រួយឡើយ ។ ទ្រង់ត្រាស់ដូច្នោះហើយ ទើបឱ្យព្រះតាបសក្រោកឡើង បរិភោគអាហារហើយ នាំទៅកាន់មហាប្រាសាទត្រាស់បញ្ជាឱ្យព្រះនាងទេវី គាត់គាត់តែងកាយហើយ ព្រះរាជទានដល់តាបស មុននឹងព្រះរាជទាន ទ្រង់ត្រាស់ឱ្យសញ្ញាដល់ព្រះទេវីថា ឱ្យជួយកែសតិស្មារតីរបស់តាបសឱ្យមានឡើងវិញ ដោយបញ្ញារបស់ខ្លួន ។

ឯតាបស ក៏នាំព្រះរាជទេវីចេញចាកមហាប្រាសាទទៅដល់ទ្វារវាំង ទើបព្រះរាជទេវីត្រាស់ថា បពិត្រព្រះគុណម្ចាស់ យើងគួរមានប្រាសាទ ១ សំរាប់នៅ ចូរលោកទៅសូមព្រះរាជា ។ តាបសក៏ត្រឡប់ទៅទូលសូមតាមបង្គាប់នាង ព្រះរាជាទ្រង់ព្រះរាជទានផ្ទះទំនេរ ១ ខ្ទង់ដែលមនុស្សទាំងឡាយធ្វើជាបង្គន់ តាបស់ក៏នាំព្រះរាជទេវីទៅក្នុងទីនោះ តែព្រះរាជទេវីមិនព្រមយាងចូលទៅ. តាបសសួរថាហេតុអ្វីក៏មិនចូលមក ខ្ញុំមិនចូលទេ ព្រោះអីមិនស្អាត. ព្រះនាងទេវីមានព្រះសវនីយ៍ដូច្នោះហើយ ប្រើតាបសឱ្យទៅសូមគ្រឿងសំរាប់បោសច្រាសអំពីព្រះរាជាទៀត តាបសក៏ទៅសូមគ្រឿងប្រដាប់ទាំងនោះមក បោសច្រាសលាង

សំអាតស្អាតហើយ. ព្រះនាងទេវីប្រើទៀតថា ចូរលោកទៅយកគ្រែ និងខ្នើយកន្ទេលមក លុះតាបសយករបស់ទាំងនោះហើយ ប្រើឱ្យទៅយកពាងក្អមជាដើមមកទៀត តាបសចេះតែធ្វើតាមដោយសព្វគ្រប់រួចហើយ ក៏ឡើងទៅអង្គុយក្នុងទីនោះ កាលតាបសអង្គុយហើយ ព្រះនាងទេវីយាងទៅគង់ជិត ចាប់ត្រចៀកព្រះតាបសទាញមកជិតព្រះឱស្ឋ ហើយរំលឹកឱ្យមានស្មារតីថា **ត្វំ សមណភាវំ វា ព្រាហ្មណភាវំ វា ន ជានាសិ** លោកមិនដឹងថាខ្លួនលោកជាសមណៈ ឬព្រាហ្មណ៍ទេឬ ? ។ ក្នុងកាលនោះ តាបសភ្ញាក់សតិឡើងវិញភ្លាម ។

កាលត្រឡប់បានសតិឡើងវិញហើយ តាបសគិតថា តណ្ហានេះចំរើនឡើងដរាបណា មិនឱ្យសត្វងើបរួចពីអបាយដរាបនោះ. គិតដូច្នោះហើយ ទើបនាំព្រះនាងទេវីទៅថ្វាយព្រះរាជាវិញ ហើយក្រាបទូលព្រះរាជាថា កាលមុនដែលអាត្មានៅមិនទាន់បានទទួល ព្រះនាងមុទុលក្ខណទេវីពីព្រះអង្គ សេចក្តីចំណង់តែម្យ៉ាងកើតហើយដល់អាត្មា លុះបានទទួលព្រះនាងទេវី ដែលមានដួងព្រះនេត្រដ៏ទូលាយក្នុងកាលណា សេចក្តីប្រាថ្នាតូចធំ ឱ្យរីងរឹតតែចំរើនឡើងក្នុងកាលនោះ ។

ខណៈនោះតាបស ក៏ញុំាងឈានឱ្យកើតឡើងវិញ ហើយស្ថិតនៅនាអាកាស សំដែងធម៌ថ្វាយព្រះរាជាហើយ ហោះទៅកាន់ព្រៃហេមពាន្តវិញ គង់នៅជាសុខក្នុងឈាន ផរាបដល់អស់ព្រះជន្ម ក៏បានទៅកើតក្នុងព្រហ្មលោក ។

# ៣៦- រឿងស្វាពោធិសត្វ

(ចាក វា. ឯ.)

(អ្នកមានសតិស្មារតីវាងវៃ តែងឈ្នះសត្រូវទាំងពួង)

ក្នុងកាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងនគរពារាណសី កាលនោះព្រះពោធិសត្វទ្រង់សោយព្រះជាតិ ជាស្វាមានរូបធំស្រមូវ មានកំឡាំងខ្លាំងដូចដំរីស្ទួរ បានដើរទៅមាត់ស្ទឹងឃើញកោះមួយ ដែលបរិបូណ៌ដោយរុក្ខជាតិមានផ្លែ ក៏លោតអំពីមាត់ស្ទឹង ទៅជាន់ដុំថ្មមួយកណ្ដាលស្ទឹង ហើយលោតអំពីដុំថ្មនោះទៅកោះ បេះផ្លែឈើផ្សេងៗ បរិភោគតាមប្រាថ្នា ដល់វេលាល្ងាច ត្រឡប់មកលំនៅរបស់ខ្លួនវិញ ។ ស្វាពោធិសត្វតែងលោតទៅមកយ៉ាងនេះជារាល់ថ្ងៃ ។

ក្នុងស្ទឹងនោះ មានក្រពើញីឈ្មោលមួយគូរ ក្រពើញីមានផ្ទៃពោះ បានឃើញព្រះពោធិសត្វ លោតឆ្លងទៅមកដូច្នោះ ក៏កើតចំណង់ចង់ស៊ីថ្លើមស្វាពោធិសត្វ ទើបប្រាប់ដល់ប្ដីថា ខ្ញុំចង់ស៊ីថ្លើមស្វានេះ ។ ក្រពើឈ្មោល ក៏និយាយថា មិនក្រអ្វីទេ ចាំបងចាប់យកឱ្យស៊ីល្ងាចនេះ ។ និយាយហើយ ក៏ឡើងទៅដេកទ្រោបលើដុំថ្ម ដែលស្វាពោធិសត្វ

តែងលោកទៅជាន់ ។ ដល់វេលាល្ងាច ស្វាពោធិសត្វមកវិញ ឈរនៅមាត់គោះ សំឡឹងមើលដុំថ្មដែលធ្លាប់លោតឃើញខ្ពស់ផុតពីទឹកជាងមុន ទើបរំពឹងថានឹងមានហេតុផលយ៉ាងណាអេះ ទឹកក្នុងស្ទឹងនេះមិនមែនស្រក និងមិនមែនឡើងខុសប្រក្រតីទេ ចុះហេតុអ្វីដុំថ្មនេះខ្ពស់ជាងមុនប្រហែលជាក្រពើធ្វើបន្លំចាំស៊ីអញហើយ ។ ពោធិសត្វគិតពិសោធន៍ឱ្យដឹងច្បាស់ ទើបហៅដុំថ្មថា ដុំថ្មអើយដុំថ្ម ! ហៅយ៉ាងនេះបីដង ទើបនិយាយនឹងដុំថ្មទៀតថា នែដុំថ្មអើយ ថ្ងៃនេះហេតុដូចម្ដេច ក៏ធ្មើងមិននិយាយឆ្លើយឆ្លងគ្នាសោះ ។ ឯក្រពើបានឮដូច្នោះគិតថា "ដុំថ្ម ធ្លាប់និយាយឆ្លើយឆ្លងនឹងស្វាពីថ្ងៃមុនៗមក " ក៏ឆ្លើយជំនួសថ្មថា ហៅអញធ្វើអ្វីបងស្វា ? ពោធិសត្វស្គាល់ជាក់ជាក្រពើទើបសួរថា អ្នកណាឆ្លើយសំឡេងប្លែក ? ក្រពើថាអញ ! ស្វាថាចុះអ្នកមកក្រាបលើដុំថ្មនេះធ្វើអ្វី ? ក្រពើថាយើងត្រូវការថ្លើមរបស់អ្នក ទើបមកក្រាបនៅទីនេះ ។ ព្រះពោធិសត្វគិតថាផ្លូវដទៃក្រៅអំពីនេះមិនមាន បើដូច្នេះអញ ត្រូវល្បួងចិត្តក្រពើនេះ គិតហើយនិយាយថា បងសំឡាញ់ក្រពើរ ! យើងឱ្យថ្លើមដល់អ្នក ចូរអ្នកហាមាត់ចាំចុះយើងនឹងលោតចូល

ទៅក្នុងមាត់តែម្តង ។

ធម្មតាសត្វក្រពើ កាលបើហាមាត់ហើយតែងបិទភ្នែក. ក្រពើក៏ហាមាត់បិទភ្នែកចាំ ។ ព្រះពោធិសត្វ ក៏លោតអំពីកោះទៅជាន់ក្បាលក្រពើ ហើយលោតទៅមាត់ស្ទឹង ក្រពើឃើញដូច្នោះគិតថា ស្វានេះអង់អាចជាបណ្ឌិតបរិបូណ៌ដោយគុណធម៌ ទើបសូត្រពាក្យស្លោកថា :

**យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ**
**សច្ចំ ធម្មោ ធិតិ ចាគោ[១] ទិដ្ឋំ សោ អតិវត្តតិ**

ប្រែថា បពិត្រស្តេចស្វា ធម៌ទាំងឡាយបួនយ៉ាងនេះ គឺ សច្ច ១. ធម្ម ១. ធិតិ ១. ចាគ ១. មានដល់បុគ្គលណាដែលដូចលោក បុគ្គលនោះតែងបង្ក្រាបនូវខ្មាំងបាន ។

---

១. សច្ច ប្រែថាពាក្យពិត បានខាងវិរីសច្ច. ២. ធម្ម ប្រែថាសភាពដែលបុគ្គលគួរទ្រ បានខាងវិចារណបញ្ញាប្រាជ្ញាសំរាប់ពិចារណា. ៣. ធិតិ ប្រែថាសេចក្តីសង្វារ បានខាងអព្ភោច្ឆិន្នវីរិយ គឺសេចក្តីព្យាយាមមិនស្រាក. ៤. ចាគ ប្រែថាសេចក្តីប្រថុយ បានខាងអត្តភាវបរិច្ចាគ សេចក្តីប្រថុយនូវខ្លួន គឺនូវជីវិត ។ ធម៌ទាំង ៤ នេះហៅថា ចាតិម្ពាតិវត្តនធម៌ ។

# ៣៧- រឿងយក្ខិនីស៊ីមនុស្ស

( ចាក តេ. ឯ.)

( សំវរធម៌ជាស្ព័យត្រាណយ៉ាងធំរបស់នគរកាយ)

កាលកន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី មានព្រះរាជឱរស ១០០ ព្រះអង្គ ព្រះពោធិសត្វជាព្រះរាជបុត្រពៅបង្អស់ ។

សម័យមួយ ព្រះពោធិសត្វទ្រង់ព្រះចិន្តាថា អញនឹងបានរាជសម្បត្តិ ឬមិនបាន ? ទើបថ្វាយបង្គំសួរព្រះបច្ចេកពុទ្ធ ដែលតែងនិមន្តមកឆាន់រាល់ថ្ងៃក្នុងវាំងអំពីរឿងនោះ លោកថ្វាយព្រះពរថា ព្រះអង្គម្ចាស់មិនបានសោយរាជ្យក្នុងនគរនេះទេ បានក្នុងនគរតក្កសិលា នាដែនគន្ធារឯនោះ បើទ្រង់យាងទៅនឹងបានសោយរាជ្យ, ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះទៅ តែផ្លូវដែលទៅនោះ បើដើរកាត់ព្រៃចម្ងាយ ៥០យោជន៍ បើដើរតាមផ្លូវវាងចម្ងាយ ១២០ យោជន៍ ក្នុងផ្លូវកាត់ព្រៃ ៥០ យោជន៍នោះ មានអន្តរាយធំដោយយក្ខិនី ។ បើបុរសណាវង្វេងដោយរូបសំឡេង ក្លិនរស សម្ផស្ស មុខជានឹងបានចំណីយក្ខិនីមិនខាន, បើទ្រង់មានសំវរធម៌សង្រួមមិនរវល់នឹងយក្ខិនីទាំងនោះ មុខជាទ្រង់នឹងបានសោយរាជ្យសម្បត្តិ

ក្នុងក្រុងតក្កសិលាក្នុងថ្ងៃទី ៧ មិនខាន ។

ព្រះពោធិសត្វ តាំងចិត្តកាន់តាមឱវាទព្រះបច្ចេកពុទ្ធមិនលះបង់ ហើយនិមន្តព្រះបច្ចេកពុទ្ធឱ្យបង្រៀនព្រះបរិត្តដើម្បីការពារព្រះអង្គ. ទ្រង់ថ្វាយបង្គំលាព្រះជនកជននីហើយទ្រង់យាងចេញចាកព្រះនគរ ជាមួយនឹងអមាត្យ ៥ នាក់ ដែលស្ម័គ្រចិត្តតាមព្រះអង្គទៅ ។ ទ្រង់យាងកាត់វាលចូលព្រៃ ៗ ឯយក្ខិនីក៏និមិត្តរូបតាមមាយារបស់វា ។ បុរសទាំង ៥ នាក់វង្វេងនឹងរូប សំឡេង ក្លិនរស សម្ផស្សរបស់យក្ខិនី ទោះបីព្រះពោធិសត្វឃាត់ហាមយ៉ាងណា ក៏មិនស្ដាប់ ធ្វើជាអស់កម្លាំងកៀចដេកសេពតាមក្នុងទីនោះ ត្រូវយក្ខិនីស៊ីអស់ឥតសល់ម្នាក់ ។ នៅសល់តែព្រះពោធិសត្វមួយព្រះអង្គឯង ដែលទ្រង់មានសំវរធម៌ ។ នាងយក្ខិនីគិតថា "បុរសនេះមានកិរិយានឹងនួនណាស់" អញនឹងដើរតាមចាប់ស៊ីឱ្យទាល់តែបាន ទើបនិម្មិតជានាងកល្យាណី មានរូបល្អដូចស្រីទេពអប្សរ ដើរតាមក្រោយព្រះពោធិសត្វទៅ ។ មានមនុស្សដែលទៅធ្វើការក្នុងព្រៃ បានឃើញយក្ខិនីក្លែងភេទនោះសួរថា បុរសដែលដើរខាងមុខជាអ្វីនឹងនាង យក្ខិនីថាពស្ដាខ្ញុំ ពោធិសត្វត្រាស់ថា នាងនេះមិនមែនជាភរិយាយើង

ទេ គឺជាយក្ខិនី វាចាប់ស៊ីគ្នាយើងអស់ ៥ នាក់ហើយ យក្ខិនីថាធម្មតាបុរស តែពេលណាខឹងហើយ តែងថាភរិយាខ្លួនជាយក្ខិនី មិនថាភរិយារបស់ខ្លួនដូច្នេះឯង ។ បន្តិចខាងយក្ខិនីក៏ធ្វើជាស្រីមានគត៌ ហើយក៏ធ្វើជាពរកូន ដើរតាមព្រះពោធិសត្វទៅ ជនទាំងឡាយឃើញហើយ ក៏សួរដូចមុន ព្រះពោធិសត្វប្រាប់គេដូចមុន យក្ខិនីក៏និយាយការពារដូចមុនដែរ ។ កាលព្រះពោធិសត្វទៅដល់នគរតក្កសិលាហើយ នាងយក្ខិនីនិមិត្តជាស្រីក្រមុំល្អស្រស់ ដើរតាមព្រះពោធិសត្វតទៅទៀត ព្រះពោធិសត្វ ទ្រង់មិនរវល់ផងសោះ ទ្រង់ប្រថាប់ក្នុងសាលាក្រៅនគរ នាងយក្ខិនីឈរក្បែរទ្វារសាលា មិនហ៊ានចូលទៅជិត ដោយចាញ់បារមីរបសព្រះពោធិសត្វ ។

សម័យនោះ ព្រះចៅក្រុងតក្កសិលា ទ្រង់យាងទៅឧទ្យាន បានទតព្រះនេត្រឃើញនាងយក្ខិនី ក៏ទ្រង់ពេញព្រះហឫទ័យ ឱ្យរាជបុរសទៅសួរ លុះទ្រង់ជ្រាបសេចក្តីអំពីព្រះពោធិសត្វថា នាងនោះជាយក្ខិនី មិនមែនជាភរិយា ក៏ទ្រង់យល់ថា ស្វាមីរបស់នាងមិនពេញចិត្ត បាននិយាយយ៉ាងនេះ ហើយទ្រង់ហៅនាងយក្ខិនីឱ្យជិះលើរទេះ យាងចូលក្នុងព្រះបរមរាជវាំង តាំងជាអគ្គមហេសីទៅ ។

យប់នោះព្រះរាជាទ្រង់ផ្ទំនឹងអគ្គមហេសីថ្មី ស្តាប់ព្រះហឫទ័យហើយ នាងយក្ខិនី ក៏ធ្វើកលមាយាយំក្បើកក្បួលថា ខ្ញុំព្រះអង្គជាស្រីដែលព្រះអង្គ ទ្រង់រើសពីផ្លូវមក តាំងជាអគ្គមហេសី មុខជាស្រីស្នំព្រះអង្គប្រណែនឫស្យានឹងខ្ញុំម្ចាស់ ធ្វើបាបខ្ញុំម្ចាស់ឱ្យក្តៅក្រហាយមិនខាន ហេតុនេះសូមព្រះអង្គទ្រង់ព្រះរាជទានអំណាចក្នុងប្រទេសទាំងមូល ដល់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាមិនព្រមព្រះរាជទានឱ្យតាមសូម ទ្រង់ឱ្យអំណាចតែត្រឹមក្នុងវាំងប៉ុណ្ណោះ ។ យក្ខិនីព្រមទទួលដោយរីករាយ ។

ដល់ពេលយប់ ព្រះរាជាទ្រង់ផ្ទំនឹងយក្ខិនីលក់ស្និទ្ធហើយ យក្ខិនី ក៏ត្រឡប់ទៅកាន់នគរយក្ស នាំពួកយក្សមកជាច្រើន ខ្លួននាងក៏ប្រហារព្រះរាជក្សយព្រះជន្ម ហើយស៊ីសាច់ហុតឈាមជាអាហារ នៅសល់តែឆ្អឹងប៉ណ្ណោះ ឯយក្ខិនីដទៃទៀត ក៏នាំគ្នាចាប់សត្វ និងមនុស្សទាំងឡាយក្នុងវាំងស៊ីអស់គ្មានសល់ម្នាក់ ហើយនាំគ្នាត្រឡប់ទៅកាន់នគរយក្សវិញ ។

លុះព្រឹកឡើង មនុស្សទាំងឡាយ ដែលនៅខាងក្រៅព្រះនគរ បានឃើញទ្វារព្រះរាជវាំងបិទជិតខុសធម្មតាក៏

សង្ស័យ នាំគ្នាគាស់ទ្វារចូលទៅ ឃើញសុទ្ធតែគំនរឆ្អឹង ទើប ប្រជុំគ្នានិយាយថា បុរសនោះគេនិយាយពិត គេបានប្រាប់ ហើយថា នាងនោះជាយក្ខិនី មិនមែនភរិយារបស់គេទេ តែ ព្រះរាជាយើងមិនជឿ ទ្រង់យកមកតាំងជាអគ្គមហេសី ឥឡូវនាងយក្ខិនីនោះឯង វានាំគ្នាមកស៊ីមនុស្សក្នុងវាំងទាំង អស់ នៅសល់តែឆ្អឹងដូច្នេះ ។

ឯព្រះពោធិសត្វក្នុងយប់នោះ ព្រះអង្គទ្រង់ស្វាធ្យាយ ព្រះបរិត្តសូត្រ កាន់ព្រះខ័នប្រថាប់ឈររហូតទាល់តែព្រះ អរុណរះ ។ ពួកប្រជាជនទាំងឡាយក្នុងព្រះនគរ ក៏នាំគ្នា សំអាតព្រះរាជវាំងស្អាតល្អហើយ ប្រឹក្សាគ្នាថា បុរសដែល យក្ខិនីថាជាស្វាមីរបស់វានោះជាមនុស្សអស្ចារ្យ មានប្រាជ្ញា វៃឆ្លាត បើយើងទាំងឡាយបានបុរសនោះ មកធ្វើជា មហាក្សត្រប្រមុខរបស់យើងប្រសើរណាស់ ។

លំដាប់នោះ ពួកនាម៉ឺនសព្វមុខមន្ត្រីសេនាយោធា និងប្រជាជនទាំងឡាយ ព្រមព្រៀងគ្នាទៅគាល់ព្រះពោធិ សត្វ អញ្ជើញព្រះអង្គឱ្យសោយរាជ្យសម្បត្តិក្នុងព្រះនគរនោះ បានហើយ ហែហាមចូលទៅក្នុងព្រះរាជវាំង អភិសេកជា ក្សត្រគ្រងរាជ្យ ថ្វាយព្រះបរមនាមថា ព្រះបាទតក្កសិលា ។

ព្រះពោធិសត្វ ទ្រង់សោយរាជសម្បត្តិប្រកបដោយទសពិធរាជធម៌ ញ៉ាំងប្រជាពលរដ្ឋទាំងប្រទេសឱ្យបានសន្តិសុខ សន្តិភាពដរាបដល់ទីបំផុតព្រះជន្មវស្សាហោង ។

# ៣៨- រឿងប្រើស និងព្រានព្រៃ

(ចាក ក. ទុ.)

(អ្នកមានសាមគ្គីរួបរួមគ្នា តែងរួចចាកភយន្តរាយ)

កាលកន្លងទៅហើយមានសត្វប្រើ ១ អណ្តើក ១ រងាវកក ១ ជាសំឡាញ់នឹងគ្នា នៅអាស្រ័យក្នុងព្រៃហេមពាន្ត, អណ្តើកនៅក្នុងស្រះ រងាវកកនៅលើចុងឈើក្បែរស្រះនោះដែរ ។ សម័យមួយមានព្រានម្នាក់ ដើរស្វែងរកបាញ់សត្វក្នុងព្រៃ បានប្រទះឃើញស្នាមជើងប្រើសចុះផឹកទឹកស្រះនោះថ្មីៗ ក៏យកអន្ទាក់ព្រ័ត្រ ៣ ផ្លូងដាក់ក្បែរកំពង់ទឹកនោះ លុះដល់បឋមយាមរាត្រី ប្រើសចុះទៅផឹកទឹក ក៏ជាប់អន្ទាក់នោះបម្រាសរើមិនរួច ក៏ស្រែកយ៉ាងខ្លាំងឮដល់ទៅអណ្តើក និងរងាវកក សត្វទាំងពីរនោះ ក៏បានមកជួបជុំគ្នាគិតរកឧបាយជួយដោះ ។ ឯរងាវកកនិយាយនឹងអណ្តើកថា នែអណ្តើក ឥឡូវប្រើសសំឡាញ់យើងមានគ្រោះថ្នាក់ជាប់អន្ទាក់គេហើយ តើឯងគិតដូចម្តេច ? អណ្តើកថា អញទាល់គំនិតមិនដឹងគិតផ្លូវណាទេ ។ រងាវកកថា "បើដូច្នោះសំឡាញ់ឯងសុខចិត្តធ្វើតាមអញទេ ? អណ្តើកថា អញធ្វើតាម, អើអណ្តើកឯងមានធ្មេញរឹងប៉ុងគ្រាន់បើ ចូរឯងទៅ

ខាំខ្សែអន្ទាក់នោះចុះ ឯខ្លួនអញគ្មានធ្វេញទេ មានតែចំពុះចាំអញអ្នកភាំងដំណើរព្រាន មិនឱ្យមកដល់ឆាប់ តើឯងយល់ព្រមឬទេ ?" អណ្តើកថា ល្អហើយអញឥតយល់ទាស់ទេ ប៉ុន្តែថប់ក្រែងខាំខ្សែអន្ទាក់នោះក្រដាច់ ហើយស្រាប់តែព្រានមកដល់ ខ្លួនអញរត់មិនលឿន មុខជានឹងស្លាប់មិនខាន. រងវកកថាសំឡាញ់ឯងខំប្រឹងប្រែងទៅចុះ កុំរួញរា ទោះបីមិនសំរេចដូចប្រាថ្នា ក៏គង់តែការនោះបានធូរខ្លះមិនខាន. អណ្តើកក៏វារទៅខំប្រឹងខាំខ្សែអន្ទាក់នោះ ។ ចំណែកខាងរងវកក ក៏ហើរសំដៅទៅផ្ទះព្រាន លុះទៅដល់ក៏ទំលើចុងឈើស្បែរផ្ទះព្រាននោះ ដើម្បីឃ្លាំចាំមើល តើព្រាននឹងចេញទៅតាមផ្លូវណា ។ ព្រលឹមឡើងព្រានភ្ញាក់ពីដេកក្រោកលប់មុខមាត់ រួចចាប់យកលំពែងចេញដើរតាមទ្វារខាងកើតផ្ទះដើម្បីទៅមើលអន្ទាក់ រងាវកកឃើញហើយ ក៏ហើស្ទាក់ឆាបមុខមាត់ព្រាននោះ មិនឱ្យធ្វើដំណើរទៅបាន. ព្រានកើតម្ហម៉ៅក្តៅចិត្តស្រែកជេរថា អាសត្វកាឡកណ្ណី ហេតុអ្វីបានជាហើមកស្ទាក់មុខអញ ទំនងជាមានគ្រោះថ្នាក់ដល់អញទេដឹង ឬមួយយ៉ាងណា ?ថាដូច្នោះហើយ ក៏ត្រឡប់វិលទៅដេកឯផ្ទះវិញ មួយស្របក់ក្រោកឡើងកាន់លំពែងដើរចេញ

តាមទ្វារខាងលិចផ្ទះ. ឯរងាវកកឃើញហើយ ក៏ហើរទៅស្ទាក់ធាបមុខមាត់ព្រាននោះទៀត ព្រានក្ដៅចិត្តខ្លាំងពេកដើរទៅមិនរួច ក៏ត្រឡប់វិលទៅដេកឯផ្ទះម្ដងទៀតឈប់ចេញទៅក្នុងថ្ងៃនោះ ។ ស្ដេះប៉ុណ្ណេះ នឹងនិយាយអំពីអណ្ដើក ក្រោយដែលរងាវកកមកនោះ ក៏ខំប្រឹងខាំខ្សែអន្ទាក់ ដរាបទាល់តែឈាមធ្មេញអស់ ដាច់បានតែត្រឹមពីរធ្នុងនៅសល់ ១ ធ្នុង នឿយហត់អស់កម្លាំង នឹងខំប្រឹងខាំតទៅទៀតមិនបាន ក៏ក្រាបដេកក្បែរអន្ទាក់នោះឯង ។ លុះដល់ព្រឹកឡើងព្រានភ្ញាក់ពីដេក ម្ដីម្នាប្រវាចាប់យកលំពែងដើរចេញទៅ ប្រាថ្នានឹងទៅមើលអន្ទាក់ម្ដងទៀត ។ វេលានោះរងាវកក ក៏ឈប់ហើរទៅធាបមុខមាត់ព្រានទៀតព្រោះគិតថាយូរក្រែលដែរហើយ ល្មមអណ្ដើកខាំខ្សែអន្ទាក់បាន ក៏ហើយទៅមុខព្រានដោយប្រញាប់ លុះទៅដល់ទើបសួរទៅអណ្ដើកថា ? បើយសំឡាញ់ ឯងខាំអន្ទាក់ដាច់ហើយនៅ ? អណ្ដើកថាមិនទាន់បានដាច់អស់ទេសំឡាញ់ បានតែ ២ ធ្នុងនៅសល់ ១ ធ្នុងទៀត ឥឡូវឈាមហូរចេញអំពីមាត់អញ ។ ខំប្រឹងខាំតទៅទៀតមិនបានទេ អស់កម្លាំងណាស់អញឈប់សំរាកបន្តិចសិន ។ រងាវកកថា ឈប់សំរាកឯណា

បានព្រានជិតមកដល់ហើយ ។ អណ្ដើកថាមិនដឹងធ្វើម្ដេចទេ អញខាំទៀតលែងកើតហើយ បើសំឡាញ់ឯងគ្រាន់បើ ជួយខាំអញបន្តិចទៅ ។

សត្វទាំងពីរកំពុងតែនិយាយគ្នា មិនយូរប៉ុន្មាន ក៏ស្រាប់តែព្រានទៅដល់ ឃើញប្រើសជាប់អន្ទាក់ដូច្នោះ កាន់លំពែងស្ទុះទៅបម្រុងនឹងចាក់ ។ ប្រើសភ័យណាស់ ក៏ប្រឹងលើកជើងកន្ត្រាក់ខ្សែអន្ទាក់ដាច់អស់ ១ រំពេច ហើយបោលគេចចូលព្រៃ ព្រានក៏នឹកតូចចិត្តពេក ក្រឡេកមើលទៅឃើញអណ្ដើកដេកក្បែរទីនោះ ក៏ស្ទុះទៅចាប់រើសដាក់ក្នុងស្បោងយកទៅដាក់ពាក់លើដង្គត់ឈើ ។ ឯប្រើសងាកមើលមកក្រោយវិញ ឃើញព្រានចាប់អណ្ដើកដាក់ក្នុងស្បោងយកទៅពាក់លើដង្គត់ឈើដូច្នោះ ក៏មានចិត្តអាណិត គិតថាឱសំឡាញ់អញកាលបើមានទុក្ខ ជួយដោះទុក្ខអញបាន ឥឡូវសំឡាញ់មានទុក្ខ ត្រូវតែអញជួយវិញ គិតដូច្នោះហើយ ធ្វើជាបោលតិចៗ បញ្ឆោតព្រាន ព្រានក៏រត់ដេញតាមប្រើសចូលក្នុងព្រៃជ្រៅ ទើបប្រើសរត់គេចមកខាងក្រោយ បុករំធស្បោងនោះដាច់ធ្លុះធ្លាយអណ្ដើកដល់ដី ហើយពាំយកអណ្ដើកចូលទៅក្នុងព្រៃបាត់ទៅ លុះព្រានរកប្រើសមិន

ឃើញ ក្រឡប់វិលមកវិញ បាត់អណ្តើកទៀត ក៏កើតទោមនស្សក្តៅចិត្តវិលត្រឡប់ទៅផ្ទះវិញហោង ។

សត្វទាំងបី ក៏បានទៅជួបជុំគ្នា ស្រឡាញ់គ្នាត្រាតែអស់ជីវិតរៀងខ្លួន ។

# ៣៩- រឿងខន្តិវាទិតាបស

( ចាក ខ. ធ. )

( កុំធ្វើបាបមនុស្សមានខន្តី ប្រយ័ត្នផែនដីស្រូប )

កាលកន្លងទៅហើយ ព្រះពោធិសត្វរបស់យើង សោយព្រះជាតិជាព្រាហ្មណ៍ នាមកុណ្ឌៈ នៅក្នុងក្រុងពារាណសី មានការនឿយណាយនឹងកិច្ចមានរវល់ក្រៃពេក ក៏ចេញទៅបួសជាតាបស នៅអាស្រ័យក្នុងហេមវន្ត ហើយក៏មានបំណងចង់ឆាន់វត្ថុប្រៃ និងជូរ ក៏ត្រឡប់មកកាន់ក្រុងពារាណសីវិញ គង់នៅក្នុងឧទ្យានរបស់សេនាបតីម្នាក់ ជាអ្នកទំនុកបំរុង ។ ថ្ងៃមួយព្រះរាជា ស្រវឹងស្រាជោគជាំ មានស្រីរបាំចោមរោមជាបរិវារ យាងទៅកាន់ឧទ្យាន ផ្ទំកើយព្រះសិរលើភ្លៅស្ត្រីពេញព្រះទ័យមួយរូបលង់លក់ស្កប់ទៅ ។ គ្រានោះស្ត្រីទាំងឡាយដទៃ ឃើញព្រះរាជាផ្ទំលក់ហើយ ក៏បបួលគ្នាទៅកាន់ឧទ្យាន ឃើញព្រះពោធិសត្វគង់ទៀបគល់សាលព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយត្រសាយ សុំសាខាសំយុងមែកចុះមកក្រោម ហើយថ្វាយបង្គំអង្គុយស្ដាប់ធម៌ដោយសេចក្ដីគោរព ។ ព្រះរាជាតើនឡើងមិនឃើញស្រីទាំងនោះទ្រង់ខ្ញាល់ជាខ្លាំង ហើយចាប់ព្រះខ័នយាងទៅ

កាន់សំណាក់តាបស ពេលនោះស្រីម្នាក់ដែលមានសេចក្តីស្និទ្ធិស្នាលនឹងព្រះរាជាជាងគេ ស្ទុះទៅចាប់ព្រះខ័នពីព្រះហស្តព្រះអង្គ ព្រះរាជាសួរពោធិសត្វដោយអាការគួរខ្លាចថា នែស្រមណ៍កំណោ អ្នកចូលចិត្តនិយាយថាម៉េច បពិត្រមហារាជ អាត្មាភាពចូលចិត្តនិយាយថា ខន្តី ។ យ៉ាងម៉េចហៅថាខន្តី ការមិនបៀតបៀនសត្វទាំងឡាយ មិនធ្វើបាបសត្វទាំងឡាយ មិនប្រទូស្តចំពោះសត្វទាំងឡាយ ដែលជេរប្រហារផ្តាសារចំពោះខ្លួន ។ ព្រះរាជាគិតថា អញបានឃើញខន្តីរបស់តាបសនោះឥឡូវហើយ ហើយត្រាស់ហៅបុរសអ្នកសម្លាប់ចោរមកបង្គាប់ថា ចូលអ្នកទាញតាបសចង្រៃនេះផ្តួលលើផែនដី ហើយយករំពាត់មានបន្លាមកវាយពីរពាន់រំពាត់ គឺខាងមុខ ប្រាំរយរំពាត់ ខាងក្រោយ ប្រាំរយរំពាត់ខាងឆ្វេងប្រាំរយរំពាត់ ខាងស្តាំប្រាំរយរំពាត់ដូចគ្នា ។ បុរសនោះធ្វើយកចិត្តទុកដាក់តាមព្រះរាជបញ្ជា ។ ព្រះរាជាត្រាស់សួរម្តងទៀតថា អ្នកចូលចិត្តនិយាយថាម៉េច ? បពិត្រមហារាជ អាត្មាភាពចូលចិត្តនិយាយថា ខន្តី ។ តែព្រះអង្គបែរជាសំគាល់ថា ខន្តីនៅនាចន្លោះស្បែកអាត្មាភាពទៅវិញ? មិនមែននៅចន្លោះស្បែកទេព្រះអង្គ ខន្តីនេះ នៅក្នុង

ចន្ទោះបេះដូងដ៏ជ្រៅរបស់អាត្មាភាព ។ នែអ្នក ចូរកាត់ដៃជើងតាបសនេះឱ្យដាច់ ។ រាជបុរសក៏កាត់តាមព្រះរាជបញ្ជា ។ ព្រះរាជាត្រាស់សួរជាគំរប់ ៣ ដងថា អ្នកចូលចិត្តនិយាយថាម៉េច ? បពិត្រមហារាជ អាត្មាភាពចូលចិត្តនិយាយថាខន្តី តែព្រះអង្គបែរជាសំគាល់ថាខន្តីនៅនឹងដៃជើងអាត្មាទេវិញ, ខន្តីក្នុងដៃនិងជើងគ្មានទេ ។ នែអ្នកចូរកាត់ច្រមុះ និងត្រចៀកតាបសនេះឱ្យដាច់ ។ បុរសនោះក៏ធ្វើតាមព្រះរាជបញ្ជាដូចលើកមុន ។ ព្រះរាជាត្រាស់សួរតែពាក្យដដែល ១ តាបសក៏ឆ្លើយតែពាក្យដដែល១ ដូចគ្នាដរាបតែព្រះរាជាខ្ញាល់ជាខ្លាំង លើកជើងទាត់កណ្ដាលដើមទ្រូងព្រះពោធិសត្វ មួយជើងក៏ងយ៉ាងធ្ងន់ ទើបថយចេញទៅ ក៏ត្រូវផែនដីស្រូបស្បែរឱឡាន ឱ្យទៅកើតក្នុងអវិចីមហានរក មានអណ្ដាតភ្លើងក្រហមច្រាលឆ្អៅ ឆេះរោលរាលស្រោបពេញខ្លួន ។ គ្រាន់តែស្ដេចអសប្បុរសចេញទៅភ្លាមសេនាបតីចូលទៅជូតឈាមព្រះពោធិសត្វ ហើយឱ្យលោកគង់ចុះនិយាយយ៉ាងនេះថា ប្រសិនបើលោកម្ចាស់ដ៏ចំរើនខ្ញាល់ គួរខ្ញាល់ចំពោះតែព្រះរាជា ដែលធ្វើកំហុសដល់លោកម្ចាស់, សូមកុំខ្ញាល់នឹងជនដទៃ ។ តាបសស្ដាប់ពាក្យនោះ

ហើយពោលគាថាថា ៖

យោ មេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ

ចិរំ ជីវតុ សោ រាជា នហិ កុជ្ឈន្តិ មាទិសា ។

ព្រះរាជាអង្គណា ត្រាស់បង្គាប់ឱ្យកាត់ដៃ-ជើង-ត្រចៀក និងច្រមុះអាត្មា, សូមឱ្យព្រះរាជាអង្គនោះមានព្រះជន្មវែងបណ្ឌិតទាំងឡាយ អម្បាលយ៉ាងអាត្មាមិនខឹងផ្តេសផ្តាសទេ ។

តាបសពោលយ៉ាងនេះហើយ ក៏ធ្វើមរណកាលក្នុងឱទ្យាននាថ្ងៃនោះឯង។ ព្រោះហេតុនោះព្រះភគវាត្រាស់ថា

អហុ អតីតមទ្ធានេ សមណោ ខន្តិទីបនោ

តំ ខន្តិយាយេវ ឋិតំ កាសិរាជា អឆេទយិ ។

ក្នុងកាលដ៏យូរលង់ហើយ សមណៈអ្នកពោលសរសើរខន្តីត្រូវស្តេចកាសីប្រើគេឱ្យសម្លាប់ខ្លួន ដែលឋិតនៅក្នុងខន្តី ។

ស្តេចកលាបុក្នុងកាលនោះ គឺភិក្ខុទេវទត្តក្នុងកាលឥឡូវនេះ ឯខន្តីវាទីតាបស គឺព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូយើងនេះ ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៤០ រឿងសច្ចខាធិនី

(បាក ម. អ.)

(និយាយពាក្យពិត គង់បានទៅកើតក្នុងស្ថានទេវលោក)

ពីដើមមានស្ត្រីម្នាក់ មិនបានឱ្យទាន មិនបានធ្វើការបូជា មិនបានស្តាប់ធម៌ទេក្នុងមួយជាតិនេះ គ្រាន់តែរក្សាពាក្យសច្ចប៉ុណ្ណោះ លុះស្លាប់ទៅ បានទៅកើតក្នុងស្ថានទេវលោក សោយទិព្វសម្បត្តិជាសុខសានសម្រាន្តសម្រួលកាយដោយសិរី មានបរិវារគាល់ជាច្រើន ។ គ្រាក្រោយព្រះមហាមោគ្គល្លាន មានឥទ្ធិឫទ្ធិច្រើន បានថ្វាយបង្គំទូលលាព្រះបរមសាស្តាជាម្ចាស់ទៅកាន់ស្ថានទេវលោក ដើម្បីនឹងបានពិនិត្យស្ថានភាពផ្សេងៗ និងសួរបុញ្ញកម្មខ្លះៗ យកមកផ្សាយក្នុងជម្ពូទ្វីបនេះ ។ កាលព្រះសាស្តាអនុញ្ញាតហើយ ក៏និមន្តទៅឋិតនៅទៀបទ្វារនៃទេពធីតាម្នាក់ ។ នាងក៏ចេញមកថ្វាយបង្គំដោយសេចក្តីគោរព ។ ព្រះថេរៈសួរថា នាងធ្វើបុញ្ញកម្មដូចម្តេច បានជាមានសម្បត្តិស្តុកស្តម្ភយ៉ាងនេះ ? ទេពធីតាខ្មាស់ព្រះថេរៈណាស់ ធ្វើឈាក់ល្មៀម មិនចង់ប្រាប់សោះ តែដោយលោកជំរិតសួរខ្លាំងពេក អត់ទ្រាំមិនបាន ក៏ទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឥតដែល

បានធ្វើបុណ្យកុសលអ្វីនឹងគេទេ កាលកើតជាមនុស្សនោះ គ្រាន់តែរក្សាសច្ចប៉ុណ្ណោះ. សម្បត្តិទាំងនេះ កើតឡើង ដោយពាក្យសច្ចៈ ដែលខ្ញុំបានរក្សានឹងថាកើតពីកុសលកម្ម ដទៃឥតអង្គីមានឡើយ ។ ព្រះថេរៈ កាលជ្រាបដំណើងសព្វ គ្រប់ហើយ ក៏ត្រឡប់ពីទេវលោកមកវិញ ចូលទៅថ្វាយបង្គំ ព្រះបរមសាស្ដាឯវត្តជេតពន ទូលសួរថា បពិត្រសម្ដេចព្រះ មានព្រះភាគដ៏ចំរើន បុគ្គលដែលគ្រាន់តែរក្សានូវសច្ចៈ មិន បានធ្វើបុណ្យទានអ្វីទេ ហើយបានទៅកើតក្នុងទេវលោក សោយសម្បត្តិទិព្វមានឬទេ ? ព្រះសាស្ដាតបថា នែមោគ្គ ល្លាន ម្ដេចក៏អ្នកចាំមកសួរតថាគត ក្រែងរឿងរ៉ាវនេះ ទេពធីតាប្រាប់អ្នកដោយសព្វគ្រប់ហើយដឹង? នែមោគ្គល្លាន សត្វទាំងឡាយ គ្រាន់តែរក្សានូវសច្ចៈខ្លះអីទៅកើតក្នុងទេវ លោក សោយទិព្វសម្បត្តិមានគគោក ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

# ៤១- រឿងសង្ខព្រាហ្មណ៍

(ចាក ស. ទ.)

(គុណនៃការធ្វើទានចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ)

ក្រុងពារាណសីកាលពីដើមមានឈ្មោះថា មោឡិនី លំដាប់នោះព្រះពោធិសត្វ កើតជាព្រាហ្មណ៍ឈ្មោះ សង្ខៈ ក្នុងនគរមោឡិនីបានធ្វើដំណើរទៅជួញដោយនាវា ក៏ស្រាប់តែឃើញព្រះបច្ចេកពុទ្ធមួយអង្គ កំពុងនិមន្តកាត់ដីខ្សាច់ប្រាកដដោយរងើកភ្លើង ក្នុងទីមានខ្យល់ និងកំដៅដ៏ឃោរឃៅក្រៃពេក មានចិត្តជ្រះថ្លាថាបុញ្ញក្ខេត្តរបស់អញមកដល់ហើយតើ ទើបយកស្បែកជើង និងឆ័ត្រមកប្រគេន ហើយត្រឡប់ទៅទូកវិញ ។ ថ្ងៃទី ៧ នាវាគាត់ក៏បែកកណ្ដាលសមុទ្រ ។ ព្រះពោធិសត្វ និងអ្នកបំរើម្នាក់ស៊ីស្ករ និងសប្បិផរាបដល់ឆ្អែតរៀងខ្លួន ក៏ឡើងទៅលើចុងក្ដោងលោតបានប្រមាណទី ១ ឧសភ ក៏ធ្លាក់ចុះក្នុងសមុទ្រនោះហែលឆ្លងទៅ ។ ព្រះពោធិសត្វហែលឆ្លងយ៉ាងនេះអស់ ៧ ថ្ងៃ ។ ពេលនោះទេពធីតាឈ្មោះមណីមេខលា ជាអាណាព្យាបាលសមុទ្រ មានបំណងនឹងស្រង់ព្រះពោធិសត្វ ក៏និម្មិតទូកជាវិការៈកែវដ៏ពេញដោយកែវ ៧ ប្រការ ហើយស្រង់ព្រះពោធិ

សត្វដាក់លើទូកនោះ តែនាងមិនអាសូរដល់ឧបដ្ឋាកព្រះពោធិសត្វសោះឡើយ ។ ព្រះពោធិសត្វ ក៏បានឱ្យចំណែកបុណ្យដែលខ្លួនបានធ្វើ ដល់បុរសនោះ ១ ក៏បានអនុមោទនានូវចំណែកបុណ្យនោះ ទេពធីតា ក៏ស្រង់បុរសនោះដាក់លើទូកទៀត ហើយនាំទូកទៅកាន់ក្រុងមោឡិនី ក៏ឱ្យនូវទ្រព្យដល់ព្រះពោធិសត្វទាំងអស់ ហើយវិលវិលមកវិញ ។

(មហា សំ - សុខ និស្សិតសាលាបាលីជាន់ខ្ពស់)

## ៤២- រឿងខ្មែរខាំប្រេត

(ចាក បេ. ខុ)

(ទោសក្បត់ស្វាមី និងមុសាវាទ)

កាលសាសនាព្រះទសពលព្រះនាមកស្សប មានគហបតីម្នាក់ ជាឧបាសកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានបបួលឧបាសក ៥០០ នាក់សុទ្ធតែបានសម្រេចសោតាបត្តិផល នាំគ្នាធ្វើទានផ្សេងៗ មានធ្វើវត្តអារាម ធ្វើស្ពានផ្លូវថ្នល់ ធ្វើទីចង្រម ធ្វើព្រះវិហារថ្វាយព្រះសង្ឃមានព្រះពុទ្ធជាប្រធាន បាននាំភរិយារបស់ខ្លួនគ្រប់គ្នា ដើរធ្វើបុណ្យទាន ពីវត្តមួយទៅវត្តមួយ មានបិតិរីករាយសើចសប្បាយរាល់ថ្ងៃ។ មានថ្ងៃមួយនោះ ភរិយាគហបតីឧបាសកនាំបរិវារ ៥០០ ទៅវត្ត ទៅដល់សាលាសំណាក់មួយ នាំគ្នាឈប់សំរាក ផ្ទួនជាមានអ្នកលេងរបាំកំឡោះពីរនាក់នៅលើសាលានោះបានឃើញពួកស្ត្រីហើយ ក៏និយាយគៀវគនាយអាយ ដោយឃើញស្ត្រីទាំងនោះមានរូបឆោមល្អឆើតឆាយឯពួកស្ត្រីទាំងនោះមិនស្ដីរកមួយម៉ាត់សោះ ។ អ្នកលេងបានទៅនិយាយនឹងបុរសម្នាក់ ឱ្យជួយនិយាយ បើបានឱ្យរង្វាន់ ១ ពាន់កហាបណៈ បុរសនោះទៅនិយាយបានលើភរិយា

គហបតីឧបាសក ។ ថ្ងៃក្រោយមកភរិយានោះ ក៏បានប្រព្រឹត្ត អសទ្ធម្មក្បត់ស្វាមីខ្លួន ហើយបានហាមប្រាមស្ត្រីបរិវារ ៥០០ របស់នាងមិនឱ្យនិយាយឱ្យស្វាមីដឹង ។ អំពើអាក្រក់លាក់ មិនកំបាំងដូចពាក្យស្លោកបុរាណថា "ជោមក្នុងទឹកគង់ធុំ ស្អុយ" ថ្ងៃមួយគហបតីឧបាសកបានដឹងថា ភរិយាខ្លួនប្រព្រឹត្ត អនាចារនឹងអ្នករបាំ ក៏ហៅទៅសួរស្វាត់កំបាំង នាងកុហក ថាមិនបានក្បត់ដូច្នោះទេ កំពុងតែនិយាយជូនជាមានឆ្កែខ្មៅ កំបុតត្រចៀកមួយរត់កាត់មុខ នាងក៏ស្បថជូនឧបាសកថា បើខ្ញុំក្បត់មែន សូមឱ្យឆ្កែខ្មៅកំបុតត្រចៀកនេះខាំស៊ីសាច់ ឈាមខ្ញុំរាល់ៗ ថ្ងៃ ។ គហបតីឧបាសក ក៏នៅមិនទាន់ជឿ ស៊ប់ ទើបហៅស្ត្រីបរិវារទាំង ៥០០ មកសួរម្នាក់ម្តង ៗ ស្ត្រី ទាំងនោះឆ្លើយតែពាក្យមួយដូចគ្នាថា ខ្ញុំមិនដឹង មិនដែល ឃើញបុរសណាទៅជិត ឬនិយាយអ្វីជាមួយម្ចាស់ស្ត្រីឡើយ បើបែរជាឃើញហើយថាមិនដឹង ខ្ញុំស្បថជូនកើតជាតិណាៗ ឱ្យកើតជាបរិវារម្ចាស់ស្ត្រីរាល់ៗ ជាតិ ។ គហបតីឧបាសក ក៏ ជឿស៊ប់ថា ភរិយាខ្លួនបរិសុទ្ធមែន ។

នាងភរិយានោះ ត្រូវទោសក្បត់ឱ្យផលក៏ចេះតែក្តៅ ញ៉ាំក្នុងខ្លួនស្គមរីងយូរៗទៅ ក៏ស្លាប់ទៅកើតជាប្រេតញីនៅ

ក្នុងចន្លោះភ្នំនាព្រៃហេមពាន្ត មានវិមានប្រាសាទសួនច្បារ និងស្រះធំមួយឈ្មោះ កណ្ណមុណ្ឌៈ ជាទីមនោរម្យក្រៃលែង ដោយអំណាចបុណ្យដែលបានធ្វើពីជាតិមុន ។ ចំណែកស្ត្រីជាបរិវារទាំង ៥០០ ដល់អស់អាយុ ក៏ទៅកើតជាបរិវារនាងទាំងអស់គ្នាព្រោះត្រូវសម្បថ ។ ឯនាងប្រេតនោះ វេលាយប់ទទួលទោសត្រូវសម្បថ បណ្ដាលឱ្យចុះពីប្រាសាទទៅក្នុងស្រះកណ្ណមុណ្ឌៈបាបកម្ម បណ្ដាលឱ្យឆ្កែខ្មៅកំបុតត្រចៀកមួយធំប៉ុនជីវី ឱ្យកើតឡើងស្ទុះទៅខាំស៊ីនាងជាកំណាត់តូចធំ ហើយកើតឡើងវិញភ្លាម ខាំស៊ីទៀតដរាបដល់ភ្លឺទើបឆ្កែនោះទៅវិញ ដល់វេលាថ្ងៃនាងសោយទិព្វសម្បត្តិ ផ្លាស់ប្ដូរតែយ៉ាងនេះរាល់វេលា ។

ថ្ងៃមួយនាងនាំពួកស្ត្រី ៥០០ ទៅលេងសួនច្បារ បេះផ្លែស្វាយទិព្វបរិភោគ ហើយបណ្ដែតលេងតាមស្ទឹងដែលហូរពីព្រៃហេមពាន្តទៅក្រុងពារាណសី ផ្លែស្វាយនោះក៏អណ្ដែតទៅជាប់នឹងសំណាញ់ នៅមុខព្រះរាជវាំងព្រះបាទព្រហ្មទត្ត ត្រង់កន្លែងដែលព្រះអង្គតែងតែទៅក្រសាលព្រះឧទកវារី ពួករាជសេវកាមាត្យ រើសផ្លែស្វាយនោះមកថ្វាយ។ ព្រះរាជាទតឃើញផ្លែស្វាយនោះអស្ចារ្យធំប៉ុនឃ្លោក មាន

ពណ៌ដូចមាស ក៏ទ្រង់ត្រាស់ឱ្យរាជសេវកាមាត្យស៊ីមើល ដល់ស៊ីទៅអាមាត្យនោះក្លាយខ្លួនទៅជាក្មេង ប្រហែលអាយុ ១៦ ឆ្នាំ មានពណ៌ល្អ មានកំឡាំងច្រើន ព្រះរាជាឱ្យរើសយក ទាំងអស់ទៅថ្វាយសោយ ក៏មានព្រះកាយពលស្រស់ល្អដូច កាលព្រះជន្ម ១៦ ឆ្នាំ ដល់សោយអស់ ព្រះរាជាចាត់រាជ បុរស ឱ្យស្វែងរកស្វាយទៀត រាជបុរសក៏មិនអាចរកថ្វាយ បាន ទើបព្រះរាជាទ្រង់ប្រជុំអ្នកខ្លាំងពូកែ ត្រាស់ថាអ្នកណា អាចទៅរកផ្លែស្វាយនេះបាន យើងឱ្យរង្វាន់ជាទីគាប់ចិត្ត ពេលនោះមានព្រានម្រឹគម្នាក់ ស្ម័លរជីវិតទៅរកផ្លែស្វាយ នោះ ។ ព្រះរាជា ក៏ចាត់ឱ្យទៅដោយរួសរាន់, ព្រានម្រឹគ ដើរទៅតាមផងស្ទឹងជាយូរថ្ងៃបានជួបនឹងឥសី ១ អង្គសួរថា ដើមស្វាយទិព្វមាននៅក្នុងទីណា ឥសីប្រាប់ថាមានក្នុងព្រៃ ហេមពាន្ត នៅត្រង់ចន្លោះភ្នំក្បែរអន្លង់ទឹកធំឈ្មោះកណ្ណ-មុណ្ឌៈចម្ងាយ ៦០ យោជន៍រាប់ពីទីនេះទៅ ។ ព្រានម្រឹគចេះ តែខំដើរស្ពាយសក្ដូវខៅតាក ឃ្លានពេកណាស់ លួកយកមក ស៊ីពេលនោះឥតឈប់បង្អង់ឱ្យយូរ ឈប់មួយតែពេលដេក ប៉ុណ្ណោះ ទៅយូរថ្ងៃបានជួបនឹងឥសី ១ អង្គទៀតសួរលោក ថា នៅប៉ុន្មានយោជន៍ទៀតទើបដល់ដើមស្វាយទិព្វ លោក

ប្រាប់ថានៅ ៣០ យោជន៍ទៀត ។ ព្រានម្រឹគខំស្រូតរូតទៅជាយូរថ្ងៃ ក៏បានជួបនឹងឥសី ១ អង្គទៀត ឥសីនេះលោកធ្លាប់ទៅដល់ បានស្គាល់ច្រកល្ហកសព្វគ្រប់ លោកប្រាប់តាមដំណើរថានៅ ១៥ យោជន៍ទៀតដល់ហើយ បើអ្នកទៅតាមស្ទឹងធំនេះឃើញមានស្ទឹងតូចមួយបែកពីស្ទឹងធំ ទៅអ្នកចូរដើរទៅតាមស្ទឹងតូចនោះ លុះទៅដល់ចន្លោះភ្នំនោះងងឹតណាស់ អ្នកត្រូវកាន់ឈើស្ងួតចងធ្វើគប់ភ្លើង អុជកាន់ដើរទៅចំនួន ៣ យោជន៍នឹងដល់ដើមស្វាយទិព្វនោះហើយ ។

ព្រានម្រឹគក៏ដើរទៅធ្វើតាមបង្គាប់ឥសី បានដល់ទៅដើមស្វាយទិព្វនោះ ស្រាប់តែភ្លឺស្រឡះ មានស្រះធំមានច្បារមានប្រាសាទល្អៗ ត្រកាល ។ មួយស្របក់ពុំទាន់បានបេះផ្លែស្វាយផង ស្រាប់តែឃើញស្រី ៥០០ នាក់រត់ប្រសាចមករក ខ្លះសើច ខ្លះបោយដៃហៅថា អ្នកស្វាមីអ្នកបង ។ ព្រានម្រឹគជាមនុស្សកាឡកណ្ណី មានរាសីទន់ ក៏ភិតភ័យ រត់ត្រឡប់មកវិញទាល់តែដល់ក្រុងពារាណសី ចូលទៅក្រាបទូលព្រះបាទព្រហ្មទត្តថា ទូលព្រះបង្គំបានទៅដល់ឃើញដើមស្វាយទិព្វមានផ្លែយោនរយាន រៀបតែនឹងឡើងបេះ ស្រាប់តែឃើញស្ត្រីល្អៗ ដូចទេវតារត់សើចក្អាកក្អាយមករកទូលព្រះ

បង្គំ ៗ ក៍យកក់ស្មុតទើបរត់ត្រឡប់មកវិញ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះហើយមានព្រះទ័យច្រូលច្រាល់ស្ដេចយាងទៅ ទើបរៀបចំប្រគល់រាជសម្បត្តិឱ្យមហាមាត្យថែរក្សា ក៏ស្ដេចយាងទៅជាមួយព្រានម្រឹគ ។ កាលបើស្ដេចយាងទៅជិតដល់ ទតឃើញច្បាស់ហើយ ឱ្យព្រានម្រឹគត្រឡប់មកនគរវិញ ។ ព្រះរាជាបានយាងចូលទៅក្នុងច្បារ ពួកស្ត្រីបរិវារ ៥០០ ឃើញហើយ រត់មកថ្វាយបង្គំនាំទៅប្រាសាទ ។ នាងប្រេតចេញមកទទួលព្រះរាជា សួរដំណឹងសព្វគ្រប់ដឹងថាព្រះចៅក្រុងពារាណសី ក៏ថ្វាយខ្លួនជាបាទបរិចារិកា នាំព្រះអង្គទៅស្រង់ទឹកកណ្ណមុណ្ឌទហៈស្រេចហើយថ្វាយសំពត់ទិព្វថ្វាយព្រះស្ងោយទិព្វនាំស្ត្រី៥០០ច្រៀងរាំថ្វាយនាំក្រសាលក្នុងច្បារ ព្រះរាជាសោយព្រះស្ងោយសោយផ្លែស្វាយហើយស្រេច មានព្រះកាយពលស្រស់បស់ហាក់ដូចជាទេវបុត្រសុទ្ធវិស័យ ដល់ពេលរាត្រី ក៏ផ្ទំក្នុងប្រាសាទជាមួយនាងប្រេតនោះ ប៉ុន្តែព្រះរាជាពុំដឹងស្ត្រីទាំងនោះជាពួកប្រេតឡើយ ។ ជាពិសេសគឺ ក្នុងប្រេតស្ថាននោះសុទ្ធតែស្ត្រីទាំងអស់ មានបុរសតែព្រះអង្គមួយ ប៉ុណ្ណោះ ។

ចំណែកនាងប្រេតនោះ ជាធម្មតាតែដល់ពេល

អាជ្រាតុ នាងចុះទៅឈរក្បែរឆ្នេរស្រះកណ្ដមុណ្ឌៈ ផ្លែខ្មៅ កំបុតត្រចៀកកើតឡើងភ្លាម ខាំស៊ីដាច់ជាកំណាត់តូចធំ ស្លាប់កើត ១ ផរាបដល់ផិតភ្លឺផុតអំណាចកម្ម នាងឡើងចូល ទៅផ្ទំក្បែរព្រះរាជាវិញ តែយ៉ាងនេះរាល់ៗ ថ្ងៃចំនួន ៤០ ឆ្នាំ គត់ គិតពីត្រឹមដែលព្រះរាជាស្ដេចយាងទៅ ប៉ុន្តែព្រះរាជា ឥតដឹងសោះ ព្រោះផលកម្មរបស់នាងបិទបាំង ។ ថ្ងៃមួយ ចុងក្រោយនាងសោយកម្មអស់ ព្រះរាជាទ្រង់តើនពី កណ្ដាលអជ្រាតុ ចាត់មិនឃើញនាង ក៏ស្ដេចតាមរកមើល ឃើញផ្លែកំពុងខាំជាកំណាត់ ១ ទើបទ្រង់យកព្រះខ័នចុះទៅ កាប់ផ្លែនោះ កាប់ដាច់ជាពីរកំណាត់កើតផ្លែពីរឡើងខាំទៀត កាប់ដាច់ផ្លែពីរនោះជាបួនកំណាត់ កើតផ្លែបួន, កាប់ដាច់ បួនកើត ៨, កាប់ដាច់ ៨ កើត ១៦,ទើបនាងប្រេតស្រែកថា ព្រះអង្គកុំធ្វើដូច្នោះ បើព្រះអង្គជួយសង្គ្រោះខ្ញុំ សូមខាក ស្ដោះទៅលើផែនដី ហើយយកព្រះបាទឈ្លី ទើបផលខ្ញុំអស់ ផ្លែលែងកើតទៀត ។ ព្រះរាជាទ្រង់ធ្វើតាម ក៏វិនាសកម្មពៀ ក្នុងពេលនោះឯង ។ ប្រេតក្រាបទូលថាកម្មខ្ញុំព្រះអង្គអស់ ត្រឹមនេះហើយ លែងសោយផលដូច្នេះទៀតហើយ ។ ព្រះ រាជាត្រាស់សួរថា ផលកម្មដូចម្ដេចពីជាតិមុនបានជាដូច្នេះ.

នាងក្រាបទូលតាមដំណើរ ព្រះរាជាបានជ្រាបសព្វគ្រប់ថា នាងនោះជាប្រេត ក៏មានព្រះទ័យអផ្សុកលានាងត្រឡប់ទៅនគរវិញ ទោះបីនាងដឹងច្បាស់ថា ព្រះរាជាមិនព្រមនៅជាមួយទៀតហើយ ក៏យកសម្បត្តិទិព្វជាច្រើនបូជាព្រះអង្គ ហើយហោះនាំបីពរព្រះរាជាទៅដាក់ដល់ប្រាសាទ នាក្រុងពារាណសី ហើយថ្វាយបង្គំឱបព្រះបាទាយំសោកលាត្រឡប់មកលំនៅខ្លួនវិញហោង ។

ចំណែកខាងព្រះរាជា មានព្រះទ័យអាណិតក្រៃពេកទ្រង់ហូរទឹកព្រះនេត្រខ្សឹកខ្សួលក្នុ[illegible]ព្រះរាជហឫទ័យ លុះបន្ទោរបង់សេចក្ដីខ្សឹកខ្សួលហើយ ក៏កើតធម្មសង្វេគយល់ច្បាស់នូវកម្ម និងផលរបស់កម្ម ទើបទ្រង់បរិច្ចាគទានរក្សាសីលដរាបដល់ទីវង្គត ទៅកើតនាស្ថានសួគ៌ទេវលោកហោង ។

លុះដល់មកក្នុងពុទ្ធកាលយើងនេះ កាលព្រះអង្គសំដែងធម្មចក្រហើយ គង់នៅក្បែរក្រុងសាវត្ថី, កាលនោះព្រះមហាមោគ្គល្លាន បាននិមិត្តទៅព្រៃហេមពាន្ត ទតឃើញប្រេតនោះ ព្រមទាំងបរិវារទាំង ៥០០ នាក់ដើរលេងត្រៀបត្រាក្បែរស្រះកុណ្ឌមុណ្ឌៈ ក៏ត្រាស់សួរប្រវត្តិបុព្វកម្មរបស់នាង បានដឹងសព្វគ្រប់អស់ហើយ និមន្តវិលត្រឡប់ទៅកាន់

សំណាក់ព្រះសម្ពុទ្ធបរមគ្រូ ក្រាបទូលតាមដំណើររឿង ។ ព្រះបរមគ្រូ ទ្រង់ប្រជុំពុទ្ធបរិស័ទទាំងគ្រហស្ថបព្វជិត ហើយមានព្រះតម្រាសថា នាងប្រេតនោះ តថាគតបានឃើញបានដឹងប្រវត្តិបុព្វកម្មសព្វគ្រប់ តាំងតែពីតថាគត ទើបនឹងត្រាស់ដឹងអនុត្តរធម៌ នៅលើរតនបល្ល័ង្គ ក្រោមម្លប់ពោធិព្រឹក្សម្ល៉េះ តែគ្មានអ្នកដទៃជាសាក្សី ទើបតថាគតស្ងៀម. ទ្រង់មានព្រះតម្រាស់ដូច្នេះហើយ ក៏ប្រារព្ធសំដែងធម៌ទេសនា យករឿងប្រេតនោះជាហេតុ ទីបំផុតទ្រង់ប្រកាសអំពីអរិយសច្ចធម៌ ៤ ប្រការ. ពុទ្ធបរិស័ទទាំងឡាយស្តាប់ហើយ មានសទ្ធាជ្រះថ្លា បានសម្រេចមគ្គផលតាមនិស្ស័យរៀង១ ខ្លួន ។ និទានរឿងប្រេតឆ្កែខាំចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

រឿងនេះក្នុងគម្ពីរមង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រ មានសំដែងខ្លី១ តាមបែបសង្ខិត្តសុត្តវណ្ណនា ហើយបានចង្អុលប្រាប់ថា មានពិស្តារក្នុងគម្ពីរបេតវត្ថុត្រង់តណ្ណមុណ្ឌបេតវត្ថុណ្ណនា ដូចសំដែងមកនេះឯង ។

# ៤៣- រឿងសមុទ្ទទេវតា

(បាក ស. តិ.)

(សេចក្ដីលោភនាំសត្វឱ្យហួងហែងហួសហេតុ)

កាលពុទ្ធសម័យព្រះសម្ពុទ្ធបរមគ្រូ ទ្រង់រំលឹកផាស់តៀនឧបនន្ទភិក្ខុ ដែលមានសេចក្ដីលោភគ្របសង្កត់ គឺធម្មតារបស់ភិក្ខុឧបនន្ទ តែដល់រដូវចូលវស្សាហើយ លោកដើរទៅចូលវស្សាធ្វើគ្រប់វត្ត ដែលលោកអាចទៅបាន. វត្តខ្លះលោកទុកស្បែកជើង ខ្លះដំរងទឹក. ខ្លះទ្រនាប់ជើង. ខ្លះធ័គ្រជាដើម ឱ្យចូលវស្សាជំនួសលោក ដល់ចេញវស្សាលោកទៅវាយចំណែកលាភគ្រប់វត្ត ដែលលោកបានទុករបស់ទាំងនោះ ដឹកទាំងរទេះៗ យកមកប្រមូលទុកក្នុងកុដិរបស់លោក ។ ពួកភិក្ខុទាំងឡាយទ្រាន់ចិត្ត នាំគ្នាទូលព្រះសម្ពុទ្ធតាមដំណើររឿង ព្រះអង្គទ្រង់ប្រជុំសង្ឃ ហើយហៅឧបនន្ទ មករំលឹកតាមលំនាំព្រះពុទ្ធពីបូរាណ ទើបនាំអតីតនិទានមកសំដែងថា ភិក្ខុឧបនន្ទនេះ មិនមែនចង់បានឥតរបបតែក្នុងជាតិនេះទេ កាលពីដើមក៏ដូច្នេះដែរ ។ ពីព្រេងនាយយូរហើយ ព្រះពោធិសត្វកើតជាសមុទ្ទទេវតា ថែរក្សាមហាសមុទ្ទ កាលនោះមានក្អែកទឹកមួយ នៅអាស្រ័យនឹង

សមុទ្ទនោះ ជាសត្វមានសេចក្ដីលោភច្រើន មួយថ្ងៃៗ ហើរមុជមើបៗ ក្នុងទឹកសមុទ្ទ ស្រែកប្រាប់ត្រីទាំងឡាយកុំឱ្យផឹកទឹកច្រើន ក្រែងអស់ទឹកសមុទ្ទ ។ ដោយសេចក្ដីហួងហែងហួសហេតុនេះ សមុទ្ទទេវតាទ្រាន់ចិត្តពេក ស្ដីតិះដៀលឱ្យក្អែកទឹកនោះថា នែ ! ក្អែកទឹកអប្បឥតប្រាជ្ញា លោភលន់ហួសហេតុ ទឹកសមុទ្ទនេះជ្រៅណាស់ មិនចេះស្រកមិនចេះជន់ទេ សូម្បីហួរចាក់ទៅក្នុងទីទំនាបច្រើនយ៉ាងណា ក៏មិនអស់ដែរ. យើងនៅថែរក្សាសមុទ្ទមកយូរហើយ មិនដែលឃើញអ្នកណាលោភហួងហែងហួសហេតុដូច្នេះទេ ។ តិះដៀលហើយនិម្មិតខ្លួនយ៉ាងធំ ដេញក្អែកទឹកនោះឱ្យរត់ចាក់ទៅ ។

ប្រជុំជាតក ក្អែកទឹកក្នុងកាលនោះគឺភិក្ខុឧបនន្ទ. សមុទ្ទទេវតាគឺតថាគតនេះឯង ។

# ៨៤- រឿងប្រគញ្ញីស៊ីខ្ទុះឈាម

(ចាក បេ. ខុ.)

(ទោសប្រមាថមើលងាយទានរបស់ជនដទៃ)

សម័យពុទ្ធកាល មានភិក្ខុ ១២ អង្គ រៀនយកព្រះកម្មដ្ឋានអំពីសំណាក់ព្រះសាស្តាហើយ នាំគ្នាចូលទៅក្នុងព្រៃរកទីស្ងាត់ ក៏បានទៅដល់ព្រៃរបោះមួយ ក្បែរក្រុងសាវត្ថី ។ កាលនោះមានជាងតម្បាញ ១៨ នាក់នៅក្នុងក្រុងសាវត្ថីនោះ បានដឹងថាមានភិក្ខុ ១២ អង្គទៅគង់នៅក្នុងព្រៃរបោះជិតលំនៅខ្លួន ក៏នាំចូលទៅថ្វាយបង្គំបវារណាបច្ច័យ ៤ និមន្តមកទទួលភត្តឯគេហស្ថានរបស់ខ្លួន ។ ជាងតម្បាញជាធំទទួលយកភិក្ខុពីរអង្គ ក្រៅពីនោះជាងតម្បាញម្នាក់យកភិក្ខុ ១ អង្គទៅប្រគេនចង្ហាន់ឯផ្ទះរៀង ៗ ខ្លួន ហើយនិមន្តឱ្យចាំវស្សានៅព្រៃនោះ ។

ចំណែកភរិយាជាងតម្បាញជាធំនោះ ជាស្ត្រីមិច្ឆាទិដ្ឋិ មិនជ្រះថ្លានឹងភិក្ខុសង្ឃសោះ ជាងតម្បាញខឹង ក៏យកប្អូនស្រីនៃភរិយានោះ មកធ្វើជាភរិយា ប្រគល់ទ្រព្យសម្បត្តិឱ្យជាធំក្នុងផ្ទះ នាំគ្នាធ្វើទាន មានប្រគេនចីវរជាដើមដល់ភិក្ខុសង្ឃ ។ លុះធ្វើទានហើយ ភរិយាមិច្ឆាទិដ្ឋិនោះ និយាយប្រមាថមើល

ងាយទាន ដែលស្វាមីបានធ្វើថា បាយទឹកដែលអ្នកឱ្យភិក្ខុសង្ឃឆាន់ នឹងឱ្យផលបុណ្យដល់អ្នកជាលាមក ខ្ទុះ ឈាម ឯចីវរដែលអ្នកប្រគេនលោកនោះ ឱ្យផលជាភ្លើងឆេះស្រោបកាយអ្នកជាប្រាកដ ។

សង្ខេបសេចក្តីតែប៉ុណ្ណេះ ដល់នាងភរិយាមិច្ឆាទិដ្ឋិនោះស្លាប់ ទៅកើតជាប្រេតញីនៅក្បែរព្រៃធំមួយ, ឯជាងតម្បាញជាប្តីរបស់នាងមិច្ឆាទិដ្ឋិនោះ ស្លាប់ទៅកើតជារុក្ខទេវតា មានស័ក្តិធំ នៅអាស្រ័យលើដើមឈើក្នុងព្រៃធំនោះឯង ។

គួរអស្ចារ្យណាស់ ប្រេតញីនោះ តាំងពីកើតឡើងពុំដែលបានចំណីអាហារស៊ី បានផឹកទឹក និងសំពត់ស្លៀកម្តងសោះ ទទួលទុក្ខវេទនារកប្រៀបគ្មាន ចេះតែដើររុកព្រៃស្រែកថ្ងូររកចំណីអាហារ ក៏បានទៅជួប នឹងរុក្ខទេវតាជាស្វាមីពីជាតិមុននោះ ស្រែកសុំបាយទឹកស៊ីផឹក, រុក្ខទេវតា ក៏យកចំណីអាហារទិព្វមកឱ្យស៊ី ប្រេតញីនោះគ្រាន់តែដាក់ដល់មាត់ ក៏ក្លាយទៅជាលាមកខ្ទុះឈាម, មើលទៅខ្លួនអាក្រាតទទេ មានសេចក្តីអៀនខ្មាស់ ស្រែកសុំសំពត់ទៀតរុក្ខទេវតាយកសំពត់ទិព្វឱ្យ ប្រេតញីទទួលយកទៅគ្រប

ដណ្ដប់ ក៏ក្លាយទៅជាភ្លើងឆេះសន្ធោសន្ធៅ ប្រកាច់ស្រែក ទ្រហោយំ ទូញទាល់តែរលាស់សំពត់នោះចោលចេញ ។ ទទួលតែសេចក្ដីទុក្ខបែបនេះជាយូរខែយូរឆ្នាំ ។

ក្នុងថ្ងៃមួយមានភិក្ខុមួយអង្គ ចេញវស្សាហើយ ចង់ទៅថ្វាយបង្គំព្រះបរមគ្រូ ក៏សុំដោយសារជាមួយឈ្មួញរទេះទៅក្រុងសាវត្ថី ទៅដល់ក្បែរព្រៃធំនោះ ដាក់រទេះឈប់សម្រាកភិក្ខុ ក៏ចូលទៅក្នុងព្រៃក្រាលសង្ឃដី សឹងក្រោមម្លប់ឈើមួយ. ពួកឈ្មួញរទេះដល់ពេលចេញដំណើរទៅទៀត រកភិក្ខុនោះ មិនឃើញក៏បររទេះហួសទៅ ។ ដល់ល្ងាចភិក្ខុនោះភ្ញាក់ឡើង រកឈ្មួញរទេះមិនឃើញចេះតែដើរតាមគន្លងរទេះ ដល់យប់ងងឹតមើលគន្លងរទេះមិនឃើញ ក៏វង្វេងចូលទៅក្នុងព្រៃជ្រៅ ។ រុក្ខទេវតាឃើញភិក្ខុនោះ ក៏ចុះពីចុងឈើ បង្ហាញខ្លួនឱ្យភិក្ខុឃើញ នាំលោកទៅក្បែរគល់ឈើនិមិត្តជាប្រាសាទ និមន្តឱ្យស្រង់ទឹករៀបកន្លែងប្រគេនសឹង ដល់ព្រឹកប្រគេនចង្ហាន់ឆាន់ទៀត ។ លុះឆាន់ហើយ ស្រាប់តែប្រេតញីនោះទៅសុំអាហារចំណី ទេវតានោះទៀត ។ ទេវតាឱ្យ ស៊ីដូចមុន ចំណីអាហារក្លាយទៅជាលាមកខ្ទុះឈាម ឱ្យសំពត់ស្លៀកក្លាយទៅជាភ្លើង ភិក្ខុឃើញ

ហើយ កើតសង្វេគអស្ចារ្យទើបសួរទេវតា ។ ប្រាប់បុព្វកម្មសព្វគ្រប់ហើយសួរ ទៅភិក្ខុនោះវិញថាធ្វើដូចម្តេចទើប ឱ្យប្រេតនេះបានស៊ីចំណី បានស្លៀកសំពត់កើត ? ភិក្ខុនោះប្រាប់ថា ឱ្យយកចំណីអាហារសំពត់ទៅប្រគេនដល់សង្ឃ ហើយឧទ្ទិសផលឱ្យទើបបាន ។ រុក្ខទេវតាក៏យកសំពត់ ចំណីអាហារនាំបង្ហាញផ្លូវ ភិក្ខុនោះទៅវត្តជេតពន ទៅប្រគេនព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយឧទ្ទិសផលឱ្យប្រេតញីនោះ ។ ក៏បានស៊ីចំណីអាហារ ស្លៀកពាក់ រួចកម្មពៀរក្លាយខ្លួន ទៅជារុក្ខទេវធីតាក្នុងវេលានោះហោង ។

(ចប់ភាគ ៣)

សូមចាំអានភាគ ៤ ទៀត

# ១~ រឿងប្រេត៤នាក់

(ចាក បេ, ខុ.)

(អំពើទុច្ចរិតជាពូជនៃពៀរទាំងឡាយ

កាលព្រះសម្ពុទ្ធគង់នៅវត្តជេតពននាក្រុងសាវត្ថី មានឈ្មួញម្នាក់ជួញស្រូវបានយកសំដីស្រូវ(សង្កៀបស្រូវ) លាយនឹងស្រូវវាល់លក់ឱ្យអ្នកដទៃ។ ឯកូនប្រុសរបស់គាត់ មើលងាយមាតារបស់ខ្លួន យកខ្សែព្រ័ត្រដាក់លើក្បាលមាតា ឯកូនប្រសាស្រី លួចលាក់សាច់ងៀតស៊ីតែម្នាក់ឯងមិនឱ្យស្វាមី មាតាបិតាបរិភោគផង។ ចំណែកភរិយារបស់ឈ្មួញនោះ ជាមនុស្សកំណាញ់ សំដីអាក្រក់ ឃើញពួកស្មូមទៅសុំអ្វីៗ ស្តីជេរលត្ទះថា ឱ្យស្មូមនោះទៅស៊ីមូត្រលាមក ។

ក្នុងពេលក្រោយមក ជនទាំង៤នាក់នោះ ស្លាប់បន្ទាប់ៗគ្នា តាមវ័យរបស់ខ្លួន ទៅកើតជាប្រេត **នៅចន្លោះភ្នំគិជ្ឈកូដ** ប្រេតទាំង៤នេះរងទុក្ខវេទនាផ្សេងៗគ្នា គឺប្រេតឈ្មួញកម្មបណ្តាលឱ្យមានសំដីស្រូវដែកឆេះក្រហមឥតជាតំនរ ប្រេតនោះចេះតែកើបដាក់លើក្បាល ឆេះក្តៅស្រែកទ្រហោយំជានិច្ចឥតស្រាកស្រាន្ត ។ ប្រេតកូនប្រុសរបស់គាត់ ផលកម្មបណ្តាលឱ្យមានញញួរដែកឆេះក្រហមកាននៅដៃ វាយសំពងក្បាលខ្លួនឯងបែកឈាមហូរស្រោចពេញខ្លួន ស្រែកថ្ងូរឥតស្រាកស្រាន្ត ។ ប្រេតកូនប្រសារស្រីរបស់គាត់

មានក្រចកវែងៗ ខ្វារហែកសាច់ចំឡុករបស់ខ្លួនយកមកស៊ី ស្រែកយំឮឥត ស្រាកស្រាន្ត ។ឯប្រេតភរិយារបស់ឈ្មួញនោះ ផលកម្មបណ្ដាលឱ្យកើត រណ្ដៅមួក្រលាមកស្អុយរលួយ ចុះទៅកើបស៊ីមួយថ្ងៃៗដរាបដល់យប់ៗ ដល់ ថ្ងៃវិញមិនចេះឆ្អែត ចេះតែឃ្លានយ៉ាងខ្លាំងក្រៃលែងឥតឧបមា ។

ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅភ្នំគិជ្ឈកូដ បានឃើញប្រេត ទាំង៤កំពុងរងទុក្ខវេទនាដូច្នោះ ក៏ស្ទូរបុព្វកម្មរបស់ប្រេតនោះបានជ្រាបសព្វ គ្រប់ហើយ និមន្តមកកាន់**វត្តវេឡុវ័ន** ក្រាបទូលរឿងប្រេតនោះចំពោះព្រះ មានព្រះភាគៗ ប្រជុំបរិស័ទ ហើយសំដែងធម៌ទេសនា ប្រារព្ធយករឿងប្រេត នោះជាហេតុ, ដល់ទីបំផុតនៃព្រះធម៌ទេសនា ទ្រង់ប្រកាសអំពីអរិយសច្ច៤ ប្រការ ពុទ្ធបរិស័ទទាំងមនុស្សនឹងទេវតា បានសម្រេចមគ្គផលតាមនិស្ស័យ រៀងៗខ្លួន ។

********

# ២. រឿងមហាកាឡិន

(បាក អ. ៦.)

(សូម្បីសម្បត្តិស្តេចចក្រពត្តិ ក៏ឃាត់មគ្គផលមិនបាន)

ឮដំអតីតកាល **មហាកាឡិន** បានកសាងបុញ្ញកម្ម ទៀបបាទមូលនៃព្រះពុទ្ធបរមគ្រូ**បទុមុត្តរៈ** អន្តោលទៅក្នុងវាលវដ្ដសង្សារ ហើយបានមកកើតក្នុងបេសការគ្រាមស្បែរក្រុងពារាណសី ជានាយតម្បាញចម្បង ។

គ្រានោះព្រះបច្ចេកពុទ្ធមួយពាន់អង្គ នៅក្នុងហេមវន្តប្រទេសអស់៨ខែ ពេលមានភ្លៀងជោកជាំ ក៏ត្រឡប់មកគង់នៅក្នុងខេត្តមួយនាក្រុងពារា-ណសីនោះ៤ខែ ហើយបញ្ជូនព្រះបច្ចេកពុទ្ធ៨អង្គឱ្យទៅសុំសេនាសនៈពីសំ-ណាក់ព្រះរាជាៗ ហេតុតែជាប់ក្នុងកម្ចល់ដោយវប្បមង្គល ទ្រង់ក៏ពោលប្រាប់ថា លោកម្ចាស់ថ្ងៃនេះ ខ្ញុំគ្មានពេលទំនេរទេ, ថ្ងៃស្អែកជាប់ធ្វើវប្បមង្គល ចាំថ្ងៃខានស្អែក ខ្ញុំនឹងចាត់ចែងឱ្យគេធ្វើប្រគេន ។ ដោយខ្វះបដិសណ្ឋារៈ ព្រះបច្ចេកពុទ្ធក៏និមន្តទៅភូមិស្រុកដទៃទៀត។ ក្នុងពេលនោះប្រពន្ធជាងតម្បាញមានកិច្ចត្រូវទៅក្រុងពារាណសី បានជួបនឹងព្រះបច្ចេកពុទ្ធទាំងនោះ ក៏ថ្វាយបង្គំសួរថា ក្នុងពេលមិនគួរនេះ លោកម្ចាស់និមន្តមកដោយកិច្ចអ្វី? លោកក៏ប្រាប់សព្វគ្រប់តាមដំណើរសេចក្តី នាងជាស្ត្រីមានបញ្ញា បាននិមន្តឱ្យទទួលភត្តក្នុងថ្ងៃស្អែក។ ព្រះបច្ចេកពុទ្ធប្រាប់ថាគ្នាអាត្មាច្រើនណាស់។ មានប៉ុន្មានអង្គ លោកម្ចាស់? មួយពាន់អង្គនាង ។

បពិត្រលោកម្ចាស់ ភូមិនេះមានមនុស្សមួយពាន់នាក់ នៅអាស្រ័យ,

មនុស្សម្នាក់ទទួលចង្ហាន់មួយអង្គគ្រប់ល្មម, ហេតុដូច្នេះសូមលោកម្ចាស់ទទួលនិមន្តចុះ ខ្ញុំព្រះករុណានឹងចាត់ធ្វើទីសេនាសនៈប្រគេន ។ ព្រះបច្ចេកពុទ្ធក៏ទទួលតាមសេចក្តីនិមន្តរបស់នាងនោះ, កាលបើព្រះបច្ចេកពុទ្ធទទួលនិមន្តហើយ, នាងដើរអំពាវនាវឃោសនាពេញភូមិស្រុកថា ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធមួយពាន់អង្គ ហើយខ្ញុំនិមន្តឱ្យលោកទទួលភត្តក្នុងថ្ងៃស្អែក, សូមអស់លោកទាំងឡាយ ជួយចាត់ចែងទីកន្លែងនឹងបបរបាយជាដើមដល់លោកផង កាលអំពាវនាវហើយ ក៏ឱ្យធ្វើមណ្ឌបត្រង់កណ្តាលស្រុកនឹងក្រាលអាសនៈ ។ ពេលស្វាងអរុណោទ័យ ក៏និមន្តព្រះបច្ចេកពុទ្ធទាំងឡាយឱ្យគង់លើអាសនៈនោះ ទើបចាត់ចែងភត្តភោជនដ៏ថ្លៃថ្លាប្រគេន។ លុះលោកឆាន់រួចកាលណានាង ក៏បបួលស្ត្រីទាំងអស់ទៅថ្វាយបង្គំ ហើយនិមន្តឱ្យចាំវស្សាក្នុងភូមិនោះ ដោយចាត់ឱ្យបុរសម្នាក់ៗ ទៅស្វែងរកគ្រឿងទព្វសម្ភារៈ មកសង់ទីលំនៅប្រគេន ។

ពួកអ្នកស្រុកទាំងអស់ ក៏យល់តាមពាក្យណែនាំរបស់នាង ហើយចេញទៅស្វែងរកឈើយក មកធ្វើបណ្ណសាលាមួយពាន់ ប្រគេនព្រះបច្ចេកពុទ្ធ។ លុះពេលចេញវស្សា នាងនោះបានបបួលពួកអ្នកស្រុកឱ្យចាត់ចែងស្បង់ចីពរប្រគេន, ឯខ្លួននាងបានជាវចីពរមួយថ្លៃមួយពាន់កហាបណៈប្រគេនព្រះបច្ចេកពុទ្ធមួយអង្គដែរ។ ព្រះបច្ចេកពុទ្ធធ្វើអនុមោទនា ហើយនិមន្តទៅតាមសេចក្តីប្រាថ្នា។ ឯអ្នកស្រុកបានធ្វើបុញ្ញកម្មយ៉ាងនេះឯង លុះច្យុតពីនោះ

ក៏បានទៅកើតនៅព្រៃត្រឹង្សពិភពលោក សន្មត់នាមថា គណទេវបុត្ត សោយទិព្វសម្បត្តិដរាបដល់ពុទ្ធកាលនៃព្រះកស្សប ទើបច្យុតចាកទីឋាននោះមកកើតក្នុងត្រកូលអ្នកមាន នាក្រុងពារាណសីវិញ។ ជាងតម្បាញចម្បង បានកើតក្នុងត្រកូលអ្នកមានជាចម្បង។ ប្រពន្ធជាងតម្បាញនោះ ក៏បានកើតក្នុងត្រកូលអ្នកមានជាចម្បងដែរ។ ពេលមានវ័យសមគួរហើយ ពួកជនទាំងនោះ ក៏បានគ្នាជាស្វាមីភរិយារៀងៗ ខ្លួនតាមប្រពៃណី ។

ថ្ងៃមួយមានការសំដែងធម៌ក្នុងវត្ត ពួកជនទាំងនោះ ក៏បបួលភរិយាទៅស្តាប់ធម៌ លុះចូលដល់កណ្តាលវត្ត មានភ្លៀងបង្អុរចុះមកជោកជាំ។ ពួកពុទ្ធបរិស័ទណាមានស្គាល់ភិក្ខុសាមណេរ ឬត្រូវជាញាតិ ក៏ចូលទៅជ្រកនាបរិ-វេណ(ថែវ)នោះ។ ឯពួកស្វាមីភរិយាមួយក្រុមនោះ ឥតមានស្គាល់ភិក្ខុ សាម-ណេរនឹងគេ ក៏ឈរហាលភ្លៀង ដោយមិនហ៊ានចូលទៅសូមទីជ្រក។ ពេលនោះកុដុម្ពិកៈ ជាច្បងពោលថា យើងគួរខ្មាស់គេណាស់។ កុដុម្ពិកៈទាំងអស់ក៏សួរព្រមគ្នាថា ចុះត្រូវយើងធ្វើយ៉ាងណា? យើងឈរហាលភ្លៀងនេះ ព្រោះយើងគ្មានកន្លែងស្និទ្ធស្នាល ដូច្នេះយើងត្រូវប្រមូលទ្រព្យ មកសាងបរិវេណមួយនៅទីនេះទើបគួរ ។

កុដុម្ពិកទាំងអស់ពោលថា ល្អហើយត្រូវហើយ ទើបបបួលគ្នាប្រមូលទ្រព្យកសាងបរិវេណមួយយ៉ាងធំសម្រាប់ជាទីប្រថាប់នៃព្រះសាស្តា។ កុដុម្ពិកជាច្បងចេញកសាងមួយពាន់កហាបណៈ, ក្រៅពីនោះចេញ៥រយកហាបណៈ

គ្រប់ៗគ្នា. ស្រីចេញ២៥០កហាបណៈ។ ទ្រព្យទាំងប៉ុណ្ណេះក៏ធ្វើបរិវេណនោះមិនគ្រាន់ ទើបចេញពាក់កណ្តាលម្នាក់ៗថែមទៀត។ កាលធ្វើបរិវេណនោះរួចហើយ ក៏ប្រារព្ធធ្វើបុណ្យឆ្លងនឹងថ្វាយទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់៧ថ្ងៃ ព្រមទាំងចាត់ចែងចីពរប្រគេនដល់ព្រះសង្ឃពីរសែនអង្គទៀត។ ប៉ុន្តែភរិយាកុដុម្ពិកជាច្បង ជាស្ត្រីមានប្រាជ្ញា នាងមិនធ្វើបុណ្យឱ្យស្មើនឹងគេទេ គឺធ្វើលើសលប់ជាងគេ ដោយយកប្រអប់ដាក់ផ្ការនោង ជាមួយនឹងសាដកមានថ្លៃមួយពាន់កហាបណៈមានពណ៌ដូចផ្ការនោងដែរ ទៅថ្វាយព្រះបរមសាស្តា ហើយតាំងសេចក្តីប្រាថ្នាថា ក្នុងទីដែលកើតហើយៗ សូមឱ្យខ្ញុំព្រះអង្គមានពណ៌ដូចផ្ការនោង ទាំងឈ្មោះក៏សូមឱ្យប្រាកដថា អនោជាដែរ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាថា សេចក្តីប្រាថ្នា ចូរសម្រេចដល់នាងយ៉ាងនេះចុះ។ កុដុម្ពិកៈជាស្វាមីភរិយាទាំងអស់គ្នានោះ បានធ្វើបុណ្យសុន្ទរ-ទានយ៉ាងនេះ លុះស្លាប់ទៅ ក៏បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិតាមកុសលចរិយា. លុះច្យុតពីទេវលោកវិញ កុដុម្ពិក៏ជាច្បងបានកើតក្នុងព្រះរាជត្រកូលនាក្រុងកុក្កុដវតី បានចំរើនព្រះជន្មតាមលំដាប់ក៏បានសោយរាជ្យតព្រះវង្សព្រះវរបិតាមានព្រះនាមថា មហាកប្បិនកុដុម្ពិក ក្រៅនេះក៏បានកើតក្នុងត្រកូលអមាត្យគ្រប់ៗគ្នា។ ឯភរិយាកុដុម្ពិកជាច្បងនោះ បានកើតក្នុងព្រះរាជត្រកូលនគរសាគលដែនមទ្ទៈ។ ព្រះនាងមានសរីរៈស្រស់ព្រំព្រេងដូចផ្ការនោងមានព្រះនាមប្រាកដថា អនោជា ពេលចំរើនព្រះជន្មបាន ១៦វស្សា ក៏

បានជាព្រះអគ្គមហេសីនៃព្រះចៅមហាកប្បិន ។ ស្រ្តីទាំងឡាយ ក្រៅពីនេះ បានកើតក្នុងត្រកូលមហាមាត្យដែរ, លុះមានអាយុល្មមរៀបការ ក៏បានជាភរិយានៃកូនអមាត្យទាំងនោះឯង។ កូនអាមាត្យទាំងនោះ មានសម្បត្តិប្រហាក់ប្រហែលនឹងព្រះរាជាដែរ។ ពេលដែលព្រះរាជាទ្រង់គ្រឿងអម្ពរព-ស្រ្តាលង្ការពករណៈ ឡើងប្រថាប់លើព្រះទីនាំងគជេន្ទ្រជ័យ យាងត្រួតត្រាព្រះនគរបែបណា អមាត្យក៏ប្រដាប់កាយបែបនោះដែរ បើព្រះអង្គប្រថាប់លើសេះ ឬលើរាជរថ អមាត្យជិះសេះ ជិះរថដូចព្រះអង្គ នេះជាបុញ្ញកម្មដែលបានធ្វើរួមគ្នា។ ឯព្រះរាជាព្រះអង្គមានសេះជាព្រះទីនាំង៥ ឈ្មោះ ពលៈ១, ពលវាហណៈ១, បប្ផៈ១, បុប្ផៈវាហនៈ១, សុបត្តៈ១ តែព្រះទីនាំងពិតប្រាកដរបស់ទ្រង់គឺសេះសុបត្តៈ. ឯសេះ៤ទៀតទ្រង់ប្រទានដល់អមាត្យទាំងឡាយសម្រាប់ឱ្យជិះដើរស្វែងរកសាសនាដែលកើតឡើងក្នុងលោក។ ថ្ងៃមួយទ្រង់ជប់លៀងអមាត្យទាំងនោះ ហើយបញ្ជូនទៅដោយព្រះឱង្ការថា អ្នកទាំងឡាយចូរទៅស្វែងរកសាសនា បើដឹងថាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកើតឡើងក្នុងលោកហើយត្រូវត្រឡប់មកប្រាប់ខ្ញុំវិញ។ អមាត្យទាំងនោះខំដើរស្វែងរកសាសនាអស់យោជន៍ពីរបី ឥតបានការអ្វីសោះ ទើបនាំដំណឹងនោះមកក្រាបបង្គំទូលព្រះរាជា ។

ថ្ងៃមួយទ្រង់ឡើងជិះសេះសុបត្តៈ មានអមាត្យមួយពាន់ចោមរោមជាព្រះរាជបរិព្វារស្តេចយាងទៅកាន់ឱទ្យាន បានជួបនឹងនាយពាណិជ ៥០០រូប

កំពុងចូលទៅក្នុងនគរ ទើបត្រាស់ហៅមកសួរថា អ្នកទាំងឡាយមកពីណា? បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមកពីក្រុងសាវត្ថី ចំងាយពីនគរនេះពីររយយោជន៍។ អ្នកទាំងឡាយបានឮថាមានសាសនាអ្វីកើតឡើងក្នុងលោកដែរឬ? ក្រាបទូលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឧប្បត្តិឡើងក្នុងលោកហើយ។ ព្រះរាជាទ្រង់អរណាស់ចំពោះពាក្យទូលតបនេះ ដរាបដល់ទ្រង់ចងចាំពាក្យនោះមិនបាន ទើបត្រាស់សួរថា អ្នកទាំងឡាយពោលថាម៉េច? បពិត្រព្រះសម្មតិទេពថាព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយ។ ព្រះរាជាទ្រង់ចាំពាក្យនោះមិនបានអស់វារៈបីដង ក្នុងលើកទី៤ទ្រង់ត្រាស់ពាក្យដដែលៗថាអ្នកទាំងឡាយពោលថាម៉េច? បពិត្រព្រះសម្មតិទេពថា ព្រះពុទ្ធឧប្បត្តិឡើងហើយ។ ម្នាលអ្នកទាំងឡាយខ្ញុំអរណាស់ សូមបូជាសំដីអ្នកមួយម៉ាត់នេះ មួយសែនកហាបណៈ, តើអ្នកមានឮសាសនាអ្វីកើតឡើងទៀតដែរ? ក្រាបទូលព្រះធម៌កើតឡើងហើយក្នុងលោក។ ទ្រង់ស្តាប់មិនបានអស់វារៈបីលើក ដល់លើកទី៤ ទ្រង់ត្រាស់ថា ខ្ញុំនឹងបូជាសំដីអ្នកមួយសែនកហាបណៈដូចមុន, តើអ្នកមានឮសាសនាអ្វីទៀតកើតឡើងដែរ? ក្រាបទូលព្រះសង្ឃកើតឡើងហើយក្នុងលោក។ ព្រះរាជាក៏ទ្រង់ចាំពាក្យនោះមិនបានទៀតអស់វារៈ៣លើក ដល់លើកទី៤ទ្រង់ត្រាស់ថា ខ្ញុំនឹងបូជាសំដីអ្នកមួយសែនកហាបណៈបន្ថែមទៀត ហើយទ្រង់បែរព្រះភក្ត្រមកមើលអមាត្យត្រាស់សួរថា តើអ្នកទាំងឡាយគិតយ៉ាងណា? ក្រាបបង្គំទូលព្រះអង្គនឹងធ្វើយ៉ាងណា? នែអមាត្យទាំងឡាយព្រះពុទ្ធព្រះធម៌

ព្រះសង្ឃ កើតឡើងហើយក្នុងលោក ខ្ញុំមិនត្រឡប់ទៅវិញទេ នឹងបួសក្នុងសំ-ណាក់ព្រះអង្គដោយពិត។ ក្រាបបង្គំទូលយើងទាំងអស់គ្នានឹងបួសជាមួយព្រះអង្គដែរ។ ព្រះរាជាទ្រង់ដាច់អាល័យពីរាជសម្បត្តិ ហើយទ្រង់លាយលក្ខណ៍អក្សរលើផ្ទាំងមាសផ្ញើនឹងនាយពាណិជ ឱ្យយកទៅថ្វាយព្រះមហេសីអនោ-ជាទេវី ថា ព្រះទេពីអនោជា! ចូរព្រះនាងប្រទានប្រាក់៣សែនកហាបណៈដល់ពាណិជ ដែលកាន់សំបុត្រមកនេះ ហើយចូរព្រះនាងសោយសម្បត្តិតាមសេចក្ដីគាប់ប្រាថ្នាចុះ ព្រោះយើងលះបង់ហើយៗ នឹងទៅបួសក្នុងសំណាក់ព្រះសម្ពុទ្ធ ។ ឯអមាត្យក៏ផ្ដេផ្ដាំតាមលំនាំនោះ ឱ្យពាណិជប្រាប់ដល់ភរិយារៀងៗខ្លួនដែរ ។

គួរអស្ចារ្យណាស់ ថ្ងៃមួយព្រះបរមគ្រូទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ ទ្រង់ជ្រាបថា ស្អែកនេះមហាកប្បិនរាជព្រមទាំងអមាត្យមួយពាន់ចោមរោមជាបរិវារប្រាថ្នាបួសក្នុងសំណាក់តថាគត, មហាកប្បិននឹងបរិវារនឹងបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ដូច្នេះគួរតថាគតទៅទទួល, លុះព្រះចិន្ដាយ៉ាងនេះហើយ ព្រឹកបំព្រាងស្វាងព្រះសុរិយាកាលណា ក៏ប្រដាប់ដោយបាត្រនឹងចីវរ ទៅទទួលអស់ផ្លូវពីររយយោជន៍ ប្រៀបដូចស្ដេចចក្រពត្តិទៅទទួលមេឃុំតូច ហើយប្រថាប់បញ្ចេញឆព្វណ្ណរង្សីក្រោមគល់ព្រះព្រៃសាខានាឡើងស្ទឹងចន្ទភាគា។ ព្រះរាជាទ្រង់យាងមកដល់ស្ទឹងមួយ ត្រាស់សួរអ-មាត្យថា ស្ទឹងនេះឈ្មោះអ្វី? ក្រាបទូលឈ្មោះ **អរច្ឆា**។ ស្ទឹងនេះមានជម្រៅ

នឹងទំហំប៉ុន្មាន? ក្រាបទូលថា ជម្រៅមួយគាវុត ទំហំពីរគាវុត ។ ចុះស្ទឹងនេះមានទូកឬក្បូនសម្រាប់ឆ្លងដែរ? ក្រាបទូលថាឥតមានទេ ។ ព្រះរាជាទ្រង់លាន់ព្រះឱស្ឋថា កាលយើងកំពុងរកមើលផលយានទាំងឡាយ មានទូកជាដើមសម្រាប់ឆ្លង, ជាតិក៏បង្ហោនចូលទៅរកជរា, ជរាចូលទៅរកមរណៈ, យើងជាអ្នកឥតមានពុតត្បុត ចេញមកនេះគឺប្រាថ្នាចំពោះព្រះរតនត្រ័យ, ដោយអានុភាពព្រះរតនត្រ័យនោះ សូមទឹកនេះកុំប្រាកដជាទឹកឡើយ ហើយទ្រង់រំលឹកពុទ្ធានុស្សតិថា ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ ដូច្នេះ ក៏យាងឆ្លងស្ទឹងនោះជាមួយអមាត្យរិស័យដូចជាន់លើខ្នងថ្ម ទាំងចុងក្រចកជើងសេះទាំងឡាយ ក៏ឥតមានទទឹកដែរ ។ ព្រះរាជាឆ្លងស្ទឹងនោះ យាងទៅក៏បានឃើញស្ទឹងមួយទៀត ស្តេចត្រាស់សួរអមាត្យថា នេះឈ្មោះស្ទឹងអ្វី? ក្រាបទូលឈ្មោះនីលវាហនា ។ ចុះជម្រៅនឹងទទឹងស្ទឹងប៉ុន្មាន? ក្រាបទូលជម្រៅនឹងទទឹងកន្លះគាវុតដូចគ្នា ។ ព្រះរាជាក៏រលឹក ធម្មានុស្សតិថា ស្វាខាតោ ភគវតា ធម្មោ ហើយយាងឆ្លងស្ទឹងនោះក៏ប្រទះស្ទឹងមួយទៀត ឈ្មោះចន្ទភាគា ។ (ពាក្យសួរឆ្លើយរវាងព្រះរាជានឹងអមាត្យដូចន័យមុន ប្លែកតែស្ទឹងចន្ទភាគានេះមានជម្រៅនឹងទទឹងមួយយោជន៍ប៉ុណ្ណោះ) ។

ព្រះរាជាទ្រង់រលឹកដល់សង្ឃានុស្សតិថា សុបដិបន្នោ ភគវតោ សាវកសង្ឃោ ហើយយាងឆ្លងស្ទឹងនោះទៅ ក៏បានឃើញព្រះសាស្តាគង់បញ្ចេញរស្មីក្រោមដើមជ្រៃ ដែលមានសន្លឹកដូចមាសដោយអំណាចរស្មីព្រះអង្គ។ ព្រះរា-

ជាទ្រង់ព្រះតម្រិះថា ពន្លឺរស្មីនេះមិនមែនជាពន្លឺចន្ទ ព្រះអាទិត្យ ទេវតា មារ ព្រហ្ម នាគ គ្រុឌ ណាមួយឡើយ គឺពិតជារបស់ព្រះពុទ្ធ ទើបទ្រង់ចុះចាក ខ្នងអស្សតរ៍ មានព្រះកាយឱនចុះយាងផ្ទោះ មកលំអានសិរសីថ្វាយបង្គំ គង់ក្នុងទីដ៏សមគួរជាមួយនឹងអមាត្យ។ ព្រះសាស្តាស្តេចសំដែងអនុបុព្វិកថាឱ្យព្រះរាជានឹងអមាត្យស្តាប់ធម៌ ហើយព្រះរាជានឹងអមាត្យក៏បានសម្រាច់ធម៌សោតាបត្តិផល ហើយក្រោកឡើងសូមបព្វជាឧបសម្បទាក្នុងទីនោះឯង។ ព្រះសាស្តាទ្រង់រំពឹងមើលថា ចីវរបាត្រដែលសម្រេចពីឫទ្ធិអាចមានដល់កុលបុត្រទាំងនេះដែរឬហ្ន? ទើបជ្រាបច្បាស់ថា កុលបុត្រទាំងនេះបានប្រគេនចីវរមួយពាន់ ដល់ព្រះបច្ចេកពុទ្ធមួយពាន់អង្គ ដល់មកពុទ្ធកាលព្រះកស្សបៈ បានប្រគេនចីវរ២០ពាន់ ដល់ភិក្ខុ២០ពាន់ទៀត ហើយទ្រង់លាព្រះហស្តត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកចូលមក[១] ចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខដោយប្រពៃចុះ ភិក្ខុទាំងនោះក៏បានទ្រទ្រង់បរិក្ខារ៨ ដូចជាព្រះថេរៈទាំងឡាយដែលមានវស្សាមួយរយ ។

រីនឹងស្រដីពីនាយពាណិជទាំងឡាយ ដែលនាំព្រះរាជសាសន៍ទៅថ្វាយព្រះទេពី លុះទៅដល់ហើយ ក៏ថ្វាយបង្គំអង្គុយក្នុងទីសមគួរមួយ។ ព្រះទេពីត្រាស់សួរថា អ្នកទាំងឡាយមកមានការណ៍អ្វី? យើងទាំងឡាយ ព្រះរាជា

១. ឧបសម្បទាសម្រេចដោយព្រះពុទ្ធដីកាថាឯហិភិក្ខុ ហៅថាឯហិភិក្ខុឧបសម្បទា ដែល ព្រះសាស្តាប្រទានផ្ទាល់ព្រះអង្គ ។

បញ្ជូនឱ្យមកកាន់សំណាក់ព្រះនាង. សូមព្រះនាងប្រទានប្រាក់បីសែនកហាបណៈដល់ទូលព្រះបង្គំទាំងអស់គ្នា។ ព្រះអគ្គមហេសីត្រាស់សួរថា អ្នកទាំងឡាយពោលនេះច្រើនពេក. អ្នកធ្វើកម្មយ៉ាងណាដល់ព្រះរាជា បានជាព្រះអង្គជ្រះថ្លាចំពោះអ្នកទើបឱ្យខ្ញុំប្រទានទ្រព្យមានប្រមាណប៉ុណ្ណេះ? បពិត្រព្រះនាង យើងបានក្រាបទូលព្រះរាជាថា សាសនាមួយកើតឡើងហើយក្នុងលោក។ អ្នកទាំងឡាយអាចប្រាប់ខ្ញុំបានទេ? ក្រាបទូលបាន. ថាព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយ។ ពាក្យសួរឆ្លើយរវាងព្រះនាងនឹងនាយពាណិជទាំងឡាយ មានរបៀបដូចពេលដែលព្រះរាជាសួរដែរ ប្លែកតែនាងប្តូរជាពាក្យមួយម៉ាត់ថា ពុទ្ធោ បីសែនកហាបណៈ ធម្មោ បីសែនកហាបណៈ សង្ឃោ បីសែនកហាបណៈប៉ុណ្ណេះ។ នាយពាណិជបានប្រាក់រួមទាំងអស់១២សែនកហាបណៈ[១]។ ពេលនោះព្រះនាងទេពីត្រាស់សួរថា ព្រះរាជាស្តេចនៅក្នុងទីណា? ក្រាបទូលស្តេចទៅបួសក្នុងសំណាក់ព្រះសាស្តា។ ទ្រង់មានផ្តែផ្តាំពាក្យពេចន៍អ្វីនឹងអ្នកទាំងឡាយដែរ? ក្រាបទូលបានផ្ញើព្រះរាជសារមក ថ្វាយដល់ព្រះនាងថា សូមព្រះនាងសោយសម្បត្តិទាំនោះ តាមគាប់ព្រះរាជអធ្យាស្រ័យចុះ។ ចុះពួកអមាត្យនៅទីណា? ក្រាបទូលទៅបួសជាមួយព្រះរាជាដែរ។ ព្រះនាងទតព្រះរាជសារហើយ ហៅភរិយាអមាត្យមកប្រាប់ថា ស្វាមីនាងទៅបួសក្នុងសំណាក់ព្រះសាស្តាហើយ. តើពួកនាងគិតយ៉ាងណា? បពិត្រព្រះនាង ស្វាមី

១. នេះជាអានិសង្សនៃវាចាសច្ច ។

ទាំងអស់ឆ្នានោះមានផ្លែផ្កាមកយើងថាម៉េចដែរ? ថាសម្បត្តិទាំងអស់គេលះបង់ហើយ ឱ្យនាងគ្រប់គ្រងចុះ ។ តើព្រះនាងនឹងធ្វើយ៉ាងណា? នែ! នាងទាំងឡាយ ព្រះរាជាឮថារតនត្រ័យកើតឡើងក្នុងលោក ហើយលះបង់ចោលរាជ្យដូចជាដុំទឹកមាត់ ហើយចេញទៅបួសក្នុងសំណាក់ព្រះសាស្តា. សម្បត្តិនេះមិនមែននាំយកទុក្ខទៅឱ្យព្រះរាជាទេ ពិតជាផ្តល់មកឱ្យខ្ញុំ ម្យ៉ាងទៀតអ្នកណាដែលអាចលុតជង្គង់ទាំងពីរទទួលទឹកមាត់ដែលព្រះរាជាស្តោះហើយ! ខ្ញុំឥតត្រូវការទេរាជសម្បត្តិ មុខជាទៅបួសក្នុងសំណាក់ ព្រះសាស្តាដោយពិត។ បពិត្រព្រះនាង យើងនឹងបួសតាមព្រះនាងដែរ។ អើ ល្អហើយ ប្រពៃហើយបើនាងបានទៅបួសជាមួយខ្ញុំ ដូច្នេះនាងទាំងឡាយចូរមក។ ព្រះនាងឡើងប្រថាប់រាជរថចេញទៅជាមួយនឹងស្រីទាំងនោះ ដល់ចន្លោះផ្លូវក៏ឃើញស្ទឹងអរវច្ឆាហើយ សួរស្រីជាបរិវារដូចព្រះរាជាសួរអមាត្យដែរ លុះជ្រាបដំណើងហើយ ក៏ពោលថា នាងទាំងឡាយរកមើលផ្លូវដែលព្រះរាជាយាងទៅមើល? ក្រាបទូលសូម្បីតែស្នាមជើងសេះក៏មិនឃើញដែរ។ ព្រះនាងទ្រង់ចិន្តាថា ព្រះរាជាស្តេចយាងទៅបួសក្នុងសំណាក់ព្រះសាស្តា ទ្រង់ធ្វើសច្ចកិរិយាហើយចេញទៅបាន. អញក៏ចេញមកបួសឧទ្ទិសចំពោះព្រះត្រៃរតន៍ដែរ. ដោយអានុភាពនៃព្រះរតនត្រ័យនេះ សូមទឹកនេះកុំប្រាកដជាទឹកឡើយ កាលបើពោលដូច្នេះហើយ ក៏ឆ្លងស្ទឹងនោះដូចជាឆ្លងលើខ្នងថ្ម។ សូម្បីចក្កាវយវៈខាងក្រោមបំផុតក៏ឥតមានទទឹកដែរ ។ ព្រះនាងឆ្លងស្ទឹងពីរទៀតបានដោយឧបាយនេះ

ឯង។

ថ្ងៃនោះព្រះសាស្តាស្តេចមកទទួលព្រះនាងទៀត។ កាលព្រះនាងយាងទៅបានឃើញរស្មី ដែលផ្សាយចេញពីព្រះសរីរៈព្រះអង្គ ទ្រង់ព្រះចិន្តាដូចព្រះរាជភស្តាដែរ ហើយចូលទៅថ្វាយបង្គំគង់ដ៏សមគួរ ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន មហាកប្បិន ចេញមករកព្រះអង្គប្រហែលជាទ្រង់មកក្នុងទីនេះ. ព្រះរាជានោះនៅក្នុងទីណា? សូមព្រះអង្គស្តេចបង្ហាញដល់ខ្ញុំព្រះអង្គទាំងអស់គ្នា។ ព្រះសាស្តាត្រាស់ថា អង្គុយសិនចុះគង់នឹងឃើញព្រះរាជាក្នុងទីនេះឯង ទើបទ្រង់សំដែងអនុបុព្វិកថា លុះចប់ធម៌ទេសនា ព្រះនាងអនោជាព្រមទាំងបរិពារក៏សម្រេចសោតាបត្តិផល ។ ឯមហាកប្បិន ព្រមទាំងបរិវារកាលស្តាប់ធម៌ ដែលព្រះសាស្តាសំដែងប្រោសស្ត្រីទាំងនោះ ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ព្រះសាស្តាស្តេចបញ្ជូនស្រីទាំងនោះ ឱ្យទៅបួសក្នុងសំណាក់ភិក្ខុនីសង្ឃ ឯក្រុងសាវត្ថីចំងាយផ្លូវពីររយយោជន៍. លុះស្រីទាំងនោះបានឧបសម្បទាជាភិក្ខុនីក្នុងសាសនមណ្ឌលហើយ ក៏បានសម្រេចព្រះអរហត្តនាពេលនោះឯង។

*********

## ៣. រឿងឧត្តរបុរស

(ចាក ធ. ខុ.)

(សេចក្ដីប្រែះថ្លាជាមេបណ្ដុះសម្បត្តិលោកិយនឹងលោកុត្តរៈ)

ក្នុងកាលដែលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ មានព្រះ ខីណាស្រព២០ពាន់អង្គជាបរិវារ ស្ដេចយាងទៅកាន់ក្រុងពារាណសី មនុស្ស ទាំងឡាយបានកំណត់ធនធានតាមកំលាំងខ្លួន ចូលគ្នា៨នាក់ខ្លះ ១០នាក់ខ្លះ ថ្វាយអាគន្តុកទានជាដើម។ ថ្ងៃមួយក្នុងទីបំផុតភត្តកិច្ចព្រះសាស្ដាធ្វើអនុមោ- ទនាថា ឧបាសកឧបាសិកាទាំងឡាយ! បុគ្គលមួយពួកក្នុងលោកនេះ ឱ្យទាន ដោយខ្លួនឯង មិនបបួលអ្នកដទៃ បុគ្គលនោះ បានតែភោគសម្បត្តិ មិនបាន បរិវារសម្បត្តិក្នុងទីដែលកើតហើយទេ. បុគ្គលមួយពួកនេះបបួលគេធ្វើទាន តែខ្លួនឯងមិនធ្វើ បុគ្គលនោះបានតែបរិវារសម្បត្តិទេ ឥតបានភោគសម្បត្តិ ឡើយ. បុគ្គលមួយពួក ខ្លួនឯងក៏មិនបានឱ្យទាំងមិនបានបបួលអ្នកដទៃផង បុគ្គលនោះទៅកើតក្នុងទីណាៗ ភោគសម្បត្តិក៏គ្មាន បរិវារសម្បត្តិក៏គ្មាន ជា អ្នករស់នៅដោយការស៊ីវត្ថុជាសំណល់គេ. បុគ្គលមួយពួកទៀត ឱ្យទានខ្លួន ឯងផង បបួលអ្នកដទៃផង បុគ្គលនោះកើតក្នុងទីណាៗ រមែងបានភោគ សម្បត្តិផង បរិវារសម្បត្តិផង។

បណ្ឌិតបុរសម្នាក់អង្គុយស្ដាប់ធម៌ស្បែរនោះគិតថា អញនឹងធ្វើឱ្យបាន សម្បត្តិទាំងពីរយ៉ាងនេះ ទើបថ្វាយបង្គំព្រះសាស្ដាទូលថា បពិត្រព្រះអង្គដ៏ចំ រើន ថ្ងៃស្អែកនេះ សូមទ្រង់ទទួលភិក្ខារ(បាយ)របស់ខ្ញុំព្រះអង្គ។ ព្រះសាស្ដា

ក្រាស់ថា អ្នកត្រូវការដោយភិក្ខុប៉ុន្មាន? បពិត្រព្រះអង្គបរិវារទ្រង់មានប៉ុន្មាន? មាន២០ពាន់រូប។ សូមនិមន្តទាំងអស់។ ព្រះសាស្តាក៏ព្រមទទួល។ បុរសនោះ ចូលទៅក្នុងស្រុក ស្រែកអំពាវនាវថា បពិត្រលោកអ្នកទាំងឡាយ ខ្ញុំបាននិមន្ត ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកទទួលភត្តក្នុងថ្ងៃស្អែក, លោកអ្នក ទាំងឡាយ ត្រូវការភិក្ខុប៉ុន្មានអង្គ សូមចាត់ចែងទានប្រគេនតាមគាប់អាធ្យា-ស្រ័យចុះ, មនុស្សទាំងឡាយក៏ទទួលថា យើងឱ្យដល់ភិក្ខុ១០អង្គ, ២០អង្គ, ៣០អង្គ, ១០០អង្គ, ខ្លះទៀត៥០០អង្គ ទើបបុរសបណ្ឌិតនោះស្រង់ឈ្មោះចុះ ក្នុងបញ្ជី។ ក្នុងនគរនោះ មានបុរសម្នាក់ ដែលជនទាំងឡាយស្គាល់ឈ្មោះ ថា មហាក្រ[១] (ក្រណាស់) បណ្ឌិតបុរស បានឃើញអ្នកមហាក្រនោះមកដល់ ចំពោះមុខខ្លួន ក៏ពោលបបួលថា អ្នកមហាក្រសម្លាញ់! ខ្ញុំបាននិមន្តព្រះភិក្ខុ សង្ឃមានព្រះពុទ្ធជាប្រធាន មកទទួលភត្តនាថ្ងៃស្អែក, តើអ្នកមានត្រូវការ ភិក្ខុប៉ុន្មានអង្គ? ហ៊ុំខ្ញុំក្រណាស់បានប្រកព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក នឹងឱ្យ ទានយ៉ាងម៉េចបានទុកឱ្យអ្នកមានទ្រព្យគេឱ្យចុះ។ បណ្ឌិតបុរសជាមនុស្សឆ្លាត ក្នុងការបបួលទុកជាឮពាក្យថាគ្មានហើយ ក៏នៅតែមិនស្ងៀមចេះតែពោល បបួលថា អ្នកមហាក្រសម្លាញ់ ជនច្រើនក្នុងនគរនេះ បរិភោគភោជនល្អៗ ស្លៀកពាក់ល្អស្រស់បស់ ដេកលើដំណេកមានសេរី សោយសម្បត្តិ, ប្លែកតែ សម្លាញ់ស៊ីឈ្នួលជួលព័ទ្ធគេរាល់ថ្ងៃ នៅតួញថាស៊ីមិនគ្រប់គ្រាន់ប្រហែលថា

[១] បាលីគេហៅថាមហាទុគ្គត

អ្នកមិនដឹងថា កាលពីដើមអញគ្មានបានឱ្យទានសោះទេឬ? ខ្ញុំក៏មិនដឹងយ៉ាងនេះដែរ។ កាលបើដូច្នោះម្តេចអ្នកមិនធ្វើបុណ្យក្នុងពេលនេះ? អ្នកជាមនុស្សកំឡោះ មានកំលាំងពលំគ្រប់គ្រាន់ ស៊ីឈ្នួលគេហើយយកកម្រៃនោះមកធ្វើបុណ្យមិនគួរឬ? អ្នកមហាក្រ. បណ្ឌិតនោះនិយាយយ៉ាងនេះរឿយៗ. ក៏កើតសេចក្តីសង្វេគ ហើយព្រមទទួលភិក្ខុមួយអង្គឱ្យឆាន់ក្នុងថ្ងៃស្អែក ទើបត្រឡប់ទៅផ្ទះ ប្រាប់ភរិយាថា នែនាងអ្នកនគរគេធ្វើភត្តប្រគេនព្រះសង្ឃថ្ងៃស្អែកនេះ អញមានបុរសម្នាក់មកបបួលថា ចូរអ្នកឱ្យភត្តដល់ភិក្ខុ១អង្គទៅ. យើងនឹកចាត់ចែងភត្តប្រគេនភិក្ខុ១អង្គ ក្នុងថ្ងៃស្អែកនេះ។ ឯភរិយាមិនបានពោលថា យើងជាអ្នកក្រ ម្តេចក៏ស្តាប់ពាក្យគេ?ទេ បែរជាពោលថា បពិត្រស្វាមីប្រពៃណាស់ហើយ. យើងព្រោះតែមិនបានឱ្យទានពីជាតិមុន ទើបជាតិនេះយើងក្ររហេមរហាម ខ្វះព្រឹកខ្វះល្ងាចយ៉ាងនេះ យើងទៅស៊ីឈ្នួលគេយកកម្រៃមកធ្វើភត្តប្រគេនលោកកុំខាន ទើបដើរទៅរកស៊ីឈ្នួលគេទាំងពីរនាក់ប្តីប្រពន្ធ។ មហាសេដ្ឋីឃើញអ្នកមហាក្រភ្លាមសួរថា អ្នកមហាក្រសម្លាញ់អ្នកមកស៊ីឈ្នួលឬ? បពិត្រលោក មករកស៊ីឈ្នួល។ អ្នកនឹងធ្វើការអ្វីហ្ន? បុរសមហាក្រប្រាប់មហាសេដ្ឋីដោយសំដីថា អ្នកទលក្រថាលោកឱ្យខ្ញុំធ្វើការអ្វី ខ្ញុំនឹងធ្វើការនោះនោះតាមបង្គាប់។ សេដ្ឋីក៏ប្រើគេឱ្យយកកាំបិតនឹងពូថៅមកឱ្យអ្នកមហាក្រដោយពាក្យថា ស្អែកនេះយើងប្រគេនចង្ហាន់ភិក្ខុពីរបីរយអង្គ. ចូរអ្នកពុះអុសចុះ។ អ្នកក្រចងក្បិនយ៉ាងមាំ ខ្នះខ្នែងជាបំផុត ដាក់

កាំបិតលើកពូថៅ ដាក់ពូថៅលើកកាំបិតមកពុះអុសតាមបង្គាប់។ សេដ្ឋីសួរថា សម្លាញ់ម្ដេចក៏អ្នកខំខ្លាំងម្ល៉េះថ្ងៃនេះ? មានហេតុយ៉ាងណា? បពិត្រលោក ស្អែកខ្ញុំប្រគេនភត្តដល់ភិក្ខុមួយអង្គដែរ។ សេដ្ឋីគិតថា ឱអ្នកមហាគ្រនេះមានសទ្ធាមុតមាំណាស់តើ មិនគិតខ្លួនក្រលំបាកសោះ។ ថ្ងៃពីភរិយាសេដ្ឋីឃើញប្រពន្ធអ្នកមហាគ្រ ក៏សួរថា ម្នាលនាង! នាងមកធ្វើការអ្វី? ចា! លោកស្រី ឱ្យតែមានការ ខ្ញុំនឹងធ្វើជូនទាំងអស់។ លោកស្រីក៏បង្គាប់ឱ្យយកចង្អេរនឹងអង្រែងជាដើម ចូលទៅប្រកបការងារក្នុងរោងត្បាល់ត្បៀង។ នាងនោះមានចិត្តរីករាយជាមហិមា បុក បែន អុំ ស្ល រោយស្រូវទាំងឡាយ ហាក់ដូចជាគេរាំ ។ លោកស្រីសួរថា នាងរីករាយខ្លាំងម្ល៉េះ មានហេតុយ៉ាងណា? លោកស្រី ខ្ញុំមកធ្វើការឈ្នួលនេះ គឺយកកម្រៃទៅ ចាត់ចែងភត្តប្រគេនភិក្ខុមួយអង្គក្នុងថ្ងៃស្អែកនេះ។ សេដ្ឋីបានឱ្យអង្ករស្រូវសាលី ៤នាឡិជាឈ្នួល ៤នាឡិទៀតជារង្វាន់នៃសេចក្ដីត្រេកអររបស់អ្នកមហាគ្រនោះ។ ឯភរិយាសេដ្ឋីបានឱ្យដបពេញដោយទឹកដោះថ្លា១ ភាជនៈពេញដោយទឹកដោះជូរ១ គ្រឿងហឹរ១ អង្ករស្រូវសាលីសុទ្ធមួយនាឡិដល់នាងនោះ។ ជនប្ដីប្រពន្ធមានសេចក្ដីត្រេកអរជាខ្លាំងលាន់មាត់ថា យើងបានទ័យធម៌ហើយ ទើបចូលកាន់និទ្រាលង់លក់ស្កប់ស្កល់ក្នុងរាត្រី។ វេលាព្រឹកព្រាង ក៏ស្ទុះក្រោកម្នីម្នា ឯភរិយាពោលប្រាប់ប្ដីថា នែ! លួមទៅរកបន្លែមក។ អ្នកមហាគ្រ ដើររកមើលក្នុងរានផ្សារ ក៏មិនឃើញមាន ហើយដើរហួសទៅកាន់ឆ្នេរស្ទឹង បេះបន្លែបណ្ដើរ

ច្រៀងបណ្តើរ។ មានព្រានម្នាក់កំពុងបង់សំណាញ់ ឮសំឡេងច្រៀងនោះ គិតថា នេះជាសំឡេងអ្នកមហាក្រទេតើ ទើបប្រកួកហៅមកសួរថា ម្តេចក៏ច្រៀងសប្បាយម្ល៉េះ មានហេតុអីសម្លាញ់? ទេ! បេះបន្លែតើ។ អើសម្លាញ់បេះធ្វើអី? យីព្រឹកនេះខ្ញុំប្រគេនចង្ហាន់លោកមួយអង្គ។ ព្រានប្រមង់ពោលថា ឱ!ភិក្ខុណាបាន់បន្លែអ្នក ភិក្ខុនោះអស់អាសវៈហើយ។ ខ្ញុំបានបន្លែហើយ តែនៅខ្វះត្រី អើឱ្យខ្ញុំធ្វើម៉េចទៀត? អើ សម្លាញ់មកដោតត្រីឱ្យខ្ញុំមួយដំណោតល្មមថ្ងៃមួយបាទខ្វះ កន្ទះបាទខ្វះ មួយកហាបណៈខ្វះ។ អ្នកនគរក៏មកទិញត្រីទាំងត្រណោតៗយកទៅធ្វើចង្ហាន់ កាលអ្នកមហាក្រកំពុង ដោតត្រី, ភិក្ខុបារវលោក៏មកដល់ ហើយពោលប្រាប់ព្រានប្រមង់ថា សម្លាញ់ ល្មមពេលលោកនិមន្តមកហើយ។ ព្រានសួរថា ត្រណោតត្រីអស់ហើយឬនៅ? អស់រលីងហើយសម្លាញ់។ អើ ត្រីផ្លិទ៤ ខ្ញុំកប់ទុកក្នុងគំនរដីខ្សាច់ឯណោះ យកចាត់ចែងធ្វើចង្ហាន់ប្រគេនលោកចុះ។

ថ្ងៃនោះព្រះសាស្តាទ្រង់ប្រមើលនិស្ស័យសត្វក៏បានជ្រាបថា អ្នកមហាក្រនឹងភរិយា ប្រគេនចង្ហាន់ភិក្ខុមួយរូបថ្ងៃនេះ, បើវៀរពីតថាគតនឹងឥតបានភិក្ខុឡើយ។ ធម្មតាព្រះពុទ្ធទាំងឡាយ តែងធ្វើសេចក្តីអនុគ្រោះចំពោះជនក្រ។ ព្រោះហេតុនោះ ទ្រង់ធ្វើសរីរកិច្ចពីព្រឹកដោយព្រះចិន្តាថា តថាគតនឹងធ្វើសេចក្តីសង្គ្រោះដល់អ្នកមហាក្រ ទើបចូលទៅប្រថាប់ក្នុងគន្ធកុដិ ថ្លែងពីអ្នកមហាក្រកំពុងយួរត្រីដើរទៅផ្ទះ ក៏ក្តៅរំជួលដល់ពិភពនៃសម្តេចអមរិន្ទ្រាធិរាជ

ស្ដេចក៏ព្រះចិន្ដាថា អ្នកមហាក្រនឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយអង្គ. ព្រះសា-ស្ដាស្ដេចនឹងអនុគ្រោះអ្នកក្រនេះដោយពិត. ដូច្នេះគួរអញទៅជួយចាត់ចែងភត្ដថ្វាយព្រះអង្គ ទើបក្លែងភេទដើរមកសុំស៊ីឈ្នួលឱ្យអ្នកមហាក្រ ដោយអួតថា ព្រះអង្គចេះវិជ្ជាដាំស្លសព្វគ្រប់ អង្វរករទាល់តែអ្នកមហាក្រសុខចិត្ដ ទើបអ្នកមហាក្រសួរថា អ្នកចាត់ចែងភត្ដមួយពេលយកថ្លៃឈ្នួលប៉ុន្មាន? ព្រះឥន្ទ-បើអ្នកប្រគេនភត្ដដល់ភិក្ខុ ខ្ញុំឥតត្រូវការដោយថ្លៃឈ្នួល សុំចែកតែបុណ្យបានហើយ។ អ្នកមហាក្រក៏ឱ្យចូលទៅក្នុងផ្ទះចាត់ចែងភត្ដ។ ឯព្រះឥន្ទប្រាប់ថា លួមអ្នកទៅទទួលលោកហើយ។ ឯអ្នកចាត់ការបានបញ្ជូនភិក្ខុទាំងឡាយតាមចំនួនក្នុងបញ្ជីរឱ្យដល់អ្នកម្ចាស់ទានរាល់ៗរូប។ អ្នកមហាក្រ ក៏ទៅទទួលភិក្ខុនឹងគេ លុះទៅដល់ក៏សួរអ្នកចាត់ថា ភិក្ខុអង្គណាដែលអ្នកត្រូវខ្ញុំ? អ្នកចាត់ភ្ញាក់ព្រើត ពោលប្រាប់ថា ខ្ញុំភ្លេចទៅហើយ។ អ្នកមហាក្រឮពាក្យនោះភ្លាមហាក់ដូចគេពួយលំពែងមានមុខដ៏មុតចំពោះចាយ ក៏យំរៀបរាប់ថា អ្នកបបួលខ្ញុំឱ្យប្រគេនចង្ហាន់ដល់ភិក្ខុមួយអង្គ. ពីម្សិលមិញខ្ញុំទៅស៊ីឈ្នួលគេទាំងប្ដីប្រពន្ធព្រឹកមិញ ដើរទៅរកបន្លែងផ្ទេរស្ពឹងទៀត. សូមអ្នកឱ្យភិក្ខុមួយអង្គ ដល់ខ្ញុំពុំខាន។ មនុស្សទាំងឡាយសួរថា អ្នកមហាក្រមានរឿងរ៉ាវយ៉ាងម៉េច? ទើបជម្រាបគេតាមសេចក្ដីនោះ។ មនុស្សទាំងនោះ ក៏សួរបញ្ជាក់អ្នកចាត់ទៀត អ្នកចាត់ក៏ពោលថាពិតមែន. ពួកមនុស្សពោលថា អ្នកធ្វើកម្មធ្ងន់ណាស់ ជាអ្នកចាត់ចែងភិក្ខុ ត្រូវឱ្យភិក្ខុមួយអង្គដល់អ្នកមាហាក្រកុំខាន។ អ្នកចាត់មាន

សេចក្តីអៀនខ្មាស់ជាពន្ទឹកក៏ពោលថា អ្នកមហាក្រសម្លាញ់ កុំឱ្យខ្ញុំវិនាស ព្រោះខ្ញុំភ្លេចឈឹង មនុស្សទាំងឡាយ ក៏នាំភិក្ខុទៅផ្ទះគេអស់ទៅហើយផ្ទះ សម្លាញ់ទៅវត្តពោលទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជា អ្នកក្រ សូមទ្រង់ធ្វើសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ, បើបុណ្យសម្លាញ់មានគង់ តែមានគង់តែបាន ព្រោះព្រះអង្គឥតទាន់ទទួលនិមន្តអ្នកណាទេ។ អ្នកមហា ក្របានរត់យ៉ាងលឿនសំដៅទៅវត្ត។ ឥស្សរជនមានស្តេចនឹងស្តេចកំឡោះ ក៏ ពោលចំអកថា អ្នកមហាក្រ ភត្តកាលមិនទាន់ដល់ដោយពិត ហេតុអ្វីបានជា អ្នកបង្ខំមក។ អ្នកមហាក្រពោលតបថា ខ្ញុំដឹងហើយថាភត្តកាលមិនទាន់ដល់ ទេ។ តែខ្ញុំមកថ្វាយបង្គំព្រះសាស្តាទេ ហើយក៏ឈរផ្តែកក្បាលលើធរណីគន្ធ-កុដិ ថ្វាយបង្គំដោយគោរពពោលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងនគរនេះឥត មាននរណាក្រជាងខ្ញុំព្រះអង្គទេ, សូមទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គ, សូមទ្រង់ ធ្វើសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ។ ព្រះសាស្តាស្តេចបើកទ្វារកុដិ ហើយ ប្រទានបាត្រឱ្យអ្នកមហាក្រនោះៗ ហាក់ដូចជាបានសោយរាជ្យ ជាស្តេច ចក្រពត្តិ។ ឥស្សរជនទាំងឡាយ ក៏រមិលមើលមុខគ្នាទៅវិញទៅមកគ្មានអ្នក ណាមួយហ៊ានដណ្តើមយកបាត្រ ដែលព្រះសាស្តាប្រទានឱ្យអ្នកមហាក្រនោះ ឡើយ។ ឥស្សរជនទាំងនោះក៏ពោលលួងលោមអ្នកមហាក្រថា ហៃអ្នកមហា ក្រគៀន ចូរអ្នកឱ្យបាត្រព្រះសាស្តាមកខ្ញុំៗ នឹងឱ្យទ្រព្យដល់អ្នកប៉ុណ្ណេះ, សម្លាញ់ជាអ្នកក្រគួរ ទទួលយកទ្រព្យទៅ វាគ្មានប្រយោជន៍ដោយបាត្រទេ។

អ្នកមហាក្រពោលថា ទេមិនឱ្យដាច់ខាតហើយ ព្រោះខ្ញុំឥតត្រូវការទ្រព្យទេ ត្រូវការតែថ្វាយចង្ហាន់ ដល់ព្រះសាស្តាប៉ុណ្ណោះ ឥស្សរជនទាំងអស់គ្នា នឹកអស់សង្ឃឹមថា នឹងបានបាត្រព្រះសាស្តាក៏ត្រឡប់ទៅផ្ទះវិញ នៅតែព្រះរាជាមួយអង្គគត់ដោយទ្រង់គិតថា អ្នកមហាក្រទុកជាអញលួងលោមដោយទ្រព្យក៏នៅតែមិនព្រមឱ្យ. រឿងនេះពិតជាគ្មាននរណាមួយហ៊ានទទួលយកបាត្រដែលព្រះសាស្តាប្រទានផ្ទាល់ព្រះអង្គឡើយ. ចាំមើលទ័យធម៌អ្នកមហាក្រនេះយ៉ាងម៉េចទៅ. អញនឹងនាំព្រះសាស្តាទៅដំណាក់ក្នុងកាលដែលអ្នកមហាក្រប្រគេនទ័យធម៌ហើយ នឹងប្រគេនអាហារដែលនាយវិសេសចាត់ចែង ដល់ព្រះអង្គ ទើបស្តេចយាងទៅជាមួយនឹងព្រះសាស្តាដែរ។ រីឯសក្កទេវរាជ ចាត់ចែងវត្ថុទាំងឡាយមានបបរ បាយ នឹងបន្ទែរួចហើយ ក៏រៀបចំអាសនៈដ៏សមគួរដល់ព្រះសាស្តា ហើយនៅអង្គុយចាំ។ អ្នកមហាក្រនិមន្តព្រះអង្គទៅដល់ផ្ទះក៏ទូលថា សូមព្រះអង្គស្តេចយាងចូល។

គួរឱ្យអស្ចារ្យណាស់ ផ្ទះគាត់ទាប បើអ្នកណាមិនឱន មិនអាចចូលទៅបានទេ. តែធម្មតាព្រះពុទ្ធទាំងឡាយ ព្រះអង្គមិនដែលឱនហើយទើបយាងចូលឡើយ. ក្នុងពេលដែលព្រះអង្គយាងចូលទៅ មហាប្រឹថពីស្រុតចុះទៅក្រោយផ្ទះអណ្តែកឡើងលើ។ នេះជាផលដែលព្រះពុទ្ធគ្រប់ព្រះអង្គបានកសាងពីបុរេជាតិ។ ព្រះសាស្តាស្តេចយាងចូលទៅគង់លើអាសនៈដែលសក្កទេវរាជក្រាលថ្វាយ។ ព្រះអង្គគង់ភ្លាម. ព្រះរាជាដែលចង់បានបាត្រ ក៏ពោល

ប្រាប់អ្នកមហាក្រថា រៃហអ្នកមហាក្រសម្លាញ់, កាលយើងសុំចាត្រអ្នក១ មិនឱ្យសោះ សក្ការៈដូចម្ដេច ដែលអ្នកបំរុងប្រគេនព្រះសាស្ដា យកមកខ្ញុំមើលផង។ លំដាប់នោះសក្កទេវរាជបើកភាជន៍បបរចាយបង្ហាញព្រះរាជា។ ក្លិនបបរចាយនោះផ្សាយទៅគ្របសង្កត់នគរទាំងអស់ ព្រះរាជាក៏រមិលមើលនូវបបរជាដើមទើបពោលទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើនខ្ញុំមកនេះគិតថា ទ័យធម៌អ្នកមហាក្រនេះមិនប៉ុន្មានទេ, បើអ្នកមហាក្រនេះប្រគេនទ័យធម៌ហើយ ខ្ញុំព្រះអង្គនឹងនិមន្តស្ដេចទៅដំណាក់ហើយថ្វាយអាហារ ដែលគេចាត់ចែងបំរុងខ្ញុំព្រះករុណា, អាហារបែបនេះខ្ញុំព្រះអង្គមិនធ្លាប់ឃើញទេ, បើខ្ញុំព្រះអង្គនៅក្នុងទីនេះអ្នកមហាក្រមុខតែលំបាក ដូច្នេះសូមថ្វាយបង្គំព្រះអង្គទៅហើយ។

ឯសក្កទេវរាជទ្រង់ចាត់ចែងទានថ្វាយព្រះសាស្ដាដោយគោរព លុះព្រះអង្គសម្រេចភត្តកិច្ចហើយ ក៏ធ្វើអនុមោទនា ហើយស្ដេចយាងត្រឡប់ទៅវិញ។ សក្កៈឱ្យសញ្ញាដល់អ្នកមហាក្រ១ក៏យកបាត្រហើយជូនដំណើររហូតដល់វត្ត។ សក្កៈត្រឡប់មកវិញ ឈរក្បែរទ្វារផ្ទះសំឡឹងមើលទៅឯអាកាសស្រាប់តែភ្លៀងកែវ៧ប្រការធ្លាក់ចុះមកបំពេញភាជនៈនឹងផ្ទះទាំងមូលឱ្យពេញរកតែទីទំនេរក៏គ្មាន ទើបប្រពន្ធអ្នកមហាក្រដឹកដៃកូនរត់ចេញទៅក្រៅផ្ទះ។ អ្នកមហាក្រត្រឡប់មកវិញ ឃើញកូនប្រពន្ធនៅខាងក្រៅផ្ទះ ក៏សួរថា ក្នុងផ្ទះកើតហេតុយ៉ាងម៉េច? បពិត្រស្វាមីផ្ទះយើងពេញដោយកែវ៧ប្រការ រកតែទី

ទំនេរក៏គ្មាន។ អ្នកមហាក្រគិតថា នេះជាផលនៃទានដែលអញឱ្យហើយក្នុងថ្ងៃនេះ ទើបដើរទៅដំណាក់ថ្វាយបង្គំព្រះរាជា។ ត្រាស់សួរថា អ្នកមានការអ្វី? បពិត្រព្រះសម្មតិទេព ផ្ទះទូលបង្គំពេញលេញដោយកែវ៧ប្រការ សូមទ្រង់ទទួលទ្រព្យនោះ។ ព្រះរាជាគិតថា ឱ! ទានដែលបុគ្គលបានថ្វាយដល់ព្រះពុទ្ធទាំងឡាយរមែងសម្រេចប្រយោជន៍ភ្លាមៗមែន ទើបត្រាស់សួរថា អ្នកយកអ្វីទៅដាក់? ក្រាបទូលយករទេះទៅមួយពាន់ទើបល្មម ព្រះរាជាក៏បញ្ជូនរទេះមួយពាន់ឱ្យទៅដឹកទ្រព្យយកមកចាក់គរក្នុងព្រះលាន គំនរនោះក៏ពស់ដើមត្នោត។ ទើបទ្រង់ត្រាស់ប្រជុំអ្នកក្រុងសួរថា ក្នុងនគរនេះ មានធនរណាមានទ្រព្យប៉ុណ្ណេះដែរ ក្រាបទូលគ្មានទេ។ ទ្រង់ក៏ប្រទានដំណែង ជាសេដ្ឋីព្រោះមានសម្បត្តិច្រើនលើសគេឯង ក្នុងនគរជាមួយគ្នា ដល់អ្នកមហាក្រនោះឱ្យក្លាយទៅជាអ្នកមានធំ[១]។ ទើបទ្រង់ប្រទានដីភូមិត្រង់ផ្ទះសេដ្ឋីម្នាក់ ឱ្យសង់ផ្ទះនៅ។ កាលជនទាំងឡាយកំពុងជំរះដីភូមិនោះឱ្យស្មើ កំណប់ទ្រព្យទាំងឡាយក៏ផុះឡើង។ អ្នកមានធំក៏នាំរឿងនោះទៅទូលព្រះរាជា។ ត្រាស់ថា កំណប់នេះកើតឡើងដោយបុណ្យរបស់អ្នកទេតើ ចូរអ្នកថែរក្សាទុកចុះ អ្នកមានធំឱ្យគេសង់ផ្ទះរួចហើយ ក៏ចាត់ចែងទានថ្វាយដល់ព្រះសង្ឃមាន ព្រះពុទ្ធជាប្រធានអស់៧ថ្ងៃ នឹងធ្វើបុញ្ញកម្មផ្សេងៗទៀតជាច្រើន លុះអស់អាយុ ក៏បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់មួយពុទ្ធន្តរ ទើបច្យុតចាក

១-នេះជាសម្បត្តិលោកិយ ។

ទីនោះ មកចាប់បដិសន្ធិក្នុងផ្ទៃនៃធីតាសេដ្ឋី ជាឧបដ្ឋាកព្រះសារីបុត្តត្ថេរ នាក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទនេះ។ តាំងពីទារកនេះ ចុះចាប់បដិសន្ធិកាល ក្នុងផ្ទៃមាតាកាលណា ជនអ្នកនៅក្នុងផ្ទះនោះ ជាជនលីលាក្តី ល្ងីល្ងើក្តី គរក្តី ឆ្កួតក្តី ក៏ក្លាយទៅជាបណ្ឌិតទាំងអស់គ្នា លុះគ្រប់ទសមាសា ក៏ប្រសូត្របុត្រ១ នោះមានឈ្មោះប្រាកដថា បណ្ឌិតទារក។ ពេលទារកនោះកើតមកក៏បណ្តាល ឱ្យទឹកចិត្តម្តាយគិតឃើញថា នឹងបណ្តោយតាមអធ្យាស្រ័យរបស់បុត្រដោយ ពិត។ កាលកុមារអាយុបាន៧ឆ្នាំ ក៏សុំមាតាទៅបួសក្នុង សំណាក់ព្រះសារីបុត្ត។ មាតាក៏បបួលញាតិចាត់ចែងគ្រឿងសម្ភារៈ នាំកុមារទៅកាន់សំណាក់ ព្រះសារីបុត្ត ហើយប្រគេនកុមារទៅលោកទូលថា សូមលោកម្ចាស់បំបួស កុមារនេះឱ្យបានផងចុះ។ ព្រះថេរៈក៏ប្រាប់រឿងបញ្ចផ្លាកម្មថា ជាការលំបាក ប្រព្រឹត្តឱ្យបានបែបបទ, តែកុមារពោលថា ខ្ញុំព្រះករុណាអាចធ្វើតាមឱវាទ របស់លោកម្ចាស់បាន។ ព្រះថេរឱ្យកាត់កោរសក់ហើយ ប្រាប់តប បញ្ចកកម្មដ្ឋាន ទើបបំបួសពេលនោះ។ ឯមាតាបិតាសាមណេរនោះនៅ ប្រគេនទានដោយសេត្រីផ្តិនដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់៧ ថ្ងៃទើបវិលទៅផ្ទះវិញ។ ថ្ងៃទី៨ ព្រះថេរៈនាំសាមណេរទៅបិណ្ឌបាត លុះ និមន្តទៅក៏បានឃើញប្រឡាយ ឃើញជាងចាំង ឃើញជាងគួនសរ ហើយសួរ ព្រះថេរៈៗ ក៏ពោលប្រាប់តាមដំណើរ ទើបឱ្យសាមណេរវិលត្រឡប់មកវិញ នឹងឱ្យកូនសោរទ្វារមកផង។ សាមណេរមកដល់វត្ត ក៏បើកទ្វារចូលទៅធ្វើ

សាមណធម៌ សម្ងំអភិរម្យនៅក្នុងកុដិតែឯកឯង។ ពេលនោះព្រះសាស្តា រមិលមើលនិស្ស័យសត្វក៏បានដឹងថា សាមណេរបណ្ឌិតនេះនឹងបានសម្រេចអរហត្តក្នុងពេលដែលតថាគតសួរប្រស្នាចំពោះសារីបុត្ត ទើបយាងទៅចាំព្រះសារីបុត្តនៅខាងក្រៅកុដិនោះ លុះព្រះថេរៈនិមន្តមកដល់ ទ្រង់សួរ៤ប្រស្នាថា ម្នាលសារីបុត្តអាហារនាំមកនូវអ្វី? ក្រាបទូលនូវវេទនា។ វេទនានាំមកនូវអ្វី? នាំមកនូវរូប។ រូបនាំមកនូវអ្វី? នាំមកនូវផស្សៈ។ លុះចប់ប្រស្នា សាមណេរនៅក្នុងកុដិក៏បានសម្រេចអរហត្តក្នុងព្រះជន្ម៧វស្សានឹង បួសបាន៨ថ្ងៃ ប្រៀបដូចជាផ្កាឈូករីកស្រស់បស់ផូរផ្ទោះឯង។

*********

# ៤. រឿងស្រីមានគូកំណាន់

(ចាក ធ. ខុ.)

(អំណាចកាមរាគនាំឱ្យកើតតម្រេកក្នុងវត្ថុមិនគួរ)

សេចក្ដីដំណាលថា មានភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតមួយអង្គ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្ដា ហើយចូលទៅកាន់ឱទ្យានចាស់មួយ ដើម្បីធ្វើសមណធម៌។ លំដាប់នោះមានស្ត្រីម្នាក់ មានរូបរាងស្រស់ល្អលើសលើសនារីទាំងអស់ក្នុងនគរ បានណាត់ពេលនឹងបុរសគូកំណាន់ម្នាក់ ឱ្យទៅជួបគ្នាក្នុងទីឈ្មោះឯណោះ ដើម្បីនឹងសប្បាយដោយមគ្គសំវាសប្រព្រឹត្តកន្លងប្រពៃណីវង្សត្រកូល នាងក៏ទៅចាំមុន។ បុរសនោះបែរជាមិនបានទៅក្នុងពេលដែលណាត់គ្នា។ កាលនាងលម្បួយរងចាំមើលផ្លូវគូរកំណាន់យូរពេក កាមរាគក៏ដុតរោលរាលក្នុងសពាង្គកាយ កើតសេចក្ដីអផ្សុកជាអស្ចារ្យ ព្រោះមិនបានគូរគាប់មកប្រឡែងគ្នាលេង ក៏ដើរចុះដើរឡើងច្រាសច្រាល់ៗដូចជាមាន់រកពង ទើបចូលទៅក្នុងឱទ្យានឃើញព្រះថេរៈកំពុងតែនភ្នែនធ្វើសមណធម៌ ក៏ក្រឡេកមើលនាយអាយក្រែងគេឃើញ លុះមិនមានឃើញអ្នកដទៃក៏គិតថា ភិក្ខុនេះក៏បុរសដែរ អញនឹងប្រលោមលោកឱ្យភាន់ភាំងដោយសារកាមទេពម្ដង ទើបទៅឈរចំពីមុខព្រះថេរៈអាក្រាតកាយបញ្ចេញស្ត្រីភាពឱ្យច្បាស់ ធ្វើអាការៈញ៉េះៗ ញ៉ោះៗ រួចទើបស្លៀកវិញ និងរំសាយសក់ផ្អៀងផ្អងធ្វើកទន់ចុះទន់ឡើងបែរផ្ទាល់ឱ្យលោកឃើញ រួចក៏ទះដៃសើចក្អាកក្អាយញញឹមប្រិមប្រិយតែឯកឯងដើម្បីឱ្យព្រះថេរមានតម្រេកតាមវត្ថុបំណងរបស់ខ្លួនជាស្រីអន្ធពាល ដែលកំ

ពុងស្រវឹងដោយកាមរាគ។ តែឥតអំពើសោះ ព្រះថេរៈរឹងរឹតតែកើតសង្វេគ មានចិត្តនឿយណាយក្នុងកាមគុណទាំង៥ មានរូបជាដើម ជាពន់ពេក ទើបលោកគិតថាហេតុនេះដូចម្ដេចហ្ន?។ កាលព្រះសាស្តាប្រមើលមើលភិក្ខុដែលរៀនកម្មដ្ឋានក្នុងសំណាក់ព្រះអង្គ ហើយនៅក្នុងឧទ្យានដើម្បីធ្វើសមណធម៌នោះ តើប្រព្រឹត្តទៅយ៉ាងណា? ក៏បានជ្រាបថា ស្ត្រីនោះកំពុងតែប្រព្រឹត្តអានាចារចំពោះភិក្ខុនោះផង នឹងសេចក្តីសង្វេគដែលកើតឡើងដល់លោកផង ទើបពោលថា ម្នាលភិក្ខុ ទីនោះមិនមែនជាកន្លែងត្រេកត្រអាលសមោសររបស់អ្នកស្វែងរកកាមទាំងឡាយទេ គឺជាទីសម្រាប់ជន ដែលមានរាគៈទៅប្រាសហើយរីករាយទេតើ ទើបត្រាស់សំដែងថា:

រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ
វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។

ព្រៃណាដែលជនមិនរីករាយ, ព្រះខីណាស្រពទាំងឡាយជាអ្នកអស់រាគៈមិនមែនជាអ្នកស្វែងរកកាមតែងរីករាយក្នុងព្រៃនោះ។

លុះចប់ធម៌ទេសនា ភិក្ខុនោះក៏បានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ទើបហោះឡានមកថ្វាយបង្គំបាទាព្រះតថាគត។ ឯស្ត្រីលម្បែងនោះអស់សង្ឃឹមនឹងបានរួមរ័ក្សមេត្រីស្នេហាក៏វិលត្រឡប់ទៅផ្ទះវិញ។

********

# ៥. រឿងកញ្ញាកុណ្ឌលកេសី

(ចាក ធ. ខុ.)

(បញ្ញាដែលខំកសាងមក មិនមែនទុកស្ងៀមទេ គឺទុកការពារខ្លួន)

ក្នុងពុទ្ធុប្បាទនេះ នាក្រុងរាជគ្រឹះ មានធីតាសេដ្ឋីម្នាក់ អាយុ១៦ឆ្នាំ មានរូបរាងល្អតល្អៃផ្ដាច់ គួរដល់ការក្រឡេកមើលជាពនពេក។ ជាធម្មតានារីទាំងឡាយ ដែលឋិតក្នុងវ័យនោះ(អាយុ១៦ឆ្នាំ) ច្រើនតែជាប់ចិត្តនឹងបុរស ឆ្កួតចិត្តព្រោះបុរសជាកំណត់។ ឯមាតាបិតាបានរៀបចំទីកន្លែងឱ្យនាងនៅក្នុងបន្ទប់ដ៏មានសិរី នាប្រាសាទមានជាន់៧ ហើយចាត់ស្ត្រីជាទាសីម្នាក់ឱ្យជាអ្នកចាំបំរើ ពេលល្ងាចព្រឹក។ និយាយពីរាជបុរស ចាប់បានមនុស្សម្នាក់ ដែលប្រព្រឹត្តធ្វើចោរកម្ម មកចងស្លាបសេក ហើយវាយបណ្ដើរទៅទីសម្លាប់។ ធីតាសេដ្ឋីឮសំឡេងគឹតកងក៏គិតថា មានហេតុយ៉ាងណាអេះ? ទើបចេញមកឈរមើលប្រុសនោះ ក៏មានចិត្តប្រតិព័ទ្ធស្នេហា ប្រាថ្នាយកមកធ្វើជាស្វាមី ហើយមិនបរិភោគ ទៅដេកសន្ធឹងសន្ធៃ ឥតនិយាយស្ដីនឹងពីណាសោះ។ ពេលនោះម្ដាយមកសួរថា នាងមានរោគយ៉ាងណា? លោកម្ដាយបើខ្ញុំបានប្រុសដែលរាជបុរសបណ្ដើរនោះមកធ្វើស្វាមី ទើបមានជីវិតរស់នៅ, បើបែរជាមិនបានវិញ, ជីវិតខ្ញុំពិតជាគ្មានរស់នៅតទៅទៀតឡើយ ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង។ ហៃកូនសម្លាញ់ទ្រូងម្ដាយ នាងកុំធ្វើយ៉ាងនេះ ចាំម្ដាយរកស្វាមីដែលមានជាតិនឹងទ្រព្យស្មើគ្នាឱ្យ។ លោកម្ដាយខ្ញុំឥតត្រូវការប្រុសដទៃទេ បើមិនបានប្រុសនេះជាប្ដីមុខជាស្លាប់។ មាតាខំនិយាយលួងលោមយ៉ាងម៉េច ក៏នាងកញ្ញា

ស្លាប់មិនបាន ទើបទៅជំរាបរឿងនោះដល់ស្វាមី។ បុរសជាបិតាមកនិយាយនៅតែឥតបានការដូចគ្នា ក៏គិតថា អញនឹងធ្វើឧបាយកលណា? គិតមិនឆ្ងាយក៏ដាច់ចិត្តឱ្យទ្រព្យមួយពាន់កហាបណៈ ជាសំណូកដល់រាជបុរសដោយពាក្យថា ចូរអ្នកទទួលយកទ្រព្យនេះ ហើយឱ្យបុរសជាប់ឃុំនោះមកខ្ញុំ។ អំណាចសំណូកអាចបង្វែងចិត្តរាជបុរសឱ្យលែងចោរនោះ ហើយចាប់បុរសដទៃមកសម្លាប់ យកដំណឹងនោះទៅទូលព្រះរាជាថា ចោរខ្លួនសម្លាប់រួចហើយថ្លែងពីសេដ្ឋី កាលបើរាជបុរសឱ្យចោរនោះមកហើយ ក៏នាំយកទៅឱ្យធីតាខ្លួន។ នាងក្រមុំបានតាក់តែងខ្លួនប្រាណលាបលនដោយប្រេងម្សៅ ប្រស់ព្រំរាងកាយយ៉ាងស្អាតបាត ដើម្បីឱ្យចោរស្រឡាញ់ ហើយចាត់ចែងវត្ថុទាំងឡាយ មានបបរបាយជាដើមដោយខ្លួនឯងឱ្យចោរស្វាមីបរិភោគ។ ចោរនោះបានរួមរសមេត្រីជាមួយនាង ដែលកំពុងក្រពុំយកលំអងក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់បានពីបីថ្ងៃ ក៏កើតសេចក្តីលោភថា អញធ្វើម្តេចហ្ន៎ នឹងបានសម្លាប់ស្ត្រីនេះ ហើយដោះយកគ្រឿងប្រដាប់លក់ទិញស្រាផឹកបាន លុះកើតគំនិតយ៉ាងនេះហើយ ក៏ដេកអត់បាយក្រហាយទឹកមិនស្តីនិយាយរកអ្នកណាសោះ។ ឯនាងប្រពន្ធឃើញដូច្នោះ ចូលទៅលួងលោមសួរថា បពិត្រស្វាមី បងកើតរោគអ្វី! ឥតមានកើតរោគអ្វីទេប្អូន។ ចុះមាតាបិតាខ្ញុំខឹងចំពោះបងឬ? លោកឥតខឹងទេ។ នាងខំឈ្លួចសួរទៀតថាចុះបងមានហេតុយ៉ាងណា សូមប្រាប់ឱ្យប្អូនដឹងផង? ប្អូនមាសព្រលឹង, កាលរាជបុរសចងបណ្តើរបងយកទៅ

សម្លាប់ បងបានបន់ស្រន់ទេវតា ដែលនៅអាស្រ័យនាជ្រោះសម្រាប់សម្លាប់ចោរថា បើបងបានរស់រូបជីវិត នឹងធ្វើពលិកម្មថ្វាយ, ឥឡូវនេះបងរួចជីវិតដោយអានុភាពនៃទេវតានោះឯង ដូច្នេះបងត្រូវតែធ្វើពលិកម្មដល់ទេវតានោះ។ បងកុំព្រួយឱ្យសោះ យើងនឹងធ្វើពលិកម្មដើម្បីលាបំណន់, បងប្រាប់មកចុះតើត្រូវការអ្វីខ្លះ? ត្រូវការមធុបាយាសមានទឹកតិច១ ផ្កានានាមានលាជ ជាគំរប់៥មុខ។ នាងពោលថា បពិត្រស្វាមីប្រសើរហើយខ្ញុំនឹងចាត់ចែងឱ្យបាន, លុះរៀបរួចហើយក៏ប្រាប់ថា បងមកយើងទៅថ្វាយពលិកម្ម។ ចោរស្វាមីតបថា បើដូច្នោះប្អូនឱ្យញាតិត្រឡប់វិញចុះ ហើយកាន់យកគ្រឿងអលង្ការ វត្ថា-ករណ៍មានថ្លៃច្រើន នឹងរៀបចំខ្លួនប្រាណឱ្យស្អាតបាតផង យើងនៅសើចលេងយ៉ាងសែនសុខ។ កុណ្ឌលកេសីនាងចេះតែធ្វើតាម ព្រោះខ្លួននាងស្រ-ឡាញ់ចោរនោះណាស់។ កាលចោរនាំនាងនោះទៅដល់ជើងភ្នំ ក៏ពោលប្រាប់ថា ប្អូនយើងទាំងពីរនាក់នឹងទៅខាងនាយពីទីនោះ, ចូរនាងឱ្យជនបរយានត្រឡប់ទៅវិញ ហើយទទូលភាជនៈដែលដាក់ពលិកម្មខ្លួនឯង យកឡើងទៅលើជ្រោះភ្នំ។ កាលបុរសស្វាមីនាំនាងទៅលើកំពូលភ្នំហើយ នាងពោលថា បពិត្រស្វាមីចូរអ្នកធ្វើពលិកម្មដល់ទេវតា តាមចិត្តអ្នកប្រាថ្នាចុះ។ ចោរឈរធ្មឹង ទើបភរិយាសួរថា ហេតុអ្វីបានជាអ្នកគ្រឹងយ៉ាងនេះ? ក៏ពោលប្រាប់ថា ឥតមានត្រូវការដោយពលិកម្មអ្វីទេ, ដែលអញនាំហងមកនេះ គឺបញ្ឆោតហងទេតើ។ បពិត្រស្វាមី អ្នកបញ្ឆោតខ្ញុំប្រាថ្នាយករបស់អ្វី? ប្រាថ្នាសម្លាប់ហងឯង

ហើយដោះយកគ្រឿងអាភរណៈរត់ទៅ។ កុណ្ឌលកេសីនាងខ្លាចសេចក្ដីស្លាប់ ក៏ពោលអង្វរថា ខ្លួនខ្ញុំក្ដីគ្រឿង អាភរណៈក្ដី សុទ្ធតែរបស់អ្នកហើយតើម្ដេច ក៏អ្នកពោលយ៉ាងនេះ? ទោះនាងអង្វរថា កុំធ្វើយ៉ាងនេះ ក៏ចោរនៅតែពោល ថា ពិតជាសម្លាប់ឯងឯងហើយ កុំអង្វរធ្វើអ្វីឥតអំពើទេ។ នាងប្រាប់ថា បើពិតជាយ៉ាងនេះមែន អ្នកសម្លាប់ខ្ញុំធ្វើអ្វី? គួរតែយកអាភរណៈទាំងនេះទៅ ហើយទុកជីវិតឱ្យខ្ញុំ. ចាប់ពីថ្ងៃនេះទៅខ្ញុំនឹងថ្វាយខ្លួននៅជាទាសីធ្វើហត្ថកម្ម បំរើអ្នកទាំងអស់ ទើបពោលថា:

ឥមេ សុវណ្ណកេយូរា សព្វេ វេឡុរិយាមយា សព្វាា
គណ្ហ ភទ្ទន្តេ មម ទាសិញ្ច សាវយ។

ខ្សែសយជាវិការនៃមាសនេះ សម្រេចពីកែវពិទូរ្យទាំងអស់ អ្នកដ៏ចំរើន យករបស់ទាំងនេះផង ឱ្យអ្នកស្រុកដឹងឮថា ខ្ញុំជាទាសីអ្នកផង។

ចោរប្រកែកថា បើអញធ្វើយ៉ាងនេះ ឯងនឹងទៅប្រាប់ម្ដាយឪពុក ឯងមិនខាន. អញពិតជាសម្លាប់ហើយ ឯងកុំយំសោកខ្លាំងពេក. ហើយ ពោលគាថាថា:

មា ពាឡ្ហំ បរិទេវេសិ ខិប្បំ ពន្ធាហ ភណ្ឌកំ។
ន តុយ្ហំ ជីវិតំ អត្ថិ សព្វំ គណ្ហាមិ ភណ្ឌកំ។

ឯងកុំយំខ្លាំងពេក ចូរស្រាយបង្វិចទ្រព្យឱ្យឆាប់. ជីវិតឯងគ្មានទេ អញនឹងយករបស់ទាំងអស់។ នាងកុណ្ឌលកេសីគិតថា ឱ!កម្មនេះធ្ងន់ណាស់

ហ្ន ធម្មតាបញ្ហាដែលបុគ្គលសាងសន្សំមកហើយមិនមែនទុកស្មោះទេ គឺទុ
ដើម្បីពិចារណាការពារភយន្តរាយ. ត្រូវអញល្បងបញ្ហាសាកនឹងគាត់នេះល
មើល ទើបពោលអង្វរថា កាលដែលរាជបុរសចាប់បងចោទថាចោរ ហើយ
នាំទៅសម្លាប់ ខ្ញុំបានប្រាប់មាតាបិតាខ្ញុំឱ្យ១ព្រាក់១ពាន់កហាបណៈទៅលោះ
បងនាំយកមកផ្ទះ. ខ្ញុំជាអ្នកមានឧបការតាំងពីពេលនោះមក ថ្ងៃនេះគួរបង
ធ្វើខ្លួនឱ្យប្រពៃ ខ្ញុំនឹងថ្វាយបង្គំលាស្លាប់ឥឡូវហើយ។ ចោរអរណាស់ពោល
ថា ល្អហើយល្អហើយ ទើបឈរបែរមុខទៅជ្រោះភ្នំឱ្យនាងថ្វាយបង្គំ។ នាង
ដើរប្រទក្សិណបុរសនោះបីជុំ ទើបថ្វាយបង្គំទិសទាំង៤ ពោលរៀបរាប់ថា
បពិត្រស្វាមី ការឃើញរូបលោកបង ក៏រលត់ត្រឹមថ្ងៃនេះ លោកបងក៏ខាន
ឃើញរូបខ្ញុំថ្ងៃនេះដែរ ហើយនាងធ្វើអាការៈឱបរឹត១ ហាក់ដូចជាមាន
អាល័យចំពោះរូបចោរជាពន់ពេក បានឱកាសឈរពីក្រោយខ្នងចោរដែល
កំពុងធ្វេសប្រហែសហើយ ក៏យកដៃម្ខាងចាប់ក ដៃម្ខាងទៀតចាប់ស្នាបប្រ
ជៀវចោរនោះ ហើយច្រានទម្លាក់ទៅក្នុងជ្រោះភ្នំនោះទៅ។ ចោរធ្លាក់ចុះមក
ប៉ះទង្គិចនឹងចង្កេះភ្នំ ដាច់ដោចខ្លួនប្រាណជាកំណាត់១ ទើបធ្លាក់មកដល់ដី
ក្សិណក្ស័យក្នុងពេលនោះឯង។ ទេព្តាដែលអាស្រ័យលើភ្នំនោះ ក៏ឱ្យពរសព្
សាធុការដល់នាងកុណ្ឌលកេសីគ្រប់១គ្នា ដោយឧទានគាថាថា:

ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បិណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។

បុរសនោះមិនមែនមានប្រាជ្ញាសព្វទីឋានទេឯស្ត្រីជាបណ្ឌិតមានបញ្ញាសម្រាប់ពិចារណា រមែងមានក្នុងទីនោះៗ។

សង្ខេបរឿងនេះប៉ុណ្ណេះ ទាញមកនេះគ្រាន់តែបញ្ជាក់ថា ប្រាជ្ញាដែលបុគ្គលចេះថ្លៃ អាចការពារខ្លួនឱ្យជៀសរឿងភយន្តរាយបាន។ អ្នកសុភាសិតទាំងឡាយ គួររាប់រឿងនេះបញ្ចូលក្នុងភាសិតបុរាណថា (ផ្លូវវៀចកុំបោះបង់ផ្លូវណាត្រង់កុំដើរហោង)ផងចុះព្រោះថា បើនាងកុណ្ឌលកេសីមិនដើរផ្លូវវៀចដោយការភូតកុហកចោរទេ ដើរតែផ្លូវត្រង់នាងពិតជាក្ស័យដោយស្នាដៃចោរជាមិនខាន តែនាងបានដើផ្លូវវៀច ដោយប្រើឧបាយកលយ៉ាងចំណានភូតចោរឱ្យជឿជាក់ក្នុងសន្ដានដរាបដល់ច្រានចោរទំលាក់មកពីភ្នំឱ្យក្ស័យក្នុងជីវិតក្នុងពេលនោះឯង។ ទើបបានរួចរស់ជីវិតរបស់នាង។

********

# ៦. រឿងព្រះបាទនន្ទរាជ

(ចាក អ. សំ.)

(អានិសង្សនៃចីវរទានដែលជនឱ្យចំពោះព្រះបច្ចេកពុទ្ធ)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានកុដុម្ពិកៈម្នាក់បានចូលទៅក្នុងព្រៃ ឃើញព្រះបច្ចេកពុទ្ធមួយអង្គកំពុងដេរចីវរ ដែលមានសំពត់មិនគ្រប់គ្រាន់ត្រង់អនុវាតបណ្ដោយ។ កុដុម្ពិកៈ កាលឃើញលោកខ្វះសំពត់ធ្វើអនុវាតដូច្នោះ ក៏មានចិត្តជ្រះថ្លា ហើយយកសំពត់សម្រាប់បង់ករបស់ខ្លួនប្រគេនលោក។ លុះស្លាប់ទៅដោយអានុភាពនៃបុញ្ញកម្មនោះឯង បុរសនោះទៅកើតក្នុងឋានតាវត្តិង្សទេវលោក សោយសម្បត្តិទិព្វអស់កាលជាយូរអង្វែង ពេលច្យុតមកវិញ បានមកកើតនាត្រកូលអមាត្យម្នាក់ នៅឆ្ងាយពីទីក្រុងពារាណសី១យោជន៍។ ទារកនោះចំរើនវ័យធំឡើងកាលណា ក៏បាននិយាយនឹងមាតាថា លោកម្ដាយ ថ្ងៃនេះជាថ្ងៃលេងនក្ខត្តឫក្ស សូមម្ដាយឱ្យសំពត់មួយមកខ្ញុំៗនឹងទៅលេងនក្ខត្តឫក្សនឹងគេ។ មាតាបានឱ្យសំពត់មួយដល់កូននោះៗពោលថា សំពត់នេះមានសាច់គ្រោតគ្រាតណាស់ ខ្ញុំមិនយកទេ សូមម្ដាយឱ្យសំពត់ដទៃទៀត។ ម្ដាយឱ្យសំពត់ដទៃទៀតតាមពាក្យសុំរបស់កូនៗ នោះក៏នៅតែទន្ទេញថា សំពត់សាច់គ្រោតគ្រាតណាស់ខ្ញុំមិនយកទេ។ ម្ដាយពោលថា ផ្ទះយើងគ្មានសំពត់ដទៃឱ្យល្អជាងនេះទៀតទេ។ បុរសកូននិយាយថាបើដូច្នោះ ខ្ញុំទៅស្វែងរកសំពត់មួយដ៏គាប់ចិត្តឱ្យបាន។ ម្ដាយពោលថា ម្ដាយឥតមានស្អប់កូនឯងទេ គឺចង់ឱ្យកូនឯង បានសោយរាជ្យ ជាម្ចាស់ផែនដីនា នគរ

ពារាណសីនេះ។ បុរសនោះក៏ថ្វាយបង្គំមាតាដើរចូលទៅកាន់នគរពារាណសី នៅដេកទទួលត្បាលលើផែនថ្មមង្គល នាព្រះរាជឧទ្យាន។ ពេលនោះជាថ្ងៃទី៧ ដែលព្រះចៅពារាណសីសោយព្រះទីវង្គតទៅ ពួកអមាត្យអ្នកមុខអ្នកងារក្នុងនគរ បានធ្វើព្រះសពសំស្ការឈាបនកិច្ចតាមប្រពៃណីរបស់ព្រះរាជា ជាស្រេចក៏ប្រឹក្សាគ្នាថា ព្រះរាជារបស់យើងមានតែព្រះរាជធីតា១ព្រះអង្គធម្មតាប្រទេស ត្រូវតែមានជនម្នាក់ជាប្រមុខ ទើបអាចឋិតថេរជាយូរបាន លុះគិតដូច្នោះហើយ ក៏រៀបចំបុស្សរថ ទឹមដោយសេះសិន្ធព៤ មានពណ៌ដូចផ្កាបុទុម ហើយដំកល់គ្រឿងរាជកកុធភណ្ឌ[1] លើរថទើបលែង[2] ទៅ។ ចំណែកបុស្សរថ ចេញទៅតាមទ្វារខាងកើត ហើយចូលទៅកាន់សួនឧទ្យាន ដើរប្រទក្សិណាបុរសកំពុងដេក៣ជុំ នៅឈប់ស្ងៀមបំរុងនឹងឱ្យបុរសនោះឡើងជិះ។ ឯរាជបរោហិតដែលទៅតាម ក៏បើកជាយសំពត់ឡើង ហើយក្រឡេកមើលផ្ទៃជើងទើបទាយថា បុរសនេះគួរនឹងបានសោយរាជ្យជាម្ចាស់ផែនដី ហើយបានប្រគុំពិណពាទ្យ ភ្លេងព្រះរាជទ្រព្យអស់វារៈ៣ដង។ លំដាប់នោះបុរសបើកមុខឡើងសួរថា អ្នកទាំងឡាយមកប្រជុំគ្នាក្នុងទីនេះតើមានការអ្វី? ជនទាំងឡាយពោលថា បពិត្រព្រះសម្មតិទេព ឥឡូវនេះរាជ្យក្រុងពារាណសី

១. ប្រដាប់អភិសេកស្តេចមាន៥គឺ ព្រះខ័ន១ ឆត្រ១ មកុដ១ ទ្រនាប់ជើង១ ផ្លិតរោមកន្ទុយសត្វ១។ ២. នេះជាទំនៀមដែលអ្នកជម្ពូទ្វីបលែងបុស្សរថឱ្យដើរស្វែងរកស្តេចដែលប្រកបដោយទសពិធរាជធម៌។

នេះត្រូវធ្លាក់មកលើព្រះអង្គហើយ សូមទ្រង់ទទួលយកតាមគាប់ព្រះរាជហឫទ័យ។ បុរសសួរថា ចុះព្រះរាជារបស់អ្នកទៅណា? ព្រះរាជារបស់យើងទ្រង់សោយព្រះទិវង្គតទៅហើយ។ ចុះព្រះរាជបុត្រក្តីព្រះរាជធីតាក្តីមិនមានទេឬ? មានតែព្រះរាជធីតា។ បើដូច្នោះយើងនឹងទទួលសោយរាជ្យ បំពេញបំណងអ្នកទាំងឡាយចុះ។ ជនទាំងឡាយ ក៏ចាត់ចែងមណ្ឌលសម្រាប់អភិសេកមួយរំពេច លុះធ្វើរួចក៏អភិសេកក្នុងមណ្ឌបនោះឯង ថ្វាយព្រះនាមព្រះរាជាថ្មីថា ព្រះបាទទន្តរាជ ហើយនាំយកសំពត់មួយ មានថ្លៃមួយពាន់កហាបណៈមកថ្វាយ។ ព្រះរាជាមានព្រះបន្ទូលថា សំពត់នេះមានសាច់គ្រោតគ្រាតណាស់ យើងមិនយកទេ ចូរអ្នកទាំងឡាយយកកុណ្ឌីមាសមក យើងនឹងបាចសាចទឹកទៅទិសខាងកើត ហើយមុខជាបានសំពត់ មានសាច់ផូរផង់ម៉ដ្ឋមិនខាន។ ពេលនោះដើមកប្បព្រឹក្ស៨ដើម១ ក៏ទំលាយផែនដីផុសឡើងគ្រប់ទិសទាំង៤ រួមជា៣២ដើម។ សំពត់ក៏កើតឡើងជាមួយដើមកប្បព្រឹក្សទាំង៣២នោះឯង។ ព្រះរាជាទ្រង់ព្រះពស្ត្រព្រះភូសាសំពត់ទិព្វ១ ដណ្តប់សំពត់ទិព្វ១ ហើយទ្រង់បានបង្គាប់ឱ្យរាជអមាត្យទូងស្គរភេរីប្រកាសប្រាប់អ្នកក្រុងពារាណសីថា ពួកស្ត្រីក្នុងដែនរបស់ព្រះអង្គ កុំបាច់រវៃសូត្រអម្បោះឡើយ ទើបទ្រង់ឱ្យលើកឆត្រឡើង ស្តេចប្រថាប់លើព្រះទីនាំងគជេន្ទ្រជ័យ យាងចូលទៅកាន់ទីក្រុងឡើងទៅលើប្រាសាទ ហើយទ្រង់ទទួលរាជ្យដែលធ្លាក់មកលើព្រះអង្គ នឹងទ្រង់បានរៀបចំ ព្រះនគរទាំងមូល យ៉ាងស្អាតល្អ ប្រហែលនឹងឧត្តរកុរុទ្វីប

ព្រមទាំងព្រះរាជទានសំពត់ទិព្វ ដល់ពួកមនុស្សក្នុងនគរនានា ដែលមកទាំងអម្បាលម៉ានគ្រប់ៗគ្នា។

លុះចំណេរកាលជាខាងក្រោយមក ទ្រង់មានសេចក្ដីនឿយណាយនឹងរាជសម្បត្តិនឹងឃរាវាសធម៌ ទើបលះបង់ចោល ហាក់ដូចជាបុគ្គលស្ដោះទឹកមាត់ ហើយចេញទៅទ្រង់ព្រះផ្នួសជាមួយព្រះទេពីអគ្គមហេសី ជាតាបសតាបសិនី គង់ក្នុងឧទ្យាន ខំចំរើនឈានអភិញ្ញា ក៏បានសម្រេចតាមព្រះបំណង ហើយជាបុគ្គលមិនដែលសាបសូន្យចាកឈានឡើយ លុះសោយព្រះទីវង្គតទៅ បានកើតនៅព្រហ្មលោកនាយហោង។

ប្រជុំជាតក ព្រះបាទធនរាជ គឺព្រះមហាកស្សបៈក្នុងកាលឥឡូវនេះ ព្រះអគ្គមហេសី គឺព្រះនាងភទ្ទាកាបិលានី។

---

# ៧~ រឿងឧបាសកតិស្សៈ

(ចាក អ. សំ.)

(អ្នកមានសីល ស៊ូលះបង់ជីវិតខ្លួន ដើម្បីប្តូរយកជីវិតសត្វទុក)

ព្រះមហាក្សត្រតិស្សមហារាជ ជាស្តេចមានធម៌ សោយរាជសម្បត្តិនៅក្រុងលង្កាទ្វីប ទ្រង់មានព្រះរាជហឫទ័យ ចង់សោយសាច់ទទាអាំងជាពន់ពេក តែទ្រង់ឈ្វេងយល់ថា បើអញនិយាយប្រាប់គេថា ចង់ស៊ីសាច់ទទាអាំង មុខជាអាណាប្រជានុរាស្ត្រនឹងធ្វើសាច់ទទាទាំងឡាយ ឱ្យវិនាសក្នុងទីប្រមាណមួយយោជន៍ជុំវិញ។ ព្រះរាជាទ្រង់ខំអត់សង្កត់ចំណង់នោះ អស់រយៈ ៣ឆ្នាំ រោគខ្ទុះ ក៏កើតឡើងនាព្រះកាណ៌ទ្រង់ៗ មិនអាចអត់ទ្រាំនឹងសេចក្តីស្រេកឃ្លានបាន ក៏ត្រាស់បន្ទូលព្រះសូរសីហនាទសួរថា អ្នកបំរើអញ មានអ្នករក្សាសីលដោយត្រឹមត្រូវដែរឬ? ក្រាបទូលមានឧបាសកម្នាក់ឈ្មោះតិស្សៈ ជាអ្នករក្សាសីលដោយត្រឹមត្រូវ មិនដែលឱ្យដាច់ដោចធ្លុះធ្លាយ ដល់ម្តងឡើយ។ ព្រះរាជាមានប្រាថ្នានឹងល្បងឧបាសកនោះមើល ទើបបង្គាប់ឱ្យហៅឧបាសកនោះមក។ ឧបាសកមកហើយ ចូលទៅថ្វាយបង្គំព្រះរាជាអង្គុយក្នុងទីដ៏សមគួរ។ ព្រះរាជាសួរថា អ្នកឯងឈ្មោះតិស្សឧបាសកឬ? ក្រាបទូលឈ្មោះតិស្សៈ។ ព្រះរាជាបង្គាប់ថាអ្នកឯងចូរទៅវិញចុះ។ ឧបាសកក៏ថ្វាយបង្គំត្រឡប់ទៅវិញ។ កាលឧបាសកទៅផុត ព្រះរាជាទ្រង់បង្គាប់បុរសម្នាក់ឱ្យយកមាន់រស១ ទៅឱ្យឧបាសកនោះ ធ្វើម្ហូបបីមុខមកថ្វាយព្រះអង្គ ជាព្រះក្រយាស្ងោយ។ បុរសនោះក៏ធ្វើតាមព្រះរាជអាជ្ញា។ ឧបាសកនិយាយនឹង

រាជបំរើនោះថា បើមាន់នេះងាប់ស្រាប់យើងអាចចាត់ចែងព្រះក្រយាស្ងោយថ្វាយតាមព្រះរាជបំណងបាន តែឥឡូវនេះ មាន់នោះរស់ យើងធ្វើមិនបានទេព្រោះយើងកាន់សីល មិនសម្លាប់សត្វ ចូរអ្នកទូលព្រះរាជាវិញចុះ។ រាជបុរសក៏ទៅទូលព្រះរាជាតាមពាក្យនោះ។ ព្រះរាជាបានត្រាស់បង្គាប់រាជបុរស ឱ្យទៅប្រាប់ទៀត. រាជបុរសក៏ទៅប្រាប់ឧបាសកនោះថា អាថ្វាស្តេចផ្ទន់ពេកណាស់ អ្នកឯងធ្វើយ៉ាងនេះមិនគួរទេ បើអ្នកសម្លាប់មាន់នេះធ្វើព្រះក្រយាស្ងោយថ្វាយព្រះរាជា ហើយដាច់សីលអ្នកឯងអាចសមាទានវិញបាន។ តិស្សឧបាសក ប្រាប់រាជបុរសនោះថា ក្នុងមួយអត្តភាព មានសេចក្តីស្លាប់តែមួយផង មិនដែលមានដល់ពីរផង ដូច្នេះយើងមិនធ្វើបាណាតិបាតកម្មបានទេ. រាជបុរសក៏ត្រឡប់ទៅក្រាបទូលព្រះរាជាវិញ។ ព្រះរាជាត្រាស់ប្រើឱ្យសម្លាប់មាន់ជាគំរប់៣ផង ក៏តិស្សឧបាសកមិនព្រម ទើបទ្រង់ត្រាស់ឱ្យហៅតិស្សឧបាសកនោះមកសួរថា ហេតុអ្វីក៏អ្នកឯងមិនសម្លាប់មាន់ ធ្វើព្រះក្រយាស្ងោយយកមកឱ្យខ្ញុំ។ ឧបាសកទូលថា ព្រះសម្មតិទេវវង្ស ខ្ញុំព្រះអង្គជាអ្នករក្សាសីល មិនអាចសម្លាប់សត្វបានទេ។ ព្រះរាជាបង្គាប់ថា នែនាយពេជ្ឈឃាដទាំងឡាយ ចូរនាំឧបាសកនេះយកទៅសម្លាប់កាត់ក្បាលវាចោលចេញ ព្រោះវាមិនស្តាប់បង្គាប់អញជាម្ចាស់ផែនដី តែទ្រង់បានប្រាប់អាថ៌កំបាំងជាសញ្ញាដល់ពេជ្ឈឃាដថា អ្នកទាំងឡាយកុំសម្លាប់មនុស្ស ហើយត្រឡប់មកប្រាប់អញវិញ។ ពួករាជបុរសនាំឧបាសកនោះទៅឱ្យដេកលើឈើជ្រញ់ ហើយឱ្យ

មាន់ទៅបុរសនោះ។ ឧបាសកក៏យកមាន់ដាក់លើទ្រូង ហើយនិយាយថា នែមាន់! យើងបានឱ្យជីវិតយើងទៅប្ដូរយកជីវិតអ្នក ដើម្បីឱ្យឯងរស់នៅ មាន់ឯងកុំភ័យអី ចូរឯងហើរទៅចុះ! ថាដូច្នោះហើយ ក៏បោះមាន់នោះទៅ។ មាន់បានទទះស្លាបហើរទៅទុំលើដើមជ្រៃមួយក្បែរនោះ។ កន្លែងនោះឈ្មោះថា កុក្កុដគិរី ប្រែថា កន្លែងឱ្យអភ័យដល់មាន់។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដំណឹងនោះហើយ ទើបត្រាស់ប្រើបុត្រអមាត្យម្នាក់ ឱ្យទៅហៅឧបាសកនោះមកវិញ ប្រទានគ្រឿងឥស្សរិយសឱ្យ ហើយត្រាស់ថា យើងមិនធ្វើទុក្ខបុកម្នេញដល់អ្នកទេ យើងគ្រាន់តែល្បងសាកមើលទេតើ ព្រោះចង់សោយសាច់ទទាអាំងកន្លងមក៣ឆ្នាំហើយ អ្នកឯងចាត់ចែងសាច់ទទាដែលបរិសុទ្ធដោយទីបំផុត៣យ៉ាង[១] ដល់យើងបានឬទេ? ឧបាសកនោះទទួលព្រះរាជបន្ទូលហើយក៏ចេញទៅឈរទៀបមាត់ទ្វារ បានឃើញបុរសម្នាក់យួរសាច់ទទា៣ ងាប់ស្រាប់មកពីព្រលឹម ទើបសួរទិញបុរសនោះឱ្យថ្លៃ២កហាបណៈ ហើយយកមកចាត់ចែងបង់គ្រឿងប្រហើរ ទាំងឡាយមានខ្ទឹមជាដើម អាំងឆ្អិនស្រាច់បាច់ហើយ ក៏នាំទៅថ្វាយព្រះរាជាជាព្រះក្រយាស្ងោយក្នុងគ្រានោះឯង។

********

១. មិនឃើញ ១ មិនឮ ១ មិនរង្កៀស ១ ។

# ៨. រឿងសញ្ជីវមាណព

(ចាក ស. ង.)

(សង្គ្រោះអសប្បុរស នឹងវិនាសខ្លួនដោយពិត)

កាលកន្លងទៅហើយ មានមាណពម្នាក់ឈ្មោះសញ្ជីវៈ បានសិក្សាមន្តវិជ្ជាការ ជាមួយនឹងសិស្ស៥០០រូប ក្នុងសំណាក់អាចារ្យទិសាបាមោក្ខ នាក្រុងពារាណសី។ សញ្ជីវមាណពបានសុំលោកអាចារ្យរៀនមន្តប្រស់សត្វស្លាប់ ឱ្យរស់មកវិញ។ លុះមន្តវិជ្ជាសាស្ត្របានសម្រេចហើយ ថ្ងៃមួយមាណពនោះ បានចូលទៅរកអុសក្នុងមហាវ័នជាមួយនឹងសិស្សនានា បានប្រទះខ្លាស្លាប់១ ក៏ពោលប្រាប់គេថា ភឿនទាំងឡាយ ចាំមើលខ្ញុំប្រស់ខ្លាងាប់នេះណា!។ សិស្សទាំងអស់គេពោលប្រាប់ថា សំឡាញ់ចូរប្រស់សាកលមើលចុះ រួចគេរត់ឡើងដើមឈើទាំងអស់គ្នាទៅ។ សញ្ជីវមាណពក៏តាំងរាយមន្តប្រស់ខ្លានោះ ហើយយកគ្រាមដៃផ្ទាត់ផង។ ខ្លាក៏រស់ឡើងភ្លាម ហើយស្ទុះទៅខាំមាណពនោះស្លាប់ ទើបដួលត្រឡប់ទៅវិញ។ ខ្លានឹងមាណពក៏ស្លាប់ក្នុងទីជាមួយគ្នា ក្នុងពេលនោះឯង។ សិស្សទាំងឡាយ ក៏នាំរឿងនោះ មកជម្រាបអាចារ្យ១ ក៏ពោល ថា នែអ្នកទាំងឡាយ ជនណាដែលបានលើកដំកើង សង្គ្រោះអសប្បុរស ហើយធ្វើសក្ការៈរាប់អានក្នុងទីមិនសមគួរ ជននោះតែងតែបានសេចក្ដីទុក្ខលំបាក វិនាសខ្លួនប្រាណ សាបសូន្យ ចាកជីវិតដូចជា សញ្ជីវមាណពនេះជាកំណត់ ព្រោះអសប្បុរស មើលមិនឃើញអ្នកសង្គ្រោះទេ ទើបពោលគាថា តទៅទៀតថា:

អសន្តំ យោ បគ្គណ្ហាតិ អសន្តញ្ចូបសេវតិ តមេវ
ឃាសំ កុរុតេ ព្យគ្ឃោ សព្ពីរកំ យថា ។

អ្នកណាលើកដំកើងនឹងគប់រកអសប្បុរស, អសប្បុរសនោះ តែងតែធ្វើអ្នកដំកើង ឱ្យទៅជាចំណីរបស់ខ្លួន ដូចខ្លានឹងមាណពឈ្មោះសព្ពីរៈ ។

*******

## ៩- រឿងព្រាហ្មណ៍ភារទ្វាជ

(ចាក អ. ព្រា.)

(អរិយសាវក មិនដែលព្រឺដោយពាក្យគម្រាមអ្នកដទៃឡើយ)

ក្រុងរាជគហៈមានព្រាហ្មណ៍ម្នាក់ឈ្មោះភារទ្វាជ ជាមនុស្សមិច្ឆាទិដ្ឋិ ឥតមានសទ្ធា ឥតមានសេចក្ដីជ្រះថ្លា នឹងរឹងត្អឹងប្រហែលដង្កត់ឈើដើមគគីរ បើមានជនណាពោលថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គាត់តែងយកដៃខ្ទប់ត្រចៀកជានិច្ច។ ឯប្រពន្ធគាត់ឈ្មោះធនញ្ជានី ជាអរិយសាវិកា មានសទ្ធា មានសេចក្ដីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាជាមហិមា។ នាងនោះឈរក្ដី អង្គុយក្ដី កណ្ដាស់ក្ដី ក្អកក្ដី តែងធ្វើការនមស្សការថា នមោពុទ្ធស្ស សូមថ្វាយបង្គំព្រះពុទ្ធ ដូច្នេះជាច្រើនប្រក្រតី។ និយាយពីព្រាហ្មណ៍ជាស្វាមី ចង់ឱ្យមធុបាយាសមានទឹកតិចដល់ព្រាហ្មណ៍៥០០រូប ក៏ពោលអង្វរប្រពន្ធថា ម្នាលនាង ស្អែកនេះខ្ញុំអញ្ជើញព្រាហ្មណ៍៥០០ ឱ្យមកឆាន់ក្នុងផ្ទះយើង. នាងកុំធ្វើនមស្សការសមណៈគោតម អស់មួយថ្ងៃស្អែកនេះ ព្រោះព្រាហ្មណ៍ទាំងឡាយ បើឮពាក្យនមស្សការនេះ មុខជាអាក់អន់ចិត្តជាមិនខាន ដូច្នេះកុំធ្វើឱ្យខ្ញុំបែកពីពួកព្រាហ្មណ៍ទាំងនោះ។ ព្រាហ្មណីពោលតបថា ខ្ញុំមិនអាចខានរលឹកព្រះសាស្ដាបានទេ ទោះអ្នកបែកពីព្រាហ្មណ៍ក៏ដោយ ពីទេព្ដាក៏ដោយ។ ព្រាហ្មណ៍ក៏ទាញព្រះខ័នមកគម្រាមថា បើនាងនមស្សការសមណគោតម ក្នុងកណ្ដាលប្រជុំព្រាហ្មណ៍ទាំងនោះ អញនឹងកាត់ក្បាលនាង ដោយព្រះខ័ននេះជាកំណត់។ ធម្មតាផែនដីមិនងាយអ្នកណាឱ្យកុំកើតបាន ឬអ្នកណាមួយអាចបង្វិលភ្នំសិនេរុ

បាននោះឡើយ ឯព្រះអរិយសាវកទាំងឡាយ ក៏មិនងាយអ្នកណា បង្ហៀលបាន យ៉ាងនោះដែរ ព្រោះហេតុនោះ បានជានាងព្រាហ្មណី ជាអរិយសាវិកា ពោលថា:

សចេ មំ អង្គមង្គានិ កាមំ ឆេជ្ជសិ ព្រាហ្មណ នេវាហំ

វិរមិស្សាមិ ពុទ្ធសេដ្ឋស្ស សាសនា ។

ម្នាលព្រាហ្មណ៍បើអ្នកពិតជាកាត់អវៈយវៈតូច-ធំខ្ញុំ ឱ្យខ្ញុំវៀរចាកសាសនា ព្រះពុទ្ធដ៏ប្រសើរ ក៏ពិតជាមិនបានដែរ។ ព្រាហ្មណ៍មិនប្រហារនាងព្រាហ្មណី ក៏ពោលថា នាងគាប់ចិត្តកម្មណាចូរ ធ្វើកម្មនោះចុះ លុះថ្ងៃព្រឹកឡើងក៏ឱ្យ គេចាត់ចែងបាយាស ហើយឱ្យទៅប្រាប់ភត្តកាលដល់ព្រាហ្មណ៍ទាំងឡាយ១ មកអង្គុយផ្ទះខ្មា ឯព្រាហ្មណ៍ក៏អង្គុយ នៅទីបំផុតនៃផ្ទះនោះដែរ។ ព្រាហ្មណី កាន់វែកមាស ចូលទៅអង្គាសភត្តឱ្យព្រាហ្មណ៍ទាំងឡាយ ប៉ះទង្គិចជើងនឹង ជញ្ជាំង ហើយរលឹកចំពោះព្រះសាស្តា ធ្វើប្រណាមវាចារ លើកករប្រណម្យ ទៅរកវត្តវេឡុវ័នថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អស់វារៈ៣ដង។ លំដាប់នោះ ពួកព្រាហ្មណ៍ខ្លះ បរិភោគរួចហើយ ខ្លះកំពុង បរិភោគ ខ្លះទៀតកំពុងលើកបាយដាក់ក្នុងមាត់ លុះឮស្សូរពាក្យនោះ ក៏ហាក់ ដូចគេយកដាវប៉ុនភ្នំសមេរុ មកសំពងក្បាល ឬដូចជាគេយកដែកស្រួច មក ចាក់ធ្លៀលត្រង់ត្រចៀក ហើយខ្ជាក់បាយចោលមកវិញជេរប្រទេច ព្រាហ្មណ៍ អ្នកអញ្ជើញ ទើបចៀសចេញទៅ។ ឯព្រាហ្មណ៍ជាស្វាមីក៏ជេរប្រទេចនាងជា

កិរិយាដោយការផ្សេងៗ តែមិនអាចធ្វើអ្វីនាងបាន ក៏ពោលថា ស្រីចង្រៃនេះ
ចេះតែពោលសរសើរសមណៈគោតមយ៉ាងនេះ ឥឡូវនេះ អញនឹងពោល
ផ្ដាញ់ផ្ដាលឱ្យ សមណៈគោតមនោះ ទើបដើរទៅវត្តវេឡុវ័ន់ទាំងកំហឹង ទៅ
ដល់មិនថ្វាយបង្គំព្រះសាស្ដាផង ស្រាប់តែសួរ ប្រស្នាថាៈ

កឹ សុ ឃត្វា សុខំ សេតិ កឹ សុ ឃត្វា ន សោចតិ
កិស្សស្ស ឯកធម្មស្ស វធំ រោចេសិ គោតម ។

បុគ្គលសម្លាប់អ្វីហ្ន៎ ទើបដេកលក់ស្រួល? សម្លាប់អ្វីហ្ន៎ ទើបមិនសោយ
សោក?បពិត្រព្រះគោតម ព្រះអង្គគាប់ចិត្តសម្លាប់ធម៌អ្វីជាធម៌តែមួយ?

ព្រះសាស្ដាតបថាៈ

កោធំ ឃត្វា សុខំ សេតិ កោធំ ឃត្វា ន សោចតិ
កោធស្ស វិសមូលស្ស មធុរគ្គស្ស ព្រាហ្មណ
វធំ អរិយា បសំសន្តិ តញ្ហិ ឃត្វា ន សោចតិ ។

បុគ្គលសម្លាប់សេចក្ដីក្រោធទើបដេកស្រួល សម្លាប់សេចក្ដីក្រោធទើប
មិនសោយសោក. ម្នាលព្រាហ្មណ៍ ព្រះអរិយៈទាំងឡាយតែងសរសើរការ
សម្លាប់សេចក្ដីក្រោធដែលមានឫសជាពិស មានចុងដ៏ផ្អែម បើបុគ្គលសម្លាប់
សេចក្ដីក្រោធនោះបាន ទើបមិនសោយសោក។ លុះចប់ប្រស្នាដែលព្រះព្យា
ករហើយព្រាហ្មណ៍ក៏មានសេចក្ដីជ្រះថ្លាហើយ សុំឧបសម្បទាក្នុងសំណាក់
ព្រះអង្គមិនយូរប៉ុន្មានក៏សម្រេចព្រះអរហត្តទៅ។

## ១០. រឿងបុរសខ្វិន

(ចាក អ. សា.)

(សិប្បៈតិចតួច បើចេះឱ្យស្ទាត់ អាចចិញ្ចឹមជីវិតបាន)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ ជាអ្នកចេះស្ទាត់សិប្បៈខាងផ្ទាត់គ្រាប់គ្រួស។ ថ្ងៃមួយ ក្មេងទាំងឡាយបានឱ្យបុរសខ្វិននោះជិះរថទៅកាន់ដើមជ្រៃធំមួយក្បែរទ្វារនគរ ឱ្យបុរសនោះធ្វើរូបដំរី ធ្វើរូបសេះ ដោយស្លឹកជ្រៃ ហើយសើចលេងសប្បាយ ទើបឱ្យរង្វាន់ដល់បុរសខ្វិននោះឯង។ បុរសខ្វិនក៏ផ្ទាត់គ្រួសធ្វើស្លឹកឱ្យចេញជារាង ជារូបផ្សេងៗ តាមចំណង់ទារកទាំងនោះ។ ពេលនោះទ្រង់ព្រះរាជា ស្តេចទៅឧទ្យាន ហើយទៅដល់ទីនោះ។ ទារកទាំងឡាយក៏រត់ប្រញាប់ ព្រោះខ្លាចនាយតម្រួត (ភ្នាក់ងារនគរបាល)។ ឯបុរសខ្វិនក៏ដេកនៅនាទីចន្លោះដើមជ្រៃនោះ ព្រោះខ្វិនរត់ ឬក៏ដើរមិនរួច។ ព្រះរាជាស្តេចយាងទៅដល់នគរ ឃើញរូបផ្សេងៗនាស្លឹកជ្រៃ ក៏ត្រាស់សួររាជបុរសថា អ្នកណាធ្វើរូបនេះ? ក្រាបទូល បុរសខ្វិន។ ព្រះរាជាទ្រង់ត្រាស់ហៅបុរសខ្វិននោះមកសួរថា ម្នាលអ្នកបុរោហិតខ្ញុំម្នាក់ ជាអ្នកមានមាត់រឹងពេក ចូលចិត្តនិយាយច្រើន. បើបុរោហិតនោះផ្តើមនិយាយហើយ គ្មានអ្នកណានិយាយផងបានទេ. អ្នកអាចធ្វើឱ្យបុរោហិតនោះកុំនិយាយបានឬទេ? ក្រាបទូល អាចធ្វើមិនឱ្យបុរោហិតនោះនិយាយបាន តែសូមទ្រង់ប្រទានអាចម៍ពពែមួយនាឡិមកទូលបង្គំ។ ព្រះរាជាទ្រង់នាំបុរសខ្វិនទៅរាជដំណាក់ ហើយឱ្យអង្គុយខាងក្នុងវាំងនន ទ្រង់ញាំងគេឱ្យ

ចោះរាំងនន ហើយឱ្យយកអាចម៍ពពែស្ងួតចំនួន១នាឡិ ទៅដាក់ជិតបុរសខ្វិន នោះ ទើបចាត់ចែងឱ្យគេក្រាលអាសនៈសម្រាប់បុរោហិតនោះ ឱ្យមានមុខ ឆ្ពោះទៅរកប្រហោងដែលទ្រង់ឱ្យគេកាត់ លុះបុរោហិតមកដល់ ក៏ទ្រង់ឱ្យ អង្គុយលើអាសនៈនោះ ហើយទ្រង់ផ្ដើមនិយាយឡើង។ បុរោហិតឥតដឹងខ្លួន បាននិយាយប៉ប៉ាច់ប៉ប៉ោចជាមួយព្រះរាជា ដោយមិនឱ្យអ្នកណាបាននិយាយ សោះឡើយ។ លំដាប់នោះបុរសខ្វិនក៏ផ្ទាត់អាចម៍ពពែមួយដុំម្ដងៗទៅក្នុងមាត់ បុរោហិតៗបុរោហិតបានលេបអាចម៍ពពែដែលចូលក្នុងមាត់ ដូចជាគេស៊ីនំ ល្ង។ ព្រះរាជាទ្រង់ជ្រាបថា អាចម៍ពពែ បុរសខ្វិនផ្ទាត់ចូលទៅក្នុងមាត់បុរោ-ហិតអស់ហើយ ក៏ត្រាស់ថា លោកអាចារ្យ ទោះលោកលេបអាចម៍ពពែអស់ ១នាឡិ ក៏នៅតែមិនដឹង ព្រោះលោកជាអ្នកមាត់រឹង ឥឡូវនេះលោកមិនអាច ធ្វើអាចម៍ពពែឱ្យរលួយបានឡើយ។ បុរោហិតនោះ ចាប់ពីពេលនោះមក ជា អ្នកនិយាយចរចានឹងព្រះរាជាស្ទើរតែមិនកើត ព្រោះនឹកអៀនខ្មាសជាពន់ ពេក។ ព្រះរាជាទ្រង់ព្រះចិន្ដាថា អញដែលមិនថ្ងង់នឹងសំដីបុរោហិតនេះទៀត ក៏ដោយសារបុរសខ្វិននេះ ទើបទ្រង់ប្រទានស្រុក៤ ក្នុងទិសទាំង៤ដែលសុទ្ធ តែស្រុកដែលឡើងសួយរាប់សែន ជាប្រមាណដល់បុរសខ្វិននោះ។ លំដាប់ នោះ អមាត្យជាបណ្ឌិតម្នាក់ បានចូលទៅគាល់ព្រះរាជា ហើយសរសើរនូវ គុណនៃសិប្បៈថា បពិត្រព្រះសម្មតិទេព បណ្ឌិតក្នុងលោកតែងតែរៀនយក សិប្បៈ, សម្បត្តិនេះបុរសខ្វិន បានអាស្រ័យដោយសិប្បៈ ត្រឹមតែផ្ទាត់គ្រួស

ប៉ុណ្ណោះ, ការកំណត់អានិសង្សនៃសិប្បៈរបស់ជនទាំងឡាយ ដូចម្ដេច ទៅ? ទើបពោលគាថាថា:

សាធុខោ សិប្បកំ នាម អបិ យាទិសកីទិសំ បស្ស
អជប្បហារេន លទ្ធា គាមា ចតុទ្ទិសា ។

អំបាលយ៉ាងសិប្បៈផ្ដេសផ្ដាស គង់សម្រេចប្រយោជន៍បានដែរ, សូម ទ្រង់ក្រឡេកមើលស្រុកទាំង៤ ដែលបុរសខ្វិនបានដោយសិប្បៈ គឺការផ្ទាត់ អាចម៍ពពែប៉ុណ្ណេះ ។

---

# ១១~ រឿងធម្មបាលកុមារ

(ចាក ម. ទ.)

(ការស្លាប់មានពិត តែអ្នករក្សាធម៌តែងមានអាយុវែង)

ក្នុងបឋមពោធិកាល សម្តេចព្រះមានជោគ បានស្តេចទៅកាន់ក្រុងកបិលពស្តុ ជាលើកដំបូង ទ្រង់គង់ក្នុងនិគ្រោធារាម។ ពេលនោះព្រះបាទ សិរីសុទ្ធោទនមហារាជ ជាព្រះវររាជបិតា បានអង្គាសចង្ហាន់ ប្រគេនព្រះអង្គនឹងព្រះសង្ឃខីណាស្រព២ម៉ឺនអង្គជាបរិវារ ទើបមានបន្ទូលសំណេះសំណាលថា កាលដែលព្រះអង្គកំពុងព្យាយាមធ្វើទុក្ករកិរិយា ស្វែងរកអនុត្តរសម្មាសម្ពោធិញ្ញាណ មានទេវតាហោះមកឋិតនៅលើអាកាសនភាល័យស្រែកប្រាប់ថា ព្រះសិទ្ធត្ថកុមារជាព្រះរាជបុត្រព្រះអង្គ សោយព្រះទិវង្គតទៅហើយ ព្រោះទ្រង់មានអាហារតិច។ ព្រះសាស្តាមានព្រះបន្ទូលថា ចុះមហារាជជឿឬ? ខ្ញុំមិនជឿទេ, បានទាំងនិយាយឃាត់ទេវតាវិញថា កូនខ្ញុំបើមិនត្រាស់ មុខជាមិនស្លាប់។ ព្រះសាស្តាមានព្រះបន្ទូលថា ឥឡូវនេះព្រះអង្គជឿដូចម្តេចកើត បើពីដើមតថាគតនៅជាមហាធម្មបាលពោធិសត្វ អាចារ្យទិសាបាមោក្ខយកឆ្អឹងពពែមកបង្ហាញថា កូនអ្នកឯងស្លាប់ទៅហើយ នេះឆ្អឹង ក៏ព្រះអង្គមិនជឿ ហើយនិយាយតបទៅថា ត្រកូលយើងមិនដែលមាននរណាស្លាប់ពីក្មេងទេ។ ព្រះបាទសុទ្ធោទនក៏អារាធនា។ ព្រះសាស្តាស្តេចនាំអតីតនិទានមកសំដែងដូចតទៅនេះ ។

ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាម

ព្រហ្មទត្ត សោយរាជ្យសម្បត្តិនៅនគរពារាណសី ជាស្តេចប្រកបដោយទស-
ពិធរាជធម៌ នឹងមានសេចក្តីស្រឡាញ់ រាប់អានអាណាប្រជានុរាស្ត្រទូទៅ។
ក្នុងកសិករដ្ឋ មានស្រុកមួយឈ្មោះធម្មបាល(បានឈ្មោះដូច្នេះព្រោះអ្នកនៅ
ក្នុងស្រុកនោះទាំងប៉ុន្មានសុទ្ធតែរក្សាធម៌)។ ព្រាហ្មណ៍ដែលនៅក្នុងស្រុកនោះ
ក៏ឈ្មោះធម្មបាលដែរ ព្រោះសុទ្ធតែជាអ្នករក្សាធម៌ គឺកុសលកម្មបថ១០។
ដោយហោចទៅ ពួកកម្មករក្នុងត្រកូលព្រាហ្មណ៍នោះ ក៏សុទ្ធតែជាអ្នកឱ្យ
ទានរក្សានិច្ចសីលឧបោសថសីលដូចៗគ្នា។ គ្រានោះ ព្រះបរមពោធិសត្វ ទ្រង់
យោនយកកំណើតក្នុងត្រកូលព្រាហ្មណ៍ធម្មបាលមានឈ្មោះថាធម្មបាលកុមារ។
ពេលធម្មបាលកុមារចំរើនអាយុឡើងគាលណា ព្រាហ្មណ៍ជាបិតាបានឱ្យប្រាក់
១ពាន់កហាបណៈ ហើយបញ្ជូនឱ្យទៅរៀនសិល្បសាស្ត្រ ឯក្រុងតក្កសិលា
ក្នុងសំណាក់អាចារ្យទិសាបាមោក្ខ។ ធម្មបាលកុមារបានខំសិក្សារៀនវិជ្ជាផរាប
ទាល់តែលោកអាចារ្យពេញចិត្ត ហើយប្រគល់មាណពជាសិស្ស ទាំង៥០០រូប
ឱ្យធម្មបាលកុមារត្រួតត្រា។ គ្រានោះកូនច្បងរបស់អាចារ្យទិសាបាមោក្ខ ក៏
ធ្វើមរណកាលទៅ។ ឯអាចារ្យនឹងមាណពជាសិស្សទាំង៥០០ ទូញយំសោយ
សោកស្រណោះស្តាយកូនជាពន់ពេក។

លុះបន្ទោបង់សេចក្តីសោយសោកហើយ ក៏រៀបចាត់ចែងធ្វើសរីរកិច្ច
កូននោះតាមប្រពៃណីទាបាឆាមួយ។ អាចារ្យ. ពួកញាតិនឹងមាណពជាសិស្ស
ទាំងអស់គ្នា ក៏ទួញយំសោកក្នុងបាឆានោះថែមទៀត ប្លែកតែធម្មបាលមួយទេ

ដែលមិនសោយសោក មិនចូលកាន់មរណសញ្ញាជាមួយនឹងគេ។ កាលដែលពួកអ្នកចូលកាន់សេចក្ដីទុក្ខទាំងអស់ត្រឡប់មកផ្ទះវិញ អង្គុយក្នុងសំណាក់លោកអាចារ្យពោលរៀបរាប់ឲ្យញត្ដែរថា ឱហេតុអ្វីហ្ន៎ បានជាមាណពនេះនៅក្មេងក្រឡាំង ហើយស្លាប់ព្រាត់ប្រាស ចាកមាតាបិតាញាតិមិត្តយ៉ាងនេះ។ ធម្មបាលកុមារនិយាយតបថា ហៃសម្លាញ់ទាំងឡាយ អ្នកពោលថាមាណពនេះស្លាប់ពីក្មេង ចុះបើក្មេងទេម្ដេចក៏ស្លាប់? ការស្លាប់ពីក្មេងវាមិនដែលមាន។ ពួកមាណពនិយាយថា នែសម្លាញ់ អ្នកឯងមិនដឹងជាសត្វតែងតែវិនាសយ៉ាងនេះឬ? ខ្ញុំដឹងណាស់ទៅហើយ តែថាសត្វទាំងឡាយដែលស្លាប់ពីក្មេងមិនដែលមាន លុះណាតែចាស់ទើបស្លាប់។ មិនមែនដូច្នេះទេធម្មបាលសម្លាញ់ សង្ខារជាសភាពមិនទៀងទាត់ឋិតថេរទេ តែកើតឡើងហើយពិតជាវិនាសទៅវិញជាធម្មតា មិនថាចាស់ឬក្មេងឡើយ។ ធម្មបាលតបថា សំដីអ្នកនិយាយ នេះត្រូវណាស់ៗ តែមិនដែលមានសត្វណាស្លាប់ពីក្មេង លុះតែចាស់ទើបស្លាប់ ទើបសង្ខារមិនទៀង។ មាណពឮល់នឹងសំដីធម្មបាលណាស់ក៏សួរថា ធម្មបាលសម្លាញ់ ចុះផ្ទះអ្នកឯងគ្មានមនុស្សស្លាប់ទេឬ? មានស្លាប់ពិតតែមិនស្លាប់ពីក្មេងទេ លុះតែចាស់ទើបស្លាប់។ ត្រកូលអ្នកឯងសុទ្ធតែយ៉ាងហ្នឹងឬ? ត្រកូលខ្ញុំយ៉ាងហ្នឹងឯង។ ពួកមាណពឮពាក្យធម្មបាលពោលដូច្នោះ ក៏នាំគ្នាទៅជំរាបលោកអាចារ្យ។ ឯអាចារ្យបានហៅធម្មបាលមកសួរថា ម្នាលធម្មបាល ឮថាត្រកូលអ្នកឯងមនុស្សមិនដែលស្លាប់ពីក្មេងមែនឬ?

បពិត្រលោកអាចារ្យ ពិតមែន។ អាចារ្យឮពាក្យនោះហើយ ក៏គិតថា ធម្ម-
បាលនិយាយពាក្យប្លែកពេកណាស់ អញនឹងទៅកាន់សំណាក់បិតាធម្មបាល
នេះ ហើយសាកសួរមើល តើគេប្រព្រឹត្តធម៌បែបណា បានជាមិនស្លាប់ពីក្មេង
បើពិតដូចថាមែន អញនឹងប្រព្រឹត្តតាមធម៌នោះដែរ។ កន្លងមក៧ ឬ៨ថ្ងៃ
អាចារ្យក៏ហៅធម្មបាលមកប្រាប់ថា ម្នាលធម្មបាល យើងមិននៅទេ ចូរឯង
បង្រៀនសិល្បសាស្ត្រដល់ពួកមាណពជំនួសយើងផង ទំរាំយើងត្រឡប់មក
វិញ លុះពោលដូច្នោះហើយ ក៏យកឆ្អឹងពពែមកលាងស្អាតចាតច្រកទៅ
ក្នុងការុង ឱ្យបំរើម្នាក់លីតាម ដោយដើរចេញពីនគរតក្កសិលា យាត្រាម្នីម្នា
ទៅធម្មបាលគ្រាម ទើបសួររកផ្ទះធម្មបាលកុមារ ហើយឈរនៅទៀបទ្វារ
ផ្ទះ។ ពួកកម្មកររបស់ព្រាហណ៍បានឃើញលោកអាចារ្យ ក៏ស្ទុះទៅទទួលឆ័ត្រ
ស្បែកជើងពីដៃលោកអាចារ្យ យកការុងពីអ្នកបំរើ អាចារ្យទិសាបាមោក្ខ
ពោលថា ចូរអ្នកទាំងឡាយជំរាបព្រាហ្មណ៍ ជាបិតាធម្មបាលកុមារថា អាចារ្យ
របស់ធម្មបាល មកឈរនៅទៀបទ្វារឯណោះ។ ខ្ញុំក៏ដើរទៅជំរាបតាមពាក្យ
លោកអាចារ្យ ឯព្រាហ្មណ៍ក៏ម្នីម្នាស្ទុះទៅទទួលរាក់ទាក់បដិសណ្ឋារៈ អញ្ជើញ
ឡើងទៅលើផ្ទះ ឱ្យអង្គុយលើគ្រែ ហើយធ្វើកិច្ច មានការលាងជើងជាដើម
ឱ្យលោកអាចារ្យនោះ។ លុះអាចារ្យបរិភោគភោជនរួចហើយ ក៏ផ្ដើមនិយាយ
ប្រាប់ព្រាហ្មណ៍ថា ធម្មបាលបុត្រអ្នកមានប្រាជ្ញាវាងវៃណាស់ រៀនសូត្រចេះ
ចប់វេទទាំង៣ នឹងសិល្បសាស្ត្រទាំង១៨ តែស្លាប់ទៅហើយ, សង្ខារជា

សភាវមិនទៀងទេ អ្នកកុំសោយសោកធ្វើអ្វី។ ព្រាហ្មណ៍ឮពាក្យនោះក៏ទះដៃសើច។ អាចារ្យសួរថា អ្នកសើចរឿងអ្វី? កូនយើងមិនស្លាប់ទេ ក្រែងតែអ្នកដទៃទើបស្លាប់។ អាចារ្យទាញឆ្អឹងពីការុង ហើយនិយាយថា នេះឆ្អឹងកូនអ្នកឯង។ ទេឆ្អឹងនេះប្រហែលជាឆ្អឹងពពែ ឬឆ្អឹងឆ្កែ មិនមែនកូនខ្ញុំទេ ព្រោះត្រកូល យើងរហូតដល់៧សន្តាន មិនដែលមានអ្នកណាមួយស្លាប់ពីក្មេងទេ. លោកនិយាយកុហកហើយ។ អាចារ្យឃើញហេតុអស្ចារ្យដូច្នេះ មានចិត្តត្រេកអរណាស់ បានសាកសួរថា ម្នាលព្រាហ្មណ៍ ត្រកូលមិនដែលមានជនណាស្លាប់ពីក្មេងនោះ មិនមែនឥតហេតុឡើយ. ហេតុដែលមិនស្លាប់ពីក្មេងនោះតើយ៉ាងណា? ទើបអាចារ្យចងជាបទគាថាសួរថា:

" អ្នកសមាទានវត្តដូចម្តេច? ព្រហ្មចរិយាដូចម្តេច? នេះជាផលរបស់កម្មអ្វី ដែលអ្នកបានសន្សំមក? ម្នាលព្រាហ្មណ៍ ចូរអ្នកប្រាប់សេចក្តីនេះដល់យើង ហេតុអ្វីបានជាពួកអ្នកមិនស្លាប់ពីក្មេង?" ព្រាហ្មណ៍ឆ្លើយប្រាប់ថា:

យើងបានរក្សាកម្មបថ១០ ដោយម៉ត់ចត់ គឺយើងមិនប្រព្រឹត្តរំលោភចង់បានទ្រព្យអ្នកដទៃ ដោយចង់បានមកជារបស់ខ្លួន មិនប្រព្រឹត្តព្យាបាទចងគំនុំគុំគួននឹងអ្នកដទៃ មិនមានគំនិតយល់ខុសមានយោបល់ថា លោកនេះគ្មាន (នត្ថិ អយំ លោកោ) ជាដើម មិននិយាយពាក្យកុហក មិននិយាយពាក្យសើកសៀតបំបែកបំបាក់អ្នកដទៃ មិននិយាយពាក្យញុះញង់ មិននិយាយរោយរាយឥតប្រយោជន៍ មិនសម្លាប់សត្វ មិនលួចទ្រព្យសម្បត្តិអ្នកដទៃ មិនប្រព្រឹត្ត

កន្លងកូនប្រពន្ធអ្នកដទៃ ទាំងភរិយាយើងសោត ក៏មិនបានប្រព្រឹត្តក្បត់យើង ព្រោះហេតុដូច្នោះ បានជាយើងមិនស្លាប់ពីក្មេង បពិត្រលោកអាចារ្យ នេះជាវត្តដែលយើងបានប្រព្រឹត្តមកដោយល្អ។

*******

# ១២_ រឿងអសោកមហារាជ

(ចាក គ. ម.)

(ឥន្ទ្រីយ៍ស្រគត់ស្រគំ អាចធ្វើមនុស្សមិច្ឆាទិដ្ឋិឱ្យជ្រះថ្លាបាន)

ក្នុងរជ្ជកាលព្រះបាទពិន្ទុសារ ជាព្រះវរបិតាព្រះអសោកមហារាជ នានគរបាដលីបុត្ត ព្រះអង្គធ្លាប់រាប់អានពួកព្រាហ្មណ៍មិច្ឆាទិដ្ឋិ ហើយតែងនិមន្តមកឱ្យឆាន់ក្នុងដំណាក់ ៦ម៉ឺនរូបរាល់ពេល។ សូម្បីព្រះអសោកជាព្រះរាជឱរសរជ្ជទាយាទ បានទទួលគ្រងសម្បត្តិជំនួសព្រះបិតាកាលណា ក៏ទ្រង់នៅតែរាប់អានព្រាហ្មណ៍តាមទំនៀមព្រះវរបិតា ឱ្យអញ្ជើញមកឆាន់ក្នុងដំណាក់អស់៣ឆ្នាំដែរ។ ថ្ងៃមួយទ្រង់បានទតឃើញព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តអានាចារ បរិភោគអាហារភោជន មិនសង្រួមឱ្យសមរម្យ ព្រះអង្គកើតវិប្បដិសារស្តាយក្រោយ មិនជ្រះថ្លា ទើបទ្រង់ពិចារណាថា ឱហ្ន៎! ទានអញធ្វើនេះអស់ប្រាក់រាប់សែនកោដិ គួរអញជ្រើសរើសអ្នកទទួលឱ្យមានឫកពាចរិយាសមសួនទើបបានផលច្រើន។

ព្រះអង្គកំពុងតែធ្វើព្រះតម្រិះយ៉ាងនេះ ក៏ស្រាប់តែទតឃើញនិគ្រោធសាមណេរជាអរហន្ត មានព្រះជន្មត្រឹម៧ឆ្នាំ ដែលជាក្មួយរបស់ព្រះអង្គ កំពុងនិមន្តកាត់ព្រះរាជវាំង បម្រុងនឹងទៅសួរព្រះនាងសុមនទេវីជាព្រះមាតា ឯស្រុកចណ្ឌាលគ្រាម ក៏មានព្រះរាជហឫទ័យជ្រះថ្លានឹងឥន្ទ្រីយ៍ ស្រគត់ស្រគំរបស់សាមណេរ ទើបទ្រង់ត្រាស់ឱ្យរាជបុរសទៅនិមន្តមក ហើយទើបទ្រង់យាងចូលទៅប្រថាប់ក្បែរ បន្ទូលសួរថា លោកក្មួយដ៏ចំរើនខ្ញុំមានសេចក្តីជ្រះ

ថ្វានឹងឥន្រ្ទីយ៍របស់លោកណាស់ សូមនិមន្តលោកមកគង់ក្នុងព្រះរាជវាំងនេះ ត្រង់កន្លែងណាដែលលោកគាប់ព្រះទ័យ។ សាមណេរឮដូច្នោះ ក៏យកព្រះហស្ត តោងព្រះហស្តព្រះមហាក្សត្រ ហើយឡើងគង់លើរាជបល្ល័ង្កក្រោមមហាស្វេតឆត្រ។ ព្រះមហាក្សត្រទតឃើញដូច្នោះរឹងរិតតែមានសេចក្តីជ្រះថ្លាទៅទៀត ទ្រង់យកព្រះក្រយាស្ងោយ ដែលនាយវិសេសចាត់ចែងថ្វាយព្រះអង្គ ប្រគេនទៅសាមណេរឆាន់ទាំងអស់ លុះសាមណេរឆាន់ស្កប់ស្កល់ហើយ ទ្រង់និមន្តឱ្យសំដែងធម៌។ ឯសាមណេរ មានបំណងនឹងឱ្យមហាក្សត្រកើតសេចក្តីជ្រះថ្លាលើសលុប ក៏សំដែងគាថាជាពុទ្ធភាសិតថា:

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ អប្បមត្តា ន មិយន្តិ យេ បមត្តា យថា មតា ។

សេចក្តីមិនប្រមាទជាផ្លូវនៃអមតៈ សេចក្តីប្រមាទជាផ្លូវនៃមច្ចុ, អ្នកណាមិនប្រមាទ ឈ្មោះថាមិនស្លាប់, អ្នកណាប្រមាទ ទុកដូចជាស្លាប់។

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ព្រះធម្មទេសនានេះហើយ រឹងរិតតែមានសេចក្តីជ្រះថ្លាជាមហិមា ទើបមានព្រះរាជបញ្ជា ឱ្យប្រគេននិច្ចភត្ត៨ សម្រាប់ដល់និគ្រោធសាមណេររៀងរាល់ថ្ងៃ។ តពីនោះមក ទ្រង់មានសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធសាសនាខ្លាំងឡើងៗជាលំដាប់ដរាបដល់និមន្តព្រះសង្ឃ ៦ម៉ឺនមកឆាន់ក្នុងដំណាក់រាល់ថ្ងៃ ហាមឃាត់មិនឱ្យព្រាហ្មណ៍មកឆាន់ឡើយ។

*********

# ១៣~ រឿងព្រះអសោកនិងអគ្គមហេសី

(ចាក ត. ម.)

(អានិសង្សនៃការប្រគេនទឹកឃ្មុំ នឹងចង្អុលបង្ហាញផ្លូវ)

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានឈ្មួញទឹកឃ្មុំម្នាក់អង្គុយលក់នារានផ្សារ។ គ្រានោះមានព្រះបច្ចេកពុទ្ធមួយអង្គកើតរោគដំបៅ. មានព្រះបច្ចេកពុទ្ធមួយព្រះអង្គទៀត ជាអ្នកដើរស្វែងរកសុំទឹកឃ្មុំដើម្បីធ្វើថ្នាំប្រគេនព្រះបច្ចេកពុទ្ធនោះ ទើបចុះពីភ្នំគន្ធមាទន៍មកកាន់ក្រុងពារាណសី។ ពេលនោះមានកុម្ភទាសីម្នាក់ ដើរកាន់ក្អមសំដៅទៅស្ទឹង បានជួបនឹងព្រះបច្ចេកពុទ្ធអង្គនោះ ក៏ទូលសួរតាមដំណើរ លុះបានជ្រាបសេចក្ដីនោះសព្វគ្រប់ហើយ ក៏លាដៃលើកឡើងចង្អុលបង្ហាញរានផ្សារលក់ទឹកឃ្មុំនិយាយថា លោកម្ចាស់ អ្នកលក់ទឹកឃ្មុំគេលក់ឯណោះ សូមលោកម្ចាស់និមន្តទៅចុះ ទើបនាងគិតថា បើអ្នកលក់គេមិនប្រគេនដល់លោកម្ចាស់ទេ អញនឹងទៅក្នុងទីនោះនិយាយខ្ចីទឹកឃ្មុំគេប្រគេនលោកជាម្ចាស់ឱ្យបាន សឹមស្វែងរកប្រាក់សងគេជាក្រោយ ហើយទៅឈរចាំក្នុងទីនោះ។ នាយឈ្មួញបានឃើញ ព្រះបច្ចេកពុទ្ធនិមន្តមកហើយ ក៏មានសេចក្ដីត្រេកអរជាខ្លាំង បានប្រគេនទឹកឃ្មុំលុះត្រាតែពេញបាត្រនឹងហូរហៀរកំពប់ពីមាត់បាត្រធ្លាក់មកផែនដី តាំងសេចក្ដីប្រាថ្នាថាបពិត្រលោកម្ចាស់ ដោយអំណាចនៃបុញ្ញកម្មនេះ ខ្ញុំសូមឱ្យបានជាស្ដេចឯករាជ្យក្នុងជម្ពូទ្វីប ម្យ៉ាងទៀត សូមឱ្យមានអំណាចផ្សាយនៅលើអាកាស១យោជន៍ ចុះទៅក្នុងផែនដី ១យោជន៍ដូចគ្នា។ ព្រះបច្ចេកពុទ្ធ ពោលថា ម្នាល

ឧបាសក សេចក្ដីប្រាថ្នារបស់អ្នកចូរសម្រេចយ៉ាងនេះចុះ ទើបនិមន្តផ្ទោះទៅភ្នំគន្ធមាទន៍វិញ។ ថ្ងៃពីនាងកុម្ភទាសី បានឃើញព្រះបច្ចេកពុទ្ធនិមន្តត្រឡប់មកវិញក៏ទូលសួរថា លោកម្ចាស់បានទឹកឃ្មុំឬទេ? អើនាងអាត្មាបានហើយ នាយឈ្មួញនោះគេប្រគេន នឹងតាំងសេចក្ដីប្រាថ្នា ជាស្ដេចឯករាជ្យក្នុងជម្ពូទ្វីប។ នាងកុម្ភទាសីឮពាក្យនោះហើយ ក៏តាំងសេចក្ដីប្រាថ្នាជាអគ្គមហេសីនៃស្ដេចអង្គនោះ។ ការអន្ទោលវិលវល់ក្នុងវដ្ដសង្សាររបស់ជនទាំងពីរនោះជាច្រើនជាតិ ទើបនាយឈ្មួញ បានមកចាប់កំណើតក្នុងផ្ទៃ ព្រះនាងធម្មាទេវីជាអគ្គមហេសីព្រះបាទពិន្ទុសារៈ ព្រះចៅបាតលីបុត្រ ពេលអំណើះពីព្រះវររាជបិតាទៅ ក៏បានទទួលរាជ្យសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រស្នងអង្គព្រះវរបិតា។ ព្រះបាទអសោកអង្គនេះ ទ្រង់មានព្រះទ័យឃោរឃៅកាចផាមហិមា បើទ្រង់មិនគាប់ព្រះទ័យនឹងអ្នកណា ក៏ឱ្យគេសម្លាប់ចោលមួយរំពេច សូម្បីពួកព្រះអង្គម្ចាស់៩៩អង្គ ដែលជាប្អូនបង្កើត គ្រាន់តែមានព្រះមាតាផ្សេងៗគ្នាប៉ុណ្ណោះ ក៏ទ្រង់សម្លាប់ចោលអស់ ទុកតែតិស្សកុមារមួយអង្គ ដែលរួមព្រះឱទរ ព្រះវរមាតាជាមួយទ្រង់។ ព្រះអង្គគ្រប់គ្រងរាជសម្បត្តិ ដោយពុំទាន់បានអភិសេកអស់៤ឆ្នាំ ទើបបានរាជាភិសេកជាស្ដេច ឯករាជ្យក្នុងជម្ពូទ្វីបនាសតវត្សទី៣(២១៨)នៃពុទ្ធសករាជ។ ឫទ្ធិអំណាចទាំងឡាយ ក៏កើតមានដល់ព្រះអង្គក្នុងពេលអភិសេកនោះគឺអំណាចជ្រែកចុះទៅក្នុងផែនដី១យោជន៍ លើអាកាស១យោជន៍ ពួកទេវតាតែងនាំយកទឹក១៦ក្អមពីស្រះអនោតត្តនាំយក

ឈើស្ទន់ជាវិការៈនៃវល្លិ៍ម្លូព្រៃដែលទន់ភ្ជន់មានរសល្អ, ផ្លែសម៉ ផ្លែកន្ទួតព្រៃជាថ្នាំនឹងផ្លែស្វាយទុំមានសម្បុលដូចមាស(ស្វាយទិព្វ) បរិបូរដោយក្លិននឹងរស អំពីព្រៃហេមពាន្ត មកថ្វាយរាល់ៗថ្ងៃ។ មានទេវតាមួយក្រុមទៀត នាំសំពត់សម្រាប់ស្លៀក-ដណ្តប់មានពណ៌៥, សំពត់ពណ៌លឿង, សំពត់សម្រាប់ជូតដៃនឹងទឹកទិព្វអំពីវិមានទេវតា ដែលតាំងនៅទៀបឆទ្ទន្តស្រះមកថ្វាយរាល់ៗថ្ងៃ។ ពួកនាគរាជនាំយកគ្រឿងក្រអូបសម្រាប់ងូត-លាប នឹងសម្ពត់ផ្កាម្លិះ ដែលគេមិនត្បាញដោយសូត្រឬអម្បោះ ដើម្បីជាសំពត់ដណ្តប់ ព្រមទាំងថ្នាំសម្រាប់លាបភ្នែកមានថ្លៃច្រើនពីពិភពនាគមកថ្វាយរាល់ៗថ្ងៃ។ ពួកសត្វសេកនាំយកស្រូវសាលីកើតឯងក្នុងឆទ្ទន្តស្រះចំនួន៩ពាន់រទេះ មកថ្វាយរាល់ៗថ្ងៃ។ ពួកកណ្តុរនាំគ្នាមកបកស្រូវសាលីទាំងនោះ ធ្វើជាអង្ករមិនឱ្យមាន អង្កាមនឹងកន្ទុកសោះ ទាំងមិនឱ្យបាក់សូម្បី១គ្រាប់ឡើយ។ ពួកឃ្មុំនាំគ្នាមកធ្វើទឹកឃ្មុំក្នុងទីដីតបង្កើយ។ ពួកសត្វករវិកនាំគ្នាមកច្រៀងបង្ហូចយំលាន់ឮទ្រហឹង វិស័យដូចត្បូងគន្ធ្រ្វទិព្វ ថ្វាយព្រះរាជាតាមប្រក្រតី។

អសោកមហារាជប្រកបដោយឫទ្ធិទាំងនេះ ដោយបុញ្ញកម្មដែលខ្លួនកើតជានាយឈ្នួញលក់ទឹកឃ្មុំ ហើយបានប្រគេនទឹកឃ្មុំដល់ព្រះបច្ចេកពុទ្ធនោះឯង។ ឯនាងកុម្ភទាសី ក៏បានមកជាអគ្គមហេសីនៃព្រះមហាក្សត្រអង្គនោះទ្រង់ព្រះនាមថា **អសន្ធិមិត្តា** បានជាព្រះនាមដូច្នេះ ព្រោះសន្លាក់ដៃជើងស្ទើរលើងស្អាតរៀវលែងតែព្រះនាងបត់ចូល ទើបមើលទៅឃើញថាមានសន្លាក់

កើតដោយអនិសង្សនៃការខ្វល់ខ្វាយ ចង្អុលបង្ហាញផ្លូវទៅរកផ្សារលក់ទឹកឃ្មុំ ដល់ព្រះបច្ចេកពុទ្ធអង្គនោះដែរ។

*********

# ១៤. រឿងពាណិជលង់ទឹកសមុទ្រ

(ចាក អ. ទេ.)

(សីលជាស្ពានរបស់សត្វ)

សេចក្ដីថាៈ មានឈ្មួញជាច្រើននាក់ នាំគ្នាទៅជួយដោយសំពៅនៅក្នុងសមុទ្រ បានបើកសំពៅយ៉ាងលឿនរហ័ស ប្រៀបដូចជាគេបាញ់កូនសរ បាន៧ថ្ងៃក៏កើតឧបទ្រព ដោយខ្យល់ព្យុះព្យោមកបក់បោកជាខ្លាំង រលកធំៗក៏បោកផ្ទប់លើសំពៅនោះ បណ្ដាលឱ្យទឹកចូលពេញ។ កាលសំពៅហៀបនឹងលិច មហាជនបាននាំគ្នានឹករលឹកដល់ទេវតារៀងៗខ្លួនមានធ្វើកិច្ចបន់ស្រន់ជាដើម ដើម្បីឱ្យទេវតាជួយអាយុជីវិត ហើយនាំគ្នាយំពេញតែសំពៅ។ ប្លែកតែបុរសម្នាក់ បាននឹករលឹកពិចារណាខុសគេថា អាត្មាអញមានអ្វីជាទីពឹងនៅគ្រាមានអាសន្នដូច្នេះ ក៏នឹកឃើញដល់សរណគមន៍នឹងសីលដ៏បរិសុទ្ធរបស់ខ្លួន ទើបអង្គុយពែនភ្នែន ក្នុងចំណោមមហាជនទាំងនោះ ប្រៀបដូចព្រះយោគីអង្គុយចំរើនកម្មដ្ឋាន។ មហាជនសួរបុរសនោះថា ហេតុអ្វីបានជាអ្នកមិនខ្លាចសេចក្ដីស្លាប់? ម្នាលអ្នកទាំងឡាយ ថ្ងៃដែលយើងឡើងជិះសំពៅមក យើងបានឱ្យទានដល់ភិក្ខុសង្ឃ បានសមាទានសរណគមន៍ នឹងសីលរួចជាស្រេច ព្រោះហេតុនោះបានជាយើងមិនខ្លាច។ មហាជនសួរថា អ្នកជាម្ចាស់ អ្នកអាចឱ្យដល់អ្នកដទៃបានឬទេ?បាន។ បើដូច្នោះ សូមអ្នកឱ្យដល់យើងរាល់គ្នាផង។ បុរសនោះ ក៏រំលែកមហាជនជា៧ចំណែក, មួយចំណែកមាន១០០រូប ទើបឱ្យនិច្ចសីលដល់មហាជនទាំងអស់គ្នា។ បណ្ដាជនទាំង៧ក្រុមនោះ ក្រុម

ទី១ សមាទានសីលក្នុងវេលាទឹកត្រឹមកជើង, ក្រុមទី២ ក្នុងវេលាទឹកត្រឹមជង្គង់ ក្រុមទី៣ ទឹកត្រឹមចង្កេះ, ក្រុមទី៤ ទឹកត្រឹមផ្ចិត, ក្រុមទី៥ ទឹកត្រឹមដោះ, ក្រុមទី៦ ត្រឹមក, ក្រុមទី៧ សមាទានសីលក្នុងវេលាទឹកប្រៃចូលមាត់។ លុះឱ្យសីលដល់មនុស្សទាំងអស់រួចហើយ បុរសនោះស្រែកប្រកាសថា អ្នករាល់គ្នាគ្មានអ្វីទីពឹងក្រៅពីសីលរបស់ខ្លួនទេ ចូរពិចារណាសីលតែម្យ៉ាងបានហើយ។ ពួកជនទាំង៧០០ ក៏ធ្វើមរណកាលកណ្ដាលសមុទ្រនោះ បានទៅកើត នាឋានត្រៃត្រឹង្សទេវលោកទាំងអស់គ្នា ព្រោះអាស្រ័យសីល ដែលខ្លួនបានសមាទានក្នុងពេលជិតស្លាប់។ វិមានទាំងឡាយក៏កើតដល់ទេវបុត្រទាំងនោះជាពួកជាបន។ វិមានមាសកំពស់១០០យោជន៍ កើតឡើងដល់ទេវបុត្រជាអាចារ្យ បំកណ្ដាលវិមានទាំងអស់។ វិមានយ៉ាងទាបបំផុត ត្រឹម១២យោជន៍។ ទេវបុត្រទាំងនោះ ពិចារណាមើលបុញ្ញកម្មក្នុងខណៈដែលខ្លួនទៅកើតរួចហើយ ក៏ដឹងច្បាស់ថា សម្បត្តិដែលខ្លួនបាននេះ ព្រោះអាស្រ័យទេវបុត្រជាអាចារ្យ ទើបនាំគ្នាហោះមកសរសើរគុណអាចារ្យ ក្នុងសំណាក់ព្រះសាស្ដាដោយបការៈផ្សេងៗពីគ្នា។

********

# ១៥~ រឿងបិប្ផលិមាណព

(ចាក អ. ក.)

(ឧបនិស្ស័យផាស់ផៀនហើយ ចំណងឃរពន្ធន៍គង់រឿតឯង)

ក្នុងក្រុងរាជគ្រឹះ មានមាណពម្នាក់ឈ្មោះបិប្ផលិ អាយុ២០ឆ្នាំ មានបុណ្យវាសនាជាអស្ចារ្យ ជាបុត្រកបិលព្រាហ្មណ៍។ ថ្ងៃមួយមាតាបិតា គិតរកភរិយាឱ្យ ទើបបញ្ជូនព្រាហ្មណ៍៨នាក់ ឱ្យដើរស្វែងរកស្ត្រីដែលបរិបូណ៌ដោយលក្ខណៈ។ ព្រាហ្មណ៍ទាំង៨នាក់ បានយកគ្រឿងបណ្ណាការ ដើរសំដៅទៅនគរសាគល។ ក្នុងនគរនោះ មានធីតាម្នាក់ឈ្មោះនាងភទ្ទាកាបិលានី មានអាយុ១៦ឆ្នាំ ជាស្ត្រីមានរូបឆោមលោមពណ៌ល្អឆើត នឹងមានបុណ្យវាសនាច្រើន ជាបុត្រីកោសិយគោត្តព្រាហ្មណ៍។ ថ្ងៃងពីព្រាហ្មណ៍ទាំង៨នាក់ កាលនាំគ្នាទៅស្វែងរកនាងក្រមុំដែលមានលក្ខណៈបរិបូណ៌ បានទៅដល់ត្រកូលព្រាហ្មណ៍នោះ ទើបសារសព្វរឿងរ៉ាវពីការចង់ចងស្ពានមេត្រីផ្លូវកាយរវាងបិប្ផលិមាណពនឹងនាងភទ្ទា ឱ្យមាតាបិតានាងស្តាប់ ឯមាតាបិតានាង ក៏បានលើកនាងឱ្យបិប្ផលិតាមពាក្យស្តីដណ្តឹងរបស់ចៅមហាទាំង៨នាក់ ទើបហៅចៅមហាលើកគ្រឿងបណ្ណាការជូនជាស្រេច ហើយនាំដំណឹងនោះទៅជំរាបកបិលព្រាហ្មណ៍ថា ធីតាបរិបូណ៌ដោយលក្ខណៈ ខ្ញុំដើរស្វែងរកបានហើយនៅឯនគរសាគល ជាធីតាកោសិយគោត្តព្រាហ្មណ៍។ ឯបិប្ផលិស្តាប់ឮពាក្យនោះហើយ ជាអ្នកឥតត្រូវការសោះឡើយរឿងប្រពន្ធ ទើបសរសេរសំបុត្រមួយជាលាយលក្ខណ៍អក្សរ ផ្ញើទៅប្រាប់នាងភទ្ទាថា នាងភទ្ទា ចូរនាងរក

បុរសណាដែលមានជាតិគោត្រត្រកូលនឹងសម្បត្តិ ឱ្យសមរម្យតាមអធ្យាស្រ័យ នាងធ្វើជាស្វាមីចុះ ចំណែកខ្ញុំសុំលានាងទៅបួសហើយ នាងកុំក្តៅក្រហាយស្តាយក្រោយឡើយ។ នាងភទ្ទាក៏សរសេរសំបុត្រ១ច្បាប់ ផ្ញើទៅបិបុលិមាណពដែរ សេចក្តីសំបុត្រក៏ដូចគ្នា ពេលសរសេរក៏ត្រូវគ្នា។ ថ្ងៃងពីអ្នកនាំសារពីរនាក់ ដែលទទួលបង្គាប់យកសំបុត្រទៅឱ្យម្ចាស់រៀងៗខ្លួន បានជួបគ្នាពាក់កណ្តាលផ្លូវ ក៏សាកសួរដំណើរដើមទងសព្វគ្រប់ ទើបស្រុះចិត្តគ្នាហែកសំបុត្រទាំងពីរមើលដឹងសេចក្តីអស់ ក៏ហែកសំបុត្រនោះចោល ហើយសរសេរសារជាថ្មី មានរៀបរាប់ពីសេចក្តីស្នេហា រួមរសមេត្រីភាពរវាងអ្នកទាំងពីរ ទើបនាំយកសំបុត្រក្លែងក្លាយនោះទៅឱ្យ។ ពេលរៀបមង្គលការហើយ ជនទាំងពីរបរិភោគបាយល្ងាចរួចកាលណា ក៏ចូលកាន់ដំណេក តាមប្រពៃណីនិយម តែមិនបានរួមមត្តសំវាសដូចជនឯទៀតឡើយ គឺមាណពចូលដេកខាងស្តាំ នាងភទ្ទាដេកខាងឆ្វេង។ ជនទាំងពីរខ្លាចប៉ះសម្ផស្សកាយគ្នាណាស់ ក៏យកកម្រងផ្កាពីរមក ដាក់ពាក់កណ្តាលដំណេក, ទោះខំផ្ទេចផ្អែកយ៉ាងណា ក៏ឥតមានលក់សោះឡើយ អស់ពេលពេញ១យប់, ពេលថ្ងៃទៀតសោត ក៏មិនដែលញញឹមរកគ្នាដែរ។ ជនទាំងពីរនាក់នេះ ជាអ្នកនៅគ្រប់គ្រងផ្ទះ មិនបានច្រឡូកច្រឡំ ដោយលោកាមិសឡើយ ជាអ្នកមានគំនិតស្របគ្នា, ពេលអំណើះពីមាតាបិតាទៅ ក៏និយាយគ្នាថា ភពទាំង៣នេះ ប្រាកដដោយផ្ទះដែលភ្លើងឆេះរន្ទាលប្រាលឆ្អៅ ដូច្នេះគួរយើងទៅបួសកុំខាន ទើបនាំគ្នាចិញ

សំពត់កាសាយៈនឹងបាត្រដីពីផ្សារមក ហើយកាត់កោរសក់ ពុកមាត់ តាំងសេចក្ដីអធិដ្ឋានថា បើលោកណាជាព្រះអរហន្តវិសេសក្នុងលោក ផ្នួសយើងសំដៅលោកនោះឯង ហើយបួសជាស្រេចក្នុងពេលដែលអធិដ្ឋាន ហើយច្រកបាត្រក្នុងស្បោកស្ពាយលើស្មាយាត្រា ចាកប្រាសាទដោយគ្មានសេចក្ដីអាល័យឡើយ។ បិប្ផលិមាណពដើរមុខបានឃើញផ្លូវបែកជាពីរ ក៏និយាយទៅកាន់នាងភទ្ទាថាប្អូន! មហាជនដែលមានចិត្តប្រទូស្តនឹងយើង បើឃើញយើងបួសហើយនៅដើរជាមួយគ្នាយ៉ាងនេះ មុខជាតិះដៀលថា មើហ្ន គាត់នេះបួសហើយ នៅយកគ្នាជាប្តីប្រពន្ធដដែល មុខជាបួសបំពេញអបាយភូមិដោយពិត បើដូច្នោះ នាងដើរទៅផ្លូវមួយ ខ្ញុំដើរទៅតាមផ្លូវមួយ។ នាងភទ្ទាពោលថា ពិតដូច្នោះមែន មាតុគ្រាមជាមន្ទិលដល់នេក្ខម្មៈ ថាដូច្នោះហើយក៏ដើរប្រទក្សិណបិប្ផលិក៣ជុំ ថ្វាយបង្គំប្រកបដោយអង្គ៥ ហើយលើកករប្រណម្យពោលថា អ្នកបង! មិត្តសន្ថវៈ ដែលយើងសន្សំ មកអស់កាលប្រមាណ១សែនកប្បហើយ ឥឡូវត្រូវបែកគ្នាពេលនេះ អ្នកបងជាមនុស្សខាងស្តាំ គួរដើរផ្លូវខាងស្តាំ ចំណែកខ្ញុំជាមាតុគ្រាមប្រកបដោយជាតិខាងឆ្វេង ត្រូវដើរតាមផ្លូវឆ្វេង លុះពោលយ៉ាងនេះហើយ ក៏សំពះបិប្ផលិមាណព ដើរចេញទៅតាមផ្លូវឆ្វេងទៅ។ កាលជនទាំងពីរនាក់ ដើរបែកផ្លូវគ្នាយ៉ាងនេះ មហាប្រឹថពីមានកម្រាស់ដ៏ក្រាស់ ក៏កក្រើករំពើកញ្ឆាប់ញ័រជាអស្ចារ្យ ហាក់ដូចជានិយាយ យើងមិនអាចទ្រទ្រង់គុណរបស់អ្នកបានទេ, ទាំងអាកាសវេ-

ហាស់ទៀតសោត ក៏លាន់ឮរំពងទ្រហឹងអឹងអាប់ដោយស្នូរ រន្ទះបាញ់ផាំងផា, កណ្តាប់ភ្នំចក្រវាឡ ក៏លាន់កក្រើកបញ្ចេញសំឡេងស្ញើចសរសើរជាមហិមា។ ពេលនោះឯងព្រះបរមសម្ពុទ្ធ ទ្រង់ប្រថាប់ក្នុងគន្ធកុដីនាវត្តវេឡុវ័ន ទ្រង់ព្រះសណ្តាប់ស្នូរគគ្រឹកគគ្រេងនៃអាកាសនភាល័យ ផែនដី ភ្នំចក្រវាឡផ្លូឡោះ ទ្រង់រំពឹងមើលសព្វគ្រប់ ស្តេចក៏ជ្រាបរឿងរ៉ាវហើយ ទ្រង់ប្រដាប់បាត្រនឹងចីវរចេញទៅទទួលអស់ផ្លូវចម្ងាយ៣គាវុត តែ១ព្រះអង្គឯង ស្តេចប្រថាប់ក្រោមម្លប់ជ្រៃមានកូនច្រើន ជាចន្លោះក្រុងរាជគ្រឹះ នឹងនាឡន្ទគ្រាម។ ឯបិប្ផលិឃើញព្រះសាស្តាក៏ចូលទៅថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះអង្គស្តេចប្រទានព្រះឱវាទ៣យ៉ាង[១] ដល់បិប្ផលិនាម្លប់ជ្រៃនោះ។ លុះចប់ ព្រះឱវាទហើយ បិប្ផលិក៏សុំបព្វជ្ជាឧបសម្បទា ជាភិក្ខុភាវៈក្នុងសាសនមណ្ឌល នៅជាបុថុជ្ជន៧ថ្ងៃ ក៏បានសម្រេចព្រះអរហត្ត ក្នុងថ្ងៃទី៨ដោយអំណាច នៃការទទួលយកពុទ្ធោវាទនោះឯង។ ឯនាងភទ្ទាក៏ទៅកាន់សំណាក់ភិក្ខុនីសង្ឃ សូមឧបសម្បទាជាភិក្ខុនី បានសម្រេចអរហត្ត ក្នុងកាលជាខាងក្រោយ។

*********

១.ឱវាទ ៣យ៉ាង មានក្នុងនិទានវគ្គ កស្សបសំយុត្ត គម្ពីរសំយុត្តនិកាយ ។

# ១៦. រឿងស្ដេចចចកឈ្មោះសព្វទាឋៈ

(ចាក អ. ស.)

(ចចកអើយចចក បង្កើងមានៈ វិនាសព្រាណឯង)

ក្នុងកាលដែលកន្លងទៅហើយ មានបុរោហិតព្រះចៅពារាណសីម្នាក់ ជាអ្នកចេះបឋវីជយមន្ត(មន្តបង្វិលផែនដីឱ្យវិល) ។ ថ្ងៃមួយបុរោហិត ចូលទៅកាន់អរញ្ញប្រទេស អង្គុយលើខ្នងថ្មដោយបំណងថា នឹងស្វាធ្យាយមន្តវិជ្ជាការខ្លួន លុះអង្គុយសិប់សូនលើខ្នងថ្មរួចស្រួលបួលហើយ ក៏តាំងរាយមន្តនោះឯង។ ក្នុងពេលដែលបុរោហិតស្វាធ្យាយមន្ត មានចចក១ដេកនៅក្នុងរន្ធខាងក្រោមផ្ទាំងសិលានោះ បានស្ដាប់ដោយយកចិត្តទុកដាក់ ហើយធ្វើឱ្យចាំស្ទាត់។ ចចកនេះ កាលពីដើមធ្លាប់កើតជាព្រាហ្មណ៍ អ្នកចេះស្ទាត់ជំនាញនូវមន្តឈ្មោះបឋវីជយៈនោះ។ ចចកបានចងចាំមន្តនេះស្ទាត់ហើយ ក៏ចោលចូលទៅក្នុងព្រៃភ្នាម ហើយតាំងរាយមន្តប្រមូលសត្វចតុប្បាទទាំងឡាយ មានដំរី សេះ សីហ ខ្លាធំ ជ្រូកជាដើម ឱ្យមកចុះចូលក្នុងអំណាចខ្លួន ហើយតាំងខ្លួនឯងជាស្ដេចនាមសព្វទាឋៈ នឹងអភិសេកចចកញីមួយជាអគ្គមហេសី។ ជាធម្មតាស្ដេចចចកនឹងអគ្គមហេសីតែងតែអង្គុយទន្ទឹមគ្នាលើខ្នងនៃសីហៈ ដែលជ្រែងលើខ្នងដំរីមួយគូរ។ ស្ដេចចចកមានយសដ៏ខ្ពង់ខ្ពស់ច្រើនមហិមាយ៉ាងនេះ ក៏កើតចិត្តមានៈលោភលន់ចង់បានសម្បត្តិ របស់ព្រះចៅពារាណសីថែមទៀត ហើយប្រមូលកងទ័ពរេហ៍ពលចូលទៅឡោមក្រុងពារាណសី មានចំនួនពល១២យោជន៍។ ទើបបញ្ជូនសារលិខិតមួយច្បាប់ទៅថ្វាយ មានសេច

ក្ដីថា "ព្រះចៅពារាណសីទ្រង់ឱ្យរាជឬ ឱ្យចំបាំងដល់យើង" អ្នកនគរក៏តក់ស្លុតភិតភ័យជាមហិមា ទើបបង្គាប់គ្នីគ្នាឱ្យបិទទ្វារក្រុង។ ក្នុងនគរនោះមានបុរោហិតម្នាក់ ជាអ្នកមានប្រាជ្ញាវាងវៃជាពន់ពេក បានលួងលោមព្រះរាជានឹងអ្នកនគរកុំឱ្យភ័យ ខ្លួនទទួលភារៈចេញច្បាំងជូស ហើយឡើងទៅលើប៉មក្បែរទ្វារស្រែកសួរថា ហៃសព្វទាឋៈសម្លាញ់អ្នកធ្វើឧបាយយ៉ាងណា ដែលមកប្រាថ្នារាជ្យនេះ. ស្ដេចចចកប្រាប់ថា យើងឱ្យសីហៈបន្លឺឡើងនូវសំរែកដ៏ខ្លាំងធ្វើឱ្យមនុស្សក្សិណក្ស័យជីវិត ទើបយករាជ្យនេះ។ លុះយកការណ៍បានហើយ បុរោហិតក៏ចុះពីប៉មមកបង្គាប់ឱ្យទូងស្គរកេរ៍ពាសពេញនគរដោយពាក្យថា មនុស្សទាំងឡាយ ចូរបិទត្រចៀកដោយម្សៅស្រណ្ដករាជមាសកុំខាន។

មនុស្សទាំងឡាយក៏ធ្វើតាមបង្គាប់គ្រប់ៗគ្នា ដោយហោចទៅ សូម្បីតែសត្វឆ្មា ក៏មនុស្សយកម្សៅស្រណ្ដករាជមាសចុកត្រចៀកឱ្យដែរ។ លុះអ្នកនគររៀបប្រដាប់ការពារខ្លួនប្រាណហើយស្រេច បុរោហិតក៏ទៅឡើងលើប៉មពោលប្រាប់ស្ដេចចចកថា នែសព្វទាឋៈ អ្នកមិនអាចនឹងញ៉ាំងសីហៈឱ្យបន្លឺសីហនាទបានឡើយ កេសររាជសីហ៍ទាំងឡាយដែលបរិបូណ៌ដោយជាតិមានដៃជើងក្រហមឆ្អៅ មិនដែលធ្វើតាមអំណា ចចចកកញ្ជាស់ប្រាកដដូចអ្នកឯងទេ. បើអ្នកអាចឱ្យសីហៈបន្លឺសំរែកបាន ចូរឱ្យបន្លឺទៅចុះ ព្រោះល្មមពេលវេលាហើយ។ ស្ដេចសព្វទាឋៈ ជាសត្វមានមានៈរឹងត្អឹង ក៏ពោលប្រាប់បុរោហិតថា អញអង្គុយលើខ្នងសីហៈណា អាចឱ្យសីហៈនោះបន្លឺសំរែក

បាន ឯសីហៈដទៃចាំបាច់យកមកនិយាយធ្វើអ្វី ពោលរួចហើយ ក៏គោះជើងឱ្យសញ្ញាដល់សីហៈ៧ក៏ខ្ទប់មាត់នៅលើក្ងបដំរី ហើយស្រែកកំទរអស់វារៈ៣ដង។ ដំរីឮសូរសម្រែកនោះ មានសេចក្ដីតក់ស្លុតជាមហិមា ក៏ជាន់ក្បាលស្ដេចសព្វ-ទាឋៈដែលធ្លាក់ពីខ្នងសីហៈមកដីខ្ទេចខ្ទីឱ្យក្សិណក្ស័យក្នុងពេលនោះទៅ។ ឯដំរីដែលយកខ្នងទ្រសីហៈ, ដោយសម្រែកលាន់ឮខ្លាំងពេក, ក៏ឡប់សញ្ញាវង្វេងវង្វាន់ភាន់ភាំងផល់តែឡាឯងស្លាប់ពេលនោះដែរ។ សត្វចតុប្បាទទាំងអស់លើកតែសីហៈចេញ ស្លាប់ទាំងអស់ដោយសម្រែកសត្វសីហៈនោះឯង។ ឯសីហៈទាំងឡាយឃើញម្ចាស់នឹងពួកពលស្លាប់អស់ដូច្នោះ ក៏ចោលទៅនៅក្នុងព្រៃវិញ។ គំនរសត្វស្លាប់ មានចំងាយ១២យោជន៍។ បុរោហិតបានបង្គាប់បុរសឱ្យយកនូវស្គរភេរីប្រកាសប្រាប់អ្នកក្រុង ឱ្យមកយកសាច់ទៅស៊ីខ្លះ ធ្វើងៀតទុកខ្លះ។ ពាក្យថាសាច់ងៀត មានពីត្រឹមនោះមក។

********

## ១៧_ រឿងចក្ខុនឧបាសក

(ចាក អ. សម្មា.)

(ឱជារសនៃសច្ចធម៌ ចាត់ជាឱសថទិព្វក្នុងលោក)

នៅសីហឡទ្វីប មានឧបាសកម្នាក់ឈ្មោះចក្ខុនៈ ឧបាសកនោះកាលនៅពីក្មេង ម្តាយកើតរោគក្នុងសរីរៈ ហើយយកពេទ្យមកមើលរោគនោះ។ ពេទ្យប្រាប់ថា បើបានសាច់ទន្សាយស្រស់យកមកធ្វើថ្នាំ ទើបរម្ងាប់រោគនេះបាន។ ឮពាក្យពេទ្យដូច្នោះ បងក៏បង្គាប់ចក្ខុនៈជាប្អូនថា ចូរឯងទៅឯស្រែនុះ ស្វែងរកសាច់ទន្សាយស្រស់យកមកធ្វើថ្នាំ។ គ្រានោះចក្ខុនៈក៏ទៅតាមបង្គាប់បង បានឃើញទន្សាយមួយកំពុងស៊ីសន្ទូងដែលណាស់ខ្ចីខៀវនៅវាលស្រែ។ ឯទន្សាយឃើញចក្ខុនៈភ័យណាស់ ក៏ស្ទុះបោលទៅ ទាក់ជើងនឹងវល្លិ៍ស្មៅក៏ឮសូរ កិរិកិរិ។ ចក្ខុនឧបាសក ឮសូរសម្លេងស្រែកនោះ ក៏ចូលទៅចាប់ បំណងនឹងសម្លាប់យកសាច់ធ្វើឱសថ ឱ្យម្តាយដែលកំពុងឈឺ ស្រាប់តែមានគំនិតមួយផុសឡើងថា អញមិនគួរផ្តាច់បង់ជីវិតសត្វដទៃ ព្រោះជីវិតម្តាយអញឡើយ លុះគិតដូច្នេះហើយ ក៏លែងទន្សាយនោះ ដោយពាក្យពោលប្រកបដោយសេចក្តីអាណិតអាសូរថា ទន្សាយ អ្នកទៅចុះ ចូរទំពារស៊ីស្មៅនឹងទឹកជាមួយទន្សាយទាំងឡាយក្នុងព្រហារណ្យ តាមសេចក្តីគាប់ចិត្តអ្នកចុះ យើងឥតសម្លាប់អ្នកទេ អ្នកកុំភ័យឱ្យសោះ។ ទន្សាយក៏បោលចូលទៅក្នុងព្រៃទៅ។ លុះចក្ខុនៈត្រឡប់ទៅផ្ទះវិញ បងក៏សួរថាឯណាទន្សាយ? គាត់ប្រាប់តាមរឿងរ៉ាវសព្វគ្រប់ បងស្តីបន្ទោសជាច្រើន ទើបគាត់ចូលទៅជិតម្តាយ ហើយពោល

សច្ចវាចាថា ខ្ញុំតាំងពីកើតមកធំប៉ុណ្ណេះ មិនដែលសម្លាប់សត្វដល់ម្តងឡើយ ដោយសច្ចវាចានេះ សូមឱ្យរោគជាសះស្បើយមួយរំពេច។ មាតាក៏ជាស្រឡះចាករោគក្នុងពេលដែលចក្ខុនៈជាកូនធ្វើសច្ចាធិដ្ឋាននោះ។

********

## ១៨_ រឿងអ្នកកំណាញ់

(ជាក អ. សុ.)

(ម្ដាយឪពុកតែងប្រាថ្នាប្រយោជន៍ឱ្យបុត្រធីតា)

ក្នុងក្រុងពារាណសី មានសេដ្ឋីម្នាក់មានសម្បត្តិ៨០កោដិ ជាមនុស្ស មានសទ្ធាយ៉ាងសិប់សួន បានចំណាយទ្រព្យកសាងសាលាទាន៦ គឺស្បែរទ្វារនគរទាំង៤ ត្រង់កណ្ដាលនគរ១ ស្បែរទ្វារនៃនិវេសន៍១ ហើយតែងបរិច្ចាកទ្រព្យ៦សែនកហាបណៈរាល់ៗថ្ងៃ ចែកចាយដល់ស្មូមយាចកមកសុំគ្រប់ៗរូប។ បុរសនោះឱ្យទានយ៉ាងនេះជារៀងរាល់ថ្ងៃ ហើយបានទូន្មានកូនរបស់ខ្លួនថា កូនអ្នកកុំលះបង់ចោលទានវង្សរបស់អញនេះ លុះស្លាប់ទៅ ក៏បានទៅកើតជាសក្កទេវរាជ។ កូនសេដ្ឋីនោះ បានបំពេញតាមវង្សបិតាដែរ ពេលស្លាប់ទៅបានកើតជាចន្ទទេវបុត្រ។ កូនសេដ្ឋី(គឺកូនចន្ទទេវបុត្រ) បានប្រព្រឹត្តតាមវង្សបិតា ក៏បានកើតជា សុរិយទេវបុត្រ. កូនសុរិយទេវបុត្របានធ្វើតាមលំនាំនោះ ក៏បានកើតជាមាតលីទេវបុត្រ. កូនមាតលី បានធ្វើទានតាមលំអានវង្សត្រកូលទៀត ក៏បានកើតជាបញ្ចសិខទេវបុត្រ។ ប្លែកតែកូនបញ្ចសិខទេវបុត្រ ឈ្មោះកោសិយ ពេលឥតពីបិតាទៅ បានទទួលតំណែងជាសេដ្ឋីមានទ្រព្យ៨០កោដិ តែជាមនុស្សស្វិតស្វាញណាស់។ ថ្ងៃមួយកោសិយសេដ្ឋីគិតថា ជីតា ជីតាទួតអញ ជាមនុស្សពាលពិត ចំណាយទ្រព្យដែលខ្លួនរកបានលំបាក ឱ្យជាទានអ្នកដទៃ. អញនឹងរក្សាទ្រព្យនេះឱ្យគង់វង្ស មិនឱ្យទានដល់អ្នកណាឡើយ លុះគិតដូច្នោះហើយ ក៏ឱ្យគេរុះរើសាលាទាន យកមកដុតភ្លើងចោលអស់ ជា

មនុស្សមានសេចក្ដីកំណាញ់ស្វិតស្វាញណាស់ បានប្រមូលទ្រព្យយកមកទុក មិនដែលចាយវាយអ្វីសោះ ទាំងមិនឱ្យដល់កូនប្រពន្ធទាំងឡាយ ចាយវាយផងដែរ។ កោសិយសេដ្ឋីនោះ បរិភោគតែបាយលាយកន្ទក់ដែលច្របូកច្របល់ដោយទឹកបាយ ស្លៀកសំពត់មានសាច់ក្រាស់ៗ ដេកលើគ្រែចគ្រដែលគេធ្វើជារបៀបស្វឹក ធ្វើដំណើរទៅណាមកណាតែដោយរថចាស់ដែលទឹមដោយគោចាស់ដូចគ្នា។ សេដ្ឋីអសប្បុរសនោះ បានទ្រព្យទាំងប៉ុណ្ណេះ វិស័យដូចជាផ្លែបានដូងព្រោះគាត់មិនចាយវាយសោះ។ ថ្ងៃមួយសេដ្ឋីនោះទៅគាល់ព្រះរាជាហើយបានចូលទៅហៅសេដ្ឋីបន្ទាប់ម្នាក់ ឱ្យទៅជាមួយ។ ខណៈនោះសេដ្ឋីបន្ទាប់កំពុងតែបរិភោគបាយាស ដែលគេតាក់តែង ដោយកំទេចស្ករក្រាមមានរស់ផ្អែម ដែលលាយឡំដោយទឹកដោះខាប់នឹងជូរ កាលឃើញកោសិសេដ្ឋីមកដល់ ក៏ក្រោកឡើងទទួលដោយរាក់ទាក់ថា បពិត្រលោកមហាសេដ្ឋីសូមលោកអញ្ជើញចូលមកអង្គុយលើអាសនៈនេះ បរិភោគបាយាស ជាមួយខ្ញុំ។ កោសិយសេដ្ឋីគ្រាន់តែឃើញបាយាស ក៏ស្រក់ទឹកមាត់ចង់បរិភោគណាស់តែធ្វើម្ដេច សេចក្ដីកំណាញ់ហាមឃាត់ចិត្តគាត់ឱ្យគិតឃើញថា ប្រសិនបើអញបរិភោគក្នុងពេលនេះ អញនឹងធ្វើទទួលគាត់នេះ ដែលទៅឯផ្ទះអញវិញ កាលបើយ៉ាងនេះ ទ្រព្យអញនឹងវិនាសដោយពិត ណ្ហើយកុំទៅចុះល្អជាងលុះគិតដូច្នេះហើយ ក៏អង្គុយក្នុងទីនោះ ទោះជាសេដ្ឋីបន្ទាប់អង្វរឱ្យបរិភោគយ៉ាងណា ក៏នៅតែពោលថា ទេខ្ញុំទើបនឹងបរិភោគរួចអម្បាញមិញនេះឯង

កាលសេដ្ឋីបន្ទាប់បរិភោគរួចហើយ ក៏បបួលគ្នាទៅគាល់ស្ដេច លុះត្រឡប់មកផ្ទះរៀងៗខ្លួនវិញ ទុកជាចំណង់ក្នុងចាយាសនោះគ្របសង្កត់យ៉ាងណា ក៏កោសិយសេដ្ឋីទ្រាំអត់ណាស់ មិនហ៊ានប្រាប់គេទេ ខ្លាចអស់ទ្រព្យ។ ចំណង់នោះ ក៏បណ្ដាលឱ្យកើតរោគលឿង។ ទោះកើតរោគយ៉ាងនេះក៏ដោយ ក៏នៅតែមិនប្រាប់គេ ដរាបដល់មានកំលាំងពលំខ្សោយទៅជាលំដាប់ ក៏ចូលទៅដេកសន្ធឹងសន្ធៃនៅលើដំណេក។ ប្រពន្ធចេះតែមកទទួចសួរ ក៏គាត់ដាច់ចិត្តប្រាប់រឿងរ៉ាវនោះ។ ប្រពន្ធដឹងហើយក៏ពោលថា អ្នកជាមនុស្សក្រណាស់ឬ? ខ្ញុំនឹងចាត់ចែងចំអិនចាយាស ឱ្យល្មម ដល់អ្នកនៅក្នុង ក្រុងពារាណសីទាំងអស់។ កោសិយឮពាក្យនោះហើយ ក៏ហាក់ដូចជាគេយកដំបង មកសំពងចំក្បាលគាត់ ទើបពោលប្រាប់ប្រពន្ធថា អញដឹងថានាងឯងក្ងួនថៅកែហើយ តែទ្រព្យនាំមកពីផ្ទះនាងក៏មាន ចូរយកទ្រព្យនោះចែកចាយ ហើយចំអិនចាយាសដល់អ្នកនគរទាំងឡាយចុះ។ ប្រពន្ធថា បើដូច្នោះខ្ញុំនឹងចំអិនឱ្យល្មមដល់ជនដែលនៅក្នុងផ្លូវជាមួយគ្នា បានឬទេ? ប្រយោជន៍អ្វីដល់ជនទាំងនោះ. ប្រពន្ធ. បើដូច្នោះ ខ្ញុំនឹងចំអិនដល់ជនជិតខាង គ្រប់ប្រាំពីរៗផ្ទះ រាប់ពីផ្ទះយើង. ឱ្យល្មមដល់ជនជាបរិវារ. ឱ្យល្មមដល់ជនជាញាតិ ក៏សេដ្ឋីមិនព្រម។ នាងប្រពន្ធពោលថា បើដូច្នោះ ខ្ញុំនឹងចំអិនឱ្យល្មមតែ អ្នកនឹងខ្ញុំ។ សេដ្ឋីថា លោតែចង់អ្វីដែរ? នាងមិនគួរបរិភោគទេ។ នាងប្រពន្ធ ក៏ពោលថា អើខ្ញុំចំអិនឱ្យល្មមតែអ្នក។ សេដ្ឋីថា អើបើយ៉ាងហ្នឹងបាន តែនាងកុំចំអិនក្នុងទីនេះ

ខ្លាចគេមកសុំ. ចូរនាងយកអង្ករមួយទូកដៃ ទឹកដោះស្រស់មួយចិប ស្ករក្រាមប៉ុនម្រាមដៃ សប្បិបន្តិចទឹកឃ្មុំ នឹងអំបែងមួយមកឱ្យអញយកទៅចំអិនក្នុងព្រៃឯណោះ ទើបគ្មាននរណាមកសុំ ហើយអញនឹងបានបរិភោគគ្រប់គ្រាន់។ នាងប្រពន្ធក៏ធ្វើតាមបង្គាប់។ កោសិយសេដ្ឋីបានឱ្យខ្ញុំកំដរម្នាក់កាន់របស់ទាំងអស់នោះចូលទៅក្នុងព្រៃ ហើយរៀបចំចង្ក្រានក្បែរឈើមួយដើមនាថ្មេរស្ទឹង ទើបឱ្យខ្ញុំកំដរទៅរកអុសនឹងទឹកយកមកទុកឱ្យហើយ បង្គាប់ថា ចូរឯងទៅចាំមើលផ្លូវ ក្រែងមាននរណាគេមក ចូរប្រាប់ដល់អញកុំខាន ហើយបង្កាត់ភ្លើងចំអិនបាយាសខ្លួនឯង។

ខណៈនោះ សក្កទេវរាជរំពឹងមើលវង្សទានរបស់ខ្លួន បានដឹងរឿងរ៉ាវទាំងអស់ទើបទ្រង់ព្រះចិន្តាថា: យី! កោសិយសេដ្ឋី កំណាញ់អ្វីក៏កំណាញ់ម្ល៉េះ បានទាំងផ្តាច់បង់វង្សទានរបស់អញទៀត បើស្លាប់ទៅនឹងកើតក្នុងនរកពិត ដូច្នេះគួរអញទៅឱ្យឱវាទ ឱ្យធ្វើបុណ្យទានទើបគួរ លុះគិតយ៉ាងនេះហើយ ក៏ប្រាប់ទេវបុត្តជាកូនចៅឱ្យដឹងរឿងរ៉ាវនោះ ហើយប្រាប់ថាអញទៅមុន អ្នកទាំងអស់គ្នាចូរទៅតាមលំដាប់លំដោយ ក្នុងពេលដែលអញអង្គុយសុំបាយាសនោះ ប្រាប់រួចហើយ ក៏និម្មិតខ្លួនជាព្រាហ្មណ៍ចូលទៅរកកោសិយសេដ្ឋីសួរថា នែអ្នកដ៏ចំរើន ផ្លូវណាហ្ន៎ ដែលទៅក្រុងពារាណសី? សេដ្ឋីឆ្លើយថា អ្នកឆ្កួតទេឬ បានជាមិនស្គាល់ផ្លូវទៅក្រុងពារាណសី ទុះផ្លូវ។ ព្រះឥន្ទ្រព្រាហ្មណ៍ធ្វើហាក់ដូចជាមិនឮ ហើយចូលទៅជិតសួរថា អ្នកនិយាយថាម៉េច? សេដ្ឋី

សំឡុតថា នែព្រាហ្មណ៍ថ្គង់ចង្រៃ! ឯងមកខាងណោះធ្វើអ្វី ថានុះផ្លូវទៅពារាណសី។ ឥន្ទព្រាហ្មណ៍និយាយថា អ្នកដ៏ចំរើន ហេតុអ្វីបានជាអ្នកស្រែក? ផ្សែងភ្លើងមានស្រាប់ហើយ អ្នកត្រូវការចំអិនបាយាសហើយ និមន្តព្រាហ្មណ៍មកឱ្យឆាន់ក៏អញ្ជើញចំអិនចុះ ខ្ញុំនឹងបានចំណែកបន្តិចក្នុងពេលដែលព្រាហ្មណ៍ទាំងឡាយឆាន់។ សេដ្ឋីគំរាមថា យើងឥតត្រូវការនិមន្តព្រាហ្មណ៍ មកឆាន់ទេ ចូរឯងទៅពីនេះឱ្យឆាប់។ ឥន្ទព្រាហ្មណ៍និយាយថា បើដូច្នោះ ខ្ញុំនឹងបានចំណែកបន្តិចក្នុងពេលដែលអ្នកបរិភោគ។

សេដ្ឋីប្រាប់ថា: សូម្បីតែបាយមួយគ្រាប់ក៏ខ្ញុំមិនឱ្យដល់អ្នកដែរព្រោះយើងចំអិនល្មមតែស៊ីម្នាក់ឯង។ ឥន្ទព្រាហ្មណ៍ឮពាក្យនោះហើយ ក៏ពោលគាថាថា: "បុគ្គល[១]ត្រូវតែឱ្យវត្ថុតិចពីវត្ថុតិច ពាក់កណ្តាលពីពាក់កណ្តាល ច្រើនពីច្រើន, ការមិនឱ្យសោះមិនគួរទេ, ម្នាលកោសិយៈ ហេតុនោះខ្ញុំមកប្រាប់ឱ្យអ្នកឯងឱ្យទានផង បរិភោគផង ឡើងកាន់ផ្លូវដ៏ប្រសើរ[២]ផង, បុគ្គលស៊ីតែឯកឯងមិនបានសុខទេ"។

សេដ្ឋីឮពាក្យនោះក៏ពោលថា ម្នាលព្រាហ្មណ៍អ្នកពោលនេះត្រូវ, អ្នកនឹងបានចំណែកបន្តិចចូរអង្គុយសិនចុះ។ ឥន្ទព្រាហ្មណ៍ក៏អង្គុយចុះ។ លំដាប់នោះចន្ទទេវបុត្តមកនិយាយតាមន័យនោះហើយពោលគាថាថា "បុគ្គលណាបើភ្ញៀវអង្គុយចុះហើយ បរិភោគភោជនតែម្នាក់ឯងគាប្បជានឹងការកប់កំណាប់

១. មិនបានដកយកគាថាមកដាក់ទេ ព្រោះនាំឱ្យវែងជ្រុល។ ២. ផ្លូវដ៏ប្រសើរគឺអរិយមគ្គ។

ទ្រព្យទុករបស់បុគ្គលនោះជាការសាបសូន្យពិត. ម្នាលកោសិយៈ ហេតុនោះខ្ញុំមកប្រាប់ឱ្យអ្នកឯងឱ្យទានផង បរិភោគផង ឡើងកាន់ផ្លូវដ៏ប្រសើរផង. បុគ្គលស៊ីម្នាក់ឯងមិនបានសុខទេ"។

សេដ្ឋីពោលថា អើចូរអង្គុយសិនចុះ យើងនឹងឱ្យអ្នកបន្តិច។ ចន្ទទេវបុត្រក៏អង្គុយចុះតាមបង្គាប់។ បន្ទាប់មកសុរិយទេវបុត្របានថ្លែងខ្លួនជាព្រាហ្មណ៍មកសួរសុំតាមន័យនោះដែរ ហើយពោលគាថាថា "បុគ្គលណា បើភ្ញៀវអង្គុយចុះ ហើយមិនបរិភោគភោជនតែម្នាក់ឯង ការបូជានឹងការកប់កំណប់ទ្រព្យទុករបស់បុគ្គលនោះតែងមានពិត. ម្នាលកោសិយៈ ហេតុនោះខ្ញុំមកប្រាប់អ្នកឯងឱ្យទានផង. បរិភោគផង. ឡើងកាន់ផ្លូវដ៏ប្រសើរផង. បុគ្គលស៊ីតែម្នាក់ឯងមិនបានសុខទេ"។

បន្ទាប់មកមាតលីទេវបុត្រមកពោលថែមថា "បុគ្គលណាបូជាស្រះទាំងអស់ គឺស្ទឹងក្តី ស្រះបោក្ខរណីក្តី កំពង់ឈ្មោះទោណៈក្តី ឈ្មោះតិម្ពរុក្តី ស្ទឹងធំដែលមានខ្សែទឹកហូរខ្លាញ់ក្តី ឬបុគ្គលណាបើភ្ញៀវមកអង្គុយហើយមិន បរិភោគម្នាក់ឯង ការបូជានឹងការកប់កំណប់ទ្រព្យទុករបស់ជននោះ ក្នុងទី មានស្ទឹងជាដើម រមែងមានពិត. ម្នាលកោសិយៈ ហេតុនោះខ្ញុំមកប្រាប់អ្នក ឯងឱ្យៗទានផង បរិភោគផង ឡើងកាន់ផ្លូវដ៏ប្រសើរផង. បុគ្គលស៊ីម្នាក់ឯង មិនបានសុខទេ"។ លំដាប់នោះបញ្ចសិខទេវបុត្រក៏មកពោលបន្ថែមទៀតថា "បុគ្គលណា បើភ្ញៀវមកអង្គុយហើយ បរិភោគម្នាក់ឯង បុគ្គលនោះតែង

គ្រលៀស លេបផ្លែសន្ទូច ព្រមទាំងនុយដែលមានខ្សែវែង. ម្នាលកោសិយៈ ហេតុនោះ ខ្ញុំមកប្រាប់អ្នកឱ្យៗទានផង បរិភោគឡើងកាន់ផ្លូវដ៏ប្រសើរផង, បុគ្គលស៊ីម្នាក់ ឯង មិនបានសុខទេ"។

សេដ្ឋីឮពាក្យទាំងនោះ ក៏ក្ដួញក្ដែរដោយសេចក្ដីទុក្ខព្រួយស្ទើរមិនដាច់ចិត្តនឹងឱ្យ ពោលថា ដូច្នោះ ចូរអ្នកអង្គុយសិនចុះនឹងបានចំណែកបន្តិចដែរ បញ្ចសិខក៏អង្គុយតាមបង្គាប់។ កាលទេវបុត្រ៥អង្គុយចុះហើយ សេដ្ឋីក៏ចំអិនបាយាសជាស្រេច ទើបឱ្យព្រាហ្មណ៍ទាំង៥យកស្លឹកឈើមក ខ្លួននឹងចែកបន្តិចៗឱ្យ។ ទេវបុត្រទាំងឡាយអង្គុយក្នុងទីនោះ ក៏លាដៃទៅឈោងបេះស្លឹកជ្រៃដ៏ធំពីព្រៃហេមពាន្តមកឱ្យសេដ្ឋីៗប្រកែកថា ស្លឹកនោះធំណាស់ខ្ញុំមិនឱ្យទេ ចូរបេះស្លឹកគគីរមកវិញ។ ទេវបុត្រក៏បេះស្លឹកគគីរមកឱ្យ។ ឯស្លឹកគគីរនោះ មួយសន្លឹកៗប៉ុនផែនក្ដារ។ សេដ្ឋីក៏ចែកបាយាសមួយវែកៗដល់ទេវបុត្រទាំងនោះ។ លុះឱ្យរួចហើយ ក៏កាន់យកឆ្នាំងបាយាសមកអង្គុយបរិភោគ។

តស្មិំ ខណេ ក្នុងខណនោះគួរអស្ចារ្យណាស់ បញ្ចសិខទេវបុត្រក៏និម្មិតខ្លួនជាឆ្កែ ហើយនោមប្រោសមុខសេដ្ឋីនឹងទេវបុត្រទាំង៤នោះទើបរត់ទៅ។ ទេវបុត្រព្រាហ្មណ៍ទាំងឡាយ យកដៃខ្ទប់បាយាសរបស់ខ្លួន។ ឯសេដ្ឋីក៏ធ្វើតាម។ ទុកជាសេដ្ឋីបិទក៏មិនជិត, ទឹកនោមឆ្កែនៅតែធ្លាក់មក ត្រូវខ្នងដៃគាត់ដដែល។ សេដ្ឋីចង់លាងដៃក៏ពោលប្រាប់ថា អ្នកទាំងឡាយមើលឆ្នាំងបាយខ្ញុំផង ទើបគាត់ចុះទៅកាន់ស្ទឹង។ លំដាប់នោះឆ្កែក៏មកនោមដាក់ឆ្នាំងបាយ

ទៀត។ សេដ្ឋីក្តៅណាស់ កាន់ដំបងយ៉ាងធំស្ទុះដេញតាមឆ្កែនោះ។ ឆ្កែក្លាយខ្លួនធំប៉ុនសេះអាជានេយ្យភ្លាម ទើបស្ទុះមកវកខាំសេដ្ឋីវិញ។ សេដ្ឋីភ័យខ្លាចស្លាប់ក៏រត់មកឱ្យព្រាហ្មណ៍ជួយ តែឥតអំពើសោះ ព្រាហ្មណ៍គេហោះទៅឋិតនៅលើអាកាសឯណោះ ទើបសេដ្ឋីសួរថា អ្នកទាំងឡាយជាអ្វី? លំដាប់នោះឥន្ទព្រាហ្មណ៍ឆ្លើយថា ព្រាហ្មណ៍នេះជាចន្ទទេវបុត្រ នេះជាសុរិយទេវបុត្រ នេះជាមាតលិទេវបុត្រ ខ្ញុំជាសក្កទេវរាជ ឆ្កែនេះជាបញ្ចសិខទេវបុត្រ. យើងមកនេះមិនមែនប្រាថ្នាសុំចាយាសអ្នកស៊ីទេ តែអ្នកត្រូវជាញាតិនឹងយើង ឥឡូវនេះអ្នកជាមនុស្សកំណាញ់ ឯអ្នកកំណាញ់ទាំងឡាយតែងតែកើតក្នុងនរក អ្នកមិនកំណាញ់គេកើតឯឋានសួគ៌ឯណោះ. ដែលយើងមកនេះ ក៏ព្រោះតែមានសេចក្តីអនុគ្រោះចំពោះអ្នកទេតើ!។ សេដ្ឋីអរណាស់គិតថាឱហ្ន៎!ទេវបុត្រទាំងនេះគេប្រាថ្នាប្រយោជន៍ដល់អញ មកស្តារអញចេញពីនរក យកទៅដាក់នៅឋានសួគ៌ ហើយទទួលនូវពរក្នុងសំណាក់ព្រះឥន្ទថា ចាប់ពីពេលនេះទៅ វត្ថុពាក់កណ្តាលៗពីពំនូតបាយដែលខ្ញុំមិនឱ្យគ្នានទេ. សូម្បីទឹកមួយកំបង់បើខ្ញុំបានហើយមិនឱ្យអ្នកដទៃ ក៏ខ្ញុំមិនផឹកដែរ។ សក្កទេវរាជ បានទូន្មានកោសិយ ឱ្យមានសេចក្តីជ្រះថ្លាចំពោះទានផ្សេងៗ ហើយឱ្យនិច្ចសីលស្រេច ទើបហោះទៅកាន់ទេវលោក ជាមួយទេវបុត្រទាំងនោះវិញ។ ថ្លែងពីកោសិយសេដ្ឋីពេលត្រឡប់ទៅផ្ទះវិញ បានទូលសុំព្រះរាជានុញ្ញាត ចែកចាយទានដល់អ្នស្មូមយាចកហើយ បានធ្វើបណ្ណសាលាមួយជាចន្លោះនៃស្ទឹងគង្គា នឹងផាត.

ស្រះក្នុងហេមពាន្តប្រទេស ចេញទៅបួសនៅសំណាក់ក្នុងសាលានោះអស់កាលដ៏យូរ លុះស្លាប់ទៅ ក៏បានកើតជាឧបបាតិកទេវបុត្រ។ ដំណឹងក៏លេចឮដល់សក្កទេវរាជ ទើបព្រះអង្គត្រាស់បង្គាប់ឱ្យ មាតលិយករថវេជយន្តរថទៅទទួលឱ្យមកកាន់សំណាក់ព្រះអង្គ ហើយទ្រង់មានព្រះទ័យសោមនស្សណាស់ បានព្រះរាជទានធីតាមួយអង្គព្រះនាមនាង ហិរិទេវី ដល់ឧបបាតិកទេវបុត្រនោះ។ គ្រឿងឥស្សរិយយសមានប្រមាណមិនបាន ក៏កើតឡើងដល់ឧបបាតិកទេវបុត្រនោះឯង។

********

## ១៩. រឿងកុហកតាបស

(ចាក អ. កុ.)

(លួចគេវាគ្រាន់ គេទាន់វាក្រែល)

ក្នុងកាលពីអតីត នៅក្រុងពារាណសី មានតាបស១រូបឈ្មោះកុហក នៅអាស្រ័យក្នុងព្រៃ នាបណ្ណសាលាដែលកុដុម្ពិកសាងប្រគេន ហើយតែងនិមន្តទៅឆាន់នៅផ្ទះកុដុម្ពីក៏នោះរាល់ៗថ្ងៃ។ កុដុម្ពិកៈជឿថា តាបសនេះជាមនុស្សមានសីលធម៌ ក៏យកមាសផ្ការទាំងរយទៅផ្ញើនឹងលោក កប់ក្រោមបណ្ណសាលានោះ ព្រោះបើទុកនៅឯផ្ទះខ្លាចចោរលួច ប្លន់ ហើយពោលទូលលោកថា លោកម្ចាស់ដ៏ចំរើន សូមទានមេត្តាថែទាំទ្រព្យសម្បត្តិនេះឱ្យខ្ញុំព្រះករុណាផង។ តាបសពោលថា នែអាវុសោ ធម្មតាបព្វជិតទាំងឡាយ គេមិនលោភលន់ចង់បានទ្រព្យអ្នកដទៃទេ។ កុដុម្ពិកៈ មានសេចក្តីកក់ក្តៅជាពន់ពេកក៏ពោលថា ខ្ញុំព្រះករុណាសូមអរព្រះគុណលោកម្ចាស់ជាពន្លឹក ទើបត្រឡប់ទៅផ្ទះវិញ។ កុហកតាបសថែទាំទ្រព្យនោះបានពីរបីថ្ងៃ ក៏កើតចិត្តលោភលន់លួចយកទ្រព្យនោះទៅកប់នៅក្បែរចន្លោះផ្លូវ រួចទើបត្រឡប់ទៅវិញ ពេលថ្ងៃឡើង ក៏ទៅធ្វើភត្តកិច្ចនៅឯផ្ទះកុដុម្ពិកៈនោះ ដោយធ្វើកលឧបាយយ៉ាងចំណាន ដើម្បីកុំឱ្យគេសង្ស័យពោលប្រាប់ថា អាវុសោ អាត្មាមកអាស្រ័យនៅនឹងផ្ទះអ្នកអស់កាលយូរលង់ណាស់ហើយ ព្រោះថា ការនៅប្រប្រូកប្របល់ដោយមនុស្សទាំងឡាយ ក្នុងទីតែមួយអស់ពេលវេលាយូរពេក ជាហេតុនាំឱ្យក្លាយទៅជាមន្ទិលដល់បណ្ឌិតទាំងឡាយ ដូចជាអាត្មានេះ ដូច្នេះ អាត្មាសុំ

ចំរើនពរទៅនៅទីដទៃហើយនោះកុដុម្ពិកៈអង្វរករយ៉ាងណា ក៏កុហកតាបស មិនព្រមព្រោះលោកធ្វើកលឧបាយ ដើម្បីនឹងបោកប្រាស់កុហកកុដុម្ពិកៈនោះ លុះចំរើនពររួចហើយ ក៏យកស្បូវមួយលាក់នៅក្នុងផ្នួងសក់ ទើបដើរចេញទៅៗ ផុតបន្តិចក៏ត្រឡប់មកវិញ។ កុដុម្ពិកៈឃើញតាបសនោះក៏សួរថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់និមន្តត្រឡប់មកវិញនេះ តើមានការអ្វី? តាបសពោលថា អាវុសោ ដែលអាត្មាត្រឡប់វិញនេះ ព្រោះមានស្បូវ១សរសៃធ្លាក់ពីដំបូលផ្ទះអ្នក មកទើរនៅលើផ្នួងសក់អាត្មា ព្រោះថាបព្វជិតទាំងឡាយ គេមិនដែលប្រព្រឹត្តធ្វើអទិន្នាទានទេ។ កុដុម្ពិកៈពោលថា ចោលទៅលោកម្ចាស់ គាត់មានសេចក្ដីជ្រះថ្លាជាពន់ពេកចំពោះតាបសកុហកនោះ បានលាន់មាត់ថា ឱហ្ន៎! លោកម្ចាស់ជាអ្នកមានសេចក្ដីរង្កៀសក្នុងសីលរបស់ខ្លួន សព្វបើគ្រាន់តែស្បូវមួយសរសៃនេះ។ គ្រានោះ ព្រះពោធិសត្វរបស់យើង បានចេញទៅធ្វើជំនួញនៅនាស្រុកបច្ចន្តគ្រាម ចូលទៅសំណាក់ចាក់អាស្រ័យនឹងផ្ទះនោះ បានឮសំដីតាបសពោលបែបនោះ ក៏សង្ស័យគិតថា ច្បាស់ជាតាបសកំណាចនេះ លួចយករបស់អ្វីមិនខានហើយទើបសួរ កុដុម្ពិកៈថា អ្នកមានបានផ្ញើអ្វីទឹងតាបសនេះដែរ? លុះឮពាក្យឆ្លើយ ក៏ប្រាប់ឱ្យកុដុម្ពិកៈទៅមើលទ្រព្យនោះ ដោយប្រញាប់ប្រញាល់។ កុដុម្ពិករត់ទៅបណ្ណសាលាកាយរកមើលទ្រព្យគឺ មាសមិនឃើញ ក៏រត់មកប្រាប់ពោធិសត្វថា សម្លាញ់ទ្រព្យវិនាសបាត់ទៅហើយ។ ជនទាំងពីរនាក់គឺកុដុម្ពិកៈ នឹងពោធិសត្វ

ក៏រត់តាមតាបសនោះទាន់ ចាប់ចងទាត់ធាក់ឱ្យនាំយកមាសមកឱ្យ។ តាបសឈឺពេក ក៏នាំជនទាំងពីរទៅ បង្ហាញកន្លែងដែលខ្លួនយកមាសទៅកប់នោះ។ ព្រះពោធិសត្វឃើញមាសហើយ ក៏តិះដៀលតាបសនោះថា នែឥសីបោកប្រាស អ្នកប្រសព្វធ្វើសេចក្ដីសង្ស័យក្នុងសីលរបស់ខ្លួន សូម្បីក្នុងចងនៃស្បូវមួយសសៃណាស់ អ្នកអាងថាខ្លួនមិនប្រព្រឹត្តអទិន្នាទានបំពោះវត្ថុទាំងឡាយ សូម្បីតែស្បូវមួយទងឡើយ។ ឥឡូវស្រាប់តែលួចយកមាសគ្មានគេទាំងរយយ៉ាងនេះ ទើបពោលឱ្យឱវាទថា អ្នកឯងក្រោយៗ កុំប្រព្រឹត្តកុហកលួចយកទ្រព្យគេយ៉ាងនេះទៀត ព្រោះជាអំពើថោកទៀបណាស់ នាំឱ្យតែខ្លួនលំបាកឈឺចាប់ឥតស្រាកស្រាន្តដោយទារុណកម្ម នៃអំពើអទិន្នាទាននោះឯង ហើយស្រាយតាបសនោះពីចំណងវិលមកផ្ទះជាមួយនឹងកុដុម្ពិកៈនោះវិញ។

*********

# ២០.រឿងមុសាវាទិព្រាហ្មណ៍

(ចាក អ. កណ្ហា)

(បើដេញទាន់អ្នកនិយាយកុហក គួរតែផាន់តែងឱ្យបាន)

ក្នុងអតីតកាល មានការលេងមហោស្រពយ៉ាងសប្បាយរីករាយជាអស្ចារ្យ។ នាគ. គ្រុឌនឹងទេវតាទាំងឡាយដែលនៅលើផែនដី ក៏មកមើលមហោស្រពនោះដែរ។ មិនតែប៉ុណ្ណោះ សូម្បីតែទេវបុត្រទាំង៤អង្គ ឋានតាវតិង្ស ក៏ប្រដាប់នូវផ្ការពៅធ្វើជាឆ្នួតក្បាល មកឋិតឰដ៏អាកាសលើព្រះរាជលាន មើលមហោស្រពដែលគេលេងក្នុងក្រុងពារាណសីនោះ។ ផ្ការពៅទិព្វទាំងអស់ដែលទេវបុត្រប្រដាប់នោះ មានខ្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ផ្សាយទៅគ្របដណ្ដប់លើពារាណសីនគរ ដែលប្រកបដោយយោជន៍១២។ មនុស្សក្នុងនគរនោះ ក្រឡេកឃើញទេវបុត្រប្រដាប់ដ៏ល្អដូច្នោះ ក៏ស្រែកសុំរៀង១ខ្លួន។ ឯទេវបុត្រទាំង៤អង្គនោះប្រាប់ថា បុគ្គលទ្រុស្តសីលមិនសមនឹងប្រដាប់នេះទេ បើបុគ្គលណាមានសីល ទើបសមនឹងយកផ្កានេះទៅប្រដាប់ប្រាណបានហើយ ពោលគាថាមួយ១ម្នាក់ ទេវបុត្រទី១ពោលថា

កាយេន យោ នាវហរេ វាចាយ ន មុសា ភណេ

យសោ លទ្ធា ន មជ្ជេយ្យ សវេ កណ្ហារុមរហតិ ។

បុគ្គលណាមិនលួចទ្រព្យគេដោយកាយ មិនពោលកុហកដោយវាចាមិនស្រវឹងព្រោះបានយស ផ្ការពៅនេះទើបគួរដល់បុគ្គលនោះ។

ទេវបុត្រទី២ពោលថាៈ

ធម្មេន វិត្តមេសេយ្យ ន និកត្យា ធនំ ហរេ ភោគេ
លទ្ធា ន មជ្ជេយ្យ សវេ ។

បុគ្គលណាស្វែងរកទ្រព្យតាមធម៌ មិនពោលកុហកប្រវ័ញ្ចយកទ្រព្យអ្នកដទៃ មិនស្រវឹងព្រោះបានភោគៈ ផ្ការពៅនេះទើបគួរដល់បុគ្គលនោះ។

ទេវបុត្រទី៣ពោលថា:

យស្ស ចិត្តំ អហាលិទ្ទំ សទ្ធា ច អវិរាគិនី ឯកោ
សាធុំ ន ភុញ្ជេយ្យ សវេ កត្តារុមរហតិ ។

បុគ្គលណាមានចិត្តមិនស្មើ ដោយសំពត់ជ្រលក់រមៀត មានសទ្ធាមិននឿយណាយ មិនបរិភោគវត្ថុមានរសឆ្ងាញ់តែម្នាក់ឯង ផ្ការពៅនេះទើបគួរដល់បុគ្គលនោះ ។

ទេវបុត្រទី៤ពោលថា:

សម្មុខា វា បរម្មុខា វា យោ សន្តេ ន បរិភាសតិ
យថាវាទី តថាការី សវេ កត្តារុមរហតិ ។

បុគ្គលណាក្នុងទីចំពោះមុខក្តី កំបាំងមុខក្តី មិនជេរសប្បុរសទាំងឡាយ ពោលយ៉ាងណាធ្វើយ៉ាងនោះ បុគ្គលនោះគួរប្រដាប់ផ្ការពៅនេះ។

ក្នុងទីបំផុតនៃគាថាទេវបុត្រទាំង៤រង្គនោះ មានបុរោហិតម្នាក់គិតថា អញមិនមានគុណនេះសូម្បីមួយឡើយ តែគួរពោលកុហកហើយសុំផ្ការពៅនេះយកប្រដាប់ព្រាណ. កាលបើមានហេតុយ៉ាងនេះ ពួកមនុស្សផ្សាយផ្លូវ

អញថាជាមនុស្សបរិបូណ៌ដោយគុណ លុះគិតរួចហើយ ក៏ធ្វើតាមយោបល់នោះឯង។ ទេវបុត្រក៏ឱ្យផ្ទុតផ្កាទាំង៤ដល់ព្រាហ្មណ៍នោះ ហើយវិលទៅកាន់ទេវលោកវិញ។ ពេលដែលទេវបុត្រទាំងនោះវិលទៅទេវលោកវិញ បុរោហិតយកផ្កានោះមកពាក់លើក្បាល ក៏ស្រាប់តែឈឺជាពន់ពេក វិស័យដូចគេយកដែកកណ្តារដ៍មុតមកខារក្បាលឬដូចជាគៀបដោយយន្តជាវិការៈនៃដែក។ បុរោហិត មានសេចក្តីវេទនាជាមហិមា ឈឺចាប់ពេញសពាង្គកាយកើតក្តីក្តៅក្រហាយព្រោះតែខ្លួនពោលកុហក ស្រែកយំខ្លែងៗប្រាប់មហាជនថា ខ្ញុំជាអ្នកពោលមុសាវាទសុំផ្កានេះយកមកពាក់លើក្បាលដោយស្មានថាផ្កាប្រសើរ តែមិនដូចការស្មាននោះ ក្បាលខ្ញុំគ្រាន់តែពាក់ផ្កានេះវេលាណា ក៏ឈឺចាប់ចុកជាខ្លាំង ដូច្នេះសូមអ្នកទាញយកផ្កានេះចេញពីក្បាលខ្ញុំមួយភ្លែត។ ទោះជាមហាជនអាណិតអាសូរខំទាញចេញយ៉ាងណាក៏ដោយ ក៏នៅតែទាញមិនរួច ព្រោះអ្វី? ព្រោះទោសនៃមុសាវាទ។ មនុស្សទាំងឡាយក៏នាំគ្នាសែងបុរោហិតនោះយកទៅផ្ទះ។ បុរោហិតឈឺចាប់អស់សពាង្គកាយពេញមួយអាទិត្យ ទើបជ្រាបដំណឹងនោះដល់ព្រះរាជា ព្រះអង្គក៏ចាត់ចែងឱ្យគេធ្វើមហោស្រពឡើង ដើម្បីឱ្យទេវបុត្រទាំង៤នោះមកមើលម្តងទៀត ហើយសុំឱ្យដោះយកផ្កានេះចេញ។ លុះទេវបុត្រមកមើលមហោស្រពក៏ព្រះរាជាត្រាស់បង្គាប់ពួករាជបុរសនាំយកបុរោហិតមក ឱ្យសូមស្មាលាទោស។ ទេវបុត្រក៏តិះដៀលបុរោហិតនោះក្នុងកណ្តាលមហាជនថា អ្នកឯងជមនុស្សទ្រុស្តសីល មិនសម

នឹងប្រដាប់ដោយផ្កានេះទេ តែអ្នកឯងមានគំនិតអាក្រក់ថា អញនឹងចោកទេវបុត្រ៤នេះយកផ្កាឱ្យបាន នេះហើយជាផលនៃមុសាវាទដែលអ្នកត្រូវតែទទួលលុះតិះដៀលរួចហើយ ក៏យកឆ្នួតផ្កានោះចេញពីក្បាលបុរោហិត ទើបត្រឡប់ទៅទេវលោកវិញ។

********

# ២១. រឿងសាធិនរាជ

(ចាក សា. ប.)

(ការមិនប្រមាទ ជាកំពូលនៃកុសលក្នុងលោក)

កាលកន្លងទៅហើយ ព្រះបរមពោធិសត្វរបស់យើង កើតជាស្តេចព្រះនាមសាធិន សោយរាជ្យសម្បត្តិ នៅនគរមិថិលា ព្រះអង្គបានសាងសាលាទាន៦ខ្នង ហើយតែងបរិចាគព្រះរាជទ្រព្យ៦សែនរៀងៗរាល់ថ្ងៃ ឱ្យជាទានដល់ស្មូមយាចកទាំងឡាយ ព្រមទាំងបានរក្សានិច្ចសីល នឹងឧបោសថសីលតាមកំណត់នៃឧបោសថកាល ឯជនអ្នកនៅក្នុងនគរមិថិលានោះ ជាអ្នកឋិតនៅក្នុងឱវាទរបស់ព្រះអង្គ បានធ្វើបុណ្យ ឱ្យទានតាមកំលាំងសទ្ធានឹងធនធាន លុះស្លាប់ទៅបានទៅកើតក្នុងទេវលោកទាំងអស់គ្នា។ ពេលមួយពួកទេវតានោះបានទៅប្រជុំនៅនាសុធម្មទេវសភា ពោលសរសើរគុណមានសីល នឹងអាចារៈជាដើមរបស់ព្រះរាជាសាធិន។ ឯទេវបុត្រទេវធីតាក្រៅពីនោះ លុះឮពាក្យសរសើរមិនដាច់ដូច្នោះ ក៏ចង់ឃើញព្រះបាទសាធិនគ្រប់ៗគ្នា។ សម្តេចព្រះអមរិន្ទ្រាធិរាជ ទ្រង់ជ្រាបចិត្តទេវបុត្រ ទេវធីតាទាំងនោះ ក៏បង្គាប់មាតលីទេវបុត្រ ឱ្យយកវេជយន្តរថទៅទទួលព្រះបាទសាធិននោះមកកាន់ទេវលោក។ កាលមាតលីទៅទទួលយកមកដល់ ពពួកទេវតាទាំងនោះ ព្រមទាំងព្រះឥន្ទមានចិត្តរីករាយជាមហិមា បានក្រោកទទួលព្រះអង្គគ្រប់ៗរូប។ គួរឱ្យស្ញើចដល់ព្រះហឫទ័យ នៃសម្តេចព្រះកោសីណាស់ ពេលដែលសាធិនពោធិសត្វទៅដល់ ក៏ព្រះអង្គប្រទានទេវនគរ. ស្រីអប្សរ២កោដិកន្លះ

នឹងវេជយន្តប្រាសាទ ដល់ព្រះពោធិសត្វពាក់កណ្តាល។ កាលព្រះពោធិសត្វគង់សោយទិព្វសម្បត្តិ នៅទេវលោកនោះបើរាប់ជាឆ្នាំមនុស្សយើងបាន៧រយឆ្នាំ។ ពេលនោះព្រះពោធិសត្វ បានសោយសម្បត្តិគ្រប់៧រយឆ្នាំ(មនុស្ស) ក៏មានសេចក្តីអផ្សុកអប្សាន្តក្នុងទេវលោកជាពន់ពេក ទើបប្រាប់ដំណឹងនោះដល់សក្កទេវរាជៗ ក៏បង្គាប់ឱ្យមាតលីនាំព្រះអង្គត្រឡប់មកកាន់ក្រុងមិថិលាវិញ ឱ្យទ្រង់ចុះក្នុងឧទ្យាន ទើបវិលទៅកាន់ទេវលោក។ កាលឧយ្យានបាលឃើញព្រះអង្គ ហើយមានសេចក្តីសង្ស័យជាពន់ពេក ទើបបង្គំសួរសព្វគ្រប់បានដឹងសេចក្តីហើយក៏ទៅទូលព្រះបាទនារទៈ។ ឯព្រះបាទនារទៈជាព្រះរាជនត្តាទួតទី៧របស់ព្រះអង្គ។ ព្រះពោធិសត្វពោលប្រាប់ព្រះចៅនារទៈនោះថា នែបា! យើងឥតត្រូវការដោយរាជសម្បត្តិនេះទេ ដែលយើងមកនេះប្រាថ្នាធ្វើបុណ្យតែម្យ៉ាង ដោយយើងខានធ្វើបុណ្យអស់៧រយឆ្នាំហើយ។ ព្រះចៅនារទៈក៏ពោលថាប្រពៃហើយព្រះអង្គ ទើបចាត់ចែងមហាទានថ្វាយដល់ព្រះបរមពោធិសត្វ។ ព្រះបរមពោធិសត្វ ទ្រង់ចំណាយឱ្យទានស្មូមយាចកអស់មួយសប្តាហ៍ ដល់ថ្ងៃទី៧ ទ្រង់ក៏សោយទិវង្គតទៅ កើតនៅនាពិភពត្រៃត្រិង្សហោង។

********

# ២២. រឿងគោបាលមាតាធេវី

(ចាក អ. ឯ.)

(សាបព្រោះពូជក្នុងស្រែល្អ តែងបានផលតាមគាប់ចិត្ត)

មាននិគមមួយឈ្មោះគេលនាឡិ ចិតនៅក្បែរផ្លូវទៅកាន់ក្រុងឧជ្ជេនី នៅក្នុងនិគមនោះ មានធីតាសេដ្ឋីពីរនាក់ ម្នាក់ជាស្ត្រីកំសត់ទុគ៌ត ពេលឥតពីមាតាបិតាទៅ នៅអាស្រ័យនឹងមេដោះ តែជាស្ត្រីមានសភាពសមរម្យ មានសក់វែងជាងស្ត្រីទាំងឡាយដទៃ កំណត់នាមថា ទីឃកេសវតី ឬកេសវតី ម្នាក់ទៀតជាស្ត្រីឥតមានសក់តែមានសម្បត្តិ មានឈ្មោះថា និក្កេសី។ គ្រានោះឯងព្រះមហាកច្ចាយនត្ថេរ មានបំណងនឹងសំដែង នូវការឧប្បត្តិឡើងនៃព្រះអរហន្តសម្មុទ្ធបរមគ្រូ ប្រោសព្រះចៅចណ្ឌប្បជ្ជោត មួយអន្លើនឹងភិក្ខុ៧អង្គនិមន្តទៅឧជ្ជេនីនគរ លុះទៅដល់គេលនាឡិនិគមក៏ចូលទៅបិណ្ឌបាត្រក្នុងនិគមនោះតែឥតបានអ្វីសោះ។ នាងកេសវតីសេដ្ឋីធីតាដឹងរឿងរ៉ាវនោះ ក៏បង្គាប់ឱ្យមេដោះទៅនិមន្តព្រះថេរទាំងនោះ មកគង់ក្នុងផ្ទះ។ លុះព្រះថេរៈនិមន្តមក នាងកេសវតីបានចូលទៅក្នុងបន្ទប់ហើយកាត់សក់ខ្លួន បញ្ជានមេដោះនោះឱ្យទៅកាន់សំណាក់នាងនិក្កេសីដោយពាក្យថា ម្នាលនាង ចូរនាងយកសក់ទាំងឡាយនោះទៅឱ្យនាងនិក្កេសី, បើនាងនិក្កេសីឱ្យវត្ថុអ្វី ចូរនាងទទួលយកមក, យើងនឹងឱ្យទានដល់លោកម្ចាស់ទាំងឡាយ។ មេដោះ ក៏យកសក់នោះទៅឱ្យនាងនិក្កេសីៗបានឱ្យប្រាក់៨កហាបណៈមកវិញ ទើបមេដោះយកប្រាក់នោះទៅឱ្យនាងកេសវតីៗ បានយកប្រាក់នោះចាត់ចែងចង្ហាន់

បិណ្ឌបាតដល់ព្រះថេរៈ៨អង្គ លៃបាន១កហាបណៈ១អង្គ ទើបចូលទៅនៅក្នុងបន្ទប់នាងវិញ។ ព្រះមហាកច្ចាយនៈជ្រាបរឿងនោះ ក៏ឱ្យគេហៅនាងកេសវតីមក។ នាងមានសេចក្ដីគោរពចំពោះព្រះថេរៈ ក៏មកថ្វាយបង្គំហើយញ៉ាំងសទ្ធាមានកំលាំងឱ្យកើតឡើង។ ទានដែលបុគ្គលឱ្យចំពោះបុញ្ញខេត្តដ៏ប្រសើរ រមែងបានទទួលផលជាក់ស្ដែងក្នុងបច្ចុប្បន្ន ព្រោះហេតុនោះ បានជាសក់របស់នាងកេសវតី ដុះឡើងវិញតាមប្រក្រតីក្នុងពេលដែល នាងឱនកាយថ្វាយបង្គំព្រះថេរៈដោយគោរព។ ព្រះថេរៈទាំង៨អង្គបានចង្ហាន់ ហើយក៏ហោះតាមអាកាសវេហាស៍ ទៅចុះនៅនាឧទ្យានកាញ្ចារ៉ៃន ធ្វើភត្តកិច្ចនៅទីនោះ ឱ្យនាងកេសវតី មើលឃើញយ៉ាងស្ដែង។ នាយរក្សាឱទ្យានបានឃើញព្រះថេរៈហើយក៏ទៅក្រាបបង្គំទូលដល់ព្រះបាទចណ្ឌប្បជ្ជោត ព្រះអង្គក៏យាងទៅកាន់ឱទ្យានថ្វាយបង្គំព្រះថេរៈរួចសួរថា ថ្ងៃនេះលោកម្ចាស់បានចង្ហាន់ហើយឬនៅ? លុះព្រះសណ្ដាប់ដំណឹងដែលព្រះថេរៈពោលប្រាប់ទើបស្ដេចទៅកាន់ព្រះបរមរាជនិវេសន៍វិញ បង្គាប់ឱ្យរាជបុរសនាំនាងកេសវតីធីតាសេដ្ឋីមកតាំងជាព្រះអគ្គមហេសី ថ្ងៃនោះឯង។ ក្នុងពេលនោះតមកព្រះនាងអគ្គមហេសី នៅរួមរសមេត្រីជាមួយព្រះរាជា ក៏បានព្រះរាជបុត្រមួយព្រះអង្គថ្វាយព្រះនាមថា គោបាល. ឯនាងក៏មានព្រះនាមប្រាកដថា គោបាលទេវី តាមនាមរបស់បុត្រដែរ។

---

## ២៣. រឿងនាងរោហិណី

(ចាក ធ. ខុ.)

(បុណ្យរមែងសម្រេចតាមបំណងអ្នកធ្វើ ដែលខានតាំងប្រាថ្នា)

មានសេចក្ដីដំណាល ព្រះអនុរុទ្ធដ៏មានអាយុ បាននាំភិក្ខុជាបរិវារ ៥០០រូប និមន្ដទៅកាន់កបិលវត្ថុបុរី។ ពេលនោះញាតិវង្សជ្រាបថា ព្រះថេរៈនិមន្ដមក ក៏នាំគ្នាមកថ្វាយបង្គំ ចាត់តែនាងរោហិណីជាប្អូនបង្កើតមិនឃើញមកថ្វាយបង្គំ។ ព្រះថេរៈក៏សួររំពឹងបានជ្រាបដោយព្រះញាតិវង្សប្រាប់ថា នាងមានសេចក្ដីអៀនខ្មាស់ជាពន់ពេក ព្រោះកើតរោគសើរស្បែក(ស្រែង) បានជាមិនមក។ ព្រះថេរៈក៏បង្គាប់ឱ្យគេហៅមក. កាលបើនាងមកដល់ហើយថ្វាយបង្គំព្រះថេរៈដោយគោរព លោកសួរថា ហេតុអ្វីបានជានាងមិនមក? នាងទូលតាមអាការៈនៃសេចក្ដីអៀនខ្មាស់ចំពោះថេរៈៗ ក៏សួរបន្ដទៅទៀតថា ចុះក្រែងនាងមិនចង់ធ្វើបុណ្យទេឬ? ឱ្យខ្ញុំព្រះករុណាធ្វើបុណ្យអ្វី? ចូរនាងសាងអាសនសាលាមួយទៅ។ នាងថាចុះខ្ញុំព្រះករុណាបានអ្វីធ្វើ? ព្រះថេរៈសួរថា ចុះនាងមានគ្រឿងបសាធនភណ្ឌដែរឬ? នាងឆ្លើយថាមាន។ បើដូច្នោះចូរនាងលក់របស់នោះ យកប្រាក់មកសង់សាលាចុះ។ នាងសួរថា បាននរណាគេជួយសង់ឱ្យខ្ញុំព្រះករុណា? ព្រះថេរៈក៏និយាយអង្វរក្រុមញាតិដែលនៅអង្គុយជិតថា សូមឱ្យជួយធ្វើអាសនសាលានាងរោហិណីផង អាត្មានឹងជួយឧបត្ថម្ភក្នុងកិច្ចកសាងនេះដែរ។ ឯក្រុមញាតិ គេមានសេចក្ដីអាណិតនាងរោហិណីនេះណាស់ នឹងគោរពតាមពាក្យអង្វរនៃព្រះថេរៈផង ក៏ជួយ

ធ្វើដោយស្មោះស្ម័គ្រ។ ព្រះថេរៈបានឱ្យគេទៅនាំទឹកសម្ភារៈ សម្រាប់ការកសាងនេះ ហើយបង្គាប់ឱ្យធ្វើសាលានោះពីរជាន់ នឹងបង្គាប់ឱ្យនាងរោហិ-ណីជាប្អូន ថែទាំបោសសំអាតសាលា ចាប់តាំងពីពេលក្រាលរនាបរួច ព្រមទាំងឱ្យតាក់តែងអាសនៈ នឹងដងទឹកដំកល់ទុក សម្រាប់ប្រើប្រាស់លើសាលាជានិច្ចនិរន្តរ៍ កុំឱ្យអាក់ខានមួយពេលណាឡើយ។ នាងរោហិណី ក៏ទទួលធ្វើតាមបង្គាប់បងឥតមានខ្ចោះ ត្រាតែដល់រោគសើរស្បែក សះស្បើយស្រពោនថយចុះបន្តិចម្តងៗ ដោយអំណាចនៃបុញ្ញកម្មដែលនាង បានបោសសំអាតសាលាជាដើម។ ថ្ងៃមួយនាងបានចាត់ចែងទានដ៏ថ្លៃថ្លា ប្រគេនដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន លើអាសនសាលារបស់នាង។ លុះព្រះបរមគ្រូសម្រេចភត្តកិច្ចហើយ ទ្រង់ត្រាស់សួរព្រះអនុរុទ្ធថា ហៃអនុរុទ្ធ អ្នកណាជាម្ចាស់ទាននេះ ព្រះអនុរុទ្ធទូលថា បពិត្រព្រះមានជោគ នាងរោហិណី ជាប្អូនស្រីខ្ញុំព្រះអង្គជាម្ចាស់ទាននេះ។ ចុះនាងនៅឯណា? បពិត្រព្រះអង្គនាងនៅក្នុងផ្ទះ។ ព្រះអង្គក៏ត្រាស់ឱ្យព្រះអនុរុទ្ធហៅនាងមក តែមិនមក, ទើបទ្រង់ត្រាស់ហៅផ្ទាល់ព្រះអង្គ ត្រាតែនាងមក ក៏ទ្រង់សួរថា នាងរោហិណី! ហេតុអ្វីបានជានាងមិនមក? នាងទូលថា ខ្ញុំព្រះអង្គមានសេចក្តីអៀនខ្មាស់ណាស់ព្រោះតែកើតរោគសើរស្បែក។ រោគនេះកើតដល់នាង តើនាងដឹងថាកើតឡើងដោយហេតុអ្វី? នាងទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនដឹងសោះ។ ព្រះអង្គត្រាស់ថា រោគសើស្បែកកើតឡើង ដោយសេចក្តីក្រោធ។

នាងក៏សួរបុព្វកម្ម ដែលខ្លួនកសាងពីបុរេជាតិ ចំពោះព្រះអង្គ។ ត្រាស់ថា:

ក្នុងកាលពីព្រេងព្រឹទ្ធយូរយាណាស់មកហើយ នាងបានជាអគ្គមហេសីនៃព្រះចៅក្រុងពារាណសី។ ក្នុងចំណោមស្រីស្នំស្រីង្គារទាំងអស់ជាព្រះរាជបរិវារ មានស្រីរបាំម្នាក់មានរូបល្អស្រស់បស់ជាទីគាប់ព្រះទ័យព្រះរាជា ទ្រង់បានរួមរសមេត្រីសេចក្ដីស្នេហាតាមភាពនៃបុថុជ្ជនជានិច្ចកាល ឥតមានប្រែព្រះទ័យទៅស្នេហាលើរូបនាងជាអគ្គមហេសី ឬស្រីស្នំឯទៀតឡើយ ម្ល៉ោះហើយអគ្គមហេសី ក៏មានសេចក្ដីប្រចណ្ឌច្រណែនឈ្នានិះចងគំនុំនឹងស្រីរបាំនោះថា អញនឹងធ្វើហងឱ្យមានសេចក្ដីទុក្ខលំបាកជាមិនខាន លុះគិតដូច្នេះក៏បង្គាប់ឱ្យស្រីស្នំទ្ធស្នាលមួយរូបយកខ្ទែរមក ទើបនាងលបគោះលំអិតខ្ទែរដាក់លើដំណេកនាងរបាំនោះ ពេលគោះហើយ ក៏ចូលទៅរកនាងរបាំប្រឡែងគ្នាលេង ធ្វើហាក់ដូចជាមានសេចក្ដីរាប់រកណាស់ ហើយគោះលំអិតខ្ទែរដាក់លើសរីរៈនាងទៀត។ នាងរបាំក៏ខ្វាខ្វាំសរីរៈនោះដរាបដល់ដោលឡើងជាពកតូចពកធំ. នាងរត់ទៅប្រះខ្លួនលើដំណេក ក៏ស្រាប់តែរមាស់ជាក្រៃលែងដោយមានលំអិតខ្ទែរនៅលើទីនោះឯង។ អគ្គមហេសីក្នុងកាលនោះ បានមកកើតជានាង(រោហិណី)ហ្នឹង។ លុះសំដែងបុព្វកម្មចប់ ហើយសម្ដេចព្រះដ៏មានបុណ្យត្រាស់ព្រះពុទ្ធដីកាតទៅទៀតថា ម្នាលនាងរោហិណី នាងបានធ្វើកម្មយ៉ាងនេះឯង ព្រោះហេតុនោះ សេចក្ដីក្រោធស្នូម្បីតែបន្តិចក្ដី សេចក្ដីប្រ

ណែនក្តីនាងមិនគួរធ្វើទេ។ ចប់ព្រះធម៌ទេសនាកាលណា នាងរោហិណីក៏បានសម្រេចសោតាបត្តិផលក្នុងពេលនោះ នឹងមានសរីរៈស្អាតបាតសមរម្យល្អដូចជាមាសទឹកដប់ លុះអស់អាយុពីលោកនេះទៅ បានទៅកើតក្នុងឋានតាវតឹង្ស ជាចន្លោះដែនទេវបុត្រទាំង៤អង្គ មានរូបរាងល្អផ្ញើមគួរជាទីចាប់ចិត្តនៃទេវបុត្រទាំងនោះជាពន់ពេក។ ព្រោះតែរូបនាងធើតយ៉ាងនេះបានជាទេវបុត្រទាំង៤មានចិត្តប្រតិព័ទ្ធជាអស្ចារ្យ ផដែកតវ៉ាគ្នា ដណ្តើមយកនាងធ្វើជាអគ្គមហេសីរៀង១ខ្លួន តែមិនដាច់ស្រាច់ ក៏នាំនាងរោហិណីស្ត្រីល្អផ្ញើមទៅប្តឹងសម្តេចអមរិន្ទ្រាធិរាជសូមទ្រង់កាត់សេចក្តីរកយុត្តិធម៌ឱ្យ។ ផ្ទាសទៅទៀតសម្តេចអមរិន្ទ្រាធិរាជ គ្រាន់តែទតព្រះនេត្រ ចំរូបនាងរោហិណីពេលណាក៏មានព្រះទ័យស្រឡាញ់ហួសទេវបុត្រទាំង៤អង្គ ទើបទ្រង់ត្រាស់សួរថា អ្នកទាំងឡាយមកនេះមានការអ្វី? ទេវបុត្រក៏ក្រាបបង្គំទូលពីរឿងរោហិណី ថាខ្លួនមានសេចក្តីស្រឡាញ់គ្រប់ៗគ្នា។ ព្រះឥន្ទ្រត្រាស់សួរទេវបុត្រទាំង៤ថា ចិត្តអ្នករាល់គ្នា តាំងពីឃើញរូបនាងរោហិណី កើតមានសេចក្តីស្រឡាញ់យ៉ាងណាខ្លះ? ចូរអ្នករ៉ាយរ៉ាប់សេចក្តីមកមើល។ ទេវបុត្រទី១ទូលថា ចិត្តខ្ញុំព្រះអង្គនៅមិនស្ងៀមសោះ តាំងពីឃើញរូបនាងកាលណា ចេះតែផ្ទុកផ្អើសអរភ័យជានិច្ចហាក់ដូចស្គរជ័យ ដែលនៅកណ្តាលរឿណរង្គ នៃសមរភូមិដូច្នោះ។ ទេវបុត្រទី២ទូលថា ចិត្តខ្ញុំព្រះអង្គស្រឡាញ់ នាងរោហិណីណាស់ តែងតែហូរ គ្របដណ្តប់លើរូបនាង មិនដាច់ពេលវេលាណាទេ ហាក់ដូចជាទឹក

ឈូរ[១] ដែលហូរចុះពីលើកំពូលភ្នំដូច្នោះ។ ទេវបុត្រទី៣ទូលថា ចិត្តខ្ញុំស្រឡាញ់នាងរោហិណីខ្លាំងណាស់ព្រះអង្គ សូម្បីចក្ខុទាំងគូរបស់ខ្ញុំដែល សំឡឹងនាងនោះស្ទើរតែលៀនចេញមកដូចជាភ្នែកក្តាមទៅហើយ។ ទេវបុត្រទី៤ទូលថា បពិត្រព្រះឧប្បត្តិទេវវង្ស! ចិត្តខ្ញុំព្រះអង្គតាំងពីឃើញនាងរោហិណីកាលណា មិនបានទៅហ្នឹងតាមធម្មតាទេ បេះតែឆ្លេឆ្លាចុះឡើងៗ ដូចជាកន្ទុយទង់ដែលគេលើកឡើងលើកំពូលចេតិយដូច្នោះឯង។

សម្តេចអមរិន្ទ្រាធិរាជទ្រង់ព្រះសណ្តាប់ សេចក្តីរាយការណ៍នៃសេចក្តីស្រឡាញ់ដែលមាន ចំពោះលើរូបនាងរោហិណី របស់ទេវបុត្រទាំង៤នោះចប់ហើយមានបន្ទូលថា ចិត្តអ្នករាល់គ្នាដែលស្រឡាញ់នេះ បើតាមខ្ញុំយល់ថានៅអត់ទ្រាំបាន មិនទាន់ជាខ្លាំងណាស់ណាទេ. ឯចិត្តខ្ញុំវិញ ចាប់តាំងពីឃើញរូបនាងនេះ ក៏មានសេចក្តីស្រឡាញ់ជាអស្ចារ្យ ទាំងបានប្តេជ្ញាថា បើមិនបាននាងរោហិណីនេះ ធ្វើជាអគ្គមហេសីទេ មុខជាស្លាប់ក្នុងទីនេះដោយពិត បើបានធ្វើជាមហេសី ទើបមានជីវិតរស់តទៅ បានឃើញមុខអ្នករាល់គ្នា។ ទេវបុត្រទាំងនោះបានឮព្រះបន្ទូលតប នៃសក្កទេវរាជហើយក៏ព្រមព្រៀងគ្នាលើកនាងរោហិណីថ្វាយជារង្វាន់ក៏គាប់ព្រះទ័យដល់ព្រះអង្គ ដើម្បីកុំឱ្យទ្រង់សោយព្រះទីវង្គត។ នាងរោហិណី បានឡើងឋានន្តរ ជាអគ្គមហេសី ជាទី

---

១. ទឹកដែលហូរឈូរចុះមកពីលើភ្នំ ហៅថាទឹកឈូរ. សម័យនេះនៅប្រទេសយើងក៏មានទឹកឈូរដែរ ដូចជានៅខេត្តកំពតជាដើម។

ពេញព្រះទ័យនៃព្រះឥន្ទជាពន់ពេក ទ្រង់តែងមានសេចក្ដីប្រោសប្រាណ ចំពោះបបួលទៅលេងក្នុងទីណាៗរបស់នាងជាធម្មតា មិនដែលហ៊ានហាមឃាត់ ឬប្រកែកនឹងពាក្យនោះដល់ម្ដងណាឡើយ។

ព្រោះហេតុនោះបានជាលោកសំដែងថា បុណ្យរមែងឱ្យសម្រេចប្រយោជន៍ តាមសេចក្ដីប្រាថ្នា គ្រប់កាលវេលាទាំងពួង ដូចនិទាននាងរោហិណីនេះ។

## ២៤. រឿងអ្នកផឹកសុរា

(ចាក ម. អ.)

(អ្នកប្រមឹកតែងហិនហោចទ្រព្យនឹងវិនាសប្រាណក្នុងបច្ចុប្បន្ន)

កាលកន្លងទៅហើយ ព្រះបរមពោធិសត្វរបស់យើងទ្រង់យោនយកកំណើតជាសេដ្ឋីមានទ្រព្យ៤០កោដិ កប់ទុកក្នុងផែនដី តែងបរិច្ចាកទានជាដើមដល់ស្មូមយាចកដែលមកសុំគ្រប់ច្រកល្ហក លុះពេលអស់ព្រះជន្មក៏បានទៅកើតជាសក្កទេវរាជ។ ឯសេដ្ឋីពោធិសត្វនេះមានកូនប្រុសតែមួយគត់។ បុត្រនោះលុះអំណើះពីសេដ្ឋីជាបិតាទៅ បានឱ្យគេកសាងមណ្ឌបមួយមានមហាជន ជាបរិវារចោមរោម ក្នុងពេលដែលគាត់អង្គុយផឹកសុរា។ អ្នកប្រមឹករូបនេះ តែងឱ្យទ្រព្យមួយពាន់កហាបណៈ ដល់ជនអ្នកថ្មឹកខាងល្បែងទាំងឡាយមានលោតរាំច្រៀងជាដើម តែយ៉ាងនេះជានិច្ចនិរន្តរ៍ ហើយក្លាយខ្លួនទៅជាមនុស្សម្នាក់ដែលល្មោភលេងស្រី ល្មោភផឹកស្រា ល្មោភស៊ីសាច់ ជាអ្នកមានប្រក្រតី ឋិតនៅក្នុងរោងមហោស្រព មានរាំនឹងច្រៀងជាដើម មិនយូរកាលប៉ុន្មាន ក៏វិនាសហិនហោចទ្រព្យទាំង៤០កោដិដែលជាមត៌កបិតារលីង នឹងប្រែភាពទៅជាមនុស្សទុគ៌ត មនុស្សកំព្រីកំព្រាអនាថាតែឯកឯង រកទីពឹងពុំនាក់អាស្រ័យគ្មានស្លៀកពាក់តែកំណាត់សំពត់ដែលគេបោះបោលទៅទីទាំងឡាយ មានផ្លូវផ្សារជាដើម។ សក្កទេវរាជ ដឹងរឿងរ៉ាវនោះក៏យកក្អមមួយជារបស់ សម្រាប់ឱ្យវត្ថុតាមគាប់ដល់សេចក្តីប្រាថ្នា មកឱ្យកូននោះដោយសេចក្តីអនុគ្រោះ នឹងការអាណិតពន់ពេក ហើយប្រាប់ថា ហៃហា! ក្អមនេះអាចឱ្យនូវ ទ្រព្យតាម

សេចក្ដីប្រាថ្នារបស់អ្នក ដូច្នេះអ្នកកុំប្រមាទ ដោយធ្វើក្អមឱ្យបែកឡើយ លុះប្រាប់យ៉ាងនេះហើយក៏ត្រឡប់ទៅកាន់ទេវលោកវិញ។ ចាប់ពីថ្ងៃនោះមកអ្នកប្រមឹក តែងតែបានទ្រព្យវត្ថុតាមសេចក្ដីប្រាថ្នាពីក្អមនោះ ហើយចែកចាយទិញស្រាមកផឹកដរាបដល់ស្រវឹងជ្រុលជ្រប់ហួសប្រមាណ ក៏បោះក្អមនោះទៅលើអាកាស ហើយយកដៃទាំងពីរទ្រចាប់តែធ្វើម្ដេចអ្នកស្រវឹងមិនដែលតាំង ស្មារតីឱ្យបាននឹងនួនមួយពេលណាឡើយ ម្ល៉ោះហើយការទទួលចាប់ក្អមដែលធ្លាក់ចុះចាកអាកាសមកវិញ ក៏មិនសម្រេចដូចបំណងសោះឡើយ។ ក្អមក៏ធ្លាក់មកប៉ះនឹងផែនដីបែកខ្ទេចខ្ទីមួយពេលនោះទៅ។ ចាប់ពីថ្ងៃនោះមកអ្នកប្រមឹករូបនេះ ក៏ក្លាយខ្លួនទៅជាមនុស្សក្រម្លងទៀតទាំងឥតនរណាគេមាន សេចក្ដីអនុគ្រោះចំពោះខ្លួនឡើយ ជាមនុស្សស្លៀកពាក់ តែសំពត់រយ៉េវយ៉ៃ លិចមុខផិតក្រោយ លិចក្រោយផិតមុខ រស់នៅដោយការកាន់អំបែងដើរ សុំទានតាមច្រកល្ហកផ្ទះនៃអ្នកដទៃ យកកម្រៃដែលសុំបាននោះមកចិញ្ចឹមលៀងជីពជន្មអាត្មាមានសេចក្ដីវេទនាខ្លោចផ្សាជាមហិមា អស់ពេលមិនយូរប៉ុន្មាន ក៏វិនាសប្រាណស្លាប់អសារបង់នៅនាសំយ៉ាបផ្ទះអ្នកដទៃវិស័យ ដូចជាខ្មោចឆ្កែ គ្មានគេរាប់រកអាណិតអាសូរសោះឡើយ ព្រោះហេតុដូច្នោះ បានជាព្រះបរមសាស្ដា កាលបានត្រាស់ដឹងបរមាភិសេកសម្មាសម្ពោធិញ្ញាណ ជាឯកអគ្គសក្យមុនីសម្ពុទ្ធមកុដក្នុងត្រៃលោក បានត្រាស់សំដែងនូវគាថា[១] ទាំងឡាយថា

១. ភទ្រឃដជាតក បញ្ចមវគ្គ តិកនិបាត។

សព្វកាមទទំ កុម្ភំ កុដំ លទ្ធាន ធុត្តកោ
យាវ សោ អនុបាលេតិ តាវ សោ សុខមេធតិ។
យទា មត្តោ ច ទិត្តោ ច បមាទា កុម្ភមព្ភិទា
តតោ នគ្គោ ច បោត្ថោ ច បច្ឆា ពាលោ វិហញ្ញតិ។
ឯវមេវ យោ ធនំ លទ្ធា បមត្តា បរិភុញ្ជតិ
បច្ឆា តប្បតិ ទុម្មេធោ កុដំ ភេត្វា វ ធុត្តកោ ។

អ្នកលេងបានក្អមឈ្មោះកុម្ភៈ ដែលឱ្យវត្ថុតាមប្រាថ្នាអ្នកលេងនោះថែទាំបានត្រឹមណា ក្អមតែងនាំសេចក្ដីសុខមកឱ្យត្រឹមនោះ។ ដរាបដល់អ្នកលេងស្រវឹងនឹងភ្លើតភ្លើន ហើយបំបែកក្អមដោយសេចក្ដីប្រមាទ ក៏ក្លាយទៅជាអាក្រាតនឹងស្លៀកសំពត់សំបកឈើ ជាមនុស្សពាលតែងលំបាកក្នុងពេលក្រោយ បុគ្គលឥតប្រាជ្ញាដែលបានទ្រព្យហើយ ប្រើប្រាស់ដោយសេចក្ដីប្រមាទយ៉ាងនេះ រមែងស្ដាយក្រោយដូចជាអ្នកលេងបំបែកក្អមដូច្នោះ។

# ២៥- រឿងអាយុវឌ្ឍនកុមារ

(ចាក អ. ធ.)

(ព្រះបរិត្តអាចការពារអាយុជីវិតឱ្យរួចចាកភយន្តរាយបាន)

មានសេចក្ដីដំណាលថា នៅក្នុងទិឃលម្ពិកៈ មានព្រាហ្មណ៍ពីរនាក់បានមូលមតិគ្នាពីរៀងចេញចាកការ ក៏ចេញទៅបួសជាតាបស ប្រព្រឹត្តតបធម៌អស់៤៨ឆ្នាំ។ តាបសម្នាក់មានគំនិតថា បើអាត្មាអញនៅបួសតទៅទៀតនឹងសាបសូន្យចាកប្រពៃណីមិនខាន ដូច្នេះគួរអញសឹកទៅបន្តពូជទៅអនាគតទៀត លុះគិតដូច្នេះហើយ ក៏លក់គ្រឿងប្រដាប់ដែលខ្លួនខំធ្វើឱ្យអ្នកដទៃហើយចូលស្ដីដណ្ដឹងធីតាម្នាក់យកមកធ្វើជាភរិយា។ ការនៅរួមជាមួយមាតុគ្រាមអស់កាលមិនយូរប៉ុន្មាន ព្រាហ្មណ៍នោះក៏បានបុត្រមួយ នាំយកទៅថ្វាយបង្គំតាបសជាសម្លាញ់ដែលព្រាត់ប្រាស់គ្នាអស់ពេលដ៏យូរ ហើយទើបនឹងមកដល់។ ពេលព្រាហ្មណ៍ជាប្ដីថ្វាយបង្គំ តាបសពោលឱ្យសព្ទសាធុការថា ចូរជាអ្នកមានអាយុវែង។ ដល់វេនដែលមាតាបិតាឱ្យទារកនោះថ្វាយបង្គំ តាបសឥតមានពោលអ្វីឡើយ នៅអង្គុយស្ងៀម ទើបព្រាហ្មណ៍សួរថា លោកម្ចាស់ពេលខ្ញុំទាំងពីររូបថ្វាយបង្គំ លោកម្ចាស់ឱ្យពរថា ចូរមានអាយុវែង លុះកូនខ្ញុំថ្វាយបង្គំម្ដេចក៏លោកម្ចាស់មិនឱ្យពរផង តើមានហេតុយ៉ាងណា? ចំរើនពរកូនអ្នកឯងរស់នៅបានតែ៦ថ្ងៃទេ នឹងមានអន្តរាយចូលមកផ្ដាច់ផ្ដិលជីវិតក្នុងថ្ងៃទី៧ដោយពិត។ ចុះអ្នកណាមានឧបាយសម្រាប់ការពារអន្តរាយនេះបាន? ចំរើនពរអាត្មាគ្មានទេ បើសមណៈគោតមទើបមាន ចូរអ្នកទៅសាកសួរគឺឧ

ចាយការពារពីសមណៈនោះចុះ។ ព្រាហ្មណ៍ប្ដីប្រពន្ធក៏នាំទារកនោះទៅថ្វាយបង្គំគាល់ព្រះបរមសាស្ដា ដោយឥតគិតពីការសាបសូន្យ ចាកតប[១] ធម៌របស់ខ្លួនឡើយ ព្រោះមានការស្ដាយអាណិតចំពោះបុត្រជាពន់ពេក។ កាលព្រាហ្មណ៍ប្រពន្ធកំពុងថ្វាយបង្គំ ព្រះសាស្ដាពោលប្រទានពរថា ចូរឱ្យអ្នកមានអាយុវែង តែវេលាទារកថ្វាយបង្គំ ទ្រង់ក៏ស្ងៀម ពុំមានព្រះវាចាដូចម្ដេចឡើយ។ ព្រាហ្មណ៍មានសង្ស័យ ក៏សាកសួរតាមន័យដែលសួរតាបសជាសម្លាញ់ដែរ។ ព្រះសាស្ដាត្រាស់ថា ម្នាលព្រាហ្មណ៍ចានជាតថាគតមិនឱ្យសព្ទសាធុកាពរដល់កូនអ្នក ព្រោះកូននេះនឹងមានអន្តរាយក្នុងថ្ងៃទី៧ដោយប្រាកដ បើអ្នកចង់ឱ្យកូននេះរួចរស់ជីវិតចូរអ្នកធ្វើមណ្ឌប១ ហើយរៀបអាសនៈ៨ឬ១៦ សម្រាប់ឱ្យសាវ័ករបស់តថាគតអង្គុយចំរើនព្រះបរិត្តអស់ពេល៧យប់៧ថ្ងៃ ទើបរួចពីមរណភ័យនេះ. តើអ្នកធ្វើតាមបង្គាប់តថាគតបានឬទេ? បពិត្រសម្ដេចដ៏មានជោគ ខ្ញុំព្រះអង្គអាចធ្វើបាន តែមិនដឹងបានភិក្ខុអង្គណា ទៅអង្គុយចំរើនព្រះបរិត្ត។ ម្នាលព្រាហ្មណ៍ អ្នកកុំព្រួយ ចូររៀបចាត់ចែងអាសនៈឱ្យស្រាច់ទៅចាំតថាគតចាត់ភិក្ខុទៅឱ្យ។ ព្រាហ្មណ៍ទទួលតាមបង្គាប់ ហើយចាត់ចែងអាសនៈរួចស្រេច ក៏មកបង្គំទូលព្រះសាស្ដា។ ក៏ទ្រង់ចាត់ភិក្ខុឱ្យទៅចំរើនព្រះបរិត្ត ព័ទ្ធ

---

១. តាមធម្មតា ពួកព្រាហ្មណ៍មិនដែលថ្វាយបង្គំព្រះសាស្ដាទេ ព្រោះខ្លាចសាបសូន្យតបៈធម៌ តែដោយសេចក្ដីស្រឡាញ់កូនផ្សាយព្រហ្មវិហារធម៌មកលើកូន ទើបព្រាហ្មណ៍ប្ដីប្រពន្ធដាច់ចិត្តទៅថ្វាយបង្គំគាល់ព្រះសាស្ដា។

ជុំវិញទារកនោះអស់៧យប់៧ថ្ងៃ។ លុះដល់យប់ទី៧ទ្រង់ក៏យាងទៅផ្ទាល់ព្រះអង្គឯង ដោយមានពួកទេព្តាក្នុងចក្រវាឡទាំងមូលចោមរោមជាគិត្តិយស។

តស្មិ ទិវសេ ក្នុងថ្ងៃនោះឯង អវរុទ្ធកយក្ស ជាអ្នកបំរើព្រះបាទវេស្សវ័ណអស់១២ឆ្នាំ ក៏បានទទួលពរពីសំណាក់ព្រះបាទវេស្សវ័ណនោះថា ឱ្យចាប់ទារកនេះស៊ីក្នុងថ្ងៃទី៧ ព្រោះហេតុនោះ បានជាអវរុទ្ធយក្សមកជ្រែងនៅលើអាកាសនភាល័យ តែមិនបានឱកាសដ៏សមគួរ ដោយពេលនោះ ទេវតាមានសក្តិធំៗ នៅគាល់ព្រះសាស្តាត្រៀបត្រា ឯទេវតាតូចតាចថយឆ្ងាយពីទីនោះ១២យោជន៍។ រីអវរុទ្ធយក្ស ក៏មានស័ក្តិល្មិតដូចគេដែរ បានជាថយឈរឆ្ងាយ១២យោជន៍។ ឯព្រះសាស្តាបានទ្រង់ស្វាធ្យាយព្រះបរិត្តពេញមួយរាត្រី។ លុះថ្ងៃទី៧កន្លងផុតទៅ អវរុទ្ធយក្ស អស់សិទ្ធិនឹងចាប់ទារកនោះស៊ីបាន ក៏វិលត្រឡប់ទៅលំនៅឋានខ្លួនវិញ។ ដល់ថ្ងៃទី៨គ្រាន់តែព្រះអាទិត្យរះបំភ្លឺលោកនាបូព៌ាទិសភ្លាម ជនទាំងនោះ ក៏នាំទារកមកថ្វាយបង្គំព្រះសាស្តា ព្រះអង្គទ្រង់ប្រទានពរថា ចូរអ្នកមានអាយុវែង។ ជនទាំងនោះក៏ក្រាបបង្គំសួរថា បពិត្រព្រះគោតមដ៏ចំរើន ទារករស់នៅបានប៉ុន្មានឆ្នាំ? ម្នាលព្រាហ្មណ៍ ទារកនេះរស់នៅបាន១២០ឆ្នាំ។ ទើបជនទាំងនោះកំណត់ឈ្មោះឱ្យទារកនោះថា អាយុវឌ្ឍនកុមារ ប្រែថា កុមារមានអាយុចំរើន។

# ២៦. រឿងនាងបតិបូជិកា

(ចាក ធ. ខុ.)

(បុណ្យអាចសម្រេចផលបានតាមបំណងអ្នកធ្វើ)

រឿងរ៉ាវនេះកើតឡើងប្រាកដនៅឋានតាវតឹង្សទេវលោកឯណោះ។ សេចក្ដីថា មាលាភារីទេវបុត្រ នាំពួកស្ត្រីទេពអប្សរបរិវារកញ្ញាមួយពាន់រូបទៅក្រសាលលេងក្នុងឧទ្យាននានាឋានតាវតឹង្សនោះ។ កញ្ញាអប្សរ៥រយរូបជាអ្នកឡើងបេះផ្កា, ៥រយរូបទៀតជាអ្នករើសយកមកប្រដាប់ឱ្យទេវបុត្រ។ ពួកស្ត្រីដែលឡើងបេះផ្កាទាំងនោះ មានស្ត្រីម្នាក់រអិលធ្លាក់ចុះមករលត់ជីវិតដូចជាអណ្ដាតប្រទីប។ វិញ្ញាណនៃស្ត្រីនោះអណ្ដែតត្រសែតរករភពថ្មី បានមកកើតក្នុងត្រកូលមួយនាក្រុងសាវត្ថី ជាស្ត្រីរលឹកឃើញជាតិ ចាប់តាំងពីកើតមកហើយនឹករឿយៗថា អញជាភរិយានៃមាលាភារីទេវបុត្រ លុះដឹងក្ដីចំរើនវ័យកាលណា តែងធ្វើការបូជាដោយផ្កានឹងគ្រឿងក្រអូបជាដើម ប្រាថ្នាឱ្យកើតក្នុងសំណាក់ប្ដី(មាលាភារី)។ នាងមានអាយុ១៦ឆ្នាំ, មាតាបិតាបានប្រកបផ្ទះសំបែងឱ្យនាង(ឱ្យមានប្ដី) នាងតែងចាត់ចែងទានផ្សេងៗ មានសលាកភត្តបក្ខិកភត្ត នឹងសំពត់ចំណាំវស្សាជាដើម ថ្វាយព្រះភិក្ខុសង្ឃ ហើយពោលប្រាថ្នាថា ចំណែកបុណ្យនេះ សូមបានជាបច្ច័យនៃការកើតក្នុងសំណាក់ប្ដីរបស់ខ្ញុំ។ ភិក្ខុទាំងឡាយក៏កំណត់នាមឱ្យនាងនោះថា បតិបូជិកា ព្រោះនាងធ្វើបុណ្យកុសលអ្វីៗ តែងប្រាថ្នាប្ដីដើម(មាលាភារីទេវបុត្រ)។ នាងបតិបូជិកាតែងបោសសំអាតអាសនសាលា ដងទឹកមកដំកល់ទុក នឹងក្រាលអាសនៈជា

និច្ច សម្រាប់ព្រះភិក្ខុសង្ឃទាំងឡាយ។ មាននមនុស្សដទៃទៀតចង់ចង់ថ្វាយសលាកភត្តជាដើម ទើបនាំយកអម្រស់អម្រមានអង្ករជាដើម មកប្រគល់ឱ្យនាងហើយពោលថា ម្នាលនាង ចូរនាងចាត់ចែងវត្ថុនេះ ធ្វើជាចង្ហាន់ថ្វាយព្រះភិក្ខុសង្ឃ។ នាងក៏ចាត់ចែង ដោយចិត្តត្រេកអរជាមហិមា។ ការដើរទៅមក ជួយចាត់ចែងទាននេះ តែងបានអានិសង្សរាល់ៗជំហាន។

ថ្ងៃក្រោយនាងមានគភ៌ តាំងនៅក្នុងផ្ទៃគ្រប់១០ខែហើយ ក៏ប្រសូត្របានបុត្រមួយ។ ពេលដែលកូនច្បងទៅមកដោយជើងបាន នាងក៏មានកូនតាមលំដាប់លំដោយ៣ទៀត រួមទាំងអស់បាន៤។ នាងបតិបូជិកា តែងឱ្យទានបូជា ស្តាប់ធម៌ទេសនា រក្សាសិក្ខាបទតាមប្រក្រតី. លុះមានរោគចូរមកយាយីក្នុងសរីរកាយ ក៏ស្លាប់ទៅ បានទៅកើតក្នុងសំណាក់មាលាភារីទេវបុត្រជាប្តីរបស់នាង នៅនាឋានតាវតឹង្សដដែល។ ទេវបុត្រឃើញនាងទៅកើតដូចដើមវិញ ក៏ពោលសួរថា តាំងពីព្រឹក ម្តេចក៏មិនឃើញនាងសោះ តើនាងទៅណា? បពិត្រលោក ខ្ញុំច្យុតចាកទេវលោកនេះ។ ច្យុតទៅកើតនៅទីឋានណា? ទៅកើតក្នុងត្រកូលនាក្រុងសាវត្ថី។ ទៅកើតនៅទីនោះអស់កាលប៉ុន្មាន? តាំងពីខ្ញុំចុះចាប់បដិសន្ធិគំរប់១០ខែ ក៏ប្រសូតិ ដល់អាយុ១៦ឆ្នាំ មាតាបិតាខ្ញុំលោកឱ្យមានប្តី. ខ្ញុំទៅនៅរួមមគ្គសំវាសជាមួយប្តីបានកូន៤ ហើយតែងធ្វើបុណ្យឱ្យទាន ប្រាថ្នាឱ្យមកកើតក្នុងសំណាក់លោកវិញ។ មនុស្សទាំងឡាយមានអាយុប៉ុន្មានឆ្នាំ? ត្រឹមតែមួយរយ(១) ឆ្នាំប៉ុណ្ណោះ។ មនុស្សទាំងឡាយមានអាយុមួយ

រយឆ្នាំនេះ សុទ្ធតែជាអ្នកដេកលក់ដោយសេចក្ដីប្រមាណ ឬក៏មានធ្វើបុណ្យទានអ្វីដែរ? មនុស្សទាំងអស់សុទ្ធតែមានសេចក្ដីប្រមាទជានិច្ច ព្រោះប្រកាន់ថា អាយុមួយរយនេះ ហាក់ដូចជា១អសង្ខេយ្យផង ហាក់ដូចជាមិនចេះចាស់មិនចេះស្លាប់ផង។ មាលាភារីទេវបុត្រមានសេចក្ដីសង្វេគកើតឡើងក្នុងចិត្តជាអស្ចារ្យ លាន់វាចារថា ឱហ្ន៎? មនុស្សទាំងឡាយសុទ្ធសឹងតែជាអ្នកលិចលង់ក្នុងការប្រមាទ តើអង្កាល់ណាទើបផុតពីសេចក្ដីទុក្ខបាន។

---

១. អាយុមួយរយឆ្នាំនេះ គិតតាមជំនាន់ពុទ្ធកាល។ ឯអាយុមនុស្សសម័យនេះ តែងថយចុះជានិច្ច គឺគិតតាមសាសនា។ បើសាសនាកន្លងទៅបានមួយរយឆ្នាំ អាយុមនុស្សក៏ថយចុះមួយឆ្នាំជាលំដាប់ដែរ។

# ២៧. រឿងឧបាសកសាងមេបុណ្យ

(ចាក អ. មណិ.)

(សាធារណទានចាត់ជាមេបុណ្យយ៉ាងឆ្នើមក្នុងលោក)

ក្នុងក្រុងសាវត្ថី មានឧបាសកម្នាក់បានធ្វើផ្លូវឱ្យរៀបស្មើ រើសបន្លាកាប់ផ្ការគុម្ពឈើតូចតាចក្នុងផ្លូវសម្រាប់ឱ្យពួកភិក្ខុនៅក្នុងព្រៃ មកបិណ្ឌបាត្រក្នុងស្រុកបានស្រួល ចងស្ពានលើប្រឡាយក្នុងពេលមានទឹក ដាំឈើយកម្លប់ក្នុងទីវាលស្រឡះ បាជីស្តឹកចេញពីស្រែ ធ្វើឱ្យបានជំនឹងជ្រៅ រៀបចំកំពង់ទឹកឱ្យបានស្រួលបួលល្អ នឹងឱ្យទានតាមសមគួរដល់សម្បត្តិរបស់ខ្លួន ព្រមទាំងបាន រក្សាសីលដោយត្រឹមត្រូវ។ ចំណេរកាលមកខាងក្រោយ ឧបាសកនោះក៏ស្លាប់ទៅ បានទៅកើតក្នុងវិមានមាសកំពស់១២យោជន៍ នាឋានតាវតឹង្សទេវលោក ថ្ងៃក្រោយ ព្រះមហាមោគ្គល្លានមានឫទ្ធិច្រើន បានថ្វាយបង្គំលាព្រះបរមសាស្តាជាម្ចាស់ ដើម្បីទៅកាន់តាវតឹង្សទេវលោក ប្រយោជន៍នឹងពិនិត្យហេតុការណ៍ ក្នុងទីឋាននោះ លុះទៅដល់មុខប្រាសាទ ក៏ទេវបុត្រនោះចុះមកថ្វាយបង្គំ លោកសួរដោយបទព្រះគាថាទាំងឡាយថា:

វិមាននេះមានសសរជាវិការៈនៃកែវមណី ខ្ពស់ឡើងទៅលើ១២យោជន៍ដោយជុំវិញ, កូដាគារដ៏ធំទូលាយទាំង៧រយ មានសសរជាវិការៈនៃកែវពៃទូរ្យ ក្រាលដោយបន្ទះក្តាររុងរឿងប្រពៃ, អ្នកនៅ, ផឹកនឹងទំពារស៊ីក្នុង វិមាននេះ ទាំងពិណទាំងឡាយដ៏ជាទិព្វ មានសម្លេងពិរោះក៏លាន់ឮឯង, កាមគុណដ៏ជាទិព្វទាំង៥ក៏មាននៅទីនេះ មានទាំងនារីទាំងឡាយប្រដាប់ ដោយគ្រឿង

អម្ពពស្រ្តាលង្ការណ៍ជាវិការៈនៃមាសក៏មានភាំ, ពណ៌សម្បុរអ្នករុងរឿងយ៉ាង នេះ សម្រេចដោយអានិសង្សដូចម្តេច? ផលសុចរិតដែលសម្រេចដល់អ្នកក្នុង វិមាននេះ តើដោយអានិសង្សដូចម្តេច? ទាំងភោគៈ ទាំងឡាយជាទីពេញ ចិត្ត ក៏កើតប្រាកដ។ ម្នាលទេវបុត្រ អាត្មាសួរអ្នកមានអានុភាពច្រើន កាលអ្នក កើតជាមនុស្សបានធ្វើបុណ្យដូចម្តេច? អ្នកមានអានុភាព ដ៏រុងរឿងយ៉ាងនេះ តើដោយបុណ្យដូចម្តេច? ទាំងពណ៌សម្បុរ អ្នកក៏ផ្សាយ ទៅគ្រប់ទិស។

ទេវបុត្រទូលថា:

កាលខ្ញុំកើតជាមនុស្ស បានជម្រះផ្លូវក្នុងព្រៃផង បានដាំឈើធ្វើជាសួន ច្បារផង មានចិត្តស្រឡាញ់អ្នកមានសីលផង មានចិត្តជ្រះថ្លាឱ្យបាយទឹកដោយ គោរពនឹងពោរពាសផង។ ខ្ញុំមានពណ៌សម្បុររុងរឿងមានផលសុចរិតសម្រេច នៅក្នុងវិមាននេះ នឹងភោគៈទាំងឡាយជាទីពេញចិត្តកើតឡើងប្រាកដ ដោយ ផលបុណ្យនេះឯង។ ខ្ញុំមានអានុភាពរុងរឿងមានពណ៌សម្បុរ ផ្សាយទៅសព្វ ទិសដោយផលបុណ្យនេះឯង។ ការដាំដើមឈើសួនច្បារ ជីកស្រះ អណ្តូង សង់ស្ពានថ្នល់ ជាដើម ដាក់ទានជាសាធារណ៍ ឈ្មោះថា បានសាងមេបុណ្យ សម្រាប់បន្តជីវភាពទៅបរលោក ព្រោះថាទានសាធារណ៍ ដែលបានចាត់ចែង ធ្វើឡើងនេះ បើមានអ្នកណាមួយចូលទៅប្រើប្រាស់ កាលណាទោះយប់ក្តី ថ្ងៃក្តី អ្នកម្ចាស់តែងបានទទួលអានិសង្សតាមលំដាប់វារៈ នៃអ្នកចូលទៅប្រើ ប្រាស់នោះដែរ ហេតុដូច្នោះបានឱ្យឈ្មោះថា មេបុណ្យ។

---

# ២៨~ រឿងមល្លិកាទេវី

(ចាក អ. កុម្មា.)

(ព្រះសម្ពុទ្ធជាមហន្តាកុសលក្ខេត្ត របស់ទាយកទាយិកា)

ជំនាន់ពុទ្ធកាល នៅក្រុងសាវត្ថី មានស្ត្រីមួយរូបអាយុ១៦ឆ្នាំ មានរូបល្អល្អះ ជាធីតានៃនាយមាលាការ។ ពេលមួយនាងធីតានោះយកនំ៣មកដាក់ក្នុងប្រែងសម្រាប់ដាក់ផ្កា ដើរទៅកាន់សួនច្បារ បានជួបនឹងព្រះបរមសាស្តាព្រមទាំងភិក្ខុសង្ឃជាបរិវារ កំពុងនិមន្តចូលទៅកាន់ក្រុង ដើម្បីបិណ្ឌបាត។ នាងមានចិត្តត្រេកអរណាស់ បានយកនំទៅដាក់បាត្រព្រះអង្គ ហើយថ្វាយបង្គំដោយសេចក្តីជ្រះថ្លាពន់ពេក ទើបថយមកឈរក្នុងទីដ៏សមគួរ។ ព្រះបរមសាស្តាទ្រង់រមិលមើលនាងដោយព្រះភក្ត្រញញឹម ទើបព្រះអានន្ទក្រាបបង្គំសួរនូវហេតុដែលទ្រង់ញញឹមនោះ។ ព្រះអង្គតបថា ម្នាលអានន្ទ នាងកញ្ញានេះនឹងបានជាអគ្គមហេសីនៃព្រះចៅបសេនទិកោសលក្នុងថ្ងៃនេះឯង ដោយអំណាចផលទានដែលនាងបានប្រគេននំនេះដល់តថាគតនេះ ហើយទ្រង់យាងចៀសចេញទៅ។ ជួនជាថ្ងៃនោះ ព្រះបាទបសេនទិកោសលទ្រង់ចេញច្បាំងតគ្នានឹងព្រះបាទអជាតសត្រូវជាព្រះភាគិនេយ្យ ហើយទ័ពព្រះអង្គបរាជ័យរត់ចេញមក ឯព្រះអង្គទ្រង់ប្រថាប់លើព្រះទីនាំងអាជានេយ្យបរចេញពីទីនោះដែរ ទ្រង់ព្រះសណ្តាប់សំឡេងច្រៀងរបស់នាងកញ្ញា ដែលបេះផ្កាបណ្តើរច្រៀងបណ្តើរក៏មានព្រះទ័យប្រតិព័ទ្ធស្នេហា ទើបទ្រង់យាងចូលទៅក្នុងសួនបានជ្រាបថា នាងមិនទាន់មានប្តី ទ្រង់ក៏បង្គាប់ឱ្យនាងឡើងជិះលើខ្នងសេះ

ចាប់ពួកយើង គប្បីលើកកន្ទុយឡើងលើ សំយុងក្បាលចុះក្រោម ហើយ វលាក់ដុំថ្មចេញពីមាត់ទើបចាប់បាន។ (អាថ៌កំបាំងរបស់ខ្លួនបុគ្គលមិនគួរប្រាប់ ដល់អ្នកដទៃ ក្រៅពីមាតាបិតាឡើយ)។ គ្រាន់តែនាគរាជចេញទៅផុត ស្ដេច គ្រុឌមកដល់ភ្លាមទើបអចេលរៀបរាប់ប្រាប់តាំងពីដើមដល់ចុងចប់។ ស្ដេចគ្រុឌ ឮពាក្យនោះហើយ ក៏ទៅចាប់នាគរាជក្នុងថ្ងៃនោះឯង. ចាប់កន្ទុយលើកឡើង ឱ្យឱ្យសំយុងក្បាលចុះក្រោម វលាក់ដុំថ្មចេញពីមាត់ ហើយស្ទុះហោះលឿន លយលើអាកាសនភាល័យ។ នាគរាជក៏យំរៀបរាប់ថា អញសំយុងក្បាលចុះ ក្រោមនេះ ព្រោះតែមិនរក្សាអាថ៌កំបាំងរបស់ខ្លួន, ឱ! បុគ្គលទ្រុស្តសីល ម្ដេច ក៏អ្នកនិយាយកុហកហើយនាំយកសេចក្ដីទុក្ខមកឱ្យខ្ញុំនឹងញាតិមិត្ត។ ស្ដេចគ្រុឌ ពោលតិះដៀលស្ដេចនាគនោះថា ក្រែងអ្នកប្រាប់អាថ៌កំបាំងរបស់ខ្លួន ដល់ អចេល ឬម្ដេចក៏ឥឡូវនេះ យំសោយសោកប្រាថ្នារកប្រយោជន៍អ្វី? ដោយ សេចក្ដីអង្វរសុំជីវិតខ្លាំងពេក ស្ដេចគ្រុឌក៏ទុកជីវិតឱ្យស្ដេចនាគនោះ។ ចាប់ពី ពេលនោះមក សត្វទាំងពីរក៏ព្រមព្រៀងយកគ្នាជាសម្លាញ់ មិនដែលប្រេះ ឆាសាមគ្គីរវាងមិត្តម្ដងណាឡើយ។ ឯនាគរាជខឹងនឹងអចេលណាស់ ហើយ ពោលតិះដៀលជាច្រើនប្រការ ទើបពោលគាថាដែលមានក្នុងបណ្ឌកជាតក តិសនិបាត ដាក់សម្បថឱ្យអចេលនោះថា:

អទុដ្ឋស្ស តុវំ ទុព្ភិ ទុព្ភី ច បិសុណោ
ចសិ ឯតេន សច្ចវជ្ជេន មុទ្ធា តេ ផលតុ សត្តធា។

នែមនុស្សទ្រុស្តមិត្ត!  ឯងទ្រុស្តនឹងញុះញង់បុគ្គលដែលមិនទ្រុស្តតប. ដោយពាក្យសព្វនេះ សូមក្បាលអ្នកឯងបែកជា៧ចំណែក។

ក្បាលអចេលក៏បែកជា៧ភាគនៅចំពោះមុខនាគរាជនោះ ទើបផែនដីបើកចន្លោះត្រង់អចេលនោះអង្គុយ ឱ្យអចេលនោះចូលទៅកើតនៅក្នុងនរកអវិចី ដោយទោសសមុសាវាទ។

## ៣១_ រឿងស្រីកំសត់

(ចាក អ. ឧ.)

(បុរសច្រើនតែភ្លក នឹងរូបស្រ្តីព្រោះកាមភោគ)

កាលកន្លងទៅហើយមានស្រីកំសត់ម្នាក់ នៅក្នុងក្រុងពារាណសី បាន ឃើញពួកស្រ្តី ដែលមានបុណ្យស្លៀកពាក់សំពត់ពណ៌ក្រហមដូចផ្កាសិរមាន់ ក៏ ចង់ស្លៀកដូចគេ ទើបចូលសារស័ព្ទប្រាប់មាតាបិតាៗពោលប្រាប់ថា ហៃកូន យើងជាមនុស្សទីទ័លក្រ តើនឹងបានសំពត់បែបនោះពីណាមកស្លៀក។ នាង ធីតាពោលថា បពិត្រលោកឪពុកលោកម្ដាយ! បើដូច្នោះ កូនសុំទានអនុញ្ញាត ទៅស៊ីឈ្នួលគេដែលជាអ្នកមានសម្បត្តិស្ដុកស្ដម្ភ។ កាលមាតាបិតាយល់ព្រម ហើយ នាងក៏ចូលទៅសុំអ្នកមានម្នាក់ដើម្បី ស៊ីឈ្នួលយកសំពត់ពណ៌ក្រហម ផ្កាសិរមាន់នោះ។ ឯត្រកូលនោះគេប្រាប់ថា បើនាងនៅធ្វើការឱ្យយើង គំរប់ ៣ឆ្នាំ ទើបបានសំពត់បែបនោះ។ នាងក៏សុខចិត្តហើយខំធ្វើការងារ បីដូច ជារបស់ខ្លួនមិនទាន់គ្រប់៣ឆ្នាំផង ដោយជនជាម្ចាស់នោះមានសេចក្ដីអាណិត អាសូរជាខ្លាំង ក៏ឱ្យសំពត់ពណ៌ក្រហមនោះនឹងសំពត់ដទៃទៀត ដល់នាង នោះ។ នាងបានសំពត់ហើយ ក៏លាជនជា ចៅហ្វាយនាយត្រឡប់ទៅផ្ទះ មាតាបិតា លុះបានដល់ពាក់កណ្ដាលផ្លូវ ក៏ចុះងូតទឹក ហើយដាក់សំពត់នោះ លើច្រាំង។ ខណៈនោះ សាវកព្រះកស្សបសម្មាសម្ពុទ្ធមួយអង្គ ចោរលួចយក ចីវរអស់ លោកស្លៀកដណ្ដប់បិទបាំងរាងកាយដោយសម្បកឈើ និមន្តមក ដល់ទីនោះ។ គួរឱ្យសរសើរដល់ចិត្តនាងណាស់. កាលព្រះថេរៈនិមន្តមក

ដល់នាងបានឃើញហើយ ក៏កើតសេចក្តីសង្វេគថា ឱហ្ន៎ លោកម្ចាស់អង្គនេះច្បាស់ជាចោរលួចយកចីវរហើយបានជាស្អៀក ដណ្តប់សំពត់សំបកឈើដូច្នេះ ម្យ៉ាងទៀតអញដែលក្រសំពត់ស្លៀកនេះក៏មក តែពីជាតិមុនមិនបានឱ្យដល់ស្រមណ៍កំណោរព្រាហ្មណ៍ ឬស្មូមរូបណាសោះ ដូច្នេះគួរអញលះចោលសេចក្តីកំណាញ់ក្នុងពេលនេះឱ្យបាន លុះគិតដូច្នេះហើយ ក៏ហែកសំពត់នោះត្រង់ពាក់កណ្តាល ប្រគេនមួយចំណែកដល់ព្រះថេរៈអង្គនោះ។ ព្រះថេរៈ ក៏និមន្តចូលទៅទីកំបាំង ហើយផ្លាស់សំពត់សំបកឈើនោះចោល ស្លៀកដណ្តប់រួចនិមន្តចេញមកវិញ។ ឯសរីរៈរបស់លោក ដែលបានស្លៀកដណ្តប់សំពត់ពណ៌ក្រហម ក៏រុងរឿងមានពន្លឺឱភាសផ្សាយ ចេញពីរាងកាយតែមួយបែបវិស័យដូចព្រះទិនករ ដែលទើបនឹងរះផុតចុងព្រឹក្សា។ នាងឃើញហើយអរណាស់នឹកក្នុងចិត្តថា លោកម្ចាស់របស់អញ ពេលមុនមិនសូវសមរម្យសោះ ឥឡូវល្អណាស់រុងរឿងណាស់ ដូចព្រះអាទិត្យទើបនឹងរះដូច្នេះអញនឹងប្រគេនសំពត់ផ្ទាំងទីពីរនេះទៀត ហើយក៏ប្រគេន ចំណែកទីពីរនោះដល់ព្រះថេរៈតាំងប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចំរើនដោយអំណាចនៃទាននេះ ខ្ញុំម្ចាស់បានកើតក្នុងភពណាក៏ដោយ សូមឱ្យមានរូបល្អធ្មើម. បើបុរសណាបានឃើញហើយ សូមកុំឱ្យទប់ចិត្តបាន ម្យ៉ាងទៀត ជាតិស្រីដូចគ្នាក្នុងលោកនេះសូមកុំឱ្យស្រីណាមួយមានរូបល្អផ្តាច់ខ្ញុំម្ចាស់បានឱ្យសោះ។ ព្រះថេរៈធ្វើអនុមោទនា ហើយនិមន្តចៀសចេញ នាងនោះបានធ្វើបុណ្យប៉ុណ្ណោះ លុះស្លាប់

ទៅក៏បានទៅកើតក្នុងឋានទេវលោក សោយទិព្វសម្បត្តិអស់កាលជាយូរលង់ ពេលច្យុតពីទេវលោកមកវិញ ក៏បានកើតជាធីតានៃសេដ្ឋីឈ្មោះគិរិជិវច្ឆៈ មាន សម្បត្តិ៨០កោដិ នៅអរិដ្ឋបុរីនាដែនសីវិ, នាងមានរូបល្អជាពន់ពេក លើស ពួកស្ត្រីក្នុងដែននោះ។ បុរសណាដែលបានឃើញនាង តែងតែភ្លួកចិត្តជានិច្ច មិនដែលមានសតិស្មារតីតាំងនៅនឹងធឹងបានឡើយ ព្រោះហេតុនោះបានជា មាតាបិតាកំណត់ឈ្មោះឱ្យនាង ថាឧម្មាទន្តី ប្រែថា ស្ត្រីធ្វើបុរសឱ្យភ្លួកចិត្ត ព្រោះរូបសម្ប័ទនាង។ ពេលដែលនាងឧម្មាទន្តីមានអាយុ១៦ឆ្នាំ នាងមានរូប ល្អណាស់ ល្អលើសមនុស្សជាតិដូចគ្នា ប្រៀបដូចជាស្ត្រីទេពអប្សរបវរកញ្ញា នាឋានសោឡសសួគ៌ាល័យ។ បុរសទាំងឡាយជាបថុជ្ជនរូបណាក៏ដោយ បើ បានឃើញរូបនាងហើយ តែងតែភ្លួកចិត្ត មិនដែលធ្វើសតិឱ្យនៅនឹងបានឡើយ ប្រៀបដូចជាបុគ្គលស្រវឹងស្រា ព្រោះងប់ចិត្តនឹងកិលេស។ គិរិជិវច្ឆសេដ្ឋីក៏ ចូលទៅក្រាបទូលរឿងរ៉ាវនោះដល់ ព្រះរាជាជាម្ចាស់សិរីរដ្ឋថា បពិត្រព្រះ សម្មតិទេវាវង្ស នៅផ្ទះទូលព្រះបង្គំជាម្ចាស់ មានស្ត្រីកែវ(ឥត្ថីរតន៍)កើតឡើង ហើយ, ស្រីនេះសមតែធ្វើជាអគ្គមហេសីនៃ ព្រះមហាក្សត្រដូច្នេះ សូមទ្រង់ ព្រះមេត្តាប្រោសបញ្ជូនហោរអ្នកទាយលក្ខណៈ ឱ្យទៅពិនិត្យនាងនោះល្បង មើល លុះក្រាបទូលយ៉ាងនេះហើយ ក៏ត្រឡប់មកផ្ទះវិញ។ ខណៈជាបន្ទាប់ ដែលសេដ្ឋីត្រឡប់ទៅផ្ទះនោះ ព្រះមហាក្សត្រជ្រើសរើសពួកព្រាហ្មណ៍ដែល ជាអ្នកចេះទាយលក្ខណៈយ៉ាងចំណាន១ បញ្ជូនទៅឱ្យពិនិត្យមើលលក្ខណៈ

សម្បត្តិនាងឧម្មាទន្តី។ ព្រាហ្មណ៍ទាំងឡាយទៅដល់ផ្ទះសេដ្ឋីហើយ ក៏បរិភោគនូវអាហារភោជនមានរសឆ្ងាញ់ ដែលសេដ្ឋី បានរៀបចំទទួលជាកិត្តិយស។

តស្មិំ ខណេ ក្នុងខណៈដែលពួកព្រាហ្មណ៍កំពុងតែបរិភោគអាហារភោជននោះ នាងឧម្មាទន្តីបានដើរចេញពីក្នុងបន្ទប់ មកកាន់សំណាក់ព្រាហ្មណ៍ទាំងនោះតាមសេចក្តីបង្គាប់បញ្ជានៃសេដ្ឋីជាបិតា។ គួរឱ្យអស្ចារ្យណាស់ ព្រះរាជាទ្រង់បញ្ជូនពួកព្រាហ្មណ៍ទាំងនោះឱ្យមកពិនិត្យមើលលក្ខណៈម្តេចក៏មិនពិនិត្យមើលបែរជាឆ្កួតទៅវិញ ព្រោះអ្វី? ព្រោះតែរូបសម្បត្តិរបស់នាងឧម្មាទន្តីល្អពេកធ្វើចិត្តព្រាហ្មណ៍ឱ្យជាប់ឈ្លក់ក្នុងកិលេស ឆ្កួតទាំងអស់គ្នា. ព្រាហ្មណ៍មួយពួកលើកពំនូតបាយបរិភោគ តែបែរជាដាក់លើក្បាលទៅវិញ មួយពួក ទៀតគិតតែពីដើរដាល់ជញ្ជាំងដោលក្តារ មួយទៀតដាក់ដុំបាយទៅក្នុងចន្លោះក្បិនស្មានថាជាមាត់របស់ខ្លួន។ ឱ!អនិច្ចាប្រជាលោកសន្និវាស មានចិត្តជោគជាំទៅដោយកិលេសណាស់ហ្ន! មានតែព្រះសម្មាសម្ពុទ្ធនឹងព្រះអរហន្តខីណាស្រពទេដែលមិនមានចិត្តជាប់នឹងកិលេស។ នាងឧម្មាទន្តីឃើញព្រាហ្មណ៍ឆ្កួតអស់ហើយក៏ពោលថា អើ ក្រែងព្រះរាជាបញ្ជូនអ្នកឱ្យមកពិនិត្យលក្ខណៈឬ? ម្តេចក៏មិនពិនិត្យទើបបង្គាប់ ស្ត្រីដែលជាខ្ញុំបំរើឱ្យចាប់អូសកព្រាហ្មណ៍ទាំងនោះចេញពីផ្ទះ។ ពួកព្រាហ្មណ៍ត្រូវគេច្រានក្បាលចេញពីផ្ទះមក ក៏មានស្មារតីឡើងវិញ មានសេចក្តីអៀនខ្មាស់ណាស់ ទើបចងគំនុំនឹងនាង ហើយទូលបង្កាច់កេរ្តិ៍ពីនាង ថ្វាយព្រះមហាក្សត្រថា បពិត្រព្រះសម្មតិទេព នាងនោះជា

ស្រីកាឡកណ្ណី មិនសមធ្វើជាអគ្គមហេសីព្រះអង្គឡើយ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ក៏ពុំបានបញ្ជារាជបុរសឱ្យទៅនាំស្ត្រីនោះមកធ្វើជាអគ្គមហេសីឡើយ ដោយទ្រង់ជឿថា នាងជាស្ត្រីចង្រៃកាឡកណ្ណីមែន។ ដំណឹងនោះមិនស្ងប់ស្ងៀម ក៏លិចឮដល់នាងឧម្មាទន្តី នាងក៏ចងគំនុំព្រះរាជាថា ហេតុនេះចូរលើកទុកសិនចុះ គង់មានថ្ងៃណាមួយ ព្រះរាជានឹងឃើញអញ ហើយឆ្កួតជាមិនខាន សឹមអញផ្ចាញ់ផ្ចាលឱ្យ។ ឯសេដ្ឋីបិតា កាលបើដឹងថា ស្ដេចមិនសព្វព្រះទ័យនឹងបុត្រីរបស់ខ្លួនហើយ ក៏លើកនាងឱ្យសេនាបតីឈ្មោះអភិបារកៈ ជាសម្លាញ់នឹងព្រះរាជា។ អភិបារកៈសេនាបតី គាប់ចិត្តស្រឡាញ់នាងណាស់ មិនដែលធ្វើ ឱ្យមោះម៉ងចិត្តម្ដងណាឡើយ។

ថ្ងៃជាខាងក្រោយ សេនាបតីបាននាងឧម្មាទន្តីធ្វើជាភរិយាហើយតែងថ្នាក់ថ្នមចិត្តនាងមិនដែលឱ្យមានរលករង្គំ ឬសំដីតូចធំពីលើនាងទេ។ ពេលនោះជាថ្ងៃពេញបូណ៌មីខែកត្តិក សេនាបតីត្រូវមានដំណើរទៅជួយចាត់ចែងបញ្ជាឱ្យជនានុជនក្នុងទីក្រុង រៀបចំបោសសំអាតផ្លូវថ្នល់នឹងផ្ទះសំបែង ព្រោះព្រះរាជាស្ដេចចេញប្រទក្សិណទីក្រុងទើបផ្ដែផ្ដាំនាងជាប្រពន្ធថា ហៃប្អូនមាសព្រលឹង! ថ្ងៃនេះជាថ្ងៃលេងមហោស្រព. ព្រះរាជានឹងប្រទក្សិណនគរហើយនឹងចូលមកផ្ទះយើងមុនគេ. ដូច្នេះសូមប្អូននាងលាក់ខ្លួនបំពួនអាត្មា កុំឱ្យព្រះអង្គឃើញ ក្រែងទ្រង់ឆ្កួតដោយសារឃើញរូបនាង លុះផ្ដែផ្ដាំរួចក៏ចៀសចេញទៅ។ ថ្ងៃពីព្រះមហាក្សត្រ ពេលដែលព្រះទិនករអស្តង្គតរលត់រស្មី យ៉ាង

ចូលទៅកាន់សួរ្យវិមានវិញ ព្រះចន្ទពេញវង់វៀណរះ លើអាកាសវេហាស៍ បញ្ចាញបញ្ចាំងចោលរស្មីពណ៌ពេជ្រពាស មកលើផែនពសុធាទាំងមូលធ្វើឱ្យ រុក្ខាលតាវល្លិទាំងឡាយ ដែលស្វិតស្រពោនដោយកំដៅនៃព្រះសុរិយា បានរីក រួសរាយសមរសតាមលំអធម្មជាតិឡើង. ស្ដេចចេញប្រទក្សិណព្រះនគរជា មួយនឹងរាជបរិវារដ៏ច្រើន ហើយយាងចូលទៅផ្ទះសេនាបតី ជាមុនដំបូង ស្រាប់តែបានទតឃើញ លោកស្រីឧម្មាទន្តីភរិយាសេនាបតី ឈរក្បែរបង្អួច ទ្រង់ក៏ឈ្លក់ព្រះទ័យព្រោះកិលេស មិនបានតាំងព្រះស្មារតីឱ្យនៅនឹងធឹងបាន ទាំងដាច់ព្រះទ័យលែងធ្វើប្រទក្សិណទីក្រុង ហើយយាងចូលមកកាន់ព្រះបរ. មរាជវាំង ចូលទៅផ្ទំនៅនាមហាប្រាសាទវវើរវាយមមើមមាយឃើញតែរូប នាងឧម្មាទន្តីនោះជាប់ក្នុងព្រះទ័យ ជួនកាលសប្បាយហាក់ដូចបាននាងមក ធ្វើជាអគ្គមហេសីផ្ទំជាមួយគ្នា សំណេះសំណាលរៀបរាប់ពីរឿងអ្វីផ្សេងៗ ដោយព្រះទ័យពោរពេញទៅដោយតាមតណ្ហា ជួនកាលទ្រង់ធ្វើព្រះភក្ត្រស្រ. ងូតស្រងាត់ហាក់ដូចជាអស់សង្ឃឹមថា នឹងមានព្រះជន្មាយុតទៅទៀត ដោយ ទ្រង់ឃ្លាតពីស្រីស្រស់ដែលគួរស្នេហា ប្រៀបដូចភមរជាតិដែលហើរថ្លៃលរក លំអងផ្កាក្នុងមហាវ័ន លុះក្រឡេកឃើញផ្កាគួរជាទីចាប់ចិត្តហើយ ក៏សម្រប ស្លាប ពោះពួយសំដៅទៅរកផ្កា តែស្រាប់ជាមានខ្យល់កំណាចបក់បោកមក បន្សាត់រាងកាយឱ្យអណ្ដែកទៅឆ្ងាយពីផ្កាជាទីប្រាថ្នានោះ ធ្វើឱ្យភមរជាតិអស់ សង្ឃឹមដូច្នោះ។ សេនាបតីដឹងថា ព្រះរាជាក្ដៅក្រហាយអន្ទះអន្ទែងដូច្នោះ

ក៏យល់បានថា ស្តេចអង្គនេះពិតជាបានឃើញរូបនាងភរិយាអញហើយបានជា ផ្ទុំអត់បាយក្រហាយទឹកលែងមាត់កយ៉ាងនេះ ដូច្នេះគួរអញ ថ្វាយនាងដល់ព្រះអង្គចុះ ដើម្បីស្រោចស្រង់ជីវិតទ្រង់ឱ្យរួចពីសេចក្តីស្លាប់ តែគួរអញធ្វើឧបាយពិសោធចិត្តព្រះអង្គសិន បើនៅតែចចែសចង់បានទៀតនឹងថ្វាយជាកំណត់ គិតដូច្នេះហើយក៏ណាត់នឹងអ្នកបំរើម្នាក់ថា អ្នកឯងចូលទៅពួននៅក្នុងប្រហោងដើមចេតិយព្រឹក្សឯណោះ តែកុំឱ្យនរណាដឹងឱ្យសោះ បើអញទៅធ្វើពលិកម្មបន់ស្រន់សួររឿងរ៉ាវពីព្រះរាជា ឯងពោលថា ព្រះរាជាស្រឡាញ់ប្រពន្ធអ្នកហើយ បានជាផ្ទុំកើតទុក្ខយ៉ាងនេះ។ បុរសនោះទទួលពាក្យតាមបង្គាប់ចៅហ្វាយនាយហើយ ក៏ទៅពួននៅក្នុងព្រង់ឈើនោះ ក្លែងខ្លួនធ្វើជាទេវតាចាំទទួលពលិកម្មរបស់សេនាបតី។ លុះវេលាព្រឹកព្រាងកាលណាសេនាបតីក៏ទៅកាន់ទីនោះធ្វើពលិកម្មថ្វាយទេវតាបន់ស្រន់ថា បពិត្រ ទេវតាលោកមានភ្នែកទិព្វត្រចៀកទិព្វ ខ្ញុំមកនេះដើម្បីធ្វើពលិកម្មបួងសួងពីរឿងហេតុនៃព្រះរាជារបស់ខ្ញុំ ដែលទ្រង់មិនព្រមក្រសាលមហោស្រពក្នុងថ្ងៃម្សិលមិញជាថ្ងៃមង្គល ហើយបែរជាចូលទៅកាន់បន្ទប់ដ៏មានសិរីផ្ទុំរវើរវាយហាក់ដូចមានជាប់ព្រះទ័យនឹងវត្ថុអ្វីមួយ. បពិត្រទេវតា សូមលោកប្រាប់រឿងនោះដល់ខ្ញុំ តើព្រះរាជាទ្រង់រវើរវាយដោយជាប់ព្រះទ័យនឹអ្វី? បុរសក្លែងខ្លួនជាទេវតានៅក្នុងព្រង់នោះ ក៏ប្រែសម្លេងធ្វើគ្រលៗ ពោលមួយៗថា នែសេនាបតី! ស្តេចនោះស្រឡាញ់ប្រពន្ធអ្នកឯងហើយ បានជារវើរវាយចិត្ត. បើស្តេច

នោះមិនបានប្រពន្ធអ្នកឯងធ្វើជាមហេសីទេ នឹងស្លាប់ដោយពិត បើបានទើបមិនស្លាប់ ដូច្នេះឯងជួយស្ដេចផង ឱ្យប្រពន្ធខ្លួនទៅស្ដេចនោះចុះ។ សេនាបតីក៏ថ្វាយបង្គំហើយពោលថា បពិត្រទេវតា ពាក្យដែលលោកពោលនេះប្រពៃណាស់ហើយ ខ្ញុំនឹងប្រព្រឹត្តតាមឱវាទលោក ដើម្បីឱ្យព្រះរាជាខ្ញុំមានព្រះជន្មតទៅទៀត ទើបចូលទៅគាល់ព្រះរាជា ក្រាបទូលដំណឹងដែលខ្លួនទៅបន់ស្រន់ទេវតា រហូតដល់ចុងចប់ថ្វាយជាព្រះសណ្ដាប់ហើយពោលថា បពិត្រព្រះចៅម្ចាស់ផែនដី សូមទ្រង់កុំមានព្រះទ័យចំបែងឱ្យសោះ បើពិតជាទ្រង់មានព្រះទ័យប្រតិព័ទ្ធលើរូបភរិយាខ្ញុំព្រះអង្គតាមពាក្យទេវតាពោលមែន សូមទ្រង់ទទួលយកនាងជាភរិយាទូលព្រះបង្គំនេះ ធ្វើជាអគ្គមហេសីតាមព្រះរាជហឫទ័យចុះ។ ព្រះរាជាទ្រង់មានព្រះបន្ទូលសួរថា ហៃសម្លាញ់អភិបារកៈ ឮថាទេវតាយក្សទាំងឡាយគេដឹងថា ខ្ញុំមានចិត្តស្រឡាញ់ប្រពន្ធអ្នកមែនឬ? អភិបារកៈពោលថាបពិត្រព្រះសម្មតិទេពពិតដូច្នោះមែន។ ព្រះរាជាមានសេចក្ដីអៀនខ្មាស់ដោយព្រះចិន្ដាថា លោក[១] ទាំងអស់គេដឹងថា អញនេះលបស្រឡាញ់ប្រពន្ធគេមែន លុះទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ក៏បិតនៅក្នុងទសពិធរាជធម៌ បន្ទោរបង់សេចក្ដីស្នេហាចំពោះរូបនាងឧម្មាទន្ដីនោះចោល ដោយឥតអាឡោះអាល័យសោះឡើយ។

---

១. ពាក្យថា លោកនេះសំដៅយកសត្វទូទៅ ទាំងមនុស្ស ទេវតា តិរច្ឆាន មារព្រហ្ម ដែលនៅប្រែប្រួលវិនាសដោយត្រជាក់នឹងក្ដៅ ដែលនៅជាប់ជំពាក់ចិត្តដោយកិលេសតណ្ហា។

# ៣២. រឿងព្រះបាទវិបុលរាជ

(ចាក វិ. ប.)

(ពោធិសត្វឱ្យទានប្រាថ្នាពោធិញ្ញាណ ប្តូរជាងសាមញ្ញជន)

កាលព្រះបរមសាស្តាគង់នៅវត្តជេតពន ក្បែរក្រុងសាវត្ថី ទ្រង់សំដែងធម៌ប្រារព្ធទាន ដែលទ្រង់បានបរិច្ចាគ ក្នុងកាលដែល សោយព្រះជាតិជាពោធិសត្វ។

សេចក្តីថា កាលនោះពួកភិក្ខុមកប្រជុំគ្នា នៅលើសាលាធម្មសភាពោលសរសើរគុណព្រះបរមគ្រូថា ម្នាលលោកដ៏មានអាយុទាំងឡាយ ព្រះសម្មាសម្ពុទ្ធទ្រង់មានបុណ្យច្រើន មានប្រាជ្ញាច្រើន បានបំពេញទានបារមីជាអនេកប្រការ គួរឱ្យអស្ចារ្យពន់ពេកណាស់។ គ្រានោះព្រះបរមសាស្តាទ្រង់យាងចេញពីគន្ធកុដិមកគង់លើពុទ្ធាសនៈ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអ្នកប្រជុំគ្នាពោលពីរឿងអ្វី? ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអង្គុយជំនុំគ្នាពីការបរិច្ចាគរបស់ព្រះអង្គ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតឱ្យទានក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យប៉ុន្មានទេ, កាលពីដើមតថាគត បានបរិច្ចាគទានបុត្តភរិយា ទៅជាខ្ញុំបំរើអ្នកដទៃទើបមានសេចក្តីអស្ចារ្យជាងនេះ។ ភិក្ខុទាំងឡាយ ក៏អារាធនាឱ្យព្រះអង្គនាំអតីតទាននោះមកសំដែងប្រាប់។ ទើបព្រះសាស្តាសំដែងថា:

កាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ ព្រះនាមវិបុលរាជសោយរាជសម្បត្តិក្នុងនគរសុចិវត្តី ព្រះអគ្គមហេសីព្រះនាមសុន្ទរីទេវី ព្រះរាជ

បុត្រីព្រះនាមសុចី។ ព្រះរាជាអង្គនេះ ទ្រង់ពុំមានសេចក្ដីលំអៀងទៅតាមអគតិធម៌ណាមួយឡើយ ទ្រង់សោយរាជ្យប្រកបដោយធម៌ បានចំណាយព្រះរាជទ្រព្យឱ្យជាងសង់សាលាសម្រាប់ឱ្យទាន៥ខ្នង ហើយតែងប្រទានព្រះរាជទ្រព្យដល់ស្មូមយាចក អស់ប្រាក់៥សែនកហាបណៈ ជារាល់ថ្ងៃ។ ពេលនោះអ្នកជម្ពូទ្វីបទាំងអស់ ឈប់ធ្វើវេជ្ជកម្ម ពាណិជ្ជកម្ម ចាំតែទទួលព្រះរាជទានប៉ុណ្ណោះ។ ជនទាំងនោះ បានជាអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិ បានចាត់ចែងរបាំចម្រៀង ជាទីកំសាន្តចិត្តពន់ពេក។ ចាត់ចែងទានប៉ុណ្ណោះហើយ នៅតែមិនស្កប់ព្រះទ័យ ថ្ងៃមួយព្រះរាជា ប្រថាប់នៅលើប្រាសាទ ទ្រង់បើកសីហបញ្ជរ រកមើលឥស្សរិយភាព ព្រះអង្គដោយព្រះតម្រិះថា អញបានបំ-ពេញហិរទាន(ទានខាងក្រៅ) ប៉ុណ្ណោះ អជ្ឈត្តិទាន(ទានខាងក្នុង) អញពុំទាន់បានបំពេញសោះ ទើបរំពឹងថា បើមានអ្នកណាមកសុំក្បាលអញៗក៏ឱ្យ ភ្នែកក៏ឱ្យ ត្រចៀកក៏ឱ្យ បើមកសុំសាច់បេះដូង អញនឹងពុះទ្រូងរូងយកសាច់បេះដូងឱ្យ. មកសុំសាច់អញៗ នឹងពន្លះចេញពីរាងឆ្អឹងទាំងមូលឱ្យអ្នកនោះ. ពុំនោះសោត បើមានអ្នកណាមួយមកនិយាយនឹងអញថា មហារាជសូមទ្រង់ធ្វើជាអ្នកបំរើខ្ញុំ ដូច្នេះអញស៊ូទៅបំរើអ្នកនោះ។ កាលព្រះអង្គកំពុងព្រះចិន្ដាយ៉ាងនេះ មហាប្រឹថពីមានកម្រាស់២សែន ៤ម៉ឺនយោជន៍ ក៏កំរើកញាប់ញ័រឮសូរខ្ទរខ្ទ័រទ្រហឹងអឹងកង, ភ្នំសិនេរុរាជក៏ឱនលំទោនទោរទន់មក, ទាំងមហាសមុទ្រក៏កើតជារលកបោកបែកផ្កាត្រែង, មហាមេឃក៏បញ្ចេញសម្លេងផ្គរ

រន្ទះបាញ់ឆាំងឆាពេញទាំងផ្ទៃមេឃ ហើយបង្អុរភ្លៀងចុះមកជាច្រើន ឯផ្លេកបន្ទោរ ពុំដូចកាលក៏ភ្លឺផ្លេកប្រវាត់. ពួកទេវតា ក៏ឱ្យសព្ទសាធុការពររហូតដល់ព្រហ្មលោក។ សេចក្តីអស្ចារ្យជាអនេក នឹងរៀបរាប់ពុំបានឡើយ។

ខណៈនោះ ក៏ក្តៅដល់សំណាក់នៃសក្កទេវរាជ ដោយតេជានុភាពនៃទានបារមី។ សម្តេចព្រះអមរិន្ទ្រាធិរាជ ទ្រង់រមិលមើលហេតុនោះហើយ លាន់ព្រះឱស្ឋថា ឱហ្ន! ព្រះបាទវិបុលរាជជាពុទ្ធង្កុរបណ្ឌលសពើជ្ញាណ ទ្រង់គង់នៅនាឋានមនុស្សឯណោះ មានព្រះរាជសទ្ធាបានចំណាយទ្រព្យឱ្យទៅជាទានដល់ស្មូមយាចកដោយឥតអាល័យប៉ុណ្ណោះ ហើយទ្រង់មិនទាន់ស្កប់ព្រះទ័យក្នុងពាហិរទាន ឥឡូវគិតនឹងបំពេញអជ្ឈត្តិកទានទៀត លុះរំពឹងដូច្នោះហើយ ក៏ក្លែងខ្លួនជាព្រាហ្មណ៍ ក្មេងមកអង្គុយនាសាលាទាន។

ពេលនោះព្រះមហាក្សត្រទ្រង់ស្រង់ព្រះសុគន្ធវារីពីព្រលឹម សោយព្រះក្រយាស្ងោយមានឱជារសផ្សេងៗ ហើយទ្រង់គ្រឿងអម្ពរពស្ត្រាលង្កា-រណ៍ស្រេចឡើងគង់លើព្រះទីនាំងគជេន្ទ្រជ័យ មានពួកអមាត្យចោមរោមជាបរិវារ យាត្រាទៅកាន់សាលាទាន។ លុះទៅដល់ទ្រង់ក៏ចុះចាកព្រះទីនាំងចូលទៅក្នុងសាលា បែងចែកព្រះរាជទ្រព្យដល់ស្មូមតាមធម្មតា។ ឥន្ទព្រា-ហ្មណ៍លើកករប្រណមផ្គងអញ្ជលីលើសិរសាក្រាបថ្វាយបង្គំទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ឈ្នះអស់មារសត្រូវសព្វៗកាល ថាដូច្នេះហើយក៏ខិតនៅក្នុងទីដ៏សមគួរ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ពោល

ព្រះគាថាត្រាស់សួរថា

ហរិតសរីរោ តវេព្ភ ទស្សនីយោ សុរូបិយោ បគ្គយ្ហ
អញ្ជលិវេទ្ទរ កិ មំ យាចសិ ព្រាហ្មណ៍ ។

ហៃព្រាហ្មណ៍ អ្នកមានសរីរៈដូចជាលាបស្រឡាបដោយខ្លឹមចន្ទន៍ក្រហម គួរអ្នកផងក្រឡេកមើល, រូបអ្នកសោតក៏សមល្អ គួរអ្នកផងគយគន់ អ្នកមកផ្គងអញ្ជលីនៅទីនេះតើសុំអ្វី?

ឥន្ទព្រាហ្មណ៍ឮហើយរីករាយណាស់ ទូលថា

យថា វារិវហោ បូរោ សព្វកាលំ ន ខិយតិ
ឯវន្តំ យចិតាគញ្ជី ទេវី មេ ទេហិ យាចិតោ ។

ទឹកក្នុងស្ទឹង តែងហូរទៅកាន់សមុទ្រសព្វកាលមិនចេះអស់យ៉ាងណា ព្រះហឫទ័យតែងជ្រះថ្លាក្នុងទានពុំចេះអស់យ៉ាងនោះ, ខ្ញុំមកសូមព្រះទេពី សូមព្រះមេត្តាប្រោសព្រះរាជទានកុំខាន។

ដោយការក្រាបទូលសុំព្រះទេពី ព្រះរាជាមានព្រះទ័យរីករាយណាស់ហាក់ដូចបុរសកំសត់បានមាសមួយពាន់ដំឡឹងពីព្រះមហាក្សត្រ ទើបត្រាស់ថា

ទទាមិ ន វិកប្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ ន បដិគុយ្ហាមិ ទានេ មេ រមតី មនោ ។

ម្នាលព្រាហ្មណ៍ អ្នកសូមរបស់អ្វី យើងឱ្យរបស់នោះឥតទើសទាល់ យើងមិនលាក់ទុករបស់ដែលមាន ចិត្តយើងត្រេកអរចំពោះទានតែម្យ៉ាង។

លុះមានព្រះបន្ទូលយ៉ាងនេះហើយ ក៏ត្រាស់ហៅមហេសីមកពោលប្រាប់ថា ហៃប្អូនមាសស្នេហ៍! ព្រាហ្មណ៍កម្លោះនេះមកសុំនាងធ្វើជាភរិយាគេ បងប្រាថ្នាសព្វញ្ញុតញ្ញាណ គួរប្អូនជួយបំពេញទានបារមីផងចុះ។

ឯព្រះអគ្គមហេសីក៏មានព្រះទ័យសោមនស្សពោលគាថាថា:

ទាសី កុយ្ហំ អហំ ទេវ សាមិកោ មម ឥស្សរោ

យស្សិច្ឆេ តស្ស មំ ទជ្ជា វិក្កិណេយ្យ ហនេយ្យ វា ។

បពិត្រព្រះភស្តាអម្ចាស់ប្អូន ខ្ញុំម្ចាស់ជាទាសីព្រះអង្គ ព្រះអង្គជាម្ចាស់ខ្ញុំ បើទ្រង់ត្រូវការប្រទានខ្ញុំម្ចាស់ដល់អ្នកណា សូមប្រទានតាមព្រះរាជហឫ-ទ័យ ទុកជាត្រូវការលក់ដូរក្តី សម្លាប់បង់ក្តី ក៏ស្រេចលើព្រះហឫទ័យព្រះអង្គ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ក៏ទាញយកក្អមមាស ចាប់ព្រះហស្តព្រះអគ្គមហេសី ប្អូងសួងយកផែនដីជាបន្ទាល់ ទ្រង់ជ្រួចស្នោទក ហើយត្រាស់ថា ហៃព្រាហ្មណ៍កម្លោះ! ភរិយាយើងជាទីស្រឡាញ់ពេញចិត្តក្រៃពេក ប៉ុន្តែយើងត្រូវការសព្វញ្ញុតញ្ញាណលើសលប់ជាងនេះមិនអាចរាប់បានឡើយ, យើងលះបង់ទេវីឱ្យអ្នកក៏មិនមែនប្រាថ្នាសម្បត្តិមនុស្ស សួគ៌ ព្រះឥន្ទ ព្រះព្រហ្ម សាវក បច្ចេកពុទ្ធទេ ប្រាថ្នាសព្វញ្ញុតញ្ញាណតែម្យ៉ាង, លុះត្រាស់យ៉ាងនេះហើយ ក៏ប្រទានព្រះមហេសីដល់ព្រាហ្មណ៍។

ឯឥន្ទព្រាហ្មណ៍បាននាងទេពីហើយ នាំយកទៅបាត់ពីទីនោះភ្លាម ហើយឥន្ទព្រាហ្មណ៍ឯងនិម្មិតជាព្រាហ្មណ៍ប្លែក មកពោលថ្វាយសព្វសាធុការ

សុំព្រះរាជធីតាថា:

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគញ្ឆិ បុត្តំ មេ ទេហិ យាចិតោ

ធម្មតាទឹកស្ទឹង តែងហូរទៅកាន់សមុទ្រសព្វៗកាល មិនចេះអស់យ៉ាងណា ព្រះហឫទ័យទ្រង់តែងជ្រះថ្លាក្នុងទានពុំចេះអស់យ៉ាងនោះ. ខ្ញុំម្ចាស់មកសុំព្រះរាជបុត្រី សូមព្រះមេត្តាប្រោសព្រះរាជទានកុំខាន។

ព្រះរាជាត្រេកអរណាស់ ក៏ពោលថា:

ទទាមិ ន វិកម្បាមិ ឥស្សរោ នយ ព្រាហ្មណ
សន្តំ ន បដិគុយ្ហាមិ ទានេ មេ រមតី មនោ ។

ម្នាលព្រាហ្មណ៍យើងជាឥស្សរៈ ឥតធុញទ្រាន់នឹងការឱ្យទេ អ្នកចាំតែទទួលយករបស់យើងឱ្យចុះ យើងមិនលាក់លៀមរបស់ដែលមានទេ ចិត្តយើងត្រេកអរក្នុងការឱ្យតែម្យ៉ាង។

លុះមានបន្ទូលដូច្នេះហើយ ក៏បញ្ជានបុត្រី ឱ្យទៅស្រង់ស្និតស្អាងព្រះកាយដោយគ្រឿងវត្ថាលង្ការណ៍សព្វយ៉ាង ហើយហៅមកឱ្យគង់លើអាសនៈទ្រង់ជប់ព្រះសិរសាល្អងលោមផ្ដែផ្ដាំអស់អាថ៌សេចក្ដី ទើបប្រកាស ដល់ពួកទេវតា ឱ្យជាបន្ទាល់សាក្សីថា: បពិត្រទេព្ដាទាំងឡាយ សូមអញ្ជើញមកជួបជុំជាបន្ទាល់សាក្សីពេជ្ញាណ សូមជួយអនុមោទនាទានខ្ញុំ ហើយទទួលយកចំណែកបុណ្យនេះ ត្បិតខ្ញុំឱ្យបុត្រីជាទីស្រឡាញ់ពេញចិត្តប្រកបដោយរូបឆោម

តែងបំរើដោយសេចក្ដីគោរព។

ឯអមាត្យទាំង៧រូប ពេលបានមកនៅក្នុងនគរ ជាសុខស្រួលជាមួយព្រះរាជាហើយ ក៏ចំណាយទ្រព្យសាងវត្ត៥ ដូច្នេះអមាត្យឈ្មោះឧត្តិយសាងវត្តមួយឈ្មោះទក្ខិណៈ នៅខាងត្បូងក្រុងអនុរាធបុរី។ អមាត្យឈ្មោះចូឡៈសាងវត្តមួយឈ្មោះចូឡៈ នៅខាងកើតវត្តទក្ខិណៈ។ អមាត្យឈ្មោះសាលិយៈសាងវត្តមួយឈ្មោះសាលិយៈ។ អមាត្យឈ្មោះបព្វតៈ សាងវត្តមួយឈ្មោះបព្វតៈ។ អមាត្យឈ្មោះតិស្សៈ សាងវត្តមួយឈ្មោះឧត្តរតិស្សៈ។ អមាត្យទាំង៥រូបសាងវត្តមួយៗម្នាក់រូចហើយ ក៏និមន្តព្រះមហាតិស្សត្ថេរៈដែលគង់នៅវត្តហម្ពុកល្លកៈ ធ្លាប់ធ្វើឧបការៈមុនដល់ខ្លួន ទើបប្រគេនវត្តទាំង៥នោះ ឱ្យលោកគង់នៅថែទាំ។ ព្រោះហេតុនោះ បានជាព្រះមហានាមលោកពោលគាថាក្នុងគម្ពីរមហាវង្សថាៈ

> តុម្ហាកំ បដិសណ្ឋារ- វសេនម្ហេហិ ការិតេ វិហារេ ទេម
> តុម្ហាកំ ឥតិ វត្វា អទំសុ ច ថេរោ សព្វត្ថ វាសេសិ
> តេ ភិក្ខូ យថា រហំ អមច្ចានំសុ សង្ឃស្ស វិរិតេ
> សមណាររហេ។

អមាត្យទាំងឡាយក៏ពោលប្រគេនថា យើងខ្ញុំសូមប្រគេនវត្តទាំងឡាយដែលបានឱ្យជាងកសាង ដល់លោកម្ចាស់ ដោយអំណាចនៃបដិសណ្ឋារៈរបស់លោកម្ចាស់. ព្រះថេរៈក៏ចាត់ភិក្ខុទាំងឡាយឱ្យនៅក្នុងវត្តទាំងអស់តាម

សមគួរ ពួកអមាត្យតែងប្រគេនបច្ច័យទាំងឡាយផ្សេងៗ ដ៏សមគួរដល់សមណៈភិក្ខុសង្ឃ។

និយាយពីព្រះចៅបិតុរាជ កាលទ្រង់បានគ្រងរាជ្យដូចដើមវិញហើយទ្រង់បានចំណាយព្រះរាជទ្រព្យធ្វើបុណ្យជាច្រើន ដរាបដល់និមន្តព្រះថេរឱ្យចារព្រះពុទ្ធវចនៈ គឺព្រះត្រៃបិតកដាក់សាស្ត្រាស្លឹករឹត ហើយឋិតនៅជាសុខក្នុងរាជសម្បត្តិតាមសមគួរ ដល់ព្រះជន្មាយុទើបសោយព្រះទីវង្គត[១] ទៅ។ កាលព្រះចៅបិតុរាជសោយព្រះទីវង្គតទៅ ឥស្សរជនទាំងឡាយមានអមាត្យជាដើម បានអភិសេកព្រះរាជនត្តាព្រះនាមចូឡិកៈនៃព្រះអង្គជាម្ចាស់គ្រងរាជសម្បត្តិដំណព្រះវង្សមក។ ដោយការអន់ព្រះទ័យនឹងការក្តៅក្រហាយ ព្រះរាជបុត្រព្រះបិតុរាជនាមមហានាគ ក៏ភាសព្រះអង្គទៅធ្វើចោរកម្ម ព្រោះហេតុរាជ្យនោះឯង ទៅនៅអាស្រ័យក្នុងវិហារនាជនបទ ដោយព្រះទ័យរីករាយជាខ្លាំង បើមានភិក្ខុទាំងឡាយមិនឱ្យទីលំនៅក្នុងវត្តណាៗព្រះអង្គម្ចាស់មហាៈនាគនោះអន់ព្រះទ័យជាខ្លាំង តាំងចិត្តថាចងពៀរ លុះពេលបានសោយរាជ្យក៏បង្គាប់ឱ្យរាជបុរសរុះរើវត្តទាំងនោះចោលអស់។ ព្រោះហេតុនោះ បានជាព្រះមហានាមពោលនូវព្រះគាថាក្នុងបរិច្ឆេទទី៣៥នៃគម្ពីរមហាវង្សថាៈ

វង្គតាមណិនោ បុត្តោ ចោរនាគោតិ វិស្សុតោ
មហាចូឡស្ស រជ្ជម្ហិ ចោរោ ហុត្វា ចរី តរា
មហាចូឡេ ឧបរតេ រជ្ជំ ការេសិ អាគតោ

---

១. ក្នុងគម្ពីរឥតមានប្រាប់ថាព្រះអង្គទៅកើតនៅទីណាទេ។

អត្តនោ ចោរកាលេ សោ និវាសំ យេសុ នាលភិ
អជ្ឈារស វិហារេ តេ វិទ្ធំសាបេតិ ទុម្មតិ ។

ព្រះរាជបុត្រព្រះចៅវដ្តគាមណិ ល្បីឈ្មោះថា ចោរនាគ មានសភាព ជាចោរក្នុងរាជ្យព្រះចៅមហាចូឡិកៈ គ្រាច់ទៅក្នុងកាលនោះ កាលព្រះបរមហាចូឡិកៈសោយទីវង្គតទៅ ក៏មកសោយរាជ្យវិញ. ចោរនាគនោះ មិនបាន លំនៅក្នុងណា ក្នុងកាលដែលខ្លួនធ្វើចោរ ជាអ្នកមានគំនិតអាក្រក់បានញ៉ាំង រាជបុរសឱ្យរុះរើវត្តទាំង១៨នោះអស់។

ចោរនាគនោះ ជាស្តេចលាមក ត្រូវព្រះទេពីជាអគ្គមហេសីឱ្យស៊ីថ្នាំ ពិស ក៏ស្លាប់ទៅកើតក្នុងលោកន្តរនរកឯណោះ។

# ៣៥. រឿងនាងបាក់ជុល

(ចាក ម. អ.)

(អានិសង្សនៃការចង្អុលបង្ហាញផ្លូវដល់មនុស្សដែលពុំស្គាល់)

កាលកន្លងទៅហើយ មានព្រះរាជាមួយអង្គព្រះនាមមហាកំសរាជ សោយរាជ្យសម្បត្តិនៅនគរអសិតញ្ជៈ នាដែនឧត្តបរាថៈ មានព្រះរាជធីតាមួយអង្គនាមទេវគព្ភ។ កាលជាខាងក្រោយ ព្រះរាជធីតានេះបានជាអគ្គមហេសីនៃព្រះរាជកុមារព្រះនាមឧបសាគរ ជាព្រះរាជបុត្រព្រះបាទមហាសាគរ សោយរាជ្យនៅដែនឧត្តរៈ។ ព្រះរាជធីតាអង្គនេះ នៅរួមនឹងព្រះរាជស្វាមី ក៏បានប្រសូត្របុត្រធីតា១១អង្គគឺៈ នាងអញ្ជនទេវី១ វាសុទេវកុមារ១ ពលទេវកុមារ១ ចន្ទទេវកុមារ១ សុរិយទេវកុមារ១ អគ្គិទេវកុមារ១ វរុណកុមារ១ អជ្ជុនកុមារ១ បជ្ជុនកុមារ១ ឃដបណ្ឌិតកុមារ១ អង្កុរកុមារ១ កុមារ១០ព្រះអង្គ លើកតែព្រះរាមច្បងជារាជធីតាចេញ នាំគ្នាច្បាំងកាប់សម្លាប់ព្រះរាជារួមទាំងអស់៦ម៉ឺន ៣ពាន់ក្នុងជម្ពូទ្វីប មានអសិតញ្ជនគរ ជាដើម ទ្វារវតីជានគរទីបំផុត ទើបនាំគ្នាទៅនៅក្នុងទ្វារវតីនគរ បែងចែករាជសម្បត្តិជា១០ ចំណែកតែប៉ុណ្ណោះ ភ្លេចនឹកដល់ព្រះនាងអញ្ជនទេវីជាច្បង។ លុះដល់ថ្ងៃ ក្រោយទើបរលឹកឃើញ ក៏នាំគ្នាមកប្រឹក្សាគិតនឹងចែកជា១១ ចំណែក តែអង្កុរកុមារជាប្អូនពៅនិយាយថា ព្រះជេដ្ឋាទាំងឡាយសូមយកចំណែកខ្ញុំម្ចាស់ថ្វាយព្រះនាងរាមច្បងចុះ ខ្ញុំម្ចាស់នឹងរកស៊ីលក់ដូរចិញ្ចឹមជីវិតវិញ តែសូមទ្រង់អនុញ្ញាតឱ្យខ្ញុំម្ចាស់រួចពន្ធដារក្នុងជនបទរបស់ព្រះរាម គ្រប់ៗ

អង្គ។ កាលបើស្រុះស្រួលគ្នាហើយ ក៏លើកចំណែករបស់អង្គុរកុមារនោះថ្វាយដល់ព្រះនាងជាបង ហើយនៅជាមួយគ្នានាទ្វារវតីនគរនោះ។ ឯកុមារជាប្អូនពៅ បានប្រកបចិញ្ចឹមជីវិតតាមផ្លូវជំនួញ មិនយូរប៉ុន្មាន ក៏ក្លាយខ្លួនទៅជាអ្នកមានទ្រព្យធនជាច្រើន ហើយតែងឱ្យទានធំជានិច្ច។ មានកម្មករម្នាក់ជានាយឃ្លាំង មានអធ្យាស្រ័យល្អ តែងប្រាថ្នាសេចក្តីចំរើនដល់អង្គុរកុមារជាម្ចាស់។ អង្គុរកុមារបានរកកញ្ញាម្នាក់ឱ្យធ្វើជាភរិយា។ កាលបើបាននៅរួមគ្នាជាយូរកាល មានសត្វចុះមកចាប់បដិសន្ធិក្នុងផ្ទៃនាង ជាភរិយាហើយកម្មករនាយឃ្លាំងនោះក៏ស្លាប់ទៅ។ ពេលកូននោះនៅក្នុងផ្ទៃមាតាគ្រប់ទសមាសហើយ ក៏ប្រសូត្រមកមានវ័យវឌ្ឍនាការ ចំរើនឡើងជាលំដាប់ មហាជនក៏ទាស់ទែងក្តីក្តាំគ្នា ព្រោះរឿងកូននោះ, អ្នកខ្លះនិយាយថា កូននោះនៅជាខ្ញុំគេដដែល ព្រោះឪវាខ្ញុំគេ ខ្លះនិយាយថា កូននោះមិនមែនជាខ្ញុំគេទេ ខ្ញុំតែឪវាទេតើ ឥឡូវឪនោះស្លាប់ទៅហើយ ត្រង់ម្តាយវាមិនមែនខ្ញុំគេទេ។ រឿងក្តីក្តាំនេះ ក៏កើតរាលដាលធំឡើងៗ ដរាបដល់ប្តឹងដល់ក្នុងរាជត្រកូល ព្រះនាងអញ្ជនទេវី បានជ្រាបរឿងនោះហើយ ក៏កាត់សេចក្តីដោយយុត្តិធម៌ ដោយព្រះនាងបានលើក យកឧទាហរណ៍មកប្រៀបធៀបថា ធម្មតាគោញីបើគោឈ្មោលជនដទៃមក ពាក់ហើយ បានកូនគោកើតឡើង កូនគោនោះត្រូវបានទៅអ្នកម្ចាស់គោញី អ្នកម្ចាស់គោឈ្មោល មិនត្រូវបានកូនគោនោះទេ រឿងនេះក៏ដូច្នោះ មាតាជាអ្នកជា ឯកូនក៏ជាអ្នកជាដែរ ទើបព្រះនាងដោះកូន

នោះ ឱ្យរួចចាកទាស[១] ភាពអ្នកដទៃ។ ឯកូននោះមានសេចក្ដីអៀនខ្មាសជាពន់ពេក មិនហ៊ានទៅក្នុងនគរនោះតទៅទៀត ក៏រត់ទៅនៅក្នុងពោរនគរចូលទៅស្ដីដណ្ដឹងកូនក្រមុំនាងចាក់ផុលធ្វើជាភរិយា សម្រេចលំនៅក្បែរផ្ទះអសយ្ហមហាសេដ្ឋី ចិញ្ចឹមជីវិតដោយការងារជាងចាក់ផុល ទើបមហាជនកំណត់នាមថា ជាងចាក់ផុល។ ក្នុងកាលនោះ អាសយ្ហមហាសេដ្ឋី បានចាត់ចែងទានយ៉ាងសម្បើមអស្ចារ្យ ដល់ស្មូមយាចក ដែលមកពីទិសផ្សេងៗ ដោយប្រកាសប្រាប់មហាជនឱ្យបានដឹងពីថ្ងៃមុនជាស្រេច ពួកស្មូមណាមិនស្គាល់ផ្លូវដើរទៅកាន់ផ្ទះមហាសេដ្ឋី ពួកស្មូមនោះ ក៏ចូលទៅសាកសួរជាងចាក់ផុល។ ជាងចាក់ផុលពិចារណាថា អាត្មាអញហេតុតែមិនបានឱ្យទាន មិនបានធ្វើបុណ្យមកពីជាតិមុន បានជាឥឡូវនេះ មិនមានទេយ្យវត្ថុល្មមចែកចាយ ដល់ស្មូមបាន. អាត្មាអញគ្រាន់តែចង្អុលប្រាប់ផ្លូវ ទៅកាន់រោងទានដល់ស្មូមទាំងនេះហើយញ៉ាំងបីតិឱ្យកើតមានឡើង ដោយឧបាយនៃការប្រាប់នូវលាភ ក៏នឹងបានសោយបុណ្យជាច្រើនពិត លុះគិតដូចច្នេះហើយ ក៏ញ៉ាំងសេចក្ដីខ្វល់ខ្វាយនឹងសេចក្ដីគោរពចំពោះស្មូមទាំងឡាយ ឱ្យកើតមានឡើង ទើបលើកដៃស្ដាំលាបង្ហាញផ្លូវថា អ្នកទាំងឡាយទៅទីនោះ នឹងបានទ្រព្យដែលគួរបាន។ ពេលជាខាងក្រោយមក ជាងចាក់ផុលនោះ នឹងធ្វើមរណភាពទៅ បានកើតជាភុម្មទេវតា នាដើមព្រះជ្រៃមួយក្នុងព្រៃ ដែលមានផ្លូវលំបាកដោយខ្សាច់។ ដើមជ្រៃនោះមានម្លប់ជិតល្អ មានព្លូវជាច្រើនពាន់ មានទំហំ៤យោជន៍ ទាំង

---

១. បើឳពុកខ្ញុំ កូនកើតមកពីឈាមឳពុកក៏ត្រូវធ្វើជាខ្ញុំគេដែរ(នេះច្បាប់សក្តិភូមិ) ។

បណ្ដាយ, ទទឹងនឹងតំពស់។ ដោយផលកម្ម ដែលបានចង្អុលបង្ហាញផ្លូវ ដល់ស្ទូម ដៃស្ដាំរបស់ទេវតានោះអាចសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាងបាន។

ថ្ងៃមួយ អង្កុររាជបុត្រនាំយកទំនិញ ផ្ទុកពេញរទេះ៥០០ ចេញទៅដើម្បីជួញ លុះដល់ផ្លូវលំបាកនោះ មក៏វង្វេងផ្លូវ ដើរវិលវល់ក្នុងទីនោះ ជាច្រើនថ្ងៃ អស់ទាំងស្មៅ អស់ទាំងទឹក អស់ទាំងស្បៀងអាហារ។

គ្រានោះ ភុម្មទេវតារលឹកឃើញឧបការដែលអង្កុររាជបុត្របានធ្វើដល់ខ្លួន ទើបចង្អុលបង្ហាញដើមជ្រៃរបស់ខ្លួនដល់អង្កុររាជបុត្រនោះ។ អង្កុររាជបុត្រ បានឃើញដើមជ្រៃនោះ ត្រេកអរជាខ្លាំង ទើបនាំបរិវារទៅនៅក្រោមដើមជ្រៃនោះ ជាដំបូង ទេវតាលាដៃស្ដាំឡើងបង្ហូរទឹកឱ្យជនទាំងនោះផឹកបានឆ្អែតស្កប់ស្កល់។ បើជនណាចង់បានវត្ថុអ្វីៗ ទេវតាតែងឱ្យវត្ថុនោះដល់ជននោះតាមសេចក្ដីប្រាថ្នា។ អង្កុរះឃើញហេតុជាអស្ចារ្យដូច្នោះ ក៏ពោលគាថាសួរទេវតាថា:

> បាណិ តេ សព្វសោវណ្ណោ បញ្ចធារោ មធុស្សវោ
> កេន តេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ។

ដៃអ្នកសុទ្ធសឹងមាស មានទទជាទីហូរនៃវត្ថុគួរតាមប្រាថ្នាពីម្រាមទាំង៥ ជាទីហូរចេញនៃវត្ថុមានរស់ផ្អែម ផលបុណ្យសម្រេចក្នុងដៃអ្នកដោយ ព្រហ្មចរិយះដូចម្ដេច?

លំដាប់នោះ ទេវតាក៏ពោលប្រាប់ថា កាលពីបុរិមជាតិ ខ្ញុំកើតជាជាង

ចាក់ជុលនៅនគររោរុវៈ សម្រេចទីនៅក្បែរផ្ទះអសឃ្ឍមហាសេដ្ឋី, ខ្ញុំមិនបាន ឱ្យទានសូម្បីបន្តិចបន្តួចឡើយ. ពួកស្មូមមិនស្គាល់ផ្លូវទៅកាន់រោងទានរបស់ អសឃ្ឍមហាសេដ្ឋី ក៏នាំគ្នាមកសួរខ្ញុំៗបានប្រាប់ផ្លូវដល់ស្មូមទាំងនោះ ផលនេះ សម្រេចដោយបុញ្ញកម្មនោះឯងហើយក៏ពោលគាថាថា:

តេន បាណិ កាមទទោ តេន បាណិ មធុស្សវោ

តេន មេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។

ដៃខ្ញុំអាចឱ្យសម្រេចសេចក្តីប្រាថ្នាទាំងពួងបាន ដោយការបង្ហាញផ្លូវ នោះ ដៃខ្ញុំជាទីហូរចេញនៃវត្ថុមានរស់ផ្អែម ដោយការបង្ហាញផ្លូវនោះ ផល បុណ្យដែលសម្រេចក្នុងដៃខ្ញុំដោយព្រហ្មចរិយៈនោះ។

********

# ៣៦_ រឿងមហាកាញ្ចនកុមារ

(ចាក ភិ. ប.)

កាលព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី គ្រានោះព្រះពោធិសត្វ បានកើតជាបុត្រព្រាហ្មណ៍មហាសាល មានទ្រព្យ៨០កោដិ បិតាមាតាព្រះពោធិសត្វឱ្យឈ្មោះថា មហាកញ្ចនកុមារ កាលព្រះពោធិសត្វចេះដើរ ក៏កើតបុត្រប្រុសម្នាក់ទៀត មាតាបិតាឱ្យ ឈ្មោះបុត្រទី២ថា ឧបកាញ្ចនកុមារ ដោយលំដាប់យ៉ាងនេះ មានបុត្រប្រុសដល់ទៅ៧នាក់នឹងបុត្រីម្នាក់ជាប្អូនពៅបង្អស់ ឈ្មោះនាងកាញ្ចនទេវី រួមជា៨នាក់។

មហាកាញ្ចនកុមារ ជាពោធិសត្វ បានទៅសិក្សាសិល្បគ្រប់យ៉ាងឯក្រុងតក្កសិលា ហើយត្រឡប់មកផ្ទះវិញ។

មតាបិតា ប្រាថ្នាដើម្បីឱ្យមហាកាញ្ចនកុមារដែលជាបឋមបុត្រមានភរិយា ទើបនិយាយថា កូនអើយ! យើងទាំងពីរនាក់នឹងនាំស្ត្រីម្នាក់ ដែលមានត្រកូលស្មើគ្នា មកឱ្យជាភរិយារបស់ឯង១ នឹងបានគ្រប់គ្រងគេហដ្ឋានតទៅ។ មហាកាញ្ចនកុមារនិយាយថាៈ "លោកឪពុកអ្នកម្ដាយ! ខ្ញុំនេះមិនមានសេចក្ដីប្រាថ្នាគ្រប់គ្រងក្នុងគេហដ្ឋានទេ ព្រោះភពទាំងបី ប្រកបទៅដោយភ័យគួរខ្លាច ប្រៀបដូចផ្ទះដែលភ្លើងឆេះ នឹងជាចំណងចងសត្វទុក ដូចគុកសម្រាប់ឃុំឃាំងអ្នកទោស នឹងជារបស់គួរស្អប់ខ្ពើមយ៉ាងក្រៃលែង ដូចជាទីចាក់ទ្ធវរបស់ស្មោកគ្រោកស្អុយអសោចិ៍ មកប្រាកដដល់ខ្ញុំជានិច្ច ឯកូនប្រុសរបស់លោកឪពុកអ្នកម្ដាយក៏មានច្រើននាក់ សូមលោកឪពុកអ្នកម្ដាយឱ្យមាន

ផ្ទះសម្បែងចុះ" មាតាបិតាអង្វរករយ៉ាងណាក៏មិនព្រម ឱ្យមិត្តភក្តិទៅជួយនិយាយយ៉ាងណាក៏មិនបានការទៀត។

សំឡាញ់ទាំងឡាយសួរមហាកាញ្ចនកុមារថា ម្នាលសំឡាញ់! អ្នកមានគំនិតគិតប្រាថ្នាអ្វី ទើបមិនប្រាថ្នាបរិភោគកាមគុណ? មហាកាញ្ចនកុមារបានប្រាប់អធ្យាស្រ័យរបស់ខ្លួន ដែលបង្អោនចិត្តទៅដើម្បីនេក្ខម្មៈ គឺការចេញបួស ឱ្យសំឡាញ់ទាំងអស់នោះស្តាប់។

មាតាបិតាដឹងដូច្នោះហើយ ទើបលួងលោមបុត្រទាំង៦នាក់តទៅទៀត តែបុត្រទាំង៦នាក់នោះ ក៏មានបំណងដូចគ្នានឹងព្រះពោធិសត្វ សូម្បីនាងកាញ្ចនទេវីក្មួនពៅបង្អស់ ក៏មិនប្រាថ្នានឹងយកស្វាមីដែរ។ តមកមាតាបិតាក៏ធ្វើកាលកិរិយាស្លាប់ទៅ មហាកាញ្ចនកុមារបណ្ឌិតចាត់ការបូជាសពមាតាបិតាទាំងពីរស្រេចហើយ ទើបយកទ្រព្យ៨០កោដិបរិច្ចាគ ឱ្យទានដល់មនុស្សកំព្រាអនាថា នឹងមនុស្សទុគ៌ត ព្រមទាំងថ្វាយទានដល់សមណព្រាហ្មណ៍ស្រេចហើយ ទើបនាំប្អូន៦នាក់នឹងប្អូនស្រីម្នាក់ ទាសៈម្នាក់ ទាសីម្នាក់ សម្លាញ់ម្នាក់ រួមជា១១នាក់ចូលព្រៃហេមពាន្ត ដើម្បីនឹងបួស។

ជនពួកទាំងនោះ លុះទៅដល់ព្រៃហេមពាន្តហើយ ក៏នាំគ្នាសាង អាស្រម លើភូមិភាគគួរជាទីរីករាយ អាស្រ័យស្រះឈូកមួយ ស្រេចហើយក៏បួសជាឫសីនៅក្នុងទីនោះ ចិញ្ចឹមជីវិតដោយមើមឈើ ផ្លែឈើជាអាហារ។

ព្រះឫសីទាំងនោះ កាលទៅព្រៃក៏ទៅជាមួយគ្នា បើអង្គណាបាន

ឃើញផ្លែឈើ ឬមើមឈើ ក៏ស្រែកហៅគ្នានឹងគ្នាឱ្យជួយបេះ ជីកតាមដែលបានឃើញ។

មហាកាញ្ចនតាបសដែលជាអាចារ្យ ត្រិះរិះថា កាលដែលយើងទាំងឡាយបានលះទ្រព្យដល់៨០កោដិចេញមកបួស ហើយនាំគ្នាទៅដើរស្វែងរកផ្លែឈើ មើមឈើ ដោយសេចក្ដីប្រព្រឹត្តរលោភលាំយ៉ាងនេះជាការមិនគួរ តាំងពីថ្ងៃនេះតទៅ យើងនឹងត្រូវរកផ្លែឈើមកឆាន់ខ្លួនឯង មិនត្រូវបបួលគ្នាទៅជាពួក១ឡើយ។ ការត្រឡប់មកកាន់អាស្រមក្នុងវេលាល្ងាចទើបឱ្យតាបសទាំងនោះមកប្រជុំគ្នា ទើបប្រាប់តាមគំនិតរបស់ខ្លួននោះឱ្យដឹង ហើយពោលថា"លោកទាំងឡាយគ្រប់គ្នាចូរនាំគ្នាចំរើនសមណធម៌ក្នុងទីនេះចុះ ខ្ញុំនឹងរកផ្លែឈើមកឱ្យឆាន់"។

លំដាប់នោះ ឫសីទាំងឡាយ មានឧបកាញ្ចនៈជាដើម ក៏ពោលនឹងអាចារ្យថា "បពិត្រលោក! យើងទាំងឡាយនាំគ្នាចេញមកបួស ព្រោះអាស្រ័យលោកតែម្នាក់ សូមលោកនៅចំរើនសមណធម៌ក្នុងអាស្រមចុះ ប្អូនស្រីនឹងនាងទាសី ចូរទៅក្នុងអាស្រមខំចំរើនធម៌ចុះ ខ្ញុំទាំង៧នាក់នឹងផ្លាស់វេនគ្នាដើររកផ្លែឈើមកចិញ្ចឹមគ្នា ចំណែកលោកទាំងបីអង្គនេះជាអ្នករួចវេនចុះ" ។ មហាកាញ្ចនតាបសជាអាចារ្យក៏យល់ព្រម។ ចាប់ដើមអំពីនោះទៅ បណ្ដាតាបសទាំង៧អង្គ អង្គណាកាលបើដល់វេនខ្លួនហើយ ក៏ដើរទៅស្វែងរកផ្លែឈើមកតាមវារៈ ផ្លាស់វេនគ្នាម្ដងម្នាក់១ បើនរណាដល់វេនហើយ ត្រូវនាំ

ផ្លែឈើមកទុកលើផែនថ្ម ដែលមាននៅទីអាស្រម បែងផ្លែឈើឱ្យជា១១ចំណែក ហើយក៏វាយរគាំងឱ្យជាសញ្ញា តាបសទាំងនោះ ក៏មកយកផ្លែឈើជាចំណែករបស់ខ្លួនៗទៅឆាន់ ហើយក៏ចំរើនសមណធម៌រៀងៗខ្លួន។ តមកឫសីទាំងនោះបានក្រអៅឈូកមកឆាន់ ទើបមានឥន្ទ្រីយ៍ចាស់ក្លា មានកំលាំងច្រើន ក៏នាំគ្នាបរិកម្មកសិណ ។

ដោយតេជៈសីលនៃទាបសទាំងនោះ ក្តៅទៅដល់ពិភពនៃព្រះឥន្ទ្រាធិរាជៗ ទ្រង់រំពឹងថា ព្រះឫសីទាំងនេះជាអ្នកមានចិត្តបង្អោនទៅដើម្បីកាមគុណឬទេ? យើងនឹងពិសោធន៍មើលតាបសទាំងនេះឱ្យដឹងពិត។ គិតហើយក៏ធ្វើក្រអៅឈូក ជាចំណែករបស់ព្រះពោធិសត្វ ឱ្យអន្តរធានបាត់ទៅដោយឫទ្ធានុភាពរបស់ខ្លួន រហូត៣ថ្ងៃ ក្នុងថ្ងៃទី១ ព្រះពោធិសត្វ មិនឃើញក្រអៅឈូកដែលជាចំណែករបស់ខ្លួនហើយទើបគិតថា ចំណែកបស់យើងគេគង់នឹងភ្លេចពិត ទើបមិនទុកដើម្បីយើង. ក្នុងថ្ងៃទី២គិតថា យើងប្រហែលជាមានទោសកំហុស ទើបគេមិនឱ្យចំណែកអាហារដើម្បីយើង. ដល់ថ្ងៃទី៣ទើបគិតថា ហេតុអ្វីហ្ន! ទើបគេមិនទុកអាហារដើម្បីយើង បើជាយើងមានទោសកំហុស នឹងសូមទោសគេ។ គិតទៅគិតមកក៏មិនបានសេចក្តីជាយ៉ាងណា។

លុះដល់វេលាល្ងាច ទើបវាយរគាំងជាសញ្ញា ឫសីទាំងនោះមកប្រជុំគ្នាទាំងអស់ហើយ សួរថានរណាវាយរគាំង? ព្រះពោធិសត្វថា: ខ្ញុំ!

- បពិត្រលោកអាចារ្យ តើលោកវាយរគាំងធ្វើអ្វី?

នែអ្នកទាំងឡាយ! ក្នុងថ្ងៃទី៣ត្រូវវេនអ្នកណានាំផ្លែឈើមក?

ឫសីម្នាក់ក្រោកឡើងសំពះ ហើយថាក្នុងថ្ងៃទី៣នោះខ្ញុំនាំមក។

- លោកបានបែងទុកដើម្បីខ្ញុំមួយចំណែកឬទេ!

- បពិត្រលោកអាចារ្យ! ចំណែករបស់លោក ជាចំណែកធំ ខ្ញុំបានចែកទុកហើយដើម្បីលោក។

ព្រះពោធិសត្វសួរតាបសដែលត្រូវវេន២រូបទៀត ក៏ឆ្លើយដូចគ្នា។ ហើយលោកពោលតទៅថា "នែលោកទាំងឡាយ! យើងមិនបានចំណែកអាហារដល់៣ថ្ងៃ ក្នុងថ្ងៃទី១នោះ កាលមិនឃើញហើយ ក៏គិតថា ប្រហែលពួកលោកភ្លេច, ក្នុងថ្ងៃទី២គិតថា ប្រហែលជាខ្ញុំមានទោសកំហុស, ដល់ថ្ងៃទី៣នេះគិតថា បើយើងមានទោស យើងនឹងសូមខមាលទោល ទើបវាយរគាំងឱ្យមកប្រជុំគ្នា, ក៏ឥឡូវនេះ លោកទាំងឡាយគ្រប់គ្នា និយាយដូចគ្នាទាំងអស់ថា បានបែងចំណែកទុកឱ្យយើង៣ថ្ងៃ តែយើងមិនបានឃើញសោះ គួរយើងរកមុខចោរដែលលួចស៊ី, កាលដែលលោកទាំងឡាយលះកាមគុណ នាំគ្នាមកបួសបានដូចនេះហើយ នឹងលួចយករបស់បន្តិចបន្តួច សព្វបើត្រអៅឈ្មោកដូច្នេះមិនជាការសមគួរឡើយ " ឫសីទាំងនោះកាលបើបានឮពាក្យព្រះពោធិសត្វពោលដូច្នោះហើយ ក៏នាំគ្នាតក់ស្លត់រន្ធត់ចិត្តថា រឿងនេះជាកម្មអាក្រក់ណាស់ហ្ន៎!។

មានរុក្ខទេវតាមួយអង្គ ជាម្ចាស់ព្រៃនៅជិតអាស្រម កាលដឹងថាមាន

ហេតុកើតឡើងដូច្នោះ ក៏ចុះមកឋិតនៅក្នុងចំណោមពួកឫសីទាំងនោះផង មានដំរីមួយ ម្ចាស់ប្រើឱ្យធ្វើការហួសកំរិតពេក មិនអាចទ្រាំសេចក្តីទុក្ខនោះបាន ទើបផ្តាច់ចំណងរត់ចូលព្រៃទៅ ធ្លាប់មកថ្វាយបង្គំពួកឫសីទាំងនោះជានិច្ច ក្នុងថ្ងៃនោះ សូម្បីដំរីនោះ ក៏បានមកក្នុងទីប្រជុំ ឈរនៅកន្លែងមួយ មានស្វាមួយបានធ្លាប់លេងនឹងពស់រួចអំពីដៃអាយលម្ពាយ ហើយក៏រត់ចូលព្រៃ មកអាស្រ័យនៅជិតអាស្រមឫសី, ថ្ងៃនោះស្វាមកថ្វាយបង្គំឫសី ហើយអង្គុយនៅមួយកន្លែង សម្តេចព្រះឥន្ទ្រាធិរាជ ក៏បានមកប្រតិស្ឋានក្នុងសំណាក់ព្រះឫសី តែមានកាយមិនប្រាកដ។

ក្នុងខណៈនោះឧបកាញ្ចនតាបស ដែលជាប្អូនទី១របស់ព្រះពោធិសត្វ បានក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំព្រះពោធិសត្វជាមុន ហើយសំដែងកិរិយាគោរពក្រែងចំពោះតាបសទាំងឡាយ និយាយថា: បពិត្រលោកអាចារ្យ! ខ្ញុំនឹងជំរះខ្លួនឱ្យបរិសុទ្ធ មិនបាច់អាងដល់អ្នកដទៃ។ ព្រះពោធិសត្វពោលថាប្រពៃហើយ។ ឧបកាញ្ចនតាបសឈរនៅក្នុងកណ្តាលពួកឫសី ហើយនិយាយថា បើខ្ញុំលួចយកក្រអៅឈូករបស់លោក ទៅបាន់ពិតមែន សូមឱ្យខ្ញុំមានហេតុប្រព្រឹត្តទៅផ្សេងៗ ទើបធ្វើពាក្យស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូកលោកទៅពិត សូមឱ្យអ្នកនោះ បានវត្ថុកាមជាទីស្រឡាញ់ពេញចិត្តគឺ សេះ គោ ប្រាក់ មាស ភរិយា ឱ្យរួបរួមទៅដោយបុត្រភរិយាទាំងឡាយចុះ។

ពួកឫសីបានស្ដាប់ពាក្យស្បថដ៏ម៉ឺងម៉ាត់ដូច្នោះហើយ ក៏នាំគ្នាបិទត្រចៀក ហើយនិយាយថា នែលោក ពាក្យស្បថរបស់លោកនេះមុតមាំណាស់។ សូម្បីព្រះពោធិសត្វក៏ពោលថា ម្នាលលោកជាប្អូន ពាក្យស្បថរបស់លោក មានទម្ងន់ណាស់ យើងជឿជាក់ហើយថា លោកមិនបានលួចទេ សូមលោកអង្គុយលើអាសនៈលោកតាមសប្បាយចុះ។

តាបសដែលជាប្អូនទី២ ក៏ក្រោកឡើងសំពះព្រះពោធិសត្វហើយស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូករបស់លោកទៅពិត សូមឱ្យអ្នកនោះបានទ្រទ្រង់នូវកម្រងផ្កា នឹងសំពត់កាសិកពស្រ្តនឹងខ្លឹមចន្ទន៍ នឹងបុត្រជាច្រើន ចូរកើតដល់អ្នកនោះ សូមឱ្យអ្នកនោះធ្វើសេចក្ដីសំឡឹងយ៉ាងក្លៀវក្លាក្នុងវត្ថុកាមនឹងកិលេសកាមចុះ។

ចំណែកតាបសជាប្អូនទី៣ស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូករបស់លោកទៅពិត សូមឱ្យអ្នកនោះ ចូរជាគ្រហស្ថ មានយសមានគ្រឿងកសិកម្មដ៏បរិបូណ៌ នឹងមានធញ្ញជាតិជាច្រើន ចូរបាននូវបុត្រទាំងឡាយ ចូរជាអ្នកស្ដុកស្ដម្ភមានទ្រព្យ បរិភោគកាមគុណទាំងពួង ចូរកុំឃើញវ័យរបស់ខ្លួនដ៏សមគួរ ដើម្បីនឹងបព្វជ្ជា ក្នុងកាលចាស់ជរា ចូរនៅគ្រប់គ្រងគេហដ្ឋាន រហូតអស់ជីវិតចុះ។

តាបសជាប្អូនទី៤ស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូករបស់លោកទៅពិត

សូមឱ្យអ្នកនោះ បានជាក្សត្រិយ៍បរមរាជាធិរាជ ទាំងយសសក្តិនឹងកំឡាំង ល្មោភធ្វើចំបាំង ញាំញីសង្កត់សង្កិន ចូលគ្រប់គ្រងបរិមណ្ឌល មានទ្វីបទាំង ៤ជាទីបំផុតចុះ។

តាបសជាប្អូនទី៥ស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូកលោកទៅពិត សូមឱ្យ អ្នកនោះចូរបានជាព្រាហ្មណ៍បរោហិត ប្រកបដោយមន្តសម្រាប់ទាយឫក្ស នឹងយាម ចូរកុំបានរវាតឃ្លាតចាកសេចក្តីគ្រេកអរ ក្នុងឋានន្តរសក្តិព្រះមហា ក្សត្រិយ៍អ្នកមានយសធំក្នុងរដ្ឋ ចូរទ្រង់បូជាព្រាហ្មណ៍ ដែលជាបរោហិតនោះ ជានិច្ចចុះ។

តាបសប្អូនទី៦ស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូករបស់លោកទៅពិត សូមមនុស្សលោកទាំងពួង ចូររាប់អានព្រាហ្មណ៍នោះ ដែលជាអ្នកប្រកប ដោយការស្វាធ្យាយន៍វេទនឹងមន្តទាំងពួង នឹងជាអ្នកមានតបះតេជះ ប្រជាជន ជនបទទាំងឡាយបានឃើញហើយ ចូរបូជាព្រាហ្មណ៍នោះចុះ។

តាបសដែលជាសម្លាញ់ព្រះពោធិសត្វស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចក្រអៅឈូករបស់លោកទៅពិត សូមឱ្យអ្នកនោះ ចូរគ្រប់គ្រងដំបន់ ស្រុក សួយ ដែលព្រះរាជាទ្រង់ប្រោសប្រ ទានឱ្យស្រុកដ៏ស្កុកស្តម្ភ សម្បូណ៌ដោយហេតុ៤ប្រការគឺ កុះករដោយមនុស្ស

ច្រើន១ សម្បូណ៌ដោយស្រូវអង្ករ១ សម្បូណ៌ដោយផ្លូវទឹក១ ទីដីក៏តវបាន ដោយងាយ១ ប្រៀបដូចជាឋានៈ ដែលព្រះឥន្ទ្រប្រទាន១ សូមកុំវ៉ាតឃ្លាត ចាកសេចក្តីក្រេកអរ ចូរឈ្លក់នៅនឹងកាមគុណ ដូចជាសត្វទាំងឡាយ មាន ជ្រូកជាដើម ឱ្យនៅគ្រប់គ្រងកាមគុណរហូតអវសាននៃជីវិតចុះ។

តាបសដែលជាទាសៈរបស់ព្រះពោធិសត្វស្បថថា:

បពិត្រព្រាហ្មណ៍! នរណាបានលួចយកក្រអៅឈូករបស់លោកទៅ ពិត សូមឱ្យអ្នកនោះ ចូរជានាយស្រុកធំ រីករាយចិត្តដោយការលេង គីតំច្រៀងក្នុងកណ្តាលពួកសម្លាញ់ ហើយកុំបានជួបសេចក្តីវិនាសខូចចិត្ត ណាមួយ មានរាជភ័យជាដើមចុះ។

នាងកាញ្ចនទេវី ដែលជាកនិដ្ឋភគិនី របស់ព្រះពោធិសត្វស្បថថា:

បពិត្រព្រាហ្មណ៍! នាងណាលួចយកក្រអៅឈូករបស់លោកទៅពិត សូម ឱ្យព្រះបាទចក្កពត្តិឯករាជ្យ ដែលទ្រង់ប្រាបប្រាមសត្រូវបានពេញបរិមណ្ឌល ចូរទ្រង់ជ្រោសតាំងនាងនោះទុកក្នុងដំណែង ជាឯកអគ្គមហេសីប្រសើរជាង ស្រី១៦ពាន់នាក់ នាងនោះ ចូរជាមហេសីប្រសើរជាងព្រះស្នំទាំងឡាយចុះ។

នាងតាបសិនីដែលជាទាសីរបស់ព្រះពោធិសត្វស្បថថា:

បពិត្រព្រាហ្មណ៍! ស្ត្រីណាបានលួចយកក្រអៅឈូករបស់លោកទៅពិត កាលព្រះឫសីទាំងឡាយមកប្រជុំគ្នាហើយ សូមឱ្យស្ត្រីនោះបានមកអង្គុយក្នុង កណ្តាលប្រជុំ មិនបានញាប់ញ័ររំភើបចិត្តថយចេញទៅ ចូរបរិភោគអាហារ

មានរសជាតិ ហើយចូរដើរអួតអាងលលួងគេ ព្រោះឃើញផលលាភរបស់អ្នកដទៃ ធ្វើលាភនឹងសក្ការៈឱ្យកើតមានឡើងដល់ខ្លួនចុះ។

ចំណែកទេវតាស្បថថា:

បពិត្រព្រាហ្មណ៍! ទេវតាណាបានលួចយកក្រអៅឈូករបស់លោកទៅពិត សូមឱ្យអ្នកនោះ បានជាព្រះថេរៈ ចៅអាវាស ធ្វើការងារថ្មីគឺ បដិសង្ខរណវិហារ ដែលទ្រុឌទ្រោមនៅក្រុងកជង្គលនគរ ចូរដាំដើមឈើនឹងទ្វារ នឹងបង្អួច រាល់ព្រឹករាល់ល្ងាចចុះ។

បានឮថាទេវតាអង្គនេះធ្លាប់បានកើតជាព្រះសង្ឃត្ថេរចៅអាវាសគ្រប់គ្រងមហាវិហារដ៏ទ្រុឌទ្រោមក្នុងក្រុងកជង្គលនគរ បានធ្វើបដិសង្ខរណៈ ជួសជុលវិហារដ៏ទ្រុឌទ្រោមនោះ បានទទួលនូវសេចក្តីលំបាកគោកយ៉ាកជាច្រើន ព្រោះហេតុដូច្នោះ ទេវតាប្រាប្បឮផលសេចក្តីទុក្ខនោះ ទើបបានស្បថដូច្នោះឯង។

ចំណែកដំរីស្បថថា:

បពិត្រព្រាហ្មណ៍! ដំរីណាបានលួចយកក្រអៅឈូករបស់លោកទៅពិត សូមឱ្យដំរីនោះ ជាប់ដោយប្រវ៉ាក់១០០ ក្នុងទីទាំង៦កន្លែងគឺ ត្រង់ជើងទាំង៤ ត្រង់កនឹងចង្កេះ ឱ្យមនុស្សនាំទៅកាន់រាជធានីចាកព្រៃជាទីរីករាយ ឱ្យម៉ចាក់ដោយលំពែងមានផ្លែដ៏វែង នឹងកាប់សាច់ដោយកង្វេ មានមុខដ៏ខ្វិចុះ។

បានឮ ដំរីនោះប្រាប្បឮនឹកផលសេចក្តីទុក្ខលំបាកក្តៅក្រហាយដែលខ្លួន

ធ្លាប់បានទទួលជួបប្រទះពីមុនមក ទើបបានពោលពាក្យស្បថដូច្នេះ។

ឯពានរស្បថថា:

បពិត្រព្រាហ្មណ៍! ស្វាណាបានលួចយកត្រអៅឈូករបស់លោកទៅពិត សូមឱ្យស្វានោះមានកម្រងផ្កាជាគ្រឿងប្រដាប់ក មានស្លឹកត្រចៀកដែលអាយលម្អាយពស់ចោះហើយ ដោយដែកស្រួច ចូរជាសត្វដែលអាយលម្អាយ-ពស់វាយដោយរំពាត់ ហ្វឹកហាត់ឱ្យលេងនឹងពស់នឹងចងឱ្យវានាំដើរលេងទៅតាមច្រកតូចច្រកធំចុះ។

ស្វានោះបំណងយកសេចក្ដីទុក្ខ ដែលខ្លួនបានទទួលសេចក្ដីក្ដៅក្រហាយព្រោះអាយលម្អាយពស់ទើបបានពោលពាក្យស្បថដូច្នេះ។

កាលជននឹងសត្វទាំង១៣នាក់ នាំគ្នាស្បថដោយប្រការដូច្នេះហើយ ព្រះពោធិសត្វគិតថា ក្រែងជនទាំងនេះគេនឹងរង្កៀសសង្ស័យចំពោះយើងថារបស់មិនបាត់ក្លែងថាបាត់ដូចនេះអញនឹងស្បថឱ្យគេស្ដាប់ គិតហើយក៏ស្បថថា

ម្នាលលោកដ៏ចំរើនទាំងឡាយ! បព្វជិតណាក្លែងថារបស់ដែលមិនបាត់ថាបាត់ក្ដី ឬនៅសង្ស័យរង្កៀសក្នុងលោកទាំងនេះក្ដី បព្វជិតនោះ ចូរបានបរិភោគតាមគុណ៥ កុំបានបព្វជ្ជាដែលគួរជាទីត្រេកអរ ចូរស្លាប់នៅក្នុងកណ្ដាលនៃផ្ទះចុះ។

កាលតាបសទាំងឡាយ នាំគ្នាធ្វើពាក្យស្បថដូចច្នោះហើយ សក្កទេវរាជមានព្រះទ័យរំភើបយ៉ាងបំផុតគិតថា អាត្មាអញចង់ល្បងមើលចិត្តឫសីទាំង

នេះឱ្យជាក់ច្បាស់ ទើបធ្វើក្រអៅឈ្លកឱ្យអន្តរធានទៅ ឬសីទាំងនេះ បែរជានាំគ្នាតិះដៀលកាមគុណ នាំគ្នាស្បថដោយប្រការដូច្នេះ ចាំអាត្មាអញនឹងសួរហេតុដែលលោកតិះដៀលកាមគុណ ព្រោះហេតុដូចម្តេចខ្លះ លុះគិតហើយ សំដែងខ្លួនឱ្យប្រាកដ លើកដៃសំពះព្រះពោធិសត្វសួរថា ពួកសត្វទាំងឡាយក្នុងលោក នាំគ្នាដើរស្វែងរកនូវវត្ថុកាមនឹងកិលេសកាមណា ដោយកិច្ចផ្សេងៗ មានកសិកម្មនឹងគោរក្ខកម្ម(ការធ្វើស្រែចិញ្ចឹមគោ)ជាដើម វត្ថុកាមនឹងកិលេសកាមនោះ សុទ្ធតែជារបស់គួរជាទីស្រឡាញ់ពេញចិត្ត នឹងជាទីបំពោងចិត្តទេព្តានឹងមនុស្សទាំងឡាយដូចគ្នា ព្រោះហេតុអ្វី ព្រះឬសីទាំងឡាយ មិនសរសើរកាមគុណ?

លំដាប់នោះព្រះពោធិសត្វ ប្រាប់ព្រះឥន្ទថា:

បពិត្រទេវរាជ! បុគ្គលរមែងបៀតបៀនគ្នាដោយអាជ្ញាក្តី ឬចាប់ចងគ្នាដោយគ្រឿងចងទាំងឡាយ មានខ្សែព្រ័ត្រ ខ្នោះឃ្នាងជាដើមក្តី ព្រោះកាមតែម្យ៉ាង ឬទុក្ខភ័យដែលកើតឡើងដល់សត្វទាំងឡាយ ក៏ព្រោះកាមនេះឯង សត្វទាំងឡាយដែលជាអ្នកប្រមាទហើយ មានសេចក្តីវង្វេងស្រវឹងក្នុងកាមគុណ រមែងធ្វើកម្មដ៏លាមក សត្វទាំងឡាយនោះជាអ្នកមានបាបកម្មហើយ ក៏គង់សោយផលនៃបាបដោយពិត កាលអស់ជីវិតហើយ នឹងទៅកើតក្នុងនរកទៀត ព្រោះកាមគុណមានទោសដូចដែលពោលមកនេះឯង បានជាអាត្មាទាំងឡាយ ដែលជាពួកឬសីឃើញទោសដូច្នោះទើប មិនបានសរសើរ

កាមគុណ។

សម្តេចអមរិន្ទឥន្ទ្រាធិរាជ បានទ្រង់សណ្តាប់ទេសនារបស់ព្រះពោធិសត្វដូច្នោះហើយ មានព្រះទ័យតក់ស្លុតភ្ញាក់ ប្រាប់ព្រះពោធិសត្វថា បពិត្រលោក! ខ្ញុំចង់ល្បងចិត្តថា ព្រះឫសីទាំងនេះនៅមានចិត្តបង្អោនទៅដើម្បីកាមគុណឬទេ ទើបបានយកក្រអៅឈូករបស់ព្រះគុណម្ចាស់ ទៅទុកនៅក្បែរកំពង់ទឹក ឥឡូវនេះ ខ្ញុំដឹងដោយកិរិយាដែលលោកទាំងឡាយ នាំគ្នាស្បថដូច្នេះហើយ លោកទាំងនេះឈ្មោះថា ជាអ្នកមិនមានបាប សុទ្ធតែជាអ្នកបរិសុទ្ធស្អាតគ្រប់អង្គ។

ព្រះពោធិសត្វ បានស្តាប់ពាក្យរបស់សក្កទេវរាជដូច្នោះហើយបន្ទោសថា

បពិត្រសហស្សនេត្ត! ក៏ពួកអាត្មាមិនមែនជាអ្នកល្បែងលេងមិនសមលោកនឹងលលេង, ម្យ៉ាងទៀត ពួកអាត្មា ក៏មិនមែនជាញាតិ មិនមែនជាសំឡាញ់នៃលោកៗ មកមើលងាយ ព្រោះហេតុអ្វីទើបបានមកលលេងនឹងពួកតាបសទាំងនេះ។

លំដាប់នោះអមរិន្ទ្រាធិរាជ បានសូមព្រះពោធិសត្វឱ្យអត់ទោសថា លោកម្ចាស់ ជាអាចារ្យ ឬបិតារបស់ខ្ញុំ សូមទានអត់ទោសដល់ខ្ញុំដែលជាអ្នកបានភាំងភ្លាត់ហើយ បពិត្រលោកអ្នកមានប្រាជ្ញាដូចផែនដី ទំនៀមបណ្ឌិតទាំងឡាយ ជាអ្នកមានខន្តីជាកំឡាំង មិនក្រោធខឹងនឹងនរណា សូមលោកចូរអត់ទោសដែលជាកំហុសលើកដំបូងដល់ខ្ញុំចុះ។

ព្រះពោធិសត្វព្រមអត់ទោស ដល់សក្កទេវរាជហើយ ក៏សូមទោសឫសីទាំងឡាយថា:

កាលលោកដ៏មានអាយុទាំងឡាយជាឫសី បាននាំគ្នាមកនៅក្នុងព្រៃស្ទម្បីតែមួយរាត្រី ឈ្មោះថាមានសេចក្ដីល្អ យើងទាំងឡាយទើបបានឃើញសម្ដេចវាសវៈដែលជាអម្ចាស់ទេវតា នៃលោកដ៏ចំរើនទាំងឡាយ បើយើងនៅឯក្រុងណានឹងបានឃើញព្រះឥន្ទ ចូរលោកទាំងឡាយនាំគ្នាសោមនស្សត្រេកអរ នាំគ្នាអត់ទោសឱ្យសក្កទេវរាជចុះ ព្រោះអ្វីទើបយើងថាយ៉ាងនេះ ព្រោះដែលយើងជាអាចារ្យរបស់លោកទាំងឡាយ បានក្រអៅឈូកមកវិញហើយនាំបរិសុទ្ធគ្រប់ព្រះអង្គហើយ។

ទេវរាជអភិវាទពួកឫសីហើយ ក៏ត្រឡប់ទៅកាន់ទេវលោកវិញ ចំណែកពួកឫសីបានសម្រេចឈាននឹងអភិញ្ញា លុះអស់ជីវិតបានទៅកើតនាព្រហ្មលោកគ្រប់អង្គ។

(ចប់ភាគទី៤នៅមានភាគ៥ នឹងភាគជាលំដាប់តទៅទៀត)

# ប្រជុំនិទានជាតក

## ១. រឿងអរិយព្រានមានសីលជាខ្លឹម

( ចាក គ.ស. )

*( ពពួកវេនេយ្យសត្វទាំងឡាយមានសភាពផ្សេងៗគ្នាតាមសកម្មភាព )*

កាលព្រះសម្មាសម្ពុទ្ធទើបនឹងបានត្រាស់ថ្មីៗ ព្រះអង្គទ្រង់យាងទៅប្រោស បញ្ចវគ្គិយភិក្ខុ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ត្រាតែបានសម្រេចព្រះអរហត្តផលគ្រប់អង្គ ។ លំដាប់នោះព្រះអង្គទ្រង់ប្រោសយសកុលបុត្តឱ្យបានសម្រេចព្រះអរហត្តផល ព្រមទាំងសម្លាញ់ទាំង ៤នាក់ទៀត គឺព្រះវិមលត្ថេរ ព្រះសុពាហុកត្ថេរ១ ព្រះបុណ្ណជិ១ ព្រះគវម្បតិ ១ ។ បន្ទាប់ពីសម្លាញ់ ៤នាក់មក មានសម្លាញ់ ៥០នាក់ទៀតបានសម្រេច មគ្គផលដូចគ្នា, ក្នុងពេលនោះព្រះអង្គទ្រង់ប្រជុំពួកព្រះអរហន្តបាន ៦១ អង្គ ព្រមទាំងព្រះអង្គផង ទ្រង់មានព្រះពុទ្ធដីការថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយចាកអន្ទាក់ទាំងពួង, ទេវតានឹងមនុស្សទាំងឡាយឯណា មានក្នុងលោកនេះ ចូរអ្នកត្រាច់ទៅកាន់ចារិកផ្សេងៗពីគ្នា កុំទៅផ្លូវមួយគ្នាពីរនាក់ ដើម្បីដោះទុក្ខទេវតានិងមនុស្សទាំង នោះឱ្យបានចាករួចអន្ទាក់ផង ។ ព្រះអរហន្តទាំងនោះ ក៏ត្រាច់ទៅទីទៃពីគ្នាតាមព្រះពុទ្ធដីការព្រះអង្គ ។

ចំណែកព្រះសុពាហុកត្ថេរ បាននិមន្តទៅជនបទមួយ ដើម្បីប្រកាសសាសនា ។ នៅក្នុងជនបទនោះ មានត្រកូលព្រាហ្មណ៍មួយ ជាមនុស្សមិច្ឆាទិដ្ឋិតែងប្រព្រឹត្តបរបាញ់សត្វចិញ្ចឹមជីវិតរៀងរាល់ថ្ងៃ។ ថ្ងៃមួយព្រានជាកូនប្រសា រៀបចំប្រដាប់ប្រដាចេញទៅបរបាញ់សត្វ បានជួបនឹងព្រះសុពាហុកត្ថេរគង់នៅក្រោមដើមឈើមួយដើម ។ ព្រាននោះគិតថា អើថ្ងៃនេះឆ្នែងណាស់ ព្រោះជួបនឹងមនុស្សកាឡកណ្ណី ហើយក៏ដើរហួសទៅ. ថ្ងៃនោះរកបាញ់សត្វអ្វីពុំបានសោះ ក៏ត្រឡប់មកវិញ. ដើរមកក៏ជួបនឹងព្រះថេរៈម្តងទៀត ចេះតែទន្ទេញថាជួបនឹងមនុស្សកាឡកណ្ណីៗដូច្នេះ ទើបព្រះថេរៈសួរថា ម្នាលព្រាន ! អ្នកឈ្មោះអ្វី ? ព្រានឆ្លើយថា ខ្ញុំឈ្មោះអរិយៈ។ លោកមានថេរៈដីការថា ម្នាលព្រានជនអ្នកបៀតបៀនសម្លាប់សត្វទាំងឡាយមិនឈ្មោះអរិយៈទេ ឯព្រះអរិយៈទាំងឡាយលោកមិនដែល បៀតបៀនសត្វឡើយ. បណ្ឌិតហៅ អរិយៈ ដោយចំពោះតែបុគ្គលដែលអស់ការបៀតបៀនសត្វ ។ ហើយព្រះថេរៈក៏សំដែងពីគុណនៃព្រះរតនត្រ័យ និង អានិសង្សនៃសិលយ៉ាងពិរោះក្បោះក្បាយ ឱ្យព្រានស្តាប់ ហើយព្រានមានចិត្តរីករាយត្រេកអរជ្រះថ្លា ទើបសុំរៀនយកមន្តពីព្រះថេរៈៗ ក៏បង្រៀនព្រាននោះថា ពុទ្ធំសរណំ គច្ឆាមិ. ធម្មំ សរណំ គច្ឆាមិ. សង្ឃំ សរណំ គច្ឆមិ ។ ល ។ ហើយក៏ថ្វាយបង្គំលាព្រះថេរៈត្រឡប់ទៅផ្ទះវិញ ដើម្បីទន្ទេញមន្តនោះទាល់តែចាំ ។ ក្នុងថ្ងៃនោះព្រានរកបរ

បាញ់សត្វណាមួយក៏ពុំបាន សូម្បីឱ្យគ្រាន់តែជួបក៏មិនជួបផង លុះទៅដល់ផ្ទះប្រពន្ធក៏មិនម្ចាស់ផ្ទះមកទទួលដូចសព្វដង ព្រោះពីដើមគាត់ធ្លាប់រែកសាច់ទៅផ្ទះស្ទើរតែមិនរួច ប្លែកអ្វីថ្ងៃនោះក៏ដើរខ្លួនទទេមានតែប្រដាប់សម្រាប់បរបាញ់ នឹងកញ្ចប់បាយទឹកបំពង់ប៉ុណ្ណោះមាត់ចេះតែទន្ទេញមន្តនោះមិនឈប់សោះ ។ លុះប្រពន្ធឃើញគ្មានបានអ្វីសោះ ក៏កើតចិត្តក្តៅក្រហាយជេរស្តីបន្ទោសរហូតឈ្លោះប្រកែកគ្នា ទើបឪពុកក្មេកម្តាយក្មេកមកឃាត់ហើយសួររឿងហេតុដែលចេញទៅបរបាញ់ពុំបានអ្វីសោះ ។ ព្រានជាកូនប្រសារជម្រាបថា បានទៅជួបនឹងព្រះថេរៈ ១ អង្គគង់នៅក្រោមដើមឈើមួយលោកសម្តែងអំពីគុណនៃព្រះរតនត្រ័យ និងសិលឱ្យខ្ញុំស្តាប់ក៏មានចិត្តត្រេកអរហើយបានសុំលោករៀនមន្តនោះ. ឪពុកម្តាយបានស្តាប់ឮដូច្នោះ ហើយ ក៏រឹតតែជួយខឹង ជេរស្តីបន្ទោសបណ្តេញចេញពីផ្ទះថា បើអ្នកឯងនៅតែកាន់របៀបនេះ យើងឈប់ឱ្យអ្នកឯងនៅលើផ្ទះនេះតទៅទៀតហើយ ។ ទើបកូនប្រសារថា បើដូច្នោះឱ្យខ្ញុំធ្វើដូចម្តេច ? ឪពុកម្តាយប្រាប់ថាយកមន្តសិលទៅឱ្យលោកវិញទៅ ។ ព្រាននាំយកមន្តសិលដើរសំដៅទៅកាន់សំណាក់ព្រះថេរៈ លុះទៅដល់ហើយលោកសំដែងសរសើរអំពីគុណនៃព្រះរតនត្រ័យឱ្យស្តាប់ម្តងទៀត ហើយបាននិយាយជូនមន្តសិលនោះទៅលោកវិញ ព្រះថេរៈបានប្រាប់ថាមិនមែនមន្តសិលរបស់អាត្មាទេព្រោះអាត្មាបានរៀនមកអំពីព្រះសម្ពុទ្ធដែរ បើអ្នកចង់ជូន

មន្តសិលនោះ លុះតែទៅជូនដល់ព្រះឯណោះទើបបាន ។ ព្រាននោះគិតក្នុងចិត្តថាវិវរហើយអញមិនដឹងជាព្រះលោកគង់នៅឯណា ? ហើយមិនដឹងជាលោកទទួល ឬ មិនទទួលទេ ! ទើបទូលសួរព្រះថេរៈថា ព្រះគង់នៅឯណា ? លោកប្រាប់ថាគង់នៅឯវត្តជេតពន ចូរអ្នកទៅឯណោះចុះ ។

ថ្លែងពីបុរសព្រាននោះ កាលបើព្រះថេរៈមិនព្រមទទួលដូច្នោះហើយ ក៏ដើរសំដៅទៅកាន់វត្តជេតពននោះ លេចវាលចូលព្រៃយ៉ាងដាច់ស្រយាល បានទៅជួបនឹងនាងទេវប្រេត ៥០០ នាក់នៅជើងភ្នំមួយស៊ីសុទ្ធតែអាហារទិព្វ តែអាក្រាតកាយនៅខ្លួនទទេទាំងអស់គ្នា គ្មានសំលៀកបំពាក់អ្វីសោះ ។ នាងទេវប្រេតទាំងនោះ សួរអរិយៈព្រាននោះថាអ្នកអញ្ជើញទៅណា ? អរិយៈព្រានប្រាប់ថា ខ្ញុំនាំមន្តសិលទៅជូនព្រះ. ហើយក៏នាំបុរសនោះទៅកន្លែងរបស់ខ្លួន រៀបចំអាហារភោជនដ៏ជាទិព្វឱ្យបរិភោគយ៉ាងឆ្អែតឆ្អន់ស្កប់ស្កល់ស្រេចហើយ ផ្តាំថាបើអ្នកបានទៅជួបនឹងព្រះ សូមទូលសួរអំពីបុព្វកម្មរបស់ខ្ញុំ តើពីដើមបានធ្វើកម្មអ្វី បានជាកើតមកបរិភោគអាហារសុទ្ធតែទិព្វ ប៉ុន្តែគ្មានសំលៀកបំពាក់សោះ បើមានបន្តិចបន្តួចយកមកដាក់ប៉ះនឹងខ្លួនមិនបាន ? ។ ព្រាននោះទទួលបណ្តាំនាងទេវប្រេតទាំងនោះរួចហើយ ក៏លាធ្វើដំណើរតទៅទៀត បានជួបនឹងដីរសមួយ ស៊ីសុទ្ធតែបន្លា មានបន្លាឫស្សី នឹងបន្លាព្រេចជាដើមមុតមាត់ចេញឈាមហូររហាម រងទុក្ខវេទនា មានសេចក្តីលំបាកនឹងការ

ចិញ្ចឹមជីវិតក្រៃលែង មានខ្លួនស្គាំងស្គមនៅតែស្បែកនឹងឆ្អឹង, បើស៊ីស្មៅ ឬស្រូវ ដែលជាវត្ថុមានឱជារសក្រៅពីបន្លាចេញនាំឱ្យក្ដៅក្រហាយ អន្ទះអន្ទែងស្ទើរដាច់ខ្យល់ ។ ឯដីរីបានឃើញហើយសួរថាអ្នកអញ្ជើញទៅណា? ព្រាននោះប្រាប់ថា ខ្ញុំនាំយកមន្តសិលទៅជូនព្រះ ហើយផ្ដាំផ្ញើឱ្យទូលសួរព្រះចែកខ្ញុំផង ថាតើជាតិមុនខ្ញុំបានធ្វើកម្មអ្វី ? បានជាមកកើតជាដីរីស៊ីរបស់អ្វីៗដទៃទៀតមិនបាន ស៊ីបានតែបន្លា១មុខប៉ុណ្ណោះ មានការលំបាករងទុក្ខវេទនានឹងការចិញ្ចឹមជីវិតយ៉ាងខ្លាំង សូមទូលសួរចែកខ្ញុំកុំខាន ។

ព្រាននោះទទួលបណ្ដាំដីរីហើយ លាចរយាត្រាដោយបានដីរីចង្អុលបង្ហាញផ្លូវទៅមុខទៀត បានជួបនឹងពស់ថ្លាន់មួយ ដេកវៀនព័ទ្ធដំបូកទៅណោមកណោមិនរួចស្គាំងស្គមនៅតែស្បែកនឹងឆ្អឹងរកអាហារស៊ីមិនសូវបាន។ បានជួបនឹងព្រាននោះសួរថា អ្នកអញ្ជើញទៅណា ? ព្រាននោះបានប្រាប់ដូចមុន រួចហើយក៏និយាយផ្ដាំផ្ញើនឹងមាណោពនោះថា បើអ្នកបានទៅជួបនឹងព្រះ សូមអ្នកមេត្តាទូលសួរអំពីបុព្វកម្មរបស់ខ្ញុំ តើពីជាតិមុន ខ្ញុំបានធ្វើអំពើអ្វី ? បានជាមកកើតជាពស់ថ្លាន់ដេកវៀននៅតែមួយកន្លែង រកទៅណោមកណោមិនរួច ? ។

លុះបានទទួលពាក្យបណ្ដាំរបស់ពស់ថ្លាន់សំគមនោះហើយ ព្រាននោះលីលាយាត្រាសំដៅទៅទៀតបានជួបនឹងពួកអសុរស នៅក្នុងជនបទ

មួយតែងតែកាប់សម្លាប់គ្នាគ្មានលោះលាត្រាប្រណើ ខ្លះបែកក្បាល ខ្លះពកក្បាលចេញឈាម ហូររហាមពេញមុខមាត់ រងទុក្ខវេទនាយ៉ាងក្រៃ លែង ។ ក្នុង១ខែឈប់កាប់គ្នាបានតែត្រឹម ៤ ថ្ងៃប៉ុណ្ណោះ ក្រៅពីនោះគិតតែពីកាប់ចាក់សម្លាប់គ្នា រួចពីកាប់ចាក់ទៅក៏ស្រុះស្រួលបបួលគ្នាដាំបាយបរិភោគជាមួយគ្នា ដូចជាគ្មានខឹងទាស់ទែងនឹងគ្នា ឱ្យតែដល់ពេលក៏ចាប់ប្រតិបត្តិការកាប់ចាក់គ្នាទៀត ។ ពួកអសុរសបានឃើញព្រាននោះក៏សួរថា អ្នកអញ្ជើញទៅណា ? អរិយព្រានក៏បានប្រាប់ដូចមុន ហើយនាំទៅកន្លែងរបស់ខ្លួន ចាត់ចែងអាហារភោជនឱ្យបរិភោគឆ្អែតស្កប់ស្កល់ហើយនិយាយផ្តាំផ្ញើ បើអ្នកបានជួបនឹងព្រះ សូមអ្នកមេត្តាទូលសួរបុព្វកម្មរបស់ខ្ញុំ តើពីជាតិមុនបានធ្វើអំពើយ៉ាងណា ? បានជាមកកើតជាអសុរសនេះចេះតែកាប់ចាក់គ្នារាល់តែពេលគ្មានឈប់ឈរសោះ ក្នុង១អាទិត្យ បានឈប់កាប់ចាក់គ្នាបានតែ១ថ្ងៃប៉ុណ្ណោះ. ហេតុនេះសូមអ្នកទូលសួរចែកខ្ញុំកុំខាន ។

អរិយព្រានទទួលបណ្តាំពួកអសុររួចហើយ ក៏លាធ្វើដំណើរទៅទៀត បានជួបនឹងព្រះរាជា១អង្គ ព្រះនាមព្រះបាទសាលរាជ មានបុត្រី ២ ព្រះអង្គសុទ្ធតែជាក្រមុំសៅកែ ។ ក្នុង១ឆ្នាំៗព្រះរាជាត្រូវតែនាំព្រះរាជវង្សានុវង្សរត់ចេញពីរាជដំណាក់ ទៅគង់នៅស្រុកជាយដែន ដែលឆ្ងាយដាច់ស្រយាលអស់រយៈកាលកន្លះខែ ឬ ១ខែ ដោយនៅក្នុងព្រះរាជា

ដំណោក់ពុំបានសោះ. បើខំជំនះតែនៅនឹងកើតហេតុឧបទ្រព្យចង្រៃជាភ្លើង ឆេះក្តៅក្រហាយវិនាសអន្តរាយគ្មានសល់អ្វីឡើយ លុះត្រាតែអស់រយៈ កាលកន្លះខែ ឬ១ខែ ទើបយាងត្រឡប់ចូលមកក្នុងនគរវិញបាន ។ ព្រះ រាជាបានជួបនឹងអរិយព្រាន ក៏សួរតាមដំណើរដើមទង ទើបអរិយព្រាន ក្រាបទូលសេចក្តីដូចមុនទៀត ហើយក៏នាំទៅកន្លែងរបស់ខ្លួនរៀបចំចាត់ ចែងអាហារភោជនឱ្យបរិភោគឆ្អែតស្រេចហើយ បានផ្តាំផ្ញើនឹងអរិយ ព្រាននោះឱ្យទទួលសួរបុព្វកម្មចែកព្រះអង្គផង ។ អរិយព្រានទទួលយក បណ្តាំព្រះរាជារួចស្រេចហើយ ក៏ក្រាបលាធ្វើដំណើរទៅទៀតបានទៅជួប នឹងព្រះសម្ពុទ្ធចូលទៅនមស្ការថ្វាយបង្គំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់សួរ ថាម្នាលព្រានអ្នកមកពីណា ? អរិយព្រានក្រាបទូលតាមដំណើរសេចក្តី. ទើបព្រះអង្គទ្រង់សំដែងធម៌ទេសនាទូន្មានប្រៀនប្រដៅ អរិយព្រានបាន ស្តាប់ហើយ ក៏រឹងរិតតែមានចិត្តជ្រះថ្លាជាងមុនទៅទៀត ហើយគិតថា អញនឹងមិនលះបង់ចោលមន្តសីលនោះទេ អញនៅតែទន្ទេញឱ្យទាល់តែ ចាំមែនទែន.លុះគិតដូច្នោះហើយ ទើបក្រាបទូលព្រះអង្គថា បពិតព្រះអង្គ ដ៏ចំរើន កាលដែលខ្ញុំព្រះអង្គចេញធ្វើដំណើរពីស្រុកមក បានជួបនឹងនាង ទេវប្រេតចំនួន ៥០០នាក់នៅជើងភ្នំមួយ ស៊ីសុទ្ធតែអាហារទិព្វ ហើយ មានខ្លួនអាក្រាតទទេទាំងអស់គ្នា. យកសំពត់មកប៉ះពាល់នឹងកាយពុំបាន សោះ បើជំនះតែខំយកមកប៉ះនឹងខ្លួន ក៏បណ្តាលឱ្យក្តៅក្រហាល់ក្រហាយ

អន្ទះអន្ទែងស្ទើរតែដាច់ខ្យល់ ។ ពួកនាងទេវប្រេតទាំងនោះបានផ្តាំផ្ញើនឹងខ្ញុំព្រះអង្គឱ្យក្រាបទូលសួរអំពីបុព្វកម្មរបស់នាង តើពីជាតិមុននាងបានធ្វើកម្មដូចម្តេចខ្លះ ? ហេតុនេះសូមព្រះអង្គទ្រង់សំដែងបុព្វកម្មរបស់នាងទេវប្រេតទាំងនោះឱ្យខ្ញុំព្រះអង្គបានដឹងផង ។ ព្រះមានព្រះភាគទ្រង់ព្រះសណ្តាប់ពាក្យព្រាននោះហើយ ទើបព្រះអង្គទ្រង់នាំអតីតនិទានមកថា ម្នាលព្រាន នាងទេវប្រេតនោះ កាលពីដើមបានកើតជាស្ត្រីនៅក្នុងជនបទមួយតែងនាំគ្នាលក់ជ្រូកចិញ្ចឹមជីវិត ដល់កាលណាលក់ជ្រូកអស់ទៅបានប្រាក់យកទៅទិញគ្រឿងអលង្ការ សម្រាប់តុបតែងខ្លួនមានខ្សែរមាស នឹងទឹកអប់ម្សៅជាដើម មួយចំណែកទៀតបានអង្គាសប្រមូលប្រាក់គ្នាយកទៅ ចាត់ចែងធ្វើទានប្រគេនចំពោះព្រះសង្ឃ តែបាយទឹក នំចំណីប៉ុណ្ណោះមិនបានធ្វើចីវរទាននឹងសេនាសទានទេ ។ ដោយបាបកម្មដែលនាងចិញ្ចឹមជ្រូកនោះក៏បណ្តាលឱ្យនាងធ្លាក់ទៅកើតជាប្រេតរងទុក្ខវេទនាគ្មានសំពត់ស្លៀកដណ្តប់នឹងកន្លែងនៅឱ្យបានស្រួលបួល ព្រោះមិនបានធ្វើចីវរទាននឹងសេនាសនទាន ។ ដោយអំពើជាកុសលដែលនាងបានប្រគេនចង្ហាន់បិណ្ឌបាតចំពោះព្រះសង្ឃអានិសង្សនៃទាននោះ ក៏បណ្តាលឱ្យនាងបានអាហារទិព្វបរិភោគតែរាល់ពេលវេលាដូច្នេះឯង ។ ព្រានបានស្តាប់ចាំហើយ ទើបទូលពីរឿងដែលខ្លួនបានជួបដីរសុិបន្ទាតទៅទៀត ។

ព្រះអង្គទ្រង់នាំអតីតនិទានមកថា កាលពីព្រេងនាយដ៏រីនោះ បាន កើតជាអ្នកកាត់ក្តីប្រកបដោយអគតិទាំង ៤ ធ្វើអំពើអាក្រក់លាមកគ្រប់ បែបយ៉ាង មានស៊ីសំណូកជាដើម, ដល់ពេលកាត់ក្តីម្តងៗកាត់មិនដែល បានត្រឹមត្រូវតាមច្បាប់សោះ ប្រកបដោយអំពើអយុត្តិធម៌គ្រប់ជំពូក ។ ដល់គាត់អស់អាយុសង្ខារទៅ បានទៅកើតជាសត្វដ៏រីស៊ីតែបន្ទាដាច់មាត់ ចេញឈាមហូររហាមរងទុក្ខវេទនានៅទីនោះ ព្រោះតែអំពើអាក្រក់ដែល គាត់បានធ្វើឱ្យបណ្តាជនក្តៅក្រហាយ ដោយសារតែគាត់កាត់ក្តីមិនសុចរិត យុត្តិធម៌ ។ ព្រានទូលសួររឿងពស់ថ្លាន់ទៀតព្រះអង្គទ្រង់នាំអតីតនិទាន ថា កាលពីដើមពស់ថ្លាន់នោះកើតជាសេដ្ឋីមានទ្រព្យច្រើន តែកំណាញ់ ស្វិតស្វាញទ្រើស្ដីស្វួរជួជាតិណាស់ មិនដែលធ្វើបុណ្យទានដល់ស្មូមយាចក អ្នកកំសត់ទុគ៌តនាមួយឡើយ សូម្បីតែខ្លួនឯងក៏មិនហ៊ានស៊ីវត្ថុដែលមានឱ ជារសឆ្ងាញ់ពិសារផង ដល់ពេលជិតស្លាប់គាត់យកទ្រព្យទៅកប់ទុកគ្មាន ឱ្យនរណាម្នាក់ដឹងសោះ ។ លុះដល់ស្លាប់ទៅបានទៅកើតជាពស់ថ្លាន់វៀន នៅតែ១កន្លែងរកទៅណាពុំរួច ដោយហេតុតែសេចក្តីកំណាញ់ដែលគាត់ បានអប់រំសន្សំមកអស់កាលដ៏យូរបានជិតជាប់នៅក្នុងចិត្តរបស់គាត់ ម្ល៉ោះ ហើយក៏មិនហ៊ានទៅណាមកណា ព្រោះខ្លាចវិនាសអន្តរាយទ្រព្យសម្បត្តិ នោះ ដូច្នោះហើយ ក៏ស៊ូទ្រាំរងទុក្ខវេទនានឹងសេចក្តីស្រេកឃ្លានតាម យថាហេតុ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថាម្នាលព្រាន ពស់ថ្លាន់នោះដែលមិន

ហ៊ានវារទៅរកស៊ីឯណា ព្រោះនៅខាងក្រោមកន្លែងដែលវៀនទោះ សុទ្ធតែកំណប់ទ្រព្យ ដែលគាត់បានកប់ទុកពីអតីតជាតិ ។ ព្រានបានស្តាប់ហើយ ក៏ធ្វើមនសិការៈកត់សំគាល់ទុកក្នុងចិត្ត រួចទូលសួរពីរឿងពួកអសុរដែលកាប់សម្លាប់គ្នាគ្មានត្រាប្រណី ក្នុង១អាទិត្យត្រូវបានឈប់សម្រាកលែងកាប់គ្នាបានតែ១ថ្ងៃ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រានក្នុងកាលខណ្ឌខាំងកំបាំងបាត់ស្នាត់កន្លងរំលងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅនគរមួយទ្រង់ប្រកបដោយទសពិធរាជធម៌ ព្រះអង្គទ្រង់ដាក់អាជ្ញាថា ក្នុង ១អាទិត្យ ត្រូវប្រជារាស្ត្រទាំងអស់ឈប់សម្រាកប្រកបការងារក្នុងថ្ងៃសិល ១ ថ្ងៃ ។ ត្រូវនាំគ្នារក្សាសិលឱ្យបានជានិច្ច បើនរណាមិនប្រតិបត្តិតាមត្រូវទទួលទណ្ឌកម្មតាមព្រះរាជអាជ្ញា ។ ចំណែកបណ្តារាស្ត្រមានកិច្ចការប្រកបផ្សេងៗគ្នា ខ្លះប្រកបខាងកសិកម្ម ខ្លះខាងលក់ស្រា ខ្លះលេងល្បែងស៊ីសងមានបញ្ជល់មាន់ជាដើម ក៏នាំគ្នាឈប់ប្រកបកិច្ចការទាំងនោះក្នុងថ្ងៃសិលតាមព្រះរាជអាជ្ញា ខ្លះបានរក្សាសិល ខ្លះទៀតក៏គ្រាន់តែឈប់ស្ងៀមទទេដោយខ្លាចអំណាចអាជ្ញាព្រះមហាក្សត្រ ។

ចំណែកពួកជនមួយក្រុម ជាអ្នកប្រព្រឹត្តអំពើអបាយមុខខាងបញ្ជល់មាន់គ្មានលស់ថ្ងៃណាមួយ, ដល់ព្រះរាជាទ្រង់ដាក់អាជ្ញាដូច្នោះ ក៏នាំគ្នាឈប់លេងល្បែងបញ្ជល់មាន់ក្នុងថ្ងៃសិល ផុតតែពីថ្ងៃនោះនាំគ្នា

បញ្ឆលមានទៀត ប្រព្រឹត្តតែអំពើបាបអកុសលយ៉ាងនេះរហូតដល់ចាស់ជរាតែរៀងៗខ្លួន ។ លុះផុតអាយុសង្ខារបានទៅកើតជាពួកអសុរតែងកាប់សម្លាប់គ្នាគ្មានត្រាប្រណី ដោយផលកម្មអាក្រក់ដែលខ្លួនបានប្រព្រឹត្តបញ្ឆលមានពីជាតិមុន ក៏ហុចផលផ្តលឱ្យចាក់កាប់សម្លាប់គ្នាយ៉ាងនេះ, ហើយដែលបានឈប់សម្រាកលែងកាប់គ្នា ១ថ្ងៃ ព្រោះខ្លាចអំណាចអាជ្ញាព្រះរាជាដែលបានកំរិតយ៉ាងតឹងតែង, ម្ល៉ោះហើយពួកអសុរនោះក៏ត្រូវបានរួចខ្លួនសុខសប្បាយក្នុង១អាទិត្យបានតែ ១ ថ្ងៃប៉ុណ្ណោះ ដូចអ្នកឃើញស្រាប់ហើយ ។ ព្រានបានស្តាប់និទាននោះហើយ ទើបទូលសួរព្រះមានបុណ្យពីរឿងព្រះរាជា១ព្រះអង្គតាមលំដាប់ហូរហែមកទៀត ។

ព្រះអង្គទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា ព្រះរាជាអង្គនោះកាលពីដើមកើតជាកុដុម្ពីមានបុត្រពីរនាក់ ជាអ្នកធ្វើស្រែចំការមានទ្រព្យច្រើន តែងជួលពួកកម្មករឱ្យកាប់ឆ្កាព្រៃធ្វើស្រែចំការក្នុង ១ឆ្នាំម្តង, លុះកាប់រួចហើយគ្រាន់តែព្រៃនោះស្ងួតស្រពាប់ល្មម១ ក៏យកភ្លើងទៅដុតឆេះស្លាប់សត្វទាំងតូចទាំងធំ តាំងពីស្រមោច-កណ្តូប-សង្កាជាដើម ដោយគ្មានសេចក្តីមេត្តាករុណា ចំពោះសត្វតូចតាច ទាំងមិនបានដេញសត្វដែលឃើញឱ្យរត់ចេញឡើយ ។ ម្ល៉ោះហើយក៏ត្រូវឆេះស្លាប់ក្នុង ភ្លើងនោះទៅ ។ ដោយពៀរវេរា ដែលព្រះអង្គដុតព្រៃឆេះសត្វស្លាប់សត្វតូចតាចអស់ជាច្រើននេះបណ្តាលឱ្យក្តៅក្រហាយរងទុក្ខវេទនាគង់នៅក្នុងព្រះរាជដំណាក់

ពុំបាន ក្នុង១ឆ្នាំត្រូវតែនាំគ្រួសាររត់ចេញទៅនៅជនបទអស់រយៈកាលកន្លះខែ ឬ១ខែ ទើបត្រឡប់ចូលមកវិញបាន ដោយបាបកម្មដែលព្រះអង្គបានធ្វើនោះឯង ។

ព្រានបានស្តាប់អតីតទាន ដែលព្រះមានព្រះភាគទ្រង់នាំមកសំដែងចប់សព្វគ្រប់ហើយ ក៏លើកករប្រណម្យថ្វាយបង្គំលាព្រះមានបុណ្យត្រឡប់ទៅវិញ ដើម្បីនាំយកពតិមាននោះទៅប្រាប់ដល់ជនទាំង ៥ នាក់ឱ្យបានដឹងពីបុព្វកម្មដែលខ្លួនបានធ្វើពីក្នុងអតីតជាតិ ។ លុះគាត់ដើរត្រឡប់ទៅវិញបានជួបនឹងព្រះរាជា ហើយអធិប្បាយរឿងនោះទូលព្រះរាជាឱ្យបានជ្រាបតាមដំណើរសេចក្តីហូរហែ ព្រះរាជាបានទ្រង់ព្រះសណ្តាប់ហើយ ក៏មានព្រះទ័យនឹកសង្វេគខ្លោចផ្សាចំពោះបាបកម្មដែលព្រះអង្គបានប្រព្រឹត្ត ហើយលើកបុត្រទាំង ២ អង្គប្រគល់ឱ្យអរិយព្រានធ្វើជាប្រពន្ធ ។ លុះអំណើសតមកព្រះអង្គប្រគល់រាជសម្បត្តិទាំងអស់ឱ្យអរិយព្រានជាកូនប្រសាគ្រប់គ្រងជំនួសព្រះអង្គ តាំងពីពេលនោះមកអរិយព្រានបានឡើងជាស្តេចព្រះនាម **សីលសាររាជ** ។ ព្រះបាទសីលសាររាជទ្រង់នាំពួកពលសកលយោធាយាងធ្វើដំណើរទៅទៀត ដើម្បីយកពតិមានទៅប្រាប់ពួកអសុរ លុះទៅដល់ហើយបានអធិប្បាយប្រាប់ដូចលើកមុន ។ ឯពួកអសុរទាំងអស់ បានប្រគល់កាយថ្វាយខ្លួនជាបរិវារ ។ ឯផលកម្មអកុសលដែលខ្លួនបានធ្វើនោះ ក៏បានផុតរលត់លែងកាប់សម្លាប់

គ្នាទៅទៀតពីពេលត្រឹមពេលដែលខ្លួនបានដឹងនោះមក ។ រួចទ្រង់យាងទៅប្រាប់ពស់ថ្លាន់នោះទៀតថា ពីជាតិមុនពស់ឯងធ្លាប់កើតជាសេដ្ឋីម្នាក់មានទ្រព្យសម្បត្តិស្តុកស្តម្ភ ប៉ុន្តែជាមនុស្សកំណាញ់ស្វិតស្វាញ មិនធ្វើបុណ្យឱ្យទានដល់ស្មូមយាចកអ្នកកំសត់ទុគតិឡើយ ម្ល៉ោះហើយបានជាឯងមកកើតជាពស់ថ្លាន់នេះ នៅខាងក្រោមដំណេកឯងក្នុងដំបូកនេះមានកំណប់ទ្រព្យជាច្រើនដែលអ្នកឯងបានកប់ទុកពីជាតិមុន យើងបានដឹងពតិមាននេះសព្វគ្រប់អស់ហើយ ។ ចំណែកពស់ថ្លាន់លុះបានដឹងដូច្នោះហើយ ក៏ប្រគល់ទ្រព្យទាំងអស់របស់ខ្លួនថ្វាយព្រះរាជាក្នុងពេលនោះ ។ ឯព្រះបាទសីលសាររាជលុះបានកំណប់ទ្រព្យ ដែលពស់ប្រគល់ឱ្យមកនោះយកទៅធ្វើបុណ្យឱ្យទានឧទ្ទិសចំណែកកុសលផ្តល់ឱ្យពស់ថ្លាន់នោះ ក៏បានរួចផុតចាកសេចក្តីទុក្ខ បានសោយសុខសម្បត្តិជាសុខក្សេមក្សាន្តតាំងពីពេលនោះរៀងដរាបមក ។

បន្ទាប់មកទ្រង់នាំពួកបរិវារដើរទៅកន្លែងដំរីទៀត លុះទៅដល់ហើយក៏និយាយរឿងរ៉ាវប្រាប់ដំរីនោះឱ្យបានដឹងសព្វគ្រប់ ។ ឯដំរីកាលបើបានដឹងបាបកម្មដែលខ្លួនធ្វើអំពើអយុត្តិធម៌ពេញបន្ទុក ឥតមានការកោតក្រែងញញើតអ្វីសោះ ព្រោះហេតុនេះបានជាបណ្តាលឱ្យទៅកើតជាដំរីស៊ីតែបន្លាមុតមាត់ចេញឈាមតែរាល់ថ្ងៃនោះហើយ, ក៏សុខចិត្តប្រគល់កាយថ្វាយខ្លួនជាសេនាព្រះបាទសីលសាររាជតាំងពីពេលនោះ ហើយបាន

រួចចាកសេចក្ដីទុក្ខគ្រប់យ៉ាង បានសោយសុខក្សេមក្សាន្តជាភិយ្យោភាព ដោយសារចំណែកកុសល ដែលព្រះបាទសីលសាររាជ បានឧទ្ទិសផ្សាយទៅឱ្យ ។ លំដាប់ពីនោះមកព្រះអង្គទ្រង់បន្តដំណើរទៅមុខទៀត ដើម្បីយកដំណឹងនេះទៅប្រាប់ដល់ពួកនាងទេវប្រេតទាំង ៥០០ ដែលបានផ្ដាំផ្ញើពីពេលមុន លុះដល់ពួកនាងទេវប្រេតទាំង ៥០០ មានចិត្តត្រេកអររីករាយនាំគ្នាចាត់ចែងអាហារភោជនថ្វាយព្រះអង្គសោយ លុះសោយរួចស្រេច ទើបទ្រង់ថ្លែងបុព្វកម្មរបស់នាងទេវប្រេតទាំងនោះឱ្យបានដឹងថា កាលពីមុននាងកើតជាមនុស្សរកស៊ីចិញ្ចឹមជ្រូកលក់ លុះបានប្រាក់មកយកទៅទិញសំលៀកបំពាក់ នឹងគ្រឿងអលង្ការសម្រាប់តាក់តែងខ្លួនមានម្សៅប្រេងជាដើម. លុះសម័យថ្ងៃមួយបាននាំគ្នាចាត់ចែងធ្វើចង្ហាន់ដាក់បាត្រព្រះសង្ឃ ដោយសារអំណាចអានិសង្សនៃបិណ្ឌបាតទាននោះ ក៏នាំឱ្យនាងទាំងអស់គ្នាបានមកកើតជាទេវប្រេត សោយអាហារសុទ្ធតែទិព្វ. ចីវរទានពួកនាងមិនបានឱ្យទេ ព្រោះហេតុនោះហើយបានជានាងរងទុក្ខវេទនារកសំលៀកបំពាក់គ្មាន ។ ចំណែកពួកនាងទេវប្រេតទាំង ៥០០ លុះបានស្ដាប់អតីតនិទានរបស់ខ្លួនដូច្នោះហើយ ក៏នឹកតក់ស្លុតតូចចិត្តអាណិតខ្លួនគ្រប់ៗគ្នា រួចបានប្រគល់កាយថ្វាយខ្លួនធ្វើជាបរិវារទាំងអស់គ្នាបានសុខសប្បាយរួចចាកទុក្ខទាំងពួង ដោយសារកុសលផលបុណ្យ

ដែលព្រះបាទសីលសារាជ បានឧទ្ទិសផ្សាយទៅឱ្យតាំងពីត្រឹមពេលនោះរៀងដរាបមក ។

## ២_រឿងឥសីមាត់ទិព្វ

( ចាក គ.នា )

( ការមើលងាយអ្នកមានតេជៈច្រើន ត្រូវវិនាសខ្លួនយ៉ាងទាន់ហន់ )

កាលពីព្រេងនាយមានឥសីមួយអង្គនៅព្រៃហេមពាន្ត ចេះសិល្ប៍ពូកែចំណានលើសឥសីទាំងពួង ជាអ្នកកាន់សច្ចៈទៀងទាត់ទើបមាត់របស់លោកក្លាយទៅជាមាត់ទិព្វ និយាយថាយ៉ាងណា បានយ៉ាងនោះ ។

សម័យមួយព្រះរាជាក្នុងដែនមគធៈ នាំព្រះអគ្គមហេសី នឹងព្រះរាជធីតាព្រមទាំងបរិវារទៅក្រសាលឧទ្យាន បានជួបនឹងឥសីនោះនៅក្នុងព្រៃពាក់កណ្ដាលផ្លូវ ។ ព្រះរាជាគង់លើរាជយានស្រែកសួរចំពោះឥសីថា លោកមកអង្គុយធ្វើអ្វីក្នុងអាណាខេត្តរបស់យើងនេះ លោកឈ្មោះអ្វី ? នៅក្នុងទីណា ? ។ ឥសីកំពុងចូលឈាន ឥតបានឮព្រះសូរសីហនាទរបស់ព្រះរាជាអង្គនោះឡើយ ។ ព្រះរាជាទ្រង់ពិរោធជាខ្លាំង ចុះចាករាជយានយាងសំដៅទៅរកឥសីត្រាស់សួរខ្លាំងៗ ឥសីនៅតែគង់ពែនភ្នែនដដែលព្រោះចិត្តលោកនៅក្នុងឈាន ។ ព្រះរាជាខ្ញាល់ខ្លាំងណាស់ថាឥសីនេះកោង អប្បាលយើងជាមហាក្សត្រម្ចាស់ផែនដីសួរមិនឆ្លើយ ទើបយក

ព្រះបាទធាក់ឥសីដួលដេកលើដី ហើយត្រាស់ប្រើរាជអមាត្យឱ្យយកដុំថ្ម ធំៗ សង្កត់ឥសីនោះ ដរាបដល់មានកំពស់ដូចដំបូកហើយយាងហួសទៅ ។

ដល់គ្រប់៧ថ្ងៃឥសីចេញចាកឈាន គឺមានសេចក្ដីទុក្ខវេទនា ដោយដុំថ្មសង្កត់នោះយ៉ាងក្រៃលែង ទើបលោកនិយាយថា ដុំថ្មនេះចូរក្លាយទៅជារូបអ្នកដែលព្យាបាទយើងចុះ ថាតែប៉ុណ្ណោះដុំថ្មទាំងនោះបាត់អស់ទៅ ពួកព្រះរាជា ព្រះអគ្គមហេសី ព្រះរាជធីតា ព្រមទាំងរាជបរិវារទាំងអស់ ដែលមានចិត្តព្យាបាទលោកកំពុងតែនៅក្នុងនគរ ក៏ក្លាយទៅជាថ្មទាំងអស់ ។ ពួកអ្នកនគរផ្អើលជ្រួលជ្រើមព្រោះគ្មានដឹងហេតុអ្វីសោះ ស្រាប់តែជនទាំងនោះក្លាយទៅជាថ្ម ក៏ខំបន់ស្រន់រៀងៈខ្លួន ទោះបីខំបន់ស្រន់បួងសួងឱ្យវត្ថុសក្ដិសិទ្ធិជួយយ៉ាងណា ក៏មិនអាចធ្វើជនទាំងនោះក្លាយជាមនុស្សដូចដើមបាន ។

ចំណែកឥសីមាត់ទិព្វ លោកនិមន្តទៅអាស្រមលោកវិញ មានអាពាធជាទម្ងន់ដោយរូបកាយលោកបាក់បែកខ្ទេចខ្ទីអស់ ។

ឯពួកទេវតាដែលរក្សានគរ រក្សាស្វេតឆត្រព្រះរាជានោះ កើតទុក្ខក្រៀមក្រំគ្រប់ៗគ្នា ដោយបានដឹងថាជនទាំងនេះ ត្រូវបណ្ដាសាឥសី មិនអាចអ្នកណាជួយឱ្យក្លាយជាមនុស្សវិញបាន ។ ទើបនាំគ្នាទៅកាន់សំណាក់ឥសី ដើម្បីសុំឱ្យជនទាំងនោះក្លាយជាមនុស្សវិញ ។

ឥសីប្រាប់ទេវតាថាកំហុសរបស់អ្នកណា ទាល់តែអ្នកនោះមកសុំទោសទើបបាន ព្រោះអំពើល្អអាក្រក់របស់អ្នកណា ត្រូវតែខ្លួនអ្នកនោះទទួលផល អ្នកដទៃជួសមិនបាន ។

ពួកទេវតាទាល់គំនិត ក៏ត្រឡប់ទៅនគរវិញ ។ ពេលបន្ទាប់នោះឥសីដឹងខ្លួនថានឹងអស់ព្រះជន្មថ្ងៃនោះហើយ ទើបលោកហៅនាយទិព្វវង្សជាសិស្សសំណប់របស់លោកមកប្រាប់ថា : អាត្មាត្រូវស្លាប់ក្នុងថ្ងៃនេះហើយ ឯងត្រូវកាន់សច្ចៈសុចរិតចុះ យើងឱ្យអ្នកឯងពូកែមានអំណាចធំជាងគេក្នុងលោកនេះ ឯគូព្រេងរបស់ឯង គឺនាងចន្ទរស្មី ជាព្រះរាជធីតារបស់ព្រះរាជាដែនមគធៈ ឥឡូវក្លាយទៅជាថ្មហើយ នៅ១ពាន់ឆ្នាំទៀតទើបរួសទោសក្លាយជាមនុស្សវិញ ។ ឯងត្រូវស្វែងរកផ្លែស្វាយទិព្វនៅក្នុងព្រៃហេមពាន្តយកមកស៊ីឱ្យបាន ទើបខ្លួនឯងនៅក្មេងដដែល បើរកមិនបានទេ មុខជាអស់បានជួបគូព្រេងឯងហើយ ព្រោះឯងមិនអាចរស់នៅបាន ១ ពាន់ឆ្នាំទេ ។ ឥសីប្រាប់នាយទិព្វវង្សជាសិស្សសំណប់តែប៉ុណ្ណោះ ក៏ឱ្យថ្នាំ១ដុំប្រាប់ថា ដល់គ្រប់ ១ ពាន់ឆ្នាំ ឯងយកថ្នាំនេះលាយនឹងទឹកស្រោចលើរូបថ្មចុះ នឹងក្លាយជាមនុស្សបានដូចបំណងហើយ លោកក៏សុគតទៅ ។

ដោយអំណាចមាត់ទិព្វរបស់ឥសី នាយទិព្វវង្ស ក៏ពូកែមានអំណាចធំជាងគេក្នុងលោកមែន សូម្បីព្រះអាទិត្យក៏មិនហ៊ានបញ្ចាំង

កំដៅឱ្យត្រូវដែរ គឺបើនាយទិព្វវង្សទៅក្នុងទីណាមេឃស្រទំក្នុងទីនោះជាដរាប ។

ក្រោយដែលនាយទិព្វវង្សបួជាសពឥសីជាគ្រូហើយ នាយដើរសំដៅទៅនគរមគធៈ ដើម្បីឱ្យឃើញមុខគូព្រេងរបស់នាយ ។ គួរអស្ចារ្យនឹងអំណាចរបស់នាយទិព្វវង្សណាស់ គឺរូបព្រះរាជា ព្រះអគ្គមហេសី ព្រះរាជធីតាដែលក្លាយទៅជាថ្មនោះ ពួកមហាជនបានធ្វើចេតិយដាក់បិទសន្ធប់យ៉ាងជិតហើយមាំមួនណាស់ មានអ្នកថែរក្សាច្រើនជាន់ច្រើនសង្កាត់ ព្រោះខ្លាចរូបថ្មនេះបាក់បែកខូច ។ នាយធ្វើដំណើរទៅដល់នគរមគធៈ បានសួរអ្នកយាមនគរថា ព្រះរូបថ្មនៅក្នុងទីណា គេចង្អុលប្រាប់ចេតិយដែលមើលឃើញច្បាស់ ។ នាយត្រេកអរណាស់ ដើរសំដៅទៅរក តែពួកអ្នកយាមទ្វារមិនឱ្យចូលទៅជិត ទើបនាយបួងសួងថាបើព្រះរាជធីតានោះត្រូវជាគូព្រេងដូចឥសីថាមែន សូមឱ្យចេតិយបាក់បែកអស់ ហើយរូបថ្មទាំងបីអណ្តែតឡើង គ្រាន់តែបួងសួបចប់ចេតិយក៏បាក់បែកខ្ទេច កំរើកញាប់ញ័រពេញនគរ រូបទាំងបីក៏អណ្តែតឡើង ឯរូបនាងចន្ទរស្មីធ្លាក់មកជិត នាយស្ទុះទៅឱបរូបនោះបបោសអង្អែល ហើយនិយាយថា ឱគូព្រេងកំសត់នៅ ១ ពាន់ឆ្នាំទៀតទើបយើងបានជួបគ្នា ឥឡូវបងត្រូវចូលទៅព្រៃហេមពាន្ត ដើររកផ្លែស្វាយទិព្វបរិភោគ ដើម្បីបន្តជីវិតបងឱ្យរស់នៅស្មើនឹងជីវិតប្អូន សូមប្អូននៅចាំបងក្នុង

ចេតិយនេះវិញចុះ ថាតែប៉ុណ្ណោះចេតិយកើតឡើងភ្លាមរូបទៅនៅចេតិយនោះដូចដើម ។

ពួកអ្នកនគរបានឃើញ បានដឹងហេតុអស្ចារ្យដូច្នោះ នាំគ្នាចូលទៅរកនាយទិព្វវង្ស អញ្ជើញឱ្យសោយរាជ្យ តែនាយមិនព្រមទទួល ព្រោះមិនទាន់ទៅរកផ្លែស្វាយទិព្វបាន ។

ផ្លែស្វាយទិព្វមានឱជារសឆ្ងាញ់យ៉ាងក្រៃលែង ដុះនៅក្នុងទីកំបាំងមិនអាចមនុស្សលោកទៅរកឃើញឡើយ ទាល់តែអ្នកមានបុណ្យទើបទៅដល់ ។ ផ្លែស្វាយទិព្វនោះក្នុង ១រយឆ្នាំ ផ្លែម្ដង បើអ្នកណាបានស៊ីហើយ មានសាច់ឈាមល្អដូចទេវតា បើចាស់ក្លាយទៅជាក្មេង ស៊ីម្ដងបន្តអាយុបាន ១រយឆ្នាំ ។

នាយទិព្វវង្សដើររកក្នុងព្រៃហោមពាន្តយូរខែឆ្នាំណាស់ ទើបបានជួបផ្លែស្វាយទិព្វនោះតែពុំអាចចូលទៅជិតបាន ព្រោះមានយក្សកំណាចៗនៅចាំរក្សាជាច្រើន ។

ពួកយក្សបានធ្វើបាបនាយទិព្វវង្សជាច្រើនប្រការ មានធ្វើជាខ្យល់ព្យុះ ធ្វើជាភ្លើងឆេះ ធ្វើជាទឹកភ្លៀងជោរជន់ នឹងចោលដុំថ្មធំៗជាដើម តែមិនអាចប៉ះពាល់ត្រូវដល់រូបកាយនាយទិព្វវង្សឡើយ ។ ពេលក្រោយយក្សដឹងថាទិព្វវង្សពូកែមានអំណាច ទើបនិម្មិតខ្លួនជាស្រីរូបល្អស្អាតចូលទៅប្រលោមតែនាយមិនរវល់ កាន់តែសច្ចៈសុចរិតតាមបណ្ដាំ

ឥសីយ៉ាងមាំមួន ពួកយក្សទាល់គំនិតក៏ព្រមបេះផ្លែស្វាយទិព្វឱ្យ ។ នាយទិព្វវង្សតាំងទីសំណាក់នៅក្បែរដើមស្វាយទិព្វនោះ ដល់១រយឆ្នាំបេះស៊ីម្ដង១ គ្រប់ ១ពាន់ឆ្នាំ ទើបត្រឡប់ទៅនគរមគធៈវិញ ដើម្បីប្រស់គូព្រេងរបស់គេឱ្យក្លាយពីថ្មមកជាមនុស្សវិញ ។

គួរឱ្យអាណោិតនាយទិព្វវង្សណាស់ ឥតដឹងថាពួកយក្សលួចយកថ្នាំដែលឥសីប្រគល់ឱ្យសំរាប់ធ្វើឱ្យថ្មក្លាយជាមនុស្សសោះ ស្រាប់តែទៅជិតដល់នគរមគធៈ ទើបដឹងថាបាត់ថ្នាំដែលខ្លួនបានរុំដោយអំបោះច្រើនជាន់ហើយចងភ្ជាប់នឹងចង្កេះ ។ ក៏វិលត្រឡប់ទៅរកក្បែរដើមស្វាយទិព្វវិញ ។ ឥតអំពើសោះថ្នាំនោះយក្សលួចយកទៅចោលក្នុងសមុទ្ទជិត ៥ រយឆ្នាំមកហើយ ។ ក្នុងពេលដែលចោលនោះ ស្ដេចក្រពើបានលេបចូល ទៅក្នុងពោះក៏កើតក្ដៅក្រហាយនៅក្នុងទឹកពុំបាន ឡើងទៅក្រាំងនៅ ក្នុងព្រៃយូរ១ ទើបក្រពើនោះក៏ក្លាយទៅជាសត្វមាស ។

មានឥសីមួយរូបឈ្មោះអគ្គិនេត្រ តាំងអាស្រមនៅក្បែរមាត់សមុទ្ទ បើលោកខ្ញាល់នឹងអ្នកណាបើកភ្នែកឡើងភ្លើងឆេះអ្នកនោះខ្ទេចខ្ទីអស់ លោកបានដឹងថាពួកយក្សបានលួចយកថ្នាំរបស់ទិព្វវង្ស ដែលជាសិស្សរបស់ឥសីមាត់ទិព្វទៅចោលក្នុងសមុទ្ទ ស្ដេចក្រពើបានលេបថ្នាំនោះហើយក្ដៅក្រហាយឡើងទៅក្រាំងនៅក្នុងព្រៃ ក្រពើនោះក៏ក្លាយទៅជាសត្វមាស ទើបលោកខាបយកសត្វមាសនោះមកចិញ្ចឹម សំរាប់ធ្វើជា

យានជំនិះរបស់លោក ដើម្បីថែរក្សាថ្នាំទុកឱ្យម្ចាស់គេវិញ ។ ដែលលោកដឹងបានយ៉ាងនេះព្រោះក្នុងពេលដែលយក្សយកទៅចោល បណ្ដាលឱ្យក្ដៅក្រហាយដល់ទេវតារក្សាសមុទ្ទ១បានមកប្រាប់ដល់លោក ។

ចំណែកនាយទិព្វវង្សកាលបើទៅដល់ដើមស្វាយទិព្វ ហើយរកមិនឃើញបានចោទប្រកាន់ចំពោះពួកយក្ស បណ្ដាលកើតឈ្លោះប្រកែកវាយតប់គ្នាជាខ្លាំង ពួកយក្សចាញ់ដៃ ក៏ចេះតែរត់ថយក្រោយ ទៅដល់អាស្រមឥសីអគ្គីនេត្រ ឥសីភ្ញាក់នឹងសទ្ទិកជើងយក្សបើកភ្នែកឡើងប្រកបដោយកំហឹង ក៏ឆេះពួកយក្សខ្ទេចខ្ទីអស់ នៅសល់តែនាយទិព្វវង្សមិនឆេះ ព្រោះបានអំណាចដែលឥសីមាត់ទិព្វប្រទានឱ្យ ។

ឥសីអគ្គីនេត្របានឃើញនាយទិព្វវង្សមិនឆេះ ក៏អស្ចារ្យក្នុងចិត្តថាបុរសនេះពូកែណាស់តាំងពីដើមមកមិនដែលឃើញដូច្នេះសោះ ទើបលោកសួរដឹងសព្វគ្រប់ហើយប្រាប់ថា ៖ ថ្នាំរបស់អ្នកនោះពួកយក្សវាលួចយកទៅចោលក្នុងសមុទ្ទ ស្ដេចក្រពើបានលេបចូលទៅក្នុងពោះកើតក្ដៅក្រហាយឡើងទៅក្រាំងក្នុងព្រៃក៏ក្លាយទៅជាសត្វរមាស ឥឡូវយើងយកសត្វរមាសនោះមកចិញ្ចឹមទុកឱ្យ ចូរអ្នកយករមាសនេះធ្វើជាយានជំនិះទៅចុះ ឯថ្នាំនោះរលាយរលួយក្នុងពោះរមាសអស់ទៅហើយ បើអ្នកត្រូវការប្រស់រូបថ្មគ្រាន់តែយកទឹកមាត់រមាសទៅលាបលើថ្មបានហើយ ។

នាយទិព្វវង្សលាឥសីអគ្គិនេត្រ ជិះរមាសសំដៅទៅនគរមគធៈ ទៅដល់រកចេតិយស្ទើរតែមិនឃើញ មានព្រៃដុះជុំជិត ព្រោះមនុស្សលែងនៅក្នុងទីនោះជិត ១ ពាន់ឆ្នាំ មកហើយ ។

នាយទិព្វវង្សចេះតែជិះរមាសរុករកព្រៃទៅ ក៏បានប្រទះឃើញចេតិយនោះហាក់ដូចជាអស់សង្ឃឹម ប៉ុន្តែនាយនឹកដល់អានុភាពរបស់ឥសីជាគ្រូថា មាត់របស់លោកជាមាត់ទិព្វ ពុំដែលប្រែប្រួលខុសសំដីរបស់លោកទេ ទើបនាយលើកដៃប្រណម្យ ហើយបួងសួងថា ដោយអានុភាពនៃគ្រូរបស់ខ្ញុំ សូមឱ្យព្រៃនេះវិនាសអស់ទៅប្រាសាទ នឹងគេហស្ថានទាំងឡាយ ព្រមទាំងទេសភាពគ្រប់យ៉ាងរបស់នគរមគធៈក្នុងសម័យមុននេះ ១ពាន់ឆ្នាំកើតឡើងដូចដើមវិញ ថាតែប៉ុណ្ណោះប្រាសាទ នឹងគេហស្ថានទាំងឡាយ ព្រមទាំងទេសភាពគ្រប់យ៉ាងកើតប្រាកដដូចដើមវិញទាំងអស់ ទើបនាយនាំរមាសចូលទៅក្នុងចេតិយយកទឹកមាត់លាបរូបព្រះរាជា ជាដំបូងក៏ក្លាយជាមនុស្សដូចដើម ។ ព្រះរាជាស្ទុះឱបនាយទិព្វវង្សដោយសេចក្តីត្រេកអរយ៉ាងក្រៃលែង សួរដឹងរឿងហេតុសព្វគ្រប់ទើបអង្វរនាយឱ្យប្រស់ព្រះអគ្គមហេសី ព្រះរាជធីតា ព្រមទាំងពួករាជបរិវារទាំងអស់ឱ្យក្លាយជាមនុស្សវិញ ។ នាយក៏ប្រស់បានដូចបំណង ។

លំដាប់មកព្រះរាជារៀបអភិសេកនាយទិព្វវង្ស ជាមួយនាង ចន្ទស្រី ជាព្រះរាជធីតា ឱ្យសោយរាជ្យក្នុងនគរមគធៈនោះ ដោយពិធីរាជាភិសេកយ៉ាងធំអស្ចារ្យតាមរាជប្បវេណីពីបុរាណកាលមក ។

## ៣. រឿងនង្គលកូដត្ថេរ

## ( ចាក ធ.ខុ. )

*( ខ្លួនទូន្មានខ្លួនឯងបាន ប្រសើរបំផុតក្នុងពិភពលោក )*

បានឮថាមានបុរសកំសត់ម្នាក់ស៊ីឈ្នួលគេចិញ្ចឹមជីវិត ។ ភិក្ខុមួយអង្គបានឃើញបុរសកំសត់នោះ ស្លៀកកំណាត់សំពត់លីនង្គ័លដើរទៅស្រែ លោកសួរថា បើអ្នកឯងបួសមិនប្រសើរជាងការរស់នៅចិញ្ចឹមជីវិតយ៉ាងនោះទេឬ ? ។ គាត់ឆ្លើយថា បពិតលោកម្ចាស់ដ៏ចម្រើន នរណានឹងបំបួសខ្ញុំព្រះករុណាដែលរស់នៅបែបនេះ ។ ព្រះថេរៈពោលថាបើអ្នកបួស អាត្មានឹងបំបួសអ្នកឯង. បុរសនោះទូលថា បពិតលោកម្ចាស់ប្រពៃណាស់ហើយ ប្រសិនបើលោកម្ចាស់បំបួសខ្ញុំព្រះករុណា១ នឹងបួស ។ លំដាប់នោះ ព្រះថេរៈនាំបុរសនោះទៅវត្តជេតពន ផ្ងូតទឹកដោយដៃខ្លួនឯង ឱ្យនៅក្នុងរោងហើយបំបួស រួចឱ្យគាត់ទុកនង្គ័ល ព្រមទាំងកំណាត់សំពត់ដែលគាត់ស្លៀកលើមែកឈើក្នុងទីមួយជិតរោង ។ តាំងពីពេលដែលឧបសម្បទ៍ហើយ ភិក្ខុនោះមាននាមប្រាកដថា " នង្គលកូដត្ថេរ " លោកចិញ្ចឹមជីវិត ដោយអាស្រ័យលាភសក្ការៈ ដែលកើតមានដល់ព្រះពុទ្ធ

សម័យក្រោយមក លោកអផ្សុកមិនអាចនឹងបន្ទោរបង់សេចក្តីអផ្សុក នោះបាន ទើបគិតថាឡូវនេះ អាត្មាអញស្លៀកដណ្តប់សំពត់កាសាវៈ ដែលគេឱ្យដោយសទ្ធា ជាការស្រួលពេកហើយ តើចង់សឹកទៅស៊ីឈ្នួលគេទៀតឬ ? ហើយដើរសំដៅទៅគល់ឈើដែលទុកនង្គ័ល នឹងកំណាត់សំពត់ ទូន្មានដោយខ្លួនឯងថា នែបុគ្គលឥតមានសេចក្តីអៀនខ្មាស អ្នកឯងស្លៀកដណ្តប់សំពត់នេះ ហើយចង់សឹកទៅស៊ីឈ្នួលគេវិញឬ ?។ កាលដែលលោកទូន្មានខ្លួនឯងយ៉ាងនេះ ចិត្តក៏រសាយបាត់ចង់សឹកទៅ, ទើបលោកត្រឡប់មកវិញ មិនបានប៉ុន្មានថ្ងៃផង ក៏មានសេចក្តីអផ្សុកម្តងទៀត លោកក៏ទូន្មានខ្លួនលោកដូចពេលមុនទៀត ចិត្តរបស់លោកក៏ភ្លេចនឹកនាពីរឿងចង់សឹកនោះទៅវិញ ។ កាលណាលោកអផ្សុកចង់សឹក លោកតែងនិមន្តទៅកន្លែងនោះ ទូន្មានខ្លួនតាមទំនងនេះជារៀងរាល់ពេល ។

ពេលមួយនោះ ពួកភិក្ខុឃើញនង្គ័លកូដភិក្ខុដើរទៅទីកន្លែងនោះ ជារឿយៗ ក៏សួរថានែនង្គ័លកូដ អ្នកទៅកន្លែងនោះរឿយៗ ព្រោះហេតុអ្វី ? ។ ភិក្ខុនោះប្រាប់ថា ខ្ញុំព្រះករុណាទៅកន្លែងអាចារ្យរបស់ខ្ញុំ លុះកន្លងពីនោះបានពីរបីថ្ងៃ ក៏បានសម្រេចជាព្រះអរហន្ត ។ ពួកភិក្ខុទាំងនោះក៏សើចចំអកឱ្យនង្គ័លភិក្ខុថា នែនង្គ័លកូដអាវុសោ អ្នកដើរទៅផ្លូវនោះជាផ្លូវគេប្រើប្រាស់មិនកើត ទំនងជាមិនទៅកន្លែងអាចារ្យរបស់លោកទេដឹង ? ។ នង្គ័លកូដភិក្ខុពោលថា ព្រះករុណាលោកម្ចាស់ដ៏

ចម្រើន កាលបើកិលេសជាគ្រឿងជាប់ជំពាក់នៅមាន ខ្ញុំព្រះករុណាទៅកន្លែងនោះ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំបានកាត់ចោលអស់ហើយ ខ្ញុំមិនទៅកន្លែងនោះទៀតទេ ។ ពួកភិក្ខុទាំងនោះបានស្តាប់ពាក្យរបស់នង្គលកូដភិក្ខុស្រេចហើយ ក៏នាំយករឿងនោះទៅក្រាបទូលព្រះសាស្តាថា ភិក្ខុនេះនិយាយពាក្យមិនពិត ពោលអួតគុណវិសេសដែលគេមិនណាចដឹងបាន ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយអើយ កូនរបស់តថាគតចេះដាស់តឿនខ្លួនដោយខ្លួនឯង ហើយបានដល់នូវទីបំផុតនៃបព្វជិតកិច្ចហើយៗទ្រង់សម្តែងធម៌ទៅទៀតថា :

ម្នាលភិក្ខុ ចូរអ្នកដាស់តឿនខ្លួនឯង ចូរពិចារណាដោយខ្លួនឯង អ្នកមានស្មារតីគ្រប់គ្រងដោយខ្លួនឯង នឹងនៅជាសុខស្រួល ។ ព្រោះថាខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនហ្នឹងជាគតិរបស់ខ្លួន ព្រោះហេតុនោះអ្នកចូរស្ងួនគ្រងខ្លួន ដូចជានាយពាណិជស្ងួនគ្រងនូវសេះដែលចម្រើនដូច្នោះដែរ ។

## ៤~ រឿងប្រេតមាត់ស្អុយ

( បេ.ខុ. )

*( មាត់ធំក្លិនស្អុយអាសោចន៍ ព្រោះស្រដីចែចូវញុះញង់ )*

បានឮមកថា ក្នុងសាសនកាលនៃព្រះពុទ្ធកស្សប មានភិក្ខុ ២អង្គនៅជាមួយគ្នាក្នុងអាវាសមួយ មានសេចក្តីរាប់អានស្រឡាញ់គ្នាដូចជាបងប្អូនចេញពីឧទរមាតាតែមួយ លោកគង់នៅក្នុងអាវាសនោះជាសុខ

សប្បាយ ពុំដែលមានមោះមែនឹងគ្នាឡើយ ។ សម័យថ្ងៃ ១ មានភិក្ខុអាគន្តុកៈមួយអង្គនិមន្តមកពីទីឆ្ងាយដាច់ស្រយាល បានមកដល់អារាមនោះចូលទៅសុំពឹងពាក់សំណាក់នៅ ព្រោះយល់ថាជាទីស្រណុកសប្បាយដោយអាហារបិណ្ឌជាដើម ។

ព្រឹកព្រាងស្វាងអរុណោទ័យ ទើបព្រះថេរៈទាំងពីរនាំអាគន្តុកៈភិក្ខុទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងឡាយឃើញព្រះថេរៈទាំង ២ អង្គមានចិត្តជ្រះថ្លា ធ្វើសក្ការបូជាដោយទេយ្យវត្ថុ មានបបរអាហារភោជនដ៏ត្រកាល ។ ឯអាគន្តុកភិក្ខុនោះគិតពិចារណាថាស្រុកនេះជាទីសប្បាយងាយស្រួលបិណ្ឌបាត ហើយមនុស្សទាំងឡាយក៏មានសទ្ធាជ្រះថ្លាផ្ចិតផ្ចង់ភោជនាហាប្រគេន ហើយអាវាសនៈថែមទៀតក៏ស្រណុកសុខសប្បាយប្រកបដោយទឹកនោះថ្លា បើអាត្មាអញបាននៅទីនេះនឹងបានសេចក្ដីសុខសព្វកាល. តែបើព្រះថេរៈទាំងពីរអង្គនេះនៅជាមួយ អាត្មាអញពុំមានសេចក្ដីសុខសប្បាយសោះឡើយ បើដូច្នោះអាត្មាអញគិតធ្វើឱ្យព្រះថេរៈនេះឈ្លោះវិវាទទាស់ទែងគ្នា ព្រាត់ប្រាសចាកចេញពីទីនេះ ។

មានកាលថ្ងៃមួយនោះ ព្រះថេរៈទាំងពីរអង្គសន្ទនាឱ្យឱវាទគ្នាទៅវិញទៅមក រួចហើយក៏ទៅកាន់លំនៅរៀងៗខ្លួន ឯភិក្ខុចែចូវអង្គុយនៅបន្តិច ក៏ទៅកាន់សណាក់ព្រះមហាថេរថ្វាយបង្គំនមស្ការ ព្រះមហាថេរដណ្ដឹងសួរថា អាវុសោមកធ្វើអ្វីក្នុងវេលានេះ ? ភិក្ខុនោះទូលព្រះពុទ្ធដីកា

ថា មានការនិយាយបន្តិចទើបព្រះមហាថេរអនុញ្ញាតថា ចូរស្រដីមកចុះ បពិតព្រះមហាថេរដ៏ជាទីស្រឡាញ់ពេញចិត្ត នៅក្នុងទីចំពោះមុខដូចមិត្ត សំឡាញ់ កំបាំងមិញដូចជាសត្រូវ ។ ទើបមហាថេរលោកស្រដី ដូចម្តេច អ្នកប្រាប់ឱ្យដឹងផង អនុត្ថេរប្រាប់ខ្ញុំម្ចាស់ថា លោកម្ចាស់ឡេះឡោះ កុហកចិញ្ចឹមជីវិតប្រព្រឹត្តខុសវិន័យធម៌ ។ ព្រះមហាថេរថា អាវុសោកុំ ស្រដីដូច្នោះ អនុត្ថេរនេះមិនមែនស្គាល់តែក្នុងកាលឥឡូវនេះទេ គឺចាប់ ស្គាល់ស្រឡាញ់រាប់អានគ្នាតាំងពីឃរាវាសម្ល៉េះ ជំពូកមួយទៀតលោកពុំ ជាអ្នកស្រដីដូច្នោះដែរ ។ ភិក្ខុពោលនោះទូលថា បពិត្រមហាថេរកុំស្មាន ថាអនុត្ថេរនោះជាមនុស្សល្អរកមន្ទិលគ្មាន ខ្ញុំព្រះករុណាថានេះនឹងប៉ុនប៉ង ចងពៀរនឹងអនុត្ថេរក៏គ្មាន លោកម្ចាស់ចាំមើលបន្តិចទៅគង់នឹងជ្រាប ឯង ។ ដោយព្រះទ័យដ៏ទោរទន់ស្រឡាញ់រាប់អានរបស់ព្រះមហាថេរ ពុំអាចនឹងព្រាត់ប្រាសគ្នាបានឡើយ ទើបភិក្ខុពាលនោះទៅកាន់សំណាក់ អនុត្ថេរញុះញង់ដូច្នោះទៀត ព្រះថេរៈទាំងពីរអង្គធន់ទ្រាំពុំបាន លុះវេលា ព្រឹកឡើងពុំមានស្រដីនឹងគ្នា ស្ងៀមដោយរៀងខ្លួនបានបាត្រចីវរត្រាច់ចរ បិណ្ឌបាតក្នុងស្រុកនោះ ហើយត្រឡប់មកអាវាសវិញចូលបន្ទប់បិទទ្វារ ឆាន់តែរៀងៗខ្លួន ពុំបានធ្វើសាមីចិកម្មនឹងគ្នាឡើយ ។ លុះព្រឹកព្រាង ស្វាងព្រះសុរិយា ព្រះថេរៈទាំងពីរចេញទៅទីទៃពីគ្នា ភិក្ខុពាលនោះ ញុះញង់បំបែកបំបាក់បានដូចប្រាថ្នាហើយ ក៏ចូលទៅបិណ្ឌបាតក្នុងស្រុក

នោះ ។ អ្នកស្រុកឃើញភិក្ខុនោះ ក៏សួរថា ព្រះថេរៈទាំង២អង្គក៏ពុំឃើញមក ? ភិក្ខុពាលនោះប្រាប់ថា លោកវិវាទទាស់ទែងគ្នាទាំងយប់អាធ្រាត អាត្មាបានឃាត់កុំឱ្យទាស់ទែងគ្នា ព្រោះការទាស់ទែងនេះរកប្រយោជន៍គ្មាន លោកពុំអាចស្ដាប់ពាក្យអាត្មាឃាត់នោះឡើយ ហើយរៀបខ្លួនដើរចេញទៅតែរៀងខ្លួន ។ ពួកមហាជនថា បើព្រះថេរៈនិមន្តទៅហើយ សូមលោកម្ចាស់អនុគ្រោះនិមន្តគង់ឱ្យសុខសប្បាយនៅទីនេះចុះ ។ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាតស្រេចហើយ ក៏ត្រឡប់ទៅអាវាសវិញ បានពីរបីថ្ងៃទើបគិតថា ព្រះមហាថេរទាំងពីរព្រះអង្គជាចៅអាវាស មានសីលបរិបូណ៌ អាត្មាអញស្រដីកំចាយរំលាយឱ្យព្រាត់ប្រាសចេញពីគ្នា អាត្មាអញធ្វើកម្មនេះជាទម្ងន់ពន់ប្រមាណ ព្រោះលោភចង់បានអាវាសនេះ ។ ដោយផលកម្មអាក្រក់នោះ ក៏បណ្ដាលចិត្តឱ្យក្ដៅក្រហាយឆាន់អាហារពុំបាន កើតរោគាក្ដៅក្រហាយអន្ទះអន្ទែងធ្វើកាលកិរិយាទៅកើតក្នុងអវិចិមហានរក ។

ចំណែកព្រះមហាថេរទាំងពីរត្រាច់ទៅតាមលំដាប់ជនបទ បានមកជួបជុំគ្នានៅក្នុងអាវាសមួយត្រេកអរសាទរជាសុខសប្បាយ រាក់ទាក់រកគ្នា និយាយប្រាប់តាមសេចក្ដីដែលភិក្ខុញុះញង់នោះបានធ្វើដល់គ្នាទៅវិញទៅមក ដឹងហេតុពុំពិតទើបបបួលគ្នាទៅគង់នៅអាវាសដើមវិញ ។ ពួកមហាជនបានឃើញព្រះថេរៈនិមន្តត្រឡប់មកវិញ មានចិត្តត្រេកអរ

នមស្ការគោរពបូជានូវចតុប្បច្ច័យដូចដើម កាលគង់នៅក្នុងអាវាសនោះ លោកបានចម្រើនវិបស្សនាកម្មដ្ឋាន បានសម្រេចព្រះអរហត្តផលជាគ្រឿងរំលត់ទុក្ខគ្រប់យ៉ាង ។ ឯភិក្ខុចែចូវនោះទៅកើតនៅក្នុងអវិចិមហានរកអស់១ពុទ្ធន្តរ លុះព្រះសមណគោតមឧប្បត្តិឡើងក្នុងលោក ក៏បានមកកើតជាប្រេតនៅទៀបជើងភ្នំគិជ្ឈកូដ មានមាត់នោះស្អុយ មានខ្លួនដូចមាស មានដង្កូវវារចេញពាសអំពីមាត់ កាត់រីមមាត់ធំក្លិនស្អុយសាយភាយចេញទៅ ។

លំដាប់នោះព្រះអនុរុទ្ធត្ថេរចុះពីភ្នំគិជ្ឈកូដ បានឃើញប្រេតនោះសួរថា ហៃព្រះស្តែងមានសម្បុរល្អ ភ្លឺច្រាលរន្ទាលឆ្អិនឆ្អៅដូចទេពតានៅព្វដ៏កណ្តាលអាកាស រីមាត់ធំក្លិនស្អុយដូចសាកអសុភ មានដង្កូវវារចេញចូលព្វដ៏មាត់គួរឱ្យខ្ពើមរអើម តើព្រះស្តែងបានធ្វើបុព្វកម្មដូចម្តេចពីជាតិមុន ? ។ ប្រេតនោះក្រាបទូលព្រះពុទ្ធដីកាថា ខ្ញុំម្ចាស់ជាមនុស្សចិត្តបាបស្រដីអាក្រក់ញុះញង់គេឱ្យបែកបាក់គ្នាពីជាតិមុន បានមកកើតជាប្រេតមាត់ស្អុយ មានដង្កូវវារចេញពីមាត់ ព្រោះស្រដីចែចូវញុះញង់ព្រះសង្ឃពីរអង្គឱ្យបែកបាក់គ្នា. ហើយមានរស្មីផ្សាយចេញពីខ្លួនដូចមាស ព្រោះត្បិតខ្ញុំម្ចាស់បានបួសជាភិក្ខុចម្រើនវិបស្សនាកមដ្ឋាន លុះប្រេតប្រាប់នូវបុព្វកម្មរបស់ខ្លួនហើយ ទើបនិយាយផ្តាំផ្ញើនឹងព្រះអនុរុទ្ធថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអង្គជាអ្នកប្រាជ្ញា សូមមេត្តាអាសូរករុណាសម្តែង

ទូន្មានប្រៀបប្រដៅសត្វផងទាំងឡាយ កុំធ្វើអំពើចែចូវ ញុះញង់មុសាវាទ ជាហេតុបណ្តោលឱ្យរងទុក្ខវេទនាដូចខ្ញុំម្ចាស់ ជាឧទាហរណ៍ស្រាប់ ។ បើអ្នកឯណាបានបំពេញបុណ្យទានសីលភាវនាហើយ មុខនឹងបានជាទេវតាឯណានីមួយ មានព្រះឥន្ទជាដើម បានសោយសុខសម្បត្តិនោះច្រើនមហិមា ។ ព្រះអនុរុទ្ធត្ថេរលុះបានស្តាប់ពាក្យប្រេតនោះហើយ ទើបនិមន្តទៅក្រុងរាជគ្រឹះ ដើម្បីយករឿងនោះទៅក្រាបទូលព្រះបរមចេស្តា ព្រះអង្គទ្រង់សម្តែងធម៌ទេសនាលើកយករឿងប្រេតនោះទុកជាទិដ្ឋានុគតិដល់សព្វសត្វទាំងឡាយ ។

## ៥_រឿងជោតិកសេដ្ឋី

( ចាក ធ.ខ. )

*( អំពើល្អជាពូជធារនៃគំនរទ្រព្យសម្បត្តិ)*

មានសេចក្តីដំណាលថា ក្នុងកាលដែលកន្លងទៅហើយមានគហបតី ជាបងប្អូនពីរនាក់នៅក្នុងនគរពារាណសី បានធ្វើចំការអំពៅយ៉ាងធំ ។ ក្នុងថ្ងៃមួយប្អូនទៅមើលចំការអំពៅកាប់ចងយកអំពៅ ២ ដើមមកផ្ទះ ដោយគិតថាអញ នឹងឱ្យអំពៅមួយដើមដល់បង ហើយ១ដើមទៀតសម្រាប់អញ ។ សម័យនោះការគាបអំពៅដោយគ្រឿងយន្តគ្មានទេ. រសនៃអំពៅក៏ហូរចេញដោយខ្លួនឯង ក្នុងពេលដែលកាត់ត្រង់ចុង ឬត្រង់គល់លើកឡើង ដូចជាទឹកហូរចេញពីធមក្រក គាប់ជួនជាក្នុងកាលដែល

បងប្អូននោះលើយកអំពៅមកពីចំការ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ លោកចេញពីសមាបត្តិគង់នៅលើភ្នំគន្ធមាទន៍ ពិចារណាថា អាត្មាអញនឹងធ្វើនូវសេចក្ដីសង្គ្រោះដល់អ្នកណាក្នុងថ្ងៃនេះ ? បានឃើញបុរសនោះចូលទៅក្នុងបណ្ដាញ គឺញាណរបស់ខ្លួនផង ដឹងនូវភាពជាអ្នកអាចធ្វើនូវសេចក្ដីអនុគ្រោះផង ក៏កាន់យកបាត្រនឹងចីវរមកដោយឫទ្ធិ បានឈរនៅចំពោះមុខបុរសនោះ ។ កុដុម្ពីគ្រាន់តែឃើញព្រះបច្ចេកពុទ្ធភ្លាម ក៏មានចិត្តជ្រះថ្លាក្រាលសំពត់សម្រាប់បង់កលើផែនដី និមន្តលោកឱ្យគង់ហើយទូលព្រះពុទ្ធដីកាថា សូមព្រះអង្គទ្រង់បង្អោនបាត្រមក រួចស្រាយចំណងពីដើមអំពៅ ។ ឯរសនៃអំពៅក៏ហូរធ្លាក់ទៅក្នុងបាត្រពេញ ។ កាលដែលព្រះបច្ចេកពុទ្ធឆាន់រសនៃអំពៅអស់ហើយ កុដុម្ពីគិតថា ឱប្រពៃណាស់ តើ ! លោកម្ចាស់ឆាន់រសនៃអំពៅ ជាចំណែករបស់អញអស់ហើយ ថាបើបងរបស់អញឱ្យអាត្មាអញចេញថ្លៃឱ្យអញនឹងចេញឱ្យ ថាបើគាត់ឱ្យអញចែកចំណែកបុណ្យ អញចែកឱ្យគាត់ លុះគិតដូច្នេះស្រេចហើយ ក៏ចាប់ស្រាយអំពៅទី២ទូលសូមឱ្យលោកបង្អោនបាត្រមកទៀត ហើយប្រគេននូវរសនៃអំពៅនោះ ។ ចំណែកព្រះបច្ចេកពុទ្ធ លោកឆាន់រសនៃអំពៅដំបូងរួចហើយ លោកមានប្រាថ្នាចែកនូវរសនៃអំពៅលើកក្រោយដល់ព្រះបច្ចេកពុទ្ធទាំងឡាយដទៃទៀត ក៏គ្រាន់តែទទួលហើយ គង់នៅស្ងៀម ។ ឯគហបតីដឹងអាការៈនៃព្រះបច្ចេកពុទ្ធ ក៏ថ្វាយបង្គំដោយ

កិរិយាតាំងទុកនូវអវៈយវៈប្រកបដោយអង្គ៥ ហើយប្រកាសសេចក្ដីប្រាថ្នា បពិតលោកម្ចាស់ដ៏ចម្រើន រសដ៏ប្រសើរដែលខ្ញុំព្រះអង្គប្រគេនទៅនេះ សូមឱ្យខ្ញុំព្រះអង្គបានសោយសម្បត្តិក្នុងទេវលោក នឹងមនុស្សលោកដោយអានិសង្សនៃអគ្គរសនេះ ហើយក្នុងទីបំផុតសូមឱ្យខ្ញុំព្រះអង្គបានសម្រេចធម៌ដែលលោកម្ចាស់បានសម្រេចកុំខាន ។ ព្រះបច្ចេកពុទ្ធពោលថា សេចក្ដីប្រាថ្នាដែលអ្នកប្រាថ្នាយ៉ាងនេះ សូមឱ្យសម្រេច រួចអនុមោទនាដោយគាថាពីរបទថា " ឥច្ឆិតំ បត្ថិតំ តុយ្ហំ " ដូច្នេះជាដើម ហើយនិមន្តទៅភ្នំគន្ធមាទន៍តាមអាកាស ទ្រង់អធិដ្ឋានថា សូមឱ្យគហបតីមើលឃើញអាត្មាអញចែកនូវរសនៃអំពៅនោះ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ៥០០ អង្គ ។ គហបតីបានឃើញបដិហារនោះ ក៏ដើរសំដៅទៅលំនៅបង. បងសួរថា ប្អូនឯងទៅណា ? ប្អូនប្រាប់ថា ខ្ញុំទៅមើលចំការអំពៅ. ចុះព្រោះហេតុអ្វីក៏ប្អូនឯងទៅចំការអំពៅហើយ ម្ដេចក៏មិនកាប់អំពៅបាន ១ដើម ឬពីរដើមយកមកផង ? ។ ប្អូនជំរាបថាបាទលោកបង ខ្ញុំកាប់យកអំពៅ ២ដើមមកដែរ ប៉ុន្តែខ្ញុំដើរមកតាមផ្លូវបានជួបនឹងព្រះបច្ចេកពុទ្ធ១អង្គ បានប្រគេនរសនៃអំពៅជាចំណែករបស់ខ្ញុំ រួចប្រគេនទាំងចំណែករបស់បងទៀត ដោយគិតថា " ខ្ញុំនឹងចេញថ្លៃឱ្យ ឬឱ្យនូវចំណែកបុណ្យដល់បង " បើដូច្នោះតើលោកបងយកថ្លៃអំពៅនោះឬ ? ឬក៏យកចំណែកបុណ្យ ?។ បងសួរថា តើព្រះបច្ចេកពុទ្ធអង្គនោះ លោក

ធ្វើដូចម្ដេចខ្លះ ? ប្អូនជម្រាបថា លោកឆាន់រសនៃអំពៅខ្ញុំហើយទទួលយករសនៃអំពៅជាចំណែកបង ហោះតាមអាកាសសំដៅទៅភ្នំគន្ធមាទន៍ បានចែកដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គឆាន់ផង ។ បងនោះកាលបើប្អូនប្រាប់ដូច្នោះហើយ ក៏មានចិត្តរីករាយត្រេកអរយ៉ាងក្រៃលែង ទើបប្រាថ្នាថា សូមឱ្យខ្ញុំបានត្រាស់ដឹងចំពោះធម៌ ដែលព្រះបច្ចេកពុទ្ធនោះបានត្រាស់ដឹងកុំបីខាន ។ ចំណែកប្អូនសូមប្រាថ្នាឱ្យបានសម្បត្តិបីប្រការ. ឯបងប្រាថ្នាឱ្យបានសម្រេចព្រះអរហន្ត នេះជាបុព្វកម្មរបស់ជនទាំងពីរនាក់នោះ ។ ជនទាំងពីរនាក់នោះបានឋិតដរាបដល់អស់អាយុ លុះច្យុតពីអត្តភាពនោះ បានទៅកើតក្នុងទេវលោកអស់ ១ពុទ្ធន្តរ. ក្នុងកាលដែលជនទាំងពីរនាក់ឋិតនៅក្នុងទេវលោក ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សីទ្រង់ឧបត្តិកឡើងក្នុងលោក ក៏ច្យុតពីទេវលោកបានមកកើតត្រកូលមួយជាមួយគ្នានៅក្នុងត្រកូលពន្ធុមតី ។ មាតាបិតាដាក់ឈ្មោះកូនបងហៅថាសេនៈ កូនប្អូនឈ្មោះអបរាជិតៈ ។ ក្នុងកាលដែលកូនទាំងពីរនោះមានវ័យគ្រប់គ្រាន់ហើយ មាតាបិតាបានចែកទ្រព្យសម្បត្តិឱ្យជាកេរ្តិ៍មរតក. បានឮការឃោសនានៅក្នុងនគរពន្ធុមតីថា ព្រះពុទ្ធ. ព្រះធម៌ ព្រះសង្ឃ ទ្រង់ឧបត្តិកឡើងក្នុងលោកហើយ ចូរអ្នកទាំងអស់គ្នាឱ្យទាន ចូរធ្វើបុណ្យ ថ្ងៃនេះជាតិថីទី ៨. ជាតិថីទី ១៤. ជាតិថីទី ១៥. ចូររក្សាឧបោសថសីល ចូរស្ដាប់ធម៌ទេសនា. លុះឃើញមហាជនកំពុងដើរទៅ

ស្តាប់ធម៌ទេសនា សេនកុដុម្ពីស្រែកសួរថា អ្នកទាំងអស់គ្នាអញ្ជើញទៅណា ? មហាជនប្រាប់ថាទៅស្តាប់ធម៌ក្នុងសំណាក់ព្រះសាស្តា ហើយក៏ដើរទៅជាមួយពួកមហាជន ទៅអង្គុយនៅខាងក្រោយគេបង្អស់ ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សេនគហបតីនោះ ព្រះអង្គទ្រង់សម្តែងអនុបុព្វីកថា លុះចប់ព្រះធម៌ទេសនា សេនគហបតីមានសេចក្តីជ្រះថ្លាក្នុងបព្វជ្ជា ទើបសុំព្រះសាស្តាបួស ។ លំដាប់នោះព្រះអង្គទ្រង់សួរថា តើអ្នកឯងមានញាតិសន្តានដែរឬទេ ? សេគហបតីក្រាបទូលថា " មាន " ព្រះអង្គត្រាស់ថា បើដូច្នោះអ្នកទៅលាពួកញាតិសន្តានសិនរួចសឹមមកបួស ។ សេនគហបតីត្រឡប់ទៅប្រាប់ប្អូនថា " ទ្រព្យសម្បត្តិទាំងអស់ដែលមានទាំងប៉ុន្មានក្នុងផ្ទះនេះ ចូរប្អូនថែរក្សាទុកដូចជាសម្បត្តិរបស់ប្អូនឯងទៅចុះ បងសូមលាប្អូនទៅបួស " ។ ប្អូននិយាយអង្វរករឃាត់មិនឱ្យបងទៅបួស ព្រោះថាកាលបើមាតាបិតាស្លាប់ទៅ ខ្ញុំបានបងទុកដូចជាមាតាបិតា ឥឡូវបើបងទៅបួសហើយ តើខ្ញុំនឹងបានអ្នកណាជាទីពឹង ? ថែមទាំងត្រកូលយើងនេះជាត្រកូលស្តុកស្តម្ភផង ហេតុនេះសូមបងនៅគ្រប់គ្រងផ្ទះជាមួយនឹងខ្ញុំ បើបងចង់ធ្វើបុណ្យទានបែបណាៗសូមបងចាត់ចែងតាមសេចក្តីត្រូវការចុះ ។ សេនគហបតីទោះបីប្អូនអង្វរករហាមឃាត់យ៉ាងណាក៏មិនសុខចិត្តទ្រាំនៅដែរ ហើយប្រាប់ថា ប្អូន ! បងបានស្តាប់ព្រះធម៌ទេសនាក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធ បងមិនអាច

នៅគ្រប់គ្រងផ្ទះបានឡើយ ចូរប្អូនកុំឃាត់បង ។ លុះបួសរួចហើយ អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។ ចំណែកប្អូនគិតថាឥឡូវបងអញគាត់បួសហើយ អញនឹងធ្វើសក្ការបូជាដល់បង ហើយចាត់ចែងធ្វើទានប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ថ្ងៃ រួចថ្វាយបង្គំទូលបងថា" លោកបងបានរលាស់ខ្លួនចេញចាកភពរួចហើយ. ចំណែកខ្ញុំត្រូវកាមគុណ ៥រួបរឹតមិនអាចចេញទៅបួសបាន ហេតុនេះសូមលោកបងប្រាប់បុញ្ញកម្ម ដ៏ធំដែលសមគួរដល់ខ្ញុំជាអ្នកគ្រប់គ្រងនៅផ្ទះ" ។ លំដាប់នោះព្រះថេរៈប្រាប់ប្អូនថា " ម្នាលប្អូន ចូរប្អូនធ្វើគន្ធកុដិថ្វាយព្រះសម្មាសម្ពុទ្ធ " ។ ប្អូនគ្រាន់តែឮថាឱ្យធ្វើគន្ធកុដិថ្វាយព្រះសម្មាសម្ពុទ្ធ ក៏មានចិត្តសោមនស្សរីករាយយ៉ាងខ្លាំង ទើបហៅជាងចាត់ចែងធ្វើសសរពាដែលវិចិត្រដោយរតនវត្ថុ ៧ប្រការ គឺសសរ ១ធ្វើពីមាស ១ធ្វើពីប្រាក់ ១ទៀតធ្វើពីកែវមណី. ហើយប្រក់ដោយឥដ្ឋដែលធ្វើពីរតនវត្ថុទាំង ៧ ប្រការដែរ ។ ក្នុងពេលដែលកំពុងកសាងគន្ធកុដិនោះ ក្មួយអបរាជិតៈដែលមានឈ្មោះដូចឪពុកមាបានចូលទៅសុំថា " បពិត្រឪពុកមា សូមលោកមេត្តាឱ្យខ្ញុំចូលកសាងជាមួយ ដើម្បីនឹងបានចំណែកបុណ្យដូចគ្នា" ឪពុកមាប្រាប់ថា " ម្នាលក្មួយ ខ្ញុំមិនឱ្យក្មួយឯងចូលទេ ខ្ញុំធ្វើមិនឱ្យទូទៅដល់ជនទាំងឡាយដទៃឡើយ " ទោះបីក្មួយអង្វរសុំយ៉ាងណា ក៏គាត់មិនឱ្យទាល់តែសោះ ទើបគិតថា " គន្ធកុដិឪពុកមាអញធ្វើទៅហើយ បើ

ដូច្នោះអញ្ជូកសាងកុញ្ជរសាលាពីខាងមុខគន្ធកុដិទើបគួរ " ហើយក៏ហៅជាងឱ្យធ្វើកុញ្ជរសាលាដែលសម្រេចពីកែវ ៧ប្រការដែរ ។ ដោយផលានិសង្សនោះ ក្លួយបានមកកើតជាមេរេភ្ញកសេដ្ឋីក្នុងពុទ្ធប្បាទនេះ ។ អបរាជិតគហបតីឱ្យជាងធ្វើទ្វារបី ដែលវិចិត្រដោយកែវទាំង ៧ប្រការ, រួចជីកស្រះបោក្ខណី ៣ ដែលពេញដោយទឹកមានក្លិនក្រអូបប្រកបដោយជាតិ៤យ៉ាង ហើយឱ្យដាំផ្កាម្លិះទាំងឡាយមានពណ៌ ៥យ៉ាង. ក្នុងពេលដែលព្រះសាស្តាយាងចូលទៅ ខ្យល់តែងបក់ក្លិនក្រអូបផ្សព្វផ្សាយពេញគន្ធកុដិ. ហើយគន្ធកុដិនោះមើលទៅសមដូចជាក្អោកពង់ រួចឱ្យគេចាក់ក្រាលជុំវិញគន្ធកុដិនោះដោយមាសទាំងអស់ ។ អបរាជិតគហបតី កាលបើកសាងគន្ធកុដិស្រេចហើយ ក៏ចូលទៅថ្វាយបង្គំព្រះថេរៈជាបងទូលថា " បពិត្រលោកបង ! គន្ធកុដិសម្រេចហើយ " ព្រះថេរចូលទៅក្រាបទូលព្រះបរមសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន គន្ធកុដិដែលប្អូនរបស់ខ្ញុំព្រះអង្គកសាងនោះ បានរួចសព្វគ្រប់ហើយ សូមនិមន្តព្រះអង្គទ្រង់យាងទៅគង់គន្ធកុដិនោះ ។ ព្រះសាស្តាទ្រង់ក្រោកចាកអាសនៈ យាងឆ្ពោះទៅគន្ធកុដិ ទ្រង់ទតឃើញគំនររតនវត្ថុដែលគហបតីចាក់ក្រាលព័ទ្ធជុំវិញ ព្រះអង្គទ្រង់ប្រថាប់ទៅត្រង់ក្លោងទ្វារ ។ លំដាប់នោះគហបតីអារាធនានិមន្តថា " បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះអង្គទ្រង់យាងចូលទៅខាងក្នុង " ព្រះអង្គទ្រង់ប្រថាប់នៅតែត្រង់កន្លែងនោះ លុះដល់គហបតីអារាធ

នាក្នុងវារៈទី ៣ ព្រះអង្គទ្រង់ក្រឡេកមើលព្រះថេរៈជាបងនៃគហបតីនោះ ។ ឯព្រះថេរៈជាបងយល់អាការៈដែលព្រះអង្គទ្រង់ក្រឡេកមើល ក៏ប្រាប់ប្អូនថា " ម្នាលប្អូនចូរមកណេះ ចូរក្រាបទូលបង្គំព្រះសាស្តាថា ការរក្សាវត្ថុទាំងនេះជាភារៈរបស់ខ្ញុំព្រះអង្គទាំងអស់ សូមព្រះអង្គគង់នៅតាមសេចក្តីសុខសប្បាយចុះ " គហបតីនោះឮបងថាដូច្នោះ ក៏លើករប្រណម្យអភិវន្ទព្រះមានបុណ្យក្រាបទូលថា " បពិត្រព្រះអង្គដ៏ចំរើន មនុស្សទាំងឡាយចូលទៅនៅក្រោមដើមឈើ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យហើយចៀសចេញទៅ ឬក៏ឆ្លងស្ទឹងជាអ្នកមិនមានសេចក្តីអាឡោះអាល័យ ហើយលះបង់ចោលក្បូន មានសភាពបែបណា ចំណែកព្រះអង្គជាអ្នកមិនមានសេចក្តីអាឡោះអាល័យ សូមទ្រង់គង់នៅតាមសភាពបែបនោះចុះ ។ សួរថា ព្រោះហេតុអ្វី ក៏ព្រះសាស្តាទ្រង់ប្រថាប់នៅតែត្រង់ចន្លោះនោះ ? ឆ្លើយថា សេចក្តីត្រិះរិះរមែងមានដល់ព្រះសាស្តាយ៉ាងនេះថា " មនុស្សជាច្រើន តែងទៅគាល់ព្រះពុទ្ធទាំងឡាយមុនពេលភត្តក៏មាន ក្រោយពេលភត្តក៏មាន កាលបើមានមនុស្សទាំងនោះកាន់យករតនវត្ថុទាំងនេះ ដែលគហបតីចាក់រាយពាសពេញបរិវេណព្រះអង្គមិនហាមឃាត់ ព្រោះហេតុនោះហើយ បានជាព្រះអង្គទ្រង់ប្រថាប់នៅដោយហេតុនេះ ព្រោះខ្លាចក្រែងលោគហបតីគំនុំចំពោះព្រះអង្គ " នឹងធ្លាក់ទៅរងទុក្ខវេទនាក្នុងអបាយភូមិមិនខាន " ។ កាល

បើគហបតីអារាធនារ៉ាប់រងដូច្នោះហើយ ទើបព្រះអង្គយាងចូលទៅក្នុង។ គហបតីចាត់ខ្ញុំបំរើរបស់ខ្លួនម្នាក់ឱ្យទៅថែរក្សាប្រាប់ថា អ្នកឯងចូរហាមឃាត់ពួកជនដែលទៅយករតនវត្ថុដោយថ្នក់ ឬកញ្ច្រែង ឬការ៉ុង តែកុំហាមឃាត់ពួកជនដែលយកតែ១ក្ដាប់ ឬ២ក្ដាប់ឡើយ ។ គហបតីគិតប្រកាសឃោសនាអ្នកនគរថា " ខ្ញុំបានចាក់រតនវត្ថុរាយពេញបរិវេណគន្ធកុដិជនអ្នកកំសត់ទីទ័លក្រទាំងឡាយ បើអញ្ជើញទៅស្ដាប់ធម៌ទេសនាក្នុងសំណាក់ព្រះសាស្ដា សូមយករតនវត្ថុនោះ ១ក្ដាប់ ឬ២ក្ដាប់ទៅចុះបើជនមានល្មមគ្រប់គ្រាន់ សូមយកតែ១ក្ដាប់បានហើយ " ។ សេចក្ដីត្រិះរិះរបស់គហបតីដូច្នោះ ដោយចង់អនុគ្រោះដល់ពួកមហាជន ថាបើអ្នកណាមានសទ្ធាចង់ទៅស្ដាប់ធម៌ នឹងនៅមិនខាន បើនរណាគ្មានសទ្ធាទៅព្រោះតែចង់បានទ្រព្យ លុះស្ដាប់ធម៌ហើយ នឹងបានរួចចាកទុក្ខទាំងអស់គ្នា ។ ពួកមហាជន ក៏កាន់យករតនវត្ថុនោះតាមពាក្យគហបតីប្រាប់ដូច្នោះមែន លុះវត្ថុដែលចាក់រាយពេញម្ដងអស់ទៅហើយ គាត់ប្រើឱ្យយកមកដាក់ត្រឹមជង្គង់ឱ្យពេញដូចមុនទៀតអស់រយៈ៣លើក រួចគាត់យកដុំមណីរតន៏ដែលមានថ្លៃច្រើនប៉ុនផ្លែឪឡឹកទៅដាក់ក្បែរព្រះបរមសាស្ដា ដោយគិតថា ពួកមហាជនសម្លឹងមើលពន្លឺដូចជាមាស ដែលផ្សាយចេញពីសិរីរៈនៃព្រះសាស្ដាមិនចេះឆ្អែតស្កប់ស្កល់ ព្រោះហេតុនោះហើយបានជាគាត់

យកដុំមណីរតន៍នោះទៅដាក់ជិតព្រះបាទព្រះសាស្ដាដូច្នោះ ទោះបីធ្វើយ៉ាងនោះក៏នៅមិនចេះឆ្អែតស្កប់ស្កល់ទៀត ។

សម័យថ្ងៃមួយ មានព្រាហ្មណ៍ម្នាក់ជាមិច្ឆាទិដ្ឋិគិតថា " បានឮថាគហបតីតម្កល់ទុកដុំមណីរតន៍១ដុំដែលមានថ្លៃច្រើន នៅក្បែរព្រះបាទព្រះសាស្ដា អញនឹងលួចយកដុំមណីរតន៍នោះ " ហើយក៏ដើរទៅថ្វាយបង្គំព្រះសាស្ដាជាមួយនឹងពួកមហាជន ។ គហបតីកំណត់សំគាល់ទុកក្នុងចិត្តថា " បុរសនេះចង់លួចយកដុំមណីរតន៍នេះ " ហើយគិតថា " ឱធ្វើដូចម្ដេចហ្ន៎ ! កុំឱ្យគាត់លួចយកបានអេះ ។ គ្រានោះតាព្រាហ្មណ៍ធ្វើហាក់ដូចជាថ្វាយបង្គំព្រះ ហើយដាក់ដៃទៅក្បែរព្រះបាទសាស្ដា កន្ត្រាកទាញយកមណីរតន៍សន្សឹម១ដាក់ទៅក្នុងថង់ ហើយដើរចេញទៅ ។ គហបតីមិនអាចធ្វើចិត្តឱ្យជ្រះថ្លាចំពោះព្រាហ្មណ៍នោះឡើយ តែមិនហ៊ានឃាត់ដោយគោរពព្រះធម៌ លុះចប់ព្រះធម៌ទេសនាគាត់ចូលទៅជិតព្រះសាស្ដាក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានចាក់រតនៈ ៧ ប្រការរាយពេញព័ទ្ធគន្ធកុដិនេះត្រឹមជង្គង់អស់បីលើក ហើយគ្មានចងគំនុំចំពោះជនដែលយកទៅទេ ចិត្តខ្ញុំព្រះអង្គរីតរឹតតែជ្រះថ្លាឡើង១ តែទ្រាំមិនបានក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបានគិតថា " ឱធ្វើដូចម្ដេចហ្ន៎ ! កុំឱ្យព្រាហ្មណ៍នេះលួចយកដុំមណីតរតន៍បាន " ហើយខ្ញុំព្រះអង្គធ្វើចិត្តឱ្យជ្រះថ្លាចំពោះព្រាហ្មណ៍ដែលលួចយកទៅមិនកើតសោះ " ។ ព្រះមានព្រះ

ភាគទ្រង់ព្រះសណ្ដាប់ពាក្យគហបតីនោះហើយត្រាស់ឱ្យន័យថា " នែឧបាសក ! ក្រែងអ្នកមិនបានធ្វើវត្ថុជារបស់ខ្លួនកុំឱ្យជនដទៃលួចបានទេឬ? ។ លុះព្រះសាស្ដាទ្រង់ព្រះប្រទានន័យដូច្នោះហើយ គហបតីក៏ថ្វាយបង្គំប្រាថ្នាថា " បពិត្រព្រះអង្គដ៏ចម្រើនចាប់ពីថ្ងៃនេះទៅ ព្រះរាជាទាំងឡាយក្ដី ចោរទាំងឡាយក្ដី ដែលអាចគ្របសង្កត់រឹបជាន់អូសយកទ្រព្យសម្បត្តិជារបស់ខ្ញុំ សូម្បីត្រឹមតែអំបោះចុងចេស ក៏សូមកុំឱ្យដាច់របេះបានឡើយ ទាំងភ្លើងក៏សូមកុំឱ្យឆេះទ្រព្យសម្បត្តិរបស់ខ្ញុំ ថែមទាំងទឹកក៏កុំឱ្យរសាត់ទៅតាមបានឡើយ " ។ កាលបើគហបតីប្រាថ្នាដូច្នេះរួចហើយ ព្រះអង្គទ្រង់អនុមោទនាថា " សេចក្ដីប្រាថ្នានោះចូរសម្រេចដល់អ្នកចុះ " រួចគហបតី ក៏តាំងផ្ដើមធ្វើបុណ្យឆ្លងគន្ធកុដិ ប្រគេនមហាទានចំពោះព្រះភិក្ខុសង្ឃ ៧៨ម៉ឺនអង្គអស់ ៩ខែ លុះដល់ថ្ងៃទីបំផុតប្រគេនត្រៃចីវរដល់ភិក្ខុគ្រប់អង្គ រួចប្រគេនចីវរដែលមានតម្លៃ ១០០០ កហាបណៈដល់ភិក្ខុថ្មីក្នុងសង្ឃ ជាកិច្ចបង្ហើយបុណ្យនោះ ។

សេដ្ឋីនោះធ្វើបុណ្យដរាបដល់អស់អាយុយ៉ាងនេះ លុះបែកធ្លាយរាងកាយទៅបានទៅកើតក្នុងទេវលោកអស់កាលដ៏យូរ លុះមកដល់ក្នុងពុទ្ធប្បាទនេះ បានចុះមកចាប់បដិសន្ធិក្នុងត្រកូលសេដ្ឋីនៅក្នុងរាជគ្រឹះ ។ គួរឱ្យប្លែកអស្ចារ្យណាស់ ក្នុងថ្ងៃដែលកុមារនោះប្រសូតចេញមក អាវុធទាំងអស់ប្រែក្លាយទៅជាក្រហមរន្ទាលច្រាលឆ្អៅភ្លឺពេញនគរទាំងមូល ។

សូម្បីតែគ្រឿងសម្លៀកបំពាក់នៃជនទាំងពួង ក៏ភ្លឺរន្ទាលច្រាលឆ្អៅដែរ ។ ចំណែកសេដ្ឋីបានទៅគាល់ព្រះរាជាតាំងពីព្រលឹម លំដាប់នោះព្រះរាជាទ្រង់ត្រាស់សួរសេដ្ឋីថា " ថ្ងៃនេះអាវុធទាំងអស់ទៅជាភ្លឺរន្ទាលច្រាលឆ្អៅហើយនគរហាក់ដូចជាមានពន្លឺតែមួយ តើលោកជ្រាបហេតុនេះដែរឬទេ? " " ក្រាបទូលខ្ញុំព្រះអង្គបានដឹងហើយ " " ចុះដឹងដូចម្តេច ? " " បពិត្រព្រះសម្មតិទេពកូនរបស់ទូលព្រះបង្គំប្រសូតក្នុងថ្ងៃនេះ ហើយការណ៍នេះកើតមានយ៉ាងនេះ ដោយអំណាចបុណ្យនៃកូនរបស់ទូលព្រះបង្គំ " " កូនអ្នកឯងជាចោរឬ ? " " ក្រាបទូលកូននោះមិនមែនជាចោរទេ គឺជាសត្វមានបុណ្យមានការកសាងធ្វើទុកពីជាតិមុន " ។ ព្រះរាជាទ្រង់បញ្ជូនទ្រព្យ ១000 កហាបនៈរាល់ៗថ្ងៃ ប្រាប់សេដ្ឋីថា " ចូរលោកថែរក្សាទារកនោះឱ្យល្អ ហើយចូរយកទ្រព្យនេះឱ្យជាតម្លៃទឹកដោះនៃទារកនោះ " ។ ដោយហេតុតែទារកនោះប្រសូតចេញមក នគរទាំងមូលដូចជាមានពន្លឺតែមួយក្នុងវេលានោះ ទើបមាតាបិតាឱ្យនាមថា " **ជោតិកកុមារ** " ។ លុះមានវ័យវឌ្ឍនាការចម្រើនពេញកម្លោះ មាតាបិតាចាត់គេជម្រះដី ដើម្បីកសាងប្រាសាទឱ្យជោតិកកុមារ ក្នុងលំដាប់នោះភពនៃព្រះឥន្ទក៏បង្ហាញអាការក្តៅ ទើបសក្កទេវរាជពិចារណាថា " តើមានហេតុដូចម្តេច ? " លុះជ្រាបថា សេដ្ឋីឱ្យគេជម្រះសំអាតផ្ទៃដី ដើម្បីកសាងប្រាសាទឱ្យជោតិកកុមារ ហើយកុមារនេះនឹងមិននៅក្នុងប្រាសាទ

ដែលជនទាំងនោះធ្វើទេ បើដូច្នោះត្រូវតែអាត្មាអញធ្វើឱ្យទើបបាន រួចក៏និម្មិតខ្លួនដូចជាងមេជាងដើមមកសួរថា " អ្នកទាំងអស់គ្នាទៅទីនោះតើមានកិច្ចការអ្វីនឹងធ្វើ ? " ពួកមហាជនប្រាប់ថា " យើងទៅសំអាតទីកន្លែងធ្វើប្រាសាទឱ្យជោតិកកុមារ " ។ សក្កទេវរាជប្រាប់ថា " អ្នកទាំងអស់គ្នាចូរចៀសចេញ ជោតិកកុមារនឹងមិននៅក្នុងប្រាសាទដែលអ្នកឯងធ្វើនោះទេ " រួចក៏ដើរមើលឃើញដី១កន្លែងទំហំ ១៦ករីស ហើយពង្រាបដីឱ្យស្មើឱ្យមានព្រំដែនត្រឹមត្រូវ ក្នុងខណៈនោះ ក៏និម្មិតប្រាសាទកែវ៧ជាន់ ឱ្យកើតឡើងភ្លាមព្រមទាំងកំពែង ក៏សុទ្ធតែកែវ៧ប្រការដែរ ។ លំដាប់នោះសក្កទេវរាជ ក៏និម្មិតដើមកប្បព្រឹក្សទាំងឡាយឱ្យដុះត្រង់ជ្រុងកំពែង នឹងពាងកំណប់ទ្រព្យទាំងឡាយ ៤ ឱ្យផុសត្រង់ជ្រុងប្រាសាទទាំង ៤ ពាងមួយទំហំ ១ យោជន៍ ពាងមួយទំហំ ៣គាវុត ពាងមួយទំហំកន្លះយោជន៍ នឹងពាងមួយទៀតទំហំ១គាវុត ។ ( ឯមាត់ពាងនោះធំប៉ុនមាត់ពាងកំណប់ទ្រព្យនៃព្រះពោធិសត្វដែរ ហើយជម្រៅខាងក្រោមរហូតដល់ទីបំផុតនៃផែនដី ) មានដើមអំពៅមាស ៤ ដើមប៉ុនដើមត្នោតសាវដុះនៅត្រង់ជ្រុងទាំង ៤ នៃប្រាសាទ ឯស្លឹកទាំងឡាយជាកែវមណី នឹងថ្នាំងជាមាស ។ បានឮថា ដើមអំពៅទាំងនេះដុះឡើងដើម្បីបង្ហាញបុព្វកម្មដល់ជោតិកកុមារ មានយក្ខ ៧ នាក់នៅចាំរក្សាត្រង់ក្លោងទ្វារទាំង៧ដែរ គឺយក្ខទី១ឈ្មោះ **យមមោឡិ** មានយក្ខជាបរិវារ

១០០០ នៅរក្សាក្លោងទ្វារទី១ យក្ខទី២ឈ្មោះ **ឧប្បលោ** មានបរិវារ ២០០០ រក្សាក្លោងទ្វារទី២, ទីពាឈ្មោះ **ទធីរោ** មានបរិវារ ៣០០០ រក្សាក្លោងទ្វារទី៣, ទី៤ឈ្មោះ **ទធីវាហោ** មានបរិវារ ៤០០០ រក្សាក្លោងទ្វារទី៤, ទី៥ឈ្មោះ **សងចោ** មានបរិវារ ៥០០០ រក្សាក្លោងទ្វារទី៥, ទី៦ឈ្មោះ **សងជក្កោ** មានបរិវារ ៦០០០ រក្សាក្លោងទ្វារទី៦ នឹងយក្ខទី៧ឈ្មោះ **ទិសាមុខោ** មានបរិវារ ៧០០០ រក្សាក្លោងទ្វារទី៧, ប្រាសាទនោះមានរក្សាយ៉ាងមុតមាំទាំងខាងក្នុងខាងក្រៅ ។ ព្រះរាជាទ្រង់ព្រះនាមព្រះបាទពិម្ពិសារទ្រង់សណ្ដាប់ថា ប្រាសាទ៧ជាន់ដែលសម្រេចដោយរតនវត្ថុ៧ប្រការបានរួចស្រេចហើយ ហើយមានកំពែង៧ជាន់ មានក្លោងទ្វារ៧ នឹងពាងកំណប់ទ្រព្យ៤ផុសឡើង ព្រះអង្គទ្រង់បញ្ជូនឆ័ត្រជាដំណែងសេដ្ឋីដល់ជោតិកកុមារ មាននាមប្រាកដហៅថា " **ជោតិកសេដ្ឋី** " តាំងពីពេលនោះមក ។ ចំណែកស្ត្រីដែលមានបុញ្ញកម្មធ្វើជាមួយគ្នានឹងជោតិកសេដ្ឋីនោះ នាងបានទៅកើតក្នុងដែនឧត្តរកុរុទ្វីបឯណោះ ។ លំដាប់នោះពួកទេវតាបានទៅនាំយកនាងពីឧត្តរកុរុទ្វីបមកឱ្យនៅក្នុងបន្ទប់ដ៏មានសេរី កាលដែលនាងមកបានយកទាំងនាឡិ ដ៏ពេញដោយអង្ករ១ នឹងដុំថ្មភ្លឺ៣ដុំមកផង ។ បាយក្នុងនាឡិនៃអង្ករនោះអាចចិញ្ចឹមជនទាំងនោះបាន១ជីវិត បើជនទាំងនោះចង់ចាក់

អង្ករឱ្យពេញរទេះរាប់រយនាឡិនោះ ក៏នៅតែមានអង្ករពេញដដែល មិនចេះខ្វះកន្លះឡើយ ដល់ពេលដាំបាយយកអង្ករនោះទៅដាក់ក្នុងឆ្នាំង ហើយលើកយកទៅដាក់លើដុំថ្មភ្លើ ៣ ដុំនោះក៏ឆេះ១រំពេច គ្រាន់តែបាយឆ្អិន ក៏រលត់ទៅវិញភ្លាម ជនទាំងឡាយបានដឹងថាបាយឆ្អិនដោយសញ្ញានោះឯង ឯការចម្អិនសម្ល ក៏មានន័យដូចគ្នាដែរ ។ ជនទាំងពីរនាក់នៅដោយសារតែពន្លឺកែវមណី មិនដែលស្គាល់ពន្លឺភ្លើងអគ្គិសនី ឬពន្លឺភ្លើងប្រទីបឡើយ ។ បានឮថាទ្រព្យសម្បត្តិរបស់ជោតិកសេដ្ឋីទាំងអម្បាលមាណ បានលេចឮរន្ទឺខ្ទរខ្ទាយទូទៅពេញសកលជម្ពូទ្វីប ពួកមហាជនទឹមយានទាំងឡាយបរមកដើម្បីទស្សនា សេដ្ឋីបង្គាប់ខ្ញុំបម្រើឱ្យចម្អិនអាហារដោយអង្ករក្នុងដែនឧត្តរកុរុ ឱ្យពួកមហាជនដែលមកទស្សនាបរិភោគឆ្អែតស្កប់ស្កល់ ហើយប្រាប់ថា " ចូរអ្នកទាំងអស់គ្នាទៅយកគ្រឿងអាភរណវត្ថុទាំងឡាយ មានសម្លៀកបំពាក់ជាដើម អំពីដើមកប្បព្រឹក្សឯណោះ " រួចប្រាប់ខ្ញុំប្រុសឱ្យបើកគំរបពាងកំណប់ទ្រព្យទំហំ ១គាវុត ហើយប្រាប់ថា " ចូរអ្នកទាំងអស់គ្នាយកទ្រព្យពីក្នុងពាងនេះដែលខ្លួនអាចលម្មយកទៅរួច " ។ កាលដែលពួកជនក្នុងជម្ពូទ្វីបទាំងមូលទៅយកទ្រព្យដែលសេដ្ឋីប្រទាន សូម្បីឱ្យកន្លះត្រឹមតែម្រាមដៃអំពីមាត់ពាងកំណប់ទ្រព្យនោះក៏គ្មានដែរ កំណប់ទ្រព្យនេះកើតដោយអានិសង្សដែលសេដ្ឋីចាក់រាយរតនវត្ថុឱ្យដូចជាខ្សាច់ពាសពេញបរិវេណគន្ធកុដិ ពីក្នុងអតី

ជាតិ ។ ព្រះបាទពិម្ពិសារព្រះអង្គចង់ទតប្រាសាទជោតិកសេដ្ឋី ប៉ុន្តែពួកមហាជនទៅទទួលយកទាន ដែលសេដ្ឋីចែកឱ្យគ្មានពេលទំនេរស្រាកស្រាន្តល្ហែសោះ លុះដល់ថ្ងៃក្រោយមកជាថ្ងៃដែលមានមនុស្សតិច ព្រះរាជាទ្រង់មានព្រះរាជបន្ទូលនឹងបិតាជោតិកសេដ្ឋីថា " យើងចង់ទៅទស្សនាប្រាសាទកូនរបស់អ្នក " សេដ្ឋីជាបិតាក្រាបទូលថា " បពិត្រព្រះសម្មតិទេពព្រះរាជឱង្ការនេះប្រពៃហើយ " ហើយគាត់ត្រឡប់ទៅវិញប្រាប់កូនថា " ម្នាលកូនសម្លាញ់ ! ព្រះរាជាចង់មកទស្សនាប្រាសាទអ្នក ! " កូនជំរាបថា " បពិត្របិតា បើព្រះអង្គបានយាងមកជាការប្រពៃហើយ ! ។ ព្រះរាជានាំពួកបរិវារយ៉ាងច្រើនយាងទៅទស្សនាប្រាសាទជោតិកសេដ្ឋីនោះ លុះយាងចូលទៅដល់ នាងទាសីដែលជាអ្នកយកសំរាមទៅចាក់ចោលបោសសំអាតនៅក្បែរក្លោងទ្វារទី១ ចាប់ដឹកព្រះហស្តព្រះរាជា ព្រះរាជាកាលអៀនខ្មាសមិនហ៊ានដាក់ព្រះហស្តទៅលើដៃនាងទាសីនោះទេ ដោយស្មានថាជាប្រពន្ធសេដ្ឋី ទៅដល់កោងទ្វារដ៏សេសទៀតក៏ព្រះអង្គមិនហ៊ានដាក់ព្រះហស្តទៅលើដៃនាងទាសីទាំងនោះដែរ ។ ឯជោតិកសេដ្ឋី ក៏បានក្រោកដើរទៅទទួលថ្វាយបង្គំព្រះរាជា ហើយដើរតាមក្រោយក្រាបទូលថា " សូមព្រះអង្គយាងទៅខាងមុខទៀត " លុះយាងទៅខាងមុខបន្តិចទៀត ទ្រង់ទតឃើញស្រមោលកែវមណីដែលចាំងទៅលើប្រឹថពី ក៏ប្រាកដដល់ព្រះអង្គថា ដូចជាអណ្តូងដ៏ជ្រៅ មានបុរស

រាប់រយនាក់នៅក្នុងនោះ ។ ព្រះរាជាទ្រង់សំគាល់ថាសេដ្ឋីនេះជីកអណ្ដូង ដើម្បីចាប់ច្រានអញទម្លាក់ទៅក្នុងនោះធ្វើឱ្យអញស្លាប់ ទ្រង់សំគាល់ដូច្នេះហើយក៏មិនហ៊ានឈានព្រះបាទយាងទៅលើកន្លែងនោះ ទ្រង់ឈរស្ងៀម ជោតិកសេដ្ឋីឃើញអាការៈដូច្នោះ ក៏ដើរទៅមុនក្រាបទូលថា " បពិត្រព្រះសម្មតិទេព នេះមិនមែនជាអណ្ដូងទេ សូមព្រះអង្គយាងតាមក្រោយខ្ញុំព្រះអង្គមក " ហើយសេដ្ឋីក៏ដើរនាំមុខព្រះរាជាទៅ ទើបព្រះអង្គហ៊ានយាងទៅតាមទស្សនាប្រាសាទនោះ តាំងពីផ្ទៃដីខាងក្រោម ដល់ថ្នាក់លើ ។

ក្នុងពេលនោះព្រះរាជកុមារព្រះនាម " អជាសត្រូវ " កាលចាប់ម្រាមព្រះហស្ដបិតាដើរឡើងទៅគិតថា " ឱបិតាអញល្ងង់ដូចជាបុគ្គលខ្វាក់ គេឋានៈត្រឹមសេដ្ឋី គេនៅក្នុងប្រាសាទកែវ ៧ជាន់ ចំណែកឯបិតាអញជាស្ដេចត្រឡាំងនៅក្នុងផ្ទះឈើវិញ មិនអីទេ ឥឡូវនេះបើអញបានជាស្ដេច អញនឹងមិនឱ្យសេដ្ឋីនៅក្នុងប្រាសាទនេះជាដាច់ខាត " ។ កាលដែលព្រះរាជាយាងឡើងទៅដល់ប្រាសាទជាន់ខាងលើ · ក៏ដល់ពេលសោយក្រយាស្ងោយក្នុងវេលាព្រឹក ទើបប្រឹក្សានឹងសេដ្ឋីថា " មហាសេដ្ឋីយើងនឹងសោយក្រយាស្ងោយពេលព្រឹកនៅកន្លែងនេះ " បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គបានឱ្យគេចាត់ចែងក្រយាស្ងោយថ្វាយព្រះអង្គហើយ " ។ ទើបសេដ្ឋីសុំយាងព្រះរាជាទៅស្រង់ឧទកវារីដែលពេញដោយ

គ្រឿងក្រអូប ៦យ៉ាង ហើយឱ្យផ្ទិសម្រាកព្រះកាយពលលើមណ្ឌលកែវ ដែលសេដ្ឋីធ្លាប់ដេក លុះដល់ពេលសោយក្រយា ពួកជនទាំងនោះថ្វាយទឹកសម្រាប់លាងព្រះហស្ត រួចដួសបាយបាយាសដ៏ជ្រាយអំពីឆ្នាំងមាសដែលមានតម្លៃ ១ សែនកហាបណៈ យកទៅដាក់ដម្កល់ទុកក្នុងទីចំពោះព្រះភ័ក្ត្រព្រះរាជា ព្រះរាជាប្រុងនឹងសោយដោយស្មានថាជាក្រយាស្ងោយ ។ លំដាប់នោះសេដ្ឋីក្រាបទូលថា " បពិត្រព្រះសម្មតិទេព វត្ថុនេះមិនមែនជាភោជនទេ គឺជាបាយបាយាសដ៏ជ្រាយ " រួចដួសភោជពីក្នុងឆ្នាំមាសដទៃទៀតយកទៅដាក់ក្នុងភោជនៈមុន ។ បានឮថាអាហារនោះបរិភោគទៅធ្វើឱ្យសុខស្រួលអំពីរដូវ ព្រះរាជាកាលសោយព្រះក្រយាស្ងោយ ដ៏មានរសឆ្ងាញ់មិនបានដឹងប្រមាណខ្លួន ។ ពេលនោះសេដ្ឋីលើករប្រណម្យថ្វាយបង្គំព្រះរាជាក្រាបទូលថា " បពិត្រព្រះសម្មតិទេព ព្រះអង្គសោយប៉ុណ្ណេះល្មមហើយ បើសោយតទៅទៀត ព្រះអង្គមិនអាចនឹងធ្វើអាហារនោះឱ្យទ្រុតទ្រោមទៅបានទេ " ។ ព្រះរាជាទ្រង់ត្រាស់នឹងសេដ្ឋីថា " ខ្លាចយើងសោយអាហារអ្នកឯងអស់ឬ ? " " ក្រាបទូលមិនខ្លាចអស់ទេ ខ្ញុំព្រះអង្គថ្វាយភោជនាហារទាំងអស់នេះដល់ព្រះអង្គបាន តែថាខ្ញុំព្រះអង្គខ្លាចទោសដែលមិនមែនជាយស " " ព្រោះហេតុអ្វី ? " ក្រាបទូល សេចក្តីខិលច្រអូសកាយគប្បីមានចំពោះព្រះអង្គម្យ៉ាងទៀតខ្ញុំព្រះអង្គខ្លាចពាក្យគេនិន្ទាថា ពិម្ពិសារមិញ ព្រះអង្គសោយក្រ

យាក្នុងផ្ទះសេដ្ឋី អំពើនេះឯងដែលសេដ្ឋីធ្វើឱ្យទៅជាយ៉ាងនោះ " ។ ព្រះរាជាថាបើដូច្នោះចូរនាំយកអាហារចេញ ហើយយកទឹកមក លុះព្រះអង្គសោយរួចហើយ ពួករាជបរិវារទាំងអស់នាំគ្នាបរិភោគអាហារនោះ ។ ព្រះរាជាទ្រង់គង់នៅជាសុខក្នុងប្រាសាទនោះ ទើបហៅសេដ្ឋីសួរថា " អ្នកឯងមិនទាន់មានប្រពន្ធទេឬ ? " " ក្រាបទូលខ្ញុំព្រះអង្គមានហើយ " " ចុះនៅឯណា ? " " ក្រាបទូលនាងនៅក្នុងបន្ទប់ដ៏មានសេរី នាងមិនបានដឹងថា ព្រះអង្គយាងមកក្នុងទីនេះទេ " ព្រះអង្គព្រមទាំងរាជបរិពារបានយាងនិងអញ្ជើញមកទីនេះ តាំងពីព្រលឹមម្ល៉េះក៏ពិតមែនហើយ តែថានាងមិនបានដឹងដំណឹងទាល់តែសោះ ។ បន្ទាប់ពីក្រាបទូលព្រះរាជាហើយ សេដ្ឋីគិតថា ព្រះរាជាចង់ឃើញប្រពន្ធអញ រួចដើរសំដៅទៅបន្ទប់ប្រពន្ធប្រាប់ថា " នាងមិនចង់ឃើញស្តេចទេឬ ? " ភរិយាជំរាបថា បពិត្រព្រះស្វាមី នរណាឈ្មោះថាជាស្តេច " ជនដែលមានឫទ្ធិអំណាចធំជាងយើងឈ្មោះថាស្តេច " នាងនឹកអាក់អន់ស្រពន់ចិត្តនិយាយរៀបរាប់ថា យើងបានធ្វើបុញ្ញកម្មមិនល្អ ដោយចិត្តគ្មានសទ្ធាមុតមាំ បានជាយើងមានឫទ្ធិអំណាចតិចជាងគេ ប៉ុន្តែដែលយើងបានទ្រព្យសម្បត្តិទាំងប៉ុណ្ណោះ ក៏ដោយសារអានិសង្សនៃទាននោះ " រួចសួរទៅប្តីថា " ចុះឥឡូវនេះឱ្យខ្ញុំធ្វើដូចម្តេច ? " សេដ្ឋីប្រាប់ថា " បើដូច្នោះចូរនាងយកផ្ចិតស្លឹកត្នោតទៅបក់ថ្វាយព្រះរាជាតាមបង្គាប់ ស្រាប់តែក្លិនឈ្នួតព្រះរាជាផ្សាយទៅប៉ះ

ភ្នែកនាងបណ្ដាលឱ្យនាងស្រក់ទឹកភ្នែក ។ លំដាប់នោះព្រះរាជាឃើញអាការៈដូច្នោះ ក៏សួរសេដ្ឋីថា " មហាសេដ្ឋីស្ត្រីនេះមានប្រាជ្ញាតិច នាងយំទំនងខ្លាចស្ដេចដណ្ដើមអូសរឹបជាន់យកសម្បត្តិប្ដីរបស់នាង ចូរអ្នកលួងលោមកុំឱ្យនាងយំ យើងគ្មានចង់បានទ្រព្យសម្បត្តិនាងទេ " ក្រាបទូលនាងមិនបានយំទេ " " ចុះហេតុនេះដូចម្ដេច ? " សេដ្ឋីក្រាបទូលថា " នាងហូរចេញទឹកភ្នែកព្រោះក្លិនឈ្មួតព្រះអង្គផ្សាយមកប៉ះត្រូវភ្នែកព្រោះថាប្រពន្ធខ្ញុំព្រះអង្គមិនដែលឃើញពន្លឺភ្លើងប្រទីប ឬភ្លើងអគ្គីសនីទេបពិត្រព្រះសម្មតិទេព នាងធ្លាប់បរិភោគក្ដី អង្គុយក្ដី ដេកក្ដី តែនឹងពន្លឺកែវប៉ុណ្ណោះ " ។ ព្រះរាជាត្រាស់ថា យីអើ!ប្លែកណាស់ហ្ន៎ យើងមិនដែលធ្លាប់ឃើញទេ រួចសេដ្ឋីក្រាបទូលថា " បពិត្រព្រះសម្មតិទេព បើដូច្នោះចាប់ពីថ្ងៃនេះទៅ សូមព្រះអង្គគង់ដោយពន្លឺកែវ ហើយក៏ថ្វាយមណីរតន៍ ដ៏មានតម្លៃច្រើន ១ដុំប៉ុនផ្លែឱឡឹកធំ ។ ព្រះរាជាទ្រង់បានទស្សនាប្រាសាទជោតិកសេដ្ឋីហើយមានព្រះរាជឱង្ការថា " ជោតិកសេដ្ឋីនេះមានសម្បត្តិច្រើនណាស់ហ្ន៎ " រួចព្រះអង្គទ្រង់យាងត្រឡប់ទៅរាជនិវេសន៍វិញ ។

ថ្លែងពីព្រះបាទអជាតសត្រូវ ដែលស្ម័គ្រស្មាគមន៍ជាមួយទេវទត្តបានសម្លាប់បិតាយករាជ្យសោយទ្រង់គិតថា " អញនឹងដណ្ដើមយកប្រាសាទជោតិកសេដ្ឋី " ហើយក៏ទ្រង់រៀបកងទ័ពចេញទៅ លុះនាំកងទ័ពទៅ

ដល់កំពែងប្រាសាទ ស្រាប់តែឃើញស្រមោលកងទ័ពរបស់ខ្លួនចាំងនឹងកំពែងកែវ ក៏សំគាល់ក្នុងចិត្តថា សេដ្ឋីបានរៀបចំកងទ័ពប្រុងច្បាំងនឹងអញ រួចក៏នាំកងទ័ពរបស់ខ្លួនរត់ត្រឡប់ទៅវិញ ។ ចំណែកសេដ្ឋីជាអ្នករក្សាឧបោសថសីល ក្នុងថ្ងៃនោះបានទៅវត្តតាំងពីព្រលឹម ដើម្បីស្តាប់ព្រះធម៌ទេសនានៃព្រះមានព្រះភាគ ។ ឯយក្ខឈ្មោះ **យមមោឡិ** ជាអ្នកថែរក្សានៅលើក្លោងទ្វារទី១ បានឃើញព្រះរាជានោះ ក៏ធ្វើឱ្យព្រះរាជាខ្លាចដេញប្រកិតតាមក្រោយ ព្រះអង្គភ័យពេករត់រហូតទៅដល់វត្ត ។ ពេលនោះសេដ្ឋីគ្រាន់តែឃើញព្រះរាជាភ្លាម ក៏ក្រោកឈរទទួលក្រាបទូលថា " បពិត្រព្រះសម្មតិទេព ព្រះអង្គមានហេតុដូចម្តេច ? ព្រះរាជាត្រាស់ថា " ម្នាលសេដ្ឋីអ្នកឯងប្រើពួកបុរសឱ្យរៀបកងទ័ពប្រុងច្បាំងនឹងយើងឬ ? ហើយខ្លួនគេចរត់មកឯណោះអង្គុយធ្វើដូចជាអ្នកអង្គុយស្តាប់ធម៌ ទើបសេដ្ឋីទូលសួរថា ព្រះអង្គចង់យកផ្ទះខ្ញុំព្រះអង្គឬ ? " អើយើងទៅយកផ្ទះអ្នកឯង " ។ សេដ្ឋីក្រាបទូលថា " បពិត្រព្រះសម្មតិទេព ទ្រព្យសម្បត្តិទាំងអស់ បើខ្ញុំព្រះអង្គថាមិនឱ្យទេ សូម្បីស្តេចមួយពាន់ក៏មិនអាចយកបានដែរ " ព្រះរាជាទ្រង់ខ្ញាល់ថា " ចុះអ្នកឯងជាស្តេចឬ " ? ។ សេដ្ឋីក្រាបទូលថា " ខ្ញុំព្រះអង្គមិនមែនជាស្តេចទេតែថាស្តេចទាំងឡាយក្តី ចោរទាំងឡាយក្តី មិនអាចដណ្តើមយកទ្រព្យរបស់ខ្ញុំព្រះអង្គ ត្រឹមតែអម្បោះចុងចេស ដែលខ្ញុំព្រះអង្គថាមិនឱ្យនោះបានទេ " " បើដូច្នោះយើង

នឹងដណ្ដើមយកតាមសេចក្ដីគាប់ចិត្តរបស់អ្នក តើអ្នកថាយ៉ាងម៉េច ? " ប ពិត្រព្រះសម្មតិទេព បើដូច្នោះជញ្ជៀន ២០វង់ ដែលនៅនឹងម្រាមដៃរបស់ខ្ញុំព្រះអង្គនេះ ខ្ញុំព្រះអង្គនឹងមិនថ្វាយទេ សូមព្រះអង្គដកយកលមើល ! ។ ព្រះរាជាលុះឮសេដ្ឋីថាដូច្នោះ ក៏គង់ប្រហោងលើដីទាញលោតទៅលើកំពស់ ១៨ហត្ថ រួចចុះមកវិញ លោតម្ដងទៀត ៨០ហត្ថ ក៏ចុះមកវិញដដែល ទ្រង់ខំប្រឹងបញ្ចេញកាយពលអស់ហើយ ដោះយកចិញ្ចៀនសូម្បីតែ១វង់ ក៏មិនបានផង ។ លំដាប់នោះសេដ្ឋីទូលថា " សូមព្រះអង្គចាំត្រងយកចុះ ខ្ញុំព្រះអង្គនឹងថ្វាយ " ហើយលាម្រាមដៃឱ្យត្រង់ស្រាប់តែចិញ្ចៀនទាំង២០វង់របូតចេញមកឯង។ ។ ទើបគាត់ទូលម្ដងទៀតថា " បើខ្ញុំព្រះអង្គមិនព្រមឱ្យទេ នរណាក៏មិនអាចយកបានដែរ " គាត់មានសេចក្ដីសង្វេគចំពោះកិរិយាអាក្រក់នៃព្រះរាជានោះ ទើបទូលថា " សូមទ្រង់មេត្តាប្រោសអនុញ្ញាតឱ្យខ្ញុំព្រះអង្គបួស " ។ ព្រះរាជាទ្រង់ព្រះចិន្តាថា បើសេដ្ឋីនេះបួស អញនឹងបានប្រាសាទនេះដេកនៅជាសុខស្រួល ទើបត្រាស់ដោយពាក្យតែ១ម៉ាត់ប៉ុណ្ណោះថា ចូរបួសចុះ ។ សេដ្ឋីនោះ លុះបួសក្នុងសំណាក់ព្រះសាស្ដាអស់កាលមិនបានយូរប៉ុន្មាន ក៏សម្រេចព្រះអរហត្តផល មាននាមប្រាកដថា **ជោតិកត្ថេរ**។ ក្នុងខណៈដែលលោកបានសម្រេចព្រះអរហត្តភ្លាម ទ្រព្យសម្បត្តិស្ទើរតែទាំងអស់អន្តរធាន

បាត់អស់ទៅជាមួយគ្នាក្នុងពេលនោះ ។ ពួកទេវតាក៏នាំយកភរិយាសេដ្ឋី ឈ្មោះនាង **សត្ថុលគាយ** ទៅឧត្តរកុរុទ្វីបវិញ ។

## ៦. រឿងស្ត្រីពីរនាក់ចងពៀរនឹងគ្នា (ចាក ធ. ខុ.)

*(អ្នកធ្វើបាបគេ ត្រូវគេធ្វើបាបខ្លួនវិញ)*

មានស្ត្រីម្នាក់ជាស្រីអាឥតកូន ខ្លាចក្រែងប្ដីយកប្រពន្ធមួយទៀត នឹងត្រួតត្រាលើខ្លួន ក៏ទៅដណ្ដឹងស្ត្រីម្នាក់មកឱ្យជាប្រពន្ធរបស់ប្ដីដោយខ្លួនឯង ដើម្បីឱ្យប្រពន្ធក្រោយនៅក្រោមអំណាចខ្លួន ។ លុះគេមានគភ៌ក៏ផ្សំថ្នាំឱ្យគេស៊ីរលូតគភ៌ដល់ពីរដង ម្ដងក្រោយទៀតជាគំរប់បី ប្រពន្ធចុង ក៏ស្លាប់ទាំងកូនក្នុងពោះ ។ វេលាទៀបនឹងស្លាប់នោះ បានចងពៀរនឹងគ្នាថា " បើអញទៅកើតជាអ្វីៗក៏ដោយ សូមឱ្យបានស៊ីកូនវាវិញកុំខាន " ។ លុះប្រពន្ធចុងស្លាប់ហើយ ប្ដីបានដឹងហេតុនោះ ក៏វាយប្រពន្ធដើមជាដំណំ មិនយូរប៉ុន្មានក៏ស្លាប់ទៅ រៀបនឹងស្លាប់បានចងពៀរដូចគ្នា ។ ឯភរិយាដែលជាប់ពៀរនឹងគ្នាទៅមុខទៀតនោះ យ៉ាងនេះគឺ :

ជាតិទី ១ ប្រពន្ធចុងជាមេឆ្មា ប្រពន្ធដើមជាមេមាន់ ។

ជាតិទី ២ ប្រពន្ធចុងជាមេម្រឹគ ប្រពន្ធដើមជាមេខ្លាដំបង ។

ជាតិទី ៣ ប្រពន្ធចុងជាយក្ខិនី ប្រពន្ធដើមជាកុលធីតា ។

ស៊ីតែកូនគ្នាទៅវិញទៅមករាល់ៗជាតិ ។ ក្នុងជាតិទី ៣ ប្រពន្ធចុងដែលកើតជាយក្ខិនីស៊ីកូនប្រពន្ធដើម ដែលកើតជានាងកុលធីតាដល់ពីរដង

វេលាដែលប្រាវព្ធនឹងស៊ីជាគំរប់បី នាងកុលធីតាក៏នាំកូនខ្ចីរត់ចូលទៅឯវត្ត ជេតពន ក្នុងវេលាដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់កំពុងសម្តែងធមិកណ្តាល ប្រជុំពុទ្ធបរិស័ទ នាងកុលធីតាក៏យកកូនទៅដាក់ក្បែរព្រះបាទថ្វាយព្រះអង្គ ។ ក្នុងខណៈនោះ នាងយក្ខិនីរត់តាមមកទាន់ ។ ព្រះអង្គមានព្រះពុទ្ធដីកាថា " នែនាងទាំងឡាយ ! ត្រូវឈប់ចងពៀរនឹងគ្នាទៅ ត្បិតអំពើដែលនាងឯងចងពៀរនឹងគ្នានេះ បើប្រសិនណាជាមិនបានចួបនឹងតថាគតទេ ពៀរនេះមុខជានឹងចេះតែចងគ្នាដរាបដល់អស់១កប្បនេះមិនខាន ប៉ុន្តែឥឡូវនេះ នាងទាំងពីរនាក់បានមកជួបនឹងតថាគតហើយឈប់ចងពៀរនឹងគ្នាទៀតទៅ ពៀរនេះនឹងរលត់អស់ត្រឹមនេះ " ។

ស្ត្រីទាំងពីរនាក់នោះ ក៏លែងចងពៀរនឹងគ្នាតាំងអំពីថ្ងៃនោះមកត្រឡប់ជាមានចិត្តស្នេហាស្រឡាញ់គ្នាតទៅ ។

## ៧. រឿងព្រានប្រេត (ចាក បេ. ខុ.)

*( អានិសង្សនៃការឧទ្ទិសផលចំពោះពួកប្រេត )*

កាលព្រះបរមលោកនាថ ព្រះអង្គគង់នៅវត្តវេឡុវ៉ន មានព្រានម្នាក់សំណាក់នៅទិសាភាគនៃនគរពារាណសី ។ ព្រាននោះតែងត្រាច់ទៅព្រៃបរបាញ់សត្វម្រឹគបក្សី បានហើយឆ្អើរសាច់បរិភោគ ឯសាច់ដែលនៅសល់ពីរនោះគាត់វែកយកមកលំនៅ ។ ចំណែកពួកក្មេងៗ បានឃើញគាត់វែកសាច់មកដល់មាត់ព្រៃដូច្នោះហើយ ម្ចីម្នាប្រញាប់រត់ទៅសុំសាច់នៃ

ព្រាននោះ គាត់ក៏ហុចឱ្យ១ដុំៗម្នាក់ ។ មានកាលសម័យថ្ងៃមួយ ព្រានទៅព្រៃបរបាញ់សត្វពុំបានមួយឡើយ ទើបគាត់បេះផ្កាវាជពិស (ផ្កាត្របែកព្រៃ) យកមកប្រដាប់អាត្មា រួចហើយតបេះដាក់អង្រែងកវែកវិលមកវិញ អស់ពួកក្មេងៗរត់ប្រញាយទៅសុំសាច់ព្រាននោះ គាត់ក៏ឱ្យផ្កាវាជពិសមួយចង្កោមម្នាក់ៗ ។ លុះយូរបន្តិចទៅព្រាននោះក្សិណក្ស័យជីវិត បានទៅកើតជាប្រេតមានរូបអាក្រក់គួរឱ្យខ្លាចក្រៃពេក ប្រដាប់ដោយផ្កាវាជពិសលើក្បាល ហើយចុះក្នុងទឹកស្ទឹងលុយច្រាសទឹកឡើងលើ ដោយគិតថានឹងទៅរកញាតិកាក្នុងស្រុកនោះ ។

(ការដោតផ្កាត្របែកព្រៃលើបាយបិណ្ឌព្រោះរឿងនេះ)

លំដាប់នោះ មានមហាមាត្យម្នាក់ឈ្មោះកាឡី ព្រះបាទពិម្ពិសារទ្រង់ត្រាស់បញ្ជាឱ្យទៅបង្រ្កាបសត្រូវនៅឯជនបទ លុះបង្រ្កាបសត្រូវបានរាបទាបស្រេចហើយ ក៏ឱ្យពលសេះ-រទេះ-ថ្មើរជើងវិលត្រឡប់តាមផ្លូវគោកមកវិញ ។ ឯអាមាត្យនោះចុះមកតាមទន្លេ បានប្រទះប្រេតនោះកំពុងលុយទឹកមានរូបអាក្រក់ក្រៃ ទើបដណ្តឹងសួរថា នែព្រះស្តែងមានរូបអាក្រក់ប្រដាប់ដោយផ្កាវាជពិសលើក្បាល លុយទឹកទៅឯណា ? តើទីលំនៅស្ថិតទៅតម្បន់ណា ? ចូរព្រះស្តែងប្រាប់យើងឱ្យបានដឹង ។ ប្រេតស្តាប់សំនួរមហាមាត្យសួរដូច្នោះហើយ ឆ្លើយប្រាប់ថាខ្ញុំទៅរកញាតិការនៅក្នុងស្រុកចូលិតគ្រាម នាទគរពារាណសី ដើម្បីនឹងរកភោជនាហារ ។

មហាមាត្យស្តាប់ហើយមានចិត្តមេត្តាករុណា ទើបនិយាយថា បាយសត្វរ ខៅតាកយើងមាន តើធ្វើដូចម្តេចនឹងបានដល់អ្នក ? ទើបប្រេតឆ្លើយថា បើលោកមេត្តាអាសូរខ្ញុំ ក្រែងមានអ្នកណាជាឧបាសករក្សាគុណព្រះរតនត្រ័យតាំងនៅក្នុងព្រះត្រៃសរណគមន៍មាននៅក្នុងទូកលោកសូមលោកឱ្យទៅអ្នកនោះ ហើយឧទ្ទិសចំណែកបុណ្យចំពោះមកខ្ញុំៗនឹងបានសេចក្តីសុខរួចចាកទុក្ខផងទាំងពួង ។

គ្រានោះមានជាងកាត់សក់ម្នាក់នៅក្នុងទូកនោះ ជាឧបាសកត្រេកអរក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទើបមហាមាត្យឱ្យឧបាសកនោះងូតទឹកស្លៀកដណ្តប់សម្តត់រលីងដូចសម្បុរមាសស្រេចហើយ ឱ្យបរិភោគអាហារភោជន រួចឧទ្ទិសចំណែកបុណ្យចំពោះទៅប្រេតថា ឥទំ ទានំ វិទាននេះចូរសម្រេចដល់ប្រេតហោង ។ ដោយការឧទ្ទិសកុសលនេះ ក៏បានសម្រេចដល់ប្រេតនោះឱ្យមានសំពត់ស្លៀកដណ្តប់ មានអាហារបរិភោគដ៏ត្រកាល ឃើញជាក់ច្បាស់ទាន់ហន់ក្នុងពេលនោះ ។ កាលដែលមហាមាត្យឧទ្ទិសកុសលដល់ប្រេត ឃើញច្បាស់ជាក់នឹងភ្នែកស្រេចហើយ ក៏ចុះទូកអុំទៅទាំងយប់ពុំឈប់និទ្រា លុះព្រឹកព្រាងស្វាងព្រះសុរិយា ក៏បានទៅដល់នគរពារាណសី ។ ព្រះភគវាទ្រង់ព្រះដំណើរមកតាមអាកាសដើម្បីនឹងអនុគ្រោះដោះទុក្ខមហាជនទាំងឡាយ ទ្រង់ចុះពីអាកាសមកប្រតិស្ឋានទៀបឆ្នេរមហាទនី។ កាលនោះកាឡិអាមាត្យឡើងមកអំពីទូក ក៏

ជួបព្រះបរមលោកនាថក្នុងទីនោះ មានចិត្តត្រេកអរម្ពីម្នាចូលទៅក្រាបថ្វាយបង្គំអារាធនានិមន្តទទួលចង្ហាន់ក្នុងវេលាព្រឹកនោះ ព្រះអង្គទ្រង់ទទួលនិមន្តដោយតុណ្ហីភាពតាមប្រវេណីនៃព្រះពុទ្ធពីបុរាណ ។ មហាមាត្យលុះដឹងថា ព្រះអង្គទទួលនិមន្តហើយ ក៏ប្រញាប់ប្រញាល់ទៅជំរះទីឱ្យរាបស្មើ ធ្វើមណ្ឌលមុខ ៤ ប្រដាប់គ្រឿងសក្ការបូជាមាលាផ្កាកម្រងគ្រឿងក្រអូបផ្សេងៗ ក្រាលអាសនៈថ្វាយព្រះអង្គគង់ ។ ព្រះអង្គគង់លើអាសនៈដ៏សមគួរហើយ ទើបមហាមាត្យក្រាបទូលអំពីហេតុដែលបានឃើញប្រេត ព្រមទាំងបានឧទ្ទិសចំណែកបុណ្យឱ្យដល់ប្រេតនោះផង ក៏បានរួចចាកទុក្ខទាំងពួង ។ ទើបព្រះអង្គទ្រង់មានព្រះចិន្តាថាពួកភិក្ខុសង្ឃចូរមកក្នុងទីនេះ ព្រះអង្គទ្រង់ព្រះចិន្តាដូច្នេះហើយ ពួកភិក្ខុសង្ឃ ក៏មកអង្គុយចោមរោមព្រះអង្គជាបរិវារ ។ មហាមាត្យឃើញព្រះសង្ឃគង់ចោមរោមព្រះសាស្តាដូច្នោះហើយ រឹងរឹតតែមានសេចក្តីត្រេកអរចូលទៅអង្គាសភត្តថ្វាយព្រះអង្គ នឹងភិក្ខុសង្ឃស្រេចហើយ ទើបព្រះអង្គទ្រង់អធិដ្ឋានថា មនុស្សផងទាំងឡាយដែលនៅទៀបនគរនេះចូរមកប្រជុំគ្នាក្នុងទីនេះ ។ ពួកមហាជនក៏មកប្រជុំគ្នាស្រេចហើយ ព្រះអង្គទ្រង់សម្តែងឫទ្ធិឱ្យមើលពួកប្រេតឃើញដោយចក្ខុរបស់ខ្លួន ។ ឯប្រេតខ្លះមានកំណាត់សំពត់បន្តិចរុំខ្លួន ខ្លះគ្មានសំពត់ស្លៀកដណ្តប់ រំសាយសក់គ្របខ្លួន ខ្លះអត់បាយអត់ទឹកស្គាំងស្គមមានតែស្បែករុំឆ្អឹងរត់ទៅរត់មក ព្រះអង្គទ្រង់សម្តែង

ឥទ្ធិឫទ្ធិឱ្យពួកប្រេតនោះមូលមកប្រជុំគ្នាតែមួយពួក ហើយឱ្យសម្តែងបុព្វកម្មរៀង១ខ្លួន ប្រេតខ្លះថា យើងជាមាតានៃក្មេងទាំងឡាយនេះ ជាអ្នកមានទ្រព្យសម្បត្តិច្រើន ពុំបានធ្វើបុណ្យសុន្ទរីទានដល់ស្មូមយាចក ពុំបានដាក់បាត្រប្រគេនព្រះសង្ឃ ខ្លះថាយើងជាមនុស្សមច្ឆរិយកំណាញ់ស្វិតស្វាញជួជាតិសាមាន្យ ពុំមានចិត្តត្រេកអរក្នុងការកុសលនានា ។ ដោយហេតុបាបកម្មយ៉ាងនេះឯង ក៏បណ្តាលឱ្យរងទុក្ខវេទនា អត់បាយអត់ទឹកមានខ្លួនអាក្រាតរកសំពត់ស្លៀកដណ្តប់ពុំបាន ។ ខ្លះថាយើងរវល់តែស្តាយអាឡោះអាល័យទ្រព្យសម្បត្តិស្រែចំការច្បារដំណាំ ពុំហ៊ានធ្វើបុណ្យទានថែមទាំងខ្លួនក៏ពុំហ៊ានបរិភោគឱ្យបានស្កប់ស្កល់ លុះដល់ស្លាប់ទៅរបស់ទាំងនោះក៏ពុំអាចយកទៅជាមួយបានផងមកតែម្នាក់ឯងកណ្តែងកណ្តោចខ្លោចផ្សារកំព្រារងទុក្ខវេទនាក្រៃពេក លុះលះបង់កំណើតអំពីប្រេតនេះទៅ និងបានទៅកើតត្រកូលថោកទាប មានត្រកូលចណ្ឌាលជាដើម ។

កាលដែលព្រះសាស្តាបរមគ្រូទ្រង់សំដែងពីទាន ដែលបុគ្គលបានធ្វើ ដើម្បីកាត់បង់សេចក្តីកំណាញ់ ត្រេកអរនឹងអំពើជាកុសលតម្កល់ទុកក្នុងជាតិនេះ លុះរំលាយខន្ធទៅ រមែងបានទៅកើតស្ថានសួគ៌បរិបូណ៌ដោយរូបឆោមពណ្ណល្អ មានបរិវារចោមរោមថ្កុំថ្កើងរុងរឿង មានរស្មីផ្សាយចេញពីរាងកាយ មានស្រះបោក្ខរណីជាទីសប្បាយ មានប្រាសាទមាស ឱកាសដោយរស្មីជាទីស្រណុកសុខសប្បាយ ឥតអន្តរាយមកបៀត

បៀនបានឡើយ លុះច្យុតអំពីស្ថានសួគ៌នោះបានមកកើតក្នុងវង្សត្រកូលថ្កុំថ្កើងរុងរឿង មានត្រកូលក្សត្រជាដើម មានសម្បត្តិនោះច្រើនអនេកមានស្រីស្រីង្គារចោមរោមជាបរិវារ ព្រោះហេតុតែបានធ្វើបុណ្យកុសលតម្កល់ទុកពីជាតិមុនទើបបានសម្បត្តិនោះក្នុងលោកិយ និងបរលោក ។ ឯសម្បត្តិទាំងពីរនេះបើបុគ្គលពុំបានធ្វើហើយ ក៏ពុំអាចនឹងបានឡើយ ។ ឯពួកមហាជន មានកាឡីអាមាត្យជាប្រធានបានស្តាប់ហើយមានចិត្តរីករាយត្រេកអរយ៉ាងក្រៃលែង លុះចប់ធម្មវិសេសទេសនា អស់មហាជនក៏បានលុះធម្មាភិសម័យតាមឧបនិស្ស័យវាសនារៀងៗខ្លួន ។

## ៨. រឿងឧបាសកត្រចៀកខ្ទូរ

(ចាក ធ. ខុ.)

*(អ្នកណារក្សាធម៌ ធម៌តែងរក្សាអ្នកនោះវិញ)*

សម័យថ្ងៃមួយ ព្រះមហាកច្ចានៈដ៏មានអាយុ លោកគង់នៅលើភ្នំបុវត្តៈក្នុងនគរកុរឃរត្រង់អវន្តិជនបទ មានឧបាសកត្រចៀកខ្ទូរម្នាក់ឈ្មោះ **សោណៈ** ជ្រះថ្លានឹងធម្មកថារបស់ព្រះថេរៈចង់បួស ព្រះថេរៈឃាត់ថា ម្នាលសោណៈ ការប្រព្រឹត្តធម៌ដ៏ប្រសើរនេះ ជាការលំបាកមានភត្តតែមួយពេល ដេកនៅតែម្នាក់ឯងរហូតអស់មួយជីវិត គាត់មានសេចក្តីជ្រះថ្លាខ្លាំងណាស់ក្នុងផ្ទួស អត់ទ្រាំមិនបានក៏ចូលទៅអង្វរករសុំបួសគ្រប់៣ដង, នៅក្នុងប្រទេសទក្ខិណាបថជាប្រទេសមានភិក្ខុតិច លុះបួសហើយ

បាន ៤ វស្សាចង់ទៅនមស្ការថ្វាយបង្គំព្រះសាស្តា ទើបលាព្រះឧបជ្ឈាយ៍ ទៅតាមបណ្តាំរបស់លោកទៅដល់ជេតពន ចូលទៅថ្វាយបង្គំព្រះសាស្តា ព្រះអង្គទ្រង់ធ្វើបដិសណ្ឋារកិច្ច ហើយទ្រង់អនុញ្ញាតឱ្យនៅក្នុងគន្ធកុដិជាមួយព្រះអង្គ លុះយប់ជ្រៅបន្តិចកន្លងទៅព្រះសាស្តាទ្រង់អារាធនាឱ្យធ្វើបទសរភញ្ញថ្វាយព្រះអង្គស្តាប់ក្នុងបច្ចូសម័យ ។ លុះចប់បទសរភញ្ញហើយ ព្រះអង្គទ្រង់អនុមោទនាយ៉ាងក្រៃលែងចំពោះសោណភិក្ខុនោះ ហើយទ្រង់ប្រទានសព្ទសាធុការពរថា សាធុ សាធុ ។ ចាប់តាំងពីពួកទេវតា នាគ នឹងគ្រុឌ ដែលឋិតនៅលើដីរហូតដល់ព្រហ្មលោក ជួយឱ្យពរសព្ទសាធុការដល់សោណភិក្ខុតាមព្រះសាស្តាដែរ ។ ខណៈនោះទេវតាដែលអាស្រ័យនៅក្នុងផ្ទះមហាឧបាសិកាជាម្តាយរបស់លោក ក្នុងកុររឃរនគរ ចម្ងាយ ១២០ យោជន៍ពីវត្តជេតពន ក៏បានឱ្យសព្ទសាធុការពរយ៉ាងខ្លាំង ។ គ្រានោះមហាឧបាសិកាសួរថានរណាឱ្យសាធុការពរនេះ ? ទេវតាប្រាប់ថាម្នាំប្អូនស្រីខ្ញុំណានាង ចុះលោកជាអ្វី ? ខ្ញុំជាទេវតាឋិតក្នុងផ្ទះនេះពីមុនក៏លោកមិនឱ្យសាធុការពរដល់ខ្ញុំ ស្រាប់តែថ្ងៃនេះក៏ឱ្យដូច្នេះ ព្រោះហេតុអ្វី ? ទេវតាប្រាប់ថា ខ្ញុំមិនឱ្យសាធុការពរដល់នាងទេ ។ បើដូច្នោះលោកឱ្យដល់នរណា ? ខ្ញុំឱ្យដល់កុដិកណ្ណសោនត្ថេរជាបុត្ររបស់នាង ចុះកូនខ្ញុំធ្វើអ្វីបានជាលោកឱ្យសាធុការពរ ? ។ ទេវតាប្រាប់ថា កូននាងគង់នៅក្នុងគន្ធកុដិជាមួយនឹងព្រះសាស្តាក្នុងថ្ងៃនេះ ហើយសម្តែងធម៌

ថ្វាយព្រះអង្គៗទ្រង់ព្រះសណ្ដាប់ធម៌កូនរបស់នាង ទ្រង់ជ្រះថ្លាឱ្យសាធុការពរ ព្រោះហេតុនោះហើយ បានជាខ្ញុំឱ្យសាធុកាពរនេះដល់កូនរបស់នាងព្រោះថាគ្រប់កន្លែងទាំងអស់ទទួលសាធុការពររបស់ព្រះសម្មាសម្ពុទ្ធតាំងពីទេវតាដែលឋិតនៅលើផែនដីរហូតដល់ព្រហ្មលោក ។ មហាឧបាសិកាសួរថា បពិត្រលោកទេវតា កូនខ្ញុំសម្ដែងធម៌ថ្វាយព្រះសាស្ដាឬ ? ឬថាព្រះអង្គសំដែងធម៌ដល់កូនខ្ញុំ? ទេវតាប្រាប់ថាកូននាងសម្ដែងធម៌ថ្វាយព្រះអង្គ ។ កាលទេវតាប្រាប់ដូច្នោះ នាងឧបាសិកាកើតបីតិទាំង ៥ ផ្សាយទៅសព្វសរីរទាំងមូល ។ លំដាប់នោះនាងឧបាសិកាគិតត្រិះរិះថា បើកូនរបស់អញនៅក្នុងគន្ធកុដិជាមួយព្រះសាស្ដា ហ៊ានសម្ដែងធម៌ថ្វាយព្រះអង្គមុខជាអាចសម្ដែងធម៌ដល់អញដែរ កាលបើលោកនិមន្តមកវិញ អញនឹងនិមន្តឱ្យសម្ដែងមិនខាន ។

ចំណែកព្រះសោណត្ថេរកាលព្រះសាស្ដាទ្រង់ប្រទានសាធុការពររួចហើយ គិតថាកាលនេះជាកាលគួរដើម្បីនឹងក្រាបទូលពាក្យបណ្ដាំដែលព្រះឧបជ្ឈាយ៍របស់អាត្មាអញផ្ដាំមក ហើយក៏ទូលសុំពរ ៥ ប្រការ នឹងព្រះមានព្រះភាគ ដើម្បីឧបសម្បទដោយគណៈសង្ឃ ៥ អង្គ មានព្រះវិន័យធរជាប្រធានក្នុងបច្ចន្តជនបទទាំងឡាយ ព្រះអង្គក៏ទ្រង់ប្រទានពរទាំង៥ប្រការនោះរួចនៅក្នុងសំណាក់ព្រះសាស្ដាអស់ពីរបីថ្ងៃ លុះរលឹកព្រះឧបជ្ឈាយ៍ ក៏ចូលទៅថ្វាយបង្គំលាព្រះសាស្ដាចេញពីវត្តជេតពន

ត្រឡប់ទៅសំណាក់ព្រះឧបជ្ឈាយ៍វិញតាមលំដាប់ ។ លុះដល់ថ្ងៃព្រឹកឡើងព្រះថេរៈនាំសោណត្ថេរទៅបិណ្ឌបាត បានទៅឈរនៅត្រង់មុខទ្វារផ្ទះមហាឧបាសិកាជាមាតា ។ គាត់ឃើញកូនមានចិត្តត្រេកអរថ្វាយបង្គំអង្គាសភត្តដោយផ្ចិតផ្ចង់ ហើយសួរថា លោកកូនលោកបាននៅក្នុងគន្ធកុដិជាមួយនឹងព្រះសាស្តា ហើយបានសំដែងធម៌ថ្វាយព្រះអង្គស្តាប់មែនឬទេ ? ។ ព្រះថេរៈសួរថា ញោមការនេះនរណានិយាយប្រាប់ញោម ? មាតាទូលថា បពិត្រលោកកូន ទេវតាដែលអាស្រ័យនៅក្នុងផ្ទះនេះបានឱ្យសាធុការពរយ៉ាងខ្លាំង១ ខ្ញុំព្រះករុណាបានសួរថានរណានេះ ? ទេវតាប្រាប់ថា ខ្ញុំជាទេវតានៅក្នុងផ្ទះនេះ ព្រោះហេតុនោះខ្ញុំព្រះករុណា បានគិតថាបើលោកកូនហ៊ានសំដែងធម៌ថ្វាយព្រះអង្គបាន មុខជាអាចហ៊ានសំដែងធម៌ដល់ខ្ញុំព្រះករុណាដែរ ។ លំដាប់នោះមាតានិយាយថា កូនសំដែងធម៌អ្វីថ្វាយព្រះសាស្តា ចូរកូនសំដែងធម៌នោះឱ្យខ្ញុំព្រះករុណាស្តាប់ផង ហើយឱ្យគេធ្វើរោងមួយធំរួចកំណត់ថ្ងៃនឹងសំដែងធម៌ ។ ព្រះថេរៈក៏ទទួលនិមន្តតាមពាក្យសុំរបស់មាតា គាត់ថ្វាយទានចំពោះភិក្ខុសង្ឃទុកស្ត្រីបំរើម្នាក់ឱ្យនៅចាំផ្ទះ រួចនាំជនជាបរិស័ទទៅស្តាប់ធម៌កូនគាត់ក្នុងបារាំ ដែលគេតាក់តែងធ្វើស្រេចនោះ ។

នៅពេលនោះស្រាប់តែមានពួកចោរ ៩០០ នាក់ ដើរគយគន់ចាំមើលឱ្យតែនាងឧបាសិកានោះ ចេញពីផ្ទះទៅផុតនឹងចូលទៅលួច ។ ចំ

ណែកផ្ទះនាងឧបាសិកានោះមានកំពែងព័ទ្ធព័ទ្ធ ៧ ជាន់ មានក្លោងទ្វារ ៧ជាន់ គេដាក់ឆ្កែកាច១ឱ្យនៅចាំគ្រប់កន្លែងទាំងអស់ រួចជីកស្នាមភ្លោះត្រង់កន្លែងដែលទឹកធ្លាក់ចុះពីដំបូលផ្ទះ ដាក់សំណោភក់ពេញ ហើយសណោនោះត្រូវក្តៅរលាយដូចទឹកពុះ ដល់ពេលយប់រឹងគគ្រាត ថែមទាំងមានចំរូងដែក ដ៏ធំ១បោះដាក់គ្មានសល់កន្លែង ។ មានការរក្សាដូចរៀបរាប់មកនេះពួកចោរមិនអាចនឹងចូលទៅលួចបាន ដោយសារនាងឧបាសិកានៅក្នុងផ្ទះនោះផង ស្រាប់តែក្នុងថ្ងៃនោះ វាដឹងថាមហាឧបាសិកាមិននៅ វាជីករូងទម្លាយចូលទៅក្នុងផ្ទះតាមចំណែកខាងក្រោមសំណោភក់ នឹងចំរូងដែកលុះចូលទៅមិនឃើញមហាឧបាសិកា វាប្រើមេចោរម្នាក់ប្រាប់ថា បើមហាឧបាសិកានោះឮដំណើងថាពួកយើងចូលទៅផ្ទះនេះ គាត់ត្រឡប់មកផ្ទះវិញ ចូរអ្នកឯងសម្លាប់នឹងដាវនេះឱ្យស្លាប់ ។ មេចោរនោះទៅឈរនៅក្នុងទីជិតនៃមហាឧបាសិកានោះ ។ ពួកចោរក៏អុជប្រទីបខាងក្នុងផ្ទះហើយបើកទ្វារបន្ទប់ដែលទុកកហាបណៈ ។ នាងទាសីឃើញពួកចោរក៏រត់ទៅជម្រាបមហាឧបាសិកាថាមានពួកចោរចូលទៅក្នុងផ្ទះ បើកទ្វារដែលដាក់កហាបណៈ ។ មហាឧបាសិកាប្រាប់ថាពួកចោរអញ្ជើញយកវត្ថុដែលពួកអ្នកឯងរកឃើញទៅចុះ ខ្ញុំកំពុងស្តាប់ធម៌ទេសនារបស់កូនខ្ញុំ ចូរកុំធ្វើសេចក្តីអន្តរាយដល់ធម៌របស់ខ្ញុំ នាងឯងទៅផ្ទះវិញប្រាប់យ៉ាងនេះចុះ ។ ឯពួកចោរបើកបន្ទប់កហាបណៈយកអស់រលីង រួចទៅបើកបន្ទប់

ដាក់ប្រាក់ទៀត ។ នាងទាសីរត់ទៅជំរាបមហាឧបាសិកានិយាយប្រាប់ដូចពេលមុន ។ វាទៅបើកបន្ទប់ដាក់ប្រាក់យកអស់ទៀត រួចទៅបើកបន្ទប់ដាក់មាសទៀត ។ នាងទាសីរត់ទៅជម្រាបមហាឧបាសិកាម្តងទៀត ។ លំដាប់នោះគាត់ហៅនាងទាសីមកប្រាប់ថា នាងឯងមកកន្លែងអញច្រើនដងហើយ មិនស្តាប់ពាក្យអញសោះ ទោះបីប្រាប់ថាវាចង់យករបស់អ្វី ឱ្យវាយកទៅចុះកុំមកធ្វើឱ្យខូចការស្តាប់ធម៌របស់អញ ឥឡូវនេះនាងឯងត្រឡប់ទៅវិញទៅ បើមកទៀតអញនឹងធ្វើទោសនាងឯង ម្តងនេះអញអត់ទោសអោយ នាងទាសីក៏ទទួលស្តាប់ធ្វើតាមបង្គាប់ ។ មេចោរឮមហាឧបាសិកានិយាយដូច្នោះ ក៏គិតថារន្ទះបាញ់បំបែកក្បាលជនណាដែលយកទ្រព្យស្ត្រីនេះមិនខាន លុះគិតដូច្នេះហើយ ក៏រត់ទៅប្រាប់ពួកចោរទាំងនោះថា នែពួកយើង កុំយកទ្រព្យមហាឧបាសិកានេះ ចូរទុកទៅវិញឱ្យនៅតាមប្រក្រតីឆាប់ៗ ពួកចោរទាំងនោះក៏ដាក់កហាបណៈប្រាក់ នឹងមាសតាមកន្លែងដើមវិញ តាមពាក្យដែលមេចោរប្រាប់ ។

តាមធម្មតាធម៌តែងរក្សានូវជនអ្នកប្រព្រឹត្តធម៌ ព្រោះហេតុនោះហើយ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា :

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ធម៌ហ្នឹងឯង តែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលគេសន្សំដោយល្អរមែងបានសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ដែលគេសន្សំដោយល្អ បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិភូមិទេ ។

ពួកចោរបានទៅឈរស្ដាប់ធម៌ទេសនា ព្រះថេរៈកំពុងសំដែងធម៌លុះដល់ពេលជិតភ្លឺ លោកបញ្ចប់ធម៌ទេសនាចុះពីធម្មាសនៈវិញ ។ ខណៈនោះមេចោរក្រាបក្បាលទៀបជើងមហាឧបាសិកាសុំខមាទោសនឹងគាត់ៗសួរថាចុះអ្នកមានការណ៍ដូចម្ដេច ? មេចោរប្រាប់ថាខ្ញុំបានចងគំនុំបម្រុងនឹងសម្លាប់លោកស្រី ។ មហាឧបាសិកានិយាយថា បើដូច្នោះខ្ញុំអភ័យទោសឱ្យ ឯពួកចោរឯទៀតក៏និយាយសុំទោសដូចមេចោរដែរ ហើយនិយាយអង្វរថា បើលោកស្រីអភ័យទោសឱ្យខ្ញុំ សូមលោកស្រីមេត្តាអង្វរករឱ្យព្រះថេរៈជាបុត្ររបស់លោកស្រី ឱ្យខ្ញុំសុំបួសក្នុងសំណាក់លោកផង ។ មហាឧបាសិកាថ្វាយបង្គំ ហើយនិយាយថា បពិត្រលោកកូន ពួកចោរទាំងនេះជ្រះថ្លាចំពោះគុណរបស់ខ្ញុំផង ចំពោះធម្មកថារបស់លោកផង ហើយសុំបួស ហេតុនេះសូមលោកកូនបំបួសពួកចោរទាំងនេះផង ។ ព្រះថេរៈពោលថាប្រពៃហើយៗប្រាប់ឱ្យកាត់សំពត់ ដែលពួកចោរទាំងនោះស្លៀកជ្រលក់ដីស្អិតពណ៌ក្រហម រួចបំបួសពួកចោរទាំងនោះឱ្យតាំងស៊ប់នៅក្នុងសីល ។ តាំងពីបួសរួចហើយព្រះថេរៈឱ្យរៀនកម្មដ្ឋានផ្សេងៗគ្នា ពួកភិក្ខុ

ទាំង ៥០០ អង្គ រៀនកម្មដ្ឋានផ្សេងៗគ្នា ឡើងទៅលើភ្នំមួយអង្គុយនៅក្រោមម្លប់ដើមឈើមួយដើម ខំស្វឹងស្វាធ៍សមណធម៌ ។

ពេលនោះព្រះសាស្ដាកំពុងគង់នៅក្នុងជេតវនមហាវិហារ ចម្ងាយ ១២០ យោជន៍ទ្រង់ប្រមើលមើលឃើញភិក្ខុទាំងនោះ ព្រះអង្គទ្រង់កំណត់ធម្មទេសនាតាមចរិកនៃភិក្ខុទាំងនោះ ហើយផ្សាយពន្លឺរស្មីត្រាស់សម្ដែងគាថាហាក់ដូចជាគង់សម្ដែងក្នុងទីចំពោះមុខថា :

ភិក្ខុណាមានកិរិយានូវប្រកបដោយមេត្តាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា អ្នកនោះរមែងបាននូវព្រះនិព្វានដ៏ស្ងប់ ជាគ្រឿងចូលទៅរម្ងាប់សង្ខារហើយនៅជាសុខ ។ ម្នាលភិក្ខុអ្នកចូរស្ដារនូវទូកគឺអត្តភាពនេះ ទូកគឺអត្តភាពនេះ បើអ្នកស្ដារហើយ រមែងដល់នូវត្រើយ គឺព្រះនិព្វានឆាប់ ហេតុនេះចូរអ្នកកាត់រាគៈ ទោសៈ មោហៈ ចេញតពីនោះទៅអ្នកនឹងបានដល់ព្រះនិព្វានពុំខាន ។ ចូរកាត់ឱរម្ភាគិយសំយោជនៈ៥ផង ចូរលះបង់ឧទ្ធម្ភាគិយសំយោជនៈ៥ផង ចូរចម្រើនឥន្ទ្រិយ៥តទៅទៀតផង បើអ្នកលះបានហើយ ឈ្មោះថាជាអ្នកកន្លងផុតកិលេសជាគ្រឿងជាប់ជំពាក់ទាំង៥ តថាគតឱ្យឈ្មោះថា អ្នកមានអន្លងកន្លងផុតអស់ហើយ ។ ម្នាលភិក្ខុចូរអ្នកពិនិត្យចូរកុំធ្វេសប្រហែស ចិត្តរបស់អ្នកចូរកុំវិលទៅរកកាមគុណវិញ អ្នកកុំប្រមាទហើយលេបនូវដុំលោហៈនោះឡើយកុំអោយភ្លើងឆេះហើយកន្ទក់កន្ទេញថានេះជាទុក្ខឡើយ ។ ឈានមិនមានដល់បុគ្គលឥតប្រាជ្ញា

រីឯបញ្ញាមិនមានដល់បុគ្គលដែលឥតឈាន ឈានក្តី បញ្ញាតិ រមែងមានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថាជាអ្នកឋិតនៅក្នុងទីជិតព្រះនិព្វាន ។ សេចក្តីត្រេកអរមិនមែនជារបស់មនុស្សទេ រមែងមានតែចំពោះតែភិក្ខុដែលចូលទៅនៅក្នុងទីស្ងប់ស្ងាត់ មានចិត្តស្ងប់រម្ងាប់ ព្រោះបានឃើញធម៌ច្បាស់ដោយខ្លួនឯង ។ ភិក្ខុណាពិចារណាការកើតឡើងនឹងការសូន្យទៅវិញនៃខន្ធទាំងឡាយក្នុងពេលណាៗ ភិក្ខុនោះរមែងបានបីតិ នឹងបាមោជ្ជនៅពេលនោះៗ បីតិនឹងបាមោជ្ជនោះជាអមតធម៌របស់អ្នកប្រាជ្ញទាំងឡាយ ។ គុណធម៌បីប្រការនេះ គឺការគ្រប់គ្រងនូវឥន្ទ្រិយ១ សេចក្តីសណ្តោស១ នឹងការសង្រួមក្នុងព្រះបាតិមោក្ខ១ ជាខាងដើមក្នុងព្រះនិព្វាននោះ តែងមានចំពោះភិក្ខុដែលមានប្រាជ្ញាក្នុងសាសនានេះ បើដូច្នោះចូរអ្នកគប់រកកល្យាណមិត្ត អ្នកចិញ្ចឹមអាជីពដោយត្រឹមត្រូវ មិនខ្ជិលច្រអូស គប្បីជាអ្នកប្រព្រឹត្តនូវបដិសណ្ឋារក្នុងអាចារៈជាអ្នកឈ្លាសក្នុងអាចារៈជាអ្នកមានបាមោជ្ជច្រើន អ្នកនឹងធ្វើឱ្យជាក់ស្តែងនូវទីបំផុតនៃសេចក្តីទុក្ខមិនខាន ។

ភិក្ខុ ៥០០ អង្គដែលកំពុងអង្គុយស្ដាប់ធម្មទេសនានោះ ក៏បានសម្រេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាញាណ ក្នុងពេលជាទីបញ្ចប់ធម៌ទេសនារបស់ព្រះអង្គ ហើយហោះទៅលើអាកាសទាំងអស់បានកន្លង

ផុតផ្លូវលំបាកចំនួន ១២០ យោជន៍ ហើយពោលសរសើរគុណរបស់ព្រះសមុទ្ទ រួចថ្វាយបង្គំទៀបព្រះបាទាព្រះសាស្តា ។

## ៩. រឿងដំរីនឹងទន្សាយ (ចាក គ.ប.)

*( អ្នកតូចអាចយកឈ្នះអ្នកធំបានដោយឧបាយកល )*

ថ្ងៃមួយ នៅក្នុងរដូវរាំងភ្លៀងរីងស្ងួតហួតហែងឥតមានទឹកភ្លៀងសោះ ដំរីមួយហ្វូងធំដែលមានក្ដីស្រេកឃ្លានបៀតបៀនហើយ ចូលទៅនិយាយនឹងដំរីជាមេខ្លោងថា : លោកជាទីពឹង! ធ្វើឧបាយដូចម្ដេចយើងទាំងអស់គ្នានឹងមានជីវិតរស់នៅតទៅទៀត ? ទីនេះត្រពាំងបឹងបួររីងអស់ហើយ សូម្បីតែសម្រាប់សត្វតូចតាចក៏មិនមានដែរ យើងទាំងអស់គ្នាបើមិនមានទឹកសម្រាប់ស្រប់សម្រាប់ផឹកសម្រាប់មុជទេ មុខជានឹងស្លាប់អសារបង់អស់ហើយ ដូចជាអណ្ដើកខ្វាក់ទៅណាមិនរួច យើងទាំងអស់គ្នានឹងទៅឯណាហ្ន៎ ? ។ កាលនោះ ស្ដេចដំរីបានស្ដាប់ហើយ នាំបរិវារដើរចេញទៅមិនឆ្ងាយប៉ុន្មានបានឃើញត្រពាំងមួយទឹកថ្លាយល់ដី ។

ក្នុងថ្ងៃដែលដំរីបបួលគ្នាដើរទៅនុ៎ះ ទន្សាយតូចធំទាំងឡាយដែលអាស្រ័យនៅនាត្រើយត្រពាំងនោះទាំងប៉ុន្មាន ត្រូវដំរីដើរជាន់ស្លាប់ខ្ទេច ខ្ទីស្ទើរតែទាំងអស់ ។ គ្រានោះមានទន្សាយមួយឈ្មោះសិលីមុខៈ កាលបានឃើញប្រព្រឹត្តិការណ៍អន្តរាយដូច្នោះ ទើបគិតថា : " ហ្វូងដំរីនេះ គឺកកងជ្រួលច្របល់ដោយក្ដីសេក្រឃ្លាន នឹងគប្បីមកកាន់ត្រពាំងនេះរាល់ៗថ្ងៃ

កាលបើដូច្នេះត្រកូលពូជទន្សាយទាំងឡាយមុខជានឹងវិនាស អន្តរធាន អស់មិនខានឡើយ " ។ទន្សាយចាស់ឈ្មោះវិជ័យនោះ ធ្វើប្តេជ្ញាដូច្នេះហើយ ក៏ដើរចេញទៅ ។

កាលដែលកំពុងដើរចេញទៅ វិជ័យដើរបណ្តើរគិតបណ្តើរថា : " គួរតែអាត្មាអញឡើងទៅលើកំពូលភ្នំសិន ហើយសឹមនិយាយប្រាប់មេខ្លោងដំរី " ។ លុះទន្សាយធ្វើដូចគំនិតស្រេចហើយ មេខ្លោងដំរីស្រែកសួរតបទៅវិញថា : " ចុះអ្នកឯងជាអ្វី ? អ្នកឯងមកពីណា ? " ។ វិជ័យឆ្លើយប្រាប់ថា : " យើងជាទន្សាយព្រះច័ន្ទដ៏មានបុណ្យលោកប្រើយើងមកកាន់សំណោក់អ្នកឯងរាល់គ្នានេះឯង " ។ មេខ្លោងដំរីសួរតបវិញភ្លាមថា : " បើដូច្នោះ ចូរនិយាយប្រាប់មកមានការដូចម្តេចខ្លះ ? " ។ វិជ័យប្រាប់ថា : ខ្ញុំនឹងសូមពោលទៅតាមព្រះរាជអាជ្ញាព្រះច័ន្ទ ដ៏មានបុណ្យដែលខ្ញុំបានទទួលមក សូមប្រុងស្តាប់ដូចតទៅនេះ " ទន្សាយទាំងឡាយនេះជាអ្នករក្សាអនូវត្រពាំងព្រះច័ន្ទ តាមបញ្ជារបស់ព្រះច័ន្ទយើង ។ ឥឡូវអ្នកទាំងឡាយមកបណ្តេញបំបរបង់ ហើយសម្លាប់ផង ការធ្វើដូច្នេះមិនត្រឹមត្រូវតាមគន្លងធម៌ទេ ព្រោះទន្សាយទាំងអស់ដែលរក្សាអនូវត្រពាំងនេះ ជាបរិវារយើង ហេតុនេះហើយបានជាមានពាក្យគេហៅថា " សសង្ក " ជានាមនេយ្យរបស់យើង ។ កាលដែលទន្សាយថ្លែងសេចក្តីដូច្នេះចប់ហើយ មេខ្លោងដំរីភ័យញ័ររន្ធត់ ហើយនិយាយទាំងញញាក់ញញ័រតបថា

" បពិត្រលោកជាអ្នកថ្លែងសេចក្តី ! យើងខ្ញុំធ្វើនេះ មកពីយើងខ្ញុំមិនដឹង បើដូច្នោះតាំងពីពេលនេះតទៅ យើងខ្ញុំលែងទៅក្នុងត្រពាំងនោះទៀតហើយ " ។

វិជ័យនិយាយបំភ័យថែមទៀតថា : " បើដូច្នោះចូរអ្នកទាំងឡាយទៅមាត់ត្រពាំងសិន ដើម្បីគោរពថ្វាយបង្គំព្រះអង្គ សូមឱ្យលោកត្រាប្រណីអត់ទោស រួចសឹមត្រឡប់ទៅវិញចុះ ព្រោះព្រះច័ន្ទ ដ៏មានបុណ្យលោកខ្ញាល់ខ្លាំងណាស់ " ។ កាលនោះវិជ័យនាំដំរីមេខ្លោង នឹងបរិវារទៅក្នុងរាត្រី ហើយបង្ហាញរូបព្រះច័ន្ទដែលកំពុងញ័រដោយលេចក្នុងត្រពាំងនោះ ដំរីមេខ្លោងមើលទៅឃើញព្រះច័ន្ទញ័រមែន ។ វិជ័យនិយាយអង្វរថា : ទេវ ! កំហុសគឺដំរីធ្វើពិតមែនហើយ ព្រោះគ្នាមិនបានដឹង បើដូច្នោះសូមលោកម្ចាស់អភ័យទោសឱ្យទានដោយករុណា តទៅហ្វូងដំរីទាំងឡាយនេះ ប្តេជ្ញាថានឹងមិនមកកាន់ទីនេះទៀតទេ ។ វិជ័យសូមអភ័យទោសឱ្យដំរីរួចហើយ ទើបបង្គាប់ឱ្យដំរីទាំងឡាយចេញពីទីនោះ ក្នុងពេលនោះហោង ។

# ១០. រឿងជដិលសេដ្ឋី

( ធ.ខុ. )

*( កំហឹងពោលពាក្យអាក្រក់ នាំឱ្យខូចប្រយោជន៍ខ្លួន )*

ឥឡូវនេះជដិលកុមារបានកើតឡើងហើយ ។ មានសេចក្ដីដំណាលថា កូនក្រមុំសេដ្ឋីម្នាក់នៅក្នុងក្រុងពារាណសី ជាស្ត្រីមានរូបដ៏ល្អឆើត ។ មាតាបិតាបានប្រគល់នាងទាសីម្នាក់ឱ្យថែរក្សានាងធីតានោះ ក្នុងកាលដែលមានអាយុ ១៥ ឬ ១៦ឆ្នាំ ឱ្យនៅលើប្រាសាទ ៧ ជាន់ក្នុងបន្ទប់ដ៏មានសេរី ក្នុងថ្ងៃមួយ យក្ខមួយឈ្មោះវិជ្ជាធរ កាលទៅតាមអាកាសបានឃើញនាងធីតានោះ ដែលនាងបើកបង្អួចហើយក្រឡេក គយគន់ទៅខាងក្រៅ មានសេចក្ដីស្នេហាកើតឡើង ក៏ចូលទៅតាមបង្អួច សេពសន្ថវៈជាមួយនឹងនាងធីតានោះ មិនយូរប៉ុន្មាន នាងធីតានោះមានគភ៌ ដោយការនៅរួមរសស្នេហា នឹងវិជ្ជាធរយក្ខ ។ គ្រានោះនាងទាសីឃើញយក្ខនោះ និយាយថា ម្ចាស់នាងតើការណ៍នេះដូចម្ដេច ? នាងធីតាប្រាប់ថា ការណ៍នេះចូរលើកទុកសិនចុះ ចូរនាងកុំប្រាប់ដល់អ្នកណាមួយឡើយ នាងទាសីក៏ស្ងៀមនៅដោយសេចក្ដីខ្លាច ។ លុះកាលកំណត់គ្រប់ ១០ ខែហើយ នាងធីតាក៏បានប្រសូតបុត្រ ឱ្យនាងទាសីយកភាជនៈថ្មីមកដាក់ផ្ដេកទារកទៅក្នុងភាជនៈថ្មីនោះ រួចបិទជិតហើយដាក់បាច់ផ្កាទាំងឡាយពីខាងលើ បង្គាប់ទៅនាងទាសីថា ចូរនាងទូលភាជនៈនេះយកទៅបណ្ដែត

ក្នុងទន្លេគង្គា ប្រសិនបើមានគេសួរថា វត្ថុនេះជាអ្វី ? នាងគប្បីប្រាប់ថា នេះជាពលិកម្មនៃម្ចាស់របស់ខ្ញុំ នាងទាសីក៏ធ្វើតាមបង្គាប់ដូច្នោះមែន ជួនជាស្ត្រីពីរនាក់កំពុងងូតទឹកក្នុងស្ទឹងគង្គារខាងក្រោម ឃើញភាជនៈនោះកាលដែលនាងទាសីបន្សាត់ចោលទៅតាមទឹក ស្ត្រីម្នាក់និយាយថា នេះភាជនៈរបស់អញ ។ ស្ត្រីម្នាក់ទៀតនិយាយថា របស់ឯណាដែលនៅខាងក្នុងភោជនៈ របស់នោះជារបស់អញ កាលបើភាជនៈមកដល់ហើយក៏នាំគ្នាលើកយកភាជនៈនោះទៅដាក់លើគោក ហើយបើកទៅក៏ឃើញទារកនៅខាងក្នុង ស្ត្រីម្នាក់និយាថា ទារកនេះជារបស់ខ្ញុំ ព្រោះខ្ញុំបាននិយាយថា ភាជនៈជារបស់ខ្ញុំ ។ ស្ត្រីម្នាក់ទៀតនិយាយថា ទារកនេះជារបស់ខ្ញុំ ព្រោះពាក្យដែលខ្ញុំពោលថា វត្ថុណាដែលមាននៅខាងក្នុងភាជនៈវត្ថុនោះពិតជារបស់ខ្ញុំ។ ស្ត្រីទាំងពីរនាក់នោះ កាលជជែកដណ្តើមគ្នាមិនដាច់ស្រេច ទើបនាំគ្នាទៅកន្លែងកាត់ក្តី ហើយជំរាបរឿងនេះដល់អាមាត្យទាំងឡាយ ពួកអាមាត្យក៏មិនអាចកាត់សេចក្តីបាន ទើបនាំយករឿងនោះទៅក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យស្ត្រីទាំងពីរនាក់ស្រេចហើយ ត្រាស់ថា នាងនេះចូរយកទារក នាងនោះចូរយកភាជនៈ ។ ស្ត្រីដែលបានទារកនោះត្រូវជាឧបដ្ឋាយិកានៃព្រះមហាកច្ចាយនត្ថេរ ។ ព្រោះហេតុនោះបានជានាងខំចិញ្ចឹមទារកនោះ ព្រោះមានបំណងថានឹងបំបួសទារកនេះក្នុងសំណាក់ព្រះថេរៈ ។ ដោយហេតុតែ

មន្ទិលនៃគភ៌គេមិនបានលាងជំរះចោលក្នុងថ្ងៃដែលទារកនោះកើត ទើបកុមារនោះមានសក់ក្រញាញ់ ព្រោះហេតុដូច្នោះហើយ បានជាពួកមហាជនឱ្យឈ្មោះថា ជដិលកុមារ ។

នៅពេលដែលទារកនោះចេះដើរ ព្រះថេរៈចូលទៅបិណ្ឌបាតក្នុងផ្ទះនោះ នាងឧបាសិកានិមន្តព្រះថេរៈឱ្យគង់ ហើយប្រគេនចង្ហាន់បិណ្ឌបាត ។ ព្រះថេរៈឃើញទារក ក៏សួរថាម្នាលឧបាសិកា នាងបានទារកនេះដូចម្តេច ? ទើបនាងឧបាសិកាទូលព្រះពុទ្ធដីកាថា ព្រះករុណាលោកម្ចាស់ ខ្ញុំចិញ្ចឹមទារកនេះដោយមានបំណងថា នឹងឱ្យបួសក្នុងសំណាក់លោកម្ចាស់ ហេតុនេះសូមលោកម្ចាស់បំបួសទារកនោះផង ។ ព្រះថេរៈពោលថាប្រពៃហើយនាង ! រួចទើបនាំយកទារកនោះទៅ ហើយពិចារណាថា ការសោយនូវសម្បត្តិនៃគ្រហស្ថជាបុញ្ញកម្មរបស់កុមារនេះ មានដែរឬទេ ? លុះដឹងថាកុមារនេះមានបុណ្យច្រើន នឹងបានសោយនូវមហាសម្បត្តិប៉ុន្តែកុមារនេះនៅក្មេងពេក ទាំងញាណក៏មិនទាន់ចាស់ក្លានៅឡើយ ហើយក៏នាំកុមារនោះទៅផ្ទះឧបដ្ឋាកម្នាក់នៅនគរតក្កសិលា ។ លុះទៅដល់ហើយ ឧបដ្ឋាកមកថ្វាយបង្គំបានឃើញកុមារនោះ សួរថាបពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានក្មេងពីណា ? ព្រះថេរៈប្រាប់ថា ចម្រើនពរឧបាសកក្មេងនេះនឹងបួស ប៉ុន្តែនៅក្មេងពេក ដូច្នេះចូរឱ្យវានៅជាមួយនឹងអ្នកផងចុះ ។ ឧបាសកនោះទទួលយល់ព្រមថាប្រពៃហើយ

លោកម្ចាស់ រួចក៏បីបាច់ថែរក្សាក្មេងនោះ ដូចជាកូនបង្កើតរបស់ខ្លួន ។ តាំងពីក្មេងនោះទៅនៅផ្ទះឧបាសកចំនួន ១២ ឆ្នាំ ទ្រព្យរបស់បានកើតនៅក្នុងផ្ទះនោះយ៉ាងច្រើន ។ ឧបាសកបាននាំយករបស់ទាំងអស់ទៅដាក់លក់ឯផ្សារ ហើយឱ្យកុមារនោះអង្គុយលក់ ប្រាប់តម្លៃនៃឥវ៉ាន់នោះថា របស់នេះថ្លៃប៉ុណ្ណេះ របស់នោះថ្លៃប៉ុណ្ណោះ រួចគាត់ដើរចេញបាត់ទៅ ។

ក្នុងថ្ងៃនោះ ទេវតាជាអ្នករក្សានគរ បណ្ដាលចិត្តរបស់ជនអ្នកត្រូវការ. ដោយហោចទៅសូម្បីត្រឹមតែម្រេចនឹងជី ឱ្យមានមុខឆ្ពោះទៅកាន់ផ្សារដែលកុមារនោះកំពុងអង្គុយលក់ ។ កុមារនោះលក់ឥវ៉ាន់ដែលកើតអស់ ១២ឆ្នាំ តែត្រឹមមួយថ្ងៃប៉ុណ្ណោះក៏អស់រលីង ។ កុដុម្ពិត្រឡប់មកវិញមិនឃើញមានសល់របស់បន្តិចបន្តួចនៅក្នុងផ្សារទើបសួរថា ម្នាលកូនឥវ៉ាន់ទាំងអស់ អ្នកឱ្យវិនាសអស់ហើយឬ ? កុមារជំរាបថា ខ្ញុំមិនបានឱ្យវិនាសទេ ខ្ញុំលក់វត្ថុទាំងអស់តាមសេចក្ដីពន្យល់ដែលលោកបានប្រាប់មកខ្ញុំ នេះជាតម្លៃនៃភណ្ឌឯណោះ ។ កុដុម្ពីមានចិត្តត្រេកអរ ហើយប្រគល់កូនក្រមុំ ដែលមានវ័យពេញក្រមុំនៅក្នុងផ្ទះរបស់ខ្លួន ឱ្យដល់ជដិលកុមារនោះថា បុរសនេះមានថ្លៃកាត់មិនបាន ជាអ្នកអាចរស់នៅក្នុងទីណានីមួយៗក៏បាន ហើយបង្គាប់ជាងឱ្យសង់ផ្ទះដល់ជដិលកុមារ កាលបើផ្ទះនោះសម្រេចហើយ កុដុម្ពីនិយាយថា អ្នកចូរទៅនៅផ្ទះរបស់ខ្លួនអ្នកចុះ។ គួរឱ្យអស្ចារ្យណាស់ក្នុងថ្ងៃនោះ ព្រះធរណីគ្រាន់តែជដិលកុមារជាន់ជើង

ម្ខាងក្នុងពេលដែលចូលទៅក្នុងផ្ទះ ភ្នំមាសកំពស់ ៨០ ហត្ថ បានទម្លាយផែនដីផុសក្នុងចំណែកខាងក្រោយផ្ទះ ។ ព្រះរាជាគ្រាន់តែឮថា ភ្នំមាសទម្លាយផែនដី ហើយផុសក្នុងផ្ទះនៃជដិលកុមារតែប៉ុណ្ណោះ ទ្រង់បញ្ជូនឆ្ឆិតជាសេដ្ឋីដល់ជដិលកុមារនោះភ្លាម ក៏មាននាមពិតប្រាកដថាជដិលសេដ្ឋី ។ គាត់មានបុត្រ ៣ នាក់ ក្នុងពេលដែលកូនទាំងបីនាក់មានវ័យគ្រប់គ្រាន់ គាត់មានចិត្តជ្រះថ្លាចង់បួស ហើយក៏ឱ្យជាងធ្វើឥដ្ឋមាស ដងជន្លួញមាស នឹងស្បែកជើងមាស ដោយចង់សាកល្បងថា តើក្នុងជម្ពូទ្វីបនេះមានត្រកូលសេដ្ឋីដែលមានទ្រព្យសម្បត្តិស្មើនឹងអញដែរឬទេ ? ថាបើមានអញអាចទៅបួសបាន បើមិនមានទេ អញនឹងមិនអាចទៅបួសបានឡើយ រួចទើបប្រើបុរសទាំងឡាយប្រាប់ថា អ្នកយកវត្ថុទាំងនេះ ចូរត្រាច់ទៅលើសាកលលោក ដូចជាដើររកមើលវត្ថុណានីមួយ ហើយត្រូវដឹងថាមានត្រកូលសេដ្ឋីនៅទីណាខ្លះដែលមានទ្រព្យសម្បត្តិមាសប្រាក់ច្រើន ស្មើនឹងយើង ឬក៏មិនមានទេ ចូរអ្នកត្រឡប់ទៅវិញ ។ បុរសទាំងនោះទទួលយកវត្ថុរួចហើយ បានដើរទៅដល់នគរភទ្ទិយៈ ។

លំដាប់នោះមេណ្ឌកសេដ្ឋីឃើញបុរសទាំងនោះសួរថា អ្នកធ្វើអ្វី? អ្នកទៅណា ? បុរសទាំងនោះប្រាប់ថាខ្ញុំដើរទៅរកវត្ថុមួយ លុះបានដឹងថា ជនទាំងនេះចាំឃ្លាំមើលខ្លួនដូច្នេះ ទើបប្រាប់ថា ចូរអ្នកទាំងអស់គ្នាដើរចូលទៅមើលខាងក្រោយផ្ទះយើងឯណោះ ។ លុះដើរទៅដល់បាន

ឃើញរូបពពែមាសប៉ុនដំរី ប៉ុនសេះខ្លះ ប៉ុនគោឧសភខ្លះ ក្នុងកន្លែងប្រមាណ៨ករីសព្វដ៏ខាងក្រោយផ្ទះនោះ ដែលទល់គ្នាទម្លាយផែនដីហើយផុសឡើង បានឃើញគ្រប់សព្វហើយនាំគ្នាធ្វើដំណើរត្រឡប់ទៅស្រុករបស់ខ្លួនវិញ ។ កាលបើទៅដល់ស្រុក សេដ្ឋីសួរថាអ្នកឯងបានឃើញត្រកូលសេដ្ឋីដែលមានទ្រព្យសម្បត្តិស្មើនឹងយើងដែរឬទេ ? បុរសទាំងនោះជំរាបថា បពិត្រលោកសេដ្ឋី សម្បត្តិដែលលោកមានប៉ុណ្ណា លោកមេណ្ឌកសេដ្ឋីនៅក្នុងភទ្ទិយនគរក៏មានប៉ុណ្ណោះដែរ ។ សេដ្ឋីឮដូច្នោះហើយក៏ត្រេកអរ ទើបឱ្យសំពត់កម្ពលដែលមានតម្លៃ ១ សែនកហាបណៈម្តងទៀតថា ដំបូងអ្នកឯងបានឃើញត្រកូលសេដ្ឋីមួយហើយ ឥឡូវតើត្រកូលសេដ្ឋីដទៃទៀតមានឬទេ ? រួចប្រើទៅទៀត ប្រាប់ថា អ្នកឯងចូរជ្រើសរើសរកត្រកូលសេដ្ឋីដទៃទៀត ។ បុរសនោះទៅដល់នគររាជគ្រឹះ នាំគ្នាប្រមូលយកឧសមកដុតក្បែរផ្ទះជោតិកសេដ្ឋី ដោយគិតថាបើជោតិកសេដ្ឋីសួរថាចុះមានហេតុដូចម្តេច ? យើងប្រាប់ថា យើងយកសំពត់កម្ពលដែលមានថ្លៃច្រើន១មកលក់ តែគ្មានរណាត្រូវការសោះ ទុកជាដើរលក់ទៀតខ្លាចពួកចោរដណ្តើមយក ព្រោះហេតុនោះហើយ បានជាយើងសុខចិត្តដុតចោល ។

គ្រានោះជោតិកសេដ្ឋីឃើញជនទាំងនោះសួរថា អ្នកទាំងអស់គ្នាធ្វើអ្វី ? លុះបានដឹងរឿងហើយ ក៏ហៅមកសួរថាសំពត់កម្ពលថ្លៃប៉ុន្មាន ?

ជនទាំងនោះជំរាបថាថ្លៃ១សែនកហាបណៈ រួចឱ្យ១សែនកហាបណៈ ហើយប្រាប់ថាអ្នកឯងចូរយកទៅឱ្យនាងទាសី ដែលបោសក្លោងទ្វារនឹង យកសម្រាមទៅចាក់ចោលនោះចុះ ។ នាងទាសីទទួលយកសំពត់កម្ពល ហើយយំដើរទៅកន្លែងសេដ្ឋី ជំរាបសួរថា បពិត្រលោកសេដ្ឋី កាលបើខ្ញុំ មានកំហុសលោកវាយខ្ញុំមិនគួរឬ ? ព្រោះហេតុអ្វី ? បានជាលោកប្រើឱ្យ យកសំពត់កម្ពលមានសាច់ម៉ត់ទៅឱ្យខ្ញុំ ? ខ្ញុំនឹងស្លៀកដណ្ដប់សំពត់នេះ ដូចម្ដេចកើត ? ។ សេដ្ឋីប្រាប់ថា យើងមិនឱ្យនាងស្លៀកដណ្ដប់សំពត់នេះ ទេ តែថាយើងឱ្យនាងយកទៅទុកក្បែរកន្លែងដេក សម្រាប់ជូតជើងដែល នាងលាងដោយទឹកមានក្លិនក្រអូប ហើយចូលទៅដេក តើនាងមិនអាច ធ្វើដូច្នោះបានទេឬ ? ។ នាងទាសីជំរាបថាខ្ញុំអាចធ្វើបាន ហើយក៏យក សំពត់នោះត្រឡប់ទៅវិញ ។ ចំណែកបុរសទាំងនោះ ឃើញហេតុដូច្នោះ ក៏នាំគ្នាត្រឡប់ទៅនគររបស់ខ្លួនវិញ សេដ្ឋីសួរថា អ្នកឯងបានឃើញ ត្រកូលសេដ្ឋីឬទេ ? ទើបជំរាបថាបពិត្រលោកសេដ្ឋីសម្បត្តិដែលលោក មានប៉ុណ្ណា ជោតិកសេដ្ឋីក៏មានប៉ណ្ណោះដែរនៅក្នុងនគររាជគ្រឹះ ។ សេដ្ឋី បានស្ដាប់ពាក្យបុរសទាំងនេះហើយ រឹងរិតតែមានចិត្តត្រេកអរខ្លាំងឡើង ដោយគិតថាអញនឹងបានបួសក្នុងពេលឥឡូវនេះ ហើយក៏ដើរទៅគាល់ ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គចង់បួស ។ ព្រះ រាជាត្រាស់ថា ប្រពៃហើយលោកសេដ្ឋី ចូរលោកបួសចុះ គាត់ថ្វាយបង្គំលា

ត្រឡប់ទៅផ្ទះវិញហៅកូនទាំងអស់មកជួបជុំគ្នា ហើយគាត់ឱ្យចប១ដង ធ្វើពីពេជ្រទៅកូនច្បងប្រាប់ថា ចូរឯងគាស់យកដុំមាសពីភ្នំមាសនៅខាងក្រោយផ្ទះ ។ កូនច្បងយកចបទៅជីកគាស់ភ្នំមាស ហាក់ដូចជាគេជីកលើផ្ទាំងថ្ម ។ សេដ្ឋីឃើញដូច្នោះ ក៏យកចបពីដៃកូនច្បង ឱ្យទៅកូនបន្ទាប់ជីកទៀត ក៏ដូចជាគេជីកទៅលើផ្ទាំងថ្មទៀត ទើបគាត់ឱ្យទៅកូនពៅម្តង ។ កាលដែលកូនពៅទទួលយកចបពីដៃឪពុកទៅជីកភ្នំមាសនោះ ក៏ដូចជាគេជីកលើគំនរដីស្អិត ។ លំដាប់នោះសេដ្ឋីឃើញដូច្នោះ ក៏ហៅកូនច្បងទាំងពីរនាក់មកប្រាប់ថា ភ្នំមាសនេះមិនកើតសម្រាប់អ្នកឯងទេ ពិតជាកើតសម្រាប់អញនឹងកូនពៅ ហេតុនេះកូនឯងទាំងពីរនាក់ចូរស់ទៅជាមួយប្អូនពៅចុះ ។ សួរថាព្រោះហេតុអ្វីភ្នំមាសនោះកើតសម្រាប់តែជនទាំងពីរនាក់នោះ ? ហើយជដិលសេដ្ឋីត្រូវគេទម្លាក់ចោលទៅក្នុងទឹក ក្នុងថ្ងៃដែលកើតព្រោះហេតុអ្វី ? ឆ្លើយថា ដោយកម្មដែលខ្លួនធ្វើទុកពីបុព្វជាតិ ។

មានសេចក្តីដំណាលថា កាលដែលមហាជនកំពុងសាងចេតិយដើម្បីបញ្ចុះព្រះសារិកធាតុព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សប មានព្រះខីណាស្រពមួយព្រះអង្គនិមន្តទៅកន្លែងចេតិយ បានរមិលមើលសព្វគ្រប់ហើយ ទើបសួរថា ម្នាលអ្នកទាំងឡាយ ហេតុអ្វីក៏គេមិនធ្វើមុខចេតិយខាងជើងឱ្យប្រាកដឡើងផង ? មហាជនទូលថាទានប្រោសមាសមិនគ្រប់គ្រាន់ ។ លោកនិយាយថា បើដូច្នោះអាត្មានឹងចូលទៅអង្គាសឃោសនា

មហាជនក្នុងស្រុក អ្នកទាំងឡាយចូរធ្វើការងារនោះដោយគោរពចុះ លោកថាតែប៉ណ្ណេះក៏ចូលទៅក្នុងស្រុកឃោសនាថា ម្នាលអ្នកដ៏ចំរើនទាំងឡាយ ចេតិយយើងខាងមុខមានមាសមិនគ្រប់គ្រាន់ទេ អ្នកទាំងអស់គ្នាចូរដឹងចុះ រួចនិមន្តទៅផ្ទះជាងមាស ។ ខណៈនោះឯងជាងមាសកំពុងឈ្លោះនឹងប្រពន្ធ លុះឃើញព្រះថេរៈនិមន្តមកឃោសនាដូច្នោះ ក៏ពោលពាក្យអសប្បុរសទ្រគោះបោះបោក ដោយសេចក្ដីក្រោធខឹង នឹងភរិយាថា លោកចូរយកត្រួរបស់លោកទៅបោះចោលក្នុងទឹកទៅ ។ លំដាប់នោះភរិយា ក៏និយាយថា យីអើអ្នក ! កម្មដែលអ្នកធ្វើនេះជាសាហ័សឧផលក្លៀវក្លាខ្លាំងណាស់ ចំណែកខាងខ្លួនខ្ញុំបើអ្នកក្រោធខឹង អ្នកត្រូវជេរស្ដីវាយបាន ព្រោះហេតុអ្វី ក៏អ្នកបែរជាធ្វើពៀរចំពោះព្រះពុទ្ធទាំងឡាយទាំងអតីត អនាគត បច្ចុប្បន្នទៅវិញ ? ភ្លាម១នោះជាងមាសមានសេចក្ដីសង្វេគតក់ស្លុត ក៏ចូលទៅក្រាបទៀបព្រះបាទាព្រះថេរៈ សូមឱ្យលោកអភ័យទោសឱ្យ ។ ព្រះថេរៈពោលថា អ្នកមិនបានពោលពាក្យអ្វីនឹងអាត្មាទេ អ្នកចូរស្មារលាទៅសនឹងព្រះសាស្ដាចុះ ។ ខ្ញុំព្រះករុណានឹងធ្វើដូចម្ដេចទើបសូមខមាទោសនឹងព្រះសាស្ដាបាន ? ព្រះថេរៈប្រាប់ថា អ្នកឯងចូរធ្វើផ្កាមាសបីផើង យកទៅដម្កល់ទុកត្រង់កន្លែងបញ្ចុះព្រះអដ្ឋិធាតុខាងក្នុងរួចស្លៀកសំពត់ទទឹកកក់សក់ ទើបសូមខមាទោសបនឹងព្រះសាស្ដាបាន ។ ជាងមាសក៏មានចិត្តសោមនស្សត្រេកអរ ប្រារព្ធនឹងធ្វើផ្កាមាសទាំងនោះ

គាត់ហៅកូនច្បងមកប្រាប់ថា នែបា! អញបានពោលពាក្យប្រកបដោយពៀរចំពោះព្រះសាស្តា ព្រោះហេតុនោះអញធ្វើផ្កាទាំងនេះយកទៅដម្កល់ទុកត្រង់កន្លែងបញ្ចុះព្រះអដ្ឋិធាតុ ដើម្បីសូមខមាទោសនឹងព្រះសាស្តា ហេតុនេះចូរបាជួយធ្វើឱពុកផង ។ កូនច្បងមិនមានចិត្តចង់ធ្វើប្រកែកថា ខ្ញុំមិនបានប្រើលោកឪពុកឱ្យពោលពាក្យបែបនោះទេ ចូរលោកឪពុកធ្វើតែម្នាក់ឯងទៅចុះ រួចគាត់ហៅកូនបន្ទាប់មកប្រកែកដូច្នោះទៀត ។ ទើបហៅកូនពៅមកប្រាប់ដូចមុន កូនពៅគិតថាកិច្ចការដែលកើតឡើងដល់បិតាជាភារៈរបស់កូន ហើយក៏ទទួលជួយធ្វើបិតាដោយគោរព ជាងមាសចាត់ចែងធ្វើផ្កាមាសបីផើងក្នុងផើងមួយៗប្រមាណ ១ចំអាមស្រេចហើយយកទៅតម្កល់ទុកត្រង់កន្លែងបញ្ចុះអដ្ឋិធាតុហើយ ស្លៀកសំពត់ទទឹក កក់សក់សូមខមាទោសទៅ ។ អាស្រ័យហេតុនេះទើបជដិលសេដ្ឋីនោះគ្រាន់តែកើតមកភ្លាម ត្រូវគេយកទៅចោលក្នុងទឹក ៧ ជាតិមកហើយ លុះដល់មកអត្តភាពជាទីបំផុតនេះ ត្រូវគេទម្លាក់ចោលទៀត ព្រោះអកុសលកម្មជាហេតុជូនមកនោះដែរ ។ ចំណែកកូនច្បងទាំងពីរនាក់មិនបានជួយខ្វល់ខ្វាយក្នុងការធ្វើផ្កាមាសនោះ ភ្នំមាសក៏មិនកើតឡើងដល់កូនទាំងពីរនាក់ ដោយហេតុនោះឯង បានកើតឡើងចំពោះតែជដិលសេដ្ឋី នឹងកូនពៅប៉ុណ្ណោះ ព្រោះជនទាំងពីរនាក់នេះបានធ្វើបុញ្ញកម្មជាមួយគ្នា ក្នុងកាលមុន ។

ចំណែកឯជដិលសេដ្ឋី លុះផ្តែផាំកូនស្រេចហើយ ក៏ទៅបួសក្នុងសំណាក់ព្រះសាស្តា មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត ។ ក្នុងសម័យថ្ងៃមួយ ព្រះសាស្តាទ្រង់យាងបិណ្ឌបាតជាមួយនឹងពួកភិក្ខុសង្ឃ ៥០០ អង្គបានទៅដល់ផ្ទះកូនជដិលភិក្ខុនោះៗ បានប្រគេនភិក្ខាហារអស់កន្លះខែ ចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ពួកភិក្ខុមកប្រជុំគ្នាក្នុងធម្មសភាសួរថា ម្នាលជដិលដ៏មានអាយុ ចំណង់ក្នុងភ្នំមាសកំពស់ ៨០ ហត្ថ នឹងចំពោះកូនទាំងឡាយរបស់អ្នកមានឬទេ ? ជដិលភិក្ខុទូលថា ចំណង់ក្តី ការប្រកាន់រឹងត្អឹងរបស់ខ្ញុំនោះ មិនមានក្នុងវត្ថុទាំងនេះទេ ។ ពួកភិក្ខុលើកទោសថា ជដិលភិក្ខុពោលអួតឧត្តរមនុស្សធម៌ ហើយក៏នាំទៅក្រាបទូលព្រះសាស្តា ព្រះអង្គត្រាស់ថាតណ្ហាក្តី មានះក្តី របស់កូនតថាគតចំពោះវត្ថុទាំងនោះមិនមានពិតមែនហើយ ចូរអ្នកទាំងអស់គ្នាដឹងដោយហេតុនេះចុះ ។

## ១១_ រឿងក្អែកញីឈ្មោលនឹងពស់

(ចាក គ.ប.)

*(អ្នកមានប្រាជ្ញាអាចញ៉ាំងអ្នកដទៃឱ្យសម្លាប់សត្រូវខ្លួនបាន)*

មានក្អែកញីឈ្មោលមួយគូ អាស្រ័យនៅលើដើមឈើមួយដើម ក្នុងព្រៃដើមឈើនោះមានពស់វែកមួយ ។ ពស់នោះវាតែងតែចាប់កូនក្អែកស៊ីជាចំណើអាហារ ។ តមក ក្អែកញីរកកល់ពងទៀត និយាយទៅកាន់ប្តី

ថា : " អ្នកបងជាទីពឹង ! គួរយើងលះបង់ចោលដើមឈើនេះទៅ ហើយហើរទៅរកដើមឈើឯទៀតអាស្រ័យនៅវិញ ព្រោះដើមឈើរជាទីលំនៅយើងនេះប្រកបដោយភ័យអំពីពស់វែកចង្រៃ វាចេះតែចាប់កូនយើងស៊ីញយៗ តទៅយើងអស់មានកូនចៅតពូជពង្សទៀតហើយ ក្អែកឈ្មោលនិយាយតបវិញថា : " នែប្អូនសំឡាញ់ ! ប្អូនកុំថប់អ្វី ទុកងាឱ្យបងរឿងនេះឱ្យបងខំទ្រាំទល់ទុក្ខវេទនា ចំពោះកំហុសធំនៃពស់វែកនេះមកជាច្រើនដងច្រើនគ្រាណាស់មកហើយ ឥឡូវនេះបងអត់ទ្រាំទៅទៀតមិនបានទេ " ។ ក្អែកញីនិយាទឹងក្អែកឈ្មោលថា : " ចុះអ្នកបងធ្វើដូចម្តេចទៅ បើពស់វែកនោះមានកម្លាំងខ្លាំងច្រើនជាងយើងម្ល៉េះ ? អ្នកបងអាចហ៊ានទៅតនឹងវាបានឬទេ " ? ក្អែកឈ្មោលនិយាយប្រាប់ថា : " នៅស្រះបោក្ខរណីតីកថ្លាយល់ដឹ ជិតទីឋានយើងនេះ មានព្រះរាជបុត្រទាំងឡាយ តែងយាងចូលមកប្រពាតក្រសាលស្រង់ ឧទកវារីលេងសប្បាយរាល់ថ្ងៃ ក្នុងស្ថានសម័យស្តេចតែងដោះខ្សែព្រះសូរងជាវិការនៃមាសសម្រាប់តែងព្រះអង្គ ទុកនៅលើផែនថ្មនាឆ្នេរស្រះហើយទើបចុះទៅស្រង់ ។

ចូរប្អូនហើរចុះទៅឆក់លួចយកនូវខ្សែព្រះសូរងជាវិការៈនៃមាសនោះដោយចំពុះ ហើយនាំយកមកទម្លាក់ទុកក្នុងព្រង់ ដែលពស់ចង្រៃវាអាស្រ័យនៅ " ។ ថ្ងៃមួយព្រះរាជបុត្រទាំងឡាយ ស្តេចយាងមកស្រង់

ក្រសាលឧទកវារី មេក្អែកក៏បានធ្វើដូចបានគិតគ្នាទុកមុន ។ គ្រានោះឯង ព្រះរាជបុត្រទាំងឡាយ បានទតឃើញមេក្អែកលបឆក់យកខ្សែព្រះសូរង ដូច្នេះ ស្តេចដេញតាមក្អែក ដើម្បីដណ្តើមយកខ្សែព្រះសូរង រហូតទៅដល់ព្រង់ទៅប្រទះឃើញពស់វែកនោះ ហើយក៏បបួលគ្នាវាយសម្លាប់ចោលបង់សៀតទៅហោង ។

## ១២. រឿងបុរសក្លាយភេទជាស្ត្រី

( ធ. ខុ.. )

*( ចិត្តដែលគេមិនបានអប់រំ រមែងធ្វើគេឱ្យកើតទុក្ខមួយជីវិត )*

កាលដែលព្រះពុទ្ធបរមគ្រូទ្រង់សម្រាន្តព្រះឥរិយាបថ នាក្រុងសាវត្ថី មានសេដ្ឋីបុត្រមួយរូបឈ្មោះ សោរេយ្យ ជិះរទេះបរចេញទៅក្រៅនគរជាមួយនឹងសម្លាញ់ម្នាក់ ព្រមទាំងបរិវារជាច្រើន ដើម្បីទៅមុជទឹកក្នុងកំពង់មួយ ។ ជួនជាក្នុងខណៈនោះ ព្រះមហាកច្ចាយនត្ថេរនិមន្តទៅបិណ្ឌបាតក្នុងទីក្រុង ។ សរីរៈរបស់លោកក៏មានពន្លឺត្រចះត្រចង់គួរឱ្យជ្រះថ្លា។ ឯសេដ្ឋីបុត្រឃើញព្រះមហាកច្ចាយនត្ថេរ ដែលមានសរីរៈត្រចះត្រចង់ដូច្នោះ គិតតែក្នុងចិត្តថា " ធ្វើម្តេចហ្ន៎ ! នឹងបានភិក្ខុអង្គនេះមកធ្វើជាភរិយា ! ឬធ្វើម្តេចហ្ន៎ ! ឱ្យភរិយាអញមានពណ៌សម្បុរដ៏ត្រចះត្រចង់ដូចព្រះភិក្ខុអង្គនេះ " ។ សេដ្ឋីបុត្រកំពុងតែគិតដូច្នេះ មិនយូរប៉ុន្មានស្រាប់តែ ក្លាយភេទខ្លួនទៅជាស្ត្រីមួយរំពេចនោះ សេចក្តីអៀនខ្មាស ក៏

កើតឡើង ទើបចុះពីរទេះភៀសខ្លួនបាត់ក្នុងពេលនោះទៅ ។ មិត្តដែលជិះរទេះជាមួយគ្នា មិនឃើញសេដ្ឋីបុត្រជាសំឡាញ់ បានដើរស្វែងរកក្នុងទីផ្សេងៗតែពុំឃើញ ហើយត្រឡប់ទៅផ្ទះវិញប្រាប់ឪពុកម្តាយតាមដំណើរសព្វគ្រប់ ។ សេដ្ឋីជាឪពុកម្តាយសំគាល់ថាកូនខ្លួនស្លាប់ហើយបាននិមន្តភិក្ខុសង្ឃវេរ មត្តកភត្ត ដោយសំអាងថាកូនខ្លួនចែកឋានទៅកាន់លោកខាងនាយហើយ ។

ឯស្ត្រីក្លាយភេទនោះ ដើរតម្រង់តាមផ្លូវទៅកាន់នគរតក្កសីលា បានជួបនឹងពួកឈ្មួញរទេះយ៉ាងច្រើន នាងក៏ដើរតាមពីក្រោយរទេះត្រាតែដល់នគរតក្កសីលា ។ ពួកឈ្មួញទាំងអស់គិតថាកូនប្រុសរបស់សេដ្ឋីក្នុងនគរយើងនេះមិនទាន់មានប្រពន្ធនៅឡើយ យើងនាំដំណឹងនេះទៅប្រាប់សេដ្ឋីៗ មុខជានឹងឱ្យរង្វាន់ខ្លះដល់យើងពុំខាន ទើបនាំគ្នាទៅជំរាបសេដ្ឋីៗ គ្រាន់តែឃើញនាងភ្លាមកើតចិត្តប្រតិពទ្ធស្នេហា ក៏នាំទៅរៀបផ្សំផ្គុំឱ្យជាភរិយានៃកូនប្រុសរបស់ខ្លួន ។

មែនពិត នឹងថាបុរសមិនធ្លាប់កើតជាស្ត្រីក៏មិនមែន នឹងថាស្ត្រីមិនធ្លាប់កើតជាបុរសក៏មិនមែន តាមពិត បុរសណាប្រព្រឹត្តបរទារកម្ម គឺការសេពមេថុនជាមួយភរិយាអ្នកដទៃ លុះរំលាយខន្ធទៅរមែងទៅសោយទុក្ខក្នុងនរកជាច្រើនសែនឆ្នាំ កាលបើមកកើតជាមនុស្សវិញរមែងកាត់ជាតិជាស្រីភេទជាច្រើនរយអត្តភាព ។ អម្បាលយ៉ាងព្រះអានន្ទត្ថេរ

ដែលបានបំពេញបារមីជាច្រើនសែនកប្បហើយជាអធិសាវក កាលកំពុងត្រាច់រង្គាតក្នុងវដ្តសង្សារ បានកើតក្នុងត្រកូលជាងមាសមួយអត្តភាពហើយបានប្រព្រឹត្តបរទារកម្ម លុះស្លាប់ទៅធ្លាក់ទៅសោយទុក្ខក្នុងនរកត្រឡប់ពីនរកមកវិញត្រូវក្លាយភេទកើតជាស្រ្តីអស់ ១៤ជាតិ ហើយត្រូវគេក្រៀវពូជ (ខ្ទើយ) អស់ ៧ជាតិទៀត ។ ឯស្ត្រី បើនឿយណាយក្នុងភេទជាស្ត្រីហើយបានធ្វើបុណ្យតាំងចិត្តប្រាថ្នាថា " សូមអានិសង្សនៃទានរបស់យើងខ្ញុំប្រព្រឹត្តទៅដើម្បីបុរិសភាពក្នុងអនាគត " តែប៉ុណ្ណោះ ក៏អាចក្លាយភេទកើតជាបុរសបាន បើពុំនោះទេគ្រាន់តែប្រព្រឹត្តគោរពប្រតិបត្តិស្វាមី លើកស្វាមីទុកដូចជាទេវតា ក៏អាចទៅជាបុរសបានដែរ ។ ក៏ឯសង្ឃើបុត្រនេះមិនបានជាចាប់អារម្មណ៍ចំពោះសរីរកាយ ព្រះមហាកច្ចាយនត្ថេរប៉ុន្មានទេ ក៏គង់ក្លាយភេទជាស្ត្រីក្នុងអត្តភាពនោះភ្លាម ។ ព្រោះហេតុនោះហើយស្ត្រីក្លាយភេទនោះ លុះនៅរួមសំវាសជាមួយកូនសេដ្ឋីមិនយូរប៉ុន្មាន បានប្រសូតកូនប្រុសមួយ មួយឆ្នាំក្រោយទៀតបានកូនមួយទៀត ។ ស្ត្រីនេះមានកូន៤នាក់ គឺនៅឯសោរេយ្យនគរ កាលដែលខ្លួនជាបុរសមានកូនពីរនាក់ ដល់ក្លាយភេទជាស្រីមានកូនពីរនាក់ទៀតរួមជា៤ ។

ថ្ងៃមួយសម្លាញ់របស់នាង បានធ្វើដំណើរចេញពីក្រុងសាវត្ថី ដើម្បីទៅជួញឯនគរតក្កសិលា នាងកំពុងតែអង្គុយលើប្រាសាទ បានឃើញ

ហើយស្គាល់ច្បាស់ ក៏ប្រើទាសីឱ្យទៅហៅឱ្យចូលទៅក្នុងប្រាសាទរៀបចំទទួលដោយគ្រឿងបដិសណ្ឋារៈដ៏គួរសម ព្រមទាំងនិយាយរ៉ាយរ៉ាប់សព្វគ្រប់ពីរឿងខ្លួន ចាប់តាំងពីជិះរទេះទៅមុជទឹកជាមួយសម្លាញ់ ឃើញព្រះមហាកច្ចាយនត្ថេរ នឹងគំនិតដែលខ្លួនបានគិតទៅលើព្រះថេរអង្គនេះ ហើយក្លាយភេទជាស្ត្រីក្នុងពេលនោះភ្លាម រហូតដល់ភៀសខ្លួនមកបានប្តីមានកូនពីរនេះទៀត ។ ឯសម្លាញ់នោះបានជ្រាបហេតុសព្វគ្រប់ ក៏រ៉ាយរ៉ាប់ថាត្រូវសូមខមាទោសនិងព្រះថេរៈអង្គនេះ ។ ឯនាងដែលក្លាយភេទនេះធ្វើតាមពាក្យរបស់សម្លាញ់ លុះដល់ព្រះមហាកច្ចាយនត្ថេរនិមន្តទៅបិណ្ឌបាត នាងបានដាក់បាត្រដល់ព្រះថេរៈ ហើយសូមខមាទោសសព្វគ្រប់ប្រការ ភេទស្ត្រីក៏ក្លាយជាបុរសក្នុងពេលនោះភ្លាម ហើយសូមបួសក្នុងសំណាក់ព្រះថេរៈអង្គនោះ ខំចម្រើនឈាននឹងអភិញ្ញារហូតដល់បានសម្រេចព្រះអរហត្ត ជាអវសានជាតិក្នុងកាលនោះហោង ។

## ១៣~ រឿងហង្សនិងក្អែក

( ចាក គ.ប. )

*( ការដែលនៅជិតជនអសប្បុរសតែងមានទុក្ខ )*

នៅតាមផ្លូវទៅកាន់ក្រុងឧជ្ជយិនី មានដើមឈើធំមួយ មានមែកទ្រឈឹងទ្រឈៃ ។ សត្វហង្សនិងក្អែកអាស្រ័យនៅលើដើមឈើនោះ ។ នៅរដូវក្តៅ មានអ្នកដំណើរម្នាក់ដើរមកដល់អស់កម្លាំងណាស់ ឃើញម្លប់

ត្រជាក់ស្រួលដាក់ធ្នូនិងសរកែ្បរគល់ឈើប្រាស់ខ្លួនដេកលង់លក់ទៅ ។ ក្រោយបន្តិច មកម្លប់ដើមឈើនោះរេបែរឃ្លាតចេញពីមុខអ្នកដំណើរនោះ ។ កាលនោះហង្សទំនៅលើដើមឈើនោះ ក្រឡេកទៅឃើញមុខអ្នកដំណើរចាំងដោយកំដៅព្រះអាទិត្យ កើតមានចិត្តល្អជាចិត្តបុណ្យដ៏ត្រជាក់ត្រជុំ ទើបកាងស្លាបខ្លួនបាំងកំដៅព្រះអាទិត្យឱ្យម្លប់ទៅចំមុខអ្នកដំណើរនោះដោយចិត្តអាណិត ។ រីឯអ្នកដំណើរកំពុងអស់កម្លាំងខ្លាំងបានម្លប់ត្រជាក់ស្រួល ក៏ដេកលក់ស៊ប់ច្រហរមាត់ធ្លុង ។ គ្រានោះឯងក្អែកដែលនៅជាមួយគ្នា ជាសត្វមានចិត្តអាក្រក់ ជាសភាពទុជិនពីកំណើត តែងច្រណែនជនដទៃជានិច្ច មិនចង់ឱ្យគេបានសេចក្ដីសុខសោះ ក៏បន្ទោបង់អាចម៍ខ្លួនឱ្យធ្លាក់ទៅចំប៉ាច់ក្នុងមាត់នៃអ្នកដំណើរនោះ ហើយហើរចេញបាត់ទៅភ្លាម ។ អ្នកដំណើរត្រូវអាចម៍ក្អែកស្អុយមួយដុំចំមាត់ក្ដាញ់ណាស់ ! ក្រោកក្រទឹក្រទាឡើង ក្រឡេកមើលទៅលើឃើញតែហង្ស មិនឃើញក្អែក ក៏ចាប់ទាញធ្នូមក ហើយបាញ់តម្រង់ទៅត្រូវស្លាប់ទៅហោង ។

## ១២_ រឿងមេណ្ឌកសេដ្ឋី

(ចាក ធ. ខុ...)

*( អនុភាពផលទាន ធំហួសនិស្ស័យប្រាជ្ញាមនុស្សលោក )*

កាលព្រះសាស្ដាអាស្រ័យនៅនគរភទ្ទិយៈ គង់នៅក្នុងព្រៃម្លិះព្រះអង្គទ្រង់សំដែងធម៌ទេសនា ប្រារព្ធនឹងមណ្ឌកសេដ្ឋី ។ មានសេចក្ដីដំ

ណាលថា ព្រះសាស្តាទ្រង់យាងទៅនគរភទ្ទិយៈ ដោយបានឃើញឧប និស្ស័យសោតាបត្តិផលនៃជនទាំងនោះគឺ មេណ្ឌកសេដ្ឋី១ នាងចន្ទបទុមា ជាភរិយានៃលោកសេដ្ឋី១ ធនញ្ជយសេដ្ឋីជាកូនប្រុស១ កូនប្រសាស្រី ឈ្មោះសុមនទេវី១ ចៅគាត់ឈ្មោះនាងវិសាខា១ នឹងខ្ញុំប្រុសឈ្មោះ បុណ្ណៈ១ ។ សួរថា ព្រោះហេតុអ្វី បានជាសេដ្ឋីនេះឈ្មោះមេណ្ឌកសេដ្ឋី ? ឆ្លើយថាមានពពែមាសប្រមាណប៉ុនដំរីខ្លះ ប៉ុនសេះខ្លះ ប៉ុនគោឧសភខ្លះ បានផុសពីក្នុងដីខាងក្រោយផ្ទះគាត់ទំហំ ៨ករីស ។ ឆ្នុកសូត្រ៥ពណ៌ ដែល បុញ្ញកម្មបានពាក់តែងឡើង នៅនឹងមាត់ពពែទាំងនោះ ។ កាលណាត្រូវ ការគ្រឿងបរិភោគ មានទឹកដោះស្រស់ ប្រេង ទឹកឃ្មុំនឹងស្ករអំពៅ ឬ គ្រឿងឧបភោគ មានសំពត់ប្រាក់មាសជាដើម គេដកឆ្នុកពីមាត់ពពែទាំង នោះ គ្រឿងឧបភោគ និងបរិភោគដែលចេញពីមាត់ពពែមួយៗ ល្មមដល់ អ្នកនៅក្នុងជម្ពូទ្វីបទាំងមូល ។ តាំងពីពេលនោះមក គេឱ្យឈ្មោះគាត់ថា មេណ្ឌកសេដ្ឋី ។

សួរថា ចុះគាត់មានធ្វើបុព្វកម្មដូចម្តេចខ្លះ ? បានឮថាក្នុងកាល ព្រះពុទ្ធទ្រង់ព្រះនាមវិបស្សី គាត់ជាក្មួយនៃកុដុម្ពីឈ្មោះអវរោជៈ ហើយ ឪពុកមាក៏ឈ្មោះអវរោជៈដែរ ។ ក្នុងជំនាន់នោះឪពុកមាបានរៀបចំធ្វើកុដិ ថ្វាយព្រះសាស្តាអង្គនោះ ។ ក្មួយទៅកន្លែងឪពុកមានិយាយសុំថា បពិត្រ លោកឪពុកមាយើងទាំងពីរនាក់កសាងកុដិជាមួយគ្នា ឪពុកមាប្រកែកមិន

ព្រមឱ្យធ្វើជាមួយគ្នា ហើយប្រាប់ថា ខ្ញុំធ្វើនេះមិនឱ្យសាធារណ៍ជាមួយនឹងនរណាទេ ខ្ញុំកសាងតែម្នាក់ឯងប៉ុណ្ណោះ ក្មួយគិតថា បើលោកឪពុកមាគាត់កសាងគន្ធកុដិនៅកន្លែងនេះ គួរតែអញកសាងកុញ្ជរសាលានៅកន្លែងនេះផង ទើបគួរសម លុះគិតឃើញហើយ ក៏ឱ្យគេដឹកនាំយកគ្រឿងទិព្វសម្ភារៈអំពីព្រៃ ហើយឱ្យធ្វើសសរទាំងឡាយយ៉ាងនេះ គឺសសរមួយស្រោបសុទ្ធតែមាស សសរមួយស្រោបសុទ្ធតែប្រាក់ នឹងសសរមួយទៀតស្រោបសុទ្ធតែកែវមណី នឹងឱ្យគេធ្វើធ្នឹម ក្របសន្ទះទ្វារ បង្អួច បង្កង់និងឥដ្ឋក្រាល សុទ្ធតែវិចិត្រដោយមាសទាំងអស់ ហើយនិងធ្វើកុញ្ជរសាលាពីកែវ៧ប្រការ ថ្វាយព្រះតថាគតនៅត្រង់កន្លែងប្រទល់មុខនឹងគន្ធកុដិ ។ ចុងកំពូលទាំង ៣ ខាងលើនៃកុញ្ជរសាលានោះធ្វើអំពីដុំមាសក្រហម កែវផលិតនឹងកែវបវាឡ ។ អវរោជៈជាក្មួយញុំាងជាងឱ្យធ្វើមណ្ឌបជាវិការៈ នៃកែវត្រង់កណ្តាលកុញ្ជរសាលា ហើយដាក់គ្រែធម្មាសនៈនៅត្រង់កន្លែងនោះ ។ ជើងគ្រែធ្វើពីដុំមាសក្រហម មេគ្រែទាំង៤ ក៏ធ្វើពីមាសដូចគ្នា ហើយគាត់ឱ្យជាងធ្វើរូបពពែមាស ៤ដាក់ទ្រជើងគ្រែធម្មាសនៈទាំង ៤ដែរ និងធ្វើរូបពពែ ២ ដាក់ទ្រជើងតាំង ដូច្នេះគាត់ត្រូវធ្វើរូបពពែមាស៦ដាក់ទុកក្នុងមណ្ឌបនោះ ដំបូងគាត់ឱ្យគេត្បាញធ្វើកម្រាលធម្មាសនៈ លើកកណ្តាលឱ្យត្បាញសូត្រធ្វើពីមាស និងលើកក្រោយឱ្យត្បាញសូត្រពីកែវមុក្តា ឯបង្អាន់ដៃធ្វើពីខ្លឹមចន្ទន៍ក្រហម ។ កាលបើកុញ្ជរ

សាលាកសាងរួចស្រេចហើយ គាត់ធ្វើបុណ្យឆ្លងសាលានោះ និមន្តព្រះសាស្តាព្រមទាំងភិក្ខុសង្ឃ៦៨សែនអង្គ ថ្វាយទានអស់ ៤ខែ ក្នុងថ្ងៃជាទីបំផុតគាត់ប្រគេនត្រៃចីវរហើយត្រៃចីវរដែលមានតម្លៃ ១០០០កហាបណៈ គាត់ប្រគេនដល់ភិក្ខុថ្មីក្នុងសង្ឃ ។

អចរោជៈបានធ្វើបុញ្ញកម្ម ក្នុងព្រះពុទ្ធកាលព្រះនាមវិបស្សីយ៉ាងនេះ ច្យុតពីអត្តភាពនោះ បានទៅកើតក្នុងទេវលោក និងមនុស្សលោកជាច្រើនជាតិ លុះដល់មកភទ្ទកប្បនេះបានមកកើតក្នុងត្រកូលសេដ្ឋីមានទ្រព្យច្រើននាក្រុងពារាណសី មាននាមប្រាកដថា ពារាណសេដ្ឋី ។ សម័យថ្ងៃមួយគាត់ដើរទៅគាល់ព្រះរាជា បានជួបនឹងបុរោហិតសួរថា លោកអាចារ្យតើមានភេទដូចម្តេច លោកបានគន់គូរមើលនក្ខត្តឫក្សដែរឬទេ ? ។ បុរោហិតជំរាបថា ខ្ញុំបានគន់គូររួចហើយ មានភ័យអន្តរាយមួយកើតឡើង ចុះភ័យនោះដូចម្តេច ? ភ័យកើតពីអត់បាយស៊ីលោកសេដ្ឋី តើនឹងមានកើតនៅពេលណា ? កន្លងពីនេះទៅចំនួន ៣ខែទៀត ។ សេដ្ឋីបានស្តាប់ពាក្យដែលបុរោហិតនោះប្រាប់ហើយ គាត់ឱ្យកម្មកររបស់គាត់ធ្វើស្រែឱ្យបានច្រើន ដើម្បីទុកការពារអត់បាយ បានធ្វើជង្រុក ២៥០ ដាក់ស្រូវពេញទាំងអស់ ។ កាលបើគាត់ដាក់ជង្រុកមិនអស់ គាត់ដាក់ក្នុងពាងថែមទៀត ហើយនៅសល់ទៀត គាត់ឱ្យជីកដីធ្វើរណ្តៅកប់ទុកថែមទៀត ។ លុះដល់សម័យថ្ងៃមួយភ័យពីអត់បាយបានកើតឡើង សេដ្ឋីបរិ

ភោគស្រូវដែលខ្លួនបានកប់ទុក លុះដល់ស្រូវដែលគាត់កបទុកក្នុងដី ដាក់ពាង និងដាក់ជង្រុកអស់ហើយ គាត់ហៅទាសកម្មកររបស់គាត់មកប្រាប់ថា នែអ្នករាល់គ្នា អ្នកឯងចូរទៅចុះ ចូរទៅរស់នៅក្នុងភ្នំ បើពេលណាដែលស្រុកបានសាន្តត្រាណ មានបាយស៊ីស្រួលបួល អ្នករាល់គ្នាចង់មកនៅជាមួយនឹងយើងមកចុះ បើមិនចង់មកនៅទេ ក៏រកកន្លែងណាដលរស់នៅបានស្រួលទៅចុះ ។ ពួកទាសកម្មករទាំងនោះ ក៏នាំគ្នាលាសេដ្ឋីទៅរកកន្លែងរៀង១ខ្លួន ប្លែកតែខ្ញុំប្រុសគាត់ម្នាក់ក្រាញនៅជាមួយនឹងសេដ្ឋី នោះមិនព្រមចេញទៅណាឡើយ ។ ជនទាំង៥នាក់គឺសេដ្ឋីនិងភរិយាកូនប្រុសនឹងកូនប្រសារ ព្រមទាំងខ្ញុំប្រុសឈ្មោះបុណ្ណៈនៅក្នុងផ្ទះនោះ កាលបើស្រូវដែលខ្លួនទុកដាក់អស់ហើយ ក៏នាំគ្នាវាយបំបែកដីស្អិតព្ធដ៏ជញ្ជាំង រើសគ្រាប់ស្រូវដែលនៅជាប់នឹងជញ្ជាំងនោះយកមកចំអិនបរិភោគ ។ លំដាប់នោះសេចក្ដីស្រេកឃ្លានគ្របសង្កត់កាន់តែខ្លាំងឡើង១ ណាមួយដីស្អិតនោះក៏ខ្លួនវាយរើសយកអស់រលីងហើយ បានស្រូវត្រឹមតែកន្លះអាឡ្ហកៈគាត់យកទៅបុកបានជាអង្ករមួយនាឡិ ហើយយកទៅដាំបាយក្នុងឆ្នាំងមួយបិទឱ្យជិតកប់ក្នុងដី ព្រោះខ្លាចចោរលួច ។ គ្រានោះសេដ្ឋីត្រឡប់ពីគាល់ព្រះរាជាវិញសួរប្រពន្ធថា ម្នាលប្អូនស្រីបងស្រេកឃ្លានណាស់ តើយើងមាននៅសល់អង្ករខ្លះដែរឬទេ ? ។ ប្រពន្ធប្រាប់ថាយើងនៅសល់អង្ករ១ នាឡិស្វាមី ។ ចុះនៅឯណា ? ខ្ញុំកប់នៅក្នុងដីព្រោះខ្លាចចោរលួច

បើដូច្នោះចូរប្អូនគាស់រើយកមកចំអិនអាហារ ។ ប្រពន្ធនិយាយប្រាប់ថា បើយើងចំអិនបបរ យើងអាចរស់នៅបានពីរពេល បើយើងដាំបាយអាច រស់បានតែមួយពេល បពិត្រស្វាមី បើដូច្នោះឱ្យខ្ញុំដាំបាយ ឬដាំបបរ ? ។ សេដ្ឋីប្រាប់ថា វត្ថុដទៃទៀតយើងគ្មានទេ បើយើងបំណាច់នឹងស្លាប់ក៏ឱ្យតែ បានបាយស៊ីឆ្អែត ហើយសឹមស្លាប់ទៅចុះ បើដូច្នោះចូរប្អូនចំអិនបាយ ទៅចុះ ។ ប្រពន្ធក៏ព្រមចំអិនបាយតាមពាក្យបង្គាប់របស់ប្ដី ហើយចែក ជា៥ចំណែក រួចដោះបាយចំណែកសេដ្ឋីដាក់នៅនឹងមុខគាត់ ។ ខណៈនោះ មានព្រះបច្ចេកពុទ្ធមួយអង្គគង់នៅភ្នំគន្ធមាទន៍ លោកទើបនឹងចេញពី សមាបត្តិ ។ តាមសេចក្ដីដំណាលថា សេចក្ដីស្រេកឃ្លានមិនបៀតបៀន លោកដែលនៅក្នុងសមាបត្តិទេ ដោយសារកម្លាំងសមាបត្តិ តែដល់ពេល ចេញមកវិញ សេចក្ដីស្រេកឃ្លានបៀតបៀនជាខ្លាំង ដូចជាដុតតម្បាពោះ លោក ព្រោះហេតុនោះ ទើបលោកពិចារណារកកន្លែងណាដែលអាចទៅ រកអាហារបិណ្ឌបាតបាន ។ ក្នុងថ្ងៃនោះ បើជនណាឱ្យទានដល់លោក តែង បានសម្បត្តិទាំងឡាយមានឋានៈជាសេនាបតីជាដើមតាមសេចក្ដីដែលខ្លួន ប្រាថ្នា ព្រោះហេតុដូច្នេះបានជាលោកត្រូវពិចារណាមើលដោយទិព្វចក្ខុ ហើយពេលនោះ ឆាតកភ័យកើតពេញជម្ពូទ្វីប ចំណែកជនទាំង៥ នាក់នៅ ក្នុងផ្ទះសេដ្ឋីចំអិនបាយតែអង្ករ១នាឡិ តើជនទាំងនោះមានសទ្ធាដែរឬទេ ហ្ន៎ ? អាចនឹងសង្គ្រោះអាត្មាអញបានដែរឬទេហ្ន៎ ? លុះពិចារណាទៅ

ឃើញថា ជនទាំងនេះមានសទ្ធាផង អាចសង្គ្រោះដល់អាត្មាអញផង ទើប លោកស្ពាយបាត្រទៅឈរបង្ហាញខ្លួននៅត្រង់ទ្វារខាងមុខផ្ទះសេដ្ឋី ។ សេដ្ឋី គ្រាន់តែបានឃើញព្រះបច្ចេកពុទ្ធភ្លាម មានចិត្តជ្រះថ្លាគិតថា ការអត់ បាយយ៉ាងនេះអញបានជួបប្រទះ ព្រោះតែអញមិនឱ្យទានក្នុងកាលមុន ហើយភត្តនេះទៀត ក៏អាចរក្សាអញបានតែ១ថ្ងៃប៉ុណ្ណោះ បើអញប្រគេន ទៅលោកម្ចាស់វិញ នឹងអាចបានជាប្រយោជន៍ដល់អញ អស់កោដិនៃកប្ប ដ៏ច្រើនមិនខាន លុះគាត់គិតឃើញដូច្នោះហើយ ក៏កាន់យកភោជនបាយ នោះ ចូលទៅរកព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាននិមន្ត លោកចូលទៅក្នុងផ្ទះ លាងព្រះបាទឱ្យគង់លើអាសនៈ ហើយយកភត្ត នោះមកដាក់ក្នុងបាត្រព្រះបច្ចេកពុទ្ធ ។ កាលបើភត្តធ្លាក់ទៅក្នុងបាត្រ បានពាក់កណ្ដាល លោកបិទបាត្រទៅវិញ ។ សេដ្ឋីទូលថា បពិត្រលោក ម្ចាស់ ដ៏ចំរើន បាយដែលគេចំអិនពីអង្ករ ១នាឡិសំរាប់ជនទាំង ៥នាក់ នោះ ឯចំណែកបាយមួយចំណែកនេះ ខ្ញុំព្រះករុណាមិនអាចធ្វើឱ្យទៅជា ពីរចំណែកបានឡើយ សូមលោកម្ចាស់កុំសង្គ្រោះខ្ញុំព្រះករុណាក្នុងជាតិនេះ ខ្ញុំព្រះករុណាប្រគេនមិនអោយមានសល់ លុះទូលព្រះពុទ្ធដីកាដូច្នោះ ហើយ គាត់ប្រគេនភត្តទាំងអស់ ហើយប្រាថ្នាប្រកាសថា បពិត្រលោក ម្ចាស់ដ៏ចំរើន ចាប់តាំងពីពេលនេះទៅ សូមកុំឱ្យខ្ញុំព្រះករុណាបានជួប ប្រទះនឹងភ័យពីអត់បាយមានសភាពបែបនេះទៀត ក្នុងជាតិដែលខ្ញុំព្រះ

ករុណាបានកើតហើយ គប្បីជាអ្នកជាអាចឱ្យវិចភត្តដល់មនុស្សដែលនៅ ក្នុងជម្ពូទ្វីបទាំងមូល នឹងសូមឱ្យធារស្រូវសាលីក្រហាមរបស់ខ្ញុំព្រះករុណា ធ្លាក់បំពេញជង្រុកទាំងអស់ក្នុងខណៈដែលខ្ញុំព្រះករុណា ប្រើឱ្យគេជម្រះ ជង្រុក ២៥០ ហើយអង្គុយក្បែរទ្វារនៃជង្រុកទាំងនោះ ហើយក្រឡេក មើលទៅខាងលើ ម្យ៉ាងទៀតភរិយានេះក្តី កូនប្រុសនេះក្តី កូនប្រសារស្រី នេះក្តី និងខ្ញុំប្រុសនេះក្តីរបស់ខ្ញុំព្រះករុណា ក៏សូមឱ្យបានសម្រេចមកជា គ្រួសាររបស់ខ្ញុំព្រះករុណាវិញកុំខានឡើយ ។ ចំណែកឯប្រពន្ធសេដ្ឋីគិតថា ស្វាមីរបស់អញត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់យ៉ាងខ្លាំង អញក៏មិន អាចនឹងបរិភោគតែម្នាក់ឯងដែរ ហើយក៏ប្រគេនភត្តចំណែករបស់ខ្លួនដល់ ព្រះបច្ចេកពុទ្ធប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចំរើន ចាប់ពីពេលនេះទៅ សូមកុំឱ្យខ្ញុំព្រះករុណាជួបប្រទះនឹងភ័យអន្តរាយបែបនេះទៀត កាលខ្ញុំ ព្រះករុណាយកថាសសំរាប់ដាក់បាយចែកមនុស្សដែលនៅក្នុងជម្ពូទ្វីបទាំង មូល ដរាបណាខ្ញុំមិនទាន់ក្រោកចេញ ដរាបនោះ សូមឱ្យមានបាយនៅ ពេញដដែល ហើយស្វាមីខ្ញុំព្រះករុណានេះក្តី កូនប្រុសនេះក្តី កូនប្រសារ នេះក្តី នឹងខ្ញុំប្រុសនេះក្តី សូមឱ្យបានជាគ្រួសារខ្ញុំព្រះករុណាវិញដដែល ។ ឯកូនប្រុស ក៏បានប្រគេនភត្តចំណែករបស់ខ្លួនទៅព្រះបច្ចេកពុទ្ធដែរ តាំងប្រាថ្នា សូមកុំឱ្យខ្ញុំបានជួបនឹងភ័យអន្តរាយបែបនេះទៀតម្យ៉ាងទៀត កាលបើខ្ញុំព្រះករុណាកាន់យកថង់មួយ ដែលមានកហាបណៈពេញឱ្យទាន

ដល់អ្នកជម្ពូទ្វីបទាំងមូលសូមឱ្យផង់នេះនៅពេញដដែល ហើយមាតាបិតាខ្ញុំនេះ ក៏សូមឱ្យនៅជាមាតាបិតាដដែល ឯភរិយាខ្ញុំនិងខ្ញុំប្រុសរបស់ខ្ញុំនេះ ក៏សូមឱ្យបាននៅជួបជុំគ្នាវិញដែរ ។ ឯកូនប្រសារស្រី ក៏ប្រគេនភត្តចំណែកខ្លួន ហើយតាំងសច្ចាថា សូមកុំឱ្យជួបនឹងភ័យបែបនេះដែរមួយវិញទៀត បើខ្ញុំដាក់កញ្ជើស្រូវមួយពីមុខ ឱ្យទានរឹជភត្តដល់អ្នកជម្ពូទ្វីប ក៏សូមកុំឱ្យខ្វះកន្លះពីកញ្ជើនេះ ហើយឪពុកម្ដាយនេះ កិសូមឱ្យបានជាឪពុកម្ដាយក្មេកនៅក្នុងអនាគតជាតិដែរ ចំណែកស្វាមី និងខ្ញុំប្រុសនេះក៏សូមបានដូចជាក្នុងជាតិនេះដែរ ។ ចំណែកខាងខ្ញុំប្រុស ក៏ប្រគេនបាយចំណែកខ្លួនទៅព្រះបច្ចេកពុទ្ធ ហើយតាំងប្រាថ្នាថា កុំឱ្យជួបនឹងឆាតភ័យដូចជាតិនេះទៀត ហើយសូមឱ្យនាយចៅហ្វាយទាំងនេះបានជានាយចៅហ្វាយរបស់ខ្លួននៅក្នុងអនាគតជាតិ ម្យ៉ាងទៀតបើកាលណាខ្ញុំភ្ជួរស្រែសូមឱ្យអាចម៏បំណាស់តែ៧ គឺអាចម៏បំណាស់៣ខាងនេះ ៣ខាងនោះនឹងកណ្ដាលមួយឱ្យបានហើយស្រេច ក្នុងស្រែមួយ ។ ក្នុងថ្ងៃនោះបើខ្ញុំប្រុសប្រាថ្នានូវដំណែងជាសេនាបតី ក៏បានសំរេចដែរ ប៉ុន្តែគាត់ប្រាថ្នាឱ្យជនទាំងអស់នោះនៅតែជាចៅហ្វាយនាយរបស់គាត់ ដោយសេចក្ដីស្រឡាញ់ចំពោះនាយចៅហ្វាយរបស់គាត់តែម្យ៉ាងប៉ុណ្ណោះ បានជាគាត់មិនប្រាថ្នាឱ្យបានទៅជាអ្វីទៀត ។ ព្រះបច្ចេកពុទ្ធ លុះជនទាំងអស់នោះតាំងចិត្តប្រាថ្នាគ្រប់គ្នាហើយ ទើបលោកពោលថា សូមឱ្យបានសំរេចដូច

សេចក្តីប្រាថ្នារបស់អ្នករាល់គ្នាចុះ ហើយអនុមោទនាដោយគាថារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ អធិដ្ឋានចិត្តឱ្យជនទាំងនោះឃើញលោកដរាបទៅដល់ភ្នំគន្ធមាទន៍ ដើម្បីឱ្យជនទាំងនោះរឹងរឹតតែមានសេចក្តីជ្រះថ្លាខ្លាំងឡើងទៀត ។ ជនទាំងនោះក៏បានឈរមើលលោកឃើញរហូតដល់ទៅភ្នំនោះ លោកបានចែកភត្តនោះដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គបានឆាន់ឆ្អែតគ្រប់គ្រាន់ដោយអានុភាពនៃឫទ្ធិរបស់លោក ។ លុះដល់ថ្ងៃជ្រេរបន្តិចប្រពន្ធសេដ្ឋីលាងឆ្នាំគ្របទៅវិញ ។ សេដ្ឋីត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ខ្លាំង ក៏ដេកលក់ទៅ លុះដល់រសៀលទើបគាត់ភ្ញាក់ពីដេកសួរប្រពន្ធថា នមានបាយក្តាំងនៅក្នុងឆ្នាំងខ្លះដែរឬទេ ? ប្រពន្ធទោះបីដឹងថាឆ្នាំងនោះខ្លួនទើបនឹងលាងទុកក៏ដោយ គាត់មិនប្រាប់ថាគ្មានបាយទេ គាត់ធ្វើជាដើរទៅជិតឆ្នាំងហើយបើកមើល ។ ភ្លាមនោះបាយក៏ពេញឆ្នាំ មានសម្បុរដូចជាផ្កាម្លិះក្រពុំ គាត់ឃើញហេតុដូច្នោះ មានសេចក្តីរីករាយ ទើបប្រាប់ថា បពិត្រស្វាមីសូមអញ្ជើញក្រោកឡើង ខ្ញុំបានលាងឆ្នាំនេះគ្របទុកទៅហើយ ស្រាប់តែឆ្នាំងនេះមានបាយពេញមានសម្បុរដូចជាផ្កាម្លិះក្រពុំនេះពិតជាបុណ្យដែលយើងធ្វើពីព្រឹកមិញហ្នឹងឯង អញ្ជើញក្រោកទៅបរិភោគ ។ កាលបើសេដ្ឋីនិងកូនប្រុសបរិភោគហើយ ប្រពន្ធសេដ្ឋីនិងកូនប្រសារអង្គុយបរិភោគជាមួយគ្នា ហើយចែកឱ្យខ្ញុំប្រុសឈ្មោះបុណ្ណៈបរិភោគទាល់តែឆ្អែតរៀងខ្លួន។ បាយតែ១ឆ្នាំងប៉ុណ្ណោះ សូម្បីដោះ១វែក

ទៅហើយ ក៏នៅតែពេញដដែល មិនចេះខ្វះកន្លះសោះ ។ សេដ្ឋីបានឃោសនាប្រាប់ពួកអ្នកនគរថា បាយមាននៅក្នុងផ្ទះលោកសេដ្ឋី អស់លោកត្រូវការវិជភត្ត សូមអញ្ជើញចូលទៅយកតាមសេចក្តីត្រូវការ ។ មនុស្សម្នាមហាជននាំគ្នាទៅយកវីជភត្តនោះតែសព្វខ្លួន ក៏មានជីវិតរស់នៅទាំងអស់គ្នា ដោយសារវីជភត្តនៅក្នុងផ្ទះលោកសេដ្ឋីនោះ ក៏បានរួចផុតពីសេចក្តីទុក្ខភ័យគ្រប់ៗគ្នា ។

សេដ្ឋីនោះច្យុតិពីអត្តភាពនោះទៅ បានទៅកើតក្នុងទេវលោក លុះ ច្យុតិពីទេវលោកមកវិញ បានមកកើតត្រកូលសេដ្ឋី ក្នុងភទ្ទិយនគរ ក្នុងពុទ្ធប្បាទនេះ ។ ឯប្រពន្ធសេដ្ឋីក៏បានមកកើតក្នុងមហាភោគត្រកូលដែរ លុះដល់មានវ័យចំរើនធំឡើង ក៏បានជួបគ្នាជាប្តីប្រពន្ធដដែល ។ ចំណែកពពែមាស ដែលយើងបានពណ៌នាមកនោះ ក៏បានកើតឡើងដោយសារបុព្វកម្មនោះដែរ ហើយជនទាំងបីនាក់ទៀត គឺកូនប្រុស កូនប្រសារស្រី នឹងខ្ញុំប្រុសឈ្មោះបុណ្ណៈ ក៏បានមកដូចសេចក្តីប្រាថ្នាពីពេលមុនមែន ។ ថ្ងៃមួយសេដ្ឋីចង់សាកល្បងបុណ្យរបស់គាត់ ទើបប្រើឱ្យគេជម្រះជង្រុក ២៥០ ហើយគាត់ឈរក្បែរទ្វារងើយមើលទៅលើ ខណៈនោះជង្រុកទាំងអស់ ក៏ពេញដោយស្រូវសាលីក្រហមមែន ។ ម្យ៉ាងទៀតគាត់ចង់សាកល្បងបុណ្យរបស់ជនដ៏សេសទៀត ទើបគាត់ប្រាប់ប្រពន្ធ និងកូនប្រុសថា ចូរអ្នករាល់គ្នាសាកល្បងមើលបុណ្យអ្នកឯងទាំងអស់គ្នាមើល៍! ។ លំដាប់

នោះប្រពន្ធគាត់តាក់តែងស្អិតស្អាងគ្រឿងអលង្ការហើយស្រេច ប្រើគេចំអិនបាយ រួចទៅអង្គុយលើអាសនៈដែលគេក្រាលទុកក្បែរក្លោងទ្វារ យកវែកមាសដួសបាយចែកឱ្យពួកមហាជន ដែលចូលមកសុំ ចាប់តាំងពីព្រលឹមទល់ព្រលប់ ក៏នៅតែមិនអស់បាយនោះផង ។ បាតដៃនាងខាងឆ្វេងមានលក្ខណៈដូចជាផ្កាឈូក បាតដៃខាងស្តាំមានលក:ដូចជាព្រះច័ន្ទ កើតឡើងដោយសារដៃនាងខាងឆ្វេងកាន់ឆ្នាំ ខាងស្តាំងកាន់វែកដួសបាយដាក់បំពេញបាត្រប្រគេនដល់ភិក្ខុសង្ឃ និងព្រះពុទ្ធពីក្នុងជាតិមុន ។ ន័យមួយទៀតថា នាងបានយកធម្មក្រកទៅត្រងទឹកប្រគេនភិក្ខុសង្ឃ ដោយអានិសង្សនៃការត្រងទឹកនោះ បានជានាងមានផ្ទៃបាតជើងខាងស្តាំមានរូបព្រះច័ន្ទ ផ្ទៃបាតជើងខាងឆ្វេងមានរូបផ្កាឈូក ដោយមានហេតុនេះទើបពួកមហាជនឱ្យឈ្មោះថាចន្ទបទុមា ។ ចំណែកកូនប្រុស និងកូនប្រសារស្រី ព្រមទាំងខ្ញុំប្រុស ក៏បានពិសោធល្បងមើលបុណ្យរបស់ខ្លួនរៀងៗខ្លួនដែរ ក៏បានឃើញពិតប្រាកដតាមសេចក្តីប្រាថ្នារបស់ខ្លួន ។តាំងពីពេលនោះមកជនអ្នកនៅក្នុងជម្ពូទ្វីប តែងទៅសុំបាយ ប្រាក់ មាស ។ ល ។ តាមសេចក្តីប្រាថ្នារបស់ខ្លួនពីផ្ទះលោកមហាសេដ្ឋីតែរៀងរាល់ថ្ងៃ ក៏មិនចេះខ្វះកន្លះឡើយ ។

សេដ្ឋីមានអនុភាពយ៉ាងនេះ លុះដឹងដំណឹងថា ព្រះសាស្តាទ្រង់យាងមក ក៏ដើរចេញទៅចាំទទួលព្រះសាស្តា ឃើញពួកអន្យតិរ្ថិយនាំគ្នា

ឈរតាមផ្លូវស្រែកឃាត់ថា ម្នាលគហបតីលោកពោលថាកម្មដែលបុគ្គល ធ្វើគ្រាន់តែជាកិរិយាធ្វើ ចុះលោកអញ្ជើញទៅសំណាក់ព្រះសមណៈគោតមដែលជាអ្នកនិយាយថា កម្មដែលបុគ្គលមិនធ្វើគ្រាន់តែជាការមិនធ្វើប៉ុណ្ណោះ ព្រោះហេតុអ្វី ? គាត់មិនរវល់អើពើនឹងសំដីពួកអន្យតិរ្ថិយទាំងនោះឡើយ លុះទៅដល់ហើយថ្វាយបង្គំព្រះបរមគ្រូ អង្គុយក្នុងកន្លែងគួរសម ។ លំដាប់នោះ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថា លុះចប់ព្រះធម៌ទេសនា សេដ្ឋីបានសំរេចសោតាបត្តិផល ទើបក្រាបទូលរឿងហេតុដែលពួកអន្យតិរ្ថិយទាំងនោះហាមឃាត់គាត់មិនឱ្យទៅជួប នឹងព្រះសាស្តា ។ បន្ទាប់មកព្រះអង្គត្រាស់ថា : ម្នាលគហបតីធម្មតាសត្វទាំងនេះ ទោះបីទោសរបស់ខ្លួនធំប៉ុណ្ណាក៏ដោយ មើលមិនឃើញទេ បើអ្នកដទៃវិញទោះមិនមានទោសសោះ ក៏បាចសាចធ្វើឱ្យទៅជាមានទោសដែរ ដូចជាគេបាចសាចអង្កាមដូច្នោះដែរ ហើយទ្រង់ត្រាស់គាថានេះបន្ថែមទៀតថា :

ទោសអ្នកដទៃ បុគ្គលអាចឃើញបានដោយស្រួល បើទោសឯងវិញ ខ្លួនឯងមើលមិនឃើញទេ ពិតដូច្នេះមែន អ្នកនោះតែងបាចសាចទោសអ្នកដទៃ ដូចជាគេបាចអង្កាម បើនរណាបិទបាំងនូវទោសខ្លួន ដូចជាព្រានសត្វស្លាបបិទបាំងនូវខ្លួនដោយស្លឹកឈើដូច្នោះដែរ ។

លុះចប់ព្រះធម្មទេសនានេះ ជនទាំងនោះ ក៏បានសំរេចសោតាបត្តិផលគ្រប់ៗគ្នា ។

# ១៥_ រឿងប្រែតស៊ីកូនម្តង៧

( ចាក បេ. ខុ.. )

*( អំពើបាបលាមកអាក្រក់សាមន្យ តែងត្រឡប់បានមកបុគ្គលអ្នកធ្វើវិញ )*

ក្នុងកាលដែលព្រះបរមពុទ្ធង្កុរបណ្តួលសារពិជ្ជូតាញាណ ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថនាក្រុងសាវត្ថី មានឧបាសកម្នាក់មានទីនៅ១ទៀបទីក្រុងនោះ។ គាត់មានកូន២នាក់ ដែលមានវ័យវឌ្ឍន៍ចម្រើនតាមលំដាប់ ។ ឯភរិយាជាស្ត្រីឆ្នាស់ មានការប្រមាទមើលងាយស្វាមី ទុកស្វាមី ដូចជាទាសា ដោយគំនិតថា ស្វាមីនឹងធ្វើអ្វីអញ បើអញមានកូនគ្រាន់ជាទីពឹងហើយ ។ ឯឧបាសកនោះ យល់ប្រពន្ធខ្លួនជាស្ត្រីឆ្នាស់ទទឹងរឹងរូសមើលងាយដូច្នោះ ទៅជានឿយណាយធុញទ្រាន់នឹងអាកប្បកិរិយារបស់ប្រពន្ធ ទើបទៅដណ្តឹងយកនាងកុមារិកាម្នាក់មកជាប្រពន្ធចុង ។ នៅរួមរសមេត្រីដោយក្តីស្នេហាមិនជាយូរប៉ុន្មាន ប្រពន្ធនោះមានគភ៌ឡើង ឯប្រពន្ធដើមឃើញដូច្នោះកើតអិរិចិត្តច្រណែនឈ្នានិសប្ឫស្យា ទើបល្បួងលួងលោមប្រពន្ធចុងធ្វើជាមិត្រស្និទ្ធស្នាល ដើម្បីបន្លំដាក់ថ្នាំទម្លាក់គភ៌នាង ។ រីបងប្អូនញាតិសន្តានបានដឹងដូច្នោះ ដណ្តឹងសួរទៅប្រពន្ធដើមថា នាងខឹងអ្វីបានជាធ្វើថ្នាំដាក់ពន្លូតគភ៌នាងនេះ ។ ប្រពន្ធដើមឆ្លើយបដិសេធថា ខ្លួនពុំបានធ្វើអំពើដ៏សាហាវឃោរឃៅដូច្នោះទេ ពួកញាតិទាំងអស់បានឱ្យនាងស្បថ នាងក៏ស្បថទាំងបំពានថា " បើខ្ញុំហើយបានធ្វើ

អំពើអាក្រក់លាមកពន្លូតកូននាងកុមារិកានេះមែន សូមឱ្យខ្ញុំកើតជាតិណា១ ស៊ីតែកូនឯងម្តង ៧រាល់១ថ្ងៃ ឱ្យខ្លួនខ្ញុំទាំងមូលនេះមានក្លិនស្អុយអាសោចិ មានរុយរោមពេញទាំងខ្លួន" ។

អំណើះតទៅ នាងប្រពន្ធដើមក៏រំលាយបញ្ចក្ខន្ធទៅ បានទៅកើតជាប្រេតញីមួយ ដោយកម្មដ៏លាមកដែលខ្លួនបានធ្វើ ព្រមទាំងពោលពាក្យស្បថទាំងបំពានដោយមុសាវាទ ។ លំដាប់នោះព្រះថេរៈទាំងឡាយគង់ចាំវស្សាក្នុងជនបទមួយ លុះចេញវស្សាហើយ ក៏និមន្តទៅកាន់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះដ៏មានបុណ្យ មកដល់ទីទួលមួយដ៏មានដីរាបស្មើល្អ ក៏ចូលទៅសម្រាកព្រះកាយ ។ ក្នុងរាត្រីនោះប្រេតញីបានសម្តែងកាយឱ្យព្រះថេរៈទាំងឡាយឃើញច្បាស់ ។ គ្រានោះព្រះសង្ឃត្ថេរមួយអង្គដណ្តឹងសួរទៅនាងថា " នែនាងប្រេតញី ! នាងឯងគ្មានសំពត់បិទបាំងរាងកាយបន្តិចសោះ មានមុខមាត់អាក្រក់ក្រៃ មានក្លិនស្អុយអសោចិ និងរុយរោមពេញទាំងខ្លួន នាងមកក្នុងទីនេះ តើព្រោះធ្វើកម្មអ្វី ? ។ នាងប្រេតឆ្លើយទូលពុទ្ធដិកាថា បពិត្រព្រះករុណាម្ចាស់! ព្រោះខ្ញុំព្រះករុណាធ្វើអំពើដ៏អាក្រក់លាមកណាស់ បានជាត្រូវមកកើតជាប្រេតនៅអាស្រ័យក្នុងទីនេះ ក្នុងវេលាព្រឹកខ្ញុំស៊ីកូនឯងអស់៧ វេលាល្ងាចស៊ីអស់៧ទៀតរាល់១ថ្ងៃ ។ បើ ទុកថាដូច្នោះ ក៏ខ្ញុំពុំអាចទប់ទល់នឹងសេចក្តីស្រេកឃ្លានបានឡើយ ។ ក្នុង កាយរបស់ខ្ញុំម្ចាស់ មានអាការៈក្តៅក្រហាយជានិច្ច ដូចជាគេឈរនៅ

កណ្តាលគំនរភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ ។ ឯបុព្វកម្មរបស់ខ្ញុំម្ចាស់នោះដូច្នោះ គឺកាលពីបុព្វជាតិខ្ញុំម្ចាស់ជាស្ត្រីរួមប្តីជាមួយនាងកុមារិកាម្នាក់ ហើយខ្ញុំម្ចាស់មានកូនពីរនាក់ ដែលមានរូបសម្បត្តិដ៏សមគួរ មានវ័យធំល្មមប្រើការបាន តែឯខ្ញុំម្ចាស់វិញជាស្ត្រីឆ្នាស់ មានការប្រមាទមើលងាយប្តីជាប្រក្រតី ។ ឯប្តីខ្ញុំម្ចាស់មិនអាចអត់ទ្រាំនៅជាមួយខ្ញុំម្ចាស់ទៀតបាន ក៏ទៅស្តីដណ្តឹងនាងកុមារិកាម្នាក់ទៀតមកជាភរិយាចុង ។ លុះនាងភរិយាចុងមានគភ៌ ខ្ញុំម្ចាស់កើតចិត្តឫស្យាច្រណែនឈ្នានិស ទើបធ្វើឱ្យគភ៌នាងរលូតចេញទៅ ។ ពួកញាតិទាំងឡាយរបស់នាងកុមារិកានោះបានជេរស្តីបន្ទោសខ្ញុំម្ចាស់ជាច្រើន តែខ្ញុំម្ចាស់ឆ្លើយបដិសេធប្រកែកពុំព្រមទទួលកំហុសដោយពាក្យមុសាវាទ បានជាខ្ញុំម្ចាស់ត្រូវមកកើតជាប្រេតញីនៅទីនេះក្នុងជាតិនេះឯង ។

ទូលព្រះថេរៈសព្វគ្រប់ហើយ នាងប្រេតក៏ផ្តែផ្តាំនឹងព្រះថេរៈសូមឱ្យនិមន្តទៅផ្ទះឧបាសកនោះ ហើយសូមប្រាប់ឱ្យឧបាសកនោះធ្វើបុណ្យឧទ្ទិសភាគផលផ្សាយឱ្យនាងផង ដើម្បីឱ្យឆាប់បានរំដោះជាតិអំពីប្រេតនេះ ។ ព្រះថេរៈទាំងឡាយ ក៏និមន្តទៅផ្ទះឧបាសកនោះ រៀបរាប់អំពីពាក្យបណ្តាំរបស់នាងប្រេតសព្វគ្រប់ ឧបាសកនោះក៏ចាត់ចែងរៀបក្រាលអាសនៈ ហើយអង្គាសដោយភត្តាហារដ៏គួរ រួចឧទ្ទិសផលជូនទៅប្រេតញីនោះ តាមចិត្តសទ្ធារបស់ខ្លួន ។ ដោយអំណាចនៃទេយ្យទាន ដែលឧបា

សកនោះឧទ្ទិសឱ្យទៅ នាងប្រេតនោះក៏បានរួចចាកទុក្ខសោយសុខដ៏លើស លុប ហើយសម្តែងកាយឱ្យឧបាសកនោះឃើញក្នុងរាត្រីនោះ ។

ព្រះថេរៈទាំងឡាយ ក៏យកសេចក្តីនេះទៅក្រាបទូលព្រះដ៏មាន ជោគ ព្រះអង្គក៏ទ្រង់សម្តែងបញ្ជាក់អំពីរឿងនេះ ដល់បរិស័ទទាំង៤ពួក ដោយយកព្រះថេរៈទាំងនេះជាសំអាង បរិស័ទទាំង ៤ ក៏កើតសោមនស្ស ជ្រះថ្លា និងសង្វេគចិត្តគ្រប់ៗគ្នា ដល់ចប់ធម្មទេសនា ក៏បានសម្រេចនូវ គុណធម៌ដ៏វិសេសគ្រប់ៗគ្នាហោង ។

## ១៦. រឿងសាមណេរ ៤ រូបជាព្រះអរហន្ត

( ចាក ធ. ខុ.. )

*( ជាតិបថុជ្ជនតែងជ្រះថ្លាចំពោះតែបុគ្គលចាស់ៗ )*

បានឮថា នាងព្រាហ្មណីម្នាក់បានចាត់ចែងឧទ្ទេសភត្តសម្រាប់ភិក្ខុ ៤ អង្គ ប្រើព្រាហ្មណ៍ជាប្តីឱ្យទៅនិមន្តលោកប្រាប់ថា " ម្នាលព្រាហ្មណ៍ ចូរអ្នកទៅវត្តនិមន្តព្រាហ្មណ៍ចាស់ៗ ៤ អង្គមក " ។ គាត់ទៅវត្តនិមន្តថា " សូមនិមន្តព្រាហ្មណ៍ ៤អង្គ " ។ ខីណាសវសាមណេរ ៤ អង្គ គឺ សង្កិច្ច ១ បណ្ឌិតៈ ១ សោបាកៈ ១ រេវតៈ ១ មានអាយុ ៧ឆ្នាំ បានសម្រេចព្រះ អរហត្តផល ។ នាងព្រាហ្មណីបានក្រាលអាសនៈដែលមានតម្លៃច្រើនរួច ស្រេច ហើយឈរចាំមើល គ្រាន់តែឃើញសាមណេរទាំង ៤ អង្គនោះ ភ្លាម ក៏មានចិត្តខឹងធ្វើនូវពាក្យ " តជិតដត់ " ដូចជាអំបិលដែលគេដាក់នៅ

លើចង្ក្រាន ពោលថា " អ្នកទៅវត្តនាំយកក្មេង ៤ នាក់ត្រឹមតែចៅរបស់ខ្លួនមក " នាងមិនឱ្យពួកសាមណេរទាំង៤អង្គគង់លើអាសនៈនោះទេ ហើយក្រាលអាសនៈទាបឱ្យគង់វិញ ប្រើព្រាហ្មណ៍ជាប្តី ឱ្យទៅនិមន្តព្រាហ្មណ៍ព្រាហ្មណ៍ចាស់ៗមកម្តងទៀត ។ ព្រាហ្មណ៍ទៅវត្តជួបនឹងព្រះសារីបុត្ត និមន្តលោកទៅឆាន់ផ្ទះរបស់ខ្លួន ព្រះថេរៈនិមន្តមកដល់ឃើញសាមណេរសួរថា លោកទាំងអស់នេះឆាន់ហើយឬនៅ ? សាមណេរទូលព្រះពុទ្ធដិកាថា " នៅឡើយទេ " ព្រះថេរៈជ្រាបថា នាងព្រាហ្មណីចាត់ចែងចង្ហាន់នេះ សម្រាប់តែលោក៤អង្គប៉ុណ្ណោះទេ លោកក៏ទទួលយកបាត្រត្រឡប់ទៅវិញ ។ ចំណែកនាងព្រាហ្មណីសួរថា លោកម្ចាស់អង្គនេះនិយាយថាម៉េច លោកប្រាប់ថា ចូរនាងឱ្យដល់ព្រាហ្មណ៍ដែលអង្គុយទាំងនេះល្មមហើយ អ្នកចូរឱ្យបាត្រមកអាត្មាវិញ ព្រះថេរៈបានបាត្រមកហើយក៏និមន្តទៅភ្លាម ឯព្រាហ្មណីនិយាយថា លោកមិនចង់ឆាន់ទេ ហើយប្រើប្តីថា ទៅនិមន្តព្រាហ្មណ៍ចាស់ៗដទៃទៀតមក ។ ព្រាហ្មណ៍ទៅជួបព្រះមហាមោគ្គល្លាននិមន្តលោកមកដូច្នោះទៀត ព្រះថេរៈឃើញសាមណេរក៏និយាយប្រាប់ដូចមុន ហើយយកបាត្រត្រឡប់ទៅវិញ ។ លំដាប់នោះនាងព្រាហ្មណីនិយាយនឹងប្តីថា លោកមិនចង់ឆាន់នៅទីនេះទេ ចូរអ្នកទៅរោងប្រជុំរបស់ព្រាហ្មណ៍ នាំយកព្រាហ្មណ៍ចាស់ម្នាក់មក ។ ឯសាមណេរ

ទាំងនោះគ្មានបានអ្វីឆាន់បន្តិចបន្តួចសោះតាំងពីព្រលឹម ត្រូវសេចក្តីស្រេកឃ្លានបៀតបៀនយ៉ាងខ្លាំងគង់នៅកន្លែងនោះ ។

គ្រានោះ ដោយតេជានុភាពនៃគុណរបស់សាមណេរទាំងនោះ អាសនៈព្រះឥន្ទ្រក៏បង្ហាញអាការៈក្តៅ ព្រះឥន្ទ្រទ្រង់ពិចារណាមើលជ្រាបថា ពួកសាមណេរទាំងនោះគង់តាំងពីព្រលឹមមានកាយលំបាកហើយៗគិតថាអញត្រូវទៅក្នុងទីនោះទើបបាន ទើបដំណែងខ្លួនជាព្រាហ្មណ៍ចាស់ជរាអង្គុយចុងអាសនៈបំផុតនៃព្រាហ្មណ៍ទាំងឡាយ ក្នុងរោងប្រជុំនោះ ។ ព្រាហ្មណ៍ឃើញតាព្រាហ្មណ៍ចាស់នោះគិតថា " នាងព្រាហ្មណីរបស់អញនឹងមានចិត្តរីករាយ ដោយសាតាព្រាហ្មណ៍នេះ ហើយក៏នាំគាត់ទៅផ្ទះ ។ នាងព្រាហ្មណីគ្រាន់តែឃើញតាព្រាហ្មណ៍នោះភ្លាម ក៏មានចិត្តរីករាយបណ្តាអាសនៈទាំងពីរនោះ នាងក្រាលកម្រាលលើអាសនៈមួយទៀត ហើយអញ្ជើញតាព្រាហ្មណ៍ឱ្យអង្គុយលើកម្រាលអាសនៈនោះ ។ ឯព្រះឥន្ទ្រចូលទៅក្នុងផ្ទះ ឃើញសាមណេរទាំង៤អង្គ ក៏ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋ ហើយអង្គុយពែនលើដីខាងចុងអាសនៈបំផុត នៃសាមណេរទាំងនោះ ។ លំដាប់នោះ នាងព្រាហ្មណីឃើញតាព្រាហ្មណ៍អង្គុយដូច្នោះក៏ពោលថា" យីអើហ្ន៎ ! តាព្រាហ្មណ៍នេះអង្គុយទាបអីម្ល៉េះ អ្នកឯងទៅនាំយកព្រាហ្មណ៍ចង្កួតនេះមកធ្វើអ្វី ទៅថ្វាយបង្គំត្រឹមតែចៅរបស់ខ្លួន ចូរអ្នកឯងនាំយកតាព្រាហ្មណ៍នេះចេញទៅឱ្យឆ្ងាយ "។ តាព្រាហ្មណ៍នោះ

កាលបើព្រាហ្មណីម្ចាស់ផ្ទះចាប់ត្រង់កផង ត្រង់ដៃផង ត្រង់ក្លៀកផង ទាញចេញទៅ គាត់មិនចង់ក្រោកទៅទេ ។ លំដាប់នោះនាងព្រាហ្មណី ពោលថា " នែព្រាហ្មណ៍ អ្នកឯងចូរចាប់ដៃម្ខាង ខ្ញុំចាប់ដៃម្ខាង " ។ ប្ដីនឹងប្រពន្ធទាំងពីរនាក់ចាប់ដៃតាព្រាហ្មណ៍ទាំងពីរ វាយខ្នងបណ្ដេញចេញទៅខាងក្រៅផ្ទះ គាត់អង្គុយគ្រវាសដៃត្រូវជនទាំងពីរនាក់ស្រែកគួរឱ្យខ្លាច ។ ខណៈនោះព្រះឥន្ទ្រធ្វើឱ្យជនទាំងនោះដឹងថាខ្លួនជាព្រះឥន្ទ្រ ទើបព្រមឱ្យអាហារដល់សាមណេរឆាន់ ។ ជនទាំង៥នាក់បរិភោគស្រេចហើយ សាមណេរ ១អង្គទម្លាយនូវមណ្ឌលនៃហោជាង ១អង្គទម្លាយរងស្បូវមុខ ១អង្គទម្លាយរងស្បូវខាងក្រោយ ១អង្គទៀតមុជជ្រែកក្នុងដី ចំណែកព្រះឥន្ទ្រគិតថា អាត្មាអញនឹងចេញទៅតាមកន្លែងណា ? ជនទាំង៥នាក់នោះបានចេញទៅតាមកន្លែងផ្សេង១ពីគ្នា ។ ក៏តាំងពីពេលនោះមកផ្ទះនោះឈ្មោះ ថាជាផ្ទះមានប្រហោង៥ ។ កាលដែលសាមណេរទៅដល់វត្តវិញពួកភិក្ខុសួរថា " នែអាវុសោទាំងឡាយការណ៍នេះតើដូចម្ដេច ? ពួកសាមណេរទូលថា លោកម្ចាស់ទាំងឡាយកុំសួរខ្ញុំព្រះករុណា នាងព្រាហ្មណីគាត់ខឹងតាំងពីពេលដែលគាត់ឃើញខ្ញុំព្រះករុណាគាត់មិនឱ្យអង្គុយលើអាសនៈដែលគេក្រាលស្រេចហើយទេ គាត់ដេញឱ្យព្រាហ្មណ៍ជាប្ដីទៅរកព្រាហ្មណ៍ចាស់១ ដល់ព្រះឧបជ្ឈាយ៍មកឃើញខ្ញុំព្រះករុណា លោកគិតថា នាងព្រាហ្មណីបានប្រាហ្មណ៍ដែលអង្គុយនៅនេះគួរហើយ១ លោកចេញត្រឡប់

ទៅវិញទៅ នាងព្រាហ្មណីឱ្យទៅរកព្រាហ្មណ៍ចាស់ៗមកទៀត ប្តីគាត់ទៅនិមន្តព្រះមហាមោគ្គលានមកទៀត ដល់លោកមកដល់ឃើញខ្ញុំព្រះករុណា ក៏ពោលដូចព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាដែរ លំដាប់នោះឯងនាងព្រាហ្មណីនិយាយថា ព្រាហ្មណ៍ទាំងនេះមិនចង់ឆាន់ទេ ហើយប្រើប្តីគាត់ឱ្យទៅអញ្ជើញព្រាហ្មណ៍ចាស់ម្នាក់ អំពីរោងប្រជុំរបស់ពួកព្រាហ្មណ៍ ដល់ប្តីគាត់ទៅបានព្រះឥន្ទ្រដែលក្លែងខ្លួនជាព្រាហ្មណ៍ចាស់មក ទើបគាត់ព្រមឱ្យអាហារខ្ញុំព្រះករុណាឆាន់ ។ ពួកភិក្ខុសួរថាចុះបើគេធ្វើយ៉ាងនេះអ្នករាល់គ្នាមិនខឹងទេឬ ? ពួកសាមណេរឆ្លើយប្រាប់ថា ខ្ញុំព្រះករុណាឥតមានខឹងអ្វីបន្តិចបន្តួចទេ ។ ពួកភិក្ខុក៏នាំយករឿងនោះទៅក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ពួកសាមណេរទាំងនេះនិយាយមិនពិតថាខ្លួនមិនខឹង ពោលអួតគុណវិសេស ដែលគេមិនអាចដឹងបាន ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខណីស្រពមិនដែលខឹងសោះឡើយ ចំពោះជនដែលខឹងប្រទូសរ៉ាយចំពោះខ្លួនលោក ហើយទ្រង់ត្រាស់គាថាខាងក្រោមនេះ :

តថាគតហៅបុគ្គលអ្នកមិនខឹងតបចំពោះបុគ្គលដែលខឹង រំលត់ជនដែលមានអាជ្ញាចំពោះខ្លួន អ្នកមានសេចក្តីប្រកាន់មាំចំពោះជនដែលមានសេចក្តីប្រកាន់ថាជាព្រាហ្មណ៍ ។

## ១៧. រឿងយមកប្បាដិហារិយ៍

( ចាក ធ. ខុ.. )

*( អំនួតបួសប្រមាណ ជាគ្រឿងទំលាយបង់នូវចរិយាល្អ )*

រឿងរ៉ាវនេះកើតមានឡើងនៅក្រុងរាជគហៈ ។ សេដ្ឋីដំណាលថា ក្នុងសម័យមួយរាជគហសេដ្ឋី បានចាត់ចែងឱ្យគេយកសំណាញ់ទៅហ៊ុំព័ទ្ធកន្លែងលេងទឹកមួយ ដើម្បីការពារគ្រឿងអលង្កាកុំឱ្យរសាត់តាមទឹក និងការពារសេចក្ដីអន្តរាយណាមួយដែលកើតមានឡើង ។ លំដាប់នោះ មានឈើចន្ទន៍ក្រហមមួយដុំ មានសណ្ឋានប៉ុនក្អមអណ្ដែតតាមទឹកមកជាប់នឹងសំណាញ់ ។ សេដ្ឋីបានឱ្យគេស្រង់រើសយកទៅទុកឯផ្ទះ ។ ប៉ុន្តែសេដ្ឋីនោះជាមជ្ឈត្តិកជន មិនជាអ្នកសម្មាទិដ្ឋិ ឬមិច្ឆាទិដ្ឋិឡើយ គាត់បានគិតថា ខ្លឹមចន្ទន៍ក្នុងផ្ទះអញក៏មានច្រើនដែរ តើអញយកខ្លឹមចន្ទន៍នេះទៅធ្វើអ្វីទៀត គាត់គិតទៀតថា ក្នុងសម័យបច្ចុប្បន្ននេះ មានអ្នកបួសជាច្រើនបានដើរឃោសនាថា " យើងជាព្រះអរហន្ត ! យើងជាព្រះអរហន្ត ! គ្រប់ៗតែគ្នា ហើយអញមិនដឹងឱ្យជាក់ច្បាស់ថា តើពួកណាជាព្រះអរហន្ត ពួកណាមិនមែនជាព្រះអរហន្តទេ ? បើដូច្នោះអញនឹងជួលជាងឱ្យក្រឡឹងខ្លឹមចន្ទន៍នេះធ្វើជាបាត្រ ហើយចងព្យួរកំពស់ ៦០ហត្ថ រួចអញប្រកាសឃោសនាថា " បើលោកអង្គណាប្រាកដជាព្រះអរហន្តមែន សូមហោះមកតាមអាកាស ហើយយកបាត្រនេះចុះ យើងខ្ញុំព្រមទាំងបុត្រ និងថ្វាយខ្លួនជា

ឧបាសក-ឧបាសិកា " ។ សេដ្ឋីនោះបានជួលជាងឱ្យធ្វើតាមគំនិតដែលខ្លួនបានគិតទុក រួចប្រកាសឃោសនាដូចមានគំនិតមែន ។

ដំណើងនេះបានផ្សាយទូទៅពេញទីក្រុង និងខេត្រក្រៅ រហូតដល់ពួកមហាគ្រូ៦រូបមាននិគណ្ឋនាដបុត្រជាដើម ។ ហើយពួកគ្រូទាំងនោះទៅអង្វរសូមបាត្រពីសេដ្ឋី១ថា " នឹងប្រគេន ប្រសិនបើលោកអាចហោះតាមអាកាសបាន ? ។ និគណ្ឋនាដបុត្រអង្វរមហាសេដ្ឋីថា សព្វបើគ្រាន់តែបាត្រឈើប៉ុណ្ណឹង មិនបាច់ឱ្យយើងហោះតាមអាកាសមកយកទេ សូមលោកសេដ្ឋីប្រគេនតែម្ដងមក! ។ ទុកជាអង្វរយ៉ាងណាក្ដី រាជគហសេដ្ឋីនៅតែប្រកាន់ខ្ជាប់នូវពាក្យដដែល ។ ឯនិគណ្ឋនាដបុត្រព្រមទាំងកូនសិស្សគណោចេះតែលួងលោមអង្វរសេដ្ឋី១ នៅតែប្រកែកមិនព្រមប្រគេន។

ថ្ងៃមួយនិគណ្ឋនាដបុត្រ បានពិចារណាគ្នាថា " យើងសំដែងអាការៈដូចជាចង់ហោះឡើងព្ធដ៏អាកាស ហើយអ្នករាល់គ្នាប្រញាប់ចាប់ដៃយើងទាញហើយនិយាយថា លោកគ្រូ ! កុំបង្ហាញគុណវិសេសដល់សាធារណជន ព្រោះហេតុតែបាត្រឈើនេះ ព្រោះគុណវិសេសនេះ យើងបានមកដោយព្យាយាមមាំណាស់ ! ។ គិតគ្នារួចហើយ និគណ្ឋនាដបុត្រ ព្រមទាំងសិស្ស ក៏បានធ្វើដូចពាក្យសន្មតដែលខ្លួនបានកំណត់ទុក តែមិនអាចធ្វើឱ្យសេដ្ឋីប្រគេនបាត្របានឡើយ ។

និគណ្ឋនាដបុត្រនេះ ព្យាយាមសូមបាត្រសេដ្ឋីអស់រយៈវេលា ៦ ថ្ងៃ តែពុំបានសម្រេចសោះ ។

លុះដល់ថ្ងៃទី ៧ ព្រះមហាមោគ្គលានត្ថេរ នឹងបណ្ឌោលភារទ្វាជត្ថេរ រៀបចំឃ្លុំចីពរស្ពាយបាត្រ ដើម្បីទទួលបិណ្ឌបាត្រក្នុងរាជគហៈ បានឮពួករបាំនិយាយគ្នាថា " នែវើយគ្នាយើង ! កាលពីដើមគ្រូទាំង ៦ រូបដើរឃោសនាថា " ពួកយើងជាព្រះអរហន្ត ! ពួកយើងជាអ្នកបានសម្រេចនូវគុណវិសេសជាន់ខ្ពស់ " ដើម្បីសុំបាត្រខ្លឹមចន្ទន៍ពីរាជគហសេដ្ឋី តែរាជគហសេដ្ឋីបានប្រកាសថា " បើលោកអាចហោះតាមអាកាសមកយកបាន សូមលោកយកចុះ " ។ សេដ្ឋីបើកឃោសនាអស់វារៈ ៦ ថ្ងៃហើយ ឥឡូវថ្ងៃនេះជាថ្ងៃទី៧ មិនឃើញមានព្រះអរហន្តអង្គណាហោះមកយកបាត្រនេះសោះ ថ្ងៃនេះហើយជាថ្ងៃដែលបញ្ជាក់ឱ្យយើងដឹងថា ព្រះអរហន្តក្នុងលោកនេះមិនមានទេ" ។

ព្រះមហាមោគ្គលានត្ថេរ បានឮពាក្យដំណោះដំនៀលពីពួកអ្នករបាំហើយ មានពុទ្ធដីកាទៅនឹងបិណ្ឌោលការទ្វារជត្ថេរថា នែភារទ្វារជៈដ៏មានអាយុ ! លោកបានឮពួកអ្នករបាំទាំងនេះពោលពាក្យបោកបោះមកលើពុទ្ធសាសនា ឬទេ ? នែលោក ! លោកក៏មានឫទ្ធិច្រើន ខ្ញុំក៏មានឫទ្ធិច្រើន ចូរលោកហោះទៅយកបាត្រនោះមក ! " " នែអាវុសោមោគ្គលាន ! លោកជាច្បងជាងភិក្ខុអ្នកមានឫទ្ធិទាំងអស់ សូមលោកហោះទៅយក

បាត្រនុំះមក៏ បើលោកមិនទៅយក ខ្ញុំនឹងយកឥឡូវ " " អើភារទ្វាជះចូរលោកយកចុះ ! " ។ បិណ្ឌោភារទ្វាជត្ថេរ បានយកអភិញ្ញា ៦ បង្កើតឱ្យជាចត្ថុជ្ឈាន ហើយត្បៀតថ្មភ្នំមួយជុំទំហំបីគាវុត ហោះប្រទក្សិណក្រុងរាជគហៈអស់វារៈ៧ជុំ វិស័យដូចប៉ុយគរ ដែលប៉ើងតាមខ្យល់ ។ ដុំថ្មនោះហាក់ដូចជានឹងគ្របទីក្រុងទាំងមូលមិនឱ្យត្រូវពន្លឺព្រះអាទិត្យ ។ ពួកជនក្នុងក្រុងឃើញថ្មហាក់ដូចជានឹងធ្លាក់គ្របទីក្រុងទាំងមូល ក៏ស្រែកផ្អើលឆោឡោឡើងថា " ថ្មនឹងធ្លាក់សង្កត់យើងហើយ ! ថ្មនឹងធ្លាក់សង្កត់យើងហើយ ! " ពួកខ្លះយកចង្អេរគ្របក្បាលកូនចៅ ខ្លះចូលក្នុងរូងឈើ ខ្លះពួនក្រោមផ្ទះ ។ ឯព្រះបិណ្ឌោភារទ្វាជៈលុះហោះក្រឡឹងទីក្រុងបាន ៧ជុំផ្ចាត់ថ្មឱ្យទៅនៅកន្លែងដើមវិញ ហើយទើបបង្ហាញខ្លួន ។

ក្នុងគ្រានោះ ពួកមហាជនផ្អើលភ្លូកភ្លឹកឆោឡោ ដោយឃើញព្រះថេរៈ ទើបនិយាយអង្វរថា : " បពិត្រព្រះភារទ្វាជៈ សូមទានមេត្តាចាប់ថ្មឱ្យជាប់កុំទំលាក់លើយើងខ្ញុំព្រះករុណាឡើយ ! " ។ ព្រះថេរៈនិមន្តចុះលើដំបូលផ្ទះសេដ្ឋី សេដ្ឋីឃើញព្រះថេរៈបាននិយាយនិមន្តឱ្យចុះមកគង់ក្នុងផ្ទះ ប្រគេនចង្ហាន់មានរសជាតិ ៤មុខ ហើយឱ្យគេយកបាត្រខ្លឹមចន្ទន៍មកប្រគេនព្រះថេរៈ ។ ឯពួកមហាជនទាំងឡាយ ដែលមិនឃើញព្រះថេរៈសំដែងបាដិហារិយៈ ចេះតែអង្វរឱ្យលោកសំដែងបាដិហារិយៈឱ្យមើល ព្រះថេរៈក៏ចេះតែសំដែងបាដិហារិយៈឱ្យមើលជាលំដាប់ ។ ពួកមហាជន

ណាដែលពុំទាន់ឃើញ  ក៏ចេះតែដើរហែហមចោមរោមលោកអង្វរឱ្យព្រះថេរៈសំដែងទៀត ។ ដំណឹងនេះមិនស្ងប់ស្ងាត់ ក៏ចូលទៅដល់ព្រះស្រោតានៃព្រះអរហន្តសម្មាសម្ពុទ្ធ ។

ព្រះបរមសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកា នឹងព្រះអានន្ទថា  អានន្ទ! សំឡេងស្អីអ៊ូរអរម្ល៉េះ ? "  ព្រះអានន្ទក្រាបទូលថា បិណ្ឌោលភារទ្វាជត្ថេរសំដែងបដិហារិយហោះយកបាត្រខ្លឹមចន្ទន៍  ដែលរាជគហសេដ្ឋីព្យួរព្ឋដំអាកាស  ហើយពួកមហាជនចោមរោមចង់ឃើញបដិហារិយនេះទៀត" ។

ព្រះបរមគ្រូទ្រង់ព្រះសណ្ដាប់ដូច្នោះ  ទ្រង់ហៅព្រះបិណ្ឌោលភារទ្វាជៈមកសាកសួរសព្វគ្រប់ទ្រង់ត្អិះតិះដៀលដោយប្រការផ្សេងៗ ទើបទ្រង់បញ្ញត្តិសិក្ខាបទលែងឱ្យសាវកអង្គដទៃសំដែងបដិហារិយតទៅទៀត។ ឯពួកតិរ្ថិយឮថាព្រះបរមគ្រូបញ្ញត្តិសិក្ខាបទចំពោះសាវក  ពីរឿងធ្វើបាដិហារិយដូច្នោះ  តាំងដើរអាក្រោសឃោសនាបន្ទុះបង្អាប់ដោយប្រការផ្សេងៗ  ចំពោះពុទ្ធសាសមណ្ឌលថា  " ឥឡូវឮថាព្រះសមណគោតមបញ្ញត្តិសិក្ខាបទហើយពួកសាវក  នឹងមិនហ៊ានប្រព្រឹត្តល្មើសសិក្ខាបទនោះទេទាំងព្រះសមណគោតម ក៏មិនល្មើសកន្លងដោយព្រះអង្គឯងដែរនេះជាឱកាសល្អរបស់យើង ហើយសាវកព្រះសមណគោតមបង្ហាញធមិជាន់ខ្ពស់

ដល់មហាជន ព្រោះតែបាតឈើឯពួកយើងមិនធ្វើដូចសាវកព្រះសមណគោតមទេឥឡូវនេះពួកយើងនឹងធ្វើបាដិហារិយ ប្រជែងនឹងព្រះសមណគោតមគ្រានេះម្តង" ។

គ្រានោះព្រះរាជាព្រះនាមពិម្ពិសារទ្រង់ព្រះសណ្តាប់ការឃោសនារបស់ពួកតិរ្ថិយ ទ្រង់យាងទៅក្រាបទូលព្រះសាស្តាពីរឿងពួកតិរ្ថិយចង់ធ្វើបាដិហារិយប្រជែងនឹងព្រះអង្គ ព្រះសម្ពុទ្ធក៏ទ្រង់ទទួលថានឹងធ្វើផ្ចាញ់ផ្ចាលពួកតិរ្ថិយទាំងនោះដែរ តែព្រះចៅពិម្ពិសារទ្រង់ទូលសួរថា "ចុះក្រែងព្រះអង្គបញ្ញត្តិសិក្ខាបទមិនឱ្យសាវកធ្វើហើយ ព្រះអង្គនឹងធ្វើដូចម្តេចបាន ? " ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អើមហារាជ ! តថាគតសូមសួរមហារាជសិនថា មហារាជមានស្វាយមួយដើមក្នុងសួន ដែលមានផ្លែមិនដេសដាស ហើយប្រជារាស្ត្រព្រះអង្គបេះយកមកបរិភោគ តើព្រះអង្គមានដាក់ទណ្ឌកម្មដែរឬទេ ? ហើយបើមហារាជបេះសោយខ្លួនព្រះអង្គ តើគួរដាក់ទណ្ឌកម្មដែរឬ ? ព្រះបាទពិម្ពិសារទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន! បើខ្ញុំព្រះអង្គបេះសោយដោយខ្លួនឯងមិនមានទោសទេ តែបើប្រជារាស្ត្របេះវិញនោះ ទើបខ្ញុំព្រះអង្គត្រូវដាក់ទោស ។ បពិត្រមហារាជ! ពិតមែនហើយអំណាចរបស់ព្រះអង្គលាតក្រាលលើអាណាចក្របាន ៣០ យោជន៍ គឺព្រះអង្គមានអំណាចអាចដាក់ទណ្ឌកម្មដល់ប្រជារាស្ត្រណាម្នាក់ ដែលប្រព្រឹត្តល្មើសនឹងព្រះរាជបញ្ញត្តិ ដោយការបេះផ្លែស្វាយរបស់

ទ្រង់ទៅបរិភោគ ផ្ទុយទៅវិញ បើព្រះអង្គបេះមកសោយនោះ ពុំអាចដាក់ទណ្ឌកម្មខ្លួនឯងទេ រឿងនេះមានឧបមាដូចតថាគតដែរ គឺបើសាវកណាមួយប្រព្រឹត្តកន្លងសិក្ខាបទ ដែលតថាគតបញ្ញត្តិហើយ ត្រូវមានទោស រីឯតថាគតជាអ្នកបញ្ញត្តិមិនមានទោសទេ ដូច្នោះតថាគត អាចនឹងធ្វើបដិហារិយ ផ្ចាញ់ផ្ចាលពួកតិរ្ថិយទាំងនោះបាន មិនទាស់ខុសឡើយ ។

ឯពួកតិរ្ថិយឮថា ព្រះបរមសម្ពុទ្ធទ្រង់បញ្ញត្តិសិក្ខាបទចំពោះតែសាវកហើយព្រះអង្គនឹងធ្វើបដិហារិយដោយព្រះអង្គឯង ទើបប្រជុំគ្នាថា " ពួកយើងវិកវរហើយ ព្រោះព្រះសមណគោតមនឹងធ្វើបដិហារិយជាមួយយើង ។ តាំងពីនោះមកពួកតិរ្ថិយ ចេះតែដើរតាមប្រកិតជាប់នឹងព្រះសម្មាសម្ពុទ្ធយាងទៅបិណ្ឌបាត ក៏ដើរតាមទៅ ហើយប្រកាសឃោសនាថា ពួកខ្លួននឹងធ្វើបាដិហារិយប្រណាំងប្រជែងជាមួយព្រះសមណគោតម ។ រីពួកមហាជនដែលចង់ឃើញឫទ្ធិបារមី នៃពួកតិរ្ថិយ នឹងព្រះបរមសម្ពុទ្ធក៏ចេះតែដើរហែមហម ដើម្បីរង់ចាំមើលបាដិហារិយនេះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់កំណត់ថានឹងធ្វើបាដិហារិយ នៅក្រុងសាវត្ថីកំណត់៤ខែទៀត ។ លុះដល់ថ្ងៃកំណត់ថានឹងធ្វើហើយ ពួកតិរ្ថិយ បានអង្គាសឃោសនាឧបដ្ឋាករបស់ខ្លួនចំនួន ១000 រៀលមួយផ្ទះ ដើម្បីចាត់ចែងធ្វើរោងក្រសាលប្រក់ព្រំដោយគ្រឿងផ្កាគ្រប់យ៉ាង សំរាប់ធ្វើបាដិហារិយ ។ គ្រានោះព្រះចៅបសេនទិកោសល ឃើញពួកតិរ្ថិយធ្វើរោងក្រ

សាល ទើបចូលទៅទូលសួរព្រះសម្ពុទ្ធថា ទ្រង់នឹងធ្វើរោងសម្រាប់អង្គព្រះសម្ពុទ្ធធ្វើបាដិហារិយ តែព្រះអង្គទ្រង់ហាមឃាត់ ហើយទ្រង់សម្រេចព្រះទ័យថ្វាយព្រះចៅបសេនទិកោសលថា តថាគតនឹងធ្វើបាដិហារិយក្រោមដើមអម្ពព្រឹក្ស ក៏បបួលញោមញាតិសិស្សគណរបស់ខ្លួនកាប់រំលំដើមអម្ពរព្រឹក្សចោលអស់ ដោយហោចទៅសូម្បីតែឈើអម្ពព្រឹក្សនោះទើបនឹងដុះក្នុងថ្ងៃនោះ ក៏ដកចោលអស់ដែរ ។

ដល់ថ្ងៃកំណត់ថានឹងធ្វើបាដិហារិយ ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់ក្រុងសាវត្ថី នាថ្ងៃបុណ្ណមីខែអាសាធ បានជួបនឹងឧទ្យានបាល របស់ព្រះបាទពិម្ពិសារម្នាក់ឈ្មោះគណ្ឌៈ កំពុងកាន់ស្វាយដើរមកដោយបំណងថានឹងយកទៅថ្វាយព្រះបាទពិម្ពិសារ ។ ឧទ្យានបាលឈ្មោះគណ្ឌ បានជួបនឹងព្រះសាស្ដា គាត់គិតថា " បើអញយកស្វាយទុំនេះទៅថ្វាយស្ដេចៗប្រគល់រង្វាន់ឱ្យអញត្រឹមតែ ២៥ ឬ១៦ កហាបណៈប៉ុណ្ណោះ បើអញប្រគេនព្រះសាស្ដាវិញ ប្រហែលជាមានផលានិសង្សច្រើន" បើអញ្ចឹងអញនឹងប្រគេនព្រះសាស្ដាវិញចុះ ។ លុះគិតហើយ ទើបគណ្ឌៈបង្អោនស្វាយនោះប្រគេនព្រះសាស្ដា ។ ព្រះសាស្ដាទទួលហើយ ទ្រង់គង់ឱ្យអានន្ទច្របាច់ស្វាយត្រងធ្វើជាទឹកបានឆាន់ក្នុងវេលានោះ ។ ឆាន់រួចហើយព្រះបរមសាស្ដាទ្រង់បុចគ្រាប់ស្វាយទៅឱ្យឧទ្យានបាលគណ្ឌៈ ដោយព្រះពុទ្ធដិកាថា នែគណ្ឌ ! ចូរឯងកប់គ្រាប់ស្វាយក្នុងទីនេះចុះ គណ្ឌធ្វើតាម

ព្រះពុទ្ធដីកា រួចព្រះសាស្ដាទ្រង់ចាក់ទឹកលាងព្រះហស្ដលើគ្រាប់ស្វាយដែលកប់ហើយនុះ ។ ព្រះសាស្ដាដកព្រះហស្ដមិនទាន់ទាំងផុតពីនោះផង ស្រាប់តែគ្រាប់ស្វាយធ្លុះដុះចេញជាពន្លក ដើមប៉ុនក្បៀងនង្គ័លភ្លាម ហើយលូតធំឡើងជាលំដាប់ ដោយបារមីនៃព្រះអង្គ ។ មែកម្ខាងៗនៃស្វាយនោះមានប្រវែង៥០ហត្ថ ដែលមានស្លឹកម្លប់ទ្រឈឹងទ្រឈៃបែកមែកគ្រប់ទិស គឺមែកលយចេញទៅគ្រប់ទិសទាំង៤ នឹងដុះត្រង់ទៅលើមួយ ហើយចេញជាផ្កាផ្លែក្នុងមួយខណៈនោះភ្លាម ។ ឯពួកសាវកដែលនិមន្តតាមលំដាប់មុនក្រោយ ក៏បានឆាន់ផ្លែស្វាយទាំងនោះតាមលំដាប់ ។ ព្រះបាទពិម្ពិសារទ្រង់ជ្រាបពតិមាននោះ បានដាក់បញ្ញត្តិមិនឱ្យនរណាម្នាក់កាប់រំលំដើមស្វាយនោះឡើយ ។ ឯពួករបាំក៏បានស៊ីផ្លែស្វាយទាំងនោះដែរ ហើយស្រែកថា នែពួកតិរ្ថិយចង្រៃ អ្នកឯងចូរដើរឱ្យឆ្ងាយចេញ ! ព្រះសាស្ដាទ្រង់ធ្វើបាដិហារិយក្រោមដើមស្វាយនេះឯង ពួកអ្នកឯងចង្រៃណាស់ដើរដកកាប់រំលំស្វាយអស់គ្មានសល់ ដើម្បីកុំឱ្យព្រះអង្គធ្វើបាដិហារិយបាន ។

លំដាប់នោះ ព្រះឥន្ទ្របង្គាប់វលាហកទេវបុត្រឱ្យធ្វើជាខ្យល់បំបើងបារាំពួកតិរ្ថិយវិនាសអស់ ។ ព្រះសុរិយទេវបុត្រ បើកពន្លឺថ្ងៃយ៉ាងក្ដៅបញ្ចាំងលើពួកតិរ្ថិយទាំងនោះ ។ ពួកតិរ្ថិយមានញើសហូរចេញជាទឹក

ត្រូវប៉ះនឹងធូលីដែលហុយផង មានសភាពដូចជាគោបពាលខ្ទង បែកបាក់គ្នាខ្ចាត់ខ្ចាយរត់រកច្រកតែរៀង១ខ្លួន ។

លំដាប់នោះមនាកសិករម្នាក់ជាឧបដ្ឋាករបស់គ្រូឈ្មោះបូរណកស្សបៈបានគិតថា ឥឡូវនេះជាកាលអញត្រូវធ្វើបាដិហារិយហើយអញនឹងទៅមើលពិធី បាដិហារិយលោកគ្រូអញ " រួចស្រាយគោលែងកាន់ខ្សែនឹងឆ្នាំងបបរដើរតម្រង់ទៅកន្លែងធ្វើបាដិហារិយ ស្រាប់តែជួបនឹងគ្រូបូរណបស្សបៈកំពុងរត់តាមផ្លូវ ទើបសួរថា លោកគ្រូ១ ! លោកគ្រូរត់ទៅណា ? ខ្ញុំមកក្នុងទី នេះប៉ងថានឹងមើលពិធីបាដិហារិយរបស់លោកគ្រូ ចុះលោកគ្រូរត់ទៅណា មិនបានធ្វើបាដិហារិយទេឬ ? " ។ បូរណកស្សបៈតបថាមានប្រយោជន៍អ្វីដោយការធ្វើបាដិហារិយនោះ ចូរអ្នកឯងឱ្យខ្សែ នឹងឆ្នាំងបបរមកអាត្មា កសិករជាឧបដ្ឋាក ក៏ប្រគេនឆ្នាំ នឹងខ្សែនោះទៅ ។ បូរណកស្សបៈ ទទួលយកខ្សែនឹងឆ្នាំងបបរហើយ ដើរសំដៅទៅកំពង់ទឹកយកខ្សែម្ខាង ចងភ្ជាប់នឹងកឆ្នាំង ចុងខ្សែម្ខាងទៀតចងភ្ជាប់នឹងកខ្លួន រួចប្រមៀលទម្លាក់ទៅក្នុងទឹក ។ ឯឆ្នាំងត្រូវទឹកចូលពេញ ក៏ទាញបូរណកស្សបៈឱ្យជ្រមុជចុះដល់នូវជីវិតក្ស័យ ក្នុងគ្រានោះឯង ។

ឯព្រះបរមសាស្តាទ្រង់និម្មិតទីចង្ក្រម ដ៏មានចុងម្ខាងគ្របដល់កណ្តាប់ចក្រវាឡខាងកើត ម្ខាងទៀតដល់កណ្តាប់ចក្រវាឡខាងលិច

ឱ្យទៅជាម្លប់សម្រាប់ពុទ្ធបរិស័ទ រួចទ្រង់យាងចេញពីគន្ធកុដិឆ្ពោះទៅកាន់ទីចង្ក្រមនោះដោយព្រះទ័យថា ពេលនេះជាពេលគួរធ្វើបាដិហារិយហើយ" ។

ក្នុងពេលនោះ មានអនាគាមិឧបាសិកាមួយរូបឈ្មោះឃរណី ចូលទៅថ្វាយបង្គំព្រះបរមសាស្តាសុំធ្វើបាដិហារិយជំនួស ដើម្បីកុំឱ្យព្រះអង្គលំបាកព្រះកាយ ។ ព្រះសាស្តាទ្រង់សួរថា ចុះនាងនឹងធ្វើពិធីបាដិហារិយយ៉ាងណា ? នាងឆ្លើយថា ខ្ញុំព្រះអង្គនឹងធ្វើផែ្ទចក្រវាឡទាំងមូលឱ្យទៅជាទឹក ហើយខ្ញុំព្រះអង្គនឹងមុជចុះក្នុងទឹកឱ្យដូចជាសកុណើទឹក ពីមាត់ចក្រវាឡខាងលិច ទៅផុសនៅកណ្តាប់មាត់ចក្រវាឡខាងកើត មុជពីខាងជើងទៅផុសខាងត្បូង កាលបើមហាជនឃើញហើយ នឹងនឹកស្ងើចដល់ខ្ញុំព្រះអង្គថា គ្រាន់តែសាវិការបស់ព្រះអង្គមានឫទ្ធិ មានអានុភាពម្លឹងទៅហើយ ចុះចំណង់បើព្រះអង្គវិញ នឹងមានឫទ្ធិអានុភាពយ៉ាងណាទៅ ? " ឯពួកតិរ្ថិយកាលបើឃើញដូច្នេះ មុខជានឹងបាក់បបខ្លួបខ្លាចអំណាចរត់ខ្ចាត់ខ្ចាយអស់ពុំខាន ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់មិនអនុញ្ញាតឱ្យ ។ តពីនោះមកមានសាវក សាវិកា ជាច្រើនបានសុំសេចក្តីអនុញ្ញាតធ្វើបាដិហារិយពីអង្គព្រះសម្ពុទ្ធ ដូចជា ចូឡអនាថបិណ្ឌិក នាងវីរសាមណេរីព្រះជន្ម៧ឆ្នាំ ចុន្ទសាមណេរព្រះជន្ម៧ឆ្នាំ ព្រះបរមសាស្តាទ្រង់សួរតាមលំដាប់ ពួកសាវកទាំងនោះ ក៏ឆ្លើយទូលពុទ្ធដីកាតាមការប៉ុនប្រសប់រៀងៗ

ខ្លួន ។ ចុងក្រោយបំផុត ព្រះមហាមោគ្គល្លានត្ថេរចូលសុំធ្វើដែរ ព្រះសាស្ដាទ្រង់សួរថាអ្នកធ្វើដូចម្ដេច ? ព្រះមហាមោគ្គល្លានទូលថា ខ្ញុំព្រះអង្គនឹងយកភ្នំនេរុរាជមកដាក់ត្រង់ចន្លោះធ្មេញ រួចទំពារស៊ីដូចជាបុគ្គលទំពារស៊ីគ្រាប់ល្ពៅ មួរមហាផែនដីដូចជាកន្ទេលរវែង ចាប់ផែនដីបង្វិលឱ្យដូចជាកងចក្រ ជាវិការៈនៃដី រួចដាក់មហាផែនដីលើបាតដៃឆ្វេង ដាក់សត្វលោកបាតដៃខាងស្ដាំ រួចយកភ្នំសិនេរុរាជធ្វើជាដងឆត្រទ្រមហាផែនដីធ្វើឱ្យទៅជាឆត្របាំងលើសត្វទាំងអស់ រួចខ្ញុំព្រះអង្គដើរចង្ក្រម ឱ្យដូចជាភិក្ខុមួយអង្គបាំងឆត្រដើរចង្ក្រមដូច្នោះ ។ ព្រះបរមគ្រូទ្រង់ហាមឃាត់ថាតថាគតដឹងថាអ្នកទាំងអស់គ្នាមានអានុភាពច្រើនហើយ តែតថាគតមិនអនុញ្ញាតឱ្យទេ ព្រោះភារៈនេះតែងកើតមានដល់ព្រះពុទ្ធតាំងពីបុរាណកាលមក ។ លុះមានពុទ្ធដិកាចប់ហើយ ព្រះអង្គទ្រង់យាងទៅកាន់ទីចង្ក្រមដែលមានពុទ្ធបរិស័ទ២៤យោជន៍ជុំវិញ ចោមរោមចាំមើលពិធីបាដិហារិយ ពិធីសំដែងបាដិហារិយ ក៏បានចាប់ផ្ដើមឡើង ។

បុច្ឆា ចុះពុទ្ធញ្ញាណដ្រលប្រព្រឹត្តទៅក្នុងពិធីបាដិហារិយនោះមានសភាពដូចម្ដេច ?

វិសជ្ជនាថា ញាណរបស់ព្រះតថាគតក្នុងពិធីសម្ដែងបាដបាហារិយនេះ មិនសាធារណ៍ដល់ពួកសាវកទេ ព្រោះថាពិធីធ្វើបាដិហារិយនេះកើត

មានតែមួយដងៗ សម្រាប់ព្រះពុទ្ធគ្រប់អង្គ ព្រោះហេតុនោះពួកសាវក សាវិកាពុំអាចធ្វើបានឡើយ គឺមានសភាពដូចតទៅនេះ :

គំនរភ្លើងចេញពីព្រះកាយខាងលើ ទរទឹកចេញពីព្រះកាយខាងក្រោម គំនរភ្លើងចេញពីព្រះកាយទរទឹកចេញពីព្រះកាយខាងលើ គំនរភ្លើងចេញពីព្រះកាយខាងក្រោម ទរទឹកចេញពីព្រះកាយខាងមុខ គំនរភ្លើងចេញពីព្រះកាយខាងស្តាំ ទរទឹកចេញពីព្រះកាយខាងឆ្វេង គំនរភ្លើងចេញពីព្រះកាយខាងឆ្វេង ទរទឹកចេញពីព្រះកាយខាងស្តាំ គំនរភ្លើងចេញពីរន្ធព្រះកាណ៍ខាងស្តាំ ទរទឹកចេញពីរន្ធព្រះការណ៍ខាងឆ្វេង គំនរភ្លើងចេញពីរន្ធព្រះកាណ៍ខាងឆ្វេង ទរទឹកចេញពីរន្ធព្រះការណ៍ខាងស្តាំ គំនរភ្លើងចេញពីព្រះនាសាខាងស្តាំ ទរទឹកចេញពីព្រះនាសាខាងឆ្វេង ទរទឹកចេញពីព្រះនាសាខាងស្តាំ គំនរភ្លើងចេញពីស្មាខាងឆ្វេង ទរទឹកចេញពីស្មាខាងឆ្វេង គំនរភ្លើងចេញពីស្មាខាងស្តាំ ទរទឹកចេញពីស្មាខាងស្តាំ គំនរភ្លើងចេញពីព្រះហស្តស្តាំ ទរទឹកចេញពីព្រះហស្តឆ្វេង គំនរភ្លើងចេញពីព្រះហស្តឆ្វេង ទរទឹកចេញពីព្រះហស្តស្តាំ គំនរភ្លើងចេញពីព្រះបាទស្តាំ ទរទឹកចេញពីព្រះបាទឆ្វេង គំនរភ្លើងចេញពីព្រះបាទឆ្វេង ទរទឹកចេញពីព្រះបាទស្តាំ ព្រះរស្មីប្រាំមួយពណ៌ គឺ ខៀវ លឿង ក្រហម ស ហង្សបាទនឹងភ្លឺផ្លេកផ្សាយចេញពីសរីរៈទាំងមូល ទ្រង់និម្មិតជាព្រះពុទ្ធបីអង្គទៀតគឺ

ព្រះមានព្រះភាគទ្រង់ចង្ក្រម ព្រះពុទ្ធដែលទ្រង់និម្មិតឈរ អង្គុយនឹងសឹង បើព្រះមានព្រះភាគទ្រង់សឹង ព្រះពុទ្ធនិម្មិតឈរ អង្គុយចង្ក្រម ។

នេះជាពុទ្ធញ្ញាណក្នុងការសំដែងបាដិហារិយ ។ ក្នុងការសំដែងបាដិហារិយនេះគំនរភ្លើង នឹងទរទឹកឥតមានការច្រឡូកច្រឡំគ្នាទេ គឺគំនរភ្លើង ហើយនឹងទរទឹកផ្លាស់គ្នាចេញពីព្រះកាយខាងស្តាំម្តង ខាងឆ្វេងម្តង ហើយលាតត្រដាងរហូតដល់កណ្តាប់នៃចក្រវាឡទាំងមូល ។

មហាជនដែលឈរត្រៀបត្រាមានចំនួន ២៤យោជន៏ជុំវិញ បានឃើញបាដិហារិយ ដ៏អស្ចារ្យដូច្នោះហើយ បានថ្វាយសព្ទសាធុការចំពោះព្រះបរមគ្រូយ៉ាងអនេកកប្បការ ។ ក្នុងពេលសំដែងបាដិហារិយ ព្រះបរមគ្រូឆ្លៀតឱកាសសំដែងធម្មទេសនាប្រោសសត្វផង ។ ធម្មាភិសម័យ គឺការត្រាស់ដឹងនូវធម៌ ក៏បានកើតប្រាកដដល់មហាជនក្នុងឱកាសនោះ ។

ឯពួកនិគ្រន្ថអន្យតិរ្ថិយ កាលបើឃើញឫទ្ធិចេស្តានៃព្រះបរមគ្រូហើយ បែរជាបាក់បបខ្លបខ្លាចអំណាចបារមីនៃព្រះអង្គ ព្រមចុះចាញ់ក្នុងពេលនោះហោង ។

លុះពិធីសំដែងបាដិហារិយ បានចប់សព្វគ្រប់ហើយ ព្រះពុទ្ធង្គូរបណ្តួលសាស្តាទ្រង់ប្រមើលថា ព្រះពុទ្ធបូរាណកាលបើបានធ្វើបាដិហារិយរួចហើយ តែងគង់ចាំវស្សាក្នុងទីណាអេះ ! ? ទ្រង់ជ្រាបថា តាមធម្មតាបើធ្វើបាដិហារិយ ព្រះពុទ្ធគ្រប់ព្រះអង្គតែងយាងទៅគង់ចាំវស្សានា

តាវតឹង្សភព ដើម្បីសំដែងព្រះអភិធម្មបិដកប្រោសពុទ្ធមាតា ។ លុះទ្រង់រំពឹងដូច្នេះហើយ ទ្រង់ក៏លើកព្រះបាទខាងស្តាំដាក់ជាន់លើកំពូលភ្នំយុគន្ធរ ព្រះបាទឆ្វេងដាក់ជាន់លើកំពូលភ្នំសិនេរុ ។ គេសួរថា ចុះភ្នំស្ថិតនៅឆ្ងាយៗម្ល៉េះ ហេតុម្តេចក៏ព្រះសម្មាសម្ពុទ្ធទ្រង់ឈានជាន់បាន ? ឆ្លើយថា ដោយអំណាចនៃឫទ្ធានុភាព និងបារមីរបស់ព្រះអង្គ ទើបភ្នំទាំងអស់ទទួលទ្រព្រះបាទ នៅពេលដែលព្រះអង្គលើកព្រះបាទជាន់លុះឈានផុតទៅ ទើបភ្នំទាំងនោះទៅឋិតនៅទីដើមវិញ ។

កាលដែលអង្គព្រះបរមគ្រូយាងផុតទៅ ពួកពុទ្ធបរិស័ទមានការសោកស្តាយទន្ទក់ទន្ទេញរលឹកព្រះអង្គ ដោយខ្សឹកខ្សួលជាបទគាថាថា " គួរស្តាយណាស់ហ្ន៎ ! ព្រះសម្ពុទ្ធទ្រង់យាងជាន់លើភ្នំគិជ្ឈកូដ ភ្នំកៃលាស និងភ្នំយុគន្ធរទៅផុតហើយ យើងខ្ញុំលែងបានឃើញព្រះអង្គជាច្បងលើលោកទៀតហើយ ! ។

ឯព្រះបរមលោកនាថទ្រង់គង់ក្នុងកណ្តាលទេវបរិស័ទសំដែងអភិធម្មបិដកប្រារព្ធគុណព្រះមាតា មានបទដើមថា " កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ធម៌ទាំងឡាយជាកុសល ធម៌ទាំងឡាយជាអកុសល ធម៌ទាំងឡាយជាអព្យាក្រិត " ។ ទ្រង់សំដែងតែអភិធម្មបិដកនេះអស់វារៈ៣ខែគត់ ។ លុះដល់តិថី ១៤កើតខែអស្សុជជាថ្ងៃបវារណាចេញព្រះវស្សា ព្រះបរមពុទ្ធង្កូរទ្រង់មានព្រះបន្ទូលទៅនឹងសក្កទេវរាជថា

បពិត្រមហារាជ ! ថ្ងៃនេះជាថ្ងៃត្រូវបវារណា ចេញវស្សាហើយតថាគត នឹងត្រូវចុះទៅកាន់មនុស្សថានវិញហើយ " ។ សក្កទេវរាជក៏បាននិម្មិតជណ្ដើរ ៣ សម្រាប់ចុះចាកឋានតាវតឹង្ស គឺជណ្ដើរមួយនិម្មិតអំពីមាស ជណ្ដើរមួយនិម្មិតអំពីកែវមណី នឹងជណ្ដើរមួយទៀតនិម្មិតអំពីប្រាក់ ដែលសុទ្ធតែមានជើងតំកល់នៅទៀបទ្វារសង្កស្សនគរ នឹងក្បាលដំកល់លើកំពូលភ្នំសិនេរុ ។ បណ្ដាជណ្ដើរទាំងបីនោះ ជណ្ដើរមាសសម្រាប់ពួកទេវតា ជណ្ដើរប្រាក់សម្រាប់ពួកមហាព្រហ្ម និងជណ្ដើរកែវសម្រាប់ព្រះតថាគត ។ សេចក្ដីអស្ចារ្យថា កាលព្រះអង្គយាងចុះពីឋានតាវតឹង្ស ទ្រង់ប្រថាប់លើកំពូលភ្នំសិនេរុ សម្ដែងបាដិហារិយ ដើម្បីយាងចុះមកទ្រង់ញ៉ាំងព្រហ្មលោក ទេវលោក មនុស្សលោក អវិចិមហានរក និងចក្រវាឡទាំងអស់ឱ្យមានការភ្លឺស្វាង អាចមើលគ្នាទៅវិញទៅមកឃើញ ។

ក្នុងព្រះរាជដំណើរយាងចុះមកនេះ ពួកបញ្ចសិខគន្ធព្វទេវបុត្រ ដែលស្ទាត់ជំនាញខាងតន្ត្រី បានប្រគំដូរ្យតន្ត្រីបូជាព្រះអង្គនៅខាងស្ដាំ មាតលិសង្គាហកទេវបុត្របូជាផ្កា និងគ្រឿងក្រអូបនៅខាងឆ្វេង មហាព្រហ្មបាំងក្លស់ថ្វាយ និងសុយាមៈកាន់ផ្លិតបក់ថ្វាយ ។ ការយាងចុះពីឋានតាវតឹង្សប្រកបដោយពុទ្ធសិរីឥតបីប្រៀប ដ៏មានពួកទេវតាជាបរិវារចោមរោមហែហមរហូតដល់ទ្វារនគរសង្កស្សៈ ។

ឯព្រះសារីបុត្តត្ថេរ និមន្តទៅថ្វាយបង្គំព្រះសាស្តារួចពោលសរសើរអំពីពុទ្ធសិរីដូចនេះថា " កាលពីមុនខ្ញុំមិនធ្លាប់បានឃើញពុទ្ធសិរីព្រះអង្គទេ ទាំងសម្លេងក៏ពុំធ្លាប់បានស្តាប់ ឯព្រះសាស្តាព្រះអង្គមានសម្លេងដូចព្រហ្មយ៉ាងនេះ ទ្រង់យាងចុះហើយពីឋានត្រៃត្រឹង្សមកកាន់មនុស្សលោកដោយពុទ្ធដំណើរដ៏មានសិរី " រួចក្រាបទូលអង្គតថាគតថា បពិត្រព្រះចមមកុដបំផុតលោក ថ្ងៃនេះពួកមនុស្ស នឹងទេវតាទន្ទឹងមើលផ្លូវព្រះអង្គគ្រប់ៗគ្នា ។ លំដាប់នោះព្រះបរមសាស្តាទ្រង់ត្រាស់ថា អើសារីបុត្រ ! ជាការធម្មតាទេ ព្រោះទេវតា នឹងមនុស្សតែងស្រឡាញ់ ឬប្រាថ្នាឱ្យតែបានជួបនឹងអ្នកប្រាជ្ញ ដែលមានគុណសម្បត្តិរបៀបនេះឯង " រួចទ្រង់សំដែងធម្មទេសនាថា

នរណាមួយជាអ្នកប្រាជ្ញ មានការខ្វល់ខ្វាយតែក្នុងឈាន ត្រេកអរតែក្នុងនេក្ខម្មៈ ទេវតានឹងមនុស្សតែងប្រាថ្នាចង់បានចង់ជួបនឹងអ្នកនោះឯង ដែលមានប្រាជ្ញាត្រាស់ដឹងព្រមទាំងស្មារតី ។

លុះចប់ធម្មទេសនា ពុទ្ធបរិស័ទទាំង៤ ក៏បានសំរេចនូវធម៌ជាន់ខ្ពស់គ្រប់ៗគ្នាក្នុងពេលនោះហោង ។

# ១៨. រឿងទីឃាវុកុមារ

( ចាក ធ. ខុ.. )

*( សេចក្តីអត់ធន់ អាចសម្រេចប្រយោជន៍គ្រប់យ៉ាង )*

កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ដែនកាសី ព្រះបាទទីឃីតិគ្រងរាជសម្បត្តិក្នុងក្រុងសាវត្ថីដែនកោសល ។ គ្រានោះព្រះបាទព្រហ្មទត្តលើកពលទៅវាយក្រុងសាវត្ថីបាន។ ព្រះបាទទីឃីតិនាំព្រះអគ្គមហេសីទៅនៅអាស្រ័យនឹងស្មូនឆ្នាំងម្នាក់ក្នុងប្រទេស១ ជាទីបំផុតដែន ។

ចំណេរមកខាងក្រោយ ព្រះអគ្គមហេសីមានព្រះរាជបុត្រ សន្មតព្រះនាមថា " ទីឃាវុកុមារ " ។ វេលាមួយ ព្រះបាទព្រហ្មទត្តចាប់ព្រះបាទទីឃីតិបាន ក៏ឱ្យពេជ្ឈឃាតនាំទៅសម្លាប់ គេកំពុងបណ្តើរទៅ ទីឃាវុមកទាន់ ។ ព្រះបាទទិឃីតិទ្រង់ប្រដៅព្រះរាជបុត្រថា " នែទីឃាវុ ! អ្នកកុំឃើញកាលវែងពេក ខ្លីពេក ធម្មតាពៀរមិនដែលរម្ងាប់ដោយពៀរទេ ពៀរតែងរម្ងាប់ដោយការមិនចងពៀរ " ទ្រង់ផ្តាំស្រេច ពេជ្ឈឃាតក៏សម្លាប់ទៅ ។

ថ្ងៃក្រោយ ទីឃាវុត ចូលថ្វាយខ្លួនជាខ្ញុំរាជការយ៉ាងជិតដិតនឹងព្រះបាទព្រហ្មទត្ត ។ សម័យ១ព្រះបាទព្រហ្មទត្តទ្រង់ស្តេចយាងទៅប្រពាតព្រៃ ឱ្យទីឃាវុធ្វើជានាយសារថីបររាជរថ ។

ទីឃាវុបានឱកាស ក៏ប្រឹងបររាជរថបង្ហួសទៅមុនពួកពលសេនា ដោយប្រាថ្នានឹងសម្លាប់ព្រះបាទព្រហ្មទត្តនោះ ។ វេលានោះព្រះបាទព្រហ្មទត្តទ្រង់ផ្ទំលើភ្លៅទីឃាវុ ដោយសេចក្ដីនឿយព្រួយព្រះកាយពល កំពុងតែផ្ទំស្កប់ ទីឃាវុចាប់ព្រះខ័នលើកឡើងប្រាថ្នានឹងសម្លាប់ តែនឹកភ្នកដល់បណ្ដាំព្រះបិតាក៏ឈប់ទៅវិញ គ្រាន់តែស្រែកសន្ធាប់ឱ្យព្រះបាទព្រហ្មទត្តជ្រាបថាជាបុត្រព្រះបាទទីឃីតិប៉ុណ្ណោះ ។ គ្រានោះក្សត្រិយ៍ទាំង២ព្រះអង្គទ្រង់បានឱ្យជីវិតដល់គ្នានឹងគ្នា ហើយទ្រង់ស្ដេចត្រឡប់ទៅព្រះនគរ ។ ព្រះបាទព្រហ្មទត្តបង្វែរក្រុងសាវត្ថីប្រទានមកទីឃាវុវិញ ព្រមទាំងប្រទានរាជធីតាឱ្យជាអគ្គមហេសី ។

លុះតមកខាងក្រោយ ព្រះបាទទីឃាវុបានគ្រងរាជ្យជាធំក្នុងដែនទាំង២ គឺ ដែនកាសី និងដែនកោសល ។

## ១៩. រឿងប្រេតញីស៊ីកូនម្ដង៥

( បេ. ខុ.. )

*( ការស្បថទាំងបំពាន មានផលដូចសម្បថ )*

កាលអង្គសម្ដេចព្រះបរមសាស្ដា ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថក្នុងក្រុងសាវត្ថី មានប្រេតញីមួយរូបស៊ីកូនឯងម្ដង៥ ។ កាលពីអតីតជាតិ ប្រេតញីនោះជាស្ត្រីមួយរូបដែលត្រូវជាភរិយាកុដុម្ពីម្នាក់ក្នុងក្រុងសាវត្ថីនោះដែរ តែនាងជាស្ត្រីអាឥតកូនម្នាក់សោះ ។ ថ្ងៃមួយពួក

ញាតិទាំងឡាយ និយាយទៅកាន់កុដុម្ពីនោះថា ភរិយារបស់អ្នកឯងជាស្ត្រីអាឥតកូនមួយសោះ ចូរឯងរកភរិយាដទៃមកក្រែងមានកូន នឹងបានតពូជពង្សវង្សត្រកូលទៅទៀត ។ ឯភរិយាក៏និយាយទៅកាន់កុដុម្ពីនោះដែរថា ខ្ញុំជាស្ត្រីអាគ្មានកូនទេ ពូជពង្សវង្សត្រកូលមុខជានឹងត្រូវរលត់ផុតត្រឹមនេះហើយ ដើម្បីបន្តពូជរបស់អ្នកឯងឱ្យបានវែងឆ្ងាយ ចូរអ្នករកភរិយាមួយមកទៀតចុះ ។ កុដុម្ពីដោយឃើញថាភរិយារបស់ខ្លួនយល់ព្រមឱ្យយកប្រពន្ធមួយទៀត ក៏ទៅស្ដីដណ្ដឹងនាងកុមារិកាម្នាក់មកជាភរិយា ។ ភរិយាក្រោយនេះនៅរួមជាមួយកុដុម្ពីមិនយូរប៉ុន្មាន គភ៌ក៏កើតប្រាកដឡើង ។ ឯស្ដ្រីអាបានឃើញនាងកុមារិកានោះមានគភ៌ដូច្នោះបែរជាគិតថា " នាងនេះមានកូន អំណើះទៅនឹងត្រូវបានជាមេផ្ទះធំត្រួតលើអញពុំខានធម្មតាមនុស្សដែលនៅក្រោមអំណាចអ្នកដទៃ ពុំដែលសប្បាយចិត្តក្នុងកាលណាម្ដងឡើយ បើដូច្នេះគួរអញធ្វើឧបាយណាមួយ ដើម្បីពន្លូតគភ៌នាងនេះចេញ " ។ គិតហើយនាងក៏បានជួលបរិព្វាជកម្នាក់ដែលប៉ិនប្រសប់ខាងផ្សំថ្នាំសម្រាប់ពន្លូតគភ៌ ។ លុះបរិព្វាជកផ្សំថ្នាំរួចយកមកឱ្យនាងបានទាំងផ្ដាំថា " ចូរនាងយកថ្នាំនេះដាក់លាយនឹងបាយឱ្យស៊ី គភ៌នឹងរលូតធ្លាក់ហើយ " ស្ត្រីនោះធ្វើតាមបណ្ដាំបរិព្វាជក ក៏បានសម្រេចដូចបំណងមែន ។ កាលដែលគភ៌ធ្លាក់ផុតទៅ នាងកុមារិកានោះ ក៏និយាយរឿងរ៉ាវប្រាប់ដល់ស្វាមី ម្ដាយ និងញាតិទាំងអស់របស់ខ្លួន អំពីគំនិត

អាឃាដព្យាបាទរបស់ស្ត្រីអានោះ ឯពួកញាតិបានស្តីបន្ទោសស្រីអានោះជាច្រើន តែស្រីអានោះជជែកពុំព្រមទទួលសារភាពថាខ្លួនបានធ្វើអំពើអាក្រក់ដូច្នោះឡើយ ហ៊ានស្បថទាំងបំពានថា បើនាងហើយបានធ្វើអំពើអាក្រក់ដូច្នោះមែន សូមឱ្យធ្លាក់រងទុក្ខវេទនាក្នុងនរក រួចពីនោះមកកើតជាប្រេតស៊ីតែកូនឯង សូមឱ្យអត់បាយក្រហាយទឹក ឱ្យមានខ្លួនធំក្លិនស្អុយរុយរោមជានិច្ច ។ ដោយអំណាចបាបកម្ម ដ៏គួរឱ្យខ្ពើមរអើមនេះ លុះរំលាយកាយទៅ ស្ត្រីអានោះក៏ធ្លាក់ទៅសោយទុក្ខក្នុងនរក រួចបានត្រឡប់ពីនរកមកកើតជាប្រេតញីអាស្រ័យនៅក្បែរភូមិនោះ ។

កាលនោះមានព្រះថេរៈ៨អង្គគង់ចាំវស្សានៅក្នុងជនបទមួយ លុះចេញវស្សា ក៏និមន្តចូលទៅក្រុងសាវត្ថី ដើម្បីនមស្សការព្រះបរមគ្រូ បានចេញពីផ្លូវចូលទៅសម្នាក់អាស្រ័យក្នុងព្រៃរបោះមួយកន្លែង ដ៏ប្រកបដោយម្លប់សែនត្រជាក់ មានទឹកថ្លាឆ្វង់មើលឃើញដី ។ ឯប្រេតញីនោះបានសំដែងកាយឱ្យព្រះថេរៈទាំងឡាយនោះឃើញ ទើបព្រះសង្ឃត្ថេរៈ៧អង្គទៀតបានឃើញ ហើយសូត្រជាបទគាថាថា

" នាងគ្មានសំពត់ស្លៀក មានខ្លួនអាក្រក់ក្រៃ មានក្លិនស្អុយអសោចិ មានរុយរោមពេញទាំងខ្លួន មកនៅអាស្រ័យក្នុងព្រៃនេះ ព្រោះធ្វើកម្មដូចម្តេច ?

នាងប្រេតនោះ តបនឹងថេរៈដីការបស់ព្រះសង្ឃត្ថេរ អំពីអំពើអាក្រក់លាមក ដែលខ្លួនបានធ្វើ ដោយបញ្ជាក់ថា ខ្ញុំធ្លាក់ទៅសោយទុក្ខក្នុងនរក រួចបានមកកើតជាប្រេតក្នុងទីនេះ ក្នុងវេលាព្រឹកខ្ញុំរលូតកូន៥មក ហើយខ្ញុំស៊ីអស់ទៅ វេលារសៀលរលូត៥ទៀត ស៊ីអស់ទៀតទៅ ទុកជាខ្ញុំស៊ីដូច្នេះ ក៏នៅតែពុំអាចចំអែតផ្ទៃខ្ញុំម្ចាស់បាន ក្នុង២ត្ដខ្ញុំម្ចាស់វិញ មានសេចក្ដីស្រេកឃ្លាន ក្តៅក្រហល់ក្រហាយ ពុំដែលបានអាហារ ដ៏មានរសជាតិទទួលទានម្ដងណាឡើយ ដូចព្រះអង្គបានជ្រាបស្រាប់ហើយ ខ្លួនខ្ញុំធំក្លិនអសោចិ មានរុយរោមពេញទាំងខ្លួន ។ ព្រះថេរៈដណ្ដឹងសួរទៀតថា នាងធ្វើកម្មដូចម្ដេច បានជាត្រូវត្រឡប់ស៊ីកូនឯងវិញ ? នាងប្រេតទូលតបថា បពិត្រព្រះករុណាម្ចាស ! កាលពីអតីតជាតិ ខ្ញុំម្ចាស់នេះជាស្ត្រីអារូមស្វាមីជាមួយនាងកុមារិកាម្នាក់ជាប្រពន្ធចុង ក្រោយមកនាងកុមារិកាមានគភ៌ ខ្ញុំម្ចាស់មានចិត្តឫស្យាច្រណែនឈ្នានីសព្យាយាមធ្វើឱ្យគភ៌របស់នាងនោះរលូតគ្រាតែសម្រេចដូចបំណង ។ ឯមាតាស្វាមី ព្រមទាំងញាតិបានស្ដីជេរបន្ទោសខ្ញុំម្ចាស់ដោយប្រការផ្សេងៗ ខ្ញុំម្ចាស់ក៏ប្រើមុសាវាទបំពានស្បថថា បើខ្ញុំម្ចាស់បានធ្វើឱ្យគភ៌នាងរលូតមែន សូមឱ្យខ្ញុំស៊ីតែកូនឯងក្នុងបួយថ្ងៃដប់កុំឱ្យសល់ខាន ឱ្យរុយរោមពេញទាំងខ្លួន មានក្លិនស្អុយអសោចិអស់កាលជានិច្ច ។ វិបាកនៃផលនៃអំពើមុសាវាទ និងសម្បថទាំងបំពានបំពាននោះ បានធ្វើឱ្យខ្ញុំម្ចាស់ទៅសោយទុក្ខក្នុងនរក រួចពីនរកមក

ទើបបានជាប្រេតនេះ ដូចព្រះអង្គបានឃើញនេះឯង ។ ទូលពុទ្ធដីកាព្រះសង្ឃត្ថេររួចហើយ បានផ្តាំថា សូមព្រះករុណាមេត្តានិមន្តទៅប្រាប់កុដុម្ពីនោះឱ្យថ្វាយទានដល់ព្រះករុណាម្ចាស់ផង ហើយសូមឱ្យឧទ្ទិសផ្សាយកុសលផលបុណ្យមកចែកខ្ញុំម្ចាស់ទទួលទានផង ដើម្បីឱ្យឆាប់បានរំដោះអំពីប្រេតវិស័យនេះ ។

ព្រះមហាថេរទាំងឡាយ ទ្រង់មានព្រះទ័យប្រកបដោយមេត្តា ក៏បាននិមន្តទៅផ្ទះកុដុម្ពីនោះ អធិប្បាយរៀបរាប់អំពីបណ្តាំរបស់ប្រេតញីកុដុម្ពី ក៏បានចាត់ចែងថ្វាយទានឧទ្ទិសផលដល់ប្រេតញីនោះ ដោយសទ្ធាជ្រះថ្លាដ៏ក្រៃលែង ត្រាតែនាងប្រេតនោះបានរំដោះចាកទុក្ខ បានសោយសុខសម្បត្តិដ៏សែនមនោរម្យ ។ ឯនាងប្រេត ក៏សំដែងកាយឱ្យកុដុម្ពីនោះឃើញច្បាស់ក្នុងខណៈនោះឯង ។ ព្រះមហាថេរៈទាំងឡាយនាំយករឿងរ៉ាវនេះ ទៅក្រាបទូលព្រះបរមសាស្តា ព្រះអង្គទ្រង់សំដែងបញ្ជាក់អំពីកម្មដ៏អកុសលនោះ លុះចប់មហាជន ក៏បានសម្រេចនូវអរិយធម៌គ្រប់ៗគ្នា ។

# ២០. រឿងអគ្គិទត្តបុរោហិត

( ចាក ធ. ខុ.. )

*( បុព្វសិក្ខា នឹងបុព្វចរិយាទុលជាស្នូរសរកទីដៅនៃជនើ ប៉ុន្តែបុគ្គលណាក៏ដោយ កាលបើគ្មានបច្ច័យវិសេសជួយបង្ហើបមុខ នៃឧត្តមគតិផងទេ មិនអាចនឹងស្វែងរកឃើញទីបំផុតនៃជាតិ បានឡើយ )*

មានសេចក្ដីដំណាលថា មានបុរោហិតម្នាក់ឈ្មោះអគ្គិទត្តជាសហសេវិករបស់ព្រះបាទកោសល នៅក្នុងដែនកោសល ។ កាលដែលព្រះវរបិតាទ្រង់ទិវង្គតទៅ ព្រះចៅបសេនទិកោសលទ្រង់ចាត់តាំងអគ្គិទត្តក្នុងដំណែងដោយក្ដីគោរព ដោយព្រះតម្រិះថា " អគ្គិទត្តនេះជាបុរោហិតនៃបិតារបស់អញ " ហើយទ្រង់តែងតែក្រោកទទួលជានិច្ចនូវបុរោហិត ក្នុងពេលដែលលោកចូលទៅកាន់ទីគំនាល់របស់ព្រះអង្គ ទ្រង់ប្រទានអាសនៈស្មើនឹងទ្រង់ ដោយព្រះរាជឱង្ការថា " បពិត្រលោកអាចារ្យ សូមលោកអង្គុយក្នុងទីនេះ ។ លោកគិតថា " ព្រះរាជាអង្គនេះតែងធ្វើសេចក្ដីគោរពចំពោះអាត្មាអញ ប៉ុន្តែធម្មតាអាធ្យាស្រ័យនៃស្ដេចទាំងឡាយ គឺអាត្មាអញពិបាកនឹងតម្រូវឱ្យត្រូវជានិច្ចកាលពុំបាន ស្ដេចនេះនៅក្មេងកំឡោះត្រឡាំងការសោយរាជ្យជាមួយបុគ្គលមានវ័យស្មើគ្នា សុខស្រួលមែន តែអាត្មាជាបុគ្គលចាស់ត្រូវតែបួសទើបគួរ " ហើយក៏ក្រាបទូលសូមព្រះរាជាអនុញ្ញាតដើម្បីបួស រួចឱ្យគេគោះគងទូងស្គរក្នុងព្រះនគរ ចំណាយទ្រព្យ

របស់ខ្លួនទាំងអស់ឱ្យជាទានអស់៧ថ្ងៃ ហើយចេញទៅបួសក្នុងលទ្ធិខាងក្រៅ ។ ក្សិណនោះមានបុរស ១០ពាន់នាក់ចេញទៅបួសជាមួយដែរ ។ អគ្គទត្តបព្វជិតព្រមទាំងបរិវារ ក៏សម្រេចការតាំងទីលំនៅក្នុងចន្លោះ នៃនគរទាំងពីរ គឺអង្គមគធៈ និងកុរុរដ្ឋ ហើយលោកតែងឱ្យឱវាទដល់បរិវារនៃអ្នករាលគ្នា ! កិលេសទាំងឡាយ មានកាមវិតក្កជាដើម របស់យើងរាល់គ្នា កាលបើកើតមានឡើងចំពោះនរណា នរនោះគួរបន្ទោរបង់ចេញដោយរើសយកពំនូកនៃដុំខ្សាច់មួយដុំ រោយចុះមកក្នុងទីនេះ ។ បុរសទាំងនោះក៏ទទួលយល់ព្រមថា " សាធុ " ហើយធ្វើតាមកតិកាសញ្ញា នៅពេលដែលកិលេសទាំងឡាយកើតឡើង ។ សម័យក្រោយមកទីនោះបានកើតបានជាភ្នំខ្សាច់១ដុំធំ មាននាគរាជមួយឈ្មោះ អហិច្ឆត្តៈហួងហែងរក្សាភ្នំខ្សាច់នោះ ។ រីឯអ្នកស្រុកអង្គមគធៈនិកុរុរដ្ឋ តែងតែនាំគ្រឿងសក្ការៈដ៏ច្រើនឱ្យជាទានដល់អ្នកបួសទាំងនោះរាល់ៗខែ ។ ដងនោះអគ្គិទត្តព្រាហ្មណ៍បានឱ្យឱវាទដល់និស្សិតទាំងនោះថា " អ្នកទាំងឡាយចូរយកភ្នំព្រៃ អារាម និងដើមឈើជាទីពឹង កាលបើអ្នករាល់គ្នាប្រព្រឹត្តយ៉ាងនេះ អ្នកនឹងបានរួចរំដោះចាកទុក្ខគ្រប់យ៉ាងបាន ហើយតែងតែឱ្យឱវាទយ៉ាងនេះចំពោះអន្តេវាសិករបស់ខ្លួនជារឿយៗ ។

គ្រានោះ ព្រះពោធិសត្វកំពុងយាងទៅបំពេញមហាភិនេស្ក្រមន៏បានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ហើយទ្រង់គង់នៅវត្តជេតពនក្នុង

ក្រុងសាវត្ថីនាសម័យនោះ ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលជិតភ្លឺ បានឃើញអគ្គិទត្តព្រាហ្មណ៍ប្រមទាំងបរិវារ ចូលទៅក្នុងសំណាញ់ញាណរបស់ព្រះអង្គ ហើយទ្រង់ជ្រាបថា "ជនទាំងអស់នោះមានឧបនិស្ស័យគួរដល់ព្រះអរហន្តហើយ" ទើបទ្រង់ត្រាស់ហៅមហាមោគ្គល្លានត្ថេរមកនៅពេលរសៀល ហើយទ្រាស់ថា : នែមោគ្គល្លាន ! នោះហ្ន៎ ! អ្នកចូរមើលអគ្គិទត្តព្រាហ្មណ៍ កំពុងញ៉ាំងមហាជនឱ្យឆ្លង (សំសារវដ្ត) ដោយលទ្ធិមិនមែនជាទីឆ្លង មែនឬ ? បើអញ្ចឹងចូរលោកទៅឱ្យឱវាទដល់ជនទាំងនោះចុះ ។ ព្រះមហាមោគ្គល្លានត្ថេរតបព្រះពុទ្ធដីកាថា : បពិត្រព្រះអង្គដ៏ចំរើនពួកមហាជនទាំងនោះច្រើនគ្នាណាស់ មិនមែនជាវិស័យរបស់ខ្ញុំព្រះអង្គទេ លុះតែព្រះអង្គយាងទៅផង ទើបជនទាំងនោះជាវិស័យរបស់ព្រះអង្គផង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លានតថាគតនឹងទៅដែរ តែអ្នកចូរទៅមុនតថាគតសិនចុះ ។ ព្រះថេរៈក៏និមន្តទៅហើយគិតថា ជនទាំងនោះមានកម្លាំងមានគ្នាច្រើន ប្រសិនបើអាត្មាអញថ្លែងនូវពាក្យណាមួយក្នុងទីប្រជុំរបស់គេៗ ទាំងអស់គ្នានឹងក្រោកជាពួកៗមិនខាន ហើយក៏បង្អោរនូវភ្លៀង ដែលមានគ្រាប់ដ៏ធ្ងោស ដោយឫទ្ធិរបស់ខ្លួន ។ ក្នុងពេលដែលភ្លៀងកំពុងធ្លាក់ចុះ ជនទាំងនោះក៏នាំគ្នាក្រោករត់ចូលទៅកាន់សាលាប្រក់ស្លឹករៀងៗខ្លួន ។ ព្រះមហាថេរៈឈរនៅក្បែរទ្វារបណ្ណសាលារបស់អគ្គិទត្ត ហើយពោលថា " នែអគ្គិទត្ត ! " ។ អគ្គិទត្តលុះឮសំលេង

ព្រះថេរៈ ហើយពោលថា ក្នុងលោកនេះមិនអាចនរណាមួយអាចហ៊ាន ហៅរកឈ្មោះអាត្មាអញសោះទេ ចុះនរណាច្រឡឹមហ៊ានហៅអញដោយឈ្មោះយ៉ាងនេះ ? ។ ព្រះថេរៈពោលថា " ម្នាលព្រាហ្មណ៍ អាត្មាភាព! " ។ ព្រាហ្មណ៍សួរថា "នរណានិយាយហ្នឹង ព្រះថេរៈឆ្លើយថា ថ្ងៃនេះអាត្មាភាពសុំសំណាក់នៅទីឯកន្លែងអ្នកមួយយប់បានឬទេ ? ។ ព្រាហ្មណ៍ពោលថាទីកន្លែងសំណាក់ក្នុងទីនេះមិនមានទេ មានតែបណ្ណសាលាមួយគត់សម្រាប់ជនម្នាក់ៗប៉ុណ្ណោះ ។ ព្រះថេរៈពោលថា ម្នាលអគ្គិទត្ត! ធម្មតាមនុស្សទាំងឡាយ តែងចូលទៅកាន់សំណាក់មនុស្សផងគ្នា ពួកគោក៏តែចូលទៅរកហ្វូងគោ អ្នកបួសតែងចូលទៅកាន់សំណាក់អ្នកបួសដូចគ្នា អ្នកកុំធ្វើអញ្ចឹងចូរឱ្យទីនៅដល់អាត្មាផង ។ អគ្គិទត្តពោលថា ចុះលោកជាអ្នកបួសឬទេ ? ។ ព្រះថេរៈ អើ! អាត្មាភាពជាអ្នកបួស ។ អគ្គិទត្ត បើជាអ្នកបួសមែន ចុះឯណាគ្រឿងបរិក្ខារបស់អ្នកបួសនៅឯណា ? ។ ព្រះថេរៈ ម្នាលព្រាហ្មណ៍គ្រឿងបរិក្ខាអាត្មាមាន ប៉ុន្តែអាត្មាកាន់យកគ្រឿងបរិក្ខាទាំងនោះតែក្នុងចិត្តប៉ុណ្ណោះ ។ អគ្គិទត្តគ្រាន់តែឮព្រះថេរៈថាដូច្នេះ ក៏ខឹងនឹងព្រះថេរៈដោយគិតថា " អ្នកបួសមិនដែលទ្រទ្រង់គ្រឿងបរិក្ខាដូច្នោះសោះ" ។ គ្រានោះព្រះថេរៈក៏និយាយថា នែអគ្គិទត្ត ? ចូរអ្នកកុំខឹង ចូរប្រាប់ទីលំនៅអាត្មា ! ។ អគ្គិទត្ត ក្នុងទីនេះមិនមានទីកន្លែងសំណាក់នៅទេ ។ ព្រះថេរៈសួរថា : ចុះនរណានៅលើគំនរភ្នំខ្សាច់ឯណោះនុះ ?

អគ្គិទត្តឆ្លើយប្រាប់ថា មានពស់នាគរាជមួយនៅទីនោះ ។ ព្រះថេរៈ បើអញ្ជឹងចូរអ្នកឱ្យកន្លែងនោះមកអាត្មា ! ។ អគ្គិទត្ត ខ្ញុំមិនអាចឱ្យបានទេ ការនេះពិបាកណាស់! ព្រះថេរៈ មិនអីទេឱ្យតែអ្នកព្រមថា ឱ្យមកខ្ញុំចុះ ។ បើអញ្ជឹងស្រេចនឹងលោកចុះ ។ ព្រះថេរៈក៏និមន្តតម្រង់ទៅភ្នំខ្សាច់ នាគរាជលុះឃើញព្រះថេរៈនិមន្តមក ក៏គិតថា សមណៈនេះចូលមកក្នុងទីកន្លែងនេះទំនងជាមិនដឹងថា អាត្មាអញនៅនឹងកន្លែងនេះទេ បើដូច្នោះ អញនឹងធ្វើផ្សែងឱ្យអក្រឡើង ហើយសម្លាប់លោកចេញ " រួចក៏ក្លែងឫទ្ធិ បញ្ចេញផ្សែងអក្រឡើងភ្លាម ។ ព្រះថេរៈគិតថា នាគរាជនេះទំនងជា គិតថាមានតែអញទេ ដែលអាចបញ្ចេញផ្សែងអក្របាន ជនដទៃទៀតមិន អាចធ្វើបានទេ គិតដូច្នោះហើយ ក៏បញ្ចេញផ្សែងដោយព្រះអង្គឯងភ្លាម ដែរ ។ ផ្សែងក៏ហុយឡើងអំពីសិរីរៈនៃព្រះថេរៈ និងនាគរាជដរាបដល់ព្រហ្មលោក ។ ផ្សែងទាំងពីរផ្ទែកមិនបៀតបៀនព្រះថេរទេ បៀតបៀន ត្រឹមនាគរាជប៉ុណ្ណោះ ។ នាគរាជកាលអត់ទ្រាំនឹងសន្ទុះនៃផ្សែងមិនបាន ក៏ធ្វើជាភ្លើងឱ្យឆេះឡើង ទាំងព្រះថេរៈក៏ប្រមូលតេជោធាតុហើយបញ្ចេះ ឡើងជាមួយនឹងភ្លើងនាគរាជនោះដែរ ។ អណ្តាតភ្លើងឆាបឆេះដរាបដល់ព្រហ្មណីលោក ហើយមិនប៉ះពាល់ដល់ព្រះកាយព្រះថេរសោះ បៀតបៀន ត្រឹមតែនាគរាជប៉ុណ្ណោះ ។ ក្សិណនោះសិរីរៈទាំងអស់របស់នាគរាជ ហាក់ដូចជាភ្លើងគប់ឆាបឆេះពេញបន្ទុកឡើង ។ ពួកឥសីក្រឡេកមើលឃើញ

ក៏គិតថា " នាគរាជដុតស្រមណើរអុញហ្ន! ស្រមណើដ៏ចំរើនមិនព្រមស្តាប់ពាក្យយើង ត្រូវវិនាសហើយ ។ ព្រះថេរៈទូន្មាននាគរាជទាល់តែអស់ពុតត្បុត ហើយគង់នៅលើភ្នំខ្សាច់ នាគរាជក៏ព័ន្ធព័ទ្ធនូវគំនរខ្សាច់ជារង្វេលឱ្យជាបល្ល័ង្ក ហើយបើកពពែប៉ុនដំបូលនៃផ្ទះបិត (កុដាគារកុច្ឆិ) បាំងពីលើព្រះថេរៈ ។ លុះព្រលឹមស្រាង១ ពួកឥសីនាំគ្នាដើរទៅកាន់សំណាក់ព្រះថេរៈដោយបំណងចង់ដឹងថាសមណៈនោះស្លាប់ឬមិនស្លាប់ ក៏ស្រាប់តែឃើញលោកគង់នៅលើកំពូលភ្នំខ្សាច់ ឃើញដូច្នោះក៏លើកកំបង់ទាំងទសថ្វាយបង្គំសរសើរសួរថា បពិត្រសមណៈ នាគរាជមិនបៀតបៀនលោកម្ចាស់ទេឬ ? ព្រះថេរៈក៏ប្រាប់ថាអ្នករាល់គ្នាមិនឃើញនាគរាជដេកវៀនបើកពពារបាំងពីលើខ្ញុំទេឬ ? ពួកឥសីឃើញដូច្នោះហើយក៏ពោលសរសើរដោយនឹកស្ញើចក្នុងចិត្តថា : យីអើហ្ន៎! អស្ចារ្យណាស់ នៃវ៉ើយគ្នាយើងមើលហ្ន៎អានុភាពរបស់សមណៈចំឡែកណាស់វ៉ឺ ! នាគរាជនេះត្រូវបានលោកទូន្មានហើយ ហើយនាំគ្នាឈរចោមរោមព្រះថេរៈ ។ ខណៈនោះព្រះសាស្តាក៏ទ្រង់និមន្តទៅដល់ដែរ ព្រះថេរៈក៏ក្រោកឡើងថ្វាយបង្គំព្រះអង្គ ។ ពេលនោះពួកឥសីក៏និយាយនឹងព្រះថេរៈថា សមណៈអង្គនេះមានមហិទ្ធិឫទ្ធិជាងលោកម្ចាស់ណាស់ទៅឬ ? ព្រះថេរៈបញ្ជាក់ថាព្រះមានព្រះភាគអង្គនេះជាគ្រូ ខ្ញុំជាសាវករបស់ព្រះអង្គ ។ ព្រះសាស្តាក៏ទ្រង់គង់លើកំពូលភ្នំខ្សាច់ ពួកឥសីថ្លែងថាគួរឱ្យសរសើរណាស់ អនុភាពនៃ

សាវកនេះមានមែន ប៉ុន្តែអានុភាពនៃសាវកអង្គនេះបន្តិចបន្តួចសោះទេ ហើយលើកករប្រយោម្យពោលសរសើរព្រះសាស្តា ។ ព្រះសាស្តាទ្រង់ត្រាស់ហៅអត្ថិទត្តមកហើយថា : ក្នុងអត្ថិទត្តកាលអ្នកឱ្យឱវាទដល់សាវកនឹងឧបដ្ឋាករបស់អ្នក តើអ្នកពោលថាម៉េច ? ចូរអ្នកថ្លែងមកមើល? អត្ថិទត្តក្រាបទូលថា ខ្ញុំព្រះអង្គតែងឱ្យឱវាទដល់សាវក និងពួកឧបដ្ឋាករបស់ខ្ញុំព្រះអង្គថា " អ្នកទាំងឡាយចូរយកភ្នំនោះជាទីរលឹក អ្នកទាំងឡាយចូរយកព្រៃ អារាម ដើមឈើជាទីពឹងទីរលឹក ព្រោះបុគ្គលដែលយកវត្ថុមានភ្នំជាដើមជាទីពឹងហើយរមែងរួចរំដោះក្តីទុក្ខគ្រប់យ៉ាងបាន" ។ ព្រះបរមគ្រូទ្រង់ត្រាស់ថា ' : ម្នាលអត្ថិទត្តមិនមែនទេ បុគ្គលដែលយកវត្ថុមានភ្នំជាដើមនោះមកជាទីពឹង មិនអាចនឹងរួចចាកពីសេចក្តីទុក្ខគ្រប់យ៉ាងបានទេ លុះណាតែយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងវិញ ទើបអាចរួចចាកទុក្ខទាំងពួងបាន ហើយទ្រង់ត្រាស់គាថាយ៉ាងនេះ :

ពួកមនុស្សកាលបើត្រូវសេចក្តីភ័យខ្លាចកំហែងគំរាមហើយ តែងយកភ្នំ ព្រៃ អារាម ដើមឈើ និងចេតិយជាទីពឹង តែទីពឹងទាំងនោះ មិនមែនជាទីពឹងដ៏ក្សេមទេ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលដែលអាស្រ័យនូវទីពឹងនុ៎ះ មិនអាចនឹងរួចចាកទុក្ខទាំងពួងបានឡើយ ។

លុះត្រាតែបុគ្គលណោមួយដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ជាទីរលឹក ឃើញច្បាស់នូវអរិយសច្ចទាំង៤ ដោយបញ្ញាដ៏ត្រឹមត្រូវយ៉ាងនេះគឺ ទុក្ខសច្ច១ សមុទយសច្ចជាហេតុបង្កបង្កើតសេចក្ដីទុក្ខ១ និរោធសច្ចជាគ្រឿងផុតរំលត់នូវសេចក្ដីទុក្ខ១ មគ្គសច្ចប្រកបដោយហេតុ ៨យ៉ាង (៨អង្គ) ជាគ្រឿងចូលទៅរម្ងាប់សេចក្ដីទុក្ខ ទីពឹងនុះជាទីពឹងដ៏ក្សេម ឧត្ដម បុគ្គលដែលបានអាស្រ័យនូវទីពឹងនោះប្រាកដប្រជាហើយ អាចរើខ្លួនរួចចេញផុតពីសេចក្ដីទុក្ខទាំងពងបាន ។

លុះចប់ធម៌ទេសនាហើយ ពួកឥសីទាំងអស់ព្រមទាំងអគ្គិទត្តព្រាហ្មណ៍បានលុះព្រះអរហត្តផល ព្រមទាំងបដិសម្ភិទា ហើយថ្វាយបង្គំសូមផ្នួសនឹងព្រះអង្គ ។ ព្រះអង្គទ្រង់លាព្រះហស្ដពីខាងក្នុងចីវរ ហើយត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកប្រព្រឹត្តព្រហ្មចរិយធម៌ចុះ " ខណៈនោះពួកឥសីទាំងនោះមានបរិក្ខារ៨ទ្រទ្រង់គ្រប់ៗគ្នា ហាក់ដូចជាព្រះថេរៈដែលមានវស្សាមួយរយ ។ ចួនជាថ្ងៃនោះ ជាថ្ងៃដែលអ្នកស្រុកអង្គមគធៈនឹងកុរុរដ្ឋ នាំយកគ្រឿងសក្ការៈមកប្រគេនពួកឥសីទាំងនោះដែរ ។ លុះមកដល់ឃើញពួកឥសីទាំងនោះបួស ក៏គិតថា " អគ្គិទត្តព្រាហ្មណ៍របស់យើងគ្រាន់បើជាង ឬក៏សាមណគោតមគ្រាន់បើជាង ? " គិតយ៉ាងនេះដោយពីភាល់ក្នុងចិត្តថា " អគ្គិទត្តធំជាងមែន ទើបព្រះសមណគោតមចូលមករក " ។ ព្រះបរមសាស្ដាទ្រង់ប្រមើលនូវអធ្យា

ស្រ័យនៃពួកបរិស័ទទាំងនោះ ហើយត្រាស់ថា " ម្នាលអគ្គិទត្ត អ្នកចូរកាត់សេចក្ដីសង្ស័យនៃបរិស័ទរបស់អ្នកឱ្យបានជ្រះស្រឡះ ។

អគ្គិទត្តព្រាហ្មណ៍ ក៏ពោលថា " ខ្ញុំព្រះអង្គមានបំណងនឹករលឹកចំពោះព្រះអង្គដោយហេតុយ៉ាងនេះ " ហើយក៏ហោះឡើងទៅអាកាសអស់វារៈ៧លើកដោយឥទ្ធិឫទ្ធិ ចុះមកវិញថ្វាយបង្គំព្រះសាស្ដា រួចពោលប្រកាសថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ពិតជាគ្រូរបស់ខ្ញុំព្រះអង្គ រីឯខ្ញុំព្រះអង្គជាសាវក" ។

## ២១. រឿងវិមានប្រេត

( ចាក ធ. ខុ.. )

*( ផលល្អនិងអាក្រក់តែងជ្រៀតជ្រែកឱ្យផលតាមកម្លាំងរបស់ខ្លួន )*

មានសេចក្ដីដំណាលថា ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ មានស្ត្រីម្នាក់មានសទ្ធាជ្រះថាក្នុងព្រះរតនត្រ័យ បានកសាងអារាម១ ប្រគេនព្រះភិក្ខុសង្ឃឱ្យគង់នៅជាសប្បាយ ព្រមទាំងចង្ហាន់ដ៏ត្រកាលជាប្រក្រតី ។ លុះចំណេរចិរកាលតទៅ នាងក៏ធ្វើកាលកិរិយាដោយផលកម្មអកុសល ដែលនាងបានធ្វើពីជាតិមុនចូលមកជ្រៀតជ្រែកនាំវិញ្ញាណនាងឱ្យទៅកើតជាវិមានប្រេត នៅលើភ្នំហេមពាន្ត មានវិមានមាសឱភាសរុងរឿងថ្កើងថ្កាន មានឱទ្យានដូចស្ថានសួគ៌ប្រកបដោយស្រះបោក្ខរណី ៤ ជ្រុង ដ៏មានកំពស់រាបស្មើសប្បាពណ្ណរាយ ដោយអានុភាពនៃបុណ្យដែល

នាងបានកសាងអារាម១ ប្រគេនដល់ភិក្ខុសង្ឃ ។ ឯរូបនាង មានសម្បុរល្អដូចរស្មីមាស ប្រាសចាកមន្ទិល ប្រៀបបាននឹងលំអរស្រីទេពអប្សរសោយសម្បត្តិនៅទីនោះ ព្រោះកុសលតាក់តែងពុំឱ្យមានទុក្ខ ។ ប៉ុន្តែប្រាសចាកកាមសុខ ត្បិតពុំមានបុរសម្នាក់ ក៏បណ្តាលឱ្យក្តៅក្រហាយក្នុងចិត្ត ទើបនាងវិមានប្រេតគិតរកឧបាយបេះផ្លែស្វាយទិព្វ បោះបណ្តែតឱ្យរសាត់តាមទឹកហូរក្នុងស្ទឹងនោះ ។

លំដាប់នោះ មានមាណពម្នាក់នៅក្នុងនគរពារាណសី ចេញពីផ្ទះចុះទៅកំពង់ទឹក ឃើញផ្លែស្វាយទិព្វ១អណ្តែតទៅដល់ ក៏រើសយកមកពិចារណាដឹងស្គាល់ជាផ្លែស្វាយទិព្វ ទើបបុរសនោះបរិភោគ ក៏មានឱជារសឆ្ងាញ់ពិសាប្លែកពីធម្មតា ហើយរៀបស្បៀងអាហារអម្រស់អម្រដើរតាមមាត់ឆ្នេរទៅព្រៃហេមពាន្ត លុះទៅដល់ហើយ នាងវិមានប្រេតចេញមកសួរទទួលនាំទៅវិមាន ឱ្យអង្គុយលើគ្រែបន្ទំសមរម្យ រួមរក្សស្នេហាតាមប្រពៃណីស្ត្រី និងបុរសក្នុងលោក ។ កាលបុរសនោះឃើញទិព្វសម្បត្តិស្ថានលំនៅនៃវិមានប្រេតស្រណុខសុខសប្បាយ ទើបសួរដណ្តឹងថាម្នាលប្អូនស្រីសម្លាញ់ នាងមានឫទ្ធានុភាពដូចស្រីទេពអប្សរប្រាង្គប្រាសាទវិមានភ្លឺស្វាងរុងរឿង ដោយកែវពៃទូរ្យសួរកាន្ត ភ្លឺដូចព្រះច័ន្ទពេញបូណ៌មីហើយនាងស្រីក៏ល្អដូចមាសជម្ពូនុទបរិសុទ្ធផុតចាកមន្ទិលសៅហ្មង តែងនាំចិត្តបុរសឱ្យត្រេកត្រអាល ហើយគង់នៅលើប្រាសាទនោះតែម្នាក់ឯង

កណ្តោចកណ្តែង កំព្រាឥតមានបុរសណាជាស្វាមីមានស្រះបោក្ខរណីប្រកប ដោយជលជាត ដុះពេញត្រៀបត្រាមានហ្វូងបក្សាបក្សីស្រែកយំទ្រហឹង អឺងកងរំពងព្រៃ ដូចជាដូវព្រៃ ដូចជាដូរ្យតន្ត្រី ទាំងប្អូនស្រីមានមុខញញឹម ស្រស់ប្រិមប្រិយ៍ សំដីនោះពិរោះយើងបានឃើញហើយតាមចិត្តគិតចង់ មកកើតនៅទីនេះ តើធ្វើដូចម្តេចនឹងបានសម្រេចដូចប្រាថ្នា ? ។ នាង វិមានប្រេតស្តាប់ហើយឆ្លើយថា ហៃមាណព បើអ្នកចង់មកកើតនៅទីនេះ ចូរសង្វាតបំពេញកុសល លុះអស់ជីវិតទៅ អ្នកនឹងបានមកកើតនៅទីនេះ បានត្រេកត្រអាលសប្បាយជាមួយនឹងយើងពុំខានឡើយ ។ ឯមាណពបាន ស្តាប់ពាក្យនាងប្រេតប្រាប់ដូច្នោះ ក៏មានចិត្តត្រេកអរមហិមា លាវិលវឹង ទៅកាន់ស្ថានលំនៅរបស់ខ្លួនវិញ ហើយធ្វើបុណ្យកុសលតំកល់ចិត្តគិតចង់ បាននាងប្រេតនោះ លុះអស់អាយុសង្ខារពីមនុស្សលោក ក៏បានកើតក្នុង វិមានរួមមគ្គសំវាសជាមួយនឹងនាងប្រេតនោះដរាបដល់អស់កំណាត់កុសល ផលបុណ្យដែលខ្លួនបានធ្វើនោះហោង ។ នាងប្រេតបាននៅទីនោះអស់ កម្លុងកាលដ៏យូរ១ ពុទ្ធន្តរ ដរាបដល់សាសនាព្រះសមណគោតមបរមគ្រូ ព្រះអង្គបានត្រាស់ប្រាជ្ញាសារពេជ្ញតាញាណក្នុងលោកនេះ ។

សម័យថ្ងៃមួយ ព្រះមហាមោគ្គលានដ៏មានអាយុ លោកនិមន្តទៅ ដល់ភ្នំនោះបានឃើញនាងវិមានប្រេត ស្ថិតនៅលើវិមានឋានទិព្វប្រដាប់ សឹងកែវពៃទូរ្យ ទើបលោកដណ្តឹងសួរថា វិមានឋាននេះមានរស្មីរុងរឿង

ថ្កើងថ្កាន តើនាងបានធ្វើកម្មដូចម្តេចពីជាតិមុន ទើបបានកើតនៅក្នុងវិមាននេះ ? នាងវិមានប្រេតប្រាប់បុព្វកម្មដែលនាងបានធ្វើពីជាតិមុនទូលព្រះមហាថេរសព្វគ្រប់ប្រការ ។ ទើបព្រះមហាមោគ្គលានដ៏មានអាយុត្រឡប់នាំយករឿងនោះទៅក្រាបទូលព្រះបរមសាស្តា ព្រះអង្គទ្រង់ប្រជុំបរិស័ទសំដែងធម៌ទេសនាប្រារព្ធយករឿងប្រេតនោះជាហេតុលុះចប់ព្រះធម៌ទេសនា បរិស័ទទាំងឡាយបានសម្រេចមគ្គផលតាមឧបនិស្ស័យវាសនារៀង១ខ្លួន ។

## ២២. រឿងសុជាតមាណព

( ចាក បេ. ខុ.. )

*( ព្រះធម៌អាចរម្ងាប់សេចក្តីសោកពានឆាប់រហ័ស )*

កាលព្រះបរមសាស្តាសារពេជ្ញតាញាណ ព្រះអង្គគង់សម្រាន្តព្រះឥរិយាបថនៅក្នុងសុគន្ធកុដិ នៃវត្តជេតពន មានកុដុម្ពីម្នាក់នៅក្នុងក្រុងសាវត្ថិបិតាអនិច្ចកម្មទៅ កុដុម្ពីនោះមានសេចក្តីសោយសោកស្រែកយំដំឌិរាយាត្រាទៅដូចជាមនុស្សឆ្កួត បានឃើញបុគ្គលណា ក៏សួរបុគ្គលនោះថាបានឃើញបិតាខ្ញុំដែរ ឬទេ ? បុគ្គលទាំងនោះមិនអាចនឹងបន្ទោបង់សេចក្តីសោករបស់កុដុម្ពីនោះបានឡើយ ។ ដោយហេតុតែឧបនិស្ស័យនៃកុដុម្ពីនោះ នឹងបានសម្រេចព្រះសោតាបត្តិផលដ៏រុងរឿង ព្រះបរមសាស្តាព្រះអង្គទ្រង់ពិតពិលរមិលមើលឧបនិស្ស័យនៃសត្វលោក លុះវេលា

ដែលបច្ចុសម័យភ្លឺស្រាងបំព្រាង ក៏ឃើញឧបនិស្ស័យនៃកុដុម្ពីនោះ នឹងបានសម្រេចព្រះសោតាបត្តិផល ទើបព្រះអង្គទ្រង់ព្រះចិន្តាថា គួរតែតថាគតនាំយកហេតុក្នុងអតីតមកបន្ទោបង់សេចក្តីសោកសៅ នៃកុដុម្ពីឱ្យបានសម្រេចព្រះសោតាបត្តិផល ។ ទ្រង់ព្រះចិន្តាស្រេចហើយ ទើបព្រះអង្គទ្រង់នាំភិក្ខុសង្ឃយាងទៅបិណ្ឌបាតផ្ទះកុដុម្ពីនោះ ។ ឯកុដុម្ពីនោះបានឮថាព្រះអង្គទ្រង់យាងមក ក៏មានចិត្តត្រេកអរពន់ប្រមាណ ស្ទុះទៅធ្វើបច្ចុមគ្គមនាការ ទទួលនិមន្តព្រះអង្គឱ្យគង់លើអាសនៈនមស្ការថ្វាយបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គបានឃើញបិតាខ្ញុំព្រះអង្គនៅក្នុងទីណា ? ព្រះបរមសាស្តាទ្រង់មានព្រះពុទ្ធដីកាថា អ្នកសួររកបិតាអ្នកដែលស្លាប់ក្នុងអតីតជាតិ ឬស្លាប់ក្នុងអនាគត ? កុដុម្ពីនោះបានស្តាប់ព្រះពុទ្ធដីកាដូច្នោះ មានចិត្តបន្ទោបង់សេចក្តីសោកដោយគិតថា កំណើតសព្វសត្វដែលកើតមកក្នុងវាលវដ្តសង្សារ នឹងរាប់បិតាពុំអស់ មិនមែនមានតែបិតាមួយទេ លុះកុដុម្ពីគិតដូច្នោះហើយ ក៏នៅស្ងៀម ។ លំដាប់នោះព្រះបរមគ្រូទ្រង់មានពុទ្ធដីកាបន្ទោបង់សេចក្តីសោក ហើយទ្រង់សំដែងធម៌ទេសនាឱ្យកុដុម្ពីនោះបានតាំងនៅក្នុងព្រះសោតបត្តិផល តំកល់ចិត្តស៊ប់ក្នុងព្រះពុទ្ធសាសនា ទើបព្រះអង្គទ្រង់នាំភិក្ខុសង្ឃយាងត្រឡប់ទៅជេតនៃមហាវិហារវិញ ។

លំដាប់នោះពួកភិក្ខុសង្ឃនាំយករឿងនោះមកប្រជុំគ្នានៅក្នុងរោងធម្មសភាថា ម្នាលអាវុសោទាំងឡាយ អ្នកចូរពិតពិលរមិលមើលអានុភាពនៃព្រះមានបុណ្យ ឧបាសកប្រកបដោយសេចក្តីសោក នឹងរកបុគ្គលណាឃាត់មិនបាន ក៏ព្រះអង្គទ្រង់ធ្វើឱ្យបានសម្រេចព្រះសោតាបត្តិផលតែម្តង ។ គ្រានោះព្រះសាស្តាទ្រង់យាងទៅកាន់រោងធម្មសភាគង់លើពុទ្ធាសនៈស្រេចហើយ ទើបមានព្រះពុទ្ធដីកាដណ្តឹងសួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមកប្រជុំគ្នាក្នុងទីនេះ តើមានហេតុដូចម្តេច ភិក្ខុទាំងឡាយថ្វាយបង្គំប្រណម្យទូលនូវហេតុនោះ ទើបព្រះអង្គទ្រង់លមានព្រះពុទ្ធដីកាថាម្នាលភិក្ខុទាំងឡាយ តថាគតបន្ទោសេចក្តីសោកនៃឧបាសកនេះមិនមែនតែក្នុងជាតិនេះទេ សូម្បីតែពីជាតិមុន ក៏តថាគតធ្លាប់បន្ទោបង់សេចក្តីសោករបស់ឧបាសកនេះដ៏អស្ចារ្យដែរទើបពួកភិក្ខុអារាធនាព្រះអង្គៗនាំយកអតីតនិទានមក សម្តែងថា ម្នាលភិក្ខុទាំងឡាយកាលខាំងកំបាំងស្ងាត់កន្លងរំលងទៅមាន ក្សត្រមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិ នៅក្រុងពារាណសី មានគហបតីម្នាក់ក្នុងស្រុកនោះ បិតាធ្វើកាលកិរិយាទៅ គហបតីនោះមានសេចក្តីទុក្ខសោកពន់ប្រមាណមានមុខជោកជាំដោយទឹកភ្នែកស្រែកយំដើរបទក្សិណជើងថ្ករខ្មោចបិតានោះ ។ ចៅសុជាត ជាកូននៃគហបតីនោះ ជាអ្នកមានប្រាជ្ញាឈ្លាសវៃគិតរកឧបាយ ធ្វើឱ្យបិតាលះបង់សេចក្តីសោក ។ ថ្ងៃមួយ

ចៅសុជាតចេញទៅក្រៅនគរ បានឃើញគោ១ស្លាប់ លុះគិតឃើញហើយ ក៏បោចស្មៅនិងទឹកយកទៅ តម្កល់ទុកនៅខាងមុខមាត់ខ្មោចគោនោះ រួចស្រែកទ្រហោយំហៅគោនោះហាក់ដូចជាមានជីវិតថាចូរ ស៊ីស្មៅផឹកទឹក ។ មនុស្សទាំងឡាយដើរទៅមក បានឃើញចៅសុជាតធ្វើដូច្នោះ ទើបស្រដីសួរថា ចៅនេះឆ្កួតទេដឹង បានជាយកស្មៅទឹកមកឱ្យគោស្លាប់ស៊ី ? ចៅសុជាតបានស្ដាប់ ហើយក៏នៅស្ងៀម ។ ពួកមនុស្សទាំងនោះនាំយកសេចក្ដីនោះទៅនិយាយប្រាប់បិតាចៅសុជាតិថា កូនអ្នកដូចជាឆ្កួត មានចិត្តប្រែប្រួលយកស្មៅទឹកឱ្យគោស្លាប់ស៊ី។ ឯគហបតីបានស្ដាប់ហើយ ក៏យាត្រាទៅយ៉ាងប្រញាប់ មានចិត្តរម្ងាប់បង់សេចក្ដីសោក ដោយគិតថា ចៅសុជាតិឆ្កួតមែនលុះទៅដល់ហើយស្រដីនឹងចៅសុជាតថា ម្នាលបាអ្នក មានចំណេះដឹងជ្រៅជ្រះ ប្រាជ្ញាឈ្លាសវៃ ព្រោះហេតុអ្វីក៏អ្នកយកស្មៅនឹងទឹកមកឱ្យគោស្លាប់ស៊ី ?កូនឯងធ្វើដូច្នេះហាក់ដូចជាមនុស្សឆ្កួតល្ងង់ខ្លៅ ។ ចៅសុជាតបានស្ដាប់ពាក្យបិតាហើយក៏គិតធ្វើឱ្យបិតាដឹងខ្លួន ទើបនិយាយថា គោនេះមាន ជើង ៤ ក្បាល ខ្លួន កន្ទុយ ភ្នែកនៅបរិបូណ៌ ពុំទាន់មានដំបៅស្អុយដេកនៅស្ងៀម ស្លាប់ដូចជាពុំស្លាប់ ខ្ញុំសំគាល់ថាវាក្រោកឡើងបាន ឯជើងក្ដី ដៃក្ដី ក្បាលក្ដី កាយក្ដីនៃជីតាពុំប្រាកដ បិតាបានដាក់ឆ្អឹងជីតានៅក្នុងស្ដូប ដែលធ្វើដោយដីឥដ្ឋ ជាមនុស្សឆោតល្ងង់ខ្លៅ មិនដឹងថាសង្ខារទាំងឡាយកើតឡើង ហើយរលត់រលាយទៅវិញ ។ បិតាបានស្ដាប់

ពាក្យព្រះពោធិសត្វ បានដឹងថាកូនជាបណ្ឌិតមែន ធ្វើការណ៍ទាំងនេះឱ្យយើងដឹងខ្លួន ទើបសសើរកូនប្រុសថា ម្នាលចៅសុជាត សព្វសត្វមានសេចក្តីស្លាប់ធម្មតា យើងបានដឹងហើយ ចាប់តាំងពីពេលនេះយើងលែងយំសោកស្រណោះអាល័យស្តាយដូចពេលមុនទៀតហើយ សេចក្តីសោកស្តាយរបស់យើងនាំឱ្យក្តៅក្រហាយ ដូចជាភ្លើងឆេះព្រៃកណ្តាលថ្ងៃ រីបាឯងដូចជាគេនាំយកទឹកមកស្រោចស្រប់រំលត់ភ្លើងនោះ ។ គហបតីលុះបានស្តាប់ពាកពាកចៅសុជាតជាកូន ហើយក៏បន្ទោបង់សេចក្តីសោកស្តាយសង្រេងសង្រៃ រួចទៅងូតទឹក បរិភោគអាហារភោជនប្រព្រឹត្តធ្វើកិច្ចការទាំងពួង លុះធ្វើកាលកិរិយា បានទៅកើតក្នុងស្ថានសួគ៌ ។ ព្រះបរមគ្រូទ្រង់នាំអតីតនិទានមកថ្លែង សំម្តែងធម៌ទេសនាអំពីចតុរារិយសច្ចស្រេចហើយ មនុស្សម្នាផងទាំងឡាយបានតម្កល់ចិត្តក្នុងព្រះសោតាបត្តិផល ទើបព្រះអង្គទ្រង់ប្រជុំនិទានជាតកថា បិតាចៅសុជាតនោះគឺកុដុម្ពីហ្នឹងឯង ឯចៅសុជាតគឺអង្គតថាគត ។

## ២៣. រឿងខេមកសេដ្ឋីបុត្ត

( ចាក ធ. ខុ.. )

*( ផលនៃសេចក្តីប្រាថ្នាខុសគន្លងធម៌ ជាទោសក្នុងលោក )*

កាលព្រះសាស្តាគង់នៅវត្តជេតពន ព្រះអង្គទ្រង់ប្រារព្ធនឹងសេដ្ឋីម្នាក់ឈ្មោះខេមកៈជាក្មួយអនាថបិណ្ឌិក ។ មានសេចក្តីដំណាលថា សេដ្ឋី

នោះមានរូបសម្បត្តិស្អាតណាស់ ពួកស្រី១ជាច្រើនឱ្យតែបានឃើញមានសេចក្តីត្រេកត្រអាលដោយរាគៈ មិនអាចនឹងតាំងនៅតាមសភាពរបស់ខ្លួនបានឡើយ ម៉្លោះហើយសេដ្ឋីបុត្រនោះ ក៏ធ្លាក់ខ្លួនទៅជាអ្នកលេងសេពកាមគុណជាមួយនឹងប្រពន្ធកូនគេ ។ លំដាប់នោះពួករាជបុរសចាប់យកទៅថ្វាយព្រះរាជា១គិតថា អញខ្លាចមហាសេដ្ឋី ហើយទ្រង់គ្មានព្រះរាជឱង្ការអ្វីបន្តិចសោះឡើយ ទ្រង់លែងទៅវិញ ។ ចំណែកសេដ្ឋីបុត្រនោះក៏នៅតែមិនលះបង់សោះ ។ គ្រានោះពួករាជបុរសចាប់ទៅថ្វាយព្រះរាជាអស់២លើក ៣លើក ព្រះរាជាទ្រង់លែងទៅវិញដដែល ។ លោកមហាសេដ្ឋីជ្រាបដំណើងនោះ ទើបនាំទៅគាល់ព្រះសាស្តា ក្រាបទូលសូមព្រះអង្គសម្តែងប្រោសដល់ក្មួយ ដើម្បីឱ្យលះបង់ឈប់ប្រព្រឹត្តអំពើអាក្រក់តទៅទៀត ។ ព្រះអង្គទ្រង់សម្តែងសំវេគកថា នឹងសម្តែងពីទោសប្រព្រឹត្តសេពប្រពន្ធកូនគេឱ្យស្តាប់ថា :

នរជនស្រវឹងសេពប្រពន្ធកូនគេ រមែងបានដល់នូវហេតុអាក្រក់៤យ៉ាងគឺ :បានបាបទី១ ដេលមិនបានស្រួលតាមសេចក្តីប្រាថ្នា ទី២ត្រូវគេត្មះតិះដៀល ទី៣នឹងធ្លាក់ទៅកើតក្នុងនរក ទី៤នរជននោះមិនមានបុណ្យជាអ្នកមានដំណើរអាក្រក់ ថែមទាំងសេចក្តីត្រេកត្រអាលរបស់ជនដែលភ័យនោះ ជាមួយនឹងស្រ្តីដែលភ័យ ជាសេចក្តីត្រេកត្រអាលមានប្រមាណ

តិច ព្រមទាំងត្រូវព្រះរាជាដាក់ទណ្ឌកម្មថែមទៀតផង ព្រោះហេតុនោះនរជនមិនគួរសេពប្រពន្ធកូនគេទេ ។

លុះចប់ព្រះធម្មទេសនានេះ ខេមកសេដ្ឋីបុត្រ បានសម្រេចសោតាបត្តិផល លែងប្រព្រឹត្តអំពើអនាចារនឹងប្រពន្ធកូនគេទៀតហើយ ។

សួរថាចុះសេដ្ឋីបុត្រនេះ បានធ្វើបុព្វកម្មដូចម្តេចពីជាតិមុន ?ឆ្លើយថា សេដ្ឋីបុត្រនេះកើតជាអ្នកលេងចំបាប់យ៉ាងឆ្នើម ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ គាត់បានលើកទង់ជ្រុងមាសពីរដាក់លើស្តូបប្រាក់នៃព្រះទសពល ហើយគាត់ប្រាថ្នាថា ពួកស្រីដ៏សេសក្រៅពីញាតិសាច់សាលោហិតរបស់អញចេញ ឱ្យតែបានឃើញអញត្រូវតែត្រេកត្រអាលរីករាយជាមួយនឹងអញកុំខាន សេចក្តីប្រាថ្នារបស់គាត់ដូច្នេះឯង ជាអំពើដែលគាត់ធ្វើក្នុងបុព្វជាតិ ។ ដូច្នេះពួកស្រីៗ ទាំងកូនទាំងប្រពន្ធគេគ្រប់តែជាតិដែលខេមកសេដ្ឋីបុត្រកើត ហើយបើបានឃើញគាត់មិនអាចនឹងអត់ទ្រាំតម្រេករបស់ខ្លួនឱ្យតាំងនៅតាមប្រក្រតីបានឡើយ ប៉ុន្តែពេលនេះជាទីបំផុតជាតិរបស់គាត់ហើយ ដោយសារបានជួបនិងព្រះពុទ្ធបរមគ្រូ ព្រះអង្គទ្រង់សំដែងត្រាស់ នៃការប្រព្រឹត្តអំពើអនាចារ ប្រាប់ពន្យល់ឱ្យឃើញពិតប្រាកដ បានរួចចាកផុតទុក្ខគ្រប់យ៉ាង បានឡើងឋានៈជាអរិយជនមានជាតិកំណើតភ្លឺស្វាងទៅក្នុងអនាគត ។

# ២៤. រឿងវង្គីសព្រាហ្មណ៍

( ចាក ធ. ខុ.. )

*( ចេះឯងមិនក្រែងចេះគេ )*

បានឮថា មានព្រាហ្មណ៍ម្នាក់ឈ្មោះវង្គីសៈនៅក្នុងនគររាជគ្រឹះ ចេះគោះក្បាលខ្មោច ហើយដឹងថា " នេះជាក្បាលខ្មោចដែលស្លាប់ទៅកើតក្នុងនរក នេះជាក្បាលខ្មោចដែលស្លាប់ទៅ កើតក្នុងកំណើតសត្វតិរច្ឆាន ក្បាលខ្មោចនេះកើតក្នុងកំណើតប្រេត ក្បាលខ្មោចនេះកើតក្នុងមនុស្សលោក ក្បាលខ្មោចនេះកើតក្នុងទេវលោក " ។ ព្រាហ្មណ៍ទាំងឡាយគិតថា យើងអាចរស់នៅក្នុងលោក ព្រោះអាស្រ័យនូវវង្គីសព្រាហ្មណ៍នេះ ហើយឱ្យវង្គីសព្រាហ្មណ៍នោះស្លៀកដណ្តប់ពណ៌ក្រហមពីរ នាំត្រាច់ទៅជនបទប្រកាសប្រាប់មហាជនថា ព្រាហ្មណ៍ឈ្មោះវង្គីសនេះ ចេះគោះក្បាលខ្មោច ហើយដឹងកន្លែងដែលខ្មោចនោះទៅកើត បើដូច្នេះ ចូរអ្នកទាំងឡាយសួរកន្លែងដែលពួកញាតិរបស់ខ្លួនទៅកើត ។ ពួកមហាជនឱ្យ ១០ កហាបណៈ ខ្លះ ២០ កហាបណៈ ខ្លះ ១០០ កហាបណៈ តាមសមគួរដល់កំលាំង ហើយសួរពីទីកន្លែង ដែលពួកញាតិរបស់ខ្លួនទៅកើត ។ ព្រាហ្មណ៍ទាំងឡាយទៅតាមលំដាប់បានដល់ក្រុងសាវត្ថី ហើយសំណាក់អាស្រ័យនៅក្នុងទីជិតវត្តជេតពន ។ ពួកព្រាហ្មណ៍បរិភោគអាហារពេលព្រឹកស្រេចហើយ ឃើញមហាជនកាន់យកផ្កាកម្រង និងគ្រឿងក្រអូប

ជាដើម កំពុងដើរទៅស្តាប់ធម៌ទេសនា ក៏ស្រែកសួរថា អ្នកទាំងអស់គ្នាទៅណា ? ពួកមហាជនប្រាប់ថាទៅស្តាប់ធម៌ទេសនាក្នុងវត្ត ទើបពួកព្រាហ្មណ៍ប្រាប់ទៀតថា អ្នកទាំងអស់គ្នាទៅក្នុងវត្តនោះ នឹងធ្វើដូចម្តេច? ព្រោះថាបុគ្គលដទៃប្រាកដស្មើដោយវង្គីសព្រាហ្មណ៍របស់យើងនេះ មិនមានទេ ព្រោះគាត់ចេះគោះក្បាលខ្មោច ហើយដឹងនូវទីកន្លែងដែលខ្មោចកើត បើដូច្នោះចូរអ្នកសួរកន្លែង ដែលពួកជនជាញាតិរបស់អ្នកកើតនឹងគាត់ចុះ ។ ជនទាំងនោះពោលថា វង្គីសៈចេះអី ? គាត់មិនស្មើនឹងព្រះសាស្តារបស់យើងទេ រួចពួកព្រាហ្មណ៍និយាយទៅវិញថា ព្រះសាស្តារបស់អ្នកឯងមិនស្មើនិងវង្គីសៈរបស់យើងទេ ។ ពួកជនទាំងពីរពួកនោះចេះតែក្អេងក្អាងអួតសរសើរគ្រូរបស់ខ្លួនតែរៀង១ខ្លួន រួចទើបពួកព្រាហ្មណ៍ទាំងនោះព្រមទាំងវង្គីសផងទៅវត្ត ដោយមានបំណងថា យើងនឹងដឹងនូវចំណេះចេះដឹងរបស់វង្គីសៈជាគ្រូរបស់អ្នក ឬថានូវចំណេះចេះដឹងនៃព្រះសាស្តាជាគ្រូរបស់យើង ។ ព្រះបរមសាស្តាព្រះអង្គទ្រង់ជ្រាបនូវដំណើរដែលជនទាំងនោះនាំគ្នាមក ហើយទ្រង់ឱ្យគេនាំយកក្បាលខ្មោច៥ គឺក្បាលខ្មោច៤ ដែលទៅកើតក្នុងទីទាំង៤ គឺកើតក្នុងនរក១ តិរច្ឆាន១ កើតក្នុងមនុស្សលោក១ ក្នុងទេវលោក១ និងព្រះសិរនៃព្រះខីណាស្រព១ ឱ្យដាក់តាមលំដាប់ ហើយទ្រង់សួរវង្គីសៈព្រាហ្មណ៍ថា បានឮថាអ្នកចេះគោះក្បាលខ្មោច ហើយដឹងនូវកន្លែងដែលខ្មោចទៅកើតមែនឬ ? គាត់ឆ្លើយថាព្រះ

ករុណាខ្ញុំដឹង ។ ព្រះអង្គត្រាស់សួរថា នេះជាក្បាលខ្មោចរបស់អ្នកណា ? វង្គីសៈព្រាហ្មណ៍គោះក្បាលខ្មោចនោះ រួចក្រាបទូលថា ក្បាលខ្មោចនេះកើតក្នុងនរក ។ លំដាប់នោះព្រះសាស្តាទ្រង់ឱ្យពរសព្ទសាធុការដល់វង្គីសព្រាហ្មណ៍ថាប្រពៃហើយ ទើបទ្រង់សួរក្បាលខ្មោចពាងទៃទៀត វង្គីសព្រាហ្មណ៍ឆ្លើយត្រូវទៀត ព្រះអង្គទ្រង់ឱ្យសព្ទសាធុការពរជ័យម្ដងទៀត រួចបង្ហាញក្បាលខ្មោចទី៥ហើយទ្រង់សួរថា ក្បាលខ្មោចនេះរបស់អ្នកណា? ។ វង្គីសព្រាហ្មណ៍គោះក្បាលខ្មោចនោះ មិនដឹងកន្លែងដែលបុគ្គលនោះកើតសោះ ។ គ្រានោះឯងព្រះសាស្តាទ្រង់ត្រាស់នឹងវង្គីសៈថា ម្នាលវង្គីសៈអ្នកឯងមិនដឹងទេឬ ? វង្គីសៈក្រាបទូលថា ព្រះករុណាខ្ញុំព្រះអង្គមិនដឹងទេ ទើបព្រះអង្គត្រាស់ថា តថាគតដឹង ។ វង្គីសៈសួរថា ព្រះអង្គដឹងដោយហេតុដូចម្ដេច ? ព្រះអង្គត្រាស់ថា តថាគតដឹងដោយកម្លាំងមន្ត ។ ទើបវង្គីសព្រាហ្មណ៍សុំរៀនមន្តនោះនឹងព្រះសាស្តាថា សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសប្រទានមន្តនោះដល់ខ្ញុំព្រះអង្គ ។ ព្រះអង្គត្រាស់ថា តថាគតមិនអាចឱ្យដល់អ្នកដែលមិនបួសទេ ។ រួចវង្គីសព្រាហ្មណ៍គិតថា កាលបើអញរៀនមន្តនេះ អញនឹងបានជាមនុស្សច្បងក្នុងសកលជម្ពូទ្វីប លុះគិតដូច្នេះហើយ ទើបបញ្ជូនពួកព្រាហ្មណ៍ជាបរិវារទាំងនោះទៅវិញថា អ្នកទាំងអស់គ្នាចូរនៅក្នុងទីនេះអស់ពីរបីថ្ងៃសិន ខ្ញុំនឹងបួសក្នុងសំណាក់ព្រះសាស្តា លុះបួសរួចហើយ មាននាមបញ្ញត្តិថាវង្គីសត្ថេរ ។ កាលដែលវង្គីសៈចូល

មកបួស ព្រះអង្គទ្រង់ឱ្យទុត្តិសាការកម្មដ្ឋាន ហើយទូន្មានថា ចូរអ្នកទន្ទេញមន្តនេះឱ្យចាំស្ទាត់ ។ វង្គីសត្ថេរកាលទន្ទេញមន្តនោះ ពួកព្រាហ្មណ៍ដទៃទៀតតែងចូលទៅសួរថា លោករៀនយកមន្តនោះហើយឬ ? ទើបលោកប្រាប់ថា អ្នកទាំងអស់គ្នាចូររង់ចាំសិន ខ្ញុំនឹងរៀនយកមន្តនោះ ។ អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ទើបពួកព្រាហ្មណ៍ចូលមកសួរម្តងទៀត លោកប្រាប់ថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ក្នុងកាលឥឡូវនេះអាត្មាជាមនុស្សមិនគួរនឹងទៅទេ ព្រោះបានដល់នូវទីបំផុតនៃសេចក្តីទុក្ខ ពោលគឺព្រះនិព្វានហើយ ។

## ២៥. រឿងនាងចិញ្ចមាណវិកា

( ចាក ធ. ខុ.. )

*( ការពោលដាក់ទោសកំហុសទៅលើអ្នកដទៃ*

*រមែងត្រូវត្រឡប់បានមកខ្លួនវិញ )*

សេចក្តីថា ក្នុងបឋមពោធិកាល ព្រះកិត្តិនាមនៃព្រះបរមសាស្តាល្បីល្បាញខ្ចរខ្ចាយសព្វទិសទី ពួកទេវតា នឹងមនុស្សទាំងឡាយបានសម្រេចនូវអរិយធម៌ ដោយបានស្តាប់ធម្មទេសនាព្រះអង្គ ម៉្លោះហើយលោកសក្ការៈកើតឡើងដល់ព្រះអង្គ ប្រៀបដូចទឹកដែលហូរចូលកាន់មហាសមុទ្រ រីឯពួកនិគ្រណ្ឋតិរ្ថិយត្រូវសាបសូន្យចាកលាភសក្ការៈ ប្រៀបដូចជាអំពិលអំពែកចាញ់រស្មីនៃព្រះអាទិត្យ ។ ដោយលាភសក្ការៈសាប

សូន្យយ៉ាងនេះ ពួកតិរ្ថិយទៅជាអាក់អន់ស្រពន់តូចចិត្ត ទើបប្រជុំគ្នាក្បែរផ្លូវធំមួយ ពិភាក្សារកមធ្យោបាយ ដើម្បីបន្ថុះបង្អាប់ព្រះកិត្តិនាម នៃព្រះបរមសាស្ដាដោយសេចក្ដីថា " ព្រះសមណគោតម ជាព្រះពុទ្ធអ្នកត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ឯពួកយើងក៏ត្រាស់ដឹងដូចគ្នាដែរ ទានដែលគេឱ្យដល់ព្រះសមនគោតមឈ្មោះថាបានផលានិសង្សច្រើន បើឱ្យដល់យើងផងក៏មានផលានិសង្សច្រើនដូចគ្នា ចុះហេតុដូចម្ដេច បានជាគេឱ្យតែព្រះសមណគោតម គេមិនឱ្យពួកយើង ? បើដូច្នេះយើងគិតរកមធ្យោបាយយ៉ាងណា ដើម្បីបំផ្លាញព្រះកិត្តិនាមព្រះសមណគោតមគ្រានេះម្ដង" ទើបសម្រេចចិត្តគិតឃើញឧបាយមួយថា " អើ ! អាំ ! នៅក្រុងសាវត្ថីមានស្ត្រីម្នាក់ឈ្មោះចិញ្ចមានវិកា មានរូបសម្ប័ទល្អះល្អឆើតឆាយគួរជាទីប្រតិព័ទ្ធស្នេហានៃជនទាំងពួង មានរស្មីចេញពីខ្លួនដូចទេពកញ្ញា ទាំងប្រាជ្ញាក៏ឈ្លាសវៃ ល្មមឱ្យយើងពឹងពាក់យកជាការបាន បើអញ្ចឹងពួកយើងត្រូវជួលនាង ព្រមទាំងប្រាប់ឧបាយកលផ្សេងៗឱ្យនាងធ្វើតាម ។ លុះគិតគ្នាស្រេចហើយ ក៏ចាត់ការតាមសេចក្ដីសម្រេចចិត្តនោះ នាងចិញ្ចមាណវិកាកាលបើបានទទួលរង្វាន់ពីពួកតិរ្ថិយហើយ ក៏ទទួលភារៈធ្វើតាមបញ្ជាពួកតិរ្ថិយ ដោយសម្ដែងមាយាដូចតទៅនេះ :

ថ្ងៃមួយ ក្នុងពេលដែលព្រះបរមសាស្ដាកំពុងសម្ដែងធម្មទេសនាក្នុងវត្តជេតពន ប្រោសពុទ្ធបរិស័ទ នាងចិញ្ចមាណវិកាកែងដណ្ដប់សំពត់

ពណើដូចមេភ្លៀង ដើរតម្រង់ទៅកាន់វត្តនោះ សម្តែងអាការៈហាក់ដូចជា នាងមានទីលំនៅតែក្នុងវត្តហ្នឹងឯង ។ កាលបើមានមហាជនសួរ នាងប្រាប់ថា ខ្ញុំជាមហេសីព្រះសមណគោតម " ។ នាងចិញ្ចមាណវិកាតែងដើរចេញចូលក្នុងវត្តជេតពនអស់វារៈ ២-៣ខែ លុះដល់ខែទី៤-ទី៥ នាងយកកំណាត់សំពត់រុំពោះនាងរួចទទូសំពត់ក្រហម សម្តែងអាការៈហាក់ដូចជាមានផ្ទៃពោះ ដើរឃោសនាប្រាប់ពួកជនអន្ធពាលថា នាងមានផ្ទៃពោះជាមួយព្រះសមណគោតម ពួកជនអន្ធពាលល្ងង់ខ្លៅ ដែលមានប្រាជ្ញាស្តួចស្តើងក៏ជឿថា ជារឿងពិតមែន ។ លុះដល់ខែទី៨ ទី៩ ជួលជាងឱ្យឆ្លាក់ឈើឱ្យមានសណ្ឋានមូល រួចចងភ្ជាប់នឹងផ្ទៃពោះ ធ្វើហាក់ដូចជាពោះកាន់តែធំឡើងៗ ជិតគ្រប់ខែហើយ នាងជួលឱ្យគេដំសាច់ខ្នងជើងឱ្យមានសាច់ដូចជាស្ត្រីមានផ្ទៃពោះ រួចដើរសន្សឹមៗចូលទៅក្នុងចំណោមពុទ្ធបរិស័ទដែលកំពុងស្តាប់ធម៌ ស្រែកប្រកាសឡើងថា នែសមណគោតម ! លោកនៅសម្តែងធម៌យ៉ាងម៉េចទៀត ? ខ្ញុំមានកូនព្រោះតែលោករួមរស់មេត្រីប្រពៃណីជាមួយខ្ញុំ ម្តេចក៏លោកមិនរកផ្ទះសម្បែងអុសភ្លើងទុកឱ្យខ្ញុំប្រសូតកូន បើមិនធ្វើខ្លួនឯងទេ គួរតែប្រើអ្នកណាធ្វើក៏បានដូចជាអនាថបណ្ឌិក ឬនាងវិសាខាជាដើម លោកបានតែរួមរស់ត្រេកត្រអាលកាមរាគជាមួយខ្ញុំ តែដល់ខ្ញុំមានផ្ទៃពោះ លោកមិនចេះថែរក្សាទេ នែ! នៅសំដែងធម៌ដល់ណាទៀត ! "

គ្រានោះព្រះសាស្តាបង្អាក់ធម្មទេសនា រួចទ្រង់មានពុទ្ធដីកាថា " អើនាង! យើងទាំងពីរនាក់គត់តែដឹងថា" រឿងនេះជារឿងពិត ឬពុំពិត នៅថ្ងៃក្រោយ " ចូរនាងជ្រាបតែប៉ុណ្ណោះចុះ ។ លំដាប់នោះដោយអំណាចបារមីនៃព្រះសាស្តា ក៏ក្តៅដល់អាសនារបស់ព្រះឥន្ទ្រ ព្រះឥន្ទ្រក៏តាំងណែងខ្លួនជាបុរសមួយឈរកាន់ផ្តិតបក់ថ្វាយព្រះសាស្តា ហើយបក់ខ្លាំងៗ គ្រាតែសំពត់រុំពោះនាងចិញ្ចមាណវិការបើកប៉ើងអស់ពីខ្លួន ។ ពួកមហាជនឃើញដូច្នេះ កជេរប្រទេចផ្តាសាថា " នែមេកាឡកណ្ណី! មេចោរឆន្ទា! ហាងឯងបានតែបង្ខូចកិត្តិនាមព្រះសាស្តាយើង" រួចយកដំបងដេញឱ្យចេញពីទីប្រជុំនោះភ្លាម ។ ចិញ្ចមាណវិកា គ្រាន់តែចេញផុតពីព្រះភ័ក្ត្រព្រះសាស្តាមក ស្រាប់តែផែនដីស្រូបទម្លាក់ ទៅក្នុងគំនរភ្លើងអវិចីរមហានរក។ ឯពួកតិរ្ថិយរឹតតែលិបរស្មីថែមទៀត ឯលាភសក្ការៈរឹតតែកើតឡើងៗដល់ព្រះសាស្តា ។

ក្នុងពេលជាមួយនោះព្រះសាស្តាទ្រង់សំដែងថា " អ្នកណាក៏ដោយ បើមិនទាន់ឃើញទោសកំហុសតូចធំរបស់អ្នកដទៃទេ មិនត្រូវទំលាក់កំហុសតែផ្តេសផ្តាសដល់គេទេ ត្រូវពិចារណាមើល ឬយកការណ៍ឱ្យច្បាស់សិន "

រួចសម្តែងរឿងមហាបទុមកុមារដូចតទៅ

សេចក្តីថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានេះ ជាស្ត្រីរួមប្តីជាមួយមាតាមហាបទុមកុមារ (ជាទេពីចុង) នៃព្រះរាជាមួយអង្គ ។ ថ្ងៃមួយ ក្នុងពេលដែលព្រះរាជាយាងទៅក្រសាលព្រៃផុតទៅ នាងបានលួងលោមមហាបទុមកុមារឱ្យធ្វើសន្ថវកិច្ចជាមួយនាង តែមហាបទុមកុមារពុំព្រម ។ នាងក៏សម្តែងអាការៈហាក់ដូចជាអាក់អន់ស្រពន់ចិត្តក្លែងទោសថា មហាបទុមកុមារសង្កត់សង្កិនបង្ខំខ្លួនដោយអសទ្ធម្ម ថ្វាយស្វាមីក្នុងគ្រាដែលយាងមកដល់ ។ ក្នុងខណៈនោះព្រះរាជាទ្រង់ពិរោធ ក៏ចាត់ប្រើពេជ្ឈឃាតឱ្យចាប់បទុមកុមារទៅទម្លាក់ក្នុងជ្រោះ សម្រាប់ទម្លាក់ចោរ តែទេវតាដែលអាស្រ័យនៅក្បែរជ្រោះបីទ្រ ហើយយកទៅដាក់ឱ្យគង់នៅឯពិភពនាគ ។ នៅក្នុងពិភពនាគមិនយូរប៉ុន្មាន បទុមកុមារក៏ទៅបួសជាឥសីនៅក្នុងព្រៃហេមពាន្ត បានសម្រេចឈាន នឹងអភិញ្ញ ។ ថ្ងៃមួយព្រានព្រៃម្នាក់បានជួបនឹងបទុមតាបស ក៏នាំដំណឹងនោះទៅថ្វាយព្រះមហាក្សត្រ ។ ព្រះមហាក្សត្រទ្រង់មានព្រះទ័យអាល័យបុត្រទ្រង់យាងទៅនិមន្តបទុមតាបសឱ្យមកសោយរាជ្យវិញ តែបទុមតាបសទេសនាទូន្មានឱ្យព្រះបិតាគ្រប់គ្រងរាជ្យ ដោយទសពិធរាជធម៌ចុះ កុំឱ្យប្រកាន់អគតិដោយមិនបានពិចារណាជាមុន ។ ឯព្រះមហាក្សត្រយាងត្រឡប់មកនគរវិញមានព្រះឱង្ការជាមួយមហាមាត្យថា កូនយើងមានអចារៈសមរម្យយ៉ាងនេះ មិនគួរបើយើងធ្វើដូច្នេះសោះ អ្នកណាធ្វើឱ្យកូនយើងមាន

ទោសដល់ម្ទឹង ? មហាមាត្យក្រាបទូលថា មានតែព្រះទេពីចុងទេ ! ៉ ។ ព្រះរាជាទ្រង់បញ្ជាឱ្យចាប់ទេពីចុង យកទៅប្រហារជីវិតក្នុងគ្រានោះ ហើយសោយរាជដោយធម៌រហុតមក ព្រោះហេតុនោះ

- មុននឹងទម្លាក់កំហុសទៅលើនរណាមួយ បុគ្គលត្រូវស៊ើបយកការណ៍ ឬពិចារណាមើលឱ្យសព្វគ្រប់សិន ។

**( ចប់ )**

**សូមរង់ចាំអានភាគ ៦ និងភាគផ្សេងៗបន្តទៅទៀត**

# ៣៥៩

## ១- រឿងអម្ពដ្ឋមាណព

(ចាក អ.ទី.)

(ខត្តិយត្រកូល ជាត្រកូលខ្ពស់បំផុតក្នុងលោកតាមវណ្ណៈ)

សម័យមួយព្រះមានព្រះភាគ គង់ក្នុងព្រៃឥច្ឆានង្គលៈ ជាមួយភិក្ខុសង្ឃចំនួន ៥០០ អង្គ ។

កាលនោះមានមាណពម្នាក់ឈ្មោះអម្ពដ្ឋៈ ជាបញ្ញវ័ន្ត បានចេះដឹងនូវត្រៃវេទ និងវេយ្យាករណ៍ស្ទាត់ជំនាញ ជាសិស្សរបស់ព្រាហ្មណ៍ឈ្មោះបោក្ខរសាតិ ។ ព្រាហ្មណ៍នេះ កាលបើដឹងថា ព្រះមានព្រះភាគយាងមកគង់ក្នុងព្រៃឥច្ឆានង្គលៈហើយ ក៏ប្រើអម្ពដ្ឋមាណពជាសិស្សឱ្យចូលទៅពិនិត្យមើលលក្ខណៈរបស់ព្រះសម្ពុទ្ធ ។

មាណពនេះ ពុំមានសេចក្ដីគោរពចំពោះព្រះសម្ពុទ្ធឡើយ ហ៊ាននិយាយសំណេះសំណាលជាមួយព្រះអង្គ ដែលកំពុងគង់ដោយឥរិយាបថដើរឈររបស់ខ្លួន ។

ព្រះសម្ពុទ្ធទ្រង់ជ្រាបអាការៈ របស់មាណពដូច្នេះហើយ ទើបត្រាស់សួរថា ម្នាលមាណព អ្នកធ្លាប់តែចរចាជា

មួយនឹងពួកព្រាហ្មណ៍ចាស់ៗ ជាអាចារ្យរបស់អ្នក ដែលកំពុងអង្គុយដោយឥរិយាបថដើរឈរដូច្នេះឬ ?

មាណពឆ្លើយថា បពិត្រព្រះគោតម ព្រាហ្មណ៍កំពុងដើរគួរនិយាយជាមួយព្រាហ្មណ៍កំពុងដើរ, ព្រាហ្មណ៍កំពុងឈរ គួរនិយាយជាមួយព្រាហ្មណ៍កំពុងឈរ, ព្រាហ្មណ៍កំពុងអង្គុយ គួរនិយាយជាមួយព្រាហ្មណ៍កំពុងអង្គុយ, ព្រាហ្មណ៍កំពុងដេក គួរនិយាយជាមួយព្រាហ្មណ៍កំពុងដេក ។ បពិត្រព្រះគោតម ការដែលខ្ញុំនិយាយចរចាជាមួយព្រះអង្គដូចជាខ្ញុំនិយាយជាមួយសមណៈត្រងោល ជាគោត្រកូលគហបតី ជាកណ្ហគោត្រ ដែលកើតអំពីព្រះបាទមហាព្រហ្មច្នោះដែរ ។

ព្រះសម្ពុទ្ធត្រាស់តបវិញថា ម្នាលមាណព អ្នកមកក្នុងទីនេះត្រូវការដោយប្រយោជន៍ណា គួរធ្វើទុកក្នុងចិត្តដោយប្រយោជន៍នោះឱ្យបានសំរេចចុះ ។

មាណពស្តាប់មិនបាន ស្មានថាព្រះសម្ពុទ្ធថាខ្លួនគ្មានការសិក្សាក៏ខឹងអាក់អន់ចិត្តនិយាយទ្រគោះចំពោះព្រះអង្គថាជាតិសាក្យៈកាចណាស់ អាក្រក់ណាស់មានចិត្តស្រាល ណាស់, ជាតិសាក្យៈជាពូជគហបតីឥតគោរពពួកព្រាហ្មណ៍ឡើយ ។

ព្រះសម្ពុទ្ធសួរថា ម្នាលមាណព ចុះពួកសាក្យៈបានប្រទូស្ត

នឹងអ្នកដូចម្ដេចខ្លះ ?

មាណពឆ្លើយថា កាលខ្ញុំទៅនគរកបិលព័ស្តុ បានចូលទៅក្នុងសាលាសម្រាប់បង្រៀនចំណេះវិជ្ជា របស់ពួកសាក្យៈ ឥតមានសាក្យៈណាគួរសមហៅខ្ញុំឱ្យអង្គុយសោះ គិតតែនិយាយសើចលេងធ្វើព្រងើយ ។ មាណពឆ្លើយដូច្នេះហើយក៏បន្ទុះបង្អាប់ពួកសាក្យៈទៀត ផរាបគ្រប់បីដង ។

ព្រះសម្ពុទ្ធមានព្រះតម្រិះថា មាណពនេះខ្លាំងណាស់តើ ហ៊ានញាំញីពួកសាក្យៈ ដោយជៀលពូជអម្បូរ. ទើបព្រះអង្គត្រាស់សួរមាណពថា ម្នាលអម្ពដ្ឋៈ អ្នកជាគោត្រអ្វីដែរ ?

មាណពឆ្លើយថា ខ្ញុំជាកណ្ហាយនគោត្រ ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលមាណព បើនិយាយទៅតាមគោត្ររបស់មាតាបិតាតាំងពីបុរាណមក នឹងបានដឹងថាមានព្រះអង្គម្ចាស់មួយអង្គជាពួកសាក្យៈ ឯខ្លួនមាណពជាកូននៃទាសីរបស់ព្រះអង្គម្ចាស់នោះ ។ ម្នាលមាណព ពួកសាក្យៈមានព្រះរាជាព្រះនាម ឧក្កាកៈ ជាបុព្វបុរស. ព្រះអង្គបានប្រទានពរចំពោះមហេសីទី ២ ដែលសុំរាជសម្បត្តិឱ្យបុត្ររបស់ខ្លួន ទើបបង្វេះព្រះរាជបុត្រ ព្រះរាជធីតារបស់មហេសីទី ១ ទាំង៩ ព្រះអង្គឱ្យទៅនៅក្នុងព្រៃ។ ព្រះរាជបុត្រព្រះរាជធីតា

ទាំងនោះបានសំរេចការនៅរួមជាមួយគ្នា ជាស្វាមីភរិយា ដោយខ្លាចខូចជាតិ នៅសល់ព្រះរាជធីតាច្បងមួយព្រះអង្គ ទុកជាមាតា, ពួកសាក្យវង្សក៏កើតមានប្រាកដឡើង ។ ព្រះបាទឧក្កាករាជនោះហើយ ជាបុព្វបុរសរបស់សាក្យៈ ។

ព្រះបាទឧក្កាករាជនោះ មានទាសីម្នាក់ឈ្មោះនាងទិសា បានបង្កើតកូនប្រុសម្នាក់ឈ្មោះកណ្ហៈ ។ លុះកណ្ហៈប្រសូត្រមក ក៏ស្រែកយំថា ម៉ែចូរលាងខ្ញុំ ម៉ែចូរផ្ងូតទឹកខ្ញុំ ម៉ែចូរនាំខ្ញុំអំពីទីស្មោកគ្រោកនេះចេញ ខ្លួនខ្ញុំនឹងមានប្រយោជន៍ដល់ម៉ែ ។ មនុស្សទាំងឡាយ នាំគ្នាសម្គាល់កណ្ហកុមារដូចជាបិសាច ។ ចាប់ពីពេលនោះមកកណ្ហាយនគោត្រក៏កើតប្រាកដឡើង ។ កណ្ហកុមារនេះឯងហើយ ជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ។

កាលព្រះសម្ពុទ្ធត្រាស់យ៉ាងនេះចប់ហើយ ពួកមាណពជាបរិវាររបស់អម្ពដ្ឋមាណពតវ៉ាថា ព្រះអង្គកុំញាំញីអម្ពដ្ឋមាណពថាជាកូនទាសីអម្ពដ្ឋៈ ជាអ្នកមានកំណើតល្អ មានត្រកូលល្អ ជាអ្នកចេះដឹងសមនឹងប្រើក្សាឆ្លើយឆ្លងជាមួយព្រះអង្គ ។

ព្រះសម្ពុទ្ធត្រាស់ថា បើអ្នកទាំងឡាយយល់ថា អម្ពដ្ឋ

មាណពមានកំណើតមិនល្អ មិនសមប្រឹក្សាឆ្លើយឆ្លងជាមួយតថាគតទេ ឱ្យអម្ពដ្ឋឈប់ចុះ ចូរអ្នកទាំងឡាយឆ្លងឆ្លើយជាមួយតថាគតវិញ. បើអ្នកទាំងឡាយយល់ថាអម្ពដ្ឋៈមានកំនើតល្អ ជាកូនអ្នកមានត្រកូលល្អ គួរឆ្លងឆ្លើយជាមួយតថាគត អ្នកទាំងឡាយចូរឈប់ចុះ ឱ្យអម្ពដ្ឋៈឆ្លងឆ្លើយគ្នាជាមួយតថាគត។

មាណពទាំងឡាយឆ្លើយថាអម្ពដ្ឋៈ ជាអ្នកមានកំណើតល្អ មានត្រកូលខ្ពស់គួរឆ្លងឆ្លើយជាមួយព្រះអង្គហើយ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់ត្រាស់ ចំពោះអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋៈ តថាគតសួរអ្នកត្រូវតែឆ្លើយ ទោះបីអ្នកប្រាថ្នា និងមិនឆ្លើយក៏ត្រូវតែឆ្លើយ បើអ្នកមិនឆ្លើយក្តី និយាយវាសវាងទៅរកហេតុដទៃក្តី នៅស្ងៀមក្តី ដើរចេញទៅក្តី ក្បាលអ្នកនឹងបែកជា ៧ ភាគក្នុងទីនេះមិនខាន។ តថាគតសួរថា អ្នកធ្លាប់ឮព្រាហ្មណ៍ចាស់ៗ និយាយថា ពួកកណ្ហាយនគោត្រកើតពីណា ? អ្នកណាជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ?

កាលព្រះសាស្តាត្រាស់សួរយ៉ាងនេះហើយ អម្ពដ្ឋមាណពនៅស្ងៀម ព្រះអង្គសួរជាគំរប់ពីរផងនៅស្ងៀមទៀត ព្រះសាស្តាត្រាស់ថា ម្នាលមាណព ឥឡូវនេះអ្នកត្រូវឆ្លើយ

ហើយមិនត្រូវនៅស្ងៀមទេ. បុគ្គលណាដែលតថាគតសួរ ប្រស្នាប្រកបដោយហេតុផល អស់វារៈបីដងហើយមិនឆ្លើយ ក្បាលបុគ្គលនោះនឹងបែកជា ៧ ភាគក្នុងទីនេះមិនខាន ។

សម័យនោះមានយក្សមួយឈ្មោះវជិរបាណិ កាន់ ដំបងដែកយ៉ាងធំ ដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ មកឈរ ឯអាកាសខាងលើអម្ពដ្ឋមាណពបម្រុងចាំវាយក្បាលមាណព នោះ ។ មាណពឃើញហើយ ក៏តក់ស្លុតស្លន់ទៅរកព្រះមាន ព្រះភាគ សុំជាទីពឹងទីរឮក ហើយអង្គុយក្នុងទីជិត ទើបក្រាប ទូលថា សូមព្រះអង្គត្រាស់ម្ដងទៀត ខ្ញុំព្រះអង្គនឹងឆ្លើយ ។

ព្រះមានព្រះភាគត្រាស់សួរដូចមុន, អម្ពដ្ឋមាទណព ឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលខ្ញុំធ្លាប់ឮមកថា កណ្ហកុមារនោះហើយជាបុព្វបុរស របស់ពួកកណ្ហាយន គោត្រ ។

កាលបើអម្ពដ្ឋមាណពឆ្លើយដូច្នេះហើយ ពួកមាណព ទាំងឡាយ ជា បរិវារ ក៏បន្លឺសម្លេងគឹកកងថា ម្នាលគ្នា យើង អម្ពដ្ឋមាណពជាមនុស្សមានជាតិត្រកូលថោកទាប ណាស់ ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា អម្ពដ្ឋមាណពត្រូវគេ

មើលងាយដូច្នេះ គួរតែថាគតជួយដោះស្រាយចេញ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ចំពោះពួកមាណព ទាំងឡាយថា អ្នកទាំងឡាយកុំមើលងាយអម្ពដ្ឋមាណពខ្លាំង ពេក, កាលពីភរិកណ្ហកុមារនោះ បានបួសជាឥសីជាអ្នកថ្កើង ថ្កានណាស់ គាត់ទៅកាន់ទក្ខិណជនបទ បានរៀនចេះស្ទាត់ ជំនាញនូវព្រហ្មមន្តទាំងឡាយ ហើយចូលទៅគាល់ព្រះបាទ ឱក្កាករាជ សូមព្រះរាជធីតានាមមទ្ទរូបី ។ ព្រះបាទឱក្កាក រាជក្រោធពិរោធថា អាមនុស្សចង្រៃ ជាកូននៃទាសីមិនគួរ មកសូមនាងមទ្ទរូបីជាធីតាអញសោះ ទើបផ្គងសរឡើងបាញ់ ឥសីនោះ ។ ប៉ុន្តែដោយអានុភាពមន្តរបស់ឥសី ព្រះបាទឱក្កា ករាជគាំងរឹងព្រះហស្តព្រះបាទ មិនអាចថ្លែងសរ មិនអាច ដាក់ចុះនូវកូនសរបាន ។

ពេលនោះពួករាជសេវកាមាត្យ បានអង្វរឥសីថា សូម សួស្តីកើតមានដល់ព្រះរាជា ។ កណ្ហឥសីតបថាសួស្តីគង់មាន ដល់ព្រះរាជាមិនខាន ប៉ុន្តែបើព្រះរាជាថ្លែងសរទៅទិសខាង ក្រោម ផែនដីនឹងស្រុត បើថ្លែងសរទៅទិសខាងលើ នឹងរាំង ភ្លៀងអស់ ៧ ឆ្នាំ, ប៉ុន្តែបើព្រះរាជាប្រគល់សរទុកលើព្រះរាជ កុមារច្បង ព្រះរាជកុមារនឹងជាអ្នកមានសួស្តី មិនមានភិត

ភ័យឡើយ ។

លំដាប់នោះពួករាជអាមាត្យ និងព្រះបាទឧក្កករាជ ទ្រង់ប្រគល់សរទៅថ្វាយព្រះរាជកុមារច្បងហើយ ព្រះបាទឧក្កករាជ បានថ្វាយព្រះរាជធីតា ព្រះនាមមទ្ធរូបីដល់កណ្ហាឥសីនោះដោយរីករាយ ។

ព្រះមានព្រះភាគ ត្រាស់បញ្ជាក់ចំពោះអម្ពដ្ឋមាណព ដូច្នេះហើយ ទើបសម្ដែងអំពីការនៅរួមសំវាសរបស់ក្សត្រ និងព្រាហ្មណ៍ ព្រះអង្គសួរឱ្យមាណពឆ្លើយ ដើម្បីឱ្យឃើញច្បាស់ថា បើមាតាជាក្សត្រ បិតាជាព្រាហ្មណ៍ កូនរបស់គ្រួសារបែបនេះឱ្យសោយរាជ្យមិនបាន, បើមាតាជាព្រាហ្មណ៍ បិតាជាក្សត្រ កូនរបស់គ្រួសារបែបនេះ គួរឱ្យសោយរាជ្យបាន ។

ទីបំផុតព្រះអង្គត្រាស់សំដែងថា :

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ

ប្រែថា ក្សត្រិយ៍ជាមនុស្សប្រសើរបំផុត ក្នុងប្រជុំជនដែលពោលអាងគោត្រ បុគ្គលដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាមនុស្សប្រសើរបំផុត ក្នុងពួកទេវតា និងមនុស្ស ។

បន្ទាប់មកអម្ពដ្ឋមាណព មានសេចក្ដីជ្រះថ្លាបានសួរអំពីវិជ្ជា និងចរណៈចំពោះព្រះមានព្រះភាគ លុះបានស្ដាប់ចប់ និងបានឃើញមហាបុរិសលក្ខណៈទាំង ៣២ របស់ព្រះអង្គហើយ ក៏លាព្រះសម្ពុទ្ធទៅកាន់សំណាក់អាចារ្យបោក្ខរសាតិវិញ ។ លោកអាចារ្យបានដំណឹងថាព្រះសម្ពុទ្ធប្រកបដោយលក្ខណៈ ៣២ ហើយ ក៏មកពិនិត្យដោយខ្លួនឯង មានសេចក្ដីជ្រះថ្លា បាននិមន្តព្រះសម្ពុទ្ធមួយអន្លើ ដោយភិក្ខុសង្ឃទទួលភត្តក្នុងលំនៅរបស់ខ្លួន បានស្ដាប់អនុបុព្វីកថា របស់ព្រះសម្ពុទ្ធហើយ បានសម្រេចមគ្គផលថ្នាក់សោតាបត្តិមគ្គ ។

## ២- រឿងនាងចូឡសុភទ្ទា

(ចាក ធ. ខុ.)

(ពិធីអាពាហ៍ពិពាហ៍របស់ពុទ្ធបរិស័ទក្នុងសម័យពុទ្ធកាល)

កាលព្រះបរមគ្រូ គង់នៅវត្តជេតពន ទ្រង់សម្តែងធម៌ប្រារព្ធនឹងនាងចូឡសុភទ្ទា ជាធីតារបស់អនាថបិណ្ឌិកសេដ្ឋី។ មានសេចក្តីដំណាលថា សេដ្ឋីបុត្រឈ្មោះ ឧគ្គៈ នៅឧគ្គនគរ ជាមិត្តសម្លាញ់នឹងអនាថបិណ្ឌិក តាំងពីកាលនៅក្មេងៗម្ល៉េះ។ ជនទាំងពីរនាក់នោះ កាលនៅរៀនមន្តក្នុងសំណាក់អាចារ្យជាមួយគ្នា បានប្តេជ្ញាគ្នាទៅវិញទៅមកថា កាលណាយើងទាំងអស់គ្នាមានគូរស្រកររៀងៗខ្លួនទៅ មានកូនប្រុសស្រីយើងត្រូវចងជាឡុងគ្នា, ជនទាំង ២ នាក់នោះប្តេជ្ញាគ្នារួចហើយ សុំលាអាចារ្យត្រឡប់ទៅស្រុកវិញ ។ លុះដល់ជនទាំងពីរនាក់នោះ មានវ័យពេញបរិបូណ៌ បានឡើងជាសេដ្ឋីទាំង២នាក់នៅក្នុងនគររៀងៗខ្លួន ។

សម័យថ្ងៃមួយ ឧគ្គសេដ្ឋីបញ្ជូនពួកទាយពាណិជ ព្រមទាំងទ្រព្យដាក់ពេញរទេះទាំង ៥០០ ទៅនគរសាវត្ថី ។ អនាថបិណ្ឌិកហៅនាងចូឡសុភទ្ទា ជាកូនក្រមុំរបស់ខ្លួនមកប្រាប់ថា ម្នាលកូនស្រី បិតាក្មេកកូនឈ្មោះឧគ្គសេដ្ឋីមកដល់

ហើយ កិច្ចការដែលនាងត្រូវទទួលចាត់ចែងចំពោះបិតាក្មួន ជាអាការៈរបស់ក្មួនឯងហើយ ។ នាងក៏ទទួលគោរពប្រតិបត្តិតាមពាក្យបិតា ។ តាំងពីថ្ងៃដែលឧគ្គសេដ្ឋីមកដល់ នាងចាត់ចែងភោជនាហារដោយដៃខ្លួនឯង តាក់តែងគ្រឿងសក្ការបូជា មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម អញ្ជើញលោកសេដ្ឋីឱ្យង្វូតមុនពេលបរិភោគបាយ លុះគាត់បរិភោគរួចហើយ នាងធ្វើកិច្ចវត្តគ្រប់យ៉ាងទៀត ។ លោកឧគ្គសេដ្ឋីពិនិត្យឃើញចរិយាសម្បត្តិរបស់នាងចូឡសុភទ្ទា មានសេចក្ដីពេញចិត្ត. ថ្ងៃមួយអង្គុយនិយាយសំណេះសំណាលគ្នាលេងជាមួយនឹងអនាថបិណ្ឌិកសេដ្ឋី ហើយញុំាងអនាថបិណ្ឌិកឱ្យរលឹកឃើញពាក្យប្ដេជ្ញានឹងគ្នាកាលនៅពីក្មេង។ ទើបនិយាយដណ្ដឹងនាងចូឡសុភទ្ទាឱ្យក្មួនប្រុសរបស់ខ្លួន ។

ចំណែកឧគ្គសេដ្ឋី ជាមនុស្សមិច្ឆាទិដ្ឋិ ព្រោះហេតុនេះហើយ បានជាអនាថបិណ្ឌិក ត្រូវនាំយករឿងនោះទៅទូលព្រះសាស្ដាឱ្យបានជ្រាប ព្រះអង្គទ្រង់ឃើញឧបនិស្ស័យនៃឧគ្គសេដ្ឋី ទើបទ្រង់អនុញ្ញាត ហើយគាត់មកប្រឹក្សាជាមួយនឹងភរិយា ក៏ស្រុះស្រួលមូលមតិព្រមឱ្យតាមពាក្យដណ្ដឹងរបស់ឧគ្គសេដ្ឋី ទើបកំណត់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ។

ការចាត់ចែងរៀបចំគ្រឿងសក្ការៈយ៉ាងឧឡារិក ក្នុងពិធីអាពាហ៍ពិពាហ៍នោះ ដូចជាធនញ្ជយសេដ្ឋីឱ្យនាងវិសាខាជាធីតារបស់ខ្លួនទៅបុត្រនៃមិគារសេដ្ឋី ឈ្មោះបុណ្ណវឌ្ឍនកុមារដែរ ។ លុះចប់កិច្ចមង្គលការហើយ អនាថបិណ្ឌិកសេដ្ឋីបានហៅនាងចូឡសុភទ្ទាមកឱ្យឱវាទ ១០យ៉ាង ដូចជាធនញ្ជយសេដ្ឋីឱ្យឱវាទដល់នាងវិសាខាដែរ ។

លុះឱ្យឱវាទហើយ បានឱ្យកុដុម្ពី ៨ នាក់ជាអ្នកធានាទៅជាមួយផង ប្រាប់ថា បើទោសមានឡើងដល់ធីតារបស់យើង អ្នកទាំងអស់គ្នាត្រូវកាត់សេចក្ដីឱ្យជ្រះស្អាតត្រឹមត្រូវផង ។ ក្នុងថ្ងៃដែលបញ្ជូននាងសុភទ្ទាទៅកាន់សំណាក់ឪពុកក្មេក អនាថបិណ្ឌិកសេដ្ឋីបានថ្វាយមហាទាន ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន រួចទើបបញ្ជូនទៅ ។

ពួកមហាជន ព្រមទាំងឪពុកក្មេក បានទៅទទួលក្នុងពេលដែលនាងទៅដល់ឧត្តនគរតាមលំដាប់. នាងអង្គុយលើរថបង្ហាញខ្លួនដល់អ្នកនគរឱ្យបានឃើញច្បាស់ ដូចជានាងវិសាខាដែរ ទើបចូលទៅក្នុងនគរ ទទួលយកគ្រឿងបណ្ណាការ ដែលពួកអ្នកនគរផ្ញើទៅជូន ហើយបានផ្ញើគ្រឿងបណ្ណាការផ្សេងៗ ទៅជូនជនទាំងនោះវិញតាមសមគួរ ហើយបាន

ធ្វើឱ្យពួកអ្នកនគរមានសេចក្ដីសាមគ្គីរាប់អានគ្នា ដោយសារគុណរបស់នាង ។

ចំណែកឪពុកក្មេក ក្នុងថ្ងៃរៀបមង្គលការ បាននិមន្តពួកអចេលក៍ជាច្រើន ហើយបង្គាប់កូនប្រសារ ឱ្យទៅថ្វាយបង្គំពួកសាមណៈរបស់គាត់ នាងមានសេចក្ដីអៀនខ្មាស មិនព្រមចេញទៅថ្វាយបង្គំពួកសាមណៈអាក្រាតទាំងនោះ ។ បិតាក្មេកប្រើញយៗ នាងប្រកែក គាត់ខឹងឱ្យដេញនាងចុះពីផ្ទះចេញ ។ នាងជម្រាបថា លោកឪពុកមិនអាចនឹងចាប់កំហុសខ្ញុំដោយគ្មានហេតុទេ ហើយនាងហៅពួកកុដុម្ពីមកប្រាប់រឿងហេតុនោះ ។ ពួកកុដុម្ពីដឹងថានាងគ្មានកំហុស បាននិយាយសម្រុះសម្រួលឱ្យជានាទឹងគ្នាវិញ ។ ឧគ្គសេដ្ឋីនិយាយប្រាប់ប្រពន្ធថា នាងសុភទ្ទានេះ វាមិនថ្វាយបង្គំសាមណៈរបស់យើង ដោយវាគិតថាព្រះសាមណៈរបស់យើងគ្មានសេចក្ដីអៀនខ្មាសបានសោះ ។ ប្រពន្ធនិយាយថា ចុះសាមណៈរបស់វាមានគុណវិសេសដូចម្ដេចទៅ បានជាវាសរសើរខ្លាំងម្ល៉េះ ? ទើបគាត់ហៅនាងសុភទ្ទាមកសួរថា : ពួកសាមណៈរបស់នាងមានគុណវិសេសដូចម្ដេចខ្លះ ? បានជានាងសរសើរអីខ្លាំងម្ល៉េះ ? ពួកសាមណៈរបស់នាងមាន

សីលដូចម្តេច? មានសមាចារដូចម្តេច ? ចូរនាងប្រាប់យើងឱ្យបានដឹងផងមើល៍ !

លំដាប់នោះ នាងសុភទ្ទាសរសើរពីគុណព្រះពុទ្ធផង ពីគុណនៃសាវកព្រះពុទ្ធផង ឱ្យម្តាយក្មេក ព្រមទាំងឪពុកក្មេកស្តាប់ ដូចតទៅនេះ :

ព្រះសមណៈទាំងឡាយណា មានឥន្ទ្រីយ៍ស្ងប់ មានចិត្តស្ងប់ ដំណើរ និងជំហររបស់ព្រះសមណៈទាំងនោះស្ងប់ មានចក្ខុសំយុងចុះ មានការពោលតាមប្រមាណ ព្រះសមណៈទាំងឡាយប្រាកដដូចជានោះ ជាព្រះសមណៈរបស់ខ្ញុំ ។ ព្រះសមណៈទាំងនោះ មានកាយកម្មស្អាត មានវិចីកម្មមិនកករល្អក់ ទាំងមនោកម្មស្អាតវិសេស ជាព្រះសមណៈរបស់ខ្ញុំ ។ ព្រះសមណៈទាំងឡាយណា មានពន្លឺដូចជាស័ង្ខ និងកែវមុក្តាដែលមានមន្ទិលទៅប្រាសហើយ ស្អាតទាំងខាងក្នុង ទាំងខាងក្រៅ ពេញបរិបូណ៌ដោយធម៌ស្អាត ព្រះសមណៈទាំងនោះ ជាព្រះសមណៈរបស់ខ្ញុំ។ សត្វលោកមានចិត្តខ្ពស់ព្រោះលាភ មានចិត្តទ្រោមចុះព្រោះមិនមានលាភ ព្រះសមណៈរបស់ខ្ញុំ លោកមានចិត្តតាំងនៅក្នុងទីតែមួយ ។ សត្វលោកមានចិត្តខ្ពស់ព្រោះយស មានចិត្តទ្រោមចុះព្រោះមិនមាន

យស ព្រះសមណៈរបស់ខ្ញុំលោកមានចិត្តតាំងនៅក្នុងទីតែមួយ ។ សព្វលោកមានចិត្តខ្ពស់ព្រោះសេចក្ដីសរសើរ មានការទ្រោមចុះព្រោះការត្មាសតិះដៀល ព្រះសមណៈរបស់ខ្ញុំលោកមានចិត្តស្មើក្នុងការសរសើរ និងការនិន្ទា ។ សព្វលោកមានចិត្តខ្ពស់ព្រោះបានសុខ មានចិត្តទ្រោមចុះព្រោះមានទុក្ខ ព្រះសមណៈរបស់ខ្ញុំ លោកមានចិត្តកំបើកក្នុងសេចក្ដីសុខ និងទុក្ខនេះ, លុះចប់ការសរសើរទាំងនេះ ឪពុកនិងម្ដាយក្មេកមានចិត្តត្រេកអរគ្រប់គ្នា ។

លំដាប់នោះឪពុកក្មេកសួរថា តើនាងអាចឱ្យយើងឃើញព្រះសមណៈរបស់នាងបានឬទេ ? នាងជម្រាបថា ខ្ញុំអាចឱ្យលោកឪពុកឃើញបាន, បើដូច្នោះ ចូរនាងធ្វើឱ្យយើងឃើញលមើល៍ ! ។ នាងនិយាយថា ប្រពៃហើយលោកឪពុកទើបឡើងទៅលើប្រាសាទខាងលើ បែរមុខឆ្ពោះទៅរកវត្តជេតពន លើកដៃថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ពិចារណាព្រះពុទ្ធព្រះគុណ បូជាគ្រឿងក្រអូប គ្រឿងអប់ ផ្កានិងធូបអធិដ្ឋានថា សូមនិមន្តព្រះភិក្ខុសង្ឃ ព្រមទាំងព្រះពុទ្ធ ដើម្បីឆាន់ក្នុងថ្ងៃស្អែក សូមព្រះសាស្ដាទ្រង់ជ្រាប នូវការនិមន្តរបស់ខ្ញុំព្រះអង្គដោយសញ្ញានេះ ហើយបោះបាច់ផ្កាម្លិះ ៨

ទៅលើអាកាស ។ បាច់ផ្កាទាំងនោះ បានទៅប្រតិស្ឋានដូចជាពិដានផ្កាកម្រង ខាងលើព្រះសាស្តាដែលកំពុងសម្តែងធម៌ទេសនាចំកណ្តាលបរិស័ទទាំង ៤ ពួក ។

ខណៈនោះ អនាថបិណ្ឌិកស្តាប់ព្រះធម្មកថាហើយ និមន្តព្រះសង្ឃឆាន់ក្នុងថ្ងៃព្រឹកឡើង។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលគហបតី តថាគតបានទទួលនិមន្តគេរួចទៅហើយ. គហបតីទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលមកដល់មុនខ្ញុំព្រះអង្គមិនមានទេ តើព្រះអង្គទទួលនិមន្តរបស់នរណា? ម្នាលគហបតី តថាគតទទួលនិមន្តរបស់នាងចូឡសុភទ្ទា. បពិត្រព្រះអង្គដ៏ចម្រើន ក្រែងនាងសុភទ្ទានៅឆ្ងាយពីទីនេះចំនួន ១២០យោជន៍ឬ? ព្រះអង្គត្រាស់ថាមែនហើយគហបតី តែថាសប្បុរសទុកជានៅឆ្ងាយយ៉ាងណាក៏ដោយ តែងតែប្រាកដដូចជានៅនឹងមុខដែរ ហើយទ្រង់សម្តែងគាថានេះថា :

សប្បុរសទាំងឡាយ ទុកជានៅឆ្ងាយក៏ដោយ រមែងប្រាកដដូចជាភ្នំហិមពាន្ត សប្បុរសទាំងឡាយរមែងមិនប្រាកដក្នុងទីនេះ ដូចសរដែលគេបាញ់នៅក្នុងវេលាយប់ដូច្នោះដែរ ។

ចំណែកខាងសក្កទេវរាជទ្រង់ជ្រាបថា ព្រះសាស្តាទ្រង់ជ្រាបថា

ទទួលនិមន្តរបស់នាងសុភទ្ទាដូច្នោះ ទើបប្រើវិស្សកម្មទេវ-បុត្រឱ្យទៅនិម្មិតផ្ទះមានកំពូល(កូដាគារ) ៥០០ខ្នង ដើម្បីព្រះសាស្ដាព្រមទាំងភិក្ខុសង្ឃនិមន្តមកឧគ្គនគរក្នុងថ្ងៃស្អែកនេះ។ លុះព្រឹកឡើងវិស្សកម្មទេវបុត្រ និម្មិតផ្ទះទាំងនោះហើយស្រេច ព្រះសាស្ដាទ្រង់ជ្រើសរើស នាំព្រះខីណាស្រពសុទ្ធតែជាសុក្ខវិបស្សកៈ៥០០អង្គ យាងទៅគង់នៅក្នុងផ្ទះទាំងនោះ ចំណែកឧគ្គសេដ្ឋី ព្រមទាំងបរិវារ ឈរចាំមើលព្រះអង្គយាងមកតាមពាក្យដែលនាងសុភទ្ទាប្រាប់ ក៏បានឃើញព្រះសាស្ដាយាងមកប្រកបដោយសិរីសម្បត្តិដ៏ មហស្ចារ្យមានចិត្តជ្រះថ្លាថ្វាយបង្គំបូជាគ្រឿងសក្ការៈ ថ្វាយមហាទានអស់ ៧ ថ្ងៃ ។ ឯព្រះសាស្ដាទ្រង់កំណត់នូវសេចក្ដី សប្បាយរីករាយរបស់ឧគ្គ-សេដ្ឋីហើយ ទើបទ្រង់សម្ដែងធម៌. សត្វ ៨៤ ពាន់មានឧគ្គ-សេដ្ឋីជាដើម បានសម្រេចគុណធម៌ផ្សេងៗគ្នា។ ព្រះអង្គទ្រង់ឃាត់ទុកព្រះអនុរុទ្ធត្ថេរឱ្យនៅកន្លែងនោះ ដើម្បីអនុគ្រោះដល់នាងសុភទ្ទា ហើយព្រះអង្គ ទ្រង់នាំព្រះខីណាស្រពដទៃទៀត យាងត្រឡប់ទៅក្រុងសាវត្ថីវិញ ។ តាំងពីពេលនោះមក ពួកអ្នកឧគ្គនគរ មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានរីកចំរើនពេញនគរទាំងមូល ។

## ៣- រឿងភរិយារបស់គោបាល និងសាហាយពីរនាក់

(ឋាក. ត.ប.)

(ការវៃឆ្លាតរបស់ស្ត្រីក្បត់ប្តី)

នៅក្នុងបុរីទ្វារាវតី មានស្ត្រីម្នាក់ជាភរិយាគោបាល ជាស្ត្រីចិត្តចើករហើរហើយ នៅចងចិត្តរីករាយដោយផ្លូវកាមលោកិយ នឹងមន្ត្រីកាន់ការទណ្ឌនាយក ព្រមទាំងបុត្រកំលោះគាត់ផងនៅក្នុងក្រុងនោះ ។

ថ្ងៃមួយ, ភរិយាគោបាលនោះអង្គុយប្រឡែងលេងជាទីរីករាយជាមួយនឹងបុត្រទណ្ឌនាយកដោយតាមតណ្ហា។ កំពុងតែរីករាយដោយសេចក្តីស្នេហា, ទណ្ឌនាយកមកដល់,ភរិយាគោបាលក៏លបយកបុត្រទណ្ឌនាយកនោះទៅលាក់ក្នុងជង្រុកភ្លាម ហើយចេញមកសំណេះសំណាលជាមួយទណ្ឌនាយកវិញ និយាយសើចលេងក្អាកក្អាយដោយក្តីប្រតិព័ទ្ធ ។ កាលនោះឯងគោបាលជាប្តីនាងនោះត្រឡប់ពីឃ្វាលគោមកដល់។ ភរិយាគោបាលឃើញប្តីមកដល់និយាយខ្សឹបៗនឹងទណ្ឌនាយកថា "នែលោកទណ្ឌនាយក! លោកកាន់ដំបងមួយ ហើយដើរចេញទៅយ៉ាងរហ័សធ្វើអាការៈហាក់ដូចជាក្រោធខឹងណាស់" និយាយរួចហើយទណ្ឌនាយកធ្វើតាមភ្លាម ។

គោបាលចូលមកដល់ក្នុងផ្ទះសួរប្រពន្ធថា : "ទណ្ឌនាយកនេះក្រោធនឹងរឿងអ្វីខ្លាំងម្ល៉េះ?" ។ ភរិយាគោបាល ឆ្លើយប្រាប់ថា : "លោកទណ្ឌនាយក លោកខឹងនឹងកូនលោក ខ្ញុំមិនដឹងជាមានហេតុអ្វីដែរ កូនលោកនោះរត់ចូលមកជ្រកក្នុងផ្ទះយើង ឥឡូវខ្ញុំជួយយកទៅលាក់ក្នុងជង្រុករក្សាទុកទៅហើយ, លោកទណ្ឌនាយកចូលមកក្នុងផ្ទះយើង រកកូនលោកនោះមិនឃើញ ខឹងណាស់មុខក្រញូវដើរចេញទៅវិញទៅ"។ ពេលនោះ ភរិយាគោបាលចូលទៅនាំយកបុត្រទណ្ឌនាយកនោះ ចេញពីជង្រុកមកបង្ហាញប្តី, ដោយកលមាយាដ៏ឆ្លាតវៃនេះ នាយគោបាលជាស្វាមីឥតដឹងការក្បត់របស់ភរិយាខ្លួនឡើយ ។

## ៨- រឿងនាងអម្ពបាលី

(ធាក. ម. ទី.)

(ឱទ្យានរបស់ស្ត្រីផ្កាមាសបានក្លាយជាអារាមរបស់ពុទ្ធសាសនា)

កាលព្រះសម្ពុទ្ធបរមគ្រូ ស្តេចយាងទៅក្រុងវេសាលី, កាលនោះ នាងអម្ពបាលីជាស្ត្រីផ្កាមាស បានដឹងថាព្រះមានព្រះភាគគង់នៅក្នុងអម្ពវ័ន(ព្រៃស្វាយ) របស់ខ្លួន ហើយមានសេចក្តីជ្រះថ្លា បានរៀបចំយានដ៏ថ្លៃថ្លា ចេញពីក្រុងវេសាលីបរសំដៅទៅអម្ពវ័ន ។ លុះទៅដល់ ថ្វាយបង្គំព្រះសម្ពុទ្ធហើយអង្គុយក្នុងទីគួរមួយ ទើបព្រះសម្ពុទ្ធសម្តែងធម្មកថាឱ្យស្តាប់, លុះបានស្តាប់ចប់ហើយ មានសេចក្តីជ្រះថ្លា បាននិមន្តព្រះសម្ពុទ្ធ ព្រមទាំងព្រះសង្ឃទទួលភត្តក្នុងថ្ងៃស្អែក ព្រះអង្គទទួលដោយតុណ្ហីភាព ។ នាងអម្ពបាលីដឹងថា ព្រះអង្គទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំធ្វើប្រទក្សិណហើយចេញទៅ ។

ចំណែកខាងពួកស្តេចលិច្ឆវី អ្នកនៅក្នុងក្រុងវេសាលីបានឮដំណឹងថា ព្រះសម្ពុទ្ធយាងមកដល់ក្រុងវេសាលី គង់នៅក្នុងអម្ពបាលីវ័នហើយ ក៏នាំគ្នារៀបចំយានដ៏ថ្លៃថ្លារៀងៗខ្លួនបរចេញទៅ មានសភាពគួរឱ្យទស្សនាពន់ពេក ព្រោះពួក

ស្ដេចលិច្ឆវីនេះ មានរូបឆោមល្អស្រស់ប្រើសំលៀកបំពាក់ គ្រឿងអលង្ការក៏ល្អស្រស់ឆើតឆាយគ្រប់ពណ៌ គឺពួកស្ដេចលិច្ឆវីខ្លះប្រើពណ៌ខៀវសុទ្ធទាំងអស់ តាំងពីឯកសណ្ឋានស្លៀកពាក់ និងគ្រឿងរាជរថជាដើម មើលទៅឃើញសុទ្ធតែខៀវ ។ ពួកខ្លះប្រើពណ៌ក្រហម មើលទៅឃើញសុទ្ធតែក្រហម ។ ពួកខ្លះប្រើពណ៌ស មើលទៅឃើញសុទ្ធតែស ។ល។ ពេលនោះនាងអម្ពបាលីស្រីផ្កាមាស បានឃើញពួកស្ដេចលិច្ឆវីកំឡោះៗ ល្អស្រស់ឆើតឆាយហើយ ក៏បរយានបំប៉ះរាជរថទាំងនោះ ។

ស្ដេចលិច្ឆវីសួរថា ហេតុអ្វីនាងធ្វើដូច្នេះ. នាងអម្ពបាលីឆ្លើយថា បពិត្រអយ្យបុត្ត បានជាខ្ញុំធ្វើយ៉ាងនេះ ព្រោះខ្ញុំនិមន្តព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃឆាន់ក្នុងថ្ងៃស្អែកបានហើយ ។ ពួកស្ដេចលិច្ឆវី មានបន្ទូលថា នែនាងអម្ពបាលី ចូរនាងឱ្យភត្តកាលនោះមកយើងៗ នឹងឱ្យតម្លៃនាង ១សែនកហាបណៈ ។

នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្ត ទុកថាព្រះអង្គប្រទានទូវក្រុងវេសាលី ព្រមទាំងជនបទដល់ខ្ញុំម្ចាស់ក៏ខ្ញុំម្ចាស់មិនព្រមថ្វាយនូវភត្តកាលដ៏ប្រសើរនេះឡើយ ។

ពួកស្តេចលិច្ឆវីអស់សង្ឃឹម ក៏បន្ទឺវាចាថា ពួកយើងចាញ់នាងអម្ពបាលីហើយ ពួកយើងត្រូវនាងបញ្ឆោតបានហើយ ។

ពេលនោះល្បឿននៃរថទាំងឡាយ របស់ស្តេចលិច្ឆវីជិតទៅអម្ពវ័នហើយ ព្រះមានព្រះភាគទតឃើញពួកស្តេចលិច្ឆវីពីចម្ងាយ ក៏ត្រាស់ប្រាប់ភិក្ខុទាំងឡាយថា ភិក្ខុណាមិនដែលឃើញពួកទេវតាក្នុងឋានត្រៃត្រឹង្ស ភិក្ខុនោះចូរមើលស្តេចលិច្ឆវីចុះ មានសម្រស់ល្អប្រហែលគ្នានឹងទេវតាក្នុងឋានត្រៃត្រឹង្សដែរ ។

លុះស្តេចលិច្ឆវីទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីគួរមួយ ក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះគោតមមួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះករុណាទាំងឡាយក្នុងថ្ងៃស្អែក។

ព្រះសម្ពុទ្ធត្រាស់ថា តថាគតទទួលនិមន្ត របស់នាងអម្ពបាលីរួចហើយ ។

ពួកស្តេចលិច្ឆវី ក៏បន្ទឺវាចាម្តងទៀតថា ពួកយើងចាញ់នាងអម្ពបាលីហើយ នាងឈ្នះយើងហើយ ។ ពួកស្តេចលិច្ឆវីទាំងឡាយ បានស្តាប់ធម្មីកថារបស់ព្រះសាស្តាហើយ ក៏លា

ត្រឡប់ទៅក្រុងវេសាលីវិញ ។

លុះរាត្រីនោះកន្លងទៅ នាងអម្ពបាលីបានតាក់តែង មាននីយភោជនីយាហារ ដ៏ថ្លៃថ្លាក្នុងអម្ពវ័នរបស់ខ្លួន ថ្វាយ ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានថ្វាយ អម្ពវ័ននោះធ្វើជាអារាមទៀត ។ ព្រះមានព្រះភាគទ្រង់ទទួល អារាមនោះហើយ សម្ដែងធម្មីកថាឱ្យនាងអម្ពបាលីមាន សេចក្ដីជ្រះថ្លា ទើបស្ដេចក្រោកចាកអាសនៈយាងទៅកាន់ វេឡុគ្រាមទៀត ។

# ៥- រឿងសក្កទេវរាជ

(ធាក. ធ. ខុ.)

(ហេតុដែលនាំឱ្យផ្សាយផលបុណ្យដល់ទេព្តា និងពួកសត្វទាំងអស់)

មានសេចក្តីដំណាលថា ក្នុងថ្ងៃមួយទេវតាក្នុងតាវតិង្ស ទេវលោក បានប្រជុំលើកយកប្រស្នា ៤ ខ មកពិភាក្សាសួរ ដេញដោលគ្នាថា បណ្តាការឱ្យទាំងអស់ ការឱ្យអ្វីចាត់ជាឲ្យង គេ. បណ្តារសទាំងអស់ រសអ្វីចាត់ជាឲ្យងគេ. បណ្តាសេចក្តី ត្រេកអរទាំងអស់ សេចក្តីត្រេកអរណាចាត់ជាឲ្យងគេ ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគចាត់ការអស់តណ្ហាថា ជាឲ្យងគេ ។ សូម្បីទេវតា ១ អង្គណា ក៏មិនអាចដោះស្រាយ ប្រស្នានោះបានឡើយ. កាលណោះមានទេវតា ១ អង្គសួរ ទៅទេវតា ១ អង្គទៀត. ទេវតាអង្គនោះ សួរទៅអង្គដទៃ ទៀត. ការដែលទេវតាទាំងនោះសួរគ្នាទៅវិញទៅមកដូច្នេះ អស់ ១២ ឆ្នាំក្នុងចក្រវាឡ មិនឃើញមានទេវតាអង្គណាមួយ ដោះស្រាយបាន ទើបប្រជុំគ្នាឡើងទៅសួរមហារាជ ៤ អង្គ ទៀត. មហារាជទាំង ៤ អង្គសួរថា ម្នាលអ្នករាល់គ្នា មហា ទេវសន្និបាតនេះ តើមានហេតុភេទដូចម្តេច ? ពួកទេវតា ក្រាបទូលថា ខ្ញុំព្រះអង្គដាក់ប្រស្នា ៤ ខ ឱ្យពួកទេវតាដទៃ

ទៀតជួយដោះស្រាយ តែគ្មានទេវតាណាមួយ ដោះស្រាយបានសោះ, ចុះប្រស្នានោះដូចម្ដេចខ្លះ ? ក្រាបទូលបណ្ដាការឱ្យ រស និងសេចក្ដីត្រេកអរ តើការឱ្យនឹងរស និងសេចក្ដីត្រេកអរណាឈ្មោះថាប្រសើរ ? ការអស់តណ្ហាឈ្មោះថាប្រសើរ ព្រោះហេតុអ្វី ? ។ មហារាជទាំង ៤ពោលថា ម្នាលអ្នករាល់គ្នា បើទុកជាយើង ក៏មិនដឹងដោះស្រាយថាដូចម្ដេចដែរ ក្រែងតែព្រះរាជារបស់យើងទើបលោកដឹងបានភ្លាម ព្រោះលោកប្រសើរវិសេសជាងយើងដោយបញ្ញាផង ដោយបុណ្យផង, ហើយនាំពួកទេវតាទៅក្រាបទូលសក្កទេវរាជ។ ទ្រង់សួរថា ទេវសន្និបាត ធំដល់ម្ល៉េះតើមានហេតុភេទដូចម្ដេច ? ទើបពពួកទេវតាទាំងនោះក្រាបទូលប្រស្នាទាំង ៤ខ នោះ ។ ព្រះឥន្ទ្រាថ្លែងថា ម្នាលអ្នករាល់គ្នា បុគ្គលដទៃណាក៏មិនអាចដឹងនូវសេចក្ដីនៃប្រស្នាទាំងនេះដែរ ព្រោះប្រស្នាទាំងនេះជាវិស័យនៃព្រះពុទ្ធចុះព្រះសាស្ដាគង់នៅក្នុងទីណាឥឡូវនេះ ? លុះបានជ្រាបថាព្រះអង្គគង់នៅវត្តជេតពន, ទើបបំភ្លឺវត្តជេតពនទាំងមូលក្នុងពេលពាក់កណ្ដាលអាធ្រាត ចូលទៅគាល់ព្រះសាស្ដាព្រមទាំងពួកទេវតាផង ថ្វាយបង្គំហើយ ឋិតនៅក្នុងកន្លែងដ៏

សមគួរ ព្រះសម្ពុទ្ធត្រាស់ថា មហារាជ ព្រះអង្គយាងមក ព្រមទាំងពពួកទេវតាដល់ម្ល៉េះ តើមានកិច្ចការដូចម្តេច ? ទើប សក្កទេវរាជ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពពួក ទេវតាចោទប្រស្នាទាំងនេះ នរណាក៏មិនអាចដឹងសេចក្តីដោះ ស្រាយបាន ហេតុនេះសូមព្រះអង្គមេត្តាប្រោសសម្តែងបំភ្លឺនូវ សេចក្តីនៃប្រស្នាទាំងនោះឱ្យទានផង ។ ព្រះសាស្តាទ្រង់ ត្រាស់ថា មហារាជ ពាក្យដែលព្រះអង្គពោលនោះប្រពៃ ហើយ តថាគតខំបំពេញបារមី ៣០ លះបង់នូវមហាបរិច្ចាគ ព្រោះតែចង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ដើម្បីនឹងកាត់នូវ សេចក្តីសង្ស័យ នៃទេវតាទាំងឡាយប្រាកដស្មើដោយព្រះអង្គ បើដូច្នោះសូមព្រះអង្គចាំស្តាប់ "ការឱ្យធម៌ប្រសើរជាងការ ឱ្យទាំងអស់, រសនៃព្រះធម៌ ប្រសើរជាងរសទាំងអស់, សេចក្តីត្រេកអរក្នុងធម៌ ប្រសើរជាងសេចក្តីត្រេកអរទាំង អស់ ឯការអស់តណ្ហា រឹតតែប្រសើរដាច់គេឯង ព្រោះការ អស់តណ្ហា ធ្វើឱ្យសត្វបានសំរេចព្រះអរហត្ត" ហើយទ្រង់ ត្រាស់គាថាខាងក្រោមនេះថា :

ធម្មទានឈ្នះទានទាំងអស់ ធម្មរសឈ្នះរសទាំងអស់ សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងអស់ ការ

ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។

កាលព្រះអង្គទ្រង់សម្ដែងនូវអត្ថនៃប្រស្នានេះ សត្វ ៨៤ ពាន់បានត្រាស់ដឹងនូវធម៌. ព្រះឥន្ទស្ដាប់ព្រះធម៌ហើយ ថ្វាយបង្គំព្រះសម្ពុទ្ធពោលសរសើថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មទានដែលថាច្បងយ៉ាងនេះ ព្រះអង្គមិនប្រាប់ពួកបរិស័ទ ឱ្យបុណ្យផលដល់ខ្ញុំព្រះអង្គផងព្រោះហេតុអ្វី ? បពិត្រព្រះ អង្គដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះទៅ បើភិក្ខុសង្ឃសម្ដែងធម៌ សូមព្រះអង្គ បញ្ជាឱ្យនូវចំណែកបុណ្យដល់ខ្ញុំព្រះអង្គផងកុំ ខាន ។ ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់ពាក្យព្រះឥន្ទនោះហើយ ទ្រង់ប្រជុំពួកភិក្ខុសង្ឃ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តាំងពី ថ្ងៃនេះជាដើមទៅ អ្នករាល់គ្នាសម្ដែងនូវធម៌ក្ដី ស្ដាប់ធម៌ក្ដី ពោលនូវកថាដែលមនុស្សចូលទៅអង្គុយជិតស្ដាប់ក្ដី ដោយ ហោចសូម្បីត្រឹមតែការអនុមោទនា ក៏ត្រូវផ្សាយចំណែក បុណ្យឱ្យដល់ពពួកសត្វទាំងអស់ដែរ ។

៙៚៙

# ៦- រឿងឧបនន្ទសក្យបុត្តត្ថេរ

( ធ. ខុ.)

( មុននឹងប្រដៅគេ ត្រូវប្រដៅខ្លួនឯងជាមុនសិន)

សេចក្ដីដំណាលថា ព្រះឧបនន្ទជាអ្នកជំនាញខាងការសម្ដែងធម្មទេសនា ។ ពួកភិក្ខុជាច្រើនអង្គ បានស្ដាប់ធម្មទេសនា ដែលសម្ដែងពីអប្បិច្ឆតាគុណ (សេចក្ដីប្រាថ្នាតិច) របស់ព្រះថេរៈអង្គនោះ ក៏បានបូជាត្រៃចីវរ និងសមាទានធុតង្គក្នុងសំណាក់លោក ក្នុងសម័យមួយ ជាសម័យជិតចូលព្រះវស្សា ព្រះឧបនន្ទ បាននិមន្តទៅកាន់វត្តមួយក្នុងជនបទ ពួកភិក្ខុសាមណេរបានឃើញហើយ បានប្រគេនកុដិមួយឱ្យគង់នៅដោយសេចក្ដីរាប់អានថា ជាធម្មកថិកដ៏ប៉ិនប្រសព្វមួយអង្គ ។ ព្រះឧបនន្ទសួរភិក្ខុសាមណេរថា ក្នុងវត្តនេះគេប្រគេនសាដកមួយអង្គប៉ុន្មាន ? "ប្រគេនតែមួយៗទេ" ហើយផ្ញើទ្រនាប់ជើងទុកក្នុងអាវាសនោះ, ទើបទៅកាន់អាវាសមួយទៀតសួរថា ក្នុងអាវាសនេះ គេប្រគេនសាដកមួយអង្គប៉ុន្មាន ? "ប្រគេនមួយអង្គពីរ" ក៏ផ្ញើឈើច្រត់ទុកក្នុងអាវាសនោះទៀត ហើយទៅកាន់អាវាសទី ៣ និងទី ៤ ក៏ផ្ញើក្អមទឹកក្នុងអាវាសទី ៣ ខ្លួនឯងទៅកាន់វស្សាក្នុងអាវាសទី ៤

ហើយសម្ដែងធម្មិកថាទូន្មានឧបាសក-សិកា និងភិក្ខុសាម-ណេរក្នុងអាវាសនោះទៅ ។ លុះចេញវស្សាហើយ ក៏ផ្ញើបណ្ដាំទៅឱ្យភិក្ខុសាមណេរ ក្នុងអាវាសទី ១ ទី ២ និងទី ៣ ផ្ញើសាដកមកលោក ដោយសំអាងថា លោកបានផ្ញើទ្រនាប់ជើង. ឈើច្រត់ និងក្អមទឹកឱ្យចាំវស្សាជំនួស ភិក្ខុសាមណេក៏ផ្ញើសាដកតាមបណ្ដាំ ។ ព្រះថេរៈអង្គនោះ ប្រមូលសាដកបានផ្ទុកពេញរទេះបរទៅតាមផ្លូវ បានជួបនឹងភិក្ខុពីរអង្គកំពុងជជែកគ្នាពីរឿងសំពត់សាដក និងសំពត់កម្ពលដែលចែកគ្នាពុំដាច់ស្រេច ក៏សូមឱ្យជួយធ្វើជាអាជ្ញាកណ្ដាល ឯភិក្ខុទាំងពីរអង្គ យល់ព្រមឱ្យព្រះថេរៈឧបនន្ទធ្វើជាមេចំណែក ។ ព្រះថេរៈនោះដាក់កតិកាសញ្ញា ថាបើលោកទាំងពីរធ្វើតាមបញ្ជាខ្ញុំ ទើបខ្ញុំព្រមធ្វើជាមេចំណែក ភិក្ខុទាំងនោះក៏ព្រមធ្វើតាម ហើយព្រះថេរៈចែកសាដកនោះឱ្យភិក្ខុមួយចំហៀងមួយអង្គ ខ្លួនលោកត្រូវបានសំពត់កម្ពល រួចយកសំពត់ផ្ទុកលើរទេះបរចេញទៅ ។

ឯភិក្ខុទាំងពីរអង្គឃើញដូច្នោះ កើតវិប្បដិសារីក្ដៅក្រហាយស្ដាយក្រោយ ឈរសម្លក់មុខគ្នាទៅវិញទៅមកអស់គំនិត មិនដឹងបើនឹងគិតយ៉ាងណា ម្ល៉ោះហើយទៅជាអាក់អន់

ចិត្តចំពោះឧបនន្ទត្ថេរនោះពន់ពេក ទើបយកពត៌មាននេះទៅថ្វាយព្រះសាស្តា ។ ព្រះសាស្តាទ្រង់ត្រាស់ថា ឧបនន្ទនេះបោកបញ្ឆោតអ្នកទាំងពីរ មិនមែនតែក្នុងបច្ចុប្បន្ននេះទេ សូម្បីពីអតីតកាល ក៏ធ្លាប់បោកបញ្ឆោតអ្នកឯងដែរ ទើបនាំអតីតនិទានមួយមកសម្តែងបញ្ជាក់ដូចតទៅ ។

ក្នុងអតីតកាល មានសត្វភេពីរ ភេមួយត្រាច់រកចាប់ត្រីតាមមាត់ច្រាំង ភេមួយមុជចាប់ត្រីក្នុងទឹកជ្រៅ ហើយចាប់បានត្រីផ្ទិនធំមួយមកហើយបម្រុងចែកគ្នា ភេមួយថាអញមុជទឹកជ្រៅ ត្រូវបានចំណែកខាងក្បាល ឯងត្រូវបានកន្ទុយឯភេមួយពុំយល់ព្រម, កំពុងតែអង្គុយជជែកគ្នា ភេទាំងពីរបានឃើញចចកដើរតម្រង់មក ក៏និយាយអង្វរថា បពិត្រលោកពុកធំ សូមលោកមេត្តាចែកត្រីនេះដល់យើងខ្ញុំផងមើល ! ។ ចចកនិយាយថា បើអ្នកទាំងពីរឱ្យខ្ញុំធ្វើជាមេចំណែក ត្រូវតែស្តាប់បង្គាប់ខ្ញុំ ភេទាំងពីរយល់ព្រម ហើយប្រគល់ត្រីឱ្យទៅចចក ។

ឯចចកទទួលយកត្រី មកវាស់កាត់ជាបីកំណាត់ ហើយវាយចំណែកដោយពាក្យថា អ្នកដើរតាមមាត់ច្រាំងត្រូវបានកន្ទុយ អ្នកលុយទឹកជ្រៅ ត្រូវបានក្បាល ឯសាច់

កណ្តាលត្រូវបានមកខ្ញុំជាមេចំណែក រួចចចកយកចំណែកសាច់កណ្តាលដើរចេញទៅ ។ វីរភេទាំងពីរស្តាយជាពន់ពេកឈរមើលមុខគ្នាទៅវិញទៅមក មិនដឹងបើគិតធ្វើយ៉ាងណា។

លុះចប់ធម្មទេសនា ព្រះសម្ពុទ្ធត្រាស់បញ្ជាក់ថា ភេទាំងពីរគឺ អ្នកទាំងពីរនេះឯង ឯចចកគឺឧបនន្ទភិក្ខុ ដោយទ្រង់បញ្ចប់ក្នុងឃ្លាថា មុននឹងប្រៀនប្រដៅគេ បុគ្គលត្រូវប្រដៅខ្លួនឯងឱ្យបានបទល្អសិន ។

ꩰꩰꩰ

## ៧- រឿងបញ្ចសិខទេវបុត្រ

(ចាក ស.ទី.)

(កាមគុណតែងដុតរោលពួកទេព្តា និងមនុស្សឥតរើសមុខ)

សម័យមួយ មានព្រះអរហន្តសម្ពុទ្ធ ទ្រង់គង់នៅក្នុងគុហាខាងកើតក្រុងរាជគ្រឹះ ។ សក្កទេវរាជមានបំណងចូលគាល់ ប៉ុន្តែមិនហ៊ាន ទើបប្រើទេវបុត្រឈ្មោះបញ្ចសិខៈឱ្យទៅគាល់មុន ដើម្បីឱ្យព្រះអង្គសព្វព្រះទ័យបើកឱកាសឱ្យ ព្រោះបញ្ចសិខៈនេះជាសិល្បករយ៉ាងជំនាញក្នុងទេវបុរី ប៉ិនប្រសព្វខាងកំប្លែងស្គូត ខាងចម្រៀង នៅលើក្បាលមានកំប៉ោយ ៥ ដៃកាន់ពិណពណ៌លឿងដូចព្នៅទុំ ។

បញ្ចសិខៈទទួលបញ្ជាព្រះឥន្ទហើយ កាន់ពិណចូលទៅឈរក្នុងទីល្មមព្រះសម្ពុទ្ធឮសំឡេង ក៏ចាប់ដេញពិណហើយច្រៀងនូវទំនុកស្នេហាមួយ ដែលប្រកបដោយគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត និងប្រកបដោយកាម ជាទំនុកដែលខ្លួនបានតែងឡើង ក្នុងពេលមានសេចក្តីស្នេហាចំពោះទេពធីតាឈ្មោះសុរិយវច្ចសាថា :

ឆន្ទេរតេ មិគាំ ភទ្ទេ តិម្ពរុំ សុរិយវច្ចសេ ។ល។

ធន្ទមានោ នមស្សាមិ យស្ស សេតាធិសី បជាតិ ។

ម្នាលនាងសុរិយវច្ចសាដ៏ចម្រើន បងសូមថ្វាយបង្គំព្រះបាទតិម្ពរុ ជាបិតារបស់នាង ដោយនាងមានលំអ ជាទីញ៉ាំងតម្រេកឱ្យកើតដល់បងដូចជាខ្យល់ ជាទីត្រេកអររបស់អ្នកមានញើស ពុំនោះសោតដូចទឹកសម្រាប់ផឹក ជាទីត្រេកអររបស់អ្នកស្រេកទឹក, នាងមានពន្លឺរស្មីនៃអវៈយវៈ ជាទីស្រឡាញ់ពេញចិត្តនៃបង ដូចនវលោកុត្តរធម៌ ជាទីស្រឡាញ់របស់ព្រះអរហន្តដូច្នោះ ។ ម្នាលនាងក្រមុំ ចូរនាងជួយលត់សេចក្ដីក្រហល់ក្រហាយរបស់បងចេញ ដូចជាគេដាក់ថ្នាំដល់អ្នកជម្ងឺ ពុំនោះដូចគេឱ្យភោជនដល់អ្នកកំពុងឃ្លាន ពុំនោះសោតដូចគេលត់ភ្លើងកំពុងឆេះដោយទឹក ។ សូមឱ្យបងបានអែបនែបត្រង់ចន្លោះសុដន និងឧទររបស់នាង ដូចជាដំរីមានសេចក្ដីក្រហល់ក្រហាយក្នុងរដូវប្រាំង បានចុះកាន់ស្រះឈូកមានទឹកដ៏ត្រជាក់ ប្រកបដោយលំអកេសរផ្កាឈូកដូច្នោះឯង បងងោងងប់ព្រោះភ្នែករបស់នាង ដែលបរិបូណ៌ដោយលក្ខណៈ ក៏លែងស្គាល់ហេតុដែលនាំឱ្យប្រាសចាកភាគៈដូចដំរីចុះប្រេងហួសវិស័យកង្វេរ គិតថាអញឈ្នះផ្ទែកង្វេរ និងលំពែង ។ បងមានចិត្តស្លុងចុះហើយក្នុងនាង បងមិនអាចទាញចិត្តឱ្យត្រឡប់វិញបានឡើយ ដូចជាត្រីលេបផ្ទែសន្ទូច ។

ម្នាលនាងមានភ្នែកដូចបណ្តូលចេក ចូរនាងឱបបង ចូរនាងកៀកបង ឱបរឹតបង ការឱបរឹតនេះ បងត្រូវការណាស់ ។ កាមរបស់បងមានតិចដែរទេ ប៉ុន្តែនាងមានសក់ក្រសាយង ឡើង សេចក្តីប្រាថ្នាបងក៏មានជាអនេក ដូចទក្ខិណាទាន ដែលគេថ្វាយចំពោះអរហន្ត ។ ម្នាលនាងមានលំអសព្វ សព៌ាង្គ បុណ្យណាដែលបងបានធ្វើហើយ ចំពោះព្រះអរហន្ត ទាំងឡាយ ជាអ្នកនឹងធឹង បុណ្យរបស់បងនោះ សូមជួយបង ឱ្យបានភប់ប្រសប់នឹងនាង ។ ព្រះមុនីជាសក្យបុត្រ ទ្រង់ ប្រកបដោយឈានគង់នៅតែមួយព្រះអង្គឯង មានព្រះប្រាជ្ញា ស្មារតី ព្រះអង្គខំស្វែងរកព្រះនិព្វានយ៉ាងណា ម្នាលនាងសុរិ-វច្ឆសា បងក៏ខំស្វែងរកអូនយ៉ាងនោះដែរ ។ មួយទៀត សម្តេចព្រះមុនី ព្រះអង្គបានសម្រេចពោធិញ្ញាណដ៏ឧត្តម ហើយ ទ្រង់រីករាយព្រះទ័យយ៉ាងណាមិញ ម្នាលនាងកល្យា-ណី ខ្លួនបងបើបានមូលមិត្តនឹងនាងហើយ ក៏នឹងរីករាយក្នុង ចិត្តយ៉ាងនោះដែរ ។ ម្នាលនាងដ៏ចម្រើនអើយ បើសក្កទេវ-រាជជាធំជាងពួកទេវតាក្នុងជាន់តាវតិង្ស ទ្រង់ប្រទានពរដល់ បង បងគប្បីប្រាថ្នានាង សេចក្តីប្រាថ្នាដែលមាំក្នុងចិត្តបង យ៉ាងនេះឯង ។ ម្នាលនាងទេពធីតា មានប្រាជ្ញាឈ្លាសវៃ

នាងមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំចំពោះអ្នកនោះ ជាបិតារបស់នាង ដូចឈើដែលមានផ្កា ។

កាលបើបញ្ចសិខទេវបុត្រ ច្រៀងយ៉ាងនេះចប់ហើយ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលបញ្ចសិខសំឡេងពិណនិងសំឡេងច្រៀងរបស់អ្នកសមល្មមស្មើគ្នាណាស់ ទំនុកច្រៀងដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្តនិងប្រកបដោយកាមនេះ អ្នកនិពន្ធឡើងពីកាលណា?

បញ្ចសិខៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទំនុកនេះ ខ្ញុំព្រះអង្គនិពន្ធទុកតាំងពីសម័យព្រះអង្គត្រាស់ដឹងជាដំបូង គង់ក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរាក្នុងឧរុវេលប្រទេសឯណោះ ។

បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះ ខ្ញុំព្រះអង្គប្រាថ្នាបាននាងសុរិយវច្ចសាដ៏ល្អ ជាធីតារបស់ព្រះបាទតិម្ពរុ ។ ប៉ុន្តែនាងនោះមានសេចក្ដីស្រឡាញ់ចំពោះបុរសដទៃវិញ គឺចង់បានសិខណ្ឌិទេវបុត្រជាកូនរបស់មាតលីសង្គាហកទេវបុត្រ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គអស់សង្ឃឹមថានឹងបាននាងនោះហើយ ខ្ញុំព្រះអង្គកាន់ពិណមានពណ៌

លឿងដូចផ្លែព្នៅទុំ ចូលសំដៅទៅលំនៅរបស់ព្រះបាទតិម្ពរុ ដេញពិណហើយច្រៀងនូវទំនុកនោះថ្វាយ ។

. បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គច្រៀងចប់ហើយ នាងសុរិយវច្ចសា បាននិយាយនឹងខ្ញុំព្រះអង្គថា ម្នាលអ្នកនិទ៌ុក្ខ ខ្ញុំមិនដែលបានឃើញព្រះមានព្រះភាគអង្គនោះក្នុងទីចំពោះព្រះភក្ត្រសោះ ប៉ុន្តែកាលខ្ញុំចូលទៅរាំក្នុងទេវសភាឈ្មោះសុធម្មា ក៏បានឮកិត្តិសព្ទរបស់ព្រះមានព្រះភាគដែរ ។ ម្នាលអ្នកនិទ៌ុក្ខ បើអ្នកច្រៀងសរសើរព្រះមានព្រះភាគអង្គនោះ ការជួបគ្នារបស់យើងក្នុងថ្ងៃនេះប្រសើរណាស់ ពិតជាជួបគ្នារហូតហើយ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលបើនាងសុរិយវច្ចសា បានស្ម័គ្រព្រមទទួលខ្ញុំព្រះអង្គជាស្វាមីហើយ ខ្ញុំព្រះអង្គក៏លែងច្រៀងទំនុកនេះតាំងពីកាលនោះមក ។

លំដាប់នោះសក្កទេវរាជ កាលបើដឹងថា ព្រះសម្ពុទ្ធទ្រង់សាទរជាមួយបញ្ចសិខៈហើយ ក៏ប្រាប់បញ្ចសិខៈឱ្យក្រាបបង្គំទូល សុំចូលក្រាបបង្គំគាល់. ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតតាមប្រាថ្នារបស់សក្កទេវរាជ ។

# ធី ៨ រឿងអនិត្ថិគន្ធកុមារ

(ធ. ខុ.)

(សេចក្ដីស្នេហា ជាមេបណ្ដាលឱ្យកើតទុក្ខសោកសៅក្នុងលោក)

សេចក្ដីដំណាលថា អនិត្ថិគន្ធកុមារនោះ បានច្យុតអំពីព្រហ្មលោក មកចាប់កំណើតកើតក្នុងត្រកូលមួយ ដែលមានភោគសម្បត្តិច្រើន នាក្រុងសាវត្ថី ។ ដោយអំណាចផលានិសង្ស ដែលបានកើតក្នុងព្រហ្មលោក ហើយច្យុតមកកាន់ជាតិជាមនុស្សនេះ, តាំងពីថ្ងៃប្រសូត្រមក កុមារនោះមិនដែលឱ្យស្ត្រីណាម្នាក់ប៉ះពាល់រាងកាយឡើយ បើស្ត្រីណាមួយប៉ះពាល់ ក៏ស្រែកទ្រហោយំ ។ ចំពោះមាតាវិញ លុះត្រាតែយកសំពត់ទ្រាប់ដៃទើបឱ្យបៅដោះបាន បើពុំធ្វើដូច្នោះទេ អនិត្ថិគន្ធកុមារនឹងស្រែកទ្រហោយំដដែល, អាស្រ័យហេតុនោះ លុះកុមារមានវ័យចម្រើនធំឡើង មាតាបិតាបម្រុងដណ្ដឹងនាងកុមារិកាម្នាក់ឱ្យជាភរិយា តែកុមារប្រកែកពុំព្រមយក បើទុកជាមាតាបិតាលួងលោមអង្វរករយ៉ាងណា កុមារនៅតែប្រកែកតាមពាក្យដដែល ។ ថ្ងៃមួយមាតាបិតា គិតរកមធ្យោបាយយ៉ាងណា ដើម្បីលួងលោមឱ្យកូនព្រមទទួលយកភរិយា ហើយក៏បានជួលជាងស្មិទ្ធជាច្រើននាក់ ឱ្យយកមាស

ឆ្លាក់មកសិទ្ធជារូបស្ត្រីមួយរូប ដ៏គួរឱ្យប្រតិព័ទ្ធស្នេហាក្រៃលែង ហើយតម្កល់ទុកក្នុងផ្ទះនោះ ទើបលួងលោមម្តងទៀតថា "ហៃកូនប្រុសសម្លាញ់! កាលបើអ្នកមិនព្រមយកភរិយាទេ វង្សត្រកូលយើងនឹងសាបសូន្យ គ្មានពូជពង្សតទៅទៀតឡើយ ឥឡូវយើងជាមាតាបិតា បម្រុងដណ្តឹងនាងកុមារីកាម្នាក់មកផ្សំផ្គុំជាភរិយាឱ្យឯង " ។ អនិត្ថិគន្ធកុមារតបថា "ប្រសិនបើរកស្ត្រីណាឱ្យមានរូបល្អដូចរូបសំណាកនេះ ទើបខ្ញុំព្រមយកជាភរិយា " ។

មាតាបិតាក៏ចាត់ឱ្យហៅព្រាហ្មណ៍ យ៉ាងចំណាន១ ៤-៥ នាក់មកប្រាប់ថា "កូនរបស់យើង ជាកូនប្រកបដោយមហាបុណ្យ ទាំងគួរព្រេងរបស់វា ក៏ប្រហែលជាមានបុណ្យច្រើនដែរ ដូច្នេះ ចូរអ្នកទាំងអស់គ្នាដើរស្វែងរកនាងកុមារីកាណា ឱ្យមានរូបឆោមល្អដូចរូបសំណាកមាសនេះ ហើយវិលមកប្រាប់យើងវិញ ។ ពួកព្រាហ្មណ៍ទាំងនោះ ក៏ទទួលព្រមស្វែងរក គ្រប់ស្រុកតូចធំទាំងអស់ក្នុងដែនមទ្ទរដ្ឋ ។

ជួនជាក្នុងពេលនោះ មាននាងកុមារីកាម្នាក់ អាយុទើបនឹងបាន ១៦ ឆ្នាំ ជាស្ត្រីមានរូបសម្បត្តិគួរគយគន់នៃអ្នកផង, មាតាបិតារបស់នាង ឱ្យនាងនៅតែលើប្រាសាទជាន់ទី៧

ហើយឱ្យទាសីម្នាក់នៅបម្រើរាល់ថ្ងៃ ។ ឯព្រាហ្មណ៍ទាំងនោះគិតគ្នាថា " យើងដាក់តម្កល់រូបសំណាកមាសទុកក្នុងទីនេះហើយ យើងរង់ចាំមើល ប្រសិនបើក្នុងនគរនេះ មាននាងកុមារីកាដែលស្អាតដូចរូបសំណាកនេះ ពួកមនុស្សក្នុងនគរនឹងនិយាយថា "នាងនេះស្អាតដូចកូននៃត្រកូលមួយក្នុងស្រុកនេះមិនខាន ទើបតម្កល់រូបសំណាកក្បែរផ្លូវចុះទៅកំពង់ទឹក។ លំដាប់នោះ មេនំរបស់នាងកុមារិកានោះ ផ្ងូតទឹកឱ្យនាងរួចហើយ ក៏ដើរទៅមុជទឹកខ្លួនឯងនាកំពង់នោះ បានឃើញរូបសំណាកដែលនៅក្បែរផ្លូវ ក៏លោតទៅទះលេងព្រមទាំងនិយាយផងថា " យី ធីតាខ្ញុំទេតើ ! ខ្ញុំទើបតែផ្ងូតទឹកឱ្យអម្បាញ់មិញ ឥឡូវស្រាប់តែមកដល់ទីនេះមុនខ្ញុំ ! " តែច្បល់ត្រង់រូបនោះមានសភាពរឹងផង មិនមានកាយវិការផង ទើបលាន់មាត់ថា " អា ! អញស្មានថាធីតារបស់អញ ! ចុះរូបស្អីអញ្ចឹង ។ ពួកព្រាហ្មណ៍ដែលលបចាំមើលក្បែរនោះ ឃើញដូច្នោះក៏សួរថា នែនាង ! ធីតារបស់នាងមានរូបសម្បត្តិស្អាតដូចរូបសំណាកនេះដែរឬ ? មេនំតបថា រូបនេះឯណាស្អាតដូចធីតាខ្ញុំ ពួកព្រាហ្មណ៍ថា បើអញ្ចឹង សូមនាងបង្ហាញយើងខ្ញុំមើលផង ! ។ មេនំនោះក៏នាំពួកព្រាហ្មណ៍ទៅផ្ទះយកទាំង

រូបសំណាកនោះទៅផង ។

គ្រាន់តែដាក់ទន្ទឹមគ្នាភ្លាម រូបសំណាកជាវិការៈនៃមាស ក៏លេចរស្មីចាញ់នាងកុមារិកានោះ ។ ពួកព្រាហ្មណ៍ក៏ត្រឡប់ទៅជម្រាបមាតាបិតាអនិត្ថិគន្ធកុមារវិញ ។ មាតាបិតានៃកុមារ មានចិត្តរីករាយយ៉ាងក្រៃលែង ទើបចាត់ចែងគ្រឿងបណ្ណាការ ទៅស្តីដណ្តឹងនាងកុមារិការៀបចំផ្សំផ្គុំ ។ ឯអនិត្ថិគន្ធកុមារ បានឮថានាងកុមារិកានោះ ស្អាតល្អជាងរូបសំណាក ក៏កើតប្រតិព័ទ្ធស្នេហាយ៉ាងក្រៃលែង ។ ចំណែកនាងកុមារិកានោះធ្លាប់តែស្រណុក មិនដែលទៅណាមកណាឆ្ងាយ ព្រោះហេតុនោះ បានជាកាលដែលគេដាក់នាងក្នុងរទេះនាំមក នាងកើតរោគខ្យល់ ស្លាប់តាមផ្លូវទៅ ។ អនិត្ថិគន្ធកុមារ តែងតែសួរជាញឹកញាប់ តែឪពុកម្តាយទុកជាដឹងថា នាងកុមារិកានោះស្លាប់ហើយក្តី ក៏បែរជានិយាយបង្វែរជានថា " នៅតែពីរបីថ្ងៃទៀតនាងមកដល់ហើយ " លុះដល់ថ្ងៃក្រោយមក ទើបប្រាប់ថានាងស្លាប់ទៅហើយ ។ ដោយអំណាចនៃសេចក្តីស្នេហាជិះជាន់ខ្លាំង គ្រាន់តែឮថានាងកុមារិកាស្លាប់ភ្លាម អនិត្ថិគន្ធកុមារ មានសេចក្តីទុក្ខក្រៀមក្រំសោកសៅមួយរយជំពូក ដូចគេយកភ្នំមកគរលើ

មទ្រូង ។ ដំណើងនេះមិនស្ងប់ស្ងាត់ ក៏បានជ្រួតជ្រាបដល់ះបរមសាស្ដា ព្រះអង្គក៏ហៅអនិត្ថិគន្ធកុមារមកសាកសួរៗគ្រប់ ក៏ទ្រង់ព្រមានឱ្យបន្ទោបង់សេចក្ដីសោកសៅនោះញ ទើបទ្រង់សម្ដែងធម្មទេសនា ទូន្មានដោយបទថា :

" នែកុមារ សេចក្ដីស្នេហានេះ ជាមេបណ្ដាលឱ្យកើតភាគសៅ សង្រែងសង្រែ រសាប់រសល់ពេកណាស់, ព្រោះ សេចក្ដីសោកក្រៀមក្រំ កើតមានព្រោះស្នេហា ភ័យព្រួយរម្ភកើតមានក៏ព្រោះស្នេហា បើអ្នកលះបង់ស្នេហាបានកើយ សោកភ័យមិនអាចកើតមានទៀតឡើយ " ។

លុះចប់ធម្មទេសនា អនិត្ថិគន្ធកុមារ ក៏សម្រេចសោតាត្តិផល ។

# ៩- រឿងព្រាហ្មណ៍កុហក

(ចាកធ. ខុ.)

( កុហកគេវាគ្រាន់ គេដឹងទាន់វាក្រែល )

សេចក្ដីដំណាលថាព្រាហ្មណ៍ម្នាក់ឡើងទៅលើដើមថ្នាន់មួយដើម ក្បែរទ្វារនគរវេសាលី ជើងទាំងពីរតោបមែកថ្នាន់ សំយុងក្បាលចុះមកក្រោម ប្រកាសប្រាប់ថា អ្នករាល់គ្នា ត្រូវឱ្យគោសម្បុរក្រហម ១០០, ឱ្យប្រាក់, ឱ្យស្ត្រីបំរើ ប្រសិនបើមិនព្រមឱ្យយើងទេ យើងនឹងទម្លាក់ខ្លួនពីលើដើមថ្នាន់នេះឱ្យស្លាប់ ហើយនិងធ្វើឱ្យនគរវិនាសអន្តរាយ ។ ក្នុងពេលដែលពួកភិក្ខុសង្ឃចោមរោមព្រះសម្ពុទ្ធ ចូលទៅក្នុងព្រះនគរបានឃើញព្រាហ្មណ៍នោះ លុះដល់ត្រឡប់ចេញមកវិញ ក៏នៅតែឃើញព្រាហ្មណ៍នោះសំយុងក្បាលដូច្នោះ ។ ឯអ្នកពួកនគរគិតគ្នាថា ព្រាហ្មណ៍នេះសំយុងក្បាលដូច្នេះតាំងពីព្រលឹមម្ល៉េះ បើគាត់ទម្លាក់ខ្លួនគាត់មកនឹងធ្វើឱ្យនគរវិនាសអន្តរាយពុំខាន, ដោយភ័យខ្លាចវិនាសនគរ ក៏ចូលទៅអង្វរករសុខចិត្តឱ្យរបស់ទាំងអស់ ដែលតាព្រាហ្មណ៍នោះត្រូវការ ។ តាព្រាហ្មណ៍ចុះមកវិញ ក៏ប្រមូលយកវត្ថុទាំងអស់ ដែលពួកមហាជនប្រគល់ឱ្យ ។ លុះតាព្រាហ្មណ៍ដើរទៅក្បែរឧបចារ

នៃវិហារ ពួកភិក្ខុស្គាល់ច្បាស់ សួរថា ម្នាលព្រាហ្មណ៍ វត្ថុដែលអ្នកប្រាថ្នានោះបានឬទេ? ព្រាហ្មណ៍តបថា ព្រះករុណាបានដូចសេចក្តីប្រាថ្នាមែន. ពួកភិក្ខុក៏នាំយករឿងនោះទៅក្រាបទូលព្រះសាស្តាៗទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយតាព្រាហ្មណ៍នេះជាចោរកុហក មិនមែនតែក្នុងពេលនេះទេ, សូម្បីពីដើមក៏ធ្លាប់ជាចោរកុហកដែរ, ក៏ប៉ុន្តែឥឡូវនេះ គាត់អាចបញ្ឆោតបានតែជនល្ងង់ទេ, គាត់មិនអាចនឹងបញ្ឆោតជនជាបណ្ឌិតបានឡើយ ហើយពួកភិក្ខុទាំងនោះ ក៏អារាធនាសុំព្រះអង្គនាំយកអតីតទានមកសម្តែងដូចតទៅនេះ :

ក្នុងកាលដែលកន្លងទៅហើយ មានតាបសកុហកម្នាក់ អាស្រ័យនៅអាសិកគ្រាម, មានត្រកូលមួយទំនុកបម្រុងតាបសនោះ តែងឱ្យខាទនីយភោជនីយាហារពេលថ្ងៃ ១ចំណែក ហើយទុកអាហារដែលខ្លួនបរិភោគពេលល្ងាច ១ ចំណែក សំរាប់ប្រគេនលោកក្នុងថ្ងៃទី ២ ។ សម័យថ្ងៃមួយត្រកូលនោះ បានសាច់ទន្សោងក្នុងវេលាល្ងាច ចំអិនស្រួលបួលទុកសម្រាប់ប្រគេនតាបសក្នុងថ្ងៃព្រឹកឡើង ។ តាបសឆាន់សាច់នោះ ក៏ញៀនញាំម សួរថានេះជាសត្វអ្វី ? ឱបដ្ឋាកប្រាប់ថាសាច់ទន្សោង ។ គ្រាន់តែឮថាសាច់ទន្សោង

ដូច្នោះ ក៏យកទឹកដោះថ្លា ទឹកដោះជូរ និងគ្រឿងហើរជាដើម ដើរទៅបណ្ណសាលា ទុកត្រង់កន្លែងមួយ ។ ក្នុងកាលនោះ មានស្តេចទន្សងមួយនៅក្នុងដំបូក ក្បែរសាលានោះ, វាតែង ចេញមកថ្វាយបង្គំតាបសម្តងម្កាល ។ ជួនជាក្នុងថ្ងៃនោះ តាបសគិតថា អញនឹងសម្លាប់ទន្សងនេះ ហើយលាក់ដំបង ក្បែរខ្លួន ធ្វើពុតជាអង្គុយដេកលក់នៅក្បែរដំបូកនោះ ។ ឯ ស្តេចទន្សងចេញពីក្នុងដំបូកមក ឃើញតាបសធ្វើពុតដូច្នោះ ក៏កត់សំគាល់អាការៈក្នុងចិត្តថា អាការៈរបស់លោកអាចារ្យ ក្នុងថ្ងៃនេះអញមិនគាប់ចិត្តសោះ ហើយត្រឡប់ចូលទៅវិញ។ តាបសដឹងថាទន្សងត្រឡប់ចូលទៅវិញ ក៏វាយមួយដំបង ដើម្បីនឹងសម្លាប់តែវាយខុស, ទន្សងក៏រត់ចូលទៅក្នុងដំបូក វិញ លៀនតែក្បាលចេញពោលនឹងតាបសថា :

ខ្ញុំស្មានលោកដែលសង្គ្រួមថាជាសាមណៈ បានជា ហ៊ានចូលទៅជិត, លោកវាយខ្ញុំមួយដំបង លោកលែងជា សាមណៈតទៅទៀតហើយ, ម្នាលតាបសឥតប្រាជ្ញា មាន ប្រយោជន៍អ្វីដល់អ្នក ដោយផ្នួងសក់ទាំងឡាយ មាន ប្រយោជន៍អ្វីដោយសំពត់ជាវិការនៃស្បែខ្លាឃ្មុំ, សន្តានចិត្ត លោកសាំញាំ លោករលើបរលោងតែខាងក្រៅទេ ។

លំដាប់នោះ តាបសនិយាយលួងលោមស្តេចទន្សងថា :

ម្នាលទន្សង អ្នកចូលមក ចូរស៊ីរសស្រូវសាលី, ខ្ញុំមានប្រេង និងអំបិល ដីផ្ទីក៏ល្មមគ្រប់គ្រាន់ ។

ស្តេចទន្សងស្គាល់ពាក្យលួងលោមរបស់តាបសហើយតបទៅវិញថា លោកនិយាយយ៉ាងណា ការរស់នៅរបស់ខ្ញុំក៏មានយ៉ាងនោះ រួចស្រែកបន្ថែមទៀតថា : ខ្ញុំនឹងចូលទៅក្នុងដំបូកយ៉ាងជ្រៅ ប្រេងក្តី អំបិលក្តីរបស់អ្នកបានប្រយោជន៍អ្វី ដីផ្ទីមិនមែនជាប្រយោជន៍ដល់ខ្ញុំទេ ។

ស្តេចទន្សងពោលថែមមួយបទទៀតថា : ខ្ញុំសម្គាល់ថាអ្នកជាសមណៈអស់កាលមកប្រមាណប៉ុណ្ណោះ ឥឡូវនេះអ្នកប៉ងវាយខ្ញុំឱ្យស្លាប់ អ្នកលែងជាសមណៈតាំងពីពេលនេះទៅហើយ តើផ្នួងសក់របស់បុគ្គលដែលមាន ប្រាជ្ញាអាក្រក់ដូចជាលោកមានប្រយោជន៍អ្វី ថែមទាំងស្បែកខ្លាឃ្មុំព្រមទាំងក្របក មានប្រយោជន៍អ្វីដល់លោក ព្រោះថាសន្តានចិត្តលោកសាំញាំ រលើបរលោងតែខាងក្រៅប៉ុណ្ណោះឯង ។

ព្រះសាស្តាទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតក៏ថា ព្រាហ្មណ៍នេះបានកើតជាតាបសកុហក ក្នុងកាលនោះ ឯស្តេចទន្សងគឺ អង្គតថាគតហ្នឹងឯង ។

## ១០- រឿងស្ទូនឆ្នាំងឈ្មោះឃដិការ

(ចាត ឃ. ម.)

(មិត្តសម្លាញ់ល្អ កម្រមានក្នុងលោក)

សម័យមួយ ព្រះមានព្រះភាគស្តេចទៅកាន់ចារិកក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃជាច្រើនអង្គ។ កំពុងតែយាង ស្រាប់តែព្រះអង្គងាកព្រះភក្ត្រទៅរកកន្លែងមួយ ហើយទ្រង់ញញឹម ។ ព្រះអានន្ទឃើញការញញឹម នោះគិតថាពិតជាមានហេតុបច្ច័យមិនខាន ព្រោះធម្មតារបស់ព្រះអរហន្តសម្ពុទ្ធគ្រប់ព្រះអង្គ មិនដែលញញឹមឥតហេតុឡើយ ។

លំដាប់នោះព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុបច្ច័យដូចម្តេច ទើបព្រះអង្គទ្រង់ញញឹម ហើយងាកព្រះភក្ត្រចំពោះទីនេះ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ រឿងរ៉ាវធ្លាប់មានមកហើយ, កាលពីព្រេងនាយ ក្នុងទីនេះមាននិគមមួយឈ្មោះវេភឡិគៈ ជានិគមស្តុកស្តម្ភមាំមួនមានមនុស្សកុះករ ។ កាលនោះ ព្រះអរហន្តសម្ពុទ្ធព្រះនាម កស្សបៈ ធ្លាប់ចូលមកសម្រេចសម្រាន្តឥរិយាបថក្នុងទីនេះឯង, ព្រោះជាអារាមរបស់ព្រះពុទ្ធអង្គនោះ ព្រះអង្គធ្លាប់គង់ ឱ្យឱវាទភិក្ខុសង្ឃជា

ពុទ្ធបរិស័ទទាំងឡាយ ។

លុះព្រះមានព្រះភាគមានព្រះពុទ្ធដីកាដូច្នោះហើយ អានន្ទក៏ក្រាលសង្ឃាដី ៤ ជាន់ត្រង់កន្លែងនោះ អារាធនាព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គគង់សម្រាកក្នុងទីនេះសិន ភូមិប្រទេសនេះនឹងបានឈ្មោះថា មានព្រះពុទ្ធពីរព្រះអង្គប្រើប្រាស់ ។

ព្រះសម្ពុទ្ធទ្រង់ទទួលអារាធនារបស់អានន្ទ ហើយគង់ក្នុងទីនោះ, លុះគង់ស្រួលបួលហើយ បាននាំអតីតនិទានប្រាប់អានន្ទ និងភិក្ខុសង្ឃថា :

ម្នាលអានន្ទ ពីព្រេងនាយទីនេះមាននិគមមួយឈ្មោះ វេភឡិគៈ, អារាមរបស់ព្រះពុទ្ធកស្សបៈ មានក្នុងទីនេះឯង, ព្រះអង្គមានឧបដ្ឋាកម្នាក់ជាស្មូនឆ្នាំងឈ្មោះឃដិការ ។ កាលនោះ តថាគតកើតជាមាណពម្នាក់ឈ្មោះ ជោតិបាល ជាសម្លាញ់ជិតស្និទ្ធនឹងឃដិការស្មូនឆ្នាំងនេះឯង ។

គ្រានោះឃដិការ ជាពុទ្ធឧបដ្ឋាកបានបបួលជោតិបាលមាណព ទៅគាល់ព្រះពុទ្ធកស្សបៈ ដោយវាចារថា នែជោតិបាល សម្លាញ់ស្មើចិត្ត ! មកយើងនាំគ្នាទៅគាល់ព្រះសម្ពុទ្ធ ព្រោះថា ការបានឃើញនូវព្រះពុទ្ធជាព្រះអរហន្ត

របស់ខ្ញុំនោះជាការប្រពៃណាស់ ។

ជោតិបាលឃាត់ឃដិការថា កុំទៅសម្លាញ់ ឯងចង់នាំយើងទៅគាល់ស្រមណ៍កំណោរនោះបានការអ្វី ។

ឃដិការស្ទូនថ្នាំង និយាយបបួលជោតិបាលមាណពយ៉ាងនេះអស់វារៈបីដង, មាណពមិនព្រមទៅ នៅតែនិយាយដដែលៗថា ទៅគាល់ស្រមណ៍កំណោរនោះបានការអ្វី ។

ឃដិការនិយាយទៀតថា បើដូច្នោះ មកសម្លាញ់យើងនាំគ្នាទៅងូតទឹកឯកំពង់, ជោតិបាលក៏ព្រមទៅ ។ លុះនាំគ្នាទៅជិត អារាមរបស់ព្រះពុទ្ធកស្សបៈ ឃដិការប្រាប់ថា នែសម្លាញ់ នេះហើយជាអារាមរបស់ព្រះសម្ពុទ្ធ នៅជិតបង្កើយទេតើ មកយើងចូលទៅគាល់ព្រះអង្គសិន ព្រោះការបានឃើញព្រះអង្គជាការប្រពៃណាស់ ។

ជោតិបាលមាណពមិនព្រមទៅ និយាយឃាត់សម្លាញ់ថា កុំទៅការគាល់ស្រមណ៍កំណោរនេះគ្មានបានការអ្វីទេ ។

ឃដិការស្ទូនថ្នាំង ខំនិយាយបបួលជោតិបាលមាណពយ៉ាងនេះអស់វារៈបីដងទៀត មាណពមិនព្រមទៅ និយាយបដិសេធដូចមុនទៀត ក៏នាំគ្នាទៅងូតទឹក, លុះងូតហើយដើរតាមផ្លូវដដែលមកវិញ ដល់ជិតអារាម ឃដិការ បបួលអស់

វារៈបីដងទៀត. ជោតិបាលមាណពនៅតែប្រកែកដដែល ទើបឃដិការ ចាប់ថ្នក់សំពត់ជាប់បបួលទៀត. មាណពប្រាប់ឱ្យឃដិការលែងថ្នក់សំពត់ចេញ ហើយប្រកែកដូចមុន ។

ឃដិការដឹងថាសម្លាញ់អញ ពិតជាមិនព្រមទៅហើយ ក៏ចាប់សក់ក្បាលអូសទៅអារាម ។

ជោតិបាលមាណពគិតថា ឱហ្ន៎អស្ចារ្យណាស់ មិនសមឃដិការជាមនុស្សថោកទាប ហ៊ានមើលងាយចាប់សក់របស់អញដែលទើបនឹងងូតទឹកហើយដូច្នេះសោះ ប្រហែលជាការទៅអារាមមិនថោកទាបឡើយ ។ ទើបមាណពប្រាប់ឃដិការថា នែសម្លាញ់ឯងលែងសក់គ្នាចេញមកយើងទៅអារាម ។

ពេលនោះឃដិការស្ទួនផ្ទាំង និងជោតិបាលមាណពក៏នាំគ្នាចូលទៅក្នុងអារាម ថ្វាយបង្គំព្រះកស្សបៈអរហន្តសម្មាសម្ពុទ្ធរួចហើយ នាំគ្នាអង្គុយក្នុងទីគួរមួយ ។

ឃដិការទូលព្រះកស្សបៈថា បពិត្រព្រះអង្គដ៏ចម្រើន ជោតិបាលមាណពនេះ ជាសម្លាញ់ពេញចិត្តនៃខ្ញុំព្រះអង្គសូមព្រះមានព្រះភាគសម្តែងធម៌ប្រោសមាណពនេះឱ្យទាន ។

ព្រះកស្សបៈអរហន្តសម្ពុទ្ធ បានពន្យល់ឃដិការស្ទួនផ្ទាំង និងជោតិបាលមាណពឱ្យយល់ឃើញច្បាស់ ឱ្យជឿជាក់

ឱ្យរីករាយដោយធម្មកថាហើយ អ្នកទាំងពីរក៏នាំគ្នាថ្វាយបង្គំលាទៅផ្ទះវិញ ។

លំដាប់នោះ ជោតិបាលមាណពសួរឃដិការស្ងួនផ្ទាំងថា ម្នាលសម្លាញ់ កាលបើបានស្តាប់ធម្មកថារបស់ព្រះសម្ពុទ្ធហើយ អ្នកឯងមិនចេញចាកផ្ទះទៅបួសទេឬ ? ។ ឃដិការតបថា សាធុ សម្លាញ់ ក្រែងឯងដឹងថា គ្នាតែងចិញ្ចឹមមាតាបិតាងងឹតចាស់ជរាដែរឬ ? បើគ្នាទៅបួសតើបានធរណាចិញ្ចឹមបម្រើគាត់ ។

ជោតិបាលមាណពតបថា បើដូច្នោះខ្ញុំសូមលាសម្លាញ់ស្មើចិត្តឯងទៅបួសក្នុងពេលនេះហើយ ។

ឃដិការមានសេចក្តីត្រេកអរណាស់ នាំជោតិបាលមាណពទៅសូមបព្វជ្ជា, ព្រះកស្សបៈសម្ពុទ្ធបំបួសជោតិបាលរួចហើយ ស្តេចធ្វើពុទ្ធដំណើរទៅក្រុងពារាណសី គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីនោះ ។

ក្នុងដែនកាសី មានព្រះរាជាមួយព្រះអង្គព្រះនាម កិកិបានជ្រាបថាព្រះកស្សបៈសម្ពុទ្ធ គង់ក្នុងឥសិបតនមិគវ័នហើយ មានសេចក្តីជ្រះថ្លា បង្គាប់ឱ្យរាជបុរសរៀបយានល្អៗយាងទៅគាល់ព្រះសម្ពុទ្ធ លុះទៅដល់ថ្វាយបង្គំសំណេះ

សំណាល ហើយស្តេចប្រថាប់ក្នុងទីគួរមួយ ស្តាប់ធម្មកថា ដោយព្រះទ័យរីករាយ លុះស្តាប់ចប់ហើយ បាននិមន្តព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ទៅទទួលភត្តនៅព្រះរាជវាំងក្នុងវេលាថ្ងៃស្អែក. ព្រះសម្ពុទ្ធទទួលដោយតុណ្ហីភាព ។ ព្រះរាជាក៏ថ្វាយបង្គំលាតាមប្រពៃណីត្រឡប់ទៅព្រះរាជវាំងវិញ ។

ព្រឹកឡើងព្រះមានព្រះភាគ និងភិក្ខុសង្ឃ យាងទៅទទួល ភត្តក្នុងព្រះរាជវាំង. ទីបំផុតនៃភត្តកិច្ច ព្រះរាជាព្រះនាម កិកិ និមន្តព្រះសម្ពុទ្ធឱ្យគង់ចាំវស្សាក្នុងទីនោះ ។ ព្រះកស្សបៈដ៏មានព្រះភាគតបថា បពិត្រមហារាជកុំឡើយ ព្រោះថាការចាំ វស្សា តថាគតនៅចាំរួចហើយ ។ ព្រះបាទកិកិចេះតែទទូចសូមនិមន្ត យ៉ាងនេះអស់វារៈបីដង ។ ព្រះពុទ្ធកស្សបៈតបយ៉ាងនេះបីដងវិញ ។

គ្រានោះព្រះរាជាទ្រង់តូចព្រះទ័យ ទើបក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ចុះបុគ្គលដទៃណាមួយដែល ជាអ្នកបម្រើព្រះអង្គវិសេសជាងទូលព្រះបង្គំទៅទៀតមានដែរឬទេ ?

ព្រះកស្សបៈសម្ពុទ្ធត្រាស់ថាមាន នៅក្នុងនិគមឈ្មោះវេភឡិគៈ មានស្មូនឆ្នាំងឈ្មោះឃដិការ ជាឱបដ្ឋាកដ៏ប្រសើរ

របស់តថាគត ។

បពិត្រមហារាជ កាលមហារាជជ្រាបថា ព្រះពុទ្ធកស្សបៈ មិនបាននៅគង់ចាំវស្សាក្នុងក្រុងពារាណសី របស់ព្រះអង្គដូច្នេះហើយ ទ្រង់តូចព្រះទ័យ ឯឃដិការស្មូនឆ្នាំង បើបានដឹងថា តថាគតគង់ចាំវស្សាក្នុងទីនេះ មិនតូចចិត្តឡើយ ព្រោះឃដិការជាអ្នកដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ជាអ្នកវៀរនូវបញ្ចវេរា ជាអ្នកមានសេចក្ដីជ្រះថ្លាមិនកម្រើកប្រកបដោយសីល ជាទីត្រេកអរនៃព្រះអរិយៈ មិនមានសង្ស័យក្នុងអរិយៈសច្ចធម៌ ។ បពិត្រមហារាជ ឃដិការជាអ្នកលះបង់នូវមាសប្រាក់កែវមណី ការធ្វើឆ្នាំងឃដិការមិនដែលជីកដីដោយជំនិតផង មិនកកាយដីដោយដៃខ្លួនឯងផង តែងទៅរែកដីច្រាំងបាក់ ឬអាចម៍ដីដែលកណ្ដុរកកាយយកមកធ្វើឆ្នាំង។ លុះធ្វើបានហើយ បើនរណាចង់បានឆ្នាំង គ្រាន់តែយកអង្ករ ឬគ្រាប់សណ្ដែកមួយកញ្ចប់ទៅឱ្យដូរយកឆ្នាំងនោះទៅ បពិត្រមហារាជ ឃដិការស្មូនឆ្នាំងយកថ្លូវទាំងនោះ ចិញ្ចឹមមាតាបិតាចាស់ជរាងងឹតភ្នែក។ ឃដិការទៀងតែទៅកើតព្រហ្មលោក ហើយបរិនិព្វាន ក្នុងទីនោះមិនត្រឡប់មកមនុស្សលោកនេះវិញឡើយ ព្រោះបានធ្វើឱ្យអស់ទៅនៃ ឱរម្ភាគិយ សំយោជនៈទាំង ៥ ជាអនាគាមីហើយ ។

ព្រះកស្សបៈសម្ពុទ្ធត្រាស់ទៀតថា បពិត្រមហារាជ កាលតថាគតនៅក្នុងវេភឡិគនិគមនោះ តថាគតទៅបិណ្ឌបាតក្នុងបុព្វណ្ហសម័យចូលទៅផ្ទះឃដិការស្មូនឆ្នាំង លុះទៅដល់ហើយ មាតាបិតារបស់ឃដិការប្រាប់តថាគតថា ឱបដ្ឋាករបស់ព្រះអង្គមិននៅទេ សូមព្រះអង្គចូលមកកកាយបាយអំពីឆ្នាំង និងសម្លទៅឆាន់ចុះ តថាគតក៏ចូលទៅយកបាយសម្លអំពីឆ្នាំងឆាន់ហើយ ទើបចេញទៅអារាម ។

លុះឃដិការមកដល់ផ្ទះវិញ ឃើញបាត់បាយសម្លក៏សួរមាតាបិតា, កាលបើបានដឹងថា ព្រះកស្សបៈសម្ពុទ្ធស្និទ្ធស្នាលនឹងខ្លួនយ៉ាងនេះហើយ សេចក្តីសុខដែលកើតអំពីបីតិ ក៏កើតឡើងដល់ឃដិការអស់កន្លះខែ ដល់មាតាបិតាឃដិការអស់ ៧ ថ្ងៃ ។

បពិត្រមហារាជ សម័យមួយទៀតតថាគតចូលទៅបិណ្ឌបាតផ្ទះឃដិការដូចមុន, មាតាបិតារបស់ឃដិការប្រាប់ថាឱបដ្ឋាករបស់ព្រះអង្គមិននៅទេ សូមព្រះអង្គយកនំកុម្មាសនិងសម្លអំពីភាជន៍ឆាន់ទៅ, តថាគតយកឆាន់ដោយខ្លួនឯងហើយ ទៅអារាមវិញ, លុះឃដិការត្រឡប់មកផ្ទះដឹងថាតថាគតមានសេចក្តីស្និទ្ធស្នាលដូច្នេះ សេចក្តីសុខដែលកើត

អំពីបីតិក៏កើតឡើងដល់ឃដិការអស់កន្ទះខែ ដល់មាតាបិតាឃដិការអស់ ៧ ថ្ងៃទៀត ។

បពិត្រមហារាជ សម័យមួយទៀតមានភ្លៀងខ្លាំង ដំបូលកុដិតថាគតចាស់ជរាត្រូវលេចទឹកភ្លៀង, តថាគតប្រើពួកភិក្ខុឱ្យ នាំគ្នាទៅយកស្មៅសម្រាប់ចាំងអំពីផ្ទះឃដិការស្មូនឆ្នាំង ។ ភិក្ខុទាំងនោះប្រាប់តថាគតវិញថា ស្មៅសម្រាប់ចាំងគ្មានក្នុងលំនៅឃដិការទេ មានតែស្មៅចាំងផ្ទះគាត់ប៉ុណ្ណោះ។ពេលនោះតថាគតឱ្យភិក្ខុទៅរុះបកស្មៅពីដំបូលផ្ទះឃដិការមកចាំងកុដិតថាគត. កំពុងតែរុះ មាតាបិតាឃដិការសួរថា អ្នកណាមករុះដំបូលផ្ទះយើង. ភិក្ខុទាំងឡាយប្រាប់ថាកុដិរបស់ព្រះសម្ពុទ្ធមាន ដំបូលចាស់លេចទឹកភ្លៀង ។ មាតាបិតាគ្រាន់តែឮដូច្នេះ ក៏ប្រាប់ភិក្ខុទាំងនោះថាសូមនិមន្តរុះយកទាំងអស់ទៅចាំងថ្វាយព្រះអង្គ ឱ្យបានជិតជិតល្អចុះ ។ ភិក្ខុទាំងឡាយក៏រុះអស់ទៅ មាតាបិតា នាំគ្នានៅក្នុងផ្ទះឥតដំបូល ។ លុះឃដិការស្មូនឆ្នាំងមកដល់ផ្ទះ ឃើញគ្មានអ្វីចាំងដូច្នោះ ក៏សួរមាតាបិតា បានដឹងថាព្រះសម្ពុទ្ធ មានសេចក្តីស្និទ្ធស្នាលចំពោះខ្លួនជាអតិបរមាយ៉ាងនេះ. សេចក្តីសុខដែលកើតអំពីបីតិបានកើតឡើងដល់ឃដិការអស់កន្ទះខែ

ដល់មាតាបិតាអស់ ៧ ថ្ងៃទៀត ។ ឯលំនៅរបស់យជិការ ដែលប្រក់បិទបាំងដោយអាកាសនោះ មានការជិតគត់មត់ អស់វារៈបីខែ សូម្បីតែភ្លៀងក៏មិនធ្លាក់ចូលក្នុងផ្ទះនោះដែរ ។ នេះជាគុណសម្បត្តិរបស់យជិការស្ទូនផ្ទាំង ជាឱបដ្ឋាករបស់តថាគត ។

ព្រះបាទកិកិ ទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ រំភើបក្នុងព្រះទ័យក្រៃលែង ទើបមានព្រះបន្ទូលចំពោះព្រះពុទ្ធកស្សបៈថា បពិត្រព្រះអង្គដ៏ចម្រើន យជិការស្ទូនផ្ទាំងមានលាភមែន អត្តភាពជាមនុស្សរបស់យជិការបានដោយល្អមែន ព្រោះជាមនុស្សដែលព្រះអង្គទ្រង់ស្និទ្ធស្នាលក្រៃពេក ណាស់ ។

គ្រានោះព្រះរាជាព្រះនាមកិកិ បានឱ្យរាជាមាត្យដឹកជញ្ជូននូវអង្ករ ស្រូវសាលីមានពណ៌លឿង ជាអង្ករបាយទន់ចំនួន ២០០ រទេះ នឹងគ្រឿងសម្លសមនឹងអង្ករនោះទៅឱ្យយជិការស្ទូនផ្ទាំង ។ លុះរាជបំរើយកវត្ថុទាំងអស់នោះទៅដល់ផ្ទះយជិការស្ទូនផ្ទាំង ហើយក៏និយាយថាវត្ថុទាំងអស់នេះព្រះរាជាព្រះនាមកិកិ បានបញ្ជូនមកឱ្យដល់អ្នក សូមទទួលប្រើប្រាស់ចុះ ។

ឃដិការស្នូនផ្ទាំងតបថា ព្រះរាជាព្រះអង្គមានកិច្ចច្រើន មានការងារច្រើន សូមអ្នកទាំងឡាយ នាំវត្ថុទាំងនេះទៅថ្វាយចំពោះព្រះអង្គវិញចុះ ខ្ញុំគ្រប់គ្រាន់ហើយ ។

ឃដិការស្នូនផ្ទាំង បានបម្រើព្រះពុទ្ធកស្សបៈក្នុងឋានៈជាពុទ្ធឧបដ្ឋាក និងបម្រើមាតាបិតា ក្នុងឋានៈជាកូនកត្តញ្ញូ ដរាបដល់អស់អាយុក៏បានទៅកើតក្នុងព្រហ្មលោក មាននាមថាឃដិការមហាព្រហ្ម ។

ឃដិការមហាព្រហ្មនេះឯង ដែលបានយកចីវរមកថ្វាយ ព្រះសមណគោតមបរមគ្រូយើងក្នុងពេលព្រះអង្គចេញបព្វជ្ជា ។

៚

# ១១- រឿងដំបូកហុយផ្សែង

(ចាត វ. ម.)

(ការដោះស្រាយប្រស្នាអាថិកំបាំង ១៥ ខ របស់ទេព្តា)

សម័យមួយព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌកសេដ្ឋី ទៀបក្រុងសាវត្ថី ។

សម័យនោះឯងព្រះកុមារកស្សបនៅក្នុងអន្ធវ័ន, មាន ទេវតាមួយរូបចូលទៅរកលោក ដោយបានបញ្ចេញរស្មីឱ្យភ្លឺ ព្រោងព្រាតក្នុងអន្ធវ័ននោះ ហើយនិយាយប្រាប់លោកថា ភិក្ខុ ភិក្ខុ ! ដំបូកហុយផ្សែងក្នុងពេលយប់ ឆេះជាភ្លើងក្នុង ពេលថ្ងៃ ព្រាហ្មណ៍បានប្រើបុរសឈ្មោះសុមេធ ឱ្យយក សាស្ត្រាវុធជីកដំបូកនោះមើល ។ សុមេធជីកទៅឃើញសន្ទះ ទ្វារកង់ ព្រាហ្មណ៍ឱ្យលើកចេញ, ជីកទៅទៀតឃើញរូបផ្លូវ បែកជាពីរព្រាហ្មណ៍ឱ្យលើកចេញ, ជីកទៅទៀតឃើញសំពត់ តម្រងក្បុងព្រាហ្មណ៍លើកចេញ, ជីកទៅទៀតឃើញអណ្តើក ព្រាហ្មណ៍ឱ្យលើកចេញ ជីកតទៅទៀតឃើញកាំបិតនិងជ្រុញ ព្រាហ្មណ៍ឱ្យលើកចេញ,ជីកទៅទៀតឃើញដុំសាច់ព្រាហ្មណ៍ ឱ្យលើកចេញ, ជីកទៅទៀតឃើញនាគ ព្រាហ្មណ៍ និយាយ ថា ទុកនាគឱ្យនៅចុះអ្នកកុំបៀតបៀនចូរថ្វាយបង្គំនាគទៅ ។

នែភិក្ខុ ! លោកចូរនាំយកប្រស្នាទាំង១៥ នេះទៅទូលសួរព្រះមានព្រះភាគ បើព្រះអង្គព្យាករ ប្រាប់លោកយ៉ាងណា ចូរចាំទុកយ៉ាងនោះចុះព្រោះអ្នកប្រាជ្ញទាំងអស់ក្នុងពិភពលោកនេះ យើងមិនដែលឃើញអ្នកណាឆ្លើយប្រស្នានេះត្រូវឡើយ. ទេវតានិយាយយ៉ាងនេះហើយក៏បាត់អំពីទីនោះភ្លាម។

លុះរាត្រីកន្លងហើយ ព្រះកុមារកស្សបចូលទៅគាល់ព្រះមានព្រះភាគ ទូលតាមដំណើររឿងសព្វគ្រប់ហើយ ទើបសួរប្រស្នារបស់ទេវតាទាំង ១៥ ចំពោះព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន :

- អ្វីហៅថាដំបូក
- អ្វីហុយផ្សែងក្នុងពេលយប់
- អ្វីឆេះក្នុងពេលថ្ងៃ
- អ្នកណាជាព្រាហ្មណ៍
- អ្នកណាជាសុមេធ
- អ្វីជាសាស្ត្រាវុធ
- អ្វីជាការជីក
- អ្វីជាសន្ទះទ្វារកង់

- អ្វីជាសត្វហ៊ឹង
- អ្វីជាផ្លូវបែកជាពីរ
- អ្វីជាសំពត់តម្រងក្បុង
- អ្វីជាអណ្ដើក
- អ្វីជាកាំបិតនិងជ្រុញ
- អ្វីជាដុំសាច់
- អ្វីជានាគ ?

ព្រះសម្ពុទ្ធទ្រង់ត្រាស់ប្រាប់កុមារកស្សបថា ម្នាលភិក្ខុ :

- ដំបូកគឺរូបកាយមនុស្សសត្វ
- ហុយផ្សែងក្នុងពេលយប់
  គឺការត្រិះរិះគិតពីកិច្ចការ
- ឆេះក្នុងពេលថ្ងៃ គឺការប្រកបកិច្ចការ
- ព្រាហ្មណ៍ គឺព្រះអរហន្តសម្ពុទ្ធ
- សុមេធគឺពួកសេខបុគ្គល
- សាស្ត្រាវុធ គឺប្រាជ្ញាដ៏ប្រសើរ
- ការជីក គឺសេចក្ដីព្យាយាម

- សន្ទះទ្វារកង់ គឺអវិជ្ជា សេចក្ដីល្ងង់
- សត្វហ៊ឹង គឺសេចក្ដីក្រោធ ការចង្អៀតចង្អល់ចិត្ត
- ផ្លូវបែកជាពីរ គឺវិចិកិច្ឆា ការមិនដាច់ស្រាច់
- សំពត់តម្រងក្បុង គឺនីវរណធម៌ទាំង ៥
- អណ្ដើក គឺឧបាទានក្ខន្ធ ៥
- កាំបិតនិងជ្រុញ គឺកាមគុណ ៥
- ដុំសាច់ គឺនន្ទិរាគៈ សេចក្ដីត្រេកត្រអាល
- នាគ គឺព្រះខីណាស្រព ។

ត្រង់ពាក្យព្រាហ្មណ៍បង្គាប់សុមេធ ថាឱ្យលើកនូវវត្ថុមួយមុខៗ ដែលជីកឃើញចេញពីដំបូកនោះបានសេចក្ដីថា ព្រះសម្ពុទ្ធ បានទូន្មានពួកសេខបុគ្គល ឱ្យលះបង់នូវវត្ថុនោះៗចេញ កុំសេពគប់ហ្លួងហែងទុកជារបស់ខ្លួនឡើយ ។

ត្រង់ពាក្យថាទុកនាគឱ្យនៅចុះ កុំបៀតបៀន ហើយគួរផ្ចាស់ថាពាក្យនោះបានសេចក្ដីថា បុគ្គលត្រូវតម្កល់ខ្លួនដោយប្រពៃកុំបៀតបៀនខ្លួនចូរសាងខ្លួនឱ្យកើតជាព្រះខីណាស្រព។

ព្រះកុមារកស្សបបានស្ដាប់ពុទ្ធភាសិតនេះហើយ មានចិត្ត ត្រេកអរីករាយក្រៃលែង ។

## ១២- រឿងអហិប្រេត

(ចាក អ. ខុ.)

(ទោសនៃការព្យាបាទ ដុតបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ)

សម័យមួយព្រះមហាមោគ្គល្លាន និមន្តទៅភ្នំគិជ្ឈកូដ បាន ឃើញប្រេតមួយឈ្មោះអហិប្រេត មានក្បាលជាមនុស្ស ខ្លួនជាពស់ មានភ្លើងឆេះសន្ធោសន្ធៅ តាំងពីក្បាលដល់ចុងកន្ទុយ ។ លោកបានឃើញប្រេតនេះហើយ បានដំណាល ប្រាប់ព្រះលក្ខណ ត្ថេរ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់រឿងប្រេតនេះហើយ ត្រាស់ថា ម្នាលមោគ្គល្លាន តថាគតបានឃើញអហិប្រេតនេះ តាំងពីថ្ងៃដែលតថាគតបានត្រាស់ជាព្រះពុទ្ធថ្មីៗម្ល៉េះ ប៉ុន្តែ ពេលនោះគ្មានសាក្សី បើតថាគតសម្ដែងទៅគេមិនជឿនាំឱ្យ ឥតប្រយោជន៍ មានទោសដល់អ្នកមិនជឿនោះ ឥឡូវបាន មោគ្គល្លាន ជាសាក្សីហើយ ចាំតថាគតសម្ដែងអតីតនិទាន របស់ប្រេតនោះឱ្យស្ដាប់ ។

ព្រះសម្ពុទ្ធត្រាស់សម្ដែងថា កាលកន្លងទៅហើយ ពួក មហាជនបាននាំគ្នាធ្វើបណ្ណសាលា ផ្ទះស្លឹកមួយ ជិតស្ទឹងក្នុង ក្រុងពារាណសី ប្រគេនព្រះបច្ចេកពុទ្ធមួយអង្គគង់នៅ ។

អ្នកក្រុងបាននាំគ្នាយកគ្រឿងក្រអូប និងផ្កាកម្រងជាដើម ទៅប្រគេនរាល់ថ្ងៃ បានដើរជាន់ស្រូវកសិករម្នាក់ ដែលបានភ្ជួរ ព្រោះកៀកជាប់នឹងផ្លូវបណ្ណសាលានោះ ។ កសិករម្ចាស់ស្រែ ឃាត់មិនស្តាប់ ក៏មានការអាក់អន់ចិត្តជាខ្លាំង កើតចិត្តព្យាបាទថា ប្រសិនបើមិនមានបណ្ណសាលា មិនមានព្រះបច្ចេកពុទ្ធមកគង់ក្នុងទីនេះទេ ស្រូវអញក៏មិនវិនាសខ្ទេចខ្ទីដូច្នេះដែរ. អញត្រូវដុតបណ្ណសាលានេះចោលទើបបាន ។

ក្នុងពេលដែលព្រះបច្ចេកពុទ្ធនិមន្តទៅបិណ្ឌបាត ក្នុងក្រុងពារាណសី កសិករនោះ ក៏វាយបំបែកភាជនៈសម្រាប់ប្រើប្រាស់របស់ព្រះបច្ចេកពុទ្ធចោលអស់ហើយ យកភ្លើងដុតបណ្ណសាលា ឆេះខ្ទេចខ្ទីអស់ទៅ ។

ព្រះបច្ចេកពុទ្ធកំពុងនិមន្តបិណ្ឌបាត បានឃើញភ្លើងឆេះបណ្ណសាលាអស់ហើយ ក៏និមន្តតាមអាកាសចាកចេញពីទីនោះបាត់ទៅ ។

ពួកមហាជនដែលបានយកគ្រឿងបូជាទៅប្រគេនព្រះបច្ចេកពុទ្ធនោះ, កាលបើឃើញបណ្ណសាលាឆេះអស់ហើយ បាត់ព្រះបច្ចេកពុទ្ធដូច្នោះ ក៏សន្និដ្ឋានថា លោកឆេះសុគតក្នុងភ្លើងទៅហើយ ឬក៏មិនទាន់និមន្តមកពីបិណ្ឌបាត ។ កំពុងតែ

ជំនុំគ្នាដូច្នេះស្រាប់តែកសិករដែលនៅក្នុងទីនោះដែរ និយាយថាខ្ញុំជាអ្នកដុតបណ្ណសាលានេះ ព្រោះអ្នករាល់គ្នាបំផ្លាញស្រូវខ្ញុំអស់ ។

ពេលនោះមហាជន ស្រែកឆោឡោឡើងថា ពួកយើងជួយចាប់ចោរដុតបណ្ណសាលា, ពួកយើងខានធ្វើទានចំពោះព្រះបច្ចេកពុទ្ធ ក៏ព្រោះតែវានេះឯង ត្រូវចាប់វាឱ្យបាន ។ លុះចាប់កសិករអ្នកដុតបណ្ណសាលានោះបានហើយ នាំគ្នាវាយតប់យកទៅធ្វើទោស តាមច្បាប់ដរាបដល់ស្លាប់ទៅ ។

កសិករទុច្ចរិតដែលស្លាប់នោះ ធ្លាក់ទៅកើតក្នុងនរកធំ ឈ្មោះអវចីជាច្រើនសែនឆ្នាំ ដរាបដល់ផែនដីដុះតម្កល់បានមួយយោជន៍ ទើបចុះរួចពីនរកធំ, នៅសល់ផលកម្មនោះបានមកកើតជាអហិប្រេតនៅលើកំពូលភ្នំគិជ្ឈកូដនេះឯង ។

៙៚

# ១៣- រឿងរដ្ឋបាលកុលបុត្រ

( ចាត រ. ម.)

( អ្នកយល់ប្រយោជន៍ពុទ្ធសាសនាពិតប្រាកដ សុខចិត្តស្លាប់ឱ្យតែបានបួស)

កាលព្រះសម្ពុទ្ធគង់ក្នុងដែនកុរុ ពួកព្រាហ្មណ៍ និងគហបតី ដែលនៅក្នុងថុល្លកោដ្ឋិតនិគម បាននាំគ្នាទៅស្តាប់ធម៌ព្រះអង្គ លុះស្តាប់ចប់មានសេចក្តីត្រេកអរីករាយចំពោះព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈថ្វាយបង្គំព្រះសម្ពុទ្ធ ធ្វើប្រទក្សិណជៀសចេញទៅ ។

ក្នុងចំណោមពុទ្ធបរិស័ទនោះ មានកុលបុត្រម្នាក់ឈ្មោះរដ្ឋបាល បានគិតថាព្រហ្មចរិយាធម៌បរិសុទ្ធណាស់ អ្នកនៅគ្រប់គ្រងផ្ទះមិនអាចប្រព្រឹត្តឱ្យបរិបូណ៌បានឡើយ ដូច្នេះអញត្រូវកោរសក់ពុកមាត់ ពុកចង្ការ បួសក្នុងសំណាក់ព្រះសម្ពុទ្ធទើបប្រសើរ ។ លុះគិតដូច្នេះហើយ ក្នុងពេលដែលពុទ្ធបរិស័ទ ទាំងឡាយចេញទៅអស់ ក៏ទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ, ព្រះអង្គសួរថាម្នាលរដ្ឋបាល អ្នកបានលាមាតាបិតារបស់អ្នកហើយឬនៅ ?

- ក្រាបទូលមិនទាន់បានអនុញ្ញាតអំពីមាតាបិតានៅឡើយ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅសុំ

អនុញ្ញាត ក្នុងពេលឥឡូវនេះ, ទូលដូច្នេះហើយ ក៏ថ្វាយបង្គំលាចេញទៅ ។

ខណៈនោះរដ្ឋបាល ចូលទៅរកមាតាបិតា និយាយជំរាបតាមដំណើរការណ៍សព្វហើយ សុំអនុញ្ញាតដើម្បីបួស។

មាតាបិតាឃាត់ថាកុំរដ្ឋបាលកូន អ្នកជាកូនប្រុសតែមួយរបស់មាតាបិតា បើកូនទៅបួសហើយ បាននរណាទទួលមត៌កវង្សត្រកូលយើងនឹងសាបសូន្យដាច់ពូជមិនខាន. កូនមិនបាច់ទៅបួសទេ ទ្រព្យសម្បត្តិយើងច្រើនណាស់ កូននៅគ្រប់គ្រងផ្ទះ ហើយចំណាយទ្រព្យធ្វើបុណ្យទានតាមចិត្តចុះ។

រដ្ឋបាលចេះតែអង្វរសុំទៅបួស មាតាបិតាចេះតែមិនព្រម ទើបរដ្ឋបាលសម្រេចចិត្តផ្តួលខ្លួនដេកផ្ទាល់ក្នុងទីឥតកម្រាល ប្តេជ្ញាថាបើមិនបានទៅបួសមិនក្រោកឡើយ បាយទឹកក៏មិនត្រូវការ ឱ្យស្លាប់ក្នុងទីនេះចុះ ។

មាតាបិតាចេះតែអង្វរ, រដ្ឋបាលមិនព្រមនិយាយស្តីសោះ ដេកអត់អាហារអស់ ៧ ពេល ។ ពួកមិត្រសម្លាញ់មកជួយអង្វរទៀត ក៏មិនស្តីតបមួយម៉ាត់សោះ, ទើបពួកមិត្រទាំងនោះចូល ទៅនិយាយប្រាប់មាតាបិតារបស់រដ្ឋបាលថា

លោកអុំលោកពូ មើលទៅរដ្ឋបាលសម្លាញ់គេមិនព្រមក្រោក ទទួលទានអាហារទេ គេប្តេជ្ញាស្លាប់នៅទីនេះហើយ ។

បើតាមពួកយើងខ្ញុំយល់ថា គួរលោកទាំងពីរអនុញ្ញាត ឱ្យទៅបួសល្អជាងទុកឱ្យស្លាប់ ព្រោះបើទៅបួសគ្រាន់បាន ជួបមុខគ្នាទៀត ។

មាតាបិតារបស់រដ្ឋបាលបានយល់ព្រម អនុញ្ញាតឱ្យ រដ្ឋបាលទៅបួសតាមបំណង គ្រាន់តែផ្តាំកូនថាបើបួសហើយ ឧស្សាហ៍ឱ្យមាតាបិតាបានឃើញញឹកញយផង ។

គ្រានោះរដ្ឋបាលក្រោកឡើង ទទួលទានអាហារ សំរាកកម្លាំងបានស្រួលខ្លួនហើយ ចូលទៅគាល់ព្រះមានព្រះ ភាគ សូមបព្វជ្ជា ឧបសម្បទាបានដូចបំណង ក៏តាមព្រះ សម្ពុទ្ធធ្វើដំណើរទៅក្រុងសាវត្ថី ។ រដ្ឋបាលភិក្ខុបានទៅនៅ ក្នុងទីស្ងាត់ ខំព្យាយាមដុតកំដៅកិលេស មិនយូរប៉ុន្មានក៏បាន សម្រេចមគ្គផលជាព្រះអរហន្ត ។

ថ្ងៃបន្ទាប់មក បានចូលទៅគាល់ព្រះមានព្រះភាគសុំ លាទៅស្រុកកំណើតដើម្បីឱ្យមាតាបិតាបានឃើញរូបលោក។ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា រដ្ឋបាលភិក្ខុជាព្រះអរហន្តហើយ មាតាបិតា មិនអាចផ្សឹកវិញបានក៏អនុញ្ញាតតាមសុំ ។

មានសេចក្តីដំណាលថា ព្រះរដ្ឋបាលនិមន្តទៅស្រុកកំណើតហើយ ចូលទៅសម្រាកក្នុងឧទ្យានឈ្មោះមិគាបីរៈរបស់ព្រះបាទកោរព្យៈ ព្រឹកឡើងនិមន្តទៅបិណ្ឌបាតក្នុងភូមិរៀងទៅដល់ផ្ទះមាតាបិតាលោក. ប៉ុន្តែបិតាមិនស្គាល់ កំពុងឱ្យជាងកោរ កាត់សក់ក្បែរទ្វារផ្ទះ គ្រាន់តែឃើញលឿង១ ក៏និយាយថាពួក ស្រមណ៍កំណោរនេះហើយ ដែលបំបួសកូនប្រុសសម្លាញ់តែមួយរបស់អញ ។

ពេលនោះព្រះរដ្ឋបាល ឃើញបិតាមិនអើពើ ហើយជេរបន្ទោសថាពួកស្រមណ៍កំណោរទៀត ក៏និមន្តហួសទៅ។

ជួនជាពេលនោះទាសីក្នុងផ្ទះរបស់ញោមលោក បានយកនំកុម្មាសផ្អូមទៅចាក់ចោលក្បែររបងផ្ទះ, លោកឃើញហើយនិយាយថា នែនាងបើនំនេះត្រូវចោលហើយ ចូរនាងដាក់ក្នុងបាតអាត្មាមក។ នាងទាសីយកនំផ្អូមទៅចាក់ក្នុងបាតហើយ បានស្គាល់ដាក់នូវដៃជើង និងសម្លេងរបស់ព្រះរដ្ឋបាលច្បាស់ថាជាចៅហ្វាយប្រុសរបស់ខ្លួនពីដើម ក៏ប្រញាប់ទៅប្រាប់មាតារបស់រដ្ឋបាល ។ មាតាអរណាស់បាននិយាយនឹងទាសីថា បើពិតជាកូនអញមកមែន អញឱ្យឯងរួចខ្លួនជាអ្នកជា ។ ទើបមាតានោះទៅប្រាប់ដល់បិតាទៀត ថាកូន

វប្អបាលយើងមកវិញហើយ ឯងទៅហៅកូនយើងមក ។

ពេលនោះ ព្រះវប្អបាលកំពុងឆាន់នំផ្អមក្បែរសាលាមួយ ។ បិតាទៅដល់ក៏និយាយថា នែវប្អបាលកូន មិនគួរមកឆាន់នំផ្អម ដែលគេចាក់ចោលដូច្នេះទេ មកដល់ផ្ទះហើយម្តេចមិនទៅផ្ទះរបស់ខ្លួន ។

ព្រះវប្អបាលឆ្លើយថា នែគហបតី ពួកយើងជាអ្នកបួសមានផ្ទះមកពីណា, អាត្មាបានទៅដល់ផ្ទះអ្នកហើយ តែមិនបានទទួលទានផង មិនបានទទួលការនិយាយរកផង បានត្រឹមតែពាក្យជេរថា ស្រមណ៍កំណោរប៉ុណ្ណឹង ។

បិតាអង្វរថា វប្អបាលកូនមកទៅផ្ទះយើង ឈប់ឆាន់នំផ្អមទៅ ។

- ណេ្ហីយគហបតី ថ្ងៃនេះអាត្មាឆាន់រួចហើយ !
- បើដូច្នោះសូមលោកកូន
  ទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។

ព្រះវប្អបាលព្រមទទួលដោយតុណ្ហីភាព ។

គហបតីជាបិតារបស់ព្រះវប្អបាល ដឹងថាថ្ងៃស្អែកទើបលោកកូនមកឆាន់ក្នុងផ្ទះ ក៏ត្រឡប់ទៅផ្ទះវិញប្រាប់ភរិយា

ហើយ ក៏នាំគ្នាជញ្ជូនមាសពេជ្រ កែវកងយកមកចាក់ក្នុងផ្ទះ ជាពីរគំនរ កំពស់ផុតក្បាល រៀបកន្លែងឱ្យវដ្ឋបាលគង់នៅកណ្ដាល និងប្រាប់ស្ត្រីទាំងពីរជាគូស្រករបស់ព្រះវដ្ឋបាលពីដើម ឱ្យរៀបចំតាក់តែងខ្លួនយ៉ាងណា ដែលវដ្ឋបាលធ្លាប់ពេញចិត្តបម្រុងទទួលលោកក្នុងថ្ងៃស្អែក ។

លុះរាត្រីកន្លងទៅ មាតាបិតាព្រះវដ្ឋបាលបានរៀបចំតាក់តែងភត្តសព្វគ្រប់ហើយ ក៏ទៅតាមព្រះវដ្ឋបាល. លោកនិមន្តមក ដល់បានចូលទៅក្នុងផ្ទះគង់លើអាសនៈដែលគេបម្រុងទុក ។ ទើបបិតាបើកគំនរមាសពេជ្រឡើងចង្អុរប្រាប់ថា នេះជាសម្បត្តិខាងបិតា នេះខាងមាតា នេះខាងជីតា ហើយនិយាយថា នែវដ្ឋបាលកូន ចូរលោកសឹកមកគ្រប់គ្រងផ្ទះវិញ ចូរប្រើប្រាស់ភោគៈទាំងនេះផង ចូរធ្វើទានផងតាមបំណងចុះ ។

ព្រះវដ្ឋបាលតបថា បពិត្រគហបតី បើញោមធ្វើតាមពាក្យរបស់អាត្មា ញោមត្រូវប្រើមនុស្សឱ្យជញ្ជូនមាសពេជ្រទាំងអស់នេះទៅចោលកណ្ដាលទន្លេគង្គាទៅ ព្រោះថាសេចក្ដីទុក្ខសោក ទាំងអស់កើតឡើងដល់ញោម មកអំពីទ្រព្យនេះឯងជាហេតុ ។

ពេលនោះពួកស្ត្រីជាគូស្រករពីមុន នាំគ្នាមកឱបជើងលោកម្នាក់ម្ខាង ហើយនិយាយថា ព្រះអយ្យបុត្រខំប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះចង់បានស្រីទេពអប្សរ តើស្រីនោះល្អយ៉ាងណាទៅ ។ ព្រះរដ្ឋបាលតបថា ម្នាលនាងអាត្មាមិនមែនប្រព្រឹត្តព្រហ្មចរិយធម៌ព្រោះហេតុចង់បានស្រីទេពអប្សរទេ។ ពួកស្រីទាំងពីរ បានឮព្រះរដ្ឋបាលហៅខ្លួនថា នាងដូច្នេះក៏ជ្រប់ដួលត្រង់ទីនោះទៅ ។ ទើបព្រះរដ្ឋបាលនិយាយនឹងបិតាថា ម្នាលគហបតី បើញោមត្រូវឱ្យភោជនអាត្មាក៏ឱ្យមកកុំបៀតបៀនអាត្មាឡើយ ។ បិតាតបថា ម្នាលកូននិមន្តឆាន់ចុះ និយាយហើយ ក៏ចាត់ចែងខាទនីយភោជនីយាហារប្រគេនព្រះរដ្ឋបាលដោយដៃខ្លួនឯងត្រាតែឆ្អែត ។

លុះឆាន់ហើយ ព្រះរដ្ឋបាលឈរសម្តែងធម្មកថាទាំងឡាយថា : ញោមចូរមើលនូវអត្តភាព ដែលសង្ខារធ្វើវិចិត្រហើយជាទីប្រជុំនៃដំបៅ ៩ អន្ទើផ្គុំឡើងដោយឆ្អឹង ៣០០កំណាត់ ក្តៅរោលរាល ដែលជនច្រើនគ្នាតែងត្រូវការ ជាកាយមិនទៀងទាត់ឋិតថេរឡើយ. ញោមចូរមើលរូបដែលសង្ខារវិចិត្រហើយប្រកបដោយកុណ្ឌលមណីដែលរួបរឹតហើយដោយឆ្អឹង និងស្បែកល្អ ដោយសារតែសំពត់ជើងទាំងឡាយ

វិចិត្រហើយដោយទឹកល័ខ មុខមាត់លាបហើយដោយគ្រឿងលម្អិត អាចឱ្យមនុស្សពាលវង្វេងបាន តែមិនអាចបំភ័ន្តអ្នកស្វែងរកត្រើយគឺ ព្រះនិព្វានបានឡើយ សក់ទាំងឡាយដែលវិចិត្រហើយ ឱ្យមានសណ្ឋានដូចក្រឡាចត្រង្គ ភ្នែកទាំងឡាយលាបហើយដោយថ្នាំសម្រាប់បន្តក់ ល្មមឱ្យបុគ្គលពាលភ័ន្តភាំងបាន តែមិនអាចបំភ័ន្តអ្នកស្វែងរកត្រើយបានឡើយ កាយស្អុយដែលបានប្រដាប់ហើយ ដូចជាបំពង់ថ្នាំដាក់ភ្នែកយ៉ាងវិចិត្រអាចបំភាន់បុគ្គលពាលបាន តែមិនអាចបំភាន់អ្នកស្វែងរកត្រើយបានឡើយ ព្រានម្រឹគដាក់នូវបង្កាត់អន្ទាក់ តែម្រឹគមិនជាប់អន្ទាក់ កាលបើព្រានចងម្រឹគកំពុងកន្ទក់កន្ទេញ អាត្មាបរិភោគបន្ទោរួចហើយ សុំលាត្រឡប់ទៅវិញ ។

ព្រះរដ្ឋបាលសម្តែងធម្មកថានេះចប់ហើយ និមន្តទៅសម្រាកក្នុងឧទ្យានមិគាចីរៈរបស់ព្រះបាទកោរព្យៈវិញ ។

ពេលនោះ ព្រះបាទកោរព្យៈចេញទៅទតសួនឧទ្យានបានជួបព្រះរដ្ឋបាលហើយ មានសេចក្តីជ្រះថ្លា បានចូលទៅថ្វាយបង្គំរាក់ទាក់សួរសម ហើយបានត្រាស់សួរថា ខ្ញុំស្គាល់លោកច្បាស់ ហេតុអ្វីបានជាលោកមកបួសទាំងក្មេងពេញកម្លោះគ្រឡាំងដូច្នេះ មនុស្សពួកខ្លះបានជួបនូវសេចក្តីសាប

សូន្យ៤ យ៉ាងទើបចេញបួស គឺចាស់ជរា១ ព្យាធិ១ក្រខ្សត់ឥត ទ្រព្យ ១ ឥតញាតិ ១ ដែលមិនអាចតាំងខ្លួនជាឃរាវាសតើ រា ។ ចំណែកលោកបានឃើញហេតុដូចម្តេចបានជាបួស ។

ព្រះវរ្ឋបាល បានអធិប្បាយអំពីធម្មទេស ៤ យ៉ាង ពន្យល់ ព្រះបាទកោរព្យៈសព្វគ្រប់ ទើបព្រះរាជាស្តេចថ្វាយ បង្គំត្រឡប់ចូលព្រះរាជវាំងវិញ ។

## ១៨- រឿងប្រេតញីឈ្មោះឧត្តរមាតា

(ចាក បេ. ខុ.)

(ទោសនៃការដាក់បណ្តាសាកូនរបស់ខ្លួន)

សម័យមួយ ព្រះកង្ខារេវតត្ថេរ កំពុងសម្រាកក្នុងវេលា ថ្ងៃក្បែរឆ្នេរទន្លេគង្គា. ពេលនោះមានប្រេតញីមួយសម្បុរអាក្រក់ ឃើញគួរខ្លាច មានសក់វែងដល់ដី អាក្រាតខ្លួនទទេ បានយកសក់ របស់ខ្លួនបិទបាំងកាយ ដើរចូលទៅរកព្រះថេរៈ ហើយនិយាយតួញត្អែថា បពិត្រលោកម្ចាស់ ចាប់តាំងពីខ្ញុំធ្វើមរណកាលមក ចំនួន ៥៥ ឆ្នាំហើយ មិនដែលបានបរិភោគអាហារ ផឹកនូវទឹកសោះឡើយ ខ្ញុំស្រេកទឹកណាស់ សូមលោកម្ចាស់ឱ្យទឹកដល់ខ្ញុំ ។

ព្រះកង្ខារេវតត្ថេរតបថាទន្លេគង្គានេះមានទឹកត្រជាក់ហូរពីភ្នំហេមពាន្តមក ចូរនាងផឹកនូវទឹកក្នុងទន្លេនេះទៅហេតុអ្វីមកសុំទឹកពីអាត្មាវិញ ។

ប្រេតឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំដងទឹកទន្លេនេះហើយ តែផឹកមិនកើត ព្រោះទឹកនេះក្លាយជាឈាម ក្នុងពេលដែលខ្ញុំដងឡើង ។ អាស្រ័យហេតុនេះ សូមលោកម្ចាស់ឱ្យទឹកខ្ញុំផឹកផង ។

ព្រះថេរៈសួរថា នាងបានធ្វើកម្មអាក្រក់ដូចម្តេច ដោយកាយវាចាចិត្តពីពេលមុន ទើបពេលនេះមានវិបាក ដូច្នេះ ?

ប្រេតឆ្លើយថា កាលពីបព្វជាតិ ខ្ញុំមានកូនប្រុសម្នាក់ ឈ្មោះឧត្តរៈ ជាឧបាសកអ្នកមានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា ខ្ញុំជាមនុស្សកំណាញ់ មិនចង់ឱ្យខាតបង់ទ្រព្យ ។ កូនខ្ញុំបានឱ្យ ចីវរបិណ្ឌបាត គិលានភេសជ្ជ និងសេនាសនៈ ចំពោះ សាមណៈ ទាំងឡាយ ។ ពេលនោះ សេចក្តីកំណាញ់រួបរឹត ចិត្តខ្ញុំបណ្តាលឱ្យមាន សេចក្តីក្រោធញាប់ញ័រជេរប្រទេច ដាក់បណ្តាសាកូនថា ម្នាលឧត្តរៈ ចីវរប្បច្ច័យជាដើមនោះ ចូរកើតទៅជាឈាមដល់ឯងក្នុង បរលោកចុះ ព្រោះផលនៃ កម្មនេះទើបទឹកទន្លេគង្គានេះក្លាយ កើតជាឈាមដល់ខ្ញុំ ។

ព្រះថេរៈមានសេចក្តីអនុគ្រោះ បានជួយប្រេតនោះឱ្យ រួចដោះចាកបាបកម្មរបស់ខ្លួន ។

## ១៥- រឿងទេវិលតាបស

(ចាក តិ. ខុ.)

(ការដាក់បណ្ដាសាអ្នកឥតកំហុស ទោសត្រូវធ្លាក់លើខ្លួនវិញ)

កាលពីព្រេងនាយ ក្នុងរាជ្យព្រះបាទពារាណសី មានតាបសមួយរូបឈ្មោះទេវិល នៅក្នុងព្រៃហេមពាន្ត បានចូលមក សូមសម្នាក់ក្នុងសាលារបស់នាយស្មូនឆ្នាំង ។ បន្ទាប់មកមាន តាបសមួយរូបទៀតចេញពីព្រៃហេមពាន្ត មកសូមនាយស្មូនឆ្នាំង សម្នាក់នៅក្នុងសាលានោះដែរ ។

នាយស្មូនឆ្នាំងនិយាយថា ខ្ញុំព្រះករុណាប្រគេនឱ្យសម្នាក់បាន ប៉ុន្តែសូមលោកម្ចាស់ ប្រាប់តាបសដែលចូលមកសម្នាក់មុននោះ ឱ្យលោកជ្រាបផង, បើលោកសុខចិត្តឱ្យនៅជាមួយ សូមគង់នៅតាមសព្វព្រះទ័យចុះ ។

នារទតាបសបានទៅដល់សាលាហើយ ថ្លែងអាការៈគួរសម សុំទេវិលតាបសសម្នាក់នៅជាមួយផង ទេវិលតាបសព្រម ឱ្យនៅបាននិយាយសួរសុខទុក្ខគ្នាទៅវិញទៅមកយ៉ាងរាក់ទាក់ ដរាបដល់ពេលយប់ជ្រៅក៏នាំគ្នាសឹង ។

នារទតាបសបានចំណាំទីសំណឹងរបស់ទេវិល និងចំណាំ ទ្វារចេញចូលហើយក៏សឹងទៅ ។

ឯទេវិលតាបស មិនបានសឹងត្រង់កន្លែងដែលបានសឹង ហើយនោះទេ បែរជាក្រោកទៅសឹងទទឹងចំកណ្ដាលទ្វារវិញ ។ ដល់ពេលនារទតាបសចេញទៅក្រៅ ក្នុងវេលាយប់ក៏ជាន់ត្រង់ផ្នួងសក់ ។ ទេវិលខឹងតឹងស្រែកជេរកណ្ដាលអាធ្រាត្រថា នែ! ជដិលកោងឯងទើបនឹងមកអំពីព្រៃហ៊ានដើរជាន់ក្បាលអញដូច្នេះឬ ? នារទៈសូមទោសហើយចេញផុតទៅ ។

ទេវិលគិតថា តាបសនេះដល់ចូលមកវិញពិតជាជាន់ក្បាលអញទៀតមិនខាន ក៏សឹងបែរក្បាលមកចុងជើងវិញ ។

នារទៈគិតថា កាលអញចុះមកបានជាន់ក្បាលទេវិលឥឡូវ ត្រូវចូលទៅខាងចុងជើងគាត់វិញ កុំឱ្យជដិលកំណាចនេះខឹងទៀត ។ គិតហើយក៏លបចូលស្ទាបៗទៅជាន់ចំកទេវិលទៀត ។

ទេវិលខឹងក្រញេងក្រញាង ស្រែកជេរដាក់បណ្ដាសាថា កាលមុនប្រហែលឯងជាន់ផ្នួងសក់អញ ឥឡូវជាន់កអញទៀត. ឯងកោងណាស់ បើព្រះអាទិត្យរះឡើង ឱ្យក្បាលឯងបែកជា ៧ ភាគកុំខាន ។

នារទៈនិយាយថា នែលោកបងអាចារ្យ ខ្ញុំគ្មានបំណង

ជាន់លោកទេ ខ្ញុំគ្មានទោសទេ អ្នកណាមានទោស សូមក្បាលអ្នកនោះបែកចុះ, ឯក្បាលអ្នកឥតទោស សូមកុំបែកឡើយ ។ ទេវិលចេះតែស្រែកជេរផាក់បណ្តាសាញាប់ស្អេក, នារទៈចេះតែឆ្លើយតបវិញយ៉ាងនេះជាច្រើនផង ។

នារទតាបស លោកមានអានុភាពច្រើន អាចរលឹកឃើញបាន ៨០ កប្ប គឺរលឹកឃើញ ៤០ កប្បក្នុងអតីតកាល ៤០ កប្បក្នុងអនាគតកាល ។ អាស្រ័យហេតុនេះ ទើបលោកអាចដឹងច្បាស់ថា សម្បថបណ្តាសានឹងធ្លាក់ត្រូវលើទេវិលតាបសជាដាច់ខាត លោកមានចិត្តអនុគ្រោះចំពោះទេវិល ក៏ឃាត់ព្រះអាទិត្យមិនឱ្យរះឡើង ដោយកម្លាំងឫទ្ធិគឺបាំងពន្លឺព្រះអាទិត្យមិនឱ្យចាំងមកបាន ឱ្យនៅតែងងឹតយប់ដដែល ។

អ្នកនគរផ្អើលឈ្លូរចរព្រោះយប់យូរពេក ក៏នាំគ្នាចូលទៅគាល់ព្រះរាជា សូមព្រះរាជាញ៉ាំងព្រះអាទិត្យឱ្យរះឡើងឆាប់ៗ ។

ព្រះរាជាត្រាស់ថា ប្រហែលមានបព្វជិតទាស់ទែងគ្នាទេដឹង. ពួករាជបុរសបានទូលថា ពីម្សិលមិញ មានតាបសពីររូបសម្នាក់នៅក្នុងសាលារបស់នាយស្មូនឆ្នាំង ។ លុះបានជ្រាបដូច្នេះហើយ នាំរាជបុរសទៅកាន់ទីនោះ ឃើញតាបស

ពីររូបមែន ក៏ថ្វាយបង្គំ ហើយសួរហេតុដែលងងឹតគ្មានពន្លឺព្រះអាទិត្យ ចំពោះតាបសទាំងពីរ ។

នារទតាបសថ្វាយព្រះពរថា បពិត្រមហារាជ រឿងហេតុនេះកើតមកពីលោកអាចារ្យទេវិល ដាក់បណ្ដាសាឱ្យអាត្មាភាពបែកក្បាលជា៧ ភាគក្នុងពេលព្រះអាទិត្យរះឡើង។ អាត្មាភាព រលឹកឃើញថា បណ្ដាសានោះត្រូវធ្លាក់លើលោកអាចារ្យទេវិលវិញ ព្រោះអាត្មាភាពគ្មានកំហុស, ប៉ុន្តែអាត្មាភាពជួយសង្គ្រោះលោក ទើបមិនបើកឱ្យព្រះអាទិត្យរះ កុំឱ្យក្បាលលោកបែកជា ៧ ភាគតាមបណ្ដាសាលោក ។

ព្រះរាជាត្រាសបង្គាប់ឱ្យទេវិលតាបស សូមខមាលទោស ឯទេវិលជាមនុស្សមានះរឹងធ្មឹង មិនព្រមចុះញ៉មចាញ់នារទតាបស មិនស្គាល់ប្រមាណខ្លួន ចេះតែជជែកជណ្ដើមត្រូវ ទើបព្រះរាជា សួររកឧបាយធ្វើកុំឱ្យមានអន្តរាយដល់ទេវិល ។

នារទៈថ្វាយព្រះពរព្រះថា បើលោកទេវិលនេះ សូមខមាទោសចំពោះអាត្មាភាព លោកគ្មានអន្តរាយឡើយ ។ ព្រះរាជាត្រាស់ឱ្យរាជបុរសចាប់ទេវិលតាបស ឱ្យក្រាបទៀបបាទា នារទៈ ហើយឱ្យយកទេវិលទៅឱ្យឈរក្នុងទឹកស្រះមួយ

ជម្រៅត្រឹមក ឱ្យយកដីស្អិតមកបិតក្បាលទេវិលជ្រមុជទៅក្នុងទឹក ។ នារទតាបស ក៏បើកឫទ្ធិឱ្យព្រះអាទិត្យរះឡើង ដីស្អិតលើក្បាលទេវិលក៏បែកជា ៧ ភាគ, ទេវិលក៏រត់ចាត់ទៅ ។

លុះដល់មកពុទ្ធកាល ព្រះសម្ពុទ្ធបរមគ្រូយើងនេះ ព្រះរាជាពារាណសីក្នុងកាលនោះ បានមកជាព្រះអានន្ទ ។ នារទតាបសក្នុងកាលនោះ បានមកជាតួអង្គព្រះសម្ពុទ្ធ ។

ចំណែកខាងទេវិលតាបស បានមកកើតក្នុងសាក្យត្រកូល ដល់ខ្លួនចាស់ ទើបចេញបួសក្នុងពុទ្ធសាសនា មានឈ្មោះថា តិស្សត្ថេរ ។ លោកនៅតែមាននិស្ស័យប្រកាន់មានះរឹងត្អឹងដដែល។

ថ្ងៃមួយ ពួកអាគន្តុកភិក្ខុទើបមកថ្មី ឃើញលោកចាស់ស្មានថាព្រះថេរៈចាស់វស្សា ក៏នាំគ្នាចូលទៅថ្វាយបង្គំដោយគោរព លោកធ្វើជាមិនដឹងថាខ្លួនលោកទើបនឹងបួស ខំវាយឫកដូចព្រះថេរៈ ឱ្យគេថ្វាយបង្គំខ្លួន ព្រោះលោកមិនចង់ចំណុះថ្វាយបង្គំអ្នកដទៃ ។

លុះពួកអាគន្តុបានដឹងថាលោកទើបនឹងបួស ក៏នាំគ្នាតិះដៀលស្តីប្រដៅតាមច្បាប់វិន័យ កុំឱ្យធ្វើឫកដូច្នេះទៀត. លោកខឹងណាស់អង្គុយយំសម្រក់ទឹកភ្នែកតក់ៗ មិនព្រមថ្វាយ

បង្គំខមាទោសព្រះថេរៈទាំងនោះវិញឡើយ ។ ភិក្ខុទាំងឡាយក៏នាំរឿងនោះទៅទូលព្រះសម្ពុទ្ធ ទើបព្រះអង្គលើកអតីតនិទាន រឿងទេវិលតាបសនេះឯងមកសម្តែង ឱ្យឃើញច្បាស់នូវនិស្ស័យរបស់តិស្សត្ថេរ ជាអ្នកមានៈរឹងត្អឹងតាំងពីអតីតជាតិមក ។

# ១៦- រឿងខក្ខលិមាណា

(ចាក ធ. ខុ.)

(គួរប្រយ័ត្ន កុំជ្រះថ្លាភាន់ច្រឡំចំពោះព្រះពុទ្ធ)

បច្ចុប្បន្ននេះ មានមនុស្សជាច្រើនដែលមានសេចក្តីជ្រះ ថ្លាភាន់ច្រឡំចំពោះព្រះពុទ្ធ ច្រឡំថាព្រះអង្គជាអ្នកឱ្យសេចក្តីសុខទុក្ខដល់ខ្លួន ជាអ្នកបម្រើខ្លួន ដោយយករង្វាន់ថ្លៃឈ្នួលយ៉ាងថោក ត្រឹមលើកដៃសំពះ ត្រឹមតែធូបទៀនពីរបីសរសៃ ត្រឹមតែផ្កាមួយបាច់ ត្រឹមតែអង្ករមួយ ត្រឹមតែលេងភ្លេងថ្វាយម្តង ឬត្រឹមតែ ចេកមួយស្និត ។ល។

ពួកជនដែលមានការជ្រះថ្លាភាន់ច្រឡំដូច្នេះ កាលបើបានយកទៀនធូបពីរបីសរសៃ ទៅអុចក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបហើយ ក៏តាំងប្រើព្រះអង្គគ្មានសំចៃ បង្គាប់ឱ្យព្រះអង្គរកទ្រព្យសម្បត្តិឱ្យខ្លួនរកសេចក្តីសុខឱ្យខ្លួន រកស្វាមីភរិយាឱ្យខ្លួន រកកូនប្រុសស្រីឱ្យខ្លួន រកបុណ្យស័ក្តិឱ្យខ្លួន ។ល។

ពួកជនខ្លះប្រើព្រះអង្គដោយការជៀបណ្តាក់ គឺប្រើថាបើព្រះអង្គជួយឱ្យបានសំរេច តាមបំណងយ៉ាងនេះៗ ហើយខ្ញុំព្រះអង្គនឹងថ្វាយចេកមួយស្និត ឬអង្ករមួយ ។ល។

ដូចរៀបរាប់យ៉ាងសង្ខេបខាងលើនេះ ជាការជ្រះថ្លា

ភាន់ច្រឡំចំពោះព្រះពុទ្ធ. ព្រោះថាព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គជាបុគ្គលវិសេសថ្លៃថ្នូរបំផុតក្នុងលោក មិនមែនជាអ្នកស៊ីឈ្នួលចាំធ្វើការបំរើអ្នកដទៃទេ ដូចជាអារក្សអ្នកតា និងព្រះអាទិទេពទាំងឡាយ មានព្រះព្រហ្ម-ឥស្វរ-នារាយណ៍ និងព្រះជេហូវ៉ា-អល្លាហ៍-យេស៊ូជាដើម ដែលជាអ្នកធ្វើការបង្កើតអ្វីៗ និងធ្វើជាអ្នកជំនួយចាំជួយឱ្យសុខទុក្ខ ជួយកសាង និងជួយលាងបាបឱ្យបុណ្យជាដើម ជាអំពើប្រាចាកហេតុផលឡើយ ។

ព្រះពុទ្ធជាអ្នកច្បាប់ ព្រះអង្គគ្រាន់តែប្រាប់ហេតុផលច្បាស់លាស់ឱ្យដឹង ។ បើនរណាចង់បានអ្វី ខំរកខំធ្វើតាមច្បាប់ខ្លួនឯងទៅ ខ្លួនត្រូវបានដូចបំណងហើយ ។

ដូចជាអ្នកចង់បានអាយុវែង ត្រូវខ្លួនឱ្យអាយុដល់អ្នកដទៃ គឺកុំសំលាប់ទេ. បើខ្លួនសំលាប់ធ្វើឱ្យគេមានអាយុខ្លីហើយព្រះណាក៏ជួយឱ្យខ្លួនមានអាយុវែងមិនបានដែរ ។

- អ្នកចង់មានបុណ្យស័ក្ត មានអានុភាពឱ្យគេគោរពកោតខ្លាច ត្រូវខ្លួនឱ្យបុណ្យស័ក្ត ឱ្យអានុភាពដល់អ្នកដទៃ គឺត្រូវចេះគោរពអ្នកមានគុណទាំងឡាយ មានមាតាបិតា ព្រះមហាក្សត្រ សមណព្រាហ្មណ៍ជាដើម និងគោរពសិទ្ធិមនុស្ស

ទូទៅកុំប្រមាថព្រហើន ធ្វើឱ្យអ្នកដទៃថោកទាប ។

- អ្នកចង់មានកំលាំងច្រើន ត្រូវឱ្យកំលាំងដល់អ្នកដទៃ គឺឱ្យចំណីអាហារ ចេះអាណិតអាសូរចំពោះអ្នកក្រខ្សត់អត់ឃ្លាន និងថ្វាយជូនអ្នកមានគុណ មានមាតាបិតា សមណព្រាហ្មណ៍ជាដើម ។

- អ្នកចង់មានពណ៌សម្បុរល្អ ត្រូវឱ្យពណ៌សម្បុរដល់អ្នកដទៃ គឺឱ្យសំពត់អាវ គ្រឿងស្លៀកពាក់ដល់មាតាបិតា សមណព្រាហ្មណ៍ និងអ្នកកំសត់ទុគត៌ ហើយកុំក្រោធខឹង កុំចងកំហឹងទុក ។ល។

បើខ្លួនយើងមិនរកបុណ្យស័ក្តិឱ្យខ្លួនយើង មិនរកកំលាំងឱ្យខ្លួនយើង មិនរកពណ៌សម្បុរឱ្យខ្លួនយើង ។ល។ ហើយទៅប្រើព្រះឱ្យរកឱ្យ តើបានពីណាមានតែបាបថែមទៀត ព្រោះខ្លួនហ៊ានប្រើព្រះ ។ នេះឯងជាសេចក្តីជ្រះថ្លាភាន់ច្រឡំ ។ អាស្រ័យហេតុនេះហើយ ទើបព្រះសម្ពុទ្ធប្រដៅថា " ខ្លួនត្រូវទីពឹងខ្លួន" ។

សេចក្តីជ្រះថ្លាភាន់ច្រឡំនេះ មានតាំងពីសម័យពុទ្ធកាលមកដូចជាវក្កលិមាណព មានសេចក្តីជ្រះថ្លាចំពោះរូបឆោមព្រះសម្ពុទ្ធ ចង់តែឃើញរាល់ពេលវេលា. ទើបគិតថា

បើទៅបួស ហើយនៅជាមួយព្រះអង្គ ទើបបានឃើញរាល់ថ្ងៃ. ក៏លះបង់ផ្ទះទៅបួសតាមបំណង. ដូចមានដំណើររឿងតទៅនេះ :

សម័យមួយវក្កលិមាណព បានឃើញព្រះមានព្រះភាគយាងទៅក្រុងសាវត្ថី មានភិក្ខុសង្ឃចោមរោមជាបរិវារ ក៏កើតសេចក្ដីជ្រះថ្លា ជាប់ចិត្តនឹងព្រះរូបឆោមរបស់ព្រះអង្គ ចង់ឃើញព្រះអង្គជានិច្ច ទើបដាច់ចិត្តលះបង់ផ្ទះទៅបួសដើម្បីឃើញ ។

លុះបួសហើយ មិនបានតាំងចិត្តចម្រើនសមណធម៌ទេ គិតតែដើរតាមគន់មើលព្រះរូបឆោមព្រះសម្ពុទ្ធប៉ុណ្ណោះ។ តមកព្រះសម្ពុទ្ធជ្រាបថាវក្កលិនេះ ចូរមកបួសក្នុងសាសនាតថាគត ដោយការភាន់ច្រឡំ មិនដឹងថាភារកិច្ចរបស់អ្នកបួសត្រូវប្រព្រឹត្តដូចម្ដេចឡើយ ។ ការយល់ច្រឡំនេះ មិនអាចត្រាស់ដឹងធម៌វិសេសបាន ទើបព្រះអង្គទ្រង់បណ្ដេញចេញអំពីពុទ្ធសម្នាក់ ។

វក្កលិត្រូវមានសេចក្ដីទោមនស្សណាស់ ព្រោះខុសនឹងបំណងរបស់ខ្លួន ក៏ឡើងទៅលើភ្នំគិជ្ឈកូដ ដើម្បីនឹងលោតទម្លាក់សំលាប់ខ្លួន ។

ព្រះសម្ពុទ្ធទ្រង់ជ្រាប ទើបស្តេចយាងទៅឱ្យវក្កលិបាន ឃើញ ហើយទ្រង់ត្រាស់ទូន្មានលួងលោមដោយធម្មកថា ។ ព្រះវក្កលិត្ថេរកើតបីតិសោមនស្សយ៉ាងខ្លាំង តាំងនៅក្នុងព្រះឱវាទ. តមកលោកបានត្រិះរិះដោយឧបាយ ឪ ប្រពៃ បន្ទោបង់សេចក្ដីស្រឡាញ់ ក្នុងរូបឆោមព្រះសាស្តា និងការភាន់ច្រឡំចេញបាន ក៏កើតធម្មសង្វេគ ខំចម្រើនវិបស្សនាមិនយូរប៉ុន្មាន បានសម្រេចព្រះអរហត្តផល ព្រមដោយបដិសម្ភិទា-ញាណ ។

ការជ្រះថ្លាភាន់ច្រឡំរបស់វក្កលិមាណព ក្នុងកាលនោះ ជាការភាន់ច្រឡំសមហេតុផលម្យ៉ាង ព្រោះបានឃើញរូបឆោមព្រះសម្ពុទ្ធ ដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ និងអនុព្យញ្ជនៈ ៨០ គួរឱ្យចង់ឃើញ ដរាបដល់លះបង់ផ្ទះសម្បែងទៅបួសឱ្យបានឃើញរាល់ថ្ងៃ ។ ឯការជ្រះថ្លាភាន់ច្រឡំរបស់យើងក្នុងបច្ចុប្បន្ននេះ ផ្ទុយពីហេតុផលស្រឡះ ប្រកបដោយមោហៈវង្វេង យល់ឃើញព្រះសម្ពុទ្ធ ដែលជាព្រះអរហន្តយ៉ាងវិសេស ថាជាអ្នកបំរើខ្លួនយ៉ាងវិសេស អាចរកសុខចំរើនឱ្យខ្លួនបានស័ក្តសិទ្ធិទៅវិញ ។ បើកុំតែមានការយល់ច្រឡំដូច្នេះ ប្រហែលមិនជ្រះថ្លាចំពោះព្រះពុទ្ធឡើយ ។

ចំណែកការជ្រះថ្លាចំពោះព្រះធម៌ និងព្រះសង្ឃ ក៏មានន័យប្រហែលដែរ ។

ដូច្នេះសូមពុទ្ធសាសនិកទាំងឡាយ រៀបចំសេចក្តីជ្រះថ្លាចំពោះព្រះរតនត្រ័យឱ្យបានសមរម្យ តាមធម៌វិន័យពុទ្ធសាសនា កុំច្រឡំយកសេចក្តីជ្រះថ្លាចំពោះព្រះព្រហ្ម-ឥស្សរ-អារក្សអ្នកតា មកប្រើចំពោះព្រះពុទ្ធសាសនាឡើយ ។

សូមបញ្ជាក់ថា បើយើងមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនាហើយ ខំប្រព្រឹត្តតាមធម៌វិន័យ ដែលមានក្នុងទ្រឹស្តីពុទ្ធសាសនានោះឱ្យបានត្រឹមត្រូវ ។ បើយើងចង់បានអ្វីៗ ខំប្រព្រឹត្តតាមតែធម៌វិន័យនោះៗ ពិតជាបានដូចបំណងហើយ កុំខំសំបូងសំរួង បន់ស្រន់ស្ទកចាំន់ ថ្វាយនេះថ្វាយនោះ ប្រើព្រះឱ្យជួយរកឱ្យខ្លួនឡើយ ព្រោះការធ្វើដូច្នេះ ថោកទាបណាស់ ចូលទៅក្នុងពួកអំពើពុករលួយ ។

# ១៧- រឿងធម្មទិន្នារាជទេវី

(ចាក ធ. ខុ.)

(កាត់ក្បាលពពែ១ ត្រូវគេកាត់ក្បាលវិញជាច្រើនជាតិស្មើនឹងរោមពពែ)

កាលពីព្រេងនាយ មានព្រះរាជបុត្តព្រះបាទពារាណសីមួយអង្គ ចង់បានរាជសម្បត្តិ បានចូលទៅជិតដើមជ្រៃមួយ ដើមហើយបន់ស្រន់ទេវតា ដែលស្ថិតនៅនាដើមជ្រៃនោះថា បពិត្រទេវតាបើឥតអំពីបិតាខ្ញុំទៅហើយ ខ្ញុំបានសោយរាជ្យ ខ្ញុំនឹងធ្វើពលិការបូជាដោយឈាមក្នុងបំពង់កស្ដេច ទាំង១០១ព្រមទាំងអគ្គមហេសី១០១ដែរ ។

កាលព្រះរាជបិតាទីវង្គតទៅ ព្រះរាជបុត្រនោះក៏បានសោយរាជ្យមែន ក៏បានចាប់ស្ដេច១០១ ព្រមទាំងអគ្គមហេសី១០១ យកមកដើម្បីធ្វើពលិការ បូជាទេវតា លើកលែងតែព្រះនាងធម្មទិន្នារាជទេវីជាមហេសី ព្រះបាទឧគ្គសេន ដែលទ្រង់គភ៌ជិតគ្រប់ខែប៉ុណ្ណោះ ។

គ្រានោះរុក្ខទេវតារក្សាដើមជ្រៃគិតថា ព្រះរាជានេះក្លាហានណាស់ បានចាប់ស្ដេចទាំងនោះមក ព្រោះតែបូជាអញ. ព្រះរាជវង្សក្នុងជម្ពូទ្វីប នឹងសាបសូន្យមិនខាន. គល់ជ្រៃអញនឹងក្រខ្វក់ដោយឈាមមិនខាន ។ តើអញនឹងឃាត់ ព្រះរាជានេះបានឬទេ ? លុះដឹងថា មិនអាចឃាត់បាន ក៏ចូលទៅរកទេវតា ដែលមានសមត្ថភាពក្នុងចក្កវាឡទាំងមូល ទេវតាទាំងនោះ បញ្ជូនឱ្យទៅទូលព្រះឥន្ទ ១ មានព្រះឱង្ការ

ថា អ្នកត្រូវស្លៀកពាក់ពណ៌ក្រហម បង្ហាញខ្លួនដើរចេញពីគល់ជ្រៃឱ្យស្តេចនោះឃើញ. ស្តេចនោះនឹងអង្វរអ្នកឱ្យទទួលពលិការបូជា ដោយពាក្យផ្សេងៗ. អ្នកត្រូវនិយាយចាប់កំហុសស្តេចនោះថា កាលព្រះរាជាបន់ថាយកឈាមបំពង់កស្តេច ១០១ និងអគ្គមហេសី ១០១ មកបូជា ឥឡូវបែរជាមិនយកឱ្យគ្រប់ចំនួន លើកនាងធម្មទិន្នារាជទេវីចេញ. យើងមិនទទួលពលិកាបូជាដោយហេតុនោះឯង ។ កាលអ្នកនិយាយយ៉ាងនេះ ស្តេចនឹងចាប់ធម្មទិន្នារាជទេវីយកមក នាងនឹងដោះលែងស្តេចទាំងនោះបានមិនខាន ។

រុក្ខទេវតាត្រឡប់មកវិញធ្វើតាមបញ្ជាព្រះឥន្ទ. ព្រះបាទពារាណសី ក៏នាំយកនាងធម្មទិន្នារាជទេវីមកថ្វាយរុក្ខទេវតា. លុះនាងមកដល់ហើយ លុតជង្គង់ថ្វាយបង្គំតែព្រះស្វាមីរបស់នាងប៉ុណ្ណោះ ។

ព្រះបាទពារាណសីទ្រង់ខ្ញាល់ថា យើងជាស្តេចធំជាងស្តេចទាំងអស់ ហេតុអ្វីនាងមិនថ្វាយបង្គំយើងផង ?

- បពិត្រមហារាជ ព្រះអង្គមិនដែលព្រះរាជទានអ្វីដល់ខ្ញុំម្ចាស់ឡើយ មានតែព្រះស្វាមីខ្ញុំម្ចាស់ប៉ុណ្ណោះ ដែលបានព្រះរាជទានឥស្សរិយយសដល់ខ្ញុំ តើថ្វាយបង្គំព្រះអង្គ

បានការអ្វី ! ។ ពេលនោះរុក្ខទេវតាឱ្យពរសព្ទសាធុការថា សាធុ សាធុ ចាប់ផ្កាមួយក្ដាប់បាចបូជានាង ។

- បើនាងមិនថ្វាយបង្គំយើង ក៏គួរថ្វាយបង្គំរុក្ខទេវតារបស់យើងដែរ !

- បពិត្រមហារាជ ស្ដេចទាំង ១០១ និងអគ្គមហេសីព្រះអង្គចាប់យកមកដោយព្រះអង្គឯង, ទេវតាមិនបានប្រើព្រះអង្គឱ្យចាប់មកទេ ។ រុក្ខទេវតាឱ្យពរទៀតថា សាធុ សាធុ ចាប់ផ្កាមួយក្ដាប់បូជានាងទៀត ។

ពេលនោះធម្មទិន្នារាជទេវីមានសវនីយ៍ថា បើទេវតារបស់ព្រះអង្គពូកែមែន បានចាប់ស្ដេចទាំងអស់នេះមកថ្វាយទ្រង់ ម៉េចក៏ទេវតាឱ្យភ្លើងឆេះដើមឈើខាងឆ្វេងអស់ មិនលត់ភ្លើងនោះឱ្យបាន ។ រុក្ខទេវតាឱ្យពរទៀតថា សាធុ សាធុ ហើយចាប់ផ្កាមួយក្ដាប់បូជានាងទៀត ។

បន្ទាប់មកព្រះនាង ទ្រង់ព្រះកន្សែងទួញយំ ហើយស្រាប់តែទ្រង់ព្រះសម្រួលសើចក្អាកក្អាយវិញ ជាឧបាយដើម្បីទូន្មានព្រះបាទពារាណសី ឱ្យស្គាល់កំហុស ឱ្យមានព្រះទ័យតក់ស្លុតចំពោះកំហុសរបស់ព្រះអង្គ ។

ពេលនោះព្រះបាទពារាណសីភាន់ភាំង មានព្រះឱង្ការ

ថា នាងឯងឆ្កួតទេឬ ?

- បពិត្រមហារាជ ស្ត្រីប្រហែលខ្ញុំម្ចាស់មិនមែនឆ្កួតទេ ។

- បើមិនឆ្កួតហេតុអ្វីយំផងសើចផងយ៉ាងនេះ ?

- បពិត្រមហារាជ ហេតុមានដូចតទៅនេះ :

ពីអតីតកាល ខ្ញុំម្ចាស់កើតជាកុលធីតានៅក្នុងត្រកូល ស្វាមីបានឃើញភ្ញៀវរបស់ស្វាមីមកដល់ ក៏រៀបចាត់ចែងភត្តទទួល. ខ្ញុំម្ចាស់បានកាត់ក្បាលពពែមួយ ដែលដេកនៅក្រោយផ្ទះដើម្បីធ្វើម្ហូប ដោយកម្មអាក្រក់ប៉ុណ្ណេះ ខ្ញុំម្ចាស់ស្លាប់ទៅកើតក្នុងនរកជាច្រើនសែនឆ្នាំ. រួចពីនរកមក ត្រូវគេកាត់ក្បាលជាច្រើនជាតិរាប់មិនអស់ ប្រហែលគ្នានឹងរោមពពែ ។ ចំណង់បើព្រះអង្គកាត់ព្រះកេសាស្ដេចទាំងរយនេះ តើកាលណានឹងរួចចាកទុក្ខបាន ខ្ញុំម្ចាស់នឹកឃើញសេចក្ដីទុក្ខរបស់ព្រះអង្គ គ្មានទីបំផុតយ៉ាងនេះបានជាយំ. ខ្ញុំម្ចាស់នឹកឃើញខ្លួនខ្ញុំម្ចាស់បានរួចផុតទុក្ខ ព្រោះការកាត់ក្បាលពពែនោះហើយបានជាសើច ។ រុក្ខទេវតាមានសេចក្ដីត្រេកអរ បានឱ្យពរថា សាធុ សាធុ ហើយចាប់ផ្កា ១ ក្ដាប់បូជានាងទៀត ។

ព្រះបាទពារាណសីទ្រង់ព្រះចិន្តាថា ឱ ! បាបកម្ម របស់អញមានទម្ងន់ណាស់តើ ទ្រង់ឃើញកំហុសមានសេចក្ដីតក់ស្លុតចំពោះកំហុស ហើយក៏ផ្គងអញ្ជលី ឱនព្រះសិរថ្វាយបង្គំស្ដេច ដែលមានវ័យចាស់ជាង និងគោរពស្ដេចដែលមានវ័យក្មេងជាង ឱ្យស្ដេចទាំងអស់ ព្រមទាំងអគ្គមហេសីទាំងអស់ អត់ទោសឱ្យហើយ ទ្រង់បញ្ជូនស្ដេចទាំងអស់ ឱ្យយាងទៅនគរព្រះអង្គវិញ ។

លុះមកដល់ពុទ្ធកាលយើងនេះ ព្រះនាងធម្មទិន្នារាជទេវី បានមកជានាងមល្លិកាទេវី ជាអគ្គមហេសីព្រះបាទបសេនទិកោសល ។ ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាព្រះបាទបសេនទិកោសល ។ ឯរុក្ខទេវតាក្នុងកាលនោះ គឺព្រះអរហន្តសម្ពុទ្ធបរមគ្រូនេះឯង ។

មានរឿងដំណាលថា កាលដែលព្រះបាទបសេនទិកោសល បានឮសម្លេងសត្វនរកស្រែកកណ្ដាលរាត្រីថា "ទុ. ស. ន. សោ." ទ្រង់មានសេចក្ដីតក់ស្លុតខ្លាំង បានជឿតាមពាក្យពួកបុរោហិត ឱ្យយកសត្វគ្រប់មុខ ១មុខ ១រយៗ និងក្មេងប្រុស ១រយ ក្មេងស្រី ១រយ ធ្វើការបូជាយញ្ញនោះ បានព្រះនាងមល្លិកានេះឯង ជួយព្រះអង្គឱ្យរួចចាកអំពើអកុសល

នោះទៀត គឺបាននាំព្រះអង្គទៅគាល់ព្រះសម្ពុទ្ធ សួរអំពីហេតុដែលឮសម្លេងសត្វនរកនោះ ។

ព្រះសម្ពុទ្ធត្រាស់សម្តែងប្រាប់ព្រះបាទបសេនទិកោ-សលថា :

ក្នុងសាសនាព្រះសម្ពុទ្ធកស្សបៈ កាលនោះមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ, ព្រះពុទ្ធកស្សបៈមានភិក្ខុសង្ឃ ២ម៉ឺនអង្គចោមរោមជាបរិវារ ស្តេចយាងទៅប្រោសសត្វ ក្នុងក្រុងពារាណសី, អ្នកក្រុងបានបបួលគ្នាធ្វើអាគន្តុកទានគ្រប់ៗគ្នា។ ឯសេដ្ឋីបុត្រ ៤ នាក់ជាសម្លាញ់នឹងគ្នា ក្នុងម្នាក់ៗមានទ្រព្យ ៤០ កោដិ នៅក្នុងក្រុងពារាណសីនោះដែរ ឥតមានសេចក្តីជ្រះថ្លាចំពោះពុទ្ធសាសនាឡើយ, បានជំនុំគ្នាថាយើងនឹងផឹកសុរាឱ្យស្រវឹង ហើយស៊ីសាច់ដែលមានរសឆ្ងាញ់ ទើបពិតជារស់នៅមានប្រយោជន៍ ។ ម្នាក់ទៀតនិយាយថា យើងគួរតែបរិភោគបាយស្រូវសាលី ដែលមានក្លិនក្រអូប និងវត្ថុមានរសផ្សេងៗ ។ ម្នាក់ទៀតនិយាយថា យើងត្រូវចំណាយប្រាក់ច្រើនឱ្យពួកស្រីៗ , ប្រពន្ធ និងកូនក្រមុំអ្នកដទៃនឹងស្ម័គ្រស្នេហានឹងយើងមិនខាន ។

សេដ្ឋីបុត្រទាំង ៤ យល់ព្រមស្ម័គ្រចិត្តរួមគ្នាយ៉ាងនេះ

ហើយក៏ចំណាយទ្រព្យប្រព្រឹត្តអបាយមុខ ស៊ីផឹក ល្បែងពួកស្រី១ ដែលមានរូបល្អ ដោយទ្រព្យយកមកនាំគ្នាប្រព្រឹត្តបរទារិកកម្ម ចំពោះប្រពន្ធគេក៏មាន កូនក្រមុំគេក៏មាន រហូតអស់ ២ម៉ឺនឆ្នាំ ទើបធ្វើមរណកាលទៅកើតក្នុងអវិចីនរក អស់ចន្លោះព្រះពុទ្ធមួយអង្គ. រួចពីនរកអវិចី បានមកកើតក្នុងនរកលោហកុម្ភី(ឆ្នាំងខ្ទះទង់ដែងយ៉ាងធំ) មានជំរៅ៦០ យោជន៍។

ពួកសត្វនរកទាំង ៤ នាក់នោះ លិចចុះក្នុងទឹកទង់ដែងចំនួន៣ ម៉ឺនឆ្នាំទើបដល់បាតខ្ទះ. អណ្តែតឡើងវិញ៣ម៉ឺនឆ្នាំទៀតទើបដល់មាត់ខ្ទះ ។

សត្វនរកទាំង ៤ នោះចង់ស្រែកថ្លែងសេចក្តីទុក្ខវេទ-នា របស់ខ្លួនប្រាប់គ្នីគ្នា ប៉ុន្តែដោយអំណាចកំសួលទឹកពុះខ្លាំងពេក ខំស្រែកបានតែម្នាក់មួយម៉ាត់ក៏លិចទៅក្នុងខ្ទះវិញ ។ អាស្រ័យហេតុនេះ ទើបមហារាជស្តាប់ឮតែ ៤ ម៉ាត់ថា "ទុ. ស. ន. សោ." ដូច្នេះ ។

សត្វនរកទី១ ដែលខំស្រែកថា ទុ. នោះបម្រុងនិយាយថា :

ទុជ្ជីវិតមជីវម្ហា យេសន្តោ ន ទទាម្ហសេ
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ហ អត្តនោ ឲ

ប្រែថា យើងទាំងឡាយមានជីវិតដ៏លាមក បានរស់នៅហើយ កាលដែលយើងកំពុងមានទ្រព្យ យើងមិនដែលឱ្យទានសោះ យើងមិនបាននូវទីពឹងរបស់ខ្លួនសោះ ។

សត្វនរកទី ២ ដែលខំស្រែកថា ស. នោះបម្រុងនិយាយថា :

**សដ្ឋិវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ**
**និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។**

ប្រែថា យើងទាំងឡាយ ដែលបាបកម្មចម្អិននៅក្នុងនរកនេះអស់ ៦ ម៉ឺនឆ្នាំគត់មិនលើសមិនខ្វះ ឱ! កាលណានឹងមានទីបំផុតនៃសេចក្តីទុក្ខបាន ។

សត្វនរកទី ៣ ដែលខំស្រែកថា ន. នោះបំរុងនិយាយថា :

**នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ**
**តថា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិសា ។**

ប្រែថា ទីបំផុតនៃសេចក្តីទុក្ខរបស់យើងទាំងឡាយមិនមានឡើយ មិនដឹងជាពេលណានឹងមានទីបំផុតនៃសេចក្តីទុក្ខបាន នែសម្លាញ់ត្បិតក្នុងកាលនោះ ខ្ញុំនិងអ្នកទាំងឡាយបានធ្វើបាបសម្បើមណាស់ ។

សត្វនរកទី ៤ ដែលខំស្រែកថា សោ. នោះបំរុង និយាយថា :

**សោហំ នូន ឥតោគន្ត្វា យោនឹ លទ្ធាន មានុសឹ**
**វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ ៕**

ប្រែថា បើខ្ញុំបានរួចពីទីនេះទៅ បានជាមនុស្ស ខ្ញុំនឹងនូវពាក្យនៃអ្នកសូមទាន ជាអ្នកមានសីល និងខំធ្វើអំពើល្អឱ្យបានច្រើន ។

លុះព្រះសម្ពុទ្ធសម្ដែងយ៉ាងនេះចប់ហើយ, ព្រះបាទបសេនទិកោសល មានព្រះទ័យរីករាយ ប្រាសចាកការភ័យតក់ស្លុត ទ្រង់បញ្ជាឱ្យរាជបុរសដោះលែងពួកសត្វ និងក្មេងប្រុសស្រី ដែលចាប់មកបម្រុងបូជាយញ្ញនោះ ឱ្យទៅទីកន្លែងរបស់ខ្លួនវិញ ។

៚

# ១៨- រឿងពាកុលកុមារ

(ចាក ធ. ខុ.)

(អានិសង្សរក្សាអ្នកជម្ងឺ និងឱសថទាន)

ក្នុងក្រុងកោសម្ពី មានមហាសេដ្ឋីមួយរូប មានបុត្រជាទីស្រឡាញ់ ។ កាលបុត្រនោះកើតបាន ៥ ថ្ងៃ មាតាបិតាបានធ្វើមង្គលកោរសក់ព្រៃ យកទៅផ្ងូតទឹកក្នុងទន្លេគង្គាតាមប្រពៃណី ដើម្បីឱ្យឈ្មោះកូន ។

ខណៈនោះ ជួនជាមានត្រីធំមួយបានឃើញទារក ហើយសម្គាល់ថាជាអាហារ ក៏ស្ទុះទៅត្របាក់លេបចូលទៅក្នុងពោះទៅ ។ ទារកនោះមានបុញ្ញាភិនីហារច្រើនពីអតីតជាតិ ទើបមិនមានអន្តរាយអ្វី ហាក់ដូចគេផ្តេកលើកម្រាលក្នុងបន្ទប់ ។

ត្រីនោះកាលលេបទារកចូលក្នុងពោះហើយ កើតសេចក្តីក្តៅក្រហាយ ក៏ហែលរត់ចេញពីទីនោះយ៉ាងលឿន មិនបានប្រុងប្រយ័ត្នទៅជាប់អួនអ្នកនេសាទ ។ អ្នកនេសាទយកអំពីអួនឡើងក៏ស្លាប់ទៅ ។ អ្នកនេសាទបានយកត្រីនោះទៅលក់ឱ្យអ្នកស្រុក តម្លៃ ១ពាន់កហាបណៈ គ្មានអ្នកណាហ៊ានទិញឡើយ ។ លុះទៅដល់ក្រុងពារាណសី សេដ្ឋីក្នុង

ក្រុងនោះបានទិញ ហើយចាក់មនុស្សឱ្យវះពោះត្រី ដោយឃើញពោះត្រីនោះធំសម្គាល់ថាមានពង ស្រាប់តែឃើញទារករស់រវើកទៅវិញ ។ ពារាណសីសេដ្ឋី បានប្រកាសរកមាតាបិតាទារកនោះ, ប៉ុន្តែមិនមានអ្នកណាមួយទទួលសោះ សេដ្ឋីក៏ចិញ្ចឹមរក្សា ស្រឡាញ់ទារកនោះដូចជាកូនបង្កើតទៅ ។

ឯកោសម្ពីមហាសេដ្ឋី កាលបើបានដឹងថា សេដ្ឋីក្រុងពារាណសីរើសបានកូនមួយក្នុងពោះត្រីហើយ ក៏យល់ច្បាស់ថាពិតជាកូនរបស់ខ្លួន ទើបប្រញាប់ប្រញាល់ធ្វើដំណើរទៅក្រុងពារាណសី ដើម្បីពិនិត្យមើលកូននោះ ។ លុះស្គាល់ច្បាស់ជាកូនរបស់ខ្លួនហើយ បានសុំកូនអំពីពារាណសីសេដ្ឋីៗមិនព្រមឱ្យ ព្រោះជាប់ចិត្តស្រឡាញ់ដូចកូនខ្លួនទៅហើយ ក៏កើតវិវាទ ប្រកែកជជែកគ្នាមិនដាច់ស្រេច ទើបនាំគ្នាយកកូននោះទៅក្រាបបង្គំគាល់ព្រះចៅក្រុងពារាណសី សុំព្រះអង្គវិនិច្ឆ័យកាត់សេចក្តី ។

ព្រះចៅក្រុងពារាណសី ទ្រង់សម្រុះសម្រួលតាមដំណើរការ ត្រាស់បង្គាប់ឱ្យសេដ្ឋីទាំងពីរត្រកូល នាំគ្នាថែរក្សាទំនុកបំរុងទារកនោះទាំងអស់គ្នា ទើបព្រះអង្គព្រះរាជ

ទាននាមចំពោះទារកថា ពាកុលកុមារ មានន័យថា កុមារ របស់ត្រកូលទាំងពីរ ឬនៅក្នុងត្រកូលទាំងពីរ។ សេដ្ឋីទាំងពីរ សុខចិត្តទទួលគោរពតាមព្រះរាជបញ្ញា ដោយចិត្តរីករាយ ទាំងអស់គ្នា ថ្វាយបង្គំលាត្រឡប់មកផ្ទះពារាណសីសេដ្ឋីវិញ។

សេដ្ឋីទាំងពីរបានជំនុំគ្នាសម្រេចថា ត្រូវសង់ប្រាសាទ ក្នុងស្រុករៀងខ្លួនម្នាក់មួយ ដើម្បីផ្លាស់វេណគ្នាថែរក្សា ពាកុលកុមារ កំណត់៤ខែម្នាក់ ហើយត្រូវមានទាសាទាសី សម្រាប់ថែរក្សា និងជូនដំណើរកុមារទៅវិញទៅមក ក្នុង ដំណាច់ខែទី៤ រាល់ៗពេល ។

សម័យមួយ ព្រះសាស្តាបានប្រកាសផ្សាយពុទ្ធសាស-នា មកដល់ក្រុងពារាណសី ពាកុលកុមារព្រមទាំងបរិវារ ចូលទៅគាល់ព្រះសម្ពុទ្ធ ស្តាប់ធម្មទេសនាកើតសទ្ធាជ្រះថ្លា ទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទាក្នុងពុទ្ធសាសនា ។ ពាកុលភិក្ខុ បានទទួលព្រះឱវាទក្នុងផ្លូវវិបស្សនាកម្មដ្ឋានអំពី ព្រះសាស្តា បំពេញព្យាយាមអស់ ៧ ថ្ងៃក៏បានសម្រេចអរហត្ត ផល ជាអសេខបុគ្គល ។

ព្រះពាកុលត្ថេរ ជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ និង អរញ្ញិកកធុតង្គ យ៉ាងតឹងតែង ចាប់ពីលោកបួសមកចំនួន ៦០

ឆ្នាំ មិនដែលគង់ចាំវស្សាក្នុងអាវាសជិតស្រុកឡើយ ជាពិសេសលោកមិនដែលមានជម្ងឺរោគាពាធអ្វី បៀតបៀនខ្លួនលោកឡើយ លោកមិនបាច់ខ្វល់ខ្វាយ រក្សារាងកាយដោយភេសជ្ជៈ សូម្បីតែផ្លែសម៉ មួយចំណិត ក៏មិនដែលឆាន់ផង ។ នេះជាអានិសង្ស ដែលលោកបានថែរក្សាបម្រើអ្នកជម្ងឺ និងបានធ្វើទានឱសថផ្សេងៗ ក្នុងអតីតជាតិ ។

អាស្រ័យហេតុនេះ ទើបព្រះសាស្តាត្រាស់សរសើរថា ជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានអាពាធតិច ។ ដល់ពេលអស់អាយុសង្ខារព្រះពាកុលត្ថេរ គង់បរិនិព្វានក្នុងកណ្តាលជំនុំសង្ឃដោយចូលតេជោសមាបត្តិ ភ្លើងដែលកើតឡើងដោយបុញ្ញរិទ្ធិរបស់លោក បានឆេះរំលាយសរីរៈអស់រលីងក្លាយគ្មានសល់ឡើយ ។

## ១៩- រឿងអបុត្តកសេដ្ឋី

(ចាក ទុ. សំ.)

(អ្នកដែលមានទ្រព្យហើយ ចេះតែមានចិត្តស្តាយ មិនហ៊ានស៊ីចាយ ធ្វើបុណ្យទាន ឱ្យបានសមរម្យតាមកម្លាំងទ្រព្យ ពិតជាមនុស្សកម្មក្រាស់, កាលពីជាតិមុនបានធ្វើបុណ្យរួចហើយ នឹកស្តាយក្រោយ)

ក្នុងសម័យពុទ្ធកាល, ព្រះសម្ពុទ្ធបរមគ្រូគង់នៅវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។

គ្រានោះព្រះបាទបសេនទិកោសល ស្តេចយាងទៅគាល់ព្រះសាស្តាទាំងថ្ងៃត្រង់ ។ លុះថ្វាយបង្គំប្រថាប់ក្នុងទីគួរសមហើយ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ចុះព្រះអង្គទើបនឹងស្តេចយាងពីទីណាទាំងថ្ងៃត្រង់ ។

ព្រះបាទបសេនទិកោសល ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មានសេដ្ឋីម្នាក់ក្នុងក្រុងសាវត្ថីនេះ ជាមនុស្សគ្មានកូន បានធ្វើមរណកាលហើយ ខ្ញុំព្រះអង្គប្រមូលបានទ្រព្យសម្បត្តិជាច្រើន គ្រាន់តែសាច់ប្រាក់ចំនួន ១ រយសែន យកទៅទុកក្នុងរាំងជាព្រះរាជទ្រព្យ ។ សេដ្ឋីនោះ កំណាញ់ណាស់ បរិភោគតែបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរ, ប្រើតែសំពត់សំបកធ្មៃប៉ះជាបីផ្ទាំង, ជិះតែរទេះចាស់តូចមួយ និងបាំងធំត្រស្លឹកយ៉ាងតូច ។

ព្រះសម្ពុទ្ធត្រាស់ថា បពិត្រមហារាជ ពាក្យនេះពិតហើយ, កាលពីព្រេងនាយ សេដ្ឋីនោះបានធ្វើទានចំពោះព្រះបច្ចេកពុទ្ធ ព្រះនាមព្រះតគរសិខី ដោយវាចាថា អ្នកទាំងឡាយចូរឱ្យបិណ្ឌបាតដល់សមណៈដូច្នេះហើយ ក៏ក្រោកអំពីអាសនៈចេញទៅ ។

លុះសេដ្ឋីនោះឱ្យទានរួចហើយ មានសេចក្តីស្តាយក្រោយថា បើទុកបិណ្ឌបាតនោះឱ្យពួកទាសាទាសី ពួកកម្មករស៊ីវិញប្រសើរជាង នេះម្យ៉ាង ។ ម្យ៉ាងទៀត សេដ្ឋីនោះបានសម្លាប់ក្មួយម្នាក់ ដើម្បីយកទ្រព្យផង ។

បពិត្រមហារាជ ដោយផលនៃបិណ្ឌបាត ដែលបានឱ្យដល់ព្រះបច្ចេកពុទ្ធនោះ គាត់បានទៅកើតក្នុងស្ថានសួគ៌អស់វារៈ ៧ ដង, សេសសល់ផលបុណ្យនោះ បានមកកើតជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះ អស់វារៈ ៧ ដងនិងជាតិនេះឯង ។

បពិត្រមហារាជដោយផលបាប ដែលមានសេចក្តីក្តៅក្រហាយស្តាយក្រោយថា បើទុកបិណ្ឌបាតឱ្យពួកទាសាទាសីកម្មករស៊ីវិញប្រសើរជាងនោះ បានជាសេដ្ឋីនោះ មានចិត្តចេះតែនឹកស្តាយ មិនហ៊ានបរិភោគចំណីឆ្ងាញ់ មិនហ៊ានស្លៀកពាក់សំលៀកបំពាក់ល្អ មិនហ៊ានប្រើយានជំនិះល្អ ។

បពិត្រមហារាជ ដោយផលបាបដែលសម្លាប់ក្មួយយកទ្រព្យនោះ គាត់ធ្លាក់ទៅនរកជាច្រើនសែនឆ្នាំ សេសសល់ផលកម្មនោះ បានមកកើតជាសេដ្ឋីគ្មានកូន ហើយត្រូវរាជការប្រមូលយកទ្រព្យសម្បត្តិ ដាក់ឃ្លាំងអស់វារៈ ៧ដងនេះហើយ ។ ឯបុណ្យចាស់របស់សេដ្ឋីនោះ ក៏អស់រលីងទៅត្រឹមពេលនេះឯង បុណ្យថ្មីរបស់គាត់ក៏គ្មានដែរ ។

បពិត្រមហារាជក្នុងថ្ងៃនេះ សេដ្ឋីបានធ្លាក់ទៅក្នុងរោរុវនរកហើយ ។

ព្រះបាទបសេនទិកោសល ត្រាស់បញ្ជាក់ព្រះសម្ពុទ្ធទៀតថា សេដ្ឋីនោះពិតជាធ្លាក់ទៅឆេះក្នុងរោរុវនរកមែនឬ?

បពិត្រមហារាជពិតមែនហើយ ។ ទើបព្រះសម្ពុទ្ធត្រាស់សម្តែងធម្មីកថាដូចខាងក្រោមនេះ :

ធញ្ញំ ធនំ រជតំ ជាតរូបំ បរិគ្គហំ ចាបិ យទត្ថិ កិញ្ចិ

ទាសាកម្មករាបេស្សា យេ ចស្ស អនុជីវិនោ

សព្វន្នាយ្យតន្ត្វាញ សព្វំ និក្ខិបគាមិនំ

យញ្ច ករោតិ កាយេន វាចាយ ឧទចេតសា

តំ ហិ តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ

តញ្ចស្ស អនុគំ ហោតិ ឆាយាវ អនុបាយិនី

តស្មា ករេយ្យ កល្យាណំ និច្ចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ៦

ប្រែថា របស់ណាមួយ គឺស្រូវ ទ្រព្យ ប្រាក់ មាស ដែលខ្លួនហួងហែងក្តី ជនទាំងឡាយគឺខ្ញុំប្រុសស្រីកម្មករ អ្នកបម្រើ និងអ្នកស៊ីឈ្នួលនៃខ្លួនក្តី បុគ្គលមិនអាចនាំយករបស់ទាំងនោះទៅបានទេ ត្រូវតែលះបង់ចោលទាំងអស់ហើយទើបទៅ ។ លុះតែបុគ្គលធ្វើកម្មណាដោយកាយវាចាចិត្ត កម្មនោះឯងជារបស់ខ្លួន បុគ្គលតែងកាន់យកនូវកម្មនោះហើយទៅ កម្មនោះតែងទៅតាម ដូចស្រមោលអន្ទោលតាមប្រាណ ។ ព្រោះហេតុនោះ សាធុជនគួរធ្វើកម្មជាកុសលដែលប្រព្រឹត្តទៅក្នុងបរលោកដ៏ច្រើន. ព្រោះថាបុណ្យទាំងឡាយ តែងបានជាទីពឹងរបស់សត្វទាំងឡាយក្នុងលោក (ពេលស្លាប់) ។

# ២០- រឿងអនុរុទ្ធសាក្យរាជកុមារ

(ចាក ធ. ខុ.)

(កម្មល្អនិងអាក្រក់ បើដល់ពេលហើយ ត្រូវតែឱ្យផលដូចឈើចេញផ្លែ)

ព្រះញាតិវង្សរបស់ព្រះសម្ពុទ្ធបរមគ្រូ ខាងបិតាមាន ៧ អង្គគឺ ព្រះសុទ្ធោទនៈ១, សុក្កោទនៈ១, អមិតោទនៈ១, ធោតោទនៈ១, ឃនិតោទនៈ១, និងព្រះរាជធីតា២ ព្រះអង្គគឺ បមិតា១, អមិតា១, រួមជា ៧ ព្រះអង្គ ។

អនុរុទ្ធសាក្យរាជកុមារ ជាបុត្ររបស់ព្រះអង្គម្ចាស់ អមិតោទនៈ នៅក្នុងក្រុងកបិលពស្តុ ។ លោកមានបងប្អូន ៣ អង្គគឺ ព្រះ អង្គម្ចាស់មហានាម ១, ខ្លួនលោក ១, និងព្រះ អង្គម្ចាស់ក្សត្រីរោហិណី ១ ។

អនុរុទ្ធសាក្យរាជកុមារព្រះអង្គនេះ ជាក្សត្រសុខុមាល ជាតិ មានបុណ្យច្រើនបរិបូណ៌ដោយសេចក្តីសុខ និងមាន ភោគសម្បត្តិគ្រប់ប្រការ មិនដែលស្គាល់ មិនដែលឮពាក្យថា ខ្វះ ថាគ្មានសោះឡើយ ។

សម័យមួយ ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ប្រថាប់នៅ នុបិយនិគមរបស់មល្លក្សត្រ ។ គ្រានោះ សាក្យកុមារទាំង ឡាយ នាំគ្នាចេញបួសជង្ហែរតាមព្រះសម្ពុទ្ធជាច្រើនអង្គ ។

សម័យមួយ ព្រះអង្គម្ចាស់មហានាម បានពិភាក្សាជាមួយអនុរុទ្ធជាព្រះអនុជថាពួកយើងមិនទាន់មានអ្នកណាមួយចេញទៅបួសសោះ គួរតែមានម្នាក់ទៅបួសទើបសមគួរ ។

ព្រះអង្គម្ចាស់អនុរុទ្ធឆ្លើយថា ខ្លួនខ្ញុំធ្លាប់តែស្ថិតនៅក្នុងសេចក្ដីសុខ ទៅបួសមិនកើតទេ សូមព្រះជេដ្ឋាទៅបួសចុះ ។

ព្រះអង្គម្ចាស់មហានាម មានបន្ទូលថា បើអនុជនៅគ្រប់គ្រងផ្ទះ ត្រូវសិក្សាឱ្យចេះដឹងកិច្ចការសព្វគ្រប់ ចាប់តាំងពីរបៀបធ្វើស្រែជាដើម ហើយបានពន្យល់អំពីរបៀបធ្វើស្រែចាប់ពីភ្ជួររាស់រហូតដល់ចប់ ។

ក្នុងវេលាស្ដាប់ចប់ហើយ ព្រះអង្គម្ចាស់អនុរុទ្ធ ជាក្មេងកំឡោះធ្លាប់តែសប្បាយ ធ្លាប់តែឃើញបាយក្នុងចានស្រាប់មិនដឹងជាបាយនោះកើតមកពីណាផង ក៏នឿយណាយធុញទ្រាន់នឹងការនៅគ្រប់គ្រងផ្ទះ ហើយសួរដេញដោលព្រះជេដ្ឋាថា លុះធ្វើស្រែចប់ហើយ គេឈប់ធ្វើទៀត ឬនៅតែធ្វើដដែលៗ យ៉ាងនេះ ?

- ចេះតែធ្វើដដែលៗ ដរាបដល់អស់ជីវិត ។

- បើយ៉ាងនេះសូមព្រះជេដ្ឋានៅគ្រប់គ្រងផ្ទះចុះ ទូល

បង្គំទៅបួសហើយ ។ មានបន្ទូលដូច្នេះរួចហើយ ក៏នាំគ្នាទៅសុំលាព្រះមាតាទៅបួស ។

ព្រះមាតាតបថា អនុរុទ្ធកូន ខ្លួនបានិងបងរបស់បាទាំងពីរ អង្គជាបុត្រសម្លាញ់ស្មើជីវិតរបស់មាតា ទោះបីបាទាំងពីរត្រូវស្លាប់ ក៏មាតាមិនចង់ឱ្យព្រាត់ប្រាស់ដែរ ឥឡូវបានៅរស់ត្រលាំង មាតាមិនឱ្យទៅបួសជាដាច់ខាត ។

ព្រះអង្គម្ចាស់អនុរុទ្ធ ចេះតែទទូចសុំមាតាទៅបួសជាច្រើនដង។ ទើបព្រះមាតាគិតថា ព្រះបាទភទ្ទិយៈ ជាសម្លាញ់របស់អនុរុទ្ធ លោកមិនអាចទៅបួសទេ មានយោបល់ដូច្នេះហើយ ក៏ប្រាប់អនុរុទ្ធថា បើព្រះបាទភទ្ទយៈលោកបួស ចូរបារបួសជាមួយគ្នាចុះ ។

ព្រះអង្គម្ចាស់អនុរុទ្ធ ក៏ចូលទៅគាល់ព្រះបាទភទ្ទិយៈទូលតាមវោហារដែលធ្លាប់ស្និទ្ធិស្នាលគ្នាថា សម្លាញ់អើយបព្វជ្ជា របស់ខ្ញុំជាប់ទាក់ទងនឹងបព្វជ្ជារបស់សម្លាញ់ហើយ ។

ព្រះបាទភទ្ទិយៈត្រាស់តបថា ខ្ញុំមិនឱ្យជាប់ទាក់ទង នាំឱ្យពិបាកដល់សម្លាញ់ឡើយ សូមសម្លាញ់ទៅបួសតាមប្រាថ្នាចុះ ។

- យើងទៅបួសជាមួយគ្នាណាសម្លាញ់ យើងទៅសុំ

ព្រះ សាស្តាបួសទាំងពីរនាក់ក្នុងពេលឥឡូវនេះ ។

- យើងមិនអាចទៅបួសទេ បើការឯទៀត យើងអាចបំពេញបំណងសម្លាញ់បាន ចូរសម្លាញ់ទៅបួសម្នាក់ឯងចុះ។

- ទៅបួសម្នាក់ឯងមិនបានទេសម្លាញ់ ព្រោះព្រះមាតា ត្រាស់ប្រាប់ថា បើព្រះភទ្ទិយៈបួសផង ចូរបាបួសចុះ បើលោកមិនបួសទេ បាមិនត្រូវបួសឡើយ ។ ដូច្នេះសូមសម្លាញ់អាណិតខ្ញុំទៅបួសជាមួយគ្នាកុំខាន ។

ព្រះបាទភទ្ទិយៈ មានព្រះទ័យអាណិតសម្លាញ់ ក៏មានបន្ទូលថា សម្លាញ់យើងយល់ព្រមទៅបួសហើយ ប៉ុន្តែសុំបង្អង់ ៧ ឆ្នាំសិន ។

- យូរណាស់សម្លាញ់ ខ្ញុំមិនអាចចាំយូរដូច្នេះបានទេ។

ព្រះបាទភទ្ទិយៈចេះតែសុំបន្ថយជាលំដាប់ ដរាបនៅត្រឹម ៧ ថ្ងៃទើបព្រះអង្គម្ចាស់អនុរុទ្ធយល់ព្រម ។

កាលបើព្រះបាទភទ្ទិយៈព្រមទៅបួសហើយ ព្រះអង្គម្ចាស់ អនុរុទ្ធក៏ទៅបបួលព្រះអង្គម្ចាស់ ៤ អង្គទៀតគឺ អានន្ទ, ភគុ, កិម្ពិលៈ, គោលីយៈគឺទេវទត្ត និងនាយឧបាលី ជាភ្នាក់ងារភូសាមាលា រួមជា ៧ ។ លុះដល់ថ្ងៃទី ៧ ហើយក៏នាំគ្នាចេញពីក្រុង កបិលពស្តុ ចូលទៅគាល់ព្រះសាស្តាក្នុង

អនុបិយនិគមនាដែន មល្វៈ ។

ពួកព្រះអង្គម្ចាស់សាក្យទាំងនោះ បានក្រាបទូលព្រះសាស្តាថា ខ្ញុំព្រះអង្គជាសាក្យៈមានទិដ្ឋិមានៈប្រកាន់ខ្លួនណាស់ ឧបាលីនេះជាមនុស្សបម្រើខ្ញុំព្រះអង្គមកយូរហើយ សូមព្រះអង្គ បំបួសឧបាលិមុនចុះ. ពួកខ្ញុំព្រះអង្គនឹងបានធ្វើកិច្ចក្រាបសំពះ ក្រោកទទួល និងកិច្ចដទៃទៀតចំពោះឧបាលី ដើម្បីបានលះបង់ អស្មិ មានះ របស់សាក្យៈចេញ ។

ព្រះសម្ពុទ្ធយល់ស្របតាមបំណងហើយ ទើបបំបួសឧបាលីមុនពួកព្រះអង្គម្ចាស់ទាំងនោះ ។

លុះបួសហើយអនុរុទ្ធភិក្ខុសុំរៀនកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្រ បាននិមន្តទៅធ្វើសមណធម៌ក្នុងព្រៃ បាចីនវង្សមិគទាយវន ជាទីស្ងាត់ ហើយពិចារណាធម្មវិន័យ ថា :

១. ធម៌នេះរបស់អ្នកប្រាថ្នាតិច មិនមែនរបស់អ្នកប្រាថ្នាច្រើន,

២. ធម៌នេះរបស់អ្នកសន្តោស មិនមែនរបស់អ្នកឥតសន្តោស,

៣. ធម៌នេះរបស់អ្នកស្ងប់ស្ងាត់ មិនមែនរបស់អ្នកត្រេកអរ និងពួកគណៈ,

៤. ធម៌នេះរបស់អ្នកមានព្យាយាម មិនមែនរបស់អ្នកខ្ជិលច្រអូស.

៥. ធម៌នេះរបស់អ្នកមានសតិខ្ជាប់ខ្ជួន មិនមែនរបស់អ្នកវង្វេងស្មារតី

៦. ធម៌នេះរបស់អ្នកមានចិត្តតាំងមាំ មិនមែនរបស់អ្នកមានចិត្តរាយមាយ.

៧. ធម៌នេះរបស់អ្នកមានបញ្ញា មិនមែនរបស់អ្នកឥតបញ្ញា ។

ព្រះសម្ពុទ្ធ និមន្តទៅក្នុងទីនោះ បានជ្រាបការពិចារ-ណា ត្រិះរិះរបស់អនុរុទ្ធភិក្ខុដូច្នោះហើយ ទ្រង់ត្រាស់អនុមោ-ទនាថា សាធុៗ អនុរុទ្ធ អ្នកបានត្រិះរិះនូវធម៌ ដែលមហាបុរសធ្លាប់ត្រិះរិះ ប្រពៃហើយ. ដូច្នេះចូរអ្នកត្រិះរិះឱ្យដល់ធម៌ទី ៨ តទៅទៀតថា "ធម៌នេះរបស់អ្នកត្រេកអរក្នុងធម៌ដែលមិនធ្វើឱ្យយឺតយូរ មិនមែនជារបស់អ្នកត្រេកអរក្នុងធម៌ដែលធ្វើឱ្យយឺតយូរទេ" ។

ម្នាលអនុរុទ្ធ អ្នកបានត្រិះរិះធម៌ដែលមហាបុរស បានត្រិះរិះទាំង ៨ ខនេះ អ្នកនឹងបានឈានទី ១-២-៣-៤. តអំពីនោះ បង្សុកូលចីវរ នឹងប្រាកដដល់អ្នក ដូចជាហិប

សំពត់ ពេញទៅដោយសំពត់ផ្សេងៗរបស់គហបតី ឬគហប-
តិបុត្ត. ភោជនគឺដុំបាយ ដែលបានដោយកម្លាំងស្មងជើង
នឹងប្រាកដដល់អ្នក ដូចជាបាយស្រូវសាលីបរិសុទ្ធឥតមន្ទិល
មានម្ហូបច្រើនមុខរបស់ គហបតី ឬគហបតិបុត្ត. សេនាសនៈ
គឺដល់ឈើនឹងប្រាកដដល់អ្នក ដូចជាផ្ទះកំពូល ឬកលាប
ដោយកំបោរ ប្រពៃហើយទាំងខាងក្នុងខាងក្រៅ មានបង្អួច
ជិតស្និទ្ធល្អ របស់គហបតី ឬគហបតិបុត្ត ទីដេក ទីអង្គុយ
ដែលក្រាលដោយស្នៅ និងចំបើងនឹងប្រាកដដល់អ្នក ដូចជា
បល្ល័ង្កវិចិត្រក្រាលដោយមាស និងប្រាក់ជាដើមរបស់
គហបតីឬគហបតិបុត្ត. ថ្នាំត្រាំដោយទឹកមូត្រនឹងប្រាកដដល់
អ្នក ដូចជាថ្នាំផ្សេងៗ មានសប្បិ. នវនីត. ប្រេង. ទឹកឃ្មុំ.
និងទឹកអំពៅជាដើម របស់គហបតីឬគហបតិបុត្តដូ ច្នោះ ។

អនុរុទ្ធភិក្ខុ កាលបានស្តាប់ពុទ្ធភាសិតដូច្នេះហើយ ខំ
បំពេញសេចក្តីព្យាយាម ក៏បានសម្រេចអរហត្តផល ជា
អសេខបុគ្គល ។

ថ្ងៃមួយ ភិក្ខុទាំងឡាយចូលទៅរកលោកហើយសួរថា
លោកម្ចាស់ដ៏មានអាយុ បានដល់ភាពជាអ្នកចេះដឹងក្រៃលែង
តើលោកបានចម្រើនធម៌អ្វី ? ខ្ញុំចម្រើនសតិបដ្ឋាន ៤ ។

ព្រះអនុរុទ្ធត្ថេរ លោកចម្រើនសតិបដ្ឋាន ៤ ដោយខ្លួនលោកឯង ដោយសារអ្នកចម្រើនសតិបដ្ឋាន៤ផង ។ សេចក្តីសរសើររបស់លោកនោះ បើបំព្រួញឱ្យខ្លីមានន័យថាអ្នកបួសបើបានចម្រើនសតិបដ្ឋាន ៤ ហើយសូម្បីព្រះរាជា ឬមហាមាត្យ ញាតិមិត្ត មកប្រលោមលួងលោមដោយទ្រព្យ សម្បត្តិបុណ្យស័ក្តិយ៉ាងណា ក៏ភិក្ខុសាមណេរអ្នកបាន ចម្រើនសតិបដ្ឋានហើយ មិនអាចសឹកទៅជាយរាវាសបានឡើយ ។

គុណ វិសេសរបស់ព្រះអនុរុទ្ធត្ថេរគឺទិព្វចក្ខុ. មានសេចក្តី ដំណាលថា ក្រោយពេលឆាន់ចង្ហាន់ហើយ លោកតែងពិចារណាមើលពពួកសត្វដោយទិព្វចក្ខុញាណ បានចំនួន ១០ ពាន់លោកធាតុ ព្រោះលោកមានបច្ចេកទេសស្ទាត់ជំនាញខាងព្រះនេត្រទិព្វ ដោយអានិសង្សទាន ដែលលោកបានធ្វើហើយ ប្រាថ្នាឱ្យមានភ្នែកទិព្វក្នុងសាសនាព្រះពុទ្ធបទុមុត្តរៈ។ (សូមមើលរឿងព្រះអនុរុទ្ធ និងសុមនសាមណេរ ក្នុងភាគទី ៧) ។

អាស្រ័យហេតុនេះ ទើបព្រះបរមគ្រូ ត្រាស់សរសើរប្រទានឯតទគ្គៈថា អនុរុទ្ធជាកំពូលនៃភិក្ខុទាំងឡាយអ្នកមានភ្នែកទិព្វ ។

## ២១- រឿងយក្សឈ្មោះកោធភក្ស

(ចាក ទុព. សំ.)

(ឈ្នះមនុស្សក្រោធ ដោយមិនក្រោធតប)

សម័យមួយ ព្រះសម្ពុទ្ធ គង់ក្នុងក្រុងសាវត្ថី បាន សម្ដែងប្រាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានយក្សមួយឈ្មោះកោធភក្ស មានសេចក្ដីក្រោធជាអាហារ ។ យក្សនោះមានសម្បុរអាក្រក់ មានខ្លួនតឿ ពោះកំពោង បានទៅ អង្គុយលើអាសនៈរបស់សក្កទេវរាជក្នុងឋានតាវត្តឹង្ស ។

ពួកទេវតាបានឃើញកោធភក្សយក្ស ឥតច្បាប់ទម្លាប់ដូច្នោះក៏នាំគ្នាស្ដីបន្ទោសតិះដៀលបន្តុះបង្អាប់ថា ឃីអើ អស្ចារ្យណាស់យក្សនេះសម្បុរអាក្រក់អាក្រី ខ្លួនតឿកន្តុលពោះកំពោង ឥតច្បាប់ហ៊ានមកអង្គុយលើអាសនៈរបស់សក្ក-ទេវរាជមិត្តរបស់យើង ។ យក្សនោះនៅតែអង្គុយស្ងៀម ។ ពួកទេវតាកាន់តែនាំគ្នាតិះដៀល បន្តុះបង្អាប់ច្រើនឡើងៗ ស្រាប់តែយក្សនោះមាន រូបកាន់តែល្អឡើងៗ គួរជាទីពិតពិលរមិលមើលគួរឱ្យជ្រះថ្លាឡើង ។

ពួកទេវតាទាំងឡាយ ឃើញហេតុចម្លែកដូច្នេះ ក៏ចូល

ទៅ កាល់សក្កទេវរាជ ក្រាស់បង្គំទូលថា បពិត្រព្រះអង្គអ្នក និទុក្ខ ឥឡូវនេះមានយក្សមួយសម្បុរអាក្រក់ ខ្លួនតឿពោះកំប៉ោង មកអង្គុយលើអាសនៈរបស់ព្រះអង្គ ។ ពួកខ្ញុំព្រះអង្គនាំគ្នាស្តី បន្ទោសត្អះតិះដៀល បន្តុះបង្អាប់ឱ្យចុះចេញ យក្សនោះមិនព្រមចុះសោះ ។ កាលពួកខ្ញុំព្រះអង្គតិះដៀលកាន់តែច្រើន រូបវាកាន់តែល្អ កាន់តែស្រស់ស្អាត ។ គួរឱ្យចង់មើលគួរជ្រះថ្លាទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន យក្សនេះពិតជាឈ្មោះកោធភក្ស មានសេចក្តីក្រោធជាអាហារហើយ ទើបវាធ្វើផ្តេសផ្តាសឱ្យពួកខ្ញុំព្រះអង្គ ក្រោធខឹងដៀលបន្តុះបង្អាប់ វាបានសេចក្តីក្រោធនោះជាអាហារ ទើបពួកយើងតែល្អ ។

ពេលនោះសក្កទេវរាជ ជាអ្នកមិនមានសេចក្តីក្រោធ បានចូលទៅរកយក្សនោះ, លុះទៅដល់ហើយ ធ្វើសំពត់ធៀងស្មាម្ខាង លុតព្រះជានុ(ជង្គង់) លើប្រថពី ប្រណម្យអញ្ជលីចំពោះយក្សនោះ ហើយបញ្ចេញព្រះនាមឱ្យឮបីដងថា នែអ្នកនិទ៌ុក្ខ ខ្ញុំជាសក្កទេវរាជ ។ យក្សនោះក៏ត្រឡប់ជាមានសម្បុររីតតែអាក្រក់ មានខ្លួនរីតតែតឿ ពោះរីតតែប៉ោងឡើង ហើយចុះពីអាសនៈរត់បាត់ទៅ ដោយអានុភាពនៃសេចក្តីមិនក្រោធរបស់សក្កទេវរាជ ។

កាលបើយក្សឈ្មោះកោធភក្សទៅបាត់ហើយ សក្កទេវរាជ ក៏ឡើងទៅគង់លើអាសនៈរបស់ខ្លួន ពន្យល់ពួកទេវតាក្នុង ឋានតាវត្តឹង្សថា :

ន សូមមាគចិតោម្ហិ
នាចង្គេន សុទានយោ
ន ខោធិរាហំ កុជ្ឈាមិ
កោធោ មយិ នាវតិដ្ឋតិ
កុទ្ធាហំ ន ផរុសំ ព្រូមិ
ន ច ធម្មានិ កិត្តយេ
សន្និគ្គណ្ហាមិ មត្តានំ
សម្បស្សំ អត្ថមត្តនោ ៥

ប្រែថា ខ្ញុំមិនឱ្យទោសបៀតបៀនបានទេ ទាំងមិនឱ្យធម៌ ជាគ្រឿងនាំត្រឡប់ចិត្ត គឺសេចក្តីក្រោធចូលមកបានដោយងាយទេ ខ្ញុំមិនក្រោធមកយូរហើយ សេចក្តីក្រោធមិនដក់នៅក្នុងខ្លួនខ្ញុំទេ បើខ្ញុំខឹងខ្ញុំមិននិយាយពាក្យអាក្រក់ផង មិនសម្តែងធម៌ទាំងឡាយផង ខ្ញុំសម្លឹងឃើញប្រយោជន៍ខ្លួន បានជាខ្ញុំសង្កត់សង្កិនខ្លួនខ្ញុំ ។

## ២២- រឿងចចកពណ៌ខៀវ

(ជាក គ. ប.)

(អ្នកដែលលះបង់បរិវារខ្លួនចោល រើសយកជាតិដទៃធ្វើ បរិវារវិញឈ្មោះថា រើសយកសេចក្ដីស្លាប់មកជាប់ខ្លួន)

កាលពីព្រេងនាយមានចចកឈ្មោលមួយ ដើរទេសស្វះស្វែងរកចំណីអាហារ ទៅដល់ជាយក្រុងមួយ ក៏ភ្លាត់ជើងធ្លាក់ទៅក្នុងរណ្ដៅផ្ទះរបស់អ្នកស្រុក មិនអាចឡើងវិញបានសោះ, ដល់ព្រឹកឡើងក៏ពុតធ្វើជាស្លាប់ស្តូកស្ដឹង ។

ខណៈនោះម្ចាស់រណ្ដៅ បានឃើញចចកមានជើងឡើងលើ ភ្នែកបិទជិត ហាមាត់បញ្ចេញធ្មេញស្ញេញ ក៏យល់ថាចចកនោះស្លាប់ហើយ ទើបស្រង់ចេញពីរណ្ដៅផ្ទះ អូសគ្រវែងចោលឆ្ងាយពីភូមិទៅ ។ ចចកកំហូចនោះរត់ចូលទៅក្នុងព្រៃ ក្រឡេកមើលឃើញខ្លួនមានពណ៌ខៀវស្រងាត់ដូច្នេះ គិតក្នុងចិត្តដោយក្ដីត្រេកអរថា យីអើអាត្មាអញនេះមានពណ៌ខៀវល្អណាស់តើ ! បើដូច្នេះអញនេះប្រសើរខ្ពង់ខ្ពស់ ជាងចចកឯទៀតទាំងអស់ ។

លុះគិតដូច្នេះហើយ ក៏ស្រែកហៅចចកទាំងឡាយក្នុងព្រៃមកជួបជុំ ហើយនិយាយប្រាប់ដោយក្ដីរីករាយថា ទេវតាដ៏

មានបុណ្យអាស្រ័យនូវក្នុងព្រៃនេះ បានតាំងយើងឱ្យធ្វើជាស្តេចម្រឹគ ហើយលោកបានអភិសេកយើងផ្ទាល់ព្រះហស្ដដោយទឹកទិព្វមន្ត យកពីជាតិឈើគ្រប់មុខ អ្នកទាំងអស់ចូរក្រឡេកមើលរូបយើងមើល៍ ! ចាប់ពីថ្ងៃនេះទៅ ពួកអ្នកធ្វើកិច្ចការអ្វីៗ ត្រូវធ្វើតាមបង្គាប់យើងទាំងអស់ ។

ចចកទាំងឡាយ បានឃើញពណ៌ចម្លែកផ្ទាល់ភ្នែកដូច្នោះហើយ ក៏បបួលគ្នាថ្វាយបង្គំនិយាយដោយគោរពថា យើងខ្ញុំទាំងអស់គ្នា សូមទទួលបញ្ជាលោកម្ចាស់គ្រប់ៗគ្នា ។ ឯពួកសត្វទាំងអស់ក្នុងព្រៃនេះ ក៏ខ្លបខ្លាចចចកពណ៌ខៀវគោរពទុកជាស្តេចរបស់ខ្លួនទៅ ។

មុនដំបូងស្តេចចចករើសយកពួកចចក ឱ្យធ្វើរាជបរិ-ពារសេនាខ្លួន, ដល់អំណាចរាជសក្តិកាន់តែខ្ពង់ខ្ពស់ឡើង ក៏លះបង់បរិវារជាតិខ្លួនចោល រើសយកម្រឹគជាតិដទៃ ដូចជាខ្លា សីហៈ ជាដើមមកធ្វើបរិវារសេនាវិញ ។

ពេលនោះមានចចកចាស់មួយ បានឃើញពួកចចកទាំងឡាយកើតទុក្ខ ត្រូវបរិវារសេនាជាតិដទៃជិះជាន់ ក៏និយាយលួងលោមថា នែសម្លាញ់ អ្នកទាំងឡាយកុំព្រួយចចកពណ៌ខៀវនេះជាសត្វល្ងង់មិនស្គាល់សមត្ថភាពពួកយើង

មើលងាយពួកយើងដែលមានជាតិដូចគ្នា ព្រោះតែស្រើងយសសក្តិ. ដូច្នេះយើងត្រូវស្រុះស្រួលគ្នាតាមខ្ញុំ. ឯសត្វសីហៈខ្លា ជាដើមដែលខ្ចបខ្វាចចចកខៀវនោះដោយការភាន់ច្រឡំមើលមិនស្គាល់ជាសត្វចចកឡើយ យើងត្រូវប្រើមធ្យោបាយឱ្យសីហៈ និងខ្លាសម្លាប់វាឱ្យបាន ។

មធ្យោបាយដែលពួកយើងត្រូវធ្វើគឺ ពេលល្ងាចនេះពួកយើងត្រូវប្រមូលចចកទាំងអស់ក្នុងព្រៃនេះ នាំគ្នាស្រែកលូពេញទំហឹង. កាលបើចចកខៀវបានឮសម្លេងលូហើយវាមុខជាភ្ញាក់មាត់លូតាមពួកយើងមិនខាន ។ លុះដល់ពេលណាត់គ្នាហើយ ចចកទាំងឡាយ ក៏នាំគ្នាស្រែកលូឡើង. ចចកខៀវក៏លូតាមមែន ។

ពួកសីហៈ និងខ្លាបានស្គាល់ច្បាស់ ថាស្តេចម្រឹគខៀវនោះមិនមែនជាសត្វវិសេសក្រៅពីចចកហើយ ក៏លោតទៅសង្គ្រុប់ខាំស៊ីអស់ទៅ ។

អាស្រ័យហេតុនេះហើយ ទើបមានភាសិតក្នុងគម្ពីរបញ្ចតន្ត្រៈថា " នរជនណាលះបង់ចោលពួកបរិវារខ្លួនហើយត្រេកអរទៅចូលដៃនឹងបរិវារបរបក្សវិញ នរជននោះជាមនុស្សល្ងង់ ត្រូវបរិវារបរបក្សសម្លាប់ចោលអសារបង់" ដូចចចកពណ៌ខៀវនេះឯង ។

## ២៣- រឿងស្តេចលិច្ឆវី និងប្រេត

(ចាក បេ. ខុ.)

(ផលនៃទក្ខិណាទាន អាចសម្រេចដល់ប្រេតបាន)

ក្នុងក្រុងសាវត្ថី មានស្តេចលិច្ឆវីមួយព្រះអង្គព្រះនាម អម្ពសក្ខរៈ បានទតឃើញប្រេតមួយ មានរូបធំអាក្រាតកាយទទេ ជិះលើខ្នងសេះសស្អាត, មានពន្លឺផ្សាយចេញពីកាយ និងមានខ្លិនល្អបក់ផ្សាយចេញពីរូបកាយផង ។

ប្រេតនោះបានជិះសេះទៅឈប់ជិតបុរសទោសម្នាក់ ដែលស្តេចលិច្ឆវី បានដោតផ្លាងដោយឈើអណ្តោតនៅក្រៅក្រុង ហើយនិយាយជាមួយអ្នកទោសថា "អ្នកចូររស់ចុះ ព្រោះការរស់នៅរបស់អ្នកប្រសើរជាងស្លាប់" ។

ស្តេចលិច្ឆវីទតឃើញប្រេតនោះហើយ មានព្រះហឫទ័យ ចង់ដឹងហេតុ ទើបយាងទៅជិតសួរប្រេតថា :

- អ្នកទោសនេះត្រូវជាអ្វីនឹងអ្នក ?

- បពិត្រព្រះរាជា បុរសនេះកាលពីជាតិមុនជាញាតិរបស់ខ្ញុំ ។

- ចុះហេតុអ្វីអ្នកនិយាយប្រាប់អ្នកទោសថា ចូរអ្នករស់ចុះព្រោះការរស់នៅរបស់អ្នកប្រសើរជាងស្លាប់ ?

- បពិត្រព្រះរាជា អ្នកទោសនេះជាអ្នកធ្វើអាក្រក់កាល បើស្លាប់ហើយនឹងកើតក្នុងនរកមិនខាន ព្រោះសេចក្តីទុក្ខក្នុង នរកខ្លាំងក្លាជាងការឈឺចាប់ដោយឈើអណ្តោតនោះឆ្ងាយណាស់ ។ ម្យ៉ាងទៀត បើបានរស់នៅបានរួចទោសហើយធ្វើបុណ្យទានតាមខ្ញុំ លះបង់អំពើអាក្រក់ចេញនឹងមានប្រយោជន៍ច្រើន ។

- យើងយល់ហើយចង់សួររឿងអ្នកទៀត បើអ្នកមិនបើកឱកាសឱ្យទេ យើងក៏មិនហ៊ានសួរដែរ ។

- បពិត្រព្រះរាជា ខ្ញុំបានប្តេជ្ញាថា មិនប្រាប់រឿងខ្ញុំដល់អ្នកដែលមិនជ្រះថ្លានឹងគ្នា មិនជឿពាក្យសម្តីគ្នាឡើយ. បើព្រះអង្គមានជំនឿហើយ សួរខ្ញុំមកចុះ ។

- យើងចង់សួរអំពីសេះស ជាយានជំនិះល្អស្អាតគួរឱ្យរមិលមើលរបស់អ្នកនេះ តើអ្នកបានមកដោយផលនៃកម្មអ្វី ?

- បពិត្រមហារាជ កាលមុនក្នុងក្រុងវេសាលីនេះមានជង្ហុកមួយ ទឹកភក់ជក់នៅរអិលដើរបានដោយលំបាក. ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បានយកឆ្អឹងក្បាលគោទៅដាក់ធ្វើជាស្ពានសម្រាប់មហាជនដើរឆ្លងជង្ហុកនោះ ។ ឯសេះសជាយានជំនិះ ល្អស្អាតរបស់ខ្ញុំនេះ កើតឡើងដោយផលនៃកម្ម

នេះឯង ។

- អើ ! យើងចង់សួរទៀតថា អ្នកមានសម្បុរភ្លឺផ្សាយទៅសព្វទិស, អ្នកមានក្លិនល្អផ្សាយទៅសព្វទិស អ្នកមានឫទ្ធិមានអានុភាពច្រើន តែជាអ្នកអាក្រាតកាយទទេ តើការចម្លែកទាំងអស់នេះជាផលនៃកម្មអ្វី ?

- បពិត្រព្រះរាជា កាលមុនខ្ញុំជាមនុស្សមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច និយាយប្រាស្រ័យជាមួយជនដទៃដោយពាក្យពិរោះផ្អែមល្ហែម. កម្មនេះឯងបញ្ចេញផលឱ្យខ្ញុំមានសម្បុរល្អជានិច្ចដូចសម្បុរទិព្វ ។ មួយទៀត ខ្ញុំបានឃើញយសសក្តិ និងកេរ្តិ៍ឈ្មោះរបស់ពួកជនតាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សាជាមួយ. កម្មនេះឯងបញ្ចេញផលឱ្យមានក្លិនល្អដូចជាក្លិន ទិព្វផ្សព្វផ្សាយទៅជានិច្ច មួយទៀតខ្ញុំបានយកសំពត់ពួកសម្លាញ់ កំពុងងូតទឹកក្នុងគំពង់លាក់លេងសប្បាយ ធ្វើឱ្យគេអាក្រាតកាយគ្រប់គ្នា ប៉ុន្តែខ្ញុំឥតមានចិត្តប្រទូស្តឡើយ. កម្មនេះឯងបញ្ចេញផលឱ្យខ្ញុំអាក្រាតកាយទទេ និងឱ្យមានការចិញ្ចឹមជីវិតយ៉ាងលំបាកពន់ពេក ។

ស្តេចលិច្ឆវីបានទ្រង់ព្រះសណ្តាប់ បុព្វកម្មរបស់ប្រេតដូច្នេះហើយ ក៏ព្រះអង្គមិនទាន់ជឿបុណ្យបាបច្បាស់លាស់

ដែរ ទើបសួរប្រេតទៀតថា :

- បើបុគ្គលឈប់ធ្វើបាបហើយ និងបុគ្គលមិនឈប់ធ្វើបាបទេ តើអ្នកប្រាជ្ញទាំងឡាយ បានសម្តែងនូវផលនៃកម្មនោះដូចម្តេច ?

- បពិត្រព្រះរាជា បើពួកមនុស្សណាមានចិត្តប្រទូស្តហើយសៅហ្មងដោយកាយនិងវាចា,មនុស្សនោះលុះស្លាប់ទៅពិតជាកើតក្នុងនរក។ ចំណែកពួកមនុស្សដែលត្រេកអរក្នុងទានជាអ្នកសង្គ្រោះគេ លុះស្លាប់ទៅពិតជាកើតក្នុងសុគតិឥតមានឃ្លាតឡើយ ។

- អើ ! យើងបានពិចារណាហើយ នេះជាផលនៃកល្យាណកម្ម និងបាបកម្មទេតើ នរណាអាចធ្វើឱ្យខ្ញុំជឿពាក្យនោះបាន ។

- បពិត្រព្រះរាជា ព្រះអង្គទតឃើញហើយសូមជឿចុះ បើគ្មានផលនៃកល្យាណកម្ម និងបាបកម្មនោះទេ នរកសួគ៌ក៏គ្មាន ។ អាស្រ័យហេតុនេះឯងទើបមនុស្សសត្វ ដែលបានធ្វើកម្មទាំងពីរនោះ មានសុខមានទុក្ខ មានឋានៈខ្ពស់ទាបល្អអាក្រក់ខុសៗគ្នា ។ ចំពោះរូបខ្ញុំបុញ្ញកម្មដែលធ្វើដោយខ្លួនឯងក៏មិនមានៃ, អ្នកឱ្យគ្រឿងស្លៀកពាក់ទីដេក

ទីអង្គុយចាយទឹកហើយឧទ្ទិសផលចំពោះខ្ញុំក៏មិនមានដែរ បាន
ជាខ្ញុំមានកាយអាក្រាត មានការចិញ្ចឹមជីវិតយ៉ាងលំបាកបំផុត ។

- នែប្រេត ! យើងចង់ជួយអ្នកឱ្យមានគ្រឿងស្លៀកពាក់ តើឱ្យយើងជួយបែបណាទើបអ្នកទទួលបាន ?

- បពិត្រព្រះរាជា ក្នុងក្រុងវេសាលីនេះ មានភិក្ខុមួយអង្គឈ្មោះកប្បតកៈ ជាអ្នកមានឈាន មានសីលល្អ ជាព្រះអរហន្ត ជាបុញ្ញក្ខេត្ត ជាទក្ខិណេយ្យបុគ្គលរបស់ទេវតា និងមនុស្សទាំងឡាយ លោកជាបុគ្គលគួរបូជា ។ បើព្រះអង្គប្រគេនសំពត់ ១គូក្តី ២គូក្តី ចំពោះព្រះថេរៈនោះឧទ្ទិសឱ្យខ្ញុំ ខ្ញុំនឹងបានសំពត់ដែលលោកទទួលហើយនោះផង ព្រះអង្គនឹងបានទតឃើញខ្ញុំស្លៀកសំពត់នោះផង ។

- អើ ! ឥឡូវនេះយើងទៅជួបសាមណៈនោះ ដើម្បីបន្ទោបង់នូវសេចក្តីសង្ស័យផង នូវការយល់ខុសផង ដែលជាសត្រូវរបស់យើងក្នុងថ្ងៃនេះបានឬទេ ?

- បពិត្រព្រះរាជា សមណៈនោះគង់នៅឯប្រទេសឈ្មោះគេបិនចូនា មានពួកទេវតាចោមរោមច្រើន លោកមាននាមថាសច្ចៈ ជាអ្នកមិនប្រមាទ កំពុងសម្តែងធម្មកថា ព្រះអង្គកុំអាលយាងទៅ ។

ព្រះរាជាលិច្ឆវីទ្រង់ព្រះសណ្ដាប់ហើយ ក៏យាងចូលទៅព្រះរាជវាំងរបស់ព្រះអង្គវិញ ដើម្បីបំពេញរាជកិច្ចផ្សេងៗ លុះបំពេញរាជកិច្ចហើយ បានជ្រើសរើសសំពត់៨គូឱ្យទាសាកាន់តាមយាងទៅទីដែលសមណៈគង់នៅ. បានទតឃើញលោកគង់នៅក្រោមម្លប់ឈើ ក៏ថ្វាយបង្គំ មានព្រះបន្ទូលរាក់ទាក់ប្រកាសនាមថា ខ្ញុំជាស្ដេចលិច្ឆវីឈ្មោះអម្ពសក្ខរៈ សូមលោកម្ចាស់ទទួលសម្ពត់ទាំង ៨គូរបស់ខ្ញុំព្រះករុណា ខ្ញុំមកទីនេះក៏ព្រោះប្រយោជន៍នេះឯង គួរឱ្យខ្ញុំមានចិត្តត្រេកអរផង ។

ព្រះថេរៈតបថា ពួកសមណៈតែងជៀសវាង នូវព្រះរាជនិវេសន៍របស់ព្រះអង្គ ព្រោះព្រះអង្គបានធ្វើបាបវាយទាត់ធាក់សមណៈ ឱ្យដេកដួលសំយុងក្បាលចុះ បែកបាត្រហែកស្បង់ចីពរ ។ ព្រះអង្គជាអ្នកកំណាញ់ មិនដែលឱ្យប្រេងប៉ុនចុងស្បូវដល់អ្នកណាឡើយ ព្រះអង្គច្រើនតែអាថ្វាអន្ធពាល ។ តើព្រះអង្គឃើញហេតុអ្វី បានជាធ្វើនូវការចែករំលែកជាមួយអាត្មាដូច្នេះ ។

បពិត្រលោកម្ចាស់ ខ្ញុំប្រព្រឹត្តដូច្នោះមែន ព្រោះខ្ញុំជាអ្នកចូលចិត្តលេងច្រើន មិនមែនធ្វើដោយចិត្តប្រទូស្តឡើយ.

ខ្ញុំបានធ្វើអំពើអាក្រក់មែនហើយ ពួកជនទាំងឡាយតែងទទួលទុក្ខ ព្រោះតែសន្សំបាបដោយការលេងនេះឯង, ខ្ញុំបានឃើញប្រេតអាក្រាត ព្រោះតែការលេងនេះដែរ, សូមលោកម្ចាស់ទទួលសំពត់ទាំង ៨គូនេះចុះ ទក្ខិណាទាននេះសូមឱ្យបានសម្រេចផលដល់ប្រេតអាក្រាតនោះផង ។

- សាធុ ! ការមិនចេះអស់ ចូរមានចំពោះព្រះអង្គ, ការឱ្យទាន ព្រះពុទ្ធទាំងឡាយទ្រង់សរសើរដោយប្រការដ៏ច្រើន អាត្មានឹងទទួលសំពត់របស់ព្រះអង្គទាំង ៨គូ សូមទក្ខិណាទានសម្រេចដល់ប្រេតចុះ ។ ក្នុងពេលដែលព្រះថេរៈទទួលសំពត់ហើយ ស្តេចលិច្ឆវី បានទតឃើញប្រេតស្លៀកដណ្តប់សំពត់ផ្ទាល់ព្រះនេត្រ, ទតឃើញខ្លួនប្រេតនោះលាបដោយលំអិតខ្លឹមចន្ទន៍ មានរូបឆោមស្រស់ មានគ្រឿងប្រដាប់តែងកាយគ្រប់សព្វ មានបរិស័ទចោមរោមបានឡើងជិះសិះស ប្រកបដោយអានុភាពធំ លុះទតឃើញដូច្នេះហើយព្រះអង្គមានបីតិសោមនស្ស មានព្រះទ័យត្រេកអរខ្ពស់អណ្តែកឡើង យល់ច្បាស់នូវកម្មផលបុណ្យបាប ទើបយាងទៅរកប្រេតនោះមានព្រះបន្ទូលថា យើងនឹងឱ្យទានអ្វីៗបន្តិចបន្តួចក៏យើងឱ្យទានដែរ អ្នកមានឧបការគុណចំពោះ

យើងច្រើនណាស់ ។

ប្រេតតបថា បពិត្រព្រះរាជា ព្រះអង្គបានឱ្យទានទាំងឡាយចំពោះតែបច្ច័យមួយ ការឱ្យទាននេះមិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសាក្សីជាមួយព្រះអង្គជាមនុស្ស ។

ស្តេចលិច្ឆវីតបថាប្រពៃណាស់ អ្នកជាគតិជាផៅពង្សជាអ្នកនាំមុខ ជាមិត្រសម្លាញ់ និងជាទេវតារបស់យើង យើងសូមលើកអញ្ជលីប្រណម្យចំពោះអ្នក យើងចង់ឃើញអ្នកទៀត ។

ប្រេតទូលថា បើព្រះអង្គមានសទ្ធាគោរពក្នុងធម៌ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ ជាអណ្តូងរបស់សមណៈព្រាហ្មណ៍យ៉ាងនេះ ទើបព្រះអង្គអាចឃើញខ្ញុំបាន ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គដោះលែងអ្នកទោសពីឈើអណ្តោតឱ្យឆាប់ផង ដើម្បីគ្នាបានប្រព្រឹត្តធម៌បានរួចពីនរក. លុះដោះលែងបុរសនោះហើយ សូមព្រះអង្គយាងទៅរកកប្បិតកភិក្ខុចាត់ចែងថ្វាយទាន ទ្រង់ព្រះសណ្តាប់នូវធម្មកថារបស់លោកកុំខាន ។

ស្តេចលិច្ឆវី បានដោះលែងនូវបុរសជាប់ឈើអណ្តោត

និងអ្នកទោសដទៃទៀតដែលគួរដោះលែងបាន ។ ព្រះអង្គប្រាប់បុរសជាប់ឈើអណ្តោតថា នែសម្លាញ់អ្នកកុំភ័យ យើងនឹងប្រគល់ខ្លួនអ្នកឱ្យពេទ្យថែរក្សាបានធាប់សះជា ។ មានបន្ទូលដូច្នេះហើយ ក៏យាងទៅរកកប្បិតកភិក្ខុ បានចាត់ចែងភោជនាហារក្នុងកាលដ៏គួរហើយ ចូលទៅគង់ជិតព្រះថេរៈស្តាប់ធម្មកថា មានព្រះទ័យជ្រះថ្លាថ្វាយខ្លួនចំពោះព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក បានសមាទាននូវសីល៥ និងសមាទាននូវឧបោសថសីលតាមកាល ។

ពួកឧបាសកឧបាសិកាក្នុងក្រុងវេសាលី មានសេចក្តីត្រេកអរដោយបានដឹងថា ស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ ជាឧបាសកប្រាកដដូច្នោះ ជាអ្នកមានសទ្ធា មានចិត្តទន់ភ្លន់ ជាអ្នកទំនុកបម្រុងភិក្ខុសង្ឃដោយគោរព ឈប់បៀតបៀនភិក្ខុសង្ឃទៀតហើយ ។

ចំណែកបុរសដែលជាប់ឈើអណ្តោតនោះ បានសះជាមុខរបួសហើយ ក៏ចូលទៅបួសក្នុងសំណាក់ព្រះថេរៈកប្បិតកៈ ខំចម្រើនសមណធម៌ ក៏បានសម្រេចមគ្គផលជាន់ខ្ពស់ ។

ឯស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ បានសម្រេចសោតា

បត្តិផលក្នុងពេលស្តាប់ធម្មកថារបស់ព្រះថេរៈកប្បិតកៈនោះឯង ។

ចំណែកខាងប្រេតនោះ បានសោយនូវសម្បត្តិទិព្វគ្រប់យ៉ាងដូចជាពួកទេវតាទាំងឡាយក្នុងឋានសួគ៌ដែរ ។

៚ ៚

## ២៨- រឿងអាឡវីរាជកុមារ

(ចាក អា. អ.)

(សេចក្តីស្រឡាញ់ទាំងអស់ក្នុងលោក មិនស្មើសេចក្តីស្រឡាញ់ខ្លួន)

ក្នុងជំនាន់ពុទ្ធកាល មានព្រះរាជាមួយព្រះអង្គនាម អាឡវីរាជ គ្រប់គ្រងរាជសម្បត្តិក្នុងដែនអាឡវី ។

ថ្ងៃមួយ ព្រះរាជាបាននាំពួកពលសេនាចេញពីព្រះរាជវាំងយាងទៅក្នុងជនបទនានា ដើម្បីសួរសុខទុក្ខប្រជារាស្ត្រផង ដេញកំចាត់ពួកចោរ និងបច្ចាមិត្រផង ។ ស្តេចយាងទៅបាន ៧ ថ្ងៃ ទ្រង់ភ្នក់ព្រះទ័យចង់ប្រពាតម្រឹគ បានប្រជុំពួកពលសេនា ហើយដាក់ព្រះរាជអាជ្ញាថា បើបានព័ទ្ធម្រឹគជាប់ហើយ ម្រឹគនោះរត់ចេញរួចត្រង់មុខអ្នកណា អ្នកនោះត្រូវមានទោស, ទ្រង់ដាក់ព្រះរាជអាជ្ញាដូច្នេះហើយ ព្រះអង្គទ្រង់ធ្នូរចូលទៅឡោមព័ទ្ធម្រឹគដែរ ។

គ្រានោះមានម្រឹគទ្រាយមួយត្រូវព្រះអង្គ និងពលសេនាព័ទ្ធជាប់មានសេចក្តីតក់ស្លុតខ្លាំង ខំបោលសម្រុករកច្រកចេញគ្រប់ទិសទី, ពួកសេនាគ្រប់គ្នា ខំការពារគម្រាមម្រឹគនោះ កុំឱ្យចេញរួចចំពោះមុខខ្លួន ស្រាប់តែម្រឹគបោលសំដៅទី ចំព្រះភក្ត្រព្រះរាជាចេញរួចទៅ, ព្រះអង្គក៏ស្ទុះដេញ

តាមម្រឹគនោះ ចូលជ្រៅទៅក្នុងព្រៃវង្វេងបាត់សេនាអស់ ទើបបាញ់ម្រឹគបាន ទ្រង់អារពន្ធះយកសាច់វែកលើព្រះអង្សា ត្រេចទៅ ។

ព្រះបាទអឡូរិរាជ ទ្រង់នឿយព្រះកាយពលពេក បាន ទតឃើញដើមជ្រៃធំមួយដើម មានម្លប់ត្រជាក់ល្អ ស្ដេចចូល ទៅសម្រាកព្រះកាយ ។ ដើមជ្រៃនោះ ដុះនៅក្នុងអាណា ខេត្តរបស់យក្សមួយ ឈ្មោះអាឡវកៈ ដែលស្ដេចចតុលោក បាលប្រទានឱ្យ ។

ក្នុងពេលនោះ អាឡវកយក្សធុំក្លិនមនុស្ស ក្រឡេក ភ្នែកទៅក្រោមដើមជ្រៃ បានឃើញស្ដេចអាឡវិរាជហើយ ក៏ ស្ទុះទៅចាប់ប្រុងនឹងស៊ី ។

ព្រះបាទអាឡវិរាជ ទ្រង់ភិតភ័យញាប់ញ័រ សុំអង្វរ យក្សថា នែមហាយក្ស ចូរអ្នកលែងយើងចុះ យើងនឹងបញ្ជូន មនុស្សម្នាក់ និងបាយមួយភាជន៍មកឱ្យអ្នករាល់ថ្ងៃចាប់តាំង ពីថ្ងៃស្អែកនេះជរាបទៅ ។

យក្សតបថា ក្រែងព្រះអង្គបានរួចពីដៃយើងហើយ រវល់ តែសប្បាយនឹងស្រីស្នំ ភ្លេចពាក្យសម្ដីរបស់ខ្លួនទេដឹង ? ចំណែកខាងយើងត្រូវការតែស៊ីព្រះអង្គក្នុងពេលនេះ ព្រោះ

ព្រះអង្គបានចូលមកក្នុងអាណាខេត្តរបស់យើងហើយ ។ ឯយើងគ្មានអំណាចទៅចាប់មនុស្សក្រៅអាណាខេត្ត ដែលស្ដេចចតុលោកបាលប្រទានឱ្យធ្វើជាចំណីបានឡើយ. យើងឈ្នះចាប់ព្រះអង្គបានហើយ យើងមិនលោតលែងឱ្យរួចទៅវិញទេ ។

ព្រះបាទអាឡវិរាជ ស្ដេចអង្វរទៀតថា នែមហាយក្សបើយើងភ្លេចបញ្ជូនមនុស្ស និងបាយមួយភាជន៍មកឱ្យអ្នកថ្ងៃណា ចូរអ្នកទៅព្រះរាជវាំងយើង ចាប់យើងនិងពលសេនាយើងធ្វើជាចំណីចុះ ។ ពេលនេះបើអ្នកស៊ីយើងហើយមុខជាល្បីខ្ចរខ្ចាយទៅគ្រប់ទិសទីថា ក្នុងទីនោះមានយក្សកំណាចចាំចាប់មនុស្សស៊ី ពួកមនុស្សទាំងឡាយមិនហ៊ានទៅជិតទីនោះឡើយ អ្នកនឹងខាតលាភធំតាំងពីថ្ងៃនេះតទៅ ។

យក្សបានស្ដាប់ពាក្យអង្វរ និងពាក្យបំភ័យដូច្នេះហើយ ក៏លែងព្រះបាទអាឡវិរាជក្នុងពេលនោះ. ព្រះអង្គបានលាយក្សត្រឡប់ទៅព្រះនគរវិញ ។

ឯពួកសេនា ដែលបោះកងទ័ពចាំព្រះរាជាខ្លួនក្នុងទីពាក់កណ្ដាលផ្លូវ ជាយូរថ្ងៃហើយនោះ លុះបានឃើញស្ដេចមកដល់ហើយ ក៏នាំគ្នាក្រោកឡើងគោរពទទួលតាមទម្លាប់

សាកសួរ ហេតុដែលព្រះអង្គដេញតាមម្រឹគទ្រាយ, ព្រះរាជាត្រាស់ប្រាប់ពលសេនា តាមដំណើរការណ៍ចប់ហើយ ស្តេចយាងចូលព្រះរាជវាំងវិញ ជម្រះព្រះកាយ សោយព្រះស្ងោយហើយ ត្រាស់ហៅសេនានាយពន្ធនាគា (មេគុក) មកប្រាប់តាមហេតុដែលកើតមានឡើង ។

នាយពន្ធនាគារក្រាបបង្គំទូលថា ការសន្យានឹងយក្សនោះព្រះអង្គបានកំណត់ប៉ុន្មានថ្ងៃ ប៉ុន្មានខែ ប៉ុន្មានឆ្នាំ ?

ព្រះរាជាតបថា យើងភ័យពេកឥតបានកំណត់ថ្ងៃខែទេ ។

នាយពន្ធនាគារក្រាបបង្គំទូលថា រឿងនេះធ្ងន់ណាស់ប្រជារាស្ត្រក្នុងនគរយើងនឹងរងទុក្ខវេទនា ដោយសារយក្សនោះរកទីបំផុតគ្មានឡើយ ។ ប៉ុន្តែរឿងនេះសូមព្រះអង្គកុំព្រួយព្រះទ័យឡើយ សូមគ្រប់គ្រងរាជ្យជាសុខចុះ ទូលព្រះបង្គំនឹងទទួលភារៈចាត់ការថ្វាយតាមកិច្ចសន្យា ។

ចាប់តាំងពីថ្ងៃនោះមក នាយពន្ធនាគារបានជ្រើសរើសយកអ្នកទោសដែលត្រូវប្រហារជីវិត បញ្ជូនទៅឱ្យយក្សមួយថ្ងៃម្នាក់ និងបាយមួយភាជន៍រាល់ៗថ្ងៃ ។

ឯយក្សក៏និម្មិតអត្តភាពធំសម្បើមមុខគួរឱ្យខ្លាច ស្ទុះ

មកទទួលយកមនុស្ស និងបាយមួយភាជន៍មកស៊ីដូចជាគេទំពាររមើមដំឡូង ។

លុះអស់អ្នកទោសឧក្រិដ្ឋនោះហើយ ក៏បញ្ជូនអ្នកទោសទាំងឡាយ ដែលមានក្នុងគុកទៅឱ្យយក្សត១មកជាច្រើនខែ ។ ពួកអ្នកនគរដឹងថា ព្រះរាជាបញ្ជូនពួកអ្នកទោសដែលជាប់គុក ទៅឱ្យយក្សស៊ីដូច្នោះហើយ ក៏លែងហ៊ានប្រព្រឹត្តអំពើចោរកម្មជាដើមទៀត មិនយូរប៉ុន្មានក្នុងគុកស្ងាត់ឈឹង គ្មានអ្នកទោសម្នាក់ឡើយ ។

នាយពន្ធនាគារ ចូលទៅក្រាបបង្គំទូលព្រះរាជាថា មនុស្សទោសអស់រលីងពីគុកហើយ គ្មានអ្នកទោសថ្មីចូលមកទៀត ព្រោះអ្នកនគរមិនហ៊ានប្រព្រឹត្តអំពើខុសឆ្គងនឹងរាជបញ្ញត្តិមានចោរកម្មជាដើម ។

ព្រះបាទអាឡវីរាជ បានត្រាស់ហៅនាយឃ្លាំងមកបង្គាប់ឱ្យចំណាយព្រះរាជទ្រព្យជាច្រើន ហើយឱ្យប្រកាសទូទៅក្នុងព្រះនគរថា បើអ្នកណាហ៊ានប្រថុយជីវិតចូលខ្លួនទៅឱ្យយក្សស៊ី ព្រះអង្គព្រះរាជទានទ្រព្យជាច្រើនដល់គ្រួសារអ្នកនោះ ។ ពួកអ្នកនគរទាំងឡាយគ្មានអ្នកណាម្នាក់សុខចិត្តយកជីវិតដូរនឹងទ្រព្យសម្បត្តិដ៏ច្រើននោះឡើយ ។

ពួកមហាមាត្យបានក្រាបបង្គំទូលថា គួរបញ្ជូនមនុស្សចាស់ជរាមួយថ្ងៃម្នាក់ទៅឱ្យយក្សស៊ីវិញ ព្រោះពួកមនុស្សនេះមុខតែស្លាប់ដដែល ។

ព្រះរាជាតបថា មិនគួរធ្វើដូច្នេះឡើយ ក្រែងពួកមនុស្សក្នុងដែនទាំងមូលកើតចលាចល ព្រោះមនុស្សចាស់ជរាទាំងអស់នោះសុទ្ធតែមានកូនចៅ មានបងប្អូនមាមីងគ្រប់ៗគ្នា ។

ពួកមហាមាត្យក្រាបបង្គំទូលទៀតថា សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នេះគួរបញ្ជូនទារកតូចៗ ដែលនៅមិនទាន់ចេះអង្គុយទៅឱ្យយក្សស៊ីវិញ ព្រោះទារកតូចៗមិនទាន់ដឹងស្គាល់ជីដូនជីតាមាតាបិតាច្បាស់លាស់នៅឡើយ ។ ព្រះរាជាយល់ស្របហើយ ទើបមហាមាត្យចាប់ទារកតូចៗបញ្ជូនទៅឱ្យយក្សរាល់ថ្ងៃតៗមកទៀត ។

ពេលនោះពួកស្ត្រីជាមាតាទារក ដែលប្រសូត្រហើយថ្មីៗក្តី ដែលកំពុងមានគភ៌ក្តី បានដឹងដូច្នោះហើយ ក៏នាំគ្នាពរកូនជញ្ជូនចៅ រត់ចេញពីដែនអាឡវីពពាក់ពពូន ទៅជ្រកនៅក្នុងដែនដទៃ ។ ពួកអាមាត្យខំស្កាត់ស្ទាក់ផ្លូវរកចាប់បញ្ជូនទៅឱ្យយក្សតែយ៉ាងនេះអស់វារៈ ១២ ឆ្នាំ ។ កាលបើរកចាប់

ទៀតមិនបានសោះហើយ ក៏ចូលទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ឥឡូវនេះអស់ទារកហើយ នៅសល់តែកាឡវីរាជកុមារជាព្រះរាជបុត្រព្រះអង្គម្នាក់គត់ប៉ុណ្ណោះ ។

ព្រះបាទអាឡវីរាជ មានព្រះបន្ទូលដោយក្រៀមក្រំថា ព្រះរាជបុត្រជាទីស្រឡាញ់របស់យើងយ៉ាងណា អ្នកដទៃក៏គង់ស្រឡាញ់កូនជីវិតខ្លួនដូច្នោះដែរ, អ្នកទាំងឡាយចូរចាប់យករាជបុត្រខ្ញុំទៅឱ្យយក្សស៊ីចុះ ។

(ត្រង់ចំណុចនេះឯង បញ្ជាក់ឱ្យឃើញច្បាស់ថា ស្រឡាញ់អ្វីទាំងអស់ក្នុងលោកនេះ មិនស្មើនឹងស្រឡាញ់ខ្លួនឡើយ, ទើបមានពុទ្ធភាសិតថា "**នត្ថិ អត្តសមំ បេមំ** ស្រឡាញ់អ្វីមិនស្មើនឹងស្រឡាញ់ខ្លួន" ដូចព្រះបាទអាឡវី សុខចិត្តឱ្យព្រះរាជបុត្រស្លាប់ដើម្បីព្រះអង្គបានរស់ ) ។

សម័យនោះព្រះរាជទេវីជាព្រះមហេសី កំពុងផ្ងូតទឹកអាឡវីរាជកុមារ ហើយផ្ដេកលើសំពត់ទុកូលពស្ត្របីស្នួយផ្ទាប់ព្រះឱរា, ស្រាប់តែពួកមហាមាត្យទៅទូលសុំរាជកុមារយកទៅឱ្យយក្សស៊ី ។ ព្រះរាជទេវី ពួកមេនំ និងពួកស្នំទាំង ១៦ ពាន់នាក់ ខំយំសោកអង្វរយ៉ាងណាក៏ពួករាជបុរសមិនហ៊ានទទឹងទាស់ចំពោះព្រះរាជបញ្ជាឡើយ បានក្រាបទូល

ព្រះរាជទេវីថា ព្រឹកស្អែកនេះ ដល់វេនព្រះរាជកុមារហើយ ព្រះរាជាបានអនុញ្ញាតរួចហើយ ។

តស្មឹ ទិវសេយេវ ក្នុងថ្ងៃនោះឯងព្រះមានព្រះភាគទ្រង់តើនក្នុងបច្ចូសសម័យភ្លឺស្រាងៗ ចូលមហាករុណាសមាបត្តិនាគន្ធកុដិក្នុងវត្តជេតពន ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ជ្រាបឃើញឧបនិស្ស័យថ្នាក់អនាគាមិផលរបស់អាឡវីរាជកុមារផង ថ្នាក់សោតាបត្តិផលរបស់អាឡវកយក្សផង និងថ្នាក់សោតាបត្តិមគ្គជាដើម របស់មហាជនចំនួន ៨ ម៉ឺន ៤ ពាន់នាក់ផង ទើបស្ដេចទ្រង់បិណ្ឌបាត បំពេញពុទ្ធកិច្ចរួចស្រេចហើយ. វេលាព្រលប់ ទ្រង់ពុទ្ធដំណើរទៅតាមផ្លូវចម្ងាយ ៣០ យោជន៍តែមួយព្រះអង្គឯង សំដៅទៅអាណាខេត្តរបស់ អាឡវកយក្ស ក្នុងថ្ងៃឧបោសថខាងរនោច ។

សេចក្ដីពន្យល់ថា ពួកយក្សឃើញវិមានរបស់ខ្លួនយ៉ាងណា. ព្រះមានព្រះភាគក៏បានទតឃើញវិមានរបស់ពួកយក្សដូច្នោះដែរ. ទើបព្រះអង្គស្ដេចយាងទៅដល់អាណាខេត្តយក្សហើយ ទ្រង់ស្ថិតនៅមាត់ទ្វារវិមានរបស់អាឡវកយក្ស ។

ពេលនោះអាឡវកយក្ស មិននៅទៅធ្វើសន្និបាតឯព្រៃហេមពាន្ត នៅតែគទ្រភយក្សឈរយាមទ្វារ ។ លុះគទ្រភ-

យក្ស ឃើញព្រះសម្ពុទ្ធហើយ ក៏ស្ទុះទៅថ្វាយបង្គំទូលសួរថា ព្រះអង្គ ស្ដេចមកក្នុងវិកាលដូច្នេះ តើមានហេតុអ្វី ?

ព្រះសម្ពុទ្ធតបថា អើគទ្រភៈ តថាគតមកដល់អម្បាញ មិញនេះឯង បើវិមាននេះទូលាយមិនចង្អៀតទេ គួរតថាគត ឈប់សម្រាកមួយរាត្រីផងបានឬទេ ?

គទ្រភយក្សក្រាបទូលថា មិនចង្អៀតទេ អាចទ្រង់ សម្រាកបាន, ប៉ុន្តែអាឡវកយក្សគេមិនទៅ វាកាចណាស់ សូម្បីតែមាតាបិតារបស់ខ្លួន ក៏មិនគោរពដែរ សូមអង្វរព្រះ អង្គ កុំសព្វព្រះទ័យសម្រាកក្នុងទីនេះធ្វើអ្វី ។

- អើគទ្រភៈ តថាគតដឹងហើយ ឥតមានអន្តរាយ ដល់តថាគតឡើយ ។

- ខ្ញុំព្រះអង្គសូមអង្វរជាគម្រប់ ២ដង សូមកុំសម្រាក ក្នុងទីនេះឡើយ ព្រោះយក្សនេះមិនស្គាល់មាតាបិតា សមណ ព្រាហ្មណ៍ មិនដឹងធម៌អាថ៌អ្វីទេ តែខឹងហើយអាចធ្វើចិត្ត អ្នកដទៃឱ្យរាយមាយទៅជាឆ្កួត ឬវះបេះដូងឱ្យខ្ចាត់ខ្ចាយ ចាប់ជើងគ្រវែងទៅត្រើយសមុទ្ទ ឬចក្រវាឡក៏សឹងមាន ។

- អើគទ្រភៈ តថាគតដឹងហើយ ឥតមានអន្តរាយដល់ តថាគតឡើយ ។ គទ្រភយក្សអង្វរព្រះសម្ពុទ្ធជាគម្រប់បីដង,

ព្រះសម្ពុទ្ធមានបន្ទូលដូចមុនជាគម្រប់បីដងដែរ, ទើបគទ្រភយក្សក្រាបទូលថា បើដូច្នេះចាំខ្ញុំព្រះអង្គទៅប្រាប់អាឡវកយក្សសិន ។

- អើគទ្រភៈអ្នកទៅចុះ, គទ្រភៈក៏ហោះសំដៅព្រៃហេមពាន្តក្នុងមួយរំពេចនោះបាត់ទៅ ។

ឯទ្វារវិមានរបស់យក្ស ក៏របើកឡើងថ្វាយព្រះសម្ពុទ្ធក្នុងខណៈនោះដែរ, ទើបស្តេចទៅគង់លើបល្ល័ង្កកែវដ៏ជាទិព្វត្រង់កន្លែងមង្គលរបស់អាឡវកយក្សបញ្ចេញរស្មីពណ៌មាសភ្លឺរន្ទាលច្រាលឆ្ពោះឡើង ។ ពួកស្រីស្នំយក្សបានឃើញហើយកើតសេចក្តីជ្រះថ្លា នាំគ្នាថ្វាយបង្គំអង្គុយគាល់ក្នុងទីសមគួរហើយ ទើបព្រះសម្ពុទ្ធសម្តែងបកិណ្ណកធម្មកថាចំពោះស្រីស្នំទាំងនោះថា "នាងទាំងឡាយបានធ្វើទានសីលបានធ្វើសក្ការរបូជាចំពោះបុគ្គលដែលគួរបូជាទុកពីជាតិមុនមកច្រើន ទើបបានសោយសម្បត្តិទិព្វក្នុងពេលនេះ, នាងទាំងឡាយត្រូវធ្វើបុញ្ញកិរិយាវត្ថុដូចមុនទៀត កុំច្រណែនឈ្នានីសគ្នាឡើយ" ។

ស្រីស្នំយក្សទាំងនោះលុះស្តាប់ចប់ហើយ មានសេចក្តីរីករាយនាំគ្នាបន្លឺសព្ទសាធុកាថ្វាយព្រះសម្ពុទ្ធ ហើយអង្គុយគាល់ព្រះអង្គត្រៀបត្រាក្នុងទីនោះ ។

ឯគទ្រភយក្សទៅដល់ព្រៃហេមពាន្តហើយ បានប្រាប់អាឡវកយក្សតាមដំណើរការណ៍. អាឡវកយក្សគ្រហឹមឆ្លើយថា អើ ! ចាំអញទៅធ្វើទុក្ខសមណៈនោះឱ្យស្គាល់ដៃម្ដង ។

ជួនជាពេលនោះពួកសាតាគិរិយក្ស នាំគ្នាត្រាច់តាមអាកាសដោយយានផ្សេងៗ បំណងទៅថ្វាយបង្គំព្រះសម្ពុទ្ធសិន ទើបទៅកាន់សន្និបាតជាខាងក្រោយ ។ ប៉ុន្តែផ្ទៃអាកាសចង្អៀតដោយយានរបស់ពួកយក្សទាំងឡាយ ដែលទៅកាន់ទីសន្និបាតដែរ. យក្សសាតាគិរីឃើញវិមានរបស់អាឡវកយក្សស្ថិតនៅលើផែនដី ជាវិមានស្កុកស្កម្ភ ខាងលើពាសសំណាញ់ដែក កម្ពស់បីយោជន៍ មានទ្វារបិទជិត ក៏បំបែរយានប្រុងបរកាត់លើវិមាននោះ ស្រាប់តែយានធ្លាក់ក្ដុកមកជីវិញ. ព្រោះជាធម្មតារបស់ព្រះសម្ពុទ្ធគ្រប់ព្រះអង្គ បើគង់ត្រង់ទីណាហើយ ទីនោះមិនអាចមានទេព្តាយក្សមារព្រាហ្មណ៍ណាកន្ទងរំលងពីលើបានឡើយ ។

សាតាគិរិយក្ស បានឃើញព្រះសម្ពុទ្ធគង់ក្នុងប្រាសាទនោះ ក៏ចូលទៅថ្វាយបង្គំស្ដាប់ធម៌ទេសនា សរសើរគុណព្រះរតនត្រ័យហើយទើបថ្វាយបង្គំលាទៅកាន់យក្ខសន្និបាត. ទៅពាក់កណ្ដាលផ្លូវបានជួបអាឡវកយក្ស ក៏ស្រែកប្រាប់ថា

នៃសម្លាញ់អ្នកពេញជាមានលាភធំ ព្រោះព្រះមានបុណ្យគង់នៅក្នុងវិមានរបស់អ្នក. បើអ្នកទៅដល់ត្រូវថ្វាយបង្គំចូលទៅអង្គុយជិតកុំខាន ។ ពួកយក្សឯទៀតក៏នាំគ្នាសរសើរគុណព្រះមានព្រះភាគគ្រប់ៗគ្នា ។

អាឡវកយក្សឮពាក្យសរសើរនោះហើយ រឹតតែក្រេវក្រោធស្រែកថា នរណាជាព្រះមានព្រះភាគ ម្ដេចក៏ហ៊ានចូលមកក្នុងវិមានយើង ។

យក្សទាំងឡាយប្រាប់ថា អ្នកមិនដឹងទេឬ ? ព្រះមានព្រះភាគជាគ្រូយើង ចុះពីស្ថានតុសិតមកសោយព្រះជាតិ ក្នុងមនុស្សលោកជាឱរសក្សត្រ ព្រះអង្គចេញបព្វជ្ជាបានត្រាស់ជាព្រះពុទ្ធ ទ្រង់សម្ដែងធម្មចក្កផ្ញើលអស់ទេវលោក និងព្រហ្មលោក ម៉េចក៏អ្នកធ្វើជាមិនដឹង ?

អាឡវកយក្ស ក៏បានដឹងដូចយក្សឯទៀតដែរ ប៉ុន្តែដោយសេចក្ដីក្រោធធ្វើជាមិនដឹង រឹតតែខឹងក្រេវក្រោធឡើងស្ទុះក្រោកទីក្រទាទៅជាន់លើកំពូលភ្នំកៃលាស ព្រមទាំងស្រែកថា អ្នកទាំងឡាយចូរមើលចុះ គ្រូរបស់អ្នកមានអានុភាពធំ ឬយើងមានអានុភាពធំជាង ។ ដុំដែកដែលបែកចេញពីភ្នំក៏ខ្ទាយព្រោងព្រាត ហើយស្រែកយ៉ាងខ្លាំងគួរឱ្យតក់ស្លុតថា

យើងនេះហើយ ដែលឈ្មោះថា អាឡវកយក្ស ។ សម្រេកលាន់ឮរំពងពេញជម្ពូទ្វីប កក្រើករំពើកភ្នំតូចធំដោយអានុភាពរបស់ខ្លួន ។ ទើបបញ្ចេញឫទ្ធិឱ្យកើតជាភ្លៀងទាំង ៩ យ៉ាងរបស់ខ្លួនឡើងគឺ :

១. បង្កើតព្យុះសង្ឃរា លាយដោយគ្រាប់ភ្លៀងបក់បំប៉ើងព្រះសមុទ្រ. មណ្ឌលខ្យល់កាចសាហាវ បក់បោកព្រៃឈើភ្នំធំតូច បែកបាក់ព្រោងព្រាត។ លុះខ្យល់នោះបក់មកជិតព្រះអង្គក៏ស្ងប់ឈឹង សូម្បីតែចីវររបស់ព្រះអង្គក៏មិនរញ្ជួយឡើយ ។ ឯពួកមនុស្សសត្វទាំងឡាយ ក៏គ្មានអន្តរាយដែរ ដោយអានុភាពដែលព្រះអង្គអធិដ្ឋានកុំឱ្យមានអន្តរាយ ។

២. អាឡវកយក្ស ឃើញខ្យល់ស្ងប់ទៅវិញដូច្នោះ ក៏បណ្ដាលជាភ្លៀងធំមានគ្រាប់ថ្លោសៗ បំណងឱ្យកើតជាទឹកជំនន់ ពន្លិចព្រះសមុទ្ទ ប៉ុន្តែទឹកជំនន់នោះ មកជិតព្រះអង្គ ក៏បាត់អស់ទៅ អន្តរាយទាំងឡាយក៏គ្មានដែរ ។

៣. ភ្លៀងដុំថ្មធំៗប៉ុនកំពូលភ្នំ ក៏ធ្លាក់បាចសាចពីអាកាសមកសំដៅរកព្រះអង្គ. លុះធ្លាក់មកជិតដល់ហើយ ក៏ក្លាយជាកម្រងផ្កាទិព្វបូជាទៅវិញ ។

៤. ភ្លៀងគ្រឿងអាវុធគ្រប់មុខមានដាវលំពែងជាដើម

ក៏ធ្លាក់ចុះមកទៀត, លុះមកជិតក៏ក្លាយជាកម្រងផ្កាទិព្វប្ញជាទៀត ។

៥. ភ្លៀងរងើកភ្លើងក្រហមរន្ទាលពេញមេឃ ក៏ធ្លាក់ចុះមកទៀត, លុះមកជិត ក៏ក្លាយជាគំនរផ្កាទិព្វប្ញជាទៀត ។

៦. ភ្លៀងផេះក្តៅពាសពេញអាកាសធ្លាក់ចុះមកទៀត លុះមកដល់ជិតហើយ ក៏ក្លាយជាលម្អិតខ្លឹមចន្ទន៍ប្ញជាទៀត ។

៧. ភ្លៀងដីខ្សាច់ធ្លាក់ចុះមកយ៉ាងខ្លាំង លុះធ្លាក់មកជិត ក៏ក្លាយជាផ្កាទិព្វប្ញជាទៀត ។

៨. ភ្លៀងភក់ជ្រាំធ្លាក់ចុះមកយ៉ាងខ្លាំង, លុះមកដល់ ក៏ក្លាយជាគ្រឿងក្រអូបទិព្វប្ញជាវិញ ។

៩. បង្កើតជាអ័ព្ទងងឹតប្រកបដោយអង្គ ៤ បិទបាំងពន្លឺគ្រប់ទិសរកមើលអ្វីមិនយល់, ស្រាប់តែរំពេចនោះមានពន្លឺរស្មីដូចព្រះអាទិត្យទៅវិញ ដោយអានុភាពព្រះសម្ពុទ្ធ ។

ងងឹតប្រកបដោយអង្គ ៤ នោះគឺ ងងឹតក្នុងថ្ងៃ១៤ រោជ ដែលប្រកបដោយពេលយប់ពាក់កណ្តាលអាធ្រាត១, ក្នុងព្រៃធំ១, ចុះអ័ព្ទ១, មានភ្លៀងធ្លាក់១, ប្រកបដោយអង្គទាំង៤នេះ ហៅថាងងឹតប្រកបដោយអង្គ៤ ។

កាលបើអាឡវកយក្ស បញ្ចេញប្ញទ្ធិទាំង៩នេះអស់

សមត្ថភាពដេញព្រះសម្ពុទ្ធមិនបានហើយ ក៏នាំចតុរង្គសេនា មានពលសេះ, ពលដំរី, ពលថ្មើរជើង និងពលរថ ព្រមទាំង មានពួកភូតបិសាចមានរូបផ្សេងៗ គួរតក់ស្លុត សម្រុកចូល ទៅរកព្រះមានព្រះភាគ ស្រែកគំរាមជេរប្រមាថដោយ អាការៈកាចសាហាវ អាក្រក់លើសលុបជាងមារាធិរាជជរាប អស់ពាក់កណ្ដាលរាត្រីហើយ មិនព្រមថយសោះ ប៉ុន្តែមិន អាចចូលជិតព្រះអង្គបានឡើយ ។ ទើបចាប់ទុស្សាវុធគឺ ឈ្នួត ក្បាលដែលជាអាវុធសាហាវបំផុត របស់ខ្លួននោះ ចោល សំដៅព្រះសម្ពុទ្ធ ឮសូរលាន់ពេញផ្ទៃអាកាស ដូចជារន្ទះបាញ់ មានពន្លឺភ្លឺច្រាល, លុះចូលទៅជិតហើយ ក៏អស់អានុភាព ធ្លាក់ជិតបាទាព្រះអង្គ ដូចជាសំពត់ជូតព្រះបាទទៅវិញ ។

ទុស្សាវុធឈ្នួតក្បាលយក្សនេះ ធ្លាប់មានអានុភាព ណាស់ បើចោលទៅក្នុងអាកាសរាំងភ្លៀងអស់ ១២ ឆ្នាំ, បើ ចោលទៅលើផែនដី រុក្ខជាតិនានាស្វិតស្រពោន ដុះមិនបាន អស់វារៈ ១២ឆ្នាំ, បើចោលទៅក្នុងសមុទ្ទ រីងទឹកអស់, បើ ចោលទៅត្រង់ភ្នំធំៗ ភ្នំនោះបាក់បែកខ្ទេចខ្ទីរអស់ ។ នេះជា អានុភាព ដែលកើតឡើងដោយអំណាចសិល្បមន្ត របស់ អាឡវកយក្ស ។

ពេលនោះ ពួកទេវតាទាំង ១ម៉ឺនលោកធាតុ មកប្រជុំគ្នាពេញផ្ទៃអាកាស ចង់ឃើញចម្បាំងយ៉ាងសាហាវផង ចង់ស្តាប់ធម៌ព្រះសម្ពុទ្ធផង ប៉ុន្តែមិនហ៊ានចូលមកជិតឡើយ ។

ចំណែកអាឡវកយក្ស ឃើញឈ្នះក្បាលរបស់ខ្លួនអស់អានុភាពដូច្នោះហើយ ក៏នឹកឃើញថាប្រហែលសមណៈនេះ ប្រកបដោយមេត្តាធម៌ទេដឹង ? អញត្រូវផ្ចាញ់លោកដោយមេត្តាវិញ ទើបនិយាយស្រួលជាមួយព្រះសម្ពុទ្ធថា អ្នកចូរចុះពីបល្ល័ង្កយើងចេញ ?

ព្រះសម្ពុទ្ធជ្រាបថា យក្សនេះរឹងរូសណាស់ មិនគួរទូន្មានដោយឧបាយរឹងទេ គួរទូន្មានដោយឧបាយទន់ភ្ទន់វិញ ទើបព្រះអង្គចុះពីបល្ល័ង្កចេញមកក្រៅ ។

លំដាប់នោះ អាឡវកយក្សនឹកក្នុងចិត្តថា សមណៈនេះប្រដៅងាយទេតើ អញបង្គាប់តែមួយម៉ាត់ធ្វើតាមអញភ្លាម មិនគួរអញយកចម្បាំងមកប្រើអស់មួយរាត្រីសោះ ។ ស្រាប់តែនឹកឃើញទៀតថា លោកចេញទៅដោយកំហឹង ឬដោយការប្រដៅងាយ ដូច្នេះអញសាកល្បងទៀត ក៏ហៅឱ្យចូលមកវិញ ។ ព្រះអង្គត្រាស់ថាល្អហើយៗ ក៏យាងចូលមកវិញ ។ យក្សចេះតែប្រើព្រះអង្គយ៉ាងនេះអស់វារៈបីដង ។

អាឡវកយក្សឃើញព្រះសម្ពុទ្ធស្ដាប់តាមខ្លួនដូច្នេះ ចិត្តបាបក៏កើតឡើង នឹកថាអញនឹងប្រើសមណៈនេះឱ្យចេញចូលដរាបដល់ភ្លឺ ហើយចាប់ជើងគ្រវែងចោលទៅត្រើយនាយទន្លេគង្គា ក៏ប្រើព្រះអង្គជាគម្រប់ទី ៤ទៀត ។

ព្រះសម្ពុទ្ធជ្រាបចិត្តយក្សហើយត្រាស់ថា តថាគតមិនចុះចេញទៅ មិនចូលមកវិញទៀតទេ ។

អាឡវកយក្សដឹងថា ព្រះសាស្ដាឈប់ស្ដាប់បង្គាប់ខ្លួនហើយ ក៏គិតថាអញនឹងផ្ចាញ់សមណៈនេះ ឱ្យខ្លាំងជាមុនត្រូវសួរប្រស្នាយ៉ាងកំពាំង ដែលឪពុកអញបានបង្រៀន ។ ស្រាប់តែនឹកឃើញភ្លាមថាសួរមិនបានទេ សមណៈនេះជាអ្នកឆ្លាតខាងធម្មកថា ព្រោះប្រស្នានោះ ឪពុកអញបានទៅសួរព្រះពុទ្ធកស្សបៈ ព្រះអង្គឆ្លើយហើយ ទើបឪពុកអញចងចាំទុកយកមកបង្រៀនអញ ។

សេចក្ដីពិសេសថា អាឡវកយក្សបានរៀនប្រស្នា៨បទពីឪពុកតាំងពីតូចមកទាំងសំណួរនិងចំលើយ. ដល់ពេលក្រោយក៏ភ្លេចចម្លើយអស់ទៅ នៅចាំតែសំនួរទើបចារឹកទុកលើផ្ទាំងមាសក្នុងវិមាន ។

អាឡវកយក្សគិតឃើញដូច្នេះហើយ ក៏នៅស្ងៀម

កំពុងនឹកវេកឧបាយព្យាបាទផ្សេងៗទៀត ។

ពេលនោះព្រះសម្ពុទ្ធត្រាស់ថា នែអាឡវកយក្សអ្នកគិតធ្វើតថាគតឱ្យលំបាកអស់១រាត្រីនេះហើយ ចាប់ជើងតថាគតគ្រវែងចោលទៅត្រើយនាយនៃទន្លេគង្គា និងសួរប្រស្នាផ្ទាញ់ផ្ទាលតថាគត ចូរអ្នកធ្វើអំពើនោះៗចុះ តថាគតឥតប្រកែកឡើយ ។

អាឡវកយក្សក៏យកប្រស្នានោះមកសួរភ្លាមថា :

១. អ្វីជាទ្រព្យប្រសើរបំផុតរបស់បុរសស្ត្រីក្នុងលោក នេះ ?

២. អ្វីដែលគេធ្វើល្អហើយនាំសុខមកឱ្យ ?

៣. អ្វីដែលមានរសឆ្ងាញ់ជាងរសនានា ?

៤. អ្នកប្រាជ្ញហៅអ្នករស់នៅយ៉ាងណាថា រស់នៅប្រសើរបំផុត ?

ព្រះសម្ពុទ្ធ ទ្រង់ឆ្លើយតបតាមលំនាំដែលព្រះពុទ្ធកស្សបៈ បានឆ្លើយហើយថា :

១. សទ្ធាជាទ្រព្យប្រសើរបំផុត របស់បុរសស្ត្រីក្នុងលោកនេះ ។

២. សុចរិតធម៌ដែលគេបានប្រព្រឹត្តល្អហើយ តែងនាំ

សុខមកឱ្យ ។

៣. ពាក្យសច្ចៈមានរសឆ្ងាញ់ជាងរសនានា ។

៤. អ្នកប្រាជ្ញហៅអ្នករស់នៅដោយប្រាជ្ញា ថារស់ប្រសើរបំផុត ។

អាឡវកយក្សបានស្ដាប់ចម្លើយ របស់ព្រះសម្ពុទ្ធទាំង ៤ បទដូច្នេះចប់ហើយ ត្រឡប់ជាមានចិត្តត្រេកអររីករាយ ទើបសួរប្រស្នា ៤ បទថែមទៀតថា :

១. សត្វឆ្លងអន្លង់បានដោយសារអ្វី ?

២. សត្វឆ្លងសមុទ្របានដោយសារអ្វី ?

៣. សត្វឆ្លងសេចក្ដីទុក្ខបានដោយសារអ្វី ?

៤. សត្វបរិសុទ្ធបានដោយសារអ្វី ?

ព្រះសម្ពុទ្ធទ្រង់ឆ្លើយតបតាមលំនាំ ដែលព្រះពុទ្ធកស្សបៈបានឆ្លើយហើយថា :

១. សត្វឆ្លងអន្លង់ គឺឱឃៈទាំង ៤ បានដោយសទ្ធា ។

២. សត្វឆ្លងសមុទ្រគឺ សង្សារវដ្តបានដោយអប្បមាទធម៌ ។

៣. សត្វឆ្លងសេចក្ដីទុក្ខព្រួយបាន ដោយសេចក្ដីព្យាយាម ។

៤. សច្ចបរិសុទ្ធបានដោយបញ្ញា ។

អាឡវកយក្សបានស្តាប់ចម្លើយ របស់ព្រះសម្ពុទ្ធ ដែលមានន័យទាក់ទងចំពោះមហគ្គតធម៌នេះហើយ ក៏បានសំរេចសោតាបត្តិផល, ទើបអាឡវកយក្ស សូត្រគាថាថ្វាយសព្ទសាធុការចំពោះព្រះសាស្តា ។ ពេលនោះព្រះអាទិត្យ ក៏រះឡើងដែរ ។ ឯពួករាជបុរស ក៏បាននាំអាឡវីរាជកុមារមកឱ្យយក្សក្នុងពេលនោះដែរ ។

ឯពួករាជបុរសទៅដល់អាណាខេត្តយក្ស បានឮសំលេងសព្ទសាធុការពរគឹកកងដូច្នោះ បានក្រឡេកមើលទៅទិសដែលផ្សាយសម្លេងចេញមកឃើញវិមាន ឃើញពន្លឺទើបដឹងច្បាស់ថា ព្រះសម្ពុទ្ធគង់ក្នុងទីនោះ ក៏នាំរាជកុមារចូលទៅ ឃើញអាឡវកយក្ស កំពុងផ្គងអញ្ជលីប្រណម្យចំពោះព្រះសម្ពុទ្ធ ក៏និយាយថា នែមហាយក្សចូរទទួលយករាជកុមារធ្វើជាចំណីក្នុងថ្ងៃនេះចុះ យើងយកមកឱ្យអ្នកហើយ ។

អាឡវកយក្ស ដែលបានសម្រេចមគ្គផលហើយនោះមានសេចក្តីអៀនខ្មាសព្រះសាស្តាណាស់ ខំលើកដៃទាំងពីរទទួលរាជកុមារយកមកថ្វាយចំពោះព្រះសម្ពុទ្ធ ហើយក្រាប

បង្គំថា បពិត្រព្រះអង្គដ៏ចម្រើន នេះអាឡវិរាជកុមារ ដែលគេនាំមកឱ្យខ្ញុំព្រះអង្គ១ សូមថ្វាយចំពោះព្រះបរមគ្រូ សូមទ្រង់ទទួលនូវរាជកុមារនេះ ដើម្បីសេចក្ដីសុខចម្រើនដល់រាជកុមារផង ។

ព្រះសម្ពុទ្ធទទួលរាជកុមារហើយ ឱ្យពរចំពោះរាជកុមារផង អាឡវកយក្សផង ទើបប្រទានរាជកុមារឱ្យរាជបុរសយកទៅថែរក្សា ដល់ធំឱ្យយកមកថ្វាយព្រះអង្គវិញ ។ ព្រះរាជកុមារនោះ ក៏មាននាមថា ហត្ថកអាឡវករាជកុមារ ព្រោះយក្សបានទទួលរាជកុមារ អំពីដៃរាជបុរស, ព្រះសម្ពុទ្ធបានទទួលរាជកុមារអំពីដៃយក្ស, ពួករាជបុរសបានទទួលអំពីព្រះហស្តព្រះសម្ពុទ្ធត្រឡប់ទៅនគរវិញ ។

មហាជនទាំងឡាយ កាលបានឃើញរាជបុរសនាំរាជកុមារត្រឡប់មកវិញដូច្នោះ ក៏នាំគ្នាភិតភ័យ នឹកថាយក្សមិនទទួលព្រោះក្មេងពេកស៊ីមិនឆ្អែត ពួកយើងពិតជាមានគ្រោះថ្នាក់ធំហើយ ។

ពួករាជបុរសប្រាប់ថា អ្នកទាំងឡាយកុំភិតភ័យ អាឡវកយក្សនោះ ព្រះបរមគ្រូបានធ្វើឱ្យស្មេមក្សាន្តហើយ ។ ពួកអ្នកក្រុងអាឡវី ក៏នាំគ្នាស្រែកថា សាធុ ! សាធុ! ពួក

យើងបានរួចពីគ្រោះភ័យត្រឹមថ្ងៃនេះហើយ ។

ឯអាឡវកយក្ស កាលបើដល់ពេលព្រះសម្ពុទ្ធទ្រង់បិណ្ឌបាតហើយ ក៏កាន់បាតជូនដំណើរដល់ពាក់កណ្ដាលផ្លូវ ទើបត្រឡប់ទៅវិមានវិញ ។ លុះព្រះមានព្រះភាគបិណ្ឌបាតក្នុងក្រុងអាឡវី ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ យាងគង់លើពុទ្ធាសនៈក្រោមដើមឈើមួយដើម ក្នុងទីស្ងាត់ជិតទ្វារនគរនោះ ។

ពេលនោះព្រះបាទអាឡវីរាជ និងព្រះញាតិវង្ស ព្រមទាំងអ្នកក្រុងជាច្រើនចូលទៅគាល់ព្រះបរមគ្រូ ក្រាបបង្គំទូលសួររឿងហេតុ ដែលព្រះអង្គបានទូន្មានអាឡវកយក្ស ។ ព្រះសម្ពុទ្ធ បានសម្ដែងរឿងរ៉ាវ ព្រមទាំងប្រស្នាទាំង ៨បទ បង្កើតជាព្រះសូត្រមួយឡើងឈ្មោះថា អាឡវកសូត្រ ដែលមានក្នុងព្រះត្រៃបិតកសព្វថ្ងៃនេះ ឱ្យពុទ្ធបរិស័ទស្ដាប់ លុះចប់ព្រះសូត្រនេះហើយ ពួកមហាជនចំនួន ៨៤០០០ នាក់បានសម្រេចមគ្គផលទាំងអស់គ្នា ។

ចំណែកខាងព្រះបាទអាឡវីរាជបានឱ្យរាជបុរសសាងទីកន្លែងឱ្យអាឡវកយក្ស នៅជិតកន្លែងស្ដេចវេស្សវ័ណ្ណហើយ បានធ្វើសក្ការបូជា មានផ្កាកម្រងជាដើមក្នុងពេលនោះ ។

ឯអាឡវិរាជកុមារ កាលបើមានវ័យធំហើយ ក៏ចូលទៅថ្វាយបង្គំស្តាប់ធម្មកថាព្រះបរមគ្រូ បានសម្រេចអនាគាមិផល បានចេះដឹងនូវពុទ្ធវចនៈច្រើន មានឧបាសក ៥០០ នាក់ជាបរិវារ ។ ព្រះសម្ពុទ្ធ ទ្រង់លើកឋានៈព្រះរាជកុមារនោះជាឯតទគ្គៈ ខាងការសង្គ្រោះបរិស័ទដោយសង្គហធម៌ វិសេសជាងសាវ័កដទៃ ។

## ២៥- រឿងព្រះនាងអសន្ធមិត្តា

(ចាក អ. ម.)

(អានិសង្សនៃការធ្វើទានសំពត់)

សម័យក្រោយពុទ្ធកាល រវាងពុទ្ធសតវត្សរ៍ទី ៣ មានព្រះអង្គម្ចាស់ក្សត្រីមួយអង្គ ព្រះនាមអសន្ធមិត្តា ជាព្រះអគ្គ-មហេសីព្រះបាទអសោក, នាងបរិបូណ៌ដោយរូបសម្បត្តិល្អឆើតក្នុងលោក ព្រមទាំងមានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា តែងនិមន្តភិក្ខុសង្ឃប្រាំមួយម៉ឺនអង្គ មកឆាន់ក្នុងរាជវាំងជាមួយព្រះបាទអសោក ។

សម័យមួយ ព្រះនាងប្រថាប់លើកៅអីជាំត្បូង កំពុងសោយអំពៅ ដែលទេព្តានាំពីព្រៃហេមពាន្តមកថ្វាយ, ជូនជាព្រះបាទអសោក ចូលទៅទតឃើញកំពុងសោយអំពៅដូច្នោះ ក៏មានព្រះបន្ទូលចំអន់លេងថា នែប្អូនស្រីនាងសោយអំពៅដែលមានរសផ្អែមដូចទឹកឃ្មុំនេះសប្បាយរីករាយចិត្តណាស់ឬ?

ព្រះនាងអសន្ធមិត្តា បានស្តាប់ព្រះវាចាចំអកនោះហើយ ក៏តូចព្រះទ័យក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពអំពៅនេះកើតក្នុងព្រៃហេមពាន្ត ទេព្តានាំមកថ្វាយនេះព្រោះតែបុណ្យរបស់ខ្ញុំម្ចាស់ មិនមែនព្រោះបុណ្យព្រះអង្គឡើយ ។

ព្រះបាទអសោកត្រាស់ថា នែស្រីល្អ សម្បត្តិទាំងអស់ក្នុងជម្ពូទ្វីបនេះជារបស់យើង នាងកុំវាយឫកស្មើនឹងយើងបន្ថោកបុណ្យរបស់យើង ។ បើនាងថាសម្បត្តិកើតព្រោះបុណ្យនាង ព្រឹកស្អែកនេះយើងនឹងនិមន្តព្រះសង្ឃប្រាំមួយម៉ឺនអង្គមកឆាន់ ចូរនាងរកសំពត់ ចំនួនប្រាំមួយម៉ឺនផាប់ប្រគេនព្រះសង្ឃឱ្យបាន នោះទើបយើងជឿថាបុណ្យរបស់នាងមានមែន. បើរកមិនបានទេ ត្រូវយើងធ្វើទោសក្នុងព្រឹកនេះឯង ។

ព្រះនាងទេវីឮព្រះឱង្ការដាក់អាជ្ញាដូច្នេះ ក៏ស្លុតព្រះទ័យនឹកថា ព្រះរាជាខ្ញាល់ហើយ តើអញទៅរកសំពត់ឯណាដល់ទៅ ៦ ម៉ឺនផាប់បាន ។ លុះព្រះរាជាយាងត្រឡប់ទៅវិញនាងចូលទៅក្នុងក្រឡាបន្ទំផ្ទំកើតទុក្ខបម្រះនឿលទៅមក១ផ្ទំមិនលក់សោះ ។

គ្រានោះស្តេចវេស្សវ័ណ្ណបានជ្រាប ដោយអំណាចបុណ្យ ដែលនាងបានប្រគេនសំពត់ព្រះបច្ចេកពុទ្ធ ក្នុងអតីតជាតិ ក៏យាងមកកាន់សំណាក់នាង ត្រាស់ថា ព្រះនាងកុំសោយសោក សំពត់សាដករបស់នាងកាលថ្វាយព្រះបច្ចេកពុទ្ធក្នុងជាតិមុននោះ មកជួយនាងហើយ (គឺក្នុងជាតិដែល

នាងកើតជាកុម្ភទាសី បានចង្អុរបង្ហាញផ្ទះឈ្មួញលក់ទឹកឃ្មុំ ដល់ព្រះបច្ចេកពុទ្ធ ហើយបានប្រគេនសំពត់សាដកចំពោះព្រះបច្ចេកពុទ្ធនោះឯង) ។ ព្រះបាទវេស្សវ័ណ្ណក៏និម្មិតប្រអប់មួយ មានជាយសំពត់ចេញក្រៅ ថ្វាយទៅព្រះនាងប្រាប់ថា បើនាងចង់បានសំពត់ប្រវែងប៉ុន្មាន ចាប់ទាញយកពីប្រអប់នេះចុះ សំពត់ទិព្វយ៉ាងល្អបំផុតនឹងចេះតែមកថ្វាយព្រះនាងបានដូចបំណង ។

ឯព្រះនាងបានទទួលប្រអប់ទិព្វពីព្រះបាទវេស្សវ័ណ្ណ ហើយក៏ផ្ទំលក់ទៅ ។ លុះព្រឹកឡើង ព្រះបាទអសោកប្រគេនចង្ហាន់ភិក្ខុសង្ឃដោយភោជនដ៏ឧត្តម បូជាដោយគន្ធបុប្ផាស្រេចហើយ ក៏ឡើងព្រះនេត្រទតព្រះនាងត្រាស់ថា ចូរនាងយកសំពត់ប្រាំមួយម៉ឺនផាប់ ដោយបុណ្យរបស់ខ្លួនមកប្រគេនព្រះសង្ឃឱ្យគ្រប់ប្រាំមួយម៉ឺនអង្គក្នុងពេលនេះ ។ នាងក៏យកប្រអប់ទិព្វមកទាញហូតយកសំពត់ ដែលល្អបំផុតថ្វាយព្រះរាជា. សំពត់ក៏ហូរចេញមកទាំងគំនរ គ្រប់ចំនួនប្រាំមួយម៉ឺនផាប់ហើយ ទើបឈប់ហូរចេញ ។ ព្រះមហាក្សត្រ បានចាត់ចែងថ្វាយភិក្ខុសង្ឃគ្រប់អង្គ ដែលគង់ក្នុងទីនោះ ។ ព្រះសង្ឃទាំងអស់អនុមោទនាថ្វាយព្រះមហាក្សត្រ និងព្រះរាជទេវី

ហើយទៅកាន់អាវាសវិញ ។

ព្រះបាទអសោក ទ្រង់សព្វព្រះទ័យរីករាយ សើ្មច សរសើរបុណ្យរបស់នាងអសន្ធមិត្តា ស្តេចទ្រង់ឈរក្នុង កណ្តាលពួកស្រីស្នំទាំងមួយម៉ឺនប្រាំមួយពាន់នាក់ ប្រកាសថា នែនាងសន្ធមិត្តាខ្ទនបងនេះ មានចិត្តជ្រះថ្លាចំពោះបុណ្យ របស់នាងណាស់ បងដឹងច្បាស់ហើយថា នាងជាស្ត្រីមាន បុណ្យបានកសាងទុកក្នុងជាតិមុន ទើបជាតិនេះយើងបានមក ជួបគ្នា ។ ការដែលបងសាកល្បងបុណ្យនាងនេះ សូមកុំតូច ចិត្តឡើយ សូមអត់ទោសផង ពីថ្ងៃនេះទៅបងប្រគល់ឥស្សរិ-យសម្បត្តិឱ្យនាងហើយ ចូរនាងបានជាធំចម្បងជាងស្រីស្នំ ទាំងមួយម៉ឺនប្រាំមួយពាន់នេះចុះ ។

ពួកស្រីស្នំទាំងឡាយដែលជិតស្និទ្ធស្នេហា នឹងព្រះ បាទអសោកជាងគេ ក៏មានចិត្តប្រណែននិន្ទាចំពោះព្រះអង្គៗ បានជ្រាបដូច្នោះ ត្រាស់បង្គាប់ឱ្យនាយពិសេស ធ្វើនំចំនួន មួយម៉ឺនប្រាំមួយពាន់មកថ្វាយ. ព្រះអង្គបានបង្កប់ចិញ្ចៀន ព្រះទម្រង់ដ៏មានតម្លៃ ក្នុងនំមួយមិនឱ្យស្ត្រីណាឃើញឡើយ ដើម្បីពិសោធន៍ស្រីស្នំទាំងអស់ឱ្យបានសុខចិត្ត កុំឱ្យប្រណែន គ្នា ហើយទ្រង់បញ្ជាឱ្យស្រីស្នំដទៃៗ យកនំម្នាក់មួយៗ មុន

នាងអសន្ធមិត្តា ។ លុះយកនំគ្រប់គ្នាហើយ ទើបព្រះរាជាឱ្យបកនំនោះមើល ។ ពួកស្រីស្នំទាំងអស់បកទៅគ្មានឃើញអ្វីសោះ ។ ឯនាងអសន្ធមិត្តា ដែលយកនំក្រោយគេ មកបកទៅបានចិញ្ចៀនមួយវង់ ។

ព្រះរាជា បានធ្វើការពិសោធន៍ ដោយយុត្តិធម៌នេះហើយ ទ្រង់ប្រកាសថា ម្នាលនាងទាំងឡាយ អ្នករាល់គ្នាបានរើសយកនំមុននាងអសន្ធមិត្តា. ហេតុដូចម្ដេចក៏នាងទាំងឡាយមិនបានព្រះទម្រង់ ? នេះហើយជាបុណ្យព្រេងរបស់នាងអសន្ធមិត្តា ដូច្នេះចូរនាងទាំងឡាយកុំមានសេចក្ដីប្រណែនតទៅទៀត ។

ចាប់ពីថ្ងៃនោះមក ពួកស្រីស្នំទាំងឡាយ ក៏សុខចិត្តស្ងប់ស្ងៀមឥតប្រណែននិន្ទាឡើយ ។ ឯនាងអសន្ធមិត្តាបានកាន់ប្រអប់ទិព្វ ដោយព្រះហស្តឆ្វេង ចាប់ទាញសំពត់ ដោយព្រះហស្តស្តាំ បានចំនួនមួយពាន់ជាប់ថ្វាយព្រះរាជា និងយកសំពត់ជាច្រើនទៀត ថ្វាយព្រះរាជវង្សានុវង្ស ពួកស្រីស្នំ ពួកសេវកាមាត្យ និងពួកចតុរង្គសេនា ឱ្យបានសំពត់ទិព្វប្រើគ្រប់គ្នាទាំងអស់ ។

ព្រះបាទអសោក បានជ្រាបហេតុចម្លែកនេះ ត្រាស់

សួរថា នែនាងអសទ្ធមិត្តា អូនបានប្រអប់ទិព្វពីណា ក៏ទាញយកសំពត់មិនចេះអស់ សោះដូច្នេះ ?

ព្រះនាងក្រាបបង្គំទូលថា បពិត្រមហារាជ កុសលដែលខ្ញុំបានសន្សំទុកហើយក្នុងជាតិមុន ទើបមកជាតិនេះ ព្រះបាទវេស្សវ័ណ្ណ ជាអ្នករក្សា លោកទ្រង់ជ្រាបថា ខ្ញុំម្ចាស់មានទុក្ខព្រួយកាលព្រះអង្គដាក់អាជ្ញា ឱ្យរកសំពត់ប្រាំមួយម៉ឺនផាប់នោះ លោកយកប្រអប់ទិព្វមកឱ្យ. បានប្រាប់ខ្ញុំម្ចាស់ថា កាលពីជាតិមុនខ្ញុំម្ចាស់បានប្រគេនសំពត់សាដក ព្រះបច្ចេកពុទ្ធមួយអង្គ ឱ្យខ្ញុំម្ចាស់រលឹកដល់បុញ្ញកម្មនោះ ហើយហូតទាញយកសំពត់ពីប្រអប់នេះចុះមិនចេះអស់ឡើយ ។ ផលបុណ្យនោះតែងហូរមកឱ្យខ្ញុំម្ចាស់មិនចេះអស់ដូច្នេះឯង ។

## ២៦- រឿងតួឯករបាំឈ្មោះតាលបុត្ត

(ចាក គា. សំ.)

(ទោសរបស់សិល្បករអ្នកលេងមហោស្រពរបាំរាំច្រៀង)

កាលព្រះអរហន្តសម្ពុទ្ធ គង់ក្នុងវត្តវេឡុវនជិតក្រុងរាជគ្រឹះ ។ គ្រានោះ មានតួឯករបាំម្នាក់ឈ្មោះតាលបុត្ត បានចូលទៅគាល់ព្រះសម្ពុទ្ធ. លុះចូលទៅដល់ហើយក៏ថ្វាយបង្គំអង្គុយក្នុងទីគួរមួយ. ទើបក្រាបបង្គំទូលព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យគ្រូរបាំជាព្រឹទ្ធាចារ្យនិយាយថា អ្នករបាំណាដែលចេះធ្វើឱ្យអ្នកទស្សនា អ្នកស្តាប់មានចិត្តរីករាយស្រស់ស្រាយ ត្រេកអររំភើបរំជើបរំជួលដោយពាក្យពិត ឬពាក្យកំប្លែងឡេះឡោះក្នុងកណ្តាលទីប្រជុំមហោស្រព. អ្នករបាំនោះឯង ដល់ពេលស្លាប់ហើយ បានទៅកើតជាមួយពួកមហាសទេវតា (ទេវតាអ្នករបាំ ដែលធ្វើឱ្យទេវតាដទៃសើចសប្បាយ) ។ តើពាក្យតើពាក្យនេះពិតឬទេ? ។

ព្រះសម្ពុទ្ធត្រាសតបថា ម្នាលតាលបុត្តរឿងនេះលើកទុកចុះអ្នកកុំសួរបែបនេះឡើយ ។

តាលបុត្តចេះតែទទូចក្រាបបង្គំទូលសួរ ព្រះសម្ពុទ្ធ

ចេះតែឃាត់អស់វារៈបីដង ព្រោះមិនចង់ឱ្យតាលបុត្តនោះមានសេចក្តីភិតភ័យអាក់អន់ចិត្ត ។

កាលបើតាលបុត្តចេះតែទទូចសួរគ្រប់បីដងហើយ ព្រះសម្ពុទ្ធត្រាស់ថា តថាគតបានឃាត់អ្នកហើយ ប៉ុន្តែអ្នកចេះតែសួរ ចង់ឱ្យតថាគតសម្តែងឱ្យស្តាប់, ដូច្នេះអ្នកប្រុងស្តាប់ចុះ ។

ម្នាលតាលបុត្ត ពួកមនុស្សដែលមិនទាន់ប្រាសចាកតម្រេក ជាអ្នកជាប់ជំពាក់ក្នុងតម្រេក, ពួកអ្នករបាំតែងខំបញ្ចេញសិល្បៈរបស់ខ្លួនដែលអាចញ៉ាំងអ្នកទស្សនា អ្នកស្តាប់ឱ្យកើតតម្រេក ឱ្យរីកតែរីករាយក្នុងតម្រេកកណ្តាលរឿណរង្គកណ្តាលមហោស្រព ។

ម្នាលតាលបុត្ត ពួកមនុស្សដែលមិនទាន់ប្រាសចាកទោសៈ ជាអ្នកជាប់ជំពាក់ដោយទោសៈ, ពួកអ្នករបាំតែងខំបញ្ចេញសិល្បៈរបស់ខ្លួន ដែលអាចញ៉ាំងអ្នកទស្សនា អ្នកស្តាប់ ឱ្យកើតទោសៈ ឱ្យរីតតែប្រកបដោយទោសៈ ក្នុងកណ្តាលរឿណរង្គ កណ្តាលមហោស្រព ។

ម្នាលតាលបុត្ត ពួកមនុស្សដែលមិនទាន់ប្រាសចាកមោហៈ ជាអ្នកជាប់ជំពាក់ដោយមោហៈ, ពួកអ្នករបាំតែងខំ

បញ្ចេញសិល្បៈរបស់ខ្លួន ដែលអាចញាំងអ្នកទស្សនា អ្នកស្តាប់ឱ្យកើតមោហៈ ឱ្យរីតតែប្រកបដោយមោហៈ ក្នុងកណ្តាលរឿណារង្គកណ្តាលមហោស្រព ។

អ្នកលេងរបាំបែបនេះ ជាអ្នកស្រវឹងដោយលោកធម៌ ជាអ្នកប្រមាទដោយខ្លួនឯង ស្ថិតនៅក្នុងសេចក្តីប្រមាទ លុះស្លាប់ទៅ តែងទៅកើតក្នុងនរក ។ បើត្រឡប់ជាយល់ថាទៅកើតស្ថានសួគ៌វិញ, សេចក្តីយល់នោះឈ្មោះថាមិច្ឆាទិដ្ឋិ. បុគ្គលជាមិច្ឆាទិដ្ឋិ តែងទៅកើតក្នុងកំណើត២គឺ នរក និងតិរច្ឆាន ក្នុងកំណើតណាមួយមិនខាន ។

តាលព្រះសម្ពុទ្ធសម្តែងដូច្នេះហើយ តាលបុត្តក៏យំសម្រក់ទឹកភ្នែក ។ ព្រះអង្គត្រាស់ថា ម្នាលតាលបុត្ត តថាគតមិនបានថាឱ្យអ្នកឯងយ៉ាងនោះទេ ណ្ហើយតាលបុត្តរឿងនោះលើកទុកចុះ កុំសួរតទៅទៀត ។

តាលបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំមិនយំ ព្រោះរឿងដែលព្រះអង្គសម្តែងនោះឡើយ. ខ្ញុំព្រះអង្គយំព្រោះចាញ់បោកគ្រូរបាំចាស់ៗ ដែលកុហកខ្ញុំព្រះអង្គថា អ្នកលេងរបាំងបានទៅកើតស្ថានសួគ៌ ជាមួយពួកមហាសទេវតានោះឯង ។ ចំពោះពុទ្ធភាសិតដែលព្រះអង្គ

សម្តែងនោះទូលបង្គំយល់ច្បាស់ហើយ ដូចគេផ្ងាររបស់ដែលផ្កាប់ ដូចបើកបង្ហាញរបស់ដែលបាំង ដូចប្រាប់ផ្លូវចំពោះអ្នកវង្វេងផ្លូវ ឬដូចគេអុជប្រទីបក្នុងទីងងឹត ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះត្រៃសរណគមន៍ ជាទីពឹងទីរឭក និងសូមបព្វជ្ជាឧបសម្បទា ក្នុងសំណាក់ព្រះអង្គ ។

ព្រះសម្ពុទ្ធទ្រង់ប្រទាន បព្វជ្ជាឧបសម្បទា ចំពោះតាលបុត្ត ។ លុះតាលបុត្តបានបួសក្នុងពុទ្ធសាសនាហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចមគ្គផល ជាព្រះអរហន្តមួយអង្គក្នុងលោក ។

៚

## ២៧- រឿងរាធព្រាហ្មណ៍

(ចាក ធ. ខុ.)

(ដើមកំណើតនៃការបំបួសកុលបុត្រ ដោយញត្តិចតុត្ថកម្មវាចា)

នៅក្នុងក្រុងរាជគ្រឹះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ រាធព្រាហ្មណ៍ កំសត់ចាស់ជរា ត្រូវប្រពន្ធកូនលះបង់ចោល ដូចគោចាស់ឈប់ចិញ្ចឹមរក្សា ទើបគាត់ចូលទៅសុំអាស្រ័យ នៅជាមួយភិក្ខុសង្ឃក្នុងវត្តវេឡុវ័ន ។

រាធព្រាហ្មណ៍ មានបំណងចង់បួសក្នុងពុទ្ធសាសនា. ភិក្ខុទាំងឡាយ មិនហ៊ានបំបួសដោយយល់ថា គាត់ជាមនុស្ស ចាស់ជរា មិនអាចប្រព្រឹត្តកិច្ចវត្តក្នុងពុទ្ធសាសនាបានបរិបូណ៌។ ការមិនបានបួសដូចបំណងនេះ គាត់កើតទុក្ខខ្វល់ខ្វាយក្នុង ចិត្ត មានរូបកាយរីតតែស្គាំងស្គម ។

សម័យមួយ គាត់ប្រថុយចូលទៅក្រាបបង្គំទូលព្រះ បរមគ្រូតាមបំណងរបស់គាត់ ថ្វាយឱ្យទ្រង់ជ្រាប ។ ព្រះសាស្តា បានឃើញឧបនិស្ស័យរបស់គាត់ហើយ ទ្រង់ អនុញ្ញាតឱ្យសារីបុត្របំបួស ដោយញត្តិចតុត្ថកម្មវាចា ។

ពេលនោះ ព្រះសម្ពុទ្ធប្រជុំភិក្ខុសង្ឃប្រកាសថា វិធី បំបួសកុលបុត្រ ដោយត្រៃសរណគមន្ទបសម្បទា ដែល

តថាគតអនុញ្ញាត មុននោះ ត្រូវបញ្ឈប់ត្រឹមពេលនេះ តទៅ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយបំបួសកុលបុត្រដោយញត្តិ-ចតុត្ថកម្មវាចា ។

រាធភិក្ខុបានទទួលឧបសម្បទា ដោយញត្តិចតុត្ថកម្ម-វាចានេះមុនគេបំផុតក្នុងពុទ្ធសាសនា ។ ពិធីបំបួសនេះឯង ដែលភិក្ខុសង្ឃគ្រប់វត្តអារាមក្នុងប្រទេសយើង បំបួសកុល-បុត្រសព្វថ្ងៃនេះ ។

ថ្ងៃងពីរាធភិក្ខុដែលបានបួសហើយថ្មីនោះ បានចូលទៅគាល់ព្រះបរមគ្រូក្រាបទូលថា សូមព្រះសុគតសម្តែងធម៌ដោយសង្ខេបចពោះខ្ញុំព្រះអង្គ១ នឹងបានចាកចេញពីគណៈទៅនៅតែម្នាក់ឯងដើម្បីភាវនា ។

ព្រះសម្ពុទ្ធត្រាសទូន្មានថា ម្នាលរាធៈរបស់ឯណាជាមារ ចូរអ្នកលះសេចក្តីត្រេកអរចំពោះរបស់នោះចេញ ។ ចុះអ្វីជាមារ ? គឺរូបវេទនា សញ្ញា សង្ខារនិងវិញ្ញាណ ដែលមិនទៀង ជាទុក្ខ ជាអនត្តា មានការអស់ទៅ សាបសូន្យទៅ កើតហើយតែងរលត់ទៅ. នេះឯងឈ្មោះថាមារ ។

កាលព្រះរាធៈទទួលព្រះឱវាទនេះហើយ ក៏បាននិមន្តចេញពីអារាម ទៅតាមព្រះសារីបុត្រជាឧបជ្ឈាយ៍ ។ លោក

ខំបម្រើនសមណធម៌ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ផល ទើបព្រះសារីបុត្រនាំលោកចូលទៅគាល់ព្រះបរមគ្រូៗ ក្រាស់សួរព្រះសារីបុត្តថា ម្នាលសារីបុត្ត សិស្សរបស់អ្នកមាន ចរិយាដូចម្ដេច ?

ព្រះសារីបុត្តក្រាបទូលថា រាធភិក្ខុនេះជាមនុស្ស ប្រដៅងាយណាស់ បើខ្ញុំព្រះអង្គទូន្មានថា ការនេះគួរធ្វើ ការ នោះមិនគួរធ្វើ. ចូរអ្នកធ្វើតែការនេះ កុំធ្វើការនោះ រាធៈមិន ដែលអាក់អន់ចិត្តខឹងឡើយ ។

ព្រះសម្ពុទ្ធទ្រង់ទូន្មាន ភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរធ្វើខ្លួនឱ្យជាអ្នកប្រដៅ ងាយដូចរាធភិក្ខុនេះចុះ ។

កាលបើឧបជ្ឈាយាចារ្យ ប្រដៅទូន្មានកុំខឹង គួរ សម្គាល់អ្នកដែលទូន្មានស្ដីប្រដៅបង្ហាញទោសនោះ ដូចជា អ្នកចង្អុរបង្ហាញកំណប់ទ្រព្យ មានគុណគាប់ប្រសើរមិនមាន ទោសលាមកសោះឡើយ ។

ព្រះរាធត្ថេរនេះ លោកបានទទួលសេចក្ដីសរសើរអំពី ព្រះបរមគ្រូថា ប្រសើរលើសលែងភិក្ខុទាំងឡាយខាងបដិភា- ណៈ គឺប្រាជ្ញាភ្លឺច្បាស់ក្នុងធម្មទេសនា អាចសម្ដែងធម៌ ដែល ព្រះសម្ពុទ្ធសម្ដែងហើយ ដោយសង្ខេបឱ្យមានសេចក្ដីពិស្ដារបាន ។

# ២៨- រឿងចុល្លបន្ថកភិក្ខុ

(ចាក ចុ. ខុ.)

(គុណនៃការគោរពបម្រើគ្រូអាចារ្យ)

ក្នុងសម័យពុទ្ធកាល មានធីតាមួយរូបជាកូនរបស់ធនសេដ្ឋី នៅក្រុងរាជគ្រឹះ នាងបានប្រព្រឹត្តកន្លងប្រពៃណីជាមួយយុវបុរសជាអ្នកបម្រើរបស់ខ្លួនហើយ នាំគ្នារត់ទៅនៅក្នុងទីឆ្ងាយ. លុះមានផ្ទៃពោះជិតគ្រប់ខែ បានអង្វរស្វាមីឱ្យជូនទៅផ្ទះវិញ. ស្វាមីមិនហ៊ានជូនទៅ ក៏ប្រាប់អ្នកជិតខាងហើយ លួចរត់ទៅមិនឱ្យស្វាមីដឹង. ដល់ពាក់កណ្ដាលផ្លូវក៏ប្រសូត្របុត្រ. ស្វាមីទៅតាមទាន់នាំយកមកផ្ទះវិញ ឱ្យឈ្មោះកូននោះថាបន្ថកៈ ព្រោះបានកើតក្នុងទីពាក់កណ្ដាលផ្លូវ ។

តមកនាងមានគភ៌ទៀត បានរត់ទៅសម្រាលបុត្រដូចមុន បានឱ្យឈ្មោះកូននោះថាបន្ថកៈទៀត. ដើម្បីកុំឱ្យហៅច្រឡំ កូនបងឈ្មោះថាមហាបន្ថកៈ ប្អូនឱ្យឈ្មោះថាចុល្លបន្ថកៈ ។

លុះដល់មហាបន្ថកៈ និងចុល្លបន្ថកៈមានវ័យធំឡើង នាំគ្នាសួរមាតាបិតា រកជីដូនជីតារបស់ខ្លួន បានដឹងហើយ ក៏រំអុកមាតាបិតាឱ្យជូនទៅទាល់តែបាន. ប៉ុន្តែធនសេដ្ឋីជីតា

ទទួលយកតែចៅទាំងពីរ. ឯកូនបង្កើត និងកូនប្រសារមិនទទួលស្គាល់ គ្រាន់តែឱ្យទ្រព្យសម្បត្តិខ្លះហើយ បញ្ជូនឱ្យទៅនៅកន្លែងដើមវិញ ដើម្បីចៀសវាងការអាម៉ាសមុខ ។

មហាបន្ថកៈ តែងតាមសេដ្ឋីជាជីតា ទៅស្តាប់ធម៌ឯវត្តវេឡុវ័ន. មានសេចក្តីជ្រះថ្លាចំពោះពុទ្ធសាសនា បានសុំជីតាទៅបួស ។ ឯធនសេដ្ឋីនាំចៅទៅថ្វាយបង្គំព្រះសម្ពុទ្ធសុំបំបួស. ព្រះអង្គអនុញ្ញាតឱ្យបួសជាសមណេរ ដល់អាយុគ្រប់ ២០ ឆ្នាំបានឧបសម្បទជាភិក្ខុទៀត. លោកមានសេចក្តីព្យាយាម ខំចម្រើនវិបស្សនាធម៌ មិនយូរប៉ុន្មាន ក៏បានសំរេចជាព្រះអរហន្ត. បានទទួលឯតទគ្គៈអំពីសំណាក់ព្រះសាស្តាថាជាកំពូលក្នុងកិច្ចចម្រើនបញ្ញាភាវនា ។ លោកមាននាទីជាភត្តុទ្ទេសក៍ អ្នកចាត់ភិក្ខុសង្ឃឱ្យទៅទទួលភត្ត គឺអ្នកចែកសង្ឃលាភចំពោះភិក្ខុសាមណេរ ។

ព្រះមហាបន្ថកត្ថេរ បាននឹកឃើញដល់ចុល្លបន្ថកៈជាប្អូន ចង់ឱ្យប្អូនបានទទួលសេចក្តីសុខ ដែលកើតអំពីឈានសមាបត្តិមគ្គផលនិព្វាន ដូចជាលោកបានទទួលហើយនោះដែរ. ទើបនិមន្តទៅផ្ទះធនសេដ្ឋីជាជីតា សុំអនុញ្ញាតបំបួសចុល្លបន្ថកៈ, ក៏បានឱ្យប្អូនបួសដូចបំណង ។

ចំណែកចុល្លបន្ថកៈបួសហើយ ត្រឡប់ជាល្ងង់អប្បឥតប្រាជ្ញា. បងឱ្យរៀនគាថាមួយអស់ ៤ ខែមិនចាំសោះ ព្រោះផលកម្មចាស់ពីអតីតជាតិ ដែលលោកបានសើចចំអកឱ្យពួកសិស្សល្ងង់ខ្លៅរួមគ្រូជាមួយ ។

ព្រះមហាបន្ថកត្រេរិតថា ប្អូនអញល្ងង់ណាស់ ធ្វើជាអ្នកបួសមិនកើតក៏បណ្តេញចេញឈប់ឱ្យនៅជាមួយ ។

ក្នុងពេលនោះ គ្រូពេទ្យឈ្មោះកោមារភ័ច្ច ប្រើបម្រើឱ្យទៅនិមន្តព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃ ៥០០ អង្គទទួលភត្តក្នុងថ្ងៃស្អែក ។ ព្រះមហាបន្ថកៈទៅទូលព្រះសម្ពុទ្ធ ហើយចាត់ភិក្ខុសង្ឃទាំង ៥០០ ដែលមានក្នុងវត្ត ដកតែចុល្លបន្ថកៈជាប្អូនចេញ មិនឱ្យទៅឆាន់នឹងគេ ។

ចុល្លបន្ថកៈតូចចិត្តណាស់ គិតថាអញត្រូវបងលះបង់ចោលហើយ អស់ទីពឹងក្នុងសាសនាហើយ ត្រូវសឹកទៅផ្ទះទីពឹងជីដូនជីតាវិញ ។ ក៏រៀបចំឥវ៉ាន់ វេចសម្ពាយរៀបចេញពីវត្តទាំងយប់កុំឱ្យខ្មាសគេ ។ ស្រាប់តែព្រះសម្ពុទ្ធយាងទៅស្ទាក់ផ្លូវ ហើយមានព្រះបន្ទូលលួងលោម ប្រទានក្ងួនកន្សែងសតូចមួយឱ្យចុល្លបន្ថកៈចាប់អង្អែលនឹកថា " **រជោហរណំ** នាំចេញនូវធូលី " ឱ្យផ្គងចិត្តពិចារណាថា សេចក្តីបរិសុទ្ធអស់ទៅ ព្រោះអាស្រ័យមន្ទិលក្នុងកាយ, ចិត្តដែលបរិសុទ្ធផ្លូវ

ផង់រមែងសៅហ្មងដោយបាបកម្ម ។ លោកពិចារណាផង ចាប់ឈ្លីសំពត់ផង ស្រាប់តែឃើញមានប្រឡាក់ក្អែលដៃ ក៏កើតសង្វេគក្នុងព្រះត្រៃលក្ខណ៍ថា រូបកាយមិនស្អាត ជា អនិច្ចំ ទុក្ខំ អនត្តា, អរិយមគ្គញ្ញាណ ក៏កើតឡើងបានសម្រេចព្រះអរហត្តបដិសម្ភិទាញាណ ព្រមទាំងអភិញ្ញាណ៦ ប្រកបដោយមនោបយទ្ធិក្នុងពេលនោះឯង ។

ព្រឹកឡើងព្រះសាស្តាមួយអន្លើ ដោយភិក្ខុសង្ឃ៤៩៩ អង្គ ស្តេចនិមន្តទៅផ្ទះគ្រូពេទ្យកោមារភ័ច្ចៗ លើកយាគូទៅថ្វាយ ព្រះអង្គបិទគ្របបាត្រ ។

គ្រូពេទ្យទូលសួរថា បពិត្រព្រះទ្រង់ញាណ មានហេតុយ៉ាងណា ទើបព្រះអង្គបិទបាត្រមិនទទួលបបរទូលបង្គំ ?

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលកោមារភ័ច្ចនៅក្នុងវត្តមានភិក្ខុមួយអង្គទៀត អ្នកមិននិមន្តលោកមកឆាន់ផងទេឬ ?

គ្រូពេទ្យចាត់បម្រើឱ្យទៅនិមន្ត, បម្រើទៅដល់ឃើញភិក្ខុសង្ឃរាប់ពាន់អង្គកំពុងធ្វើកិច្ចការផ្សេងៗពេញវត្ត ដោយឫទ្ធិមនោឃិទ្ធិរបស់ភិក្ខុចុល្លបន្ថកៈ ដែលលោកកំពុងសាក

អ្នកបម្រើនឹកឆ្ងល់ថា ចៅហ្វាយថានៅក្នុងវត្តសល់តែភិក្ខុមួយអង្គ ឱ្យអញមកនិមន្ត, ចុះឥឡូវលោកច្រើនយ៉ាងនេះ

តើអញគួរនិមន្តលោកណា ? គិតហើយក៏ត្រឡប់ទៅជម្រាបចៅហ្វាយវិញ ។

គ្រូពេទ្យប្រាប់ថាឯងទៅវត្តម្ដងទៀត ទៅនិមន្តភិក្ខុឈ្មោះចុល្លបន្ថកៈ ជាប្អូនរបស់ព្រះមហាបន្ថកត្ថេរ ។

អ្នកបម្រើទៅដល់វត្តហើយក៏ស្រែកថា ខ្ញុំព្រះករុណាសូមនិមន្តភិក្ខុចុល្លបន្ថកៈទៅឆាន់យាគូ ទៅផ្ទះគ្រូពេទ្យកោមារភ័ច្ច តើអង្គណាឈ្មោះចុល្លបន្ថកៈសូមនិមន្ត. ភិក្ខុសង្ឃពេញវត្តឆ្លើយថា អាត្មាឈ្មោះចុល្លបន្ថកៈ ! ព្រម១គ្នា ។

អ្នកបម្រើទាល់ចំណោះ ត្រឡប់មកជម្រាបគ្រូពេទ្យម្ដងទៀត គ្រូពេទ្យប្រាប់ថា ឯងចាំសង្កេតមើ ភិក្ខុណាឆ្លើយមុនគេ, ទូលលោកភ្លាមថា ព្រះសាស្ដាឱ្យហៅមកឆាន់យាគូនៅផ្ទះកោមារភ័ច្ច ។

អ្នកបម្រើទៅម្ដងទៀត ធ្វើតាមពាក្យគ្រូពេទ្យ ទើបនិមន្តបានព្រះអរហន្តចុល្លបន្ថកៈមក, ភិក្ខុរាប់ពាន់ដែលកើតដោយឫទ្ធិ ក៏បាត់អស់ទៅ, លុះឆាន់ហើយ ព្រះសាស្ដាត្រាស់ឱ្យចុល្លបន្ថកភិក្ខុ ធ្វើភត្តានុមោទនាតែម្នាក់ឯង, ព្រះអង្គនាំភិក្ខុសង្ឃទាំងអស់ទៅវត្តវិញ ។ ឯព្រះមហាបន្ថកត្ថេរ លោកមិនបានជាគិត ក៏នឹកថាវីវរហើយប្អូនអញ គ្មានចេះធម៌១ម៉ាត់

សោះ បានអីនឹងសូត្រ. លុះ ពិចារណាទៅ ក៏បានជ្រាបថា ប្អូនលោកបានសម្រេចជាព្រះអរហន្តហើយ ទើបមានព្រះទ័យរីករាយ ។

ព្រះចុល្លបន្ថកៈនេះ ព្រះសាស្តាបានតាំងលោកក្នុងឋានៈជាឯតទគ្គៈ ជាអ្នកស្ទាត់ជំនាញបំផុតខាងមនោមយិទ្ធិវិជ្ជា ៗ

ពួកភិក្ខុទាំងឡាយទៅដល់វត្តវិញ បានដឹងថាភិក្ខុចុល្ល-បន្ថកៈជាព្រះអរហន្ត ក៏នាំគ្នានិយាយថា ព្រះសម្ពុទ្ធជាទីពឹងយ៉ាងវិសេស អាចជួយមនុស្សដូចចុល្លបន្ថកៈ ដែលគ្មានទីពឹងត្រូវបងលះបង់ចោលហើយ ឱ្យមានទីពឹងយ៉ាងប្រសើរបំផុតគឺអរហត្តផល ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតធ្លាប់ជាទីពឹងរបស់ចុល្លបន្ថកៈតាំងពីព្រេងនាយមក. ទើបទ្រង់នាំអតីតនិទានថា :

ពីព្រេងនាយ មានមាណពម្នាក់ នៅក្នុងក្រុងពារាណសី បានទៅរៀនសិល្បសាស្ត្រ ឯក្រុងតក្កសិលា ។ ក្នុងចំណោមសិស្សទាំង ៥០០ មានតែមាណពនេះឯង ជាអ្នកចេះគោរពប្រតិបត្តិបម្រើគ្រូអាចារ្យជាងគេ ប៉ុន្តែជាមនុស្សអប្បឥតប្រាជ្ញា រៀនមន្តអ្វីមិនចាំសោះ ។

អាចារ្យទិសាបាមោក្ខគិតថា មាណពនេះមានឧបការៈច្រើនចំពោះអញៗ ត្រូវបង្ហាត់វាឱ្យរៀនបានចេះដឹងនឹងគេ, ទើបខំបង្ហាត់នាំសូត្រ នាំទន្ទេញអស់សមត្ថភាព, មាណពនៅតែមិនចាំមួយម៉ាត់សោះដដែល ។

ឯមាណពដឹងខ្លួនឯងថា អស់សង្ឃឹមក្នុងការសិក្សាហើយ ក៏លាអាចារ្យទៅផ្ទះវិញ ។ លោកអាចារ្យនឹកថា សិស្សនេះខំគោរពបម្រើអញណាស់ ត្រូវតែអញបង្រៀនឱ្យចេះមន្តមួយ សម្រាប់ធ្វើជាស្បៀងចិញ្ចឹមជីវិត មិនគួរឱ្យទៅខ្លួនទទេដូច្នេះសោះ, ទើបលោកអាចារ្យនាំសិស្សនោះទៅក្នុងព្រៃចងមន្តថា "**ឃដេសិ ឃដេសិ កឹ ការណា ឃដេសិ អហំ បិ តំ ជានាមិ** " ប្រែជាសេចក្ដីថា "ឯងព្យាយាមធ្វើអីៗហ្នឹង អញក៏ដឹងដែរ" ។ លុះចងមន្តនេះហើយ បង្ខំឱ្យមាណពជាសិស្សរៀនទន្ទេញច្រាសបណ្ដោយជាច្រើនរយ ច្រើនពាន់ដង ដរាបដល់ចាំស្ទាត់ ទើបឱ្យស្បៀងអាហារបរិភោគតាមផ្លូវហើយ ប្រាប់បន្ថែមទៀតថា ឯងខំសូត្រមន្តនេះកុំឱ្យភ្លេច មន្តនេះអាចជួយជីវិតឯង ឱ្យរស់បានងាយ ។ មាណពថ្វាយបង្គំលាគ្រូអាចារ្យធ្វើដំណើរទៅក្រុងពារាណសីវិញ ។

គ្រានោះព្រះចៅក្រុងពារាណសី ទ្រង់ក្លែងភេទមិនឱ្យអ្នកដទៃស្គាល់ ដើម្បីស៊ើបយកការពិត ឱ្យដឹងសុខទុក្ខប្រជាពលរដ្ឋពិតប្រាកដ កុំឱ្យពួកអ្នករាជការទុច្ចរិតថ្វាយពត៌មានក្លែងបន្លំបាន. ព្រះអង្គយាងចេញពីព្រះរាជវាំងក្នុងវេលាយប់ យាងសសៀរក្បែរជញ្ជាំងផ្ទះអ្នកស្រុក តាមលំដាប់ហូរហែទៅ ។

ខណៈនោះ មានចោរជីករូងចូលប្លន់ផ្ទះអ្នកស្រុកដែលមាណពស្នាក់នៅ, មាណពភ្ញាក់ឡើងស្វាធ្យាយមន្តដែលបានរៀនពីអាចារ្យមក, ចោរឮមន្តនោះស្មានថាគេដឹងនូវអំពើចោរកម្មរបស់ខ្លួនហើយ ក៏ទម្លាក់សម្ភាយទ្រព្យចោលរត់អស់ទៅ ។

ព្រះរាជាបានទតបានជ្រាបព្រឹត្តិការណ៍នោះសព្វគ្រប់ក៏យាងចូលក្នុងរាជវាំងវិញ. ព្រឹកឡើងប្រើរាជបុរសឱ្យទៅហៅមាណព អំពីផ្ទះអ្នកស្រុកមកគាល់ព្រះអង្គ. លុះមកដល់ហើយត្រាស់សួរថា ម្នាលអ្នកអាចារ្យ ឯងទើបមកពីរៀនមន្តអំពីអាចារ្យទិសាបាមោក្ខ ក្នុងក្រុងតក្កសីលាឬ ?

មាណពក្រាបបង្គំទូលថា ព្រះករុណាថ្លៃវិសេស ទើបនឹងចេញអំពីសំណាក់លោកអាចារ្យ ។

- អើប្រសើរណាស់ ល្មាចមិញយើងបានឃើញឥទ្ធិឫទ្ធិមន្តរបស់ឯងហើយ. អ្នកឯងឱ្យយើងរៀនមន្តនោះផងបានឬទេ ?

- សូមទ្រង់ព្រះមេត្តាប្រោសបាន. ប៉ុន្តែសូមព្រះអង្គគង់លើអាសនៈស្មើនឹងទូលបង្គំទើបរៀនបាន ។

- អើអ្នកអាចារ្យ មិនទាស់ខុសអ្វីទេ. ព្រះរាជាក៏ហៅមាណព ឱ្យទៅអង្គុយលើអាសនៈស្មើព្រះអង្គ ទើបសិក្សាមន្តនោះបានចេះចាំហើយ ព្រះរាជទានប្រាក់ជារង្វាន់១ពាន់កហាបណៈ បូជាអាចារ្យ ។

ថ្ងៃមួយ មានសេនាបតីម្នាក់ក្បត់រាជបល្ល័ង្ក បានហៅខ្ញាន់ព្រះកេសទៅផ្ទះខ្លួន សូកឱ្យប្រាក់១ពាន់កហាបណៈ ឱ្យខ្ញាន់ព្រះកេសនោះអារស្វរងព្រះរាជា ក្នុងពេលកោរកាត់ព្រះកេសា.ខ្ញាន់ព្រះកេស ក៏ទទួលយល់ព្រមរួមអំពើក្បត់ជាមួយ។

លុះដល់ពេលសំអាតព្រះកេសា និងព្រះមស្សុ (ពុកចង្កា) ហើយ ខ្ញាន់ព្រះកេស ត្របះកាំបិតយ៉ាងមុតបម្រុងកោរពុកមាត់. ព្រះរាជា ក៏ងើយព្រះកេសឡើង. ខ្ញាន់ព្រះកេសគិតថា នឹងអារតែមួយខ្វាកឱ្យដាច់ព្រះស្វរងតែម្តង។ ប៉ុន្តែព្រះរាជា កាលងើយព្រះកេសឡើង ក៏ស្វាធ្យាយមន្ត

ដែលទើបនឹងរៀនពីមាណពថ្មី១.    ខ្មាន់ព្រះកេសឮមន្តថា "ឯងព្យាយាមធ្វើអី១ហ្នឹង អញក៏ដឹងដែរ" ដូច្នេះ ស្មានថាព្រះរាជាដឹងអំពើក្បត់របស់ខ្លួនហើយ ក៏ទម្លាក់កាំបិតលុតជង្គង់ក្រាបទៀបព្រះបាទាដោយសេចក្ដីតក់ស្លុតក្រៃលែង ។

ព្រះរាជាភាន់ភាំង មិនដឹងជាខ្មាន់ព្រះកេស មានហេតុដូចម្ដេច. ទើបមានព្រះឱង្ការថា នែ!ខ្មាន់ ឯងដឹងថាយើងជាព្រះរាជារបស់ឯងទេ? ម៉េចក៏ឯងមិនគោរពគាត់ដូចសព្វដង ។

ខ្មាន់ព្រះកេសតក់ស្លុតពេក មិនអាចលាក់រឿងក្បត់បាន ក៏ក្រាបបង្គំទូលតាមការណ៍ពិតថា បពិត្រព្រះសម្មតិទេពជាអម្ចាស់ជីវិតលើត្បូង លោកសេនាបតី បានឱ្យប្រាក់ទូលបង្គំ១ពាន់កហាបណៈ ឱ្យធ្វើគត់ព្រះអង្គ ដោយផ្ដាច់ព្រះសូរង៩

ព្រះរាជាត្រាស់ថា អើខ្មាន់! ល្អហើយឯងហ៊ានប្រាប់ការពិត ដល់អញ១ឱ្យឯងរួចជីវិត. ទើបប្រើរាជបុរសឱ្យចាប់សេនាបតីនោះមកសួរចម្លើយ បានជ្រាបការពិតសព្វគ្រប់ហើយ ទ្រង់និរទេសសេនាបតីនោះចាកដែនទៅ ។ ព្រះអង្គទ្រង់ព្រះតម្រិះថា អញមានជ័យជំនះចំពោះការក្បត់ បានរស់ជីវិត ដោយសារតែមន្តលោកអាចារ្យរបស់អញ១ ត្រូវបូជា

គុណដ៏ធ្ងន់នេះឱ្យបានសមរម្យ. ទ្រង់ព្រះតម្រិះយ៉ាងនេះ ហើយ ក៏ប្រើរាជបុរស ឱ្យទៅអញ្ជើញមាណពជាអាចារ្យរបស់ព្រះអង្គមក ទ្រង់ព្រះរាជទានយសសក្តិ តាំងជាសេនាបតី ជំនួសសេនាបតីក្បត់នោះឡើង ។

ព្រះរាជា បានគោរពរាប់អានមាណពនោះ ក្នុងឋានៈជាគ្រូអាចារ្យរបស់ព្រះអង្គដរាបអវសានជីវិត ។

ព្រះសម្ពុទ្ធសម្តែងអតីតនិទាននេះចប់ហើយ ព្រះអង្គបានប្រជុំជាតក៍ថា មាណពក្នុងពេលនោះ បានមកកើតជាចុល្លបន្ថកភិក្ខុ. ព្រះរាជាក្រុងពារាណសីក្នុងកាលនោះ បានមកកើតជាអានន្ទ. ឯអាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺព្រះអង្គតថាគតនេះឯង ទើបក្នុងជាតិជាទីបំផុតនេះ ត្រូវតថាគតជួយចុល្លបន្ថកភិក្ខុឱ្យមានទីពឹងទៀត ។

៚

## ២៩- រឿងនកុលបិតា

(ចាក អ. ច.)

(ធម៌ដែលនាំឱ្យស្វាមីភរិយាបានជួបគ្នារាល់ៗជាតិ)

សម័យថ្ងៃមួយ ព្រះសម្ពុទ្ធបរមគ្រូយើង ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជិតក្រុងសុង្សុមារគិរៈក្នុងដែនភគ្គៈ ។ ព្រះអង្គទ្រង់ស្បង់ចាត្រចីវរក្នុងបុព្វណ្ហសម័យ យាងចូលទៅផ្ទះរបស់គហបតីឈ្មោះនកុលបិតា គង់លើអាសនៈដែលគេក្រាលហើយ នកុលបិតា និងនកុលមាតា ជាស្វាមីភរិយាបាននាំគ្នាចូលទៅក្រាបថ្វាយបង្គំ អង្គុយក្នុងទីសមគួរ ។

ពេលនោះ នកុលបិតាក្រាបបង្គំទូលសួរថា " បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំព្រះអង្គទាំងពីរនាក់បានប្រសប់គ្នា តាំងពីកំលោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តគ្នាឡើយ សូម្បីគ្រាន់តែនឹកក្នុងចិត្តថានឹងក្បត់គ្នា ក៏គ្មានដែរ. ខ្ញុំព្រះអង្គមានប្រាថ្នា ឱ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ក្នុងបរលោកផង កុំឱ្យបែកគ្នាឡើយ" ។ ចំណែកខាងនកុល-មាតា ក៏បានក្រាបបង្គំទូលព្រះសម្ពុទ្ធដូចស្វាមីខ្លួន ប្រាថ្នាឱ្យបានជួបនឹងស្វាមីខ្លួន រាល់ៗជាតិដែរ ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលគហបតី និងគហបតានី

បើជនទាំងពីរប្ដីប្រពន្ធ ប្រាថ្នាឱ្យបានជួបគ្នាក្នុងបច្ចុប្បន្ននេះផង ក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះមានធម៌ ៤ យ៉ាងស្មើគ្នាគឺ :

១. សមសទ្ធា មានសទ្ធាស្មើគ្នា.

២. សមសីលា មានសីលស្មើគ្នា.

៣. សមចាគា មានចាគៈស្មើគ្នា.

៤. សមបញ្ញា មានបញ្ញាស្មើគ្នា ។

ព្រះអង្គទ្រង់សម្ដែងបញ្ជាក់ទៀតថា "ជនទាំងពីរនាក់ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យពេចន៍នៃស្មូម ជាអ្នកសង្រួមក្នុងសីល ជាអ្នកចិញ្ចឹមជីវិតតាមគន្លងធម៌. ប្រពន្ធនិងប្ដីនោះនិយាយពាក្យផ្អែមល្ហែមរកគ្នានឹងគ្នា តែងមានសេចក្ដីចម្រើនដ៏ច្រើនស្ថិតនៅជាសុខ ជនទាំងពីរដែលមានសីលនិងវត្តប្រតិបត្តិស្មើគ្នា. លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ បើមានចំណង់ក្នុងកាម រមែងជាអ្នកត្រេកអររីករាយក្នុងទេវលោកបាន ។

(ចាប់ភាគ ៦)

# ១- រឿងអញ្ញតរភិក្ខុ

( ចាក អ. ធ. )

( បាលីពុទ្ធគាថាសម្រាប់សូត្រកុំឱ្យពស់ចឹក និងកុំឱ្យសត្វសាហាវបៀតបៀន )

សម័យមួយ ព្រះសម្ពុទ្ធគង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យនោះ ក្នុងក្រុងសាវត្ថី មានភិក្ខុមួយរូប ត្រូវពស់ចឹកធ្វើមរណកាលទៅ ។ ភិក្ខុជាច្រើនអង្គ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុមួយរូប ត្រូវពស់ចឹកធ្វើមរណកាលទៅហើយ ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែនហើយ ព្រោះភិក្ខុនោះ មិនបានផ្សាយមេត្តាចិត្តចំពោះត្រកូលស្តេចពស់ទាំង ៤ ពួក គឺត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈ ១, ឈ្មោះឯរាបថៈ ១, ឈ្មោះឆព្យាបុត្តៈ ១, និងឈ្មោះកណ្ហាគោតមកៈ ១ ។ ប្រសិនបើភិក្ខុនោះ បានផ្សាយមេត្តាចិត្តចំពោះស្តេចពស់ទាំង ៤ នោះ ពស់មិនហ៊ានចឹកឡើយ ។

ពេលនោះព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតឱ្យភិក្ខុទាំងឡាយ

ផ្សាយមេត្តាចិត្តចំពោះស្តេចពស់ទាំង ៤ ថា " អនុជានាមិ ភិក្ខវេ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិតុំ អត្តគុត្តិយា អត្តរក្ខាយ អត្តបរិត្តាយ " ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឱ្យផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ដើម្បីគ្រប់គ្រងខ្លួន រក្សាខ្លួន ការពារខ្លួន ។

ពុទ្ធគាថាសម្រាប់សូត្រផ្សាយចិត្តមេត្តានោះថា :

វិរូបក្ខេហិ មេ មេត្តំ មេត្តំ ឯរាបថេហិ មេ
ឆព្យាបុត្តេហិ មេ មេត្តំ មេត្តំ កណ្ហាគោតមកេហិ ច ។
អបាទកេហិ មេ មេត្តំ មេត្តំ ទិបាទកេហិ មេ
ចតុប្បទេហិ មេ មេត្តំ មេត្តំ ពហុប្បទេហិ មេ ។
មា មំ អបាទកោ ហឹសិ មា មំ ហឹសិ ទិបាទកោ
មា មំ ចតុប្បទោ ហឹសិ មា មំ ហឹសិ ពហុប្បទោ ។
សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា ច កេវលា
សព្វេ ភទ្រានិ បស្សន្តុ មា កិញ្ចិ បាបមាគមា ។
អប្បមាណោ ពុទ្ធោ អប្បមាណោ ធម្មោ អប្បមាណោ
សង្ឃោ បមាណវន្តានិ សរីសបានិ អហិ វិច្ឆិកា

សតបទិ ខុណ្ឌានាគី សះពុ បុសិកា ម្ន កតា មេ រក្ខា កតា មេ បរិត្តា បដិក្កមន្តុ ភូតានិ សោហំ នមោ ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ ។

ប្រែថា ភាវៈជាមិត្ររបស់អាត្មាអញ ចូរមានជាមួយនឹងត្រកូលស្តេចពស់ឈ្មោះ វិរូបក្ខៈទាំងឡាយផងជាមួយនឹងត្រកូលស្តេចពស់ឈ្មោះឯរាបថៈទាំងឡាយផង ជាមួយនឹងត្រកូលស្តេចពស់ឈ្មោះ ឆព្យាបុត្តៈទាំងឡាយផង ជាមួយស្តេចពស់ឈ្មោះ កណ្ហាគោតមកៈទាំងឡាយផង ។ ភាវៈជាមិត្ររបស់អាត្មាអញ ចូរមានជាមួយនឹងសត្វ ឥតជើងទាំងឡាយផង សត្វជើង២ ទាំងឡាយផង សត្វជើង៤ ទាំងឡាយផង សត្វមានជើងច្រើនទាំងឡាយផង ។ សត្វឥតជើង សត្វជើង ២ សត្វជើង ៤ និងសត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ ។ សព្វសត្វ សព្វប្រាណ សព្វភូតទាំងអស់គ្នា ចូរបានជួបប្រទះនូវសេចក្តីចំរើនទាំងឡាយ សេចក្តីអាក្រក់បន្តិចបន្តួចកុំមានមកដល់អ្នកឡើយ ។

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានគុណប្រមាណមិនបាន សត្វលូន សត្វវារទាំងឡាយគឺ ពស់ ខ្ទួយ ក្អែប ពីងពាង ត្តុកកែ កណ្តុរ សុទ្ធតែមានប្រាណរាប់បាន ប៉ុន្តែមិនច្រើនដូច

គុណព្រះរតនត្រៃយ៍ឡើយ ។ កិរិយារក្សាការពារ ខ្ញុំបានធ្វើហើយ ពួកសត្វកាចចូរចៀសចេញទៅ ខ្ញុំសូមនមស្ការចំពោះព្រះមានព្រះភាគ សូមនមស្ការ ព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ ។ ចប់ ។

ពុទ្ធគាថានេះ មិនមែនជាមន្តអាគមអួមអាមទេ គឺជាធម៌សម្រាប់ផ្សាយមេត្តាចំពោះពួកសត្វ ។ ធម៌មេត្តានេះ បើចំរើនឱ្យកើតមានក្នុងចិត្តពិតប្រាកដហើយ សត្វអ្វីៗ ដែលកាចសាហាវផុតលេខយ៉ាងណា ព្រមទាំងពួកភូត បិសាច អារក្ស អ្នកតា ដែលមានចិត្តអាក្រក់ ក៏ប្រែរជាមាន ចិត្តល្អស្លូតស្រឡាញ់ ជួយថែរក្សាអ្នកមានមេត្តាធម៌នោះ ដូចជាមិត្រសម្លាញ់របស់ខ្លួន មិនប្រទូស្តបៀតបៀនឡើយ ព្រោះជាពុទ្ធានុញ្ញាតពូកែសក្តិសិទ្ធិបំផុតក្នុងលោក ។

ប៉ុន្តែបើគ្រាន់រៀនឱ្យចេះចាំ ទុកសម្រាប់សូត្រឱ្យសត្វសាហាវខ្លាច ដើម្បីចាប់សត្វនោះ ៗ យកទៅលក់ទាំងរស់ ឬ ចាប់យកពង យកស្បែកធ្វើជាប្រយោជន៍ទៅវិញ មិនមានចិត្តល្អផ្សាយមេត្តាឱ្យសត្វទាំងនោះបានសុខចម្រើនទេ បាលីគាថានោះមិនពូកែឡើយ ពិតជាត្រូវសត្វសាហាវនោះ ៗ សម្លាប់មិនខាន ព្រោះខុសអំពីពុទ្ធបំណង ដែលព្រះអង្គឱ្យ

ផ្សាយមេត្តា គឺសេចក្ដីល្អចំពោះសព្វសត្វ ។

ម្យ៉ាងទៀត បើបានរៀនចេះចាំហើយ មិនដឹងសេចក្ដីនៃពុទ្ធគាថានោះថាយ៉ាងណា គ្រាន់តែដឹងថា គាថាសំរាប់សូត្រឱ្យសត្វសាហាវមានពស់ជាដើមចឹកប៉ុណ្ណោះ មិនបានផ្សាយចិត្តមេត្តាចំពោះសត្វទាំងនោះថាយ៉ាងណា ៗ នោះពុទ្ធគាថានេះក៏មិនពូកែដែរ ។

បើបានផ្សាយមេត្តាចិត្ត តាមសេចក្ដីក្នុងពុទ្ធគាថាហើយ ប៉ុន្តែផ្សាយដោយចិត្តរវើរវាយ មានអារម្មណ៍មិនមូលល្អចំពោះសព្វសត្វ គឺចេះតែនឹកឃើញទៅនេះទៅនោះជាញឹកញយនោះ ក៏មិនសូវពូកែដែរ ព្រោះការផ្សាយមេត្តាចិត្តនេះ ត្រូវប្រើកម្លាំងដួងចិត្តរបស់ខ្លួនទៅគ្របសង្កត់ដួងចិត្តអ្នកដទៃ ឬសត្វដទៃយ៉ាងខ្លាំង ទើបមានប្រសិទ្ធិភាពល្អ ។

## ២- រឿងកណ្ឌកទេវបុត្រ

(ធាក វិ. ខុ.)

(សត្វតិរច្ឆាន មានចិត្តស្មោះត្រង់ស៊ូស្លាប់នឹងម្ចាស់ មិនដូចមនុស្សមានចិត្តសាំញ៉ាំឡើយ)

សម័យមួយ ព្រះមោគ្គល្លានត្ថេរ បាននិមន្តទៅឋានត្រៃត្រឹង្សទេវលោក, បានឃើញវិមានទិព្វ មានពន្លឺដូចព្រះអាទិត្យទើបនឹងរះ ជាវិមានវិចិត្រដោយកែវ ៧ ប្រការ លោកឈប់នៅមុខវិមាននោះ, កណ្ឌកទេវបុត្រជាម្ចាស់វិមាន បានមកថ្វាយបង្គំគួរសមរាក់ទាក់និមន្តគង់លើអាសនៈទិព្វរបស់ខ្លួន ។

ព្រះមោគ្គល្លានសួរទេវបុត្រនោះថា "ម្នាលទេវបុត្រ! វិមានទិព្វដ៏រុងរឿងដោយរស្មី មានជាន់ដ៏វិចិត្រដោយកែវពិទូរ្យ និងមាសផង ដោយកែវផលិក និងប្រាក់ផង ដោយកែវពព្រុះនិងកែវមុក្តាផង ដោយកែវទទឹមនិងកែវមណីផង ក្រាលហើយដោយកែវពិទូរ្យ មានកំពូលទាំងឡាយគួរជាទីរីករាយ, ប្រាសាទរបស់អ្នកនេះ បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ទាំងស្រះបោក្ខរណីរបស់អ្នក ក៏ជាទីរីករាយ ដេរដាសដោយមច្ឆាជាតិ មានទឹកថ្លាល្អ ក្រាលដោយខ្សាច់មាស មាន

ឈូកផ្សេងៗ ឆ្អកឆ្អាស់ដោយឈូកស មានក្លិនក្រអូបជាទីចាប់ចិត្ត. គុម្ពផ្កាទាំងឡាយ ក្បែរខាងទាំងពីរនៃស្រះបោក្ខរ-ណីរបស់អ្នក ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ មានឈើផ្កា និងឈើផ្លែ ដុះល្អូតលាស់យ៉ាងល្អគ្រប់កាល. មានពួកស្រីអប្សរ ស្អិតស្អាងដោយគ្រឿងអលង្ការ និងកម្រងផ្កាផ្សេងៗ ចាំបម្រើអ្នក ដែលអង្គុយលើបល្ល័ង្កមាស. អ្នកតែងរីករាយដោយវត្ថុទិព្វទាំង ១០ ប្រការ តើអ្នកបានធ្វើបុណ្យអ្វីក្នុងជាតិមុន ? ចូរអ្នកប្រាប់នូវបុញ្ញកម្មនោះដល់អាត្មា ?

កណ្ឋកទេវបុត្រ មានចិត្តរីករាយឆ្លើយតបព្រះមោគ្គ-ល្លានថា : " ប ពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនបានធ្វើសីលទានអ្វីទេ កាលនោះខ្ញុំជាសេះ ឈ្មោះកណ្ឋកៈ កើតក្នុងថ្ងៃដំណាលនឹងព្រះសិទ្ធត្ថរាជកុមារ ជាព្រះរាជបុត្រព្រះបាទសុទ្ធោទនៈ ក្នុងក្រុងកបិលព័ស្តុ ។

កាលព្រះរាជបុត្រនោះ ទ្រង់ចេញទៅបព្វជ្ជា ដើម្បីពោធិញ្ញាណ នាពាក់កណ្តាលរាត្រី ទ្រង់ទះខ្ញុំត្រង់ភ្លៅដោយព្រះហស្តដ៏ទន់ មានព្រះនខាក្រហមរុងរឿង ហើយទ្រង់ត្រាស់ចំពោះខ្ញុំថា នែសម្លាញ់ អ្នកចូរនាំយើងទៅបព្វជ្ជាបើយើងបាននូវពោធិញ្ញាណដ៏ឧត្តមហើយ នឹងចំលងសត្វ

លោកចាកសង្សារវដ្ដ ។ កាលដែលខ្ញុំបានឮព្រះតម្រាស់ ច្នេះ ខ្ញុំមានចិត្តរីករាយ មានកម្លាំងកាយខ្លាំងក្លាក្រៃលែង ទទួលយល់ព្រមភ្លាម ដើម្បីដង្ហែព្រះអង្គទៅបព្វជ្ជា. លុះ ព្រះរាជបុត្រឡើងគង់លើខ្នងខ្ញុំហើយ ខ្ញុំមានចិត្តរីករាយថែម ទៀត ដង្ហែព្រះអង្គចេញទៅយ៉ាងឆាប់រហ័ស បានដល់ទីដៅ តាមព្រះរាជបំណង ។

កាលព្រះអាទិត្យរះឡើង ព្រះអង្គក៏លះបង់ចោលខ្ញុំ និងឆន្នាមាត្រ ខ្ញុំឱនលិទ្ធព្រះបាទា ដែលមានព្រះនខាក្រហម រលោងហើយយំ. ព្រះអង្គស្ដេចយាងចេញទៅ ខ្ញុំខំសម្លឹង មើលដោយក្ដីអាល័យ ដរាបដល់បែកហឫទ័យស្លាប់ ក៏ ស្រាប់តែមកកើតក្នុងឋានត្រៃត្រឹង្ស ស្ថិតនៅក្នុងគំនរសម្បត្តិ ទិព្វនេះឯង ដោយអានុភាពនៃសេចក្ដីជ្រះថ្លាស្មោះចំពោះ ការយាងចេញបព្វជ្ជាផង ដោយសេចក្ដីរីករាយ ព្រោះបាន ស្ដាប់ព្រះតម្រាស់ថា ព្រះអង្គយាងចេញទៅស្វែងរកពោធិ-ញ្ញាណ ខ្ញុំមុខជាបានដឹង ស្គាល់នូវពោធិញ្ញាណនោះមិនខាន

បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់ និមន្តទៅក្នុងសម្នាក់នៃព្រះពុទ្ធជាសាស្ដា សូមលោកម្ចាស់ ក្រាបបង្គំទូលនូវកិរិយា ថ្វាយបង្គំព្រះបាទាដោយសិរ្សៈរបស់

ខ្ញុំចំពោះព្រះអង្គផង ។ ចំណែកខ្ញុំគង់នឹងទៅជួបព្រះអង្គក្នុងថ្ងៃណាមួយមិនខាន ព្រោះការបានឃើញនូវព្រះសម្ពុទ្ធជាលោកនាថរកបានដោយកម្រណាស់ ។

ឯកណ្ណកទេវបុត្រនោះ ជាអ្នកមានកតញ្ញូកតវេទិតា ថ្ងៃមួយបានចូលទៅគាល់ព្រះសាស្តា ស្ថិតនៅក្នុងទីគួរហើយ ព្រះសម្ពុទ្ធ បានប្រាស្រ័យដោយធម្មកថាគួរជាទីរីករាយ, លុះបានស្តាប់ធម្មកថានោះហើយ ក៏បានសម្រេចនូវសោតាបត្តិមគ្គ ជម្រះនូវទិដ្ឋិ វិចិកិច្ឆា និងសីលព័ត ថ្វាយបង្គំបាទាព្រះសាស្តាហើយ ក៏ចាកទីនោះបាត់ទៅ ។

ឲ្យ៚

## ៣- រឿងសានុវាសិប្រេត

(ចាក បេ. ខុ.)

(សង្ឃទានអាចសម្រេចផលដល់ប្រេតជាញាតិខ្លួនបាន)

សម័យមួយព្រះថេរៈឈ្មោះពោដ្ឋបាទ ជាអរិយសាវ័ក នៅអាស្រ័យលើភ្នំឈ្មោះ សានុវាសី នាក្រុងកុណ្ឌី. មាតាបិតារបស់លោកបានកើតជាប្រេត មានមាត់តូចប៉ុនរន្ធក្តិតម្ជុល ស៊ីចំណីអាហារផឹកទឹកមិនបាន រងទុក្ខវេទនា ដោយការស្រេកឃ្លានយ៉ាងក្រៃលែង មានកាយស្គមកំព្រឹងអាក្រាតខ្លួនទទេ ឃើញសុទ្ធតែឆ្អឹង មានសេចក្តីភ័យតក់ស្លុតរន្ធត់ញាប់ញ័រជានិច្ចមិនហ៊ានបង្ហាញខ្លួនឱ្យគេឃើញឡើយ។ ឯបងប្រុសរបស់ព្រះថេរៈនោះ ក៏កើតជាប្រេតអាក្រាតដែរ នៅក្នុងច្រកព្រៃតែម្នាក់ឯង ជាប្រេតវារលូនលើផែនដី ។ គឺចង់ទៅទីណាៗ ទៅបានដោយឥរិយាបថវារ ។

ថ្ងៃមួយព្រះថេរៈនិមន្តដើរកាត់ព្រៃ ដែលប្រេតនោះនៅ ប្រេតជាបង ក៏ខំវារតាមព្រះថេរៈ បង្ហាញខ្លួនឱ្យឃើញ ព្រះថេរៈមិនបានឃើញនិមន្តហួសទៅ. ប្រេតនោះខំស្រែកថា លោកម្ចាស់ៗ ខ្ញុំជាបងរបស់លោក បានមកកើតជាប្រេត, ឯមាតាបិតារបស់លោក ក៏មកកើតជាប្រេតដែរ

ព្រោះមិនបានធ្វើបុណ្យទានក្នុងជាតិមុន. លោកជាអ្នកមានបុណ្យ មានចិត្តអាណិតអាសូរ សូមអនុគ្រោះឱ្យទានឧទ្ទិសផលចំពោះខ្ញុំ និងមាតាបិតាលោកផង ។

ពោធិ៍បាទត្ថេរ បានឃើញបានជ្រាប នូវសេចក្តីទុក្ខវេទនារបស់ប្រេតទាំងបីនោះហើយ ក៏និមន្តទៅបិណ្ឌបាតជាមួយនឹងភិក្ខុ ១២ អង្គ. លុះត្រឡប់មកវិញ បានប្រជុំគ្នាក្នុងទីមួយ. ព្រះថេរៈសុំចំណីអាហារខ្លះអំពីភិក្ខុទាំង ១២ អង្គនោះ ធ្វើសង្ឃទានឧទ្ទិសផលចំពោះប្រេតទាំងបីរូប១ ក៏បានចំណីអាហារទិព្វបរិបូណ៌ មានកម្លាំង មានសម្បុរល្អ បានសេចក្តីសុខហើយ ប្រេតជាបងបង្ហាញខ្លួនឱ្យព្រះថេរៈឃើញនិយាយសុំសំលៀកបំពាក់ទៀត ។

ព្រះថេរៈ បានរើសកំណាត់ទាំងឡាយពីគំនរសំរាមមកធ្វើជាចីវរ ហើយប្រគេនដល់សង្ឃ ឧទ្ទិសផលចំពោះប្រេតទាំងបី ១ ក៏បានសំពត់ទិព្វប្រើប្រាស់គ្រប់១គ្នា ។ ប្រេតជាបងបានបង្ហាញខ្លួនឱ្យព្រះថេរៈឃើញ ហើយសុំផ្ទះនៅទៀត ។

ព្រះថេរៈបានធ្វើកុដិប្រកស្លឹក ហើយប្រគេនដល់សង្ឃ ដែលនិមន្តមកពីទិសទាំង ៤ ឧទ្ទិសផលចំពោះប្រេត

ទាំងបី ៧ ក៏បានប្រាសាទទិព្វនៅជាសុខក្សេមក្សាន្ត ហើយបានសុំទឹកសំរាប់ផឹកទៀត ។

ព្រះថេរៈ បានចាក់ទឹកបំពេញធម្មក្រក (បំពង់ទឹក) ហើយប្រគេនដល់សង្ឃ ឧទ្ទិសផលចំពោះប្រេតទាំងបី ៧ ក៏បានស្រះបោក្ខរណីទិព្វ កើតឡើងមានទឹកត្រជាក់ មានកំពង់ល្អសម្រាប់ចុះងូត ដេរដាសដោយផ្កាឈូកមានក្លិនក្រអូប ។

ប្រេតទាំងនោះ បានបង្ហាញខ្លួនចំពោះព្រះថេរៈ ហើយនិយាយថា ពួកយើងបានចំណីអាហារ បានសំពត់ បានប្រាសាទ បានស្រះបោក្ខរណី សុទ្ធតែរបស់ទិព្វប្រើប្រាស់ហើយ ប៉ុន្តែជើងទាំងឡាយរបស់យើងឈឺពុកពងដោយគ្រួស និងបន្លា សូមលោកឱ្យនូវយានជំនិះចំពោះពួកយើងផង ។

ព្រះថេរៈ បានប្រគេនស្បែកជើងដល់សង្ឃ ហើយឧទ្ទិសផលចំពោះប្រេតទាំងបី ៧ ក៏បានរាជរថទិព្វជិះទៀត ទើបនាំគ្នាជិះរាជរថទៅថ្វាយបង្គំ ថ្លែងអំណរគុណព្រះថេរៈថា បពិត្រលោកដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញ ប្រកបដោយសេចក្តីករុណាក្នុងលោក ថាដូច្នេះហើយក៏បាត់អំពីនោះទៅ ។

## ៤- រឿងព្រះអង្គម្ចាស់វីតសោក

(ចាក អ. ម.)

(ទោស និងអានិសង្សនៃបាណាតិបាត និងធ្វើទានទឹកអដ្ឋបាន)

សម័យក្រោយពុទ្ធកាល មានព្រះអង្គម្ចាស់មួយអង្គ ព្រះនាមវីតសោក ជាព្រះអនុជរបស់ព្រះបាទធម្មាសោក ជាជនមិច្ឆាទិដ្ឋិ គោរពរាប់អានតែពួកតិរ្ថិយ តែងត្មះតិះដៀលព្រះធម៌ពុទ្ធសាសនា មានព្រះទ័យយល់ខុសថា ពួកសមណៈខាងពុទ្ធសាសនា ដែលចេញបួសហើយ បានសម្រេចព្រះនិព្វាននោះមិនមានឡើយ ។

ថ្ងៃមួយ ព្រះបាទធម្មាសោក ត្រាស់សួរព្រះអង្គម្ចាស់វីតសោក ជាព្រះអនុជថា ហេតុអ្វីបានជាអ្នកដឹងថា ពួកសមណសក្យបុត្ត ចេញបួសហើយមិនបានសម្រេចព្រះនិព្វាន ?

ព្រះអង្គម្ចាស់វីតសោកក្រាបទូលថា ព្រោះពួកសមណសក្យបុត្ត លោកស្វែងរកតែសេចក្ដីសុខស្រួល មិនប្រតិបត្តិឱ្យលំបាកដូចពួកតិរ្ថិយ ។

ព្រះបាទធម្មាសោក ត្រាស់រំលឹកព្រះអានុជថា អ្នកកុំយល់ខុសដូច្នេះ កុំជឿវត្ថុដែលមិនគួរជឿដូច្នេះ ចូរកុំនិយាយ

ដូច្នេះទៀត និងកុំគ្នះគិះដៀលអ្នកមានសទ្ធាចំពោះពុទ្ធសាសនាឡើយ អ្នកត្រូវញាំងសទ្ធាដ៏ធំទូលាយឱ្យកើតមានឡើងចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកុំខាន ។

សម័យមួយ ព្រះបាទធម្មសោកបាននិវត្តសោកទៅប្រពាធព្រៃ បានឃើញពួកត្ថិរយម្នាក់ កំពុងកំដៅកិលេសដោយភ្លើង ៥ ភ្នក់ដែលឆេះសន្ធោសន្ធៅ. ព្រះអង្គម្ចាស់វិតសោក មានសទ្ធាជ្រះថ្លា កើតឡើង ចូលទៅគោរព ថ្វាយបង្គំត្រាស់សួរថា " លោកម្ចាស់ដ៏ចម្រើន ទុក្ករកិរិយានេះលោកធ្វើមកបានប៉ុន្មានឆ្នាំហើយ" ?

ត្ថិរយតបថា (បាន ១២ ឆ្នាំហើយ) ។

- លោកទម្លាប់បរិភោគអ្វីជាអាហារ ?
- អាត្មាបរិភោគតែផ្លែឈើ មើមឈើជាអាហារ ។
- លោកបិទបាំងកាយដោយអ្វី ?
- អាត្មាបិទបាំងកាយដោយស្មៅ ។
- លោកយកអ្វីជាទីដេក ?
- អាត្មាយកស្មៅក្រាលផ្ទាល់ផែនដីជាទីដេក ។
- កិច្ចដែលលោកធ្វើមានអ្វីលំបាកជាងនេះទៅទៀត
- កិច្ចដែលលំបាកស្ទើរអាត្មាអត់ទ្រាំមិនបាននោះ គឺ

គាប់ឃើញសត្វម្រឹគពាក់ញីឈ្មោល តាមរដូវរបស់វា អាត្មាឃើញហើយរាគៈ ក៏កើតឡើងដុតរោលអាត្មាឱ្យមានតម្រេករសាប់រសល់យ៉ាងខ្លាំង តាមពួកម្រឹគនោះៗ ។

ព្រះអង្គម្ចាស់វីតសោក ត្រាស់ថា "ឱហ្ន៎ ! ចំណង់បើលោកម្ចាស់ប្រព្រឹត្តតឹងតែងបែបនេះ មានកិលេសប៉ុណ្ណេះទៅហើយ តើពួកសមណសក្យបុត្ត ដែលប្រព្រឹត្តធូរថយប្រើប្រាស់បច្ច័យ ៤ នោះយ៉ាងណាទៅទៀត. ព្រះជេដ្ឋា ឥតដឹងរឿងនេះសោះឡើយ ទើបព្រះអង្គចាញ់បោកពួកសមណ-សក្យបុត្តដល់ម្ល៉េះ ។

ពេលនោះព្រះបាទធម្មសោក បានឮពាក្យនោះហើយ ទ្រង់ត្រាស់ចំពោះសេនាបតី ដែលអង្គុយគាល់ព្រះអង្គថា យើងត្រូវប្រើឧបាយយ៉ាងវិសេសមួយ ដើម្បីជួយវីតសោកឱ្យមានសទ្ធា មានទិដ្ឋិយល់ត្រូវតាមសភាវៈពិតរបស់ពុទ្ធសាសនា. ពួកសេនាបតី យល់ស្របតាមឧត្តមគតិរបស់ព្រះអង្គ ។ បានពន្យល់ឧបាយឱពួកសេនាបតីធ្វើតាមគ្រប់គ្នា ។

ព្រះបាទធម្មសោក បានយាងចូលទៅក្នុងមហាប្រាសាទ ដែលតម្កល់បល្ល័ង្ករាជ្យ ហើយទ្រង់ដោះម្កុដ និងគ្រឿងទ្រង់របស់ក្សត្រ ដាក់ក្បែរបល្ល័ង្ករាជ្យ ទ្រង់ព្រះពស្ត្រ

សម្រាប់ស្រង់យាងចូលទៅក្នុងបន្ទប់ទឹកបាត់ទៅ នៅតែព្រះអង្គម្ចាស់វីតសោក និងពួកសេនាបតី ៧ ទូលព្រះអង្គម្ចាស់វីតសោកថា "បើឥតអំពីព្រះបាទធម្មសោកទៅ ព្រះអង្គម្ចាស់ នឹងឡើងគ្រងរាជ្យ ដូច្នេះសូមទ្រង់ លគ្រឿងប្រដាប់និងមកុដ ហើយឡើងគង់លើបល្លង្ករាជ្យមើល តើសមទេ ?

ព្រះអង្គម្ចាស់វីតសោក ជឿតាមឧបាយរបស់សេនាបតី ក៏ទ្រង់គ្រឿងប្រដាប់ក្សត្រសព្វគ្រប់ ហើយឡើងគង់លើបល្លង្ករាជ្យ ។ ពេលនោះព្រះបាទធម្មសោក យាងចេញពីបន្ទប់ទឹកមកភ្លាម ត្រាស់គម្រាមព្រះអនុជថា " ឯងធ្វើមធំណាស់ អញមិនទាន់ស្លាប់ផង ឯងហ៊ានដណ្តើមរាជ្យ. នែនាយពេជ្ឈឃាត ត្រូវចាប់វីតសោក វាយប្រដៅវាឱ្យអញ !។

ពួកសេនាបតីក្រាបទូលសូមទោសថា ព្រះអង្គម្ចាស់វីតសោក ជាព្រះអនុជរួមព្រះមាតាព្រះអង្គ សូមទ្រង់ព្រះរាជទានទោសដោយអនុគ្រោះ ។

ព្រះបាទធម្មសោកត្រាស់ថា យើងព្រមលើកលែងទោសតាមអ្នកទាំងឡាយ យើងឱ្យវាសោយរាជ្យបាន ៧ ថ្ងៃ ចុះ ដល់ថ្ងៃទី ៨ ត្រូវសម្លាប់វាចោល ព្រោះវាហ៊ានដណ្តើមរាជ្យយើង ។

ក្នុងពេល ៧ ថ្ងៃនោះ ពួកភ្លេងតូរ្យតន្ត្រីរាប់សែននាក់ បានប្រគុំឡើងគគ្រឹកគគ្រេង. ពួកព្រាហ្មណ៍ ១ សែននាក់ បានគាល់ប្រណម្យអញ្ជលី សរសើរបុណ្យព្រះបាទវីតសោក. ពួកស្រីស្នំ ១ សែននាក់ចោមរោមគាល់ត្រៀបត្រា ។ ឯពួកពេជ្ឈឃាតទាំង ៤ មានដៃប្រទាក់ឈាមស្រស់ៗ ក៏នាំគ្នាស្រែកនៅមាត់ទ្វារទាំង ៤ ថា រាត្រីមួយបានកន្លងទៅហើយ នៅតែ ៦ រាត្រីទៀតទេ យើងនឹងផ្តាច់បង់ជីវិតហើយ ចេះតែនាំគ្នាស្រែកឱ្យព្រះបាទវីតសោកឮដូច្នេះ ដរាបដល់គ្រប់៧ ថ្ងៃ ។

លុះ ៧ ថ្ងៃកន្លងផុតហើយ ពួកសេនាបតី បាននាំព្រះបាទវីតសោក ទៅគាល់ព្រះបាទធម្មសោក. ព្រះអង្គត្រាស់សួរព្រះអនុជថា ការសោយរាជ្យ ៧ ថ្ងៃនេះឯងសប្បាយរីករាយណាស់ឬ ?

ព្រះអង្គម្ចាស់វីតសោក ក្រាបទូលថាទុក្ខខ្លាំងណាស់ ផ្ទំក៏មិនលក់ សោយអាហារក៏មិនបាន មានតែសេចក្តីតក់ស្លុតចំពោះសេចក្តីស្លាប់តែម្យ៉ាង អារម្មណ៍ទាំង ៦ របស់ទូលបង្គំទទួលតែមរណភ័យ ឮតែសំលេងពេជ្ឈឃាតស្រែកគួរឱ្យតក់ស្លុតម្យ៉ាង ។

ព្រះបាទធម្មាសោកត្រាស់ថា គ្រាន់តែសេចក្ដីស្លាប់ក្នុងជាតិមួយប៉ុណ្ណោះឯងតក់ស្លុត លែងទទួលសេចក្ដីសុខរបស់ក្សត្រគ្រងរាជ្យទៅហើយ ចំណង់បើពួកសមណសក្យ-បុត្តិយ៍ ដែលលោកឃើញនូវសេចក្ដីទុក្ខជាច្រើនជាតិ ដែលកើតអំពី ជាតិ ជរា ព្យាធិ មរណៈ គ្មានទីបំផុត និងទុក្ខក្នុងនរកជាដើមនោះ តើចិត្តលោកធុញទ្រាន់ចំពោះកាមគុណយ៉ាងណា នឿយណាយចំពោះវដ្ដសង្សារយ៉ាងណា លោកមិនចាំបាច់ធ្វើទុក្ករកិរិយាឱ្យលំបាកកាយ ឥតអំពើដូចពួកតិរ្ថិយ កាលបើចិត្តធុញទ្រាន់នឿយណាយចំពោះភពទាំងបីហើយ លោកនឹងបានសម្រេចនូវអមតធម៌ គឺនិព្វានពុំខាន ។

ខណៈនោះ ព្រះអង្គម្ចាស់វីតសោក បានលះបង់នូវមិច្ឆាទិដ្ឋិ លើកដៃប្រណម្យចំពោះព្រះបាទធម្មាសោក ហើយត្រាស់ថា បពិត្រព្រះជេដ្ឋាពេលនេះ ខ្ញុំសូមដល់នូវព្រះរតន-ត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិតទៅ ។

ព្រះបាទធម្មាសោក មានព្រះទ័យត្រេកអរ លូកព្រះហស្តអោបព្រះអនុជត្រាស់ថា យើងប្រាថ្នាចង់ឱ្យឯងមានសទ្ធាជ្រះថ្លាចំពោះធម៌របស់ព្រះសម្ពុទ្ធយ៉ាងនេះឯង ទើបយើងធ្វើឧបាយកលនេះ យើងមិនសម្លាប់ឯងទេ ឈប់ភិត

ភ័យទៅ ។

បន្ទាប់មក ព្រះអង្គម្ចាស់វីតសោក បានយកកម្រងផ្កាទៅបូជាព្រះសថូបទាំងឡាយ ដែលបញ្ចុះព្រះបរមធាតុរបស់ព្រះសម្ពុទ្ធ, បានទៅស្តាប់ធម៌ទេសនា ធ្វើសក្ការបូជាចំពោះភិក្ខុសង្ឃ ហើយយាងទៅវត្តកុក្កុដារាម ថ្វាយបង្គំព្រះយសត្ថេរ ។ ពិចារណាមើលឧបនិស្ស័យ បានជ្រាបដោយអហន្តញាណថា ព្រះអង្គម្ចាស់ វីតសោក មានបារមីជ្រះថ្លាអាចសម្រេចព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ទើបលោកសម្តែងអំពីការបំពេញព្រហ្មចរិយាធម៌ ថ្នាក់ខ្ពស់បំផុតចំពោះព្រះអង្គម្ចាស់វីតសោក ។ ទ្រង់ព្រះសណ្តាប់ចប់ធម្មទេសនា ហើយមានព្រះទ័យរីករាយចំពោះសមណភេទ បានសុំបួសក្នុងសម្នាក់ព្រះយសត្ថេរ។ ឱ្យសុំអនុញ្ញាតអំពីព្រះបាទធម្មាសោកជាមុនសិន ។

ព្រះអង្គម្ចាស់វីតសោក បានទៅសុំព្រះរាជានុញ្ញាតអំពីព្រះបាទធម្មាសោកជាព្រះជេដ្ឋា ដើម្បីបួសក្នុងពេលឆាប់ៗ ។ ព្រះរាជាបានជ្រាបថា ព្រះអនុជមានសទ្ធាចំពោះពុទ្ធសាសនា ដរាបដល់សុំបួសដូច្នេះ ក៏គៀកស្ទរងព្រះអនុជទ្រង់ព្រះកន្សែងឱ្យកខ្សូលថ្លែងថា ព្រះអនុជជាទីស្រឡាញ់

ចូរឯងកុំបួសឡើយ ព្រោះបព្វជិត មានការចិញ្ចឹមជីវិតដោយលំបាក បរិភោគប្រើប្រាស់តែរបស់តាមបាន ជួនកាលបរិភោគម្ហូបអាហារជូរផ្អូម ប្រើសំពត់បង្សុកូល ដេកផ្ទាល់ផែនដី ពេលមានអាពាធ គ្មានថ្នាំល្អថ្លៃថ្លាសម្រាប់ព្យាបាល, ឯងជាក្សត្រសុខុមាលជាតិ ធ្លាប់តែប្រើរបស់ថ្លៃថ្នូរ នៅក្នុងមហាប្រាសាទ មានទាសាទាសីនៅចាំបំរើ, បើឯងបួសហើយ នឹងមានសេចក្តីទុក្ខលំបាក វេទនាមិនខាន ជេដ្ឋាមិនដាច់ព្រះទ័យឱ្យឯងបួសឡើយ ។

ព្រះអង្គម្ចាស់រិតសោក មានបន្ទូលថា បពិត្រព្រះជេដ្ឋាជាទីគោរព ខ្ញុំព្រះអង្គមិននឿយណាយចំពោះព្រះរាជត្រកូលទេ តែខ្ញុំភ័យខ្លាចសេចក្តីទុក្ខ ដែលកើតអំពីជាតិ ជរា ព្យាធិ មរណៈ មិនអាចទ្រាំនៅស្ងៀមបាន ទើបសូមព្រះជេដ្ឋាទៅបួស ដើម្បីព្រះនិព្វាន ជាទីរំលត់ទុក្ខទាំងនេះឯង ។

ព្រះរាជាត្រាស់ថា បើដូច្នេះ យើងឱ្យឯងសាកល្បងចំពោះចរិយាវត្តរបស់អ្នកបួសមើលសិន ក្រែងអនុជឯងទ្រាំទ្រមិនបាន គឺឯងត្រូវប្រព្រឹត្តបិណ្ឌបាតក្នុងវាំង អង្គុយក្រោមម្លប់ឈើ ផ្ទំលើកម្រាលស្មៅផ្ទាល់ផែនដី ។

ព្រះអង្គម្ចាស់រិតសោក លះបង់មហាប្រាសាទ និង

គ្រឿងឧបភោគបរិភោគ ជារបស់គ្រហស្ថទាំងអស់ ហើយទទួលបាត្រអំពីព្រះថេរៈ យាងបិណ្ឌបាតគ្រប់ផ្ទះស្រីស្នំក្នុងវាំងសោយ ផ្ទំក្រោមម្លប់ឈើជាច្រើនថ្ងៃ ។

ព្រះបាទធម្មាសោក បានត្រាស់សួរស្រីស្នំថា នាងរាល់គ្នាបានដាក់បាតព្រះអនុជ ដោយភោជនាហារយ៉ាងណា ?

ពួកស្រីស្នំក្រាបបង្គំទូលថា ដាក់នូវភោជនាហារឧត្ដមថ្លៃថ្លា ដែលព្រះអង្គម្ចាស់ធ្លាប់សោយ ។

ព្រះរាជាត្រាស់ថា ចាប់ពីថ្ងៃនេះទៅ ត្រូវដាក់តែភោជនាហារថោកទាប ជាអាហាររបស់អ្នកក្រខ្សត់ ដើម្បីឱ្យព្រះអនុជទម្លាប់សោយ បើអាចសោយអាហារបែបនោះ ១ បានហើយ ទើបយើងអនុញ្ញាតឱ្យបួស ។

ចាប់ពីថ្ងៃនោះមក ព្រះអង្គម្ចាស់វីតសោក បានទទួលតែអាហារថោកទាប មានបាយចុងអង្ករ និងទឹកជ្រក់ជាដើម យកមកសោយយ៉ាងឆ្ងាញ់ រឹតតែមានព្រះទ័យរីករាយចំពោះបព្វជ្ជាថែមទៀត ។

ព្រះបាទធម្មាសោក បានទតឃើញព្រះអនុជសោយយ៉ាងឆ្ងាញ់ មិនរវល់នឹងឋានៈអាហារ ហើយមានព្រះទ័យរីក

ភាយថែមទៀត ដូច្នេះក៏អនុញ្ញាតឱ្យបួសតាមបំណង គ្រាន់តែផ្ដាំថា បើអនុជបួសហើយឧស្សាហ៍មកសួរយើងផង ។

ព្រះអង្គម្ចាស់វីតសោក បានព្រះរាជានុញ្ញាតហើយ ស្ដេចទៅវត្តកុក្កុដារាម មានព្រះតម្រិះថា បើអញបួសនៅទីនេះ មិនផុតកង្វល់ទាក់ទងដោយហេតុផ្សេងៗ ព្រះអង្គក៏យាងទៅបួសក្នុងនគរដទៃ មិនយូរប៉ុន្មានបានសម្រេចព្រះអរហត្តផល ជាព្រះអរហន្តមួយអង្គក្នុងលោក ។

ថ្ងៃមួយព្រះថេរវីតសោក មានព្រះទ័យនឹកឃើញបណ្ដាំព្រះបាទធម្មាសោកថា " បើឯងបួសហើយឧស្សាហ៍មកសួរយើងផង " គួរអាត្មាអញទៅថ្វាយព្រះពរក្នុងពេលព្រឹកព្រលឹមនេះ, ព្រះថេរៈតើនពីព្រលឹម ស្ពាយបាត្រនិមន្តទៅក្រុងបាតលិបុត្រ ទទួលអាហារបិណ្ឌបាតបណ្ដើរៗ តាមផ្លូវរហូតដល់ទ្វារព្រះរាជវាំង ទើបលោកប្រាប់ទ្វារបាលថា "ភិក្ខុវីតសោក មានប្រាថ្នាថ្វាយព្រះពរចំពោះព្រះបាទធម្មា-សោក សូមអ្នកបើកទ្វារឱ្យអាត្មាទៅផង" ។

ទ្វារបាលម្នីម្នាទៅទូលព្រះរាជាថា បពិត្រព្រះសម្មតិ-ទេព ឥឡូវនេះព្រះភិក្ខុវីតសោក បាននិមន្តមកហើយ មានប្រាថ្នាចូលថ្វាយព្រះពរចំពោះព្រះអង្គ ។

ព្រះរាជាត្រាស់ថា ចូរឯងទៅនិមន្តលោកឱ្យចូលមក ឆាប់ៗ កុំបង្អង់យូរ ។

កាលព្រះថេរៈវីតសោក និមន្តដល់មាត់ទ្វារ រាជតម្នាក់ហើយ ព្រះបាទធម្មាសោក យាងទៅទទួល ក្រាបថ្វាយបង្គំផ្ទាល់ផែនដី លើកព្រះហស្តប្រណម្យទតព្រះភ័ក្ត្រព្រះថេរៈជាព្រះអនុជហើយ ទ្រង់ព្រះកន្សែងដោយសេចក្តីអាឡោះអាល័យ មានព្រះបន្ទូលថា ខ្ញុំឃើញព្រះនេត្រលោកមិនរំជើបរំជួលសោះ ពិតជាបានសម្រេចមគ្គផលហើយ ។

ពេលនោះរាជគុម្ពៈ សេនាបតីទី ១ របស់ព្រះបាទធម្មាសោក ដែលបានឃើញព្រះថេរៈវីតសោក ប្រើសំពត់បង្សុកូល កាន់បាត្រដីទទួលអាហារបិណ្ឌបាតគ្រប់យ៉ាង មិនអើពើនឹងឋានៈអាហារ បានក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះថេរៈវីតសោក មានចិត្តក្សេមក្សាន្តហើយ ជាអ្នកប្រាជ្ញតិច លោកបានកាត់ចិត្តចោលរាជសម្បត្តិលះបង់ក្រុងបាតលិបុត្រ ដូចជាគេខាកកំហាកចោលហើយ។ ព្រះរាជា ទ្រង់ព្រះសណ្តាប់ដោយយកព្រះទ័យទុកដាក់ហើយក៏និមន្តព្រះអនុជ ឱ្យគង់លើរាជ្យបល្ល័ង្ក ចាត់ចែងភត្តយ៉ាងវិសេសបំផុត ប្រគេនផ្ទាល់ព្រះហស្ត ។

លុះព្រះថេរៈវីតសោកឆាន់រួចហើយ ព្រះបាទធម្មា-សោក យាងទៅគង់ក្នុងទីគួរមួយជិតព្រះអនុជ និមន្តឱ្យសម្តែងធម៌ទេសនា ។

ព្រះថេរៈសម្តែងធម៌ទេសនា រំលឹកទូន្មានព្រះរាជាថា រាជ្យសម្បត្តិ ជាធម្មជាតិគួរគោរព និងថ្លៃថ្នាថ្កើងថ្កានណាស់ សូមព្រះរាជាកុំប្រមាទក្នុងរាជកិច្ច. ព្រះរតនត្រ័យជាធម្មជាតិ បានជួបដោយកម្រណាស់ សូមព្រះអង្គឧបត្ថម្ភធ្វើសក្ការបូជាដោយគោរពក្រៃលែង ។

ក្នុងទីបំផុតនៃធម្មទេសនានេះ ព្រះថេរៈចុះចាករាជបល្ល័ង្ក ថ្វាយព្រះពរលាព្រះបាទធម្មាសោក និងរាជបរិពារ ។ ព្រះរាជា ព្រមទាំងរាជបរិពារជាច្រើនពាន់នាក់ បានជូនដំណើរព្រះថេរៈដល់ទ្វារខាងក្រៅ ។ ព្រះថេរបាននឹកឃើញថា ក្នុងពេលមុនព្រះរាជា បានខំធ្វើឧបាយផ្សេងៗ ដើម្បីឱ្យអាត្មារកឃើញនូវអមតធម៌ គឺព្រះនិព្វាន, ឥឡូវនេះគួរអាត្មាញុំាងព្រះរាជាឱ្យរឹងរឹតតែមានសេចក្តីជ្រះថ្លា ចំពោះពុទ្ធសាសនាថែមទៀត ។ លុះគិតដូច្នេះហើយ ក៏ចូលឈានហោះឡើងកាន់អាកាស សម្តែងបាដិហារ្យផ្សេងៗ ។ ព្រះរាជា និងពួកបរិពារ មានសេចក្តីជ្រះថ្លា លើកព្រះហស្ត

លើកដៃប្រណម្យ ប្រកបដោយបិតិសោមនស្សគ្រប់ៗគ្នា ។

ព្រះរាជាទ្រង់បន្ទឹព្រះសូរសីហនាទថា " លោកម្ចាស់ឃ្លាតផុតសាច់សាលោហិត ដែលថ្នាក់ថ្នមជាទីស្រឡាញ់ហើយ ទើបលោកអណ្តែកត្រសែតទៅក្នុងអាកាសដូចជាបក្សី, ឯខ្លួនខ្ញុំនៅជាប់ចំណងរីករួតដោយរាជ្យសម្បត្តិ ជាប់ជំពាក់នៅក្នុងលោកនេះ ។ លោកបានក្រេបផឹកនូវរសដ៏ប្រសើរគឺអមតធម៌ ព្រោះលោកទូន្មានចិត្តបានហើយ ។ ផលនៃឈានសមាបត្តិ គឺពួកមនុស្សឥតប្រាជ្ញា កំចាំងគំនិតគិតមិនយល់ទេ ។ ចារឹយាបថរបស់លោកឰដ៏អាកាសនេះបានបំបាត់បង់នូវមានះរបស់ខ្ញុំ ទុកជាកម្លាំងប្រាជ្ញាស្មារតីរបស់ខ្ញុំ ធ្វើចិត្តខ្ញុំឱ្យសុខសាន្តបាន ។ ព្រះថេរវីតសោកស្តាប់ព្រះបន្ទូលនេះចប់ហើយ ក៏ហោះតាមអាកាសចេញអំពីក្រុងបាតលិបុត្រទៅកាន់ទីនៃបាត់ទៅ ។

សម័យក្រោយមក ព្រះថេរវីតសោក មានអាពាធជាទម្ងន់ ដរាបដល់ជ្រុះព្រះកេសាអស់រលីង, ព្រះរាជាបានជ្រាប ក៏បញ្ជូនវេជ្ជបណ្ឌិតឱ្យទៅព្យាបាលបានជា ដុះព្រះកេសាដូចដើមវិញ លោកនិមន្តទៅគង់ក្នុងព្រៃស្បាត ក្បែរលំនៅអ្នកគង្វាលពពែម្នាក់ ។

សម័យបន្ទាប់មកទៀត ពួកនិគ្រន្ថក្នុងប្រទេសបុណ្ឌ-វឌ្ឍនៈ បានប្រមាថមើលងាយព្រះពុទ្ធរូប វាយបំបែកបំបាក់ លុប កោស កែ ធ្វើជារូបនិគ្រន្ថជាទីគោរពរបស់ខ្លួនវិញ ។ ពួកឧបាសកជាពុទ្ធសាសនិក បានក្រាបបង្គំរឿងនោះចំពោះព្រះបាទធម្មាសោក ។ ទ្រង់ព្រះពិរោធជាខ្លាំង ចាត់ពួកយក្សនាគដែលនៅក្នុងអំណាចព្រះអង្គ ឱ្យទៅចាប់សម្លាប់ពួកនិគ្រន្ថអស់ចំនួន ១ ម៉ឺន ៨ ពាន់នាក់ ។

ចំណែកក្នុងក្រុងបាតលិបុត្រ ក៏មានពួកនិគ្រន្ថប្រមាថមើលងាយចំពោះព្រះពុទ្ធដូច្នោះដែរ. ព្រះបាទធម្មា-សោក បានឱ្យពេជ្ឈឃាត ចាប់ពួកនិគ្រន្ថទាំងអស់នោះ ព្រមទាំងគ្រួសារ មកដុតទាំងរស់វិនាសអស់ឥតសល់ ទើបទ្រង់ប្រកាសថា បើអ្នកណាចាប់បានកាត់ក្បាលនិគ្រន្ថបានមួយអ្នកនោះ ត្រូវបានរង្វាន់ជាមាសឆ្តោរ ១ ដុំ ។

ក្នុងពេលនោះឯង ព្រះថេរវីតសោក មានអាពាធទៀត បានទៅសុំសំណាក់ក្នុងផ្ទះនិគ្រន្ថម្នាក់ លោកមានត្រៃចីវរដាច់ដាចរយីករយាក ព្រះកេសាវែងមើលច្រឡំស្មានថាពួកនិគ្រន្ថ. ពួកអ្នកលេងបានឃើញហើយ ក៏ងារដាវឡើងបម្រុងកាត់ព្រះសិរយកមកដូរយកមាសឆ្តោរ. លោកបាន

រំពឹងឃើញបុព្វកម្មរបស់លោកពីអតីតជាតិ ក៏គង់នៅស្ងៀម ឱ្យគេកាត់ព្រះសិរនោះមកថ្វាយព្រះបាទធម្មាសោក ដូរយក រង្វាន់មាសផ្កោរ. ព្រះរាជាបានស្គាល់ជាក់ជាព្រះសិរ វីតសោក និងបានជ្រាបអំពីពួកសេនាបតីក្រាបបង្គំទូលថា មានគេសម្លាប់សមណសក្យបុត្តិយ៍ ដោយការភាន់ច្រឡំ ច្រើនណាស់យ៉ាងនេះហើយ ទ្រង់សោយសោកសន្ធប់ព្រះ ស្មារតីដួលទៅលើផែនដី. លុះមានព្រះស្មារតីវិញ ទ្រង់ហាម ថា ចាប់ពីថ្ងៃនេះទៅ មិនត្រូវជនណាសំលាប់សមណៈទៀត ឡើយ ។

ពួកភិក្ខុសង្ឃក្នុងពេលនោះ មានការសោកស្ដាយ ចំពោះព្រះថេរវីតសោក បាននាំគ្នាទៅថ្វាយបង្គំ សួរព្រះ មហាថេរឧបគុត្តថា ព្រះថេរៈវីតសោក លោកបានធ្វើកម្មអ្វី ពីជាតិមុន ទើបជាតិនេះត្រូវជនពាលកាត់ព្រះសិរដូច្នេះ ។

ព្រះមហាថេរ ជាព្រះអរហន្តទ្រង់ញាណ បាន ដំណាលរឿងប្រាប់ភិក្ខុទាំងនោះថា ក្នុងកាលកន្លងទៅ ហើយ មានព្រានម្រឹគម្នាក់ បានទៅដាក់អន្ទាក់ក្បែរមាត់ទឹក មានព្រះបច្ចេកពុទ្ធមួយអង្គ ត្រឡប់ពីបិណ្ឌបាតវិញ បានចូល ទៅក្នុងព្រៃ ឈប់សម្រាកក្រោមម្លប់ឈើមួយ ក្បែរអន្ទាក់

នោះ ព្រានបានទៅមើលអន្ទាក់មិនឃើញមានជាប់ម្រឹគសោះ ក៏គិតថាទីនេះ មានម្រឹគច្រើនណាស់ ហេតុអ្វីបានជាមិនជាប់អន្ទាក់អញ គិតផងដើរផង ស្រាប់តែឃើញព្រះបច្ចេកពុទ្ធកំពុងសម្រាកក្រោមម្លប់ឈើ ក៏កើតទោសៈ ហូតដាវឡើង កាត់ព្រះសិរព្រះបច្ចេកពុទ្ធនោះបរិនិព្វានទៅ ដោយហេតុប្រកាន់ថា មកពីលោកទៅគង់ក្នុងទីនោះ ទើបផ្អើលម្រឹគអស់ ។

ព្រានម្រឹគនោះ គឺព្រះថេរីតសោកនេះឯង ដោយឃាតកម្មចំពោះព្រះបច្ចេកពុទ្ធ ព្រានបានទៅសោយទុក្ខក្នុងនរកជាច្រើនកោដិកប្ប សេសសល់ផលកម្ម បានត្រូវគេកាត់ក្បាលដោយដាវជាច្រើនជាតិ ដរាបមកដល់បច្ឆិមជាតិនេះ ក៏ត្រូវបរិនិព្វានដោយគេកាត់ព្រះសិរទៀត ។

ចំណែកខាងគុណសម្បត្តិ ដែលព្រះថេរីតសោកបានកើតក្នុងត្រកូលខ្ពង់ខ្ពស់ និងបានសម្រេចព្រះអរហត្ត-ផលនោះគឺ ក្នុងកាលកន្លងទៅហើយ ក្នុងសាសនាព្រះពុទ្ធកស្សបៈ លោកជាជនមួយរូបមានសទ្ធាចំពោះពុទ្ធសាសនាបានធ្វើបិណ្ឌបាតទាន ចាត់ចែងធ្វើទឹកបាន ដោយផ្លែឈើផ្សេងៗ ប្រគេនចំពោះភិក្ខុសង្ឃដោយសេចក្ដីគោរព និង

បានបួសជាភិក្ខុសង្ឃ ប្រព្រឹត្តព្រហ្មចរិយាធម៌អស់ ១ សែន ឆ្នាំ ដោយផលបុណ្យនេះឯង ដែលលោកបានកើតក្នុងត្រកូលខ្ពង់ខ្ពស់ផង បានសម្រេចព្រះអរហត្តផលផង ។

## ៥- រឿងសុភមាណព

(ចាក ចូ. ម.)

(សកម្មភាពនៃកម្មចែកសត្វក្នុងពិភពលោក)

សម័យមួយព្រះបរមគ្រូ គង់ក្នុងវត្តជេតពន, សុភមាណព ជាកូនរបស់តោទេយ្យព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសួរ អំពីហេតុបច្ច័យនៃកម្មចែកសត្វក្នុងពិភពលោកថា :

បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យដែលនាំឱ្យពួកមនុស្សមានសេចក្ដីថោកទាប និងខ្ពង់ខ្ពស់ ព្រោះថា :

- មនុស្សខ្លះ មានអាយុខ្លី
- មនុស្សខ្លះ មានអាយុវែង
- មនុស្សខ្លះ មានជម្ងឺច្រើន
- មនុស្សខ្លះ មានជម្ងឺតិច
- មនុស្សខ្លះ មានសម្បុរអាក្រក់
- មនុស្សខ្លះ មានសម្បុរល្អ
- មនុស្សខ្លះ មានសក្តិតូច
- មនុស្សខ្លះ មានសក្តិធំ

- មនុស្សខ្លះ មានភោគសម្បត្តិតិច
- មនុស្សខ្លះ មានភោគសម្បត្តិច្រើន
- មនុស្សខ្លះ មានត្រកូលទាប
- មនុស្សខ្លះ មានត្រកូលខ្ពស់
- មនុស្សខ្លះ មានប្រាជ្ញាតិច
- មនុស្សខ្លះ មានប្រាជ្ញាច្រើន ។

ព្រះសម្ពុទ្ធសម្តែងប្រាប់ សុភមាណពថា :

កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ ។

ប្រែថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក កម្មតែងចែកសត្វទាំងឡាយឱ្យថោកទាប និងឱ្យខ្ពង់ខ្ពស់ក្នុងលោក ។

សុភមាណពស្តាប់មិនបាន ទើបទូលសូមឱ្យព្រះសម្ពុទ្ធ សម្តែងវែកញែកឱ្យបានពិស្តារ ។ ព្រះសម្ពុទ្ធទ្រង់សម្តែងថា ម្នាលមាណព បើដូច្នោះ ចូរអ្នកយកចិត្តទុកដាក់ស្តាប់ចុះ តថាគតនឹងសម្តែង. មាណពទទូលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។

ព្រះសម្ពុទ្ធ ត្រាស់សម្តែងវែកញែក ចែកតាមកម្ម របស់សត្វលោកថា :

- អ្នកមានអាយុខ្លី ព្រោះការសម្លាប់មនុស្សសត្វ
- អ្នកមានអាយុវែង ព្រោះការមិនសម្លាប់មនុស្សសត្វ
- អ្នកមានជម្ងឺច្រើន ព្រោះការបៀតបៀនមនុស្សសត្វ
- អ្នកមានជម្ងឺតិច ព្រោះការមិនបៀតបៀនមនុស្សសត្វ
- អ្នកមានសម្បុរអាក្រក់ ព្រោះមានសេចក្តីក្រោធខឹងច្រើន
- អ្នកមានសម្បុរល្អ ព្រោះមិនមានសេចក្តីក្រោធខឹង
- អ្នកមានសក្តិតូច ព្រោះសេចក្តីច្រណែនអ្នកដទៃ
- អ្នកមានសក្តិធំ ព្រោះមិនមានសេចក្តីច្រណែន
- អ្នកមានភោគសម្បត្តិតិច ព្រោះមិនធ្វើទាន
- អ្នកមានភោគសម្បត្តិច្រើន ព្រោះបានធ្វើទាន
- អ្នកមានត្រកូលទាប ព្រោះមានការមើលងាយគេ
- អ្នកមានត្រកូលខ្ពស់ ព្រោះមិនមានការមើលងាយ
- អ្នកមានប្រាជ្ញាតិច ព្រោះមិនសាកសួរ (មិនសិក្សា)
- អ្នកមានប្រាជ្ញាច្រើន ព្រោះមានការសាកសួរ (បានសិក្សា) ។

លទ្ធផលនៃអំពើទាំងអស់នេះ ជាសំណល់កម្មដែល សេសសល់ពីការទទួលផល ក្នុងនរកប្រេតតិរច្ឆាន ឬពីស្ថាន សួគ៌. ដល់មកកើតជាមនុស្ស ទើបត្រូវទទួលផលបែបនេះ ។

កាលព្រះសម្ពុទ្ធទ្រង់សម្ដែងចប់ហើយ សុភមាណព ក្រាបបង្គំទូលព្រះមានព្រះភាគថា ពិរោះណាស់ ភ្លឺច្បាស់ណាស់ ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរលឹក. សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសក អ្នកដល់នូវសរណៈរស្មីដោយជីវិត ចាប់ផ្ដើមអំពីថ្ងៃនេះតរៀងទៅ ។

## ៦- រឿងព្រះអង្គម្ចាស់ក្សត្រីសុប្បវាសា

(ចាក ធ. ខុ.)

( ម្ដាយនិងកូនបើមានចេតនាក្នុងកម្ម ណារួមគ្នា តែងបានផលនៃកម្មនោះរួមគ្នាដែរ )

ក្នុងសម័យពុទ្ធកាល មានព្រះអង្គម្ចាស់ក្សត្រីមួយព្រះអង្គ ព្រះនាមសុប្បវាសា ជារាជធីតាព្រះចៅក្រុងកោលិយៈ។ ព្រះនាងមានព្រះរាជបុត្រមួយអង្គ ព្រះនាមសីវលិ ជាទីសព្វព្រះទ័យក្រៃលែង ។

មានរឿងដំណាលថា កាលសីវលិរាជកុមារ មកចាប់បដិសន្ធិ បានញុំាងព្រះវរមាតា ឱ្យបាននូវលាភសក្ការៈយ៉ាងច្រើន ។ ប៉ុន្តែកម្មអកុសល ដែលបានធ្វើរួមគ្នាជាមួយបុត្រពីអតីតជាតិ ក៏មកផ្ដល់នូវទុក្ខវេទនាឱ្យដែរ គឺព្រះនាងមានគភ៌យូរណាស់ដល់ទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបប្រសូត្រសីវលិកុមាររួច, កាលមានគភ៌គ្រប់ ៧ ឆ្នាំ ៧ ខែហើយចាប់ឈឺព្រះឧទរ ប៉ុន្តែប្រសូត្រមិនរួចសោះ ព្រោះទារកធ្លាក់មកនៅទទឹងទ្វារមាស ស្ទះមូត្រ លាមក អស់ ៧ ថ្ងៃ សោយទុក្ខវេទនាយ៉ាងខ្លាំងក្រៃលែង. ដល់ថ្ងៃទី ៧ ស្រាប់តែប្រសូត្រងាយដូចគេចាក់ទឹកចេញពីក្អម. ប្រសូត្របាន ៧ ថ្ងៃ ទារក

នោះចេះនិយាយស្តី ដឹងកិច្ចការសព្វគ្រប់ ដូចមនុស្សចាស់. ដោយហេតុនេះ ព្រះញាតិវង្សានុវង្ស បានថ្វាយនាមថា សីវលិកុមារ ។

សីវលិកុមារ កាលមានវ័យចម្រើនហើយ បានចេញបួសក្នុងសម្នាក់សារីបុត្ត ។ បានទទួលទានឱ្យពិចារណាអំពីទុក្ខលក្ខណៈ ។ ក្នុងពេលដាក់កាំបិតកោរព្រះកេសា ១ កាំបិតដំបូង បានសម្រេចសោតាបត្តិផល. កោរ ១ កាំបិតទៀតជាលើកទី ២ បានសម្រេចសក្ទទាមិផល. កោរ ១ កាំបិតទៀតជាលើកទី ៣ បានសម្រេចអនាគាមិផល ។ ក្នុងពេលកោរព្រះកេសាហើយស្រេច បានសម្រេចព្រះអរហត្តផលជាព្រះអរហន្តមួយអង្គក្នុងពុទ្ធសាសនា ។

ព្រះសីវលិត្ថេរអង្គនេះ លោកមានអធ្យាស្រ័យល្អប្រកបដោយសង្គហធម៌ធំទូលាយណាស់គាប់ចិត្ត នាំភិក្ខុសង្ឃរាប់រយរាប់ពាន់អង្គ ឱ្យធ្វើដំណើរទៅទីផ្សេង ៗ ជាមួយលោក ដើម្បីជួយទំនុកបំរុង ឱ្យបានសុខស្រួលបរិបូណ៌ដោយបច្ច័យទាំង ៤ ព្រោះលោកជាអ្នកបរិបូណ៌ដោយមហាលាភសក្ការៈ ជាឯតទគ្គៈ ខាងអ្នកមានលាភច្រើនបំផុតសូម្បីព្រះសម្ពុទ្ធ ក៏បានទទួលលាភសក្ការទិព្វរបស់លោក

ចំនួន ៣ ខែដែរ ។ ក្នុងពេលដែរលោកនិមន្តតាមព្រះសាស្តា យាងទៅកាន់សម្នាក់ ខទិរវនិយរេវតភិក្ខុ ជាប្អូនពៅរបស់ព្រះសារីបុត្ត ក្នុងព្រៃគីរអស់ចម្ងាយផ្លូវ ៣០ យោជន៍ ។

ក្នុងពេលនោះ ផលបុណ្យដែលព្រះសីវលិត្ថេរបានធ្វើហើយ ក្នុងអតីតជាតិ បានផ្តល់មហាលាភសក្ការៈសម្បើមអស្ចារ្យណាស់ដល់លោក គឺមានពួកទេវតានិម្មិតធ្វើជាវត្តអារាមចំនួន ៣០ វត្ត ពីវត្តមួយទៅវត្តមួយ មានចម្ងាយ ១ យោជន៍, ក្នុងវត្តមួយៗ បរិបូណ៌ដោយបច្ច័យ ៤ ជាទិព្វដែលទេវតានាំមកប្រគេន ។

ព្រះបរមគ្រូ ព្រមទាំងភិក្ខុសង្ឃ ៥០០ អង្គបានឈប់សម្រាកគ្រប់វត្តទាំង៣០ ឆាន់ប្រើប្រាស់វត្ថុទិព្វយ៉ាងបរិបូណ៌ដរាបយាងទៅដល់ព្រៃគីរ ។ កាលគង់នៅក្នុងព្រៃគីរនោះ ១ ខែ, ព្រះសម្ពុទ្ធ និងភិក្ខុសង្ឃ ៥០០ អង្គ ក៏បានឆាន់ចង្ហាន់ទិព្វរាល់ថ្ងៃ ដោយសារបុណ្យលោកទៀត, ដល់ព្រះសម្ពុទ្ធយាងត្រឡប់វិញ ក៏បានទទួលលាភសក្ការទិព្វដូចកាលយាងទៅដែរ ។

កាលព្រះសម្ពុទ្ធយាងមកដល់ក្រុងសាវត្ថី, ពួកភិក្ខុទាំងឡាយ បានក្រាបថ្វាយបង្គំទូលសួរ បុព្វកម្មរបស់ព្រះ

សិវលិត្ថេរ. ព្រះអង្គសម្ដែងថា :

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនាព្រះពុទ្ធវិបស្សី រាប់ពីភទ្ទកប្បនេះទៅចំនួន ៩១ កប្ប ។ កាលនោះព្រះរាជាជាពុទ្ធបិតាព្រះពុទ្ធវិបស្សី បានចាត់ចែងធ្វើអាគន្តុកទាន បានហៅអ្នកនគរឱ្យមកអនុមោទនាទានរបស់ព្រះអង្គ ។

អ្នកនគរបានឃើញទាននោះហើយ មានចិត្តជ្រះថ្លាលើសលប់ បានជំនុំគិតគ្នាថា ពួកយើងត្រូវរួមគ្នាធ្វើទានម្ដងឱ្យបានលើសជាងទានព្រះរាជា. ក៏ចាត់ចែងទាននោះឡើងទៅនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានក្រាបបង្គំទូលយាងព្រះរាជា មកជាអធិបតីក្នុងពិធីបុណ្យនោះផង។

ព្រះរាជា បានសព្វព្រះរាជហឫទ័យយាងទៅក្នុងពិធីបុណ្យនោះ ទតឃើញមហាជនចាត់ចែងបុណ្យលើសលប់ជាងព្រះអង្គ ក៏មានព្រះទ័យជ្រះថ្លា. ព្រឹកឡើងបានចាត់ចែងទានឱ្យលើសអ្នកនគរទៅទៀត ។ ការធ្វើទានប្រណាំងប្រជែងគ្នារបៀបនេះអស់វារៈ ៦ លើកមិនមានអ្នកណាចាញ់ឈ្នះឡើយ ។

ក្នុងលើកទី ៧ ពួកអ្នកនគរ គិតគ្នាថា យើងឱ្យទានក្នុងថ្ងៃស្អែក ត្រូវឱ្យមានវត្ថុគ្រប់មុខ កុំឱ្យខ្វះមុខណាឡើយ.

ព្រឹកឡើង បានប្រមូលទេយ្យទានមកពិនិត្យមើល ឃើញនៅខ្វះផ្ទិតឃ្មុំស្រស់ ក៏ប្រែប្រាក់គ្នាបាន ៤ ពាន់កហាបណៈ ឱ្យមនុស្ស ៤ នាក់ចេញទៅរកទិញ ឱ្យបានទាន់ក្នុងពេលថ្ងៃត្រង់ ។ អ្នកទាំង ៤ ទៅដល់ជនបទមួយក្រៅក្រុង បានជួបបុរសម្នាក់កាន់ផ្ទិតឃ្មុំស្រស់ ១ បម្រុងយកទៅជូនចៅសង្កាត់របស់ខ្លួន ។ អ្នកទិញឃ្មុំបានឱ្យថ្លៃដេញឡើងរហូតដល់ ១ ពាន់កហាបណៈ. អ្នកមានឃ្មុំ មិនព្រមលក់ បានសួរគ្នាថា អ្នករាល់គ្នាឆ្កួតទេឬ ? មិនដែលមានឃ្មុំ ១ ផ្ទិតថ្លៃ ១ ពាន់កហាបណៈឡើយ. តើអ្នកត្រូវការផ្ទិតឃ្មុំយកទៅធ្វើអ្វី?

អ្នកទិញឃ្មុំ បាននិយាយប្រាប់តាមដំណើរការណ៍ដែលខ្លួនបានចាត់ចែងធ្វើមហាទានឱ្យអ្នកមានឃ្មុំស្តាប់ ។

អ្នកមានឃ្មុំ មានចិត្តជ្រះថ្លាព្រឺរោមព្រឺស្បែក និយាយសុំចូលរួមធ្វើបុណ្យជាមួយផង ។ អ្នកមានឃ្មុំ ឈប់យកផ្ទិតឃ្មុំនោះទៅជូនចៅសង្កាត់របស់ខ្លួន ក៏កាន់ផ្ទិតឃ្មុំដើរតាមអ្នកទិញឃ្មុំសំដៅទៅរោងបុណ្យ. លុះទៅដល់ហើយ អ្នកនគរមានចិត្តត្រេកអរ បានយកភាជន៍មាសយ៉ាងធំមួយ មកឱ្យដាក់ឃ្មុំនោះ ។ ម្ចាស់ឃ្មុំក៏លើកភាជន៍នោះ ប្រគេនព្រះពុទ្ធវិបស្សី ព្រមទាំងភិក្ខុសង្ឃទាំងអស់. ដោយអានុភាព

របស់ព្រះសម្ពុទ្ធ ទឹកឃ្មុំក្នុងភាជន៍នោះមិនចេះអស់សោះ ចេះតែមានទឹកហូរចេញ អំពីក្បាលថ្និតឃ្មុំជានិច្ចដូចជាអណ្តូងទឹក ។

ដោយបុញ្ញកម្មនេះ នៅពេលដែលម្ចាស់ឃ្មុំអស់អាយុសង្ខារហើយ បានទៅកើតក្នុងមនុស្សលោក និងទេវលោក សោយនូវសេចក្តីសុខអស់កាលជាយូរអង្វែង ។

សម័យមួយម្ចាស់ឃ្មុំនោះ បានមកកើតជាព្រះរាជបុត្រព្រះចៅក្រុងពារាណសី, លុះអំណើះតតអំពីរាជបិតាទៅ ក៏បានសោយរាជ្យសម្បត្តិ គង់ជាសុខក្នុងសិរីរាជសម្បត្តិ ជាមួយព្រះវរមាតា ។

ជាធម្មតារបស់សត្វលោក មិនចេះឆ្អែតស្កប់ស្កល់ដោយទ្រព្យ លាភយសឡើយ ចេះតែចង់បានថែមទៀត គ្មានទីបំផុត, ទើបព្រះចៅក្រុងពារាណសីថ្មីអង្គនេះ បានទៅឡោមព័ទ្ធនគរមួយយកជាចំណុះព្រះអង្គ, បានចាត់យោធាឱ្យបិទទ្វារធំ ៦ របស់នគរនោះទាំងអស់ មិនឱ្យអ្នកនគរចេញចូលបានអស់ ៧ ឆ្នាំ ៧ ខែ ប៉ុន្តែ ព្រះរាជានគរនោះមិនព្រមចុះចាញ់សោះ ។

ចំណែកព្រះវរមាតាបានជ្រាបថា ក្នុងនគរនោះនៅ

មានទ្វារតូចៗ ៤ ទៀត ដែលអ្នកនគរតែងលួចចេញចូលយកស្បៀងអាហារ. ក៏ប្រើរាជបម្រើទៅថ្វាយដំណឹងចំពោះព្រះរាជបុត្រឱ្យបិទទ្វារតូចៗ នោះទៀត។ ព្រះរាជាឱ្យយោធាទៅបិទតាមព្រះរាជសវនីយមាតា. អ្នកនគរចេញចូលមិនបានជិតដាច់ពោះស្លាប់ហើយ ក៏នាំគ្នាធ្វើគត់ព្រះរាជាខ្លួនចោលលើករាជសម្បត្តិថ្វាយព្រះចៅក្រុងពារាណសីនោះទៅ ។

ដល់ទីបំផុតនៃព្រះជន. ព្រះចៅក្រុងពារាណសី បានទៅឆេះក្នុងនរកអវចី ជាមួយព្រះវរមាតាជាច្រើនឆ្នាំ. សេសសល់ផលកម្មនោះ ព្រះវរមាតា បានមកកើតជាព្រះនាងសុប្បវ៉ាសា. ព្រះចៅក្រុងពារាណសី បានមកកើតជាព្រះសិវលិកុមារ ត្រូវរងទុក្ខវេទនានៅក្នុងគភ៌អស់ ៧ ឆ្នាំ ៧ ខែ. ព្រះមាតាត្រូវរងទុក្ខខ្លាំង ស្ទះឡូវ មូត្រ លាមក អស់ ៧ ថ្ងៃ ដោយផលដែលបញ្ជាឱ្យរាជបុត្របិទទ្វារតូច ៗ ទាំង ៤ នោះឯង ។

ចំណែកខាងព្រះសីវលិត្ថេរ ដែលបរិបូណ៌ដោយលាភសក្ការៈយ៉ាងច្រើនអស្ចារ្យ និងបានសម្រេចមគ្គផលធាប់នោះ ដោយបុណ្យដែលបានប្រគេនទឹកឃ្មុំក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ។

## ៧- រឿងទេពធីតា ២៥ រូប

(ចាក វិ. ខុ.)

(អនុក់ ១ ក្ដាប់របស់ស្ត្រីមានសទ្ធាអាចដូរយកសម្បត្តិសួគ៌បាន)

សម័យមួយព្រះមហាមោគ្គល្លាន បាននិមន្តទៅឋានត្រៃត្រឹង្សទេវលោក បានឃើញវិមានប្រាសាទ និងរូបឆោមពន្លឺរស្មីរបស់ទេពធីតាទាំង ២៥ រូប ដែលមានទីលំនៅជិតៗគ្នា ក៏ចូលទៅក្នុងទេវសង្កាត់នោះ. ពួកទេពធីតាទាំង ២៥ រូប បានឃើញព្រះមោគ្គល្លានហើយ ក៏នាំគ្នាទៅថ្វាយបង្គំរួចស្ថិតនៅក្នុងទីសមគួរ. ទើបព្រះមហាមោគ្គល្លានសួរថា ម្នាលទេពធីតាទាំងឡាយ នាងមានសម្បុររុងរឿង ញ៉ាំងទិសទាំងពួង ឱ្យភ្លឺស្វាងដូចផ្កាយព្រឹក នាងបរិបូណ៌ដោយភោគៈ គឺវត្ថុទិព្វទាំង ១០ យ៉ាង តើនាងបានធ្វើបុណ្យអ្វីក្នុងជាតិមុន ?

ទេពធីតាទី ១ ឆ្លើយថា យើងខ្ញុំទាំងអស់គ្នា បានឃើញភិក្ខុនិមន្តទៅបិណ្ឌបាតក្នុងភូមិ មានសេចក្ដីជ្រះថ្លា បានប្រគេនស្ករអំពៅបន្តិច ។

ទេពធីតាទី ២ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្លែទម្លាប់មួយ ។

- ទេពធីតាទី ៣ មានសេចក្ដីជ្រះថ្លា បានប្រគេនអំពៅ ១ កំណាត់ ។

- ទេពធីតាទី ៤ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្លែត្រសក់១

- ទេពធីតាទី ៥ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្លែ ល្ពៅ ១

- ទេពធីតាទី ៦ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្លែត្រសក់ស្រូវ ១ ។

- ទេពធីតាទី ៧ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្លែមាក់ប្រាំងមួយ ។

- ទេពធីតាទី៨ មានសេចក្ដីជ្រះថ្លា បានប្រគេនចង្ក្រានកំដៅដៃ ១ ។

- ទេពធីតាទី៩ មានសេចក្ដីជ្រះថ្លា បានប្រគេនអន្ទក់១ ក្ដាប់

- ទេពធីតាទី១០ មានសេចក្ដីជ្រះថ្លា បានប្រគេនផ្កា ១ ក្ដាប់

- ទេពធីតាទី១១ មានសេចក្ដីជ្រះថ្លា បានប្រគេនមើមដំឡូង ១ ដុំ ។

- ទេពធីតាទី ១២ មានសេចក្ដីជ្រះថ្លា បានប្រគេនស្លឹកស្ពៅ ១ ក្ដាប់ ។

- ទេពធីតាទី១៣ មានសេចក្ដីជ្រះថ្លា បានប្រគេនជ្រក់ស្វាយបន្តិច ។

- ទេពធីតាទី ១៤ មានសេចក្តីជ្រះថ្លា បានប្រគេនល្ងបុក បន្តិច ។

- ទេពធីតាទី ១៥ មានសេចក្តីជ្រះថ្លា បានប្រគេនវត្ថុពន្លចង្កេះ ១ ។

- ទេពធីតាទី១៦ មានសេចក្តីជ្រះថ្លា បានប្រគេនយោគបាត្រមួយ ។

- ទេពធីតាទី ១៧ មានសេចក្តីជ្រះថ្លា បានប្រគេនស្បោងបាត្រ ១ ។

- ទេពធីតាទី ១៨ មានសេចក្តីជ្រះថ្លា បានប្រគេនផ្ចិត ៤ ជ្រុង មួយ ។

- ទេពធីតាទី ១៩ មានសេចក្តីជ្រះថ្លា បានប្រគេនផ្ចិតស្លឹកត្នោត ១ ។

- ទេពធីតាទី ២០ មានសេចក្តីជ្រះថ្លា បានប្រគេនផ្ចិតកន្ទុយក្ងោក ១ ។

- ទេពធីតាទី ២១ មានសេចក្តីជ្រះថ្លា បានប្រគេនធ័ត្រ ១ ។

- ទេពធីតាទី ២២ មានសេចក្តីជ្រះថ្លា បានប្រគេនស្បែកជើង ១ សម្រាប់ ។

- ទេពធីតាទី២៣ មានសេចក្តីជ្រះថ្លា បានប្រគេននំ១ ។

- ទេពធីតាទី ២៤ មានសេចក្តីជ្រះថ្លា បានប្រគេនត្រប៉ែបន្តិច ។

- ទេពធីតាទី ២៥ មានសេចក្តីជ្រះថ្លា បានប្រគេននំក្រៀបមួយ ។

ទេពធីតាទាំង ២៥ រូបបានប្រាប់បុញ្ញកម្មរបស់ខ្លួន ៗ ដូច្នេះហើយ បាននិយាយចំពោះព្រះមហាមោគ្គល្លានថា សូមលោកម្ចាស់មើលទិព្វវិមានរបស់យើងខ្ញុំចុះ យើងខ្ញុំជាស្រីអប្សរ មានសម្បុរជាទីប្រាថ្នា មានបរិវារម្នាក់ ១ ពាន់រូបចោមរោមបម្រើ នេះជាផលបុញ្ញកម្មនោះឯង ។

ព្រះមហាមោគ្គល្លាន បានជ្រាបពត៌មាននេះសព្វគ្រប់ហើយ ក៏និមន្តចាត់អំពីទីនោះទៅ ។

## ៨- រឿងចៅអធិការវត្តឈ្មោះធម្មិកៈ

(ចាក អ. ធ.)

(ទោសនៃការជេរប្រទេចបៀតបៀនអាគន្តុកភិក្ខុ)

សម័យមួយព្រះសម្ពុទ្ធ គង់លើភ្នំគិជ្ឈកូដ ក្បែរក្រុងរាជគ្រឹះ. មានចៅអធិការវត្តមួយអង្គឈ្មោះ ធម្មិកៈ ជាមនុស្សកាច រអ៊ូរទាំច្រើន តែងជេរប្រទិចបៀតបៀននិយាយចាក់ដោតកោសរួស នូវពួកអាគន្តុកភិក្ខុ ដែលចូលមកសុំនៅក្នុងវត្តជាមួយ ។ ភិក្ខុសាមណេរ ទ្រាំមិនបានក៏រត់ចេញពីវត្តអស់ ។

ពួកឧបាសកជើងវត្តបានជំនុំគ្នាថា យើងខំផ្គត់ផ្គង់ភិក្ខុសាមណេរក្នុងវត្តដោយបច្ច័យ ៤ មិនដែលឱ្យខ្វះកន្លះ. ហេតុអ្វីបានជាភិក្ខុសាមណេរ មិនចង់នៅក្នុងវត្តរបស់យើង ប្រហែលជាលោកគ្រូចៅអធិការបៀតបៀនហើយ ? កាលបើស៊ើបសួរបានដឹងច្បាស់ថា ភិក្ខុសាមណេរទាំងអស់ ដែលរត់ចេញពីវត្តទៅ ព្រោះលោកគ្រូចៅអធិការ ជេរប្រទិចបៀតបៀន មិនឱ្យទ្រាំនៅបាន ដូច្នោះហើយ ក៏នាំគ្នាដេញលោកគ្រូចៅអធិការចេញពីវត្តនោះទៅ ។

ចៅអធិការធម្មិកៈ ដឹងថាពួកឧបាសកជើងវត្តនោះ

គេមិនត្រូវការខ្លួនហើយ ក៏ចេញទៅធ្វើចៅអធិការវត្តមួយទៀត ។ មិនយូរប៉ុន្មាន ភិក្ខុសាមណេរក្នុងវត្តនោះ ត្រូវចៅ-អធិការធម្មិកៈ ជេរប្រទិចប្រៀតប្រៀន, ទ្រាំនៅជាមួយមិនបាន ក៏នាំគ្នាចេញពីវត្តអស់ទៅ ។ ពួកឧបាសកជើងវត្តដឹងដូច្នោះ ក៏ដេញចៅអធិការធម្មិកៈចេញពីវត្តនោះទៀត ។

លោកគ្រូចៅអធិការធម្មិកៈ ត្រូវឧបាសកឧបាសិកាជើងវត្តដេញយ៉ាងនេះអស់ ៧វត្ត ព្រោះតែលោកជេរប្រទិចប្រៀតប្រៀនភិក្ខុសាមណេរ ដែលចូលមកសុំសម្នាក់នៅជាមួយ ។ ក្នុងពេលដែលគេដេញចេញពីវត្តទី ៧ នេះលោកមានសេចក្តីត្រិះរិះថា ពេលនេះអញត្រូវចូលទៅរកព្រះសម្ពុទ្ធបរមគ្រូវិញទើបបានសុខ, បើនៅតែធ្វើចៅអធិការវត្តតទៅទៀត នឹងត្រូវគេដេញឱ្យចេញពីវត្តទៀតមិនខាន, លុះគិតដូច្នេះហើយ ក៏ប្រមូលបាត្រចីវរដើរសំដៅទៅក្រុងរាជគ្រឹះ ចូលទៅថ្វាយបង្គំព្រះសាស្តានៅលើភ្នំគិជ្ឈកូដ ។

ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលធម្មិកៈ អើ ! អ្នកមកពីណាហ្នឹង ?

- បពិត្រព្រះបរមគ្រូ ខ្ញុំព្រះអង្គត្រូវឧបាសកឧបាសិកាជើងវត្តបណ្តេញចេញអំពីវត្តទាំង ៧ ដែលទូលព្រះបង្គំបាន

បានធ្វើចៅអធិការ ។

- ណ្ហើយ ! ធម្មិកៈ អ្នកឯងគ្មានប្រយោជន៍ក្នុងការធ្វើចៅអធិការទេ, ទាល់តែពួកឧបាសកដេញវត្តទាំង ៧ វត្ត គេដេញ ទើបអ្នកឯងមករកតថាគត ។

ព្រះបរមគ្រូមានព្រះបន្ទូលដូច្នេះហើយ ក៏នាំអតីតនិទានមកសម្ដែងប្រាប់ចៅអធិការធម្មិកៈនោះថា :

ម្នាលធម្មិកៈ កាលពីព្រេងនាយ មាននាយសំពៅម្នាក់បានចាប់សត្វស្វាបបង្ហាញត្រើយយកទៅជាមួយ សំរាប់បង្ហាញត្រើយ, លុះទៅដល់កណ្ដាលសមុទ្រ មើលកោះត្រើយមិនឃើញហើយក៏លែងសត្វនោះទៅ ឱ្យវាបង្ហាញត្រើយ ។ សត្វនោះបានហើរទៅគ្រប់ទិស, បើឃើញត្រើយនៅទិសណា វាហើរទៅទិសនោះ, នាយសំពៅក៏បើកនាវាតាមទៅទិសនោះ, បើសត្វនោះហើរទៅរកមើលត្រើយមិនឃើញទេ វាក៏ហើរមករកសំពៅវិញ ។ ម្នាលធម្មិកៈ ខ្លួនអ្នកឯងក៏ដូច្នោះដែរ ទាល់តែគេដេញចេញគ្រប់វត្តទាំង ៧ គ្មានទីពឹងហើយ ទើបមករកតថាគតវិញ ។

ម្នាលធម្មិកៈ នៅមានរឿងមួយទៀត, កាលពីព្រេងនាយ មានស្ដេចដើមជ្រៃមួយឈ្មោះ សុប្បតិដ្ឋៈ របស់ព្រះ

រាជាកោរព្យៈ មានមែក ៥ មានម្លប់ត្រជាក់ជាទីរីករាយចិត្ត មានទំហំ ១២ យោជន៍ មានបណ្តាញឫស ៥ យោជន៍ មានផ្លែធំៗ ប៉ុនភាជនៈ ល្មមធ្វើឆ្នាំងចម្អិនភត្តបាន. ផ្លែស្តេចជ្រៃនោះ មានរសផ្អែមដូចទឹកឃ្មុំ ។ ព្រះរាជា និងស្រីស្នំ សោយផ្លែដែលមានក្នុងមែកមួយ, ពួកពលសេនា, ពួកអ្នកនិគមជនបទ, ពួកសាមណព្រាហ្មណ៍ និងពួកម្រឹគបក្សីទាំង ៤ ពួកនេះ បរិភោគផ្លែ ដែលមានក្នុងមែកទាំង ៤ ទៀតរៀងៗខ្លួនមិនច្រឡំគ្នា មិនលួចគ្នាឡើយ ។

កាលនោះមានបុរសម្នាក់ ទៅបេះផ្លែស្តេចជ្រៃនោះស៊ីដរាបដល់ឆ្អែត ហើយកាប់កាច់មែកជ្រៃទាំងនោះទៀត ទើបដើរចេញទៅ ។

រុក្ខទេវតា ដែលនៅលើដើមស្តេចជ្រៃនោះគិតថា យីអើ មនុស្សនេះចំជាបាបចំណាស់តើ មិនគួរឱ្យស្តេចជ្រៃនេះមានផ្លែទៀត, ស្តេចជ្រៃក៏ឈប់ផ្លែតទៅទៀត ។

ព្រះបាទកោរព្យៈ បានជ្រាបថា ស្តេចជ្រៃឈប់ផ្លែហើយ ក៏ទៅប្រាប់ព្រះឥន្ទ ៗ ធ្វើឱ្យដើមជ្រៃនោះ រលំផ្កាប់ផ្ការ ឫសឡើងលើចុងចុះក្រោម ដោយអំណាចខ្យល់ព្យុះដែលកើតពីទេវានុភាព ។

ទេវតារត់ចេញស្រែកទូញយំ កើតទុក្ខព្រោះអត់ទីលំនៅ ។

ព្រះឥន្ទសួរថា អ្នកកើតទុក្ខទូញយំ, ព្រោះហេតុអ្វី ?

- បពិត្រលោកម្ចាស់ ព្រោះមានខ្យល់ព្យុះបោកបក់ស្តេចជ្រៃ ជាទីលំនៅរបស់ខ្ញុំ ឱ្យរលំត្រឡប់ មានឫសឡើងលើ ធ្វើឱ្យខ្ញុំឥតទីជម្រក ។

- តើអ្នកបានឋិតនៅក្នុងរុក្ខធម៌ឬទេ ?

- ចុះរុក្ខធម៌នោះដូចម្តេច ?

- ម្នាលទេវតាក្នុងលោកនេះ បើពួកជនត្រូវការដោយឫសឈើ តែងនាំយកឫសទៅ ១, អ្នកត្រូវការដោយសម្បក តែងនាំយកសម្បកទៅ ១, អ្នកត្រូវការដោយស្លឹក តែងនាំយកស្លឹកទៅ ១, អ្នកត្រូវការដោយផ្កា តែងនាំយកផ្កាទៅ ១, អ្នកត្រូវការដោយផ្លែ តែងនាំយកផ្លែទៅ ១, អ្នកមិនត្រូវខឹង អាក់អន់ចិត្តចំពោះអ្នកទាំងនោះឡើយ, នេះឯងឈ្មោះថា រុក្ខធម៌ ។

- បពិត្រលោកម្ចាស់ ខ្ញុំមិនបានឋិតនៅក្នុងរុក្ខធម៌នេះឡើយ ទើបត្រូវខ្យល់បក់បោកស្តេចជ្រៃ ជាលំនៅរបស់ខ្ញុំឱ្យវិនាសអស់ តទៅខ្ញុំរក្សានូវរុក្ខធម៌នេះហើយ ។

- ម្នាលទេវតា បើអ្នកបានរក្សាកុសលធម៌នេះហើយ លំនៅរបស់អ្នកនឹងកើតមានដូចមុនវិញ ។ ព្រះឥន្ទក៏ធ្វើឱ្យដើមស្តេចជ្រៃនោះ មានឫសចុះក្រោមដូចដើមវិញ. ទេវតាក៏បាននៅអាស្រ័យក្នុងដើមជ្រៃនោះតទៅ ។

ព្រះសម្ពុទ្ធសម្តែងអតីតនិទាននេះចប់ហើយ ទ្រង់ត្រាស់ចំពោះចៅអធិការធម្មិកៈថា ម្នាលធម្មិកៈ ក្រែងអ្នកមិនបានឋិតនៅក្នុងធម៌របស់សមណៈទេដឹង ! ទើបឧបាសកជើងវត្តទាំង ៧ វត្ត គេដេញអ្នកឯង ?

ធម្មិកៈទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ចុះសមណៈឋិតនៅក្នុងធម៌របស់សមណៈនោះដូចម្តេច ?

- ម្នាលធម្មិកៈ សមណៈក្នុងសាសនានេះ ត្រូវឋិតនៅក្នុងធម៌ ៣ យ៉ាងគឺ :

១- អក្កោសន្តំ ន បច្ចក្កោសតិ មិនជេរតបបុគ្គល ដែលជេរខ្លួន.

២- រោសន្តំ ន បដិរោសតិ មិនកោសរូសតបបុគ្គលដែលកោសរូសខ្លួន.

៣- ភណ្ឌន្តំ ន បដិភណ្ឌតិ មិនឈ្លោះតបបុគ្គលដែលឈ្លោះនឹងខ្លួន ។

នេះឯង ធម្មិកៈ ! ឈ្មោះថា សមណៈឋិតនៅក្នុងសមណធម៌ ។

. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានឋិតនៅក្នុងសមណធម៌នេះឡើយ ទើបត្រូវឧបាសកជើងវត្តបណ្ដេញទូលបង្គំឱ្យចេញអំពីវត្តទាំង ៧ ។

តមកព្រះសម្ពុទ្ធបានសម្ដែងអំពីគ្រូទាំង ៦ ក្នុងអតីតកាល និងសិស្ស. អំពីទោសនៃការជេរប្រទេចអ្នកដទៃ និងគុណនៃការស្ដាប់ធម៌ ស្ដាប់ឱវាទរបស់គ្រូជាព្រះអរហន្ត និងគ្រូជាបុថុជ្ជនឱ្យធម្មិកៈស្ដាប់ ដើម្បីឱ្យលះបង់គំនិតចរិតចាស់ចោលចេញ ។

## ៩- រឿងព្រះកុមារកស្សប

(ចាក ឆ. ខុ.)

(អ្នកធំបើមិនទាន់ស្គាល់ហេតុផលច្បាស់ផ្ទាល់ខ្លួន មិនគួរនិយាយ មិនគួរវិនិច្ឆ័យឡើយ)

ក្នុងក្រុងរាជគ្រឹះ មានសេដ្ឋីធីតាមួយរូប ជ្រះថ្លាចំពោះពុទ្ធសាសនា បានសុំមាតាបិតាទៅបួសជាភិក្ខុនី, មាតាបិតាមិនព្រមអនុញ្ញាតសោះ ។ លុះដល់សេដ្ឋីធីតានោះមានស្វាមីហើយ ទើបសុំលាស្វាមីទៅបួសបាន ។

សេដ្ឋីធីតា បានទៅបួសក្នុងសម្នាក់ពួកភិក្ខុនី ដែលនៅក្រោមការគ្រប់គ្រងរបស់ភិក្ខុទេវទត្ត ។ តមកភិក្ខុនីនោះមានផ្ទៃពោះកាន់តែធំឡើង, ពួកនាងភិក្ខុនី មានសេចក្ដីរង្កៀសបានចោទថា នាងបួសហើយ មានសាហាយនឹងបុរសណាមួយ មិនគួរឱ្យនៅក្នុងពួកភិក្ខុនីសង្ឃឡើយ ក៏នាំរឿងនោះទៅប្រាប់ទេវទត្ត ។ ហៅភិក្ខុនីនោះទៅវិនិច្ឆ័យតាមពាក្យចោទ ហើយផ្សឹកនាងចេញ ។ ភិក្ខុនីនោះមិនព្រមសឹក បានប្រាប់តាមការពិតថា តាំងពីថ្ងៃបួសមកខ្លួននាងមានសេចក្ដីបរិសុទ្ធ មិនដែលសៅហ្មងឡើយ ។

ភិក្ខុទាំងឡាយ បានដឹងរឿងនោះហើយ ក៏ទៅក្រាប

បង្គំទូលព្រះសម្ពុទ្ធ ។ ត្រាស់បង្គាប់ឱ្យឧបាលិត្ថេរវិនិច្ឆ័យអធិករណ៍នោះ ។

ព្រះឧបាលីបានអញ្ជើញមហាត្រកូលទាំងឡាយ មានមហាឧបាសិកាវិសាខាជាដើម មកប្រជុំពិនិត្យរូបភិក្ខុនីនោះ រកការណ៍ពិត ទីប្រជុំបានរកការពិតឃើញហើយ ប្រគេនដំណឹងព្រះឧបាលីថា ភិក្ខុនីនេះ ចាប់មានផ្ទៃពោះតាំងពីនាងនៅគ្រហស្ថ ដោយការនៅរួមជាមួយស្វាមីនាងម្ល៉េះ ប៉ុន្តែនាងមិនដឹង ទើបសុំស្វាមីមកបួស ។ ព្រះឧបាលី ក៏បានដឹងច្បាស់ដូច្នោះដែរ ព្រោះលោកជាព្រះអរហន្ត ទើបវិនិច្ឆ័យថា សីលរបស់ភិក្ខុនីនេះ បរិសុទ្ធឥតមានមន្ទិលឡើយ ចូរនាងខំប្រព្រឹត្តព្រហ្មចរិយធម៌ចុះ ។

ព្រះបរមសាស្តា ទ្រង់ព្រះសណ្តាប់ការវិនិច្ឆ័យនេះហើយ អនុមោទនាថា ម្នាលឧបាលី អ្នកវិនិច្ឆ័យនេះត្រឹមត្រូវល្អហើយ សមហេតុផលហើយ ។

ឯភិក្ខុនីនោះ លុះមានគតិគ្រប់ខែហើយ ក៏ប្រសូត្របុត្រមួយមក ដោយមានមហាត្រកូលទាំងឡាយ មាននាងវិសាខាជាដើម ជួយចាត់ចែងក្នុងប្រសូត្រកិច្ចនោះ ។ ព្រះបាទបសេនទិកោសល ទ្រង់ឱ្យរាជបម្រើទទួលយកកុមារ

នោះទៅចិញ្ចឹមរក្សា ឱ្យនាមថា កុមារកស្សប ដល់មានវ័យធំឡើង ទើបព្រះអង្គនាំទៅបំបួសក្នុងសម្នាក់ព្រះសាស្តា ។

កុមារកស្សបភិក្ខុនេះ ជាអ្នកសង្វាតព្យាយាមណាស់ លោកបានសិក្សាខាងគន្ថធុរៈផង វិបស្សនាធុរៈផង មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ព្រមដោយចតុប្បដិសម្ភិទាញាណ ដោយអានិសង្សផ្នួសរបស់លោកក្នុងអតីតជាតិ ដែលបានបួសក្នុងសាសនាព្រះពុទ្ធកស្សប. លោកចូលទៅអាស្រ័យនៅក្នុងព្រៃអម្ពវ័ន ។

ព្រះកុមារកស្សបត្ថេរនេះ ជាអ្នកមានសមត្ថភាពខាងការសម្តែងធម៌ចំពោះបរិស័ទទាំង ៤ យ៉ាងវិចិត្រពិស្តារ មានសេចក្តីឧបមាប្រៀបធៀបហេតុផលជាក់ច្បាស់ ជាឧបាយទូន្មានបរិស័ទយ៉ាងប្រសើរ ។

ព្រះបរមគ្រូ ទ្រង់ប្រារព្ធគុណធម៌នេះ ទើបសរសើរលោកថា ជាអ្នកឆ្នើមជាងភិក្ខុទាំងឡាយខាងចិត្តកថា ប៉ិនទេសនាពិរោះស្តាប់ ហើយបានការច្រើនផង ។

៚

## ១០- រឿងព្រះបាទមធុររាជ

(ចាក ម. ម.)

(អ្នកកាន់ព្រះពុទ្ធសាសនា គ្មានវណ្ណៈឡើយ)

ព្រះបាទមធុររាជព្រះចៅក្រុងមធុរា បានឮដំណឹងថា ព្រះមហាកច្ចានៈ ជាព្រះអរហន្ត គង់នៅក្នុងកុន្ទាវ័ន ជិតក្រុងមធុរានោះ ហើយមានព្រះទ័យជ្រះថ្លា បានចូលទៅគោរពថ្វាយបង្គំ គង់ក្នុងទីដ៏សមគួរ ហើយត្រាស់សួរព្រះមហាកច្ចានៈថា :

បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាអួតសរសើរថា ព្រាហ្មណវណ្ណៈ ជាវណ្ណៈខ្ពស់ជាងវណ្ណៈដទៃ ជាវណ្ណៈល្អបរិសុទ្ធ ព្រោះព្រាហ្មណ៍ជាបុត្ររបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម តើលោកម្ចាស់សម្គាល់ដូចម្តេចទៅវិញ ។

ព្រះមហាកច្ចានៈ ថ្វាយព្រះពរថា បពិត្រមហារាជ វណ្ណៈទាំង៤ នឹងសម្គាល់ថា វណ្ណៈណាល្អបរិសុទ្ធខ្ពង់ខ្ពស់ជាងវណ្ណៈណាមិនបានឡើយ ស្រេចតែអំពើរបស់បុគ្គលម្នាក់ ៗ ដូចជាវណ្ណៈសុទ្ទៈ ដែលពួកព្រាហ្មណ៍ សម្គាល់ថា ថោកទាប បើជនសុទ្ទៈនោះបានប្រព្រឹត្តអំពើល្អ មានបុណ្យវាសនា មានប្រាជ្ញាចេះគ្រប់គ្រងប្រជាជន ជាងពួកព្រាហ្មណ៍ ពួក

ក្សត្រ ពួកវេស្សៈ ជាទីស្រឡាញ់នៃប្រជាជន, ពួកប្រជាជនបានលើកឱ្យធ្វើជាស្តេច តើជនសុទ្ទៈនោះឈ្មោះថាក្សត្រឬឈ្មោះថា សុទ្ទៈ ?

ព្រះបាទមធុរាជតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឈ្មោះថាក្សត្រ, ពួកជនដែលមានវណ្ណៈជាព្រាហ្មណ៍ ជាក្សត្រ ជាវេស្សៈ នាំគ្នាគោរពស្តាប់តាមឱវាទក្សត្រនោះ ។

ព្រះមហាកច្ចានៈ សម្តែងប្រៀបធៀបទៀតថា បពិត្រមហារាជ បើជនមានវណ្ណៈ ជាព្រាហ្មណ៍ ដែលគេសម្គាល់ថាជាវណ្ណៈល្អបរិសុទ្ធនោះ បានប្រព្រឹត្តអាក្រក់លួចទ្រព្យគេ តើមហារាជសម្គាល់ព្រាហ្មណ៍នោះថាជា ចោរបានឬទេ ?

- បពិត្រលោកម្ចាស់ដ៏ចម្រើន ឈ្មោះថាជាចោរពិតប្រាកដ ។

- សូមថ្វាយព្រះពរ ចំណែកជនក្នុងវណ្ណៈបីទៀតគឺ ខត្តិយៈ វេស្សៈ និងសុទ្ទៈ បើប្រព្រឹត្តអាក្រក់លួចទ្រព្យគេ តើមហារាជឱ្យឈ្មោះជនទាំងនោះថាចោរបានឬទេ ?

- បពិត្រលោកម្ចាស់ដ៏ចម្រើនឈ្មោះថាចោរដូចគ្នា។

- សូមថ្វាយព្រះពរ បើជនក្នុងវណ្ណៈទាំង ៤ គឺ

ព្រាហ្មណៈ ខត្តិយៈ វេស្សៈ និងសុទ្ទៈ បានប្រព្រឹត្តអំពើអាក្រក់. ដល់ជនទាំងនោះស្លាប់ទៅ បានទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតអសុរកាយ និងនរកដូចគ្នា ឬ មិនទៅកើតទេ ? មហារាជទ្រង់យល់ដូចម្ដេច ?

. បពិត្រលោកម្ចាស់ដ៏ចម្រើន ពិតជាទៅកើតក្នុងកំណើតទាំង ៤ នោះក្នុងកំណើតណាមួយដូចគ្នាឥតខុសគ្នាឡើយ ។

. សូមថ្វាយព្រះពរ បើជនក្នុងវណ្ណៈទាំង ៤ បានប្រព្រឹត្តធ្វើអំពើល្អ លុះស្លាប់ទៅ តើបានទៅកើតក្នុងសុគតិភពដូចគ្នាឬទេ ?

. ដូចគ្នាលោកម្ចាស់ ឥតខុសគ្នាឡើយ ។

. សូមថ្វាយព្រះពរ បើជនក្នុងវណ្ណៈទាំង ៤ បានចេញចាកផ្ទះ ហើយប្រព្រឹត្តព្រហ្មចរិយធម៌ តើជនទាំងនោះឈ្មោះថា សមណៈដូចគ្នាឬទេ ?

. ដូចគ្នាលោកម្ចាស់ ឥតខុសគ្នាឡើយ ។ ខ្ញុំយល់ច្បាស់ហើយថា វណ្ណៈទាំង ៤ គឺព្រាហ្មណៈ ខត្តិយៈ វេស្សៈ និងសុទ្ទៈ ជាវណ្ណៈស្មើ ៗ គ្នា ខ្ញុំពុំបានឃើញអំពើផ្សេងៗ គ្នាបន្តិចឡើយ ។

កាលព្រះបាទមធុររាជ មានព្រះបន្ទូលដូច្នេះហើយ ទ្រង់បន្ទឹព្រះឧទានងថា ពិរោះណាស់ ៗ ដូចគេផ្ងារបស់ដែលគេផ្កាប់ ដូចគេបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះមហាកច្ចានៈ ដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរឭកចាប់ដើម តាំងអំពីថ្ងៃនេះជាដើមទៅ. សូមលោកម្ចាស់ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ។

ព្រះមហាកច្ចានៈតបថា បពិត្រមហារាជ ព្រះអង្គកុំយកអាត្មាជាទីពឹងទីរលឹកឡើយ អាត្មាដល់នូវព្រះមានព្រះភាគណាជាទីពឹងទីរឭក សូមព្រះអង្គ ដល់នូវព្រះមានព្រះភាគនោះជាទីពឹងទីរលឹកចុះ ។

បើលោកម្ចាស់មានថេរដីកាដូច្នេះ តើព្រះមានព្រះភាគអង្គនោះគង់នៅក្នុងទីណា ?

បពិត្រមហារាជ ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិនិព្វានហើយ ។

ព្រះបាទមធុររាជ ទ្រង់មានព្រះបន្ទូលថា បពិត្រព្រះមហាកច្ចានៈ បើប្រសិនជាខ្ញុំឮដំណើងថា ព្រះមានព្រះភាគ

នោះគង់នៅក្នុងទីប្រមាណ ១០ យោជន៍ ឬ ២០ . ៣០ . ៤០ . ៥០ រហូតដល់ ១០០ យោជន៍ យើងខ្ញុំគប្បីទៅក្នុងទីនោះ ដើម្បីឃើញព្រះអង្គ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលបើព្រះមានព្រះភាគបរិនិព្វានហើយ យើងខ្ញុំសូមដល់នូវព្រះមានព្រះភាគ ដែលទ្រង់បរិនិព្វានហើយមួយអន្លើដោយព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរលឹក, សូមលោកម្ចាស់ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសកដល់នូវសរណៈគមន៍ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះទៅ ។

## ១១- រឿងបុក្កុសាតិកុលបុត្រ

(ចាក ធ. ម)

(ការខកខានមិនបានឧបសម្បទព្រោះមិនបានធ្វើចីវរទាន)

សម័យមួយព្រះសម្ពុទ្ធ ស្តេចយាងទៅដែនមគធៈ ទៅដល់ក្រុងរាជគ្រឹះ បានចូលទៅផ្ទះស្មូនឆ្នាំងឈ្មោះ ភគ្គវៈ ដើម្បីសូមផ្ទះសម្នាក់មួយរាត្រី ។ ស្មូនឆ្នាំងបានក្រាបបង្គំទូលថា មានបព្វជិតមួយអង្គ ចូលទៅសម្នាក់ក្នុងផ្ទះមុនទៅហើយ បើបព្វជិតនោះមិនយល់ទាស់ទេ សូមព្រះអង្គសម្នាក់នៅតាមសព្វព្រះទ័យចុះ ។

ឯបព្វជិតដែលចូលទៅសម្នាក់ ក្នុងផ្ទះស្មូនឆ្នាំងមុននោះ គឺកុលបុត្រឈ្មោះ បុក្កុសាតិ បានចេញបួសដោយសទ្ធាចំពោះព្រះសម្ពុទ្ធ. ប៉ុន្តែមិនដែលស្គាល់ព្រះសម្ពុទ្ធសោះឡើយ គ្រាន់តែឮដំណឹងថា មានព្រះពុទ្ធកើតឡើងក្នុងលោកហើយ ក៏ចេញចាកផ្ទះបួសឧទ្ទិសចំពោះព្រះអង្គតែម្តង ។

ព្រះសម្ពុទ្ធ បានយាងចូលទៅរកបុក្កុសាតិកុលបុត្រដែលបួសជាឥសីនោះ ហើយទ្រង់ត្រាស់សុំសម្នាក់ថា ម្នាលភិក្ខុ បើអ្នកមិនមានសេចក្តីចង្អៀតចង្អល់ទេ តថាគតសូមនៅក្នុងផ្ទះនេះមួយរាត្រីផង ។

បុក្កុសាតិ ឆ្លើយថា ម្នាលអាវុសោ សូមលោកដ៏មានអាយុនៅតាមបំណងចុះ ។

ព្រះមានព្រះភាគយាងចូលទៅក្នុងផ្ទះ ក្រាលកម្រាលស្មៅក្នុងទីសមគួរហើយ គង់ផ្គត់ព្រះភ្នែន តម្រង់ព្រះកាយ ផ្ចង់ព្រះសតិចម្រើនកម្មដ្ឋានដរាបដល់យប់ជ្រៅ ។ ឯបុក្កុសាតិ ក៏អង្គុយដល់យប់ជ្រៅដែរ ។ ទើបព្រះមានព្រះភាគ មានសេចក្តីត្រិះរិះថា កុលបុត្តនេះ មានចរិយាគួរឱ្យជ្រះថ្លាដែរ គួរតថាគតសួរមើល ។

ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលភិក្ខុ អ្នកបួសចំពោះលោកណា លោកណាជាគ្រូរបស់អ្នក, មួយទៀតអ្នកពេញចិត្តនឹងធម៌របស់អ្នកណា ?

បុក្កុសាតិ ឆ្លើយថា ម្នាលអាវុសោ ព្រះសមណគោតមជាសក្យបុត្រ បានចេញចាកសក្យត្រកូលទៅបួស បានត្រាស់ជាព្រះពុទ្ធ មានកិត្តិសព្ទល្បីខ្ចរខ្ចាយថា ព្រះអង្គទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសិលាទិគុណ ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជា

សាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចៈ ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ។ អាស្រ័យហេតុនេះ ទើបខ្ញុំបួសចំពោះព្រះអង្គនោះ ព្រះពុទ្ធអង្គនោះឯងជាគ្រូរបស់ខ្ញុំ ខ្ញុំពេញចិត្តចំពោះធម៌របស់ព្រះពុទ្ធអង្គនោះ ។

ព្រះសម្ពុទ្ធត្រាស់សួរទៀតថា ម្នាលភិក្ខុ ចុះព្រះពុទ្ធអង្គនោះ លោកគង់ក្នុងទីណា ?

បុក្កុសាតិ ឆ្លើយថា ម្នាលអាវុសោ លោកគង់នៅក្នុងក្រុងសាវត្ថី ។

ព្រះសម្ពុទ្ធសួរទៀតថា ចុះព្រះពុទ្ធអង្គនោះ អ្នកដែលបានឃើញឬទេ ? ប្រសិនបើឃើញអ្នកស្គាល់ឬទេ?

បុក្កុសាតិ ឆ្លើយថា ម្នាលអាវុសោ ខ្ញុំមិនដែលឃើញព្រះពុទ្ធអង្គនោះឡើយ បើទុកជាខ្ញុំឃើញក៏មិនស្គាល់ដែរ ។

ពេលនោះព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះថា កុលបុត្តនេះបួសចំពោះអញ តថាគតគួរតថាគតសម្តែងធម៌ប្រោសកុលបុត្តនេះ ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាល់ភិក្ខុ យើងនឹងសម្តែងធម៌ឱ្យអ្នកស្តាប់ ចូរយកចិត្តទុកដាក់ស្តាប់ដោយប្រពៃចុះ ។

បុក្កុសាតិ ឆ្លើយថា អើអាវុសោ អ្នកសម្តែងចុះ យើងចាំស្តាប់ហើយ ។

ព្រះសម្ពុទ្ធ ទ្រង់សម្តែងនូវធាតុវិភង្គសូត្រឱ្យស្តាប់. លុះស្តាប់ចប់ហើយ បានសម្រេចជាអនាគាមី ទើបដឹងថាអ្នកសម្តែងធ៌ឱ្យស្តាប់នោះ គឺតួអង្គព្រះសម្ពុទ្ធ ជាគ្រូរបស់ខ្លួន ក៏ថ្វាយបង្គំក្រាបទៀបព្រះបាទា សូមខមាលទោស ដែលបានប្រព្រឹត្តល្មើសមានហៅអាវុសោជាដើម ។ ព្រះសម្ពុទ្ធត្រាស់ថា អើភិក្ខុអ្នកមានសេចក្តីល្មើសហើយ កាលបើអ្នកបានឃើញទោសតាមទោសហើយ យើងនឹងអត់ទោសនោះចំពោះអ្នក ។

ពេលនោះបុក្កុសាតិភិក្ខុ បានសូមឧបសម្បទា ក្នុងសម្នាក់ព្រះមានព្រះភាគ ១ ត្រាស់ថា ម្នាលភិក្ខុអ្នកមានបាត្រ ចីវរគ្រប់គ្រាន់ហើយឬនៅ ?

បុក្កុសាតិភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បាត្រ និងចីវររបស់ទូលព្រះបង្គំមិនមានគ្រប់គ្រាន់ឡើយ ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុ ព្រះតថាគតទាំងឡាយមិនដែលបំបួសកុលបុត្រ ដែលមានបាត្រ និងចីវរ មិនគ្រប់

គ្រាន់ឡើយ ។

បុក្កុសាតិភិក្ខុ មានចិត្តត្រេកអរ បានថ្វាយបង្គំលាព្រះសម្ពុទ្ធ ទៅស្វែងរកបាត្រ និងចីវរ ទៅដល់ពាក់កណ្តាលផ្លូវ គោញីមានកូនខ្ចីជល់ស្លាប់ ខានបានបួស ក៏ទៅកើតក្នុងស្ថានសួគ៌ ដល់កំណត់កាល ក៏បរិនិព្វានក្នុងទីនោះទៅ មិនបានត្រឡប់មកកើតក្នុងលោកនេះទៀតឡើយ ព្រោះបានកំចាត់បង់នូវ ឱរម្ភាគិយ សំយោជន ទាំង ៥ អស់ហើយ ។

## ១២- រឿងកសិករឈ្មោះចុល្លកាឡ

(ចាក ធ. ខុ.)

(អានិសង្សនៃការធ្វើទាន ក្នុងរដូវធ្វើស្រែ)

កាលពីព្រេងនាយ រាប់អំពីភទ្ទកប្បយើងទៅអតីតកាលចំនួន ៩១ កប្ប មានព្រះពុទ្ធមួយអង្គព្រះនាមវិបស្សី ទ្រង់ឧប្បត្តិឡើងក្នុងលោក ។

គ្រានោះ មានកុដុម្ពិកៈពីរនាក់ ជាបងប្អូនបង្កើត ជាកសិករ. បងឈ្មោះមហាកាឡ ប្អូនឈ្មោះចុល្លកាឡ មានស្រែស្រូវសាលីជាច្រើន ។

ថ្ងៃមួយចុល្លកាឡ ដែលជាអ្នកមានសទ្ធាក្នុងពុទ្ធសាសនា បានដើរទៅមើលថែស្រូវក្នុងស្រែ បានហែកបង្អើបស្រូវសាលីមកទំពារមានរសឆ្ងាញ់ ក៏កើតបុព្វចេតនាចង់ឱ្យទានចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន. ទើបចូលទៅនិយាយប្រាប់មហាកាឡជាបងថា យើងគិតហែកបង្អើបស្រូវសាលីកិនចម្អិនលាយទឹកដោះថ្វាយព្រះសម្ពុទ្ធ ប្រហែលជាបានបុណ្យច្រើន ។

មហាកាឡតបថា ម៉េចឯងនិយាយចង្រៃយ៉ាងហ្នឹង គេមិនដែលធ្វើស្រូវកំពុងជិតចេញផ្លែឱ្យវិនាសដូច្នេះទេ ។ ចុល្លកាឡ ចេះតែអង្វរបងជាច្រើនដង. បងមិនព្រមសោះ

ត្រឡប់ជានិយាយតបប្អូនវិញថា បើឯងនៅតែចចេសបំផ្លាញស្រូវដូច្នេះ ត្រូវចែកស្រែគ្នាចុះ. ស្រែណាជាចំណែកអញឯងកុំពាល់. ចំណែកស្រែរបស់ឯង ១ ចង់ធ្វើយ៉ាងណា ក៏តាមចិត្តឯងចុះ ។

ចុល្លកាឡ មានសេចក្តីត្រេកអរណាស់ ប្រាប់បងថា ស្រួលហើយ ចែកឱ្យខ្ញុំចុះ ដើម្បីខ្ញុំបានធ្វើទានក្នុងពេលឆាប់ៗ នេះកុំឱ្យស្រូវចេញផ្លែទាន់ ។ លុះបងចែកស្រែឱ្យហើយ ក៏នាំមិត្តជាច្រើនទៅជួយហែកបង្អើបស្រូវយកមកកិន ចម្អិនលាយទឹកដោះស្រស់ ផ្សំដោយសប្បិទឹកឃ្មុំ ស្ករក្រាម យកទៅថ្វាយភិក្ខុសង្ឃ ដែលមានព្រះពុទ្ធវិបស្សីជាប្រធាន ហើយប្រាថ្នាថា ទានរបស់ខ្ញុំព្រះអង្គនេះ ជាទានកើតអំពីស្រូវដំបូងបំផុត ជាទានប្រសើរ ខ្ញុំសូមឱ្យបានត្រាស់ដឹងនូវធម៌ប្រសើរមុនគេក្នុងអនាគតកុំខាន ។

ព្រះពុទ្ធវិបស្សីទ្រង់អនុមោទនាថា សូមអ្នកបានសម្រេចដូចសេចក្តីប្រាថ្នាចុះ ។ លុះបានទទួលពរនេះហើយ ក៏ថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ បានចូលទៅមើលស្រែម្តងទៀត ស្រាប់តែឃើញដើមស្រូវ ដែលបានហែកហើយនោះ បញ្ចេញផ្លែគ្រប់ដើមដូចជាគេចងកណ្តឹង. បីតិទាំង ៥ ក៏

កើតមានឡើង គិតថាបុណ្យឱ្យផលអញជាក់ស្តែងណាស់តើ ដូច្នេះអញត្រូវតែធ្វើទានក្នុងរដូវធ្វើស្រែនេះឱ្យបាន ៩ ដង ក្នុងមួយរដូវ ។

លុះដល់ស្រូវនោះល្មមធ្វើអំបុក ចុល្លកាឡ ធ្វើទានម្តងទៀតជាលើកទី ២. ស្រូវក្នុងស្រែដុះវិញដូចដើម. ដល់ពេលច្រូតកាត់ ធ្វើទានម្តងទៀត ជាលើកទី ៣. ដល់ពេលហាលដៃ ធ្វើទានម្តងទៀត ជាលើកទី ៤. ដល់ពេលចងកណ្តាប់ ធ្វើទានម្តងទៀត ជាលើកទី ៥. ដល់ពេលជញ្ជូនកណ្តាប់ដាក់លាន ធ្វើទានម្តងទៀតជាលើកទី ៦. ដល់ពេលបែនបោក ធ្វើទានម្តងទៀតជាលើកទី ៧. ដល់ពេលរោយស្រូវចាក់ធារ ធ្វើទានម្តងទៀតជាលើកទី ៨. ដល់ពេលដឹកស្រូវចាក់ជង្រុក ធ្វើទានម្តងទៀតជាលើកទី ៩ ។ ចុល្លកាឡបានធ្វើភត្តទានអស់វារៈ ៩ ដងក្នុងមួយរដូវធ្វើស្រែដូច្នេះ. ស្រូវសាលីចេះតែចម្រើនឡើងឥតមានខូចខាតឡើយ ។

ដល់ពេលធ្វើមរណកាល កសិករចុល្លកាឡ បានទៅសោយសេចក្តីសុខក្នុងទេវលោក និងមនុស្សលោកជាយូរអង្វែង. លុះមកខាងចុងនៃកប្បមួយរាប់អំពីភទ្ទកប្បនេះទៅចំនួន ១ សែនកប្ប. គាត់បានកើតក្នុងត្រកូលអ្នកមានទ្រព្យ

ម្នាក់ បានធ្វើមហាទានអស់ ៧ ថ្ងៃទៀតក្នុងសាសនាព្រះសម្ពុទ្ធព្រះនាម បទុមុត្តរៈ ក្នុងនគរហង្សវតី. លុះថ្វាយមហាទានហើយ គាត់ចូលទៅក្រាបទៀបព្រះបាទា នៃព្រះពុទ្ធអង្គនោះ សូមប្រាថ្នាឱ្យបានត្រាស់ដឹងអត្ថធម៌មុនគេទៀត ។

លុះមកដល់ភទ្ទកប្បនេះ គាត់បានមកកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងស្រុកទោណវត្ថុ ជិតក្រុងកបិលៈពស្តុ មានឈ្មោះថា កោណ្ឌញ្ញៈ បានកើតមុនព្រះសម្ពុទ្ធបរមគ្រូ ចុះចាប់បដិសន្ធិ ជាច្រើនឆ្នាំ ។ កាលមានវ័យធំហើយ មាតាបិតា បានឱ្យសិក្សារៀនសូត្រ រហូតដល់ចេះចប់គម្ពីរត្រៃវេទ និងតម្រាទាយមហាបុរិសលក្ខណៈ ។ ក្នុងពេលដែលព្រះបាទសុទ្ធោទនៈ អញ្ជើញព្រាហ្មណ៍ ១០៨ ទៅធ្វើពិធីថ្វាយទំនាយព្រះសិទ្ធត្ថកុមារក្នុងព្រះរាជវាំង បានជប់លៀងព្រាហ្មណ៍ទាំងអស់ឱ្យឆ្អែតស្កប់ស្កល់ហើយ ឱ្យទៅលំនៅវិញ រើសទុកតែព្រាហ្មណ៍បញ្ញវ័ន្ត ៨ រូបនោះ. កោណ្ឌញ្ញព្រាហ្មណ៍ មាននៅក្នុងចំនួន ៨ នោះដែរ ជាព្រាហ្មណ៍ក្មេងជាងគេបំផុត បានថ្វាយទំនាយចំពោះព្រះសិទ្ធត្ថកុមារដាច់ខាតតែម្នាក់ឯងថា ពិតជាចេញបព្វជ្ជាបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ ។

កោណ្ឌញ្ញព្រាហ្មណ៍ បានតាំងចិត្តតាំងពីកាលនោះមកថា កាលណាព្រះសិទ្ធត្ថចេញបព្វជ្ជា លោកនឹងចេញបួសតាមព្រះអង្គដែរ ។ ២៩ ឆ្នាំក្រោយមក កាលបើបានដឹងថាព្រះសិទ្ធត្ថៈ ចេញបព្វជ្ជាហើយ លោកបានបបួលព្រាហ្មណ៍ ៤ រូបទៀតគឺ វប្បៈ, ភទ្ទិយៈ, មហានាម, អស្សជិ និងខ្លួនលោកជាគម្រប់ ៥ ទៅបួសតាមបម្រើព្រះអង្គ មាននាមជាបញ្ចវគ្គិយ ។ ដល់ពេលព្រះអង្គលះបង់ទុក្ករកិរិយា ពួកបញ្ចវគ្គិយ អស់ក្តីសង្ឃឹម ក៏នាំគ្នាទៅនៅក្នុងព្រៃ ឥសិបតនមិគទាយវ័ន ក្នុងក្រុងពារាណសីទៅ ។

លុះព្រះបរមគ្រូ បានត្រាស់ជាព្រះអរហន្តសម្ពុទ្ធហើយ ទ្រង់ត្រិះរិះរកបុគ្គល ដែលគួរទទួលបឋមទេសនានោះមិនឃើញមានអ្នកណាក្រៅពីបញ្ចវគ្គិយភិក្ខុឡើយ ព្រោះអ្នកមាននិស្ស័យខ្ពស់គួរទទួលមុន បានធ្វើមរណកាលផុតទៅហើយ, ព្រះអង្គក៏យាងសំដៅទៅព្រៃឥសិបតនមិគទាវ័នសម្តែងបឋមទេសនា ទីបំផុតធម៌ទេសនានោះ កោណ្ឌញ្ញភិក្ខុបានសម្រេចសោតាបត្តិផលមុនគេក្នុងលោក ទើបព្រះសម្ពុទ្ធទ្រង់បន្លឺឧទានថា :

" អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ "

ប្រែថា កោណ្ឌញ្ញៈ បានដឹងធម៌ហើយហ្ន ! ២ ។ អាស្រ័យព្រះឧទាននេះ ទើបមានពាក្យថា អញ្ញាកោណ្ឌញ្ញៈ ជាប់ជានាមរបស់លោកតមកក្នុងប្រវត្តិពុទ្ធសាសនា ។

កាលព្រះអញ្ញាកោណ្ឌញ្ញៈ បានសម្រេចសោតាបត្តិផលហើយ. ព្រះបរមគ្រូ បានប្រទានឯហិភិក្ខុ ឧបសម្បទាចំពោះលោកមុនគេទៀតតាមសេចក្ដីសូមរបស់លោក។ តមក ព្រះបរមគ្រូសម្ដែងអនត្តលក្ខណសូត្រ លោកក៏បានសំរេចជាព្រះអរហន្ត ឯភិក្ខុ៤រូបទៀត ក៏បានសម្រេចព្រះអរហន្តដែរ ។ លោកជាព្រះថេរៈចាស់ទុំជាងគេ ជាព្រះអរិយសាវ័កមុនដំបូងបំផុតក្នុងលោក សមតាមសេចក្ដីប្រាថ្នារបស់លោកមែន

ក្នុងពេលមួយ លោកបាននិមន្តទៅជាតិភូមិរបស់លោក បាននាំក្មួយឈ្មោះបុណ្ណមាណ ឱ្យមកបួសក្នុងសម្នាក់ព្រះសម្ពុទ្ធ ហើយទើបលោកថ្វាយបង្គំលាព្រះបរមគ្រូ ទៅគង់ចាំវស្សាក្នុងព្រៃហេមពាន្ត ជិតស្រះភទ្ទន្ត ជាទីស្ងប់ស្ងាត់តែមួយអង្គឯងអស់រយៈវេលា១២ ឆ្នាំដល់កំណត់អាយុសង្ខារហើយ ក៏បរិនិព្វានក្នុងទីនោះឯង មុនព្រះពុទ្ធបរិនិព្វាន ។

ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ បានទទួលឋានៈជាឯកទគ្គៈខាងរត្តញ្ញូ ព្រះសម្ពុទ្ធ ត្រាស់សរសើរថាជាអ្នកដឹងរាត្រីជាកំពូលនៃភិក្ខុទាំងឡាយក្នុងពុទ្ធសាសនា ។

## ១៣- រឿងមល្លិកាបញ្ហា

(ចាក អ. ច.)

(ហេតុដែលនាំឱ្យមនុស្សមានរូបអាក្រក់ ល្អ មាន ក្រ ក្នុងលោក)

សម័យមួយព្រះសម្ពុទ្ធ គង់ក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។ ពេលនោះនាងមល្លិកាទេវី ជាអគ្គមហេសីព្រះបាទបសេនទិកោសល បានចូលទៅគាល់ព្រះមានព្រះភាគ ក្រាបបង្គំទូលសួរប្រស្នា ៤ ខ ចំពោះព្រះអង្គថា :

១. បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុបច្ច័យ ដែលនាំឱ្យស្ត្រីខ្លះក្នុងលោកនេះ មានសម្បុរអាក្រក់ផង មានរូបរាងអាក្រក់ផង ក្រខ្សត់ផង មានស័ក្តិតូចផង ?

ព្រះសម្ពុទ្ធសម្តែងថា ម្នាលនាងមល្លិកា ! ស្ត្រីនោះជាអ្នកក្រោធខឹងច្រើន មានចិត្តចង្អៀតចង្អល់ គេនិយាយប៉ះពាល់បន្តិចបន្តួច ក៏ចងចិត្តខឹងព្យាបាទ មានះ រឹងត្អឹងក្រញ៉េក្រញ៉ូវរអ៊ូរទាំឡូឡាផង មិនដែលធ្វើទាន មានឱ្យបាយទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបទីដេក ទីសម្នាក់ និងគ្រឿងប្រទីបចំពោះសមណៈព្រាហ្មណ៍ផង ជាអ្នកមានចិត្តឫស្យា ច្រណែនប្រទូសចំពោះលាភសក្ការៈ សេចក្តីគោរពរាប់អាន សំពះបូជារបស់ជន

ទាំងឡាយដទៃផង, ទើបស្ត្រីនោះរូបអាក្រក់ផង ក្រខ្សត់ផង មានស័ក្តិតូចផង ។

បញ្ហានេះមានន័យទូទៅទាំងបុរសស្ត្រីគឺ ការក្រោធខឹង ជាហេតុឱ្យមានរូបកាយពណ៌សម្បុរអាក្រក់, ការមិនធ្វើទាន ជាហេតុឱ្យក្រខ្សត់ភោគទ្រព្យ, ការច្រណែនឫស្យាប្រទូស ចំពោះលាភសក្ការៈអ្នកដទៃ គឺមានចិត្តអាក្រក់ មិនចង់ឱ្យអ្នកដទៃគ្រាន់បើជាងខ្លួន ជាហេតុឱ្យមានស័ក្តិតូច ត្រកូលថោកទាប ។

២. បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុបច្ច័យ ដែលនាំឱ្យស្ត្រីខ្លះក្នុងលោកនេះមានសម្បុរអាក្រក់ មានរូបអាក្រក់ តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើនផង មានស័ក្តិធំផង ?

ព្រះសម្ពុទ្ធសម្តែងថា ម្នាលនាងមល្លិកា ! ស្ត្រីនោះជាអ្នកក្រោធខឹងច្រើន មានះ រឹងត្អឹង រអ៊ូរទាំឡូឡា តែជាអ្នកធ្លាប់ធ្វើទាន មានឱ្យបាយទឹកជាដើម ចំពោះសមណៈព្រាហ្មណ៍ផង ជាអ្នកមិនមានចិត្តច្រណែនឫស្យា ចំពោះអ្នកដទៃផង, ទើបស្ត្រីនោះមានរូបអាក្រក់ ប៉ុន្តែមានទ្រព្យសម្បត្តិ និងមានស័ក្តិធំ ។

៣. បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុបច្ច័យដែល

នាំឱ្យស្ត្រីខ្លះក្នុងលោកនេះ មានរូបល្អគួរឱ្យចង់មើល ចង់ឃើញផង ជាអ្នកប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង គួរជាទីជ្រះថ្លាផង ជាអ្នកក្រខ្សត់ មានស័ក្តិតូច ?

ព្រះសម្ពុទ្ធសម្តែងថា ម្នាលនាងមល្លិកា ! ស្ត្រីនោះជាអ្នកមិនក្រោធ មិនមានចិត្តច្រើន ទុកជាគេនិយាយប៉ះពាល់ ក៏មិនខឹង មិនព្យាបាទ មិនបញ្ចេញសេចក្តីក្រោធឱ្យច្បាស់ នៅតែមានភាពស្រស់បស់ដដែល ប៉ុន្តែជាស្ត្រីមិនដែលធ្វើទាន មានឱ្យបាយទឹកជាដើម ចំពោះសមណៈព្រាហ្មណ៍ផង ជាស្ត្រីមានចិត្តប្រណែនឫស្យាចំពោះអ្នកដទៃផង. ទើបស្ត្រីនោះមានរូបល្អ សម្បុរល្អ ប៉ុន្តែក្រខ្សត់ មានស័ក្តិតូច ។

៤. បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុបច្ច័យដែលនាំឱ្យស្ត្រីខ្លះក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានស័ក្តិធំផង ?

ព្រះសម្ពុទ្ធសម្តែងថា ម្នាលនាងមល្លិកា ! ស្ត្រីនោះជាអ្នកមិនក្រោធ ទុកជាគេនិយាយប៉ះពាល់ក៏មិនខឹង មិន

ព្យាបាទ មិនបញ្ចេញសេចក្តីក្រោធឱ្យច្បាស់ នៅមានទឹកមុខស្រស់បស់ដដែលផង ជាស្ត្រីធ្លាប់ធ្វើទាន មានឱ្យបាយទឹកជាដើមផង មិនមានសេចក្តីប្រណែនប្ញស្យាប្រទូស ចំពោះលាភសក្ការៈអ្នកដទៃផង. ទើបស្ត្រីនោះមានរូបល្អ មានសម្បុរល្អ មានទ្រង់ទ្រាយដ៏ឧត្តម គួរឱ្យចង់មើលចង់ឃើញផង ជាអ្នកមានទ្រព្យស្តុកស្តម្ភផង មានសក្តិធំផង ។

លុះចប់ប្រស្នាទាំង ៤ ខ នេះហើយ. ព្រះនាងមល្លិកាទេវី ក្រាបបង្គំទូលព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ពីជាតិមុនខ្ញុំព្រះអង្គជាអ្នកខឹងច្រើន មានចិត្តមានះរឹងត្អឹង ទើបជាតិនេះខ្ញុំព្រះអង្គមានរូបអាក្រក់ មានសម្បុរអាក្រក់. ប៉ុន្តែក្នុងជាតិមុន ខ្ញុំព្រះអង្គបានធ្វើទានផង មិនមានចិត្តប្រណែនប្ញស្យាអ្នកដទៃផង ទើបជាតិនេះ ខ្ញុំព្រះអង្គមានភោគទ្រព្យស្តុកស្តម្ភផង មានស័ក្តិធំផង ជាអធិបតីលើខត្តិយកញ្ញាខ្លះ ព្រាហ្មណកញ្ញាខ្លះ គហបតិកញ្ញាខ្លះ ដែលមានចំនួនច្រើនក្នុងរាជត្រកូលនេះ ។

បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គមិនក្រោធខឹង ខំអត់សង្កត់នូវសេចក្តីក្រោធផង ខំធ្វើទានឱ្យបានច្រើនផង មិនឱ្យសេចក្តីប្រណែនប្ញស្យាចំពោះ

អ្នកដទៃកើតឡើងបានផង ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានយល់ភ្លឺច្បាស់ណាស់ អស់សង្ស័យចំពោះរឿងនេះទៀតហើយ. សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសិកា អ្នកដល់នូវសរណៈ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះតរៀងទៅ ។

៚

# ១៤- រឿងព្រះអនុរុទ្ធ និងសុមនសាមណេរ

( ចាក ធ. ខុ. )

( ការចែកបុណ្យដល់អ្នកដទៃ ត្រូវបានបុណ្យមួយជាពីរមកវិញ )

ក្នុងសាសនាព្រះសម្ពុទ្ធបទុមុត្តរៈ, មានកុលបុត្រម្នាក់បានឃើញភិក្ខុមួយរូប ដែលព្រះពុទ្ធ បទុមុត្តរៈ តាំងជាឯតទគ្គៈខាងទិព្វចក្ខុ ក្នុងកណ្ដាលទីប្រជុំពុទ្ធបរិស័ទ ហើយក៏មានចិត្តជ្រះថ្លាចង់បានឋានៈ ដូចភិក្ខុនោះ, ទើបត្រឡប់មកផ្ទះវិញ ចាត់ចែងចង្ហាន់ប្រគេនភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយតាំងសេចក្ដីប្រាថ្នាថា "ខ្ញុំព្រះអង្គសូមឱ្យបានជាអ្នកប្រសើរជាងភិក្ខុ មានទិព្វចក្ខុទាំងអស់ក្នុងអនាគតកាល" ។

ព្រះពុទ្ធបទុមុត្តរៈ ទ្រង់ជ្រាបថានឹងបានសម្រេច ទើបទ្រង់ព្យាករណ៍ថា "នៅ ១ សែនកប្បទៀត អ្នកនឹងបានជាព្រះថេរៈ ឈ្មោះអនុរុទ្ធ ប្រសើរជាងភិក្ខុ មានទិព្វចក្ខុ ក្នុងសាសនាព្រះគោតម" ។

កុលបុត្រនោះ លុះអស់អាយុបានទៅកើតទេវលោក និងមនុស្សលោក សោយសេចក្ដីសុខជាយូរអង្វែងចំនួន ១ សែនកប្ប, ដល់មកខាងដើមនៃភទ្ទកប្បនេះ បានមកកើតក្នុង

ត្រកូលអ្នកកំសត់មានឈ្មោះថា អន្នភារៈ នៅអាស្រ័យជាមួយសុមនសេដ្ឋី ក្នុងក្រុងពារាណសី ។

ថ្ងៃមួយ មានព្រះបច្ចេកពុទ្ធមួយអង្គ នៅភ្នំគន្ធមាទន៍ ព្រះនាមឧបរិដ្ឋ ទើបនិងចេញអំពីនិរោធសមាបត្តិ ពិចារណារកទីទៅបិណ្ឌបាត បានឃើញអន្នភារបុរស ទើបនឹងរែកស្មៅមកអំពីព្រៃ ជាបុរសគួរលោកជួយសង្គ្រោះ ទើបឃ្លុំចីពរនិមន្តទៅដោយឫទ្ធិ ។

អន្នភារបុរស ក្រឡេកឃើញព្រះបច្ចេកពុទ្ធហើយមាន សេចក្តីជ្រះថ្លាសួរថា លោកម្ចាស់បានចង្ហាន់ខ្លះហើយឬនៅ ? អើអ្នកមានបុណ្យធំ អាត្មាគង់នឹងបានឥឡូវនេះ ។ បុរសនោះដាក់អង្រែមកអំពីស្មា រត់សំដៅទៅផ្ទះខ្លួន សួរភរិយាថា នែនាងបាយដែលទុកបម្រុងបងមានហើយឬនៅ? ថា មានហើយ. ទើបរត់ត្រឡប់ទៅទទួលយកបាត្រពីព្រះបច្ចេកពុទ្ធ យកមកដាក់ចង្ហាន់ បានគិតថា កាលអញចង់ឱ្យទានគ្មានទេយ្យធម៌. កាលបើមានទេយ្យធម៌ គ្មានអ្នកទទួល. ឥឡូវនេះអញមានលាភធំណាស់ ទេយ្យធម៌ក៏មាន អ្នកទទួលក៏មានព្រមគ្នាតែម្តង. លុះដាក់ចង្ហាន់ពេញបាត្រ យកទៅប្រគេនព្រះបច្ចេកពុទ្ធ រួចហើយតាំងសេចក្តីប្រាថ្នាថា

"ខ្ញុំព្រះអង្គសូមកុំឱ្យឮពាក្យថា គ្មានឱ្យសោះ ចាប់ពីពេលនេះទៅ" ។ ព្រះបច្ចេកពុទ្ធអនុមោទនាថា សូមឱ្យអន្នភារៈបានសម្រេចដូចប្រាថ្នាចុះ ហើយនិមន្តចេញទៅ ។

ខណៈនោះមានសេចក្តីអស្ចារ្យកើតឡើង ដោយឮសំឡេងទេវតា ដែលរក្សាស្វេតច្ឆត្តសុមនសេដ្ឋី ស្រែកបន្លឺសព្ទសាធុការអស់វារៈបីដងថា "ទានដែលអន្នភារៈ បានថ្វាយចំពោះព្រះបច្ចេកពុទ្ធព្រះនាម ឧបរិដ្ឋ ជាទាន មានផលធំបំផុត" ។

សេដ្ឋីសួរទេវតាថា ខ្ញុំបានឱ្យទានច្រើនណាស់ដែរ អ្នកមិនដែលឃើញទេឬ ?

ទេវតាប្រាប់ថា ខ្ញុំឱ្យសព្ទសាធុការនេះ មិនមែនចំពោះទានលោកទេ, ខ្ញុំឱ្យដោយសេចក្តីជ្រះថ្លាចំពោះអន្នភារៈទេតើ ។ សេដ្ឋីនឹកថា អញឱ្យទានច្រើនណាស់ទេវតាមិនដែលឱ្យពរម្តងសោះ, ឯអន្នភារៈនៅជាមួយអញរស់ដោយសារអញ ម៉េចក៏ទេវតាឱ្យពរក្នុងពេលដែលវាទើបនឹងឱ្យទានម្តង ប្រហែលជាទានវាមានផលច្រើន គិតដូច្នេះហើយ ក៏សុំចំណែកបុណ្យអំពីអន្នភារៈ ។ មិនព្រមចែកឱ្យសេដ្ឋីហ៊ានទិញបុណ្យរហូតដល់ ១ពាន់កហាបណៈ អន្នភារៈ

នៅតែមិនឱ្យទៀត ។

ពេលនោះអន្នភារៈ ពិបាកចិត្តដោយសារសេដ្ឋី ចេះតែតាមអង្វរទិញបុណ្យញយៗ ពេក ក៏ទៅថ្វាយបង្គំ សួរព្រះបច្ចេកពុទ្ធថា "បុណ្យដែលខ្ញុំបានធ្វើហើយ បើចែកឱ្យអ្នកដទៃ តើបុណ្យនោះអស់ទៅ ឬនៅសល់ខ្លះដែរ?

ព្រះបច្ចេកពុទ្ធប្រាប់ថា ម្នាលអន្នភារៈ បុណ្យដែលបុគ្គលបានធ្វើហើយ បើបានឧទ្ទិសចែកឱ្យទៅអ្នកដទៃ បុណ្យនោះ រឹតតែកើនចម្រើនឡើងទ្វេរមួយជាពីរ មិនចេះខ្វះក្រឡះអស់ទៅឡើយ ។ លុះបានស្តាប់យ៉ាងនេះហើយ ទើបព្រមចែកបុណ្យឱ្យសេដ្ឋី ៗ មានចិត្តត្រេកអរ បានបូជាអន្នភារៈដោយកហាបណៈយ៉ាងច្រើន ។

ឯព្រះចៅពារាណសី កាលបើបានដឹងថា អន្នភារៈបានធ្វើបុណ្យ ហើយមានពួកទេវតា មានចិត្តត្រេកអរជួយឱ្យពរដូច្នោះ មានព្រះទ័យជ្រះថ្លា ចាត់រាជបុរសឱ្យហៅអន្នភារៈមក ហើយទ្រង់ព្រះរាជទានភោគៈជាច្រើន តែងតាំងជាសេដ្ឋីក្នុងពេលនោះ ។

អន្នភារៈសេដ្ឋី មានសេចក្តីគោរពរាប់អាន សុមនៈសេដ្ឋី ដែលខ្លួនធ្លាប់រស់នៅជាមួយដូចជាមាតាបិតា, ឯ

សមនសេដ្ឋី ក៏មានសេចក្ដីស្រឡាញ់រាប់អានវិញក្នុងឋានៈជាមិត្រយ៉ាងជិតស្និទ្ធ តែងបបួលគ្នាធ្វើបុណ្យទាន ដរាបដល់អស់ជីវិតរៀងខ្លួន ។ អ្នកទាំងពីរ បានទៅកើតក្នុងទេវលោក និងមនុស្សលោក ដោយសេចក្ដីសុខជាយូរអង្វែង ។

លុះមកដល់ពុទ្ធកាលនេះ អន្នភារៈ បានមកចាប់បដិសន្ធិក្នុងឧទរព្រះជាយារបស់ព្រះអង្គម្ចាស់អមិតោ្តទនៈ នាក្រុងកបិលពស្តុ មាននាមថា "អនុរុទ្ធកុមារ" ។

ថ្ងៃមួយពួកក្សត្រសក្យៈទាំង ៦ អង្គនាំគ្នាក្រសាលល្បែងអង្គញ់ភ្នាល់ដាក់នំ ថាបើអ្នកណាចាញ់ អ្នកនោះត្រូវយកនំមកចែកគ្នាសោយ ។ អនុរុទ្ធកុមារ លេងចេះតែចាញ់គេ បានប្រើរាជបម្រើឱ្យទៅយកនំអំពីព្រះមាតាអស់វារៈ ៣ លើក. ដល់លើកទី ៤ ព្រះមាតាប្រាប់ថាគ្មានទេ ។ អ្នកបម្រើត្រឡប់មកទូលអនុរុទ្ធកុមារថានំគ្មានទេ ។ អនុរុទ្ធកុមារ ប្រើឱ្យទៅយកនំគ្មាននោះមក ព្រោះព្រះអង្គម្ចាស់នេះ ព្រះរាជមាតាបិតាថ្នាក់ថ្នមណាស់ បរិបូណ៌ដោយសេចក្ដីសុខដូចជាទេវតា មិនធ្លាប់ឮពាក្យថាគ្មានសោះឡើយ កាលដែលអ្នកបម្រើទៅយកនំគ្មាន ព្រះមាតាក៏ឱ្យភាជន៍មាសទទេមក ។

ខណៈនោះទេវតាដែលរក្សាព្រះនគរគិតថា ព្រះរាជកុមារនេះ មានបុណ្យធំបានធ្វើហើយពីអតីតជាតិ ប្រាថ្នាមិនឱ្យជួបនឹងការគ្មាន ឱ្យស្គាល់តែការមាន ដូច្នេះអញត្រូវយកនំទិព្វដាក់ក្នុងភាជនៈទទេនេះឱ្យពេញ បើមិនធ្វើយ៉ាងនេះទេក្បាលអញត្រូវបែកជា ៧ ភាគ ។ ទេវតា ក៏ដាក់នំទិព្វក្នុងភាជន៍មាសនោះទៅ ។ អ្នកបម្រើយកភាជន៍ទៅថ្វាយ បើកគម្របឡើងស្រាប់តែឃើញនំពេញ មានក្លិនក្រអូបឈ្ងុយពេញនគរទាំងមូល. ក្សត្រ ៦ អង្គក៏នាំគ្នាសោយអស់ទៅ ។

ចំណែកអនុរុទ្ធកុមារ បានសោយនំទិព្វដែលមានរសឆ្ងាញ់នោះ ហើយគិតថា ព្រះមាតាប្រហែលមិនស្រឡាញ់អញទេ បានជាមុនៗ មកមិនដែលធ្វើនំគ្មានឱ្យអញស៊ីសោះ ។ ដល់ពេលយាងទៅដំណាក់វិញ ក៏សួរព្រះមាតាថា ព្រះមាតាមិនស្រឡាញ់បុត្រទេឬ ?" ព្រះមាតាប្រាប់ថា នែ ពាសព្វថ្ងៃមាតាស្រឡាញ់ជាងសាច់ហឫទ័យមាតាទៅទៀត ។

អនុរុទ្ធកុមារសួរថា បើមាតាស្រឡាញ់ដល់ម្ល៉េះហេតុអ្វីពីដើមមក មិនដែលធ្វើនំគ្មានឱ្យបុត្រញុំសោះ. ពីថ្ងៃនេះទៅបុត្រមិនញុំនំដទៃទេ ញុំតែនំគ្មាននោះឯង ។

ព្រះមាតាស្តាប់ហើយឆ្ងល់ណាស់ តែមិនមានបន្ទូល

ឱ្យបុត្រដឹង. លុះបុត្រចេញផុត ទើបហៅបម្រើមកសួរ. អ្នកបម្រើទូលថា កាលទូលបង្គំយកភាជន៍ទៅដល់ហើយ បើកគម្របឡើង ស្រាប់តែឃើញនំពេញ. នំនោះមានក្លិនក្រអូបឈ្ងុយណាស់ ។ ព្រះនាងយល់ភ្លាមថា បុត្រមានបុណ្យណាស់ បើនៅគ្រប់គ្រងផ្ទះមិនទៅបួសទេ ទេវតានឹងឱ្យនំទិព្វនោះសោយរហូតតទៅ ។

លុះដល់ពេលអនុរុទ្ធកុមារ មានវ័យពេញកម្លោះហើយ បានទៅបួសក្នុងសម្នាក់ព្រះសាស្ដា បានសម្រេចព្រះអរហត្តផល បរិបូណ៌ដោយវិជ្ជា ៣ អាចប្រមើលមើលពួកសត្វដោយទិព្វចក្ខុបាន ១០ ពាន់លោកធាតុ ពូកែវិសេសជាងភិក្ខុអ្នកមានភ្នែកទិព្វទាំងអស់ ។ ព្រះសម្ពុទ្ធ បានប្រកាសកណ្ដាលបរិស័ទ តាំងជាឯតទគ្គៈខាងទិព្វចក្ខុ ។ លោកបានសម្រេចដូចសេចក្ដីប្រាថ្នា ដែលលោកបានធ្វើក្នុងសាសនាព្រះពុទ្ធបទុមុត្តរៈនោះមែន ។

សម័យមួយព្រះអនុរុទ្ធត្ថេរ បានពិចារណាមើលដោយទិព្វចក្ខុរកសុមនសេដ្ឋី ជាសម្លាញ់របស់លោកពីអតីតជាតិ បានឃើញទៅកើតក្នុងផ្ទះមហាមុណ្ឌឧបាសក នាស្រុកមុណ្ឌនិគម មានឈ្មោះថា "ចូឡសុមនៈ" និងជ្រាបថាមាន

ឧបនិស្ស័យគួរបានសម្រេចអរហត្តហើយ ។ ដល់ពេលជិតចូលវស្សា ក៏និមន្តទៅតាមអាកាស ឈប់ក្បែរស្រុកនោះ ។

មហាមុណ្ឌឧបាសកធ្លាប់ស្គាល់គ្នាពីភពមុនមក ក្នុងកាលដែលគាត់ជាបិតារបស់សុមនសេដ្ឋីនោះ. គ្រាន់តែបានឃើញព្រះអនុរុទ្ធត្ថេរ ក៏មានចិត្តរីករាយ ដូចជាធ្លាប់ស្គាល់ច្បាស់ណាស់ បានប្រាប់ចូឡសុមនកុមារជាកូនថា នែកូន ! លោកម្ចាស់របស់អញនិមន្តមកហើយ ឯងទៅទទួលបាត្រអំពីលោកយកមក. អញក្រាលអាសនៈ ។ កាលបើបានចាត់ចែងភត្តប្រគេនស្រេចហើយ. មហាមុណ្ឌបាសកបានបវារណា និមន្តចាំវស្សាក្នុងទីនោះ ព្រះអនុរុទ្ធព្រមទទួលគង់ចាំវស្សាអស់ត្រៃមាសក្នុងទីនោះឯង ។

លុះចេញវស្សាហើយ ឧបាសកបានយកគ្រឿងបរិក្ខារមានត្រៃចីវរជាដើមទៅប្រគេន. ព្រះអនុរុទ្ធមិនព្រមទទួល។ ឧបាសកបវារណាទៀត លាភនេះត្រូវបានចំពោះភិក្ខុដែលចាំវស្សាអស់ត្រៃមាសក្នុងទីនេះ ហើយសូមលោកម្ចាស់ទទួលដោយសេចក្ដីអនុគ្រោះ ។

ព្រះអនុរុទ្ធតបថា អាត្មាមិនត្រូវការវត្ថុនេះទេ ព្រោះសាមណេរ ដែលជាកប្បិយការកៈរបស់អាត្មាពុំទាន់មាន ។

ឧបាសកក៏និមន្តឱ្យបំបួស ចូឡសុមនកុមារ ដែលមាន អាយុ ៧ ឆ្នាំជាសាមណេរ ដើម្បីបានធ្វើជាកប្បិយការកៈ ។ ព្រះថេរៈបានស្របតាមបំណងហើយក៏បំបួស ចូឡសុមនកុមារ ដែលត្រូវជាសម្លាញ់របស់លោកពីអតីតជាតិ កាលកើតជាសុមនសេដ្ឋីក្នុងពេលនោះឯង ។ មានសេចក្តីអស្ចារ្យថា កាលចូឡសុមនកុមារ បានឱ្យគេកោរសក់រួចហើយ ក៏បានសម្រេចអរហត្តផលភ្លាម បរិបូណ៌ដោយ ឥទ្ធិឫទ្ធិ មាននាមថា សុមនសាមណេរ ។

៚

## ១៥- រឿងធម្មកថិកឈ្មោះកបិលភិក្ខុ

(ចាក ក. ខុ.)

(ទោសនៃការនិយាយកាច់មូលព្រះពុទ្ធដីកា)

ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមកស្សបៈ កាលព្រះអង្គបរិនិព្វានហើយ មានត្រកូលមួយនាំគ្នាទៅបួសក្នុងសម្នាក់សាវ័កទាំងឡាយគឺ មាតាឈ្មោះសាធនី បានបួសក្នុងសម្នាក់ភិក្ខុនី. កូនច្បងឈ្មោះសោធនៈ និងកូនបន្ទាប់ឈ្មោះកបិលៈ បានបួសក្នុងសម្នាក់ភិក្ខុ. ឯប្អូនស្រីមួយរូបទៀតឈ្មោះ តាបនា ក៏បានបួសក្នុងសម្នាក់ភិក្ខុនីដែរ ។

សោធនៈ ជាបងបួសហើយ ខំចម្រើនវិបស្សនាកម្មដ្ឋាន បានសម្រេចជាព្រះអរហន្ត ។ កបិលភិក្ខុជាប្អូនបានរៀនគន្ថធុរៈចេះចប់ព្រះត្រៃបិដក ចេះទេសនាពីរោះក្បោះក្បាយ មានសិស្សគណបរិវារច្រើន មានលាភសក្ការៈពោលពាស ជាអ្នកថ្កើងដោយយស មានចិត្តស្រវឹងថា អញជាអ្នកប្រាជ្ញ ជាពហុស្សូត. កាលបើលាភ យស គ្របសង្កត់ខ្លាំងហើយសម្គាល់ថា គ្មាននរណាចេះស្មើនឹងអញ ក៏និយាយកាច់មូលព្រះពុទ្ធដីកា តាមបំណងរបស់ខ្លួន គឺហ៊ានប្រែត្រឡប់ វត្តប្រតិបត្តិដែលមិនគួរ ថាគួរវិញ. អំពើមានទោស

ថាឥតទោសវិញ អំពើឥតទោស ថាមានទោសវិញ, មិនតែប៉ុណ្ណោះថែមទាំងប្រើអំណាចស្តីបន្ទោស ជេរប្រទេចពួកភិក្ខុអ្នកមានសីលបរិសុទ្ធទៀត ។

ពួកភិក្ខុទាំងឡាយ បានប្រាប់រឿងនោះចំពោះព្រះសោធនត្ថេរជាបង, លោកបានហៅកបិលភិក្ខុមករំលឹកដាស់តឿនថា ម្នាលអាវុសោកបិល សេចក្ដីប្រព្រឹត្តត្រឹមត្រូវរបស់ភិក្ខុដែលមានអានុភាពដូចប្អូនឯងឈ្មោះថា គំរូល្អប្រសើរបំផុត ជាអាយុជីវិតនៃពុទ្ធសាសនា ហេតុនេះអ្នកកុំលះបង់វត្តប្រតិបត្តិត្រូវតាមធម៌វិន័យ និងកំណត់វត្តប្រតិបត្តិដែលគួរតាមធម៌វិន័យ, អ្នកកុំនិយាយយ៉ាងហ្នឹងទៀត ។

កបិលភិក្ខុមិនខ្វល់ស្ដាប់ ព្រោះអាងលាភ យស មានសិស្សគណច្រើន មានគេរាប់អានច្រើន រឹតតែមានមាយាទអាក្រក់ថែមទៀត ។

ចំណែកខាងសាធនីភិក្ខុនីជាមាតា និងតាបនាភិក្ខុនីជាប្អូននាំគ្នាកាន់ជើងកបិលភិក្ខុ ដើម្បីបានថ្កុំថ្កើងដោយសារលាភ យសរបស់កបិលភិក្ខុ ។

លុះដល់ទីបំផុតនៃអាយុសង្ខារ ព្រះសោធនត្ថេរលោកបរិនិព្វានទៅ, ឯកបិលភិក្ខុ និងសាធនីភិក្ខុជាមាតា

ព្រមទាំងតាបនាភិក្ខុនីជាប្អូន បានទៅកើតក្នុងនរកអវិចី ឆេះក្នុងនរកនោះអស់ចន្លោះព្រះពុទ្ធមួយអង្គ. លុះមកដល់ពុទ្ធកាលនេះ កបិលភិក្ខុបានមកប្រកាសផលកម្មតែម្នាក់ឯង គឺបានមកកើតជាត្រីធំ ១ ឈ្មោះ កបិលមច្ឆៈ មានសម្បុរដូចមាស នៅក្នុងស្ទឹងអចិរវតី ប៉ុន្តែមានមាត់ស្អុយដូចគម្រង់បក់ផ្សាយក្លិនអាក្រក់រាប់យោជន៍ ព្រោះទោសនិយាយមួលបង្កាច់ព្រះពុទ្ធដីកា ត្រង់មានសម្បុរល្អ ព្រោះបានរៀនចេះព្រះត្រៃបិតក និងបានបួសក្នុងពុទ្ធសាសនា ។

ថ្ងៃមួយពួកព្រានប្រមង់មងសំណាញ់ ចាប់បានត្រីនោះ ឃើញចម្លែកជាងត្រីធម្មតា និងធំក្លិនស្អុយចេញពីមាត់ដូចគម្រង់ ក៏ខ្ពើមមិនហ៊ានស៊ី នាំយកទៅថ្វាយព្រះបាទបសេនទិកោសល. ព្រះរាជាឱ្យនាំយកត្រីនោះទៅវត្តជេតពន ដើម្បីសួរបុព្វកម្មរបស់ត្រីនោះចំពោះព្រះសម្ពុទ្ធ ។

ក្នុងពេលនោះ ព្រះសម្ពុទ្ធបាននាំអតីតនិទាន រឿងកបិលភិក្ខុខាងលើមកសម្ដែង. លុះសម្ដែងចប់ហើយ ព្រះអង្គសួរផ្ទាល់ចំពោះត្រីនោះ ដោយពុទ្ធានុភាពថា នែ ! កបិលមច្ឆៈ សោធនត្ថេរ ជាបងរបស់ឯងទៅកើតក្នុងទីណា?

ត្រីឆ្លើយថា បងរបស់ខ្ញុំព្រះអង្គ លោកចូលនិព្វាន

ហើយ ។

- ចុះម្តាយ និងប្អូនស្រីរបស់ឯងនៅឯណា ?

- ក្រាបទូល នៅឯនរកអវិចី ជាមួយទូលបង្គំ ។

កបិលមច្ឆៈ គ្រាន់តែមកប្រកាសបុព្វកម្មរបស់ខ្លួនក្នុងចំពោះព្រះភក្ត្រព្រះសម្ពុទ្ធដូច្នេះហើយ ក៏បោកក្បាលខ្លួនងស្លាប់ ទៅកើតក្នុងនរកអវិចីដូចដើមវិញ ។

ꩺꩻꩼ

## ១៦- រឿងក្អែកប្រពន្ធនាយសំពៅ និងក្មេងឃ្វាលគោ

( ចាក ក. ខុ. )

( អ្នកធ្វើកម្មបែបណា តែងបានទទួលផលបែបនោះវិញ )

ក្នុងសម័យពុទ្ធកាល មានភិក្ខុសង្ឃជាច្រើនអង្គមកពីស្រុកក្រៅ ចូលទៅគាល់ព្រះសម្ពុទ្ធ ក្នុងវត្តជេតពន ។ កាលភិក្ខុទាំងនោះធ្វើដំណើរមក ភិក្ខុមួយក្រុមបានឃើញក្អែក ១ កំពុងហើរពួដ៍អាកាស ស្រាប់តែចូលក្បាលទៅក្នុងរង្វេលស្មៅ ដែលភ្លើងកំពុងឆេះ បានប៉ើងមកអំពីដំបូលផ្ទះស្រីម្នាក់ ហើយស្លាប់កណ្តាលអាកាសនោះទៅ ។

ភិក្ខុមួយពួកទៀតមកតាមផ្លូវទឹក បានឃើញពួកអ្នកសំពៅនាំគ្នាចាប់ប្រពន្ធនាយសំពៅ ចងកភ្ជាប់នឹងក្អមដែលពេញដោយដីខ្សាច់ ទម្លាក់ក្នុងសមុទ្រស្លាប់ទៅ ព្រោះគេសម្គាល់ថាជាស្រីកាឡកណ្ណី ។

ភិក្ខុ ៧ អង្គទៀតមកតាមផ្លូវគោក បានសម្នាក់នៅក្នុងគុហាវត្ត ១ កណ្តាលផ្លូវស្រាប់តែមានថ្ម ១ ផ្ទាំងធំរមៀលមកបិទរូងគុហានោះជិតអស់ ៧ ថ្ងៃ ទើបផ្ទាំងថ្មនោះបើកចេញ ធ្វើឱ្យភិក្ខុ ៧ អង្គនោះអត់បាយទឹក មានរូបកាយស្គាំងស្គមជិតនឹងស្លាប់ ។

កាលភិក្ខុសង្ឃទាំងបីក្រុមនេះ មកជួបជុំគ្នាក្នុងវត្តជេតពន ហើយក៏ដំណាលរឿងចម្លែកដែលខ្លួនជួបប្រទះតាមផ្លូវ ទូលព្រះសម្ពុទ្ធបរមគ្រូរៀងៗ ខ្លួន ព្រះសម្ពុទ្ធទ្រង់នាំអតីតនិទានមកសម្តែងថា :

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានកសិករម្នាក់នៅជិតក្រុងពារាណសី មានកូនគោឈ្មោលមួយ កាលគោនោះធំល្មមហើយ ក៏បង្ហាត់ពង្រាបដើម្បីប្រើការ. គោនោះចេះតែគៀចដេក មិនព្រមក្រោកដើរសោះ ។ កសិករជាម្ចាស់គោនោះ វាយចាក់នឹងជន្លួញអស់ចិត្ត មិនក្រោកមានចិត្តក្រេវក្រោធ ក៏យកចំបើងមករុំព័ទ្ធគោនោះ ហើយដុតភ្លើងឆេះសន្ធោសន្ធៅ. គោនោះក៏ស្លាប់ទៅ ។ ដល់ពេលកសិករនោះអស់អាយុ ក៏បានទៅកើតក្នុងនរកជាយូរអង្វែង លុះរួចពីនរកនោះ បានមកកើតជាក្អែក ត្រូវភ្លើងឆេះស្លាប់កណ្តាលអាកាស ដូចអ្នករាល់គ្នាបានឃើញនោះអស់ ៧ ជាតិមកហើយ ។

រឿងមួយទៀត កាលពីព្រេងនាយ ភរិយារបស់គហបតីម្នាក់នៅក្រុងពារាណសី បានចិញ្ចឹមឆ្កែឈ្មោលមួយ ឆ្កែនោះធ្លាប់ជាប្តីនាងពីអតីតជាតិ មានចិត្តស្រឡាញ់នាងជា

ម្ចាស់នោះណាស់ នាងធ្វើការអ្វី ឆ្កែតែងរត់ទៅជិត ហើយអង្គុយមើលមុខនាងជានិច្ចរាល់ថ្ងៃ ។ ពេលដែលនាងយកបាយទៅស្រែ ឬទៅរកអុសក្នុងព្រៃ ឬក៏ទៅលេងទីណាៗ ឆ្កែនោះចេះតែបោលតាមទៅ. ពួកកំលោះៗ ឃើញហើយក៏នាំគ្នាសើចចំអន់លេងថា នែរីយមើលព្រានទៅព្រៃចាប់ម្រឹគ ហើយថ្ងៃនេះយើងនឹងបានសាច់ស៊ីមិនខាន. នាងមានសេចក្ដីអៀនខ្មាសខ្លាំង ក៏យកដំបងដេញឆ្កែនោះចេញ. ឆ្កែនោះគ្រាន់តែគេចចេញបន្តិចក៏រត់តាមទៅទៀត ។

ថ្ងៃមួយ នាងយកបបរទៅជូនប្ដីនាងឯស្រែ មុននឹងទៅ បានយកខ្សែគោដាក់ក្នុងថ្នក់ទៅផង បម្រុងសម្លាប់ឆ្កែនោះចោល ដើម្បីកុំឱ្យមានសេចក្ដីអៀនខ្មាសតទៅទៀត. លុះជូនបបរប្ដីបរិភោគហើយ ក៏យកឆ្នាំងដើរសំដៅទៅកំពង់ទឹក យកដីខ្សាច់ដាក់ពេញឆ្នាំងហើយ ហៅឆ្កែមកជិត. ឆ្កែសប្បាយចិត្តណាស់គិតថា អញមិនដែលបានឮពាក្យសំដីពិរោះរបស់ម្ចាស់អញដូចក្នុងថ្ងៃនេះឡើយ ។ នាងចាប់ឆ្កែនោះទាញ មកយកខ្សែចងកជាប់ ហើយយកកន្ទុយខ្សែម្ខាងចងភ្ជាប់នឹងកឆ្នាំង ក៏រុញឆ្កែនោះទម្លាក់ទឹកលិចស្លាប់ទៅ ។ ដល់ពេលនាងនោះស្លាប់ បានទៅកើតក្នុងនរកជាយូរអង្វែង

បានរួចពីនរកមកកើត ស្ត្រីត្រូវគេចងពន្ធិចឱ្យស្លាប់ក្នុងទឹក ដូចអ្នករាល់គ្នាបានឃើញនោះ អស់មួយរយជាតិមកហើយ។

រឿងមួយទៀត កាលពីព្រេងនាយ មានក្មេងឃ្វាលគោ ៧ នាក់ គៀងគោទៅឃ្វាលក្នុងព្រៃអស់ ៧ កន្លែង គឺមួយថ្ងៃឃ្វាលមួយកន្លែងជាលំដាប់ ដល់គ្រប់ ៧ ថ្ងៃមកជួបកន្លែងដើមវិញ ធ្វើយ៉ាងនេះដើម្បីឱ្យទីនោះ ៗ មានស្មៅដុះល្អ ។

ថ្ងៃមួយក្មេងទាំង ៧ នាក់នោះបានឃើញទន្សងមួយក្នុងពេលដែលដេញគោត្រឡប់មកផ្ទះវិញ ក៏នាំគ្នាដេញ. ទន្សងនោះបានរត់ចូលទៅក្នុងរន្ធដំបូកមួយ មិនអាចចាប់បានភ្លាម១ ក៏កាច់មែកឈើម្នាក់មួយក្តាប់ យកទៅចុករន្ធទន្សងនោះ ហើយដេញគោទៅផ្ទះ ដោយគិតថា ស្អែកសឹមមកចាប់វា ។ លុះស្អែកឡើង ត្រូវដេញគោទៅឃ្វាលទីដទៃភ្លេចនឹករឿងទន្សងនោះទៅ. ដល់ថ្ងៃទី ៧ ត្រូវដេញគោទៅឃ្វាលទីនោះវិញ ទើបនឹកឃើញនាំគ្នាទៅដកធ្នុកចេញ. ទន្សងដាច់ចំណីយូរ ហើយស្គមនៅតែឆ្អឹង មានខ្លួនញ័ររំប្រេបវារត់គើមចេញមក ។ ក្មេងទាំង ៧ នាក់ឃើញដូច្នោះហើយ ក៏មានចិត្តអាណិតអាសូរ នាំគ្នាអង្អែលខ្នងទន្សង

នោះហើយលែងទៅ ។ ក្មេងទាំង ៧ នាក់មិនបានទៅកើតក្នុងនរកឡើយ ព្រោះមិនបានធ្វើទន្យងនោះឱ្យស្លាប់ គ្រាន់តែមានពៀរ ត្រូវដាច់បាយទឹក ៧ ថ្ងៃ វេទនាជិតស្លាប់អស់ ១៤ជាតិមកហើយ ។ ក្នុងជាតិនេះបានមកកើតជាភិក្ខុ៧ រូប ត្រូវជាប់នៅក្នុងរូងគុហា អត់បាយអត់ទឹកអស់ ៧ ថ្ងៃនេះឯង ។

## ១៧- រឿងឯកបុត្តគហបតី

(ចាក បិ. ម.)

(សេចក្ដីទុកសោក កើតអំពីសេចក្ដីស្រឡាញ់)

កាលនោះព្រះមានព្រះភាគ គង់នៅវត្តជេតពន ជិតក្រុងសាវត្ថី ។ មានគហបតីម្នាក់ កើតទុក្ខក្រៀមក្រំ បានចូលទៅគាល់ព្រះអង្គ ក្រាបថ្វាយបង្គំហើយអង្គុយក្នុងទីគួរមួយ។

ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី អ្នកមានមុខក្រៀមស្រពាប់ស្រពោន តើមានហេតុអ្វី ?

គហបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលព្រះបង្គំមានបុត្រតូចតែមួយគត់ ឥឡូវវាធ្វើមរណកាលចោលខ្ញុំព្រះអង្គទៅ ។ និយាយដូច្នេះហើយ ក៏យំសោកចំពោះព្រះភក្ត្រ រៀបរាប់ថា ម្នាលកូនសម្លាញ់ ឪពុកស្រឡាញ់កូនណាស់ ស្រឡាញ់កូនស្មើជីវិត តាំងពីកូនស្លាប់ទៅ ឪតែងទៅយំសោក ហៅរកកូនទៅឈាបនដ្ឋានរាល់ថ្ងៃ កិច្ចការ និងចំណីអាហារ ឪលះបង់អស់ហើយ ឥតចង់បានទ្រព្យ ឥតស្រេកឃ្លានឡើយ. តើឥឡូវនេះកូនទៅទីណាឱ្យឪឃើញមុខផង ។

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលគហបតី ដំណើរនេះពិត

យ៉ាងហ្នឹងហើយ សេចក្តីសោកស្តាយ ខ្សឹកខ្សួល ទុក្ខតូចចិត្ត និងការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

គហបតីឆ្លើយបដិសេធពុទ្ធភាសិតនេះថា ត្រូវដូច្នោះខ្លះដែរ ប៉ុន្តែបើតាមពិតនោះ សេចក្តីត្រេកអរ និងសេចក្តីរីករាយ តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតវិញទេ ។ និយាយដូច្នេះហើយ ក៏ក្រោកចាកអាសនៈចេញទៅ ឥតមានការគួរសមចំពោះព្រះសម្ពុទ្ធឡើយ ។ ទៅដល់ពាក់កណ្តាលផ្លូវ បានជួបពួកអ្នកលេងល្បែងភ្នាល់ ក៏និយាយប្រាប់អ្នកទាំងនោះថា ព្រះពុទ្ធបានសម្តែងខុសយ៉ាងនេះថា សេចក្តីទុក្ខសោកកើតមកពីសេចក្តីស្រឡាញ់ ។ ចំណែកខ្ញុំយល់ថា សេចក្តីត្រេកអររីករាយសប្បាយ កើតពីសេចក្តីស្រឡាញ់វិញ ។ ពួកអ្នកលេងឆ្លើយអបជើងថា ប្របាទរូច លោកមានប្រសាសន៍ពិតជាត្រូវ ។ គហបតីគិតថា វាទៈរបស់អញសម់គ្នានឹងយោបល់របស់ពួកអ្នកលេងហើយ ។ ក៏ដើរចេញពីទីនោះទៅ ។

ពាក្យនេះបានឮខ្ចរខ្ចាយទៅក្នុងព្រះរាជវាំង, ព្រះបាទបសេនទិកោសល ត្រាស់សួរនាងមល្លិកាទេវីជាមហេសី

ថា ព្រះសមណគោតម ជាគ្រូរបស់នាងបានសម្តែងថា សេចក្តីទុក្ខសោកកើតអំពីសេចក្តីស្រឡាញ់ ដូច្នោះមែនឬ ?

ព្រះនាងមល្លិកាទេវីក្រាបបង្គំទូលថា បើព្រះសម្ពុទ្ធបរមគ្រូសម្តែងយ៉ាងណាពិតជាដូច្នោះមែនហើយ ។

វេលានោះព្រះបាទបសេនទិកោសល ទ្រង់ខ្ញាល់ចំពោះនាងមល្លិកាទេវីថា នែ ! មល្លិកានាងចេះតែចាក់បណ្តោយ ឱ្យតែគ្រូថាយ៉ាងណា សិស្សចេះតែគាំទ្រថាត្រូវយ៉ាងនោះ នាងចូរជៀសចេញអំពីមុខអញទៅ នាងឯងខិលខូចណាស់ ។ នាងក៏ចេញទៅរាជដំណាក់វិញ ។

លុះទៅដល់ហើយ បានហៅនាឡិជង្ឃព្រាហ្មណ៍ឱ្យចូលគាល់ មានព្រះសវនីយ៍ថា នែ ព្រាហ្មណ៍ចូរអ្នកទៅគាល់ព្រះសម្ពុទ្ធបរមគ្រូ ថាខ្ញុំសូមថ្វាយបង្គំព្រះបាទា ដោយសិរ.សាហើយថា ខ្ញុំសូមក្រាបបង្គំទូលសួរអំពីព្រះវាចាថាសេចក្តីទុក្ខសោក កើតអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត តើព្រះអង្គបានសម្តែងដូច្នេះមែនឬទេ ។

កាលនាឡជង្ឃព្រាហ្មណ៍ទៅដល់ថ្វាយបង្គំ តាមដំណើការណ៍ ហើយព្រះសម្ពុទ្ធត្រាស់ថា ពិតដូច្នោះមែនរឿងធ្លាប់មានមកហើយ ។

ម្នាល់ព្រាហ្មណ៍ ក្នុងក្រុងសាវត្ថីនេះ មានស្ត្រីម្នាក់កើតទុក្ខសោក ព្រោះមាតាស្លាប់ នាងទៅជាឆ្កួត ដើរគ្រប់ច្រកល្ហកសួររកមាតាខ្លួន ។ នេះហើយជាសេចក្ដីទុក្ខសោកកើតអំពីសេចក្ដីស្រឡាញ់ ។

ម្នាលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថីនេះឯង មានបុរសម្នាក់កើតទុក្ខព្រោះមាតាស្លាប់ដែរ បុរសនោះទៅជាឆ្កួតដើរគ្រប់ច្រកល្ហកសួររកមាតាខ្លួន ។ នេះហើយជាសេចក្ដីទុក្ខកើតអំពីសេចក្ដីស្រឡាញ់ ។

ម្នាលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថីនេះឯង មានស្ត្រីម្នាក់ទើបនឹងមានស្វាមី, ពួកញាតិរបស់នាងមិនពេញចិត្តបាននិយាយបំបែកចេញអំពីស្វាមី បម្រុងលើកនាងទៅឱ្យបុរសដទៃទៀត ។ នាងមានសេចក្ដីស្រឡាញ់ចំពោះស្វាមីបានដំណាលរឿងនោះប្រាប់ ។ ឯស្វាមីក៏មានសេចក្ដីស្រឡាញ់ចំពោះនាងដែរ សុខចិត្តស្លាប់ទាំងអស់គ្នា សុំឱ្យបានជួបគ្នាក្នុងបរលោក គិតស្រុះគ្នាដូច្នេះហើយ ស្វាមីកាប់ប្រពន្ធជាពីរកំណាត់ ហើយវះពោះខ្លួនឯងស្លាប់ជាមួយគ្នាទៅ ។ នេះឯងជាសេចក្ដីទុក្ខសោក កើតអំពីសេចក្ដីស្រឡាញ់ ។

គ្រានោះ នាឡិជង្ឃព្រាហ្មណ៍ ត្រេកអរ អនុមោទនាចំពោះព្រះពុទ្ធភាសិតនេះ ហើយថ្វាយបង្គំលាទៅបរមរាជវាំង នាំពុទ្ធភាសិតនោះទៅក្រាបទូលនាងមល្លិកាទេវីតាមដំណើររឿង ។

ព្រះនាងមល្លិកាទេវី មានព្រះទ័យរីករាយ ចូលទៅគាល់ព្រះបាទបសេនទិកោសល ទូលសួរថា បពិត្រមហារាជកុមារីព្រះនាមវជីរី ជារាជធីតា តើព្រះអង្គសព្វព្រះទ័យស្រឡាញ់ទេ ?

- អើមល្លិកា យើងស្រឡាញ់ វជីរីកុមារណាស់ ។

- បើកុមារីនេះ និរាសព្រាត់ប្រាស់ទៅ តើព្រះអង្គមានសេក្តីទុក្ខសោកតូចព្រះទ័យឬទេ ?

- អើ មល្លិកា បើដូច្នេះមែន ជីវិតរបស់អញ ក៏មុខជានឹងប្រែប្រួលទៅដែរ ចំណង់បើសេចក្តីទុក្ខសោកនោះនឹងខានកើតមានដល់អញឯណាបាន ។

- បពិត្រមហារាជ នាងវាសភខត្តិយា ព្រះអង្គសព្វព្រះទ័យស្រឡាញ់ឬទេ ?

- អើ មល្លិកា យើងស្រឡាញ់វាសភខត្តិយាណាស់ ។

- បើនាងព្រាត់ប្រាស់និរាសទៅ តើព្រះអង្គមាន

សេចក្ដីទុក្ខសោកតូចព្រះទ័យឬទេ ?

- ពិតជាមានណាស់ហើយ ។

- បពិត្រមហារាជ វិឌូឌភសេនាបតី ព្រះអង្គសព្វព្រះទ័យស្រឡាញ់រាប់អានឬទេ ?

- អើ មល្លិកា យើងស្រឡាញ់សេនាបតីនេះណាស់។

- បើសេនាបតីនោះព្រាត់ប្រាស់និរាសទៅ តើព្រះអង្គមានសេចក្ដីទុក្ខសោកតូចព្រះទ័យឬទេ ?

- ពិតជាមានណាស់ហើយ ។

- បពិត្រមហារាជ ចុះខ្លួនខ្ញុំម្ចាស់ តើព្រះអង្គសព្វព្រះទ័យស្រឡាញ់ដែរឬទេ ?

- អើ មល្លិកា ឯងជាទីស្រឡាញ់របស់អញណាស់ដែរ។

- បើខ្ញុំម្ចាស់ ព្រាត់ប្រាស់និរាសចាកព្រះអង្គទៅ តើព្រះអង្គមានសេចក្ដីទុក្ខសោក អាឡោះអាល័យតូចព្រះទ័យដែរឬទេ ?

- អើ មល្លិកា ! បើឯងព្រាត់ប្រាស់ពីអញទៅ សេចក្ដីទុក្ខសោក នឹងកើតមានដល់អញប្រាកដណាស់ សូម្បីជីវិតអញក៏នឹងប្រែប្រួលទៅដែរ ។

- បពិត្រមហារាជ ដែនកាសី និងដែនកោសល តើ

អង្គសព្វព្រះទ័យឬទេ ?

- អើ មល្លិកា ដែនទាំងពីរនេះ ជាទីស្រឡាញ់របស់ព្រោះយើងប្រើប្រាស់ខ្លឹមចន្ទន៍ ដែលបានមកអំពីដែនទ្រទ្រង់កម្រងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗអានុភាពនៃដែនទាំងពីរនេះឯង ។

- បើដែនទាំងពីរនេះ មានវិបត្តិប្រែប្រួលទៅ តើព្រះមានសេចក្តីទុក្ខសោក តូចព្រះទ័យឬទេ ?

- អើ មល្លិកា ពិតជាមានណាស់ហើយ ។

កាលបើព្រះបាទបសេនទិកោសល បានយល់ហេតុនៃសេចក្តីស្រឡាញ់ និងសេចក្តីទុក្ខសោកដូច្នេះហើយនាងមល្លិកាទើបក្រាបបង្គំទូលថា :

បពិត្រមហារាជ ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូរបស់ខ្ញុំទ្រង់ជ្រាបច្បាស់ ឃើញច្បាស់តាមដំណើរនេះហើយព្រះអង្គត្រាស់សម្តែងថា " បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកា ប្រែថា សោកខ្សឹកខ្សួល សេចក្តីទុក្ខតូចចិត្ត សេចក្តីចង្អៀតចិត្ត តែងកើតឡើងអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត " ។

ព្រះបាទបសេនទិកោសល ត្រាស់ថា អស្ចារ្យណាស់ មល្លិកា ព្រះសម្ពុទ្ធអង្គនោះ ប្រហែលជាទ្រង់ត្រាស់ដឹង ឃើញច្បាស់ដោយប្រាជ្ញាមែន. នាងចូរឱ្យទឹកសម្រាប់ជម្រះ កាយដល់អញ ។ លុះព្រះអង្គជម្រះព្រះកាយហើយ ពាន់ា សំពត់ ប្រណម្យអញ្ជលីឆ្ពោះត្រង់ទីព្រះសម្ពុទ្ធ ទ្រង់គង់បន្លឺ ឧទានអស់វារៈបីដងថា "នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស " ។

# ១៨- រឿងកុណាលរាជកុមារ

(ចាក អ. ម.)

(អានិសង្សសាងព្រះពុទ្ធរូប ជួសជុលព្រះចេតិយ និងទោសខ្វះភ្នែកសត្វ)

សម័យក្រោយពុទ្ធកាល ព្រះនាងអសន្ធមិត្តា ជាឯក-អគ្គមហេសីព្រះបាទធម្មាសោក មានព្រះរាជបុត្រមួយអង្គ ប្រកបដោយរូបឆោមសមល្អអស្ចារ្យ. ក្នុងពេលប្រសូត្រហើយ សេនាបតីមួយរូប បានទៅថ្វាយដំណឹងព្រះបាទធម្មា-សោកថា សូមមហារាជក្សាន្តព្រះរាជហឫទ័យចុះ ព្រោះព្រះរាជបុត្រដ៏ល្អអស្ចារ្យបានប្រសូត្រហើយ ។

ព្រះរាជា មានព្រះទ័យត្រេកអរ ទ្រង់បន្លឺព្រះសូរសី-ហនាទថា រាជត្រកូលយើងបានថ្កើងរុងរឿងដល់ថ្នាក់ខ្ពស់បំផុតហើយ ព្រោះយើងបានគ្រប់គ្រងរាជ្យប្រកបដោយធម៌ ទើបបានរាជបុត្រប្រសើរបែបនេះ សូមឱ្យវាបានទំនុកបំរុងពុទ្ធសាសនា ឱ្យចម្រើនក្រៃលែងទៅទៀត ។

ពេលនោះ ភីលៀងបាននាំព្រះរាជបុត្រទៅថ្វាយទតព្រះរាជាទតហើយ សព្វព្រះទ័យណាស់ ទ្រង់ត្រាស់ថា ចក្ខុរបស់ទារកនេះល្អណាស់ វាបានប្រកបដោយមហាកុសលធំណាស់ ដូចជាផ្កាឧប្បលទើបនឹងរីក មានភក្ត្រល្អស្រស់ប្រិម-

ប្រិយ អ្នកណាបានឃើញ អ្នកនោះនឹងបានសប្បាយរីករាយគ្រប់គ្នា ។ តើលោកសេនាបតីធ្លាប់បានឃើញមនុស្សមានភ្នែកល្អ ដូចចក្ខុទារកខ្ញុំដែរឬ ?

សេនាបតីក្រាបបង្គំទូលថា ភ្នែករបស់មនុស្សក្នុងលោកនេះ មិនមានល្អដូចព្រះនេត្ររាជទារកនេះឡើយ មានតែបក្សីម្យ៉ាងនៅកំពូលភ្នំហេមពាន្តឈ្មោះកុនាលៈ ទើបមានភ្នែកល្អ ស្រដៀងនឹងព្រះនេត្រព្រះរាជទារកនេះ ។

គ្រានោះ ព្រះរាជាបានប្រើយក្សជាសេនា ឱ្យទៅចាប់បក្សីកុនាលៈនោះមកថ្វាយទត. លុះបានទតភ្នែកបក្សីនោះហើយ ត្រាស់ថា អើហ្ន ! ភ្នែកបក្សីនេះល្អដូចនេត្រាទារកអញ ដូច្នេះយើងថ្វាយនាមទារកយើងថា "កុនាលរាជកុមារ" ព្រះនាម និងព្រះនេត្រដ៏ល្អនេះ ក៏ល្បីទូទៅក្នុងជម្ពូទ្វីប ។ លុះព្រះរាជកុមារ កុនាលៈពេញវ័យហើយ ព្រះញាតិវង្ស បានថ្វាយរាជកុមារីម្នាក់ឈ្មោះកាញ្ចនមាលាជាព្រះជាយា ។

ថ្ងៃមួយ ព្រះរាជាបាននាំព្រះរាជកុមារកុនាលៈ ទៅវត្តកុក្កុដារាម ថ្វាយបង្គំព្រះយសត្ថេរ ១ បានពិចារណាព្រះរូបឆោមដ៏ល្អស្រស់របស់ព្រះកុនាលៈហើយ ជ្រាបថា តទៅថ្ងៃមុខ ព្រះរាជកុមារនេះនឹងខូចព្រះនេត្រទាំងពីរ ព្រោះ

ផលកម្មខ្វះភ្នែកសត្វពីអតីតជាតិ. លុះខូចព្រះនេត្រហើយ នឹងបានសម្រេចមគ្គផលថ្នាក់សកទាគាមិ ព្រោះផលល្អដែលបានសាងព្រះពុទ្ធរូប និងជួសជុលព្រះចេតិយ។ លោកជ្រាបដូច្នេះហើយ ទើបថ្វាយព្រះពរព្រះរាជាថា បពិត្រមហារាជហេតុអ្វីបានជាទ្រង់មិនអនុញ្ញាតឱ្យព្រះអង្គ ម្ចាស់កុនាលៈស្តាប់ធម៌ដោយគោរព ?

ព្រះរាជា ទ្រង់អនុញ្ញាតឱ្យព្រះរាជបុត្រ ធ្វើតាមឱវាទព្រះថេរៈ. ព្រះរាជកុមារ ក៏ចូលទៅជិតថ្វាយបង្គំ ប្រុងស្តាប់ធម៌ ព្រះថេរៈមានថេរដីកាថា សូមព្រះរាជកុមារយកព្រះទ័យទុកដាក់ ព្យាយាមពិចារណានូវវិបស្សនាកម្មដ្ឋានជានិច្ចរាល់ថ្ងៃថា "**ចក្ខុនោះៗ មិនមែនជារបស់ខ្លួនឡើយ**" បើព្រះរាជកុមារ បានពិចារណាស្ទាត់ជំនាញហើយ សេចក្តីសុខដ៏ធំទូលាយ នឹងកើតមានដល់ព្រះរាជកុមារមិនខាន ។ តាំងពីពេលនោះមក ព្រះកុនាលរាជកុមារ ខំព្យាយាមពិចារណាតាមថេរដីកាឥតធ្វេសប្រហែសឡើយ ។

ថ្ងៃមួយ បានចូលទៅសម្ងំពិចារណាក្នុងព្រះរាជដំណាក់ស្ងាត់. ស្រាប់តែនាងតិស្សរក្ខិតា ជាព្រះមាតាចុងដែលមានសេចក្តីស្នេហាព្រះរូបឆោមរាជកុមារ បានចូលទៅ

ឱបរឹត និយាយប្រលោមក្នុងផ្លូវកាមតណ្ហា. ព្រះរាជកុមារសុំអង្វរហើយមានបន្ទូលថា ទូលបង្គំមិនចង់ឮវាចាអពមង្គលនេះឡើយ ព្រះអង្គក៏ជាមាតាទូលបង្គំដែរ មិនគួរមកធ្វើកម្មដ៏លាមកដូច្នេះសោះ អំពើនេះនឹងនាំព្រះអង្គទៅនរកមិនខាន សូមព្រះអង្គយាងចេញពីបន្ទប់ដ៏ស្ងាត់របស់ទូលបង្គំនេះទៅ កុំនៅបង្អង់យូរ ទូលបង្គំសុខចិត្តលះបង់ជីវិត ដើម្បីសុចរិតធម៌ ទូលបង្គំមិនបំពេញបំណងអាប់យសរបស់ព្រះអង្គឡើយ ។

នាងតិស្សរក្ខិតា កាលមិនបានសម្រេចដូចបំណងហើយ ក៏ត្រឡប់មកមហាប្រាសាទវិញ មានសេចក្ដីអៀនខ្មាស់ក្រៃលែង. ចាប់ពីថ្ងៃនោះមក នាងខំស្វែងរកទោសដើម្បីសម្លាប់ព្រះរាជកុមារជាការសងសឹក ។

ក្នុងពេលមួយ ដែលមានការបះបោរ នាក្រុងតក្កសិលាក្នុងដែនគន្ធារៈ. ព្រះរាជាសព្វព្រះហឫទ័យទៅបង្ក្រាបផ្ទាល់ព្រះអង្គ ។ ពួកសេនាបតីក្រាបបង្គំទូលថា បពិត្រមហារាជ ការបះបោរនោះមិនធំប៉ុន្មានគួរនឹងយាងទៅបង្ក្រាបផ្ទាល់ព្រះអង្គឡើយ គ្រាន់តែចាត់ព្រះរាជបុត្រអង្គណាមួយទៅបង្ក្រាបបានហើយ ។

ព្រះរាជាត្រាស់សួទៅកុនាលៈថា កូនអាចទៅបង្ក្រាបបានឬទេ ?

ព្រះកុនាលៈក្រាបបង្គំទូលថា ខ្ញុំព្រះអង្គអាចទៅបង្ក្រាបថ្វាយបាន ។

កាលព្រះកុនាលៈ យាងទៅជិតដល់ក្រុងតក្កសិលា អ្នកនគរនាំគ្នាស្អិតស្អាងផ្លូវ សម្អាតទីក្រុងនាំយកគ្រឿងសក្ការបូជា ទៅថ្វាយក្នុងទីកន្លះយោជន៍ ក្រាបបង្គំទូលថា ពួកយើងខ្ញុំ មិនក្បត់ព្រះរាជារបស់ខ្លួនឡើយ ដែលបះបោរនេះ ប្រឆាំងចំពោះតែអ្នករាជការទុច្ចរិត ដែលជាអ្នកធ្វើការថ្វាយព្រះរាជា មិនយុត្តិធម៌, ទើបនាំគ្នាហែហមព្រះកុនាលៈរាជកុមារ ចូលទៅក្នុងក្រុងដោយសេចក្តីគោរពក្រៃលែង ។

ក្នុងវេលានោះ ព្រះបាទធម្មាសោក ទ្រង់ប្រឈួនយ៉ាងខ្លាំងធ្លាក់ឧច្ចារៈតាមព្រះឱស្ឋ និងចេញព្រះលោហិតស្អុយផ្អេះផ្សាបតាមព្រះលោមា, ព្រះអង្គមានព្រះឱង្ការនឹងពួកសេនាបតី ឱ្យទៅយាងព្រះកុនាលៈមកអភិសេកឱ្យសោយរាជ្យ ព្រោះព្រះអង្គគ្មានសង្ឃឹមថា នឹងមានព្រះជន្មតទៅទៀតឡើយ ។

ព្រះនាងតិស្សរក្ខិតា ជាមហេសីចុង បានឮព្រះឱង្ការ

នោះហើយ គិតថា បើកុំនាលៈបានសោយរាជ្យ ខ្លួនអញពិត ជាស្លាប់. គិតដូច្នេះហើយ ក៏ក្រាបទូលព្រះរាជាថា សូមព្រះ អង្គអនុញ្ញាតឱ្យខ្ញុំម្ចាស់ព្យាបាលសិន ពីថ្ងៃនេះទៅ កុំឱ្យពេទ្យ ចូលមកព្យាបាលទៀត ចាំខ្ញុំម្ចាស់រកឱសថព្យាបាលឱ្យក្សាន្ត ព្រះទ័យ ជាព្រះរោគក្នុងពេលឆាប់ៗ ។ ព្រះរាជាសព្វព្រះ ទ័យតាមសំណូមពរនាង ក៏ហាមឃាត់ពេទ្យមិនឱ្យចូលមក ទៀត ។

ព្រះនាងតិស្សរក្ខិតា បានចេញប្រកាសប្រាប់អ្នកនគរ ថា បើមានបុរសស្ត្រីណាកើតរោគដូចរោគព្រះរាជា ត្រូវ បញ្ជូនអ្នកជម្ងឺនោះមកក្នុងវាំង ដើម្បីព្រះនាងព្យាបាលសាក ល្បងមើល ។

បន្ទាប់មករាជបុរស បាននាំបុរសម្នាក់មានជម្ងឺដូច ព្រះរាជា មកថ្វាយព្រះនាង ១ ឱ្យសម្លាប់បុរសនោះវះពោះ មើល ឃើញមានដង្កូវធំមួយក្នុងក្រពះ. កាលដង្កូវនោះស្ទុះ ឡើងលើ ឧច្ចារៈក៏ច្រាលឡើងក្អួតចេញមក, កាលស្ទុះទៅ ក្រោម ឧច្ចារៈក៏ចុះភគតាមបាតទៅ ។ ព្រះនាងបានយកថ្នាំ គ្រប់យ៉ាងដាក់សម្លាប់ដង្កូវនោះមិនស្លាប់ យកម្រេចដាក់ក៏ មិនស្លាប់ ដល់យកខ្ទឹមសបុកដាក់ ដង្កូវនោះក៏ស្លាប់ភ្លាម ។

ព្រះនាងបានចូលទៅក្រាបបង្គំទូលព្រះរាជាឱ្យសោយខ្ទឹម ។

ព្រះរាជាត្រាស់ថា យើងជាជាតិក្សត្រ នឹងសោយខ្ទឹមដូចម្ដេចបាន ។

ព្រះនាងក្រាបបង្គំទូលជាច្រើនដងថា ការសោយខ្ទឹមនេះ ជាឱសថព្យាបាលសក្តិសិទ្ធិអាចរំងាប់ព្រះរោគព្រះអង្គបាន ។

ព្រះរាជាចង់បំបាត់រោគចម្លែកនោះ ក៏សព្វព្រះទ័យសោយខ្ទឹមជាច្រើន. ដង្កូវក្នុងព្រះឧទរ ត្រូវជាតិខ្ទឹមហើយ ក៏ស្លាប់ធ្លាក់មកតាមបាទ. ព្រះអង្គបានជាស្រឡះចាករោគាពាធមួយរំពេចក្នុងពេលនោះ ទ្រង់មានព្រះទ័យត្រេកអរចំពោះព្រះនាងតិស្សរក្ខិតា បានព្រះរាជទានពរដល់ព្រះនាងថា បើចង់បានអ្វី នឹងព្រះរាជទានតាមបំណង ។

ព្រះនាងបានឱកាសល្អនឹងសងសឹក ចំពោះព្រះកុនាលរាជកុមារ ហើយក៏ក្រាបបង្គំទូលថា ខ្ញុំម្ចាស់ចង់សោយរាជ្យសម្បត្តិបាន ៧ ថ្ងៃ. ព្រះរាជាបានប្រទានរាជ្យ ៧ ថ្ងៃចំពោះព្រះនាង ដោយព្រះទ័យរីករាយ ។

លុះព្រះនាងបានសោយរាជ្យហើយ ក៏ក្លែងលិខិតថា ព្រះបាទធម្មាសោក បង្គាប់ទៅអ្នកនគរតក្កសិលាឱ្យនាំគ្នា

ឆ្កៀលភ្នែកទាំងពីររបស់ព្រះកុនាលៈចេញ ព្រោះវាមានកំហុសទទឹងទាស់ចំពោះព្រះរាជអាជ្ញា ។ លុះសរសេរលិខិតនេះចប់ហើយ ព្រះនាងក៏ធ្វើជាចូលទៅគាល់ ដើម្បីលួចប្រថាប់ត្រាព្រះទន្តរបស់ព្រះរាជា, ព្រោះថា ព្រះបាទធម្មា-សោកមានការប្រុងប្រយ័ត្នណាស់ ព្រះរាជសារព្រះអង្គដែលចេញប្រើជាផ្លូវការ សុទ្ធប្រថាប់ដោយព្រះទន្ត(ធ្មេញ) ព្រះអង្គ អាស្រ័យហេតុនេះហើយ ទើបព្រះនាងតិស្សរក្ខិតានៅរង់ចាំព្រះរាជាផ្ទំលក់នឹងលួចប្រថាប់ព្រះទន្ត ។

ក្នុងពេលព្រះអង្គផ្ទំលក់ ព្រះនាងកំពុងតែរៀបប្រថាប់ព្រះទន្ត ស្រាប់តែព្រះរាជាមានសុបិនអាក្រក់ស្ទុះឡើង មានព្រះបន្ទូលថា យើងសុបិនអាក្រក់ណាស់ ឃើញត្មាត វាចង់ចោះកែវភ្នែក កុនាលៈ កូនយើង ។ មានបន្ទូលហើយក៏ផ្ទំលក់ទៅវិញ, ព្រះនាងប្រុងប្រថាប់ព្រះទន្តទៀត សុបិនអាក្រក់ក៏កើតឡើងចំពោះព្រះរាជាទៀត ព្រះអង្គស្ទុះឡើងមានបន្ទូលថា យើងឃើញកុនាលៈ កូនយើងមានសក់ពុកមាត់ ពុកចង្កាវែង អង្គុយផ្ទាល់លើផែនដី ។ ព្រះនាងតិស្សរក្ខិតាក្រាបទូលថា ព្រះកុនាលៈ មានបុណ្យបារមីណាស់ ពុំមាននរណាបៀតបៀនឡើយ ។ ព្រះរាជាក៏ផ្ទំលក់

ទៅទៀត. ព្រះនាងក៏លួចប្រថាប់ព្រះទន្តបានក្នុងពេលនោះ ហើយចេញទៅ. ព្រះរាជាទ្រង់សុបិនទៀតថា ព្រះទន្តរបស់ព្រះអង្គបាក់ជ្រុះអស់ ។ លុះព្រឹកឡើង ព្រះរាជាបានហៅហោរាឱ្យមកកាត់សុបិនថ្វាយ. ហោរាក្រាបបង្គំទូលថា ព្រះអង្គម្ចាស់កុនាលៈ ពិតជាមានគ្រោះថ្នាក់ខូចព្រះនេត្រទាំងពីរមិនខាន ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យហោរាហើយ ទ្រង់ប្រណាម្យអញ្ជើញមនុស្សការគ្រប់ទិសទាំង ៤ បួងសួងវត្ថុសក្តិសិទ្ធិ មានព្រះរតនត្រ័យជាដើម សូមជួយរក្សាព្រះរាជបុត្រឱ្យបានសុខផុតគ្រោះថ្នាក់ ។

ថ្លែងពីពួកអ្នកនគរតក្កសិលា កាលបើបានទទួលព្រះរាជសារក្លែនោះហើយ មានចិត្តតក់ស្លុតអាណិតព្រះកុនាលៈគ្រប់ៗគ្នា មិនដាច់ចិត្តថ្វាយព្រះរាជសារឱ្យព្រះអង្គជ្រាបឡើយ ។ កាលបើនឹកឃើញដល់ព្រះរាជអាជ្ញា ដែលមិនមាននរណាទប់ទល់បាន ក៏ដាច់ចិត្តថ្វាយព្រះរាជសារនោះចំពោះព្រះកុនាលៈៗ បានទទួលហើយមិនរំភើបព្រះទ័យឡើយមានបន្ទូលថា អ្នកទាំងឡាយចូរផ្តៀលភ្នែកខ្ញុំតាមព្រះរាជសារចុះខ្ញុំមិនប្រកែក មិនទោមនស្សឡើយ ខ្ញុំពេញចិត្តគោរព

តាមព្រះរាជសាវបិតាខ្ញុំហើយ ។

ពួកអ្នកនគរតក្កសិលាទូលថា យើងខ្ញុំសុខចិត្តឆ្កៀល ភ្នែករបស់ខ្លួនជំនួសព្រះអង្គវិញ យើងខ្ញុំមិនហ៊ានប៉ះពាល់ព្រះអង្គឡើយ ។

ព្រះកុនាលៈបានយកប្រអប់មាសមួយតម្លៃ ១ សែនកម្លឹងប្រទានឱ្យពួកចណ្ឌាលជារង្វាន់ ឱ្យឆ្កៀលព្រះនេត្រថ្វាយព្រះបិតា, ពួកចណ្ឌាលប្រកែកគ្រប់ៗ គ្នា ។

ជួនជាពេលនោះ កម្មពីអតីតជាតិបានផ្តល់មកបណ្តាលឱ្យមនុស្សវិកលវិការម្នាក់ស្ទុះចូលទៅសុំឆ្កៀលព្រះនេត្រព្រះកុនាលៈ ។ នឹកឃើញដល់វិបស្សនាធម៌ ដែលព្រះយសត្ថេរឱ្យចម្រើនជាយូរមកហើយនោះថា ភ្នែកជារបស់មិនទៀត ទើបព្រះអង្គម្ចាស់កុនាលៈ ត្រាស់ចំពោះមនុស្សវិកលវិកាថា ចូរអ្នកឆ្កៀលភ្នែកយើងម្ខាង ដាក់មកលើបាតដៃយើងសិន ហើយចាំឆ្កៀលម្ខាងទៀត. មនុស្សនោះក៏ឆ្កៀលព្រះនេត្រម្ខាងដាក់ទៅលើព្រះហស្តថ្វាយ ។

ពួកអ្នកនគរមានសេចក្តីតក់ស្លុត ស្រែកទ្រហឹងអឹងកងឡើងថា ឱ ! ព្រះនេត្រដ៏ល្អត្រកាលដូចដួងច័ន្ទ ឥឡូវធ្លាក់ចុះហើយ ក៏នាំគ្នាទួញយំ ដោយសេចក្តីសោកស្តាយ

និងអាណិតអាសូរចំពោះព្រះកុមារ ។

ពេលនោះព្រះកុនាលរាជកុមារ ទតព្រះនេត្រដែលនៅលើបាតព្រះហស្ត ពិចារណាវិបស្សនាកម្មដ្ឋាន តាមឱវាទព្រះយសត្ថេរ ក៏បានសម្រេចសោតាបត្តិផល, ទើបត្រាស់បង្គាប់មនុស្សវិកលវិការនោះថា ចូរអ្នកឆ្កៀលភ្នែកខ្ញុំម្ខាងទៀតដាក់មកលើបាតដៃខ្ញុំម្ខាងទៀតចុះ ។ មនុស្សនោះក៏ឆ្កៀលថ្វាយមួយរំពេច ទទួលយករង្វាន់ប្រអប់មាសនោះទៅ ។

ព្រះកុនាលរាជកុមារ បានពិចារណាវិបស្សនាកម្មដ្ឋានទៀត ក៏បានសម្រេចជាសកទាគាមិ ជ្រាបច្បាស់នូវអរិយសច្ចធម៌ ហើយមានព្រះបន្ទូលថា "មំសចក្ខុរបស់អញវិនាសអស់ហើយ អញបាននូវបញ្ញាចក្ខុ គឺធម្មចក្ខុ ដ៏ប្រសើរជំនួសវិញ. ព្រះបិតាបោះបង់អញជាបុត្រចោលហើយក្នុងវដ្តសង្សារ អញត្រឡប់បានជាបុត្ររបស់ព្រះពុទ្ធជាធម្មារាជាវិញ បើទុកជាអញវិនាសហើយចាករាជសម្បត្តិ ក៏អញបាននូវធម្មសម្បត្តិ រួចស្រឡះចាកសេចក្តីទុក្ខព្រួយហើយ ។ ព្រះរាជកុមារបានជ្រាបដោយបញ្ញាចក្ខុក្នុងពេលនោះថា ព្រះរាជសារឱ្យឆ្កៀលព្រះនេត្រនោះ ជាសារក្លែងក្លាយរបស់ព្រះ

នាងតិស្សរក្ខិតា ធ្វើសងសឹកព្រះអង្គ ដែលមិនព្រមរួមរ័ក្ស ស្នេហាជាមួយ. ព្រះអង្គក៏ផ្សាយមេត្តាចិត្ត ឱ្យព្រះនាងបាន សុខចម្រើន មានព្រះជន្មវែង ជុំធ្លើងក្នុងរាជសម្បត្តិតទៅ ព្រោះព្រះនាងមានគុណធំ បានធ្វើឱ្យព្រះអង្គបានសម្រេច មគ្គផលរួចចាកទុក្ខទាំងពួង ។

គ្រានោះនាងកាញ្ចនមាលាជា ជាយាព្រះកុនាលៈ បានជ្រាបថា គេខ្វៀលព្រះនេត្រព្រះស្វាមីហើយ ក៏ស្ទុះមីម្នា ទៅរក ឃើញលោហិតកំពុងហូរចេញពីព្រះនេត្រទាំងគូរ ក៏ ស្រែកយំរន្ធត់សន្ធប់បាត់ស្មារតី. លុះមានស្មារតីវិញ ក៏ទ្រង់ ព្រះកន្សែងរៀបរាប់សោកស្តាយថា "ព្រះនេត្រាដ៏បរិសុទ្ធ ល្អផុតក្នុងលោកវិនាសអស់ហើយ ធ្វើម្តេចឡើយនឹងមានដូច ដើមវិញ" ។

ព្រះកុនាលៈត្រាស់លួងលោមថា "អំពើអកុសល ដែលបងបានធ្វើហើយពីអតីតជាតិ បងត្រូវទទួលអំពើនោះ ផ្ទាល់ខ្លួនវិញ សេចក្តីទុក្ខសោក ជាការធម្មតារបស់សត្វ លោក ចូរប្អូនលះបង់ចេញ គ្មានប្រយោជន៍អំពីការយំសោក ឡើយ" យើងត្រូវចេញអំពីនេះតាមព្រះរាជសារ ដែលឱ្យ ខ្វៀលភ្នែក ហើយឱ្យបំបរបង់ចេញអំពីនគរតក្កសិលានេះ ។

ព្រះនាងកាញ្ចនមាលា បានដឹកព្រះហស្តព្រះកុនាលៈ ជាស្វាមី លាមហាជនក្នុងទីប្រជុំចេញចាកក្រុងតក្កសិលា យាត្រាផ្ទាល់ព្រះបាទលើផែនដី សុំទានអាហារអ្នកស្រុក សោយ ដោយដេញពិណ និងច្រៀងឱ្យម្ចាស់ទានស្តាប់ ជាច្រើនថ្ងៃខែ ទើបបានដល់ក្រុងបាតលីបុត្រ ។

ព្រះកុនាលៈ មានបំណងចង់ចូលទៅថ្វាយបង្គំព្រះបិតា បានឱ្យព្រះជាយានាំទៅសុំផ្លូវអ្នកយាមទ្វារ ៗ មិនឱ្យចូល ក៏ផ្ទំក្បែររោងដំរីជិតទ្វារព្រះរាជវាំង. លុះព្រលឹមស្រាងៗ ឡើងទ្រង់ដេញពិណ ច្រៀងរៀបរាប់ជីវប្រវត្តិរបស់ព្រះអង្គដ៏សែនវេទនាក់. អ្នកដែលបានស្តាប់ឮទាំងប៉ុន្មានកើតធម្មសង្វេគគ្រប់ៗគ្នា ។

ចំណែកព្រះបាទធម្មាសោក កាលបានឮសម្លេងពិណ និងច្រៀងនោះហើយ ក៏ភ្ញាក់ព្រះទ័យ នឹកព្រះកុនាលៈជារាជបុត្រ មានព្រះទ័យសង្ស័យដូចជាសម្លេងរាជបុត្រ ក៏ប្រើរាជបម្រើឱ្យទៅមើល។ រាជបម្រើទៅដល់មិនស្គាល់ព្រះកុនាលៈ និងព្រះជាយាឡើយ ព្រោះមានអាការៈស្គាំងស្គម ព្រះកេសាវែង ព្រះពស្ត្រារហែកប្រឡាក់ក្រខ្វក់ ក៏សម្គាល់ថាអ្នកសុំទាន ត្រឡប់ទៅក្រាបបង្គំទូលព្រះរាជាវិញថា អ្នកដេញពិណ

ហើយច្រៀងនោះ គឺស្នូមខ្វាក់ម្នាក់ស្គមកំព្រីង អង្គុយជិតប្រពន្ធវា ដែលមានសំលៀកបំពាក់ក្រខ្វក់រហែករយ៉ៃ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់រំលឹកដល់សុបិន ដែលឃើញត្មាតចោះព្រះនេត្រព្រះរាជបុត្រ ក៏ហាក់ដូចជាជ្រាបច្បាស់ថា ព្រះរាជបុត្រត្រូវខ្វាក់ព្រះនេត្រ ហើយពិតជាអ្នកសុំទាននោះឯង ក៏ប្រើព្រះរាជបម្រើថា ឯងទៅឱ្យគេចូលមកធាប់ ៗ អញនឹកកូនអញណាស់ ។ រាជបម្រើបានទៅនាំអ្នកសុំទាននោះមកថ្វាយភ្លាមមួយរំពេច ។

ព្រះរាជាចំណាំបុត្រមិនបាន គ្រាន់តែប្រហាក់ប្រហែល ក៏ត្រាស់សួរថា "ឯងជាកុនាលៈ មែនទេ ?

អ្នកសុំទានត្រាស់បង្គំទូលថា ព្រះករុណាថ្លៃវិសេសទូលព្រះបង្គំនេះហើយជាកុនាលៈ ត្រូវជាបុត្រព្រះអង្គ. ភរិយាទូលបង្គំនេះឈ្មោះកាញ្ចានមាលា ។

ព្រះរាជាកាលបានទតច្បាស់ ជ្រាបច្បាស់នូវការពិតនេះហើយ ទ្រង់ស្លុតព្រះហឫទ័យ សន្លប់បាត់ស្មារតី ដោយសេចក្ដីស្នេហា និងការអាណិតអាសូរបុត្រសំណប់ព្រះទ័យ។ លុះមានស្មារតីវិញ ក៏ទ្រង់លើកបីត្រកងបុត្រដាក់លើព្រះឱរូស្ទាបព្រះនេត្របុត្រ ហើយទ្រង់ព្រះកន្សែងថា "គ្រាមុន

នេត្រាបុត្រល្អដូចភ្នែកបក្សីកុនាលៈ ឥឡូវបុត្រវិនាសចាក នេត្រាដ៏ល្អនោះទៅហើយ ដូចជាផ្ទៃមេឃប្រាសចាកដួងចន្ទ តើនរណាឃោរឃៅ ហ៊ានបំផ្លាញនេត្រាបុត្រ ចូរប្រាប់បិតាឆាប់ ៗ មក បិតាមានការឈឺចាប់សោកស្តាយណាស់ " ។

ព្រះកុនាលរាជឱរស ឱនព្រះសិរក្រាបជិតបាទាព្រះបិតា ហើយក្រាបបង្គំទូលលួងលោមព្រះបិតាដោយធម្មកថាថា "សូមព្រះបិតាកុំសោយសោក ក្រេវក្រោធ ចំពោះអំពើដែលកន្លងហួសទៅហើយ កម្មទាំងឡាយជាកុសល និងអកុសលដែលខ្លួនបានធ្វើហើយ ខ្លួនត្រូវទទួលផលកម្មនោះវិញដោយខ្លួនឯង គ្មានបុរសបុគ្គលណាផ្តល់ឱ្យឡើយ. សូម្បីព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ក៏ត្រូវតែទទួលផលកម្មនោះដែរ ។ ចំណែកទូលបង្គំ ដែលបានទទួលផលអាក្រក់ដូច្នេះ ក៏ដោយអំពើអកុសលរបស់ទូលបង្គំដែរ មិនគួរស្តីបន្ទោស ផ្ចាញ់ផ្ចាលធ្វើទោសអ្នកដទៃឡើយ" ។

ព្រះបាទធម្មាសោក ទោះបីបានស្តាប់កម្មកថារបស់បុត្រសំណប់ព្រះទ័យនេះហើយ ក៏នៅតែក្តៅចេះធូលសោកស្តាយដដែល ទើបត្រាស់សួរព្រះរាជបុត្រទៀតថា "តើជនណាឃោរឃៅចិត្តគំនិតបំផ្លាញនេត្រាទាំងគូររបស់បុត្រ ?"

ព្រះកុនាលៈជ្រាបថា មិនអាចលាក់ចាំងបាន ក៏ទូលថា " នេត្រារបស់ទូលបង្គំ ត្រូវវិនាសដោយអំណាចព្រះរាជសារព្រះបិតា ដែលបានប្រថាប់ព្រះទន្ត ឱ្យគេឆ្កៀលនេត្រារបស់បុត្រ ហើយឱ្យបំបរបង់បុត្រចេញពីក្រុងតក្កសិលា ។

ព្រះរាជាទ្រង់បន្ទឺព្រះសូរសីហនាទថា បើបិតាបង្គាប់ឱ្យគេឆ្កៀលនេត្រាបុត្រមែន បិតានឹងកាត់ជិវ្ហា គាល់ព្រះទន្តចោលចេញដោយខ្លួនឯង ។

ក្នុងពេលនោះ ដោយអំណាចកម្មអកុសល បណ្ដាលឱ្យព្រះនាងតិស្សរក្ខិតា កើតវិប្បដិសារីយ៉ាងខ្លាំង បានហៅទាសីជំនិតមកប្រាប់ថា នាងឯងឆ្កៀលភ្នែកអញចុះ អញនឹងនាំបុត្រដើរសុំទានគេចិញ្ចឹមជីវិត ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ឮទាន់ពាក្យនោះ ក៏បានយល់ច្បាស់ថា ពិតជានាងតិស្សរក្ខិតានេះឯង ក្លែងព្រះរាជសារ ឱ្យគេឆ្កៀលនេត្រាកុនាលៈកូនសម្លាញ់អញ. ទោសៈក៏កើតឡើងឆេះឆួលក្នុងព្រះឱរា ទ្រង់សម្លឹងចំពោះព្រះនាងមិនដាក់ព្រះនេត្រ ហើយគម្រាមគួរឱ្យតក់ស្លុតថា "ហាងឯងលួចក្លែងព្រះរាជសារ ឱ្យគេបំផ្លាញភ្នែកកូនអញ. ហាងឯងជាស្រីចង្រៃ អញនឹងហែកហួរខ្លួនហាងឯងឱ្យខ្ទេចខ្ទី នឹង

ចាក់ហាងឯងទាំងរស់ ដោយឈើអណ្ដាត និងច្រៀកហាងឯងដោយចម្រៀកតូចៗ ដោយរណារ និងកាត់អណ្ដាតហាងឯងដោយកាំបិត និងក្របែលឆ្អឹងហាងឯងដោយពូថៅធំមុខគម្រិល នឹងបោះចោលហាងឯងក្នុងគុកភ្លើង នឹងបង្អកមាត់ហាងឯងដោយថ្នាំពិសពុលគ្រប់មុខ " ។

ព្រះរាជាមានព្រះឱង្ការដូច្នេះចប់ហើយ ព្រះកុនាលៈក្រាបទូលព្រះបិតា ដោយព្រះទ័យប្រកបដោយមេត្តាករុណាចំពោះនាងតិស្សរក្ខិតាថា " បពិត្រព្រះបិតា នាងតិស្សរក្ខិតាបានប្រព្រឹត្តខុសហើយ សូមទ្រង់ព្រះរាជទានទោសចំពោះព្រះនាង សូមកុំឱ្យមានការពិឃាតព្យាបាទជនណាឡើយ ។

ព្រះរាជាមិនស្ដាប់តាមព្រះរាជបុត្រ បានឱ្យពិឃ្ឍ-ឃាត នាំនាងតិស្សរក្ខិតា និងអ្នកក្រុងតក្កសិលា ដែលរួមគំនិតគ្នា ទៅដុតទាំងរស់ក្នុងពេលនោះ ។

ចំណែកភិក្ខុសង្ឃទាំងឡាយ បានឃើញហេតុអស្ចារ្យដូច្នេះហើយ ក៏នាំគ្នាសួរបុព្វកម្មរបស់ព្រះកុនាលៈ ចំពោះព្រះឧបគុត្តត្ថេរ ៗ សម្ដែងប្រាប់ថា :

កាលពីព្រេងនាយ មានព្រានព្រៃម្នាក់ នៅក្នុងក្រុងពារាណសី ក្នុងហេមន្តរដូវ តែងទៅបរបាញ់សត្វក្នុងព្រៃភ្នំ

ទាំងឡាយ រហូតដល់ភ្នំហិមពាន្ត ។ ពេលមួយមានភ្លៀងធំធ្លាក់មក មានព្រិលសពាសពេញព្រៃ ពួកម្រឹគទាំងឡាយនាំគ្នារត់ចូលទៅពួនក្នុងរូងភ្នំមួយ ដើម្បីការពារខ្លួនកុំឱ្យធាតុត្រជាក់បៀតបៀន ។ ព្រានឃើញម្រឹគចូលទៅក្នុងរូងភ្នំដូច្នោះ ក៏បិទមាត់រូង ហើយគិតថា ម្រឹគច្រើនយ៉ាងនេះ បើអញសម្លាប់ទាំងអស់តែម្តង នឹងស្អុយសាច់ខូច ដូច្នេះអញត្រូវឆ្កៀលភ្នែកវាចេញកុំឱ្យរត់រួច ហើយអញសម្លាប់វាស៊ីមួយថ្ងៃមួយជាលំដាប់ទៅ ក៏ចាប់ម្រឹគនោះឆ្កៀលភ្នែកបានចំនួន ៥០០ ក្បាលឱ្យខ្វាក់ទាំងអស់ ។

ព្រានព្រៃក្នុងកាលនោះ គឺព្រះកុនាលរាជនេះឯងកម្មនោះតាមឱ្យផល ត្រូវគេឆ្កៀលភ្នែកទាំងពីរឱ្យខ្វាក់ចំនួន ៥០០ ជាតិ និងជាតិនេះឯង ។

ព្រះឧបគុត្តត្ថេរ សម្តែងទៀតថា ដែលព្រះកុនាល-រាជកុមារ មានព្រះរូបឆោមល្អ កើតក្នុងត្រកូលខ្ពស់ ហើយបានសម្រេចមគ្គផល ដល់ថ្នាក់សកទាគាមិនោះ ដោយអំណាចកុសលកម្ម ដែលបានធ្វើពីអតីតជាតិដែរ គឺក្នុងសាសនាព្រះពុទ្ធកកុសន្ធៈ កាលព្រះអង្គបរិនិព្វានហើយ. ព្រះបាទសោកៈ បានសាងព្រះចេតិយ ដោយកែវ ៧ ប្រការ

បញ្ចុះព្រះបរមធាតុព្រះសម្ពុទ្ធអង្គនោះ ។ ខាងក្រោយមក មានព្រះរាជាមួយអង្គទៀតព្រះនាម អសទ្ធៈ មិនជ្រះថ្លាចំពោះពុទ្ធសាសនា បានឱ្យគេគាស់កកាយព្រះចេតិយនោះ យកកែវ ៧ ប្រការអស់ ។ អ្នកនគរនាំគ្នាយំសោក គិតកសាងចេតិយជាថ្មីវិញ ។ ពេលនោះ មានកុលបុត្រមួយរូប មានសទ្ធាជ្រះថ្លាចំពោះពុទ្ធសាសនា បានសូមព្រះរាជានុញ្ញាត សាងជួសជុលព្រះចេតិយដោយកែវ ៧ ប្រការដូចដើមវិញ នឹងបានសាងព្រះពុទ្ធរូបមួយអង្គមានព្រះរូបឆោមល្អ ស្រដៀងនឹងព្រះពុទ្ធកកុសន្ធៈ ហើយតាំងសេចក្តីប្រាថ្នាថា " ក្នុងអនាគតជាតិ ខ្ញុំសូមឱ្យមានរូបឆោមសមល្អដូចព្រះពុទ្ធរូប ដែលខ្ញុំបានសាងហើយនេះ និងសូមឱ្យបានត្រាស់ដឹងនូវអមតនិព្វាន " ។

លុះដល់មកបច្ចុប្បន្ននេះ កុលបុត្រនោះ បានមកកើតជាព្រះកុនាលរាជកុមារនេះឯង គឺផលនៃការជួសជុលព្រះចេតិយនោះ នាំឱ្យកើតក្នុងត្រកូលខ្ពស់មានឫទ្ធិអំណាចច្រើន ។ ផលនៃការសាងព្រះពុទ្ធរូប បានបណ្តាលឱ្យមានរូបឆោមសមល្អ ហើយបានសម្រេចមគ្គផល ជាព្រះសកទាគាមី ។

## ១៩- រឿងកុទ្ទាលកបណ្ឌិត

(ចាក កុ. ខុ.)

(ការជាប់ជំពាក់ចិត្តចំពោះអ្វីមួយ ត្រូវបិទផ្លូវកាយ និងវាចា ជាមុនទើបលះបង់បាន)

កាលពីព្រេងនាយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី ។ ពេលនោះ មានបុរសម្នាក់ឈ្មោះកុទ្ទាលកបណ្ឌិត មានចិត្តធុញទ្រាន់ក្នុងការគ្រប់គ្រងផ្ទះ បានចេញទៅបួសជាតាបស នៅក្នុងព្រៃហេមពាន្តអស់ ៨ ខែ. ដល់រដូវភ្លៀងសើមដី ក៏នឹកភ្នកដល់គ្រាប់ស្ពៅកន្ទះនាឡិ និងចបកាប់កញ្ចាស់មួយនៅឯផ្ទះ ហើយសឹកទៅដាំគ្រាប់ស្ពៅនោះ ធ្វើរបងព័ទ្ធជុំវិញ ដល់ស្ពៅនោះទុំហើយ បានបេះយកគ្រាប់ សំចៃទុកធ្វើពូជមួយនាឡិ សល់ពីនោះទុកបរិភោគ ។

លុះធ្វើរបរនេះរួចហើយ គិតថានៅផ្ទះគ្មានប្រយោជន៍ បានរៀបចំទុកគ្រាប់ពូជ និងចបកាប់កញ្ចាស់ស្រួលបួលហើយ ក៏ទៅបួសជាតាបសបាន ៨ ខែទៀត. ដល់រដូវភ្លៀងសើមដី នឹកឃើញដល់គ្រាប់ស្ពៅ និងចបកាប់កញ្ចាស់នោះទៀត បានសឹកមកប្រកបមុខរបរនោះដូចមុន។ គ្រាន់តែសឹកបួស ៗ បែបនេះអស់ ៦ ដង ។

កុទ្ទាលកបណ្ឌិត គិតថាឥឡូវដល់រដូវភ្លៀងសើមដីទៀតហើយ បើអញសឹកម្ដងទៀតជាលើកទី ៧ ហើយ ព្រោះតែគ្រាប់ស្ពៃ និងចបកញ្ចាស់មួយ. យីអើ ! អាចបកញ្ចាស់ និងគ្រាប់ស្ពៃនេះ ដឹកនាំអញឱ្យវឹកវរណាស់តើ ? ចេះតែមកល្បួងឱ្យឯងសឹកទៅនៅជាមួយវា ដូច្នេះអញត្រូវយកវាទៅប្រោសចោលឱ្យស្រឡះទើបបាន. គិតហើយក៏ទៅយក កញ្ចប់ គ្រាប់ស្ពៃ ចងភ្ជាប់នឹងក្បាលចប លីដើរទៅមាត់ស្ទឹងគង្គា ដល់ហើយឈរធ្មេចភ្នែក គ្រវីចបលើក្បាលបីជុំ គ្រវាត់ចោលប្រួងទៅក្នុងទឹក ហើយស្រែកថាឈ្នះហើយ ៗ បីដង ។

គ្រានោះព្រះចៅក្រុងពារាណសី ទើបនឹងត្រឡប់ពីបង្ក្រាបសត្រូវក្នុងបច្ចន្តជនបទ មកឈប់សម្រាកព្រះកាយពល ត្រង់ឆ្នេរស្ទឹងគង្គាជិតទីដែលកុទ្ទាលកបណ្ឌិតទៅចោលចបកញ្ចាស់នោះដែរ. ទ្រង់ព្រះសណ្ដាប់ឮសម្លេងឈ្នះហើយ ៗ នោះបានទតទៅត្រង់ទិសដែលមានសម្លេង បានឃើញតាបសកំពុងឈរ ក៏យាងទៅជិតសួរថា លោកម្ចាស់យើងបានបង្ក្រាបសត្រូវឈ្នះអស់ហើយ ទើបមកសម្រាកទីនេះ តើលោកស្រែកថាឈ្នះហើយ ៗ នោះឈ្នះនូវអ្វី ?

កុទ្ទាលកតាបសទូលថា បពិត្រមហារាជ ! ព្រះអង្គឈ្នះពួកចោរខាងក្រៅ. ជម្នះរបស់ព្រះអង្គនេះ គេអាចយកឈ្នះវិញបាន ។ ឯចោរគឺលោភតណ្ហា ដែលអាត្មាបានឈ្នះហើយនេះ វាមិនអាចយកឈ្នះអាត្មាវិញបានឡើយ ជាជម្នះអាចសម្រេចប្រយោជន៍បាន. លោកសូត្រភាសិតថ្វាយថា :

**ន តំ ជិតំ សាធុ ជិតំ**

**យំ ជិតំ អវជីយតិ**

**តំ ខោ ជិតំ សាធុ ជិតំ**

**យំ ជិតំ នាវជីយតិ ។**

ប្រែថា ជម្នះឯណាដែលគេត្រឡប់ឈ្នះវិញបាន ជម្នះនោះមិនសម្រេចប្រយោជន៍ឡើយ. ជម្នះឯណាដែលគេមិនអាចយកឈ្នះវិញបាន ជម្នះនោះឯងទើបសម្រេចប្រយោជន៍បាន

លុះសូត្រភាសិតនេះចប់ហើយ តាបសសម្លឹងខ្សែទឹកក្នុងស្ទឹងគង្គា ក៏បានសម្រេចអាបោកសិណ ហើយអង្គុយពែនព្ធ័អាកាស ដូចជាដុំពពក ។

ព្រះចៅក្រុងពារាណសី និងពលសេនា មានព្រះទ័យមានចិត្តជ្រះថ្លា ព្រឺរោម ព្រឺស្បែក បានក្រាបថ្វាយបង្គំសូមបព្វជ្ជា ជាតាបសទាំងអស់គ្នាក្នុងពេលនោះ ។

តមកស្តេចបទេសរាជទាំង ៧ អង្គដែលចង់ដណ្តើមរាជ្យ កាលបើដឹងថា ព្រះចៅក្រុងពារាណសី និងពលសេនាបានបួសហើយ ក៏មានព្រះទ័យជ្រះថ្លា នាំពលសេនាទៅបួសជាតាបសដែរ ។

ចំណែកកុទ្ទាលកតាបស ខំប្រព្រឹត្តព្រហ្មចរិយធម៌ដរាបដល់អស់អាយុ បានទៅកើតព្រហ្មលោក ។ ឯកុទ្ទាលកតាបសនោះ គឺតួអង្គព្រះសម្ពុទ្ធនេះឯង ។

ថ្ងៃមួយព្រះសម្ពុទ្ធគង់នៅវត្តជេតពន មានព្រះថេរៈមួយអង្គឈ្មោះចិត្តហត្ថេរ ចេះតែបួសសឹក ១ អស់វារៈ ៦ ដង, ដល់បួសលើកទី ៧ ទើបបានសម្រេចព្រះអរហត្តផល។ ភិក្ខុទាំងឡាយនាំគ្នានិយាយថា កិលេសមានទម្ងន់ណាស់ សូម្បីអ្នកមាននិស្ស័យជាព្រះអរហន្ត ដូចចិត្តហត្ថេរនេះហើយ ទម្រាំតែលះបង់បាន ត្រូវបួសសឹក ១ អស់ ៧ ដង ។

ពេលនោះ ព្រះសាស្តាត្រាស់សម្តែងចំពោះភិក្ខុទាំងឡាយថា កិលេសនោះមានទម្ងន់ណាស់ បើមានរូប គ្មានកន្លែងទុកដាក់ឡើយ សូម្បីចក្កវាឡនិងព្រហ្មលោកក៏ចង្អៀតដែរ តថាគតជាបុរសអាជានេយ្យ ក៏ធ្លាប់កិលេសដឹកនាំឱ្យបួស សឹក ១ អស់ ៧ ដងដែរ, ទើបព្រះអង្គនាំអតីតនិទានកុទ្ទាលកបណ្ឌិតមកសម្តែងដូចខាងលើនេះឯង ។

## ២០- រឿងចចកលោភ

(ចាក ត. ម.)

(សេចក្ដីលោភនាំឱ្យថោកទាប ខាតលាភទ្រព្យសម្បត្តិ អាយុជីវិត)

ពីព្រេងនាយ មានព្រានព្រៃម្នាក់ឈ្មោះ ភៃរវៈ នៅក្នុងស្រុកកល្យាណកជកៈ បានចូលទៅក្នុងព្រៃជ្រៅ បាញ់បានប្រើសមួយ ហើយលីយកប្រើសនោះត្រឡប់មកផ្ទះវិញ ស្រាប់តែជួបនឹងជ្រូកព្រៃធំមួយ ក្នុងទីពាក់កណ្ដាលផ្លូវ មានចិត្តត្រេកអរណាស់ ក៏ទម្លាក់ប្រើសទុក ចាប់ធ្នូបាញ់ជ្រូកនោះភ្លាម ។ ជ្រូកដែលត្រូវព្រួញនោះ ស្រែកយ៉ាងខ្លាំង រត់សំដៅមករកព្រាន ហើយខ្វេះស្លាប់ទៅ, ក្នុងពេលព្រានដួលទៅនោះ បានវាត់ជើងត្រូវពស់ធំមួយស្លាប់ទៀត ។

ពេលនោះ មានចចកមួយឈ្មោះ ទីឃរាវៈ កំពុងដើរស្វះស្វែងរកចំណីអាហារ ក៏បានទៅឃើញប្រើសព្រានព្រៃនិងពស់ស្លាប់ស្រាប់ដូច្នោះ ក៏គិតថា អើថ្ងៃនេះ អញពេញជាមានលាភធំសម្បើមអស្ចារ្យ អញគិតស៊ីអ្វីមុន បើចំណីច្រើនយ៉ាងនេះ, សេចក្ដីលោភធំក៏កើតឡើង គិតថា កុំអាលស៊ីចំណីដ៏សម្បើមនេះ ទុកចាំស៊ីក្រោយ កុំឱ្យឆាប់អស់, អញត្រូវស៊ីខ្សែធ្នូឥតរសជាតិនេះមុនជាបឋមបរិភោគ គិតដូច្នេះ

ហើយ ក៏អោនកកេរខ្សែធ្នូហៀរទឹកមាត់កក្អាក់ កំពុងតែខំកកេរខ្សែធ្នូនោះ ក៏ដាច់មាត់ វាត់ខ្ទាប់មុតខ្លួនធ្លុះដល់បេះដូង ដួលស្លាប់បង់ចំណីក្នុងទីនោះហោង ។

អ្នកអានកាលបានអានរឿងនេះចប់ហើយ គួរជ្រាបដល់ភាសិតមួយបទថា ទ្រព្យណាដែលខ្លួនបានឱ្យចំពោះបុគ្គលដ៏ប្រសើរហើយ ទ្រព្យណាដែលខ្លួនបានបរិភោគប្រើប្រាស់រាល់ ៗ ថ្ងៃហើយ. ទ្រព្យនោះឯងជាសម្បត្តិរបស់ខ្លួនពិតប្រាកដ. តើខ្លួនគួរឆ្គួតវង្វេង រក្សាទ្រព្យទុកឱ្យអ្នកដទៃឬ? ម៉េចមិនធ្វើបុណ្យ មិនស៊ីចាយប្រើប្រាស់តាមការគួរទៅ !

ក្នុងលោកនេះ មានមនុស្សច្រើនណាស់ ដែលជាញាតិសន្តានរបស់ចចកល្មោភ. គឺអ្នកដែលមានទ្រព្យសម្បត្តិហើយ មិនហ៊ានធ្វើបុណ្យទាន ស៊ីចាយប្រើប្រាស់ ចេះតែកំណាញ់សន្សំទុក សុខចិត្តបរិភោគតែចំណីអាហារថោកទាបឥតរសជាតិ ដូចជាចំណីអាហារអ្នកសុំទាន ឃើញគេស៊ីចំណីឆ្ងាញ់ ទ្រាំបង្ហូរទឹកមាត់កក្អាក ដូចចចកល្មោភកកេរខ្សែធ្នូ ។

ꧾ

## ២១- រឿងព្រះបាទបិង្គលកៈ និងប្រេត

(ចាក បេ. ខុ.)

(អានិសង្សទានដែលកូនឧទ្ទិសជូនមាតាបិតា)

សម័យក្រោយពុទ្ធកាល មានព្រះរាជាមួយអង្គព្រះនាម បិង្គលកៈ ជាស្ដេចក្នុងសុរដ្ឋប្រទេស ស្ដេចទៅគាល់ព្រះបាទធម្មាសោក ជាស្ដេចចុល្លចក្រ ។ លុះត្រឡប់មកវិញ ស្ដេចយាងកាត់ភក់កណ្ដាលថ្ងៃត្រង់ កំពុងតែយាងស្រាប់តែបានទតឃើញផ្លូវថ្នល់យ៉ាងល្អ ដែលប្រេតនិម្មិតថ្វាយ. ប៉ុន្តែព្រះរាជាមិនជ្រាប ស្ដេចមានបន្ទូលទៅកាន់ពួកចតុរង្គសេនាថា នែអ្នករាល់គ្នា យើងធ្វើដំណើរតាមផ្លូវល្អនេះវិញ ទើបឆាប់បានដល់ប្រទេសយើង ។ ព្រះរាជាក៏នាំពលសេនាយាងតាមផ្លូវនោះទៅ ។

ពេលនោះពួកពលសេនាព្រឺរោមព្រឺស្បែកគ្រប់ៗ គ្នា បានក្រឡេកមើលគ្រប់ទិស នាយសេនាម្នាក់ ដែលមានការតក់ស្លុតជាងគេ បានក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ យើងធ្វើដំណើរតាមផ្លូវនេះមិនស្រួលទេ មានសភាពតក់ស្លុតណាស់ មើលទៅខាងមុខឃើញផ្លូវ ដល់ក្រឡេកមើលក្រោយវិញ មិនឃើញផ្លូវដែលយើងមកសោះ ។ ម្យ៉ាង

ទៀតមានក្លិនប្លែកបកមក ទាំងមានសម្លេងគិកកងគួរឱ្យភ័យខ្លាចផង ។

ព្រះរាជាទ្រង់មានសេចក្ដីតក់ស្លុតដែរ ទើបត្រាស់ប្រាប់នាយសារថីថា យើងដើរពារផ្លូវមិនស្រួលហើយ បានជាពួកយើងមានចិត្តតក់ស្លុត ព្រឺរោមព្រឺស្បែកចម្លែក ធំក្លិនអាក្រក់ ឮសម្លេងគិកកងគួរខ្លាចយ៉ាងនេះ ។ មានព្រះបន្ទូលហើយ ក៏ឡើងលើខ្នងដំរីទតមើលគ្រប់ទិសទាំង ៤ បានឃើញដើមជ្រៃធំមួយ មានស្លឹកខៀវស្រងាត់ ក៏នាំចតុរង្គសេនាយាងសំដៅដើមជ្រៃធំនោះ ។

ថ្លែងពីប្រេតឈ្មោះនន្ទិកា ដែលនៅអាស្រ័យដើមជ្រៃនោះ បាននិម្មិតខ្លួនជាទេវតា ស្អិតស្អាងគ្រឿងអាភរណៈទាំងពួង មានរូបកាយល្អស្រស់ ចូលទៅរកព្រះរាជា ហើយនិយាយថា បពិត្រមហារាជ ស្ដេចយាងមកនេះល្អហើយ សូមទ្រង់សោយនូវវិសុទ្ធិរស ទឹកមានរសឆ្ងាញ់ និងនំទាំងឡាយ ដែលទូលបង្គំរៀបថ្វាយនេះសិន សឹមបន្តព្រះរាជដំណើរទៅមុខទៀត ។

ព្រះរាជា និងពួកពលសេនា បានសោយនិងបរិភោគនូវវិសុទ្ធរស និងនំទិព្វឆ្អែកស្កប់ស្កល់ហើយ ត្រាស់សួរប្រេត

ថា :

- អ្នកជាទេវតា ឬជាគន្ធព្វ ឬជាព្រះឥន្ទ្រ ចូរអ្នកប្រាប់យើងឱ្យបានដឹងផង ។

- បពិត្រមហារាជ ខ្ញុំមិនមែនទេវតា មិនមែនគន្ធព្វ មិនមែនជាព្រះឥន្ទ្រទេ ខ្ញុំជាប្រេតឈ្មោះនន្ទិកា មកនៅក្នុងទីនេះ ។

- អើហ្ន ! អ្នកមានអានុភាពច្រើន មានចំណីអាហារទិព្វ តើអ្នកមានសីល មានសមាចារៈ ដូចម្ដេច ? អ្នកបានប្រព្រឹត្តធម៌ដ៏ប្រសើរដូចម្ដេចខ្លះ ?

- បពិត្រមហារាជ ជាស្ដេចចម្រើនក្នុងដែន សុរដ្ឋប្រទេស សូមព្រះអង្គព្រមទាំងពួកអាមាត្យ និងព្រាហ្មណ៍បុរោហិត ទ្រង់ព្រះសណ្ដាប់ និងស្ដាប់ពាក្យរបស់ខ្ញុំចុះ ។ ពីដើមខ្ញុំនៅក្នុងសុរដ្ឋប្រទេសនោះដែរ ជាបុរសមានចិត្តអាក្រក់ ជាមិច្ឆាទិដ្ឋិ ទ្រុស្តសីល កំណាញ់ប្រទេចផ្ដាសាសមណព្រាហ្មណ៍ ។ លុះខ្ញុំស្លាប់ហើយ បានទៅកើតក្នុងអវីចិនរក ដែលមានភ្លើងឆេះរន្ទាលច្រាលឆ្អៅ ក្ដៅក្រហាយក្រៃលែង ។ នរកនោះ មានកំពែងដែកព័ទ្ធជុំវិញ មានគម្របដែក កំដៅក្នុងនរកនោះខ្លាំងណាស់ ផ្សាយចេញមកក្រៅ

ចំនួន ១០០ យោជន៍ជុំវិញ ។ ខ្ញុំឆេះក្នុងនរកនោះអស់កាលយូរអង្វែង ដោយផលនៃបាបកម្មនោះឯង ។ សេសសល់ផលកម្មនោះ បានមកកើតជាប្រេតក្នុងកាលឥឡូវនេះ ។ ខ្ញុំមានកូនស្រីម្នាក់ បានមកកើតជានាងឧត្តរា ជាឧបាសិការបស់ព្រះសក្យមុនីសម្ពុទ្ធ ជាអ្នកមានសីល មានសទ្ធាត្រេកអរក្នុងទាន មិនកំណាញ់បានប្រគេននូវទឹកសម្រាប់ផឹក និងនំទាំងឡាយចំពោះភិក្ខុសង្ឃមានសីលបរិសុទ្ធ ហើយឧទ្ទិសផលថា សូមផលនៃទាននេះ សម្រេចដល់បិតារបស់ខ្ញុំ ដែលចែកឋានហើយ ។ ផលក៏សម្រេចដល់ខ្ញុំជាលំដាប់គ្រប់ពេលដែលនាងឧទ្ទិស ខ្ញុំបានសម្បត្តិទិព្វតាមប្រាថ្នា ដូចជាស្តេចវេស្សវ័ណ្ណ ។

អាស្រ័យហេតុនេះ សូមមហារាជ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹកផង សូមព្រះអង្គវៀរនូវបញ្ចវេរាទាំង ៥ ផង ។

ព្រះរាជាតបថា ម្នាលប្រេតដូចជាទេវតា អ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ចំពោះយើង. យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យរបស់យើង. យើង

សូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹកផង រៀននូវបញ្ចវេរាទាំង ៥ ផង ។ លុះពោលវាចានេះ ព្រះរាជា ប្ដេជ្ញាចំពោះមុខប្រេតនន្ទិកាថា :

បាណាតិបាតា វិរមាមិ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយាមិ
អមជ្ជបោ នោ ច មុសា ភណាមិ
សកេន ទារេន ហោមិ តុដ្ឋោ ឬ
និច្ចុនាភិ មហាទារតេ
នទិយា វា សីយគាមិយា
ទមាមិ បាបកំ ទិដ្ឋិ
ពុទ្ធានំ សាសនេ រតោ ។

ប្រែថា យើងវៀរបាណាតិបាត យ៉ាងឆាប់រហ័ស យើងលះបង់ការកាន់យកទ្រព្យ ដែលគេមិនបានឱ្យក្នុងលោក យើងលែងផឹកទឹកស្រវឹង លែងនិយាយកុហក យើងជាអ្នកត្រេកអរតែនឹងប្រពន្ធរបស់ខ្លួន ។ ម្នាលប្រេត យើងត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ បាចនូវទិដ្ឋិអាក្រក់ចោល ដូចជាអង្កាមក្នុងទីមានខ្យល់ធំផង បន្សាត់ចោលនូវទិដ្ឋិ

អាក្រក់ ដូចសម្រាមក្នុងទន្លេ មានខ្សែទឹករហ័សផង ។

ព្រះបាទបិង្គលកៈ មានព្រះរាជឱង្ការដូច្នេះហើយ ក៏លើកព្រះហស្តប្រណម្យ ថ្វាយបង្គំ ឧទ្ទិសចំពោះព្រះមានព្រះភាគអរហន្តសម្ពុទ្ធហើយ លាប្រែតយាងគង់លើរាជរថ ជៀសចេញទៅ ។

៙៚៙

## ២២- រឿងភិក្ខុធុតង្គ ៧ អង្គ

(បាក ទា. ខុ.)

(អ្នកបួសក្នុងពុទ្ធសាសនា ត្រូវបានអរហត្តផលជាដាច់ខាតក្នុងជាតិណាមួយ)

ក្នុងសាសនាព្រះពុទ្ធកស្សបៈ កំពុងរៀវរោយ មានភិក្ខុ ៧ អង្គ បានឃើញអាការៈប្លែករបស់ភិក្ខុសាមណេរដទៃ ក៏មានចិត្តសង្វេគ គិតគ្នាថា "បើពុទ្ធសាសនា មិនទាន់អន្តរាយទៅទេ យើងទាំងឡាយនឹងធ្វើនូវទីពឹងដល់ខ្លួនឱ្យបាន" គិតគ្នាយ៉ាងនេះហើយ នាំគ្នាថ្វាយបង្គំសុវណ្ណចេតិយដែលបញ្ចុះព្រះសារីរិកធាតុ ចូលទៅធុតង្គក្នុងព្រៃ. បានឃើញភ្នំមួយ ក៏និយាយគ្នាថា "លោកអង្គណានៅស្តាយជីវិតគួរត្រឡប់វិញចុះ. បើអង្គណាមិនស្តាយជីវិតទេ ចូរឡើងទៅលើភ្នំនេះជាមួយគ្នា" ។ ពេលនោះគ្មានលោកអង្គណាមួយប្រកែក ក៏នាំគ្នាចងបង្អោងឡើងទៅលើកំពូលភ្នំដ៏ខ្ពស់នោះ. លុះឡើងដល់ហើយ ក៏ច្រានបង្អោងចេញ. នាំគ្នាធ្វើសមណធម៌ក្នុងទីនោះទាំងអស់គ្នា ។

បណ្តាភិក្ខុទាំង ៧ អង្គនោះ មានភិក្ខុមួយអង្គជាសង្ឃត្ថេរ បានសម្រេចព្រះអរហត្តក្នុងយប់ទី ១ នោះ. លោកហោះទៅលុបលាងព្រះភក្ត្រក្នុងស្រះអនោតត្ត ហើយ

ទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប យកមកប្រាប់ភិក្ខុទាំង ៦ អង្គ ថា អាវុសោទាំងឡាយ លោកនាំគ្នាឆាន់ចង្ហាន់នេះចុះ ។ ភិក្ខុទាំងឡាយទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងទាំងឡាយបានប្ដេជ្ញាថា បើបានសម្រេចគុណវិសេស ដូចលោកម្ចាស់ ទើបទៅរកចង្ហាន់ឆាន់ដោយខ្លួនឯង. យើងទាំងឡាយមិនឆាន់ដោយសារអ្នកដទៃឡើយ. សូមលោកម្ចាស់ឆាន់តាមសប្បាយចុះ ។

ក្នុងថ្ងៃទី ២ ព្រះថេរៈបន្ទាប់បានសម្រេចអនាគាមិ-ផល. លោកទៅបិណ្ឌបាតយកមកឱ្យភិក្ខុទាំងឡាយឆាន់ទៀត ។ ភិក្ខុទាំងនោះប្រកែកដូចមុន សុខចិត្តស្លាប់ បើមិនបានសម្រេចគុណវិសេសណាមួយ ។

ថ្ងៃបន្ទាប់មក ភិក្ខុដែលបានសម្រេចព្រះអរហត្ត បរិនិព្វានទៅ ។ ឯភិក្ខុដែលបានសម្រេចអនាគាមិផល លោកធ្វើមរណកាល ទៅកើតក្នុងព្រហ្មលោក ។ នៅសល់ភិក្ខុ ៥ អង្គ មិនបានសម្រេចគុណវិសេសអ្វីឡើយ. ដល់ថ្ងៃទី ៧ មានកាយស្គាំងស្គមស្លេកស្លាំង ព្រោះអត់អាហារ ក៏ធ្វើមរណកាលទៅកើតក្នុងទេវលោកទាំង ៥ អង្គទៅ ។

លុះដល់មកពុទ្ធកាលនេះ ទើបច្យុតចាកទេវលោក

មកកើតក្នុងត្រកូលផ្សេង ៗ គ្នាគឺ ទេវបុត្រ ១ អង្គបានមកកើតជាព្រះរាជាព្រះនាមកក្កុសាតិ, ១ អង្គទៀតមកកើតជាកុមារកស្សបៈ, ១ អង្គទៀតមកកើតជាទារុចិរិយៈ, ១ អង្គទៀតមកកើតជាទព្វមល្លបុត្រ, ១ អង្គទៀតមកកើតជាសភិយបរិព្វាជក, សុទ្ធតែបានសម្រេចព្រះអរហត្តគ្រប់ទាំង ៥ អង្គ ។

# ២៣- រឿងព្រះសមុទ្ទត្ថេរ

(ចាក អ. ម.)

(គុណនៃការពិចារណានូវព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា)

ក្នុងសម័យព្រះបាទអសោក សោយរាជ្យនៅក្រុងបាតលីបុត្រ មានគហបតីមួយរូប ជាមហាពាណិជ្ជករ ខាងសមុទ្រសាគរ បាននាំភរិយាទៅកាន់សមុទ្ទដើម្បីជំនួញ. លុះទៅដល់សមុទ្ទហើយ ភរិយាក៏ប្រសូត្របានបុត្រមួយរូប នាំគ្នាឱ្យឈ្មោះបុត្រនោះថា "សមុទ្ទកុមារ" ។

១២ ឆ្នាំកន្លងមក គហបតីបាននាំភរិយាមកដីគោកជាស្រុកកំណើតវិញ. ពួកចោរសមុទ្ទបានស្ទាក់ផ្លូវ ប្លន់យកទ្រព្យសម្បត្តិអស់ ហើយសម្លាប់គហបតី និងភរិយាទៅ នៅសល់តែសមុទ្ទកុមារម្នាក់ឯងរត់រួច ។

គ្រាក្រោយមក សមុទ្ទកុមារបានបួសជាភិក្ខុ ហើយតែងស្វែងរកអាហារបិណ្ឌបាត តាមនិគមជនបទរៀងៗ ទៅរហូតដល់ក្រុងបាតលីបុត្រ. លោកចូលទៅបិណ្ឌបាតតាមពន្ធនាគារ(គុក) របស់ព្រះបាទអសោក ដែលមាននាយចណ្ឌគិរិកៈ ជានាយគុក ។ ចណ្ឌគិរិកៈនេះ ជាមនុស្សកាចសាហាវបំផុត ដូចជាពួកនិរយបាលក្នុងឋាននរក បានធ្វើ

ទារុណកម្មអ្នកនៅក្នុងគុកនោះ យ៉ាងសាហាវបំផុត ដូចក្នុងឋាននរកដែរ. មានការកាត់អណ្តាត បកស្បែក ស្រុះទឹកក្តៅ អាររច្រៀកដោយរណាជាដើម ជាពិសេសបើជនណាបានចូលទៅក្នុងគុកនោះហើយ ទោះមានទោសក្តី ឥតទោសក្តី ត្រូវតែសម្លាប់ទាំងអស់ មិនឱ្យចេញមកវិញឡើយ. គេចាត់ទុកទីនោះ ជាឋាននរករបស់ព្រះបាទអសោក ។

សមុទ្ទភិក្ខុ បាននិមន្តចូលទៅក្នុងគុកនោះហើយ បានឃើញទារុណកម្មយ៉ាងសាហាវដូច្នោះ ក៏គិតថា ទីនេះមើលពីខាងក្រៅមក ស្មានថាទីលំនៅរបស់មនុស្ស ដល់ចូលមកខាងក្នុងជាឋាននរកទេវិញ ។ ពេលនោះនាយចណ្ឌគិរិកៈបានឃើញភិក្ខុនោះហើយ ក៏គម្រាមថា លោកចូលមកដល់ទីនេះ ត្រូវតែស្លាប់ មិនអាចចេញទៅវិញបានឡើយ ។ គ្រាន់តែឮពាក្យនេះ សមុទ្ទភិក្ខុ ក៏ស្រែកទ្រហោយំខ្សឹកខ្សួលរំពងក្នុងគុក ។

ចណ្ឌគិរិកៈ សួរថា ហេតុអ្វីបានជាលោកយំខ្លាចស្លាប់ យើងមិនបាននាំលោកមកទីនេះទេ គឺលោកចូលមកស្លាប់ខ្លួនឯង ។

សមុទ្ទភិក្ខុ ប្រាប់តបវិញថា អាត្មាមិនមែនយំសោក

ខ្លាចស្លាប់ឡើយ គឺយំសោកស្តាយនូវគុណនៃសមណធម៌ដែលអាត្មាត្រូវបាន ព្រោះអាត្មាទើបនឹងបួស មិនទាន់បានបំពេញសមណធម៌ឱ្យបានពេញលេញនៅឡើយ ។ ម្យ៉ាងទៀតការកើតមកជាមនុស្សជាការក្រ បានកើតជាមនុស្សហើយ បានជួបនឹងធម៌ព្រះពុទ្ធ ក៏រឹតតែក្រណាស់ទៅទៀត. អាស្រ័យហេតុនេះ ទើបអាត្មាយំសោកស្តាយ ។

ចណ្ឌគិរិកៈ ប្រាប់ថា តាំងពីយូរយារមកហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានព្រះរាជទានពរឱ្យខ្ញុំថា បើមានមនុស្សចូលមកដល់កន្លែងគុកនេះ ត្រូវសម្លាប់ចោលមិនឱ្យចេញទៅវិញបានឡើយ ។

សមុទ្ទភិក្ខុ អង្វរនាយគុកថា សូមលោកទុកជីវិតឱ្យអាត្មាភាពបាន ៧ ថ្ងៃសិន, ដល់ថ្ងៃទី ៨ បើលោកចង់សម្លាប់អាត្មា តាមបំណងលោកចុះ ។ នាយគុកក៏យល់ព្រមតាមពាក្យអង្វររបស់លោក ។

គ្រានោះព្រះបាទ បានទតឃើញស្ត្រីម្នាក់ កំពុងទាក់ទងក្នុងផ្លូវស្នេហា ជាមួយយុវព្រះអង្គម្ចាស់មួយអង្គ ក៏ទ្រង់ពិរោធ ត្រាស់បង្គាប់ឱ្យរាជបុរសចាប់អ្នកទាំងពីរនាំទៅដាក់គុក។ នាយចណ្ឌគិរិកៈ ទទួលយកអ្នកទោសពានរាំងទាំងពីរ

នោះទៅដាក់គុកហើយ ក៏វាយសំពងក្បាលអ្នកទោសទាំងពីរដោយអង្រែដែក ខ្ទេចក្បាលលៀនភ្នែកស្លាប់មួយរំពេច ។

សមុទ្ទភិក្ខុ បានឃើញច្បាស់នូវទារុណកម្មនេះហើយ ក៏កើតសង្វេគពិចារណាថា រូបកាយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា តែងបែកធ្លាយទៅដោយឆាប់រហ័ស ដូចជាពពុសទឹក ។ មើលចុះ រូបឆោម យុវបុរសយុវនារីទាំងពីរដ៏ល្អស្រស់ប្រិមប្រិយនេះ កំពុងពេញវ័យចម្រើនល្អតលាស់ដូចក្រពុំផ្កា ឥឡូវនេះវិនាសសភាពសង្ខា លំអរនោះអស់ទៅក្លាយជារូបអសុភ គួរខ្ពើមរអើម ។ លោកពិចារណាក្នុងព្រះត្រៃលក្ខណ៍យ៉ាងនេះអស់មួយរាត្រី ក៏បានសម្រេចសោតាបត្តិផល. ដល់ថ្ងៃទី ៧ ក៏បានសម្រេចអរហត្តផល ជាអសេខបុគ្គល ។

នាយគុក ចណ្ឌគិរិកៈ ប្រាប់ព្រះសមុទ្ទត្ថេរថា លោកចាំពាក្យសន្យាឬទេ ? ថ្ងៃនេះដល់វេនលោកស្លាប់ហើយ ។

ព្រះសមុទ្ទត្ថេរ មានថេរដីកាថា អាត្មាចាំហើយ រាត្រីរបស់អាត្មាកន្លងទៅអស់ហើយ ដូងព្រះអាទិត្យរបស់អាត្មាគឺការឃើញច្បាស់នូវលោកទាំងបីបានរះហើយ ពេលជាមង្គលរបស់អាត្មា គឺកិច្ចដែលព្រះសម្ពុទ្ធធ្វើហើយ អាត្មាបាន

បំពេញសព្វគ្រប់ហើយ បើអ្នកចង់សម្លាប់អាត្មា តាមបំណងអ្នកចុះ ។

ពេលនោះ នាយចណ្ឌគិរិកៈ ក៏ចាប់ព្រះសមុទ្ទត្ថេរ បោះចូលទៅក្នុងខ្ទះដែកយ៉ាងធំ ដែលពេញប្រៀបទៅដោយខ្លាញ់ខ្ទះឈាមគំទេចសាកសពកំពុងពុះហើយ ប្រាប់អ្នកដុតភ្លើងឱ្យដុតថែម ឆេះសន្ធោសន្ធៅឡើង ។

កាលព្រះសមុទ្ទត្ថេរ ជាព្រះអរហន្ត ធ្លាក់ចុះដល់ខ្ទះនោះហើយ កំដៅក៏វិនាសបាត់អស់ទៅ ផ្កាឈូកយ៉ាងធំ ប៉ុនមាត់ខ្ទះមានត្របក ១ ពាន់ស្រទាប់ក៏កើតឡើង លោកគង់ស្ងៀមធ្វើសមាធិលើផ្កាឈូកនោះ ។

នាយចណ្ឌគិរិកៈ ឃើញដូច្នោះរឹតតែក្រេវក្រោធ ស្ទុះទៅសំពងលោកមួយដំបងដែក ហើយបង្គរអុសដុតឱ្យឆេះសន្ធោសន្ធៅថែមទៀត, ប៉ុន្តែទម្ងន់ដំបងដែក និងកំដៅភ្លើងមិនអាចប៉ះពាល់ដល់សរីរៈរបស់ព្រះថេរៈឡើយ ។ នាយរឹតតែខឹង ក៏បោចរោចផ្ទះចាស់ៗ សម្ភារៈផ្សេងៗ ដែលអាចដុតបានយកមកគរលើខ្ទះខ្លះ ក្រោមខ្ទះខ្លះ យកមកដុតឱ្យឆេះសន្ធោសន្ធៅ ក្រៃលែងជាងមុន, ដល់ភ្លើងនោះឆេះទ្រោមអស់ទៅ ឃើញព្រះថេរគង់លើផ្កាឈូកស្រស់ញញឹមដដែល

ទាំងខ្ទះទាំងទឹកក៏គ្មានក្តៅសោះឡើយ ឃើញហេតុអស្ចារ្យដូច្នេះហើយ ក៏រត់ទៅក្រាបបង្គំទូលព្រះបាទអសោក សូមស្តេចយាងមកទតហេតុអស្ចារ្យនោះ ។

ព្រះរាជា ស្តេចយាងមកជាមួយរាជបរិពារ ជាច្រើនពាន់នាក់ ទម្លាយកំពែងគុក ឱ្យមនុស្សរាប់កោដិបានចូលទៅមើលព្រះថេរៈផង ។ ពួកមហាជនក្នុងក្រុង ក៏នាំគ្នាទៅចោមរោមមើលព្រះថេរៈមីដេរដាសពេញផ្ទៃគុក ក៏ធំទូលាយនោះ ។

ព្រះសមុទ្ទត្ថេរបានជ្រាបថា ព្រះបាទអសោក ជាមហារាជបួបត្ថម្ភចំពោះព្រះពុទ្ធសាសនា យ៉ាងក្រៃលែងទៅអនាគត ទើបលោកថ្លែងរិទ្ធិហោះចេញចាកខ្ទះ ទៅប្រតិ-ស្ឋានឰដ៍អាកាស បញ្ចេញទឹកឱ្យហូរចេញពីកាយប៉ែកខាងលើ ហើយបញ្ចេញភ្លើង ឱ្យផ្សាយចេញពីកាយផ្នែកខាងក្រោម មានពន្លឺព្រោងព្រាតពេញផ្ទៃមេឃ ដើម្បីញ៉ាំងព្រះបាទអសោក ឱ្យរឹតតែមានសេចក្តីជ្រះថ្លាចំពោះពុទ្ធសាសនា

ពេលនោះព្រះបាទអសោក និងពួករាជបរិពារ ព្រមទាំងមហាជន មានបីតិស្ញប់ស្ញែងព្រឺរោមព្រឺស្បែក. ព្រះរាជាលើកព្រះហស្តប្រណម្យ មានព្រះបន្ទូលថា ភិក្ខុនេះដូច

គ្នានឹងយើងរាល់គ្នាដោយរូបកាយ ប៉ុន្តែឫទ្ធានុភាព និង សេចក្ដីបរិសុទ្ធរបស់លោក វិសេសលើសលប់ជាងមនុស្ស ទូទៅ. ខ្ញុំមិនទាន់ស្គាល់ព្រះនាមលោកម្ចាស់ទេ សូមលោក ម្ចាស់ជាទីពឹង ខ្ញុំនឹងគោរពតាមឱវាទលោកម្ចាស់តទៅ ។

ព្រះសមុទ្ទត្ថេរ មានថេរដីកា ចំពោះព្រះបាទអសោក ថា បពិត្រមហារាជ ព្រះអរហន្តសម្ពុទ្ធជាបរមគ្រូ មាន ករុណាដ៏ធំ បានសម្រេចនូវអមតនិព្វាន ហើយញុំាងអ្នកដទៃ ឱ្យគោរពតាមឱវាទព្រះអង្គ ឱ្យបានសម្រេចនូវអមតនិព្វាន ដូចព្រះអង្គដែរ ។ បពិត្រមហារាជ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា ក្រោយពេលព្រះអង្គបរិនិព្វានទៅ មានព្រះរាជាមួយព្រះអង្គ ព្រះនាមអសោក គឺតួព្រះអង្គនេះឯង ជាស្ដេចចក្រពត្តិ គ្រប់ គ្រងជម្ពូទ្វីបទាំងមូល ជាធម្មិកមហារាជ ជួយទំនុកបំរុង ពង្រីកផ្សាយព្រះពុទ្ធសាសនា ឱ្យបានចម្រើនរុងរឿងក្រៃ លែង. ឥឡូវត្រឡប់ជាផ្ទុយទៅវិញ ព្រះអង្គបានឱ្យគេសាង គុកដ៏ធំដូចជាសាងឋាននរក ទ្រង់បានបំផ្លាញ និងឱ្យគេ បំផ្លាញជីវិតមនុស្សរាប់ម៉ឺនសែន ។ បពិត្រមហារាជ សូម ទ្រង់ព្រះរាជទាន អភ័យចំពោះសត្វលោកទាំងអស់ សូមព្រះ អង្គធ្វើមេត្តាករុណាធម៌ឱ្យកើតឡើង សូមចែកចាយព្រះ

សារីរិកធាតុ ផ្សាយពុទ្ធសាសនាឱ្យបានរុងរឿងឡើង ឱ្យបាន ស្របតាមពុទ្ធទំនាយរបស់ព្រះបរមគ្រូ ។

ព្រះរាជា មានព្រះទ័យរីករាយជ្រះថ្លា ប្រណម្យអញ្ជលី មានបន្ទូលថា អំពើរបស់ខ្ញុំព្រះករុណាក្នុងពេលមុន អាក្រក់ណាស់ សូមលោកម្ចាស់អត់ទោសចំពោះខ្ញុំព្រះករុណា ខ្ញុំសូមដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកហើយ ចាប់ពីថ្ងៃនេះទៅ ខ្ញុំនឹងផ្ដើមបំពេញការកុសល និងសាងព្រះស្តូបឱ្យបានច្រើនលើផ្ទៃប្រថពីនេះ ដើម្បីជាទីគោរពសក្ការៈ និងជាទីរលឹកចំពោះអង្គព្រះអរហន្តសម្ពុទ្ធ ។

ព្រះសមុទ្ទត្ថេរបានជ្រាបថា ព្រះបាទអសោកមានសទ្ធាជ្រះថ្លាស៊ប់ចំពោះពុទ្ធសាសនាហើយ ក៏ថ្វាយព្រះពរលានិមន្តតាមអាកាសបាត់ទៅ ។

ពេលនោះ ព្រះរាជាប្រុងយាងទៅព្រះរាជដំណាក់វិញ, ចណ្ឌគិរិកៈ ទូលឃាត់ថា បពិត្រមហារាជ កាលពីមុនព្រះអង្គមានបន្ទូលប្រទានពរចំពោះខ្ញុំព្រះអង្គថា បើអ្នកណាចូលមកក្នុងទីគុកនេះ ចេញទៅវិញពុំបាន ត្រូវខ្ញុំព្រះអង្គសម្លាប់ ឥឡូវព្រះអង្គយាងមកដល់ហើយ សូមគង់ក្នុងទីនេះ ។

ព្រះរាជាត្រាស់សួរថា ឯងចង់សម្លាប់យើងឬ ?

- ព្រះករុណាវិសេស ទូលបង្គំនឹងធ្វើគត់ព្រះអង្គតាមកិច្ចសន្យា ។

- អើ ! យើងទាំងពីរនាក់នេះ គឺអ្នកណាចូលមកក្នុងទីនេះមុន ?

- សូមទ្រង់ជ្រាប ទូលបង្គំចូលមកក្នុងទីនេះមុន ព្រោះជាអ្នករក្សាទីនេះ ។

- អើ ! ត្រូវតាមសន្យាហើយ អញត្រូវសម្លាប់ឯងមុន ។

ក្នុងមួយរំពេចនោះ ព្រះរាជាត្រាស់ហៅរាជបរិវារមកឱ្យចាប់នាយចណ្ឌគិរិកៈកំណាច យកទៅវាយផ្ចាញ់ផ្ចាល ហើយដុតទាំងរស់ស្លាប់ទៅ ។ ទើបព្រះរាជា ត្រាស់ឱ្យទម្លាយរុះរើគុកចោល ទ្រង់ប្រទានអភ័យចំពោះសត្វលោកទាំងអស់ និងបានឧបត្ថម្ភព្រះពុទ្ធសាសនាយ៉ាងក្រៃលែងដរាបដល់អស់ព្រះជន្ម ។ ពួកមហាជន ក៏បានថ្វាយបរមនាមព្រះអង្គថា ព្រះបាទធម្មាសោក ជាប់រហូតដល់សព្វថ្ងៃនេះ ព្រោះព្រះអង្គ មានព្រះទ័យស្លូតបូត ប្រកបដោយធម៌. កាលព្រះអង្គប្រសូត្រមក មានបរមនាមថា "អសោក" ព្រោះ

កាលប្រសូត្រ ព្រះមាតាមិនមានសេចក្ដីលំបាក ដោយប្រឈួនព្រះឧទរឡើយ កាលព្រះអង្គកំពុងប្រើឫទ្ធិអំណាចកាចសាហាវ មានបរមនាមថា "ចណ្ឌាសោក" ព្រោះព្រះអង្គមានឫទ្ធិអំណាចកាចសាហាវណាស់ ទ្រង់សម្លាប់មនុស្សរាប់ម៉ឺនសែន ដោយផ្ទាល់ព្រះហស្ដផង ដោយប្រើព្រះខន្ធពេជ្រ ឱ្យទៅកាត់ក្បាលមនុស្ស បានក្នុងទីមួយយោជន៍ផង និងដោយប្រើច្រវាក់មាស ឱ្យទៅចងមនុស្ស ក្នុងទីមួយយោជន៍បានធាប់រហ័ស តាមព្រះរាជបំណងផង ។

## ២៤- រឿងត្នោតខ្វាក់ និងឆ្មា

(ចាក ត. ម.)

(សំដីសប្បុរសរបស់សត្រូវប្រចាំជាតិ ជាសំដីរបស់មច្ចុរាជ)

ពីព្រេងនាយ នៅលើភ្នំគិជ្ឈកូដ ក្បែរត្រើយទន្លេគង្គា មានដើមមួយដើមធំ សម្បូណ៌ដោយប្រហោងព្រង់ ជាទីអាស្រ័យនៅនៃត្មាតខ្វាក់មួយឈ្មោះជរទ្គវៈ ។

ពួកបក្សីទាំងឡាយ ដែលអាស្រ័យនៅនាដើមជ្រៃនោះ តែងមានចិត្តអាណិតអាសូរត្មាតខ្វាក់ចាស់រេចរិលក្រចក បានរំលែកចំណីអាហារម្នាក់បន្តិច ៗ ជួយចិញ្ចឹមឱ្យមានជីវិតរស់នៅរាល់ ៗ ថ្ងៃ ។

សម័យមួយ មានឆ្មាមួយឈ្មោះទីឃិកណៈ បានចូលទៅរកចាប់កូនបក្សី ក្នុងព្រង់ជ្រៃនោះធ្វើចំណីអាហារ បណ្តាលឱ្យកូនបក្សីទាំងឡាយ កើតកោលាហលផ្អើលឆោឡោឡើង ។

ត្មាតខ្វាក់ឮសម្លេងនោះហើយ ក៏ស្រែកសួរថា "អាណាមកឆាឆៅនៅទីនេះ ?

ឆ្មាក្រឡេកមើលទៅតាមសូរសម្លេង បានឃើញត្មាតធំសម្បើម ក៏ភ័យតក់ស្លុតគិតថា "អញគ្រោះស្លាប់ដល់ហើយ

ពេលនេះវិវរធំហើយ អញថយទៅក្រោយវិញក៏មិនបាន. ល្ហើយអញគិតចូលទៅនិយាយកុហក ថ្លែងសេចក្ដីស្និទ្ធស្នាលនឹងត្មាតនេះសិន ដើម្បីឱ្យបានសម្រេចដូចគោលបំណង" លុះគិតហើយ ក៏ថ្លែងវាចាគួរសមថា "បពិត្រលោកអាចារ្យ ខ្ញុំសូមជម្រាបសួរ ! " ។

ត្មាតខ្វាក់សួរថា ឯងជាអ្វី ? ហ៊ានមកដល់ទីនេះ មិនខ្លាចស្លាប់ទេឬ ?

ឆ្មាឆ្លើយថា ខ្ញុំប្របាទម្ចាស់ ជាឆ្មាវិឡារជាតិ ជាសត្វកាន់សីលស្លូតបូត ។

ត្មាតខ្វាក់គម្រាមថា " នែ ! អាសត្វចង្រៃ ចូរចេញឱ្យឆាប់ ប្រយ័ត្នស្លាប់ " ។

ឆ្មាអង្វរថា " ឈប់សិនលោកម្ចាស់ ខ្ញុំបាទជាសត្វកាន់សីល នៅក្បែរត្រើយទន្លេគង្គានេះដែរ តែងប្រព្រឹត្តមុជទឹកលាងបាប កាន់ព្រហ្មចរិយធម៌ជាប់ជានិច្ច មិនហ៊ានស៊ីសាច់ឈាម ដូចឆ្មាដទៃឡើយ ខ្ញុំបាទបានឮកិត្តិស័ព្ទលោកម្ចាស់ ដែលពួកហ្វូងបក្សីទាំងឡាយសរសើរថា ជាអ្នកចេះដឹងច្រើន មានចិត្តធ្ងន់ក្នុងធម៌ ល្មមទុកចិត្តយកជាមិត្របានទើបខ្ញុំបាទ មានចិត្តត្រេកអរ ចង់ចូលមកត្រង់ត្រាប់ស្ដាប់

ឱវាទធម៌អាថ៌អំពីលោកម្ចាស់ សូមលោកម្ចាស់អភ័យទោស ទទួលខ្ញុំបាទជាបរិវារផង ។

ត្មាតខ្វាក់ឆ្លើយកាត់ថា "អញមិនជឿឯងទេ ឱ្យតែឈ្មោះថា សត្វឆ្មាវិឡារជាតិហើយ គឺជាសត្រូវប្រចាំជាតិនឹងពួកបក្សី ពួកឯងចូលចិត្តស៊ីសាច់បក្សីណាស់. ឯងកុំថ្លែងវាចាកុហកបញ្ឆោតអញ" ។

ឆ្មាឮដូច្នោះ ភិតភ័យដាក់មុខចុះ ជើងមុខស្ទាបត្រចៀក ក្រាបសំពះ និយាយអង្វរបញ្ជាក់ថា "ខ្ញុំបាទសិក្សាធម៌អាថ៌ច្រើនណាស់មកហើយ លោភៈ ទោសៈ មោហៈបានលះបង់ចោលអស់ហើយ ខ្ញុំកាន់អហាសាការមិនបៀតបៀនជានិច្ច សូមលោកអាចារ្យជ្រាប តាមវាចាពិតរបស់ខ្ញុំចុះកុំប្រទ្បំ ។

កាលឆ្មានិយាយបន្ទន់ចិត្តត្មាតខ្វាក់ឱ្យទុកចិត្ត ជឿតាមឧបាយខ្លួនហើយ ត្មាតនៅស្ងៀម. ឆ្មាក៏លប ៗ ចូលទៅក្នុងព្រង់ចាប់កូនបក្សីស៊ីជារាល់ ៗ ថ្ងៃ វិនាសអស់កូនបក្សីក្នុងព្រង់ជ្រៃនោះ ។

ពួកមេបក្សីទាំងឡាយ កាលបើបាត់កូនអស់គ្រប់ ៗ គ្នាហើយ ក៏ឃើសោកសង្រេងសង្រែរត់ឆ្វេឆ្វា. ឯឆ្មាក៏រត់

ចេញពីព្រង់នោះបាត់ទៅ ។ លុះមេបក្សីទាំងនោះ បាន ឃើញឆ្អឹងគរនៅក្បែរគល់ជ្រៃនោះ ក៏ចោទប្រកាន់ត្មាតខ្វាក់ថា ស៊ីកូនខ្លួនទើបនាំគ្នាសម្លាប់ត្មាតខ្វាក់នោះស្លាប់អសារបង់ជំនូសឆ្មាកំហូចនោះហោង ។

## ២៥- រឿងព្រះបាទអស្សកៈ

(ចាក អ. ទុ.)

(ទោសនៃការស្រឡាញ់ក្នុងរូបកាយ គិតតែតែងខ្លួន មិនធ្វើបុណ្យទាន)

កាលព្រះសម្ពុទ្ធទ្រង់ប្រថាប់ក្នុងវត្តជេតពន មានបុរសម្នាក់លាប្រពន្ធទៅបួស. លុះបួសហើយ ប្រពន្ធចេះតែទៅប្រលោមឱ្យសឹកវិញ ។ ភិក្ខុនោះ ក៏មានសេចក្ដីអផ្សុកចង់សឹក ។ ព្រះសាស្ដាបានហៅភិក្ខុនោះមកត្រាស់សួរថា : ម្នាលភិក្ខុបានឮថា អ្នកឯងចង់សឹកមែនឬ ?

- សូមទ្រង់ព្រះមេត្តាប្រោស អផ្សុកមែន ព្រោះស្ត្រីជាប្រពន្ធទូលបង្គំពីមុន បានមកបបួលឱ្យសឹកទៅវិញ ។

ម្នាលភិក្ខុ ! ស្ត្រីនោះមិនមែនធ្វើឱ្យអ្នកឯងអផ្សុកព្រោះស្នេហាទៅលើរូបវាតែក្នុងជាតិនេះទេ, វាធ្លាប់ធ្វើឱ្យអ្នកឯងមានទុក្ខធំតាំងពីព្រេងនាយមកម្ល៉េះ ។

- សូមទ្រង់ព្រះមេត្តាប្រោស តើអតីតនិទាននោះដូចម្ដេច សូមអារាធនា សម្ដែងអតីតនិទាននោះ ដើម្បីទូលបង្គំបានដឹងផង ។

ព្រះសម្ពុទ្ធទ្រង់នាំអតីតនិទានមកសម្ដែងថា :

ម្នាលភិក្ខុ ! ក្នុងកាលកន្លងទៅយូរហើយ មានព្រះរាជាមួយអង្គនាមអស្សកៈ សោយរាជ្យក្នុងក្រុងបាតលី រដ្ឋកាសី មានអគ្គមហេសីឈ្មោះ ឧព្វរី ជាស្ត្រីមានរូបឆោមល្អ ធើតជាទីគាប់ព្រះទ័យណាស់ ។ មិនយូរប៉ុន្មានមហេសីនោះសោយទីវង្គត់ទៅ ។

គ្រានោះព្រះបាទអស្សកៈ មានទុក្ខសោកសៅសង្រេងសង្រៃក្រៃលែង បានបញ្ជាឱ្យគេលើកសពនាងដាក់ក្នុងស្នូកដែលចាក់ប្រេងលាប មានក្លិនក្រអូប ដើម្បីកុំឱ្យសពនោះស្អុយរលួយ ហើយទើបឱ្យលើកស្នូកនោះដាក់លើគ្រែខ្ពស់មួយ ។ ព្រះរាជាទ្រង់ទតហើយ ទ្រង់ព្រះកន្សែងសោយសោកផ្ទំអត់ព្រះស្ងោយ. ទោះបីព្រះញាតិវង្សានុវង្ស អាមាត្យ មន្ត្រី ព្រាហ្មណ៍ ព្រឹទ្ធ អង្វរព្រះទ័យយ៉ាងណាក៏ពុំបាន ចេះតែទ្រង់ព្រះកន្សែងរវើរវាយថា ឧព្វរី ! ៗ អស់ ៧ ថ្ងៃនាំឱ្យគេលំបាកចិត្តគ្រប់ ៗ គ្នា ។

កាលនោះ មានតាបសមួយរូបបានសម្រេចអភិញ្ញា ៥ និងសមាបត្តិ ៨ នៅអាស្រ័យក្នុងហិមវន្តប្រទេស បានចម្រើនអាលោកកសិណ មានចក្ខុទិព្វបានរំពឹងឃើញព្រះរាជាអង្គនោះ កំពុងខ្សឹកខ្សួលទុក្ខសោកដូច្នោះ បានជ្រាបថា

អាចជួយដោះទុក្ខបាន ក៏ហោះតាមអាកាស មកគង់លើថ្មមង្គល ក្នុងឧទ្យានព្រះបាទអស្សកៈ ។

ពេលនោះ មានមាណពតីព្រាហ្មណ៍កំលោះម្នាក់ចូលទៅក្នុងឧទ្យាន បានឃើញតាបសហើយ ក៏ចូលទៅថ្វាយបង្គំ ។

តាបសសួរថា ម្នាលមាណព ស្ដេចក្នុងនគរនេះ ជាធម្មិករាជឬទេ ?

- ករុណា ព្រះគុណម្ចាស់ ព្រះអង្គជាធម្មិករាជ, ប៉ុន្តែអគ្គមហេសីព្រះអង្គ ធ្វើកាលកិរិយាក្ស័យព្រះជន្មទៅហើយ។ ព្រះអង្គឱ្យគេដាក់សពអគ្គមហេសីក្នុងស្នូកហើយ ទ្រង់ផ្ទំកើតទុក្ខសោក របើរវាយខ្លាំងណាស់ ចំនួន ៧ ថ្ងៃមកហើយ, ម៉េចក៏ព្រះគុណម្ចាស់មិនជួយសង្គ្រោះព្រះរាជាផង ។

- ម្នាលមាណព អាត្មាមិនដែលស្គាល់ព្រះរាជាហ្នឹងសោះ, ប្រសិនបើព្រះអង្គស្ដេចយាងមក អាត្មាអាចថ្វាយព្រះពរ សូមព្រះរាជាជ្រាបទីកន្លែងកំណើតនៃអគ្គមហេសីនោះ នឹងឱ្យអគ្គមហេសីនោះថ្លែងការណ៍ថ្វាយ ក្នុងទីជិតបាទាព្រះអង្គបាន ។

- បើពិតដូច្នោះមែន សូមព្រះគុណម្ចាស់ រង់ចាំក្នុង

ទីនេះសិន ខ្ញុំព្រះករុណាទៅក្រាបបង្គំទូល សូមព្រះរាជាយាងមកក្នុងទីនេះ ។ មាណព ក៏ថ្វាយបង្គំតាបសលាទៅក្រាបបង្គំទូលព្រះរាជា តាមការណ៍ដែលខ្លួនបានជួប ។

ព្រះរាជាមានព្រះទ័យត្រេកអរ ដោយទ្រង់ព្រះចិន្តាថា អញនឹងបានឃើញនាងឧព្វរីមិនខាន ។ ទើបស្តេចឡើងគង់ទីន័ងរាជរថទៅក្នុងឧទ្យាននោះ លុះយាងដល់ថ្វាយបង្គំតាបស គង់ក្នុងទីសមគួរហើយ សួរតាបសថា :

- បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា លោកម្ចាស់ជ្រាបទីដែលនាងទេវីមហេសីខ្ញុំម្ចាស់ ចាប់កំណើតមែនឬ ?

- ថ្វាយព្រះពរមហារាជ អាត្មាដឹងមែន ។

- ចុះវាចាប់កំណើតក្នុងទីណាលោកម្ចាស់ ?

- បពិត្រមហារាជ នាងទេវីនោះ ស្រវឹងនឹងរូប ជាស្ត្រីមានសេចក្តីប្រមាទ ឥតបានធ្វើបុណ្យកុសលសោះ គិតតែពីសប្បាយ ឥឡូវបានកើតជាសត្វកំពោងអាចម៍គោ ក្នុងឧទ្យាននេះឯង ។

- សូមទោសលោកម្ចាស់ ខ្ញុំមិនជឿទេ ។

- បើដូច្នោះ អាត្មាភាពបង្ហាញរូបវា សូមទ្រង់ទតនិងឱ្យវានិយាយជាភាសាមនុស្សថ្វាយក្នុងពេលនេះ ។

- សូមលោកម្ចាស់ឱ្យវានិយាយចុះ ខ្ញុំបានឃើញរូបវាហើយ ។

ពេលនោះដោយអានុភាពរបស់តាបស សត្វកំពោងអាចម៍គោញីឈ្មោលទាំងពីរ ក៏វាចេញពីដុំអាចម៍គោ មកឈប់ក្នុងទីជិតព្រះរាជា ។ តាបសចង្អុរបង្ហាញកំពោងញីថា មហារាជនេះជាឧព្វរីទេវីរបស់មហាបពិត្រ. នាងលះបង់ចោលព្រះអង្គហើយ វារតតើបតាមក្រោយកំពោងឈ្មោលជាប្តីរបស់វា សូមទ្រង់ទតមើលចុះ !

- ខ្ញុំព្រះករុណាដូចជាមិនជឿ ប្រហែលប៉ុននាងឧព្វរីជាស្រីល្អឆើត មិនសមមកកើតជាសត្វកំពោងញីដូច្នេះសោះ

- ចាំអាត្មាភាពសួរឱ្យវានិយាយថ្វាយព្រះអង្គ គង់បានជ្រាបពុំខាន ។ តាបសនិយាយជាមួយកំពោងញីដោយអានុភាពខ្លួនថា នែ នាងឧព្វរី ! កំពោងញីឆ្លើយជាភាសាមនុស្សថា មានការអីទានប្រោស ?

- កាលពីក្នុងអតីតជាតិនាងឈ្មោះអ្វី ?

- ជាតិមិនខ្ញុំឈ្មោះ ឧព្វរី ជាអគ្គមហេសីស្តេចអស្សកៈ ។

- ចុះឥឡូវនេះ នាងស្រឡាញ់ព្រះបាទអស្សកៈ ឬ

ស្រឡាញ់កំពោងឈ្មោលរបស់ឯង ?

- ទានប្រោសក្នុងជាតិមុនព្រះអស្សកៈជាប្ដីរបស់ខ្ញុំ. កាលនោះ ខ្ញុំតែងត្រេកត្រអាលរីករាយសប្បាយចំពោះបញ្ចកាមគុណ ជាមួយនឹងស្ដេចអស្សកៈក្នុងឧទ្យាននេះ ។ ប៉ុន្តែឥឡូវខ្ញុំចែកឋានហើយ ស្ដេចអស្សកៈនោះគ្មានទាក់ទងអីនឹងគ្នាឡើយ. ខ្ញុំត្រូវសម្លាប់ ស្ដេចអស្សកៈយកឈាមក្នុងបំពង់ក លាបជើងកំពោងឈ្មោលជាប្ដីសម្លាញ់របស់ខ្ញុំក្នុងពេលនេះ ខ្ញុំស្អប់ស្ដេចអស្សកៈ ឥតមានចិត្តស្រឡាញ់បន្តិចសោះឡើយ ។

ស្ដេចអស្សកៈ ទ្រង់ព្រះសណ្ដាប់សម្ដីគួរឱ្យឈឺចាប់របស់កំពោងញីនោះហើយ ទ្រង់មានវិប្បដិសារីតូចព្រទ័យថា ឯងខំប្ដូរជីវិតស្រឡាញ់វា នឹកវាជរាបភ្លេចបាយភ្លេចទឹកភ្លេចដេកពួន ឥឡូវវាមានប្ដីជាទីស្រឡាញ់របស់វា ស្អប់ខ្ពើមឯង ចង់យកឈាមបំពង់កឯងលាបជើងឱ្យប្ដីសម្លាញ់របស់វាទៀត អើហ្ន អញពេញជាឆោត ពេញជាខុស ។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏បន្ទោរបង់នូវសេចក្ដីសោកស្ដាយទាំងអស់ចេញ បានបញ្ជាឱ្យរាជបុរសទៅយកសាកសពសម្ដុយដែលដាក់ក្នុងស្នូបឯមហាប្រាសាទ ទៅចោលក្នុងព្រៃស្ង

សាន ហើយទ្រង់ជម្រះព្រះកេសា ព្រះសិរកាយ ព្រះអង្គស្អាតហើយថ្វាយបង្គំតាបស ។ តាបសបានថ្វាយនិវាទទូន្មានព្រះរាជាឱ្យយល់ច្បាស់តាមធម៌ ហើយថ្វាយព្រះពរទៅព្រៃហេមពាន្តវិញ ។

ព្រះរាជាក៏ថ្វាយបង្គំលាតាបសទៅនគរវិញ បានតែងតាំងស្ត្រីឯទៀត ជាអគ្គមហេសី ហើយគ្រប់គ្រងរាជ្យសម្បត្តិប្រកបដោយទសពិធរាជធម៌តរៀងមកដោយសុវត្ថិភាព ។

លុះព្រះបរមសាស្តា សម្តែងអតីតនិទាននេះចប់ហើយ ទ្រង់ប្រកាសនូវសច្ចធម៌ទាំងឡាយ ហើយទ្រង់ក្តុំជាតក៍ ។

ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុអផ្សុកចង់សឹកនោះ បានសម្រេចសោតាបត្តិផល ។

ព្រះសម្ពុទ្ធទ្រង់ក្តុំជាតក៍ថា នាងឧព្វរីក្នុងកាលនោះគឺភរិយាពីមុនរបស់ភិក្ខុចង់សឹក ។ អស្សកៈរាជក្នុងកាលនោះគឺភិក្ខុចង់សឹក ។ មាណពក្នុងកាលនោះ គឺសារីបុត្រ ឯតាបសក្នុងកាលនោះគឺ តថាគតនេះឯង ។

(ចប់ភាគ ៧)

# មាតិកាស្រឿង ពីភាគ ១ ដល់ភាគបញ្ចប់

សៀវភៅប្រជុំនិទានជាតកនេះ សន្មតថា ចប់ត្រឹមភាគ ៧ នេះឯង. ក្នុងភាគបញ្ចប់នេះ ខ្ញុំធ្វើវិភាគវែកញែកខាងជំនឿ ចំពោះនិទានជាតកទាំងឡាយ ដែលមានក្នុងសៀវភៅប្រជុំនិទានជាតក តាំងពីភាគ ១ មក ព្រោះរឿងខ្លះមានហេតុអស្ចារ្យ ស្ទើរតែមិនអាចជឿបាន ។ ឯរឿងដែលមានហេតុផលធម្មតា អាចយល់បានងាយនោះ មិនបានយកមកធ្វើការវែកញែកឡើយ ។

# ទិភាគបទ

រឿងទាំងអស់ ទោះជានិទានក្ដី ជាតកក្ដី ចំនួន ៣៦១ រឿង ដែលមានក្នុងសៀវភៅ ប្រជុំនិទានជាតកនេះ សុទ្ធតែជារឿងមានពិត្រប្រាកដក្នុងគម្ពីរដីកា ។ រឿងខ្លះជាព្រះពុទ្ធដីកា ខ្លះជាថេរដីការបស់ព្រះអរហន្ត និងអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធឃោសាចារ្យជាដើម ។ រឿងទាំងអស់នេះ ជារឿងផ្នែកសាសនា មានប្រភពកើតនៅប្រទេសឥណ្ឌា និងកោះសិរីលង្កា ពុំមែនជារឿងរបស់អ្នកនិពន្ធខ្មែរតាក់តែងឡើយ ។ ឯអ្នកនិពន្ធខ្មែរ គ្រាន់តែប្រែមកជាភាសាជាតិប៉ុណ្ណោះ អាស្រ័យហេតុនេះ ទើបមានជនភាគខ្លះយល់ថា រឿងប្រជុំនិទានជាតកទាំងអស់ សុទ្ធតែជារឿងបរទេសកើតមាននៅស្រុកគេ ពុំមែនជារឿងរបស់ខ្មែរឡើយ. ហេតុអ្វីក៏អ្នកប្រាជ្ញខ្មែរ មិននិពន្ធរឿងនិទានជាតករបស់ខ្មែរឡើង. កុំឱ្យពិបាកខ្ចីរឿងបរទេសយកមកប្រើ ព្រោះប្រទេសខ្មែរបានកាន់ព្រះពុទ្ធសាសនា ជាយូរយាណាស់មកហើយ ថែមទាំងក្នុងរដ្ឋធម្មនុញ្ញខ្មែរ ក៏បានបញ្ជាក់ថា ពុទ្ធសាសនាជាសាសនារបស់ខ្មែរផង ?

ចម្លើយ : វប្បធម៌ខាងសាសនា មានន័យប្លែកអំពី

វប្បធម៌ដទៃទៀតក្នុងលោក មិនចាត់ទុកជាវប្បធម៌បរទេសឡើយ ជាពិសេសគឺ វប្បធម៌ខាងពុទ្ធសាសនានេះឯង ដែលមិនមែនជារបស់បរទេសណាមួយឡើយ ព្រោះជាសាសនាប្រចាំលោក ឬ ជាទ្រឹស្តីលោក សម្រាប់មនុស្សលោកទាំងអស់គ្នា ។ សូម្បីតែព្រះសមណគោតមបរមគ្រូ និងព្រះពុទ្ធទាំងឡាយ ដែលនិព្វានហើយរាប់ម៉ឺនអង្គនោះ ក៏ពុំមែនជាម្ចាស់នៃពុទ្ធសាសនា ជាអ្នកតាក់តែងបង្កើតពុទ្ធសាសនាដែរ ព្រះសម្ពុទ្ធគ្រប់ព្រះអង្គនោះ គ្រាន់តែមានប្រាជ្ញាញាណអាចត្រាស់ដឹងបាន តាមលំនាំទ្រឹស្តីពុទ្ធសាសនា ដែលធ្លាប់មានពីបុរាណកាលប៉ុណ្ណោះ ។

ឯឈ្មោះមនុស្ស ឈ្មោះនគរ ភូមិស្រុកក្នុងរឿងនិទានជាតក ដែលច្រើនតែជាឈ្មោះ នគរ ភូមិ ស្រុក ក្នុងប្រទេសឥណ្ឌានោះ ព្រោះព្រះពុទ្ធកើតនៅប្រទេសឥណ្ឌា ព្រះអង្គសម្តែងយករឿងរ៉ាវ ក្នុងប្រទេសឥណ្ឌានោះជាគំរូជាភស្តុតាងចងក្រងជាព្រះត្រៃបិតក ជាទ្រឹស្តីពុទ្ធសាសនាឡើង តាមហេតុផលដែលព្រះអង្គឧប្បត្តិកើត គង់នៅ និងបរិនិព្វានក្នុងទីនោះ, បើយើងយល់ថា ជាសាសនាបរទេសជារឿងបរទេស ហើយចង់បង្កើតជាសាសនាខ្មែរ ជារឿង

ខ្មែរវិញនោះ វាអស់សេចក្ដីពិតជាពុទ្ធសាសនាទៅហើយ រឿងនិទានជាតកទាំងអស់នោះ ក៏ទៅជារឿងប្រលោមលោកទៅវិញ ដូចដែលអ្នកនិពន្ធខ្មែរយើងសព្វថ្ងៃ បានតាក់តែងរឿងប្រលោមលោកទាំងឡាយនោះដែរ ទោះបីអ្នកនិពន្ធបានប្រឌិតថា កាលនោះ ព្រះសម្ពុទ្ធបានគង់នៅអង្គរវត្ត ហើយបាននិមន្តទៅបិណ្ឌបាត ព្រោសសត្វនៅក្នុងក្រុងសៀមរាប បានសម្ដែងធម៌យ៉ាងនេះយ៉ាងនោះ ដូច្នេះជាដើម ក៏នៅតែជាប្រលោមលោកដដែល ព្រោះវាខុសសេចក្ដីពិត ដែលយើងគេទាំងអស់គ្នា បានដឹងច្បាស់ថា ព្រះពុទ្ធបានកើត និងគង់នៅតែក្នុងប្រទេសឥណ្ឌាឯណោះទេ ។

ក្នុងរឿងនេះដដែល មានជនខ្លះនិយាយរិះគន់ថា រឿងរ៉ាវរបស់ខ្មែរ ដែលមានមកពីបុរាណ និងរឿងព្រេងដែលនិយាយត ៗ គ្នាពីមាត់មួយទៅមាត់មួយនោះ ក៏មិនមែនជារឿងខ្មែរដែរ ព្រោះឈ្មោះនគរ ភូមិ ស្រុកក្នុងរឿងនោះ ៗ គ្មានក្នុងស្រុកខ្មែរសោះ ដូចជារឿងទាំងឡាយដែលពួកល្ខោនបាសាក់លេងសព្វថ្ងៃ ឮតែនគររាជគ្រឹះតក្កសិលា ពារាណសី និងព្រៃហេមពាន្តជាដើម ដែលមាននៅក្នុងប្រទេសឥណ្ឌាទាំងអស់ ហាក់ដូចជានៅស្រុកខ្មែរ

គ្មានឈ្មោះនគរ ភូមិ ស្រុក សោះ ?

ការរិះគន់នេះពិតជាត្រូវណាស់ ព្រោះរឿងព្រេង រឿងល្ខោនអស់នោះមិនមែនជានិទានជាតក ក្នុងគម្ពីរពុទ្ធសាសនាឡើយ. នេះជាកំហុសមួយរបស់អ្នកនិពន្ធខ្មែរខ្លះ តាំងពីបុរាណមក. តាមការសង្កេតគឺ អ្នកនិពន្ធនោះ ១ បើនិពន្ធរឿងអ្វីមួយ ច្រើនតែនឹកឃើញទៅទេសភាព និងជីវភាពនៅបរទេស ជាពិសេសប្រទេសឥណ្ឌាទៅវិញ ហាក់ដូចជាស្រុកខ្មែរយើង គ្មានទឹកដី ភ្លើង ខ្យល់ គ្មានទេសភាព និងជីវភាពសោះ តើមកពីហេតុអ្វី ?

ចម្លើយ : មកពីហេតុ ២ គឺ :

១. អ្នកនិពន្ធនោះ មានការអប់រំស្ទើរភ្លើង អំពីវប្បធម៌ឥណ្ឌា ដែលចូលមកប្រទេសខ្មែរ តាមពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ក៏វង្វេងចិត្តគំនិត ខូចសតិសម្បជញ្ញជាតិងងឹតភ្នែកមើលទេសភាព និងជីវភាពស្រុកទេសខ្លួន មិនឃើញត្រង់ណា ដែលល្មមយកមកនិពន្ធជារឿងរ៉ាវកើត នឹកឃើញតែទេសភាព និងជីវភាពក្នុងប្រទេសឥណ្ឌាតែប៉ុណ្ណោះ ។

២. មកពីអ្នកនិពន្ធនោះ ចង់ឱ្យគេជឿរឿងខ្លួន ថាជា

រឿងពិត ទើបមិនយកឈ្មោះនគរ ភូមិ ស្រុកខ្មែរមកនិយាយ មានខ្លះចង់ឱ្យគេជឿពេក រហូតដល់ខ្ចីតួអង្គព្រះសម្ពុទ្ធយក មកឱ្យដើរតួក្នុងរឿងខ្លួនទៀត ដូចជារឿងពុទ្ធទំនាយជាដើម បង្ហាញស្នាដៃនិពន្ធរបស់ខ្លួន ឱ្យគេឃើញច្បាស់ថា ខ្លួនគិត តែប្រយោជន៍ផ្ទាល់ខ្លួន ឥតគិតប្រយោជន៍ជាតិឡើយ ។

បើនៅតែមានអ្នកនិពន្ធខ្មែរ របៀបនេះតទៅទៀត រឿងព្រេងដែលកើតពីគំនិតខ្មែរ ឯឈ្មោះនគរ ភូមិ ស្រុក នៅក្នុងប្រទេសឥណ្ឌានោះ ក៏មិនចប់ដែរ ។ ឯវប្បធម៌ជាតិ ខ្មែរ ផ្នែករឿងព្រេង រឿងនិទាន ដែលមានលក្ខណៈជាខ្មែរ នោះ ក៏គ្មានក្នុងអក្សរសាស្ត្រខ្មែរដែរ ។

ដើម្បីឱ្យអ្វីៗ ដែលខ្មែរធ្វើកើត បានជារបស់ពិតប្រាកដនោះ គួរតែអ្នកនិពន្ធ និងផលិតករទាំងឡាយ កុំជក់ចិត្ត តែខាងបរទេសជ្រុលពេក ព្រោះខ្មែរយើងក៏ជាមនុស្ស មាន ចិត្តគំនិត មានប្រទេសជាតិ ទឹកដី ព្រៃព្រឹក្សា ទន្លេសមុទ្រ ដូចបរទេសដែរ មានតែប្រសើរជាងបរទេសខ្លះទៀតផង ព្រោះជាតិខ្មែរ ទឹកដីខ្មែរ មានចំណាស់ជាងគេបង្អស់ ក្នុង ជ្រោយសុវណ្ណភូមិនេះ ហេតុអ្វីក៏ចង់តែតោងកន្ទុយបរទេស ទៅវិញ មិនព្រមដឹកមុខបរទេសផង !

ច្បាប់ធម្មជាតិ បានកម្រិតទុកមកជាស្រេចគឺ "អ្នករត់តាមគេ តែងតែនៅពីក្រោយគេជានិច្ច" ដូច្នេះយើងត្រូវធ្វើយ៉ាងណា រត់ឱ្យស្មើនឹងគេ និងឱ្យគេរត់តាមយើងវិញ ខាងផ្នែកអ្វីមួយដែលយើងអាច ទើបឈ្មោះថា ជាអ្នកស្នេហាជាតិខ្លួនមែន ។

ចំពោះរឿងនិទានជាតក ៣៦១ រឿងដែលជារឿងផ្នែកសាសនានេះ តើយើងគួរជឿថាជារឿងពិតទាំងអស់ ឬក៏មានរឿងប្រឌិតខ្លះដែរ ?

ត្រង់ចំណុចនេះ ខ្មែរយើងខ្លះ ជឿផ្តេសផ្តាសណាស់ ឱ្យតែឮថា ព្រះពោធិសត្វ ឬព្រះពុទ្ធមាននៅក្នុងរឿងនោះ ជឿម៉ោទាំងអស់តែម្តង ថាសុទ្ធតែជារឿងពិត ស្តាប់ហើយលើកដៃសំពះនេះទៀតម្យ៉ាង ។

ម្យ៉ាងទៀត ឱ្យតែឃើញរឿងនេះជាភាសាបាលី ឬគេសរសេរលើក្រាំង លើស្លឹករឹត ក៏ជឿឥតបើគិតណាស់ដែរ ។

ម្យ៉ាងវិញទៀតឱ្យតែដឹងថា រឿងនោះមានក្នុងគម្ពីរព្រះត្រៃបិតក ឬគម្ពីរអដ្ឋកថាដីកា ក៏ជឿថាជារឿងពិត ថាសុទ្ធតែព្រះពុទ្ធដីកាថែមទៀត ។

នេះជាលក្ខណៈ របស់អ្នកមានជំនឿហួសហេតុផល

ជឿត្រឹមតែពាក្យគេថាពិត ឬមិនពិតតែប៉ុណ្ណោះ មិនបានយកប្រាជ្ញាត្រិះរិះ រកហេតុផលនៃរឿងនោះ ១ ឱ្យបានដឹងថាមានអត្ថន័យ អត្ថប្រយោជន៍យ៉ាងណាឡើយ ។

ឯពាក្យថា និទាន ដែលយើងប្រែថា រឿង - រឿងជាតក រឿងព្រេងជាដើមនេះ មានលក្ខណៈសំខាន់ចំពោះតែអត្ថន័យល្អ អាក្រក់ ប៉ុណ្ណោះ ។

ឯពាក្យថា ពិត ឬ មិនពិតរបស់និទាននោះ គ្មានប្រយោជន៍ចំពោះអ្នកអាន-អ្នកស្តាប់ឡើយ ។

ដូច្នេះចំពោះរឿងនិទានជាតកនេះ ក៏យើងមិនគួរចំណាយគំនិត ចំណាយពេលឥតប្រយោជន៍ ក្នុងការចង់ដឹងថា ជារឿងពិត ឬរឿងប្រឌិតនោះដែរ ព្រោះវាគ្មានភស្តុតាង សុទ្ធតែអតីតនិទានកន្លងទៅយូរណាស់ហើយ. ឧបមាថា ព្រះសម្ពុទ្ធ ឬព្រះអរហន្ត លោកទ្រង់ញាណឃើញពិត ឬក៏ទ្រង់ប្រឌិតជារឿងរ៉ាវឡើង ដើម្បីប្រោសសត្វឱ្យបានសម្រេចមគ្គផលនោះ ក៏យើងមិនអាចទៅសួរបញ្ជាក់ថាព្រះអង្គទ្រង់ញាណឃើញរឿងពិត ឬព្រះអង្គប្រឌិតឡើងដូច្នេះបានដែរ ព្រោះព្រះអង្គនិព្វានអស់ទៅហើយ ។ ជាពិសេសក្នុងពេលដែលព្រះអង្គកំពុងសម្តែងនោះ ក៏ក្នុងគម្ពីរ

មិនឃើញមាននិយាយថា មានគេសួរព្រះអង្គថា ជារឿងពិត ឬជារឿងប្រឌិតអ្វីដែរ គេគិតតែពីស្ដាប់ ហើយត្រិះរិះ ពិចារណាតាមអត្ថន័យរបស់រឿងនោះ ៗ បានសម្រេចមគ្គផលទៅ ។

ចំពោះព្រះត្រៃបិដក ដែលខ្មែរយើងបានសម្រិតសម្រាំង បោះពុម្ពសម្ភោធ ទុកជាគោលចារឹកពុទ្ធសាសនានោះឃើញផ្នែកព្រះសូត្រខ្លះ ដែលមានដំណាលជារឿងនិទាន ដូវទៅទូតសូត្រ និងអគ្គញ្ញសូត្រជាដើម ច្រើនស្របទៅនឹងលទ្ធិព្រាហ្មណ៍ បើយករឿងរ៉ាងទាំងអស់នេះ ទៅផ្ទឹងនឹងតម្លៃប្រាជ្ញាញាណរបស់ព្រះសម្ពុទ្ធ ដែលជាកំពូលនៃត្រៃភពនោះ ហាក់ដូចជាត្រង់កន្លែងខ្លះជាមតិរបស់សង្គីតិ-កាចារ្យ ដែលលោកសរសេរព្រះត្រៃបិដកទុកក្នុងអក្សរសាស្ត្រក៏មិនដឹង ? ព្រោះសេចក្ដីខ្លះ ឃើញស្របនឹងគម្ពីរវិសុទ្ធិមគ្គរបស់ព្រះពុទ្ធឃោសាចារ្យ ត្រង់អភិញ្ញានិទ្ទេសដែលនិយាយអំពីព្រះអាទិត្យ ព្រះចន្ទ អំពីកប្បជាដើម មានន័យមិនសូវស្របនឹងវិទ្យាសាស្ត្រសព្វថ្ងៃ ដែលគេបានទៅដល់ព្រះចន្ទ ឬមួយក៏អ្នកចម្លងត ៗ ជាច្រើនតំណរមករាប់ពាន់ឆ្នាំ នាំឱ្យឃ្លាតឆ្ងាយពីអត្ថបទដើម ?

នេះគ្រាន់តែជាការសង្កេតមួយ របស់ខ្ញុំប៉ុណ្ណោះ ព្រោះអ្វីក៏ដោយ ឱ្យតែមិនសូវសមហេតុផល អ្វីនោះមិនមែនព្រះសម្ពុទ្ធសម្តែងឡើយ ។

សូមអ្នកអានកុំយល់រហូតដល់ថា ព្រះត្រៃបិដកខុស ឬជាព្រះសូត្រនេះខុសដូច្នេះឡើយ ដែលខ្ញុំនិយាយនេះ គ្រាន់តែត្រង់ផ្នែករឿងរ៉ាវនិទានខ្លះ ដែលនិយាយមិនសូវសមនឹងតម្លៃប្រាជ្ញាញាណរបស់ព្រះសម្ពុទ្ធ ឯព្រះធម៌ និងវិន័យក្នុងព្រះត្រៃបិដកនោះ គ្មានអ្នកណាអាចបន្ថែមបន្ថយបានឡើយ ។

បន្ទាប់ពីនេះ ខ្ញុំលើកយករឿងនិទានជាតកមួយៗ ដែលមានសេចក្តីអស្ចារ្យ អាឡូតហេតុ មកសាកល្បងវែកញែកជូនអ្នកអានដូចខាងក្រោម :

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ១ រឿងទី ២ គឺរឿងព្រះបាទមន្ធាតុ ដកពីរឿងគម្ពីរតិកនិបាត មានសេចក្តីគួរសង្ស័យដូចតទៅនេះ ។

រឿងនោះថា ▪ ក្នុងខាងដើមនៃភទ្ទកប្បនេះ មានព្រះបរមចក្រពត្រាធិរាជមួយអង្គ ព្រះនាមមន្ធាតុ មានមហិទ្ធិឫទ្ធិធំអស្ចារ្យ សោយរាជ្យក្នុងទ្វីបទាំង ៤ មាន

មហាក្សត្រិយ៍ ៨ ម៉ឺន ៤ ពាន់ព្រះអង្គជាបរិវារ ។ មនុស្សក្នុងជំនាន់នោះ មានអាយុកំណត់មួយអសង្ខេយ្យឆ្នាំ ។ ឯព្រះមន្ធាតុនោះ មានឥទ្ធិពលសម្បើមអស្ចារ្យណាស់ គ្រាន់តែទះដៃវេលាណា មានភ្លៀងកែវ ៧ ប្រការធ្លាក់ចុះមកវេលានោះ ទ្រង់នៅជាកុមាររត់លេងសប្បាយ ដោយល្បែងក្មេងជាង ៨ ម៉ឺនឆ្នាំ ដល់ព្រះជន្មគម្រប់ ៨ ម៉ឺន ៤ ពាន់ ព្រះរាជបិតា ទ្រង់ប្រទានកិត្តិយសឱ្យធ្វើជាឧបរាជ ១ បាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ បានទទួលរាជាភិសេកស្តេចបរមចក្រពត្រាធិរាជ សោយរាជ្យបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ ទ្រង់មិនស្កប់ស្កល់ដោយរាជ្យសម្បត្តិ បានត្រាស់សួរមហាមាត្យថា ទីដែលបរិបូណ៌ដោយរាជ្យសម្បត្តិវិសេសជាងនេះទៅទៀត មានឬទេ ? ។ មហាមាត្យទូលថា បពិត្រព្រះសម្មតិទេព ក្នុងមនុស្សលោកនេះពុំមានទេ មានតែស្ថានចាតុមហារាជិកា ទើបបរិបូណ៌ដោយសេចក្តីសុខប្រសើរជាងស្ថានមនុស្ស ។ ព្រះបាទមន្ធាតុ បានជ្រាបហើយ ក៏ទ្រង់កាន់ចក្ករតន៍គ្រវីអណ្តែតទៅឰដ៏អាកាស ព្រមទាំងចតុរង្គសេនា ទៅចុះនៅស្ថានចាតុមហារាជិកា ។ ពួកទេវតាក្នុងស្ថាននោះបានឃើញព្រះបាទមន្ធាតុហើយ ក៏នាំគ្នាកាន់ភ្ញីផ្កាចូលទៅបូជា ថ្វាយរាជ្យ

សម្បត្តិទិព្វដល់ព្រះបាទមន្ធាតុននោះ ១ បានសោយរាជ្យសម្បត្តិនៅស្ថានចាតុមហារាជិកាបានចំនួន ៨ ម៉ឺន ៤ ពាន់ឆ្នាំមនុស្ស ទ្រង់មិនបានស្កប់ស្កល់ក្នុងព្រះរាជ្យសម្បត្តិនោះទៀត. ទើបត្រាស់សួរទៅស្ដេចចតុបាលទាំង ៤ ថា ទីស្ថានដែលបរិបូណ៌ដោយសេចក្ដីសុខជាងនេះមានដែរឬទេ ? ។ ស្ដេចចតុលោកបាលទាំង ៤ ក្រាបទូលថា រាជ្យសម្បត្តិក្នុងស្ថាននេះ មិនវិសេសជាងស្ថានមនុស្សប៉ុន្មានទេ មានតែរាជ្យសម្បត្តិក្នុងស្ថានត្រៃត្រឹង្ស ទើបប្រសើរជាងនេះ ១ រយគុណ ។ ព្រះបាទមន្ធាតុបានជ្រាបហើយ ក៏ចាប់ចក្ករតន៍ ត្រឡប់ហោះទៅស្ថានត្រៃត្រឹង្សទៀត ។ ព្រះឥន្ទ្រាធិរាជ បានទតឃើញព្រះបាទមន្ធាតុហើយ ក៏មានព្រះទ័យសោមនស្សរីករាយ កាន់ផ្កាភ្ញីទៅបូជាថ្វាយរាជ្យសម្បត្តិពាក់កណ្ដាល ។ ព្រះបាទមន្ធាតុ បានសោយរាជ្យពាក់កណ្ដាលលំនៅស្ថានត្រៃត្រឹង្សនោះ ជាសុខក្សេមក្សាន្តអស់កាលជាយូរអង្វែងណាស់ ចំនួន ៣៦ ជំណាន់ព្រះឥន្ទ្រ ។ ឯសេចក្ដីប្រាថ្នារបស់ព្រះអង្គ មិនចេះពេញសោះ នៅតែខ្វះកន្ទះជានិច្ច សូម្បីសោយរាជ្យសម្បត្តិទិព្វជាយូរអង្វែងដល់ម្ល៉ោះ ក៏មិនចេះស្កប់ស្កល់ ទើបទ្រង់ព្រះចិន្ដាថា បើអញសម្លាប់ព្រះឥន្ទ្រចោល

ហើយសោយរាជ្យតែម្នាក់ឯង ទើបល្មមសមនឹងបុណ្យស័ក្តិរបស់អញ ។ គ្រាន់តែគិតយ៉ាងនេះ ការទ្រុឌទ្រោមនៃសរីរៈក៏កើតឡើងប្រាកដ ពុំអាចនៅលាយឡំជាមួយនឹងពួកទេវតាបាន ស្រាប់តែច្យុតមកស្ថិតនៅក្នុងឧទ្យានរបស់ព្រះអង្គ នាស្ថានមនុស្សដូចកាលមុនវិញ ។

អត្ថបទក្នុងផ្ទៃរឿងនេះមាន ៣ ចំណុច ដែលប្រកបដោយសេចក្តីអស្ចារ្យ ប្លែកពីធម្មតានាបច្ចុប្បន្ននេះគឺ :

១. ព្រះបាទមន្ធាតុ សោយរាជ្យក្នុងទ្វីបទាំង ៤ មានមហាក្សត្រ ៨ ម៉ឺន ៤ ពាន់អង្គជាបរិវារ, ឯមនុស្សក្នុងជំនាន់នោះ មានអាយុវែងណាស់ដល់មួយអសង្ខេយ្យឆ្នាំ.

២. ព្រះបាទមន្ធាតុ គ្រាន់តែទះដៃ មានភ្លៀងកែវ ៧ ប្រការធ្លាក់ចុះពីអាកាសមក.

៣. ព្រះបាទមន្ធាតុ កាន់ចក្ករតន៍គ្រវីហើយ អណ្តែតទៅឰដ៏អាកាស ព្រមទាំងចតុរង្គសេនា ទៅដល់ស្ថានសួគ៌បានដូចបំណង.

ទាំង ៣ ចំណុចនេះ សុទ្ធតែជារឿងប្លែក ដែលយើងគេសព្វថ្ងៃ មិនដែលឃើញសោះ, តើអាចមានយ៉ាងនេះដែរឬទេ ? ព្រោះហេតុអ្វី ?

មុននឹងឈានគំនិតចូលទៅក្នុងការត្រិះរិះ រកហេតុផលអំពីរឿងនេះ សូមជ្រាបជាបឋមថា រឿងនេះផលិតចេញមកពីចិត្តសាស្ត្រ មិនមែនផលិតចេញមកពីវិទ្យាសាស្ត្រ ដូចគ្រឿងឧបភោគបរិភោគផ្សេងៗ មានយន្តហោះជាដើមនោះឡើយ ។

ដូចនេះ យើងរកហេតុផលក្នុងក្បួនចិត្តសាស្ត្រ ដែលមាននិយាយល្អិតល្អន់ក្នុងបរមត្ថវិជ្ជា ផ្នែកទ្រឹស្តីពុទ្ធសាសនាទើបឃើញ ។ បើភាវរកហេតុផលតាមក្បួនវិទ្យាសាស្ត្រនោះមិនឃើញឡើយ ព្រោះមាននាទីខុសគ្នាគឺ វិទ្យាសាស្ត្រជាក្បួនផ្សំវត្ថុធាតុ ដែលនៅរាក់រាយប្រើការមិនកើត ឱ្យជាវត្ថុធាតុមានសម្ព័ន្ធភាពផ្សំគ្នា កើតជា យន្តហោះ រថយន្ត វិទ្យុទូរទស្សន៍ជាដើម សម្រាប់ប្រើប្រាស់បានដូចបំណង ។ ឯចិត្តសាស្ត្រ ជាក្បួនផ្សំចិត្ត វិញ្ញាណ ដែលនៅទន់ខ្សោយរាក់រាយ ឱ្យមានមហិទ្ធិឫទ្ធិ ប្រសិទ្ធិភាព អាចប្រើបានដូចបំណង ។ ផ្សំតាមវិធានទាំងបី គឺ ទាន, សីល, ភាវនា ។

ចំណុចទី ១ ដែលថាព្រះបាទមន្ធាតុ សោយរាជ្យក្នុងទ្វីបទាំង ៤ នោះ, បើតាមភូមិសាស្ត្រសកលសព្វថ្ងៃ គ្មានឃើញទ្វីបទាំង ៤ គឺជម្ពូទ្វីប, ឧត្តរកុរុទ្វីប, អបរគោយានី

ទ្វីប និងបុព្វវិទេហទ្វីបនេះឡើយ ។ ឯជម្ពូទ្វីបនោះ ថានៅត្រង់ប្រទេសឥណ្ឌាសព្វថ្ងៃ ហាក់ដូចមិនត្រូវ បើថានៅក្នុងសកលលោកសព្វថ្ងៃ ដែលចែកជាទ្វីបតូចៗ ថា ទ្វីបអាស៊ីអឺរ៉ុប អាហ្វ្រិក អាមេរិក និងអូសេអានី ទាំងអស់នេះឈ្មោះថាជម្ពូទ្វីបទើបត្រូវ ព្រោះក្នុងគម្ពីរវិសុទ្ធិមគ្គ របស់ព្រះពុទ្ធឃោសាចារ្យថា មនុស្សនៅក្នុងជម្ពូទ្វីបនោះ ចិញ្ចឹមជីវិតដោយរបរកសិកម្ម ពាណិជ្ជកម្ម. ស្ត្រីមានគភ៌ ៩ ឬ ១០ ខែទើបប្រសូត្របុត្រ ។

ឯទ្វីបបីទៀត មនុស្សចិញ្ចឹមជីវិតដោយផលបុណ្យមានដើមកប្បព្រឹក្សជាដើម សម្រាប់បំពេញសេចក្តីប្រាថ្នាគឺចង់បរិភោគអ្វី ចង់បានអ្វី គ្រាន់តែដើរទៅរកដើមនោះបានដូចបំណង. ស្ត្រីមានគភ៌តែ ៧ ថ្ងៃប្រសូត្របុត្រ ប្រសូត្របាន ៧ ថ្ងៃចេះដើរ ចេះរត់ ។ល។ ឃើញថាទ្វីបបីទៀតនោះមិនដឹងនៅឯណាទេ ព្រោះក្នុងសកលលោកយើងសព្វថ្ងៃគ្មានមនុស្សរស់នៅតាមរបៀបនេះឡើយ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គថា ឧត្តរកុរុទ្វីប នៅទិសខាងជើងភ្នំសិនេរុ បុព្វវិទេហទ្វីប នៅខាងកើតភ្នំ. អបរគោយានីទ្វីបនៅខាងលិចភ្នំ. ឯជម្ពូទ្វីបយើងនេះនៅខាងត្បូងភ្នំ ។

តើភ្នំសិនេរុ គឺភ្នំព្រះសុមេរុនោះ នៅឯណា. ភ្នំនេះ មិនមែនជាភ្នំហិមាឡាយ៉ា ឬហិមាល័យ ហេមពាន្ត ដែលមាននៅក្នុងប្រទេសឥណ្ឌានោះឡើយ. ថាភ្នំនោះនៅចំកណ្ដាលលោកធាតុ. បើរកភ្នំនោះឃើញហើយ ទ្វីបបីនោះក៏រកឃើញដែរ ។ ភ្នំ និងទ្វីបបីនោះ ពិតជាមាននៅក្នុងលោកធាតុដ៏ធំល្វឹងល្វើយនេះមែន ដូចជាពួកផ្កាយទាំងឡាយដែរ. ព្រោះព្រះសម្ពុទ្ធ បាននិមន្តទៅបិណ្ឌបាតនៅឧត្តរកុរុទ្វីបនោះដែរ. ទ្វីបនោះមានយប់ និងថ្ងៃខុសគ្នាពីជម្ពូទ្វីបយើង ។

សូមប្រគល់ភារៈរកភ្នំ រកទ្វីបនេះ ចំពោះអ្នកវិទ្យាសាស្ត្រចុះ ព្រោះបានរកឃើញផ្កាយព្រះអង្គារ ព្រះសុក្រដែលមាននៅក្នុងក្បួនខ្មែរយើងនោះដែរហើយ យ៉ាងយូរណាស់ កន្ទះសតវត្សទៀត ប្រហែលជារកឃើញមិនខាន ។

ក្នុងចំណុចទី ១ ដដែលត្រង់ថា ជំនាន់ព្រះបាទមន្ធាតុនោះ មនុស្សមានអាយុ ១ អសង្ខេយ្យឆ្នាំ. តើដែលមានអាយុមនុស្សវែងយ៉ាងនេះឬទេ ?

តាមទ្រឹស្តីសាសនាថា មានយ៉ាងនេះមែន គឺពេលដែលអាយុក្ខ័យមនុស្ស ត្រូវចម្រើន អាចឡើងដល់រាប់

អសង្ខេយ្យឆ្នាំ. ពេលចុះទៅតិចបំផុតត្រឹម ១០ ឆ្នាំស្លាប់. ស្ត្រីមានអាយុ ៥ ឆ្នាំល្មមឱ្យមានប្តី។ ក្នុងប្រវែងអាយុនេះ ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ឧប្បត្តិកកើត តែក្នុងពេលដែលមនុស្សមានអាយុក្ស័យពីត្រឹម ១ សែនឆ្នាំ ចុះមកដល់ ១០០ ឆ្នាំប៉ុណ្ណោះ ។

ចំណុចទី ២ ថាព្រះបាទមន្ធាតុនោះ គ្រាន់តែទះដៃធ្លាក់កែវ ៧ ប្រការមានមាស ពេជ្រជាដើមពីអាកាសមក ។ ត្រង់ចំណុចនេះ ដូចជាផ្ទុយនឹងសភាវៈពិត នាបច្ចុប្បន្ននេះខ្លាំងណាស់. តើអាចមានយ៉ាងនេះដែរឬទេ ?

អាចមានយ៉ាងនេះដែរ. ព្រោះទានដែលបុគ្គលបានឱ្យហើយ ដោយសេចក្តីជ្រះថ្លាចំពោះព្រះសម្ពុទ្ធជាម្ចាស់ ឬព្រះបច្ចេកពុទ្ធ និងព្រះអរហន្តទាំងឡាយ អាចញ៉ាំងសេចក្តីប្រាថ្នាទាំងពួង ឱ្យសម្រេចបានដូចបំណង ។

ឯហេតុដែលបណ្តាលឱ្យ ព្រះបាទមន្ធាតុ ទះដៃធ្លាក់កែវ ៧ ប្រការនោះ គឺការថ្វាយទានចំពោះព្រះសម្ពុទ្ធព្រះនាមវិបស្សី ក្នុងជាតិដែលកើតជាអ្នកទ័លក្រ រាប់ពីភទ្ទកប្បនេះទៅក្រោយវិញចំនួន ៩១ កប្ប. ក្នុងពេលថ្វាយទាននោះ មានសទ្ធាមុតមាំណាស់ បានធ្វើសេចក្តីប្រាថ្នា

ប្រកាសចំពោះព្រះភក្ត្រព្រះសម្ពុទ្ធថា " ក្នុងអនាគតជាតិ សូមឱ្យបានជាធំ ជាងជនអ្នកត្រូវការដោយកាមទាំងឡាយ, បើខ្ញុំទះដៃវេលាណា សូមឱ្យភ្លៀងកែវ ៧ ប្រការធ្លាក់ចុះពីអាកាសវេលានោះ " ។ នេះជាហេតុធំមួយ ។

ហេតុមួយទៀត ដែលបណ្ដាលឱ្យមានកែវ ៧ ប្រការធ្លាក់ចុះពីអាកាសដូចគ្រាប់ភ្លៀងនោះ ជានិមិត្តហេតុ នៃការបាចបោះគ្រាប់សណ្ដែកស្ងោរ សំដៅទៅបាត្រព្រះសម្ពុទ្ធវិបស្សី, ដៃដែលបាចគ្រាប់សណ្ដែកនោះឯង ហុចផលឱ្យព្រះបាទមន្ធាតុ មានឫទ្ធិនៅបាតដៃ គ្រាន់តែទះធ្លាក់ភ្លៀងកែវ ៧ ប្រការ ។

តើកែវ ៧ ប្រការនេនោះ អ្នកណាទម្លាក់មកឱ្យក៏ច្រើនម្ល៉េះ គ្រប់តែពេលដែលទះដៃ ?

ចម្លើយ : អំពើររបស់ខ្លួនទម្លាក់មកឱ្យខ្លួន គ្មានអ្នកណាទម្លាក់ឱ្យឡើយ គឺជាវិស័យរបស់កម្ម ដែលធ្លាប់និយាយថា ផលបុណ្យដែលខ្លួនបានធ្វើហើយ ប្រកបដោយលក្ខណសម្បត្តិ ២ ប្រការយ៉ាងបរិបូណ៌, លក្ខណៈទី ១ អ្នកឱ្យមានចេតនាប្រកបដោយអង្គបី គឺមានសេចក្ដីជ្រះថ្លាខ្លាំង មុននឹងឱ្យទាន ១, កំពុងឱ្យរីករាយជ្រះថ្លា ១, ឱ្យទានរួចហើយរីងរីក

តែជ្រះថ្លាថែមទៀត ១ (ព្រះបាទមន្ធាតុ កាលកើតជាបុរសកំសត់ មានចេតនាទាំងបីនេះឯង. សូមអានរឿងព្រះបាទមន្ធាតុ ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ១ នឹងឃើញច្បាស់មិនខាន) ។ លក្ខណៈ ទី ២ បានឱ្យទានចំពោះព្រះសម្ពុទ្ធ ដែលជាកំពូលនៃព្រះអរហន្តទាំងឡាយ ។ អ្នកដែលបានឱ្យទានមានសភាពបែបនេះ តែងតែមានផលច្រើនប្រកបដោយសេចក្ដីអស្ចារ្យតាមចិត្តប្រាថ្នា ។

ចំណុចទី ៣ ថាព្រះបាទមន្ធាតុ កាន់ចក្ករតន៍ត្រីហើយអណ្ដែកទៅឰដ៏អាកាស ព្រមទាំងចតុរង្គសេនា ទៅដល់ឋានសួគ៌. តើអ្វីជាចក្ករតន៍ ! ក៏ពូកែជាងកាំជ្រួចហោះឆ្ងាយម៉្លេះ ? ចតុរង្គសេនានោះគឺសេនាអ្វីខ្លះ ? ឋានសួគ៌នៅឯណា ?

ចម្លើយ : ចក្ករតន៍ គឺកង់កែវ មានខ្នងកង់ មានដុំមានកាំ ១ ពាន់ សុទ្ធតែកែវដ៏មានតម្លៃទាំងអស់ ។ ចក្កនេះសម្រាប់អ្នកមានបុណ្យធំជាស្ដេចចក្រពត្តិ កើតឡើងក្នុងថ្ងៃអភិសេក អាចបំពេញបំណងស្ដេចចក្រ បានគ្រប់យ៉ាង ។ ស្ដេចចក្រនេះយូរៗ ណាស់ទើបកើតមានក្នុងលោកម្ដងតែងកើតមានក្នុងពុទ្ធន្តរ គឺក្នុងកាលជាចន្លោះនៃពុទ្ធកាល ។

ចតុរង្គសេនាមាន ៤ គឺ កងទ័ពដំរី_ទ័ពសេះ_ទ័ពរថ និងទ័ពថ្មើរជើង ។ ទ័ពទាំងអស់នេះ អាចអណ្តែតលឿនទៅ ឰដ៏អាកាសបានជាមួយស្តេចចក្រពត្តិ ដោយអំណាចចក្ករតន៍

ការអណ្តែតទៅឰដ៏អាកាស ទាំងកងទ័ពគ្មានអ្វីទ្រ គ្មានអ្វីសម្រាប់ជិះ គ្មានកាច់ចង្កូត ហើយទៅកាន់ទីដៅបាន ដូចបំណងយ៉ាងឆាប់រហ័សដូច្នេះ ឃើញថាហួសហេតុពេក មិនអាចជឿបាន ក្រែងជារឿងប្រឌិតទេឬ ?

មិនមែនជារឿងប្រឌិតឡើយ ពិតជាអាចកើតដូច្នោះមែន ព្រោះដោយអំណាចចក្ករតន៍, ចក្កនេះកើតឡើងដោយមនុស្សធ្វើ, ដូចព្រះបាទមន្ធាតុ ជាស្តេចចក្រពត្តិនេះ ព្រះអង្គបានធ្វើកម្មជាកុសលធំណាស់ កាលកើតជាបុរសកំសត់ ទើបកើតចក្ករតន៍នេះឡើង, បើមនុស្សមិនធ្វើ ចក្ករតន៍នេះក៏គ្មានដែរ ។ ដែលថាហាក់ដូចជាប្លែកអស្ចារ្យណាស់នោះ មកពីយើងមិនធ្លាប់ឃើញ មិនធ្លាប់ដឹងឮ ។

សេចក្តីអស្ចារ្យរបស់ចក្ករតន៍នេះ មិនខុសគ្នាពីសេចក្តីអស្ចារ្យរបស់វិទ្យុ ទូរទស្សន៍ ដែលយើងបានឃើញដឹងឮសព្វថ្ងៃនេះឡើយ, ព្រោះវិទ្យុទូរទស្សន៍នេះ បើដល់ទៅសម័យ ដែលបាត់បង់វិទ្យាសាស្ត្រពីសង្គមមនុស្សលោកយើង

ទៅ. មនុស្សសម័យនោះបានឃើញអត្ថបទ ឬ ឮគេនិយាយថា កាលពីមុន មានហិបយន្តមួយ គ្រាន់តែមូលគន្លឹះ ស្រាប់តែឃើញរូបមនុស្សពិត ៗ កំពុងនិយាយ កំពុងច្រៀងរាំ អាចស្ដាប់ពាក្យសំដី ស្ដាប់ចម្រៀងរបស់រូបមនុស្សនោះបានទៀត ។ល។ តើមនុស្សសម័យនោះ អាចជឿបានឬទេ ? ពិតជាគេនិយាយថា និយាយកុហក ថាជារឿងប្រឌិតមិនខាន ព្រោះគេមិនដែលឃើញ ។ ចំណែកយើងសព្វថ្ងៃវិញ ដែលធ្លាប់ឃើញ ធ្លាប់ប្រើនោះ ថាជារឿងពិត មានពិតមែន ប៉ុន្តែរឿងចក្ករតន៍ ដែលយើងមិនធ្លាប់ឃើញ គិតមិនយល់នោះ យើងបែរជាមិនជឿថាមាន ថាជារឿងគេប្រឌិតទៅវិញ ។ នេះជាលក្ខណៈធម្មតារបស់មនុស្សលោក ដែលផ្ញើជំនឿតែតាមភ្នែក ។

ចំណែកខាងឋានសួគ៌ ដែលចក្ករតន៍នាំព្រះបាទមន្ធាតុ ព្រមទាំងចតុរង្គសេនាទៅដល់នោះ តើនៅឯណា ? បើអ្នកវិទ្យាសាស្ត្រសព្វថ្ងៃនេះ មិនដែលជួបប្រទះសោះ !

នៅត្រង់កន្លែងរបស់ឋានសួគ៌នោះឯង ព្រោះក្នុងលោកធាតុយើងនេះធំធេងណាស់ ជាទីប្រជុំនៃពួកផ្កាយទាំងឡាយ, ផ្កាយមួយៗ ជាទ្វីបមួយ ៗ ជាឋានមួយ ៗ, ឯ

ព្រះអាទិត្យ ព្រះចន្ទ និងផែនដីយើងនេះ ក៏ជាផ្កាយដែរ បើគេនៅឆ្ងាយជាងយើង គេនឹងមើលឃើញតូច ៗ ដូចយើងឃើញផ្កាយដែរ ។

ឯអ្នកអវកាសសព្វថ្ងៃ ទើបតែនឹងទៅដល់ផ្កាយខ្លះដែលនៅជិតផែនដីប៉ុណ្ណោះ នៅសល់ផ្កាយរាប់អសង្ខេយ្យមិនអស់ទៀតនោះ តើយើងអាចបដិសេធថាគ្មានឋានសួគ៌ឬ ? អាចដឹងថាសួគ៌នៅត្រង់ណាបានដែរឬទេ ?

រឿងនរក - សួគ៌នេះ អ្នកនិពន្ធខ្ញុំបានសរសេរវែកញែកយ៉ាងពិស្តារក្នុងសៀវភៅ "ជំនឿចាស់-មនុស្សថ្មី" ចាប់ពីទំព័រ ៤២ ដល់ទំព័រ ៧៥ ។ បើចង់ជ្រាប សូមអានសៀវភៅនោះចុះ ។

(ចប់ការរើកញែករឿងព្រះបាទមន្ធាតុ)

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ២ រឿងទី ៥០ គឺរឿងពាណិជបុរស ដកពីគម្ពីរ អដ្ឋកថា វលាហកជាតក មានសេចក្តីអស្ចារ្យប្លែកដូចតទៅនេះ :

ថ្ងៃមួយ មានពាណិជ ៥០០ នាក់ ធ្វើដំណើរទៅតម្ពបណ្ណិទ្វីប មានគ្រោះថ្នាក់បែកសំពៅ ត្រង់ទីជិតនគរយក្ខិនី.

យក្ខិនីទាំងឡាយ ក៏លួងលោមនាំយកពាណិជទាំងនោះ ទៅនគររបស់ខ្លួនធ្វើជាស្វាមីរៀងៗ ខ្លួន ។ លុះពាណិជទាំងនោះដេកលក់ស៊ប់ហើយ វាក៏នាំគ្នាទៅស៊ីមនុស្សជាប្ដីរបស់វាក្នុងពេលមុន ដែលវាយកទៅលាក់ទុកក្នុងកន្លែងមួយ ។ ពាណិជបានឃ្លាំមើល ដឹងថាស្រីទាំងនោះជាយក្ខិនីហើយ ក៏ប្រាប់ដល់គ្រប់ពាណិជជាបរិវារ ដើម្បីរកឱកាសនឹងរត់ចោលស្រីទាំងនោះ ។ ពាណិជចំនួន ២៥០ នាក់ ប្រកែកមិនព្រមរត់ចោលស្រីទាំងនោះឡើយ ។ ខាងក្រោយមកត្រូវយក្ខិនីទាំងនោះស៊ីអស់ទៅ ។ ចំណែកពាណិជ ២៥០ នាក់ដែលនាំគ្នារត់ទៅនោះ បានជួបនឹងសេះមួយឈ្មោះវលាហកៈ ។ សេះឈ្មោះវលាហកៈនេះ គឺជាអង្គព្រះពោធិសត្វ មានរូបកាយសគ្រសុស មានឫទ្ធិអស្ចារ្យ អាចហោះហើរព្វដ៏អាកាសបាន ។ ពេលនោះសេះវលាហកៈ បានហោះពីព្រៃហេមពាន្ត មកស៊ីស្រូវសាលីដុះឯងក្នុងគម្ពបណ្ណិទ្វីប ពេលត្រឡប់ទៅវិញ បានឃើញពាណិជទាំង ២៥០ នាក់នោះ ក៏ស្រែកសួរដោយសេចក្ដីករុណាថា អ្នកទាំងអស់គ្នាចង់ទៅជនបទដែរឬ ? ពាណិជទាំងនោះឮហើយ ក៏ស្រែកព្រមគ្នាថា យើងទាំងអស់គ្នានឹងទៅ ។ សេះក៏បន្ទាប

ខ្លួនមក ហើយនិយាយថា ចូរអ្នកទាំងឡាយឡើងជិះលើខ្នងមក ។ លំដាប់នោះ ពាណិជមួយក្រុមឡើងជិះលើខ្នង. មួយក្រុមទៀតតោងកន្ទុយ មួយក្រុមទៀតឈររលើដី លើកដៃសំពះដោយអានុភាពរបស់ខ្លួន ស្តេចសេះអាចនាំពាណិជទាំង ២៥០ នាក់ទៅកាន់ជនបទដំណាលគ្នាតែម្តងបាន ។

អត្ថបទក្នុងរឿងនេះមាន ៣ ចំណុចដែរ ដែលប្រកបដោយសេចក្តីអស្ចារ្យប្លែក មិនធ្លាប់ឃើញក្នុងបច្ចុប្បន្ននេះគឺ

១. យក្ខិនី - នគរយក្ស.

២. សេះវលាហកៈ អាចហោះនាំមនុស្ស ២៥០ នាក់បាន.

៣. សត្វចេះនិយាយ ចេះស្តាប់ភាសាមនុស្ស ។

ចំណុចទី ១ រឿងយក្ស និងនគរយក្សនេះ យើងគេសព្វថ្ងៃ ហាក់ដូចជានឹកសម្គាល់ថា មិននៅឆ្ងាយឡើជាមួយនគរមនុស្សឡើយ គឺជានគរនៅក្នុងទីណាមួយ ដែលយើងទៅមិនដល់ មានសុទ្ធតែយក្សអាស្រ័យនៅ គឺមានស្តេចយក្សនាម៉ឺនយក្ស រាស្ត្រយក្ស. នេះតាមរឿងព្រេង ដែលមានក្នុងអក្សរសាស្ត្រយើង ដូចរឿងព្រះជិនវង្សជាដើម ។ អ្នកតែងរឿងទាំងនេះ គេយកលំនាំតាមគម្ពីរវេទ ដែលនិយាយពី

ឋានអសុរ ស្ដេចចតុលោកបាល នៅឋានសួគ៌ឈ្មោះ ចតុមហារាជិកា ដែលនៅត្រង់ជើងភ្នំសិនេរុឯណោះ ។ ឯយក្ស និងនគរយក្សក្នុងជម្ពូទ្វីប ដូចនគរយក្ខិនីនៅជិតតម្ព-បណ្ណិទ្វីប (លង្កាទ្វីប) នោះគឺមាននៅជាមួយភូមិស្រុកមនុស្សយើងនេះឯង ព្រោះពាក្យថាយក្សនេះ សម្រាប់ហៅពួកមនុស្សទាំងអស់ ដែលមានរូបកាយមិនប្រាកដ ជួនបាត់ជួនឃើញ ចេះប្រែកាឡាបានតាមចិត្ត ដូចរុក្ខទេវតា ភុម្មទេព្តា(ព្រះភូមិ) វត្ថុទេព្តា អារក្ស អ្នកតា ខ្មោចបិសាច ជាដើម ទោះមានចិត្តល្អក្តី ចិត្តអាក្រក់ក្តី ដែលពួកមនុស្សរាប់អានបូជា សែនព្រេន បន់ស្រន់ ទាំងអស់នេះហៅថាយក្ស ។

ឯយក្ខិនីដែលយកពាណិជ ៥០០ នាក់ចែកគ្នាធ្វើប្តីនោះ គឺរុក្ខទេពធីតា ឬភុម្មទេពធីតា ខ្មោចបិសាច ដែលអាស្រ័យនៅជិតតម្ពបណ្ណិទ្វីបនោះឯង ។ យក្សបែបនេះស្រុកខ្មែរយើង មានគរគោកនៅតាមព្រៃភ្នំ វត្តអារាម ផ្ទះអ្នកស្រុក និងកន្លែងកប់ខ្មោចជាដើម, ប៉ុន្តែខ្មែរយើងឥតចាប់ភ្ញីកនឹកថាយក្សទេ ព្រោះធ្លាប់ស្តាប់រឿងព្រេងថាយក្សនៅនគរយក្សឯណោះ មានមុខមាត់អាក្រក់ មានចង្កូម, ឯ

កូនក្រមុំយក្ស សុទ្ធតែស្អាតៗ ដូចទេពអប្សរ ។ តាមការពិត យក្សនៅតែជាមួយយើងសព្វថ្ងៃ នៅស្ទើរគ្រប់ផ្ទះទាំងអស់ យក្សប្រុសក៏មាន យក្សស្រីក៏មាន. អ្នកដែលចូលចិត្តរាប់អាន យក្សជាងគេគឺ ចិន-យួន. ផ្ទះណាក៏មានជើងធូបសម្រាប់ អុជបន់ស្រន់ព្រឹកល្ងាចដែរ ។ ចិន-យួននេះខ្លាចយក្សណាស់ ប៉ុន្តែចូលចិត្តរាប់អានយក្សក៏ណាស់ដែរ ព្រោះគេមិនស្គាល់ ថាយក្ស ។

ចំណុចទី ២ សេះឈ្មោះវលាហកៈ អាចហោះនាំ មនុស្ស ២៥០ នាក់បាន. រឿងនេះថាប្លែកក៏បាន ថាជា ធម្មតាក៏បាន ព្រោះពូជសេះឈ្មោះវលាហកៈនេះកម្រកើត មានក្នុងលោកណាស់ មានតែពោធិសត្វដែលមានបុណ្យ ច្រើន ហើយភ្ជាត់គតិទើបទៅកើតជាសេះបែបនេះបាន មិន មែនជាសត្វតិរច្ឆានធម្មតាឡើយ ។

ដែលថាជាធម្មតានោះ ព្រោះជាវិស័យនៃធម្មជាតិ ។ ពួកអ្នកវិទ្យាសាស្ត្រ ផ្នែកធម្មជាតិវិទ្យា ក៏អាចយល់ពីឥទ្ធិពល នៃធម្មជាតិនេះដែរ ដូចជាសត្វត្រីក្នុងប្រទេសអេហ្សិប ឈ្មោះ ហ្ស៊ីមណាក. ត្រីនេះរស់នៅក្នុងទន្លេនីល ដែលមាន ទឹកល្អក់ រកមើលអ្វីមិនយល់អស់មួយរដូវ. វាពូកែបំផុតអាច

ហែលចៀសឧបសគ្គនានាសំដៅរកចំណី និងរកសត្វញី ឈ្មោលវាបានដោយងាយ ដូចមានភ្នែកទិព្វ. ជនជាតិអេហ្ស៊ីប គេទុកត្រីនេះជាទេវតាមួយអង្គ ។

អ្នកវិទ្យាសាស្ត្រ មានការភ្ញាក់ផ្អើលអស្ចារ្យចំពោះត្រីហ្ស៊ីមណាកនេះណាស់ បានចាប់យកទៅពិសោធន៍ មើលឃើញវាមានប្រដាប់វិទ្យាសាស្ត្រធម្មជាតិម្យ៉ាង ដែលអ្នកវិទ្យាសាស្ត្រមិនងាយធ្វើកើត គឺវាមានវ៉ុលតាម៉ែត្រយ៉ាងតូចល្អិតមួយជួរនៅជុំវិញខ្លួនវា. វាអាចវាស់ដឹងនូវតង់ស្យុងគ្រប់ពេលវេលា ដែលមានរវាងប៉ូតង់ស្យែលអគ្គីសនីខ្លួនវា និងប៉ូតង់ស្យែលដែលមាននៅជិតវា កាលណាវាទៅជិត ។ល។

ឯសេះឈ្មោះវលាហកៈ ក៏មានប្រដាប់វិទ្យាសាស្ត្រធម្មជាតិនៅក្នុងខ្លួន សម្រាប់បញ្ជូនថាមពលស្រូបយិតយោងមនុស្សបាន ២៥០ នាក់ ឱ្យអណ្តែកទៅតាមដូចបំណងវាដែរ ។ នេះបើនិយាយតាមរបៀបវិទ្យាសាស្ត្រ ។

ចំណុចទី ៣ សត្វចេះនិយាយ ចេះស្តាប់ភាសាមនុស្ស. នេះក៏មិនជាការអស្ចារ្យអ្វីដែរ ចំពោះសេះឈ្មោះវលាហកៈ ដែលជាសត្វពិសេសនោះ ។ បើចំពោះសត្វទូទៅវិញ ក៏មានគរគោកនៅស្រុកយើង ដូចសារិកាកែវ_សេក

ជាដើម ដែលចេះនិយាយ ចេះស្តាប់ភាសាមនុស្ស ។ ឯមនុស្សដែលចេះនិយាយ ចេះស្តាប់ភាសាសត្វវិញនោះ ក្នុងក្បួនវេទ ក៏មានវិជ្ជាសម្រាប់សិក្សាឱ្យចេះនិយាយ ចេះស្តាប់ភាសាសត្វដែរ, ប៉ុន្តែសព្វថ្ងៃ យើងមិនស្រាវជ្រាវរកវិជ្ជានោះមកសិក្សា ទើបមិនដែលឃើញអ្នកណាចេះនិយាយ ចេះស្តាប់ភាសាសត្វ គឺតទៅមនុស្សសព្វថ្ងៃ ដូចជាអន់ជាងសត្វផ្នែកភាសានេះ ព្រោះសត្វវាចេះនិយាយ ចេះស្តាប់ភាសាមនុស្ស ដូចសេក សារិកាជាដើម. ឯមនុស្សសព្វថ្ងៃគ្មាននរណាចេះភាសាសត្វវិញសោះ ។

មានមតិខ្លះបដិសេធថា សត្វចេះនិយាយ ចេះស្តាប់ភាសាមនុស្ស និងមនុស្សចេះស្តាប់ភាសាសត្វនោះជារឿងកុហក មិនដែលមានសោះឡើយ ។

បើបដិសេធយ៉ាងនេះ គួរបដិសេធរឿងដែកចេះនិយាយភាសាមនុស្ស និងមនុស្សចេះស្តាប់ភាសាដែកដែរដែលអ្នកវិទ្យាសាស្ត្រ បង្កើតឡើងឱ្យឈ្មោះជាខ្មែរថាទូរសព្ទនោះ, ព្រោះថាបើដល់ទៅសម័យវិទ្យាសាស្ត្រសាបសូន្យទៅ, មនុស្សសម័យនោះ គេឃើញក្នុងសៀវភៅ ឬ ឮគេនិយាយថា កាលសម័យវិទ្យាសាស្ត្រ មានដែកមួយដុំ មាន

ខ្សែនៅជាប់ជាកន្ទុយ ដែកនោះចេះនិយាយ ចេះស្តាប់ភាសាមនុស្ស ឯមនុស្សក៏ចេះស្តាប់ ចេះនិយាយនឹងដែកនោះដែរ គេប្រាកដជាមិនជឿសោះ ដូចយើងមិនជឿរឿងសត្វចេះនិយាយ ចេះស្តាប់ភាសាមនុស្សដែរ ព្រោះមិនដែលឃើញ។

(ចប់ការរែកញែករឿងពាណិជបុរស)

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ៣ រឿងទី ៣៩ គឺរឿងខន្តិវាទតាបស ដកពីគម្ពីរចតុកនិបាត មានសេចក្តីដំណាលថា :

កាលកន្លងទៅហើយ ព្រះពោធិសត្វរបស់យើងសោយព្រះជាតិព្រាហ្មណ៍នាម កុណ្ឌៈ នៅក្នុងពារាណសី មានការនឿយណាយនឹងកិច្ចឃរាវាសក្រៃពេក ក៏ចេញទៅបួសជាតាបស នៅអាស្រ័យក្នុងហេមប្រទេសអស់កាលដ៏យូរ លុះមានបំណងចង់ឆាន់វត្ថុប្រៃនិងជូរ ក៏ត្រឡប់មកកាន់ក្រុងពារាណសីវិញ គង់នៅក្នុងព្រះរាជឧទ្យាន មានសេនាជាអ្នកទំនុកបំរុង ។ ថ្ងៃមួយ ព្រះរាជាកលាបុស្រវឹងស្រាជោគជាំ មានស្រីរបាំចោមរោមជាបរិវារ យាងទៅកាន់ឧទ្យាន ផ្ទំកើយព្រះសិរលើភ្លៅ ពេញព្រះទ័យមួយរូបលង់

លក់ស្កប់ស្កល់ទៅ ។ គ្រានោះស្ត្រីទាំងឡាយដទៃ ឃើញព្រះរាជាផ្ទំលក់ហើយ ក៏បបួលគ្នាទៅឱទ្យាន ឃើញព្រះពោធិសត្វ គង់ទៀបគល់សាលព្រឹក្ស ដែលមានផ្ការីកស្គុសស្គាយ ព្រុសុះព្រុសុំសាខាសំយុងមែកចុះមកក្រោម ហើយថ្វាយបង្គំអង្គុយស្តាប់ធម៌ដោយសេចក្តីគោរព ។ ព្រះរាជាតើនឡើង មិនឃើញស្ត្រីទាំងនោះ ទ្រង់ខ្ញាល់ជាខ្លាំង ហើយចាប់ព្រះខ័នយាងទៅកាន់សំណាក់តាបស ពេលនោះស្ត្រីម្នាក់ដែលមានសេចក្តីស្និទ្ធស្នាលនឹងព្រះរាជាជាងគេ ស្ទុះទៅចាប់យកព្រះខ័នពីព្រះហស្តព្រះអង្គ ព្រះរាជាសួរពោធិសត្វដោយអាការគួរខ្លាចថា នែស្រមកំណោរ អ្នកចូលចិត្តនិយាយថាម៉េច បពិត្រមហារាជ អាត្មាចូលចិត្តនិយាយថាខន្តី ។ ការមិនបៀតបៀនសត្វទាំងឡាយ មិនធ្វើបាបសត្វទាំងឡាយ មិនប្រទូស្តចំពោះសត្វទាំងឡាយ ដែលជេរប្រហារផ្តាសារចំពោះខ្លួន ។ ព្រះរាជាគិតថា អញបានឃើញខន្តីរបស់តាបសនោះឥឡូវហើយ ហើយត្រាស់ហៅបុរសអ្នកសម្លាប់ចោរមកបង្គាប់ថា ចូរអ្នកទាញតាបសនេះផ្តួលលើផែនដី ហើយយករំពាត់មានបន្ទា មកវាយពីរពាន់រពាត់ ខាងឆ្វេងប្រាំរយរំពាត់ ខាងស្តាំប្រាំរយរំពាត់ដូចគ្នា ។ បុរសនោះធ្វើ

យកចិត្តទុកដាក់តាមព្រះរាជាបញ្ជា ។ ព្រះរាជាត្រាស់សួរម្តងទៀតថា អ្នកចូលចិត្តនិយាយថាម៉េច ? បពិត្រមហារាជ អាត្មាភាពចូលចិត្តនិយាយថាខន្តី ។ តែព្រះអង្គបែរជាសំគាល់ថា ខន្តីនៅទាចន្នោះស្បែកអាត្មាភាពទៅវិញ ? មិនមែននៅចន្លោះស្បែកទេព្រះអង្គ ខន្តីនេះនៅក្នុងចន្លោះបេះដូងដ៏ជ្រៅរបស់អាត្មាភាព ។ នែអ្នក ចូរកាត់ដៃជើងតាបសនេះឱ្យដាច់។ រាជបុរសក៏កាត់តាមព្រះរាជបញ្ជា ។ ព្រះរាជាត្រាស់សួរជាគំរប់ ៣ ដងថា អ្នកចូលចិត្តនិយាយថាម៉េច ? បពិត្រមហារាជ អាត្មាភាពចូលចិត្តនិយាយថាខន្តី តែព្រះអង្គបែរជាសំគាល់ថា ខន្តីនៅនឹងដៃជើងរបស់អាត្មាភាពទៅវិញ. ខន្តីក្នុងដៃនិងជើងគ្មានទេ ។ នែអ្នក ចូរកាត់ច្រមុះ និងត្រចៀកតាបសនេះឱ្យដាច់ ។ បុរសនោះក៏ធ្វើតាមព្រះរាជបញ្ជាដូចលើកមុន ។ ព្រះរាជាត្រាស់សួរតែពាក្យដដែល ៗ តាបសក៏ឆ្លើយតែពាក្យដដែល ៗ ដូចគ្នា ដរាបតែព្រះរាជាខ្ញាល់ជាខ្លាំង លើកជើងទាត់កណ្តាលដើមទ្រូងព្រះពោធិសត្វមួយជើងភឹងយ៉ាងធ្ងន់ ទើបថយចេញទៅក៏ត្រូវផែនដីស្រូបក្បែរឱទ្យាន ឱ្យទៅកើតក្នុងអវិចីមហានរក មានអណ្តាតភ្លើង ក្រហមច្រាលឆ្អៅឆេះរោលរាលស្រោចពេញខ្លួន ។

អត្ថបទក្នុងផ្ទៃរឿងនេះ មានតែមួយចំណុចទេដែលប្លែក គួរយកមកធ្វើការវែកញែក គឺផែនដីស្រូប ឬព្រះធរណីស្រូប ។

ពាក្យថាព្រះធរណីស្រូបនេះ ធ្លាប់បានដឹងឮគ្រប់ៗគ្នាប៉ុន្តែមិនធ្លាប់បានឃើញផ្ទាល់ភ្នែកសោះឡើយ គឺមានពិតមែន ឬក៏ជារឿងប្រឌិតទេ ?

រឿងនេះក្នុងទ្រឹស្តីវិទ្យាសាស្ត្រគ្មាននិយាយទេ ព្រោះតាំងពីវិទ្យាសាស្ត្រកើតឡើង មិនដែលមានព្រះធរណីស្រូបមនុស្សណាឡើយ ទើបអ្នកប្រាជ្ញវិទ្យាសាស្ត្រ មិនបានស្រាវជ្រាវរកហេតុផលនៃរឿងនេះ ព្រោះមិនធ្លាប់បានដឹង ។

ផ្នែកខាងទ្រឹស្តីពុទ្ធសាសនា ទើបមាននិយាយពីរឿងព្រះធរណីស្រូបមនុស្សនេះច្បាស់លាស់ ព្រោះក្នុងពុទ្ធកាលមានមនុស្សព្រះធរណីស្រូប ដូចជាភិក្ខុទេវទត្ត. ស្តេចសុប្បពុទ្ធ និងនាងចិញ្ចមាណវិកាជាដើម ។

ក្នុងទ្រឹស្តីពុទ្ធសាសនានិយាយថា មនុស្សដែលត្រូវព្រះធរណីស្រូបនោះ បានប្រព្រឹត្តអំពើអកុសលជាក់ស្តែងចំពោះអ្នកមានគុណធម៌ខ្ពង់ខ្ពស់ជាងខ្លួន មានព្រះអរហន្តសម្មាសម្ពុទ្ធជាដើម ។

សព្វថ្ងៃនេះ បានជាមិនដែលឃើញមានមនុស្សណាត្រូវព្រះធរណីស្រូប ព្រោះក្នុងលោកសម័យនេះ គ្មានអ្នកមានគុណធម៌ខ្ពង់ខ្ពស់ដល់ថ្នាក់ព្រះអរហន្ត ទើបអំពើអកុសល ដែលគេបានធ្វើនោះមិនឱ្យផលជាក់ស្តែង ដរាបដល់ផែនដីទ្រមិនឈ្នះ ដែលហៅថាព្រះធរណីស្រូបនោះឡើយ ។

ម្យ៉ាងទៀត បានជាសព្វថ្ងៃនេះគ្មានមនុស្សដែលត្រូវព្រះធរណីស្រូប ព្រោះមនុស្សភាគច្រើនក្នុងលោកនេះច្រើនតែប្រព្រឹត្តអំពើអាក្រក់ប្រហែលៗ គ្នា គ្មាននរណាវិសេសជាងនរណាប៉ុន្មានឡើយ សុទ្ធតែមនុស្សបុថុជ្ជនដូចគ្នា ទើបអំពើអកុសល ដែលបានប្រព្រឹត្តរវាងគ្នានឹងគ្នានោះក៏មិនជាធ្ងន់ខ្លាំង ដរាបដល់ព្រះធរណីស្រូបឡើយ ។

ក្នុងរឿង ខន្តិវាទិតាបសខាងលើនេះ ដែលថាស្តេចកលាបុបញ្ជាឱ្យរាជបុរស វាយតាបសចំនួនពីរពាន់រំពាត់ ហើយឱ្យកាត់ដៃកាត់ជើង កាត់ត្រចៀកច្រមុះរួច ស្តេចលើកជើងធាក់ចំកណ្តាលទ្រូងតាបស ហើយដើរចេញទៅ ត្រូវព្រះធរណីស្រូប ឱ្យទៅកើតក្នុងនរកនាពេលនោះភ្លាមមួយរំពេច ។

បើតាមរឿងនេះ ហាក់ដូចជានរកនៅក្រោមដី. តាមការពិតនរកមិនមែននៅក្នុងដី ឬក្រោមដីទេ គឺនរកនៅឯឋាននរក ជាលោកមួយផ្សេង ដែលក្នុងទ្រឹស្តីពុទ្ធសាសនាហៅថា យមលោក (បើចង់ជ្រាបច្បាស់រឿងឋាននរកនេះ សូមអានសៀវភៅ "ជំនឿចាស់មនុស្សថ្មី" របស់អ្នកនិពន្ធ សុង-ស៊ីវ ខ្ញុំ). ត្រង់ដែលថា ស្តេចកលាបុ ព្រះធរណីស្រូបឱ្យកើតក្នុងឋាននរកនោះ គឺឋាននរកនៅទីណា អកុសលកម្មនាំខ្លួនស្តេចកលាបុទាំងស្រស់ទៅដល់ទីនោះភ្លាមមួយរំពេច តាមជើងគម្ពីរប្រាប់ថា មិនមែនព្រះធរណីស្រូប ហើយស្លាប់កប់សាកសពនៅក្នុងដី ត្រង់ទីនោះទើបវិញ្ញាណទៅកើតក្នុងឋាននរកនោះឡើយ, គឺទៅសោយទុក្ខក្នុងនរកទាំងរស់តែម្តង ។

(ចប់ការវែកញែករឿងខន្តិវាទិតាបស)

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ៤ រឿងទី ៨ គឺរឿងគឺ រឿងសញ្ជីវមាណព ដកពីគម្ពីរឯកនិបាត មានសេចក្តីដំណាលថា :

កាលកន្លងកន្លងទៅហើយ មានមាណពម្នាក់ឈ្មោះ

សញ្ជីវៈ បានសិក្សាមន្តវិជ្ជាជាមួយនឹងសិស្ស ៥០០ រូប ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ នាក្រុងពារាណសី ។ សញ្ជីវមាណព បានសុំលោកអាចារ្យរៀន មន្តប្រស់សត្វស្លាប់ឱ្យរស់មកវិញ ។ លុះមន្តវិជ្ជាសាស្ត្រ បានសម្រេចហើយ ថ្ងៃមួយមាណពនោះ បានចូលទៅរកអុស ក្នុងមហាវ៉នជាមួយនឹងសិស្សនានា បានប្រទះខ្លាស្លាប់មួយ ក៏ពោលប្រាប់គេថាភឿនទាំងឡាយ ចាំមើលយើងប្រស់ខ្លាស្លាប់នេះណា ! ។ សិស្សទាំងអស់គេពោលប្រាប់ថា សម្លាញ់ ចូរប្រស់សាកលមើលចុះ រួចគេរត់ឡើងដើមឈើទាំងអស់គ្នាទៅ ។ សញ្ជីវមាណព ក៏តាំងរាយមន្តប្រស់ខ្លានោះ ហើយយកម្រាមដៃផ្ទាត់ផង ។ ខ្លាក៏រស់ឡើងភ្លាម ហើយស្ទុះទៅខាំមាណពនោះស្លាប់ ទើបដួលត្រុចទៅវិញ ។ ខ្លា និងមាណព ក៏ស្លាប់ក្នុងទីជាមួយគ្នាក្នុងពេលនោះឯង ។ សិស្សទាំងអស់ បាននាំរឿងនោះមកប្រាប់អាចារ្យ ។ ក៏ពោលថា នែអ្នកទាំងឡាយជនណាដែលបានលើកដំកើង សង្គ្រោះអសប្បុរស ហើយធ្វើសក្ការៈរាប់អានក្នុងទីមិនសមគួរ ជននោះតែងតែបានទទួលទុក្ខលំបាក វិនាសខ្លួនប្រាណសាបសូន្យ ចាកជីវិតដូចជាសញ្ជីវមាណពនេះជាកំណត់ ព្រោះអសប្បុរសមើលមិន

ឃើញអ្នកសង្គ្រោះទេ ទើបពោលគាថាតទៅទៀតថា : អ្នកណាលើកដំកើង និងគប់រកអសប្បុរស. អសប្បុរសនោះតែងតែធ្វើអ្នកដំកើង ឱ្យទៅជាចំណីរបស់ខ្លួនដូចខ្លា និងមាណពឈ្មោះសញ្ជីវៈ ។

អត្ថបទក្នុងរឿងនេះ មានចំណុចមួយប្លែកពីសម័យបច្ចុប្បន្ន គួរយកមកធ្វើការវែកញែក គឺការប្រស់មនុស្សស្លាប់ ឬសត្វស្លាប់ឱ្យរស់វិញ តើជារឿងពិត ឬជារឿងប្រឌិតទេ ?

រឿងនេះបើតាមទ្រឹស្តីក្រៅពុទ្ធសាសនា មានក្បួនវេទរបស់សាសនាព្រាហ្មណ៍ជាដើម គេថាមានមន្តអាគមសម្រាប់ប្រស់មនុស្សសត្វស្លាប់ឱ្យរស់វិញបាន ។ ចំណែកទ្រឹស្តីខាងពុទ្ធសាសនា ដែលមានព្រះត្រៃបិតកជាគោលនោះ មិនមានបាលីគាថាណាមួយសម្រាប់សូត្រប្រស់មនុស្សសត្វដែលស្លាប់ ឱ្យរស់វិញឡើយ មានតែព្រះពុទ្ធដីកាសម្តែងថា មនុស្ស សត្វ ដែលស្លាប់ហើយ មិនអាចត្រឡប់ រស់ដូចដើមវិញបានឡើយ ។

បើក្នុងទ្រឹស្តីក្នុងពុទ្ធសាសនា បដិសេធការប្រស់មនុស្ស សត្វ ស្លាប់ឱ្យរស់វិញដូច្នេះ ហេតុអ្វីក៏ក្នុងគម្ពីរ

ឯកនិបាត ដែលរាប់បញ្ចូលក្នុងទ្រឹស្តីពុទ្ធសាសនាដែរនោះ មាននិយាយពីរឿងសញ្ជីវមាណព ដែលទាក់ទងដល់ការប្រស់មនុស្ស សត្វស្លាប់ឱ្យរស់វិញដែរ ?

បានជាមានដូច្នេះព្រោះអដ្ឋកថាចារ្យ ដែលលោកយករឿងសញ្ជីវមាណព មកសរសេរក្នុងគម្ពីរឯកនិបាតនោះ, ត្រង់ការប្រស់មនុស្សសត្វស្លាប់ឱ្យរស់វិញ លោកទុកជារឿងប្រឌិត គ្រាន់តែឱ្យប្លែកក្នុងដំណើររឿងប៉ុណ្ណោះ, ឯគោលសំខាន់ក្នុងរឿងនេះ សំដៅត្រង់គាថាដែលប្រដៅ មិនឱ្យលើកដំកើង និងសេពគប់ជាមួយអសប្បុរសប៉ុណ្ណោះ ។

**(ចប់ការរើកញែករឿងសញ្ជីវមាណព)**

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ៥ រឿងទី ១២ គឺ រឿងបុរសក្លាយភេទជាស្ត្រី ដកពីគម្ពីរធម្មបទ ខុទ្ទកនិកាយ មានសេចក្តីដំណាលថា :

កាលដែលព្រះពុទ្ធបរមគ្រូ គង់នៅក្រុងសាវត្ថី មានសេដ្ឋីបុត្រ ១ រូបឈ្មោះ សោរេយ្យ ជិះរទេះបរចេញទៅក្រៅនគរជាមួយនិងសំឡាញ់ម្នាក់ ព្រមទាំងបរិវារជាច្រើន ដើម្បីទៅមុជទឹកក្នុងកំពង់មួយ ។ ជួនជាក្នុងខណៈនោះ

ព្រះមហាកច្ចាយនត្ថេរ និមន្តទៅបិណ្ឌបាតក្នុងទីក្រុង ។ សរីរៈរបស់លោក ក៏មានពន្លឺត្រចះត្រចង់គួរឱ្យជ្រះថ្លា ។ ឯសេដ្ឋីបុត្រ ឃើញព្រះមហាកច្ចាយនត្ថេរ ដែលមានសរីរៈត្រចះត្រចង់ដូច្នេះ គិតតែក្នុងចិត្តថា " ធ្វើម្ដេចហ្ន ! នឹងបានភិក្ខុអង្គនេះមកធ្វើជាភរិយា ! ឬធ្វើម្ដេចហ្ន ! ឱ្យភរិយាអញមានពណ៌សម្បុរ ដ៏ត្រចះត្រចង់ ដូចព្រះភិក្ខុអង្គនេះ " ។ សេដ្ឋីបុត្រកំពុងតែគិតដូច្នេះ មិនយូរប៉ុន្មាន ស្រាប់តែក្លាយភេទ ក្លាយខ្លួនទៅជាស្ត្រីមួយរំពេច. សេចក្ដីអៀនខ្មាស ក៏កើតមានឡើង ទើបចុះពីរទេះភៀសខ្លួនបាត់ក្នុងពេលនោះទៅ ។ ឯស្ត្រីក្លាយភេទនោះ ដើរតម្រង់តាមផ្លូវទៅកាន់នគរតក្កសិលា បានជួបនឹងពួកឈ្មួញរទេះយ៉ាងច្រើន នាងដើរតាមពីក្រោយរទេះ គ្រាតែដល់នគរតក្កសិលា ។ ពួកឈ្មួញទាំងអស់គិតគ្នាថា កូនប្រុសរបស់សេដ្ឋីក្នុងនគរយើងនេះ មិនទាន់មានប្រពន្ធនៅឡើយ យើងនាំដំណឹងនេះទៅប្រាប់សេដ្ឋី ១ មុខជាឱ្យរង្វាន់ខ្លះដល់យើងពុំខាន ទើបនាំគ្នាទៅជម្រាបសេដ្ឋី ១ គ្រាន់តែឃើញនាងភ្លាម កើតចិត្តប្រតិពទ្ធស្នេហា ក៏នាំទៅរៀប ផ្សំផ្គុំឱ្យជាភរិយានៃកូនប្រុសរបស់ខ្លួន ។

ថ្ងៃមួយសម្លាញ់របស់នាង បានធ្វើដំណើរចេញពីក្រុងសាវត្ថី ដើម្បីទៅជួញឯនគរតក្កសិលា នាងកំពុងតែអង្គុយលើប្រាសាទ បានឃើញហើយស្គាល់ច្បាស់ ក៏ប្រើទាសីឱ្យទៅហៅឱ្យចូលទៅក្នុងប្រាសាទ រៀបចំទទួលដោយគ្រឿងបដិសណ្ឋារៈដ៏សមគួរ ព្រមទាំងនិយាយរ៉ាយរ៉ាប់សព្វគ្រប់ពីរឿងខ្លួន ចាប់តាំងពីជិះរទេះទៅមុជទឹកជាមួយសម្លាញ់. ឃើញព្រះមហាកច្ចាយនត្ថេរ និងគំនិតដែលខ្លួនបានគិតទៅលើព្រះថេរៈអង្គនេះ ហើយក្លាយភេទជាស្ត្រីក្នុងពេលនោះភ្លាម រហូតដល់កៀសខ្លួនមកបានប្ដីមានកូនពីរនេះទៀត ។ ឯសម្លាញ់នោះ បានជ្រាបហេតុសព្វគ្រប់ ក៏រ៉ាយរ៉ាប់ថា ត្រូវសូមខមាលទោសនឹងព្រះថេរៈអង្គនេះ ។ ឯនាងដែលក្លាយភេទនោះ បានធ្វើតាមពាក្យរបស់សម្លាញ់លុះដល់ព្រះមហាកច្ចាយនត្ថេរនិមន្តទៅបិណ្ឌបាត នាងក៏បានដាក់បាត្រដល់ព្រះថេរៈ ហើយសូមខមាទោសសព្វគ្រប់ប្រការ ភេទស្ត្រីក៏ក្លាយជាប្រុសក្នុងពេលនោះភ្លាម ហើយសូមបួសក្នុងសំណាក់ព្រះថេរៈអង្គនោះ ខំចម្រើនឈាន និងអភិញ្ញារហូតដល់បានសម្រេចព្រះអរហត្ត ជាអវសានជាតិក្នុងកាលនោះហោង ។

អត្ថបទក្នុងរឿងនេះ មានចំណុចមួយដែលប្លែកគឺ រឿងបុរសក្លាយភេទជាស្ត្រី តើជារឿងពិត ឬជារឿងប្រឌិត?

ខាងទ្រឹស្តីពុទ្ធសាសនា ថាជារឿងពិត ធ្លាប់កើតមានជាក់ស្តែងក្នុងសម័យពុទ្ធកាល ។ អ្នកកាន់ពុទ្ធសាសនាទាំងឡាយ ដែលធ្លាប់បានសិក្សាធម៌វិន័យ យល់នូវកម្ម ផលច្បាស់លាស់នោះ ឥតមានសង្ស័យចំពោះរឿងភេទនេះឡើយ ព្រោះធ្លាប់បានស្គាល់ប្រវត្តិរឿងរ៉ាវ របស់ព្រះមហាកច្ចាយនត្ថេរ និងសោរេយ្យភិក្ខុ ដែលជាព្រះអរហន្តមានកិត្តិនាមក្នុងពុទ្ធសាសនា ។

ហេតុដែលបណ្តាលឱ្យក្លាយភេទ មកពីអកុសលចិត្ត ដែលប្រកបដោយរាគៈ តម្រេកក្នុងកាម ចំពោះទៅលើតួអង្គព្រះអរហន្ត ដែលមានគុណវិសេសខ្ពង់ខ្ពស់ក្រៃលែងជាងខ្លួន ។ គ្រប់តែអំពើទាំងអស់ ទោះជាកុសលក្តី អកុសលក្តី ដែលបុគ្គលជាបុថុជ្ជន បានធ្វើចំពោះព្រះអរហន្តទាំងឡាយ ជាកម្មធ្ងន់ណាស់ អាចឱ្យផលក្នុងបច្ចុប្បន្នជាក់ស្តែង ព្រោះទង្វើនេះឯង បណ្តាលឱ្យសេដ្ឋីបុត្រ ឈ្មោះសោរេយ្យ ដែលមានរាគៈ តម្រេកចំពោះព្រះអរហន្តនោះ ក្លាយខ្លួនជាស្ត្រីភេទបានមួយរំពេច ។

ចំពោះរឿងក្លាយភេទនេះ តាមទ្រឹស្តីពុទ្ធសាសនាថា មនុស្សទាំងអស់ក្នុងពិភពលោក តាំងពីជាតិទី ១ រហូតដល់ជាតិទីបំផុត ពុំដែលមានអ្នកណាកើតជាបុរស ហើយនៅជាបុរសរហូត និងកើតជាស្ត្រី ហើយនៅជាស្ត្រីរហូតនោះឡើយ គឺតែងតែផ្លាស់ប្តូរភេទជានិច្ច ទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត ដូចជាការផិតក្បត់ចំពោះស្វាមី ភរិយាអ្នកដទៃ អំពើនេះឯងជាហេតុនាំឱ្យបុរស ក្លាយភេទជាស្ត្រីបានដោយងាយ មុននឹងក្លាយភេទជាស្ត្រី ត្រូវរងទុក្ខវេទនាក្នុងនរក. កើតជាមនុស្សខ្ទើយ និងត្រូវគេក្រៀវជាច្រើនជាតិ ចំណែកស្ត្រីវិញ បើចង់ក្លាយភេទជាបុរស មានការពិបាកជាងបុរសក្លាយភេទជាស្រី ទាល់តែស្ត្រីនោះ ខំធ្វើអំពើល្អយ៉ាងច្រើនហើយគោរពប្រតិបត្តិស្វាមីដោយហ្មត់ចត់ផង ទើបក្លាយភេទជាបុរសបាន ។ ឯស្ត្រីដែលត្រូវទោស កាមេ ត្រូវសោយទុក្ខក្នុងនរក ត្រូវខ្ទើយ ត្រូវគេក្រៀវ និងត្រូវនៅព្រៅឥតប្តីមួយជីវិត បើសិនជាមានប្តី ត្រូវប្តីលែងលះចោលជាច្រើនជាតិ ។

ផ្នែកខាងទ្រឹស្តីវិទ្យាសាស្ត្រនាបច្ចុប្បន្ននេះ គេកំពុងតែចាប់អារម្មណ៍ ចំពោះការក្លាយភេទនេះដែរ. ពួកអ្នកប្រាជ្ញ

វិទ្យាសាស្ត្រ ជាអ្នកឯកទេសខាងភេទ មានលោក អេទីយេន វ៉ុលហ្វ. វីសារវ៉េស្កុលមិដទ៍ និងលោកម៉ូរីសហ្គោឡីវ៉ា បាន ពិនិត្យចំពោះការក្លាយភេទ របស់លោក រ៉ូប៉ែរក្លូវ៉ែល្វ ជាតិ អង់គ្លេស អាយុ ៣៦ ឆ្នាំ ជាអនុសេនីយទោ នៃកងអាកាស ចរណ៍ចក្រភពអង់គ្លេស ។ លោកនេះបានក្លាយភេទពីឆ្នាំ ១៩៤៨ បន្តិចម្តង ៗ ដរាបដល់ក្លាយជាស្រីពិតប្រាកដ. កាល នៅជាបុរស លោកមានប្រពន្ធ មានកូនពីរនាក់ ។ រឿង ក្លាយភេទរបស់លោក រ៉ូប៉ែរវ៉ែល្វនេះ ខ្លួនលោកបានសរសេរ ជាសៀវភៅ រៀបរាប់អំពីការក្លាយភេទ និងផ្សាយរូបថត របស់លោក កាលនៅជាបុរស និងរូបដែលក្លាយជាស្ត្រី ហើយនោះផង ។

ដូច្នេះឃើញថា ការក្លាយភេទនោះ សម័យបច្ចុប្បន្ន នេះក៏មានដូចក្នុងសម័យពុទ្ធកាលដែរ ។

(ចប់ការរើកញែករឿងបុរសក្លាយភេទជាស្ត្រី)

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ៦ រឿងទី ១៤ គឺ រឿងប្រេតញីឈ្មោះ ឧត្តរមាតា ដកពីគម្ពីរបេតវត្ថុ ខុទ្ទក- និកាយដ្ឋកថា មានសេចក្តីដំណាលថា :

សម័យមួយព្រះកង្ខារេវតត្ថេរ កំពុងសម្រាកក្នុងវេលាថ្ងៃ ក្បែរឆ្នេរទន្លេគង្គា ពេលនោះមានប្រេតញីមួយសម្បុរអាក្រក់ ឃើញគួរខ្លាច មានសក់វែងដល់ដី អាក្រាតខ្លួនទទេ បានយកសក់ខ្លួនបិទបាំងកាយ ដើរចូលទៅរកព្រះថេរៈ ហើយនិយាយត្អូញត្អែរថា បពិត្រលោកម្ចាស់ ចាប់តាំងពីខ្ញុំធ្វើមរណកាលមកចំនួន ៥៥ ឆ្នាំហើយ មិនដែលបានបរិភោគអាហារ ផឹកនូវទឹកសោះឡើយ ខ្ញុំស្រេកទឹកណាស់ សូមលោកម្ចាស់ឱ្យទឹកដល់ខ្ញុំ ។

ព្រះកង្ខារេវតត្ថេរតបថា ទន្លេគង្គានេះមានទឹកត្រជាក់ ហូរពីភ្នំហេមពាន្តមក ចូរនាងផឹកនូវទឹកក្នុងទន្លេនេះទៅ ហេតុអ្វីមកសុំទឹកពីអាត្មាវិញ ។ ប្រេតឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំដងទឹកទន្លេនេះហើយ តែផឹកមិនកើត ព្រោះទឹកនោះក្លាយជាឈាម ក្នុងពេលដែលខ្ញុំដងឡើង ។ អាស្រ័យហេតុនេះ សូមលោកម្ចាស់ឱ្យទឹកខ្ញុំផឹកផង ។

ព្រះថេរៈសួរថា នាងបានធ្វើកម្មអាក្រក់ដូចម្តេចដោយកាយវាចាចិត្តពីមុន ទើបពេលនេះមានវិបាកដូច្នេះ ?

ប្រេតឆ្លើយថា កាលពីបុព្វជាតិ ខ្ញុំមានកូនប្រុសម្នាក់ឈ្មោះឧត្តរៈ ជាឧបាសក អ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធ

សាសនា. ខ្ញុំជាមនុស្សកំណាញ់ មិនចង់ឱ្យខាតបង់ទ្រព្យ ។ កូនខ្ញុំបានឱ្យនូវចីវរ បិណ្ឌបាត គិលានភេសជ្ជៈ និងសេនា-សនៈចំពោះសមណៈទាំងឡាយ ។ ពេលនោះ សេចក្ដីកំណាញ់រួបរឹតចិត្តខ្ញុំ បណ្ដាលឱ្យមានសេចក្ដីក្រោធញាប់ញ័រជេរប្រទេច ដាក់បណ្ដាសាកូនថា ម្នាលឧត្តរៈ ចីវរប្បច្ច័យជាដើមនោះ ចូរកើតទៅជាឈាមដល់ឯងក្នុងបរលោកចុះ. ព្រោះផលនៃកម្មនេះ ទើបទឹកទន្លេគង្គារនេះ ក្លាយកើតជាឈាមដល់ខ្ញុំ ។

ព្រះថេរៈមានសេចក្ដីអនុគ្រោះ បានជួយប្រេតនោះឱ្យរួចរំដោះចាកបាបកម្មរបស់ខ្លួន ។

អត្ថបទក្នុងរឿងនេះ មានបីចំណុចដែលគួរលើកមកវែកញែក គឺ :

១. ប្រេតមានមែនឬទេ ? ឬក៏ជារឿងប្រឌិត ?

២. ក្នុងរឿងខាងលើនេះថា ប្រេតអត់បាយ អត់ទឹកចំនួន ៥៥ ឆ្នាំ តើរស់ម្ដេចកើត ?

៣. ហេតុអ្វីក៏ប្រេតនោះមានទឹកហើយផឹកមិនកើត?

ចំណុចទី ១ ក្នុងទ្រឹស្ដីពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ថា ប្រេតពិតជាមានមែន ជាអបាយិកសត្វ រស់នៅ

ក្នុងអបាយភូមិទាំង ៤ គឺ នរក-ប្រេត-តិរច្ឆាន និងអសុរកាយ ។ សត្វទាំង ៤ ពួកនេះ លើកតែសត្វនរកចេញ សុទ្ធតែរស់នៅជាមួយនឹងមនុស្សនេះឯង ។ ចំណែកប្រេត និងអសុរកាយ ជាអទិស្សមានកាយ មានរូបមិនប្រាកដ ជួនបាត់ ជួនឃើញ ដែលយើងធ្លាប់ហៅថា ខ្មោច ព្រាយ អារក្ស អ្នកតានោះឯង ។ ប្រេត និងអសុរកាយនេះ ខ្លះសោយទុក្ខវេទនារហូត ខ្លះក៏មានសោយសេចក្ដីសុខដោយកាល ដោយពេលដែរ ដូចវេមានិកប្រេតជាដើម ។

ចំណុចទី ២ ចំពោះប្រេតញីឈ្មោះឧត្តរៈមាតា ដែលថាតាំងពីធ្វើមរណកាលទៅកើតជាប្រេតចំនួន ៥៥ ឆ្នាំហើយ មិនដែលបានបរិភោគអាហារ មិនបានផឹកទឹកមួយដំណក់សោះ ហើយចេះតែមានជីវិតរស់នៅនោះ គឺរស់នៅដោយអំណាចអកុសលកម្មរបស់ខ្លួន ដែលបានធ្វើពីជាតិមុន ព្រោះកម្លាំងទាំងអស់ក្នុងលោក មិនមានកម្លាំងអ្វីឱ្យស្មើនិងកម្លាំងកម្មឡើយ មានតែកម្លាំងកម្មនេះឯង ដែលរចនាជីវិតមនុស្សសត្វក្នុងលោក ឱ្យមានសភាពប្លែក ៗ គ្នា និងអស្ចារ្យហួសបញ្ញាមនុស្សបុថុជ្ជន គិតមិនបាន ប្រមាណមិនត្រូវ ។

ចំណុចទី ៣ ដែលថាប្រេតឈ្មោះឧត្តរៈមាតា បាន

ជួបនឹងទឹកហើយ ជីកមិនកើត ឃើញទឹកនោះសុទ្ធតែឈាមទៅវិញ ត្រង់នេះក៏មកពីកម្លាំងកម្មរបស់ខ្លួនដែរ ដែលពាក្យខ្មែរយើងថាត្រូវបណ្តាសា ព្រោះកាលខ្លួនកើតជាមាតារបស់ឧបាសកឧត្តរៈ អ្នកមានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា ដែលបានប្រគេនបច្ច័យ ៤ ចំពោះសមណៈ ខ្លួនមានសេចក្តីក្រោធហើយដាក់បណ្តាសាឱ្យកូនថា បច្ច័យ ៤ មានចីវរជាដើមនេះ ចូរកើតជាឈាមដល់ឯងក្នុងបរលោកចុះ ។ បណ្តាសានេះមិនត្រូវដល់កូន ដែលជាជនសប្បុរស ត្រឡប់ជាធ្លាក់មកត្រូវខ្លួនឯងវិញ ។

(ចប់ការរើកញែករឿងប្រេតញីឈ្មោះឧត្តរមាតា)

ក្នុងសៀវភៅប្រជុំនិទានជាតកភាគ ៧ រឿងទី ២ គឺរឿងកណ្ឌកទេវបុត្រ ដកពីគម្ពីរ វិមានវត្ថុខុទ្ទកនិកាយ មានសេចក្តីដំណាលថា :

សម័យមួយ ព្រះមោគ្គល្លានត្ថេរ បាននិមន្តទៅឋានត្រៃត្រិង្សទេវលោក, បានឃើញវិមានទិព្វ មានពន្លឺដូចព្រះអាទិត្យទើបនឹងរះ ជាវិមានវិចិត្រដោយកែវ ៧ ប្រការលោកឈប់នៅមុខវិមាននោះ, កណ្ឌកទេវបុត្រជាម្ចាស់

វិមាន បានមកថ្វាយបង្គំគួរសមរាក់ទាក់ និមន្តគង់លើ អាសនៈទិពរបស់ខ្លួន ។

ព្រះមោគ្គល្លានសួរទេវបុត្រនោះថា ម្នាលទេវបុត្រ ! វិមានទិព្វដ៏រុងរឿងដោយរស្មី មានជាន់វិចិត្រដោយកែវពិទូរ្យ និងមាសផង ដោយកែវផលិក និងប្រាក់ផង ដោយកែវពព្រុះ និងកែវមុក្តាផង ដោយកែវទទឹម និងកែវមណីផង ក្រាលហើយដោយកែវពិទូរ្យ មានកំពូលទាំងឡាយ គួរជាទីរីករាយ ប្រាសាទរបស់អ្នកនេះ បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ទាំងស្រះបោក្ខរណីរបស់អ្នក ក៏ជាទីរីករាយដេរដាសដោយមច្ឆាជាតិ មានទឹកថ្លាល្អ ក្រាលដោយខ្សាច់មាស មានឈូកផ្សេងៗ ឆ្នូកឆ្មាសដោយឈូកស មានក្លិនក្រអូបជាទីចាប់ចិត្ត គម្ពផ្កាទាំងឡាយក្បែរខាងទាំងពីរ នៃស្រះបោក្ខរណីរបស់អ្នក ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ មានឈើផ្កា និងឈើផ្លែ ដុះលូតលាស់យ៉ាងល្អត្រកាល. មានពួកស្រីអប្សរស្អិតស្អាងដោយគ្រឿងអលង្ការ និងកម្រងផ្កាផ្សេងៗ ចាំបម្រើអ្នក ដែលអង្គុយលើបល្ល័ង្កមាស. អ្នកតែងរីករាយដោយវត្ថុទិព្វទាំង ១០ ប្រការ តើអ្នកបានធ្វើបុណ្យអ្វីក្នុងជាតិមុន ? ចូរអ្នកប្រាប់នូវបុញ្ញកម្មនោះដល់អាត្មា ?

កណ្ឋទេវបុត្រ មានចិត្តរីករាយ ឆ្លើយតបព្រះមោគ្គល្លានថា : "បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា មិនបានធ្វើសីលទានអ្វីទេ. កាលនោះខ្ញុំជាសេះឈ្មោះកណ្ឋកៈ កើតក្នុងថ្ងៃដំណាលនឹងព្រះសិទ្ធត្ថរាជកុមារ ជាព្រះរាជបុត្រព្រះបាទសុទ្ធោទនៈក្នុងក្រុងកបិលព័ស្តុ ។

កាលព្រះរាជបុត្រនោះ ទ្រង់ចេញទៅបព្វជ្ជា ដើម្បីពោធិញ្ញាណនាពាក់កណ្តាលរាត្រី ទ្រង់ទះខ្ញុំត្រង់ភ្លៅ ដោយព្រះហស្តដ៏ទន់ មានព្រះនខាក្រហមរុងរឿង ហើយទ្រង់ត្រាស់ចំពោះខ្ញុំថា នែសម្លាញ់ ចូរអ្នកនាំយើងទៅបព្វជ្ជា បើយើងបានទូវពោធិញ្ញាណដ៏ឧត្តមហើយ នឹងចម្លងសត្វលោកចាកសង្សារវដ្ត ។ កាលដែលខ្ញុំបានឮព្រះតម្រាសដូច្នេះ ខ្ញុំមានចិត្តរីករាយ មានកម្លាំងកាយខ្លាំងក្លាក្រៃលែង ខ្ញុំទទួលយល់ព្រមភ្លាម ដើម្បីដង្ហែព្រះអង្គទៅបព្វជ្ជា. លុះព្រះរាជបុត្រឡើងគង់លើខ្នងខ្ញុំហើយ ខ្ញុំមានចិត្តរីករាយថែមទៀតដង្ហែព្រះអង្គចេញទៅយ៉ាងឆាប់រហ័ស បានដល់ទីដៅតាមព្រះរាជបំណង ។

កាលព្រះអាទិត្យរះឡើង ព្រះអង្គក៏លះបង់ចោលខ្ញុំនិងអាមាត្យ ខ្ញុំឱនលិទ្ធព្រះបាទា ដែលមានព្រះនខាក្រហម

រលោងហើយយំ. ព្រះអង្គស្តេចយាងចេញទៅ ខ្ញុំខំសម្លឹងមើលដោយក្តីអាល័យ ផរាបដល់បែកហឫទ័យស្លាប់ ក៏ស្រាប់តែមកកើតក្នុងឋានត្រៃត្រឹង្ស ស្ថិតនៅក្នុងគំនរសម្បត្តិទិព្វនេះឯង ដោយអានុភាពនៃសេចក្តីជ្រះថ្លា ស្មោះចំពោះការយាងចេញបព្វជ្ជាផង ដោយសេចក្តីរីករាយ ព្រោះបានស្តាប់ព្រះតម្រាស់ថា ព្រះអង្គយាងចេញទៅស្វែងរកពោធិញ្ញាណ ខ្ញុំមុខជាបានដឹងស្គាល់ នូវពោធិញ្ញាណនោះមិនខាន ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់និមន្តទៅសម្នាក់ នៃព្រះពុទ្ធជាសាស្តា សូមលោកម្ចាស់ក្រាបបង្គំទូលនូវកិរិយាថ្វាយបង្គំព្រះបាទា ដោយសិរ្សៈរបស់ខ្ញុំចំពោះព្រះអង្គផង ។ ចំណែកខ្ញុំគង់នឹងទៅជួបព្រះអង្គក្នុងថ្ងៃណាមួយមិនខាន ព្រោះការបានឃើញនូវព្រះសម្ពុទ្ធ ជាលោកនាថ រកបានដោយកម្រណាស់ ។

ឯកណ្ឌកទេវបុត្រនោះ ជាអ្នកមានកតញ្ញូកតវេទិតា. ថ្ងៃមួយបានចូលទៅគាល់ព្រះសាស្តា ស្ថិតនៅក្នុងទីគួរហើយ. ព្រះសម្ពុទ្ធបានប្រាស្រ័យដោយធម្មកថាគួរជាទីរីករាយ. លុះបានស្តាប់ធម្មកថានោះហើយ ក៏បានសម្រេចនូវ

សោតាបត្តិមគ្គ ជម្រះនូវទិដ្ឋិ វិចិកិច្ឆា និងសីលពិត ថ្វាយបង្គំបាទាព្រះសាស្តាហើយ ក៏ចាកទីនោះបាត់ទៅ ។

អត្ថបទក្នុងរឿងនេះ បញ្ជាក់ឱ្យដឹងច្បាស់ថា ក្នុងសម័យពុទ្ធកាល មនុស្សលោកអាចទៅស្ថានសួគ៌បាន, ប៉ុន្តែមិនមែនមនុស្សធម្មតាចេះតែទៅបានដោយមានយានសំរាប់ជិះទៅដូចពួកអ្នកអវកាស ជិះអាប៉ូឡូទៅស្ថានព្រះចន្ទ ដែលឥតមនុស្សនៅ មានតែដីទទេនោះឡើយ គឺទៅបានតែពួកអរហន្ត ដែលមានឫទ្ធិដូចព្រះមោគ្គល្លានជាដើម ។

បើពិនិត្យតាមការសន្ទនារវាងព្រះមោគ្គល្លាន និងកណ្ឌកទេវបុត្រ ឃើញថាក្នុងស្ថានសួគ៌នោះ មានទេសភាពដូចស្ថានមនុស្សដែរ គឺមានវិមានប្រាសាទ មានស្រះទឹក មានត្រី មានដើមឈើផ្កា និងឈើផ្លែជាដើម ។

ឯទីកន្លែង ឬទីបរបស់ស្ថានសួគ៌នោះ ក្នុងទ្រឹស្តីពុទ្ធសាសនាមិនឃើញមានប្រាប់ថានៅត្រង់ទីណាឡើយ គ្រាន់តែថា ស្ថានសួគ៌ និងព្រះអាទិត្យ ព្រះចន្ទ ជាទ្វីប ជាពិភពដទៃអំពីពិភពមនុស្ស ឬថាជាលោកដទៃអំពីមនុស្សលោក ។ បានសេចក្តីថា ស្ថានសួគ៌មិនមែននៅក្នុងឋានមនុស្សនេះឡើយ គឺជាលោក ជាពិភពមួយផ្សេងដូចព្រះអាទិត្យ ព្រះចន្ទ

និងផ្កាយទាំងឡាយដែរ គឺផ្កាយមួយ ជាភពមួយ ។ ក្នុងលំហអាកាស និងអវកាស ឬថាលើមេឃដែលយើងមើលក្នុងវេលាយប់ ឃើញផ្កាយព្រោងព្រាតរាប់អសង្ខេយ្យនោះ យើងដឹងបានថា ក្នុងលំហអាកាស និងអវកាសនេះ មានពិភពរាប់អសង្ខេយ្យដែរ ប៉ុន្តែយើងមិនអាចដឹងច្បាស់បានថា ស្ថានសួគ៌ឈ្មោះត្រៃត្រឹង្ស ឈ្មោះយាមា ឈ្មោះតុសិតនោះជាផ្កាយណាមួយឡើយ សូម្បីតែអ្នកប្រាជ្ញវិទ្យាសាស្ត្រ ដែលកំពុងចម្រើនខាងតារាវិទ្យា ស្ទើរដល់កំពូលទៅហើយនោះ ក៏មិនអាចស្គាល់ផ្កាយឱ្យបានមួយរយឈ្មោះដែរ គឺស្គាល់តែផ្កាយព្រះសុក្រ ព្រះអង្គារ និងព្រះអាទិត្យ ព្រះចន្ទ ជាដើមប៉ុណ្ណោះ ។

ចំពោះមតិខ្លះដែលយល់ថា ឋានសួគ៌គ្មានទេ គឺភូមិស្រុក ឬប្រទេសណាដែលសម្បូរសប្បាយ ភូមិស្រុក ឬប្រទេសនោះឯងឈ្មោះថាឋានសួគ៌ នោះគ្រាន់តែជាឋានសួគ៌ដោយសន្មត់ប៉ុណ្ណោះ មិនមែនជាឋានសួគ៌មែនទែនឡើយ ។ ព្រោះឋានសួគ៌ពិតប្រាកដមែនទែននោះ ជាពិភពរបស់ជីវិត ដែលបានធ្វើការងារល្អ មានចិត្តគំនិតស្អាតស្អំរួចហើយ ទើបទៅរស់នៅទីនោះបាន ដែលធ្លាប់ហៅថាពួក

ទេព្តា ។ ពួកទេព្តានេះ កាលបើស្លាប់ហើយ គ្មានសាកសព ឡើយ គឺបាត់រូបកាយតែម្តង ព្រោះជាពួកអមនុស្ស កើត ឡើង និងរស់នៅដោយផលនៃអំពើល្អស្អាតស្អំ ដែលធ្លាប់ ហៅថា ផលបុណ្យ មិនមែនកើតពីផ្ទៃមាតា រស់នៅដោយ អាហារបាយទឹកនំចំណីឡើយ ។ ឯពួកមនុស្ស និងសត្វតិរច្ឆានដែលស្លាប់ទៅ មានសល់សាកសពស្អុយគគ្រុកនោះ ព្រោះមនុស្សសត្វកើតពីផ្ទៃមាតា មានបាយទឹកនំចំណីជា អាហារ ។

ក្នុងផ្ទៃរឿងជដែលនេះ ព្រះមោគ្គល្លាន បានសរសើរ ពីសម្បត្តិទិព្វរបស់កណ្ឌកទេវបុត្រថា មានស្រះ មានមច្ឆា ជាតិ គឺមានត្រីជាដើម ដែលជាសត្វតិរច្ឆាន នៅក្នុងឋានសួគ៌ នោះផងដែរ ។

បើឋានសួគ៌មានសត្វតិរច្ឆានរស់នៅជាមួយទេព្តាដែរ គឺក្នុងស្ថានសួគ៌ ក៏មានពួកអបាយិកសត្វដែរ ឬថាក្នុងឋាន សួគ៌មានអបាយភូមិដែរ ។

ពួគអបាយិកសត្វ មាននៅតែក្នុងឋានមនុស្ស និង ឋាននរកប៉ុណ្ណោះ ក្នុងឋានសួគ៌គ្មានសត្វតិរច្ឆានឡើយ ។ ពួកមច្ឆាជាតិ ដែលមាននៅក្នុងស្រះរបស់កណ្ឌកទេវបុត្រ

នោះ គឺជាបុញ្ញកម្មនិម្មិត កើតឡើងដោយផលបុណ្យ ជាគ្រឿងលម្អក្នុងស្រះ មិនមែនជាត្រីកើតពីមេត្រីស៊ីចំណីអាហារ ដូចត្រីនៅក្នុងមនុស្សលោកផ្លាបយ៉ាងនេះឡើយ ។ ត្រី, ស្រះ, វិមានប្រាសាទ, ដើមឈើជាដើមនោះ, កាលបើទេវបុត្រជាម្ចាស់នោះស្លាប់ហើយ របស់ទាំងអស់នោះក៏បាត់អស់ទៅដែរ ។

ចំណែកពួកស្រីទេពអប្សរ ជាបរិវាររបស់ទេវតាមួយ ១ ដែលល្បីថាមានពីប្រាំរយនាក់ឡើងទៅដល់រាប់ម៉ឺនតាមឋានៈទេវតាមួយ ១ នោះ, មតិខ្លះឆ្ងល់ថា តើអ្នកធ្វើបុណ្យបែបណា បានជាទៅកើតជាទេវតាខ្ញុំគេ, ពួកទេវតាខ្ញុំគេនេះក៏ច្រើនម្ល៉េះ ច្រើនតែស្រី ៗ ផង គឺទេវបុត្រមួយអង្គ ១ មានទេពអប្សរចោមរោមបម្រើរាប់រយពាន់នាក់, តើមកពីហេតុអ្វី ?

ពួកទេវតាជាបរិវាររាប់រយពាន់នាក់នោះ ច្រើនតែជាបុញ្ញកម្មនិម្មិតឱ្យកើតឡើង ដើម្បីជាកិត្តិយសចំពោះទេវតានោះ ៗ មិនមែនអ្នកធ្វើបុណ្យទានហើយ ទៅកើតជាទេវតាខ្ញុំគេសម្រាប់បម្រើគេនោះឡើយ ។ មានខ្លះដែរ ចំពោះអ្នកដែលធ្វើបុណ្យទាន ហើយប្រាថ្នាឱ្យបានជាបរិវារអ្នកណា

មួយ ដែលខ្លួនធ្លាប់ស្រឡាញ់គោរពបម្រើ, បើសេចក្តីប្រាថ្នានោះសមហេតុផល ក៏បានសម្រេចខ្លះទៅដែរ។

ចំពោះទេពអប្សរបរិវារ៉ាប់រយពាន់ ដែលកើតឡើងដោយបុញ្ញកម្មនិម្មិតនោះ បើទេព្តាដែលជាម្ចាស់នោះស្លាប់ទៅ ទេពអប្សរទាំងអស់នោះ ក៏បាត់អស់ទៅដែរ ។ នេះជាជីវភាពពិសេសក្នុងឋានសួគ៌, សន្មតថាចប់ត្រឹមនេះ ។

(សង្ខេបចបរិភោគបទ)

ᨀᨁᨂ